# ជាតក

CS sut.kn.jat.001 | ភាគទី ៥៨

## សង្ខេប

ចាតក គឺជាបណ្តុំនៃ ៥៤៧ រឿងដោយពុទ្ធសាសនា អំពីការចាប់បដិសន្ធិរបស់ព្រះពុទ្ធពីមុន ទាំងទម្រង់ជាមនុស្ស និងសត្វ។

sut kn jat បាលី cs-km: sut.kn.jat អដ្ឋកថា: sut.kn.jat_att PTS: ?

# ជាតក

## «រឿងនៃជាតិពីអតីតកាល»

បកប្រែពីភាសាបាលីដោយ
ព្រះសង្ឃនៅប្រទេសកម្ពុជា ប្រតិចារិកពី sangham.net [http://forum.sangham.net/index.php/topic,2446.0]
ជាសេចក្តីព្រាងច្បាប់ការបោះពុម្ពផ្សាយ

សង្ឃទាន ២០២២

ការបកប្រែជំនួស: មិនទាន់មាននៅឡើយទេ

អានដោយ (គ្មានការថតសំលេង៖ ចង់ចែករំលែកមួយទេ?)

0:00 / 0:00

ជាតក នៅលើទំព័រមួយ។

ជាតក នៅក្នុងឯកសារ pdf មួយ។ (sut.kn.jat.pdf)

- នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស -

ជាតក ទី ១ | ២ | ៣ | ៤ | ៥ | ៦ | ៧ | ៨ | ៩ | ១០ | ១១ | ១២ | ១៣ | ១៤ | ១៥ | ១៦ | ១៧ | ១៨ | ១៩ | ២០ | ២១ | ២២ | ២៣ | ២៤ | ២៥ | ២៦ | ២៧ | ២៨ | ២៩ | ៣០ | ៣១ | ៣២ | ៣៣ | ៣៤ | ៣៥ | ៣៦ | ៣៧ | ៣៨ | ៣៩ | ៤០ | ៤១ | ៤២ | ៤៣ | ៤៤ | ៤៥ | ៤៦ | ៤៧ | ៤៨ | ៤៩ | ៥០ | ៥១ | ៥២ | ៥៣ | ៥៤ | ៥៥ | ៥៦ | ៥៧ | ៥៨ | ៥៩ | ៦០ | ៦១ | ៦២ | ៦៣ | ៦៤ | ៦៥ | ៦៦ | ៦៧ | ៦៨ | ៦៩ | ៧០ | ៧១ | ៧២ | ៧៣ | ៧៤ | ៧៥ | ៧៦ | ៧៧ | ៧៨ | ៧៩ | ៨០ | ៨១ | ៨២ | ៨៣ | ៨៤ | ៨៥ | ៨៦ | ៨៧ | ៨៨ | ៨៩ | ៩០ | ៩១ | ៩២ | ៩៣ | ៩៤ | ៩៥ | ៩៦ | ៩៧ | ៩៨ | ៩៩ | ១០០ | ១០១ | ១០២ | ១០៣ | ១០៤ | ១០៥ | ១០៦ | ១០៧ | ១០៨ | ១០៩ | ១១០ | ១១១ | ១១២ | ១១៣ | ១១៤ | ១១៥ | ១១៦ | ១១៧ | ១១៨ | ១១៩ | ១២០ | ១២១ | ១២២ | ១២៣ | ១២៤ | ១២៥ | ១២៦ | ១២៧ | ១២៨ | ១២៩ | ១៣០ | ១៣១ | ១៣២ | ១៣៣ | ១៣៤ | ១៣៥ | ១៣៦ | ១៣៧ | ១៣៨ | ១៣៩ | ១៤០ | ១៤១ | ១៤២ | ១៤៣ | ១៤៤ | ១៤៥ | ១៤៦ | ១៤៧ | ១៤៨ | ១៤៩ | ១៥០ | ១៥១ | ១៥២ | ១៥៣ | ១៥៤ | ១៥៥ | ១៥៦ | ១៥៧ | ១៥៨ | ១៥៩ | ១៦០ | ១៦១ | ១៦២ | ១៦៣ | ១៦៤ | ១៦៥ | ១៦៦ | ១៦៧ | ១៦៨ | ១៦៩ | ១៧០ | ១៧១ | ១៧២ | ១៧៣ | ១៧៤ | ១៧៥ | ១៧៦ | ១៧៧ | ១៧៨ | ១៧៩ | ១៨០ | ១៨១ | ១៨២ | ១៨៣ | ១៨៤ | ១៨៥ | ១៨៦ | ១៨៧ | ១៨៨ | ១៨៩ | ១៩០ | ១៩១ | ១៩២ | ១៩៣ | ១៩៤ | ១៩៥ | ១៩៦ | ១៩៧ | ១៩៨ | ១៩៩ | ២០០ | ២០១ | ២០២ | ២០៣ | ២០៤ | ២០៥ | ២០៦ | ២០៧ | ២០៨ | ២០៩ | ២១០ | ២១១ | ២១២ | ២១៣ | ២១៤ | ២១៥ | ២១៦ | ២១៧ | ២១៨ | ២១៩ | ២២០ | ២២១ | ២២២ | ២២៣ | ២២៤ | ២២៥ | ២២៦ | ២២៧ | ២២៨ | ២២៩ | ២៣០ | ២៣១ | ២៣២ | ២៣៣ | ២៣៤ | ២៣៥ | ២៣៦ | ២៣៧ | ២៣៨ | ២៣៩ | ២៤០ | ២៤១ | ២៤២ | ២៤៣ | ២៤៤ | ២៤៥ | ២៤៦ | ២៤៧ | ២៤៨ | ២៤៩ | ២៥០ | ២៥១ | ២៥២ | ២៥៣ | ២៥៤ | ២៥៥ | ២៥៦ | ២៥៧ | ២៥៨ |

២៥៩ | ២៦០ | ២៦១ | ២៦២ | ២៦៣ | ២៦៤ | ២៦៥ | ២៦៦ | ២៦៧ | ២៦៨ | ២៦៩ | ២៧០ | ២៧១ | ២៧២ | ២៧៣ | ២៧៤ | ២៧៥ | ២៧៦ | ២៧៧ | ២៧៨ | ២៧៩ | ២៨០ | ២៨១ | ២៨២ | ២៨៣ | ២៨៤ | ២៨៥ | ២៨៦ | ២៨៧ | ២៨៨ | ២៨៩ | ២៩០ | ២៩១ | ២៩២ | ២៩៣ | ២៩៤ | ២៩៥ | ២៩៦ | ២៩៧ | ២៩៨ | ២៩៩ | ៣០០ | ៣០១ | ៣០២ | ៣០៣ | ៣០៤ | ៣០៥ | ៣០៦ | ៣០៧ | ៣០៨ | ៣០៩ | ៣១០ | ៣១១ | ៣១២ | ៣១៣ | ៣១៤ | ៣១៥ | ៣១៦ | ៣១៧ | ៣១៨ | ៣១៩ | ៣២០ | ៣២១ | ៣២២ | ៣២៣ | ៣២៤ | ៣២៥ | ៣២៦ | ៣២៧ | ៣២៨ | ៣២៩ | ៣៣០ | ៣៣១ | ៣៣២ | ៣៣៣ | ៣៣៤ | ៣៣៥ | ៣៣៦ | ៣៣៧ | ៣៣៨ | ៣៣៩ | ៣៤០ | ៣៤១ | ៣៤២ | ៣៤៣ | ៣៤៤ | ៣៤៥ | ៣៤៦ | ៣៤៧ | ៣៤៨ | ៣៤៩ | ៣៥០ | ៣៥១ | ៣៥២ | ៣៥៣ | ៣៥៤ | ៣៥៥ | ៣៥៦ | ៣៥៧ | ៣៥៨ | ៣៥៩ | ៣៦០ | ៣៦១ | ៣៦២ | ៣៦៣ | ៣៦៤ | ៣៦៥ | ៣៦៦ | ៣៦៧ | ៣៦៨ | ៣៦៩ | ៣៧០ | ៣៧១ | ៣៧២ | ៣៧៣ | ៣៧៤ | ៣៧៥ | ៣៧៦ | ៣៧៧ | ៣៧៨ | ៣៧៩ | ៣៨០ | ៣៨១ | ៣៨២ | ៣៨៣ | ៣៨៤ | ៣៨៥ | ៣៨៦ | ៣៨៧ | ៣៨៨ | ៣៨៩ | ៣៩០ | ៣៩១ | ៣៩២ | ៣៩៣ | ៣៩៤ | ៣៩៥ | ៣៩៦ | ៣៩៧ | ៣៩៨ | ៣៩៩ | ៤០០ | ៤០១ | ៤០២ | ៤០៣ | ៤០៤ | ៤០៥ | ៤០៦ | ៤០៧ | ៤០៨ | ៤០៩ | ៤១០ | ៤១១ | ៤១២ | ៤១៣ | ៤១៤ | ៤១៥ | ៤១៦ | ៤១៧ | ៤១៨ | ៤១៩ | ៤២០ | ៤២១ | ៤២២ | ៤២៣ | ៤២៤ | ៤២៥ | ៤២៦ | ៤២៧ | ៤២៨ | ៤២៩ | ៤៣០ | ៤៣១ | ៤៣២ | ៤៣៣ | ៤៣៤ | ៤៣៥ | ៤៣៦ | ៤៣៧ | ៤៣៨ | ៤៣៩ | ៤៤០ | ៤៤១ | ៤៤២ | ៤៤៣ | ៤៤៤ | ៤៤៥ | ៤៤៦ | ៤៤៧ | ៤៤៨ | ៤៤៩ | ៤៥០ | ៤៥១ | ៤៥២ | ៤៥៣ | ៤៥៤ | ៤៥៥ | ៤៥៦ | ៤៥៧ | ៤៥៨ | ៤៥៩ | ៤៦០ | ៤៦១ | ៤៦២ | ៤៦៣ | ៤៦៤ | ៤៦៥ | ៤៦៦ | ៤៦៧ | ៤៦៨ | ៤៦៩ | ៤៧០ | ៤៧១ | ៤៧២ | ៤៧៣ | ៤៧៤ | ៤៧៥ | ៤៧៦ | ៤៧៧ | ៤៧៨ | ៤៧៩ | ៤៨០ | ៤៨១ | ៤៨២ | ៤៨៣ | ៤៨៤ | ៤៨៥ | ៤៨៦ | ៤៨៧ | ៤៨៨ | ៤៨៩ | ៤៩០ | ៤៩១ | ៤៩២ | ៤៩៣ | ៤៩៤ | ៤៩៥ | ៤៩៦ | ៤៩៧ | ៤៩៨ | ៤៩៩ | ៥០០ | ៥០១ | ៥០២ | ៥០៣ | ៥០៤ | ៥០៥ | ៥០៦ | ៥០៧ | ៥០៨ | ៥០៩ | ៥១០ | ៥១១ | ៥១២ | ៥១៣ | ៥១៤ | ៥១៥ | ៥១៦ | ៥១៧ | ៥១៨ | ៥១៩ | ៥២០ | ៥២១ | ៥២២ | ៥២៣ | ៥២៤ | ៥២៥ | ៥២៦ | ៥២៧ | ៥២៨ | ៥២៩ | ៥៣០ | ៥៣១ | ៥៣២ | ៥៣៣ | ៥៣៤ | ៥៣៥ | ៥៣៦ | ៥៣៧ | ៥៣៨ | ៥៣៩ | ៥៤០ | ៥៤១ | ៥៤២ | ៥៤៣ | ៥៤៤ | ៥៤៥ | ៥៤៦ | ៥៤៧

# ឯកនិបាតជាតក

CS sut.kn.jat.v01 | ភាគទី ៥៨

(បឋមោ ភាគោ) ១. ឯកកនិបាតោ

## អបណ្ណកវគ្គ ទី១

CS sut.kn.jat.v01.01 | ភាគទី ៥៨

(១. អបណ្ណកវគ្គោ)

### អបណ្ណកជាតក ទី១

CS sut.kn.jat.001 | ភាគទី ៥៨

(១. អបណ្ណកជាតកំ)

[១] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) បុគ្គលពួកខ្លះជាបណ្ឌិត រមែងប្រកាន់ហេតុដែលមិនខុស បុគ្គលពួកខ្លះ ត្រិះរិះយកឯង រមែងប្រកាន់ហេតុទី ២ (ហេតុខុស) មេធាវីបុគ្គល បានដឹងនូវហេតុដែលខុស និងហេតុដែលមិនខុសនេះហើយ គប្បីកាន់យកនូវហេតុ ដែលមិនខុសនោះ។

ចប់ អបណ្ណកជាតក ទី១។

### វណ្ណុបថជាតក ទី២

CS sut.kn.jat.002 | ភាគទី ៥៨

(២. វណ្ណុបថជាតកំ)

[២] (ព្រះសម្ពុទ្ធត្រាស់ថា) ពួកជនមិនខ្ជិលច្រអូស កាលជីក (ផែនដី) ត្រង់ផ្លូវខ្សាច់ ឬក្នុងទីទួល បាននូវទឹកត្រង់ផ្លូវនោះ (យ៉ាងណា) អ្នកប្រាជ្ញ បរិបូណ៌ដោយព្យាយាម និងកំឡាំងកាយ មិនខ្ជិលច្រអូស ក៏បាននូវសេចក្តីស្ងប់រម្ងាប់នៃហឫទ័យយ៉ាងនោះដែរ។

ចប់ វណ្ណុបថជាតក ទី២។

### សេរិវវាណិជជាតក ទី៣

CS sut.kn.jat.003 | ភាគទី ៥៨

(៣. សេរិវវាណិជជាតកំ )

[៣] (ព្រះសម្ពុទ្ធត្រាស់ថា) បើអ្នកធ្វើនូវសោតាបត្តិមគ្គ ជាគ្រឿងកំណាត់នូវព្រះសទ្ធម្មនោះ ឲ្យឃ្លាតចាកសាសនានេះហើយ អ្នករមែងក្តៅក្រហាយរឿយ ៗ អស់កាលយូរ ដូចជាពាណិជឈ្មោះសេរិវៈនេះ។

ចប់ សេរិវវាណិជជាតក ទី៣។

## ចុល្លកសេដ្ឋិជាតក ទី៤

CS sut.kn.jat.004 | ភាគទី ៥៨

(៤. ចូឡសេដ្ឋិជាតកំ)

[៤] (ព្រះសាស្តា ត្រាស់ថា) អ្នកប្រាជ្ញ ឈ្លាសវៃ រមែងតាំងខ្លួនបានដោយទ្រព្យជាដើមទុន សូម្បីមានប្រមាណតិច ដូចបុគ្គលបង្កាត់ភ្លើងដ៏តូច។

ចប់ ចុល្លកសេដ្ឋិជាតក ទី៤។

## តណ្ឌុលនាឡិជាតក ទី៥

CS sut.kn.jat.005 | ភាគទី ៥៨

(៥. តណ្ឌុលនាឡិជាតកំ)

[៥] (អាមាត្យពោធិសត្វ សួរថា) អង្ករមួយនាឡិ ថ្លៃ (ស្មើនឹង) ក្រុងពារាណសី ទាំងខាងក្នុង ទាំងខាងក្រៅ ឬសេះ ៥០០ នេះ ថ្លៃត្រឹមតែអង្ករ ១ នាឡិទេឬ។

ចប់ តណ្ឌុលនាឡិជាតក ទី៥។

## ទេវធម្មជាតក ទី៦

CS sut.kn.jat.006 | ភាគទី ៥៨

(៦. ទេវធម្មជាតកំ)

[៦] (ព្រះមហិស្សាសរាជកុមារពោធិសត្វ ពោលថា) ពួកសប្បុរស អ្នកមានចិត្តស្ងប់រម្ងាប់ បរិបូណ៌ដោយហិរិ និងឱត្តប្បៈ តាំងមាំហើយក្នុងធម៌ស លោកពោលថាមានទេវធម៌ក្នុងលោក។

ចប់ ទេវធម្មជាតក ទី៦។

## កដ្ឋហារិជាតក ទី៧

CS sut.kn.jat.007 | ភាគទី ៥៨

(៧. កដ្ឋហារិជាតកំ)

[៧] (ព្រះរាជកុមារពោធិសត្វ ពោលថា) បពិត្រមហារាជ ខ្ញុំជាបុត្ររបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងពួកជន សូមព្រះអង្គចិញ្ចឹមខ្ញុំផង ព្រះសម្មតិទេពទ្រង់ចិញ្ចឹមពួកជនដទៃបាន ម្តេចព្រះសម្មតិទេពក៏មិនចិញ្ចឹមសត្វដែលជាបុត្ររបស់ព្រះអង្គផង។

ចប់ កដ្ឋហារិជាតក ទី៧។

## គាមណិជាតក ទី៨

CS sut.kn.jat.008 | ភាគទី ៥៨

(៨. គាមណិជាតកំ)

[៨] (គាមណិកុមារ ពោលថា) ការប្រាថ្នានូវផល តែងសម្រេចព្រម ដល់ពួកជនអ្នកមិនរួសរាន់ អញជាអ្នកមានព្រហ្មចារ្យចាស់ក្លាហើយ ម្នាលគាមណិ អ្នកចូរដឹងយ៉ាងនេះចុះ។

ចប់ គាមណិជាតក ទី៨។

## មឃទេវជាតក ទី៩

CS sut.kn.jat.009 | ភាគទី ៥៨

(៩. មឃទេវជាតកំ)

[៩] (ព្រះរាជាពោធិសត្វ ទ្រង់ត្រាស់ថា) សក់ទាំងឡាយនេះ នាំទៅនូវវ័យ (ស្កូវ) កើតដល់អញហើយ ទេវទូត កើតប្រាកដហើយ (នេះ) ជាសម័យនៃផ្នួសរបស់អញ។

ចប់ មឃទេវជាតក ទី៩។

## សុខវិហារិជាតក ទី១០

CS sut.kn.jat.010 | ភាគទី ៥៨

(១០. សុខវិហារិជាតកំ)

[១០] (ឥសីពោធិសត្វ ពោលថា) ពួកជនដទៃ មិនរក្សាជនណា ម្យ៉ាងទៀត ជនណាមិនរក្សាពួកជនដទៃ បពិត្រព្រះរាជា ជននោះឯង

មិនមានសេចក្តីអាឡោះអាល័យក្នុងកាមទាំងឡាយទេ រមែងដេកជាសុខ។

ចប់ សុខវិហារិជាតក ទី១០។

ចប់ អបណ្ណកវគ្គ ទី១។

ឧទ្ទាននៃអបណ្ណកវគ្គនោះគឺ

និយាយអំពីបុគ្គលខ្លះប្រកាន់ហេតុមិនខុសដ៏ប្រសើរ ក្នុងអបណ្ណកជាតក ១ វណ្ណុបថជាតក ១ សេរិវវាណិជជាតក ១ បុគ្គលមានប្រាជ្ញាជាគ្រឿងពិចារណា ក្នុងចុល្លកសេដ្ឋិជាតក ១ តណ្ឌុលនាឡិជាតក ១ បុគ្គលមានហិរិ ក្នុងទេវធម្មជាតក ១ ព្រះរាជបុត្ត ក្នុងកដ្ឋហារិជាតក ១ គាមណិជាតក ១ មឃទេវជាតក ១ ជនណាមិនរក្សាជនដទៃ ក្នុងសុខវិហារិជាតក ១ ត្រូវជា ១០ ជាតក។

## សីលវគ្គ ទី២

CS sut.kn.jat.v01.02 | ភាគទី ៥៨

(២. សីលវគ្គោ)

### លក្ខណជាតក ទី១

CS sut.kn.jat.011 | ភាគទី ៥៨

(១១. លក្ខណមិគជាតកំ)

[១១] (ម្រឹគពោធិសត្វ ពោលថា) សេចក្តីចំរើន តែងមានដល់ពួកជនអ្នកមានសីល អ្នកប្រព្រឹត្តបដិសន្ថារៈ នាងចូរមើលម្រឹគឈ្មោះលក្ខណៈ កំពុងដើរមក ដែលពួកញាតិហែហមហើយ នាងឃើញម្រឹគឈ្មោះកាឡៈនេះ ដែលសាបសូន្យចាកពួកញាតិ (កំពុងដើរមក) ឬទេ។

ចប់ លក្ខណជាតក ទី១។

### និគ្រោធមិគជាតក ទី២

CS sut.kn.jat.012 | ភាគទី ៥៨

(១២. និគ្រោធមិគជាតកំ)

[១២] (មេម្រឹគ ពោលថា) បុគ្គលគប្បីសេពនូវម្រឹគឈ្មោះនិគ្រោធៈតែម្យ៉ាង កុំគប្បីសេពនូវម្រឹគឈ្មោះសាខៈឡើយ ការស្លាប់ក្នុងសំណាក់នៃម្រឹគឈ្មោះនិគ្រោធៈ ជាការប្រសើរ ការរស់នៅក្នុងសំណាក់នៃម្រឹគឈ្មោះសាខៈ ពុំប្រសើរឡើយ។

ចប់ និគ្រោធមិគជាតក ទី២។

### កណ្ឌិនជាតក ទី៣

CS sut.kn.jat.013 | ភាគទី ៥៨

(១៣. កណ្ឌិជាតកំ)

[១៣] (រុក្ខទេវតាពោធិសត្វ ពោលថា) ចូរតិះដៀលនូវបុរសអ្នកមានសរមុតចូលទៅ ដែលមានរបួសយ៉ាងខ្លាំង ស្រីជាបរិណាយិកា (អ្នកត្រួតត្រា) នៅក្នុងជនបទណា ចូរតិះដៀលនូវជនបទនោះ ម្យ៉ាងទៀត សត្វទាំងឡាយណា លុះអំណាចពួកស្រី សត្វទាំងឡាយនោះ ក៏បណ្ឌិតតិះដៀលហើយ។

ចប់ កណ្ឌិនជាតក ទី៣។

### វាតមិគជាតក ទី៤

CS sut.kn.jat.014 | ភាគទី ៥៨

(១៤. វាតមិគជាតកំ)

[១៤] (ព្រះរាជាទ្រង់មានព្រះឱង្ការថា ឆន្ទរាគ) ដោយអាវាសៈទាំងឡាយ ឬដោយការស្និទ្ធស្នាលទាំងឡាយ ជាសភាវៈលាមកជាងឆន្ទរាគ ដោយរសទាំងឡាយមិនមានទេ ឧយ្យានបាលឈ្មោះ សញ្ជ័យ បាននាំសត្វឈ្លូសដែលអាស្រ័យនូវព្រៃស្បាត មកកាន់អំណាច (របស់ខ្លួន) បាន ព្រោះតែរសទាំងឡាយ។

ចប់ វាតមិគជាតក ទី៤។

### ខរាទិយជាតក ទី៥

CS sut.kn.jat.015 | ភាគទី ៥៨

(១៥. ខរាទិយជាតកំ)

[១៥] (ម្រឹគពោធិសត្វ ពោលថា) ម្នាលនាងខរាទិយា យើងមិនអាចទូន្មានម្រឹគ មានក្រចក ៨ មានស្នែងវៀចគល់ និងស្រួចចុងដ៏ក្រៃលែង ជាសត្វកន្លងនូវកាលនៃដម្បូន្មាន ៧ នោះបានឡើយ។

ចប់ ខរាទិយជាតក ទី៥។

## តិបល្លត្ថមិគជាតក ទី៦

CS sut.kn.jat.016 | ភាគទី ៥៨

(១៦. តិបល្លត្ថមិគជាតកំ)

[១៦] (ម្រឹគពោធិសត្វ ពោលថា) អញបានញុំាងម្រឹគ មានដំណោក ៣ មានក្រចក ៨ ជាសត្វផឹកទឹកក្នុងពេលអធ្រាត្រ ឲ្យរៀនមាយាច្រើនហើយ ម្រឹគជាក្មួយបានដកដង្ហើមខ្ទប់នឹងផែនដី ដោយរន្ធច្រមុះម្ខាង បញ្ឆោត (ព្រានព្រៃ) ដោយកល ៦ យ៉ាង។

ចប់ តិបល្លត្ថមិគជាតក ទី៦។

## មាលុតជាតក ទី៧

CS sut.kn.jat.017 | ភាគទី ៥៨

(១៧. មាលុតជាតកំ)

[១៧] (ឥសីពោធិសត្វ ពោលថា) កាលណាខ្យល់បក់ ទោះខាងរនោចក្តី ខាងខ្នើតក្តី កាលនោះ ត្រជាក់ទាំងឡាយ ក៏កើតអំពីខ្យល់ អ្នកទាំងពីរ មិនចាលចាញ់ ក្នុងប្រស្នានេះឡើយ។

ចប់ មាលុតជាតក ទី៧។

## មតកភត្តជាតក ទី៨

CS sut.kn.jat.018 | ភាគទី ៥៨

(១៨. មតកភត្តជាតកំ)

[១៨] (រុក្ខទេវតាពោធិសត្វ ពោលថា) បើពួកសត្វគប្បីដឹងយ៉ាងនេះថា ការកើតនៃជាតិនេះ រមែងនាំមកនូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វ រមែងសោយសោក។

ចប់ មតកភត្តជាតក ទី៨។

## អាយាចិតភត្តជាតក ទី៩

CS sut.kn.jat.019 | ភាគទី ៥៨

(១៩. អាយាចិតភត្តជាតកំ)

[១៩] (រុក្ខទេវតា ពោលថា) បើអ្នកចង់រួច ត្រូវរួចក្នុងលោកខាងនាយ ព្រោះថា អ្នករួចឥឡូវនេះ គង់ជាប់ (ដោយបាបកម្ម) អ្នកប្រាជ្ញទាំងឡាយ មិនធ្លាប់រួចយ៉ាងនេះឡើយ ការរួចរបស់ជនពាល ឈ្មោះថាចំណងវិញទេ។

ចប់ អាយាចិតភត្តជាតក ទី៩។

## នឡបានជាតក ទី១០

CS sut.kn.jat.020 | ភាគទី ៥៨

(២០. នឡបានជាតកំ)

[២០] (ស្វាពោធិសត្វ ពោលថា) យើងឃើញស្នាមជើងដែលមិនឡើង ឃើញតែស្នាមជើងដែលចុះ យើងផឹកទឹកដោយដើមបបុស អ្នកនឹងសម្លាប់យើងមិនបានឡើយ។

ចប់ នឡបានជាតក ទី១០។

ចប់ សីលវគ្គ ទី២។

ឧទ្ទាននៃសីលវគ្គនោះគឺ

និយាយអំពីលក្ខណជាតក ១ ម្រឹគឈ្មោះសាខៈ (ក្នុងនិគ្រោធមិគជាតក) ១ ចូរតិះដៀល (ក្នុងកណ្ឌិនជាតក) ១ មិនលាមកជាងរសទាំងឡាយ (ក្នុងវាតមិគជាតក) ១ ខរាទិយជាតក ១ ម្រឹគបញ្ឆោតព្រានព្រៃ (ក្នុងតិបល្លត្ថមិគជាតក) ១ មាលុតជាតក ១ បុគ្គលមិនត្រូវសម្លាប់សត្វដទៃ (ក្នុងមតកភត្តជាតក) ១ ការរួច (ក្នុងអាយាចិតភត្តជាតក) ១ នឡបានជាតក ១ ត្រូវជា ១០។

# កុរុង្គវគ្គ ទី៣

CS sut.kn.jat.v01.03 | ភាគទី ៥៨

(៣. កុរុង្គវគ្គោ)

## កុរុង្គមិគជាតក ទី១

CS sut.kn.jat.021 | ភាគទី ៥៨

(២១. កុរុង្គមិគជាតកំ)

[២១] (ប្រើសពោធិសត្វ ពោលថា) ម្នាលដើមចម្បក់ អ្នកជម្រុះផ្លែមកដោយហេតុណា ហេតុនុ៎ះ អញជាប្រើសបានដឹងហើយ អញនឹងទៅកាន់ដើមចម្បក់ឯទៀត ផ្លែរបស់អ្នក អញមិនពេញចិត្តទេ។

ចប់ កុរុង្គមិគជាតក ទី១។

## កុក្កុរជាតក ទី២

CS sut.kn.jat.022 | ភាគទី ៥៨

(២២. កុក្កុរជាតកំ)

[២២] (សុនខពោធិសត្វ ពោលថា) ពួកឆ្កែណាកើតក្នុងរាជត្រកូល បរិបូណ៌ដោយសម្បុរ និងកំឡាំង ចំរើនហើយក្នុងរាជត្រកូល ឆ្កែទាំងនោះ គេមិនសម្លាប់ទេ យើងទាំងឡាយត្រូវគេសម្លាប់ នេះមិនឈ្មោះថាសម្លាប់ដោយត្រឹមត្រូវឡើយ នេះឈ្មោះថាសម្លាប់តែឆ្កែដែលមានកំឡាំងខ្សោយ។

ចប់ កុក្កុរជាតក ទី២។

## ភោជាជានីយជាតក ទី៣

CS sut.kn.jat.023 | ភាគទី ៥៨

(២៣. គោជានីយជាតកំ)

[២៣] (សេះអាជានេយ្យពោធិសត្វ ពោលថា) សេះភោជាជានីយ សូម្បីត្រូវសរទាំងឡាយមុតហើយ ដេកផ្អៀង គង់ប្រសើរជាងសេះសាម័ញ្ញ នៃសារថី អ្នកចូរទឹមខ្ញុំដោយគ្រឿងក្រឹសទាំងឡាយចុះ។

ចប់ ភោជាជានីយជាតក ទី៣។

## អាជញ្ញជាតក ទី៤

CS sut.kn.jat.024 | ភាគទី ៥៨

(២៤. អាជញ្ញជាតកំ)

[២៤] (សេះអាជានេយ្យពោធិសត្វ ពោលថា) សេះអាជានេយ្យ ធ្វើនូវសន្ទុះក្នុងទីណា ក្នុងកាលណាម្តង ៗ ឬក្នុងខណៈណា ក្នុងមណ្ឌលចំបាំងណា ក្នុងកាលណាម្តង ៗ សេះសាម័ញ្ញទាំងឡាយ តែងសាបសូន្យ ក្នុងកាលនោះ ក្នុងទីនោះ។

ចប់ អាជញ្ញជាតក ទី៤។

## តិត្ថជាតក ទី៥

CS sut.kn.jat.025 | ភាគទី ៥៨

(២៥. តិត្ថជាតកំ)

[២៥] (អាមាត្យពោធិសត្វ ពោលថា) ម្នាលសារថី អ្នកចូរញ៉ាំងសេះឲ្យផឹក (ទឹក) តាមកំពង់ទឹកទាំងឡាយដទៃ ៗ ចុះ ឯសេះឆ្អែតដោយបាយាស ដោយការស៊ីជ្រុលហើយ (រមែងមិនត្រូវការបរិភោគទៀតទេ)។

ចប់ តិត្ថជាតក ទី៥។

## មហិឡាមុខជាតក ទី៦

CS sut.kn.jat.026 | ភាគទី ៥៨

(២៦. មហិឡាមុខជាតកំ)

[២៦] (អាមាត្យពោធិសត្វ ពោលថា) ដំរីដ៏ឧត្តមឈ្មោះមហិឡាមុខៈ បានស្តាប់ពាក្យរបស់ចោរទាំងឡាយមុនហើយ ក៏ប្រព្រឹត្តតាមបានបោកសម្លាប់ (ហ្មដំរី) លុះបានស្តាប់ពាក្យពួកលោកអ្នកមានខ្លួនសង្រួមល្អហើយ ក៏បានតាំងនៅក្នុងគុណគ្រប់យ៉ាង។

ចប់ មហិឡាមុខជាតក ទី៦។

## អភិណ្ហជាតក ទី៧

CS sut.kn.jat.027 | ភាគទី ៥៨

(២៧. អភិណ្ហជាតកំ)

[២៧] (អាមាត្យពោធិសត្វ ពោលថា) (ដំរី) មិនអាចកាន់យកនូវពំនូតបាយ មិនអាចកាន់យកនូវដុំបាយ មិនអាចកាន់យកនូវស្មៅទាំងឡាយ មិនអាចត្រដុស (សរីរៈ) ទេ ខ្ញុំសំគាល់ថាដំរីបានធ្វើសេចក្តីស្រឡាញ់ស្មោះចំពោះឆ្កែ ព្រោះការឃើញរឿយ ៗ។

ចប់ អភិណ្ហជាតក ទី៧។

## នន្ទិវិសាលជាតក ទី៨

CS sut.kn.jat.028 | ភាគទី ៥៨

(២៨. នន្ទិវិសាលជាតកំ)

[២៨] (ព្រះសាស្តា ទ្រង់ត្រាស់ថា) បុគ្គលគប្បីនិយាយពាក្យជាទីគាប់ចិត្តតែម្យ៉ាង មិនគប្បីនិយាយពាក្យមិនជាទីគាប់ចិត្តក្នុងកាលណាឡើយ កាលព្រាហ្មណ៍និយាយពាក្យជាទីគាប់ចិត្ត (គោនន្ទិវិសាល) បានទាញភារៈដ៏ធ្ងន់រួច ញុំាងព្រាហ្មណ៍នោះឲ្យបានទ្រព្យផង ជាសត្វមានចិត្តរីករាយដោយការញុំាងព្រាហ្មណ៍នោះឲ្យបានទ្រព្យនោះផង។

ចប់ នន្ទិវិសាលជាតក ទី៨។

## កណ្ហជាតក ទី៩

CS sut.kn.jat.029 | ភាគទី ៥៨

(២៩. កណ្ហជាតកំ)

[២៩] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ធុរៈធ្ងន់ ក្នុងទីណា ។ ផ្លូវដ៏ជ្រៅ ក្នុងទីណា កាលនោះឯង ពួកជននាំគ្នាទឹមគោឈ្មោះកណ្ហៈ គោឈ្មោះកណ្ហៈនោះ ក៏អូសនូវធុរៈដ៏ធ្ងន់នោះទៅបាន។

ចប់ កណ្ហជាតក ទី៩។

## មុណិកជាតក ទី១០

CS sut.kn.jat.030 | ភាគទី ៥៨

(៣០. មុនិកជាតកំ)

[៣០] (គោពោធិសត្វ ឈ្មោះមហាលោហិតៈ ពោលថា) អ្នកកុំចូលចិត្ត (ភោជន) របស់ជ្រូកឈ្មោះមុណិកៈ (ព្រោះ) ជ្រូកមុណិកៈស៊ីភោជនក្តៅក្រហាយ អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិច ហើយស៊ីតែចំបើងចុះ នេះជាលក្ខណៈនៃអាយុវែង។

ចប់ មុណិកជាតក ទី១០។

ចប់ កុរុង្គវគ្គ ទី៣។

ឧទ្ទាននៃកុរុង្គវគ្គគឺ

និយាយអំពីកុរុង្គមិគជាតក ១ កុក្កុរជាតក ១ ភោជាជានីយជាតក ១ សេះដ៏ប្រសើរ (ក្នុងអាជញ្ញជាតក) ១ សេះសាម័ញ្ញ និងសេះដ៏ប្រសើរ (ក្នុងតិត្ថជាតក) ១ មហិឡាមុខជាតក ១ អភិណ្ហជាតក ១ បុគ្គលមិនត្រូវពោលពាក្យមិនគាប់ចិត្ត (ក្នុងនន្ទិវិសាលជាតក) ១ គោកណ្ហអូសនូវធុរៈ (ក្នុងកណ្ហជាតក) ១ មុណិកជាតក ១ ត្រូវជា ១០។

# កុលាវកវគ្គ ទី៤

CS sut.kn.jat.v01.04 | ភាគទី ៥៨

(៤. កុលាវកវគ្គោ)

## កុលាវកជាតក ទី១

CS sut.kn.jat.031 | ភាគទី ៥៨

(៣១. កុលាវកជាតកំ)

[៣១] (ព្រះឥន្ទពោធិសត្វ ពោលថា) ម្នាលមាតលិ ពួកកូនគ្រុឌ (ទំ) នៅដើមរកា អ្នកចូរចៀសវាង (កុំឲ្យពួកវាលំបាក) ដោយមុខចន្ទោលរថឡើយ តាមពិត យើងស៊ូលះជីវិត ចំពោះពួកអាសុរវិញ កុំឲ្យតែកូនគ្រុឌទាំងនេះ មានសំបុកខ្ទាតខ្ទាយ។

ចប់ កុលាវកជាតក ទី១។

## នច្ចជាតក ទី២

CS sut.kn.jat.032 | ភាគទី ៥៨

(៣២. នច្ចជាតកំ)

[៣២] (ស្តេចហង្សមាស ពោលថា) សំឡេងយំ (របស់អ្នក) ក៏ពីរោះ ខ្នងក៏រុងរឿង ក មានសម្បុរប្រហែលគ្នានឹងពណ៌នៃកែវពិទូរ្យ ស្លាបទាំងឡាយ ប្រមាណមួយព្យាម អញមិនឲ្យកូនស្រីដល់អ្នក ព្រោះតែការរាំឡើយ។

ចប់ នច្ចជាតក ទី២។

## សម្មោទមានជាតក ទី៣

CS sut.kn.jat.033 | ភាគទី ៥៨

(៣៣. សម្មោទមានជាតកំ)

[៣៣] (ព្រានសត្វស្លាប ពោលថា) ពួកបក្សីស្រុះស្រួលគ្នា នាំយកលប់ទៅបាន តែបើពួកបក្សីទាំងនោះ ជជែកទាស់គ្នាក្នុងកាលណា ពួកបក្សីទាំងនោះ នឹងលុះអំណាចអញក្នុងកាលនោះមិនខានឡើយ។

ចប់ សម្មោទមានជាតក ទី៣។

## មច្ឆជាតក ទី៤

CS sut.kn.jat.034 | ភាគទី ៥៨

(៣៤. មច្ឆជាតកំ)

[៣៤] (ត្រីឈ្មោល ពោលថា) ត្រជាក់មិន (បៀតបៀន) អញទេ ក្តៅក៏មិន (បៀតបៀន) អញដែរ ការបៀតបៀនអញព្រោះលប មិនមានឡើយ (អញ) ព្រួយតែត្រង់ត្រីញីសំគាល់អញថា ត្រីឈ្មោលនោះ ទៅរកត្រីញីដទៃ ដោយតម្រេក។

ចប់ មច្ឆជាតក ទី៤។

## វដ្តកជាតក ទី៥

CS sut.kn.jat.035 | ភាគទី ៥៨

(៣៥. វដ្តកជាតកំ)

[៣៥] (កូនចាបពោធិសត្វ ពោលថា) ស្លាបទាំងឡាយមាន តែហើរមិនរួច ជើងទាំងឡាយមាន តែដើរមិនបាន មេ និងបា (របស់យើង) ចេញបាត់ទៅហើយ នែភ្លើងព្រៃ អ្នកចូរថយទៅចុះ។

ចប់ វដ្តកជាតក ទី៥។

## សកុណជាតក ទី៦

CS sut.kn.jat.036 | ភាគទី ៥៨

(៣៦. សកុណជាតកំ)

[៣៦] (សត្វស្លាបពោធិសត្វ ពោលថា ពួកសត្វស្លាប) អាស្រ័យនឹងដើមឈើណា ដែលដុះលើផែនដី ដើមឈើនោះ ក៏បញ្ចេញភ្លើង ម្នាលអ្នកមានអវយវៈ (ក្បាល និងក) វៀចទាំងឡាយ អ្នកទាំងឡាយ ចូរគប់ទិស (ទាំង៤) ចុះ ភ័យកើតអំពីដើមឈើជាទីពឹងហើយ។

ចប់ សកុណជាតក ទី៦។

## តិត្តិរជាតក ទី៧

CS sut.kn.jat.037 | ភាគទី ៥៨

(៣៧. តិត្តិរជាតកំ)

[៣៧] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ពួកជនណា ជាអ្នកឈ្លាសក្នុងធម៌ ប្រព្រឹត្តកោតក្រែងចំពោះបុគ្គលដែលចំរើនហើយ ពួកជននោះ អ្នកផងគប្បីសរសើរ ក្នុងបច្ចុប្បន្នផង សម្បរាយលោក គឺសុគតិ ក៏កើតមាន (ដល់ពួកជននោះ) ផង។

ចប់ តិត្តិរជាតក ទី៧។

## ពកជាតក ទី៨

CS sut.kn.jat.038 | ភាគទី ៥៨

(៣៨. ពកជាតកំ)

[៣៨] (រុក្ខទេវតាពោធិសត្វ ពោលថា) បុគ្គលមានប្រាជ្ញាជាគ្រឿងបញ្ឆោត រមែងមិនដល់សេចក្តីសុខ អស់កាលជានិច្ច ព្រោះបញ្ញាជាគ្រឿងបញ្ឆោតឡើយ បុគ្គលមានប្រាជ្ញាជាគ្រឿងបញ្ឆោត (នោះ) រមែងបាន (នូវលទ្ធផលអាក្រក់) ដូចសត្វកុក (បាននូវការដាច់ក) អំពីក្តាម។

ចប់ ពកជាតក ទី៨។

## នន្ទជាតក ទី៩

CS sut.kn.jat.039 | ភាគទី ៥៨

(៣៩. នន្ទជាតកំ)

[៣៩] (កុដុម្ពិកពោធិសត្វ ពោលថា) យើងសំគាល់ថា គំនរមាស និងកម្រងមាស មានក្នុងទីដែលខ្ញុំប្រុសឈ្មោះនន្ទកៈ ជាកូនរបស់ខ្ញុំស្រីឈ្មោះអាមា ឈរពោលនូវពាក្យអាក្រក់នោះ។

ចប់ នន្ទជាតក ទី៩។

## ខទិរង្គារជាតក ទី១០

CS sut.kn.jat.040 | ភាគទី ៥៨

(៤០. ខទិរង្គារជាតកំ)

[៤០] (សេដ្ឋីពោធិសត្វ ពោលថា) តាមពិត ខ្ញុំព្រះអង្គ ស៊ូមានជើងឡើងលើ មានក្បាលចុះក្រោម ហើយធ្លាក់ទៅកាន់នរក ខ្ញុំនឹងពុំធ្វើអំពើមិនប្រសើរទេ បើដូច្នោះ សូមព្រះអង្គ ទទួលនូវចង្ហាន់បិណ្ឌបាតចុះ។

ចប់ ខទិរង្គារជាតក ទី១០។

ចប់ កុលាវកវគ្គ ទី៤។

ឧទ្ទាននៃកុលាវកវគ្គនោះគឺ

និយាយអំពីមាតលី (ក្នុងកុលាវកជាតក) ១ ធីតា (ក្នុងនច្ចជាតក) ១ ពួកបក្សីដ៏ប្រសើរ (ក្នុងសម្មោទមានជាតក) ១ ត្រីឈ្មោលទៅដោយតម្រេក (ក្នុងមច្ឆជាតក) ១ មេបា (ក្នុងវដ្តកជាតក) ១ ដើមឈើដុះលើផែនដី (ក្នុងសកុណជាតក) ១ បុគ្គលចំរើន (ក្នុងតិត្តិរជាតក) ១ ក្ដាមឈ្លាសវៃក្នុងពកជាតក ១ នន្ទជាតក ១ ដុំបាយដ៏ប្រសើរ ក្នុងខទិរង្គារជាតក ១ ត្រូវជា ១០។

# អត្ថកាមវគ្គ ទី៥

CS sut.kn.jat.v01.05 | ភាគទី ៥៨

(៥. អត្ថកាមវគ្គោ)

## លោសកជាតក ទី១

CS sut.kn.jat.041 | ភាគទី ៥៨

(៤១. លោសកជាតកំ)

[៤១] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្ដីចំរើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងសោកសៅ ដូចជាមិត្តវិន្ទុកៈប្រតោងជើងនៃមេតពៃសោកសៅ។

ចប់ លោសកជាតក ទី១។

## កបោតកជាតក ទី២

CS sut.kn.jat.042 | ភាគទី ៥៨

(៤២. កបោតជាតកំ)

[៤២] (ព្រាបពោធិសត្វ ពោលថា) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្ដីចំរើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ តែងដេកសោកសៅ ដូចក្អែកតាំងនៅក្នុងកណ្ដាប់ដៃនៃបុគ្គលជាសត្រូវ ព្រោះមិនធ្វើតាមពាក្យនៃសត្វព្រាប។

ចប់ កបោតកជាតក ទី២។

## វេឡុកជាតក ទី៣

CS sut.kn.jat.043 | ភាគទី ៥៨

(៤៣. វេឡុកជាតកំ)

[៤៣] (ឥសីពោធិសត្វ ពោលថា) បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្ដីចំរើន អនុគ្រោះដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គលនោះ រមែងដេកស្លាប់ ដូចឥសីជាបិតានៃពស់ឈ្មោះវេឡុកៈ។

ចប់ វេឡុកជាតក ទី៣។

## មកសជាតក ទី៤

CS sut.kn.jat.044 | ភាគទី ៥៨

(៤៤. មកសជាតកំ)

[៤៤] (ឈ្មួញពោធិសត្វ ពោលថា) បុគ្គលជាសត្រូវ តែប្រកបដោយប្រាជ្ញា ប្រសើរជាង ឯបុគ្គលជាមិត្ត ដែលប្រាសចាកប្រាជ្ញា មិនប្រសើរឡើយ ដូចយ៉ាងកូនបង្កើតដែលល្ងង់ខ្លៅ គិតថាអញនឹងសម្លាប់មូស ត្រឡប់ជាបំបែកក្បាលបិតាវិញ។

ចប់ មកសជាតក ទី៤។

## រោហិណីជាតក ទី៥

CS sut.kn.jat.045 | ភាគទី ៥៨

(៤៥. រោហិណិជាតកំ)

[៤៥] (សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលជាសត្រូវ តែជាអ្នកប្រាជ្ញ ប្រសើរជាង ឯបុគ្គលពាល ជាអ្នកទំនុកបម្រុង មិនប្រសើរឡើយ អ្នកចូរមើលទាសីឈ្មោះរោហិណី ជាស្រីអាក្រក់ សំឡាប់ម្ដាយ ហើយសោកសៅ។

ចប់ រោហិណីជាតក ទី៥។

## អារាមទូសកជាតក ទី៦

CS sut.kn.jat.046 | ភាគទី ៥៨

(៤៦. អារាមទូសកជាតកំ)

[៤៦] (បណ្ឌិតបុរសពោធិសត្វ ពោលថា) ការប្រព្រឹត្តិនូវសេចក្ដីចំរើន របស់អ្នកមិនឈ្លាសក្នុងហេតុចំរើន រមែងមិននាំមកនូវសេចក្ដីសុខទេ បុគ្គលឥតប្រាជ្ញា តែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចស្វារក្សាសួន (បានធ្វើប្រយោជន៍ឲ្យវិនាស)។

ចប់ អារាមទូសកជាតក ទី៦។

## វារុណិទូសកជាតក ទី៧

CS sut.kn.jat.047 | ភាគទី ៥៨

(៤៧. វារុណិទូសកជាតកំ)

[៤៧] (សេដ្ឋីពោធិសត្វ ពោលថា) ការប្រព្រឹត្តិនូវសេចក្ដីចំរើនរបស់អ្នកមិនឈ្លាសក្នុងហេតុចំរើន រមែងមិននាំមកនូវសេចក្ដីសុខទេ បុគ្គលឥតប្រាជ្ញា តែងធ្វើប្រយោជន៍ឲ្យសាបសូន្យ ដូចកោណ្ឌញ្ញៈបានញុំាងសុរាឲ្យវិនាស។

ចប់ វារុណិទូសកជាតក ទី៧។

## វេទព្វជាតក ទី៨

CS sut.kn.jat.048 | ភាគទី ៥៨

(៤៨. វេទព្វជាតកំ)

[៤៨] (កូនសិស្សពោធិសត្វ ពោលថា) បុគ្គលណា ប្រាថ្នាសេចក្ដីចំរើនដោយខុសឧបាយ បុគ្គលនោះ រមែងលំបាក ដូចពួកចោរនៅក្នុងដែនចេតៈ បានសម្លាប់នូវវេទព្វព្រាហ្មណ៍ ចោរទាំងអស់នោះ ក៏ដល់នូវសេចក្ដីវិនាស។

ចប់ វេទព្វជាតក ទី៨។

## នក្ខត្តជាតក ទី៩

CS sut.kn.jat.049 | ភាគទី ៥៨

(៤៩. នក្ខត្តជាតកំ)

[៤៩] (បណ្ឌិតបុរសពោធិសត្វ ពោលថា) ប្រយោជន៍រមែងកន្លងបង់នូវមនុស្សល្ងង់ ដែលរាប់អាននក្ខត្តឫក្ស (ព្រោះ) សេចក្ដីចំរើននៃប្រយោជន៍ ឈ្មោះថានក្ខត្តឫក្ស ឯផ្កាយទាំងឡាយ នឹងធ្វើអ្វីបាន។

ចប់ នក្ខត្តជាតក ទី៩។

## ទុម្មេធជាតក ទី១០

CS sut.kn.jat.050 | ភាគទី ៥៨

(៥០. ទុម្មេធជាតកំ)

[៥០] (ព្រះរាជាពោធិសត្វ ពោលថា) ការបូជា អញបានបួងសួងហើយដោយសារមនុស្សអាប់ឥតប្រាជ្ញារាប់ពាន់នាក់ ឥឡូវនេះ អញនឹងបូជា (ព្រោះ) ជនមិនប្រកបដោយធម៌ច្រើននាក់។

ចប់ ទុម្មេធជាតក ទី១០។

ចប់ អត្ថកាមវគ្គ ទី៥។

ចប់ បឋមបណ្ណាសក។

ឧទ្ទាននៃអត្ថកាមវគ្គនោះគឺ

និយាយអំពីមិត្តវិន្ទកៈ (ក្នុងលោសកជាតក) ១ កបោតកជាតក ១ វេឡុកជាតក ១ បុគ្គលល្ងង់ខ្លៅ (ក្នុងមកសជាតក) ១ រោហិណីជាតក ១ ស្វា (ក្នុងអារាមទូសកជាតក) ១ វារុណិទូសកជាតក ១ ចោរនៅក្នុងដែនចេតៈ (ក្នុងវេទព្វជាតក) ១ ផ្កាយ (ក្នុងនក្ខត្តជាតក) ១ ការបូជា (ក្នុងទុម្មេធជាតក) ១ ត្រូវជា ១០។

### អាសឹសវគ្គ ទី៦

CS sut.kn.jat.v01.06 | ភាគទី ៥៨

## មហាសីលវជាតក ទី១

CS sut.kn.jat.051 | ភាគទី ៥៨

(៥១.មហាសីលវជាតកំ)

[៥១] (ព្រះរាជាសីលវៈពោធិសត្វ ពោលថា) បុរសជាបណ្ឌិត គប្បីប៉ុនប៉ងឲ្យមុតមាំ មិនគប្បីនឿយណាយឡើយ យើងឃើញខ្លួនយើងស្រាប់ហើយ យើងប្រាថ្នាយ៉ាងណា បានយ៉ាងនោះ។

ចប់ មហាសីលវជាតក ទី១។

## ចូឡជនកជាតក ទី២

CS sut.kn.jat.052 | ភាគទី ៥៨

(៥២. ចូឡជនកជាតកំ)

[៥២] (ព្រះបាទជនកពោធិសត្វ ពោលថា) បុរសជាបណ្ឌិត ត្រូវតែប្រឹងប្រែង មិនត្រូវនឿយណាយឡើយ យើងឃើញខ្លួនយើងដែលឡើងអំពីទឹក កាន់គោកស្រាប់ហើយ។

ចប់ ចូឡជនកជាតក ទី២។

## បុណ្ណបាតិជាតក ទី៣

CS sut.kn.jat.053 | ភាគទី ៥៨

(៥៣. បុណ្ណបាតិជាតកំ)

[៥៣] (សេដ្ឋីពោធិសត្វ ពោលថា) ភាជន៍សុរានៅពេញដដែល តែសំដីចេញទៅដោយឡែក យើងដឹងបានដោយហេតុ (នេះ) សុរានេះមិនមែនស្រួលទេ។

ចប់ បុណ្ណបាតិជាតក ទី៣។

## ផលជាតក ទី៤

CS sut.kn.jat.054 | ភាគទី ៥៨

(៥៤. កិំផលជាតកំ)

[៥៤] (ឈ្មួញរទេះពោធិសត្វ ពោលថា) ឈើនេះ មិនមែនលំបាកឡើង ទាំងមិនឋិតនៅឆ្ងាយអំពីស្រុក ខ្ញុំដឹងបានដោយហេតុ (នេះ) ឈើនេះ មិនមែនមានផ្លែស្រួលទេ។

ចប់ ផលជាតក ទី៤។

## បញ្ចាវុធជាតក ទី៥

CS sut.kn.jat.055 | ភាគទី ៥៨

(៥៥. បញ្ចាវុធជាតកំ)

[៥៥] (ព្រះសាស្តា ទ្រង់ត្រាស់ថា) បុរសណា មានចិត្តមិនរួញរា ចំរើនកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តមិនរួញរា បុរសនោះ គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួង តាមលំដាប់។

ចប់ បញ្ចាវុធជាតក ទី៥។

## កញ្ចនក្ខន្ធជាតក ទី៦

CS sut.kn.jat.056 | ភាគទី ៥៨

(៥៦. កញ្ចនក្ខន្ធជាតកំ)

[៥៦] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) បុរសណា មានចិត្តរីករាយ ចំរើនកុសលធម៌ ដើម្បីដល់នូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ ដោយចិត្តដែលរីករាយ បុរសនោះ គប្បីដល់នូវធម៌ជាគ្រឿងអស់ទៅនៃសំយោជនៈទាំងពួង តាមលំដាប់។

ចប់ កញ្ចនក្ខន្ធជាតក ទី៦។

## វានរិន្ទជាតក ទី៧

CS sut.kn.jat.057 | ភាគទី ៥៨

(៥៧. វានរិន្ទជាតកំ)

[៥៧] (ក្រពើ ពោលថា) បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៤ ដូចអ្នក គឺសេចក្តីទៀងទាត់ ១ ធម៌ គឺប្រាជ្ញាជាគ្រឿងពិចារណា ១ ព្យាយាមមិនដាច់ ១ ការលះ ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន។

ចប់ វានរិន្ទជាតក ទី៧។

## តយោធម្មជាតក ទី៨

CS sut.kn.jat.058 | ភាគទី ៥៨

(៥៨. តយោធម្មជាតកំ)

[៥៨] (អារក្សទឹក ពោលថា) បពិត្រវានរិន្ទ បុគ្គលណា មានធម៌ ៣ ដូចអ្នក គឺសេចក្តីសង្វាត ១ សេចក្តីក្លៀវក្លា ១ បញ្ញា ១ បុគ្គលនោះ រមែងកន្លងបង់នូវសត្រូវបាន។

ចប់ តយោធម្មជាតក ទី៨។

## ភេរិវាទជាតក ទី៩

CS sut.kn.jat.059 | ភាគទី ៥៨

(៥៩. ភេរិវាទកជាតកំ)

[៥៩] (អ្នកវាយស្គរពោធិសត្វ ពោលថា) បុគ្គលគប្បីវាយ (ស្គរ) ចុះ ប៉ុន្តែកុំវាយឲ្យជ្រុល ព្រោះការវាយស្គរជ្រុល ជាការអាក្រក់ កហាបណៈមួយរយ ដែលបានហើយដោយការវាយស្គរ (កូនវាឲ្យ) វិនាសហើយ ដោយការវាយស្គរជ្រុល។

ចប់ ភេរិវាទជាតក ទី៩។

## សង្ខធមនជាតក ទី១០

CS sut.kn.jat.060 | ភាគទី ៥៨

(៦០. សង្ខធមជាតកំ)

[៦០] (អ្នកផ្លុំស័ង្ខពោធិសត្វ ពោលថា) បុគ្គលគប្បីផ្លុំ (ស័ង្ខ) ចុះ ប៉ុន្តែកុំគប្បីផ្លុំឲ្យជ្រុល ព្រោះការផ្លុំជ្រុល ជាការអាក្រក់ ភោគៈទាំងឡាយ ដែលបានហើយដោយការផ្លុំ បិតាផ្លុំបំផ្លាញភោគៈទាំងនោះ។

ចប់ សង្ខធមនជាតក ទី១០។

ចប់ អាសីសវគ្គ ទី៦។

ឧទ្ទាននៃអាសីសវគ្គនោះគឺ

និយាយអំពីអ្នកប្រាជ្ញប្រាថ្នាយ៉ាងណា ប្រយោជន៍ក៏កើតយ៉ាងនោះ (ក្នុងមហាសីលវជាតក) ១ ការឡើងអំពីទឹកមកកាន់គោក (ក្នុងចូឡជនកជាតក) ១ សុរា (ក្នុងបុណ្ណបាតិជាតក) ១ ឈើមានផ្លែមិនស្រួល (ក្នុងផលជាតក) ១ បុរសមានចិត្តមិនរួញរា (ក្នុងបញ្ចាវុធជាតក) ១ បុរសមានចិត្តរីករាយ (ក្នុងកញ្ចនក្ខន្ធជាតក) ១ ធម៌ ៤ (ក្នុងវានរិន្ទជាតក) ១ ធម៌ ៣ (ក្នុងតយោធម្មជាតក) ១ ការបានកហាបណៈមួយរយ (ក្នុងភេរិវាទជាតក) ១ ផ្លុំស័ង្ខបានភោគៈ (ក្នុងសង្ខធមនជាតក) ១ ត្រូវជា ១០។

## ឥត្ថីវគ្គ ទី៧

CS sut.kn.jat.v01.07 | ភាគទី ៥៨

(៧. ឥត្ថិវគ្គោ)

## អសាតមន្តជាតក ទី១

CS sut.kn.jat.061 | ភាគទី ៥៨

(៦១. អសាតមន្តជាតកំ)

[៦១] (មាណព ពោលថា) ធម្មតាពួកស្ត្រីក្នុងលោក តែងមានសេចក្តីប្រាថ្នា (ចំពោះបុរសដែលមានចិត្តជាប់ចំពាក់នឹងខ្លួន) វេលា (ឬកម្រិត) របស់ស្ត្រីទាំងនោះ មិនមានឡើយ (ស្ត្រីទាំងនោះ) ត្រេកត្រអាលផង រលោភលាំផង ដូចភ្លើងដែលឆេះវត្ថុគ្រប់យ៉ាង (មិនរើសមុខ) ខ្ញុំនឹងលះបង់ស្ត្រីទាំងនោះ ហើយបួស ចំរើននូវវិវេកធម៌។

ចប់ អសាតមន្តជាតក ទី១។

## អណ្ឌភូតជាតក ទី២

CS sut.kn.jat.062 | ភាគទី ៥៨

(៦២. អណ្ឌភូតជាតកំ)

[៦២] (ព្រះរាជាពោធិសត្វ ទ្រង់ត្រាស់ថា) ព្រាហ្មណ៍ បានរុំមុខរបស់ខ្លួន ហើយដេញពិណដោយហេតុណា (មិនដឹងហេតុនោះទេ) ប្រពន្ធដែលខ្លួនចិញ្ចឹមតាំងពីនៅជាអណ្ឌៈ (កូននៅក្នុងគភ៌) អ្នកណាគប្បីទុកចិត្តចំពោះប្រពន្ធទាំងនោះ ដោយដាច់ខាតបាន។

ចប់ អណ្ឌភូតជាតក ទី២។

## តក្កជាតក ទី៣

CS sut.kn.jat.063 | ភាគទី ៥៨

(៦៣. តក្កបណ្ឌិតជាតកំ)

[៦៣] (ព្រះសាស្តា ទ្រង់ត្រាស់ថា) (ធម្មតាស្ត្រី) ច្រើនខឹង មិនដឹងឧបការៈដែលគេធ្វើដល់ខ្លួន ជាអ្នកញុះញង់ បំបែកបំបាក់មិត្ត ម្នាលភិក្ខុ អ្នកចូរប្រព្រឹត្តព្រហ្មចរិយៈចុះ អ្នកនោះនឹងមិនវិនាសសេចក្តីសុខ។

ចប់ តក្កជាតក ទី៣។

## ទុរាជានជាតក ទី៤

CS sut.kn.jat.064 | ភាគទី ៥៨

(៦៤. ទុរាជានជាតកំ)

[៦៤] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) អ្នកកុំត្រេកអរ (ថាស្ត្រីនេះ) ប្រាថ្នាអញ កុំសោកសៅ (ថាស្ត្រីនេះ) មិនប្រាថ្នាអញ ភាពរបស់ស្ត្រីទាំងឡាយ ដឹងបានដោយក្រ ដូចជាដំណើរទៅនៃត្រីក្នុងទឹក។

ចប់ ទុរាជានជាតក ទី៤។

## អនភិរតិជាតក ទី៥

CS sut.kn.jat.065 | ភាគទី ៥៨

(៦៥. អនភិរតិជាតកំ)

[៦៥] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) ទន្លេក្តី ផ្លូវក្តី តៀមស្រាក្តី សាលាសំណាក់ក្តី អណ្តូងទឹកក្តី (ជារបស់សាធារណៈ) យ៉ាងណា ធម្មតាស្ត្រីទាំងឡាយក្នុងលោក ក៏យ៉ាងនោះដែរ បណ្ឌិតទាំងឡាយ មិនខឹងនឹងស្ត្រីទាំងនោះទេ។

ចប់ អនភិរតិជាតក ទី៥។

## មុទុលក្ខណជាតក ទី៦

CS sut.kn.jat.066 | ភាគទី ៥៨

(៦៦. មុទុលក្ខណជាតកំ)

[៦៦] (ឥសីពោធិសត្វ ពោលថា) មុនអំពីពេលដែលមិនទាន់បាននូវនាងមុទុលក្ខណា សេចក្តីប្រាថ្នាមានតែមួយ កាលណាអាត្មាភាពបាននាងមុទុលក្ខណា ជាស្ត្រីមានភ្នែកល្អហើយ សេចក្តីប្រាថ្នារឹតតែញុាំងសេចក្តីប្រាថ្នា (ផ្សេងៗ) ឲ្យកើតឡើងទៀត។

ចប់ មុទុលក្ខណជាតក ទី៦។

## ឧច្ឆង្គជាតក ទី៧

CS sut.kn.jat.067 | ភាគទី ៥៨

(៦៧. ឧច្ឆង្គជាតកំ)

[៦៧] (ស្ត្រីម្នាក់ ពោលថា) បពិត្រព្រះសម្មតិទេព កូនរបស់ខ្ញុំព្រះអង្គ (ដូចជាអន្លក់ដែលដក់) ក្នុងថ្នក់ (បានដោយងាយ) ស្ត្រីដែលដើរទៅតាមផ្លូវ រកប្តី (បានដោយងាយ) ឯខ្ញុំព្រះអង្គមិនឃើញប្រទេស គឺផ្ទៃនៃមាតានោះ ដែលខ្ញុំព្រះអង្គគួរនាំយកបងប្អូនប្រុសបង្កើតមកបាន។

ចប់ ឧច្ឆង្គជាតក ទី៧។

## សាកេតជាតក ទី៨

CS sut.kn.jat.068 | ភាគទី ៥៨

(៦៨. សាកេតជាតកំ)

[៦៨] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ចិត្តតាំងនៅស៊ប់ ឬក៏ចិត្តជ្រះថ្លា ក្នុងបុគ្គលណា ដែលខ្លួនមិនធ្លាប់ឃើញហើយ ជនតែងស្និទ្ធស្នាល ចំពោះបុគ្គលនោះ ដោយពិត។

ចប់ សាកេតជាតក ទី៨។

## វិសវន្តជាតក ទី៩

CS sut.kn.jat.069 | ភាគទី ៥៨

(៦៩. វិសវន្តជាតកំ)

[៦៩] (ពស់ ពោលថា) អញនឹងស្រូបយកពិសណាវិញ ដែលអញបានខ្ជាក់ចោលហើយ ព្រោះហេតុនៃជីវិត ចូរតិះដៀលនូវពិសដែលអញខ្ជាក់ចោលហើយនោះចុះ អញស្លាប់ ប្រសើរជាងរស់នៅ។

ចប់ វិសវន្តជាតក ទី៩។

## កុទ្ទាលជាតក ទី១០

CS sut.kn.jat.070 | ភាគទី ៥៨

(៧០. កុទ្ទាលជាតកំ)

[៧០] (កុទ្ទាលកបណ្ឌិតពោធិសត្វ ពោលថា) សេចក្តីឈ្នះណា ត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ មិនឈ្មោះថា ឈ្នះប្រពៃទេ សេចក្តីឈ្នះណា មិនត្រឡប់ចាញ់វិញបាន សេចក្តីឈ្នះនោះ ទើបឈ្មោះថា ឈ្នះប្រពៃមែនពិត។

ចប់ កុទ្ទាលជាតក ទី១០។

ចប់ ឥត្ថីវគ្គ ទី៧។

ឧទ្ទាននៃឥត្ថីវគ្គនោះគឺ

និយាយអំពីភ្លើងឆេះវត្ថុគ្រប់យ៉ាង (ក្នុងអសាតមន្តជាតក) ១ ពិណដ៏ប្រសើរ (ក្នុងអណ្ឌភូតជាតក) ១ ស្ត្រីជាអ្នកញុះញង់ និងបំបែកបំបាក់មិត្រ (ក្នុងតក្កជាតក) ១ ការត្រេកអរ (ក្នុងទុរាជានជាតក) ១ ស្ទឹង (ក្នុងអនភិរតិជាតក) ១ នាងមុទុលក្ខណា (ក្នុងមុទុលក្ខណជាតក) ១ បងប្អូន (ក្នុងឧច្ឆង្គជាតក) ១ ចិត្ត (ក្នុងសាកេតជាតក) ១ ពិស (ក្នុងវិសវន្តជាតក) ១ សេចក្តីឈ្នះប្រពៃ (ក្នុងកុទ្ទាលជាតក) ១ ត្រូវជា ១០។

# វរុណវគ្គ ទី៨

CS sut.kn.jat.v01.08 | ភាគទី ៥៨

(៨. វរុណវគ្គោ)

## វរុណជាតក ទី១

CS sut.kn.jat.071 | ភាគទី ៥៨

(៧១. វរុណជាតកំ)

[៧១] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) អំពើទាំងឡាយ ដែលគេត្រូវធ្វើក្នុងកាលមុន នរៈណា ប្រាថ្នាធ្វើខាងក្រោយវិញ នរៈនោះ រមែងក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយ ដូចជាមាណព ដែលកាច់ឧសឈើថ្លាន់។

ចប់ វរុណជាតក ទី១។

## សីលវនាគជាតក ទី២

CS sut.kn.jat.072 | ភាគទី ៥៨

(៧២. សីលវហត្ថិជាតកំ)

[៧២] (រុក្ខទេវតា ពោលថា) ប្រសិនបើគេឲ្យផែនដីទាំងមូលដល់បុរសអកតញ្ញូ ជាអ្នកឃើញទោសជានិច្ច ក៏មិនគប្បីញ៉ាំងបុរសអកតញ្ញូនោះឲ្យត្រេកអរបានឡើយ។

ចប់ សីលវនាគជាតក ទី២។

## សច្ចង្កិរជាតក ទី៣

CS sut.kn.jat.073 | ភាគទី ៥៨

(៧៣. សច្ចំកិរជាតកំ)

[៧៣] (តាបសពោធិសត្វ ពោលថា) បានឮថា នរៈពួកខ្លះ ក្នុងលោកនេះ បាននិយាយពិតយ៉ាងនេះថា ឧសដែលគេស្រង់ឡើងអំពីទឹក ប្រសើរជាង នរៈពួកខ្លះដែលគេស្រង់ឡើង (អំពីទឹក) មិនប្រសើរឡើយ។

ចប់ សច្ចង្កិរជាតក ទី៣។

## រុក្ខធម្មជាតក ទី៤

CS sut.kn.jat.074 | ភាគទី ៥៨

(៧៤. រុក្ខធម្មជាតកំ)

[៧៤] (រុក្ខទេវតាពោធិសត្វ ពោលថា) មានពួកញាតិច្រើននាក់ ប្រពៃ សូម្បីពួកឈើ ដែលដុះក្នុងព្រៃច្រើនដើម ក៏ប្រពៃដែរ ឯខ្យល់រមែងរំលំនូវឈើជាធំក្នុងព្រៃ បរិបូណ៌ដោយមែក និងប្រគាប ដែលតាំងនៅតែឯង។

ចប់ រុក្ខធម្មជាតក ទី៤។

## មច្ឆជាតក ទី៥

CS sut.kn.jat.075 | ភាគទី ៥៨

(៧៥. មច្ឆជាតកំ)

[៧៥] (ត្រីពោធិសត្វ ពោលថា) បពិត្រមេឃ សូមអ្នកញ៉ាំងផ្គរឲ្យលាន់ឡើង សូមបំផ្លាញកំណប់របស់ក្អែកឲ្យវិនាស សូមធ្វើទុក្ខក្អែកឲ្យសោកសៅ សូមញ៉ាំងខ្ញុំ (និងពួកញាតិខ្ញុំ) ឲ្យរួចចាកសេចក្តីសោក។

ចប់ មច្ឆជាតក ទី៥។

## អសង្កិយជាតក ទី៦

CS sut.kn.jat.076 | ភាគទី ៥៨

(៧៦. អសង្កិយជាតកំ)

[៧៦] (តាបសពោធិសត្វ ពោលថា) យើងជាអ្នកមិនមានសេចក្តីរង្កៀសក្នុងស្រុក យើងជាអ្នកមិនមានភ័យក្នុងព្រៃ បានឡើងកាន់ផ្លូវត្រង់ ដោយមេត្តា និងករុណាហើយ។

ចប់ អសង្កិយជាតក ទី៦។

## មហាសុបិនជាតក ទី៧

CS sut.kn.jat.077 | ភាគទី ៥៨

(៧៧. មហាសុបិនជាតកំ)

[៧៧] (ព្រះរាជា ទ្រង់ត្រាស់ថា មហាសុបិន ១៦ គឺ) គោឡើងកទាំងឡាយ ១ ឈើទាំងឡាយ ១ មេគោទាំងឡាយ ១ គោឈ្មោលទាំងឡាយ ១ សេះ ១ ភាជន៍ (មាស) ១ មេចចក ១ ក្អម ១ ស្រះបោក្ខរណី ១ បាយឆៅ ១ ខ្លឹមចន្ទន៍ ១ ផ្លែឃ្លោកទាំងឡាយលិច ១ ថ្មទាំងឡាយអណ្តែត ១ មេកង្កែបទាំងឡាយខាំពស់វែកទាំងឡាយ ១ រាជហង្សមាសទាំងឡាយចោមរោមក្អែក ១ ខ្លាដំបងទាំងឡាយ (រត់ទៅ) ព្រោះភ្ញាក់ផ្អើល ដោយសេចក្តីខ្លាចអំពីពពែទាំងឡាយ ១ បរិយាយចំឡែកប្រព្រឹត្តទៅ ន័យទាំងឡាយមានក្នុងសុបិនទាំងនេះ។

ចប់ មហាសុបិនជាតក ទី៧។

## ឥល្លិសជាតក ទី៨

CS sut.kn.jat.078 | ភាគទី ៥៨

(៧៨. ឥល្លិសជាតកំ)

[៧៨] (ជាងកោរកាត់ពោធិសត្វ ពោលថា) ជនទាំងពីរនាក់ខ្វក ជនទាំងពីរនាក់ក្ញែង ជនទាំងពីរនាក់មានភ្នែកស្រលៀង ពកកើត (លើក្បាល) របស់ជនទាំងពីរនាក់ ខ្ញុំព្រះអង្គមិនស្គាល់ (អ្នកណា) ជាឥល្លិសសេដ្ឋីទេ។

ចប់ ឥល្លិសជាតក ទី៨។

## ខរស្សរជាតក ទី៩

CS sut.kn.jat.079 | ភាគទី ៥៨

(៧៩. ខរស្សរជាតកំ )

[៧៩] (ពាណិជពោធិសត្វ ពោលថា) កាលណា (ពួកចោរ) ប្លន់សម្លាប់គោទាំងឡាយ ដុតផ្ទះទាំងឡាយ និងនាំជនយកទៅហើយ ក្នុងកាលនោះ កូនរបស់ស្ត្រីដែលមានកូនស្លាប់ហើយ (គឺចៅហ្វាយស្រុកឥតមានសេចក្តីអៀនខ្មាស) វាយស្គរឲ្យមានសំឡេងខ្លាំង ដើរមក។

ចប់ ខរស្សរជាតក ទី៩។

## ភីមសេនជាតក ទី១០

CS sut.kn.jat.080 | ភាគទី ៥៨

(៨០. ភីមសេនជាតកំ)

[៨០] (ចូឡធនុគ្គហបណ្ឌិតពោធិសត្វ ពោលថា) ម្នាលភីមសេន ក្នុងកាលមុន ឯងបានអួតហើយ ក្នុងកាលក្រោយ ស្រាប់តែគ្រឿងសំអុយសម្រាប់ហូរចេញ (អាចម៍) របស់ឯង ហូរចេញមក ហេតុទាំងពីរមិនសមគ្នា គឺការនិយាយអំពីចំបាំង និងការចង្អៀតចង្អល់ចិត្តរបស់ឯងនេះ។

ចប់ ភីមសេនជាតក ទី១០។

ចប់ វរុណវគ្គ ទី៨។

ឧទ្ទាននៃវរុណវគ្គនោះគឺ

និយាយអំពីវរុណជាតក ១ អកតញ្ញូ (ក្នុងសីលវនាគជាតក) ១ ពាក្យពិតដ៏ប្រសើរ (ក្នុងសច្ចង្កិរជាតក) ១ ឈើម្ចាស់ព្រៃ (ក្នុងរុក្ខធម្មជាតក) ១ ការធ្វើឲ្យផ្គរឲ្យលាន់ (ក្នុងមច្ឆជាតក) ១ ករុណា (ក្នុងអសង្កិយជាតក) ១ ថ្នអណ្ដែត (ក្នុងមហាសុបិនជាតក) ១ ឥល្លិសសេដ្ឋី (ក្នុងឥល្លិសជាតក) ១ ស្គរ (ក្នុងខរស្សរជាតក) ១ គ្រឿងសំអុយសម្រាប់ហូរចេញ (ក្នុងភីមសេនជាតក) ១ ត្រូវជា ១០។

## អបាយិម្ហវគ្គ ទី៩

CS sut.kn.jat.v01.09 | ភាគទី ៥៨

(៩. អបាយិម្ហវគ្គោ)

### សុរាបានជាតក ទី១

CS sut.kn.jat.081 | ភាគទី ៥៨

(៨១. សុរាបានជាតកំ)

[៨១] (ពួកតាបស ពោលថា) ពួកយើងបានផឹកសុរា បានរាំ បានច្រៀង បានយំហើយ ពួកយើង មិនមែនជាពានរ ព្រោះតែផឹកសុរា ដែលធ្វើឲ្យខូចសញ្ញា ទើបឃើញ (អាក្រក់ជាល្អ)។

ចប់ សុរាបានជាតក ទី១។

### មិត្តវិន្ទជាតក ទី២

CS sut.kn.jat.082 | ភាគទី ៥៨

(៨២. មិត្តវិន្ទកជាតកំ)

[៨២] (ទេវរាជពោធិសត្វ ពោលថា) អ្នកនោះ កន្លងនូវប្រាសាទកែវផ្លេកផង ប្រាសាទប្រាក់ផង ប្រាសាទកែវមណីផង ជាអ្នកត្រូវថ្ម (គឺចក្រមានមុខមុតដូចកាំបិតកោរ) គ្របសង្កត់ហើយ អ្នកកាលរស់នៅ មិនរួចអំពីចក្រនោះទេ។

ចប់ មិត្តវិន្ទជាតក ទី២។

### កាឡកណ្ណិជាតក ទី៣

CS sut.kn.jat.083 | ភាគទី ៥៨

(៨៣. កាលកណ្ណិជាតកំ)

[៨៣] (មហាយសសេដ្ឋីពោធិសត្វ ពោលថា) បុគ្គលដែលជាមិត្តបាន ដោយ (ហេតុត្រឹមតែដើរជាមួយគ្នា) ប្រាំពីរជំហាន បុគ្គលជាសម្លាញ់បាន ដោយ (ហេតុត្រឹមតែដើរជាមួយគ្នា) ដប់ពីរជំហាន បុគ្គលដែលជាញាតិបាន ដោយ (ការនៅជាមួយគ្នា) មួយខែ ឬកន្លះខែ បុគ្គលដែលទុកស្មើនឹងខ្លួន ព្រោះនៅលើសអំពីកាលនោះទៅទៀត ខ្ញុំនោះនឹងលះបង់នូវសំឡាញ់ឈ្មោះកាឡកណ្ណិ ដែលធ្លាប់ស្និទ្ធស្នាល អស់កាលយូរ ព្រោះហេតុនៃសេចក្ដីសុខរបស់ខ្លួនដូចម្ដេចបាន។

ចប់ កាឡកណ្ណិជាតក ទី៣។

### អត្ថស្សទ្វារជាតក ទី៤

CS sut.kn.jat.084 | ភាគទី ៥៨

(៨៤. អត្ថស្សទ្វារជាតកំ)

[៨៤] (សេដ្ឋីពោធិសត្វជាបិតា ពោលថា) បុគ្គលគប្បីប្រាថ្នាលាភដ៏ឧត្តម គឺការមិនមានរោគ ១ សីល (គឺមារយាទ) ១ ការយល់ឃើញតាមបណ្ឌិតអ្នកដឹង ១ ការឧស្សាហ៍ស្ដាប់ ១ ការអនុវត្តន៍នូវសុចរិតធម៌ ១ ការមិនរួញរានៃចិត្ត ១ ធម៌ទាំង ៦ នេះ ជាទ្វារ ទាំងជាប្រធាននៃសេចក្ដីចំរើន។

ចប់ អត្ថស្ស ទ្វារជាតក ទី៤។

### កិម្បក្កជាតក ទី៥

CS sut.kn.jat.085 | ភាគទី ៥៨

(៨៥. កឹបក្កជាតកំ)

[៨៥] (ព្រះសាស្ដា ទ្រង់ត្រាស់ថា) បុគ្គលណា មិនយល់ទោសក្នុងអនាគត ហើយសេពកាមទាំងឡាយ (កាមទាំងនោះ) តែងសម្លាប់បុគ្គលនោះ ក្នុងទីបំផុតនៃផល ដូចបុគ្គលស៊ីផ្លែឈើកិម្បក្កៈ (ឈើពុល)។

ចប់ កិម្បក្កជាតក ទី៥។

### សីលវីមំសនជាតក ទី៦

CS sut.kn.jat.086 | ភាគទី ៥៨

(៨៦. សីលវីមំសកជាតកំ)

[៨៦] (ព្រាហ្មណ៍បុរោហិតពោធិសត្វ ពោលថា) បានឮថា សីលជាគុណជាតល្អ សីលជាគុណជាតដ៏លើសលុបក្នុងលោក សូមព្រះអង្គទតចុះ ពស់មានពិសដ៏ពន្លឹក មិនបៀតបៀនគេ ឈ្មោះថាជាសត្វមានសីល។

ចប់ សីលវីមំសនជាតក ទី៦។

## មង្គលជាតក ទី៧

CS sut.kn.jat.087 | ភាគទី ៥៨

(៨៧. មង្គលជាតកំ)

[៨៧] [៨៧] (ព្រះសាស្តា ទ្រង់ត្រាស់ថា) មង្គលទាំងឡាយក្តី ឧត្បាតទាំងឡាយក្តី សុបិនទាំងឡាយក្តី លក្ខណៈទាំងឡាយក្តី ដែលបុគ្គលណា បានផ្តាច់បង់ហើយ បុគ្គលនោះ ឈ្មោះថាអ្នកកន្លងផុតនូវទោសនៃមង្គល (ភ្ញាក់ផ្អើល) ជាអ្នកគ្របសង្កត់នូវយុគក្កិលេស [1] និងយោគក្កិលេស [2] រមែងមិនមកកើតទៀត។

ចប់ មង្គលជាតក ទី៧។

## សារម្ភជាតក ទី៨

CS sut.kn.jat.088 | ភាគទី ៥៨

(៨៨. សារម្ភជាតកំ)

[៨៨] (ព្រះសាស្តា ទ្រង់ត្រាស់ថា) បុគ្គលគប្បីបញ្ចេញវាចាល្អតែម្យ៉ាង មិនគប្បីបញ្ចេញវាចាអាក្រក់ឡើយ ការបញ្ចេញវាចាល្អ ជាការប្រពៃ ព្រោះបុគ្គលបញ្ចេញវាចាអាក្រក់ រមែងក្តៅក្រហាយ។

ចប់ សារម្ភជាតក ទី៨។

## កុហកជាតក ទី៩

CS sut.kn.jat.089 | ភាគទី ៥៨

(៨៩. កុហកជាតកំ)

[៨៩] (ឈ្មួញពោធិសត្វ ពោលថា) បានឮថា វាចារបស់អ្នកដែលពោលទន់ភ្លន់ ជាវាចាពីរោះ អ្នកបានជាប់ក្នុងវត្ថុត្រឹមតែស្មៅ ត្រង់នាំផ្គោរមាស ១០០ យកទៅ មិនជាប់សោះ។

ចប់ កុហកជាតក ទី៩។

## អកតញ្ញូជាតក ទី១០

CS sut.kn.jat.090 | ភាគទី ៥៨

(៩០. អកតញ្ញុជាតកំ)

[៩០] (សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលណា មិនដឹងនូវអំពើល្អ ដែលគេធ្វើហើយ នូវប្រយោជន៍ដែលគេធ្វើហើយ ក្នុងកាលមុនទេ បុគ្គលនោះ កាលបើកិច្ចកើតព្រមហើយ ក្នុងកាលខាងក្រោយ រមែងមិនបាននូវបុគ្គលអ្នកធ្វើ (ឧបការគុណមុននោះជាគ្នា) ឡើយ។

ចប់ អកតញ្ញូជាតក ទី១០។

ចប់ អបាយិម្ហវគ្គ ទី៩។

ឧទ្ទាននៃអបាយិម្ហវគ្គនោះគឺ

យើងបានផឹកសុរា (ក្នុងសុរាបានជាតក) ១ ប្រាសាទកែវមណី (ក្នុងមិត្តវិន្ទជាតក) ១ ៧ជំហាន (ក្នុងកាឡកណ្ណិជាតក) ១ ធម៌ ៦ (ក្នុងអត្ថស្សទ្វារជាតក) ១ ទោសក្នុងអនាគត (ក្នុងកិម្បកជាតក) ១ ពស់មានសីល (ក្នុងសីលវីមំសជាតក) ១ ការប្រកាន់មង្គល (ក្នុងមង្គលជាតក) ១ វាចាលាមក (ក្នុងសារម្ភជាតក) ១ ផ្គោរមាស ១០០ (ក្នុងកុហកជាតក) ១ ប្រយោជន៍ ដែលគេធ្វើតបវិញ (ក្នុងអកតញ្ញូជាតក) ១ ត្រូវជា ១០។

# លិត្តវគ្គ ទី១០

CS sut.kn.jat.v01.10 | ភាគទី ៥៨

(១០. លិត្តវគ្គោ)

## លិត្តជាតក ទី១

CS sut.kn.jat.091 | ភាគទី ៥៨

(៩១. លិត្តជាតកំ)

[៩១] (អ្នកលេងស្កាពោធិសត្វ ពោលថា) បុរសកាលលេបនូវកូនស្កាប្រឡាក់ដោយថ្នាំពិស មានតេជៈដ៏ខ្លាំង ក៏មិនដឹងខ្លួន ម្នាលអ្នកចង្រៃ អ្នកចូរលេបទៅ នែអ្នកលេងអាក្រក់ អ្នកចូរលេបទៅ ពិសដ៏ផ្សាក្តៅ នឹងមានដល់អ្នក ក្នុងកាលជាខាងក្រោយ។

ចប់ លិត្តជាតក ទី១។

## មហាសារជាតក ទី២

CS sut.kn.jat.092 | ភាគទី ៥៨

(៩២. មហាសារជាតកំ)

[៩២] (ព្រះរាជា ទ្រង់ត្រាស់ថា) ក្នុងកាលសង្គ្រាមកើតឡើង ពួកជនរមែងប្រាថ្នានូវបុរសអ្នកក្លៀវក្លា ក្នុងពួកអ្នកប្រឹក្សាការ គេប្រាថ្នានូវបុរសអ្នកមានវាចាមិនរោយរាយ ក្នុងកាលមានបាយទឹកឆ្ងាញ់ គេប្រាថ្នានូវបុរសជាទីស្រឡាញ់ ក្នុងកាលអាថ៌ (កំបាំង) កើតឡើង គេប្រាថ្នានូវបណ្ឌិត។

ចប់ មហាសារជាតក ទី២។

## វិស្សាសភោជនជាតក ទី៣

CS sut.kn.jat.093 | ភាគទី ៥៨

(៩៣. វិសាសភោជនជាតកំ)

[៩៣] (សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលមិនគប្បីស្និទ្ធស្នាលក្នុងបុគ្គលដែលមិនធ្លាប់ស្និទ្ធស្នាល មិនគប្បីស្និទ្ធស្នាលក្នុងបុគ្គល សូម្បីធ្លាប់ស្និទ្ធស្នាលហើយ ភ័យរមែងទៅតាមបុគ្គលនោះ ព្រោះសេចក្តីស្និទ្ធស្នាល ដូចជាភ័យដែលជាប់តាមនូវសត្វសីហៈ ព្រោះមេម្រឹគ។

ចប់ វិស្សាសភោជនជាតក ទី៣។

## លោមហំសជាតក ទី៤

CS sut.kn.jat.094 | ភាគទី ៥៨

(៩៤. លោមហំសជាតកំ)

[៩៤] (អាជីវកពោធិសត្វ ពោលថា) អាត្មាអញ ក្តៅណាស់ហើយ ត្រជាក់ណាស់ហើយ នៅតែម្នាក់ឯង ក្នុងព្រៃគួរខ្លាច ជាមនុស្សអាក្រាត ទាំងមិនអាំងភ្លើង ជាអ្នកខ្វល់ខ្វាយក្នុងការស្វែងរក (នូវព្រហ្មចរិយធម៌) ប្រតិបត្តិ ដើម្បីមោនៈ។

ចប់ លោមហំសជាតក ទី៤។

## មហាសុទស្សនជាតក ទី៥

CS sut.kn.jat.095 | ភាគទី ៥៨

(៩៥. មហាសុទស្សនជាតកំ)

[៩៥] (ព្រះពោធិសត្វ ពោលថា) សង្ខារទាំងឡាយមិនទៀងទេ មានការកើតឡើង និងសូន្យទៅជាធម្មតា (ព្រោះ) កើតឡើងហើយ តែងរលត់ទៅវិញ ការរម្ងាប់សង្ខារទាំងនោះបាន ទើបនាំមកនូវសេចក្តីសុខ។

ចប់ មហាសុទស្សនជាតក ទី៥។

## តេលបត្តជាតក ទី៦

CS sut.kn.jat.096 | ភាគទី ៥៨

(៩៦. តេលបត្តជាតកំ)

[៩៦] (ព្រះសាស្តា ទ្រង់ត្រាស់ថា) បុគ្គលគប្បីនាំទៅនូវភាជន៍ប្រេង ដែលពេញត្រឹមកណ្តាប់មាត់ មិនឲ្យស្រក់ទៅបាន យ៉ាងណាមិញ (ព្រះយោគាវចរ) កាលប្រាថ្នានូវទិសដែលខ្លួនមិនធ្លាប់ទៅ គឺព្រះនិព្វាន គប្បីរក្សានូវចិត្តរបស់ខ្លួន (ដោយសតិ) យ៉ាងនោះដែរ។

ចប់ តេលបត្តជាតក ទី៦។

## នាមសិទ្ធិជាតក ទី៧

CS sut.kn.jat.097 | ភាគទី ៥៨

(៩៧. នាមសិទ្ធិជាតកំ)

[៩៧] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) មាណពឈ្មោះបាបកៈ បានឃើញបុរសរស់ ហើយស្លាប់ផង ឃើញទាសីឈ្មោះនាងរក្សាទ្រព្យ ហើយខ្សត់ទ្រព្យផង ឃើញបុរសអ្នកដើរផ្លូវ ហើយវង្វេងក្នុងព្រៃផង មកវិញហើយ។

ចប់ នាមសិទ្ធិជាតក ទី៧។

## កូដវាណិជជាតក ទី៨

CS sut.kn.jat.098 | ភាគទី ៥៨

(៩៨. កូដវាណិជជាតកំ)

[៩៨] (បិតារបស់អតិបណ្ឌិតពាណិជ ពោលថា) បុគ្គលដែលឈ្មោះថាបណ្ឌិត ជាអ្នកប្រពៃពិត ឯបុគ្គលឈ្មោះថាអតិបណ្ឌិត មិនប្រពៃទេ អាត្មាអញ ត្រូវភ្លើងរោល ព្រោះតែកូនឈ្មោះអតិបណ្ឌិត។

ចប់ កូដវាណិជជាតក ទី៨។

## បរោសហស្សជាតក ទី៩

CS sut.kn.jat.099 | ភាគទី ៥៨

(៩៩. បរោសហស្សជាតកំ)

[៩៩] (មហាព្រហ្មពោធិសត្វ ពោលថា) ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងពាន់នាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីកន្ទក់កន្ទេញអស់ ១០០ ឆ្នាំ បុរសណា ប្រកបដោយប្រាជ្ញា បានដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ នៅតែម្នាក់ឯង ប្រសើរជាង។

ចប់ បរោសហស្សជាតក ទី៩។

## អសាតរូបជាតក ទី១០

CS sut.kn.jat.100 | ភាគទី ៥៨

(១០០. អសាតរូបជាតកំ)

[១០០] (ព្រះសាស្តា ទ្រង់ត្រាស់ថា) របស់មិនឆ្ងាញ់ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់ឆ្ងាញ់ របស់មិនគួរស្រឡាញ់ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃរបស់គួរស្រឡាញ់ សេចក្តីទុក្ខ រមែងគ្របសង្កត់នូវបុគ្គលប្រមាទ ដោយសភាពនៃសេចក្តីសុខ។

ចប់ អសាតរូបជាតក ទី១០។

ចប់ លិត្តវគ្គ ទី១០។

ចប់ មជ្ឈិមបណ្ណាសកៈ។

ឧទ្ទាននៃលិត្តវគ្គនោះគឺ

និយាយអំពីការលេបកូនស្កា (ក្នុងលិត្តជាតក) ១ បុរសមានវាចាមិនពោយពាយ (ក្នុងមហាសារជាតក) ១ មេម្រឹគ (ក្នុងវិស្សាសភោជនជាតក) ១ ប្រតិបត្តិដើម្បីមោនៈ (ក្នុងលោមហំសជាតក) ១ សង្ខារមិនទៀង (ក្នុងមហាសុទស្សនជាតក) ១ ភាជន៍ប្រេង (ក្នុងតេលបត្តជាតក) ១ ទាសីឈ្មោះនាងរក្សាទ្រព្យ (ក្នុងនាមសិទ្ធិជាតក) ១ អតិបណ្ឌិតពាណិជ (ក្នុងកូដវាណិជជាតក) ១ ជនជាងពាន់នាក់ (ក្នុងបរោសហស្សជាតក) ១ របស់មិនឆ្ងាញ់ (ក្នុងអសាតរូបជាតក) ១ ត្រូវជា ១០។

# បរោសតវគ្គ ទី១១

CS sut.kn.jat.v01.11 | ភាគទី ៥៨

(១១. បរោសតវគ្គោ)

## បរោសតជាតក ទី១

CS sut.kn.jat.101 | ភាគទី ៥៨

(១០១. បរោសតជាតកំ)

[១០១] ជនទាំងឡាយមកប្រជុំគ្នាហើយ សូម្បីជាងរយនាក់ ជនទាំងនោះឥតប្រាជ្ញា គប្បីពិចារណា (នូវអត្ថនៃភាសិត) អស់ ១០០ ឆ្នាំ បុរសណា ប្រកបដោយប្រាជ្ញា ដឹងច្បាស់នូវអត្ថនៃភាសិត បុរសនោះ នៅតែម្នាក់ឯងប្រសើរវិញ។

ចប់ បរោសតជាតក ទី១។

## បណ្ណិកជាតក ទី២

CS sut.kn.jat.102 | ភាគទី ៥៨

(១០២. បណ្ណិកជាតកំ)

[១០២] (កូនស្រីរបស់ឧបាសក ពោលថា) បុគ្គលណា គប្បីជាទីពឹងរបស់ខ្ញុំ ដែលមានទុក្ខពាល់ត្រូវហើយ បុគ្គលនោះឈ្មោះថាជាបិតារបស់ខ្ញុំ នឹងធ្វើនូវការប្រទូស្តក្នុងព្រៃ ខ្ញុំនោះកន្ទក់កន្ទេញ ក្នុងកណ្តាលព្រៃ ដើម្បីបុគ្គលដូចម្តេច បុគ្គលណា ជាអ្នករក្សា បុគ្គលនោះនឹងធ្វើនូវកម្មដ៏ខ្លាំងក្លា (មេថុន)។

ចប់ បណ្ណិកជាតក ទី២។

## វេរិជាតក ទី៣

CS sut.kn.jat.103 | ភាគទី ៥៨

(១០៣. វេរិជាតកំ)

[១០៣] (សេដ្ឋីពោធិសត្វ ពោលថា) បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា អ្នកប្រាជ្ញមិនគប្បីនៅក្នុងទីនោះ បុគ្គលនៅក្នុងសំណាក់នៃបុគ្គលមានពៀរអស់មួយរាត្រី ឬពីររាត្រី ក៏នាំមកនូវសេចក្ដីទុក្ខ។

ចប់ វេរិជាតក ទី៣។

## មិត្តវិន្ទជាតក ទី៤

CS sut.kn.jat.104 | ភាគទី ៥៨

(១០៤. មិត្តវិន្ទកជាតកំ)

[១០៤] (ទេវបុត្រពោធិសត្វ ពោលថា) អ្នក (ចេញ) អំពីវិមានិកប្រេត ៤ បានវិមានិកប្រេត ៨ (ចេញ) អំពីវិមានិកប្រេត ៨ បានវិមានិកប្រេត ១៦ (ចេញ) អំពីវិមានិកប្រេត ១៦ បានវិមានិកប្រេត ៣២ (ក៏នៅតែមិនស្កប់ស្កល់) ចក្រក៏វិលលើក្បាលនៃបុរស កាលប្រាថ្នា ក្នុងទីនោះ ៗ ទើបមកដល់កង់ចក្រ កង់ចក្រ រមែងវិលលើក្បាលបុគ្គលដែលមានសេចក្ដីប្រាថ្នាគ្របសង្កត់។

ចប់ មិត្តវិន្ទជាតក ទី៤។

## ទុព្វលកដ្ឋជាតក ទី៥

CS sut.kn.jat.105 | ភាគទី ៥៨

(១០៥. ទុព្វលកដ្ឋជាតកំ)

[១០៥] (រុក្ខទេវតាពោធិសត្វ ពោលថា) ឈើគ្រាំគ្រា ដែលខ្យល់កាច់បំបាក់បានក្នុងព្រៃនោះ មានច្រើន ម្នាលដំរី ប្រសិនបើអ្នកខ្លាចឈើនោះ អ្នកមុខជានឹងស្គមមិនខាន។

ចប់ ទុព្វលកដ្ឋជាតក ទី៥។

## ឧទញ្ចនីជាតក ទី៦

CS sut.kn.jat.106 | ភាគទី ៥៨

(១០៦. ឧទញ្ចនីជាតកំ)

[១០៦] (កូនតាបសពោធិសត្វ ពោលថា) មេចោរដុតចំអិន ល្មោភស៊ី ដូចជាភាជន៍ដងនូវទឹក រមែងសូមនូវប្រេងផង នូវអំបិលផង នឹងខ្ញុំដែលធ្លាប់រស់នៅជាសុខ ដោយសំដីហាក់ដូចជាប្រពន្ធ។

ចប់ ឧទញ្ចនីជាតក ទី៦។

## សាលិត្តកជាតក ទី៧

CS sut.kn.jat.107 | ភាគទី ៥៨

(១០៧. សាលិត្តកជាតកំ)

[១០៧] (អាមាត្យពោធិសត្វ ពោលថា) ធម្មតា សិល្បសាស្ត្រយ៉ាងណាក៏ដោយ សុទ្ធតែសំរេចប្រយោជន៍ សូមព្រះអង្គទត ស្រុកសួយទាំង ៤ ទិស ដែលបុរសខ្វិនបានហើយ ដោយការផ្ទាត់ (អាចម៍ពពែ) នៃបុរសខ្វិន។

ចប់ សាលិត្តកជាតក ទី៧។

## ពាហិយជាតក ទី៨

CS sut.kn.jat.108 | ភាគទី ៥៨

(១០៨. ពាហិយជាតកំ)

[១០៨] (អាមាត្យពោធិសត្វ ពោលថា) ជនគប្បីសិក្សានូវកិច្ចដែលត្រូវសិក្សា ពួកជន រមែងមានសេចក្ដីពេញចិត្តក្នុងកិច្ចនោះ ចំណែកស្រីអ្នកស្រុកពាហិយៈ បានញុំាងព្រះរាជាឲ្យត្រេកអរ ដោយការខ្មាសអៀន (របស់ខ្លួន)។

ចប់ ពាហិយៈជាតក ទី៨។

## កណ្ឌកបូវជាតក ទី៩

CS sut.kn.jat.109 | ភាគទី ៥៨

(១០៩. កុណ្ឌបូវជាតកំ)

[១០៩] (រុក្ខទេវតាពោធិសត្វ ពោលថា) បុរសស៊ីយ៉ាងណា ទេវតារបស់បុរសនោះ ក៏ស៊ីយ៉ាងនោះដែរ អ្នកចូរនាំយកនូវនំកុណ្ឌកនុំះមក អ្នកកុំញុំាងនំកុណ្ឌក ជាចំណែករបស់ខ្ញុំឲ្យវិនាសទៅ។

ចប់ កុណ្ឌកបូវជាតក ទី៩។

## សព្វស័ហារកបញ្ហា ទី១០

CS sut.kn.jat.110 | ភាគទី ៥៨

(១១០. សព្វសំហារកបញ្ហជាតកំ)

[១១០] គ្រឿងអប់ទាំងពួងគ្មានទេ សុទ្ធតែផ្កាប្រយង្គុទេតើ បក់ផ្សាយទៅ (នោះ) ឯស្រ្តីអ្នកលេង រមែងពោលពាក្យមិនពិត ស្រ្តីចាស់ទើបបានពោលពាក្យពិត។

ចប់ សព្វសំហារកបញ្ហា ទី១០។

ចប់ បរោសតវគ្គ ទី១១។

ឧទ្ទាននៃបរោសតវគ្គនោះគឺ

និយាយអំពីបុគ្គលជាងមួយរយ ១ បុគ្គលជាទីពឹង ១ បុគ្គលមានពៀរ ១ ចក្រវិល ១ ដំរីប្រសើរ ១ រស់នៅជាសុខ ១ សិល្បៈ ១ ស្រីអ្នកស្រុកពាហិយៈ ១ នំកុណ្ឌក ១ ស្រីចាស់ ១ ត្រូវជា ១០។

## ហំសិវគ្គ ទី១២

CS sut.kn.jat.v01.12 | ភាគទី ៥៨

(១២. ហំចិវគ្គោ)

## គទ្រភបញ្ហា ទី១

CS sut.kn.jat.111 | ភាគទី ៥៨

(១១១. គទ្រភបញ្ហជាតកំ)

[១១១] បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គរីករាយ រមែងសំគាល់ថា បិតាប្រសើរជាងកូនយ៉ាងនេះ បើដូច្នោះ មានតែសត្វលារបស់ព្រះអង្គនេះ ប្រសើរជាងសេះអស្សតរ ព្រោះសត្វលាជាបានៃសេះអស្សតរ។

ចប់ គទ្រភបញ្ហា ទី១។

## អមរាទេវិបញ្ហា ទី២

CS sut.kn.jat.112 | ភាគទី ៥៨

(១១២. អមរាទេវីបញ្ហជាតកំ)

[១១២] (បពិត្រអ្នកម្ចាស់) រានផ្សារដែលគេលក់សដូវ និងម្សូវ និងដើមរលួសមានស្លឹកពីរជាន់ មាននៅក្នុងទិសាភាគណា ខ្ញុំកាន់បបរដោយដៃណា ខ្ញុំម្ចាស់ប្រាប់ផ្លូវដោយដៃនោះ ខ្ញុំមិនបានកាន់បបរដោយដៃណា ខ្ញុំមិនប្រាប់ផ្លូវដោយដៃនោះទេ ទិសាភាគនុ៎ះឯងហើយ ជាផ្លូវនៃយាវមជ្ឈគ្រាម អ្នកចូរដឹងផ្លូវដ៏កំបាំងនុ៎ះចុះ។

ចប់ អមរាទេវិបញ្ហា ទី២។

## សិគាលជាតក ទី៣

CS sut.kn.jat.113 | ភាគទី ៥៨

(១១៣. សិង្គាលជាតកំ)

[១១៣] (រុក្ខទេវតាពោធិសត្វ ពោលថា) ម្នាលព្រាហ្មណ៍ អ្នកជឿពាក្យចចកដែលផឹកសុរាដូចម្តេចបាន (សូម្បីសម្បក) ខ្យងចំនួនមួយរយមិនមានទេ តើកហាបណៈ ពីររយ នឹងមានមកអំពីទីណា។

ចប់ សិគាលជាតក ទី៣។

## មិតចិន្តិជាតក ទី៤

CS sut.kn.jat.114 | ភាគទី ៥៨

(១១៤. មិតចិន្តិជាតកំ)

[១១៤] (ព្រះសាស្តា ត្រាស់ថា) ត្រីឈ្មោះពហុចិន្តី និងអប្បចិន្តី ១ ទាំងពីរ បានជាប់នៅក្នុងសំណាញ់ ត្រីឈ្មោះមិតចិន្តី បានដោះឲ្យរួចខ្លួន ត្រីទាំងពីរ បានជួបគ្នាក្នុងទឹកនោះ។

ចប់ មិតចិន្តិជាតក ទី៤។

## អនុសាសិកជាតក ទី៥

CS sut.kn.jat.115 | ភាគទី ៥៨

(១១៥. អនុសាសិកជាតកំ )

[១១៥] (បក្សីជាធំពោធិសត្វ ពោលថា) មេបក្សីណា ប្រៀនប្រដៅនូវបក្សីដទៃ តែជាអ្នកប្រព្រឹត្តលោភដោយខ្លួនឯង មេបក្សីនោះ ដេកបាក់ស្លាប ដូចជាសត្វសាលិកា ដែលកង់កិនហើយ។

ចប់ អនុសាសិកជាតក ទី៥។

## ទុព្វចជាតក ទី៦

CS sut.kn.jat.116 | ភាគទី ៥៨

(១១៦. ទុព្វចជាតកំ)

[១១៦] (កូនសិស្សពោធិសត្វ ពោលថា) បពិត្រលោកអាចារ្យ អំពើដែលធ្វើជ្រុលនេះ មិនគាប់ចិត្តខ្ញុំទេ លោកលោតបានតែផ្លែលំពែងទី៤ ហើយត្រូវលំពែងទី ៥ មុតហើយ។

ចប់ ទុព្វចជាតក ទី៦។

## តិត្តិរជាតក ទី៧

CS sut.kn.jat.117 | ភាគទី ៥៨

(១១៧. តិត្តិរជាតកំ)

[១១៧] (តាបសពោធិសត្វ ពោលថា) វាចាដែលខ្ពស់ហួស ខ្លាំងហួស ពោលហួសកាលវេលា រមែងសម្លាប់បុគ្គលពាល អ្នកឥតបញ្ញា ដូចជាវាចាដែលសម្លាប់នូវសត្វទទាដែលរងាវហួស។

ចប់ តិត្តិរជាតក ទី៧។

## វដ្តកជាតក ទី៨

CS sut.kn.jat.118 | ភាគទី ៥៨

(១១៨. វដ្តកជាតកំ)

[១១៨] (ចាបពោធិសត្វ ពោលថា) បុរសកាលមិនបានរិះគិត រមែងមិនបានសម្រេចនូវគុណវិសេសឡើយ អ្នកចូរឃើញផលនៃឧបាយដែលខ្ញុំគិតហើយ ព្រោះខ្ញុំរួចអំពីសេចក្តីស្លាប់នឹងចំណង។

ចប់ វដ្តកជាតក ទី៨។

## អកាលរាវិជាតក ទី៩

CS sut.kn.jat.119 | ភាគទី ៥៨

(១១៩. អកាលរាវិជាតកំ)

[១១៩] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) មាន់នេះ ចំរើននៅក្នុងសំណាក់នៃបុគ្គលមិនមែនជាមាតាបិតា កាលនៅក្នុងត្រកូលនៃបុគ្គលមិនមែនជាអាចារ្យ រមែងមិនដឹងច្បាស់នូវកាលគួររងាវ ឬកាលមិនគួររងាវ។

ចប់ អកាលរាវិជាតក ទី៩។

## ពន្ធនមោក្ខជាតក ទី១០

CS sut.kn.jat.120 | ភាគទី ៥៨

(១២០. ពន្ធនមោក្ខជាតកំ )

[១២០] (បុរោហិតពោធិសត្វ ពោលថា) ជនពាលទាំងឡាយ ពោលក្នុងទីណា ពួកជនដែលមិនទាន់ជាប់ រមែងជាប់នៅក្នុងទីនោះ អ្នកប្រាជ្ញទាំងឡាយ ពោលក្នុងទីណា ពួកជនសូម្បីជាប់ហើយ រមែងរួចក្នុងទីនោះ។

ចប់ ពន្ធនមោក្ខជាតក ទី១០។

ចប់ ហំសិវគ្គ ទី១២។

ឧទ្ទាននៃហំសិវគ្គនោះគឺ

និយាយអំពីគទ្រភបញ្ហា ១ សង្ខរ ១ រយកហាបណៈ ១ ត្រីឈ្មោះពហុចិន្តិ ១ មេបក្សី ១ អំពើដែលធ្វើជ្រុល ១ ហួសវេលា ១ គុណវិសេស ១ មាន់គ្មានអាចារ្យ ១ អ្នកប្រាជ្ញពោល ១ ត្រូវជា ១០។

## កុសនាឡិវគ្គ ទី១៣

CS sut.kn.jat.v01.13 | ភាគទី ៥៨

(១៣. កុសនាឡិវគ្គោ)

## កុសនាឡិជាតក ទី១

CS sut.kn.jat.121 | ភាគទី ៥៨

(១២១. កុសនាឡិជាតកំ)

[១២១] (រុក្ខទេវតា ពោលថា) ជនស្មើគ្នាក្តី ទាំងជនប្រសើរជាងក្តី គប្បីធ្វើ (នូវមិត្តធម៌) សូម្បីជនម្នាក់ជាអ្នកថោកទាប ក៏គប្បីធ្វើ (នូវមិត្តធម៌ដែរ) ព្រោះមិត្តទាំងនោះ គប្បីធ្វើនូវប្រយោជន៍ដ៏ឧត្តមក្នុងកាលដែលមានសេចក្តីវិនាស ដូចជាខ្ញុំជាទេវតា ឈ្មោះកុសនាឡិ និងទេវតាឈ្មោះរុចា ធ្វើនូវប្រយោជន៍ដ៏ឧត្តម (ក្នុងកាលដែលមានសេចក្តីវិនាស)។

ចប់ កុសនាឡិជាតក ទី១។

## ទុម្មេធជាតក ទី២

CS sut.kn.jat.122 | ភាគទី ៥៨

(១២២. ទុម្មេធជាតកំ)

[១២២] (ទ្រម័កដំរី ពោលថា) បុគ្គលឥតប្រាជ្ញា បានយសបរិវារហើយ តែងប្រព្រឹត្តនូវកម្មមិនជាប្រយោជន៍ដល់ខ្លួន ទាំងប្រតិបត្តិ ដើម្បីបៀតបៀនដល់ខ្លួនឯងផង ដល់ជនទាំងឡាយដទៃផង។

ចប់ ទុម្មេធជាតក ទី២។

## នង្គលីសជាតក ទី៣

CS sut.kn.jat.123 | ភាគទី ៥៨

(១២៣. នង្គលីសជាតកំ)

[១២៣] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលពាល រមែងពោលនូវវាចាដែលមិនទៅក្នុងវត្ថុទាំងពួង ក្នុងទីទាំងពួង មាណពនេះ មិនស្គាល់ទឹកដោះជូរ មិនស្គាល់ចន្ទោលនង្គ័លឡើយ ទើបសំគាល់នូវទឹកដោះជូរ និងទឹកដោះស្រស់ ថាជាចន្ទោលនៃនង្គ័លទៅវិញ។

ចប់ នង្គលីសជាតក ទី៣។

## អម្ពជាតក ទី៤

CS sut.kn.jat.124 | ភាគទី ៥៨

(១២៤. អម្ពជាតកំ)

[១២៤] (តាបសពោធិសត្វ ពោលថា) បុរសជាបណ្ឌិត គប្បីប្រឹងប្រែង មិនគប្បីធុញទ្រាន់ឡើយ អ្នកចូរឃើញផលនៃសេចក្តីព្យាយាមដ៏ជាក់ស្តែង (ព្រោះ) ផ្លែស្វាយទាំងឡាយជាដើម ដែលពួកឥសីបរិភោគហើយ។

ចប់ អម្ពជាតក ទី៤។

## កដាហកជាតក ទី៥

CS sut.kn.jat.125 | ភាគទី ៥៨

(១២៥. កដាហកជាតកំ)

[១២៥] (ធីតានៃសេដ្ឋី ពោលថា) ទាសៈឈ្មោះកដាហកៈនោះ ទៅកាន់ជនបទដទៃ ពោលអួតនូវពាក្យច្រើន សេដ្ឋីជាម្ចាស់មកតាម (ម្តងទៀត) គប្បីប្រទូស្តមិនខាន ម្នាលកដាហកៈ អ្នកចូរបរិភោគនូវភោគៈទាំងឡាយទៅ។

ចប់ កដាហកជាតក ទី៥។

## អសិលក្ខណជាតក ទី៦

CS sut.kn.jat.126 | ភាគទី ៥៨

(១២៦. អសិលក្ខណជាតកំ)

[១២៦] (ព្រះរាជាពោធិសត្វ ពោលថា) ការកណ្តាស់នោះ របស់បុគ្គលខ្លះល្អ ការកណ្តាស់នោះ របស់បុគ្គលខ្លះអាក្រក់ ហេតុនោះ ការកណ្តាស់ មិនមែនល្អទាំងអស់ មិនមែនអាក្រក់ទាំងអស់ទេ។

ចប់ អសិលក្ខណជាតក ទី៦។

## កលណ្ឌុកជាតក ទី៧

CS sut.kn.jat.127 | ភាគទី ៥៨

(១២៧. កលណ្ឌុកជាតកំ)

[១២៧] (កូនសេក ពោលថា) នោះជាប្រទេស នោះជាទីកន្លែង (គឺផ្ទៃនៃទាសី) សូម្បីខ្ញុំជាសត្វគោចរក្នុងព្រៃ (គង់ដឹងដំណើរទនុំះម្ចាស់ទាំងឡាយរបស់អ្នក) រកឃើញហើយ ចាប់អ្នកមិនខាន ម្នាលកលណ្ឌុកៈ អ្នកចូរផឹកនូវទឹកដោះ។

ចប់ កលណ្ឌុកជាតក ទី៧។

## មូសិកជាតក ទី៨

CS sut.kn.jat.128 | ភាគទី ៥៨

(១២៨. ពិឡារវតជាតកំ)

[១២៨] (កណ្ដុរពោធិសត្វ ពោលថា) បុគ្គលអ្នកបិទបាំងទោសណា ធ្វើនូវធម៌ឲ្យជាទង់ជ័យ ញុំាងសត្វទាំងឡាយឲ្យទុកចិត្ត ហើយប្រព្រឹត្តនូវអំពើអាក្រក់ វត្តរបស់បុគ្គលនោះ ឈ្មោះថាពិឡារវត្ត (វត្តឆ្មា)។

ចប់ មូសិកជាតក ទី៨។

## អគ្គិកជាតក ទី៩

CS sut.kn.jat.129 | ភាគទី ៥៨

(១២៩. អគ្គិកភារទ្វាជជាតកំ)

[១២៩] (កណ្ដុរពោធិសត្វ ពោលថា) កំប៉ោយនេះ មិនមែនមាន ព្រោះហេតុនៃបុណ្យទេ កំប៉ោយនេះមាន ព្រោះហេតុតែគ្រឿងបរិភោគ ការរាប់ដោយកន្ទុយ រមែងប្រព្រឹត្តទៅ នៃអគ្គិកៈ ការនៅរួមគ្នា គួរដល់អ្នកហើយ។

ចប់ អគ្គិកជាតក ទី៩។

## កោសិយជាតក ទី១០

CS sut.kn.jat.130 | ភាគទី ៥៨

(១៣០. កោសិយជាតកំ)

[១៣០] (ព្រាហ្មណ៍ជាប្ដី ពោលថា) នាងចូរបរិភោគឲ្យដូចជាសំដី ចូរលេប (ថ្នាំ) ឲ្យដូចជាបាយដែលនាងស៊ីហើយ ម្នាលព្រាហ្មណីជាកោសិយគោត្រ (ព្រោះ) វាចា និងភត្តដែលនាងបរិភោគហើយទាំងពីរ (នេះ) មិនស្មើគ្នាទេ។

ចប់ កោសិយជាតក ទី១០។

ចប់ កុសនាឡិវគ្គ ទី១៣។

ឧទ្ទាននៃកុសនាឡិវគ្គនោះគឺ

និយាយអំពីកុសនាឡិជាតក ១ យស ១ ទឹកដោះជូរ ១ ស្វាយ ១ ទាសៈឈ្មោះកដាហកៈ ជាគំរប់ប្រាំ ១ ទឹកដោះស្រស់ ១ វិឡារវត្ត ១ ចចកមានកំប៉ោយ ១ កណ្ដាស់អាក្រក់ ១ ព្រាហ្មណីជាកោសិយគោត្រ ១ ត្រូវជា ១០។

# អសម្បទានវគ្គ ទី១៤

CS sut.kn.jat.v01.14 | ភាគទី ៥៨

(១៤. អសម្បទានវគ្គោ)

## អសម្បទានជាតក ទី១

CS sut.kn.jat.131 | ភាគទី ៥៨

(១៣១. អសម្បទានជាតកំ)

[១៣១] (សេដ្ឋីពោធិសត្វ ពោលថា) ការរាប់អានទាំងឡាយ របស់ជនពាល រមែងទៅជាទោស ព្រោះតែមិនទទួលនូវវត្ថុ តាមមានតាមបាន ព្រោះហេតុនោះ បានជាយើងខ្ញុំនាំយកសំដីស្រូវកន្លះ មានៈ (៤ នាឡិ) មក កុំឲ្យការមេត្រីរាប់អានរបស់យើង បែកបាក់ទៅឡើយ សូមឲ្យការមេត្រីរាប់អាននេះ នៅទៀងទាត់។

ចប់ អសម្បទានជាតក ទី១។

## បញ្ចភិរុកជាតក ទី២

CS sut.kn.jat.132 | ភាគទី ៥៨

(១៣២. ភីរុកជាតកំ)

[១៣២] (ព្រះរាជាពោធិសត្វ ពោលថា) យើងមិនបានលុះក្នុងអំណាចនៃពួកយក្ខិនីឡើយ ព្រោះមានសេចក្ដីព្យាយាមដ៏មាំ ក្នុងឧបាយគ្រឿងណែនាំរបស់ព្រះបច្ចេកពុទ្ធ ជាអ្នកឈ្លាសផង ព្រោះភាពជាអ្នកគ្របសង្កត់សេចក្ដីខ្លាច និងសេចក្ដីតក់ស្លុតផង សុវត្ថិភាពចាកភ័យដ៏ធំនោះ មានដល់ខ្ញុំ។

ចប់ បញ្ចភិរុកជាតក ទី២។

## យតាសនជាតក ទី៣

CS sut.kn.jat.133 | ភាគទី ៥៨

(១៣៣. យតាសនជាតកំ)

[១៣៣] (ស្តេចបក្សីពោធិសត្វ ពោលថា) សេចក្តីក្សេមក្សាន្ត មាននៅលើខ្នងទឹកណា លើខ្នងទឹកនោះ មានសត្រូវកើតហើយ ព្រោះភ្លើងឆេះត្រង់ពាក់កណ្តាលនៃទឹក ទីអាស្រ័យនៅ (នៃពួកយើង) លើដើមឈើ (ដែលដុះ) លើផែនដីធំ ក្នុងថ្ងៃនេះគ្មានទេ អ្នកទាំងឡាយចូរទៅកាន់ទិសដទៃទៀតទៅ ថ្ងៃនេះភ័យកើតឡើងដល់យើងទាំងឡាយ អំពីឈើជាទីពឹងហើយ។

ចប់ យតាសនជាតក ទី៣។

## ឈានសោធនជាតក ទី៤

CS sut.kn.jat.134 | ភាគទី ៥៨

(១៣៤. ឈានសោធនជាតកំ)

[១៣៤] (មហាព្រហ្មពោធិសត្វ ពោលថា) ពួកសត្វណា មានសញ្ញា ពួកសត្វនោះ ក៏ទុគ៌ត (មិនបានសមាបត្តិ) ពួកសត្វណា មិនមានសញ្ញា ពួកសត្វនោះក៏ទុគ៌ត អ្នកចូរវៀរនូវសត្វទាំងពីរពួកនោះចេញ សុខដែលកើតអំពីសមាបត្តិនោះ ឈ្មោះថា មិនមានទីទួល គឺកិលេសឡើយ។

ចប់ ឈានសោធនជាតក ទី៤។

## ចន្ទាភជាតក ទី៥

CS sut.kn.jat.135 | ភាគទី ៥៨

(១៣៥. ចន្ទាភជាតកំ)

[១៣៥] (មហាព្រហ្មពោធិសត្វ ពោលថា) បុគ្គលណា ក្នុងលោកនេះ បាននូវកសិណ មានពន្លឺដូចព្រះចន្ទ (ឱទាតកសិណ) មានពន្លឺដូចព្រះអាទិត្យ (បីតកសិណ) ដោយបញ្ញា បុគ្គលនោះ រមែងទៅកើតក្នុងអាភស្សរព្រហ្មលោក ដោយឈានមិនមានវិតក្កៈ (ទុតិយជ្ឈាន)។

ចប់ ចន្ទាភជាតក ទី៥។

## សុវណ្ណហំសជាតក ទី៦

CS sut.kn.jat.136 | ភាគទី ៥៨

(១៣៦. សុវណ្ណហំសជាតកំ)

[១៣៦] (ព្រះសាស្តា ត្រាស់ថា) ទ្រព្យណា ដែលបុគ្គលបានមកហើយ បុគ្គលគប្បីត្រេកអរដោយទ្រព្យនោះ ព្រោះថាសេចក្តីល្មោភហួសជារបស់លាមក (ដូចនាងព្រាហ្មណី) ក៏សាបសូន្យ ចាកមាស ព្រោះចាប់ស្តេចហង្ស។

ចប់ សុវណ្ណហំសជាតក ទី៦។

## ពព្ពុជាតក ទី៧

CS sut.kn.jat.137 | ភាគទី ៥៨

(១៣៧. ពព្ពុជាតកំ)

[១៣៧] (ព្រះសាស្តា ត្រាស់ថា) ឆ្មា ១ បានកណ្តុរក្នុងទីណា ឆ្មាជាគំរប់ពីរ គំរប់បី គំរប់បួន រមែងកើតក្នុងទីនោះ ឆ្មាទាំងនោះ (ប្រហារ) នូវរន្ធនេះ ហើយដល់នូវសេចក្តីស្លាប់។

ចប់ ពព្ពុជាតក ទី៧។

## គោធជាតក ទី៨

CS sut.kn.jat.138 | ភាគទី ៥៨

(១៣៨. គោធជាតកំ)

[១៣៨] (ទន្សងពោធិសត្វ ពោលថា) ម្នាលតាបសឥតបញ្ញា ប្រយោជន៍អ្វីដោយជដារបស់អ្នក ប្រយោជន៍អ្វីដោយស្បែកខ្លាឃ្មុំរបស់អ្នក ព្រោះគ្រឿងសាំញាំដោយ (រាគាទិក្កិលេស) មានខាងក្នុងរបស់អ្នក អ្នកខំដុះខាត់តែខាងក្រៅទេ។

ចប់ គោធជាតក ទី៨។

## ឧភតោភដ្ឋជាតក ទី៩

CS sut.kn.jat.139 | ភាគទី ៥៨

(១៣៩. ឧភតោភដ្ឋជាតកំ)

[១៣៩] (រុក្ខទេវតាពោធិសត្វ ពោលថា) ភ្នែកទាំងឡាយបែកធ្លាយហើយ សំពត់បាត់ហើយ ការឈ្លោះ ក៏មានក្នុងផ្ទះនៃស្ត្រីជាសំឡាញ់ ការងារទាំងឡាយខូចទាំងសងខាង គឺក្នុងទឹកផង លើគោកផង។

ចប់ ឧភតោភដ្ឋជាតក ទី៩។

## កាកជាតក ទី១០

CS sut.kn.jat.140 | ភាគទី ៥៨

(១៤០. កាកជាតកំ)

[១៤០] (ក្អែកពោធិសត្វ ពោលថា) ក្អែកទាំងឡាយ ជាសត្វមានហឫទ័យភ្ញាក់ផ្អើលជានិច្ច ជាសត្វបៀតបៀនមនុស្សលោកទាំងពួង ព្រោះហេតុនោះ បានជាខ្លាញ់រាវនៃពួកក្អែក ជាញាតិរបស់យើងទាំងនោះ មិនចេះមានឡើយ។

ចប់ កាកជាតក ទី១០។

ចប់ អសម្បទានវគ្គ ទី១៤។

ឧទ្ទាននៃអសម្បទានវគ្គនោះគឺ

និយាយអំពីវគ្គតាមមានតាមបាន ១ យក្ខិនី ១ ទីក្រុម ១ អាភស្សរមហាព្រហ្មដូចក្នុងបរោសតបញ្ហា ១ អាភស្សរមហាព្រហ្ម ១ ទៀត ហង្សឧត្តមប្រសើរ ១ ឆ្មា ១ ជដា ១ ព្រានបាត់សំពត់ ១ ក្អែក ១ ត្រូវជា ១០។

## កកណ្ដកវគ្គ ទី១៥

CS sut.kn.jat.v01.15 | ភាគទី ៥៨

(១៥. កកណ្ដកវគ្គោ)

## គោធជាតក ទី១

CS sut.kn.jat.141 | ភាគទី ៥៨

(១៤១. គោធជាតកំ)

[១៤១] (ស្តេចទន្សងពោធិសត្វ ពោលថា) បុគ្គលអ្នកសេពគប់នូវជនបាប រមែងមិនដល់នូវសេចក្តីសុខពិតទេ ដូចជាត្រកូលទន្សង មិនបានសេចក្តីសុខ ព្រោះត្រគួត រមែងញុំាងខ្លួនឲ្យដល់នូវសេចក្តីវិនាស។

ចប់ គោធជាតក ទី១។

## សិង្គាលជាតក ទី២

CS sut.kn.jat.142 | ភាគទី ៥៨

(១៤២. សិង្គាលជាតកំ)

[១៤២] (ស្តេចចចកពោធិសត្វ ពោលថា) អ្នកដេកធ្វើពុតជាស្លាប់ ដោយហេតុណា ហេតុរបស់អ្នកនុ៎ះ ដឹងបានដោយក្រ តែដំបងមិនរបូត អំពីដៃរបស់អ្នក កំពុងចាប់កាន់នោះ។

ចប់ សិង្គាលជាតក ទី២។

## វិរោចនជាតក ទី៣

CS sut.kn.jat.143 | ភាគទី ៥៨

(១៤៣. វិរោចជាតកំ)

[១៤៣] (កេសរសីហពោធិសត្វ ពោលថា) ខួរក្បាលរបស់អ្នកធ្លាយចេញផង រលាក្បាលរបស់អ្នកបែកធ្លាយផង ឆ្អឹងជំនីរទាំងអស់ របស់អ្នក ដំរីបំបាក់ហើយផង ក្នុងថ្ងៃនេះ អ្នកនៅរុងរឿងអ្វីទៀត។

ចប់ វិរោចនជាតក ទី៣។

## នង្គុដ្ឋជាតក ទី៤

CS sut.kn.jat.144 | ភាគទី ៥៨

(១៤៤. នង្គុដ្ឋជាតកំ)

[១៤៤] (តាបសពោធិសត្វ ពោលថា) ម្នាលភ្លើង ជាអសប្បុរស យើងនឹងបូជាអ្នកដោយកន្ទុយណា កន្ទុយប៉ុណ្ណោះច្រើនហើយ ក្នុងថ្ងៃនេះ សាច់មិនមានដល់អ្នកដ៏គួរដល់សាច់ទេ អ្នកដ៏ចំរើន ចូរទទួលយកតែកន្ទុយចុះ។

ចប់ នង្គុដ្ឋជាតក ទី៤។

## រាធជាតក ទី៥

CS sut.kn.jat.145 | ភាគទី ៥៨

(១៤៥. រាធជាតកំ)

[១៤៥] (សេកពោធិសត្វ ពោលថា) ម្នាលរាធៈ អ្នករមែងមិនដឹងច្បាស់ថា ពួកមនុស្សប៉ុណ្ណេះ ក្នុងពេលពាក់កណ្តាលអធ្រាត្រមិនទាន់មកដល់ ពោលចរចានូវពាក្យមិនប្រាកដនឹងនាងព្រាហ្មណី ជាកោសិយគោត្រអ្នកមិនមានតម្រេក (នឹងស្វាមីខ្លួន)។

ចប់ រាធជាតក ទី៥។

## កាកជាតក ទី៦

CS sut.kn.jat.146 | ភាគទី ៥៨

(១៤៦. សមុទ្ទកាកជាតកំ)

[១៤៦] (ពួកក្អែក ពោលថា) អើ ចង្កាយើងក៏រោយ ទាំងមាត់ក៏ស្ងួតក្រៀមក្រោះ យើងមិនអាចបាចទឹក ក្នុងសមុទ្រឲ្យរីងបានទេ ព្រោះមហាសមុទ្រនៅតែពេញដដែល។

ចប់ កាកជាតក ទី៦។

## បុប្ផរត្តជាតក ទី៧

CS sut.kn.jat.147 | ភាគទី ៥៨

(១៤៧. បុប្ផរត្តជាតកំ)

[១៤៧] (មនុស្សទុគ៌ត ពោលថា) ក្អែកចោះអញ ដោយហេតុណា ហេតុនេះ មិនជាទុក្ខទេ សេចក្តីទុក្ខនោះ ក៏មិនមានដល់យើងឡើយ ទុក្ខមានដល់យើងនោះ ត្រង់ភរិយាឈ្មោះសាមា មិនស្លៀកសណ្តប់សំពត់ ដែលជ្រលក់ដោយទឹកដក់គាំ ដើរមើលមហោស្រព ក្នុងខែកត្តិក។

ចប់ បុប្ផរត្តជាតក ទី៧។

## សិង្គាលជាតក ទី៨

CS sut.kn.jat.148 | ភាគទី ៥៨

(១៤៨. សិង្គាលជាតកំ)

[១៤៨] (ចចកពោធិសត្វ ពោលថា) យើងនឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីទៀត យើងនឹងមិនចូលកាន់ពោះដំរីញយ ៗ ទេ ព្រោះយើងត្រូវភ័យគម្រាមហើយ ដូច្នោះ។

ចប់ សិង្គាលជាតក ទី៨។

## ឯកបណ្ណជាតក ទី៩

CS sut.kn.jat.149 | ភាគទី ៥៨

(១៤៩. ឯកបណ្ណជាតកំ)

[១៤៩] (ឥសីពោធិសត្វ ពោលថា) ឈើនេះ ទើបតែនឹងមានស្លឹកតែមួយ ៗ ដុះអំពីផែនដី មិនទាន់ដល់ ៤ធ្នាប់ មានផ្លែដូចជាថ្នាំពិសទៅហើយ ចំណាង់ឈើនេះធំឡើង នឹងដូចម្តេចទៅទៀត។

ចប់ ឯកបណ្ណជាតក ទី៩។

## សញ្ជីវជាតក ទី១០

CS sut.kn.jat.150 | ភាគទី ៥៨

(១៥០. សញ្ជីវជាតកំ)

[១៥០] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលណា លើកដំកើងនូវជន ជាអសប្បុរសផង ចូលទៅសេពគប់នូវជនជាអសប្បុរសផង ជនជាអសប្បុរសនោះ រមែងធ្វើនូវបុគ្គលនោះឯង ឲ្យទៅជាអាហារ ដូចខ្លានិងសញ្ជីវមាណព។

ចប់ សញ្ជីវជាតក ទី១០។

ចប់ កកណ្តកវគ្គ ទី១៥។

ឧទ្ទាននៃកកណ្តកវគ្គនោះគឺ

និយាយអំពីបុគ្គលដល់នូវសេចក្តីសុខ ១ ដំបងប្រសើរ ១ ខួរក្បាល ១ កន្ទុយ ១ សេកឈ្មោះរាធៈ ដ៏ប្រសើរ ជាគំរប់ប្រាំ ១ សមុទ្ទ ១ មហោស្រពខែកត្តិក ១ ពោះដំរី ១ ឈើដុះ ៤ ធ្នាប់ ១ ខ្លាដ៏ប្រសើរ ១ ត្រូវជា ១០។

ឧទ្ទាននៃវគ្គមានក្នុងឯកនិបាតនោះគឺ

អបណ្ណកវគ្គ ១ សីលវគ្គ ១ កុរុង្គវគ្គ ១ កុលាវកវគ្គ ១ អត្ថកាមវគ្គ ជាគំរប់ប្រាំ ១ អសីសវគ្គ ១ ឥត្ថីវគ្គ ១ វរុណវគ្គ ១ អបាយិម្ហវគ្គ ១ លិត្តវគ្គ ១ ត្រូវជា ១០ បរោសតវគ្គ ១ ហំសិវគ្គ ១ កុសនាឡិវគ្គ ១ អសម្បទានវគ្គ ១ កកណ្ដកវគ្គ ១ ក្នុងឯកនិបាតប្រដាប់ (ដោយវគ្គដូច្នេះឯង)។

ចប់ ឯកនិបាត។

# ទុកនិបាតជាតក

CS sut.kn.jat.v02 | ភាគទី ៥៨

(២. ទុកនិបាតោ)

## ទឡ្ហវគ្គ ទី១

CS sut.kn.jat.v02.01 | ភាគទី ៥៨

(១. ទឡ្ហវគ្គោ)

### រាជោវាទជាតក ទី១

CS sut.kn.jat.151 | ភាគទី ៥៨

(១៥១. រាជោវាទជាតកំ (២-១-១))

[១៥១] (សារថីរបស់ព្រះបាទរាជាពល្លិកៈ ពោលថា) ព្រះបាទពល្លិកៈ រមែងបោះនូវរបស់មាំដល់បុគ្គលអ្នកមាំ ឈ្នះនូវបុគ្គលទន់ដោយកិរិយាទន់ ឈ្នះនូវសប្បុរស ដោយសប្បុរស ឈ្នះនូវអសប្បុរស ដោយអសប្បុរស ព្រះរាជានេះ (មានសីល និងអាចារៈ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅ។

[១៥២] (សារថីរបស់ព្រះបាទពារាណសី ពោលថា) ព្រះរាជាគប្បីឈ្នះបុគ្គលអ្នកក្រោធ ដោយសេចក្តីមិនក្រោធ គប្បីឈ្នះអសប្បុរស ដោយសប្បុរស គប្បីឈ្នះបុគ្គលកំណាញ់ ដោយការឲ្យ គប្បីឈ្នះបុគ្គលអ្នកពោលពាក្យកុហក ដោយការពោលពាក្យពិត ព្រះរាជានេះ (មានសីល និងអាចារៈ) ប្រាកដដូច្នេះ ម្នាលសារថី អ្នកចូរចៀសចេញអំពីផ្លូវទៅ។

ចប់ រាជោវាទជាតក ទី១។

### សិគាលជាតក ទី២

CS sut.kn.jat.152 | ភាគទី ៥៨

(១៥២. សិគាលជាតកំ)

[១៥៣] (រាជសីហ៍ពោធិសត្វ ពោលថា) ការងារទាំងឡាយនោះ ញាំងបុគ្គលអ្នកមានការងារមិនបានពិចារណាដោយត្រឹមត្រូវ ឲ្យសំរេចដោយរួសរាន់ឲ្យក្តៅក្រហាយ ដូចជាវត្ថុក្តៅដែលបុគ្គលពមចូលទៅក្នុងមាត់។

[១៥៤] (ព្រះសាស្តា ត្រាស់ថា) សីហៈញាំងភ្នំប្រាក់ឲ្យលាន់ឮខ្លាំង ដោយសីហនាទ ចចកនៅក្នុងភ្នំប្រាក់ បានឮសំលេងគឹកកងនៃសត្វសីហៈហើយ ក៏ភ័យតក់ស្លុតបែកហ្ឫទ័យស្លាប់។

ចប់ សិគាលជាតក ទី២។

### សូករជាតក ទី៣

CS sut.kn.jat.153 | ភាគទី ៥៨

(១៥៣. សូករជាតកំ (២-១-៣))

[១៥៥] (សូករៈ ពោលថា) ម្នាលសំឡាញ់អ្នកមានធុរៈស្មើ ខ្ញុំមានជើង ៤ ម្នាលសំឡាញ់ អ្នកឯងក៏មានជើង ៤ ដែរ ម្នាលសំឡាញ់ អ្នកចូរត្រឡប់មក អ្នកខ្លាចឬ បានជារត់ចេញ។

[១៥៦] (សីហៈពោធិសត្វ ពោលថា) ម្នាលសូករៈ អ្នកមានកាយមិនស្អាត មានរោមប្រឡាក់ដោយវត្ថុស្អុយ មានក្លិនអាក្រក់បក់ទៅ បើអ្នកចង់ច្បាំងគ្នា ម្នាលសំឡាញ់ យើងឲ្យជ័យដល់អ្នកឯង។

ចប់ សូករជាតក ទី៣។

### ឧរគជាតក ទី៤

CS sut.kn.jat.154 | ភាគទី ៥៨

(១៥៤. ឧរគជាតក (២-១-៤ ))

[១៥៧] (គ្រុឌ ពោលថា) ស្តេចនាគដ៏ប្រសើរជាងពស់ទាំងឡាយ មានភេទដូចជាកែវដែលកើតអំពីថ្ម ប្រាថ្នាដើម្បីរួច បានចូលទៅក្នុងសំពត់ស្លៀកនេះ ខ្ញុំកោតក្រែងនូវបុគ្គលមានភេទដ៏ប្រសើរ ខ្ញុំប្រាថ្នានឹងបរិភោគ តែមិនអាចនឹងបរិភោគបាន។

[១៥៨] (តាបសពោធិសត្វ ពោលថា) អ្នកមានបុគ្គលដ៏ប្រសើរគ្រប់គ្រងហើយ ចូររស់នៅអស់កាលយូរ អាហារជាទិព្វទាំងឡាយ ចូរកើតប្រាកដដល់អ្នក (ព្រោះថា) អ្នកកោតក្រែងនូវបុគ្គលមានភេទដ៏ប្រសើរ អ្នកប្រាថ្នានឹងបរិភោគ តែមិនអាចបរិភោគបាន។

ចប់ ឧរគជាតក ទី៤។

## ភគ្គជាតក ទី៥

CS sut.kn.jat.155 | ភាគទី ៥៨

### (១៥៥. ភគ្គជាតកំ (២-១-៥))

[១៥៩] (មាណពពោធិសត្វ ពោលថា) បពិត្រភគ្គៈ សូមលោករស់នៅអស់ ១២០ ឆ្នាំ បិសាចទាំងឡាយ ចូរកុំទំពាស៊ីនូវខ្ញុំឡើយ សូមលោករស់នៅអស់ ១២០ ឆ្នាំ។

[១៦០] (បិតារបស់ពោធិសត្វ ពោលថា) ចូរអ្នករស់នៅអស់ ១២០ ឆ្នាំដែរ បិសាចទាំងឡាយ ចូរទំពាស៊ីនូវថ្នាំពិស អ្នកចូររស់នៅអស់ ១២០ ឆ្នាំ។

ចប់ ភគ្គជាតក ទី៥។

## អលីនចិត្តជាតក ទី៦

CS sut.kn.jat.156 | ភាគទី ៥៨

### (១៥៦. អលីនចិត្តជាតកំ (២-១-៦))

[១៦១] (ព្រះសាស្តា ត្រាស់ថា) សេនាដ៏ច្រើន មានចិត្តរីករាយ ព្រោះអាស្រ័យនូវអលីនចិត្តរាជកុមារ បានញ៉ាំងដំរីឲ្យចាប់យកព្រះបាទកោសលទាំងរស់ដែលមិនត្រេកអរហើយ ដោយរាជសម្បត្តិរបស់ខ្លួនយ៉ាងណាមិញ។

[១៦២] ភិក្ខុអ្នកបរិបូណ៌ដោយនិស្ស័យ មានសេចក្តីព្យាយាមប្រារព្ធហើយ កាលចំរើននូវកុសលធម៌ ដើម្បីសម្រេចនូវព្រះនិព្វាន ជាទីក្សេមចាកយោគៈ គប្បីដល់នូវការអស់ទៅនៃសំយោជនៈទាំងពួងដោយលំដាប់ ក៏យ៉ាងនោះដែរ។

ចប់ អលីនចិត្តជាតក ទី៦។

## គុណជាតក ទី៧

CS sut.kn.jat.157 | ភាគទី ៥៨

### (១៥៧. គុណជាតកំ (២-១-៧))

[១៦៣] (ចចក ពោលថា) អ្នកមានកំឡាំង បណ្តេញ (នូវបុគ្គលអ្នកសេពគប់នឹងខ្លួន) តាមសេចក្តីប្រាថ្នាបាន បពិត្រស្តេចម្រឹគ (នេះ) ជាធម្មតានៃអ្នកមានកំឡាំង បពិត្រស្តេចម្រឹគ អ្នកមានចង្កូមស្រួច លោកចូរដឹងចុះ មរណភ័យកើតហើយអំពីទីជាទីពឹង (របស់យើង)។

[១៦៤] (សីហៈពោធិសត្វ ពោលថា) ប្រសិនបើមិត្រមានកំឡាំងខ្សោយ តែតាំងនៅក្នុងមិត្រធម៌ទាំងឡាយ បុគ្គលនោះ ហៅថាជាញាតិផង ជាផៅពង្សផង បុគ្គលនោះហៅថា មិត្រផង បុគ្គលនោះហៅថា សំឡាញ់របស់យើងផង ម្នាលមេម្រឹគមានចង្កូម នាងកុំមើលងាយចចកឈ្មោល និងចចកញីជាសំឡាញ់យើងឡើយ ព្រោះចចក ជាអ្នកឲ្យជីវិតដល់យើង។

ចប់ គុណជាតក ទី៧។

## សុហនុជាតក ទី៨

CS sut.kn.jat.158 | ភាគទី ៥៨

### (១៥៨. សុហនុជាតកំ (២-១-៨))

[១៦៥] (អមាត្យពោធិសត្វ ពោលថា) សេះឈ្មោះសុហនុ ធ្វើនូវសេចក្តីស្រឡាញ់នេះ ជាមួយនឹងសេះឈ្មោះសោណៈ មិនមែនដោយមារយាទមិនស្មើគ្នាទេ សេចក្តីប្រព្រឹត្តរបស់សេះឈ្មោះសោណៈយ៉ាងណា សេះឈ្មោះសុហនុ ក៏ប្រាកដយ៉ាងនោះដែរ។

[១៦៦] អំពើរមែងស្មើគ្នាដោយការស្ទុះទៅ និងការឃ្មើសឃ្មង និងការខាំកាត់នូវខ្សែជានិច្ច អំពើអាក្រក់ស្មើគ្នា ដោយអំពើអាក្រក់ ការមិនរៀបរយស្មើគ្នា ដោយការមិនរៀបរយ។

ចប់ សុហនុជាតក ទី៨។

## មោរជាតក ទី៩

CS sut.kn.jat.159 | ភាគទី ៥៨

### (១៥៩. មោរជាតកំ (២-១-៩ ))

[១៦៧] (ក្ងោកពោធិសត្វ ពោលថា) សុរិយទេវបុត្រណា ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុង

រះឡើង ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សា អស់វេលាថ្ងៃក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សំរេចនូវវេទ ក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងឡាយនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងឡាយនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វនោះ ធ្វើបរិត្តនេះរួចហើយ ទើបត្រាច់ទៅស្វែងរកអាហារ។

[១៦៨] (សុរិយទេវបុត្រណា) ជាឯករាជ មានចក្ខុ មានសម្បុរដូចជាមាស មានពន្លឺផ្សាយទៅលើផែនដី កំពុងអស្តង្គតទៅ ខ្ញុំសូមនមស្ការនូវសុរិយទេវបុត្រនោះ អ្នកមានសម្បុរដូចមាស មានពន្លឺផ្សាយទៅលើផែនដី ខ្ញុំសូមឲ្យលោកគ្រប់គ្រងរក្សា អស់រាត្រីក្នុងថ្ងៃនេះ ព្រាហ្មណ៍ទាំងឡាយណា សំរេចនូវវេទ ក្នុងធម៌ទាំងពួង សូមព្រាហ្មណ៍ទាំងនោះ ទទួលនូវការនមស្ការរបស់ខ្ញុំ សូមព្រាហ្មណ៍ទាំងនោះ រក្សានូវខ្ញុំ ការនមស្ការ ចូរមានដល់លោកអ្នកត្រាស់ដឹងទាំងឡាយ ការនមស្ការ ចូរមានដល់សេចក្តីត្រាស់ដឹង ការនមស្ការ ចូរមានដល់លោកអ្នករួចទាំងឡាយ ការនមស្ការ ចូរមានដល់វិមុត្តិ ក្ងោកពោធិសត្វ ធ្វើបរិត្តនេះរួចហើយ ទើបបានសម្រេចការនៅ។

ចប់ មោរជាតក ទី៩។

## វិនីលកជាតក ទី១០

CS sut.kn.jat.160 | ភាគទី ៥៨

(១៦០. វិនីលជាតកំ (២-១-១០))

[១៦៩] (កូនក្អែកកាត់ហង្ស ពោលថា) ហង្សទាំងឡាយ (រមែងនាំយើង) ឈ្មោះវិនីលកៈទៅបានយ៉ាងណាមិញ សេះអាជានេយ្យទាំងឡាយ នាំនូវព្រះបាទវិទេហៈអ្នកគ្រប់គ្រងក្រុងមិថិលា ក៏យ៉ាងនោះដែរ។

[១៧០] (ហង្សពោធិសត្វជាបិតា ពោលថា) ម្នាលចៅវិនីលៈ អ្នកគប់រកនូវព្រៃភ្នំមានច្រកចង្អៀត ម្នាលកូន អ្នកសេពនូវកន្លែងមិនមែនជាទីរបស់អ្នក ៗ ចូរសេពនូវកន្លែងជាទីបំផុតនៃស្រុកចុះ ទីនោះជាលំនៅរបស់មាតាអ្នកហើយ។

ចប់ វិនីលកជាតក ទី១០។

ចប់ ទឡ្ហវគ្គ ទី១។

ឧទ្ទាននៃទឡ្ហវគ្គនោះគឺ

និយាយអំពីព្រះបាទពល្លិកៈដ៏ប្រសើរ ១ ភ្នំប្រាក់ ១ សូករៈ ១ នាគប្រសើរជាងពស់ ១ បិតាឈ្មោះភគ្គៈ ១ ជាគំរប់ ៥ សេនាធំ ១ ចចកប្រសើរ ១ សេះឈ្មោះសុហនុដ៏ឧត្តម ១ ក្ងោក ១ វិនីលកៈ ១ ត្រូវជា ១០។

# សន្ថវវគ្គ ទី២

CS sut.kn.jat.v02.02 | ភាគទី ៥៨

(២. សន្ថវវគ្គោ)

## ឥន្ទសមានគោត្តជាតក ទី១

CS sut.kn.jat.161 | ភាគទី ៥៨

(១៦១. ឥន្ទសមានគោត្តជាតកំ (២-២-១))

[១៧១] (តាបសពោធិសត្វ ពោលថា) បុគ្គលកុំគប្បីធ្វើសេចក្តីស្និទ្ធស្នាលជាមួយនឹងបុរសលាមក អរិយបុគ្គល ដឹងច្បាស់នូវប្រយោជន៍ (ក៏មិនគប្បីធ្វើនូវសេចក្តីស្និទ្ធស្នាល ជាមួយនឹងបុគ្គលមិនមែនជាអរិយៈ (បុគ្គលមិនមែនជាអរិយៈ) សូម្បីនៅជាមួយគ្នាអស់កាលយូរ រមែងធ្វើអំពើអាក្រក់ ដូចជាដំរីកាលព្រេចនូវតាបសឈ្មោះឥន្ទសមានគោត្រ។

[១៧២] បុគ្គលគប្បីដឹងនូវជនណាថា បុគ្គលនេះស្មើគ្នា ដោយសីលផង បញ្ញាផង សុតៈផង របស់អញ គប្បីធ្វើនូវមេត្រីជាមួយនឹងជននោះចុះ (ព្រោះ) ការគប់រកដោយសប្បុរស តែងនាំមកនូវសេចក្តីសុខដោយពិត។

ចប់ ឥន្ទសមានគោត្តជាតក ទី១។

## សន្ថវជាតក ទី២

CS sut.kn.jat.162 | ភាគទី ៥៨

(១៦២. សន្ថវជាតកំ (២-២-២))

[១៧៣] (តាបសពោធិសត្វ ពោលថា) ការស្និទ្ធស្នាលណា ជាមួយនឹងបុរសលាមក របស់ដទៃលាមកក្រៃលែងជាងការស្និទ្ធស្នាល (នោះ) មិនមានទេ ដូចជាភ្លើងដែលយើងឲ្យឆ្អែតដោយសប្បិ និងបាយាស នៅតែឆេះខ្ទមស្លឹកដែលយើងធ្វើហើយដោយលំបាក។

[១៧៤] ការស្និទ្ធស្នាលណា ជាមួយនឹងសប្បុរស របស់ដទៃប្រសើរក្រៃលែងជាងការស្និទ្ធស្នាល (នោះ) មិនមានទេ ដូចជាមេម្រឹគឈ្មោះសាមា លិទ្ធមាត់នៃស្តេចរាជសីហ៍ផង ខ្លាធំផង ខ្លាដម្បងផង ព្រោះការស្និទ្ធស្នាល។

ចប់ សន្ថវជាតក ទី២។

## សុសីមជាតក ទី៣

CS sut.kn.jat.163 | ភាគទី ៥៨

### (១៦៣. សុសីមជាតកំ (២-២-៣ ))

[១៧៥] (ពោធិសត្វ ពោលថា) បពិត្រព្រះរាជា ទ្រង់ព្រះនាមសុសីមៈ ម្រឹគខ្មៅ មានភ្លុកស (ដំរី) នេះ របស់ព្រះអង្គច្រើនជាងរយ បិទបាំងដោយបណ្ដាញមាស ព្រះអង្គទ្រង់រឭកនូវព្រះបិតា និងជីតា (របស់ខ្ញុំព្រះអង្គ) ទើបត្រាស់ថា អញនឹងឲ្យដំរីទាំងឡាយនោះ ដល់ព្រាហ្មណ៍ទាំងនោះមែនឬ។

[១៧៦] (ព្រះរាជា ត្រាស់ថា) ម្នាលមាណព ម្រឹគខ្មៅមានភ្លុកសនេះ របស់ខ្ញុំច្រើនជាងរយ បិទបាំងដោយបណ្ដាញមាស ខ្ញុំកាលរឭកនូវបិតា និងជីតា ទើបពោលថា ខ្ញុំនឹងឲ្យនូវដំរីទាំងឡាយនោះ ដល់ព្រាហ្មណ៍ទាំងនោះមែន។

ចប់ សុសីមជាតក ទី៣។

## គិជ្ឈជាតក ទី៤

CS sut.kn.jat.164 | ភាគទី ៥៨

### (១៦៤. គិជ្ឈជាតកំ (២-២-៤ ))

[១៧៧] (ព្រះរាជាពារាណសី ត្រាស់ថា) ត្មាតរមែងក្រឡេកមើលឃើញសាកសពចម្ងាយ ១០០ យោជន៍បាន ចុះហេតុអ្វី បានជាអ្នកហើរមកដល់បណ្ដាញ និងអន្ទាក់ហើយ ក៏នៅតែមិនភ្ញាក់ខ្លួន។

[១៧៨] (ត្មាតពោធិសត្វ ពោលថា) សេចក្ដីវិនាស មានក្នុងវេលាណា សត្វមកដល់បណ្ដាញ និងអន្ទាក់ រមែងមិនបានភ្ញាក់ខ្លួនក្នុងការអស់ទៅនៃជីវិត ក្នុងវេលានោះ។

ចប់ គិជ្ឈជាតក ទី៤។

## នកុលជាតក ទី៥

CS sut.kn.jat.165 | ភាគទី ៥៨

### (១៦៥. នកុលជាតកំ (២-២-៥))

[១៧៩] (តាបសពោធិសត្វ ពោលថា) ម្នាលស្កាជាជលាពុជៈ អ្នកធ្វើនូវមិត្តភាពដោយសត្រូវដែលជាអណ្ឌជៈកំណើតហើយ មកដេកបញ្ចេញចង្កូម តើសេចក្ដីភ័យ មានមកដល់អ្នកអំពីទីណា។

[១៨០] (ស្កា ពោលថា) បុគ្គលគប្បីរង្កៀសក្នុងសត្រូវ មិនគប្បីស្និទ្ធស្នាល សូម្បីក្នុងមិត្រ ភ័យដែលកើតឡើងអំពីជនដែលមិនគួរភ័យ រមែងកាត់នូវឫសគល់ទាំងឡាយបាន។

ចប់ នកុលជាតក ទី៥។

## ឧបសាឡ្ហកជាតក ទី៦

CS sut.kn.jat.166 | ភាគទី ៥៨

### (១៦៦. ឧបសាឡ្ហកជាតកំ (២-២-៦))

[១៨១] (តាបសពោធិសត្វ ពោលថា) ពួកញាតិឈ្មោះឧបសាឡ្ហកៈ ចំនួន ១៤០០០ នាក់ គេដុតហើយ ក្នុងប្រទេសនេះ ក្នុងលោករកទីដែលមិនមានគេស្លាប់ មិនមានឡើយ។

[១៨២] សច្ចៈ ១ ធម្មៈ ១ អហឹសា ១ សញ្ញមៈ ១ ទមៈ ១ មាននៅក្នុងបគ្គលណា ព្រះអរិយៈទាំងឡាយ រមែងសេពគប់នូវបុគ្គលនុ៎ះ គុណជាតនុ៎ះឈ្មោះថា មិនចេះស្លាប់ ក្នុងលោក។

ចប់ ឧបសាឡ្ហកជាតក ទី៦។

## សមិទ្ធិជាតក ទី៧

CS sut.kn.jat.167 | ភាគទី ៥៨

### (១៦៧. សមិទ្ធិជាតកំ (២-២-៧))

[១៨៣] (នាងទេពធីតា ពោលប្រលោមថា) បពិត្រភិក្ខុ លោកមិនទាន់បរិភោគកាមសិន ហើយត្រាច់ទៅ ដើម្បីភិក្ខុភាព បើលោកបរិភោគកាមរួចហើយ សឹមត្រាច់ទៅ ដើម្បីភិក្ខា មិនបានឬ បពិត្រភិក្ខុ សូមលោកបរិភោគកាមសិន ហើយសឹមត្រាច់ទៅ ដើម្បីភិក្ខាចុះ កុំឲ្យកាល (ជាទីបរិភោគកាម) កន្លងនូវលោកបានឡើយ។

[១៨៤] (តាបសពោធិសត្វ ពោលថា) យើងមិនបានដឹងនូវមរណកាលដោយពិត មរណកាលកំបាំងមិនប្រាកដ ព្រោះហេតុនោះ បានជាយើងមិនបរិភោគកាម ហើយត្រាច់ទៅដើម្បីភិក្ខា កុំឲ្យកាល (ធ្វើសមណធម៌) កន្លងនូវយើងបានឡើយ។

ចប់ សមិទ្ធិជាតក ទី៧។

## សកុណគ្ឃិជាតក ទី៨

CS sut.kn.jat.168 | ភាគទី ៥៨

(១៦៨. សកុណគ្ឃិជាតកំ (២-២-៨ ))

[១៨៥] (ព្រះសាស្ដា ត្រាស់ថា) សត្វខ្លែងបោះពួយចុះមក ដោយកំឡាំងរហ័ស ឆាបនូវសត្វប្រចៀចដែលទំនៅលើ (អាចម៍បំណះ) ជាទីគោចរ (របស់ខ្លួន) ក៏ដល់នូវសេចក្ដីស្លាប់ ដោយហេតុនោះទៅ។

[១៨៦] (ប្រចៀច ពោលថា) ខ្ញុំនោះ ជាអ្នកបរិបូណ៌ដោយឧបាយ ត្រេកអរក្នុងទីគោចរជារបស់បិតា ឃើញនូវប្រយោជន៍របស់ខ្លួន ហើយប្រាសចាកសត្រូវ នៅរីករាយ។

ចប់ សកុណគ្ឃិជាតក ទី៨។

## អរកជាតក ទី៩

CS sut.kn.jat.169 | ភាគទី ៥៨

(១៦៩. អរកជាតកំ (២-២-៩ ))

[១៨៧] (អរកសាស្ដា ពោលថា) បុគ្គលណាសង្គ្រោះដល់សត្វលោកទាំងមូល ដោយមេត្តាចិត្តក្នុងទិសខាងលើផង ទិសខាងក្រោមផង ទិសទទឹងផង ដោយអាការទាំងពួង រកប្រមាណមិនបាន។

[១៨៨] ចិត្តដែលប្រកបដោយប្រយោជន៍ រកប្រមាណមិនបាន ឈ្មោះថាបុគ្គលបានចំរើនបរិបូណ៌ហើយ អំពើណា ដែលបុគ្គលបានធ្វើល្មមប្រមាណ អំពើនោះ រមែងមិនសល់នៅក្នុងចិត្តរបស់បុគ្គលអ្នកបានចំរើននោះឡើយ។

ចប់ អរកជាតក ទី៩។

## កកណ្ដកជាតក ទី១០

CS sut.kn.jat.170 | ភាគទី ៥៨

(១៧០. កកណ្ដកជាតកំ (២-២-១០))

[១៨៩] (ព្រះបាទវិទេហៈ ត្រាស់ថា) កាលពីដើម បង្កួយនេះនៅលើក្លោងទ្វារ មិនក្រអឺតក្រអោងទេ ម្នាលមហោសថ អ្នកចូរដឹង ព្រោះហេតុអ្វី បានជាបង្កួយត្រឡប់ទៅជារបឹងរឹងរូសវិញ។

[១៩០] (មហោសថពោធិសត្វ ពោលថា) បង្កួយបានរបស់ដែលមិនធ្លាប់បាន ចំនួនកន្លះមាសកៈ រមែងមើលងាយព្រះបាទវិទេហៈ ដែលសោយរាជ្យក្នុងនគរមិថិលា។

ចប់ កកណ្ដកជាតក ទី១០។

ចប់ សន្ថវវគ្គ ទី២។

ឧទ្ទាននៃសន្ថវវគ្គនោះគឺ

និយាយអំពីឥន្ទសមានតាបស ១ ខ្ទមស្លឹក ១ ព្រះរាជាសុសីមៈ ១ ត្មាត ១ ស្ដាជាជលាពុជ ១ ឧបសាឡ្ហកព្រាហ្មណ៍ ១ ភិក្ខុ ១ ប្រចៀចដ៏ប្រសើរ ១ មេត្តាដ៏ប្រសើរ ១ បង្កួយក្រអឺតក្រអោង ១ ត្រូវជា ១០។

# កល្យាណធម្មវគ្គ ទី៣

CS sut.kn.jat.v02.03 | ភាគទី ៥៨

(៣. កល្យាណវគ្គោ)

## កល្យាណធម្មជាតក ទី១

CS sut.kn.jat.171 | ភាគទី ៥៨

(១៧១. កល្យាណធម្មជាតកំ (២-៣-១))

[១៩១] (សេដ្ឋីពោធិសត្វ ពោលថា) បពិត្រព្រះអង្គជាធំជាងជន កាលណា នរជនប្រកបដោយបញ្ញា ដល់នូវសមញ្ញា (ឈ្មោះ) ថាជាអ្នកមានកល្យាណធម៌ក្នុងលោក (កាលនោះ) មិនគប្បីឲ្យសាបសូន្យចាកសមញ្ញានោះ សប្បុរសទាំងឡាយ តែងកាន់យកនូវបព្វជ្ជាធុរៈ ដោយហិរិ និងឱត្តប្បៈ។

[១៩២] បពិត្រព្រះអង្គជាធំជាងជន សមញ្ញានោះឯង ថាជាអ្នកមានកល្យាណធម៌ក្នុងលោក មកដល់ខ្ញុំក្នុងថ្ងៃនេះ ហើយខ្ញុំព្រះអង្គពិចារណាឃើញនូវសមញ្ញានោះ នឹងបួសក្នុងថ្ងៃនេះ សេចក្ដីពេញចិត្តក្នុងការបរិភោគកាមក្នុងលោកនេះ មិនមានដល់ខ្ញុំទេ។'

ចប់ កល្យាណធម្មជាតក ទី១។

## ទទ្ទរជាតក ទី២

CS sut.kn.jat.172 | ភាគទី ៥៨

(១៧២. ទទ្ទរជាតកំ (២-៣-២))

[១៩៣] (កូនសីហៈ សួរថា) បពិត្រសីហរាជ ជាធំជាងម្រឹគ នរណាហ្ន៎ មានសំឡេងខ្លាំង ញ៉ាំងភ្នំទទ្ទរៈឲ្យលាន់ឮ ពួកសីហៈ មិនបន្លឺតបទៅនឹងវាឡើយ សត្វដែលបន្លឺសំឡេងគឹកកងបាននុ៎ះ ជាសត្វឈ្មោះអ្វី។

[១៩៤] (សីហៈពោធិសត្វ ពោលថា) ម្នាលកូន ចចក ជាសត្វថោកទាបជាងម្រឹគទាំងឡាយ វាបន្លឺឡើង ពួកសីហៈ កាលខ្ពើមរអើមនូវជាតិរបស់វា រមែងនាំគ្នាអង្គុយនៅស្ងៀម។

ចប់ ទទ្ទរជាតក ទី២។

## មក្កដជាតក ទី៣

CS sut.kn.jat.173 | ភាគទី ៥៨

(១៧៣. មក្កដជាតកំ (២-៣-៣))

[១៩៥] (តាបសជាកូន ពោលថា) បពិត្របិតា មាណពនុ៎ះ បានឈរផ្អែកនឹងគល់ត្នោត រោងរបស់យើងនេះមាន បើដូច្នោះ យើងនឹងប្រគល់រោងឲ្យទៅមាណពនោះចុះ។

[១៩៦] (តាបសពោធិសត្វ ពោលថា) ម្នាលកូន អ្នកកុំហៅវាឡើយ វាគប្បីប្រទូស្តនូវរោងរបស់យើងមិនខាន មុខព្រាហ្មណ៍ដែលមានសីលធម៌ល្អ មិនមែនបែបយ៉ាងនេះទេ។

ចប់ មក្កដជាតក ទី៣។

## ទុព្ភិយមក្កដជាតក ទី៤

CS sut.kn.jat.174 | ភាគទី ៥៨

(១៧៤. ទុព្ភិយមក្កដជាតកំ (២-៣-៤))

[១៩៧] (ព្រាហ្មណ៍ពោធិសត្វ ពោលថា) យើងបានឲ្យទឹកច្រើនដល់ឯង ដែលត្រូវកំដៅថ្ងៃបៀតបៀនស្រេកហើយ ឥឡូវនេះ ឯងផឹកហើយ ធ្វើសំឡេងគំហកថា កិកិ ដូច្នេះ ការសេពគប់ដោយជនអាក្រក់ មិនប្រសើរឡើយ។

[១៩៨] (ស្វាទេវទត្ត ពោលថា) អ្នកឯងដែលបានឮ ឬបានឃើញថា ស្វាណាមានសីលធម៌ ឥឡូវនេះ យើងនឹងបន្ទោបង់វច្ចៈលើក្បាលរបស់អ្នកឯង នេះជាធម្មតារបស់ពួកយើង។

ចប់ ទុព្ភិយមក្កដជាតក ទី៤។

## អាទិច្ចុបដ្ឋានជាតក ទី៥

CS sut.kn.jat.175 | ភាគទី ៥៨

(១៧៥. អាទិច្ចុបដ្ឋានជាតកំ (២-៣-៥))

[១៩៩] (ពួកមនុស្ស ពោលថា) បានឮថា បណ្ដាពួកសត្វទាំងអស់ (មានពួកសត្វខ្លះ) ប្រកបដោយសីលធម៌ អ្នកចូរមើលស្វាដំលាមកដែលកំពុងឈរនមស្ការព្រះអាទិត្យ។

[២០០] (តាបសពោធិសត្វ ពោលថា) អ្នកទាំងឡាយ មិនបានដឹងច្បាស់នូវមារយាទរបស់ស្វានេះទេ អ្នកទាំងឡាយ ពោលសរសើរស្វា ព្រោះមិនដឹងស្វានោះ ដុតនូវរោងបូជាភ្លើងផង ទំលាយនូវក្អមទឹកពីរផង។

ចប់ អាទិច្ចុបដ្ឋានជាតក ទី៥។

## កឡាយមុដ្ឋិជាតក ទី៦

CS sut.kn.jat.176 | ភាគទី ៥៨

(១៧៦. កឡាយមុដ្ឋិជាតកំ (២-៣-៦))

[២០១] (អមាត្យពោធិសត្វ ក្រាបទូលថា) បពិត្រព្រះអង្គជាធំជាងជន ស្វានេះល្ងង់ ប្រាជ្ញារបស់វាមិនមានទេ វាបានបាចសណ្ដែកមួយកំបង់ចោលអស់ ទើបទៅស្វែងរកសណ្ដែកមួយគ្រាប់ដែលជ្រុះទៅ។

[២០២] បពិត្រព្រះរាជា យើងខ្ញុំទាំងឡាយក្ដី ជនទាំងឡាយដទៃដែលល្មោភក្រៃលែងក្ដី គប្បីលះបង់របស់ច្រើនព្រោះរបស់តិច ដូចជាស្វាកាលលះបង់សណ្ដែកច្រើន ព្រោះសណ្ដែកតិចដូច្នោះឯង។

ចប់ កឡាយមុដ្ឋិជាតក ទី៦។

## តិន្ទុកជាតក ទី៧

CS sut.kn.jat.177 | ភាគទី ៥៨

(១៧៧. តិន្ទុកជាតកំ (២-៣-៧))

[២០៣] (ពួកស្វា ពោលថា) យើងត្រូវពួកមនុស្សមានធ្នូ និងបំពង់ព្រួញក្នុងដៃ កាន់ដាវដ៏មុត ព័ទ្ធជុំវិញហើយ ធ្វើម្ដេចនឹងរួចខ្លួនបាន។

[២០៤] (ស្វាពោធិសត្វ ពោលថា) សេចក្ដីត្រូវការនីមួយ គប្បីកើតឡើងដល់ពួកមនុស្សដែលមានកិច្ចច្រើនដោយពិត ផ្លែឈើច្រើន

យើងរើសប្រមូលមកហើយ អ្នកទាំងឡាយ ចូរនាំគ្នាស៊ីនូវផ្លែទន្លាប់នោះចុះ។

ចប់ តិន្ទុកជាតក ទី៧។

## កច្ឆបជាតក ទី៨

CS sut.kn.jat.178 | ភាគទី ៥៨

(១៧៨. កច្ឆបជាតកំ (២-៣-៨))

[២០៥] (អណ្តើក និយាយថា) ខ្ញុំនៅក្នុងភក់ដោយគិតថា ខ្ញុំកើតហើយ ខ្ញុំចំរើនហើយ (ក្នុងទីនេះ) ភក់បានកប់សង្កត់ខ្ញុំនោះ ធ្វើឲ្យទុព្វលភាព បពិត្រភគ្គវៈ ខ្ញុំសូមពោលនូវហេតុនោះនឹងអ្នក អ្នកចូរស្តាប់នូវពាក្យខ្ញុំចុះ។

[២០៦] បុគ្គលបានសេចក្តីសុខក្នុងទីណា ទោះក្នុងស្រុក ឬក្នុងព្រៃ ទីនោះហើយ ជាទីកើត ជាទីចំរើនរបស់បុរសជាអ្នកដឹង (នូវប្រយោជន៍ និងមិនមែនប្រយោជន៍) បុគ្គលគប្បីរស់នៅក្នុងទីណា គប្បីទៅក្នុងទីនោះចុះ កុំគប្បីឲ្យទីដែលធ្លាប់នៅ សម្លាប់ខ្លួនបានឡើយ។

ចប់ កច្ឆបជាតក ទី៨។

## សតធម្មជាតក ទី៩

CS sut.kn.jat.179 | ភាគទី ៥៨

(១៧៩. សតធម្មជាតកំ (២-៣-៩))

[២០៧] (មាណពឈ្មោះសតធម្ម ពោលថា) (អាហារណា ដែលបានបរិភោគហើយ) បាយនោះជារបស់តិចផង សល់ដែលផង បុរសចណ្ឌាល បានឲ្យបាយនោះដល់យើងដោយសេចក្តីលំបាក យើងប្រកបដោយជាតិជាព្រាហ្មណ៍ អាហារណាដែលយើងបានបរិភោគហើយ អាហារនោះឯង ក៏ក្អួតចេញមក។

[២០៨] (ព្រះសាស្តា ត្រាស់ថា) ភិក្ខុណាលះបង់នូវធម៌ គឺអាជីវបារិសុទ្ធិសីល ហើយចិញ្ចឹមជីវិតដោយខុសធម៌យ៉ាងនេះ ភិក្ខុនោះមិនត្រេកអរ ដោយលាភដែលខ្លួនបានហើយ ដូចជាសតធម្មមាណព។

ចប់ សតធម្មជាតក ទី៩។

## ទុទ្ទទជាតក ទី១០

CS sut.kn.jat.180 | ភាគទី ៥៨

(១៨០. ទុទ្ទទជាតកំ (២-៣-១០))

[២០៩] (តាបសពោធិសត្វ ពោលថា) ពួកសប្បុរស កាលឲ្យនូវទាន ដែលគេឲ្យបានដោយកម្រ ធ្វើនូវអំពើដែលគេធ្វើបានដោយកម្រ ពួកអសប្បុរសធ្វើតាម (នូវអំពើនោះ) មិនបានសភាពនៃសប្បុរសទាំងឡាយ គេដឹងបានដោយកម្រ។

[២១០] (ព្រោះហេតុនោះ ដំណើរអំពីលោកនេះរបស់សប្បុរស និងអសប្បុរស រមែងបែកផ្សេង ៗ គ្នា ពួកអសប្បុរស រមែងទៅកាន់នរក ពួកសប្បុរស រមែងទៅកាន់ឋានសួគ៌។

ចប់ ទុទ្ទទជាតក ទី១០។

ចប់ កល្យាណធម្មវគ្គ ទី៣។

ឧទ្ទាននៃកល្យាណធម្មវគ្គនោះគឺ

និយាយអំពីសមញ្ញាល្អ ១ មិគាធិភូ ឬសីហៈជាធំជាងម្រឹគ ១ មាណព ១ ទឹកច្រើន ១ សំពះព្រះអាទិត្យ ១ សណ្តោក ១ ផ្លែទន្លាប់ ១ ភក់ ១ មាណពឈ្មោះសតធម្ម ១ ទានដែលឲ្យបានដោយក្រពេក ១ ត្រូវជា ១០។

# អសទិសវគ្គ ទី៤

CS sut.kn.jat.v02.04 | ភាគទី ៥៨

(៤. អសទិសវគ្គោ)

## អសទិសជាតក ទី១

CS sut.kn.jat.181 | ភាគទី ៥៨

(១៨១. អសទិសជាតកំ (២-៤-១))

[២១១] (ព្រះសាស្តា ត្រាស់ថា) ព្រះរាជបុត្រទ្រង់ព្រះនាមអសទិសៈ ជាខ្មាន់ធ្នូមានកំឡាំងច្រើន បាញ់ធ្នូទៅក្នុងទីឆ្ងាយ បាញ់ត្រង់ទំលាយនូវកងទ័ពធំបាន។

[២១២] ព្រះរាជកុមារទ្រង់ច្បាំងនឹងសត្រូវទាំងពួងបាន តែមិនបានបៀតបៀននូវជនណាមួយឡើយ ធ្វើព្រះអនុជឲ្យសួស្តី ហើយដល់នូវសេចក្តីសង្រួម គឺចូលទៅកាន់ផ្នួស។

ចប់ អសទិសជាតក ទី១។

## សង្គាមាវចរជាតក ទី២

CS sut.kn.jat.182 | ភាគទី ៥៨

(១៨២. សង្គាមាវចរជាតកំ (២-៤-២))

[២១៣] (ទម័កដំរីពោធិសត្វ ពោលថា) ម្នាលដំរី អ្នកល្បីថាជាសត្វចូលសង្គ្រាម មានកំឡាំងក្លៀវក្លា ហេតុអ្វី មកដល់ក្លោងទ្វារហើយ ក៏ថយក្រោយទៅវិញ។

[២១៤] ម្នាលដំរី អ្នកចូរញាំញីទំលាយនូវសន្ទះទ្វារ ហើយដកភើចសសរខឿនចេញឲ្យឆាប់ ចូរញាំញីនូវក្លោងទារ ហើយចូលទៅយ៉ាងឆាប់។

ចប់ សង្គាមាវចរជាតក ទី២។

## វាលោទកជាតក ទី៣

CS sut.kn.jat.183 | ភាគទី ៥៨

(១៨៣. វាលោទកជាតកំ (២-៤-៣))

[២១៥] (ព្រះរាជាពារាណសី ត្រាស់ថា) សេចក្តីស្រវឹងកើតឡើងដល់ពួកលា ព្រោះផឹកទឹកដែលច្រស់ដោយសម្បកក្រចៅ មានរសតិចជារបស់ថោកទាប សេចក្តីស្រវឹងមិនកើតដល់ពួកសេះសិន្ធវៈ ព្រោះផឹកទឹកមានរសដ៏ឧត្តមនេះទេ។

[២១៦] (អមាត្យពោធិសត្វ ក្រាបទូលថា) បពិត្រព្រះអង្គជាធំជាងជន សត្វដែលមានជាតិថោកទាប ផឹកទឹកមានរសតិចហើយ សត្វនោះត្រូវទឹកមានរសតិចពាល់ត្រូវហើយ រមែងស្រវឹង ចំណែកសត្វអ្នកនាំនូវធុរៈ និងមានមារយាទ កើតក្នុងត្រកូល (ដ៏ខ្ពស់) បានផឹកទឹកមានរសដ៏ប្រសើរ រមែងមិនស្រវឹងទេ។

ចប់ វាលោទកជាតក ទី៣។

## គិរិទត្តជាតក ទី៤

CS sut.kn.jat.184 | ភាគទី ៥៨

(១៨៤. គិរិទត្តជាតកំ (២-៤-៤))

[២១៧] (អមាត្យពោធិសត្វ ក្រាបទូលថា) សេះឈ្មោះបណ្ឌវៈរបស់ព្រះរាជាទ្រង់ព្រះនាមសាមៈ ដែលគង្វាលឈ្មោះគិរិទត្តប្រទូស្តរ៉ាយហើយ បានលះប្រក្រតីរបស់ខ្លួនពីដើមចេញ ហើយប្រព្រឹត្តតាមនាយគង្វាលនោះ។

[២១៨] ថាបើបុរសមានជាតិដ៏សមគួរដល់សេះនោះ កាត់កោរសក់ និងពុកមាត់ដោយអាការដ៏ល្អ គប្បីកាន់សេះនោះត្រង់បង្ហៀរ ហើយដឹកក្រឡឹងក្នុងមណ្ឌលក្រោល សេះនោះ នឹងលះបង់នូវ (អាការខ្វកចេញ) ហើយធ្វើតាមបុរសនោះវិញដោយឆាប់។

ចប់ គិរិទត្តជាតក ទី៤។

## អនភិរតិជាតក ទី៥

CS sut.kn.jat.185 | ភាគទី ៥៨

(១៨៥. អនភិរតិជាតកំ (២-៤-៥ ))

[២១៩] (អាចារ្យទិសាបាមោក្ខ ពោលថា) កាលបើទឹកល្អក់មិនថ្លា បុគ្គលរមែងមើលមិនឃើញនូវខ្ចងខ្ចៅ និងក្រួស ដីខ្សាច់ ហ្វូងត្រី យ៉ាងណាមិញ កាលបើចិត្តល្អក់ហើយ បុគ្គលនោះ ក៏មើលមិនឃើញនូវប្រយោជន៍ខ្លួន និងប្រយោជន៍អ្នកដទៃ យ៉ាងនោះដែរ។

[២២០] កាលបើទឹកថ្លាស្អាត បុគ្គលរមែងមើលឃើញនូវខ្ចងខ្ចៅ និងក្រួស ខ្សាច់ ហ្វូងត្រីបាន យ៉ាងណាមិញ កាលបើចិត្តមិនល្អក់ហើយ បុគ្គលនោះ ក៏មើលឃើញនូវប្រយោជន៍របស់ខ្លួន និងប្រយោជន៍អ្នកដទៃបាន យ៉ាងនោះដែរ។

ចប់ អនភិរតិជាតក ទី៥។

## ទធិវាហនជាតក ទី៦

CS sut.kn.jat.186 | ភាគទី ៥៨

(១៨៦. ទធិវាហនជាតកំ (២-៤-៦))

[២២១] (ព្រះបាទទធិវាហនៈ ត្រាស់សួរថា) ក្នុងកាលមុន ដើមស្វាយនេះ ប្រកបដោយពណ៌ ក្លិន និងរស បាននូវគ្រឿងសក្ការៈបូជានោះដដែល ហេតុអ្វីស្វាយ ក៏មានផ្លែល្វីងទៅវិញ។

[២២២] (អមាត្យពោធិសត្វ ពោលថា) បពិត្រព្រះរាជាទ្រង់ព្រះនាមទធិវាហនៈ ស្វាយរបស់ព្រះអង្គ មានដើមស្ដៅដុះរួបរិតជុំវិញ ឫសច្រទ្បំគ្នាដោយឫស មែកពាក់ព័ន្ធគ្នានឹងមែក ដោយការនៅជាមួយនឹងដើមស្ដៅមិនមានរសផ្អែម ព្រោះហេតុនោះ បានជាស្វាយត្រឡប់ជាមានផ្លែល្វីងទៅវិញ។

ចប់ ទធិវាហនជាតក ទី៦។

## ចតុមដ្ឋជាតក ទី៧

CS sut.kn.jat.187 | ភាគទី ៥៨

(១៨៧. ចតុមដ្ឋជាតកំ (២-៤-៧ ))

[២២៣] (ចចក ពោលថា) អ្នកទាំងឡាយ ឡើងទៅលើប្រគាបឈើដ៏ខ្ពស់ ហើយនិយាយគ្នាក្នុងទីស្ងាត់ អ្នកទាំងឡាយ ចូរចុះមកខាងក្រោម និយាយគ្នាវិញ ស្តេចម្រឹគនឹងស្តាប់ផង។

[២២៤] (រុក្ខទេវតាពោធិសត្វ ពោលថា) ហង្សនិយាយគ្នានឹងហង្ស ទេវតានិយាយគ្នានឹងទេវតា ប្រយោជន៍អ្វីដល់ចចកជាសត្វទទេស្អាតចាកសម្បត្តិ ៤ [4] ក្នុងរឿងនោះ ម្នាលសត្វលាមក ឯងចូរទៅកាន់រូងវិញទៅ។

ចប់ ចតុមដ្ឋជាតក ទី៧។

## សីហកោត្ថុកជាតក ទី៨

CS sut.kn.jat.188 | ភាគទី ៥៨

(១៨៨. សីហកោត្ថុជាតកំ (២-៤-៨))

[២២៥] (កូនសីហៈ ពោលថា) សីហៈ ១ នោះ មានម្រាមជើងជាសីហៈ មានក្រចកជាសីហៈ ឈរដោយជើងជាសីហៈ តែបន្លឺឡើងប្លែកម្នាក់ឯងក្នុងហ្វូងសីហៈ។

[២២៦] (សីហពោធិសត្វ ពោលថា) ម្នាលកូនស្តេចសីហៈ អ្នកកុំបន្លឺឡើយ អ្នកចូរមានសម្លេងតិចនៅក្នុងព្រៃ ហ្វូងសត្វគប្បីស្គាល់អ្នកដោយសម្លេង ព្រោះសម្លេងអ្នកមិនមែនកាត់បានមកខាងឪពុកឡើយ។

ចប់ សីហកោត្ថុកជាតក ទី៨។

## សីហចម្មជាតក ទី៩

CS sut.kn.jat.189 | ភាគទី ៥៨

(១៨៩. សីហចម្មជាតកំ (២-៤-៩))

[២២៧] (អ្នកស្រែពោធិសត្វ ពោលថា) នុ៎ះមិនមែនសម្រែកសីហៈ មិនមែនសម្រែកខ្លាធំ មិនមែនសម្រែកខ្លាដម្បងទេ លាដ៏លាមកគេដណ្តប់គ្របដោយស្បែកសីហៈ ស្រែកទេតើ។

[២២៨] (ពាណិជ ពោលថា) លាដណ្តប់ដោយស្បែកសីហៈ ស៊ីស្រូវសំទូងនោះ អស់កាលជាយូរណាស់ហើយ ទាល់តែស្រែក (ឲ្យគេដឹង) បានជាប្រទូស្តខ្លួន។

ចប់ សីហចម្មជាតក ទី៩។

## សីលានិសំសជាតក ទី១០

CS sut.kn.jat.190 | ភាគទី ៥៨

(១៩០. សីលានិសំសជាតកំ (២-៤-១០ ))

[២២៩] (សមុទ្ទទេវតាពោធិសត្វ ពោលថា) អ្នកចូរឃើញផលនៃសទ្ធា សីល ចាគៈ នាគនេះ មានភេទដូចជាសំពៅ នាំឧបាសកមានសទ្ធា។

[២៣០] បុគ្គលគប្បីសេពគប់ជាមួយនឹងពួកសប្បុរស គប្បីធ្វើនូវសេចក្តីស្និទ្ធស្នាលជាមួយនឹងពួកសប្បុរស ដូចជាងផ្ទួតទឹកដល់នូវសួស្តី ព្រោះនៅរួមជាមួយនឹងពួកសប្បុរស។

ចប់ សីលានិសំសជាតក ទី១០។

ចប់ អសទិសវគ្គ ទី៤។

ឧទ្ទាននៃអសទិសវគ្គនោះគឺ

និយាយអំពីខ្មាន់ធ្នូ ១ កុញ្ជរ ១ មានរសតិច ១ គង្វាលសេះ ឈ្មោះគិរិទត្ត ១ ចិត្តថ្លាជាចិត្តប្រសើរ ១ ព្រះរាជាទធិវាហនៈ ១ ចចកជម្ពុកៈ ១ សត្វមានក្រចកជាសីហៈ ១ ស្រូវសំទូង ១ នាគដ៏ប្រសើរ ១ ត្រូវជា ១០។

## រុហកវគ្គ ទី៥

CS sut.kn.jat.v02.05 | ភាគទី ៥៨

(៥. រុហកវគ្គោ)

## រុហកជាតក ទី១

CS sut.kn.jat.191 | ភាគទី ៥៨

### (១៩១. រុហកជាតកំ (២-៥-១))

[២៣១] (ព្រះរាជាពោធិសត្វ ត្រាស់ថា) ម្នាលរុហកព្រាហ្មណ៍ដ៏ចំរើន ខ្សែបន្លោះធ្នូសូម្បីដាច់ហើយ គេតឲ្យជាប់វិញ អ្នកចូរតភ្ជាប់ជាមួយនឹងនាងបូរាណីវិញចុះ កុំលុះក្នុងអំណាចនៃសេចក្តីក្រោធឡើយ។

[២៣២] (រុហកបុរោហិត ក្រាបទូលថា) កាលបើសំបកក្រចៅដែល (ទន់) មាន ទាំងជនអ្នកធ្វើក៏មាន ទូលព្រះបង្គំ នឹងធ្វើនូវខ្សែបន្លោះធ្នូដទៃ មិនគួរឡើយនឹងតភ្ជាប់ជាមួយនឹងនាងបូរាណីទេ។

ចប់ រុហកជាតក ទី១។

## សិរីកាឡកណ្ណិជាតក ទី២

CS sut.kn.jat.192 | ភាគទី ៥៨

### (១៩២. សិរិកាឡកណ្ណិជាតកំ (២-៥-២ ))

[២៣៣] (ព្រះបាទវិទេហរាជ ត្រាស់ថា) ម្នាលមហោសធ ស្ត្រីដែលមានរូបល្អ តែស្ត្រីនោះមានសីល បុរសមិនគប្បីប្រាថ្នាស្ត្រីនោះ អ្នកជឿឬទេ។

[២៣៤] (មហោសធ ក្រាបទូលថា) បពិត្រមហារាជ ទូលព្រះបង្គំជឿ បុរសដែលថោកទាប (មិនត្រូវការនឹងស្ត្រីនោះទេ) (ព្រោះ) សិរី និងកាឡកណ្ណី រមែងមិនចួបប្រសព្វគ្នាក្នុងកាលណាម្តងឡើយ។

ចប់ សិរីកាឡកណ្ណិជាតក ទី២។

## ចុល្លបទុមជាតក ទី៣

CS sut.kn.jat.193 | ភាគទី ៥៨

### (១៩៣. ចូឡបទុមជាតកំ (២-៥-៣))

[២៣៥] (ព្រះរាជាពោធិសត្វ ត្រាស់ថា) ស្ត្រីទ្រុស្តសីលនោះ គឺមេនេះឯង បទុមកុមារនោះ មិនមែនអ្នកដទៃឡើយ គឺអញនេះឯង (ស្ត្រីនោះ) និយាយចំពោះបុរសណាថា ជាប្តីអំពីក្មេងរបស់អញ បុរសនោះ មានដៃកំបុត មិនមែនអ្នកដទៃឡើយ គឺអាកំបុតនេះឯង ស្ត្រីទាំងឡាយត្រូវគេសម្លាប់ចោល ព្រោះស្ត្រីទាំងឡាយ មិនមានពាក្យសច្ចៈ។

[២៣៦] អ្នកទាំងឡាយ ចូរសំពងបុរសលាមកអាក្រក់ ប្រាកដស្មើដោយសាកសព ដែលសេពនូវប្រពន្ធនៃបុគ្គលដទៃនេះ ដោយអង្រែផង ហើយកាត់ត្រចៀក និងច្រមុះនៃស្ត្រីដែលរស់នៅ គោរពប្តីអាក្រក់នេះផង។

ចប់ ចុល្លបទុមជាតក ទី៣។

## មណិចោរជាតក ទី៤

CS sut.kn.jat.194 | ភាគទី ៥៨

### (១៩៤. មណិចោរជាតកំ (២-៥-៤))

[២៣៧] (នាងសុជាតា ពោលថា) ពួកទេវតា (ជាអ្នករមិលមើលពួកជនអ្នកមានសីលក្នុងលោកនេះ) មិនមាន រមែងប្រាសខ្ចាត់ខ្ចាយដោយពិត (ពួកសមណព្រាហ្មណ៍) ដែលគេសន្មតថាជាលោកបាលក្នុងលោកនេះ ក៏មិនមានដោយពិត ទាំងពួកជនអ្នកហាមឃាត់នូវជនទាំងឡាយអ្នកមិនសង្រួម ធ្វើតែអំពើដ៏សហ័ស (អាក្រក់) ក៏មិនមានដោយពិត។

[២៣៨] (ព្រះឥន្ទ្រ ត្រាស់ថា) ក្នុងរាជ្យនៃស្តេចមិនប្រកបដោយធម៌នោះ ភ្លៀងរមែងបង្អុរចុះក្នុងកាលមិនគួរ មិនបង្អុរចុះក្នុងកាលដែលគួរ ឯស្តេចមិនប្រកបដោយធម៌នោះ រមែងច្យុតចាកឋានសួគ៌ ត្រូវគេសម្លាប់ចោលដោយហេតុត្រឹមប៉ុណ្ណោះដោយពិត។

ចប់ មណិចោរជាតក ទី៤។

## បព្វតូបត្ថរជាតក ទី៥

CS sut.kn.jat.195 | ភាគទី ៥៨

### (១៩៥. បព្វតូបត្ថរជាតកំ (២-៥-៥))

[២៣៩] (ព្រះបាទព្រហ្មទត្ត ត្រាស់ថា) ស្រះបោក្ខរណីដ៏ត្រជាក់ កើតហើយក្បែរជើងភ្នំ ជាទីរីករាយ ចចកកាលដឹងថា ស្រះបោក្ខរណីនោះ សីហៈរក្សាហើយ ក៏នៅតែផឹក (ទឹកក្នុងស្រះនោះ)។

[២៤០] (អមាត្យពោធិសត្វ ពោលថា) បពិត្រមហារាជ (មិនត្រឹមតែចចកប៉ុណ្ណោះទេ) ពួកសត្វដែលមានជើង រមែងនាំគ្នាចុះផឹកទឹកស្ទឹងធំដែរ (តែស្ទឹងធំនោះ) នឹងក្លាយទៅជាមិនមែនស្ទឹងដោយហេតុនោះក៏ទេ បើ (ស្ត្រីនោះ) ជាទីស្រឡាញ់របស់ព្រះអង្គហើយ សូមព្រះអង្គអត់ទោសចុះ។

ចប់ បព្វតូបត្ថរជាតក ទី៥។

## វលាហកជាតក ទី៦

(១៩៦. វលាហកស្សជាតកំ (២-៥-៦))

[២៤១] (ព្រះសាស្តា ត្រាស់ថា) ពួកនរជនណា មិនធ្វើតាមឱវាទដែលព្រះពុទ្ធសំដែងហើយ ពួកនរជននោះ នឹងដល់នូវសេចក្តីវិនាស ដូចពួកឈ្មួញដែលអារក្សទឹកទាំងឡាយ (លួងលោមហើយ)។

[២៤២] (ម្យ៉ាងទៀត ពួកនរជនណា ធ្វើតាមឱវាទដែលព្រះពុទ្ធសំដែងហើយ ពួកនរជននោះ នឹងដល់នូវត្រើយ គឺព្រះនិព្វានដោយសួស្តី ដូចពួកឈ្មួញ (ធ្វើតាមពាក្យ) ដែលស្តេចវលាហក (ពោលហើយ)។

ចប់ វលាហកជាតក ទី៦។

## មិត្តាមិត្តជាតក ទី៧



(១៩៧. មិត្តាមិត្តជាតកំ (២-៥-៧))

[២៤៣] (ព្រះពោធិសត្វ ពោលថា) បុគ្គលឃើញបុគ្គលនោះហើយ មិនញញឹមផង មិនរីករាយតបនឹងបុគ្គលនោះផង មិនឲ្យភ្នែកចំពោះបុគ្គលនោះ គឺមិនសំឡឹងចំភ្នែកនឹងភ្នែកផង ប្រព្រឹត្តខ្មាំងសត្រូវ (ចំពោះបុគ្គលនោះផង)។

[២៤៤] បុគ្គលជាបណ្ឌិត ឃើញហើយ ឮហើយ គប្បីស្គាល់នូវបុគ្គលមិនមែនជាមិត្ត ដោយអាការៈទាំងឡាយណា អាការៈទាំងឡាយនុ៎ះ រមែងមានតាំងនៅក្នុងបុគ្គលមិនមែនជាមិត្ត។

ចប់ មិត្តាមិត្តជាតក ទី៧។

## រាធជាតក ទី៨



(១៩៨. រាធជាតកំ (២-៥-៨))

[២៤៥] (ព្រាហ្មណ៍ ពោលថា) ម្នាលអ្នក អញមកអំពីទីព្រាត់ប្រាសហើយ ទើបនឹងមកដល់ក្នុងកាលអម្បាញ់មិញនេះ ម្នាលអ្នក ចុះមាតារបស់អ្នក មិនចូលទៅសេពនឹងបុរសដទៃខ្លះទេឬ។

[២៤៦] (សេកឈ្មោះរាធៈ ពោលថា) បុគ្គលកាលពោលវាចា ដែលប្រកបដោយសច្ចៈនេះ តែមិនល្អ គប្បីដេកដូចជាសេកឈ្មោះបោដ្ឋបាទ ត្រូវនាងព្រាហ្មណីដុត ក្នុងជើងក្រានដូច្នោះ។

ចប់ រាធជាតក ទី៨។

## គហបតិជាតក ទី៩



(១៩៩. គហបតិជាតកំ (២-៥-៩ ))

[២៤៧] (គហបតីពោធិសត្វ ពោលថា) ហេតុទាំងពីរយ៉ាង មិនគួរដល់យើង ហេតុទាំងពីរយ៉ាង យើងមិនពេញចិត្តទេ ស្រីនេះចុះកាន់ជង្រុក ហើយនិយាយថា ខ្ញុំមិនសងដូច្នេះ។

[២៤៨] ម្នាលម្ចាស់ស្រុក ព្រោះហេតុនោះ បានជាយើងនិយាយនឹងអ្នក កាលបើជីវិតលំបាកតិច (ប្រព្រឹត្តទៅយ៉ាងនេះ កាលយើងកាន់យក) នូវសាច់ អ្នក (បានឲ្យ) នូវគោចាស់ស្គម ហើយធ្វើនូវការកំណត់ពីរខែ ឥឡូវនេះ មកទៀនទារក្នុងកាលដែលមិនទាន់ដល់កំណត់ក៏អំពើនោះ យើងមិនពេញចិត្តឡើយ។

ចប់ គហបតិជាតក ទី៩។

## សាធុសីលជាតក ទី១០



(២០០. សាធុសីលជាតកំ (២-៥-១០))

[២៤៩] (ព្រាហ្មណ៍ សួរថា) ភាពនៃបុគ្គលមានសរីរៈល្អ ភាពនៃបុគ្គលចាស់ ភាពនៃបុគ្គលមានជាតិល្អ ភាពនៃបុគ្គលមានសីលល្អ យើងសូមសួរអ្នកជាព្រាហ្មណ៍ថា បណ្តាបុគ្គលទាំងបួននាក់នោះ តើយើងប្រាថ្នានូវបុគ្គលណា។

[២៥០] (អាចារ្យពោធិសត្វ ពោលថា) សេចក្តីចំរើនរមែងមានក្នុងបុគ្គលមានសរីរៈល្អ យើងសូមធ្វើនមស្ការចំពោះបុគ្គលចាស់ សេចក្តីចំរើន រមែងមានក្នុងបុគ្គលដែលមានជាតិល្អ តែសីលរមែងពេញចិត្តដល់យើងទាំងឡាយ។

ចប់ សាធុសីលជាតក ទី១០។

ប់ រុហកវគ្គ ទី៥។

ឧទ្ទាននៃរុហកវគ្គនោះគឺ

និយាយអំពីរបាកព្រាហ្មណ៍ ១ ស្រីមានរូបល្អ ១ បុរសដែលគេប្រហារដោយអង្រែ ១ ទេវតាព្រាត់ប្រាស ១ ស្រះបោក្ខរណី ១ ជាគំរប់ ៥ តពីនោះមក ពួកឈ្មួញរួចពីអារក្សទឹក ១ ញញឹម ១ ការមកអស់កាលដ៏យូរ ១ ជង្រុក ១ សរីរៈ ១ ត្រូវជា ១០ ជាតក។

## នតំទឡ្ហវគ្គ ទី៦

CS sut.kn.jat.v02.06 | ភាគទី ៥៨

(៦. នតំទឡ្ហវគ្គោ)

### ពន្ធនាគារជាតក ទី១

CS sut.kn.jat.201 | ភាគទី ៥៨

(២០១. ពន្ធនាគារជាតកំ (២-៦-១))

[២៥១] (តាបសពោធិសត្វ ពោលថា) ចំណងណា កើតអំពីដែកក្តី កើតអំពីឈើក្តី កើតអំពីស្មៅជំណោកទន្សាយក្តី ចំណងនោះ អ្នកប្រាជ្ញទាំងឡាយមិនហៅថាចំណងមាំឡើយ ជនទាំងឡាយមានសេចក្តីត្រេកអរជ័ក្រៃលែង ក្នុងកែវមណី និងកុណ្ឌលទាំងឡាយផង សេចក្តីអាឡោះអាល័យ ក្នុងកូន និងប្រពន្ធទាំងឡាយផង។

[២៥២] អ្នកប្រាជ្ញទាំងឡាយ ពោលថា ចំណងនុ៎ះមាំ អាចទាញសត្វទំលាក់ចុះក្នុងអបាយ ជាចំណងដ៏ធូរ តែបុគ្គលស្រាយបានដោយក្រ ចំណែកខាងអ្នកប្រាជ្ញទាំងឡាយ បានកាត់នូវចំណង គឺកិលេសនេះ ហើយមិនមានសេចក្តីអាឡោះអាល័យ បានលះបង់នូវសេចក្តីសុខក្នុងកាម ចៀសចេញទៅ។

ចប់ ពន្ធនាគារជាតក ទី១។

### កេឡិសីលជាតក ទី២

CS sut.kn.jat.202 | ភាគទី ៥៨

(២០២. កេឡិសីលជាតកំ (២-៦-២))

[២៥៣] (ព្រះសាស្តា ត្រាស់ថា) ហង្សទាំងឡាយក្តី ក្រៀលទាំងឡាយក្តី ក្ងោកទាំងឡាយក្តី ដំរីទាំងឡាយក្តី ពួកម្រឹគពិសេសក្តី សត្វទាំងអស់ រមែងខ្លាចសត្វសីហៈ (ព្រោះ) ការប្រៀបផ្ទឹមក្នុងកាយមិនមានឡើយ។

[២៥៤] បណ្តាមនុស្សទាំងឡាយ (មនុស្សណា) បើទុកជាខ្លួននៅក្មេង តែមានប្រាជ្ញាវាងវៃ មនុស្សនោះ ទើបឈ្មោះថា ធំក្នុងពួកមនុស្សនោះ មនុស្សល្ងង់ខ្លៅ សូម្បីមានសរីរៈ (ធាត់ធំ) ក៏មិនឈ្មោះថាធំឡើយ។

ចប់ កេឡិសីលជាតក ទី២។

### ខន្ធបរិត្តជាតក ទី៣

CS sut.kn.jat.203 | ភាគទី ៥៨

(២០៣. ខណ្ឌជាតកំ (២-៦-៣))

[២៥៥] (តាបសពោធិសត្វ ពោលថា) ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះវិរូបក្ខៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះឯរាបថៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះឆព្យាបុត្តៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងត្រកូលស្តេចនាគឈ្មោះកណ្ហាគោតមកៈទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វឥតជើងទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងពីរទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើង ៤ ទាំងឡាយផង ភាវៈជាមិត្ររបស់អាត្មាអញ (ចូរមានជាមួយ) នឹងសត្វជើងច្រើនទាំងឡាយផង សត្វឥតជើងកុំបៀតបៀនអាត្មាអញឡើយ សត្វជើងពីរកុំបៀតបៀនអាត្មាអញឡើយ សត្វជើង ៤ កុំបៀតបៀនអាត្មាអញឡើយ សត្វជើងច្រើនកុំបៀតបៀនអាត្មាអញឡើយ សព្វសត្វទាំងឡាយផង សព្វប្រាណទាំងឡាយផង សព្វភូតទាំងឡាយផង ទាំងអស់គ្នា សូមសព្វសត្វ (ទាំងនោះ) ឃើញនូវសេចក្តីចំរើនទាំងឡាយ សេចក្តីលាមកអាក្រក់តិចតួច កុំមកដល់ឡើយ គឺថា កុំកើតមានដល់សត្វទាំងនោះឡើយ។

[២៥៦] ព្រះពុទ្ធមានគុណប្រមាណមិនបាន ព្រះធម៌មានគុណប្រមាណមិនបាន ព្រះសង្ឃមានគុណប្រមាណមិនបាន សត្វលូន ឬសត្វវារទាំងឡាយ គឺពស់ ខ្ទួយ ក្អែប ពីងពាង តុកកែ និងកណ្តុរ សុទ្ធតែមានប្រមាណ (មិនច្រើនដូចគុណព្រះរតនត្រ័យ) កិរិយារក្សាអាត្មាអញបានធ្វើហើយ កិរិយាការពារ អាត្មាអញបានធ្វើហើយ ពួកសត្វ (កាច) ទាំងឡាយ ចូរចៀសចេញទៅ អាត្មាអញ (ធ្វើ) នូវនមស្ការចំពោះព្រះមានព្រះភាគ នមស្ការចំពោះព្រះសម្មាសម្ពុទ្ធទាំងឡាយ ៧ ព្រះអង្គ។

ចប់ ខន្ធបរិត្តជាតក ទី៣។

### វីរកជាតក ទី៤

CS sut.kn.jat.204 | ភាគទី ៥៨

(២០៤. វីរកជាតកំ (២-៦-៤))

[២៥៧] (ប្រពន្ធរបស់ក្អែកគោក សួរថា) នែក្អែកទឹកឈ្មោះវីរកៈ អ្នកឃើញសត្វស្លាបដែលពោលពាក្យពីរោះ មានភ្លួតកដូចជាភ្លួតកនៃក្ងោក ជាក្អែកគោកឈ្មោះសវិដ្ឋកៈ ជាប្តីរបស់ខ្ញុំដែរឬ។

[២៥៨] (ក្អែកទឹកពោធិសត្វ ពោលថា) ក្អែកសវិដ្ឋកៈ កាលធ្វើតាមសត្វស្លាប អ្នកត្រាច់ទៅក្នុងទឹក និងលើគោក បានបរិភោគត្រី

ស្រស់ជានិច្ចនោះ ត្រូវសោរាយព័ន្ធព័ទ្ធស្លាប់ទៅហើយ។

ចប់ វីរកជាតក ទី៤។

## គង្គេយ្យជាតក ទី៥

CS sut.kn.jat.205 | ភាគទី ៥៨

(២០៥. គង្គេយ្យជាតកំ (២-៦-៥))

[២៥៩] (អណ្ដើក ពោលថា) ត្រីទាំងឡាយ នៅក្នុងទន្លេគង្គាក៏ល្អ ត្រីទាំងឡាយនៅក្នុងទន្លេយមុនាក៏ល្អ តែបុរសមានជើង ៤ នេះ [5] មានបរិមណ្ឌលដូចដើមជ្រៃផង មានករវែងដូចចន្ទោលនៃរថផង ល្អរុងរឿងលើសអ្នកទាំងឡាយរាល់គ្នាទៅទៀត។

[២៦០] (ត្រីទាំងឡាយ ពោលថា) យើងសួរហេតុណា មិនប្រាប់ហេតុនោះ យើងសួរហើយត្រឡប់ប្រាប់ហេតុដទៃវិញ សត្វសរសើរតែខ្លួនឯងនេះ មិនគាប់ចិត្តយើងទេ។

ចប់ គង្គេយ្យជាតក ទី៥។

## កុរុង្គមិគជាតក ទី៦

CS sut.kn.jat.206 | ភាគទី ៥៨

(២០៦. កុរុង្គមិគជាតកំ (២-៦-៦))

[២៦១] (សត្វចចាត ពោលថា) ម្នាលអណ្ដើក សូមអ្នកកាត់នូវអន្ទាក់ព្រ័ត្រ ដោយធ្មេញចុះ យើងនឹងធ្វើព្រានមិនឲ្យមកបាន។

[២៦២] (ព្រះសាស្ដា ត្រាស់ថា) អណ្ដើកចូលទៅកាន់ទឹក សត្វប្រើសក៏ចូលទៅព្រៃ ឯសត្វចចាត បាននាំកូនទាំងឡាយអំពីចុងឈើទៅក្នុងទីឆ្ងាយ។

ចប់ កុរុង្គមិគជាតក ទី៦។

## អស្សកជាតក ទី៧

CS sut.kn.jat.207 | ភាគទី ៥៨

(២០៧. អស្សកជាតកំ (២-៦-៧ ))

[២៦៣] (សត្វកំពោងញី ពោលថា កាលពីដើម) ឧយ្យានប្រទេសនេះ ខ្ញុំបានត្រាច់ទៅជាមួយនឹងស្ដេចអស្សកៈ ជាប្ដី ជាទីស្រឡាញ់ដែលខ្ញុំប្រាថ្នាគេ ៗ ប្រាថ្នានូវខ្ញុំ។

[២៦៤] សេចក្ដីសុខ និងទុក្ខថ្មី តែងបិទបាំងនូវសុខ និងទុក្ខចាស់ ព្រោះហេតុនោះ សត្វកំពោងឈ្មោល ជាទីស្រឡាញ់របស់ខ្ញុំជាងស្ដេចអស្សកៈទៅទៀត។

ចប់ អស្សកជាតក ទី៧។

## សុំសុមារជាតក ទី៨

CS sut.kn.jat.208 | ភាគទី ៥៨

(២០៨. សុសុមារជាតកំ (២-៦-៨))

[២៦៥] (ស្វាពោធិសត្វ ពោលថា) ផ្លែឈើទាំងឡាយណា (ដែលអ្នកឃើញហើយ) នាត្រើយសមុទ្រខាងនាយ ផ្លែឈើទាំងនោះ គឺផ្លែស្វាយក្ដី ផ្លែព្រីងក្ដី ផ្លែខ្នុរក្ដី មិនគួរដល់យើងឡើយ ដើមល្វា (នេះឯង) ជាឈើដ៏ប្រសើររបស់យើង។

[២៦៦] សរីរៈរបស់អ្នក ធំមែន ប៉ុន្តែប្រាជ្ញាសមគួរនឹងសរីរៈនោះមិនមាន នៃក្រពើ ឯងត្រូវអញបញ្ឆោតហើយ ឥឡូវ ចូរឯងទៅតាមស្រួលចុះ។

ចប់ សុំសុមារជាតក ទី៨។

## កក្ករជាតក ទី៩

CS sut.kn.jat.209 | ភាគទី ៥៨

(២០៩. កុក្កុដជាតកំ (២-៦-៩))

[២៦៧] (មាន់ព្រៃ ពោលថា) ដើមត្រចៀកប្រើស និងដើមស្រម៉ពិភេទទាំងឡាយដុះក្នុងព្រៃ យើងធ្លាប់ឃើញហើយ អ្នកអាចឈានដើរទៅកាន់ដើមឈើបានយ៉ាងណា ឯឈើទាំងនោះ មិនអាចឈានដើរទៅបានយ៉ាងនោះទេ។

[២៦៨] (ព្រាន ពោលថា) មាន់ព្រៃចាស់នេះ ទំលាយនូវទ្រុងចេញមកហើយ ជាសត្វឈ្លាសក្នុងអន្ទាក់ ដែលធ្វើដោយរោមកន្ទុយក៏បានចេញទៅផង និយាយផង។

ចប់ កក្ករជាតក ទី៩។

### កន្ទគលកជាតក ទី១០

CS sut.kn.jat.210 | ភាគទី ៥៨

**(២១០. កន្ទគលកជាតកំ (២-៦-១០))**

[២៦៩] (សត្វសសេះឈ្មោះកន្ទគលកៈ ពោលថា) ម្នាលសសេះឈ្មោះខទិរវនិយៈដ៏ចំរើន អំបែងក្បាលបែកហើយ ដោយការប្រហារតែម្តង ព្វដ៏ដើមឈើណា ដើមឈើនេះ មានស្លឹកល្អិតប្រកបដោយបន្លា តើជាឈើឈ្មោះអ្វី។

[២៧០] (ខទិរនិវយបក្សី ពោលថា) ឱហ្ន៎ សសេះនេះ កាលចោះនូវឈើក្នុងព្រៃទាំងឡាយ បានហើរទៅក្នុងពួកឈើមិនមានខ្លឹម ជាចំណែកនៃឈើស្ងួត ក្នុងកាលជាខាងក្រោយមក សសេះ (នេះ) បានហើរមកទំលាយអំបែងក្បាល (របស់ខ្លួន) នឹងដើមសង្កែ ជាឈើន័យដោយច្រើន គេប្រែថា ដើមគគី។ មានខ្លឹមអំពីកំណើត។

ចប់ កន្ទគលកជាតក ទី១០។

ចប់ នតំទឡ្ហវគ្គ ទី៦។

ឧទ្ទាននៃនតំទឡ្ហវគ្គនោះគឺ

និយាយអំពីចំណងមាំ ១ ហង្សប្រសើរ ១ ស្តេចនាគឈ្មោះវិរូបក្ខៈ ១ ក្អែកគោកឈ្មោះសវិដ្ឋកៈ ១ ត្រីដ៏ប្រសើរ ១ ប្រើស ១ ស្តេចឈ្មោះអស្សកៈ ១ ផ្លែស្វាយដ៏ប្រសើរ ១ មាន់ ១ សសេះ ១ ត្រូវជា ១០។

## ពីរណត្ថម្ភកវគ្គ ទី៧

CS sut.kn.jat.v02.07 | ភាគទី ៥៨

**(៧. ពីរណថម្ភវគ្គោ)**

### សោមទត្តជាតក ទី១

CS sut.kn.jat.211 | ភាគទី ៥៨

**(២១១. សោមទត្តជាតកំ (២-៧-១))**

[២៧១] (ពោធិសត្វ ពោលថា បពិត្រលោកអាពុក) លោកមិនមានសេចក្តីធ្វេសប្រហែសជានិច្ច បានធ្វើសេចក្តីព្យាយាម ក្នុងព្រៃស្មសានដ៏ដេរដាសដោយគុម្ពនៃស្បូវអណ្តាស អស់ ១ ឆ្នាំ (កាលបើដូច្នេះ) លោកចូរទៅកាន់បរិសទ្យ ហើយធ្វើ (នូវហេតុនោះ) ឲ្យទៅជាហេតុដទៃវិញ សេចក្តីព្យាយាម រមែងមិនរក្សានូវបុគ្គលដែលឥតប្រាជ្ញាឡើយ។

[២៧២] (ព្រាហ្មណ៍ ពោលថា) ម្នាលសោមទត្តជាកូន ធម្មតាជនអ្នកសូមគេ រមែងដល់នូវហេតុពីរយ៉ាង គឺមិនបាននូវទ្រព្យ ១ បាននូវទ្រព្យ ១ ព្រោះថា ការសូមគេ រមែងមានសភាពយ៉ាងនេះជាធម្មតា។

ចប់ សោមទត្តជាតក ទី១។

### ឧច្ឆិដ្ឋភត្តជាតក ទី២

CS sut.kn.jat.212 | ភាគទី ៥៨

**(២១២. ឧច្ឆិដ្ឋភត្តជាតកំ (២-៧-២))**

[២៧៣] (ព្រាហ្មណ៍ ពោលថា) អាការខាងលើដទៃ អាការខាងក្រោមដទៃ ម្នាលនាងព្រាហ្មណី អញសួរចំពោះនាងថា បាយខាងក្រោមតើដូចម្តេច បាយខាងលើ តើដូចម្តេច។

[២៧៤] (កូនអ្នករបាំពោធិសត្វ ពោលថា) ម្នាលអ្នកដ៏ចំរើន ខ្ញុំអ្នករបាំ ជាអ្នកសូម មកដល់ក្នុងទីនេះ ឯសហាយរបស់នាងព្រាហ្មណីនេះ ចុះទៅហើយកាន់ជង្រុក អ្នកស្វែងរកនូវបុរសណា បុរសនោះ នេះឯង។

ចប់ ឧច្ឆិដ្ឋភត្តជាតក ទី២។

### ភរុរាជជាតក ទី៣

CS sut.kn.jat.213 | ភាគទី ៥៨

**(២១៣. ភរុជាតកំ (២-៧-៣))**

[២៧៥] (ព្រះសាស្តា ត្រាស់ថា) តថាគតបានឮដូច្នេះថា ស្តេចនៅក្នុងដែនភរុ បានធ្វើនូវទោសដល់ពួកឥសី ស្តេចនោះ (ដល់នូវឆន្ទាគតិ) ក៏ដាច់សូន្យព្រមទាំងដែន ដល់នូវសេចក្តីវិនាស។

[២៧៦] ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ តែងមិនសសើរនូវការលុះក្នុងឆន្ទាគតិ (បុគ្គល) មានចិត្ត គឺកិលេសមិនប្រទូស្តហើយ គប្បីពោលនូវវាចាដែលប្រកបដោយសច្ចៈ។

ចប់ ភរុរាជជាតក ទី៣។

### បុណ្ណនទីជាតក ទី៤

### (២១៤. បុណ្ណនទីជាតកំ (២-៧-៤ ))

[២៧៧] (ព្រះរាជាទ្រង់លិខិតក្នុងព្រះរាជសាសន៍ថា) ជនទាំងឡាយពោលនូវស្ទឹង ដែលល្មមសត្វណាផឹកបាន ថាជាស្ទឹងពេញហើយផង ជនទាំងឡាយពោលនូវសន្ទូង ដែលល្មមសត្វណាពួនបាន ថាជាសន្ទូងកើតហើយផង ជនទាំងឡាយហៅរកនូវបុគ្គលដែលទៅហើយកាន់ទីឆ្ងាយដោយសត្វណាផង សត្វនោះ យើងនាំមកហើយដើម្បីអ្នក ម្នាលព្រាហ្មណ៍ ចូរអ្នកបរិភោគ (នូវសាច់ក្អែកនេះ) ចុះ។

[២៧៨] (ពោធិសត្វ ពោលថា) កាលណាស្តេចរព្ញកអញ សូម្បីតែសាច់ក្អែកក៏ផ្ញើមក (កាលស្តេចបាន) ហង្សក្តី ក្រៀលក្តី ក្ងោកក្តី (ហេតុអ្វីក៏មិនរព្ញក) ការមិនរព្ញកនេះឯង ជាសេចក្តីលាមកបំផុត (ក្នុងលោក)។

ចប់ បុណ្ណនទីជាតក ទី៤។

## កច្ឆបជាតក ទី៥



### (២១៥. កច្ឆបជាតកំ (២-៧-៥ ))

[២៧៩] (អាមាត្យពោធិសត្វ ពោលថា) អណ្តើក កាលបើឈើ ខ្លួនពាំស៊ប់ហើយ ហានិយាយសម្លាប់នូវខ្លួនឯង ឈ្មោះថាសម្លាប់ដោយវាចារបស់ខ្លួន។

[២៨០] បពិត្រព្រះអង្គមានព្យាយាមប្រសើរជាងជន (ឯបណ្ឌិតបុរស) ឃើញនូវហេតុនេះហើយ មិនគប្បីបញ្ចេញវាចាជាកុសល ឲ្យហួសវេលា ព្រះអង្គគង់នឹងទតឃើញអណ្តើក ដែលដល់នូវសេចក្តីវិនាស ព្រោះតែនិយាយច្រើន។

ចប់ កច្ឆបជាតក ទី៥។

## មច្ឆជាតក ទី៦



### (២១៦. មច្ឆជាតកំ (២-៧-៦))

[២៨១] (ត្រីឈ្មោល ពោលថា) ភ្លើងនេះអញមិនក្តៅ ឈើស្រួចដែលគេបិតសំរួចល្អហើយ ក៏អញមិនឈឺ អញឈឺតែត្រង់មេត្រីសំគាល់អញ ថាទៅត្រេកអរនឹងមេត្រីដទៃនោះ។

[២៨២] ភ្លើង គឺរាគៈនោះ រលាកនូវអញផង ចិត្ត (ដ៏សម្បយុត្តដោយរាគៈ) ក៏ញាំងអញឲ្យក្តៅផង បពិត្រព្រានសំណាញ់ទាំងឡាយ សូមអ្នកទាំងឡាយលែងខ្ញុំទៅ (សត្វដែលបិតនៅ) ក្នុងកាម អ្នកទាំងឡាយកុំបៀតបៀនក្នុងហេតុនីមួយ។

ចប់ មច្ឆជាតក ទី៦។

## សេគ្គុជាតក ទី៧



### (២១៧. សេគ្គុជាតកំ (២-៧-៧))

[២៨៣] (បិតា ពោលថា) សត្វលោកទាំងអស់ ជាអ្នកមានចិត្តរីករាយ (ដោយការសេពកាម) នាងសេគ្គុ ជាស្រីមិនឈ្លាសក្នុងធម៌របស់អ្នកស្រុក នាងដែលយើងចាប់ហើយ យំក្នុងព្រៃ ដោយធម្មតាណា ធម្មតានោះរបស់នាង ឈ្មោះថា នៅក្មេងទេឬ។

[២៨៤] (នាងសេគ្គុកុមារិកា ពោលថា) ជនណាគប្បីជាទីពឹងរបស់ខ្ញុំ ដែលទុក្ខពាល់ត្រូវហើយ ជននោះជាបិតារបស់ខ្ញុំ បានប្រទូស្តក្នុងព្រៃ ខ្ញុំនោះកន្ទក់កន្ទេញចំពោះអ្នកណា ក្នុងកណ្តាលព្រៃ បិតាណា ជាអ្នកការពារ បិតានោះធ្វើនូវកម្មដ៏សហស។

ចប់ សេគ្គុជាតក ទី៧។

## កូដវាណិជជាតក ទី៨ (២១៨)



### (២១៨. កូដវាណិជជាតកំ (២-៧-៨))

[២៨៥] (វិនិច្ឆយាមាត្យពោធិសត្វ ពោលថា) កលបញ្ឆោតតបចំពោះបុគ្គលអ្នកមានកលបញ្ឆោត អ្នកគិតល្អហើយ ការកោងតបចំពោះបុគ្គលអ្នកកោង អ្នកបានតទល់ (ល្អ) ហើយ ថាបើកណ្តុរទាំងឡាយ គប្បីស៊ីនូវផាលមែន ហេតុអ្វីក៏សត្វខ្លែងទាំងឡាយ នាំក្មេងទៅមិនបាន។

[២៨៦] ព្រោះថា បុគ្គលកោងតបទាំងឡាយ រមែងមានចំពោះបុគ្គលអ្នកកោង បុគ្គលអ្នកបោកប្រាស ដទៃអំពីបុគ្គលអ្នកបោកប្រាស រមែងមាន (ដល់) បុគ្គលអ្នកបោកប្រាស ម្នាលបុរសអ្នកបាត់កូន អ្នកចូរឲ្យនូវផាលដល់បុរសអ្នកបាត់ផាល កុំឲ្យអ្នកបាត់ផាលលួចកូនអ្នកទៅឡើយ។

ចប់ កូដវាណិជជាតក ទី៨។

## គរហិតជាតក ទី៩

(២១៩. គរហិតជាតកំ (២-៧-៩))

[២៨៧] (ពានរពោធិសត្វ ពោលថា) វាចាដែលពោលថា ប្រាក់របស់អញ មាសរបស់អញ អស់យប់ និងថ្ងៃនេះ ជាវាចារបស់មនុស្សទាំងឡាយអ្នកឥតប្រាជ្ញា មិនឃើញអរិយធម៌។

[២៨៨] កក្នុងផ្ទះមួយ មានម្ចាស់ផ្ទះពីរ ១ នាក់ បណ្ដាម្ចាស់ផ្ទះពីរនាក់នោះ ម្ចាស់ផ្ទះម្នាក់ ៗ មិនមានពុកមាត់ មានដោះយារចុះ មានផ្នួងសក់បួងហើយ មានត្រចៀកចោះប្រដាប់ហើយ ដែលគេទិញដោយទ្រព្យដ៏ច្រើន ម្ចាស់ផ្ទះនោះ តែងពោលចាក់ដោតនូវជននោះ។

ចប់ គរហិតជាតក ទី៩។

## ធម្មទ្ធជជាតក ទី១០



(២២០. ធម្មធជជាតកំ (២-៧-១០))

[២៨៩] (សក្កទេវរាជ ពោលថា) អ្នកមានសភាពរស់នៅជាសុខ ចេញចាកដែន ហើយមកកាន់ព្រៃដ៏ស្ងាត់ អ្នកនោះតែម្នាក់ឯង អង្គុយសញ្ជប់សញ្ជឹងនៅជិតគល់ឈើ (ក្នុងព្រៃ) ដូចជាមនុស្សកំព្រា។

[២៩០] (បុរោហិតពោធិសត្វ ពោលថា) ខ្ញុំមានសភាពរស់នៅជាសុខ ចេញចាកដែន ហើយមកកាន់ព្រៃស្ងាត់ ខ្ញុំនោះតែម្នាក់ឯង ការរឭកធម៌របស់សប្បុរស អង្គុយសញ្ជប់សញ្ជឹង ជិតគល់ឈើ (ក្នុងព្រៃ) ដូចជាមនុស្សកំព្រា។

ចប់ ធម្មទ្ធជជាតក ទី១០។

ចប់ ពីរណត្ថម្ភកវគ្គ ទី៧។

ឧទ្ទាននៃពីរណត្ថម្ភកវគ្គនោះគឺ

និយាយអំពីគុម្ពស្មៅរណ្ដាសដ៏ប្រសើរ ១ អ្នករបាំ ១ ស្ដេចកុរុដ៏ឧត្តមប្រសើរ ១ ស្ទឹងពេញដោយទឹក ១ បុគ្គលនិយាយច្រើន ១ ភ្លើង ១ ព្រៃធំ ១ សត្វកណ្ដុរ ១ មនុស្សដោះយារ ១ មនុស្សកំព្រា ១ ត្រូវជា ១០។

# កាសាវវគ្គ ទី៨



(៨. កាសាវវគ្គោ)

## កាសាវជាតក ទី១



(២២១. កាសាវជាតកំ (២-៨-១ ))

[២៩១] (ដំរីពោធិសត្វ ពោលថា) បុគ្គលណា មានទឹកចត់ គឺកិលេសមិនទាន់លះចេញហើយ ជាអ្នកប្រាសចាកទមៈ (ការទូន្មាននូវឥន្ទ្រិយ) និងសច្ចៈ និងស្លៀកដណ្ដប់នូវសំពត់ ដែលជ្រលក់ដោយទឹកចត់ បុគ្គលនោះ មិនគួរនឹងស្លៀកដណ្ដប់នូវសំពត់ជ្រលក់ដោយទឹកចត់ឡើយ។

[២៩២] ចំណែកខាងបុគ្គលណា មានទឹកចត់ គឺកិលេសខ្ជាក់ចោលហើយ មានចិត្តតាំងមាំល្អក្នុងសីលទាំងឡាយ ជាអ្នកប្រកបដោយទមៈ និងសច្ចៈ បុគ្គលនោះឯង ទើបគួរនឹងស្លៀកដណ្ដប់នូវសំពត់ជ្រលក់ដោយទឹកចត់បាន។

ចប់ កាសាវជាតក ទី១។

## ចុល្លនន្ទិយជាតក ទី២



(២២២. ចូឡនន្ទិយជាតកំ (២-៨-២))

[២៩៣] (នាយព្រាន ពោលថា) បារាសរិយព្រាហ្មណ៍ បានពោលនូវពាក្យណាថា បាបកម្មណា ដែលធ្វើហើយ ញុំាងអ្នកឲ្យក្ដៅក្រហាយក្នុងកាលជាខាងក្រោយ អ្នកកុំធ្វើបាបកម្មនោះឡើយ នេះជាពាក្យរបស់អាចារ្យ។

[២៩៤] បុរសធ្វើនូវអំពើទាំងឡាយណា រមែងឃើញនូវអំពើទាំងឡាយនោះ ចំពោះខ្លួន បុរសអ្នកធ្វើអំពើល្អ រមែងទទួលផលល្អ ចំណែកខាងបុរសអ្នកធ្វើអំពើអាក្រក់ រមែងទទួលផលអាក្រក់ បុគ្គលសាបព្រោះនូវពូជណា រមែងបាននូវផ្លែបែបនោះ។

ចប់ ចុល្លនន្ទិយជាតក ទី២។

## បុដភត្តជាតក ទី៣



(២២៣. បុដភត្តជាតកំ (២-៨-៣))

[២៩៥] (អាមាត្យពោធិសត្វ ពោលថា) បុគ្គលគប្បីឱនលំទោនតបចំពោះបុគ្គលអ្នកឱនលំទោនខ្លួន គប្បីគប់រកនូវបុគ្គលអ្នកគប់រកខ្លួន គប្បីធ្វើកិច្ចតបចំពោះបុគ្គលអ្នកធ្វើនូវកិច្ចដល់ខ្លួន កុំគប្បីធ្វើប្រយោជន៍ដល់បុគ្គលអ្នកប្រាថ្នានូវសេចក្តីវិនាសដល់ខ្លួន មិនគប្បីរាប់រកនូវបុគ្គលអ្នកមិនរាប់រកខ្លួន។

[២៩៦] បុគ្គលគប្បីលះនូវបុគ្គលអ្នកលះបង់នូវខ្លួន មិនគប្បីធ្វើនូវឈើដែលតាំងនៅក្នុងព្រៃ គឺសេចក្តីប៉ុនប៉ងក្នុងបុគ្គលនោះ មិនគប្បីសមាគមជាមួយនឹងបុគ្គលដែលមានចិត្តវិប្បលាស សត្វស្លាបដឹងនូវឈើដែលមានផ្លែអស់ហើយ រមែងស្វះស្វែងរកនូវដើមឈើឯទៀតដែលមានផ្លែយ៉ាងណា (បុគ្គលគប្បីគប់រកបុគ្គលដទៃ យ៉ាងនោះដែរ) ព្រោះថា លោកសន្និវាសនៅធំទូលាយណាស់។

ចប់ បុដភត្តជាតក ទី៣។

## កុម្ពីលជាតក ទី៤

CS sut.kn.jat.224 | ភាគទី ៥៨

(២២៤. កុម្ភិលជាតកំ (២-៨-៤))

[២៩៧] (ក្រពើ បាននិយាយថា) បុគ្គលណាមានធម៌ ៤ យ៉ាង គឺសច្ចៈ ១ សុចរិតធម៌ ១ សេចក្តីព្យាយាម ១ ចាគៈ ១ ជាគុណដ៏ចំរើនក្រៃលែង បុគ្គលនោះ រមែងកន្លងនូវសត្រូវបាន។

[២៩៨] ចំណែកបុគ្គលណា មិនមានធម៌ ៤ យ៉ាងនេះ គឺសច្ចៈ ១ សុចរិតធម៌ ១ សេចក្តីព្យាយាម ១ ចាគៈ ១ ជាគុណដ៏ចំរើនក្រៃលែង បុគ្គលនោះ រមែងមិនកន្លងនូវសត្រូវបានទេ។

ចប់ កុម្ពីលជាតក ទី៤។

## ខន្តិវណ្ណនជាតក ទី៥

CS sut.kn.jat.225 | ភាគទី ៥៨

(២២៥. ខន្តិវណ្ណជាតកំ (២-៨-៥))

[២៩៩] (អាមាត្យ បានក្រាបទូលថា) បពិត្រព្រះសម្មតិទេព មានបុរសរបស់ទូលព្រះបង្គំម្នាក់ ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចការទាំងពួង តែបុរសនោះ មានកំហុសមួយ ព្រះអង្គទ្រង់សំគាល់ក្នុងកំហុសរបស់បុរសនោះថា គួរនឹងធ្វើដូចម្តេច។

[៣០០] (ព្រះរាជាពោធិសត្វ មានព្រះបន្ទូលថា) បុរស (ជាអ្នកប្រទូស្ត) ក្នុងផ្ទះរបស់យើងមានដែរ ឯបុរសបែបនេះ (ឥឡូវនេះ) មានក្នុងទីនេះ តែបុរសអ្នកប្រកបដោយចំណែកនៃគុណ គេរកបានដោយកម្រ បានជាយើងចូលចិត្តអត់ធន់។

ចប់ ខន្តិវណ្ណនជាតក ទី៥។

## កោសិយជាតក ទី៦

CS sut.kn.jat.226 | ភាគទី ៥៨

(២២៦. កោសិយជាតកំ (២-៨-៦))

[៣០១] (អាមាត្យពោធិសត្វ ពោលថា) ការចេញទៅក្នុងកាលគួរ ជាការប្រពៃ ការចេញទៅក្នុងកាលមិនគួរ មិនជាការប្រពៃទេ ព្រោះថា (ជនណាមួយ) ចេញទៅក្នុងកាលមិនគួរ រមែងមិនញ៉ាំងប្រយោជន៍តិចតួចឲ្យកើតបាន ជនជាសត្រូវដ៏ច្រើន នឹងចោមចាប់នូវបុរសតែម្នាក់ឯង (ដែលចេញទៅក្នុងកាលមិនគួរ ហើយឲ្យដល់នូវសេចក្តីវិនាសដ៏ធំ) ដូចសេនាក្អែក (ចោមចឹក) នូវសត្វមៀម (ដែលចេញទៅក្នុងកាលមិនគួរ)។

[៣០២] អ្នកប្រាជ្ញដឹងនូវរបៀប និងការចាត់ចែង ដឹងនូវទោសរបស់ជនទាំងឡាយដទៃ បានធ្វើនូវមិត្រទាំងអស់ឲ្យលុះក្នុងអំណាចរបស់ខ្លួន គប្បីបាននូវសេចក្តីសុខដូចសត្វមៀម (មានប្រាជ្ញាចឹកក្បាលក្អែកឲ្យដាច់ស្លាប់) បានសេចក្តីសុខដូច្នោះ។

ចប់ កោសិយជាតក ទី៦។

## គូថបាណកជាតក ទី៧

CS sut.kn.jat.227 | ភាគទី ៥៨

(២២៧. គូថបាណជាតកំ (២-៨-៧ ))

[៣០៣] (សត្វកំពោង ពោលថា) អ្នកជាសត្វក្លៀវក្លា មកចួបប្រទះនឹងយើងជាអ្នកក្លៀវក្លា មានសេចក្តីប្រឹងប្រែង អាចប្រហារគ្នាបាន នៃដំរី អ្នកចូរមក អ្នកចូរត្រឡប់មក អ្នកខ្លាចឬ បានជារត់ទៅ អ្នកស្រុកអង្គៈ និងមគធៈទាំងឡាយ ចូរមើលសេចក្តីព្យាយាម របស់យើងនិងអ្នក។

[៣០៤] (ដំរី ពោលថា) យើងនឹងមិនសម្លាប់អ្នកដោយជើង មិនសម្លាប់ដោយភ្លុក មិនសម្លាប់ដោយប្រមោយទេ យើងនឹងសម្លាប់អ្នកដោយអាចម៍ សត្វស្អុយ ចូរវិនាសដោយរបស់ស្អុយ។

ចប់ គូថបាណកជាតក ទី៧។

## កាមនីតជាតក ទី៨

CS sut.kn.jat.228 | ភាគទី ៥៨

(២២៨. កាមនីតជាតកំ (២-៨-៨))

[៣០៥] (ព្រះបាទពារាណសី ត្រាស់ថា) យើងប្រាថ្នានូវដែន ជាចន្លោះនៃក្រុងទាំង ៣ គឺដែនបញ្ចាលៈ ១ កុរុ ១ កេកកៈ ១ ម្នាលព្រាហ្មណ៍ យើងត្រូវការរាជសម្បត្តិ ក្នុងក្រុងទាំង ៣ នោះ ក្រៃលែងជាងរាជសម្បត្តិក្នុងក្រុងពាណសីនោះទៅទៀត ម្នាលព្រាហ្មណ៍ អ្នកចូររក្សានូវយើង ដែលកាមនាំទៅហើយ។

[៣០៦] (សក្កទេវរាជពោធិសត្វ ត្រាស់ថា) ពេទ្យពួកខ្លះ រមែងធ្វើ (នូវការរក្សា) ចំពោះបុគ្គលដែលពស់ចឹកហើយ បណ្ឌិតទាំងឡាយតែងធ្វើ (នូវការរក្សា) ចំពោះបុគ្គលដែលខ្មោចចូលហើយ បុគ្គលនីមួយ (ក្រៅពីបណ្ឌិត) រមែងមិនធ្វើនូវការរក្សា ចំពោះបុគ្គលដែលកាមនាំទៅហើយ ព្រោះថា ការរក្សាដូចម្ដេច ចំពោះបុគ្គលដែលមានធម៌សដាក់ចុះហើយ។

ចប់ កាមនីតជាតក ទី៨។

## បលាយិជាតក ទី៩

CS sut.kn.jat.229 | ភាគទី ៥៨

(២២៩. បលាយិតជាតកំ (២-៨-៩))

[៣០៧] (ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់ថា) ក្រុងតក្កសិលា យើងឡោមព័ទ្ធជុំវិញហើយ ដោយពពក គឺពលដំរី ស្រែកសំទារដ៏ប្រសើរ ដោយកម្រងផ្កា គឺពលសេះដ៏ប្រសើរ ដោយរលក់ទឹក គឺពលរថ ដោយភ្លៀងខ្លាំង គឺសរ ដោយខ្មាន់ធ្នូជាអ្នកលបចាំប្រហារមាំ។

[៣០៨] អ្នកទាំងឡាយ ចូរស្ទុះទៅផង ចូរលោតផ្លោះទៅផង ចូរស្រែកដោយសម្លេងផ្សេងៗ (មួយអន្លើ) ដោយពលដំរីទាំងឡាយ សម្លេងគឹកកងដ៏ខ្លាំង (ប្រាកដស្មើដោយសម្លេងនៃរន្ទះ) ចូរប្រព្រឹត្តទៅក្នុងថ្ងៃនេះ ដូចជាផ្លេកបន្ទោរ ដែលចេញផុតចាកមេឃកាលគ្រហឹមដូច្នោះ។

ចប់ បលាយិជាតក ទី៩។

## ទុតិយបលាយិជាតក ទី១០

CS sut.kn.jat.230 | ភាគទី ៥៨

(២៣០. ទុតិយបលាយិតជាតកំ (២-៨-១០))

[៣០៩] (ព្រះរាជាគន្ធារៈ ទ្រង់ត្រាស់ថា) ទង់សម្រាប់រថប្រមាណមិនបាន ពលពាហនៈមានត្រើយមិនមានទីបំផុត (រាប់មិនបាន) ពួកសត្រូវគ្របសង្កត់បានដោយក្រ ដូចជាសមុទ្ទសាគរ ដែលហ្វូងក្អែក (គ្របសង្កត់បានដោយក្រ) (ពួកពលរបស់យើងនេះ) ពួកពលដទៃគ្របសង្កត់បានដោយក្រ ដូចជាភ្នំដែលខ្យល់គ្របសង្កត់បានដោយក្រ ក្នុងថ្ងៃនេះ អាត្មាអញប្រកបដោយពលប្រាកដដូច្នោះ កម្រអ្នកណានឹងគ្របសង្កត់បាន។

[៣១០] (ព្រះរាជាពារាណសីពោធិសត្វ ពោលថា) ព្រះអង្គកុំនិយាយនូវអំពើពាលឡើយ ព្រោះបុគ្គលប្រហែលដូចព្រះអង្គ មិន (អាចយករាជសម្បត្តិបានទេ) ព្រះអង្គក្ដៅអន្ទះអន្ទែង (ដោយភ្លើង គឺរាគៈ ទោសៈ មោហៈ និងមានៈតែប៉ុណ្ណោះ) ដ្បិតថា ព្រះអង្គរមែងមិនបាននូវបុគ្គលប្រាកដស្មើដោយខ្ញុំ ដែលជាអ្នកកំចាត់បង់ទេ ដំរីណា នឹងគក់បោកនូវព្រះអង្គ ដូចជាជាន់ឈ្លីនូវដើមបបោសដោយជើង ព្រះអង្គដូចជាដំរី (ចុះប្រេង) ចូលទៅរក ត្រាច់ទៅតែម្នាក់ឯងនោះ។

ចប់ ទុតិយបលាយិជាតក ទី១០។

ចប់ កាសាវវគ្គ ទី៨។

ឧទ្ទាននៃកាសាវវគ្គនោះគឺ

និយាយអំពីសំពត់ដ៏ប្រសើរ ១ ពាក្យរបស់អាចារ្យ ១ ផ្លែឈើអស់ហើយ ១ ធម៌ដ៏ប្រសើរ ៤ យ៉ាង ១ បុរសដ៏ខ្ពង់ខ្ពស់ ១ សត្វក្អែក ១ ពួកជនក្នុងដែនមគធៈ ១ ដែន ៣ កន្លែង ១ ដំរីដ៏ប្រសើរស្រែកសំទារ ១ ទង់ដ៏ប្រសើរ ១ ត្រូវជា ១០។

# ឧបាហនវគ្គ ទី៩

CS sut.kn.jat.v02.09 | ភាគទី ៥៨

(៩. ឧបាហនវគ្គោ)

## ឧបាហនជាតក ទី១

CS sut.kn.jat.231 | ភាគទី ៥៨

(២៣១. ឧបាហនជាតកំ (២-៩-១))

[៣១១] (ទ្រម័កដំរីពោធិសត្វ ពោលថា) ស្បែកជើងដែលបុរសទិញហើយ ដើម្បីប្រយោជន៍ដោយសេចក្ដីសុខ ជាស្បែកជើងក្ដៅហើយដោយកំដៅថ្ងៃ បៀតបៀនផ្ទៃជើង គប្បីនាំមកនូវសេចក្ដីទុក្ខ គប្បីស៊ីនូវជើងនៃបុរសនោះឯង មានឧបមាយ៉ាងណា។

[៣១២] បុគ្គលណា កើតក្នុងត្រកូលអាក្រក់ ជាអ្នកមិនប្រសើរ បានរៀនវិជ្ជា និងសូត្រ (អំពីសំណាក់) នៃអ្នកទាំងឡាយ (អាចារ្យ) ហើយរមែងស៊ីនូវខ្លួននោះឯង ព្រោះវិជ្ជា និងសូត្រដែលខ្លួនរៀនហើយ ក្នុងសំណាក់នៃអាចារ្យនោះ បុគ្គលនោះ (បណ្ឌិតពោលថា) ជាមនុស្សមិនប្រសើរ មានឧបមាដោយស្បែកជើង ដែលធ្វើមិនល្អហើយ យ៉ាងនោះដែរ។

ចប់ ឧបាហនជាតក ទី១។

## វីណាថូណជាតក ទី២

CS sut.kn.jat.232 | ភាគទី ៥៨

### (២៣២. វីណាគុណជាតកំ (២-៩-២))

[៣១៣] (សេដ្ឋីពោធិសត្វ ពោលថា) ប្រយោជន៍នេះ នាងគិតតែម្នាក់ឯង បុរសពាល នាំនាងទៅមិនបាន ម្នាលនាងដ៏ចំរើន ព្រោះថា នាងមិនគួរដើម្បីទៅជាមួយនឹងបុរសគមតឿឡើយ។

[៣១៤] (សេដ្ឋីធីតា ពោលថា) ខ្ញុំសំគាល់បុរសគម ថាជាបុរសឧសភៈ បានប្រាថ្នាហើយ បុរសគមនេះ ដេករួញអង្កុញ ដូចជាពិណដែលមានខ្សែដាច់។

ចប់ វីណាថូណជាតក ទី២។

## វិកណ្ណកជាតក ទី៣

CS sut.kn.jat.233 | ភាគទី ៥៨

### (២៣៣. វិកណ្ណជាតកំ (២-៩-៣))

[៣១៥] (បុរសអ្នកឲ្យបាយត្រី ពោលថា) ឯងប្រាថ្នាក្នុងទីណាប្រាកដ ចូរទៅក្នុងទីនោះចុះ ឯងត្រូវច្បូកមុតហើយ ត្រង់ទីជាទីស្លាប់ ឯងជាសត្វរលោភលាំ ដេញតាមចាប់នូវត្រីទាំងឡាយ ត្រូវគេសម្លាប់ហើយដោយបាយ ព្រមទាំងគ្រឿងប្រគំ។

[៣១៦] (ព្រះសាស្តា ទ្រង់ត្រាស់ថា) បុគ្គលកាលប្រព្រឹត្តទៅតាមលោកាមិសៈ ជាអ្នកលុះក្នុងអំណាចនៃចិត្ត រមែងក្តៅក្រហាយ បុគ្គលនោះ រមែងក្តៅក្រហាយក្នុងកណ្តាលពួកញាតិ និងសំឡាញ់ បុគ្គលនោះ ដូចក្រពើដេញតាមនូវត្រីដូច្នោះ។

ចប់ វិកណ្ណកជាតក ទី៣។

## អសិតាភុជាតក ទី៤

CS sut.kn.jat.234 | ភាគទី ៥៨

### (២៣៤. អសិតាភូជាតកំ (២-៩-៤))

[៣១៧] (នាងអសិតាភូ ពោលថា) (ខ្ញុំ) អស់សេចក្តីស្រឡាញ់ចំពោះអ្នកព្រោះអំពើណា អ្នកបានធ្វើអំពើនេះ ក្នុងកាលឥឡូវនេះ សេចក្តីស្រឡាញ់នោះ មិនតជាប់វិញទេ ដូចជាភ្លុកដំរីដែលគេកាត់ដោយរណាដូច្នោះ។

[៣១៨] (ព្រហ្មទត្តរាជកុមារ មានបន្ទូលថា) បុគ្គលមានសេចក្តីប្រាថ្នាលើសលុប រមែងសាបសូន្យចាកប្រយោជន៍ ព្រោះលោភហួសហេតុផង ព្រោះសេចក្តីស្រវឹងក្នុងការចង់បានហួសហេតុផង ដូចយើងសាបសូន្យចាករាជធីតាឈ្មោះអសិតាភូ។

ចប់ អសិតាភុជាតក ទី៤។

## វច្ឆនខជាតក ទី៥

CS sut.kn.jat.235 | ភាគទី ៥៨

### (២៣៥. វច្ឆនខជាតកំ (២-៩-៥))

[៣១៩] (ពារាណសីសេដ្ឋី ពោលថា) បពិត្រវច្ឆនខតាបស លោកជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ គប្បីបរិភោគផង ផឹកផង ហើយដេកក្នុងផ្ទះទាំងឡាយណា ផ្ទះទាំងឡាយនោះ ប្រកបដោយប្រាក់ និងមាស ប្រកបដោយភោជន ជាសុខ (យ៉ាងក្រៃលែង)។

[៣២០] (វច្ឆនខតាបស ពោលថា) ការគ្រប់គ្រងផ្ទះ មិនមានដល់បុគ្គលឥតព្យាយាម ការគ្រប់គ្រងផ្ទះ មិនមានដល់បុគ្គលមិននិយាយពាក្យកុហក ការគ្រប់គ្រងផ្ទះ មិនមានដល់បុគ្គលមិនកាន់យកនូវអាជ្ញា មិនធ្វើទោសដល់ជនទាំងឡាយដទៃ បុគ្គលណានឹងគ្រប់គ្រងផ្ទះដែលធ្លុះ បំពេញបានដោយកម្រយ៉ាងនេះ។

ចប់ វច្ឆនខជាតក ទី៥។

## ពកជាតក ទី៦

CS sut.kn.jat.236 | ភាគទី ៥៨

### (២៣៦. ពកជាតកំ (២-៩-៦))

[៣២១] (ពួកត្រី ពោលថា) សត្វស្លាបនេះ ស្រួលបួលពេក ដូចផ្កាកុមុទ មានស្លាបទាំងពីរសម្លបហើយ ឈរសំកុកហាក់ដូចជាមានកំឡាំងខ្សោយ។

[៣២២] (ត្រីពោធិសត្វ ពោលថា) អ្នកទាំងឡាយ មិនដឹងច្បាស់នូវសីលរបស់កុកនោះទេ អ្នកទាំងឡាយ មិនដឹងហើយ នាំគ្នាសរសើរសត្វស្លាបមិនមែនរក្សានូវយើងឡើយ ព្រោះហេតុនោះ ទើបសត្វស្លាប (នេះ) មិនកម្រើកខ្លួន។

ចប់ ពកជាតក ទី៦។

## សាកេតជាតក ទី៧

(២៣៧. សាកេតជាតកំ (២-៩-៧ ))

[៣២៣] (ពួកភិក្ខុ ពោលថា) បពិត្រព្រះមានព្រះភាគ ហេតុអ្វីហ្ន៎ ហឫទ័យត្រជាក់ យ៉ាងក្រៃលែង ទាំងចិត្តក៏ជ្រះថ្លាក្នុងបុគ្គលពួកខ្លះក្នុងលោកនេះ។

[៣២៤] (ព្រះសាស្តា ទ្រង់ត្រាស់ថា) សេចក្តីស្រឡាញ់នោះ រមែងកើតដោយហេតុពីរយ៉ាង គឺដោយធ្លាប់នៅរួមគ្នា ក្នុងកាលមុន ១ ដោយការទំនុកបម្រុងគ្នាក្នុងបច្ចុប្បន្ននេះ ១ ដូចជាឧប្បលដែលដុះក្នុងទឹក ដោយហេតុពីរយ៉ាង គឺទឹក ១ ភក់ ១។

ចប់ សាកេតជាតក ទី៧។

## ឯកបទជាតក ទី៨



(២៣៨. ឯកបទជាតកំ (២-៩-៨))

[៣២៥] (កុមារជាកូននៃព្រះពោធិសត្វ ពោលថា) បពិត្របិតា យើងញុំាងប្រយោជន៍ឲ្យសម្រេច ដោយបទណា សូមអញ្ជើញលោកប្រាប់នូវបទនោះតែមួយ ដែលអាស្រ័យនូវបទជាប្រយោជន៍ច្រើន ដែលសង្គ្រោះ (រួមចូល) តែមួយ។

[៣២៦] (បិតា ប្រាប់ថា) នែកូន សេចក្តីឧស្សាហ៍ (ប្រកបដោយញាណ) ជាបទតែមួយដែលអាស្រ័យនូវបទជាប្រយោជន៍ច្រើន តែសេចក្តីឧស្សាហ៍នោះ ប្រកបដោយសីល ប្រកបដោយខន្តិធម៌ អាចញុំាងពួកមិត្រឲ្យសុខ ឬដើម្បីសេចក្តីទុក្ខដល់ពួកបុគ្គលមិនមែនជាមិត្រ។

ចប់ ឯកបទជាតក ទី៨។

## ហរិតមាតជាតក ទី៩



(២៣៩. ហរិតមណ្ឌូកជាតកំ (២-៩-៩))

[៣២៧] (សត្វពស់ សួរថា) ម្នាលអ្នកជាកូននៃហរិតមណ្ឌូកមាតា ត្រីទាំងឡាយ ស៊ីនូវយើង ដែលជាសត្វមានពិស ដែលចូលទៅកាន់មាត់លប ដោយហេតុណា ហេតុនេះ ពេញចិត្ត (ដល់អ្នកដែរឬ)។

[៣២៨] (នីលមណ្ឌូកពោធិសត្វ ពោលថា) (ឥស្សរភាព) របស់បុរសនោះ បានប្រព្រឹត្តទៅ ដរាបណា បុរស (នោះ) រមែងរឹបជាន់ (ជនដទៃដរាបនោះ) លុះពួកជនដទៃ (បានឥស្សរភាព) រមែងរឹបជាន់វិញ ក្នុងកាលណា បុរសអ្នករឹបជាន់នោះ ត្រូវពួកជនដទៃរឹបជាន់វិញ ក្នុងកាលនោះ។

ចប់ ហរិតមាតជាតក ទី៩។

## មហាបិង្គលជាតក ទី១០



(២៤០. មហាបិង្គលជាតកំ (២-៩-១០))

[៣២៩] (ព្រះពោធិសត្វ ពោលថា) ជនទាំងអស់ ត្រូវស្តេចបិង្គលៈបៀតបៀនហើយ កាលស្តេចនោះសោយទិវង្គតហើយ ជនទាំងឡាយរមែងបាននូវសេចក្តីត្រេកអរ ម្នាលទ្វារបាល ស្តេចអកណ្ហនេត្រ ជាទីស្រឡាញ់របស់អ្នកឬ ព្រោះហេតុអ្វីបានជាអ្នកយំ។

[៣៣០] (ទ្វារបាលបុរស ពោលថា) ស្តេចអកណ្ហនេត្រ មិនមែនជាទីស្រឡាញ់របស់ខ្ញុំទេ ខ្ញុំខ្លាចស្តេចនោះត្រឡប់មកវិញ (ព្រោះស្តេចនោះ) ទៅអំពីមនុស្សលោកនេះ គប្បីបៀតបៀននូវមច្ចុរាជ មច្ចុរាជនោះ ក្រែងត្រូវស្តេចបិង្គលៈបៀតបៀនហើយ គប្បីនាំមកទុកក្នុងមនុស្សលោកនេះវិញ។

[៣៣១] (ព្រះពោធិសត្វ ពោលថា) ព្រះបាទបិង្គលៈនោះ គេដុតដោយឧស ១ ពាន់ដឹក គេស្រោចដោយទឹកមួយរយក្អម ឯទីសម្រាប់ដុតគេបិទបាំងជុំវិញហើយ អ្នកកុំភ័យឡើយ ស្តេចបិង្គលៈនោះ នឹងមិនមកវិញបានទេ។

ចប់ មហាបិង្គលជាតក ទី១០។

ចប់ ឧបាហនវគ្គ ទី៩។

ឧទ្ទាននៃឧបាហនវគ្គនោះគឺ

និយាយអំពីស្បែកជើងប្រសើរ ១ បុរសគម ១ ក្រពើត្រូវច្បូកមុត ១ ព្រះរាជធីតាឈ្មោះអសិតាភូ ១ វច្ឆនខតាបស ១ សត្វកុក ១ សេចក្តីស្រឡាញ់ដ៏ប្រសើរឧត្តម ១ បទតែមួយ ១ មាត់លប ១ ស្តេចឈ្មោះបិង្គលៈ ១ ត្រូវជា ១០។

# សិគាលវគ្គ ទី១០



(១០. សិង្គាលវគ្គោ)

## សព្វទាឋិជាតក ទី១

CS sut.kn.jat.241 | ភាគទី ៥៨

**(២៤១. សព្វទាឋិជាតកំ (២-១០-១))**

[៣៣២] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ចចក រឹងត្អឹងដោយមានះ ត្រូវការដោយបរិវារ (ច្រើន) ក៏ដល់ភូមិសម្បត្តិដ៏ធំ បានជាស្តេចនៃពួកសត្វមានចង្កូមទាំងពួង។

[៣៣៣] បណ្តាមនុស្សទាំងឡាយ មនុស្សណា ជាអ្នកមានបរិវារ មនុស្សនោះ ឈ្មោះថាជាធំក្នុងពួកបរិវារនោះ ដូចជាចចក (បានជាធំ) ជាងសត្វមានចង្កូមទាំងឡាយ ដូច្នោះឯង។

ចប់ សព្វទាឋិជាតក ទី១។

## សុនខជាតក ទី២

CS sut.kn.jat.242 | ភាគទី ៥៨

**(២៤២. សុនខជាតកំ (២-១០-២))**

[៣៣៤] (ព្រះពោធិសត្វ ពោលថា) ឆ្កែណា មិនស៊ីព្រ័ត្រ ឆ្កែនុ៎ះពេញជាល្ងង់ ម្យ៉ាងទៀត ឆ្កែគួរដោះខ្លួនអំពីចំណង ស៊ីព្រ័ត្រឆ្អែតហើយ គប្បីទៅកាន់ផ្ទះ (របស់ខ្លួន)។

[៣៣៥] (ឆ្កែពោលថា ពាក្យរបស់អ្នក) ខ្ញុំបានតាំងទុកក្នុងចិត្តខ្ញុំហើយ ម្យ៉ាងទៀត ខ្ញុំបានធ្វើទុកក្នុងហឫទ័យខ្ញុំហើយ ជនដេកលក់ស៊ប់ដរាបណា ខ្ញុំរង់ចាំនូវកាល ដរាបនោះ។

ចប់ សុនខជាតក ទី២។

## គុត្តិលជាតក ទី៣

CS sut.kn.jat.243 | ភាគទី ៥៨

**(២៤៣. គុត្តិលជាតកំ (២-១០-៣))**

[៣៣៦] (ព្រះពោធិសត្វ ពោលថា) បពិត្រព្រះឥន្ទ្រកោសិយ ខ្ញុំបាន (ញុំាងសិស្សឈ្មោះមុសិលៈ) ឲ្យរៀននូវពិណមានខ្សែ ៧ មានសម្លេងពីរោះ ជាទីរីករាយនៃចិត្ត (ឥឡូវនេះ) សិស្សឈ្មោះមុសិលៈនោះ ហៅខ្ញុំក្នុងកណ្តាលរង្គមណ្ឌល (កន្លែងរាំ) សូមព្រះអង្គជាទីពឹងនៃខ្ញុំ។

[៣៣៧] (សក្កទេវរាជ ទ្រង់មានព្រះបន្ទូលថា) ម្នាលសំឡាញ់ ខ្ញុំនឹងជាទីពឹងរបស់អ្នក ខ្ញុំជាអ្នកបូជានូវអាចារ្យ សិស្សនឹងមិនឈ្នះអ្នកបពិត្រអាចារ្យ អ្នកនឹងឈ្នះនូវសិស្សវិញ។

ចប់ គុត្តិលជាតក ទី៣។

## វិគតិច្ឆជាតក ទី៤

CS sut.kn.jat.244 | ភាគទី ៥៨

**(២៤៤. វិគតិច្ឆជាតកំ (២-១០-៤))**

[៣៣៨] (តាបសពោធិសត្វ ពោលថា) បុគ្គលឃើញនូវរបស់ណា មិនប្រាថ្នានូវរបស់នោះ មួយទៀត មិនឃើញនូវរបស់ណា ចង់បានរបស់នោះ យើងសំគាល់ថា បុគ្គលនោះ នឹងត្រាច់ទៅ (ក្នុងសង្សារ) អស់កាលយូរ ព្រោះថា បុគ្គលនោះប្រាថ្នារបស់ណា មិនបាននូវរបស់នោះ។

[៣៣៩] (បុគ្គលបាននូវរបស់ណា) មិនត្រេកអរនឹងរបស់នោះ ប្រាថ្នាសម្បត្តិណា មើលងាយនូវសម្បត្តិ ដែលបានហើយនោះ ព្រោះថាសេចក្តីប្រាថ្នា ជាដំណើររកទីបំផុតគ្មាន យើងសូមធ្វើនមស្ការចំពោះពួកបណ្ឌិត ដែលមានសេចក្តីប្រាថ្នាទៅប្រាសហើយ។

ចប់ វិគតិច្ឆជាតក ទី៤។

## មូលបរិយាយជាតក ទី៥

CS sut.kn.jat.245 | ភាគទី ៥៨

**(២៤៥. មូលបរិយាយជាតកំ (២-១០-៥))**

[៣៤០] (អាចារ្យទិសាបាមោក្ខពោធិសត្វ សួរថា) កាល រមែងស៊ីនូវពួកសត្វទាំងអស់ ព្រមទាំងខ្លួនឯង ចំណែកសត្វណា ជាអ្នកស៊ីនូវកាល សត្វនោះ ឈ្មោះថា ដុតនូវតណ្ហាដែលជាធម្មជាតិដុតសត្វ។

[៣៤១] (ព្រះពោធិសត្វ តិះដៀលថា) ក្បាលនរជនទាំងឡាយដ៏ច្រើន ក្បាលទាំងនោះ មានរោមផង ធំផង គ្របនៅលើ ក បណ្តាមនុស្សទាំងអម្បាលនេះ គង់មានមនុស្សណាមួយ ដែលមានប្រាជ្ញាមិនខាន។

ចប់ មូលបរិយាយជាតក ទី៥។

## ពាលោវាទជាតក ទី៦

(២៤៦. ពាលោវាទជាតកំ (២-១០-៦))

[៣៤២] (កុដុម្ពិក៍ម្នាក់ ពោលថា) បុគ្គលអ្នកមិនត្រូវសង្រួមប្រហារសត្វផង ធ្វើសត្វឲ្យលំបាកផង ធ្វើសត្វឲ្យស្លាប់ផង ហើយឲ្យទាន (ដល់សមណៈណា) សមណៈនោះ កាលបរិភោគនូវភត្តបែបនេះ ឈ្មោះថា ប្រឡាក់ដោយបាបដែរ។

[៣៤៣] (ព្រះពោធិសត្វ តបថា) ប្រសិនបើបុគ្គលអ្នកមិនសង្រួម សូម្បីសម្លាប់នូវកូន និងប្រពន្ធ ហើយឲ្យទាន (ដល់សមណៈណា) សមណៈនោះ ជាអ្នកប្រកបដោយប្រាជ្ញា ទុកជាកាលបរិភោគ ក៏មិនប្រឡាក់ដោយបាបឡើយ។

ចប់ ពាលោវាទជាតក ទី៦។

## បាទញ្ជលិជាតក ទី៧



(២៤៧. បាទញ្ជលីជាតកំ (២-១០-៧))

[៣៤៤] (អាមាត្យពោធិសត្វ សរសើរថា) ព្រះរាជកុមារព្រះនាមបាទញ្ជលី រុងរឿងកន្លងនូវពួកយើងទាំងអស់គ្នា ដោយប្រាជ្ញាពិតមែន ដូច្នោះ បានជាទ្រង់ពេបព្រះឱស្ឋ ទ្រង់ទតឃើញនូវហេតុដ៏ក្រៃលែងដោយពិត។

[៣៤៥] (ព្រះពោធិសត្វ ដៀលថា) ព្រះរាជកុមារព្រះនាមបាទញ្ជលីនេះ មិនទ្រង់ជ្រាបនូវសភាពជាធម៌ និងសភាពមិនមែនជាធម៌ផង នូវប្រយោជន៍ និងមិនមែនជាប្រយោជន៍ផង ព្រះរាជកុមារព្រះនាមបាទញ្ជលីនេះ វៀរលែងតែការពេប នូវព្រះឱស្ឋចេញហើយ ទ្រង់មិនជ្រាបនូវហេតុតិចតួចឡើយ។

ចប់ បាទញ្ជលិជាតក ទី៧។

## កឹសុកោបមជាតក ទី៨



(២៤៨. កឹសុកោបមជាតកំ (២-១០-៨))

[៣៤៦] (ព្រះរាជា ពោលថា) ដើមចា អ្នករាល់គ្នាបានឃើញហើយ អ្នកទាំងឡាយនៅសង្ស័យក្នុងដើមចានោះ ថាដូចម្តេចហ្ន៎ ដ្បិតអ្នកទាំងឡាយ មិនបានសាកសួរនាយសារថី ក្នុងទីទាំងពួងសោះ។

[៣៤៧] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ធម៌ទាំងឡាយ ដែលពួកជនណា មិនបានដឹងហើយ ដោយញាណទាំងឡាយទាំងពួង យ៉ាងនេះ ពួកជននោះឯង រមែងសង្ស័យក្នុងធម៌ទាំងឡាយ ដូចជា (ព្រះរាជបុត្រទាំង ៤ ព្រះអង្គ) ជាបងប្អូននឹងគ្នា សង្ស័យក្នុងដើមចាដូច្នោះ។

ចប់ កឹសុកោបមជាតក ទី៨។

## សាលកជាតក ទី៩



(២៤៩. សាលកជាតកំ (២-១០-៩))

[៣៤៨] (ហ្មាពស់ ពោលថា) នែសាលកវានរៈ អ្នកជាក់ជាកូនប្រុសតែមួយ (នៃយើង) មួយទៀត អ្នកនឹងបានជាធំក្នុងត្រកូលរបស់យើង ចូរអ្នកចុះអំពីដើមឈើមក យើងនឹងទៅផ្ទះ ក្នុងកាលឥឡូវនេះ។ '

[៣៤៩] (ស្វាពោលតបថា) ក្រែងអ្នកសម្គាល់ខ្ញុំថាជាសត្វមានហឫទ័យល្អ តែអ្នកបៀតបៀនខ្ញុំដោយបន្ទះឫស្សី ខ្ញុំត្រេកអរក្នុងព្រៃស្វាយ ដែលមានផ្លែទុំ អ្នកចូរទៅផ្ទះតាមសប្បាយចុះ។ '

ចប់ សាលកជាតក ទី៩។

## កបិជាតក ទី១០



(២៥០. កបិជាតកំ (២-១០-១០ ))

[៣៥០] (តាបសកុមារ ពោលថា) ឥសីអង្គនេះ ត្រេកអរក្នុងការស្ងប់ និងការសង្រួម លោកត្រូវភ័យអំពីរងាបៀតបៀនហើយ សូមឲ្យតាបសនេះ ចូលមកកាន់ផ្ទះនេះ ដើម្បីបន្ទោបង់នូវត្រជាក់ នឹងសេចក្តីក្រវល់ក្រវាយចេញ កុំឲ្យមានសេសសល់ឡើយ។

[៣៥១] (ពោធិសត្វ ពោលថា) អ្នកនេះមិនមែនជាឥសីអ្នកត្រេកអរក្នុងការស្ងប់ និងការសង្រួមទេ អ្នកនេះជាសត្វស្វា ជាសត្វគោចរនៅលើមែកល្វា ស្វានោះជាសត្វខឹងប្រទូស្ត មានសន្តានចិត្តដ៏លាមក បើវាចូលមក មុខតែប្រទូស្តផ្ទះនេះមិនខាន។

ចប់ កបិជាតក ទី១០។

ចប់ សិគាលវគ្គ ទី១០។

ឧទ្ទាននៃសិគាលវគ្គនោះគឺ

និយាយអំពីស្តេចចចក ១ សុនខ ១ ព្រះឥន្ទ្រកោសិយ ១ បុគ្គលប្រាថ្នា ១ បុគ្គលអ្នកស៊ីនូវកាល ១ ទានដ៏ប្រសើរ ១ ព្រះរាជកុមារពេបព្រះឱស្ឋ ១ នាយសារថី ១ ព្រៃស្វាយ ១ ស្វារងា ១ ត្រូវជា ១០។

ឧទ្ទាននៃវគ្គគឺ

និយាយអំពីទឡ្ហវគ្គ ១ សន្ថវវគ្គដទៃ ១ កល្យាណវគ្គ ១ អសទិសវគ្គ ១ រុហកវគ្គ ១ នតំទឡ្ហវគ្គ ១ ពីរណត្ថម្ភកវគ្គ ១ កាសាវវគ្គ ១ ឧបាហនវគ្គ ១ សិគាលវគ្គ ១ ត្រូវជា ១០។

ចប់ ទុកនិបាត។

# តិកនិបាតជាតក

CS sut.kn.jat.v03 | ភាគទី ៥៨

(៣. តិកនិបាតោ)

## សង្កប្បវគ្គ ទី១

CS sut.kn.jat.v03.01 | ភាគទី ៥៨

(១. សង្កប្បវគ្គោ)

### សង្កប្បរាគជាតក ទី១

CS sut.kn.jat.251 | ភាគទី ៥៨

(២៥១. សង្កប្បរាគជាតកំ (៣-១-១))

[៣៥២] (តាបសពោធិសត្វ ពោលថា) អាត្មាត្រូវ (សរ គឺកិលេស) ដែលលាងដោយទឹក គឺសង្កប្បរាគៈ (រាគៈប្រកបដោយកាមវិតក្កៈ) ផង ដែលសំលៀងដោយថ្ម គឺកាមវិតក្កៈផង មិនបានចំរើនដោយគ្រឿងតាក់តែងផង (មិនមែន) ជាងសរធ្វើហើយផង។

[៣៥៣] មិនមែនទាញមកនូវគុម្ពត្រចៀកហើយលែងទៅវិញផង ទាំងមិនជាប់ដោយស្លាបក្ងោកផង ជាសរអាចដុតអវយវៈទាំងអស់ឲ្យក្តៅនោះ បានមុតហើយត្រង់ហឫទ័យ។

[៣៥៤] ឈាមគប្បីហូរចេញ ចាកមុខរបួស ដែលសរណាមុតហើយ អាត្មាមើលមិនឃើញមុខរបួស ដែលសរនោះមុតហើយទេ ចិត្ត (របស់អាត្មា ត្រូវសរមុតជាប់ហើយ) ព្រោះខុសទំនង អាត្មានាំមកនូវសេចក្តីទុក្ខដោយខ្លួនឯង។

ចប់ សង្កប្បរាគជាតក ទី១។

### តិលមុដ្ឋិជាតក ទី២

CS sut.kn.jat.252 | ភាគទី ៥៨

(២៥២. តិលមុដ្ឋិជាតកំ (៣-១-២ ))

[៣៥៥] (ព្រះបាទព្រហ្មទត្ត ពោលថា) អ្នកចាប់យើងត្រង់ដើមដៃ ហើយវាយយើងដោយរំពាត់ ព្រោះហេតុតែល្ងមួយក្តាប់ ការវាយនោះប្រាកដក្នុងចិត្តរបស់យើង ដរាបដល់ថ្ងៃនេះ។

[៣៥៦] ម្នាលព្រាហ្មណ៍ អ្នកមកដោយហេតុណា អ្នកមិនត្រេកអរក្នុងជីវិតដោយហេតុនោះទេឬ ព្រោះអ្នកចាប់យើងត្រង់ដើមដៃ ហើយវាយ អស់វារៈបីដង។

[៣៥៧] (ព្រាហ្មណ៍ ពោលថា) អរិយជនណា ហាមឃាត់នូវបុគ្គលមិនប្រសើរ កាលធ្វើនូវអំពើអាក្រក់ដោយអាជ្ញា ការហាមឃាត់របស់អរិយជននោះ រាប់ថាជាពាក្យប្រៀនប្រដៅ ការហាមឃាត់ អរិយជននោះ មិនមែនជាពៀរឡើយ បណ្ឌិតទាំងឡាយរមែងដឹងនូវហេតុនោះដូច្នេះឯង។

ចប់ តិលមុដ្ឋិជាតក ទី២។

### មណិកណ្ឋជាតក ទី៣

CS sut.kn.jat.253 | ភាគទី ៥៨

(២៥៣. មណិកណ្ឋជាតកំ (៣-១-៣))

[៣៥៨] (មណិកណ្ឋនាគរាជ ពោលថា) បាយ និងទឹក កើតដល់ខ្ញុំច្រើនពេកក្រៃ ព្រោះហេតុនៃកែវមណីនេះ ខ្ញុំនឹងមិនឲ្យកែវមណីនោះដល់លោក លោកជាអ្នកសូមហួសហេតុ ខ្ញុំនឹងមិនមកកាន់អាស្រមរបស់លោកទេ។

[៣៥៩] លោកកាលសូមកែវមណីដែលកើតអំពីថ្ម នាំឲ្យខ្ញុំតក់ស្លុត ដូចមនុស្សកំឡោះ មានដៃកាន់ដាវសំលៀងហើយដោយថ្ម មកញាំងខ្ញុំឲ្យតក់ស្លុតដូច្នោះ ខ្ញុំមិនឲ្យកែវមណីនោះដល់លោកទេ (ព្រោះ) លោកជាអ្នកសូមហួសហេតុ ខ្ញុំនឹងលែងមកកាន់អាស្រមរបស់លោកហើយ។

[៣៦០] (តាបសពោធិសត្វជាបង ពោលថា) បុគ្គលដឹងនូវវត្ថុណាថា ជាទីស្រឡាញ់របស់គេ មិនត្រូវសូមវត្ថុនោះទេ សេចក្តីស្អប់

រមែងមាន ព្រោះការសូមជ្រុលពេក ដូចស្តេចនាគដែលត្រូវព្រាហ្មណ៍សូមកែវមណី ទៅកាន់ទីលែងមើលឃើញតាំងអំពីកាលនោះ។

ចប់ មណិកណ្ឋជាតក ទី៣។

## កុណ្ឌកកុច្ឆិសិន្ធវជាតក ទី៤

CS sut.kn.jat.254 | ភាគទី ៥៨

### (២៥៤. កុណ្ឌកកុច្ឆិសិន្ធវជាតកំ (៣-១-៤ ))

[៣៦១] (ឈ្មួញសេះពោធិសត្វ ពោលថា) អ្នកធ្លាប់បរិភោគស្មៅដ៏សល់ដែល ធ្លាប់បរិភោគបាយក្តាំង និងកុណ្ឌកមកហើយ នេះជាភោជនរបស់អ្នក ឥឡូវនេះ ហេតុអ្វីក៏អ្នកមិនបរិភោគ។

[៣៦២] (កូនសេះសិន្ធវៈ ពោលថា) បពិត្រមហាព្រហ្ម ជនទាំងឡាយមិនស្គាល់សត្វដែលគួរចិញ្ចឹមដោយជាតិ ឬដោយមារយាទដែលគួរទូន្មាន ក្នុងទីណា ក្នុងទីនោះ ថ្វីក៏ខ្ញុំមិនបរិភោគបាយក្តាំង និងកុណ្ឌកច្រើន។

[៣៦៣] ចំណែកខាងលោក ស្គាល់ខ្ញុំច្បាស់ថា សេះនេះឧត្តមយ៉ាងណា ៗ ខ្ញុំកាលដឹង ព្រោះអាស្រ័យអ្នកជាអ្នកដឹង ទើបមិនបរិភោគនូវកុណ្ឌករបស់អ្នក។

ចប់ កុណ្ឌកកុច្ឆិសិន្ធវជាតក ទី៥។

## សុកជាតក ទី៥

CS sut.kn.jat.255 | ភាគទី ៥៨

### (២៥៥. សុកជាតកំ (៣-១-៥))

[៣៦៤] (ព្រះសាស្តា ត្រាស់ថា) សត្វហើរ គឺសេកនោះ ដឹងប្រមាណក្នុងភោជន ដរាបណា ក៏បានដល់នូវអាយុវែងផង បានចិញ្ចឹមមាតាផង ដរាបនោះ។

[៣៦៥] មួយទៀត សេកនោះបរិភោគនូវភោជនដ៏ច្រើនលើសលុប ក្នុងកាលណា ក៏លិចចុះក្នុងសមុទ្រនោះឯង ក្នុងកាលនោះ ព្រោះសេកនោះមិនស្គាល់ប្រមាណ។

[៣៦៦] ព្រោះហេតុនោះ ការដឹងប្រមាណ មិនល្មោភក្នុងភោជន ជាការប្រពៃ ព្រោះពួកជនដែលមិនដឹងប្រមាណ រមែងលិច ពួកជនដែលដឹងប្រមាណ រមែងមិនលិចទេ។

ចប់ សុកជាតក ទី៥។

## ជរូទបានជាតក ទី៦

CS sut.kn.jat.256 | ភាគទី ៥៨

### (២៥៦. ជរូទបានជាតកំ (៣-១-៦ ))

[៣៦៧] (ព្រះសាស្តា ត្រាស់ថា) ពួកឈ្មួញអ្នកត្រូវការដោយទឹក កាលជីកអណ្តូងចាស់ ក៏បាននូវដែក និងទង់ដែងផង នូវសំណរភក់ផង នូវកែវមណីទាំងឡាយផង នូវប្រាក់ និងមាសផង នូវកែវមុក្តា និងកែវពៃទូរ្យទាំងឡាយផងដ៏ច្រើន។

[៣៦៨] តែពួកឈ្មួញទាំងនោះ មិនសន្តោសដោយទ្រព្យនោះ រឹងរឹតតែជីកចុះទៅទៀត សត្វមានពិសដ៏ក្លៀវក្លា មានតេជះ ក៏សម្លាប់នូវពួកឈ្មួញទាំងនោះ ដោយតេជះ (នៃពិស) ក្នុងអណ្តូងទឹកនោះឯង។

[៣៦៩] ព្រោះហេតុនោះ បុគ្គលគប្បីជីក តែកុំជីកឲ្យជ្រៅហួសពេក ព្រោះការជីកអណ្តូងជ្រៅហួសពេក ជាការលាមក ទ្រព្យ (ដែលពួកឈ្មួញ) បានហើយដោយការជីក ក៏វិនាសអស់ ព្រោះតែការជីកជ្រៅហួសពេក។

ចប់ ជរូទបានជាតក ទី៦។

## គាមណិចន្ទជាតក ទី៧

CS sut.kn.jat.257 | ភាគទី ៥៨

### (២៥៧. គាមណិចន្ទជាតកំ (៣-១-៧))

[៣៧០] (ព្រះរាជកុមារពោធិសត្វ ពោលថា) សត្វនេះជាសត្វមិនឈ្លាស (ក្នុងការធ្វើ) នូវផ្ទះទាំងឡាយ សត្វនេះជាសត្វខិលខូច មានមុខជ្រួញ បានតែខាងប្រទូស្ត ចំពោះកិច្ចការដែលគេធ្វើហើយ ៗ ត្រកូលនេះជាធម្មតាយ៉ាងនេះឯង។

[៣៧១] រោមនេះ មិនមែនជារោមនៃសត្វមានចិត្ត (សម្បយុត្តដោយបញ្ញា ជាគ្រឿងពិចារណា) ទេ ម្រឹគ គឺស្វានេះ មិនអាចធ្វើគេឲ្យចូលចិត្តបានទេ ក្បួនខ្ញាតព្រះរាជបិតារបស់ខ្ញុំ ទ្រង់ព្រះនាមជនសន្ធៈ (បានត្រាស់ហើយ) ថា ស្វានេះ មិនដឹងនូវហេតុតិចតួចឡើយ។

[៣៧២] បុរសប្រាកដដូច្នេះ មិនគប្បីចិញ្ចឹមនូវមាតាបិតា បងប្អូនប្រុស និងបងប្អូនស្រីរបស់ខ្លួនបានទេ ព្រះបាទទសរថ (ជាព្រះបិតា) បានប្រៀនប្រដៅខ្ញុំ (យ៉ាងនេះ)។

ចប់ គាមណិចន្ទជាតក ទី៧។

## មន្ធាតុរាជជាតក ទី៨

CS sut.kn.jat.258 | ភាគទី ៥៨

(២៥៨. មន្ធាតុជាតកំ (៣-១-៨))

[៣៧៣] (ព្រះសាស្តា ត្រាស់ថា) ព្រះចន្ទ្រ និងព្រះអាទិត្យទាំងឡាយ (ដើរក្រឡឹង) ភ្នំសិនេរុ ទិសទាំងឡាយភ្លឺរុងរឿង រហូតទីមានកំណត់ត្រឹមណា សត្វទាំងឡាយណា ដែលអាស្រ័យលើផែនដី សត្វទាំងអស់នោះ ជាទាសៈរបស់ស្តេចមន្ធាតុ រហូតទីមានកំណត់ត្រឹមណោះ។

[៣៧៤] ការឆ្អែតក្នុងកាមទាំងឡាយ រមែងមិនមាន ដោយភ្លៀងកហាបណៈទេ បណ្ឌិតបានដឹងថា កាមទាំងឡាយមានសេចក្តីសុខតិច មានសេចក្តីទុក្ខ (ច្រើន)។

[៣៧៥] ព្រោះហេតុនោះ សាវ័កនៃព្រះសម្មាសម្ពុទ្ធនោះ មិនបានត្រេកអរក្នុងកាមទាំងឡាយ សូម្បីជាទិព្យ ជាអ្នកត្រេកអរតែក្នុងធម៌ជាគ្រឿងអស់ទៅនៃតណ្ហា។

ចប់ មន្ធាតុរាជជាតក ទី៨។

## តិរិតិវច្ឆជាតក ទី៩

CS sut.kn.jat.259 | ភាគទី ៥៨

(២៥៩. តិរីដវច្ឆជាតកំ (៣-១-៩))

[៣៧៦] (ឧបរាជទូលសួរព្រះរាជាថា) កម្មតិចតួចដែលសម្រេចដោយវិជ្ជារបស់តាបសនេះ មិនមានឡើយ មួយទៀត តាបសនេះមិនមែនជាផៅពង្ស ទាំងមិនមែនជាសំឡាញ់របស់ព្រះអង្គទេ កាលបើយ៉ាងនេះ ហេតុអ្វីបានជាតាបសឈ្មោះតិរិតិវច្ឆៈ កាន់ឈើច្រត់មានចំពាម ៣ បរិភោគនូវដុំបាយមានរសដ៏ប្រសើរ។

[៣៧៧] (ព្រះរាជា ត្រាស់ថា) ក្នុងគ្រាមានអន្តរាយ កាលអញច្បាំងចាញ់គេ (តាបសនេះ) បានធ្វើ (នូវសេចក្តីអនុគ្រោះ) ដល់អញម្នាក់ឯង ក្នុងព្រៃគួរខ្លាចដ៏ពន្លឹក បានលានូវដៃ (យោងអញ) ដែលដល់នូវសេចក្តីលំបាក (ក្នុងអណ្តូង) ព្រោះហេតុនោះ អញដែលត្រូវសេចក្តីទុក្ខគ្របសង្កត់ ទើបបានឡើងរួចមក។

[៣៧៨] អញ (ឋិតនៅ) ក្នុងជីវលោក (នេះ ដល់) នូវវិស័យនៃសេចក្តីស្លាប់ ទៅហើយ តែមកក្នុងទីនេះបាន ព្រោះសេចក្តីលំបាកនៃតាបសនេះ ម្នាលកូន រីតិរីតិវច្ឆតាបស ជាបុគ្គលគួរដល់លាភ អ្នកទាំងឡាយ ចូរឲ្យនូវគ្រឿងបរិភោគផង ចូរបូជានូវវត្ថុដែលគួរបូជាផងដល់លោក។

ចប់ តិរិតិវច្ឆជាតក ទី៩។

## ទូតជាតក ទី១០

CS sut.kn.jat.260 | ភាគទី ៥៨

(២៦០. ទូតជាតកំ (៣-១-១០ ))

[៣៧៩] (លោលបុរស ពោលថា) សត្វទាំងឡាយមកកាន់ប្រទេសឆ្ងាយ ដើម្បីសូមនូវវត្ថុនឹងបុគ្គលសូម្បីជាសត្រូវ ដើម្បីប្រយោជន៍ដល់ផ្ទៃណា ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ។

[៣៨០] មាណពទាំងឡាយ លុះអំណាចនៃផ្ទៃណា ទាំងថ្ងៃទាំងយប់ ខ្ញុំព្រះអង្គជាទូតរបស់ផ្ទៃនោះ បពិត្រព្រះអង្គប្រសើរក្នុងពលរថ សូមទ្រង់កុំខ្ញាល់នឹងខ្ញុំព្រះអង្គឡើយ។

[៣៨១] (ព្រះរាជា ទ្រង់ត្រាស់ថា) ម្នាលព្រាហ្មណ៍ យើងឲ្យនូវគោសម្បុរក្រហម ១ ពាន់ ព្រមទាំងគោបា ដល់អ្នក ព្រោះយើងជាទូត (របស់ផ្ទៃ) នឹងមិនឲ្យដល់អ្នក ជាទូត (របស់ផ្ទៃដែរ) ដូចម្តេចកើត យើងទាំងឡាយ សុទ្ធតែជាទូតរបស់ផ្ទៃដូចគ្នា។

ចប់ ទូតជាតក ទី១០។

ចប់ សង្កប្បវគ្គ ទី១។

ឧទ្ទាននៃសង្កប្បវគ្គនោះគឺ

និយាយអំពីជាងសរប្រសើរ ១ លូមួយក្តាប់ ១ កៃរមណី ១ ស្តេចសេះ ១ សត្វហើរឮដ៏អាកាស ១ ពស់មានពិសដ៏ក្លៀវក្លា ១ ស្តេចទ្រង់ព្រះនាមជនសន្ធៈ ១ ភ្លៀងកហាបណៈ ១ តាបសឈ្មោះតិរិតិវច្ឆៈ ១ ទូតរបស់ផ្ទៃ ១ ត្រូវជា ១០។

# បទុមវគ្គ ទី២

CS sut.kn.jat.v03.02 | ភាគទី ៥៨

(២. បទុមវគ្គោ)

## បទុមជាតក ទី១

CS sut.kn.jat.261 | ភាគទី ៥៨

(២៦១. បទុមជាតកំ (៣-២-១ ))

[៣៨២] (សេដ្ឋីបុត្រទី ១ ពោលថា) សក់ក្តី ពុកមាត់ក្តី ដែលគេកោរកាត់ចោលហើយ រមែងដុះឡើងវិញ យ៉ាងណា សូមឲ្យច្រមុះរបស់អ្នកដុះឡើងវិញ យ៉ាងនោះដែរ យើងសូមផ្កាឈូកហើយ អ្នកចូរឲ្យ។

[៣៨៣] (សេដ្ឋីបុត្រទី ២ ពោលថា) ពូជក្នុងសរទកាល (រដូវរំហើយ) ដែលគេព្រោះក្នុងស្រែ រមែងលូតលាស់ យ៉ាងណាមិញ សូមឲ្យច្រមុះរបស់អ្នកដុះឡើងវិញ យ៉ាងនោះដែរ យើងសូមផ្កាឈូកហើយ អ្នកចូរឲ្យ។

[៣៨៤] (សេដ្ឋីបុត្រពោធិសត្វ ទី៣ ពោលថា) ជនទាំងពីរនាក់នេះ និយាយកុហក ដោយគិតថា ធ្វើដូចម្តេចហ្ន៎ (បុរសនេះ) នឹងឲ្យផ្កាឈូកទាំងឡាយខ្លះ ទោះជនទាំងពីរនាក់នោះ ពោលក្តី មិនពោលក្តី ការដុះឡើងនៃច្រមុះគ្មានទេ ម្នាលសំឡាញ់ សូមអ្នកឲ្យផ្កាឈូកទាំងឡាយ យើងសូមហើយ សូមអ្នកឲ្យផ្កាឈូកទាំងឡាយ។

ចប់ បទុមជាតក ទី១។

## មុទុបាណិជាតក ទី២

CS sut.kn.jat.262 | ភាគទី ៥៨

### (២៦២. មុទុបាណិជាតកំ (៣-២-២))

[៣៨៥] (ព្រះរាជធីតា ពោលថា) បើចូឡបដ្ឋាក មានដៃដ៏ទន់ ១ ដំរីដែលព្រះអង្គបង្ហាត់រាបសារហើយ ១ ពេលងងឹតស្ងន្យឈឹង ១ ភ្លៀងបង្អុរចុះ ១ គប្បីមានក្នុងកាលណា សេចក្តីប៉ងក្នុងព្រះរាជហឫទ័យរបស់ព្រះអង្គ គង់នឹងសម្រេច ក្នុងកាលនោះមិនខាន។

[៣៨៦] (ព្រះរាជាពោធិសត្វជាបិតា ពោលថា) ស្រីទាំងឡាយនោះ បុគ្គលមិនគួរនិយាយដោយពាក្យទន់ភ្លន់ឡើយ ជាស្រីដែលបំពេញបានដោយកម្រ ប្រាកដស្មើដោយស្ទឹង រមែងលិចចុះ (ក្នុងអបាយ ៤) បណ្ឌិតបុរសដឹងច្បាស់ហើយ គួរគេចចេញអំពីចម្ងាយ។

[៣៨៧] ស្រីទាំងនុ៎ះ ចូលទៅគប់រកបុរសណា ដោយសេចក្តីពេញចិត្តក្តី ដោយទ្រព្យក្តី តែងដុតបំផ្លាញបុរសនោះ (ឲ្យវិនាស) យ៉ាងឆាប់ដូចភ្លើង (ដែលឆេះ) នូវទីនៅរបស់ខ្លួន។

ចប់ មុទុបាណិជាតក ទី២។

## ចុល្លបលោភនជាតក ទី៣

CS sut.kn.jat.263 | ភាគទី ៥៨

### (២៦៣. ចូឡបលោភនជាតកំ (៣-២-៣))

[៣៨៨] (ព្រះរាជបុត្រពោធិសត្វ ពោលថា) លោកមក (តាមអាកាស) ដោយខ្លួនឯង លើទឹកមិនបែករលក ដោយអំណាចនៃឫទ្ធិ លុះទៅច្រឡូកច្រឡំដោយស្រី ក៏លិចចុះក្នុងសមុទ្រធំ។

[៣៨៩] ធម្មតាស្រីទាំងឡាយ រមែងញាំងបុរសឲ្យវិលវល់ មានមាយាច្រើន ញាំងព្រហ្មចរិយធម៌ឲ្យកំរើក រមែងលិចចុះ (ក្នុងអបាយ ៤) បណ្ឌិតបុរស ដឹងច្បាស់ហើយ គប្បីចៀសវាងអំពីចម្ងាយ។

[៣៩០] ស្ត្រីទាំងឡាយនុ៎ះ ចូលទៅគប់រកបុរសណា ដោយសេចក្តីពេញចិត្តក្តី ដោយទ្រព្យក្តី តែងដុតបំផ្លាញបុរសនោះ (ឲ្យវិនាស) យ៉ាងឆាប់ ដូចភ្លើង (ដែលឆេះ) នូវលំនៅរបស់ខ្លួន។

ចប់ ចុល្លបលោភនជាតក ទី៣។

## មហាបនាទជាតក ទី៤

CS sut.kn.jat.264 | ភាគទី ៥៨

### (២៦៤. មហាបនាទជាតកំ (៣-២-៤))

[៣៩១] (ព្រះសាស្តា ត្រាស់ថា) ព្រះរាជាអង្គនោះ ទ្រង់ព្រះនាមបនាទៈ មានប្រាសាទមាស មានទទឹងប្រវែងកិរិយាធ្លាក់ចុះនៃកូនសរ ១៦ (កន្លះយោជន៍) (អ្នកប្រាជ្ញទាំងឡាយ) ពោលថា ប្រាសាទនោះកំពស់ ១ ពាន់តំណនៃកូនសរ (២៥ យោជន៍)។

[៣៩២] ប្រាសាទនោះ កំពស់ ១ ពាន់តំណនៃកូនសរ មានជាន់ប្រាំពីរ បរិបូណ៌ដោយទង់ ព័ន្ធព័ទ្ធហើយដោយកែវមណីមានពណ៌ខៀវ ពួករបាំ ៦០០០ ចែកជាប្រាំពីរចំណែក បានរាំលើប្រាសាទនោះ (គ្រប់ ៗ ថ្នាក់)។

[៣៩៣] ម្នាលភទ្ទជិ អ្នកពោលហើយយ៉ាងណា ប្រាសាទនោះមានហើយ ក្នុងកាលនោះ យ៉ាងនោះ តថាគតកើតជាព្រះឥន្ទ្រ ជាវេយ្យាវច្ចករ របស់អ្នក។

ចប់ មហាបនាទជាតក ទី៤។

## ខុរប្បជាតក ទី៥

CS sut.kn.jat.265 | ភាគទី ៥៨

### (២៦៥. ខុរប្បជាតកំ (៣-២-៥))

[៣៩៤] (កូនរបស់ឈ្មួញរទេះ ពោលថា) អ្នកឃើញនូវព្រួញដែលពួកចោរបាញ់ហើយដោយកំឡាំងនៃធ្នូផង នូវព្រះខាន់សំលៀងដោយប្រេងដ៏មុត ដែលពួកចោរកាន់ហើយផង កាលសេចក្តីស្លាប់ដែលគួរខ្លាចនោះ ចូលមកតាំងនៅចំពោះមុខហើយ ហេតុអ្វីក៏អ្នកមិនមានសេចក្តីតក់ស្លុតសោះ។

[៣៩៥] (ពោធិសត្វ ជាមេអ្នករក្សាដងព្រៃ ពោលថា) ខ្ញុំឃើញនូវព្រួញដែលបាញ់ហើយដោយកំឡាំងនៃធ្នូ នូវព្រះខាន់សំលៀង ដោយប្រេងដំមូត ដែលពួកចោរកាន់ហើយ កាលសេចក្តីស្លាប់ដែលគួរខ្លាចនោះ ចូលមកតាំងនៅចំពោះមុខ ខ្ញុំក៏ត្រឡប់បានសេចក្តីត្រេកអរច្រើនដ៏លើសលុប។

[៣៩៦] ខ្ញុំនោះមានសេចក្តីត្រេកអរ បានគ្របសង្កត់នូវពួកសត្រូវ (ព្រោះថា) ខ្ញុំបានលះបង់ជីវិតមុនហើយ ព្រោះថា បុគ្គលអ្នកក្លៀវក្លា កាលធ្វើសេចក្តីអាល័យក្នុងជីវិត គប្បីធ្វើនូវកិច្ចរបស់អ្នកក្លៀវក្លាក្នុងកាលណា ៗ មិនបានទេ។

ចប់ ខុរប្បជាតក ទី៥។

## វាតគ្គសិន្ធវជាតក ទី៦

CS sut.kn.jat.266 | ភាគទី ៥៨

**(២៦៦. វាតគ្គសិន្ធវជាតកំ (៣-២-៦))**

[៣៩៧] (កូនលា ពោលថា) អ្នកម្តាយកើតរោគស្គមស្លៀង ព្រោះតែប្តីណា មិនពេញចិត្តនឹងភត្ត ព្រោះតែប្តីណា ប្តីនោះមកដល់ហើយ ឥឡូវនេះ ហេតុអ្វីបានជាអ្នកម្តាយរត់ចេញទៅ។

[៣៩៨] (មេលា ពោលថា) ម្នាលកូន ម្តាយយល់ថា ធម្មតា សន្តវៈ (របស់ស្រ្តី) កើតដោយហេតុពីដម្បូង (ភ្លាម) យសរបស់ស្រ្តីទាំងឡាយ ក៏សាបសូន្យ ហេតុនោះបានជាអញរត់ចេញ។

[៣៩៩] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ស្ត្រីណាមិនប្រាថ្នានូវបុរសមានយសកើតក្នុងត្រកូល ដែលគេនាំមកឲ្យ ស្ត្រីនោះ រមែងសោកសៅអស់កាលយូរអង្វែង ដូចជាមេលា (ដែលយំសោកស្តាយ) សេះសន្ធព ឈ្មោះវាតគ្គៈ។

ចប់ វាតគ្គសិន្ធវជាតក ទី៦។

## សុវណ្ណកក្កដកជាតក ទី៧

CS sut.kn.jat.267 | ភាគទី ៥៨

**(២៦៧. កក្កដកជាតកំ (៣-២-៧))**

[៤០០] (ដំរីពោធិសត្វ ពោលថា) ម្រឹគមានសម្បុរដូចមាស (ក្តាម) ជាសត្វមានភ្នែកលៀនវែង មានឆ្អឹងជាស្បែក ជាសត្វនៅក្នុងទឹក មិនមានរោម យើងត្រូវក្តាមនោះថ្ងៀបហើយ ទើបក៏ស្រែកទួញយំ សូមភរិយាកុំលះបង់នូវខ្ញុំដែលស្មើដោយជីវិតឡើយ។

[៤០១] (មេដំរី ពោលថា) បពិត្រអ្នកជាម្ចាស់ ខ្ញុំមិនលះបង់អ្នកដែលជាដំរីថែមថយកំឡាំងក្នុងកាលនៃខ្លួនមានអាយុ ៦០ ឆ្នាំឡើយ ខ្ញុំស្រឡាញ់អ្នកក្រៃលែងជាងប្រថពីដែលទល់នឹងសមុទ្រទាំង ៤ ទៅទៀត។

[៤០២] (មេដំរី ពោលថា) ពួកក្តាមណា ដែលនៅក្នុងសមុទ្រក្តី ក្នុងទន្លេគង្គាក្តី យមុនាក្តី អ្នកជាសត្វទឹកប្រសើរជាងក្តាមទាំងនោះ សូមអ្នកមេត្តាលែងប្តី កាលដែលខ្ញុំកំពុងទួញយំរកប្តី សូមអ្នកមេត្តាលែងប្តី (របស់ខ្ញុំ) មកវិញ ក្នុងកាលឥឡូវនេះ។

ចប់ សុវណ្ណកក្កដកជាតក ទី៧។

## អារាមទូសកជាតក ទី៨

CS sut.kn.jat.268 | ភាគទី ៥៨

**(២៦៨. អារាមទូសកជាតកំ (៣-២-៨))**

[៤០៣] (បុរសពោធិសត្វ ពោលថា) ស្វាណា ដែលគេសន្មតថា ជាសត្វប្រសើរបំផុតជាងពួកស្វា ដែលមានជាតិស្មើគ្នានេះ ប្រាជ្ញារបស់ស្វានោះ មានតែត្រឹមប៉ុណ្ណេះ ពួកសត្វ (ស្វា) ក្រៅនេះ នឹងមានប្រាជ្ញាដូចម្តេចទៅ។

[៤០៤] (ហ្វូងស្វា ពោលថា) បពិត្រអ្នកដ៏ប្រសើរ ការតិះដៀលយ៉ាងនេះ ព្រោះតែមិនដឹង បុគ្គលមិនឃើញនូវឫស ហើយគប្បីដឹងនូវដើមឈើដែលតាំងនៅសិប ដូចម្តេចកើត។

[៤០៥] (ពោធិសត្វ ពោលថា) យើងមិនតិះដៀលពួកអ្នកដែលជាពានរ អាស្រ័យនៅក្នុងព្រៃនេះទេ តែថាពួកជនអ្នកដាំដើមឈើ ដើម្បីប្រយោជន៍ដល់ស្តេចវិស្សសេនណា ស្តេចវិស្សសេននោះ គួរគេតិះដៀលបាន។

ចប់ អារាមទូសកជាតក ទី៨។

## សុជាតាជាតក ទី៩

CS sut.kn.jat.269 | ភាគទី ៥៨

**(២៦៩. សុជាតជាតកំ (៣-២-៩))**

[៤០៦] (ព្រះរាជាពោធិសត្វ ត្រាស់ថា) ពួកជនប្រកបដោយសម្បុរ មានសំឡេងពីរោះ មានរូបជាទីស្រឡាញ់ គួររមិលមើល តែជាអ្នកមានវាចារឹងរូស មិនជាទីស្រឡាញ់របស់អ្នកផងក្នុងលោកនេះ នឹងលោកខាងមុខទេ។

[៤០៧] ព្រះមាតាឃើញមេតាវៅខ្មៅនេះ ដែលមានសម្បុរអាក្រក់ ដេរដាសដោយពណ៌ពព្រុះអុច ៗ តែថាជាទីស្រឡាញ់ របស់សត្វច្រើន ដោយសារវាចាពីរោះឬទេ។

[៤០៨] ព្រោះហេតុនោះ បុគ្គលគប្បីជាអ្នកមានវាចាល្អិតល្អ ជាអ្នកពោលពាក្យលៃតាមប្រាជ្ញា មិនមានចិត្តរាយមាយ រមែងសំដែងនូវអត្ថ និងធម៌ ភាសិតរបស់បុគ្គលនោះ ទើបឈ្មោះថាពីរោះ។

ចប់ សុជាតាជាតក ទី៩។

## ឧលូកជាតក ទី១០

CS sut.kn.jat.270 | ភាគទី ៥៨

(២៧០. ឧលូកជាតកំ (៣-២-១០))

[៤០៩] (ក្អែកពោលថា) ឮថាពួកញាតិទាំងអស់ បានលើកកោសិយៈ (មៀម) ឲ្យធ្វើជាធំ ប្រសិនបើពួកញាតិអនុញ្ញាត ខ្ញុំសូមនិយាយនូវពាក្យមួយម៉ាត់។

[៤១០] (ហ្វូងសត្វស្លាប ពោលថា) ម្នាលសំឡាញ់ យើងអនុញ្ញាតហើយ អ្នកចូរនិយាយនូវហេតុ និងពាក្យដែលជាប់ទាក់ទងដោយបវេណីប៉ុណ្ណោះ ដ្បិតពួកបក្សីក្មេង ៗ ដែលមានប្រាជ្ញា ទ្រទ្រង់នូវសេចក្តីរុងរឿង នៅមាន។

[៤១១] (ក្អែក ពោលថា) សូមឲ្យអ្នកទាំងឡាយ មានសេចក្តីចំរើន ការដែលអភិសេកមៀម មិនពេញចិត្តខ្ញុំទេ អ្នកទាំងឡាយ ចូរមើលមុខមៀម ដែលមិនទាន់ខឹង (បែបនេះទៅហើយ) ចំណង់បើខឹងហើយ តើវាធ្វើមុខដូចម្តេចទៅ។

ចប់ ឧលូកជាតក ទី១០។

ចប់ បទុមវគ្គ ទី២។

ឧទ្ទាននៃបទុមវគ្គនោះគឺ

និយាយអំពីផ្កាឈូកដ៏ឧត្តម ១ ដំរីមានសិរី ១ សមុទ្រធំ ១ ប្រាសាទ ១ ព្រួញដ៏ប្រសើរ ១ លាញីឈ្មោះភទ្ទលី ១ ដំរី ១ ដើមឈើ ១ វាចារឹងរូស ១ ស្តេចមៀម ១ ត្រូវជា ១០។

# ឧទបានវគ្គ ទី៣

CS sut.kn.jat.v03.03 | ភាគទី ៥៨

(៣. ឧទបានវគ្គោ)

## ឧទបានទូសកជាតក ទី១

CS sut.kn.jat.271 | ភាគទី ៥៨

(២៧១. ឧទបានទូសកជាតកំ (៣-៣-១))

[៤១២] (ឥសីពោធិសត្វ សួរថា) ម្នាលសំឡាញ់ ហេតុអ្វីបានជាអ្នកប្រទូស្តអណ្តូងទឹក ដែលបុគ្គលធ្វើបានដោយក្រ របស់ឥសីអ្នកនៅក្នុងព្រៃ ប្រព្រឹត្តតបធម៌ អស់រាត្រីដ៏អង្វែង។

[៤១៣] (ចចក ពោលថា) ពួកយើងផឹកទឹកក្នុងទីណា ហើយជុះនោម បំផ្លាញ (ទីនោះ) នេះជាធម្មតារបស់ចចកទាំងឡាយ នេះជាធម្មតារបស់មាតា និងជីតា អ្នកមិនគួរពោលទោសចំពោះធម្មតានោះ។

[៤១៤] (ពោធិសត្វ ពោលថា) អាការនេះធម្មតារបស់ពួកអ្នកណា ចំណង់បើអាការមិនមែនជាធម្មតា នឹងប្រាកដដូចម្តេចទៅ យើងសូមកុំឲ្យជួបប្រទះនឹងអាការជាធម្មតា ឬមិនមែនជាធម្មតារបស់ពួកនោះ ក្នុងកាលណាឡើយ។

ចប់ ឧទបានទូសកជាតក ទី១។

## ព្យគ្ឃជាតក ទី២

CS sut.kn.jat.272 | ភាគទី ៥៨

(២៧២. ព្យគ្ឃជាតកំ (៣-៣-២))

[៤១៥] (រុក្ខទេវតាពោធិសត្វ ពោលថា)សេចក្តីក្សេមចាកយោគៈ គឺសេចក្តីសុខកាយ សុខចិត្ត រមែងសាបសូន្យទៅ ព្រោះច្រឡូកច្រឡំដោយបាបមិត្តណា បណ្ឌិតគប្បីញ៉ាំញីនូវបាបមិត្តនោះជាមុន ហើយគប្បីរក្សា (ខ្លួន) ដូចបុគ្គលកាលរក្សានូវភ្នែកដូច្នោះ។

[៤១៦] សេចក្តីក្សេមចាកយោគៈ រមែងចំរើនឡើង ព្រោះច្រឡូកច្រឡំដោយកល្យាណមិត្តណា បណ្ឌិតគប្បីធ្វើនូវការប្រព្រឹត្តិក្នុងកិច្ចទាំងពួងឲ្យស្មើនឹងខ្លួន។ [៤១៧] (ទេវតាពាល ពោលថា) នែខ្លា និងសីហៈ អ្នកទាំងឡាយ ចូរមក ចូរត្រឡប់ទៅកាន់ព្រៃធំវិញចុះ កុំឲ្យមហាជនកាប់ព្រៃរបស់យើង ព្រោះតែព្រៃមិនមានខ្លា កុំឲ្យខ្លា នឹងសីហៈជាសត្វមិនមានព្រៃឡើយ។

ចប់ ព្យគ្ឃជាតក ទី២។

## កច្ឆបជាតក ទី៣

CS sut.kn.jat.273 | ភាគទី ៥៨

(២៧៣. កច្ឆបជាតកំ (៣-៣-៣))

[៤១៨] (តាបសពោធិសត្វ ពោលថា )បុគ្គលណាហ្ន៎ ដើរមក ហាក់ដូចជាបុគ្គលអ្នកមានភត្តដួសស្រេចហើយ ឬដូចជាព្រាហ្មណ៍មានលាភពេញដៃ អ្នកដើរទៅសូមក្នុងទីណា ឬអ្នកចូលទៅរកបុគ្គលណា ដែលមានសទ្ធា។

[៤១៩] (ពានរ ពោលថា) ខ្ញុំជាស្វាឥតប្រាជ្ញា បានប៉ះពាល់នូវវត្ថុទាំងឡាយដែលគេមិនគួរប៉ះពាល់ សូមលោកម្ចាស់ដោះខ្ញុំឲ្យរួច សូមសេចក្តីចំរើនចូរមានដល់លោក ខ្ញុំនោះបានរួចហើយ នឹងទៅកាន់ភ្នំវិញ។

[៤២០] (ពោធិសត្វ ពោលថា) ពួកអណ្តើក ជាកស្សបគោត្ត ពួកស្វាជាកោណ្ឌញ្ញគោត្ត ម្នាលកស្សប អ្នកចូរលែងកោណ្ឌញ្ញ (ស្វាទ្រុស្តសីលនេះ) ដែលធ្វើមេថុនកម្មនឹងអ្នក។

ចប់ កច្ឆបជាតក ទី៣។

## លោលជាតក ទី៤

CS sut.kn.jat.274 | ភាគទី ៥៨

**(២៧៤. លោលជាតកំ (៣-៣-៤))**

[៤២១] (ព្រាបពោធិសត្វ ពោលថា) កុកនេះដូចម្តេច មានសីរជាសត្វល្អួច មានពពកជាជីតា នៃកុក អ្នកចូលមកអាយ (ព្រោះ) ក្អែកជាសំឡាញ់យើង ជាសត្វកាច។

[៤២២] (ក្អែក ពោលថា) ខ្ញុំមិនមែនជាកុកមានសីរទេ ខ្ញុំជាក្អែករលោរលាំ អ្នកទើបនឹងមក ចូរមើលខ្ញុំដែលត្រូវគេដកស្លាប ព្រោះតែមិនធ្វើតាមពាក្យរបស់អ្នក។

[៤២៣] (ពោធិសត្វ ពោលថា) ម្នាលសំឡាញ់ អ្នកនឹងប្រទះ (បែបនេះ) ម្តងទៀតពុំខាន ព្រោះថាសីល (មារយាទ) របស់អ្នកប្រាកដដូច្នោះ គ្រឿងបរិភោគទាំងឡាយ ជារបស់នៃមនុស្ស មិនមែនសត្វស្លាបបរិភោគបានដោយងាយឡើយ។

ចប់ លោលជាតក ទី៤។

## រុចិរជាតក ទី៥

CS sut.kn.jat.275 | ភាគទី ៥៨

**(២៧៥. រុចិរជាតកំ (៣-៣-៥))**

[៤២៤] (ពោធិសត្វ ពោលថា) កុកនេះជាអ្វី មានសម្បុររលើប មកនៅក្នុងសំបុកក្អែក សំបុកនេះជារបស់ក្អែកណា ក្អែកជាសំឡាញ់របស់ខ្ញុំនោះ កាចណាស់។

[៤២៥] (ក្អែក ពោលថា) ម្នាលសំឡាញ់ស្មើចិត្ត ជាសត្វមានកំណើតពីរ ក្រែងអ្នកស្គាល់ខ្ញុំដែលជាសត្វមានពូជស្មៅជាភោជនដែរឬ អ្នកទើបនឹងមក ចូរមើលខ្ញុំដែលគេដកស្លាប ព្រោះតែមិនធ្វើតាមពាក្យរបស់អ្នក។

[៤២៦] (ពោធិសត្វ ពោលថា) ម្នាលសំឡាញ់ អ្នកនឹងប្រទះ (បែបនេះ) ម្តងទៀតពុំខាន ព្រោះថា សីលធម៌របស់អ្នកប្រាកដដូច្នោះ គ្រឿងបរិភោគទាំងឡាយ ជារបស់មនុស្ស មិនមែនសត្វស្លាបបរិភោគបានដោយងាយឡើយ។

ចប់ រុចិរជាតក ទី៥។

## កុរុធម្មជាតក ទី៦

CS sut.kn.jat.276 | ភាគទី ៥៨

**(២៧៦. កុរុធម្មជាតកំ (៣-៣-៦))**

[៤២៧] (ពួកព្រាហ្មណ៍ ក្រាបទូលថា) បពិត្រព្រះជនាធិបតី យើងទាំងឡាយ ដឹងច្បាស់នូវសទ្ធា និងសីលរបស់ព្រះអង្គហើយ នឹងទទួលយកនូវដំរីមានសម្បុរប្រាកដស្មើដោយផ្កាអញ្ជន ទៅក្នុងសំណាក់នៃព្រះបាទកាលិង្គៈ។

[៤២៨] (ព្រះរាជាពោធិសត្វ ពោលថា) ពួកសត្វដែលយើងចិញ្ចឹមដោយបាយក្តី មិនចិញ្ចឹមក្តី សត្វណាក្នុងជីវលោកនេះ ដើរមកសំដៅយើង ពួកសត្វទាំងអស់នោះ យើងមិនបានឃាត់ឡើយ នេះជាពាក្យរបស់បុព្វាចារ្យ (មាតា បីតារបស់យើង)។

[៤២៩] ម្នាលព្រាហ្មណ៍ទាំងឡាយ យើងឲ្យដំរីដ៏ប្រសើរនេះ ដែលសមគួរដល់ព្រះរាជា ជាជំនិះរបស់ព្រះរាជា មានយស ប្រដាប់តាក់តែងហើយ បំពាក់ហើយដោយបណ្តាញមាស ដល់អ្នកទាំងឡាយ អ្នកទាំងឡាយ ព្រមទាំងសារថី (ចូរនាំ) ទៅតាមប្រាថ្នាចុះ។

ចប់ កុរុធម្មជាតក ទី៦។

## រោមជាតក ទី៧

CS sut.kn.jat.277 | ភាគទី ៥៨

**(២៧៧. រោមកជាតកំ (៣-៣-៧))**

[៤៣០] (តាបស ពោលថា) ម្នាលរោមកៈ យើងនៅក្នុងគុហាភ្នំ ជាង ៥០ ឆ្នាំ ពួកអណ្ឌជសត្វ (សត្វកើតអំពីពងទាំងនេះ ) មិនមានសេចក្តីរង្កៀស ជាសត្វមានចិត្តស្លូតត្រង់ រមែងមកកាន់កណ្តាប់ដៃនៃយើងក្នុងកាលមុន។

[៤៣១] ម្នាលសត្វមានអវយវៈក្ងក់ ឥឡូវនេះ ពួកទិជសត្វ (សត្វកើតពីរដង) ទាំងនោះ (ឃើញ) ហេតុអ្វីបានជាមានសេចក្តីខ្វល់ខ្វាយ

(គេចចេញអំពីញកភ្នំនេះ) ទៅនៅញកភ្នំដទៃវិញ ក្រែង (ពួកបក្សីទាំងនេះ) ទៅឃ្លាតឃ្លាយ បានជាមិនស្គាល់យើងដូចជាក្នុងកាលមុន ឬក៏ពួកបក្សីទាំងនេះ មិនមែនជាពួកបក្សីទាំងនោះទេ។

[៤៣២] (ពោធិសត្វ ពោលថា) ពួកយើងស្គាល់លោក មិនមែនច្រឡំទេ លោក ក៏គឺលោកហ្នឹងដដែល ពួកយើង គឺសត្វទាំងនោះ មិនមែនជាសត្វដទៃទេ តែថា ចិត្តរបស់លោក ប្រទូស្តចំពោះពួកជននេះ ម្នាលអាជីវក ព្រោះហេតុនោះ បានជាពួកយើងតក់ស្លុតនឹងលោក។

ចប់ រោមជាតក ទី៧។

## មហិសជាតក ទី៨

CS sut.kn.jat.278 | ភាគទី ៥៨

### (២៧៨. មហឹសរាជជាតកំ (៣-៣-៨))

[៤៣៣] (រុក្ខទេវតា ពោលថា) អ្នកអាស្រ័យហេតុដូចម្តេច ទើបអត់ទ្រាំនូវសេចក្តីលំបាកនេះនឹងស្វាមានចិត្តរហ័ស ជាសត្វប្រទូស្ត មិត្ត (ដូចជាបុគ្គលអត់ទ្រាំនឹងសេចក្តីលំបាក) នឹងម្ចាស់ដែលជាអ្នកឲ្យសេចក្តីប្រាថ្នាទាំងពួង។

[៤៣៤] អ្នកចូរវៃផ្ទស្វានេះដោយស្នែង ចូរជាន់កំទេចដោយជើងចុះ ប្រសិនបើមិនមានអ្នកកំចាត់បង់ទេ ពួកពាលនឹងគប្បីរឹងរឹតបៀតបៀនឡើង។

[៤៣៥] (ពោធិសត្វ ពោលថា) ស្វានេះ កាលមើលងាយខ្ញុំបាន គង់នឹងធ្វើ (អនាចារ) យ៉ាងនេះ នឹងក្របីដទៃទៀត ក្របីទាំងនោះ នឹងសម្លាប់វាក្នុងទីនោះ ការរួច (ចាកសេចក្តីលំបាក) នោះ នឹងមានដល់ខ្ញុំ។

ចប់ មហិសជាតក ទី៨។

## សតបត្តជាតក ទី៩

CS sut.kn.jat.279 | ភាគទី ៥៨

### (២៧៩. សតបត្តជាតកំ (៣-៣-៩))

[៤៣៦] (ព្រះសាស្តា ត្រាស់ថា) មាណពសំគាល់នូវមេចចកក្នុងផ្លូវ ជាសត្វគោចរទៅក្នុងព្រៃ ប្រាថ្នានូវសេចក្តីចំរើន តែងប្រាប់ហេតុឲ្យដឹង ថាជាសត្វប្រាថ្នានូវសេចក្តីវិនាស សំគាល់នូវសត្វចចាត ជាសត្វប្រាថ្នានូវសេចក្តីវិនាស ថាជាសត្វប្រាថ្នានូវសេចក្តីចំរើនយ៉ាងណាមិញ។

[៤៣៧] បុគ្គលខ្លះក្នុងលោកនេះ ជាអ្នកប្រាកដដូច្នោះ ដែលជនទាំងឡាយ អ្នកប្រាថ្នានូវប្រយោជន៍ ពោលពាក្យ (ប្រៀនប្រដៅ) ទទួលយកឆ្វេងទៅវិញ ក៏យ៉ាងនោះដែរ។

[៤៣៨] មួយទៀត ពួកបុគ្គលណា សរសើរនូវបុគ្គលនោះក្តី លើកដំកើងបុគ្គលនោះ ព្រោះភ័យក្តី បុគ្គលនោះ រមែងសំគាល់ពួកបុគ្គលថាជាមិត្ត ដូចមាណព (កាលសំគាល់) នូវសត្វចចាត ថាជាមិត្តដូច្នោះ។

ចប់ សតបត្តជាតក ទី៩។

## បុដទូសកជាតក ទី១០

CS sut.kn.jat.280 | ភាគទី ៥៨

### (២៨០. បុដទូសកជាតកំ (៣-៣-១០))

[៤៣៩] (ពោធិសត្វ ពោលថា) មិគរាជ គឺស្តេចស្វា ជាសត្វឈ្លាសក្នុងការធ្វើកញ្ចប់ស្លឹកឈើដោយពិត ព្រោះហេតុដូច្នោះ ទើបបានបំផ្លាញកញ្ចប់ចោល នឹងធ្វើកញ្ចប់ដទៃឲ្យល្អជាងកញ្ចប់មុនដោយពិត។

[៤៤០] (វានរ ពោលថា) បិតា ឬមាតារបស់ខ្ញុំ មិនមែនជាសត្វឈ្លាសក្នុងការធ្វើកញ្ចប់ទេ តែពួកខ្ញុំ បានតែខាងបំផ្លាញនូវវត្ថុដែលគេធ្វើហើយ ៗ ប៉ុណ្ណោះ នេះជាត្រកូល (របស់វានរ) តែងមានយ៉ាងនេះ ជាធម្មតា។

[៤៤១] (ពោធិសត្វ ពោលថា) ធម្មតារបស់ពួកអ្នកណា ប្រាកដយ៉ាងនេះទៅហើយ ចំណាង់បើមិនមែនធម្មតា តើនឹងដូចម្តេចទៅវិញ យើងសូមកុំឲ្យជួបប្រទះនឹងអាការជាធម្មតា ឬមិនមែនជាធម្មតារបស់ពួកអ្នកនោះ ក្នុងកាលណាឡើយ។

ចប់ បុដទូសកជាតក ទី១០។

ចប់ ឧទបានវគ្គ ទី៣។

ឧទ្ទាននៃឧទបានវគ្គនោះគឺ

និយាយអំពីអណ្តូងទឹកប្រសើរ ១ ខ្លាក្នុងព្រៃ ១ ស្វា ១ កុកមានសីរ ១ កុកដ៏រលើបល្ល ១ ជនាធិបតីល្អ ១ ព្រាបឈ្មោះរោមកៈ ១ ស្វាប្រទូស្ត ១ សត្វចចាត ១ ការធ្វើកញ្ចប់ ១ ត្រូវជា ១០។

## អព្ភន្តរវគ្គ ទី៤

CS sut.kn.jat.v03.04 | ភាគទី ៥៨

### (៤. អព្ភន្តរវគ្គោ)

## អព្ភន្តរជាតក ទី១

CS sut.kn.jat.281 | ភាគទី ៥៨

**(២៨១. អព្ភន្តរជាតកំ (៣-៤-១))**

[៩៤២] (សក្កទេវរាជ ត្រាស់ថា) នាងនារីមានបែបចាញ់ផ្ទៃ បានបរិភោគផ្លែឈើ (ស្វាយ) ឈ្មោះអព្ភន្តរៈជាទិព្វ ហើយប្រសូត (ព្រះរាជបុត្រ) ជាស្តេចចក្រពត្តិ។

[៩៤៣] ម្នាលនាងដ៏ចំរើន នាងជាមហេសី ទាំងជាទីស្រឡាញ់របស់ព្រះរាជាជាភស្តា ព្រះរាជានឹងនាំផ្លែស្វាយ ឈ្មោះអព្ភន្តរៈនេះ មកដល់នាង។

[៩៤៤] (កូនសេក ពោលថា) បុគ្គលអ្នកក្លៀវក្លា ស៊ូលះបង់ខ្លួន ប្រឹងប្រែងក្នុងប្រយោជន៍របស់បុគ្គលអ្នកចិញ្ចឹម ៗ ខ្លួន រមែងបាននូវឋានៈណា ខ្ញុំបាននូវឋានៈនោះដែរ។

ចប់ អព្ភន្តរជាតក ទី១។

## សេយ្យជាតក ទី២

CS sut.kn.jat.282 | ភាគទី ៥៨

**(២៨២. សេយ្យជាតកំ (៣-៤-២))**

[៩៤៥] (ព្រះរាជាពោធិសត្វ ត្រាស់ថា) បុគ្គលណា គប់រកនូវបុគ្គលប្រសើរ (បុគ្គលនោះ) ជាអ្នកមានចំណែកប្រសើរ ជាអ្នកប្រសើរបំផុត ខ្ញុំបានធ្វើនូវការជាប់តជាមួយនឹងស្តេច ជាចោរម្នាក់ (ដោយមេត្តាភាវនា) បានដោះអ្នកទាំងឡាយ ១០០ នាក់ ដែលត្រូវគេសំឡាប់ (ឲ្យរួចបាន)។

[៩៤៦] ព្រោះហេតុនោះ បុគ្គលម្នាក់ឯង ធ្វើនូវការជាប់តជាមួយនឹងលោកទាំងមូល (ដោយមេត្តាភាវនា) លុះទំលាយខន្ធទៅ គប្បីបានឋានសួគ៌ អ្នកទាំងឡាយដែលនៅក្នុងដែនកាសី ចូរស្តាប់នូវពាក្យរបស់យើងនេះចុះ។

[៩៤៧] (ព្រះសាស្តា ត្រាស់ថា) ព្រះរាជាជាធំ ព្រះនាមកំសៈ ព្រះអង្គគ្រប់គ្រងក្រុងពារាណសី បានត្រាស់ដូច្នេះហើយ ទ្រង់ដាក់ធ្នូ និងព្រួញចោល ហើយទើបចូលទៅកាន់ការសង្រួម គឺបព្វជ្ជា។

ចប់ សេយ្យជាតក ទី២។

## វឌ្ឍកីសូករជាតក ទី៣

CS sut.kn.jat.283 | ភាគទី ៥៨

**(២៨៣. វឌ្ឍកីសូករជាតកំ (៣-៤-៣))**

[៩៤៨] (ជដិលមានចិត្តកោង ពោលថា) កាលពីដើម អ្នករឹបជាន់នូវជ្រូកទាំងឡាយ ក្នុងប្រទេសនេះ តែងសំឡាប់ជ្រូកដ៏ប្រសើរ ៗ បាន ម្នាលខ្លា ឥឡូវនេះ អ្នកនោះត្រឡប់មកម្នាក់ឯង សញ្ជប់សញ្ជឹង ម្នាលខ្លា ថ្ងៃនេះកំឡាំងកាយរបស់អ្នកគ្មានទេឬ។

[៩៤៩] (ខ្លា ពោលថា) កាលពីដើម ជ្រូកទាំងនេះជាច្រើន ត្រូវភ័យបៀតបៀនហើយ ក៏ស្វែងរកទីជ្រកកោន ហើយក៏បោលទៅកាន់ទិសតូចទិសធំ ឥឡូវនេះ ជ្រូកទាំងនេះ ឋិតនៅក្នុងទីណា ដែលខ្ញុំបៀតបៀនមិនបាន ជ្រូកទាំងនោះ ក៏មកជួបជុំគ្នា នៅក្នុងទីនោះជាមួយគ្នា។

[៩៥០] (រុក្ខទេវតា ពោលថា) យើងសូមថ្វាយបង្គំពួកជ្រូក ដែលមកជួបជុំគ្នា (ក្នុងទីនេះ) យើងបានឃើញនូវមិត្តភាព (របស់អ្នកទាំងឡាយ) ដ៏អស្ចារ្យដោយខ្លួនឯងទើបពោល ព្រោះថា ពួកម្រឹគមានខ្នាយ បានឈ្នះនូវខ្លា រួចចាក (មរណភ័យ) ដោយសេចក្តីព្រមព្រៀងក្នុងពួកជ្រូកមានខ្នាយជាកំឡាំង។

ចប់ វឌ្ឍកីសូករជាតក ទី៣។

## សិរីជាតក ទី៤

CS sut.kn.jat.284 | ភាគទី ៥៨

**(២៨៤. សិរិជាតកំ (៣-៤-៤))**

[៩៥១] (ព្រះសាស្តា ត្រាស់ថា) ពួកបុគ្គលឥតបុណ្យ ខ្វល់ខ្វាយប្រមូលទ្រព្យណាដ៏ច្រើន ចំណែកខាងបុគ្គលអ្នកមានបុណ្យ ទោះមានសិល្បៈក្តី មិនមានសិល្បៈក្តី ក៏រមែងបានបរិភោគនូវទ្រព្យទាំងនោះ។

[៩៥២] ភោគៈទាំងឡាយច្រើន រមែងកន្លងនូវពួកបុគ្គលឥតបុណ្យ កើតឡើងសម្រាប់បុគ្គលអ្នកមានបុណ្យធ្វើហើយ ក្នុងទីទាំងពួងសូម្បីក្នុងទីមិនមែនជាកន្លែងសម្រាប់កើត។

[៩៥៣] មាន់ឈ្មោលក្តី កែវមណីក្តី ឈើច្រត់ក្តី នាងបុញ្ញលក្ខណាទេវី ជាប្រពន្ធ (របស់សេដ្ឋី) ក្តី រមែងកើតឡើងដល់អនាថបណ្ឌិតសេដ្ឋី អ្នកមិនមានបាប ជាអ្នកមានបុណ្យធ្វើហើយ។

ចប់ សិរីជាតក ទី៤។

## មណិសូករជាតក ទី៥

(២៨៥. មណិសូករជាតកំ (៣-៤-៥))

[៤៥៤] (ពួកជ្រូក ពោលថា) យើងខ្ញុំប្រមាណ ៣០ នាក់ នៅក្នុងមណិគុហា អស់ប្រាំពីរឆ្នាំ យើងខ្ញុំប្រឹក្សាគ្នាថា យើងខ្ញុំកំចាត់បង់នូវពន្លឺនៃកែវមណីដូច្នេះ។

[៤៥៥] យើងខ្ញុំដដុសកែវមណី ដរាបណា កែវមណីរឹងរឹតតែភ្លឺឆ្លុះឡើង ឥឡូវនេះ យើងខ្ញុំសូមសួរនូវហេតុនេះថា លោកយល់នូវកិច្ចដូចម្តេច ក្នុងរឿងនេះ។

[៤៥៦] (ពោធិសត្វ ពោលថា) កែវមណីនេះ ដូចជាកែវពៃទូរ្យ មិនមែនកញ្ចក់ ជាកែវស្អាតឥតមន្ទិល អ្នកណាមួយមិនអាចដើម្បីកំចាត់បង់ពន្លឺនៃកែវមណីនុ៎ះ ឲ្យស្អាប់សម្បុរបាន នៃជ្រូកទាំងឡាយ ពួកអ្នក ចូរចៀសចេញទៅ។

ចប់ មណិសូករជាតក ទី៥។

## សាលុកជាតក ទី៦



(២៨៦. សាលូកជាតកំ (៣-៤-៦))

[៤៥៧] (គោឈ្មោះមហាលោហិតពោធិសត្វ ពោលថា) អ្នកកុំប្រាថ្នា (នូវអាហារ) របស់ជ្រូកឈ្មោះសាលុកឡើយ (ដ្បិតជ្រូកនេះ) បរិភោគបាយ ជាគ្រឿងក្តៅក្រហាយ អ្នកចូរមានសេចក្តីខ្វល់ខ្វាយតិច ហើយបរិភោគនូវអង្កាមចុះ ការបរិភោគនូវអង្កាមនេះឯងហើយ ជាលក្ខណៈនៃហេតុឲ្យអាយុវែង។

[៤៥៨] បុរសអ្នករៀបការនោះជាសេវកៈ (ប្រកបដោយបរិសទ្យ) ជាភ្ញៀវមកប្រជុំក្នុងទីនេះ ក្នុងកាលឥឡូវនេះ អ្នកនឹងឃើញជ្រូកឈ្មោះសាលុកដេកស្ងៀម ត្រូវគេសម្លាប់ក្នុងចន្លោះនៃអង្រែមិនខាន។

[៤៥៩] (ព្រះសាស្តា ត្រាស់ថា) គោចាស់ (ទាំងពីរ) ឃើញជ្រូកដេកស្ងៀម ត្រូវគេសម្លាប់ក្នុងចន្លោះនៃអង្រែដែលគេកាច់ហើយ ក៏គិតថា អង្កាមជាអាហារដ៏ប្រសើររបស់យើង។

ចប់ សាលុកជាតក ទី៦។

## លាភគរហិកជាតក ទី៧



(២៨៧. លាភគរហជាតកំ (៣-៤-៧))

[៤៦០] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) បុគ្គលមិនឆ្កួត រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមិននិយាយញុះញង់ រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមិនមែនអ្នករបាំ រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ បុគ្គលមានសំដីក្រអឺមក្រអៀម រមែងមិនបានលាភក្នុងសំណាក់នៃមនុស្សល្ងង់ទេ នេះជាពាក្យប្រៀនប្រដៅរបស់អ្នក។

[៤៦១] (កូនសិស្ស ពោលថា) បពិត្រព្រាហ្មណ៍ ខ្ញុំសូមតិះដៀលនូវការបានយស និងការបានទ្រព្យ ព្រោះតែប្រព្រឹត្តចិញ្ចឹមជីវិតដោយធ្វើខ្លួនឲ្យលិចលង់ (ដោយកិច្ចមានកិរិយាសម្លាប់គេជាដើម) ឬដោយការប្រព្រឹត្តិនូវទុច្ចរិត។

[៤៦២] បុគ្គលសូវធ្វើជាអ្នកបួស កាន់បាត្រ (ដើរសូមគេ) (ព្រោះថា) ការប្រព្រឹត្តិចិញ្ចឹមជីវិតនេះឯង ប្រសើរបំផុតជាងកិរិយាស្វែងរកចិញ្ចឹមជីវិតដោយអធម៌។

ចប់ លាភគរហិកជាតក ទី៧។

## មច្ឆុទានជាតក ទី៨



(២៨៨. មច្ឆុទ្ទានជាតកំ (៣-៤-៨))

[៤៦៣] (ពោធិសត្វ ពោលថា) ត្រីទាំងឡាយ ថ្លៃមួយពាន់កហាបនៈ លើសដោយ (៧ មាសក) មិនមានអ្នកណាមួយ ជឿនូវហេតុនេះតែថា (មក) ដល់អញក្នុងទីនេះនៅតែថ្លៃ ៧ មាសក អញគប្បីទិញនូវពួកត្រីនោះ។

[៤៦៤] (នទីទេវតា ពោលថា) អ្នកបានឲ្យភោជនដល់ពួកត្រី ហើយផ្សាយចំណែកផលដល់ខ្ញុំ ខ្ញុំរលឹកនូវទក្ខិណានោះ ជាសេចក្តីគោរពដែលអ្នកធ្វើហើយ (ទើបរក្សាទ្រព្យនេះទុកឲ្យអ្នក)។

[៤៦៥] សេចក្តីចំរើន មិនមានដល់បុគ្គលអ្នកមានចិត្តប្រទូស្តឡើយ មួយទៀត បុគ្គលណាធ្វើអំពើអាក្រក់ បោកប្រាសទ្រព្យសម្បត្តិដែលជាកេរ្តិ៍មតិករបស់បិតា និងបងប្អូនឯង ពួកទេវតាក៏មិនបូជាបុគ្គលនោះឡើយ។

ចប់ មច្ឆទានជាតក ទី៨។

## នានាឆន្ទជាតក ទី៩

(២៨៩. នានាឆន្ទជាតកំ (៣-៤-៩))

[៩៦៦] (ព្រាហ្មណ៍បុរោហិត ពោលថា) បពិត្រមហារាជ យើងខ្ញុំទាំងឡាយ មានចំណង់ផ្សេង ៗ គ្នា នៅក្នុងផ្ទះជាមួយគ្នា ចំណែកខ្ញុំព្រះអង្គចង់បានស្រុកសួយ នាងព្រាហ្មណីជាប្រពន្ធ ចង់បានគោ ១០០។

[៩៦៧] កូនប្រុស (របស់ខ្ញុំព្រះអង្គ) ចង់បានរថទឹមដោយសេះអាជានេយ្យ នាងកញ្ញា (កូនប្រសាស្រី) ចង់បានកុណ្ឌលកែវមណី ចំណែកខាងនាងបុណ្ណកាទាសីថោកទាប ចង់បានត្បាល់ (មួយអន្លើដោយចង្អេរ និងអង្រែ)។

[៩៦៨] (ព្រះរាជា ត្រាស់ថា) អ្នកទាំងឡាយ ចូរឲ្យស្រុកសួយដល់ព្រាហ្មណ៍ ចូរឲ្យគោ ១០០ ដល់នាងព្រាហ្មណី ចូរឲ្យរថទឹមដោយសេះអាជានេយ្យដល់បុត្ត (របស់ព្រាហ្មណ៍) ចូរឲ្យកុណ្ឌលកែវមណីដល់នាងកញ្ញា មួយទៀត អ្នកទាំងឡាយ ចូរចាត់ចែងរកត្បាល់ (ព្រមទាំងចង្អេរ និងអង្រែ) ឲ្យនាងបុណ្ណកាទាសីថោកទាបនោះផង។

ចប់ នានាឆន្ទជាតក ទី៩។

## សីលវីមំសជាតក ទី១០

CS sut.kn.jat.290 | ភាគទី ៥៨

(២៩០. សីលវីមំសកជាតកំ (៣-៤-១០))

[៩៦៩] (ព្រាហ្មណ៍ពោធិសត្វ ពោលថា) ឮថា សីល ជាគុណជាតល្អ សីល ជាគុណជាតប្រសើរបំផុតក្នុងលោក អ្នកចូរមើលចុះ ពស់មានពិសដ៏ពន្លឹក មិនបៀតបៀន (ហ្មពស់) ដោយយល់ថា អ្នកមានសីល។

[៩៧០] បុគ្គលប្រព្រឹត្តស្មើតាមការប្រព្រឹត្តិរបស់ព្រះអរិយៈ ទើបបណ្ឌិតហៅថា អ្នកមានសីល ដោយសីលណា យើងនឹងសមាទាននូវសីលនោះ ដែលបណ្ឌិតយល់ព្រមហើយថា សីលនេះជារបស់ក្សេម (ចាកភ័យ) ក្នុងលោក។

[៩៧១] ម្យ៉ាងទៀត បុគ្គលអ្នកមានសីលជាទីស្រឡាញ់នៃពួកញាតិផង រមែងរុងរឿងក្នុងពួកមិត្រផង លុះបែកធ្លាយរាងកាយ ក៏ទៅកើតក្នុងសុគតិភព។

ចប់ សីលវីមំសជាតក ទី១០។

ចប់ អព្ភន្តរវគ្គ ទី៤។

ឧទ្ទាននៃអព្ភន្តរវគ្គនោះគឺ

និយាយអំពីផ្លែឈើអព្ភន្តរៈ ១ ព្រះរាជាព្រះនាមកំសៈ ១ ជ្រុកដ៏ប្រសើរ និងម្រឹគ គឺខ្លា ១ កែវមណី ១ ជ្រុកនៅក្នុងគុហាកែវមណី ១ ជ្រូកឈ្មោះសាលុក ១ ការប្រៀនប្រដៅ ១ ត្រីដ៏ប្រសើរ ១ កុណ្ឌលកែវមណី ១ សីល ១ ត្រូវជា ១០។

# កុម្ភវគ្គ ទី៥

CS sut.kn.jat.v03.05 | ភាគទី ៥៨

(៥. កុម្ភវគ្គោ)

## ភទ្រឃដភេទកជាតក ទី១

CS sut.kn.jat.291 | ភាគទី ៥៨

(២៩១. សុរាឃដជាតកំ (២-៥-១))

[៩៧២] (ព្រះសាស្តា ត្រាស់ថា) អ្នកលេងបាននូវឆ្នាំងកំណាប់ ដែលឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ហើយរក្សាឆ្នាំងនោះ ដរាបណា អ្នកលេងនោះ ក៏ដល់នូវសេចក្តីសុខ ដរាបនោះ។

[៩៧៣] ក្នុងកាលណា អ្នកលេងស្រវឹងផង គឃ្លើនផង បានបំបែកឆ្នាំង ព្រោះសេចក្តីប្រមាទ ក្នុងកាលនោះ បុគ្គលពាលទៅជាអ្នកអាក្រាតផង ជាអ្នកស្លៀកកំណាត់សំពត់កន្ទបផង រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយ។

[៩៧៤] បុគ្គលឥតប្រាជ្ញា បាននូវទ្រព្យយ៉ាងនេះហើយ ជាអ្នកមានសេចក្តីប្រមាទប្រើប្រាស់ រមែងក្តៅក្រហាយក្នុងកាលខាងក្រោយ ដូចជាអ្នកលេង (ដែលក្តៅក្រហាយស្តាយក្រោយ) ព្រោះតែបំបែកឆ្នាំងចោល។

ចប់ ភទ្រឃដភេទកជាតក ទី១។

## សុបត្តជាតក ទី២

CS sut.kn.jat.292 | ភាគទី ៥៨

(២៩២. សុបត្តជាតកំ (៣-៥-២))

[៩៧៥] (ក្អែក ពោលថា) បពិត្រមហារាជ ស្តេចក្អែកឈ្មោះសុបត្តៈ នៅអាស្រ័យក្បែរក្រុងពារាណសី មានក្អែក ៨០ ០០០ ជាបរិវារ។

[៩៧៦] នាងសុបស្សា ជាភរិយារបស់ស្តេចក្អែកនោះ មានសេចក្តីចាញ់ផ្ទៃ ចង់បរិភោគនូវក្រយាស្ងោយមានថ្លៃច្រើន ដែលនាយពិសេសចំអិន ដើម្បីថ្វាយព្រះរាជា ក្នុងរោងសំរាប់ចំអិនក្រយាស្ងោយ។

[៩៧៧] ឯខ្ញុំព្រះអង្គជារាជទូតរបស់ស្តេចក្អែកទាំងនោះ ត្រូវស្តេចបញ្ជូនមក បានជាមកក្នុងទីនេះ ខ្ញុំព្រះអង្គធ្វើនូវសេចក្តីគោរព ចំពោះ

ម្ចាស់ ហើយបានធ្វើឲ្យមានរបួស ត្រង់ច្រមុះ (របស់នាយពិសេស)។

ចប់ សុបត្តជាតក ទី២។

## កាយនិព្វិន្ទជាតក ទី៣

CS sut.kn.jat.293 | ភាគទី ៥៨

**(២៩៣. កាយនិព្វិន្ទជាតកំ (៣-៥-៣))**

[៤៧៨] (តាបសពោធិសត្វ ពោលថា) កាលអញត្រូវព្យាធិរោគណាមួយប៉ះពាល់ហើយ ដល់នូវសេចក្តីទុក្ខយ៉ាងខ្លាំងក្លា ដែលរោគកំពុងបៀតបៀន រាងកាយនេះ ដ៏នឹងរីងស្ងួតយ៉ាងឆាប់ ដូចជាផ្កាឈើដែលគេដោតលើអាចម៍ដី ដ៏ក្តៅ (ក៏ស្ងួតដូច្នោះ)។

[៤៧៩] (រាងកាយនេះ) មិនជាទីគាប់ចិត្ត តែជនពាលពោលថា ជាទីគាប់ចិត្ត មិនស្អាតទេ តែជនពាល សន្មតថាជារបស់ស្អាត រាងកាយដ៏ពេញប្រៀប ដោយសាកសពផ្សេង ៗ មានសភាពជាទីគាប់ចិត្តនៃជនពាល។

[៤៨០] យើងគួរតិះដៀលនូវកាយស្អុយនេះ ជារបស់ឈឺជានិច្ច គួរខ្ពើមរអើម មិនស្អាត មានព្យាធិជាធម្មតា ដែលពួកសត្វប្រមាទជ្រប់ជាប់ ញ៉ាំងផ្លូវនៃសុគតិភព ឲ្យវិនាសសាបសូន្យ។

ចប់ កាយនិព្វិន្ទជាតក ទី៣។

## ជម្ពុខាទកជាតក ទី៤

CS sut.kn.jat.294 | ភាគទី ៥៨

**(២៩៤. ជម្ពុខាទកជាតកំ (៣-៥-៤))**

[៤៨១] (ចចក ពោលថា) អ្នកណានេះ មានសំឡេងក្រលួច ពីរោះឧត្តមជាងពួកសត្វ ដែលមានសំឡេង ទំលើមែកព្រីង ហើយយំពីរោះដូចជាសំឡេងនៃកូនក្ងោក។

[៤៨២] (ក្អែក ពោលថា) កុលបុត្តចេះសរសើរកុលបុត្ត (ដូចគ្នា) ម្នាលសំឡាញ់ មានសម្បុរដូចជាសម្បុរនៃកូនខ្លា ខ្ញុំសូមជូន (ផ្លែព្រីង) ដល់អ្នក ចូរអ្នកពិសាចុះ។

[៤៨៣] (រុក្ខទេវតា ពោលថា) យូរណាស់ហើយ យើងទើបតែឃើញនូវក្អែកជាសត្វស៊ីនូវកំអួតផង នូវចចកជាសត្វស៊ីនូវសាកសពផង ជាសត្វពោលពាក្យកុហក មកចួបគ្នា ហើយសរសើរគ្នាទៅវិញទៅមក។

ចប់ ជម្ពុខាទកជាតក ទី៤។

## អន្តជាតក ទី៥

CS sut.kn.jat.295 | ភាគទី ៥៨

**(២៩៥. អន្តជាតកំ (៣-៥-៥))**

[៤៨៤] (ក្អែក ពោលថា) ករបស់អ្នក ដូចជាកនៃគោឧសភៈ ការមិតពត់របស់អ្នក ដូចជាការមិនពត់នៃសត្វសីហៈ បពិត្រមិគរាជ ខ្ញុំសូមថ្វាយបង្គំអ្នក ធ្វើម្តេចយើងនឹងបាននូវសាច់តិចតួច។

[៤៨៥] (ចចក ពោលថា) កុលបុត្រចេះសរសើរនូវកុលបុត្រដូចគ្នា ម្នាលក្អែកមានផ្នួតកដូចជាក្ងោក អ្នកចូរចុះអំពីដើមល្ហុងនេះមក។

[៤៨៦] (រុក្ខទេវតា ពោលថា) ចចកជាសត្វថោកទាបជាងម្រឹគទាំងឡាយ ឯក្អែកជាសត្វថោកទាប ជាងបក្សីទាំងឡាយដែរ ដើមល្ហុងជាឈើថោកទាបជាងឈើទាំងឡាយ ពួកថោកទាបទាំង ៣ មកជួបប្រទះគ្នា។

ចប់ អន្តជាតក ទី៥។

## សមុទ្ទជាតក ទី៦

CS sut.kn.jat.296 | ភាគទី ៥៨

**(២៩៦. សមុទ្ទជាតកំ (៣-៥-៦))**

[៤៨៧] (សមុទ្ទទេវតា ពោលថា) អ្នកណានេះហ៊ុំ ស្ទុះទៅមក ដោយជុំវិញ ក្នុងសមុទ្រមានទឹកប្រៃ ហាមឃាត់នូវពួកត្រី និងពួកមករលំបាកក្នុងរលកទឹក។

[៤៨៨] (ក្អែកសមុទ្រ ពោលថា) ខ្ញុំជាសត្វស្លាប ជាសត្វផឹកទឹកមិនមានទីបំផុត ល្បីល្បាញទៅគ្រប់ទិស ថាជាសត្វមិនចេះឆ្អែត ប្រាថ្នាដើម្បីផឹកនូវទឹកសមុទ្រ គឺសាគរ ដែលជាម្ចាស់នៃទន្លេ។

[៤៨៩] (សមុទ្ទទេវតា ពោលថា) សមុទ្ទធំនោះ ជួនកាល ក៏នាចទៅ ជួនកាលក៏ជោរឡើង ទីបំផុតនៃទឹកសមុទ្ទនោះដែលសកលលោកផឹកហើយ មិនប្រាកដទេ ឮថាសាគរ អ្នកណាមួយ ក៏មិនអាចផឹកទឹកឲ្យអស់បានឡើយ។

ចប់ សមុទ្ទជាតក ទី៦។

## កាមវិលាបជាតក ទី៧

(២៩៧. កាមវិលាបជាតកំ (៣-៥-៧))

[៤៩០] (បុរសម្នាក់ ពោលថា) ម្នាលសត្វស្លាប អ្នកទៅក្នុងទីខ្ពស់ ទៅដោយស្លាបបាន ទៅតាមអាកាសបាន សូមអ្នកប្រាប់ (ប្រពន្ធខ្ញុំ) ដែលមានភ្លៅស្រលូតដូចដើមចេក ប្រពន្ធរបស់ខ្ញុំនោះ នឹងរលឹកខ្ញុំអស់កាលយូរ។

[៤៩១] ប្រពន្ធខ្ញុំនោះ មិនដឹងនូវដាវ និងលំពែងនេះឯង ដែលគេដោតចុះហើយ វាជាស្រីឆ្លាស តែងធ្វើនូវសេចក្តីក្រោធ ការក្រោធរបស់វានោះ រមែងក្តៅក្រហាយដល់ខ្ញុំ (ឯដាវ និងលំពែងដែលគេដោត) ក្នុងទីនេះ មិនមែនក្តៅក្រហាយដល់ខ្ញុំទេ។

[៤៩២] ច្បូកដូចជាផ្កាឧប្បល និងក្រោះនោះ ចិញ្ចៀនមាស សំពត់មានសាច់ដ៏ទន់ ដែលជននាំមកអំពីដែនកាសី ខ្ញុំដាក់លើក្បាលដំណេក (ប្រពន្ធខ្ញុំ) ជាស្រីត្រូវការនឹងទ្រព្យ ចូរយកចិញ្ចឹមជីវិតឲ្យស្កប់ស្កល់ចុះ។

ចប់ កាមវិលាបជាតក ទី៧។

## ឧទុម្ពរជាតក ទី៨



(២៩៨. ឧទុម្ពរជាតកំ (៣-៥-៨))

[៤៩៣] (ស្វាធំ ពោលថា) ពូកដើមល្វាផង ដើមជ្រៃផង ដើមខ្ទិតផង ទាំងនេះឯង សុទ្ធតែមានផ្លែទុំ អ្នកចូរមក ហើយចេញទៅបរិភោគ (នូវផ្លែឈើទាំងនោះ) អ្នកស្លាប់ដោយសេចក្តីឃ្លានដូចម្តេចកើត។

[៤៩៤] (ស្វាតូច ពោលថា) បុគ្គលណា គោរពកោតក្រែងចាស់ព្រឹទ្ធាចារ្យ បុគ្គលនោះ បានឈ្មោះថា ឆ្អែតស្កប់ស្កល់ហើយយ៉ាងនេះ ដូចជាក្នុងថ្ងៃនេះ ខ្ញុំបានបរិភោគផ្លែឈើទុំឆ្អែតស្កប់ស្កល់ហើយ។

[៤៩៥] (ស្វាធំ ពោលថា) ស្វាដែលកើតក្នុងព្រៃ គប្បីបញ្ឆោតនូវស្វាដែលកើតក្នុងព្រៃដូចគ្នា ព្រោះហេតុណា ហេតុនោះ ស្វាដែលនៅក្មេង (ដូចជាអ្នក) មិនគប្បីជឿបានទេ ស្វាចាស់គ្រាំគ្រា (ដូចយើង) ក៏មិនគប្បីជឿបានដែរ។

ចប់ ឧទុម្ពរជាតក ទី៨។

## កោមារិយបុត្តជាតក ទី៩



(២៩៩. កោមារបុត្តជាតកំ (៣-៥-៩))

[៤៩៦] (ពួកតាបស ពោលថា) ម្នាលស្វា កាលពីដើម អ្នកឯងលោតលេងជិតអាស្រម ក្នុងសំណាក់នៃយើងអ្នកមានសីល អ្នកចូរធ្វើ (នូវអាការទាំងឡាយ មានញាក់មុខជាដើម) ដែលជាល្បែងរបស់ស្វា យើងមិនត្រេកអរនឹងសីលវតែនោះទេ។

[៤៩៧] (ស្វា ពោលថា) សេចក្តីបរិសុទ្ធិដ៏ក្រៃលែងរបស់តាបសឈ្មោះកោមារិយបុត្ត ជាពហូស្សុត ខ្ញុំបានឮហើយ ឥឡូវនេះ លោកកុំសំគាល់ខ្ញុំដូចមុនឡើយ នែអាវុសោ (ឥឡូវនេះ) ពួកយើងជាអ្នកប្រកបក្នុងឈាន។

[៤៩៨] (តាបស ពោលថា) ប្រសិនបើ បុគ្គលគប្បីព្រោះនូវពូជលើថ្ម ទោះភ្លៀងបង្អុរចុះក៏ដោយ ឯពូជនោះ មិនគប្បីលូតលាស់បានឡើយ សេចក្តីបរិសុទ្ធិដ៏ក្រៃលែង នោះអ្នកបានឮហើយ នែស្វា អ្នកឆ្ងាយអំពីឈានភូមិណាស់។

ចប់ កោមារិយបុត្តជាតក ទី៩។

## ពកជាតក ទី១០



(៣០០. វកជាតកំ (៣-៥-១០ ))

[៤៩៩] (ព្រះសុគត ទ្រង់ត្រាស់ថា) កុកកាលរស់នៅ មានសាច់ និងឈាមជាភោជន ព្រោះសម្លាប់តែសត្វដទៃ (ហើយអួតថា) សមាទាននូវវត្ត រក្សាឧបោសថ។

[៥០០] សក្កទេវរាជ បានដឹងច្បាស់នូវវត្តរបស់កុកនោះ ហើយចូលមកដោយ (ក្លែងខ្លួន) ជារូបពពែ កុកមានតបៈទៅប្រាសហើយ ជាសត្វផឹកនូវឈាម (នៃសត្វដទៃ) បានស្ទុះចូលទៅ (ដើម្បីចឹកពពែស៊ី) ហើយក៏ទំលាយបង់នូវតបៈ ដែលខ្លួនសមាទានហើយ។

[៥០១] បុគ្គលពួកខ្លះក្នុងលោកនេះ ជាអ្នកមានកំឡាំថយ ក្នុងការសមាទាន ឈ្មោះថា ធ្វើខ្លួនឲ្យហើស ដូចជាកុក (ដែលទំលាយនូវតបៈរបស់ខ្លួន) ព្រោះហេតុតែពពែ ក៏យ៉ាងនោះឯង។

ចប់ ពកជាតក ទី១០។

ចប់ កុម្ភវគ្គ ទី៥។

ឧទ្ទាននៃកុម្ភវគ្គនោះគឺ

និយាយអំពីផ្ទាំងដ៏ប្រសើរ ១ ស្តេចក្អែកឈ្មោះសុបត្តៈ ១ រូបកាយដែលសន្មតថាស្អាត ១ ក្អែកមានសំឡេងក្រឡៅ ១ ចចកមានកដូចឧសភៈ ១ សមុទ្រជាម្ចាស់នៃទន្លេ ១ ប្រពន្ធឆ្លាស ១ ស្វាចាស់ ១ ល្បែងរបស់ស្វា ១ កុក ១ ត្រូវជា ១០។

ឧទ្ទាននៃវគ្គគឺ

និយាយអំពីសង្កប្បវគ្គ ១ បទុមវគ្គ ១ ឧទបានវគ្គ ជាគំរប់បី ១ អព្ភន្តរវគ្គ ១ កុម្ភវគ្គ ១ (ទាំងអស់នេះ) រួមបញ្ចូលក្នុងតិកនិបាត។

ចប់ តិកនិបាត។

# ចតុក្កនិបាតជាតក

CS sut.kn.jat.v04 | ភាគទី ៥៨

(៤. ចតុក្កនិបាតោ)

## កាលិង្គវគ្គ ទី១

CS sut.kn.jat.v04.01 | ភាគទី ៥៨

(១. កាលិង្គវគ្គោ)

### ចុល្លកាលិង្គជាតក ទី១

CS sut.kn.jat.301 | ភាគទី ៥៨

(៣០១. ចូឡកាលិង្គជាតកំ (៤-១-១))

[៥០២] (នន្ទសេនាមាត្យ ពោលថា) អ្នកទាំងឡាយ ចូរបើកទ្វារ ថ្វាយព្រះរាជធីតាទាំង ៤ ព្រះអង្គនេះ ដើម្បីស្តេចចូលទៅខាងក្នុងព្រះនគរ ដែលខ្ញុំជាអាមាត្យឈ្មោះនន្ទិសេន ជាបុរសសីហៈរបស់ព្រះបាទអរុណ ដែលអាចារ្យប្រៀនប្រដៅល្អ រក្សាល្អហើយ។

[៥០៣] (ព្រះបាទកាលិង្គៈ ពោលថា) ម្នាលព្រហ្មចារិតាបស អ្នកពោលយ៉ាងនេះថា ជំនះនឹងមានដល់ពួកកាលិង្គៈ ដែលជាអ្នកអត់ធន់ចំពោះទុក្ខភ័យ ដែលគេអត់ធន់មិនបាន បរាជ័យនឹងមានដល់ពួកអស្សកៈដូច្នេះ ជនទាំងឡាយ អ្នកមានសន្តានស្លូតត្រង់ មិនពោលនូវពាក្យមិនពិតឡើយ។

[៥០៤] (តាបសពោធិសត្វ ពោលថា) បពិត្រសក្កទេវរាជ ពួកទេវតាប្រព្រឹត្តកន្លងហើយនូវមុសាវាទ ព្រះអង្គគួរធ្វើនូវពាក្យពិតដ៏ទៀងទាត់យ៉ាងក្រៃលែង បពិត្រមឃវទេវរាជ ជាធំលើផែនដី ម្យ៉ាងទៀត ព្រះអង្គអាស្រ័យហេតុអ្វី ទើបពោលនូវពាក្យមុសាវាទនោះ។

[៥០៥] (ព្រះឥន្ទ្រ ពោលថា) បពិត្រព្រាហ្មណ៍ ក្រែងលោកបានឮពាក្យគេនិយាយថា ពពួកទេវតាមិនច្រណែនចំពោះសេចក្តីព្យាយាមរបស់បុរសទេ ការទូន្មានខ្លួន ១ ការតម្កល់មាំ មិនបែកចិត្ត ១ ការមិនបន្ទរបន្ថយ ការប្រឹងប្រែងក្នុងការគួរ ១ ព្យាយាមដ៏មាំ ១ ការសង្វាតរបស់បុរស ១ (មានដល់ពួកអស្សកៈ) ហេតុនោះ បានជាជ័យជំនះមានហើយ ដល់ពួកអស្សកៈ។

ចប់ ចុល្លកាលិង្គជាតក ទី១។

### មហាអស្សារោហជាតក ទី២

CS sut.kn.jat.302 | ភាគទី ៥៨

(៣០២. មហាអស្សារោហជាតកំ (៤-១-២))

[៥០៦] (ព្រះរាជាពោធិសត្វ ត្រាស់ថា) បុគ្គលណា កាលឲ្យចំពោះជនទាំងឡាយដែលមិនដែលឲ្យ (ដល់ខ្លួន) មិនឲ្យចំពោះជនទាំងឡាយដែលធ្លាប់ឲ្យ បុគ្គលនោះ បានដល់នូវសេចក្តីវិនាស មិនបាននូវមិត្រសំឡាញ់ ក្នុងគ្រាមានសេចក្តីអន្តរាយទាំងឡាយ។

[៥០៧] បុគ្គលណា មិនឲ្យទានចំពោះជនទាំងឡាយ ដែលមិនដែលឲ្យ បានឲ្យចំពោះជនទាំងឡាយដែលឲ្យ បុគ្គលនោះ ក៏ដល់នូវសេចក្តីវិនាស មិនបាននូវសំឡាញ់ ក្នុងកាលមានសេចក្តីអន្តរាយទាំងឡាយ។

[៥០៨] ការសំដែងនូវសេចក្តីស្និទ្ធស្នាល និងការបរិភោគរួម ឲ្យវិសេសក្នុងពួកជនអ្នកមានធម៌មិនប្រសើរ ជាអ្នកអួតអាង ក៏រមែងវិនាស ម្យ៉ាងទៀត សូម្បីទានបន្តិចបន្តួច ដែលបុគ្គលធ្វើហើយ ចំពោះពួកព្រះអរិយៈផង ចំពោះពួកបុគ្គលអ្នកមានចិត្តស្លូតត្រង់ផង ជាទានមានផលច្រើន។

[៥០៩] បុគ្គលណា បានធ្វើឧបការៈដ៏ល្អទុកហើយ ក្នុងកាលមុន បុគ្គលនេះ ឈ្មោះថា បានធ្វើអំពើដែលគេធ្វើបានដោយក្រក្រៃពេកក្នុងលោក លុះដល់កាលជាខាងក្រោយ បុគ្គលនោះ ធ្វើ (គុណនីមួយដទៃទៀតក្តី) មិនធ្វើក្តី ក៏ឈ្មោះថាជាបុគ្គលគួរដល់កិរិយាបូជាដោយពិត។

ចប់ មហាអស្សារោហជាតក ទី២។

### ឯករាជជាតក ទី៣

CS sut.kn.jat.303 | ភាគទី ៥៨

(៣០៣. ឯករាជជាតកំ (៤-១-៣))

[៥១០] (ព្រះបាទទុព្ភិសេន ទ្រង់ត្រាស់ថា) បពិត្រព្រះអង្គ ជាឯករាជ កាលពីដើម ព្រះអង្គនៅសោយកាមគុណទាំងឡាយ ជារបស់ស្អុកស្កម្ភ រកអ្វីប្រសើរជាងគ្មាន ឥឡូវនេះ ព្រះអង្គនោះ គេបោះទៅក្នុងរណ្តៅក្រហេងក្រហូងហើយ នៅតែមិនលះបង់នូវពណ៌សម្បុរ

និងកម្លាំងពីដើម។

[៥១១] (ព្រះបាទពារាណសី ពោលថា) បពិត្រព្រះបាទទុព្ភិសេន សេចក្តីអត់ធន់ក្តី សេចក្តីប្រព្រឹត្តិតបៈក្តី ខ្ញុំមានបំណងទុកហើយពីមុន បពិត្រមហារាជ ឥឡូវនេះ ខ្ញុំបានសម្រេចនូវសេចក្តីប្រាថ្នានោះហើយ តើគប្បីលះបង់នូវពណ៌សម្បុរ និងកំឡាំងពីដើមដូចម្តេចកើត។

[៥១២] (ទាន សីល ឧបោសថកម្ម) ទាំងអស់របស់ខ្ញុំ សម្រេចហើយ បពិត្រព្រះអង្គមានយស មានប្រាជ្ញារកនរណាគ្របសង្កត់មិនកើត ខ្ញុំបានយសដ៏ធំ ជាយសដែលខ្ញុំមិនធ្លាប់បានក្នុងកាលពីដើមហើយ ទើបខ្ញុំមិនលះបង់ពណ៌សម្បុរ និងកម្លាំងពីដើម។

[៥១៣] បពិត្រព្រះជនិន្ទ្រ ពួកសប្បុរស បន្ទោបង់នូវរជ្ជសុខដោយទុក្ខ បន្ទោបង់នូវសេចក្តីទុក្ខ ដែលបុគ្គលគ្របសង្កត់មិនបាននោះ ដោយសារឈានសុខ ជាអ្នកមានចិត្តត្រជាក់ ស្មើក្នុងសេចក្តីសុខ និងទុក្ខទាំង ២ យ៉ាង។

ចប់ ឯករាជជាតក ទី៣។

## ទទ្ទរជាតក ទី៤

CS sut.kn.jat.304 | ភាគទី ៥៨

### (៣០៤. ទទ្ទរជាតកំ (៤-១-៤))

[៥១៤] (នាគឈ្មោះចុល្លទទ្ទរៈ ពោលថា) បពិត្រមហាទទ្ទរៈ ពាក្យអាក្រក់ទាំងឡាយនេះ ក្នុងមនុស្សលោក ធ្វើខ្ញុំឲ្យក្តៅក្រហាយ ឯពួកក្មេងទាំងឡាយនេះ មិនមានពិសសោះ ប៉ុន្តែហ៊ានជេរខ្ញុំដែលមានពិស ថាជាអ្នកស៊ីកង្កែបផង នៅក្នុងទឹកផង។

[៥១៥] (នាគឈ្មោះមហាទទ្ទរៈ និយាយតបទៅវិញថា) បុគ្គលដែលគេបំបរបង់ចេញចាកដែនរបស់ខ្លួនហើយ ទៅកាន់ជនបទឯទៀត ត្រូវធ្វើជង្រុកឲ្យធំ ដើម្បីដាក់នូវពាក្យអាក្រក់ទាំងឡាយចុះ។

[៥១៦] ពួកជនមិនដឹងនូវបុរសដោយជាតិ ឬដោយវិន័យ គឺគុណសម្បត្តិក្នុងទីណា បុគ្គលកាលនៅក្នុងសំណាក់នៃពួកជនដែលខ្លួនមិនស្គាល់ មិនត្រូវធ្វើសេចក្តីប្រកាន់ក្នុងទីនោះឡើយ។

[៥១៧] បុគ្គលប្រកបដោយប្រាជ្ញា (សូម្បីមានអានុភាព) ស្មើដោយភ្លើង កាលនៅក្នុងប្រទេសដទៃ ត្រូវតែអត់សង្កត់ពាក្យ ទោះបីមនុស្សជាខ្ញុំគេ គម្រាមក៏ដោយ។

ចប់ ទទ្ទរជាតក ទី៤។

## សីលវីមំសជាតក ទី៥

CS sut.kn.jat.305 | ភាគទី ៥៨

### (៣០៥. សីលវីមំសនជាតកំ (៤-១-៥))

[៥១៨] (មាណពពោធិសត្វ ពោលថា) ធម្មតាសេចក្តីស្ងាត់កំបាំង របស់បុគ្គលអ្នកធ្វើអំពើអាក្រក់ មិនមានក្នុងលោកទេ ពួកភូតដែលនៅក្នុងព្រៃ គង់គេឃើញបាន បុគ្គលពាល រមែងសំគាល់នូវអំពើអាក្រក់ដែលធ្វើនោះថា ស្ងាត់កំបាំង។

[៥១៩] ខ្ញុំមិនឃើញថា ស្ងាត់កំបាំងទេ ឬទីដែលសូន្យ (ចាកសត្វ) ក៏មិនមាន ខ្ញុំមិនឃើញថា សូន្យ ក្នុងទីណា ទីនោះក៏មិនសូន្យអំពីខ្ញុំទេ។

[៥២០] (ព្រះសាស្តា ត្រាស់ថា) ពួកមាណព គឺ ទុជ្ជច្ចៈ ១ សុជច្ចៈ ១ នន្ទៈ ១ សុខវច្ឆនៈ ១ វជ្ឈៈ ១ អធុវសីលៈ ១ (ជាដើម) នោះ ជាអ្នកត្រូវការ (ដោយស្ត្រី) ក៏សាបសូន្យចាកសភាវៈ (ការបាននូវស្ត្រី)។

[៥២១] ចំណែកព្រាហ្មណ៍ណា ដែលមានប្រាជ្ញា មានព្យាយាមក្នុងសច្ចៈ បានរក្សានូវធម៌ទុក ព្រាហ្មណ៍នោះ ជាអ្នកដល់នូវត្រើយនៃធម៌ទាំងពួង តើគប្បីសាបសូន្យ (ចាកការបាននូវស្ត្រី) ដូចម្តេចកើត។

ចប់ សីលវីមំសជាតក ទី៥។

## សុជាតាជាតក ទី៦

CS sut.kn.jat.306 | ភាគទី ៥៨

### (៣០៦. សុជាតជាតកំ (៤-១-៦ ))

[៥២២] (នាងសុជាតាទេវី សួរថា) បពិត្រព្រះទេវៈ នេះផ្លែអ្វី មូលរលីង មានពណ៌ក្រហម ដូចជាឈាម ដែលដាក់ក្នុងភាជន៍មាស ខ្ញុំម្ចាស់សួរហើយ សូមព្រះអង្គប្រាប់ឲ្យទាន។

[៥២៣] (ព្រះបាទពារាណសី ទ្រង់ត្រាស់ថា) ម្នាលទេវី ក្នុងកាលមុន នាងមានក្បាលរលីង ស្លៀកកំណាត់សំពត់ចាស់ មានដៃក្នុងថ្នក់ ហើយបេះនូវផ្លែឈើទាំងឡាយណា (នេះ) គឺផ្លែពុទ្រា របស់នាងនោះហើយ។

[៥២៤] ស្ត្រីថោកទាប រមែងក្តៅក្រហាយ មិនត្រេកអរ (ក្នុងរាជត្រកូល) ភោគៈរបស់ស្តេចទាំងឡាយ រមែងលះបង់នូវស្ត្រីឥតបុណ្យនោះ ស្ត្រីថោកទាប បេះនូវផ្លែពុទ្រាក្នុងទីណា អ្នកទាំងឡាយ ចូរនាំស្ត្រីនោះទៅ ក្នុងទីនោះចុះ។

[៥២៥] (អាមាត្យពោធិសត្វ ទូលថា) បពិត្រមហារាជ ទោសខុស ព្រោះសេចក្តីប្រមាទទាំងនេះ រមែងមកដល់នាងនារី ដែលដល់នូវយសសក្តិ បពិត្រព្រះទេវៈ សូមព្រះអង្គអត់ទោសដល់ព្រះនាងសុជាតាទេវី បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គកុំទ្រង់ព្រះពិរោធចំពោះព្រះនាងសុជាតាទេវីនេះឡើយ។

ចប់ សុជាតាជាតក ទី៦។

## បលាសជាតក ទី៧

CS sut.kn.jat.307 | ភាគទី ៥៨

(៣០៧. បលាសជាតកំ (៤-១-៧))

[៥២៦] (រុក្ខទេវតាពោធិសត្វ ពោលថា ) ម្នាលព្រាហ្មណ៍ អ្នកដឹងថាដើមចារនេះ ជាឈើឥតចេតនា ឥតចេះស្តាប់ ឥតដឹងអ្វីទេ ជាអ្នកប្រារព្ធព្យាយាម មិនប្រហែសធ្វេសជានិច្ច ហេតុអ្វី ក៏សួរពេកការដេកជាសុខ (របស់ដើមឈើ)។

[៥២៧] (ព្រាហ្មណ៍ ពោលថា) ដើមឈើ ប្រាកដក្នុងទីដ៏ឆ្ងាយផង ធំផង ដុះនៅក្នុងទី (ទួល) មានសភាពជាទីនៅរបស់ភូត ហេតុនោះ បានជាខ្ញុំថ្វាយបង្គំដើមចារនេះ ពួកភូតណា នៅអាស្រ័យលើដើមឈើនេះ (ខ្ញុំថ្វាយបង្គំ) ពួកភូតនោះ ព្រោះហេតុតែទ្រព្យ។

[៥២៨] (រុក្ខទេវតា ពោលថា) ម្នាលព្រាហ្មណ៍ ខ្ញុំនោះឯង កាលសម្លឹងឃើញនូវការដឹងគុណ ដែលអ្នកធ្វើហើយ ខ្ញុំនឹងធ្វើនូវការតបគុណដល់អ្នក តាមសមគួរដល់អានុភាព ការដែលអ្នកមកខ្វល់ខ្វាយ ក្នុងសំណាក់សប្បុរស និងជារបស់សោះសូន្យដូចម្តេចកើត។

[៥២៩] ដើមល្វៀបណា ដុះនៅខាងមុខដើមទន្លាប់ យញ្ញដែលគេធ្វើហើយក្នុងកាលមុនច្រើន ជាកំណប់ដែលគេកប់ព័ទ្ធជុំវិញក្បែរគល់ល្វៀបនោះឯង ជាកំណប់មិនមានអ្នកទទួល អ្នកចូរទៅគាស់យកកំណប់ទ្រព្យនោះចុះ។

ចប់ បលាសជាតក ទី៧។

## ជវសកុណជាតក ទី៨

CS sut.kn.jat.308 | ភាគទី ៥៨

(៣០៨. សកុណជាតកំ (៤-១-៨))

[៥៣០] (សត្វសសេះ ពោលថា) កម្លាំងណារបស់យើង មានហើយ យើងធ្វើកិច្ចដល់អ្នកតាមកម្លាំងនោះ បពិត្រមិគរាជ ខ្ញុំសូមក្រាបថ្វាយបង្គំអ្នក យើងត្រូវបានសាច់បន្តិចបន្តួចខ្លះ។

[៥៣១] (រាជសីហ៍ ឆ្លើយតបថា) អ្នកឯងចូរទៅតាមចន្លោះនៃធ្មេញរបស់ខ្ញុំ ដែលជាអ្នកស៊ី (សាច់) និងឈាម ធ្វើនូវអំពើអាក្រក់ទាំងឡាយជានិច្ច រស់នៅដោយសាច់ណា សាច់នោះមានច្រើន។

[៥៣២] (សសេះឆ្លើយតបថា) សេចក្តីដឹងគុណដែលគេធ្វើហើយ មិនមានក្នុងបុគ្គលណា ការសេពគប់នឹងបុគ្គលអ្នកមិនដឹងគុណដែលគេធ្វើហើយ មិនធ្វើ (គុណនឹងអ្នកណា) មិនតបស្នងសងគុណ ដល់អ្នកដែលធ្វើគុណហើយដល់ខ្លួននោះ ជាការឥតប្រយោជន៍។

[៥៣៣] បណ្ឌិត មិនបានមិត្តធម៌ ដោយសារគុណដែលខ្លួនសន្សំហើយ ក្នុងទីចំពោះមុខបុគ្គលណា បណ្ឌិតមិនត្រូវឫស្សា មិនត្រូវជេរ ត្រូវតែគេចចេញចាកបុគ្គលនោះ ដោយសន្សឹម ៗ។

ចប់ ជវសកុណជាតក ទី៨។

## ឆវជាតក ទី៩

CS sut.kn.jat.309 | ភាគទី ៥៨

(៣០៩. ឆវកជាតកំ (៤-១-៩))

[៥៣៤] (ពោធិសត្វ ក្រាបទូលព្រះបាទពារាណសីថា) កិច្ចដែលយើងទាំងបីនាក់ ធ្វើហើយ ទាំងអស់នេះ ជាកិច្ចលាមក បុគ្គលណា (អង្គុយក្នុងទីទាប) បង្ហាញមន្ត ១ បុគ្គលណា (អង្គុយក្នុងទីខ្ពស់) រៀននូវមន្ត ១ បុគ្គលទាំងពីរនាក់ (នោះ) មិនឃើញនូវបោរាណធម៌ផង បុគ្គលទាំងពីរនាក់ (នោះ) ឃ្លាតចាកប្រក្រតីផង។

[៥៣៥] (ព្រាហ្មណ៍បុរោហិត ឆ្លើយតបថា) ខ្ញុំបរិភោគបាយស្រូវសាលីស្អាត (របស់ស្តេចនេះ) លាយដោយសាច់ ហេតុនោះ បានជាខ្ញុំមិនសេពគប់នូវធម៌ ដែលពួកឥសីសេពគប់ហើយនោះទេ។

[៥៣៦] (ពោធិសត្វ ពោលថា ) អ្នកចូរជៀសចេញពីទីនេះទៅ លោកនេះក៏ធំទូលាយ ពួកសត្វឯទៀត តែងស្លដណ្តាំដែរ អ្នកកុំប្រព្រឹត្តអធម៌ ដូចជាថ្មដែលបំបែកនូវឆ្នាំងឡើយ។

[៥៣៧] ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលនូវការបានយស និងការបានទ្រព្យ ព្រោះការប្រព្រឹត្តិបំផ្លាញខ្លួន ឬដោយកិរិយាប្រព្រឹត្តិអធម៌។

ចប់ ឆវជាតក ទី៩។

## សយ្ហជាតក ទី១០

CS sut.kn.jat.310 | ភាគទី ៥៨

(៣១០. សេយ្យជាតកំ (៤-១-១០))

[៥៣៨] (តាបសពោធិសត្វ ពោលថា) បុគ្គលមិនគប្បីប្រាថ្នានូវផែនដី ដែលមានសណ្ឋានដូចកុណ្ឌល ក្នុងកណ្តាលសាគរ មានសមុទ្រព័ទ្ធជុំវិញ មួយអន្លើដោយពាក្យនិន្ទាឡើយ ម្នាលសយ្ហាមាត្យ ចូរអ្នកដឹងយ៉ាងនេះចុះ។

[៥៣៩] ម្នាលព្រាហ្មណ៍ យើងសូមតិះដៀលការបានយស និងការបានទ្រព្យ ព្រោះការប្រព្រឹត្តិបំផ្លាញខ្លួន ឬដោយការប្រព្រឹត្តិអធម៌។

[៥៤០] សូវអាត្មា ជាអ្នកមិនមានផ្ទះសម្បែងប្រព្រឹត្តិកាន់បាត្រ (សូមគេ) ការចិញ្ចឹមជីវិតនោះឯង ប្រសើរជាជាងការស្វែងរក មិនប្រកបដោយធម៌។

[៥៤១] សូវអាត្មាជាអ្នកមិនមានផ្ទះសំបែង ប្រព្រឹត្តកាន់បាត្រ មិនបៀតបៀននូវសត្វដទៃក្នុងលោក ការប្រព្រឹត្តិនោះ ប្រសើរជាជាងរាជសម្បត្តិទៅទៀត។

ចប់ សយ្ហជាតក ទី១០។

ចប់ កាលិង្គវគ្គ ទី១។

ឧទ្ទាននៃកាលិង្គវគ្គនោះគឺ

និយាយអំពីការបើកទ្វារ ១ ជនមិនឲ្យ ១ កាមគុណដ៏មាំមួន ១ នាគឈ្មោះទទ្ទរៈ ១ អំពើបាបមិនមានស្ទាត់កំបាំង ១ ផ្លែពុទ្រា ១ ដើមចារ ១ ការធ្វើអំពើដ៏ប្រសើរ ១ អំពើលាមក ១ ផែនដីមានសមុទ្រព័ទ្ធជុំវិញ ១ ត្រូវជា ១០។

## បុចិមន្ទវគ្គ ទី២

CS sut.kn.jat.v04.02 | ភាគទី ៥៨

(២. បុចិមន្ទវគ្គោ)

### បុចិមន្ទជាតក ទី១

CS sut.kn.jat.311 | ភាគទី ៥៨

(៣១១. បុចិមន្ទជាតកំ (៤-២-១))

[៥៤២] (និម្ពរុក្ខទេវតា ពោលថា) ម្នាលចោរ អ្នកចូរក្រោកឡើង អ្នកដេកធ្វើអ្វី ប្រយោជន៍អ្វីដោយការដេកលក់របស់អ្នក កុំឲ្យរាជបុរសទាំងឡាយ ចាប់អ្នកដែលធ្វើកម្មអាក្រក់ក្នុងស្រុកឡើយ។

[៥៤៣] (អស្សត្ថទេវតា និយាយថា) រាជបុរសទាំងឡាយនឹងចាប់តែចោរដែលធ្វើកម្មអាក្រក់ក្នុងស្រុកទេតើ ប្រយោជន៍អ្វីដល់បុចិមន្ទទេវតា ដែលបិតនៅក្នុងព្រៃនោះ។

[៥៤៤] (បុចិមន្ទទេវតា ពោលថា) ម្នាលអស្សត្ថទេវតា អ្នកមិនដឹងនូវទោសនៃខ្ញុំផង នៃចោរផង ពួករាជបុរសចាប់បានចោរ អ្នកធ្វើអំពើអាក្រក់ក្នុងស្រុក ហើយដោតចោរនោះដោយមែកស្តៅស្រួច ខ្ញុំរង្កៀសចិត្តក្នុងហេតុនោះ។

[៥៤៥] (អស្សត្ថទេវតា ពោលថា) អ្នកប្រាជ្ញគប្បីរក្សានូវហេតុដែលគួររង្កៀស គប្បីរក្សានូវភ័យដែលមិនទាន់មកដល់ អ្នកប្រាជ្ញតែងសំឡឹងមើលនូវលោកទាំងពីរ ព្រោះអនាគតភ័យ។

ចប់ បុចិមន្ទជាតក ទី១។

### កស្សបមន្ទិយជាតក ទី២

CS sut.kn.jat.312 | ភាគទី ៥៨

(៣១២. កស្សបមន្ទិយជាតកំ (៤-២-២))

[៥៤៦] (តាបសពោធិសត្វ ពោលថា) បពិត្រកស្សបជាបិតា បើក្មេងតូចដេរ ឬវាយ ព្រោះវាជាក្មេង បណ្ឌិតអ្នកមានប្រាជ្ញា តែងអត់សង្កត់នូវកំហុសទាំងអស់នោះ។

[៥៤៧] ប្រសិនបើសប្បុរសទាំងឡាយ ទាស់ទែងគ្នា សប្បុរសរមែងតបានវិញយ៉ាងឆាប់ ឯក្មេងពាលទាំងឡាយ រមែងបែកគ្នាដូចបាត្រដីក្មេងពាលទាំងនោះ មិនដល់នូវការស្ងប់រម្ងាប់ឡើយ។

[៥៤៨] ជនណាដឹងនូវទោស ដែលខ្លួនធ្វើឲ្យកន្លងហួសទៅហើយផង ជនណាដឹងនូវការសំដែងនូវទោសផង ជនទាំងពីរពួកនោះ (បើទុកជាបែកគ្នាហើយ) ច្រើនរួបរួមគ្នាវិញបាន ការតមិត្តរបស់ជនទាំងពីរពួកនោះ មិនរលុបរលាយឡើយ។

[៥៤៩] ជនណា គួរតនូវមិត្តភាពរបស់ពួកជនដទៃដែលទោសគ្របសង្កត់ហើយ ដោយខ្លួនឯងបាន ជននោះជាមនុស្សខ្ពង់ខ្ពស់លើសលុប ជាមនុស្សនាំទៅនូវភារៈបាន ជាមនុស្សទ្រទ្រង់នូវធុរៈបាន។

ចប់ កស្សបមន្ទិយជាតក ទី២។

### ខន្តិវាទិជាតក ទី៣

CS sut.kn.jat.313 | ភាគទី ៥៨

(៣១៣. ខន្តីវាទីជាតកំ (៤-២-៣))

[៥៥០] (សេនាបតី ពោលថា) បពិត្រលោកមានព្យាយាមធំ ព្រះរាជាណាកាត់ព្រះហស្តទាំងពីរក្តី កាត់ព្រះបាទទាំងពីរក្តី កាត់ត្រចៀកនិងច្រមុះក្តី របស់លោក សូមលោកខ្ញាល់ចំពោះបុគ្គលនោះចុះ សូមលោកកុំញុាំងដែននេះឲ្យវិនាសឡើយ។

[៥៥១] (តាបសពោធិសត្វ ពោលថា) ព្រះរាជាណា កាត់ដៃទាំងពីរក្តី កាត់ជើងទាំងពីរក្តី កាត់ត្រចៀក និងច្រមុះក្តី របស់អាត្មា សូមឲ្យ

ព្រះរាជានោះ ទ្រង់មានព្រះជន្មយឺនយូរ ពួកអ្នកប្រាជ្ញដូចយ៉ាងអាត្មា មិនខឹងឡើយ។

[៥៥២] (ព្រះសាស្តា ទ្រង់ត្រាស់ថា) សមណៈ ជាអ្នកសំដែងនូវខន្តី មានហើយក្នុងអតីតកាល ព្រះបាទកាសី ទ្រង់ត្រាស់ឲ្យចោរឃាតកបុរសសម្លាប់សមណៈនោះ អ្នកតាំងនៅក្នុងខន្តី។

[៥៥៣] ព្រះបាទកាសី តាំងនៅក្នុងនរក សោយនូវផលនៃកម្មណា ផលនៃកម្មអាក្រក់នោះ ជាផលក្តៅក្រហាយ។

ចប់ ខន្តិវាទិជាតក ទី៣។

## លោហកុម្ភិជាតក ទី៤

CS sut.kn.jat.314 | ភាគទី ៥៨

### (៣១៤. លោហកុម្ភិជាតកំ (៤-២-៤))

[៥៥៤] (សត្វនរកម្នាក់ ពោលថា) ពួកយើងដែលមិនបានឲ្យទាន បានជាពួកយើងរស់នៅដោយត្រដាបត្រដួស កាលភោគៈទាំងឡាយមាន ពួកយើងមិនបានធ្វើនូវទីពឹងបម្រុងខ្លួនសោះ។

[៥៥៥] (សត្វនរកម្នាក់ទៀត ពោលថា) ពួកយើងដែលឆេះក្នុងនរក គ្រប់ជា ៦០ ០០០ ឆ្នាំ ដោយអាការៈទាំងពួងហើយ កាលណានឹងមានទីបំផុត (នៃទុក្ខ)។

[៥៥៦] (សត្វនរកម្នាក់ទៀត ពោលថា) ម្នាលអ្នកស្មើនឹងខ្ញុំ ទីបំផុត (នៃទុក្ខយើង) មិនមានទេ ទីបំផុតនឹងមានមកពីណា ទីបំផុតនឹងមិនប្រាកដទេ ព្រោះថា ខ្ញុំ និងអ្នក បានធ្វើបាបក្នុងកាលនោះ។

[៥៥៧] (សត្វនរកម្នាក់ទៀត ពោលថា) ខ្ញុំនោះ លុះទៅអំពីទីនេះ បានកំណើតជាមនុស្ស ចាប់អំពីដឹងក្តីទៅ សូមជាអ្នកបរិបូណ៌ដោយសីល ធ្វើកុសលឲ្យច្រើន។

ចប់ លោហកុម្ភិជាតក ទី៤។

## មំសជាតក ទី៥

CS sut.kn.jat.315 | ភាគទី ៥៨

### (៣១៥. សព្វមំសលាភជាតកំ (៤-២-៥))

[៥៥៨] (ព្រានព្រៃនិយាយនឹងសេដ្ឋីបុត្រ ទី១ ថា) វាចារបស់អ្នកអាក្រក់ណាស់ អ្នកជាអ្នកសុំសាច់ តែវាចាប្រហែលនឹងវាវ នៃសំឡាញ់ យើងនឹងឲ្យវាវដល់អ្នក។

[៥៥៩] (ព្រានព្រៃ និយាយនឹងសេដ្ឋីបុត្រ ទី២ ថា) ជនជាបងប្អូន គេទុកជាអវយវៈរបស់មនុស្សទាំងឡាយក្នុងលោក វាចារបស់អ្នកប្រហែលនឹងអវយវៈ នៃសំឡាញ់ យើងនឹងឲ្យសាច់អវយវៈដល់អ្នក។

[៥៦០] (ព្រានព្រៃ និយាយនឹងសេដ្ឋីបុត្រ ទី៣ ថា) កូនកាលហៅបិតាថា ឪពុក ឪពុក ដូច្នេះ រមែងធ្វើបេះដូងបិតាឲ្យកម្រើក វាចារបស់អ្នក ប្រហែលនឹងបេះដូង នៃសំឡាញ់ យើងនឹងឲ្យបេះដូងដល់អ្នក។

[៥៦១] (ព្រានព្រៃ និយាយនឹងសេដ្ឋីបុត្រ ទី៤ ថា) សំឡាញ់របស់បុរសណា មិនមានក្នុងស្រុក លំនៅរបស់បុរសនោះ ក្នុងស្រុកនោះឯងដូចព្រៃ វាចារបស់អ្នកប្រហែលនឹងសម្បត្តិទាំងពួង នៃសំឡាញ់ យើនឹងឲ្យសាច់ទាំងអស់ដល់អ្នក។

ចប់ មំសជាតក ទី៥។

## សសបណ្ឌិតជាតក ទី៦

CS sut.kn.jat.316 | ភាគទី ៥៨

### (៣១៦. សសបណ្ឌិតជាតកំ (៤-២-៦))

[៥៦២] (ភេ និយាយនឹងឥន្ទព្រាហ្មណ៍ថា) ខ្ញុំមានត្រីឆ្អិន ៧ ដែលព្រានសន្ទូចស្រង់ឡើងពីទឹកដាក់លើគោក ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ (ចំរើនសមណធម៌) នៅក្នុងព្រៃចុះ។

[៥៦៣] (ចចក និយាយនឹងឥន្ទព្រាហ្មណ៍ថា) ភត្តរបស់អ្នករក្សាស្រែឯណោះ គឺសាច់ពីរជ្រនួចផង ទន្សោងមួយផង ដបទធិមួយផង ខ្ញុំបាននាំមកក្នុងវេលាយប់ ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ (ចំរើនសមណធម៌) នៅក្នុងព្រៃចុះ។

[៥៦៤] (ស្វា និយាយនឹងឥន្ទព្រាហ្មណ៍ថា) ផ្លែស្វាយទុំ ទឹកត្រជាក់ ទីមានម្លប់ត្រជាក់ ជាទីគាប់ចិត្ត ម្នាលព្រាហ្មណ៍ នេះរបស់ខ្ញុំ អ្នកចូរបរិភោគរបស់នេះ ហើយ (ចំរើនសមណធម៌) នៅក្នុងព្រៃចុះ។

[៥៦៥] (ទន្សាយ និយាយនឹងឥន្ទព្រាហ្មណ៍ថា) ទន្សាយ មិនមានល្ង មិនមានសណ្តែក មិនមានអង្ករទេ អ្នកចូរបរិភោគនូវខ្ញុំ ដែលឆ្អិនដោយភ្លើងនេះ ហើយ (ចំរើនសមណធម៌) នៅក្នុងព្រៃចុះ។

ចប់ សសបណ្ឌិតជាតក ទី៦។

## មតរោទនជាតក ទី៧

CS sut.kn.jat.317 | ភាគទី ៥៨

(៣១៧. មតរោទនជាតកំ (៩-២-៧))

[៥៦៦] (សេដ្ឋីពោធិសត្វ ពោលថា) អ្នកទាំងឡាយ យំរកបុគ្គលស្លាប់ទៅហើយ ៗ តែម្យ៉ាង បុគ្គលណា បម្រុងស្លាប់ អ្នកទាំងឡាយ មិនយំរកបុគ្គលនោះសោះ ពួកសត្វទាំងអស់ ជាអ្នកទ្រទ្រង់នូវសរីរៈ តែងលះបង់នូវជីវិតតាមលំដាប់។

[៥៦៧] ពួកទេវតា មនុស្ស សត្វជើង ៤ ពួកសត្វស្លាប និងពួកពស់ ប្រកបដោយភ្នែន មិនជាធំក្នុងសរីរៈឡើយ តែងលះបង់ជីវិត ទាំងកំពុងត្រេកអរ (ក្នុងឋានៈដែលខ្លួនកើតហើយ)។

[៥៦៨] សុខ និងទុក្ខជាធម្មជាតកម្រើក មិនតាំងនៅយ៉ាងនេះ បុគ្គលគួររមិលមើលក្នុងពួកមនុស្ស ការកន្ទក់កន្ទេញ ការយំសោក ជារបស់មិនមានប្រយោជន៍ទេ ព្រោះហេតុអ្វី ក៏គំនរនៃសេចក្ដីសោក គ្របសង្កត់អ្នកទាំងឡាយ។

[៥៦៩] ពួកជនណា ជាអ្នកលេង ជាអ្នកស្រវឹង មិនធ្វើ (សេចក្ដីចំរើន) ជាមនុស្សពាល ភ្លៀវភ្លា មិនមានសេចក្ដីព្យាយាម មិនឈ្លាស ក្នុងធម៌ ពួកជននោះ តែងសំគាល់នូវអ្នកប្រាជ្ញ (ដែលមិនយំសោកជាដើម) ថាជាមនុស្សពាលទៅវិញ។

ចប់ មតរោទនជាតក ទី៧។

## កណវេរជាតក ទី៨

CS sut.kn.jat.318 | ភាគទី ៥៨

(៣១៨. កណវេរជាតកំ (៩-២-៨))

[៥៧០] (ពួករបាំ ច្រៀងថា) អ្នកឱបរឹតនាងសាមាណា ដោយដើមដៃ ក្បែរគុម្ពច្បារទាំងឡាយ មានផ្កាក្រហម ដូចពន្លឺព្រះអាទិត្យ ក្នុង វសន្តសម័យ (ហើយរត់ទៅ ឥឡូវនេះ) នាងសាមានោះ ប្រាប់មកអ្នក (ថានាង) មិនមានរោគទេ។

[៥៧១] (ពោធិសត្វ ពោលថា) នែនាងដ៏ចំរើន បានឮថា ខ្យល់បក់ផាត់ភ្នំ ដោយហេតុណា ខ្ញុំមិនគប្បីជឿនូវហេតុនោះទេ បើខ្យល់ បក់ផាត់ភ្នំបាន បក់ផាត់ផែនដីទាំងមូល ក៏បានដែរ នាងសាមាណា ស្លាប់បាត់ទៅហើយ អ្នកពោលថា នាងសាមានោះ មិនមានរោគ (ខ្ញុំមិន គប្បីជឿទេ)។

[៥៧២] (ពួករបាំ ច្រៀងថា) នាងសាមានោះ មិនស្លាប់ផង នាងមិនចង់បានបុរសដទៃផង ឮថា នាងសាមា មានប្ដីតែមួយ នាងចង់ បានតែប្ដីនោះឯង។

[៥៧៣] (ព្រះពោធិសត្វ ពោលថា) នាងសាមា ប្ដូរយកខ្ញុំ ដែលមិនធ្លាប់ស្និទ្ធស្នាល ដោយប្ដីដែលស្និទ្ធស្នាល អស់កាលយូរ ប្ដូរយកខ្ញុំជាប្ដី មិនពិតប្រាកដ ដោយប្ដីពិតប្រាកដ នាងសាមា មុខតែប្ដូរយកបុរសដទៃ ដោយខ្ញុំ ខ្ញុំនឹងទៅកាន់ទីឆ្ងាយ លើសពីនេះទៅទៀត។

ចប់ កណវេរជាតក ទី៨។

## តិត្តិរជាតក ទី៩

CS sut.kn.jat.319 | ភាគទី ៥៨

(៣១៩. តិត្តិរជាតកំ (៩-២-៩))

[៥៧៤] (សត្វទទា សួរតាបសពោធិសត្វថា) ខ្ញុំរស់នៅជាសុខសប្បាយណាស់ ទាំងបានបរិភោគ (ដោយស្រួល) តែខ្ញុំឋិតនៅក្នុងសេចក្ដី អន្តរាយ បពិត្រលោកដ៏ចំរើន តើគតិរបស់ខ្ញុំដូចម្ដេច។

[៥៧៥] (ព្រះពោធិសត្វ ពោលថា) ម្នាលចៅបក្សី បើចិត្តរបស់អ្នកមិនបង្អោនទៅរកអំពើបាបទេ បាបក៏មិនប្រឡាក់នូវអ្នកដ៏ចំរើនដែលជា អ្នកមិនខ្វល់ខ្វាយឡើយ។

[៥៧៦] (ទទា ពោលថា) សត្វទទាជាច្រើនមក ព្រោះគិតថា ញាតិយើងទំនៅ (ត្រង់ទីនោះ) ព្រានប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះ អាស្រ័យខ្ញុំ ចិត្តរបស់ខ្ញុំ ក៏រង្កៀសក្នុងរឿងនោះ។

[៥៧៧] (ពោធិសត្វ ពោលថា) ព្រានមិនប៉ះពាល់នូវបាណាតិបាតកម្ម ព្រោះអាស្រ័យអ្នកទេ បើចិត្តអ្នកមិនប្រទូស្ត បាបមិនប្រឡាក់ នូវអ្នកដ៏ចំរើន ដែលមិនមានសេចក្ដីខ្វល់ខ្វាយឡើយ។

ចប់ តិត្តិរជាតក ទី៩។

## សុចជជាតក ទី១០

CS sut.kn.jat.320 | ភាគទី ៥៨

(៣២០. សុច្ចជជាតកំ (៩-២-១០))

[៥៧៨] (នាងទេវី ពោលថា) ព្រះរាជាកាលមិនប្រទានភ្នំ (សូម្បី) ដោយព្រះវាចា ឈ្មោះថាមិនលះបង់នូវរបស់ដែលគួរលះបង់ដោយ ងាយទេ ប្រសិនបើព្រះរាជាបានប្រទានភ្នំ (សូម្បី) ដោយព្រះវាចា ព្រះរាជានោះ (ដែលខ្ញុំសូមហើយ) គង់លះបង់វត្ថុខ្លះ។

[៥៧៩] (ព្រះរាជា ត្រាស់ថា) បុគ្គលធ្វើអំពើណា គប្បីនិយាយអំពើនោះ មិនធ្វើអំពើណា មិនគប្បីនិយាយអំពើនោះ ពួកបណ្ឌិតរមែង កំណត់ដឹងនូវបុគ្គល ដែលមិនធ្វើ (គ្រាន់តែ) និយាយ។

[៥៨០] (ព្រះនាងទេវី ពោលថា) បពិត្រព្រះរាជបុត្រ ខ្ញុំសូមថ្វាយបង្គំព្រះអង្គ ដែលឋិតនៅក្នុងវចីសច្ចៈផង ក្នុងសភាវធម៌ផង សូម្បី ដល់នូវសេចក្ដីវិនាស ក៏ព្រះហឫទ័យ របស់ព្រះអង្គនៅតែត្រេកអរក្នុងសច្ចៈ។

[៥៨១] (ព្រះពោធិសត្វ សំដែងគុណរបស់ព្រះនាងទេវីថា) ភរិយាណា របស់ប្តីអ្នកទ័លក្រ ក៏ជាស្រីទ័លក្រដែរ របស់ប្តីអ្នកស្តុកស្តម្ភ ក៏ជាស្រីស្តុកស្តម្ភ មានកេរ្តិ៍ឈ្មោះដែរ ភរិយានោះ ឈ្មោះថាជាភរិយាដ៏ឧត្តមរបស់ប្តីនោះ ស្រីទាំងឡាយរបស់អ្នកមានប្រាក់ (ក៏ដូច្នោះដែរ)។

ចប់ សុចជជាតក ទី១០។

ចប់ បុចិមន្ទវគ្គ ទី២។

ឧទ្ទាននៃបុចិមន្ទវគ្គនោះគឺ

និយាយអំពីចោរ ១ កស្សបតាបស ១ តាបសខន្តិវាទី ១ ការរស់នៅអាក្រក់ ១ សំដីអាក្រក់ ១ ទន្សាយ ១ បុគ្គលស្លាប់ ១ វសន្តកាល ១ ការរស់នៅជាសុខ ១ ព្រះរាជាមិនលះបង់នូវរបស់ដែលលះបង់ងាយ ១ ត្រូវជា ១០។

## កុដិទូសកវគ្គ ទី៣

CS sut.kn.jat.v04.03 | ភាគទី ៥៨

(៣. កុដិទូសកវគ្គោ)

### កុដិទូសកជាតក ទី១

CS sut.kn.jat.321 | ភាគទី ៥៨

(៣២១. កុដិទូសកជាតកំ (៤-៣-១))

[៥៨២] (គ្រលេងគ្រលោង ពោលថា) នែពានរ ក្បាល ដៃ និងជើងរបស់អ្នក ដូចជាមនុស្សដែរ តែព្រោះហេតុអ្វី បានជាផ្ទះរបស់អ្នកគ្មាន។

[៥៨៣] (ពានរ ឆ្លើយថា) នែគ្រលេងគ្រលោង ក្បាល ដៃ និងជើងរបស់ខ្ញុំ ដូចមនុស្សមែនហើយ តែប្រាជ្ញាណា ដែលបោរាណាចារ្យពោលថា ប្រសើរក្នុងពួកមនុស្ស ប្រាជ្ញានោះ របស់ខ្ញុំមិនមានទេ។

[៥៨៤] (គ្រលេងគ្រលោង ពោលថា) ធម្មតា អ្នកមានចិត្តមិននឹងនួន មានចិត្តរហ័សរហួន ជាអ្នកប្រទូស្តចំពោះមិត្រ មានមារយាទមិនទៀងជានិច្ច តែងមិនមានសេចក្តីសុខ។

[៥៨៥] នែពានរ អ្នកនោះចូរធ្វើនូវអានុភាព (ឲ្យកើតបញ្ញា) ចូរផ្លាស់មារយាទចេញ ចូរធ្វើខ្ទមជាគ្រឿងការពារនូវត្រជាក់ និងខ្យល់។

ចប់ កុដិទូសកជាតក ទី១។

### ទុទ្ទុភាយជាតក ទី២

CS sut.kn.jat.322 | ភាគទី ៥៨

(៣២២. ទុទ្ទុភជាតកំ (៤-៣-២))

[៥៨៦] (ទន្សាយ និយាយថា) សូមសេចក្តីចំរើនមានដល់លោកចុះ ខ្ញុំនៅក្នុងប្រទេសណា ប្រទេសនោះធ្វើសំឡេងឮទុទ្ទុភ ⑧ តែខ្ញុំមិនដឹងនូវប្រទេសនុ៎ះថា អ្វីនេះ ធ្វើសំឡេងឮទុទ្ទុភ។

[៥៨៧] (ព្រះសាស្តា ទ្រង់សំដែងថា) ទន្សាយឮសូរផ្លែព្នៅជ្រុះថាទុទ្ទុភ ដូច្នេះ ក៏ស្ទុះបោលប្រេច ហ្វូងសត្វម្រឹគបានឮពាក្យទន្សាយក៏ភ័យតក់ស្លុត។

[៥៨៨] ពួកជនពាលនោះ មិនទាន់សម្រេចនូវចំណែកនៃសោតវិញ្ញាណ ឮសំឡេងនៃជនដទៃ មានសេចក្តីប្រហែសធ្វេសដ៏ក្រៃលែង ជនពាលទាំងនោះ រមែងលុះតាមពាក្យជនដទៃ។

[៥៨៩] ចំណែកពួកជនណា បរិបូណ៌ដោយសីល និងបញ្ញា ត្រេកអរក្នុងការស្ងប់រម្ងាប់ ជាធីរជន អ្នកឆ្លាយ អ្នកវៀរចាកបាប ធីរជននោះ មិនលុះតាមពាក្យជនដទៃទេ។

ចប់ ទុទ្ទុភាយជាតក ទី២។

### ព្រហ្មទត្តជាតក ទី៣

CS sut.kn.jat.323 | ភាគទី ៥៨

(៣២៣. ព្រហ្មទត្តជាតកំ (៤-៣-៣))

[៥៩០] (តាបសពោធិសត្វ ពោលថា) បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសូម រមែងបានផលពីរយ៉ាង គឺការមិនបានទ្រព្យ ១ ការបានទ្រព្យ ១ ព្រោះថា ការសូម មានយ៉ាងនេះជាធម្មតា។

[៥៩១] បពិត្រព្រះអង្គជាឥស្សរៈលើរថនៃដែនបញ្ចាល អ្នកប្រាជ្ញទាំងឡាយ បានពោលនូវការសូមថាជាការយំ បុគ្គលណា ឃាត់នូវការសូម អ្នកប្រាជ្ញទាំងឡាយហៅបុគ្គលនោះ ថាជាអ្នកមានការយំតប។

[៥៩២] កុំឲ្យពួកជនអ្នកដែនបញ្ចាលមកប្រជុំគ្នា ឃើញអាត្មាភាពកំពុងយំ ឬព្រះអង្គកំពុងយំតបឡើយ ព្រោះហេតុនោះ បានជាអាត្មាភាពត្រូវការទីស្ងាត់។

[៥៩៣] (ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់ថា) បពិត្រព្រាហ្មណ៍ ខ្ញុំនឹងឲ្យគោញីសម្បុរក្រហម ១០០០ ព្រមទាំងគោឈ្មោលដល់លោក

ព្រោះថាអរិយជន បានស្តាប់នូវគាថាប្រកបដោយធម៌ របស់លោកជាអរិយៈ មិនគប្បីឲ្យ ដូចម្តេចកើត។

ចប់ ព្រហ្មទត្តជាតក ទី៣។

## ចម្មសាដកជាតក ទី៤

CS sut.kn.jat.324 | ភាគទី ៥៨

(៣២៤. ចម្មសាដកជាតកំ (៤-៣-៤ ))

[៥៩៤] (ចម្មសាដកបរិព្វាជក ពោលថា) ឱ ពពែដ៏ប្រសើរនេះ ជាសត្វជើង ៤ មានសភាពល្អ ដ៏ចំរើនល្អ មានមារយាទ ជាទីស្រឡាញ់ មានយស តែងគោរពព្រាហ្មណ៍អ្នកបរិបូណ៌ដោយជាតិ និងមន្ត។

[៥៩៥] (បណ្ឌិតពាណិជពោធិសត្វ ពោលថា) ម្នាលព្រាហ្មណ៍ អ្នកកុំស្និទ្ធស្នាលនឹងសត្វជើង ៤ ដោយការឃើញមួយរំពេចឡើយ ដ្បិតសត្វពពែនេះ ប្រាថ្នានឹងធ្វើនូវការប្រហារដ៏មាំ បានជាថយក្រោយ និងព្រលែងនូវការប្រហារឲ្យងាយ។

[៥៩៦] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ឆ្អឹងភ្លៅរបស់ព្រាហ្មណ៍ក៏បាក់ អម្រែករបស់ព្រាហ្មណ៍ក៏ធ្លាក់ចុះ ទ្រព្យទាំងអស់របស់ព្រាហ្មណ៍ក៏បែកហើយ ព្រាហ្មណ៍លើកដៃទាំងពីរឡើង កន្ទក់កន្ទេញថា ពពែស្ទុះមកសម្លាប់ព្រហ្មចារីបុគ្គល។

[៥៩៧] (បរិព្វាជក និយាយតទៅទៀតថា) ខ្ញុំជាមនុស្សឥតប្រាជ្ញា ត្រូវពពែបុះសម្លាប់ក្នុងថ្ងៃនេះយ៉ាងណា បុគ្គលណា សរសើរបុគ្គលដែលមិនគួរបូជា បុគ្គលនោះ ត្រូវគេសម្លាប់ ដេកនៅ (ក្នុងទីនេះ) យ៉ាងនោះដែរ។

ចប់ ចម្មសាដកជាតក ទី៤។

## គោធជាតក ទី៥

CS sut.kn.jat.325 | ភាគទី ៥៨

(៣២៥. គោធរាជជាតកំ (៤-៣-៥))

[៥៩៨] (ទន្សងពោធិសត្វ និយាយនឹងតាបសថា) ខ្ញុំស្មានអ្នកថាជាសមណៈ បានចូលទៅរកអ្នក ជាអ្នកមិនសង្រួម អ្នកនោះ ប្រហារខ្ញុំដោយដំបង ដូចមនុស្សមិនមែនជាសមណៈដែរ។

[៥៩៩] ម្នាលតាបសកម្លៅ ប្រយោជន៍អ្វីដោយផ្នួងសក់របស់អ្នក ប្រយោជន៍អ្វី ដោយស្បែកខ្លាឃ្មុំរបស់អ្នក ខាងក្នុងរបស់អ្នកសាំញ៉ាំដោយកិលេស អ្នកបោសរលីងតែសរីរៈខាងក្រៅ។

[៦០០] (តាបស និយាយថា) នែទន្សង ឯងចូរមកណេះ ឯងត្រឡប់មកវិញ ចូរបរិភោគបាយស្រូវសាលីចុះ ប្រេង និងអម្បិលរបស់អញក៏មាន ដីប្លីរបស់អញក៏មានច្រើន។

[៦០១] (ទន្សងឆ្លើយថា) ខ្ញុំនោះនឹងចូលទៅរកដំបូក ជំរៅ ១០០ជួរបុរសយ៉ាងក្រៃលែង ថ្វីបើអ្នកឯងមានប្រេង និងអម្បិល ដីប្លីរបស់អ្នកមិនជាប្រយោជន៍ដល់ខ្ញុំឡើយ។

ចប់ គោធជាតក ទី៥។

## កក្ការុជាតក ទី៦

CS sut.kn.jat.326 | ភាគទី ៥៨

(៣២៦. កក្ការុជាតកំ (៤-៣-៦))

[៦០២] (ទេវបុត្តជាធំ ពោលថា) បុគ្គលណា មិនលួចទ្រព្យគេដោយកាយ មិននិយាយកុហកដោយវាចា បានយសសក្តិហើយ មិនស្រវឹង បុគ្គលនោះឯង គួរប្រដាប់ផ្កាត្រឡាចជាទិព្វទាំងឡាយ។

[៦០៣] (ទេវបុត្តទី២ ពោលថា) បុគ្គលណា ស្វះស្វែងរកទ្រព្យដោយធម៌ មិននាំយកទ្រព្យគេដោយបោកប្រាស បានទ្រព្យទាំងឡាយហើយ មិនស្រវឹង បុគ្គលនោះឯង គួរប្រដាប់នូវផ្កាត្រឡាចបាន។

[៦០៤] (ទេវបុត្តទី៣ ពោលថា) បុគ្គលណា មានចិត្តមិនឆាប់ហើរដូចរមៀត មានសទ្ធាមិនរសាយ មិនបរិភោគវត្ថុមានរសឆ្ងាញ់តែម្នាក់ឯង បុគ្គលនោះ ទើបគួរប្រដាប់នូវផ្កាត្រឡាចបាន។

[៦០៥] (ទេវបុត្តទី៤ ពោលថា) បុគ្គលណា មិនជេរប្រទេចពួកសប្បុរសក្នុងទីចំពោះមុខ ឬកំបាំងមុខ ជាអ្នកនិយាយយ៉ាងណា ធ្វើយ៉ាងនោះ បុគ្គលនោះ ទើបគួរប្រដាប់នូវផ្កាត្រឡាចបាន។

ចប់ កក្ការុជាតក ទី៦។

## កាកាតិជាតក ទី៧

CS sut.kn.jat.327 | ភាគទី ៥៨

(៣២៧. កាកវតីជាតកំ (៤-៣-៧))

[៦០៦] (នដកុវេរគន្ធព្វច្រៀងថា) ស្ត្រីជាទីស្រឡាញ់របស់ទូលព្រះបង្គំនៅក្នុងទីណា ក្លិនក្រអូបនេះ ក៏បក់មកអំពីទីនោះ ចិត្តរបស់ទូលព្រះបង្គំត្រេកអរក្នុងស្ត្រីណា ស្ត្រីនោះឈ្មោះនាងកាកាតិ ទៅនៅក្នុងទីឆ្ងាយអំពីទីនេះ។

[៦០៧] (ស្តេចគ្រុឌ ពោលថា) អ្នកបានឆ្លងសមុទ្រ ដោយឧបាយដូចម្តេច បានឆ្លងទន្លេឈ្មោះកេបុកៈ ដោយឧបាយដូចម្តេច បានឆ្លងសមុទ្រទាំង ៧ ជាន់ ដោយឧបាយដូចម្តេច បានឡើងដើមរកា (ជាលំនៅរបស់យើង) ដោយឧបាយដូចម្តេច។

[៦០៨] (នដកុវេរគន្ធព្វ ឆ្លើយតបថា) ខ្ញុំបានឆ្លងសមុទ្រជាមួយនឹងលោក បានឆ្លងទន្លេឈ្មោះកេបុកៈជាមួយនឹងលោក បានឆ្លងសមុទ្រទាំង ៧ ជាន់ជាមួយនឹងលោក បានឡើងដើមរកាជាមួយនឹងលោក។

[៦០៩] (ស្តេចគ្រុឌ ពោលថា) អញនាំមក ទាំងនាំទៅនូវសហាយរបស់ប្រពន្ធ ហេតុណា ហេតុនោះ គួរតិះដៀលខ្លួនអញ មានកាយធំ គួរតិះដៀលខ្លួនអញ ដែលមិនមានគំនិត។

ចប់ កាកាតិជាតក ទី៧។

## អននុសោចិយជាតក ទី៨

CS sut.kn.jat.328 | ភាគទី ៥៨

(៣២៨. អននុសោចិយជាតកំ (៤-៣-៨))

[៦១០] (តាបសពោធិសត្វ ពោលថា) នាងសម្មិល្លហាសិនី ជាស្រីដ៏ចំរើន មានក្នុងចន្លោះពួកសត្វដ៏ច្រើនដែលស្លាប់ហើយ ពួកសត្វដែលស្លាប់ហើយនោះ នឹងមានប្រយោជន៍អ្វីដល់ខ្ញុំ ហេតុនោះ បានជាខ្ញុំមិនសោកស្តាយនាងសម្មិល្លហាសិនី ជាទីស្រឡាញ់នុ៎ះឡើយ។

[៦១១] វត្ថុណា ។ មិនមានដល់សត្វនោះ បើសត្វគប្បីសោកស្តាយ ចំពោះវត្ថុដែលគ្មាននោះ ។ គប្បីសោយសោកចំពោះខ្លួនឯង ដែលលុះក្នុងអំណាចនៃមច្ចុគ្រប់កាលផង។

[៦១២] អាយុសង្ខារមិនទៅតាមសត្វណាមួយ ដែលឈរ អង្គុយ ដេក ដើរទៅមកឡើយ សត្វបើកភ្នែក ធ្មេចភ្នែក ដរាបណា វ័យរបស់សត្វតែងរំកិលទៅដរាបនោះ។

[៦១៣] កាលបើសេចក្តីព្រាត់ប្រាសក្នុងខ្លួន ជាផ្លូវឥតសង្ស័យនោះហើយ បុគ្គលគប្បីអាណិតសត្វរស់នៅដ៏សេសសល់ មិនគួរសោយសោក ចំពោះសត្វដែលច្យុតហើយទេ។

ចប់ អននុសោចិយជាតក ទី៨។

## កាឡពាហុជាតក ទី៩

CS sut.kn.jat.329 | ភាគទី ៥៨

(៣២៩. កាឡពាហុជាតកំ (៤-៣-៩ ))

[៦១៤] (សេកឈ្មោះបោដ្ឋបាទជាប្អូន និយាយថា) កាលពីដើម យើងបានបាយ និងទឹកណា អំពីសំណាក់នៃស្តេចនោះ ឥឡូវនេះ បាយនិងទឹកនោះ បានទៅស្វាវិញហើយ បពិត្របងរាធៈ ឥឡូវនេះ យើងនឹងនាំគ្នាទៅព្រៃវិញ ព្រោះព្រះបាទធនញ្ជ័យ លែងរាប់អានយើងហើយ។

[៦១៥] (សេកពោធិសត្វ ឈ្មោះរាធៈជាបង និយាយតបថា) លាភក្តី អលាភក្តី យសក្តី អយសក្តី និន្ទាក្តី បសំសាក្តី សុខក្តី ទុក្ខក្តី លោកធម៌ទាំង ៨ នោះ មិនទៀង ក្នុងមនុស្សសត្វទាំងឡាយទេ ម្នាលបោដ្ឋបាទ អ្នកកុំសោកស្តាយឡើយ អ្នកនឹងសោកស្តាយធ្វើអ្វី។

[៦១៦] (សេកឈ្មោះបោដ្ឋបាទ និយាថា) បពិត្របងរាធៈ បងជាអ្នកប្រាជ្ញមែនពិតហើយ បងដឹងនូវប្រយោជន៍ ដែលមិនទាន់មានមក តើយើងនឹងឃើញស្វាដ៏លាមក ដែលត្រូវគេបណ្តេញពីរាជត្រកូលដោយឧបាយដូចម្តេចហ្ន៎។

[៦១៧] (រាធៈ និយាយតបថា) ស្វាខ្មៅឈ្មោះកាឡពាហុ ញាក់ត្រចៀក ធ្វើមុខក្រញូវ គង់ធ្វើឲ្យព្រះរាជកុមារភិតភ័យ ដោយការសង្ឃកថា មុហុំ មុហុំ វាមុខជានឹងឋិតនៅឆ្ងាយអំពីបាយ និងទឹក ដោយហេតុណា វានឹងធ្វើនូវហេតុនោះ ដោយខ្លួនឯងពុំលែងឡើយ។

ចប់ កាឡពាហុជាតក ទី៩។

## សីលវីមំសជាតក ទី១០

CS sut.kn.jat.330 | ភាគទី ៥៨

(៣៣០. សីលវីមំសជាតកំ (៤-៣-១០ ))

[៦១៨] (បុរោហិតពោធិសត្វ និយាយថា) បានឮមកថា សីល ជាគុណជាតដ៏ល្អ សីល ជាគុណដ៏ប្រសើរក្រៃលែងក្នុងលោក សូមព្រះអង្គទតមើលចុះ ដូចយ៉ាងនាគ ជាសត្វមានពិសដ៏ខ្លាំងពន្លឹក មិនហ៊ានបៀតបៀន ដោយយល់ថា បុគ្គលនេះមានសីល។

[៦១៩] (ពោធិសត្វ ពោលថា) ដុំសាច់បន្តិចបន្តួច នៅមានដល់ខ្លែងនោះ ដរាបណា ពួកប្រមង់ក្នុងលោក ចោមចឹកខ្លែងនោះ ដរាបនោះដែរ សត្វបក្សីដ៏សេស មិនបានបៀតបៀនខ្លែងដែលមិនមានសាច់ជាគ្រឿងកង្វល់នោះ។

[៦២០] បុគ្គលដេកលក់ជាសុខ ព្រោះមិនមានសេចក្តីប្រាថ្នា សេចក្តីប្រាថ្នាដែលមានលទ្ធផលក៏ជាសុខ នាងបិង្គលាទាសី បានធ្វើនូវសេចក្តីប្រាថ្នា ឲ្យគ្មានសេចក្តីប្រាថ្នាវិញ ក៏ដេកលក់ជាសុខដែរ។

[៦២១] ក្នុងលោកនេះក្តី ក្នុងលោកខាងមុខក្តី មិនមានធម៌ដទៃប្រសើរជាងសមាធិឡើយ (ព្រោះ) បុគ្គលអ្នកតាំងនៅក្នុងសមាធិហើយ រមែងមិនបៀតបៀនបុគ្គលដទៃផង មិនបៀតបៀនខ្លួនឯងផង។

ចប់ សីលវីមំសជាតក ទី១០។

ចប់ កុដិទូសកវគ្គ ទី៣។

ឧទ្ទាននៃកុដិទូសកវគ្គនោះគឺ

និយាយអំពីក្បាល និងដៃជើងរបស់ស្វាដូចមនុស្ស ១ ប្រទេសធ្វើនូវសំឡេងថាទុទ្ទុភៈ ១ បុគ្គលអ្នកសូម ១ សត្វពពែប្រសើរ ១ សត្វទន្សោងប្រសើរ ១ ការមិនល្អដោយកាយ ១ ទន្លេឈ្មោះកេបុកៈ ១ ស្ត្រីចំរើនប្រសើរ ១ សេកឈ្មោះរាធៈ ១ សីលប្រសើរ ១ ត្រូវជា ១០។

## កោកិលវគ្គ ទី៤

CS sut.kn.jat.v04.04 | ភាគទី ៥៨

(៤. កោកិលវគ្គោ)

## កោកាលិកជាតក ទី១

CS sut.kn.jat.331 | ភាគទី ៥៨

(៣៣១. កោកិលជាតកំ (៤-៤-១))

[៦២២] (អាមាត្យពោធិសត្វ ពោលថា) បុគ្គលណានិយាយហួសប្រមាណ ក្នុងកាលដែលមិនសម្រេច (លទ្ធផល) បុគ្គលនោះ ត្រូវគេកំចាត់ចេញ ដេកនៅតែម្នាក់ឯង ដូចកូនតាវៅ (ដែលមេក្អែកចឹកកំចាត់ចេញ)។

[៦២៣] កាំបិតទុកជាគេសំលៀងមុតហើយ ឬថ្នាំពិសដ៏ក្លាខ្លាំង ក៏មិនទាញបុគ្គលឲ្យធ្លាក់ចុះ ដូចវាចាជាទុព្ភាសិតទេ។

[៦២៤] ហេតុនោះ អ្នកប្រាជ្ញគួររក្សាវាចាទុក ក្នុងកាលដែលគួរ និងកាលមិនគួរ មិនគួរនិយាយហួសប្រមាណ សូម្បីចំពោះបុគ្គលដែលស្មើនឹងខ្លួន។

[៦២៥] ចំណែកបុគ្គលណាមានគំនិតគិតទុកមុន មានប្រាជ្ញាជាគ្រឿងពិចារណា និយាយល្មមប្រមាណ ក្នុងកាលគួរ បុគ្គលនោះ អាចចាប់សត្រូវទាំងពួងបាន ដូចគ្រុឌចាប់នាគដូច្នោះ។

ចប់ កោកាលិកជាតក ទី១។

## រថលដ្ឋិជាតក ទី២

CS sut.kn.jat.332 | ភាគទី ៥៨

(៣៣២. រថលដ្ឋិជាតកំ (៤-៤-២))

[៦២៦] (អាមាត្យពោធិសត្វ ពោលថា) បពិត្រព្រះរាជា បុគ្គលខ្លះប្រហារខ្លួន ដោយខ្លួនឯង ហើយនិយាយថា គេប្រហារក៏មាន ផ្ចាញ់គេហើយនិយាយថា គេផ្ចាញ់ខ្លួនក៏មាន អ្នកប្រាជ្ញកុំគប្បីជឿពាក្យនៃអ្នកនិយាយមុនដោយដាច់ខាតឡើយ។

[៦២៧] ហេតុនោះ បណ្ឌិតជាតិ គួរស្តាប់ពាក្យរបស់បុគ្គលក្រៅពីនេះផង លុះស្តាប់ពាក្យរបស់ជនទាំងពីរនាក់ហើយ គប្បីធ្វើតាមច្បាប់ចុះ។

[៦២៨] គ្រហស្ថអ្នកបរិភោគកាម ជាអ្នកខ្ជិលច្រអូស មិនប្រពៃ អ្នកបួសមិនសង្រួម មិនប្រសើរ ព្រះរាជាមិនពិចារណាហើយធ្វើ មិនប្រសើរ បណ្ឌិតដែលជាអ្នកច្រើនក្រោធ ក៏ពុំប្រសើរ។

[៦២៩] បពិត្រព្រះអង្គជាម្ចាស់នៃទិស ក្សត្រិយ៍គប្បីពិចារណាហើយសឹមធ្វើ បើមិនទាន់ពិចារណា មិនត្រូវធ្វើទេ យសក្តី កិត្តិស័ព្ទក្តី រមែងចំរើនដល់ព្រះរាជា ដែលពិចារណាហើយទើបធ្វើ។

ចប់ រថលដ្ឋិជាតក ទី២។

## គោធជាតក ទី៣

CS sut.kn.jat.333 | ភាគទី ៥៨

(៣៣៣. បក្កគោធជាតកំ (៤-៤-៣))

[៦៣០] (នាងទេវី ក្រាបបង្គំទូលថា) ព្រះអង្គណា ដែលមានព្រះខ័នសៀត ទ្រង់ស្លិតស្លាងហើយ ទ្រទ្រង់នូវសំពត់គិរីជិ ទ្រង់មានទន្សោងឆ្អើរ បានបោលទៅអំពីមែកអស្សត្ថព្រឹក្ស ព្រះអង្គនោះ ទ្រង់ប្រសើរក្នុងរថ គឺខ្ញុំដឹងច្បាស់ហើយ ក្នុងកណ្តាលព្រៃ ក្នុងកាលនោះឯង។

[៦៣១] (ពោធិសត្វ ពោលថា) បុគ្គលគប្បីសំពះបុគ្គលអ្នកសំពះខ្លួន គប្បីសេពគប់បុគ្គលអ្នកសេពគប់ខ្លួន គប្បីធ្វើកិច្ចរបស់បុគ្គលដែលជួយធ្វើកិច្ចខ្លួន មិនគប្បីធ្វើនូវសេចក្តីចំរើនដល់បុគ្គលអ្នកប្រាថ្នាសេចក្តីវិនាស មិនគប្បីគប់រកនូវបុគ្គលដែលមិនគប់រក (ខ្លួននោះឡើយ)។

[៦៣២] គប្បីលះបង់នូវបុគ្គល ដែលលះបង់ខ្លួន មិនគប្បីធ្វើនូវសេចក្តីស្រឡាញ់ដោយតណ្ហា (ក្នុងបុគ្គលនោះ) មិនគប្បីគប់រកនូវបុគ្គលដែលមានចិត្តរវើរវាយ ដូចសត្វបក្សីដឹងថា ឈើមានផ្លែអស់ហើយ (ហើរទៅរកដើមឈើដែលមានផ្លែបរិបូណ៌) គប្បីរមិលមើលបុគ្គលដទៃ ព្រោះថា លោកសន្និវាសធំណាស់។

[៦៣៣] (ព្រះរាជា ត្រាស់ថា) យើងនោះ ជាក្សត្រិយ៍ កាលឃើញនូវភាពនៃកតញ្ញូ នឹងធ្វើតបដល់នាងតាមសមត្ថភាព យើងនឹងឲ្យឥស្សរិយយសទាំងអស់ដល់នាង នាងចង់បានរបស់ណា យើងនឹងឲ្យរបស់នោះដល់នាង។

ចប់ គោធជាតក ទី៣។

## រាជោវាទជាតក ទី៤

CS sut.kn.jat.334 | ភាគទី ៥៨

(៣៣៤. រាជោវាទជាតកំ (៤-៤-៤))

[៦៣៤] (ព្រះពោធិសត្វ ពោលថា) កាលដែលពួកគោញីឆ្លងដើរទៅ បើគោមេហ្វូងដើរវៀច ពួកគោញី ក៏ដើរវៀចតាមដែរ ព្រោះគោមេហ្វូងដើរវៀចនោះ។

[៦៣៥] ក្នុងពួកមនុស្ស ក៏យ៉ាងនោះដែរ មនុស្សណា ដែលគេសន្មតថា ប្រសើរជាងគេ បើមនុស្សនោះ ប្រព្រឹត្តអធម៌ នឹងបាច់និយាយទៅថ្វី ដល់ប្រជាជនឯទៀត បើព្រះរាជាជាអ្នកប្រព្រឹត្តអធម៌ រាស្ត្រទាំងអស់ រមែងដេកជាទុក្ខ។

[៦៣៦] កាលដែលពួកគោញីដើរឆ្លងទៅ បើគោមេហ្វូងដើរត្រង់ ពួកគោញីទាំងអស់ ក៏ដើរត្រង់ដែរ កាលបើគោមេហ្វូងនាំដើរទៅត្រង់។

[៦៣៧] ក្នុងពួកមនុស្សក៏យ៉ាងនោះដែរ មនុស្សណា ដែលគេសន្មតថា ប្រសើរជាងគេ បើមនុស្សនោះ ប្រព្រឹត្តិធម៌ នឹងបាច់និយាយទៅថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាជាអ្នកប្រព្រឹត្តធម៌ រាស្ត្រទាំងអស់ក៏ដេកជាសុខ។

ចប់ រាជោវាទជាតក ទី៤។

## ជម្ពុកជាតក ទី៥

CS sut.kn.jat.335 | ភាគទី ៥៨

(៣៣៥. ជម្ពុកជាតកំ (៤-៤-៥))

[៦៣៨] (រាជសីហ៍ និយាយថា) នែចចក ដំរីនោះធំណាស់ មានកាយក៏ខ្ពស់ មានភ្លុកក៏វែង ពួកសត្វកើតក្នុងត្រកូលរាជសីហ៍ណា រមែងចាប់ដំរីបាន អ្នកឯងមិនមែនកើតក្នុងត្រកូលរាជសីហ៍នោះទេ។

[៦៣៩] សត្វណា មិនមែនជារាជសីហ៍ ក្លែងខ្លួនដោយមានះថា អញជារាជសីហ៍ សត្វនោះ រមែងដេកថ្ងូរលើផែនដី ដូចជាចចកមកកាន់ដំរី (ត្រូវដំរីជាន់)។

[៦៤០] ចចកនេះ មិនដឹងកំឡាំងកាយ កំឡាំងប្រាជ្ញា និងកំណើតរបស់សីហៈ ដែលជាសត្វមានយស ជាសត្វឧត្តម ជាសត្វមានខ្លួនមាំមួន ជាសត្វមានកំឡាំងខ្លាំងសោះ ទើបត្រូវដំរីជាន់ស្លាប់។

[៦៤១] ក្នុងលោកនេះ បុគ្គលណា បានពិចារណាឲ្យដឹងច្បាស់នូវកំឡាំងកាយ និងកំឡាំងប្រាជ្ញាក្នុងខ្លួន ជាអ្នកកំណត់ដោយការស្វាធ្យាយ ដោយការប្រឹក្សា ដោយសុភាសិត (ជាមុន) ទើបធ្វើការងារ បុគ្គលនោះឈ្មោះថា ឈ្នះនូវប្រយោជន៍ធំ គឺមិនសាបសូន្យប្រយោជន៍។

ចប់ ជម្ពុកជាតក ទី៥។

## ព្រហាឆត្តជាតក ទី៦

CS sut.kn.jat.336 | ភាគទី ៥៨

(៣៣៦. ព្រហាឆត្តជាតកំ (៤-៤-៦))

[៦៤២] (អាមាត្យពោធិសត្វ ទូលថា) ព្រះអង្គត្រាស់ថា ស្មៅ ៗ ដូច្នេះ តើនរណាហ្ន៎ លួចយកស្មៅរបស់ព្រះអង្គទៅ ហេតុដូចម្តេច បានជាព្រះអង្គមានកិច្ចដោយស្មៅ ទើបត្រាស់រកតែស្មៅប៉ុណ្ណោះ។

[៦៤៣] (ព្រះបាទពារាណសី ត្រាស់ថា) តាបសឈ្មោះឆត្ត មានរាងកាយដ៏ខ្ពស់ ជាព្រហ្មចារីបុគ្គល ជាពហុស្សូត បានមកក្នុងទីនេះ លោកបានប្រមូលទ្រព្យរបស់យើងទាំងអស់ រួចដាក់ស្មៅ (ក្នុងពាងទាំងឡាយ) ហើយទៅបាត់។

[៦៤៤] (ព្រះពោធិសត្វ ពោលថា) ការកាន់យកទ្រព្យទាំងអស់ របស់ខ្លួនក្តី ការមិនកាន់យកស្មៅ (ដែលមិនគួរយកទៅ) នេះក្តី ជាកិច្ចដែលអ្នកប្រាថ្នានូវទ្រព្យដ៏ច្រើន ដោយយកស្មៅបន្តិចបន្តួច (ជាលើស) គប្បីធ្វើយ៉ាងនេះឯង (ព្រោះហេតុនោះ) ឆត្តតាបស ដាក់ស្មៅក្នុងពាងទាំងឡាយ ហើយទៅបាត់ ចុះការខ្សឹកខ្សួលធ្វើអ្វី ក្នុងរបស់នោះ។

[៦៤៥] (ព្រះបាទពារាណសី ត្រាស់ថា) ពួកលោកអ្នកមានសីលធម៌ មិនធ្វើបែបនេះទេ ចំណែកមនុស្សពាល ទើបធ្វើសីលធម៌ទាំងឡាយរបស់ខ្លួន (ឲ្យអាក្រក់) ភាពជាបណ្ឌិត នឹងធ្វើខ្លួនឲ្យជាបុគ្គលអ្នកទ្រុស្តសីល មានសីលមិនខ្ជាប់ខ្ជួន ដូចម្តេចកើត។

ចប់ ព្រហាឆត្តជាតក ទី៦។

## បីឋជាតក ទី៧

CS sut.kn.jat.337 | ភាគទី ៥៨

(៣៣៧. បីឋជាតកំ (៤-៤-៧ ))

[៦៤៦] (ពារាណសីសេដ្ឋី ពោលថា) យើងខ្ញុំទាំងឡាយមិនបានប្រគេនតាំង មិនបានប្រគេនទឹក ទាំងមិនបានប្រគេនភោជនាហារ ដល់លោក សូមលោកជាព្រហ្មចារីអត់ទោសដល់ខ្ញុំ ខ្ញុំឃើញទោសនុ៎ះហើយ។

[៦៤៧] (ពោធិសត្វ ពោលថា) អាត្មាមិនជាប់ចំពាក់ផង មិនខឹងផង ទាំងវត្ថុតិចតួច ដែលមិនជាទីស្រឡាញ់របស់អាត្មា ក៏មិនមានឡើយ មួយទៀត អាត្មាមានសេចក្តីត្រិះរិះ ក្នុងចិត្តថា ធម្មតា នៃត្រកូលប្រាកដដូច្នេះ ដោយពិត។

[៦៤៨] (សេដ្ឋី ពោលថា) យើងខ្ញុំបានប្រគេនអាសនៈ ប្រគេនទឹក ប្រគេនប្រេងសម្រាប់លាងជើងទាំងអស់នេះ នេះជាធម្មតារបស់ឪពុក និងជីតា ក្នុងត្រកូលរបស់យើងខ្ញុំ សព្វ ៗ កាល។

[៦៤៩] យើងខ្ញុំនឹងបម្រើ (សមណព្រាហ្មណ៍អ្នកប្រព្រឹត្តធម៌ល្អ) ដូចជាញាតិជាន់ខ្ពស់ ដោយសេចក្តីគោរព នេះជាធម្មតារបស់ឪពុក និងជីតាក្នុងត្រកូលរបស់យើងខ្ញុំ សព្វ ៗ កាល។

ចប់ ពីបជាតក ទី៧។

## ថុសជាតក ទី៨

CS sut.kn.jat.338 | ភាគទី ៥៨

(៣៣៨. ថុសជាតកំ (៤-៤-៨ ))

[៦៥០] (ព្រះរាជា ទ្រង់ត្រាស់ថា) កណ្តុរទាំងឡាយ ស្គាល់ច្បាស់នូវអង្កាម ស្គាល់ច្បាស់នូវអង្ករ កណ្តុរទាំងឡាយ វៀរបង់នូវអង្កាម ស៊ីតែអង្ករ។

[៦៥១] ការប្រឹក្សាគ្នាណាក្នុងព្រៃ ការខ្សឹបណាក្នុងស្រុក ទាំងការគិត (ប្រុងប្រហារ) ណា រឿងទាំងនេះ អញដឹងច្បាស់ហើយ។

[៦៥២] ពួថាទំនៀម ស្វាជាឪពុក តែងយកធ្មេញទៅខាំផ្តាច់នូវអង្គជាតរបស់កូនតូច ដែលកើតហើយ។

[៦៥៣] អ្នកឯងលូនវារ ដូចជាពពែខ្វាក់ក្នុងចំការស្ពៃ បុគ្គលណា ដេកខាងក្រោមទីដេក អំពើរបស់បុគ្គលនោះ យើងដឹងច្បាស់ហើយ។

ចប់ ថុសជាតក ទី៨។

## ពាវេរុជាតក ទី៩

CS sut.kn.jat.339 | ភាគទី ៥៨

(៣៣៩. ពាវេរុជាតកំ (៤-៤-៩))

[៦៥៤] (ព្រះសាស្តា ត្រាស់ថា) ជនទាំងឡាយ បានយកសាច់ និងផ្លែឈើ បូជាក្អែកក្នុងដែននោះ ព្រោះមិនទាន់ឃើញសត្វក្ងោក ជាសត្វមានសិរី មានសំឡេងពីរោះ។

[៦៥៥] ក្ងោកជាសត្វបរិបូណ៌ដោយសំឡេងពីរោះ បានមកដល់ដែនពាវេរុ ក្នុងកាលណា លាភ និងសក្ការៈរបស់ក្អែក ក៏សាបសូន្យក្នុងកាលនោះ។

[៦៥៦] ព្រះពុទ្ធជាធម្មរាជ ទ្រង់ធ្វើនូវពន្លឺ មិនទាន់កើតឡើងដរាបណា ពួកជនឯទៀត បានបូជាសមណព្រាហ្មណ៍ដ៏ច្រើន ដរាបនោះ។

[៦៥៧] ព្រះពុទ្ធ ព្រះអង្គបរិបូណ៌ដោយសំឡេង បានសំដែងនូវព្រះធម៌ក្នុងកាលណា លាភ និងសក្ការៈរបស់តិរ្ថិយទាំងឡាយ ក៏សាបសូន្យអស់ក្នុងកាលនោះ។

ចប់ ពាវេរុជាតក ទី៩។

## វិសយ្ហជាតក ទី១០

CS sut.kn.jat.340 | ភាគទី ៥៨

(៣៤០. វិសយ្ហជាតកំ (៤-៤-១០))

[៦៥៨] (សក្កទេវរាជ ត្រាស់ថា) នែវិសយ្ហសេដ្ឋី ក្នុងកាលមុន អ្នកបានឲ្យទានទាំងឡាយហើយ កាលអ្នកចេះតែឲ្យ សភាវៈអស់ទៅនៃភោគៈទាំងឡាយ បានកើតមានហើយ ខាងមុខអំពីនេះទៅ បើអ្នកមិនឲ្យទានទេ ភោគសម្បត្តិទាំងឡាយរបស់អ្នក ដែលឈប់ឲ្យ ទើបគង់នៅ។

[៦៥៩] (វិសយ្ហសេដ្ឋី ពោលថា) នែសហស្សនេត្រ ព្រះអរិយៈទាំងឡាយ បានពោលថា អំពើដ៏លាមក អរិយជនសូម្បីជាអ្នកកំសត់ ក៏មិនគប្បីធ្វើដែរ នែជនិន្ទ្រ យើងលះបង់ហើយនូវសេចក្តីជឿក្នុងទាន ព្រោះហេតុតែទ្រព្យណា ទ្រព្យនោះពុំមានដល់យើងឡើយ។

[៦៦០] រថមួយ បរទៅតាមផ្លូវណា រថឯទៀត ក៏បរទៅតាមផ្លូវនោះដែរ នែវាសវៈ កិច្ចវត្តដែលយើងបំពេញមកក្នុងកាលមុន ចូរប្រព្រឹត្តទៅចុះ។

[៦៦១] បើទ្រព្យមាន យើងនឹងឲ្យបាន កាលបើទ្រព្យមិនមាន យើងនឹងឲ្យដូចម្តេចកើត ថ្វីបើយើងជាអ្នក (ច្រូតស្មៅលក់) យើងនៅតែឲ្យទាន យើងមិនប្រហែសក្នុងទានទេ។

ចប់ វិសយ្ហជាតក ទី១០។

ចប់ កោកិលវគ្គ ទី៤។

ឧទ្ទាននៃកោកិលវគ្គនោះគឺ

និយាយអំពីបុគ្គលនិយាយហួសប្រមាណ ១ បុគ្គលផ្ចាញ់ខ្លួនឯង ១ ព្រះរាជាប្រសើរក្នុងរថកណ្តាលព្រៃ ១ គោដើរវៀច ១ ឆ្កែចចក ១ ស្តេចត្រាស់ថាស្មៅ ១ ជើងតាំងជាអាសនៈដ៏ប្រសើរ ១ អង្គុរ ១ សត្វក្ងោក ១ វិសយ្ហសេដ្ឋី ១ ត្រូវជា ១០។

## ចុល្លកុណាលវគ្គ ទី៥

CS sut.kn.jat.v04.06 | ភាគទី ៥៨

### (៥. ចូឡកុណាលវគ្គោ)

## កុណ្ឌលិកជាតក ទី១

CS sut.kn.jat.341 | ភាគទី ៥៨

### (៣៤១. កណ្ឌរីជាតកំ (៤-៥-១ ))

[៦៦២] (ព្រះអង្គ ត្រាស់ថា) ស្ត្រីទាំងឡាយ អ្នកធ្វើនូវសេចក្តីត្រេកអរ ចំពោះបុរសទាំងឡាយ ជាស្ត្រីមានចិត្តច្រើនផង ផ្ចាញ់ផ្ចាល់មិនបានផង ប្រសិនបើស្ត្រីទាំងអស់ ធ្វើនូវសេចក្តីពេញចិត្ត (ចំពោះបុរស) ដោយខ្លួនឯងក៏ដោយ បុរសមិនគប្បីទុកចិត្តទេ ព្រោះថា ស្រីទាំងឡាយ ស្មើដោយកំពង់ទឹក។

[៦៦៣] ហេតុនៃសេចក្តីធុញទ្រាន់ណា នៃព្រះរាជាទ្រង់ព្រះនាមកិន្នរៈ និងនាងទេវីទ្រង់ព្រះនាមកិន្នរី (ហេតុនៃសេចក្តីធុញទ្រាន់នោះ) បុគ្គលឃើញហើយ (គប្បីដឹងចុះ) ស្រីទាំងពួង រមែងមិនត្រេកអរ (នឹងស្វាមី) ក្នុងផ្ទះរបស់ខ្លួន នាងកិន្នរីទេវី ជាភរិយា លះបង់នូវព្រះរាជាកិន្នរៈនោះ ជាស្វាមីប្រាកដដូច្នោះ ព្រោះតែឃើញនូវបុរសខ្វិនដទៃ។

[៦៦៤] នាងបញ្ចបាបី ជាភរិយារបស់ព្រះបាទពកៈផង របស់ព្រះបាទពាវរិកៈផង ដែលលុះក្នុងកាមដ៏ជ្រុលពេក ក៏បានប្រព្រឹត្តបទមិនគួរជាមួយនឹងបុរសអ្នកបម្រើ ធ្វើម្តេចហ្ន៎ ស្ត្រីមិនប្រព្រឹត្តបទមិនគួរ នឹងបុរសដទៃនោះ។

[៦៦៥] អគ្គមហេសីឈ្មោះនាងបិយង្គានី ជាទីគាប់ព្រះហឫទ័យរបស់ព្រះបាទព្រហ្មទត្ត ជាធំក្នុងលោកទាំងមូល បានប្រព្រឹត្តបទមិនគួរជាមួយនឹងបុរសអ្នកឃ្វាលសេះមង្គល ជាអ្នកបម្រើនៃអគ្គមហេសីនោះ ជាស្រីប្រាថ្នាកាម ក៏មិនបាននូវបុរសអ្នកឃ្វាលសេះនោះផង (នូវទីជាអគ្គមហេសីផង)។

ចប់ កុណ្ឌលិកជាតក ទី១។

## វានរជាតក ទី២

CS sut.kn.jat.342 | ភាគទី ៥៨

### (៣៤២. វានរជាតកំ (៤-៥-២))

[៦៦៦] (ពានរពោធិសត្វ ពោលថា) នែសត្វទឹកក្រពើ អញអាចរើខ្លួនអំពីទឹកមកលើគោកហើយ ឥឡូវនេះ អញមិនលុះអំណាចនៃអ្នកឯងទៀតទេ។

[៦៦៧] ផ្លែឈើទាំងឡាយណា ដែលយើងគប្បីទៅកាន់ត្រើយនៃសមុទ្រ ហើយស៊ីផ្លែឈើទាំងឡាយនោះ គឺផ្លែស្វាយ ផ្លែព្រីង ផ្លែខ្នុរ មិនគួរដល់យើងឡើយ ឯផ្លែល្វារបស់យើង ទើបប្រសើរជាង។

[៦៦៨] បុគ្គលណា មិនដឹងហេតុដែលកើតឡើងភ្លាម ៗ ទេ បុគ្គនោះ គង់លុះក្នុងអំណាចសត្រូវផង រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយផង។

[៦៦៩] បុគ្គលណា ដឹងនូវហេតុដែលកើតឡើងភ្លាម បុគ្គលនោះ គង់រួចចាកសេចក្តីចង្អៀត គឺសត្រូវផង មិនក្តៅក្រហាយក្នុងកាលជាខាងក្រោយផង។

ចប់ វានរជាតក ទី២។

## កុន្តិនីជាតក ទី៣

CS sut.kn.jat.343 | ភាគទី ៥៨

### (៣៤៣. កុន្តិនីជាតកំ (៤-៥-៣ ))

[៦៧០] (មេក្រៀលទូលស្តេចថា) ខ្ញុំនៅអាស្រ័យក្នុងព្រះរាជដំណាក់របស់ព្រះអង្គ ។ ធ្វើសក្ការបូជាជានិច្ច ឥឡូវនេះ ព្រះអង្គបានធ្វើ (នូវហេតុឲ្យខ្ញុំចេញទៅ) បពិត្រមហារាជ បើដូច្នោះ ខ្ញុំព្រះអង្គនឹងទៅ។

[៦៧១] (ព្រះរាជាពោធិសត្វ ត្រាស់ថា) បុគ្គលណា (ដឹង) អំពើអាក្រក់ ដែលអ្នកដទៃធ្វើហើយចំពោះខ្លួន (ដឹង) អំពើអាក្រក់តប ដែលខ្លួនធ្វើតបតវិញ ពៀររបស់បុគ្គលនោះ រមែងស្ងប់ម្ងាប់ដោយអាការយ៉ាងនេះ នែនាងក្រៀល ចូរនាងនៅចុះ កុំទៅឡើយ។

[៦៧២] (មេក្រៀល និយាយថា) មិត្តភាពនៃបុគ្គលដែលត្រូវគេធ្វើ និងបុគ្គលអ្នកធ្វើ (តប) រមែងមិនតគ្នាទៀតបានឡើយ ចិត្តរបស់ខ្ញុំមិនយល់តាមទេ បពិត្រព្រះអង្គប្រសើរក្នុងរថ ខ្ញុំនឹងទៅមិនខាន។

[៦៧៣] (ព្រះរាជា ត្រាស់ថា) មិត្តភាពរបស់បុគ្គលដែលត្រូវគេធ្វើ និងបុគ្គលអ្នកធ្វើ (តប) រមែងតគ្នាទៀតបានចំពោះពួកជនជាអ្នកប្រាជ្ញ មិនចំពោះពួកជនពាលទេ ម្នាលនាងក្រៀល នាងចូរនៅចុះ នាងកុំទៅឡើយ។

ចប់ កុន្តិនីជាតក ទី៣។

## អម្ពជាតក ទី៤

CS sut.kn.jat.344 | ភាគទី ៥៨

(៣៤៤. អម្ពជាតកំ (៤-៥-៤))

[៦៧៤] (សេដ្ឋីធីតាទី១ ពោលថា) ស្ត្រីណាលួចស្វាយរបស់លោកម្ចាស់ ស្ត្រីនោះ ចូរលុះក្នុងអំណាចនៃបុរសដែលប្រដាប់ដោយវត្ថុសម្រាប់ធ្វើសក់ឲ្យខ្មៅ លំបាកដោយសណ្ឋាសចុះ (បានប្ដីចាស់)។

[៦៧៥] (សេដ្ឋីធីតាទី២ ពោលថា) ស្ត្រីណាលួចស្វាយរបស់លោកម្ចាស់ ស្ត្រីបែបនោះ ទោះបីអាយុដល់ ២០ ឆ្នាំ ឬ ២៥ ឆ្នាំ ឬក៏ថយពី ៣០ ឆ្នាំ ក៏កុំឲ្យបានប្ដីឡើយ។

[៦៧៦] (សេដ្ឋីធីតាទី៣ ពោលថា) ស្ត្រីណាលួចស្វាយរបស់លោកម្ចាស់ ស្ត្រីនោះតែម្នាក់ឯង ពឹងផ្អែកតែនឹងប្ដី ហើយដើរទៅកាន់ផ្លូវឆ្ងាយ កុំឲ្យចួបនឹងប្ដីក្នុងទីដែលសន្យាគ្នាឡើយ។

[៦៧៧] (សេដ្ឋីធីតាទី៤ ពោលថា) ស្ត្រីណាលួចស្វាយរបស់លោកម្ចាស់ ស្ត្រីនោះមានខ្លួនប្រដាប់ហើយ មានសំលៀកបំពាក់ដ៏ស្អាត ទ្រទ្រង់កម្រងផ្កា ប្រោះព្រំដោយខ្លឹមចន្ទន៍ ចូរដេកនៅលើទីដេកតែម្នាក់ឯងចុះ។

ចប់ អម្ពជាតក ទី៤។

## គជកុម្ភជាតក ទី៥

CS sut.kn.jat.345 | ភាគទី ៥៨

(៣៤៥. គជកុម្ភជាតកំ (៤-៥-៥))

[៦៧៨] (អាមាត្យពោធិសត្វ ពោលថា) កាលណាភ្លើង ៗ ឆេះព្រៃ ម្នាលបចលកៈ អ្នកនឹងធ្វើដូចម្ដេច បើអ្នកមានសេចក្ដីព្យាយាមយឺតយូរយ៉ាងនេះ។

[៦៧៩] (គជកុម្ភៈ (ខ្យងសោក) ពោលថា) ប្រហោងឈើ ក្រហែងដីមានច្រើន បើយើងទៅមិនដល់ទីទាំងនោះទេ យើងទៀងតែស្លាប់។

[៦៨០] (ពោធិសត្វ ពោលថា) បុគ្គលណា រហ័សរហួនក្នុងកាលដែលខ្លួនធ្វើការងារយឺតយូរផង យឺតយូរក្នុងការងារដែលគេត្រូវធ្វើឲ្យរហ័សរហួនផង បុគ្គលនោះ ឈ្មោះថា បំបាក់នូវប្រយោជន៍របស់ខ្លួនចោលើ ដូចជាបុរសដើរជាន់ស្លឹកត្នោតស្ងួតឲ្យខ្ទេចដូច្នោះ។

[៦៨១] បុរសណា យឺតយូរក្នុងការងារដែលខ្លួនត្រូវធ្វើឲ្យយឺតយូរផង រហ័សរហួនផង ក្នុងការងារដែលខ្លួនធ្វើឲ្យរហ័សផង ប្រយោជន៍របស់បុរសនោះ តែងពេញគ្រប់គ្រាន់ ដូចជាព្រះចន្ទ្រវែករាត្រី (ឲ្យលេចពន្លឺធំម្ដងបន្តិច ៗ)។

ចប់ គជកុម្ភជាតក ទី៥។

## កេសវជាតក ទី៦

CS sut.kn.jat.346 | ភាគទី ៥៨

(៣៤៦. កេសវជាតកំ (៤-៥-៦))

[៦៨២] (នារទាមាត្យ ទូលសួរកេសវតាបសថា) កេសវតាបសមានព្រះភាគ (របស់យើងខ្ញុំ) នេះ លះបង់ព្រះបាទពារាណសី ជាធំជាងមនុស្ស អ្នកឲ្យសំរេចសេចក្ដីប្រាថ្នាទាំងពួង ហើយត្រេកអរសប្បាយក្នុងអាស្រមរបស់កប្បកៈ តើដោយឧបាយដូចម្ដេច។

[៦៨៣] (កេសវតាបស និយាយថា) ម្នាលអាមាត្យ រសទាំងឡាយដ៏ឆ្ងាញ់ គួររីករាយក៏មាន ដើមឈើទាំងឡាយ ជាទីរីករាយចិត្តក៏មាន ពាក្យជាសុភាសិតទាំងឡាយរបស់កប្បកៈ តែងធ្វើឲ្យអាត្មាត្រេកអរបាន។

[៦៨៤] (នារទាមាត្យ ពោលថា) លោកម្ចាស់ ឆាន់ចង្ហាន់ស្រូវសាលី ដែលលាយនឹងសាច់ដ៏ស្អាត ហេតុដូចម្ដេច បានជាស្រងៃរ និងស្មៅគែលលកដែលមិនមានរសប្រៃសោះ ធ្វើឲ្យលោកម្ចាស់ត្រេកអរបាន។

[៦៨៥] (កេសវតាបស និយាយតបថា) បុគ្គលមានសេចក្ដីស្និទ្ធស្នាល បរិភោគភោជនទោះបីឆ្ងាញ់ក្ដី មិនឆ្ងាញ់ក្ដី តិចក្ដី ច្រើនក្ដី ក្នុងកន្លែងណា ភោជន (ណាមួយដែលបុគ្គលបរិភោគហើយ ក្នុងទីកន្លែងនោះ ជាភោជនប្រសើរ) ព្រោះរស មានសេចក្ដីស្និទ្ធស្នាលជាយ៉ាងក្រៃលែង។

ចប់ កេសវជាតក ទី៦។

## អយកូដជាតក ទី៧

CS sut.kn.jat.347 | ភាគទី ៥៨

(៣៤៧. អយកូដជាតកំ (៤-៥-៧))

[៦៨៦] (ពោធិសត្វ ពោលថា) អ្នកណា ឈរកាន់ញញួរដែកទាំងមូលធំហួសប្រមាណ លើអាកាស អ្នកនោះមកឋិតនៅ ដើម្បីរក្សាអញ (ក្នុងថ្ងៃនេះ) ឬព្យាយាម ដើម្បីសម្លាប់អញ។

[៦៨៧] (យក្ស ពោលថា) បពិត្រមហារាជ ខ្ញុំព្រះអង្គជាទូតរបស់អារក្សទឹក ខ្ញុំព្រះអង្គត្រូវពួកអារក្សទឹកប្រើមកក្នុងទីនេះ ដើម្បីសម្លាប់ព្រះអង្គ តែថា ព្រះឥន្ទ្រជាស្ដេចទេវតារក្សាព្រះអង្គ ហេតុនោះ ខ្ញុំព្រះអង្គនឹងបំបែកព្រះសិរ្សរបស់ព្រះអង្គមិនបានទេ។

[៦៨៨] (ពោធិសត្វ ពោលថា) បើទេវរាជ ទេវានមិន្ទ្រ មឃវៈ សុជម្បតិ រក្សានូវអញ ម្នាលបិសាច អារក្សទាំងអស់ ចូរបន្លឺឡើងតាមសេចក្ដីប្រាថ្នាចុះ យ៉ាងអញមិនតក់ស្លុត ចំពោះពួកអារក្សទឹកទេ។

[៦៨៩] ពួកកុម្ភណ្ឌ និងពួកបិសាចនៅលើគំនរសំរាមទាំងអស់ ចូរកំចាត់តាមសេចក្ដីប្រាថ្នាចុះ នៃបិសាច ពួកបិសាចទាំងអស់ មិនអាចដើម្បីច្បាំងនឹងអញបានទេ ការបន្លាចគួរឲ្យខ្លាចនោះធំណាស់ (តែអញមិនខ្លាចឯងទេ)។

ចប់ អយកូដជាតក ទី៧។

## អរញ្ញជាតក ទី៨

CS sut.kn.jat.348 | ភាគទី ៥៨

(៣៤៨. អរញ្ញជាតកំ (៤-៥-៨))

[៦៩០] (តាបសកុមារ និយាយប្រាប់បិតាថា) បពិត្របិតា ខ្ញុំបាទចេញអំពីព្រៃ មករកស្រុកវិញ គួរសេពគប់នឹងបុរសមានមារយាទដូចម្ដេច មានវត្តប្រតិបត្តិដូចម្ដេច ខ្ញុំបាទសួរហើយ សូមបិតាប្រាប់ហេតុនោះ (ដល់ខ្ញុំ) ឲ្យទាន។

[៦៩១] (តាបសពោធិសត្វជាបិតា ប្រាប់ថា) ម្នាលកូន បុរសណា គប្បីស្និទ្ធស្នាលនឹងអ្នក គប្បីអត់ទ្រាំនូវសេចក្ដីស្និទ្ធស្នាលរបស់អ្នក ជាអ្នកចង់ស្ដាប់ពាក្យរបស់អ្នក អត់ទោសដល់អ្នក អ្នកទៅអំពីព្រៃនេះទៅ ចូរសេពគប់នឹងបុរសនោះចុះ។

[៦៩២] បុរសណា មិនមានអំពើអាក្រក់ដោយកាយ វាចា ចិត្ត បើអ្នកចេញអំពីព្រៃនេះទៅ អ្នកចូរសេពគប់បុរសនោះចុះ ធ្វើដូចជាកូនដែលតាំងនៅឰដ៏ទ្រូង។

[៦៩៣] បើផ្ទៃជម្ពូទ្វីបនេះ គ្មានមនុស្សអ្នកវៀរចាកកាយទុច្ចរិតជាដើមទេ ម្នាលកូន អ្នកកុំសេពគប់នឹងបុរសដែលមានចិត្តដូចទឹកល្មៀតជាគ្រឿងជ្រលក់ (មានចិត្តមិនបានខ្ជាប់ខ្ជួន) មានចិត្តដូចជាអាការនៃស្វា ជួនត្រេកអរ ជួនមិនត្រេកអរ (ប្រែប្រួលភ្លាម ៗ) ប្រាកដដូច្នោះឡើយ។

ចប់ អរញ្ញជាតក ទី៨។

## សន្ធិភេទជាតក ទី៩

CS sut.kn.jat.349 | ភាគទី ៥៨

(៣៤៩. សន្ធិភេទជាតកំ (៤-៥-៩))

[៦៩៤] (ព្រះរាជា មានព្រះឱង្ការនឹងសារថីថា) ម្នាលសារថី សេចក្ដីស្មើគ្នា (របស់សត្វទាំងពីរ) ក្នុងសត្វញីទាំងឡាយ មិនមាន ក្នុងចំណីអាហារទាំងឡាយ ក៏មិនមានដែរ អ្នកចូរមើលគំនិតរបស់ចចកអ្នកបំបែកនូវតំណនៃមិត្រនោះ គិតមើលឲ្យល្អចុះ។

[៦៩៥] ពួកម្រឹគអធមិ (ចចក) ស៊ីគោផង ស៊ីសីហៈផង ព្រោះសេចក្ដីញុះញង់ណា សេចក្ដីញុះញង់នោះ រមែងប្រែប្រួលដូចជាដាវមុតក្នុងសាច់។

[៦៩៦] ម្នាលសារថី អ្នកឃើញកិរិយាដេកស្លាប់ (នៃសត្វទាំងពីរ) នេះ បុគ្គលណា ជឿពាក្យរបស់បុគ្គលអ្នកញុះញង់ បំបែកនូវតំណនៃមិត្រ បុគ្គលនោះ រមែងដេកស្លាប់យ៉ាងនេះ (ពុំខាន)។

[៦៩៧] ម្នាលសារថី ពួកជនណា មិនជឿពាក្យញុះញង់របស់អ្នកបំបែកនូវតំណនៃមិត្រ ពួកជននោះ តែងបាននូវសេចក្ដីសុខ ដូចជាពួកនរជនអ្នកទៅកើតក្នុងឋានសួគ៌ដូច្នោះ។

ចប់ សន្ធិភេទជាតក ទី៩។

## ទេវតាបញ្ហជាតក ទី១០

CS sut.kn.jat.350 | ភាគទី ៥៨

(៣៥០. ទេវតាបញ្ហជាតកំ (៤-៥-១០))

[៦៩៨] (ទេវតា សួរថា) បុគ្គលណា ប្រហារដោយដៃទាំងពីរផង ដោយជើងទាំងពីរផង ប្រហារនូវមាត់ផង បពិត្រមហារាជ បុគ្គលនោះ ជាទីស្រឡាញ់នៃគេ ហេតុនោះ ព្រះអង្គយល់ថាបុគ្គលណា។

[៦៩៩] បុគ្គលណា ជេរប្រទេចតាមសេចក្ដីប្រាថ្នា តែមិនប្រាថ្នានូវការមកដល់បុគ្គលនោះ បពិត្រមហារាជ បុគ្គលនោះ ជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា។

[៧០០] បុគ្គលណា ពោលបង្កាច់ដោយពាក្យមិនពិត ប្រកាសប្រាប់ឲ្យឮដោយពាក្យឡូឡា បពិត្រមហារាជ បុគ្គលនោះ ជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា។

[៧០១] ពួកអ្នកនាំយកទៅ បាននាំយកបាយផង ទឹកផង សំពត់ និងសេនាសនៈទាំងឡាយផង ដោយពិត បពិត្រមហារាជ ពួកអ្នកនាំយកទៅនោះ ជាទីស្រឡាញ់របស់គេ ហេតុនោះ ព្រះអង្គយល់ថា បុគ្គលណា។

ចប់ ទេវតាបញ្ហជាតក ទី១០។

ចប់ ចុល្លកុណាលវគ្គ ទី៥។

ឧទ្ទាននៃចុល្លកុណាលវគ្គនោះគឺ

និយាយអំពីស្រីធ្វើសេចក្តីត្រេកអរដល់ពួកបុរស ១ ព្រះពោធិសត្វបានរើខ្លួន ១ មេក្រៀលនៅក្នុងដំណាក់ស្តេច ១ វត្តធ្វើសក់ឲ្យខ្មៅ ១ ភ្លើងដ៏ប្រសើរ ១ រសទាំងឡាយ ១ ញញួរដែកដ៏ប្រសើរ ១ ការចេញអំពីព្រៃ ១ នាយសារថី ១ ប្រហារដោយដៃ ១ ត្រូវជា ១០។

ឧទ្ទាននៃវគ្គក្នុងចតុក្កនិបាតនោះគឺ

កាលិង្គវគ្គ ១ បុចិមន្ទវគ្គ ១ កុដិទូសកវគ្គ ១ កោកិលវគ្គ ១ ចុល្លកុណាលវគ្គ គំរប់ជា ៥ លោកសំដែងល្អហើយ។

ចប់ ចតុក្កនិបាត។

ចប់ ភាគ៥៨ ។

# បញ្ចកនិបាតជាតក

CS sut.kn.jat.v05 | ភាគទី ៥៩

(៥. បញ្ចកនិបាតោ)

## មណិកុណ្ឌលវគ្គ ទី១

CS sut.kn.jat.v05.01 | ភាគទី ៥៩

(១. មណិកុណ្ឌលវគ្គោ)

### មណិកុណ្ឌលជាតក ទី១

CS sut.kn.jat.351 | ភាគទី ៥៩

(៣៥១. មណិកុណ្ឌលជាតកំ (៥-១-១ ))

[១] (ព្រះរាជាកោសលពោលថា) ព្រះអង្គសាបសូន្យចាកដែនសេះ កែវមណី និងកុណ្ឌល សាបសូន្យចាកបុត្ត និងភរិយា ដូច្នោះដែរ កាលបើភោគៈទាំងអស់ មិនមានសេសសល់ទេ តើហេតុអ្វី ទើបព្រះអង្គមិនក្តៅក្រហាយ ក្នុងកាលដែលគួរសោកស្តាយ។

[២] (ព្រះរាជាពោធិសត្វពោលថា) ភោគៈទាំងឡាយលះបង់សត្វមុនក៏មាន សត្វ លះបង់ភោគៈទាំងនោះមុនក៏មាន បពិត្រព្រះអង្គទ្រង់ប្រាថ្នាកាម ជនអ្នកមានភោគៈទាំងឡាយ មិនទៀងទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយក្នុងកាលដែលគួរសោកស្តាយ។

[៣] ព្រះចន្ទ្ររមែងរះឡើង ពេញវង់ រួចអស់ទៅ ព្រះអាទិត្យក៏អស្តង្គតទៅដូចគ្នា បពិត្រស្តេចជាសត្រូវ ពួកលោកធម៌ ខ្ញុំឈ្នះហើយ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្តាយ ក្នុងកាលដែលគួរសោកស្តាយ។

[៤] គ្រហស្ថអ្នកបរិភោគកាម ជាអ្នកខ្ជិលច្រអូស មិនល្អ បព្វជិតមិនសង្រួម មិនល្អ ព្រះរាជាមិនបានពិចារណាមុន ហើយធ្វើ មិនល្អ បណ្ឌិតអ្នកច្រើនក្រោធ មិនល្អទេ។

[៥] បពិត្រព្រះអង្គជាម្ចាស់នៃទិស ក្សត្រិយ៍គប្បីពិចារណាហើយសឹមធ្វើ មិនគប្បីធ្វើទាំងមិនបានពិចារណាទេ យសក្តី កិត្តិគុណក្តី រមែងចំរើនដល់ព្រះរាជា ដែលពិចារណាហើយទើបធ្វើ។

ចប់ មណិកុណ្ឌលជាតក ទី១។

### សុជាតជាតក ទី២

CS sut.kn.jat.352 | ភាគទី ៥៩

(៣៥២. សុជាតជាតកំ (៥-១-២))

[៦] (បិតារបស់ពោធិសត្វ ពោលថា) អ្នករលះរលាំងទៅច្រូតស្មៅស្រស់ ហើយនិយាយនឹងគោចាស់ ដែលមានជីវិតបាត់បង់ទៅហើយថា ឯងស៊ីទៅ ឯងស៊ីទៅ ដូចម្តេចកើត គោស្លាប់ហើយ មិនគប្បីក្រោកឡើងបាន ព្រោះគ្រឿងស៊ី និងគ្រឿងផឹកទេ អ្នករវើរវាយទទេ ដូចជាមនុស្សល្ងង់ខ្លៅ។

[៧] (សុជាតមាណពជាបុត្រ ពោលថា) ក្បាលក៏តាំងនៅដដែល ដៃជើង កន្ទុយ និងត្រចៀក ក៏តាំងនៅដដែលដែរ ខ្ញុំសំគាល់ថា គោនៅក្រោកឡើងបាន ត្រង់ក្បាលដៃជើងរបស់ជីតា មិនប្រាកដទេ ឪពុកយំទួញជិតស្តូបដែលធ្វើដោយដីស្អិត មិនមែនជាអ្នកល្ងង់ខ្លៅទេឬ។

[៨] (បិតាពោលថា) អ្នកបានស្រោចស្រប់នូវខ្ញុំ ដែលភ្លើង គឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញ៉ាំងសេចក្តីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលស្រោចភ្លើងដែលឆេះឆ្នាំងខ្លាញ់ដោយទឹក សរ គឺសេចក្តីសោក ដែលអាស្រ័យនូវហឫទ័យរបស់យើង អ្នកដកចេញហើយ អ្នកបានបន្ទោបង់នូវសេចក្តីសោកក្នុងបិតានៃយើង ដែលមានសេចក្តីសោកបៀតបៀនហើយ។

[៩] ខ្ញុំនោះមានសរដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលមាណព ខ្ញុំលែងសោក លែងយំ ព្រោះបានស្តាប់ពាក្យរបស់អ្នក។

[១០] ពួកជនណា ប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ (ដោះទុក្ខ) រមែងធ្វើយ៉ាងនេះ រមែងដោះ (បុគ្គលដទៃ) ចេញចាកសេចក្តីសោក ដូចសុជាតមាណព ដោះបិតាចាកសេចក្តីទុក្ខសោក។

ចប់ សុជាតជាតក ទី២។

## វេនសាខជាតក ទី៣

CS sut.kn.jat.353 | ភាគទី ៥៩

**(៣៥៣. វេនសាខជាតកំ (៥-១-៣))**

[១១] (អាចារ្យទិសាបាមោក្ខពោធិសត្វ ពោលថា) ម្នាលព្រហ្មទត្តកុមារ សេចក្ដីក្សេមក្សាន្តក្ដី ភិក្ខាដ៏សម្បូរក្ដី សេចក្ដីសុខក្នុងកាយក្ដី នេះ មិនគប្បីមានជានិច្ចទេ (កាលបើឥស្សរភាពវិនាស) ក្នុងកាលជាទីកន្លងនៃប្រយោជន៍ អ្នកកុំវង្វេងជ្រប់ ដូចបុគ្គលដែលបែកធ្លាយនាវា ក្នុងកណ្ដាលសាគរ។

[១២] បុរសធ្វើនូវអំពើទាំងឡាយណា រមែងឃើញនូវអំពើនោះចំពោះខ្លួនវិញ បុរសអ្នកធ្វើល្អ រមែងបានផងល្អ អ្នកធ្វើអាក្រក់ រមែងបានផលអាក្រក់ បុរសអ្នកសាបព្រោះពូជបែបណា ផលបែបនោះ ក៏រមែងដុះឡើង។

[១៣] (ស្ដេចព្រហ្មទត្ត ពោលថា) អាចារ្យបារាចរិយគោត្រ បានពោលនូវពាក្យណា នេះជាពាក្យរបស់អាចារ្យនោះថា បាបណា ដែលអ្នកធ្វើហើយ គប្បីក្ដៅក្រហាយក្នុងកាលជាខាងក្រោយ អ្នកកុំធ្វើបាបនោះឡើយ។

[១៤] ខ្ញុំ និងបិង្គិយបុរោហិត សម្លាប់នូវពួកក្សត្រិយ៍មួយពាន់នាក់ ដែលប្រដាប់លាបដោយខ្លឹមចន្ទន៍ ទៀបដើមឈើណា ដើមឈើនេះឯង ជាដើមជ្រៃ មានមែកត្រសាយត្រសុំ (មិនអាចជួយអញបាន) សេចក្ដីទុក្ខនោះឯង ត្រឡប់មកត្រូវខ្ញុំវិញ។

[១៥] (អគ្គមហេសីរបស់ខ្ញុំ) ឈ្មោះនាងឧព្វរី មានខ្លួនលាបដោយខ្លឹមចន្ទន៍ មានសម្បុរដូចមាស ស្រលូតស្រឡៅ ដូចជាលំពង់ឈើម្រំត្រវខ្យល់បក់ល្អ ខ្ញុំមិនបានឃើញនាងឧព្វរី នឹងធ្វើមរណកាល ការមិនបានឃើញនាងឧព្វរីនោះ ជាទុក្ខដ៏លើសលុបដល់ខ្ញុំ ជាងទុក្ខព្រោះសេចក្ដីស្លាប់នេះទៅទៀត។

ចប់ វេនសាខជាតក ទី៣។

## ឧរគជាតក ទី៤

CS sut.kn.jat.354 | ភាគទី ៥៩

**(៣៥៤. ឧរគជាតកំ (៥-១-៤))**

[១៦] (ព្រាហ្មណ៍ពោធិសត្វ ពោលថា) កូនរបស់ខ្ញុំ លះបង់នូវសរីរៈហើយទៅ ដូចជាពស់លះបង់នូវសំណកចាស់ កាលបើសរីរៈប្រើប្រាស់មិនបាន ធ្វើកាលកិរិយា ទៅកាន់លោកខាងមុខយ៉ាងនេះ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួលនៃញាតិទាំងឡាយ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកស្ដាយ ចំពោះកូននុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ។

[១៧] (នាងព្រាហ្មណី ពោលថា) កូន (របស់ខ្ញុំ) ដែលមកអំពីបរលោក ខ្ញុំក៏មិនបានអង្វរ គេទៅអំពីលោកនេះ ក៏ខ្ញុំមិនអនុញ្ញាត គេមកយ៉ាងណា គេក៏ទៅយ៉ាងនោះ ខ្សឹកខ្សួលធ្វើអ្វី ព្រោះការដែលគេទៅនោះ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងកូននុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ។

[១៨] (នាងព្រាហ្មណីជាប្អូន ពោលថា) បើខ្ញុំយំទូញ ខ្ញុំនឹងស្គាំងស្គម កាលខ្ញុំនោះយំទូញ នឹងមានផលដូចម្ដេច សេចក្ដីមិនត្រេកអររបស់ពួកញាតិមិត្រ និងសំឡាញ់របស់យើង គប្បីមានដោយក្រៃលែង រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួល នៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងបងនោះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ។

[១៩] (ភរិយាពោលថា) ទារកយំទារព្រះចន្ទ្រដែលកំពុងចរទៅ យ៉ាងណា បុគ្គលដែលសោករកអ្នកស្លាប់ទៅកាន់លោកខាងមុខនេះឯង ជាគ្រឿងប្រៀបធៀប យ៉ាងនោះដែរ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួលនៃពួកញាតិទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងប្ដីនុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ។

[២០] (ទាសីពោលថា) ក្អមទឹកដែលបែកធ្លាយ តវិញមិនជាប់យ៉ាងណា បុគ្គលសោកស្ដាយនឹងអ្នកស្លាប់ ទៅកាន់លោកខាងមុខ នេះឯងជាគ្រឿងធៀប ក៏យ៉ាងនោះដែរ រាងកាយកាលត្រូវគេដុត រមែងមិនដឹងនូវសេចក្ដីខ្សឹកខ្សួលនៃញាតិទាំងឡាយទេ ព្រោះហេតុនោះ ទើបខ្ញុំមិនសោកនឹងម្ចាស់នុ៎ះ គតិណាជារបស់គេ គេក៏ទៅកាន់គតិនោះ។

ចប់ ឧរគជាតក ទី៤។

## ធង្កជាតក ទី៥

CS sut.kn.jat.355 | ភាគទី ៥៩

**(៣៥៥. ឃដជាតកំ (៥-១-៥))**

[២១] (ស្ដេចធង្កៈ សួរព្រះរាជាពោធិសត្វថា) ពួកជនឯទៀត តែងសោកយំទូញ ពួកជនឯទៀត មានមុខជោកដោយទឹកភ្នែក ម្នាលឃដកុមារ អ្នកមានសម្បុរមុខស្រស់បស់ អ្នកមិនសោកសៅព្រោះហេតុអ្វី។

[២២] (ពោធិសត្វ ឆ្លើយថា) សេចក្ដីសោក នាំមកនូវសេចក្ដីសុខ ដែលកន្លងទៅហើយមិនបានទេ នាំមកនូវសេចក្ដីសុខដែលមិនទាន់មកមិនបានទេ បពិត្រស្ដេចធង្កៈ ព្រោះហេតុនោះ ទើបខ្ញុំមិនសោក ភាពជាសំឡាញ់ក្នុងសេចក្ដីសោក មិនមានទេ។

[២៣] បុគ្គលកាលសោក រមែងជាអ្នកមានរោគលឿង ស្គាំងស្គម ទាំងបាយ រមែងមិនពេញចិត្តដល់បុគ្គលនោះ បុគ្គលដែលត្រូវសរ គឺសេចក្ដីសោកមុតហើយ ក៏ទុក្ខព្រួយ ពួកជនជាសត្រូវ រមែងមានចិត្តត្រេកអរ។

[២៤] សេចក្ដីវិនាសនឹងមករកខ្ញុំ ដែលឋិតនៅក្នុងស្រុក ឬក្នុងព្រៃ ក្នុងទីទាប ឬទីទួល មិនបានទេ (ព្រោះ) ខ្ញុំឃើញច្បាស់ផ្លូវធម៌យ៉ាងនេះ

ហើយ។

[២៥] បុគ្គលណា មានខ្លួនតែមួយ មិនអាចជាអ្នកនាំយកនូវរសនៃសេចក្តីប្រាថ្នា គឺសុខក្នុងឈានទាំងពួងបាន សូម្បីផែនដីទាំងមូល ក៏មិនអាចនាំមកនូវសេចក្តីសុខ ដល់បុគ្គលនោះបាន។

ចប់ ធង្កជាតក ទី៥។

## ការន្ទិយជាតក ទី៦

CS sut.kn.jat.356 | ភាគទី ៥៩

(៣៥៦. ការណ្ឌិយជាតកំ (៥-១-៦))

[២៦] (អាចារ្យសួរថា) អ្នកតែម្នាក់ឯង រលះរលាំងលើកដុំថ្មធំ ៗ បោះទៅក្នុងជ្រោះភ្នំ ក្នុងព្រៃរឿយ ៗ ម្នាលការន្ទិយៈ អ្នកមានប្រយោជន៍ដូចម្តេចក្នុងជ្រោះនេះ។

[២៧] (ពោធិសត្វឆ្លើយថា) ខ្ញុំនឹងធ្វើនូវផែនដីនេះ ដែលមានសាគរជាទីបំផុត ឲ្យស្មើដូចជាផ្ទៃបាតដៃ ព្រោះហេតុនោះ បានជាខ្ញុំពង្រាបភ្នំដី និងភ្នំថ្ម ហើយបោះថ្មទៅក្នុងជ្រោះ។

[២៨] (អាចារ្យពោលថា) មនុស្សម្នាក់ មិនគួរដើម្បីធ្វើផែនដីធំនេះ ឲ្យរាបស្មើ ដូចបាតដៃបានទេ ម្នាលការន្ទិយៈ ខ្ញុំសំគាល់នូវអ្នកដែលស្វែងរកថ្មភ្នំនេះឯង (ដើម្បីបំពេញជ្រោះ) អ្នកនឹងលះបង់នូវជីវលោក (ស្លាប់ខ្លួន)។

[២៩] (ពោធិសត្វពោលថា) បើមនុស្សម្នាក់នេះ មិនអាចដើម្បីធ្វើនូវផែនដីធំនេះ ឲ្យរាបស្មើបានទេ យ៉ាងណា ម្នាលព្រាហ្មណ៍ អ្នកនឹងដឹកនាំពួកមនុស្សទាំងនេះ ដែលមានទិដ្ឋិផ្សេង ៗ គ្នា មិនបាន ក៏យ៉ាងនោះដែរ។

[៣០] (អាចារ្យពោលថា) ម្នាលការន្ទិយៈ អ្នកដ៏ចំរើនពោលនូវពាក្យនេះដោយសង្ខេប ជាពាក្យមានប្រយោជន៍ដល់ខ្ញុំយ៉ាងនេះ ផែនដីនេះ គេមិនអាចធ្វើឲ្យរាបស្មើ យ៉ាងណា ពួកមនុស្ស ក៏មនុស្សមិនអាចធ្វើបាន យ៉ាងនោះដែរ។

ចប់ ការន្ទិយជាតក ទី៦។

## លដុកិកជាតក ទី៧

CS sut.kn.jat.357 | ភាគទី ៥៩

(៣៥៧. លដុកិកជាតកំ (៥-១-៧))

[៣១] (ចាបចៀបកប្បាស ពោលនឹងដំរីពោធិសត្វថា) ខ្ញុំសូមថ្វាយបង្គំលោក ជាដំរីមានកំឡាំងខ្សោយ ក្នុងកាលមានអាយុ ៦០ ជាអ្នកនៅក្នុងព្រៃ ជាម្ចាស់ហ្វូង មានយស ខ្ញុំសូមធ្វើនូវអញ្ជលិកម្មចំពោះលោក ដោយស្លាបទាំងឡាយ សូមកុំឲ្យលោកសម្លាប់កូនរបស់ខ្ញុំ ជាសត្វមានកំឡាំងខ្សោយ។

[៣២] (ចាបចៀបកប្បាស ពោលនឹងដំរីទេវទត្តថា) ខ្ញុំសូមថ្វាយបង្គំលោក ជាដំរីត្រាច់ទៅតែម្នាក់ឯង ជាអ្នកនៅក្នុងព្រៃ ដើរទៅតាមញកភ្នំ ខ្ញុំសូមធ្វើអញ្ជលិកម្ម ដោយស្លាបទាំងឡាយ សូមលោកកុំសម្លាប់កូនខ្ញុំ ជាសត្វមានកំឡាំងខ្សោយ។

[៣៣] (ដំរីទេវទត្តពោលថា) នែមេចាបចៀបកប្បាស អញនឹងសម្លាប់នូវកូននាង នាងជាសត្វមានកំឡាំងខ្សោយ នឹងធ្វើអ្វីដល់អញ អញនឹងជាន់នូវចាប សូម្បីមួយសែន ប្រហែលនឹងនាងឯង ដោយជើងឆ្វេង។

[៣៤] (ចាបចៀបកប្បាសពោលថា) កិច្ចដោយកំឡាំងកាយ មិនមែនប្រើបានគ្រប់កន្លែងទេ ព្រោះកំឡាំងកាយ សម្លាប់បានតែអ្នកល្ងង់ទេ នែស្តេចដំរី អ្នកណាសម្លាប់កូនរបស់ខ្ញុំ ជាសត្វមានកំឡាំងថយ ខ្ញុំនឹងធ្វើនូវសេចក្តីវិនាសដល់អ្នកនោះវិញ។

[៣៥] (ព្រះសាស្តា ទ្រង់ត្រាស់ថា) អ្នកចូរមើលនូវក្អែក ចាបចៀបកប្បាស កង្កែប និងរុយខៀវ សត្វទាំងនុ៎ះ សម្លាប់នូវដំរីបាន អ្នកចូរមើល (នូវគតិ) នៃពៀររបស់ពួកសត្វមានពៀរ ព្រោះហេតុនោះ អ្នកទាំងឡាយ កុំធ្វើនូវពៀរនឹងជនណាមួយ សូម្បីមិនជាទីស្រឡាញ់ឡើយ។

ចប់ លដុកិកជាតក ទី៧។

## ចុល្លធម្មបាលជាតក ទី៨

CS sut.kn.jat.358 | ភាគទី ៥៩

(៣៥៨. ចូឡធម្មបាលជាតកំ (៥-១-៨ ))

[៣៦] (ព្រះនាងចន្ទាទេវី ពោលថា) ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្តីចំរើន ដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមលែងនូវធម្មបាល (ជាកូនខ្ញុំ) នេះចេញ សូមកាត់នូវដៃទាំងឡាយរបស់ខ្ញុំម្ចាស់វិញចុះ។

[៣៧] ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្តីចំរើនដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលែងនូវធម្មបាលនេះចេញ សូមកាត់នូវជើងទាំងឡាយរបស់ខ្ញុំវិញចុះ។

[៣៨] ខ្ញុំម្ចាស់ជាស្រីប្រទូស្ត ជាអ្នកបំផ្លាញនូវសេចក្តីចំរើនដល់ស្តេចឈ្មោះមហាបតាបៈ បពិត្រព្រះសម្មតិទេព សូមព្រះអង្គលែងនូវធម្មបាលនេះចេញ សូមកាត់នូវក្បាលរបស់ខ្ញុំម្ចាស់វិញចុះ។

[៣៩] ពួកមិត្តអាមាត្យ និងជនអ្នកមានហឫទ័យល្អរបស់ស្តេចនេះ មិនមានទេឬ បានជាមិននិយាយឃាត់ស្តេចថា សូមព្រះអង្គកុំសម្លាប់បុត្តជាឱរស។

[៤០] ពួកមិត្ត ញាតិ និងជនអ្នកមានហឫទ័យល្អរបស់ស្តេចនេះ មិនមានទេឬ បានជាមិននិយាយឃាត់ស្តេចថា សូមព្រះអង្គកុំសម្លាប់បុត្តដែលកើតអំពីខ្លួន។

[៤១] ដើមដៃទាំងឡាយ ដែលលាបដោយខ្លឹមចន្ទន៍របស់ធម្មបាល អ្នកជាទាយាទផែនដីដាច់ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងរលត់។

ចប់ ចុល្លធម្មបាលជាតក ទី៨។

## សុវណ្ណមិគជាតក ទី៩

CS sut.kn.jat.359 | ភាគទី ៥៩

(៣៥៩. សុវណ្ណមិគជាតកំ (៥-១-៩))

[៤២] (ម្រឹគញីជាប្រពន្ធពោលថា) បពិត្រមហាម្រឹគ អ្នកចូរខំប្រឹង បពិត្រម្រឹគមានជើងដូចមាស អ្នកចូរខំប្រឹង ចូរកាត់នូវអន្ទាក់ដែលធ្វើដោយព្រ័ត្រ ខ្ញុំជាម្រឹគញីម្នាក់ឯង មិនអាចត្រេកអរក្នុងព្រៃបានទេ។

[៤៣] (ម្រឹគពោធិសត្វជាប្តី ពោលថា) អញខំប្រឹងមិនរួចទេ អញនឹងកកាយផែនដី ដោយកំឡាំង អន្ទាក់ដែលគេធ្វើដោយព្រ័ត្រជាប់មាំមួន រឹតកួតជើងរបស់អញ។

[៤៤] (ម្រឹគញីពោលថា) បពិត្រអ្នកព្រាន អ្នកចូរក្រាលនូវស្លឹកឈើ អ្នកចូរហូតដាវ (អំពីស្រោម) អ្នកសម្លាប់ខ្ញុំមុន ហើយសឹមសម្លាប់មហាម្រឹគ ជាខាងក្រោយ។

[៤៥] (ព្រាន ពោលថា) អញមិនដែលឮ ឬឃើញមេម្រឹគ ចេះនិយាយភាសាមនុស្សទេ ម្នាលមេម្រឹគដ៏ចំរើន នាងឯងចូរនៅជាសុខចុះ ទាំងមហាម្រឹគនុ៎ះ ក៏សូមឲ្យនៅជាសុខចុះ។

[៤៦] (ម្រឹគញី ពោលថា) បពិត្រអ្នកព្រាន ខ្ញុំត្រេកអរ ព្រោះឃើញនូវមហាម្រឹគ ដែលរួច (ចាកអន្ទាក់) ក្នុងថ្ងៃនេះ យ៉ាងណា សូមអ្នកត្រេកអរ ជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ។

ចប់ សុវណ្ណមិគជាតក ទី៩។

## សុសន្ធីជាតក ទី១០

CS sut.kn.jat.360 | ភាគទី ៥៩

(៣៦០. សុយោនន្ទីជាតកំ (៥-១-១០))

[៤៧] (អ្នកបរបាំឈ្មោះអគ្គៈ ពោលថា) ក្លិននៃផ្កាតិមិរព្រឹក្ស[10] រមែងផ្សាយទៅ សមុទ្រដែលពេញដោយទឹក មានសំឡេងគឹកកង បពិត្រស្តេចតម្ពៈ ព្រោះថា នាងសុសន្ធី (នៅ) ក្នុងទីឆ្ងាយពីនគរនេះ កាមទាំងឡាយ តែងចាក់ដោតខ្ញុំ។

[៤៨] (ស្តេចគ្រុឌ ពោលថា) អ្នកឆ្លងសមុទ្របាន ដោយប្រការដូចម្តេច អ្នកឃើញកោះឈ្មោះសេរុម ដោយប្រការដូចម្តេច ម្នាលអគ្គៈ ការជួបប្រសព្វនាងសុសន្ធី និងអ្នក បានមានមកដោយប្រការដូចម្តេច។

[៤៩] (អ្នកបរបាំឈ្មោះអគ្គៈ ពោលថា) នាវារបស់ពួកឈ្មួញ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆា បែកធ្លាយដោយមង្ករ ខ្ញុំក៏ឆ្លងសមុទ្រដោយផែនក្តារ។

[៥០] នាងសុសន្ធីនោះ ជាស្ត្រីមានវាចាទន់ពីរោះ មានក្លិនដូចខ្លឹមចន្ទន៍ អស់កាលជានិច្ច ជាស្ត្រីចំរើន ស្រង់ខ្ញុំដោយអវយវៈ ដូចមាតាត្រកងនូវបុត្តដែលកើតអំពីទ្រូង។

[៥១] នាងជាស្ត្រីមានភ្នែកទន់ បានផ្គត់ផ្គង់ខ្ញុំដោយបាយ ទឹក សំពត់ និងទីដេក ព្រមទាំងខ្លួន បពិត្រស្តេចតម្ពៈ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ។

ចប់ សុសន្ធីជាតក ទី១០។

ចប់ មណិកណ្ឌលវគ្គ ទី១។

ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីដៃន និងកែវមណីដ៏ប្រសើរដែលសាបសូន្យ ១ អ្នកច្រូតស្មៅ យកស្មៅខ្ចី (ឲ្យគោស្លាប់) ១ បុគ្គលវង្វេង ដូចបុគ្គលធ្លាយសំពៅ ១ បុគ្គលលះបង់សរីរៈ ដូចពស់លះបង់ សំណក ១ ព្រះរាជាឈ្មោះយែដកុមារ ១ ជ្រោះភ្នំ ១ កុញ្ជរ ១ មហេសីអ្នកបំផ្លាញនូវសេចក្តីចំរើន ១ ម្រឹគ ១ ការត្រកងនូវកូន ១ រួមជា ១០។

# វណ្ណារោហវគ្គ ទី២

CS sut.kn.jat.v05.02 | ភាគទី ៥៩

(២. វណ្ណារោហវគ្គោ)

## វណ្ណារោហជាតក ទី១

CS sut.kn.jat.361 | ភាគទី ៥៩

(៣៦១. វណ្ណារោហជាតកំ (៥-២-១))

[៥២] (ខ្លាឈ្មោះសុពាហុ ពោលថា) អ្នកឈ្មោះសុទាឋៈ និយាយថា ខ្លាឈ្មោះសុពាហុ មិនប្រសើរជាងអញ ដោយទំហំ កំពស់ ជាតិ កំឡាំងកាយ និងសេចក្តីព្យាយាម ដូច្នេះឬទេ។

[៥៣] (សីហៈឈ្មោះសុទាឋៈ ពោលថា) អ្នកឈ្មោះសុពាហុ និយាយថា សីហៈឈ្មោះសុទាឋៈ មិនប្រសើរជាងអញ ដោយទំហំ កំពស់ ជាតិ កំឡាំងកាយ និងសេចក្តីព្យាយាម ដូច្នេះឬទេ។

[៥៤] ម្នាលសុពាហុសំឡាញ់ បើអ្នកប្រទូស្តចំពោះខ្ញុំដែលកំពុងនៅយ៉ាងនេះ ឥឡូវនេះ ខ្ញុំមិនពេញចិត្តចំពោះការនៅរួមជាមួយអ្នកទេ។

[៥៥] អ្នកណាជឿនូវពាក្យនៃជនដទៃដ៏ផ្តេសផ្តាស អ្នកនោះ គប្បីបែកធ្លាយចាកមិត្តឆាប់រហ័ស ទាំងបាននូវពៀរជាច្រើន។

[៥៦] មិត្តណាជាអ្នកប្រយ័ត្ន រង្កៀសក្នុងការបែកធ្លាយ (ចំពោះមិត្ត) ឃើញតែទោសសព្វកាល អ្នកនោះ មិនឈ្មោះថាមិត្តឡើយ មួយទៀត បុគ្គលណាដែលពួកជនដទៃបំបែកមិនបាន រមែងដេកនៅរួម ដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះឯង ទើបឈ្មោះថាមិត្ត។

ចប់ វណ្ណារោហជាតក ទី១។

## សីលវីមំសជាតក ទី២

CS sut.kn.jat.362 | ភាគទី ៥៩

(៣៦២. សីលវីមំសជាតកំ (៥-២-២))

[៥៧] (ព្រាហ្មណ៍ពោធិសត្វ ពោលថា) ខ្ញុំមានសេចក្តីសង្ស័យថា សីលជារបស់ប្រសើរ ឬសុតៈជារបស់ប្រសើរ សីល (មារយាទ) ជារបស់ប្រសើរជាងសុតៈ (ការចេះដឹង) ខ្ញុំមិនមានសេចក្តីសង្ស័យ ដូច្នោះឡើយ។

[៥៨] ជាតិ និងវណ្ណៈ ឥតអំពើ សីលហ្នឹងឯង ទើបឧត្តម បុគ្គលកាលបើប្រាសចាកសីលហើយ ប្រយោជន៍ដោយសុតៈ មិនមានទេ។

[៥៩] ក្សត្រិយ៍មិនឋិតនៅក្នុងធម៌ (ច្បាប់) វេស្សៈ មិនអាស្រ័យធម៌ ពួកជនទាំងនោះ រមែងលះបង់លោកទាំងពីរ ទៅកាន់ទុគ្គតិ។

[៦០] ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ សុទ្ទៈ ចណ្ឌាល និងបុក្កុសជន ប្រព្រឹត្តធម៌ក្នុងលោកនេះ រមែងស្មើគ្នា ក្នុងទេវលោក។

[៦១] វេទ ក៏មិនមែនឲ្យសុខក្នុងបរលោក ជាតិ ក៏មិនមែនឲ្យសុខក្នុងបរលោក ផៅពង្ស ក៏មិនមែនឲ្យសុខក្នុងបរលោក មានតែសីលដ៏បរិសុទ្ធរបស់ខ្លួន ទើបនាំមកនូវសេចក្តីសុខ ក្នុងបរលោក។

ចប់ សីលវីមំសជាតក ទី២។

## ហិរិជាតក ទី៣

CS sut.kn.jat.363 | ភាគទី ៥៩

(៣៦៣. ហិរិជាតកំ (៥-២-៣))

[៦២] (ពារាណសីសេដ្ឋី ពោលថា) បណ្ឌិតគប្បីដឹងច្បាស់នូវបុគ្គលដែលលះបង់នូវសេចក្តីខ្មាស គួរខ្ពើមរអើម (ដោយមេត្តាភាវនា) ដែលគ្រាន់តែពោលថា ខ្ញុំ (ជាមិត្ត) របស់អ្នក តែមិនកាន់យកនូវអំពើដ៏ប្រសើរថា អ្នកនុ៎ះ មិនមែនជាមិត្តរបស់អញ។

[៦៣] ពិតណាស់ បុគ្គលធ្វើនូវអំពើណា គួរនិយាយចំពោះអំពើនោះ បុគ្គលមិនធ្វើនូវអំពើណា មិនគួរនិយាយចំពោះអំពើនោះ ពួកបណ្ឌិតតែងស្គាល់ច្បាស់នូវបុគ្គលដែលមិនធ្វើ គ្រាន់តែនិយាយ។

[៦៤] បុគ្គលណា ជាអ្នកប្រយ័ត្នក្នុងកាលទាំងពួង រង្កៀសក្នុងការបែកធ្លាយ (ចំពោះមិត្ត) សំឡឹងរំពៃរកទោសតែម្យ៉ាង អស់កាលជានិច្ច អ្នកនោះ មិនឈ្មោះថាមិត្តឡើយ មួយទៀត បុគ្គលណា ដែលពួកជនដទៃបំបែកមិនបាន រមែងដេកនៅរួម ដូចជាកូនដែលកើតអំពីទ្រូង បុគ្គលនោះ ទើបឈ្មោះថា មិត្តដោយពិត។

[៦៥] កុលបុត្តអ្នកមានផលានិសង្ស កាលនាំទៅនូវធុរៈ[1] ជារបស់បុរស រមែងចំរើននូវហេតុជាគ្រឿងធ្វើនូវបាមោជ្ជៈ ជាគ្រឿងនាំមកនូវសេចក្តីសរសើរជាសុខ។

[៦៦] បុគ្គលផឹកនូវរសនៃវិវេកធម៌ផង នូវរសនៃសេចក្តីស្ងប់រម្ងាប់ផង ផឹកនូវរសនៃធម្មបីតិផង ទើបជាអ្នកមិនមានកង្វល់ មិនមានបាប។

ចប់ ហិរិជាតក ទី៣។

## ខជ្ជោបនកជាតក ទី៤

CS sut.kn.jat.364 | ភាគទី ៥៩

(៣៦៤. ខជ្ជោបនកជាតកំ (៥-២-៤))

[៦៧] (ទេវតាពោលថា) នរណាហ្ន៎ កាលបើពន្លឺមាន ត្រាច់ទៅស្វែងរកភ្លើង បានឃើញនូវអំពិលអំពែកក្នុងវេលាយប់ ក៏សំគាល់ថាភ្លើង។

[៦៨] បុរសនោះ ក៏ច្របាច់ឈ្លីនូវលំអិតនៃអាចម៍គោ និងស្មៅ ដោយសេចក្តីសំគាល់ខុស មិនអាចនឹងបង្កាត់ភ្លើងឲ្យឆេះឡើងបានទេ។

[៦៩] បុគ្គលកាលរូតទឹកដោះមេគោ អំពីស្នែង រមែងមិនបាននូវទឹកដោះ យ៉ាងណាបុគ្គលអន្ធពាល ក៏មិនបាននូវប្រយោជន៍ ដោយហេតុមិនមែនឧបាយ យ៉ាងនោះដែរ។

[៧០] ជនទាំងឡាយ តែងបាននូវប្រយោជន៍ ដោយឧបាយទាំងឡាយផ្សេង ៗ គឺការផ្ចាញ់ផ្ចាល់សត្រូវទាំងឡាយផង គឺការទំនុកបម្រុងចំពោះមិត្តទាំងឡាយផង។

[៧១] ពួកអ្នករក្សាផែនដី រមែងគ្រប់គ្រងនូវផែនដីដែលទ្រទ្រង់នូវទ្រព្យសម្បត្តិ ដោយការបំពេញបាន ចំពោះសេនាជាប្រធានផង ដោយការណែនាំរបស់ពួកមន្ត្រីដែលជាអ្នកស្និទ្ធស្នាលផង។

ចប់ ខជ្ជោបនកជាតក ទី៤។

## អហិតុណ្ឌិកជាតក ទី៥

CS sut.kn.jat.365 | ភាគទី ៥៩

(៣៦៥. អហិតុណ្ឌិកជាតកំ (៥-២-៥))

[៧២] (អហិតុណ្ឌិកបុរសអ្នកចាប់ពស់ និយាយនឹងស្វាថា) ម្នាលសម្លាញ់មានមុខល្អ ខ្ញុំជាអ្នកលេងល្បែង ចាញ់ហើយដោយល្បែងភ្នាល់ អ្នកចូរទំលាក់នូវផ្លែស្វាយទុំ យើងស៊ីដោយសារសេចក្តីព្យាយាមរបស់អ្នក។

[៧៣] (ស្វានិយាយថា) ម្នាលសម្លាញ់ ពាក្យនេះ ពេញជាកុហក អ្នកសរសើរខ្ញុំ ដោយពាក្យមិនពិត ស្វាណាឈ្មោះថា មានមុខល្អ ដែលអ្នកធ្លាប់ឮ ឬធ្លាប់ឃើញ។

[៧៤] ម្នាលអហិតុណ្ឌិកៈ អ្នក (ធ្វើ) នូវអំពើណា ចំពោះខ្ញុំ អំពើនោះ (មាន) ក្នុងចិត្តអញ ក្នុងថ្ងៃនេះឯង អ្នកចូរទៅឯផ្សារលក់ស្រូវ ជាអ្នកស្រវឹង ហើយវាយខ្ញុំដែលកំពុងស្រេកឃ្លាន។

[៧៥] ខ្ញុំកាលនឹកឃើញហេតុនោះ ដេកជាទុក្ខ ទោះបីអ្នកឲ្យខ្ញុំសោយរាជ្យ ហើយអ្នកសុំស្វាយខ្ញុំ ខ្ញុំក៏មិនឲ្យ ព្រោះខ្ញុំត្រូវភ័យគំរាមហើយ។

[៧៦] អ្នកប្រាជ្ញស្គាល់នូវបុគ្គលណា ដែលកើតក្នុងត្រកូល ជាអ្នកឆ្អែតស្កប់ស្កល់ក្នុងគតិ ជាអ្នកមិនកំណាញ់ គួរចងសម្លាញ់ ចងមិត្តនឹងបុគ្គលនោះ។

ចប់ អហិតុណ្ឌិកជាតក ទី៥។

## គុម្ពិយជាតក ទី៦

CS sut.kn.jat.366 | ភាគទី ៥៩

(៣៦៦. គុម្ពិយជាតកំ (៥-២-៦))

[៧៧] (ព្រះសម្ពុទ្ធ ទ្រង់ពោលថា) ថ្នាំពិស មានពណ៌ល្អ មានរសឆ្ងាញ់ មានក្លិនក្រអូប យក្ខឈ្មោះគុម្ពិយៈ ស្វែងរកអាហារ បានដាក់ថ្នាំពិស (ទុកនៅ) ក្នុងព្រៃ។

[៧៨] ជនទាំងឡាយណា សំគាល់ថ្នាំពិស ថាជាវត្ថុផ្អែម ក៏លិទ្ធភក្សនូវថ្នាំពិសនោះ ជនទាំងឡាយនោះ ក៏ពុលដល់នូវសេចក្តីស្លាប់ដោយថ្នាំពិសនោះ។

[៧៩] ជនទាំងឡាយណា ពិចារណាឃើញច្បាស់ ថាជាថ្នាំពិស ហើយវៀរចេញ ជនទាំងឡាយនោះ ដល់នូវសេចក្តីសុខក្នុងពួកជនកំពុងក្តៅក្រហាយ ជាអ្នកត្រជាក់ចិត្ត ក្នុងពួកជនកំពុងក្តៅរោលរាល។

[៨០] ថ្នាំពិស តែងប្រជុំចុះទៀបផ្លូវធំ យ៉ាងណាមិញ កាមទាំងឡាយ ដូចជាពិស តែងប្រជុំចុះក្នុងពួកមនុស្ស ក៏យ៉ាងនោះដែរ កាមគុណនេះ ជានុយ ជាចំណង ជាអំណាចនៃមច្ចុ ជាគូហា ជាទីអាស្រ័យនៅនៃមច្ចុ។

[៨១] ជនទាំងឡាយ ជាអ្នកក្តៅក្រហាយ លះវៀរនូវកាមទាំងនេះ ដែលជាគ្រឿងប្រើប្រាស់ អស់កាលទាំងពួង ជនទាំងឡាយនោះ ក៏រមែងកន្លងនូវកិលេស ជាគ្រឿងជាប់ក្នុងលោកបាន។

ចប់ គុម្ពិយជាតក ទី៦។

## សាលិយជាតក ទី៧

CS sut.kn.jat.367 | ភាគទី ៥៩

(៣៦៧. សាឡិយជាតកំ (៥-២-៧ ))

[៨២] (ពោធិសត្វពោលថា) បុរសណា ឲ្យគេចាប់នូវពស់វែក ដោយបញ្ឆោតថា កូនសាលិកា បុរសអ្នកប្រៀនប្រដៅអាក្រក់នេះ ត្រូវពស់នោះចឹកស្លាប់ហើយ។

[៨៣] ជនណាប្រាថ្នាដើម្បីសម្លាប់នូវបុគ្គល ប៉ុន្តែមិនបានប្រហារ មិនបានសម្លាប់វិញ ជននោះ ក៏ត្រូវដេកស្លាប់ យ៉ាងនេះ ដូចជាបុរសដែលស្លាប់នេះ។

[៨៤] ជនណាប្រាថ្នាដើម្បីសម្លាប់នូវបុគ្គល អ្នកមិនបានបៀតបៀន មិនបានសម្លាប់វិញ ជននោះ ក៏ត្រូវដេកស្លាប់ យ៉ាងនេះ ដូចជាបុរសដែលស្លាប់នេះ។

[៨៥] បុរសអ្នកក្តាប់នូវអាចម៍ដី បាចទៅកាន់ទីច្រាសខ្យល់ ធុលីនោះ រមែងវិលមក ប៉ះបុរសនោះវិញ ដូចជាបុរសដែលស្លាប់នេះ។

[៨៦] បុគ្គលពាលណា ប្រទូស្តចំពោះជនដែលមិនបានប្រទូស្តតបវិញ ជាបុគ្គលបរិសុទ្ធ មិនមានទីទូល គឺកិលេស បាបរមែងវិលត្រឡប់

មករកបុគ្គលពាលនោះវិញ ដូចជាធុលីដ៏ល្អិត ដែលបុគ្គលបាចទៅកាន់ទីច្រាសខ្យល់។

ចប់ សាលិយជាតក ទី៧។

## តចសារជាតក ទី៨

CS sut.kn.jat.368 | ភាគទី ៥៩

(៣៦៨. តចសារជាតកំ (៥-២-៨))

[៨៧] (ស្តេចព្រហ្មទត្ត សួរថា) អ្នកទាំងឡាយ នៅក្នុងកណ្តាប់ដៃសត្រូវ ជាប់ដោយឃ្នាងឫស្សី តែនៅមានសម្បុរមុខស្រស់បស់ ព្រោះហេតុអ្វី ទើបអ្នកទាំងឡាយ មិនសោយសោក។

[៨៨] ពោធិសត្វ ទូលតបថា សេចក្តីចម្រើន សូម្បីមានប្រមាណតិច ក៏គេមិនដែលបាន ព្រោះសេចក្តីសោកខ្សឹកខ្សួលទេ ជនជាសត្រូវទាំងឡាយ ដឹងច្បាស់នូវបុរសនេះ ដែលកំពុងសោក ដល់នូវទុក្ខហើយ រមែងជាអ្នកមានចិត្តត្រេកអរ។

[៨៩] កាលណា បណ្ឌិតអ្នកឈ្លាស ក្នុងការវិនិច្ឆ័យនូវប្រយោជន៍ មិនញាប់ញ័រ ក្នុងអន្តរាយទាំងឡាយ កាលនោះ បុគ្គលជាសត្រូវជាទុក្ខ ព្រោះឃើញនូវមុខរបស់បណ្ឌិតនោះ មិនប្រែប្រួល នៅដូចអំពីដើម។

[៩០] បុគ្គលបាននូវប្រយោជន៍ ព្រោះការរាយមន្តក្តី ការប្រឹក្សាក្តី ពោលពាក្យពីរោះក្តី ការឲ្យសំណូកក្តី ប្រវេណីក្តី ក្នុងទីណាយ៉ាងណា ៗ ត្រូវប្រឹងប្រែងក្នុងទីនោះ យ៉ាងនោះ ៗ។

[៩១] កាលណាបុគ្គលដឹងថា ប្រយោជន៍នុ៎ះ ទោះបីអញ ឬបុគ្គលដទៃ មិនគប្បីបាន បណ្ឌិតមិនសោកស្តាយ ត្រូវអត់ធន់ ដោយគិតថា កម្មមានកំឡាំងមាំ ឥឡូវនេះ អាត្មាអញនឹងធ្វើដូចម្តេច។

ចប់ តចសារជាតក ទី៨។

## មិត្តវិន្ទុកជាតក ទី៩

CS sut.kn.jat.369 | ភាគទី ៥៩

(៣៦៩. មិត្តវិន្ទកជាតកំ (៥-២-៩))

[៩២] (មិត្តវិន្ទកៈ ពោលថា) ខ្ញុំបានធ្វើអំពើដូចម្តេច ដល់ពួកទេវតា ខ្ញុំបានធ្វើបាបដូចម្តេច ទើបចក្រសង្កត់លើក្បាល វិលកិនអំបែងក្បាលរបស់ខ្ញុំ ដោយជាប់បណា (បាបនោះ ដូចម្តេចខ្លះ)។

[៩៣] (ទេវបុត្រពោធិសត្វ ពោលថា) អ្នកឯងកន្លងផុតនូវប្រាសាទកែវផលិក ប្រាសាទប្រាក់ ប្រាសាទកែវមណី ប្រាសាទមាស ហើយមកក្នុងទីនេះ ដោយហេតុអ្វី។

[៩៤] (មិត្តវិន្ទកៈ ពោលថា) អ្នកចូរមើលខ្ញុំដល់នូវសេចក្តីវិនាស ដោយសេចក្តីសំគាល់នេះថា ភោគៈទាំងឡាយច្រើនជាងភោគៈទាំងឡាយក្នុងទីនេះ ប្រហែលជានឹងមានក្នុងទីនោះ។

[៩៥] (ពោធិសត្វពោលថា អ្នកចេញ) អំពីវេមានិកប្រេត ៤ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៨ នាក់ (ចេញ) អំពីវេមានិកប្រេត ៨ នាក់ទៅ ក៏បាននូវវេមានិកប្រេត ១៦ នាក់ (ចេញ) អំពីវេមានិកប្រេត ១៦ នាក់ទៅ ក៏បាននូវវេមានិកប្រេត ៣២ នាក់ អ្នកកាលប្រាថ្នាខ្លាំងពេក ទើបមកប្រទះនឹងចក្រ ចំណែកខាងចក្រ ក៏វិលកិនអម្បែងក្បាលរបស់សត្វ ដែលត្រូវសេចក្តីច្រណែនបៀតបៀន។

[៩៦] តណ្ហា ជាធម្មជាតិដ៏ទូលាយក្នុងខាងលើ ដែលសត្វបំពេញបានដោយក្រ ជាដំណើរដ៏រេះរាម ដោយអំណាចនៃសេចក្តីប្រាថ្នា ពួកជនណាជាប់ចំពាក់ដោយតណ្ហានោះ ពួកជននោះ រមែងទ្រទ្រង់នូវចក្រ។

ចប់ មិត្តវិន្ទុកជាតក ទី៩។

## បលាសជាតក ទី១០

CS sut.kn.jat.370 | ភាគទី ៥៩

(៣៧០. បលាសជាតកំ (៥-២-១០))

[៩៧] (ព្រះសម្មាសម្ពុទ្ធ សំដែងថា) ស្តេចហង្ស បាននិយាយនឹងបលាសទេវតា (ថា) ម្នាលសំឡាញ់ ដើមជ្រៃដុះ ដើមជ្រៃនោះ ដូចសត្រូវអង្គុយលើភ្លៅរបស់អ្នក នឹងកាត់បង់នូវជីវិតសង្ខាររបស់អ្នក។

[៩៨] (បលាសទេវតា និយាយថា) ខ្ញុំជាទីពឹងរបស់ដើមជ្រៃនុ៎ះ ដូចជាមាតាបិតា ដើមជ្រៃនុ៎ះនឹងជាទីពឹង (របស់ខ្ញុំ) ក្នុងកាលដែលវាចំរើនឡើង យ៉ាងនោះដែរ។

[៩៩] (ស្តេចហង្ស និយាយថា) អ្នកបណ្តុះនូវឈើមានជ័រ ដូចទឹកដោះ ជ្រៃដែលគួរខ្លាច ដូចសត្រូវនៅលើភ្លៅ ដោយហេតុណា ហេតុនោះ ទើបយើងប្រាប់អ្នកហើយនឹងទៅ ការចំរើនឡើងនៃដើមជ្រៃនោះ មិនពេញចិត្ត (ខ្ញុំ) ទេ។

[១០០] (បលាសទេវតា និយាយថា) ឥឡូវនេះ ដើមជ្រៃញុំាងអញឲ្យភ័យ ភ័យដ៏ធំមកដល់អញ ព្រោះមិនយល់ពាក្យនៃស្តេចហង្ស ជាពាក្យដូចជាភ្នំសិនេរុដ៏ធំ។

[១០១] (ព្រះសម្មាសម្ពុទ្ធ សំដែងថា) អន្តរាយណា កាលចំរើនឡើង រមែងបំផ្លាញនូវទីពឹង សេចក្តីចំរើននៃអន្តរាយនោះ ជនអ្នកឈ្លាសវៃ មិនសរសើរឡើយ អ្នកប្រាជ្ញកាលរង្កៀសនឹងសេចក្តីវិនាស រមែងព្យាយាម ដើម្បីសម្លាប់នូវមូលហេតុ នៃសេចក្តីអន្តរាយនោះ។

ចប់ បលាសជាតក ទី១០។

ចប់ វណ្ណារោហវគ្គ ទី២។

## អឌ្ឍវគ្គ ទី៣

CS sut.kn.jat.v05.03 | ភាគទី ៥៩

**(៣. អឌ្ឍវគ្គោ)**

### ទីឃីតិកោសលជាតក ទី១

CS sut.kn.jat.371 | ភាគទី ៥៩

**(៣៧១. ទីឃីតិកោសលជាតកំ (៥-៣-១))**

[១០២] (ទីឃាវុកុមារ ពោលថា) បពិត្រព្រះរាជា ព្រះអង្គធ្លាក់មកក្នុងអំណាចរបស់ខ្ញុំ យ៉ាងនេះ បរិយាយណា ញ៉ាំងព្រះអង្គឲ្យរួចចាកទុក្ខ បរិយាយណាមួយនោះ មានដែរឬ។

[១០៣] (ព្រះរាជា ពោលថា) ម្នាលអ្នក ខ្ញុំធ្លាក់មកក្នុងអំណាចរបស់អ្នក ប្រាកដយ៉ាងនេះ បរិយាយណា ញ៉ាំងខ្ញុំឲ្យរួចចាកទុក្ខ បរិយាយណាមួយនោះ របស់យើងមិនមានទេ។

[១០៤] (ទីឃាវុកុមារ ពោលថា) បពិត្រព្រះរាជា គុណជាតដទៃអំពីសុចរិត ទីពឹងមិនបានទេ បពិត្រព្រះរាជា គុណជាតដទៃអំពីសុភាសិត ទីពឹងមិនបានទេ ទ្រព្យក្រៅពីនេះ ក៏យ៉ាងនោះដែរ។

[១០៥] បុគ្គលទាំងឡាយណា ចងនូវពៀរនោះ (ដោយគិតថា) អ្នកឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក (ទ្រព្យ) របស់អញ ពៀររបស់បុគ្គលទាំងឡាយនោះ រមែងមិនរម្ងាប់ទេ លុះតែបុគ្គលទាំងឡាយណា មិនចងនូវពៀរនោះ (ដោយគិតថា) អ្នកឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក (ទ្រព្យ) របស់អញ ពៀររបស់បុគ្គលទាំងឡាយនោះ ទើបរម្ងាប់បាន។

[១០៦] តាំងពីកាលណាមក ពៀរទាំងឡាយក្នុងលោកនេះ រមែងមិនរម្ងាប់ដោយពៀរទេ ពៀរទាំងឡាយ រមែងរម្ងាប់បានដោយមិនមានពៀរ នេះជាបុរាណធម៌។

ចប់ ទីឃីតិកោសលជាតក ទី១។

### មិគបោតកជាតក ទី២

CS sut.kn.jat.372 | ភាគទី ៥៩

**(៣៧២. មិគបោតកជាតកំ (៥-៣-២))**

[១០៧] (ព្រះឥន្ទ្រពោលថា) លោកចេញចាកផ្ទះ ជាបុគ្គលមិនមានផ្ទះ ជាសមណៈ លោកសោកស្តាយចំពោះសត្វដែលទៅកាន់លោកខាងមុខណា សេចក្តីសោកស្តាយនោះ មិនប្រពៃទេ។

[១០៨] (តាបស តបថា) បពិត្រសក្កៈ សេចក្តីស្រឡាញ់ រមែងកើតឡើងក្នុងហឫទ័យ ដោយការនៅរួមរបស់មនុស្ស ឬរបស់ម្រឹគ ខ្ញុំមិនអាចមិនសោយសោកនឹងម្រឹគនោះបានទេ។

[១០៩] (សក្កទេវរាជ ពោលថា) ពួកជនណា យំនឹងបុគ្គលដែលស្លាប់ទៅហើយ ឬនឹងស្លាប់ បុគ្គលនោះ រមែងយំ រមែងរវើរវាយ (ឥតឈប់) បពិត្រឥសី ព្រោះហេតុនោះ លោកកុំយំឡើយ ព្រោះថា ពួកសប្បុរស បានពោលនូវការយំ ថាជាការឥតអំពើ។

[១១០] បពិត្រព្រហ្ម ប្រសិនបើបុគ្គលដែលស្លាប់ លះលោកនេះទៅហើយ គប្បីក្រោកឡើងបាន ដោយការយំ យើងទាំងអស់ចូរប្រជុំគ្នាយំនឹងពួកញាតិនៃគ្នានឹងគ្នា។

[១១១] (តាបស ពោលថា) អ្នកបានស្រោចស្រប់នូវខ្ញុំ ដែលភ្លើង គឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញ៉ាំសេចក្តីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលស្រោចនូវភ្លើងដែលឆេះឆ្នាំងខ្លាញ់ដោយទឹក សរ គឺសេចក្តីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្តីសោកនោះ ខ្ញុំបានដកចេញហើយ អ្នកណាបានបន្ទោបង់សេចក្តីសោក ព្រោះបុត្តដល់ខ្ញុំ ដែលត្រូវសេចក្តីសោកបៀតបៀន ខ្ញុំនោះ ជាអ្នកមានសរ គឺសេចក្តីសោកដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលវាសវៈ ខ្ញុំលែងសោកស្តាយ លែងយំទួញ ព្រោះបានស្តាប់ពាក្យរបស់អ្នក (នោះ)។

ចប់ មិគបោតកជាតក ទី២។

### មូសិកជាតក ទី៣

CS sut.kn.jat.373 | ភាគទី ៥៩

**(៣៧៣. មូសិកជាតកំ (៥-៣-៣))**

[១១២] (ព្រះរាជាពោលថា) អ្នកផងនិយាយរវើរវាយថា នាងមូសិកាទាសីទៅឯណា ទៅក្នុងទីណា អញតែម្នាក់ឯងដឹងថា នាងមូសិកាទាសី ត្រូវគេសម្លាប់ (ទម្លាក់ទៅ) ក្នុងស្រះ។

[១១៣] (ព្រះរាជា ពោលថា) អ្នកគិតរកនូវឱកាសនៃការប្រហារដូច្នេះ បែរងើកងាក ដូចសត្វលា ព្រោះហេតុណា ហេតុនោះ អ្នកសម្លាប់នូវនាងមូសិកាទាសី (ទម្លាក់ទៅ) ក្នុងស្រះ ប្រាថ្នាដើម្បីស៊ីនូវបាយដំណើបឬ។

[១១៤] (ព្រះរាជា ពោលតទៅទៀតថា) ម្នាលអ្នកឥតប្រាជ្ញា អ្នកជាបុគ្គលនៅក្មេងតូច តាំងនៅក្នុងបឋមវ័យ កាន់យកនូវគ្រឿងប្រហារមានដងដ៏វែងនេះ យើងមិនឲ្យជីវិតដល់អ្នកទេ។

[១១៥] (ព្រះរាជា ពោលគាថាដ៏ពិសេសថា) អញមិនមែនរួច (អំពីសេចក្ដីស្លាប់) ព្រោះវិមានលើអាកាស ឬព្រោះបុត្រប្រាកដស្មើដោយអវយវៈបានទេ ព្រោះថាអញត្រូវកូនប្រាជ្ញា (នឹងសម្លាប់) បានរួចខ្លួន ព្រោះគាថាទាំងឡាយ។

[១១៦] បុគ្គលគប្បីសិក្សានូវសុតៈទាំងពួង ទោះបីថោកទាប ឧក្រិដ្ឋ ឬយ៉ាងកណ្ដាល គប្បីដឹងនូវប្រយោជន៍នៃសុតៈទាំងអស់ តែមិនគប្បីប្រកបនូវសុតៈទាំងអស់ទេ សុតៈនាំមកនូវប្រយោជន៍ក្នុងកាលណា កាលប្រាកដដូច្នោះ រមែងមានប្រាកដ។

ចប់ មូសិកជាតក ទី៣។

## ចុល្លធនុគ្គហជាតក ទី៤

CS sut.kn.jat.374 | ភាគទី ៥៩

**(៣៧៤. ចូឡធនុគ្គហជាតកំ (៥-៣-៤ ))**

[១១៧] (ស្ត្រីនោះនិយាយថា) ម្នាលព្រាហ្មណ៍ អ្នកនាំយកទ្រព្យទាំងអស់ ឆ្លងទៅកាន់ត្រើយនាយ ម្នាលអ្នកដ៏ចំរើន អ្នកចូរត្រឡប់មកវិញយ៉ាងឆាប់រួសរាន់ សូមអ្នកចម្លងខ្ញុំឥឡូវនេះផង។

[១១៨] (ចោរនិយាយថា) នាងផ្លាស់ប្ដូរយកអញ អ្នកមិនស្និទស្នាល ដោយប្ដីដែលស្និទស្នាលអស់កាលយូរ ផ្លាស់ប្ដូរយកអញដែលមិនមែនជាប្ដីទៀងទាត់ ដោយប្ដីទៀងទាត់ នាងនឹងផ្លាស់ប្ដូរយកប្រុសឯទៀតនឹងអញមិនខាន អញនឹងទៅកាន់ទីឆ្ងាយជាងទីនេះ។

[១១៩] (ចចក និយាយថា) ស្ត្រីនេះជាអ្វី ទើបធ្វើនូវសំណើចយ៉ាងខ្លាំងទៀបគុម្ពរទើក ការរាំក្ដី ច្រៀងក្ដី ប្រគំក្ដី ដែលគេតាំងទុកដោយល្អក្នុងទីនេះ មិនមានទេ ម្នាលស្ត្រីមានទ្រគាកល្អ មានរូបល្អ ហេតុដូចម្ដេច ទើបនាងសើចក្អាកក្អាយក្នុងកាលគួរយំ។

[១២០] (នាងនោះ និយាយថា) ម្នាលចចកជម្ពុកៈពាលឥតប្រាជ្ញា ឯងជាសត្វគ្មានប្រាជ្ញា ឯងសាបសូន្យចាកត្រី និងដុំសាច់ សព្វាប់សញ្ជឹងដូចសត្វកំព្រា។

[១២១] (ចចក និយាយថា) ទោសរបស់ជនទាំងឡាយឯទៀត ឃើញបានដោយងាយ ចំណែកខាងទោសរបស់ខ្លួន ឃើញបានដោយក្រណាស់ នាងឯងជាស្ត្រីសាបសូន្យចាកប្ដី និងសហាយ សព្វាប់សញ្ជឹងជាងអញទៅទៀត។

[១២២] (នាងនោះ និយាយថា) ម្នាលស្ដេចម្រឹគជម្ពុកៈ អ្នកនិយាយយ៉ាងណា ពាក្យនុ៎ះ យ៉ាងហ្នឹងហើយ ខ្ញុំនោះទៅអំពីទីនេះ នឹងលុះអំណាចប្ដីដោយពិត។

[១២៣] (សក្កទេវរាជ ពោលថា) អ្នកណាហ៊ានលួចភាជន៍ដី អ្នកនោះ គង់ហ៊ានលួចភាជន៍សម្រិទ្ធិទៀត បាបដែលនាងបានធ្វើរួចហើយ នាងនឹងធ្វើយ៉ាងនេះទៀតមិនលែងឡើយ។

ចប់ ចុល្លធនុគ្គហជាតក ទី៤។

## កបោតកជាតក ទី៥

CS sut.kn.jat.375 | ភាគទី ៥៩

**(៣៧៥. កបោតជាតកំ (៥-៣-៥))**

[១២៤] (ក្អែក និយាយថា) ឥឡូវនេះ អញបានសុខ មិនមានរោគ មិនមានសត្រូវ ដូចបន្លា (ព្រោះ) ព្រាបហើរចេញទៅហើយ ឥឡូវនេះអញនឹងធ្វើនូវសេចក្ដីត្រេកអរនៃចិត្ត ព្រោះថាសាច់ និងអន្លក់ រមែងញុំាងអញឲ្យមានកំឡាំង។

[១២៥] (ព្រាប និយាយចំអកថា) នេះជាកុកអ្វី ជាសត្វមានកំប៉ោយ ជាចោរ មានពពកជាជីតា នៃនាងកុក នាងចូរមកខាងអាយ ក្អែកជាសម្លាញ់របស់ខ្ញុំ កាច។

[១២៦] (ក្អែក និយាយថា) អ្នកមិនគួរសើចនឹងខ្ញុំ ព្រោះឃើញខ្ញុំ (ដល់នូវសេចក្ដីទុក្ខ) យ៉ាងនេះ ដែលត្រូវកូនអ្នកគ្រូ ដកស្លាបប្រឡាក់ដោយម្សៅម៉ត់។

[១២៧] (ព្រាបនិយាយថា) អ្នកមានខ្លួនងូតស្អាត ស្រលាបដោយល្អ ឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹក អ្នកមានកែវពៃទូរ្យព្វដ៏កនឹងទៅកាន់នគរកជង្គលៈឬ។

[១២៨] (ក្អែក និយាយថា) សត្វជាមិត្ត ឬជាសត្រូវរបស់អ្នក កុំទៅកាន់នគរកជង្គលៈឡើយ ពួកជនក្នុងនគរនោះ បានបោចរោមហើយចងប្រឡៅត្រង់ក។

[១២៩] (ព្រាប និយាយថា) ម្នាលសម្លាញ់ អ្នកនឹងដល់នូវអំពើយ៉ាងនេះទៀត ព្រោះមារយាទរបស់អ្នកតែយ៉ាងហ្នឹង ភោគៈទាំងឡាយរបស់មនុស្ស មិនមែនសត្វស្លាបបរិភោគបានទេ។

ចប់ កបោតកជាតក ទី៥។

ចប់ អឌ្ឍវគ្គ ទី៣។

ឧទ្ទាននៃជាតកនោះគឺ

និយាយអំពីវណ្ណារោហជាតក ១ សីលវិមំសជាតក ១ ហិរិជាតក ១ ខជ្ជោបនកជាតក ដែលបុគ្គលបានប្រយោជន៍ ១ ស្វាមានមុខល្អ ១ (គុម្ពិយជាតក ១) សាលិយជាតក ១ មិត្តដ៏ប្រសើរ ១ ចក្ក ១ បលាសជាតក ១ ព្រះរាជកុមារ (ព្រះនាមទីឃិតិ) ១ មិគបោតកជាតក ១

បាយដំណើប ១ ចចកពាល ១ កបោតកជាតក ១ រួមជា ១៥ ជាតក។

ឧទ្ទានវគ្គ មានក្នុងបញ្ចកនិបាតនោះគឺ

អំពីមណិកុណ្ឌលវគ្គ (និយាយអំពីបុគ្គលសាបសូន្យចាកដែនជាដើម) វណ្ណារោហវគ្គ អំពីវគ្គខាងលើ មិនស្មើគ្នា វគ្គទាំងឡាយ ២០ ដែលព្រះសុគតសំដែងទុកល្អហើយ ហៅថា ជាតក ព្រះសង្គីតិកាចារ្យ បានសំដែងនូវភាពនៃព្រហ្មចរិយធម៌ដ៏ប្រសើរ របស់ព្រះគាថាទាំងឡាយមានអត្ថ ព្រមទាំងព្យញ្ជនៈ (បរិបូណ៌)។

ចប់ បញ្ចកនិបាត។

# ឆក្កនិបាតជាតក

CS sut.kn.jat.v06 | ភាគទី ៥៩

(៦. ឆក្កនិបាតោ)

## អាវារិយវគ្គ ទី១

CS sut.kn.jat.v06.01 | ភាគទី ៥៩

(១. អវារិយវគ្គោ)

### អាវារិយជាតក ទី១

CS sut.kn.jat.376 | ភាគទី ៥៩

**(៣៧៦. អវារិយជាតកំ (៦-១-១))**

[១៣០] (ព្រះពោធិសត្វ ទូន្មានថា) បពិត្រម្ចាស់ផែនដី សូមព្រះអង្គកុំខ្ញាល់ បពិត្រព្រះអង្គប្រសើរលើរថ សូមព្រះអង្គកុំខ្ញាល់ ព្រះរាជាកាលមិនខ្ញាល់តបចំពោះបុគ្គលដែលខឹង រាស្ត្រតែងបូជា អាត្មារមែងប្រៀនប្រដៅមនុស្សក្នុងទីទាំងពួង គឺក្នុងស្រុក ឬក្នុងព្រៃ ទីទាប ឬទីទួល បពិត្រព្រះអង្គប្រសើរលើរថ សូមព្រះអង្គកុំខ្ញាល់។

[១៣១] (ព្រះសាស្តា ត្រាស់ថា) នាយទូកក្នុងទន្លេគង្គា ឈ្មោះអាវារិយបិតា តែងចម្លងនូវជនមុន ហើយទើបសុំយកនូវថ្លៃឈ្នួលក្នុងកាលខាងក្រោយ ហេតុនោះ ការឈ្លោះប្រកែក ក៏រមែងមានដល់គាត់ គាត់ក៏មិនចម្រើនដោយភោគសម្បត្តិទាំងឡាយ។

[១៣២] (តាបសពោធិសត្វ ទូន្មានថា) ម្នាលនាយទូក ចូរអ្នកសុំយកថ្លៃចំពោះមនុស្ស ដែលមិនទាន់ឆ្លងទៅកាន់ត្រើយនាយឲ្យហើយសិន ព្រោះថាចិត្តមនុស្សដែលឆ្លងហើយផ្សេង ចិត្តរបស់មនុស្សអ្នកស្វែងរកត្រើយ (ត្រូវការឆ្លង) ផ្សេង។

[១៣៣] អាត្មាតែងប្រៀនប្រដៅមនុស្សក្នុងទីទាំងពួង គឺក្នុងស្រុក ឬក្នុងព្រៃ ទីទាប ឬទីទួល ម្នាលនាយទូក ចូរអ្នកកុំខឹង។

[១៣៤] (ព្រះសាស្តា ត្រាស់ថា) ព្រះរាជា បានប្រទានស្រុកសួយ ដោយពាក្យប្រៀនប្រដៅណា នាយទូកក៏ទះមាត់ (ឥសី) ដោយពាក្យប្រៀនប្រដៅនោះដែរ។

[១៣៥] ភាជន៍បាយក៏បែក ភរិយាក៏ត្រូវខ្លួនប្រហារ គភ៌របស់ភរិយាក៏ធ្លាក់ចុះទៅលើផែនដី មនុស្សពាលមិនញុំាំងប្រយោជន៍ឲ្យចំរើនដោយឱវាទនោះ ដូចជាម្រឹគមិនចម្រើនដោយមាសប្រាក់។

ចប់ អាវារិយជាតក ទី១។

### សេតកេតុជាតក ទី២

CS sut.kn.jat.377 | ភាគទី ៥៩

**(៣៧៧. សេតកេតុជាតកំ (៦-១-២))**

[១៣៦] (អាចារ្យទិសាបាមោក្ខ ទូន្មានសេតកេតុព្រាហ្មណ៍ថា) ម្នាលអ្នក ចូរអ្នកកុំខឹង ព្រោះថាការខឹង ជាការមិនល្អទេ អ្នកមិនដែលឃើញ មិនដែលឮ នូវទិសជាច្រើនទេ ម្នាលអ្នកឈ្មោះសេតកេតុ មាតាបិតា ទុកជាទិស (ខាងដើម អ្នកប្រាជ្ញទាំងឡាយ) ពោលថា អាចារ្យទុកជា (ទិសខាងស្តាំ) ប្រសើរជាងទិសទាំងឡាយ។

[១៣៧] ពួកជនជាគ្រហស្ថ ជាអ្នកឲ្យបាយ ទឹក និងសំពត់ ជាអ្នកហៅរក (នូវអ្នកទទួលទាន) ណា អ្នកប្រាជ្ញទាំងឡាយ មានព្រះពុទ្ធជាដើម ពោលនូវបុគ្គលនោះថា ជាទិស (ខាងលើ) ម្នាលសេតកេតុ បុគ្គលមានទុក្ខ ត្រឡប់ជាបានសេចក្ដីសុខវិញព្រោះដល់នូវទិស (និព្វាន) ណា ទិសនុ៎ះ ជាទិសដ៏ប្រសើរ។

[១៣៨] (ព្រះរាជា សួរបុរោហិតថា) ជដិលទាំងឡាយណា ទ្រទ្រង់ស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រកបដោយមន្ទិល មានសភាពដ៏សៅហ្មង តែងស្វាធ្យាយនូវមន្តទាំងឡាយ ជដិលទាំងនោះ (បិតនៅ) ក្នុងសេចក្ដីព្យាយាមជារបស់មនុស្ស ដឹងច្បាស់នូវលោកនេះ បានរួចចាកអបាយឬទេ។

[១៣៩] (បុរោហិត ទូលតបថា) បពិត្រព្រះរាជា បុគ្គលជាពហុស្សូត ធ្វើបាបកម្មទាំងឡាយ មិនប្រព្រឹត្តធម៌ សូម្បីចេះដឹងច្រើនហើយអាស្រ័យការចេះដឹងនោះ មិនបានដល់នូវការប្រព្រឹត្តិ ក៏រមែងមិនបានរួចចាកទុក្ខឡើយ។

[១៤០] (ព្រះរាជា ពោលថា) បុគ្គលអ្នកចេះច្រើន អាស្រ័យនូវការចេះដឹងនោះ តែមិនបានដល់នូវការប្រព្រឹត្តិ ក៏រមែងមិនរួចចាកទុក្ខ

ខ្ញុំសំគាល់ថា ការចេះដឹង មិនមានផលទេ ការប្រព្រឹត្តិ ព្រមទាំងការសង្រួមទៀងទាត់ ទើបមានផល។

[១៩១] (បុរោហិតទូលថា) ការចេះដឹង មិនមែនឥតផលទេ ការប្រព្រឹត្តិ ព្រមទាំងការសង្រួមនោះឯង ក៏មិនទៀងទាត់ដែរ បុគ្គលដល់នូវកិត្តិសព្ទ ព្រោះអាស្រ័យការចេះដឹង បុគ្គលមានខ្លួនទូន្មានបានហើយ ដល់នូវព្រះនិព្វាន ព្រោះការប្រព្រឹត្តិ។

ចប់ សេតកេតុជាតក ទី ២។

## ទរីមុខជាតក ទី៣

CS sut.kn.jat.378 | ភាគទី ៥៩

(៣៧៨. ទរីមុខជាតកំ (៦-១-៣ ))

[១៩២] (ព្រះបច្ចេកពុទ្ធទរីមុខ ឲ្យឱវាទដល់ព្រះរាជាព្រហ្មទត្តថា) កាមទាំងឡាយ ដូចភក់ផង កាមទាំងឡាយ ដូចគ្រឿងស្អិតផង នេះជាភ័យមានឫសគល់ ៣ យ៉ាង ដែលព្រះសម្ពុទ្ធពោលទុកហើយ កាមទាំងឡាយ ដូចធូលីផង ដូចផ្សែងផង ដែលអាត្មាប្រកាសហើយ បពិត្រព្រះរាជាព្រហ្មទត្ត សូមព្រះអង្គលះបង់ (កាមទាំងនោះ) ហើយបួសចុះ។

[១៩៣] (ព្រះរាជាព្រហ្មទត្ត ពោលថា) បពិត្រព្រាហ្មណ៍ ខ្ញុំជាអ្នកជាប់ចំពាក់ ត្រេកអរជ្រុលជ្រប់ក្នុងកាមទាំងឡាយ ជាអ្នកត្រូវការដោយជីវិត មិនអាចដើម្បីលះនូវកាម មានសភាពគួរខ្លាចនោះបានទេ ខ្ញុំនឹងធ្វើបុណ្យទាំងឡាយច្រើន។

[១៩៤] (ព្រះបច្ចេកពុទ្ធ ពោលថា) បុគ្គលណា កាលគេប្រាថ្នាសេចក្ដីចំរើន អនុគ្រោះដោយប្រយោជន៍ ប្រៀនប្រដៅ តែមិនធ្វើតាមពាក្យប្រៀនប្រដៅ សំគាល់ថា នេះឯងប្រសើរ ជាមនុស្សល្ងង់ខ្លៅ រមែងចូលទៅកាន់គភ៌ញយ ៗ។

[១៩៥] បុគ្គលល្ងង់ខ្លៅនោះ រមែងចូលទៅកាន់នរក មានសភាពដ៏ពន្លឹក ជាទីមិនស្អាតដល់ពួកកុលបុត្តអ្នកស្អាត ពេញដោយមូត្រ និងករីស សត្វទាំងឡាយណា ជាអ្នកមិនទាន់ប្រាសចាករាគៈ ជាប់ចំពាក់ក្នុងកាមទាំងឡាយ សត្វទាំងឡាយនោះ រមែងមិនលះបង់នូវសកាយៈ (ការនៅក្នុងគភ៌)។

[១៩៦] សត្វទាំងឡាយ ប្រសូត (ចាកគភ៌នៃមាតា) រមែងជាប់ដោយលាមក ប្រឡាក់ដោយឈាម ជាប់ដោយរំអិល ប៉ះពាល់នូវទ្វារជាទីប្រសូតណា ។ ដោយកាយ ក្នុងខណៈនោះ ទ្វារទាំងអស់នោះ ជារបស់មិនស្អាត សុទ្ធតែជាទុក្ខទាំងអស់។

[១៩៧] អាត្មាឃើញទើបពោល មិនមែនស្ដាប់អំពីបុគ្គលដទៃទេ អាត្មារលឹកឃើញ នូវបុព្វេនិវាសច្រើន។ (ព្រះសម្មាសម្ពុទ្ធ ត្រាស់ថា) ព្រះបច្ចេកពុទ្ធ ព្រះនាមទរីមុខៈ ពន្យល់ស្ដេចព្រហ្មទត្ត មានប្រាជ្ញាល្អ ដោយគាថាទាំងឡាយដ៏វិចិត្រដែលសំដែងហើយដោយល្អ។

ចប់ ទរីមុខជាតក ទី ៣។

## នេរុជាតក ទី៤

CS sut.kn.jat.379 | ភាគទី ៥៩

(៣៧៩. នេរុជាតកំ (៦-១-៤))

[១៩៨] (សុវណ្ណហង្សជាប្អូន និយាយថា) ហ្វូងក្អែកព្រៃ ក្អែកស្រុក និងយើង ជាសត្វប្រសើរជាងពួកសត្វស្លាប មកដល់ភ្នំនេះ មានសម្បុរប្រហែលគ្នាទាំងអស់។

[១៩៩] ពួកសីហៈ ខ្លាធំ សត្វស្លាប ម្រឹគថោកទាបក្នុងទីនេះ មានសម្បុរប្រហែលគ្នាទាំងអស់ តើភ្នំនេះ ឈ្មោះអ្វី។

[២០០] (សុវណ្ណហង្សពោធិសត្វ ពោលថា) មនុស្សទាំងឡាយ ដឹងថាភ្នំដ៏ឧត្ដមនេះឈ្មោះនេរុ សព្វសត្វទាំងឡាយនៅក្នុងទីនេះ ជាសត្វបរិបូណ៌ដោយពណ៌សម្បុរ។

[២០១] (សុវណ្ណហង្សជាប្អូន ពោលថា) ការមិនរាប់អាន ឬការមើលងាយនូវពួកសប្បុរស ឬក៏ការរាប់អានបុគ្គលថោកទាប មានក្នុងទីណា បុគ្គលមិនគប្បីនៅក្នុងទីនោះទេ។

[២០២] មនុស្សខ្ជិល និងមនុស្សឧស្សាហ៍ មនុស្សក្លៀវក្លា និងមនុស្សខ្លាច គេបូជាស្មើគ្នា ក្នុងទីណា សប្បុរសទាំងឡាយ រមែងមិននៅក្នុងទីនោះ ជាភ្នំមិនធ្វើឲ្យប្លែកបាន។

[២០៣] ភ្នំនេរុនេះ មិនចែកនូវសត្វឲ្យថោកទាប ឲ្យខ្ពង់ខ្ពស់ ឲ្យជាកណ្ដាល ភ្នំនេរុមិនធ្វើឲ្យប្លែកគ្នាបាន បើដូច្នោះ យើងទាំងឡាយលះបង់នូវភ្នំនេរុចោល។

ចប់ នេរុជាតក ទី៤។

## អាសង្កជាតក ទី៥

CS sut.kn.jat.380 | ភាគទី ៥៩

(៣៨០. អាសង្កជាតកំ (៦-១-៥ ))

[២០៤] (នាងអាសង្កាកុមារិកា ពោលថា) វល្លិឈ្មោះអាសាវតី កើតក្នុងឧទ្យានឈ្មោះចិត្តលតាវ័ន វល្លិនោះ ក្នុងមួយពាន់ឆ្នាំ ទើបកើតផ្លែ ១។

[២០៥] ទោះបើផ្លែមាននៅក្នុងទីឆ្ងាយដល់ម្ល៉េះ ពួកទេវតានៅតែចូលទៅរកវល្លិនោះ បពិត្រព្រះរាជា សូមព្រះអង្គប្រាថ្នាចុះ សេចក្ដីប្រាថ្នារមែងមានផល នាំមកនូវសេចក្ដីសុខ។

[១៥៦] អំបាលសត្វស្លាបនោះ (កុក) នៅប្រាថ្នាបាន អំបាលសត្វមានកំណើតពីរ គង់ប្រាថ្នាបាន ថ្វីបើទន្លេមាននៅក្នុងទីឆ្ងាយ សេចក្តីប្រាថ្នារបស់កុកនោះ គង់សម្រេចមិនខាន បពិត្រព្រះរាជា សូមព្រះអង្គប្រាថ្នាចុះ សេចក្តីប្រាថ្នារមែងមានផលជាសុខ។

[១៥៧] (ព្រះរាជាព្រហ្មទត្ត ពោលថា) នាងបានញុំាងខ្ញុំឲ្យឆ្អែតដោយវាចា មិនឆ្អែតដោយការងារ ដូចជាផ្កាកម្រងនៃឈើសោរេយ្យក: មានតែពណ៌ មិនមានក្លិន។

[១៥៨] បុគ្គលណា មិនឲ្យ មិនលះបង់ភោគ: គ្រាន់តែធ្វើនូវវាចាដ៏ពីរោះ ជាវាចាឥតផល ចំពោះមិត្តទាំងឡាយ តំណ (នៃសេចក្តីស្និទ្ធស្នាល) របស់បុគ្គលនោះ រមែងសាបសូន្យទៅ ដោយហេតុនោះឯង។

[១៥៩] ពិតណាស់ បុគ្គលធ្វើនូវអំពើណា គប្បីនិយាយនូវអំពើនោះ មិនធ្វើនូវអំពើណា មិនគប្បីនិយាយនូវអំពើនោះ បណ្ឌិតទាំងឡាយ រមែងកំណត់ដឹងនូវបុគ្គលអ្នកមិនធ្វើ គ្រាន់តែនិយាយ។

[១៦០] ពលរបស់ខ្ញុំអស់ហើយ ទាំងស្បៀងអាហារក៏មិនមាន ខ្ញុំរង្កៀសចំពោះការវិនាសនៃជីវិត បើដូច្នោះ ខ្ញុំនឹងទៅឥឡូវនេះ។

[១៦១] (នាងអាសង្កា ទូលថា) បពិត្រព្រះអង្គ ទ្រង់ប្រសើរលើរថ ពាក្យណាដែលមានក្នុងឈ្មោះ ពាក្យនុ៎ះឯង ជាឈ្មោះរបស់ខ្ញុំព្រះអង្គ បពិត្រមហារាជ សូមព្រះអង្គរង់ចាំចុះ ខ្ញុំព្រះអង្គនឹងអញ្ជើញបិតាសិន។

ចប់ អាសង្កជាតក ទី ៥។

## មិគលោបជាតក ទី៦

CS sut.kn.jat.381 | ភាគទី ៥៩

### (៣៨១. មិគាលោបជាតកំ (៦-១-៦))

[១៦២] (ត្មាតពោធិសត្វ និយាយនឹងកូនថា) ម្នាលមិគលោប: ដំណើររបស់អ្នកប្រាកដដូច្នោះ មិនពេញចិត្តអញទេ ម្នាលកូន ដ្បិតអ្នកហើរទៅខ្ពស់ពេក ម្នាលកូន អ្នកសេពគប់នូវទីមិនមែនផែនដី។

[១៦៣] ផែនដីប្រាកដដល់អ្នក ដូចជាស្រែមានជ្រុង ៤ ម្នាលកូន ចូរអ្នកត្រឡប់អំពីទីនោះមកវិញ កុំទៅហួសអំពីទីនេះឡើយ។

[១៦៤] ពួកសកុណជាតិឯទៀត មានស្លាបជាយាន ទៅកាន់អាកាស ពួកសត្វទាំងនោះ សំគាល់ខ្លួនថា ស្មើដោយវត្ថុដ៏ទៀងទាត់ ត្រូវកំឡាំងខ្យល់បក់បោកវិនាស។

[១៦៥] (ព្រះសម្មាសម្ពុទ្ធ ទ្រង់សំដែងថា) មិគលោប: មិនធ្វើតាមពាក្យប្រដៅរបស់បិតាចាស់ ឈ្មោះអបរណ្ណ: ហើរកន្លងនូវខ្យល់វេរម្ភ បានទៅដល់អំណាចនៃខ្យល់ព្យុះ។

[១៦៦] កូនក្តី ប្រពន្ធក្តី ឬសត្វឯទៀត ជាអ្នកចិញ្ចឹមជីវិតតាមមិគលោប:នោះ ពួកសត្វស្លាបទាំងអស់ ក៏ដល់នូវសេចក្តីវិនាស ព្រោះទិជជាតិ (មិគលោប:) មិនធ្វើតាមឱវាទ។

[១៦៧] បុគ្គលណា មិនយល់នូវពាក្យរបស់បុគ្គលចាស់ទុំ ក្នុងលោកនេះ បុគ្គលនោះ (ដល់នូវសេចក្តីវិនាស) ដូចជាត្មាតកន្លងពាក្យប្រៀនប្រដៅ ជាសត្វភ្លើតភ្លើនត្រាច់ទៅកាន់ទីហួសដែន ជនទាំងអស់ដល់នូវសេចក្តីវិនាស ព្រោះមិនធ្វើតាមពាក្យប្រដៅរបស់ព្រះពុទ្ធ។

ចប់ មិគលោបជាតក ទី៦។

## សិរិកាឡកណ្ណិជាតក ទី៧

CS sut.kn.jat.382 | ភាគទី ៥៩

### (៣៨២. សិរិកាឡកណ្ណិជាតកំ (៦-១-៧ ))

[១៦៨] (សុចិបរិវារសេដ្ឋីពោធិសត្វ សួរនាងទេវធីតាឈ្មោះកាឡកណ្ណិថា) នាងជាអ្វី មានវណ្ណ:ខ្មៅ ទាំងមិនមានគ្រឿងមើលជាទីស្រឡាញ់ នាងជាអ្វី ឬជាធីតារបស់អ្នកណា យើងស្គាល់នាងដូចម្តេចបាន។

[១៦៩] (នាងកាឡកណ្ណិ ឆ្លើយថា) ខ្ញុំឈ្មោះចណ្ឌិយា ជាធីតានៃមហារាជ ឈ្មោះវិរូបក្ខ: ខ្ញុំមានសម្បុរខ្មៅ ជាស្ត្រីឥតបុណ្យ ពួកទេវតារមែងស្គាល់ខ្ញុំថា ជាកាឡកណ្ណិ អ្នកកាលបើខ្ញុំសូមឱកាស សូមឲ្យ យើងនឹងនៅក្នុងសំណាក់នៃអ្នក។

[១៧០] (សេដ្ឋីពោធិសត្វ សួរថា) នាងដឹកល់ចិត្តចំពោះបុរសមានសីលធម៌ដូចម្តេច មានសមាចារដូចម្តេច ម្នាលនាងកាឡី នាង ខ្ញុំសួរហើយ ក៏ចូរប្រាប់មក យើងនឹងស្គាល់នាង ដូចម្តេចបាន។

[១៧១] (នាងកាឡកណ្ណិ ឆ្លើយប្រាប់ថា) បុរសណា ជាអ្នកលុបគុណ ប្រឡងវាសនា ប្រណាំងប្រជែង ច្រណែន កំណាញ់ ជាអ្នកអួតអាងបានទ្រព្យហើយបំផ្លាញទៅវិញ បុរសនោះ ជាទីត្រេកអររបស់ខ្ញុំ។

[១៧២] បុរសណា ច្រើនក្រោធ ចងសេចក្តីក្រោធទុក ញុះញង់បំបែកមិត្ត ពោលពាក្យចាក់ដោតដូចបន្លា ពោលពាក្យទ្រគោះ បុរសនោះជាទីត្រេកអរក្រៃលែង របស់ខ្ញុំជាងនោះទៅទៀត។

[១៧៣] បុរសមិនយល់ប្រយោជន៍របស់ខ្លួនថា (កិច្ចនេះត្រូវធ្វើ) ក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក កាលបើគេទូន្មាន ក៏ខឹងតប មើលងាយនូវបុគ្គលប្រសើរ។

[១៧៤] បុរសណា ជាប់ចិត្តក្នុងល្បែង គឺកាមគុណ រមែងឃ្លាតចាកមិត្តទាំងពួង បុរសនោះ ជាទីត្រេកអររបស់ខ្ញុំ ទាំងខ្ញុំក៏មិនមានមោះមៃចំពោះបុរសនោះទេ។

[១៧៥] (ពោធិសត្វ តិះដៀលថា) ម្នាលនាងកាឡី នាងចូរចៀសចេញអំពីទីនេះទៅ អំពើអាក្រក់នេះ មិនមានក្នុងយើងទាំងឡាយទេ នាងចូរទៅកាន់ជនបទ ឬនិគមរាជធានី ដទៃចុះ។

[១៧៦] (នាងកាឡកណ្ណី ពោលថា) ខ្ញុំក៏បានដឹងហេតុនោះដែរ អំពើនោះ មិនមានក្នុងអ្នកទេ ពួកជនជាអ្នកឥតបុណ្យក្នុងលោក រមែងប្រមូលនូវទ្រព្យច្រើន ខ្ញុំនឹងទេវតាជាបងរបស់ខ្ញុំ ទាំងពីរនាក់ តែងបំផ្លាញនូវទ្រព្យនុ៎ះ។

[១៧៧] (ពោធិសត្វ សួរថា) នាងជាអ្វី មានវណ្ណៈជាទិព្វ មកឋិតលើផែនដី នាងជាអ្វី ឬជាធីតារបស់នរណា យើងនឹងស្គាល់នាងដូចម្តេចបាន។

[១៧៨] (នាងសិរីទេវធីតា ពោលថា) ខ្ញុំជាធីតានៃមហារាជ ឈ្មោះធតរដ្ឋដ៏មានសិរី ខ្ញុំជាស្រ្តីឈ្មោះសិរីផង លក្ខីផង ពួកទេវតារមែងស្គាល់ខ្ញុំថា ជាស្រ្តីមានប្រាជ្ញាដូចផែនដី លោក ខ្ញុំសូមឱកាសហើយ សូមឲ្យ យើងនឹងសូមនៅក្នុងសំណាក់លោក។

[១៧៩] (ពោធិសត្វ សួរថា) នាងនឹងដំកល់ចិត្តចំពោះបុរសមានសីលធម៌ដូចម្តេច មានសមាចារៈដូចម្តេច ម្នាលនាងលក្ខី ខ្ញុំសួរហើយ នាងចូរប្រាប់ យើងស្គាល់នាងដូចម្តេច។

[១៨០] (នាងសិរីទេវធីតា ពោលថា) បុរសណា គ្របសង្កត់នូវត្រជាក់ក្តី ក្តៅក្តី ខ្យល់ និងកំដៅថ្ងៃក្តី របោម ពស់តូច ពស់ធំក្តី ឃ្លានក្តី ស្រេកក្តី ទាំងអស់ ហើយប្រកបព្យាយាមរឿយ ៗ ក្នុងវេលាយប់ និងថ្ងៃ រមែងមិនញ៉ាំងប្រយោជន៍ដែលតាំងនៅក្នុងកាលគួរ ឲ្យវិនាស បុរសនោះ ជាទីពេញចិត្តរបស់ខ្ញុំ ខ្ញុំគប្បីស៊ប់ចិត្តក្នុងបុរសនោះឯង។

[១៨១] បុរសណា ជាអ្នកមិនក្រោធ មានកល្យាណមិត្ត មានការបរិច្ចាគ ជាអ្នកបរិបូណ៌ដោយសីល មិនមែនជាអ្នកលេងបោកប្រាស់ ជាអ្នកត្រង់ ជាអ្នកមានសង្គហធម៌ មានវាចាទន់ភ្លន់ មានវាចាពីរោះ សូម្បីដល់នូវភាពជាអ្នកធំ ក៏ប្រព្រឹត្តឱនលំទោន ខ្ញុំជាអ្នកមានចិត្តធំទូលាយចំពោះបុរសនោះ ដូចជារលក (ប្រាកដជារបស់ធំទូលាយ ដល់បុគ្គលដែលសំឡឹងមើល) នូវពណ៌របស់សមុទ្រ។

[១៨២] បុគ្គលណា ប្រព្រឹត្តនូវសេចក្តីសង្គ្រោះក្នុងចំពោះមុខ កំបាំងមុខ ចំពោះពួកមិត្តក្តី សត្រូវក្តី បុគ្គលប្រសើរក្តី ស្មើគ្នាក្តី ថោកទាបក្តី បុគ្គលអ្នកប្រព្រឹត្តនូវប្រយោជន៍ក្តី មិនមែនជាប្រយោជន៍ក្តី មិនពោលពាក្យអាក្រក់ក្នុងកាលណាម្តង ខ្ញុំជាអ្នកគប់រកចំពោះបុរសនោះ ទោះបីស្លាប់ក្តី រស់ក្តី។

[១៨៣] បណ្តាគុណទាំងនុ៎ះ បុរសណាមួយ ជាអ្នកគ្មានបញ្ញា បាននូវសិរី ជាទីត្រេកអរណាមួយ ហើយស្រវឹង ខ្ញុំវៀរនូវបុរសនោះ អ្នកប្រព្រឹត្តមិនស្មើ មានសភាពដ៏ក្តៅក្រហាយ ដូចជាបុគ្គលវៀរបង់នូវរណ្តៅលាមក។

[១៨៤] បុគ្គលធ្វើនូវគុណសម្បត្តិ គឺបុណ្យដោយខ្លួនឯង ធ្វើនូវអំពើមិនមែនជាបុណ្យ ក៏ដោយខ្លួនឯង ព្រោះថា បុគ្គលដទៃ ធ្វើនូវគុណសម្បត្តិ គឺបុណ្យក្តី មិនមែនបុណ្យក្តី ដល់បុគ្គលដទៃទៀតមិនបានទេ។

ចប់ សិរិកាឡកណ្ណិជាតក ទី៧។

## កុក្កុដជាតក ទី៨

CS sut.kn.jat.383 | ភាគទី ៥៩

**(៣៨៣. កុក្កុដជាតកំ (៦-១-៨))**

[១៨៥] (សំពោចញី និយាយថា) នែអ្នកមានខ្លួនបិទបាំងដោយស្លាបដ៏វិចិត្រល្អ ជាសត្វមានសិរ្សក្រហម ទៅកាន់អាកាសបាន ចូរអ្នកចុះអំពីមែកឈើមក ខ្ញុំនឹងជាប្រពន្ធរបស់អ្នកដោយទំទេ។

[១៨៦] (មាន់ពោធិសត្វ ឆ្លើយថា) ម្នាលនាងដ៏ល្អ ជាទីត្រេកអរនៃចិត្ត នាងជាសត្វជើងបួន ខ្ញុំជាសត្វជើងពីរ ពួកម្រឹគ និងសត្វបក្សី មិនសមគ្នាទេ នាងចូរស្វែងរកសត្វឯទៀត ធ្វើជាស្វាមីចុះ។

[១៨៧] (សំពោចញី និយាយថា) ខ្ញុំនៅជាកុមារី ជាស្រ្តីនិយាយពីរោះ ពោលពាក្យជាទីស្រឡាញ់ នឹងបានជា (ប្រពន្ធ) របស់អ្នក អ្នកចូរបាននូវខ្ញុំ ជាស្ត្រីល្អ ជាព្រហ្មចារិនី ដោយការបានដ៏ប្រសើរ។

[១៨៨] (មាន់ពោធិសត្វ តិះដៀលថា) នែនាងជាសត្វស៊ីនូវសាកសព ផឹកនូវឈាម ជាចោរបៀតបៀននូវមាន់ នាងឯងមិនមែនចង់បាននូវអញធ្វើជាប្តីដោយការបានប្រសើរទេ។

[១៨៩] (ព្រះសម្ពុទ្ធសំដែងថា) នារីទាំងឡាយ ដែលមានការវាងវៃ ឃើញនូវបុរសដ៏ប្រសើរហើយ រមែងដឹកនាំ ដោយវាចាដ៏ពីរោះ យ៉ាងនេះឯង ដូចជាសំពោចញី ប្រលោមនូវមាន់ឈ្មោល (មកធ្វើជាប្តីរបស់ខ្លួន)។

[១៩០] បុគ្គលណា មិនឆាប់យល់នូវប្រយោជន៍ដែលកើតឡើង បុគ្គលនោះ រមែងលុះអំណាចនៃសត្រូវផង រមែងក្តៅក្រហាយក្នុងកាលជាខាងក្រោយផង។

[១៩១] លុះតែបុគ្គលណា ឆាប់យល់ច្បាស់នូវប្រយោជន៍ដែលកើតឡើង បុគ្គលនោះ រមែងរួចចាកការបៀតបៀនអំពីសត្រូវ ដូចមាន់ឈ្មោល រួចអំពីសំពោចញី។

ចប់ កុក្កុដជាតក ទី៨។

## ធម្មទ្ធជជាតក ទី៩

CS sut.kn.jat.384 | ភាគទី ៥៩

**(៣៨៤. ធម្មធជជាតកំ (៦-១-៩))**

[១៩២] (ក្អែក និយាយនឹងពួកសត្វស្លាបថា) ម្នាលញាតិទាំងឡាយ អ្នកទាំងឡាយ ចូរប្រព្រឹត្តធម៌ អ្នកទាំងឡាយ ចូរប្រព្រឹត្តធម៌

សេចក្ដីចំរើន (នឹងមាន) ដល់អ្នកទាំងឡាយ អ្នកប្រព្រឹត្តធម៌ រមែងដេកជាសុខក្នុងលោកនេះ និងលោកខាងមុខ។

[១៩៣] (ពួកសត្វស្លាប សរសើរថា) សត្វស្លាបមានកំណើតពីរនេះ ប្រសើរណាស់តើ ជាអ្នកប្រកបដោយធម៌ដ៏ក្រៃលែង ឈរតែជើងម្ខាង ប្រៀនប្រដៅតែធម៌។

[១៩៤] (បក្សីពោធិសត្វ ពោលថា) អ្នកទាំងឡាយ មិនស្គាល់ច្បាស់នូវមារយាទនៃក្អែកនោះទេ អ្នកទាំងឡាយសរសើរ ព្រោះមិនដឹង (ចំណែកខាងក្អែកអាក្រក់) ស៊ីទាំងពងទាំងកូន (របស់ពួកយើង) ហើយពោលថា ធម៌ ៗ ដូច្នេះ។

[១៩៥] បុគ្គលអាក្រក់ និយាយដោយវាចាផ្សេង ធ្វើដោយកាយផ្សេង វាប្រព្រឹត្តធម៌តែសំដី មិនមែនទាំងកាយផងទេ មិនដំកល់ខ្លួនទុកក្នុងធម៌នោះ។

[១៩៦] បុគ្គលអ្នកទន់ភ្លន់ដោយវាចា តែគេស្គាល់ចិត្តបានដោយក្រ ដូចជាពស់វែកបិទបាំងខ្លួន អាស្រ័យនៅក្នុងរូង បុគ្គលមានធម៌ជាទង់ជ័យ គេសន្មតថាល្អក្នុងស្រុក និងនិគមទាំងឡាយ បុគ្គលបែបនេះ បុរសអ្នកល្ងង់ខ្លៅ ស្គាល់បានដោយក្រ។

[១៩៧] អ្នកទាំងឡាយ ចូរបៀតបៀនក្អែកនេះដោយចំពុះផង ចូរបៀតបៀនក្អែកនេះ ដោយជើងផង ចូរញ៉ាំងក្អែកលាមកនេះឲ្យវិនាសទៅ ក្អែកនេះ មិនគួរឲ្យនៅជាមួយទេ។

ចប់ ធម្មទ្ធជជាតក ទី៩។

## នន្ទិយមិគរាជជាតក ទី១០

CS sut.kn.jat.385 | ភាគទី ៥៩

**(៣៨៥. នន្ទិយមិគរាជជាតកំ (៦-១-១០))**

[១៩៨] (ម្រឹគមាតាបិតា និយាយផ្ដាំថា) ម្នាលព្រាហ្មណ៍ បើអ្នកទៅកាន់ឧទ្យានឈ្មោះអញ្ជ័ន ក្នុងក្រុងសាកេត និយាយប្រាប់កូនឈ្មោះនន្ទិយៈ ជាឱរសរបស់ខ្ញុំថា មាតាបិតាទាំងឡាយ របស់អ្នកចាស់ហើយ គាត់ចង់ឃើញអ្នក។

[១៩៩] (នន្ទិយម្រឹគ និយាយថា) បន្លែទាំងឡាយ ទឹក និងភោជនរបស់ព្រះរាជា ខ្ញុំបានបរិភោគហើយ ម្នាលព្រាហ្មណ៍ ខ្ញុំមិនអាចបរិភោគទទេ នូវដុំភោជនជាអំណោយ របស់ព្រះរាជានោះទេ។

[២០០] ខ្ញុំនឹងបែរនូវចំហៀងខ្លួនដល់ព្រះរាជា មានសរក្នុងដៃ ក្នុងកាលណោះ ខ្ញុំក៏ដល់នូវសេចក្ដីសុខ រួចចាក (មរណៈ) ហើយប្រហែលនឹងបានឃើញនូវមាតា។

[២០១] (ព្រះសាស្ដា ទ្រង់ត្រាស់ថា) កាលពីដើម តថាគតជាសត្វជើង ៤ មានរូបល្អ ជាស្ដេចម្រឹគ ឈ្មោះនន្ទិយៈដោយឈ្មោះ នៅក្នុងលំនៅនៃស្ដេចកោសល។

[២០២] ព្រះរាជាកោសល ផ្ទាប់ព្រួញយិតធ្នូមក ដើម្បីសម្លាប់នូវតថាគតនោះ ក្នុងឧទ្យានឈ្មោះអញ្ជ័ន ជាទីដែលពួកជនថ្វាយ។

[២០៣] តថាគតក៏បែរនូវចំហៀងខ្លួន ដល់ព្រះរាជានោះ ដែលមានកូនសរក្នុងដៃ ក្នុងកាលណោះ តថាគតក៏ដល់នូវសេចក្ដីសុខ រួចចាក (មរណៈ) ហើយបានមកឃើញមាតា។

ចប់ នន្ទិយមិគរាជជាតក ទី១០។

ចប់ អាវារិយវគ្គ ទី១។

ឧទ្ទាននៃអាវារិយវគ្គនោះគឺ

(អំពីអាវារិយជាតក) មានពាក្យថា បពិត្រព្រះអង្គប្រសើរលើរថ សូមព្រះអង្គកុំខ្ញាល់ ១ សេតកេតុជាតកដ៏ប្រសើរ ១ ទរីមុខជាតក ១ នេរុជាតក ១ (អាសង្កជាតក) ១ ទៀត ការមិនត្រេកអរ ១ សិរីទេវធីតា ១ មាន់មានស្លាបដ៏ប្រសើរវិចិត្រ ១ ក្អែកសំដែងធម៌ ១ ម្រឹគឈ្មោះនន្ទិយៈ ១ ត្រូវជា ១០។

# ខុរបុត្តវគ្គ ទី២

CS sut.kn.jat.v06.02 | ភាគទី ៥៩

**(២. ខរបុត្តវគ្គោ)**

## ខុរបុត្តជាតក ទី១

CS sut.kn.jat.386 | ភាគទី ៥៩

**(៣៨៦. ខរបុត្តជាតកំ (៦-២-១))**

[២០៤] (សេះសិន្ធវៈ និយាយថា) ឮថា បណ្ឌិតទាំងឡាយ បានពោលនូវសត្វពពែថា ជាសត្វពាលដោយពិត អ្នកចូរមើលចុះ សត្វពាលមិនដឹងនូវអំពើដែលគួរធ្វើ ក្នុងទីកំបាំង ទៅធ្វើក្នុងទីវាល។

[២០៥] (ពពែ និយាយថា) ម្នាលសម្លាញ់ អ្នកទេឬ ជាសត្វពាល ម្នាលខុរបុត្រ អ្នកចូរដឹងចុះ អ្នកជាសត្វដែលត្រូវគេរួបរឹតដោយខ្សែ មានបបូរមាត់វៀច មានមុខឱនចុះ។

[២០៦] ម្នាលសំឡាញ់ អ្នកណាបានរួចចេញ (អំពីរថ) មិនរត់ទៅ អ្នកនោះ ពេញជាពាលទៅទៀត ម្នាលសំឡាញ់ អ្នកនាំនូវស្ដេចសេនកៈណា ស្ដេចសេនកៈនោះ ចាត់ជាមនុស្សពាលបំផុត។

[២០៧] (សេះសិន្ធវៈ និយាយថា) ម្នាលសំឡាញ់ បើខ្ញុំជាសត្វពាលដោយហេតុណា ម្នាលអជរាជ អ្នកចូរដឹងនូវហេតុនោះចុះ តែថា ស្តេចសេនកៈ ជាមនុស្សពាល ដោយហេតុដូចម្តេច អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់ហេតុនោះ។

[២០៨] (ពពែ ប្រាប់ថា) បុគ្គលណា បាននូវមន្តជាប្រយោជន៍ដ៏ឧត្តមហើយ ប្រគល់ឲ្យប្រពន្ធ (បុគ្គលនោះ) នឹងលះបង់នូវខ្លួន ដោយការឲ្យមន្តនោះ ទាំងប្រពន្ធនោះ នឹងមិនមានដល់បុគ្គលនោះឡើយ។

[២០៩] (ពពែ ពោលថា) បពិត្រព្រះអង្គជាធំជាងជន បុគ្គលបែបនោះ លះបង់ចោលនូវខ្លួន មិនសេពគប់នូវវត្ថុជាទីស្រឡាញ់ ដោយគិតថា (វត្ថុនេះ) ជាទីស្រឡាញ់របស់អញ ខ្លួនឯង តើប្រសើរជាងរបស់ដែលប្រសើរទៅទៀត ព្រោះបុរសដែលមានខ្លួនអប់រំហើយ គប្បីបាននូវជនជាទីស្រឡាញ់ក្នុងកាលជាខាងក្រោយ។

ចប់ ខុរបុត្តជាតក ទី១។

## សូចិជាតក ទី២

CS sut.kn.jat.387 | ភាគទី ៥៩

### (៣៨៧. សូចិជាតកំ (៦-២-២))

[២១០] (កុមារបុត្រពោធិសត្វ ពោលថា) នរណាចង់ទិញម្ជុល (របស់ខ្ញុំ) ជាម្ជុលមិនគ្រោតគ្រាត មិនអាក្រក់ ដែលសំលៀងដោយថ្មមានច្បោះដ៏ល្អ មានចុងដ៏ស្រួចឆ្មារ។

[២១១] នរណាចង់ទិញម្ជុល ជាម្ជុលដែលដុសខាត់ល្អ មានច្បោះល្អ ដែលប្រព្រឹត្តទៅដោយល្អតាមលំដាប់ (រៀវតូច) ចាក់ទម្លុះនូវរបស់ក្រាស់បាន។

[២១២] (នាងកុមារី ពោលថា) ម្ជុល និងសន្ទូច តែងចេញអំពីស្រុកនេះ ក្នុងកាលឥឡូវនេះ ចុះបុរសនេះជាអ្វី ចង់លក់ម្ជុលក្នុងស្រុករបស់ជាង។

[២១៣] គ្រឿងសស្ត្រា និងការងារផ្សេង ៗ ជាច្រើន តែងចេញទៅអំពីស្រុកនេះ ចុះបុរសនេះជាអ្វី ក៏មកលក់ម្ជុលក្នុងស្រុកជាងលោហៈ។

[២១៤] (ពោធិសត្វ ពោលថា) ជនអ្នកចេះដឹង ត្រូវលក់ម្ជុលក្នុងស្រុកជាងលោហៈ អាចារ្យទាំងឡាយ រមែងដឹងច្បាស់នូវការងារដែលគេធ្វើល្អ និងអាក្រក់។

[២១៥] ម្នាលនាង បើបិតារបស់នាងស្គាល់នូវម្ជុលដែលខ្ញុំធ្វើហើយនេះ គាត់នឹងអញ្ជើញ (ផ្សំផ្គុំ) ខ្ញុំ ជាមួយនាង ព្រមទាំងទ្រព្យដទៃដែលមាននៅក្នុងផ្ទះ។

ចប់ សុចិជាតក ទី២។

## តុណ្ឌិលជាតក ទី៣

CS sut.kn.jat.388 | ភាគទី ៥៩

### (៣៨៨. តុណ្ឌិលជាតកំ (៦-២-៣))

[២១៦] (ចូឡតុណ្ឌិលសុករៈ ពោលថា) ម្ចាស់យើងធ្លាប់ឲ្យ (បបរកណ្តក និងបាយក្តាំង) ឥឡូវនេះ គាត់ឲ្យបន្លែស្រស់វិញ ស្នូកនេះ ពេញ (ដោយបាយសស្អាត) ស្ត្រីជាម្ចាស់យើង ក៏ឈរនៅ (ជិតស្នូកនោះដែរ) អ្នកផងច្រើនគ្នា មានដៃកាន់អន្ទាក់ ខ្ញុំមិនចង់ស៊ីទេ។

[២១៧] (មហាតុណ្ឌិលៈ ពោលថា) អ្នកតក់ស្លុត ស្លន់ស្លោ ប្រាថ្នារកទីពឹងពួន អ្នកឥតទីពឹងទេ អ្នកនឹងទៅក្នុងទីណា ម្នាលតុណ្ឌិលៈ អ្នកចូរមានសេចក្តីខ្វល់ខ្វាយ បរិភោគចុះ យើងដែលគេចិញ្ចឹម ដើម្បីប្រយោជន៍តែសាច់ (ប៉ុណ្ណោះ)។

[២១៨] (បើអ្នកខ្លាចសេចក្តីស្លាប់) អ្នកចូរចុះទៅកាន់ស្រះដែលមិនមានភក់ អ្នកចូរជម្រះនូវញើស និងក្អែលទាំងអស់ចេញ ក្លិននៃគ្រឿងលាបណា មិនដាច់ ក្នុងកាលណាមួយ អ្នកចូរកាន់យកនូវគ្រឿងលាបដ៏ថ្មីនោះចុះ។

[២១៩] (ចូឡតុណ្ឌិលៈ សួរថា) ស្រះមិនមានភក់ តើដូចម្តេច អ្វីហ្ន៎ ដែលលោកហៅថា ញើស និងក្អែល មួយទៀត គ្រឿងលាបដ៏ថ្មី តើដូចម្តេច ទាំងក្លិនរបស់វា ក៏មិនដាច់ក្នុងកាលណាមួយ។

[២២០] (មហាតុណ្ឌិលៈ ឆ្លើយថា) ធម៌ ទុកជាស្រះមិនមានភក់ បាប លោកពោលថា ញើស និងក្អែល សីល ទុកជាគ្រឿងលាបដ៏ថ្មី ទាំងក្លិនរបស់សីលនោះ មិនដាច់ ក្នុងកាលណាម្តង។

[២២១] ពួកជន អ្នកសម្លាប់នូវសរីរៈ (នៃសត្វទាំងឡាយ) រមែងត្រេកអរ ចំណែកខាង ពួកសត្វ អ្នកទ្រទ្រង់នូវសរីរៈ រមែងមិនត្រេកអរឡើយ ពួកសត្វទាំងឡាយ (ប្រាកដដូចជាយើង) រមែងត្រេកអរ លះបង់នូវជីវិត ក្នុងខែពេញ មានព្រះចន្ទពេញវង់។

ចប់ តុណ្ឌិលជាតក ទី៣។

## សុវណ្ណកក្កដកជាតក ទី៤

CS sut.kn.jat.389 | ភាគទី ៥៩

### (៣៨៩. សុវណ្ណកក្កដជាតកំ (៦-២-៤ ))

[២២២] (ក្អែក ពោលថា) ម្រឹគមានពណ៌ដូចមាស (ក្តាម) មានភ្នែកលៀន មានស្បែកដូចឆ្អឹង អាស្រ័យនៅក្នុងទឹក ជាសត្វមិនមានរោម ខ្ញុំត្រូវក្តាមនោះគ្របសង្កត់ ទើបយំ កំព្រា (តែម្នាក់ឯង) ម្នាលសំឡាញ់អើយ ហេតុអ្វី ទើបអ្នកបោះបង់ខ្ញុំចោល។

' [២២៣] ពស់នោះ កាលជួយ (ក្អែកនោះ) បើកពពាដំធំ លូនចូលទៅជិតក្តាម យកអាសាការពារសំឡាញ់ដ៏ស្និទ្ធស្នាល ក្តាមក៏ចាប់ពស់ទៀត។

[២២៤] (ពស់ ពោលថា) ចំណែកខាងក្តាម ជាសត្វត្រូវការដោយចំណី មិនគួរចាប់ក្អែក មិនគួរចាប់ពស់ទេ ម្នាលអ្នកមានភ្នែកលៀន ខ្ញុំសូមសួរអ្នក ហេតុអ្វី ក៏អ្នកមកចាប់យើងទាំងពីរនាក់ ។

[២២៥] (ក្តាមនិយាយថា) បុរសនេះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ អ្នកណា ចាប់ខ្ញុំនាំទៅក្នុងទឹក កាលបើអ្នកនោះស្លាប់ ខ្ញុំ (នឹងមាន) សេចក្តីទុក្ខច្រើន (ព្រោះ) ខ្ញុំនឹងបុរសនេះ ទាំងពីរនាក់ នឹងមិននៅជាមួយគ្នា។

[២២៦] ឯអ្នកផងឃើញខ្ញុំមានកាយចំរើន (ធំ) គប្បីប្រាថ្នា ដើម្បីបៀតបៀនតែប៉ុណ្ណោះ សូម្បីពួកក្អែក បានឃើញខ្ញុំ មានសាច់ឆ្ងាញ់ក្រាស់ ទន់ ក៏គប្បីបៀតបៀនដែរ។

[២២៧] (ពស់ ពោលថា) បើអ្នកចាប់យើងទាំងពីរនាក់ ព្រោះហេតុតែបុរសនោះ បុរសចូរក្រោកឡើង ខ្ញុំនឹងស្រូបយកពិសចេញ អ្នកចូរលែងខ្ញុំ និងក្អែកឲ្យឆាប់ ព្រោះកាលពីដើម ពិសដ៏ក្លៀវក្លាជ្រាបចូលក្នុងសត្វ។

[២២៨] (ក្តាម និយាយថា) អញលែងពស់ តែមិនលែងក្អែកទេ ព្រោះថា ក្អែកទុកជាអ្នកធានាសិន អញលុះឃើញនូវបុរសមានសេចក្តីសុខ មិនមានរោគ ទើបលែងក្អែក ដូចយ៉ាងពស់ដែរ។

[២២៩] ក្អែកក្នុងកាលណោះ បានមកជាទេវទត្ត ចំណែកខាងពស់វែក បានមកជាដំរី ក្តាមបានមកជាអានន្ទដ៏ចំរើន ព្រាហ្មណ៍ក្នុងកាលណោះ បានមកជាតថាគត ជាសាស្តា។

ចប់ សុវណ្ណកក្កដកជាតក ទី៤។

## មយ្ហកសកុណជាតក ទី៥

CS sut.kn.jat.390 | ភាគទី ៥៩

**(៣៩០. មយ្ហកជាតកំ (៦-២-៥))**

[២៣០] (តាបសពោធិសត្វ ពោលថា) សត្វស្លាបឈ្មោះមយ្ហកៈ[12] ហើរទៅតាមញក និងច្រកភ្នំ ទៅទំដើមលៀប ដែលមានផ្លែទុំ យំកន្ទក់កន្ទេញថា របស់អញ ៗ ដូច្នេះ។

[២៣១] កាលសត្វមយ្ហកៈនោះ ស្រែកយំការពារយ៉ាងនេះ ពួកសត្វទិជជាតិ ក៏មកប្រជុំគ្នា ស៊ីផ្លែលៀបហើយហើរទៅ សត្វនោះក៏នៅតែស្រែកយំការពារ។

[២៣២] ដូចយ៉ាងជនពួកខ្លះក្នុងលោកនេះ ប្រមូលមកនូវទ្រព្យ មានប្រមាណច្រើន ហើយមិនចាត់ចែងនូវទ្រព្យ ឲ្យសមគួរដល់ចំណែកដើម្បីខ្លួន មិនទំនុកបម្រុងដល់ញាតិទាំងឡាយ។

[២៣៣] បុគ្គលនោះ រមែងមិនបានប្រើប្រាស់នូវគ្រឿងស្លៀកពាក់ និងបាយ មិនបានទ្រទ្រង់នូវកម្រងផ្កា មិនបានលាបនូវគ្រឿងលាប (ដ៏ល្អទេ) មិនបានប្រើប្រាស់នូវវត្ថុណាមួយជារបស់ខ្លួនទេ ទាំងមិនបានសង្គ្រោះនូវញាតិទាំងឡាយឡើយ។

[២៣៤] កាលបើបុគ្គលនោះ ពោលរៀបរាប់ ហួងហែងថា របស់អញ ៗ យ៉ាងនេះ ស្រាប់តែពួកព្រះរាជា ឬពួកចោរ និងពួកជនអ្នកត្រូវទទួលមត៌ក មិនជាទីស្រឡាញ់ នាំយកទ្រព្យនោះទៅ បុគ្គលនោះ ក៏នៅតែនិយាយរៀបរាប់។

[២៣៥] ឯអ្នកប្រាជ្ញ បាននូវភោគៈហើយ រមែងសង្គ្រោះញាតិទាំងឡាយ អ្នកប្រាជ្ញនោះ រមែងបាននូវសេចក្តីសរសើរ ដោយការសង្គ្រោះញាតិនោះ លុះលះលោកនេះទៅហើយ រមែងរីករាយក្នុងឋានសួគ៌។

ចប់ មយ្ហកសកុណជាតក ទី៥។

## បព្វជិតវិហេឋកជាតក ទី៦

CS sut.kn.jat.391 | ភាគទី ៥៩

**(៣៩១. វិជ្ជាធរជាតកំ (៦-២-៦))**

[២៣៦] (ព្រះរាជាពារាណសី ត្រាស់ថា) អ្នកមានពណ៌ទ្រង់ទ្រាយដ៏ល្អ ផ្គងអញ្ជលីនមស្ការ តម្កល់នូវបុគ្គលមានរូបអាក្រក់ អំពីខាងមុខ តើបុរសនោះ ប្រសើរជាងអ្នក ឬប្រហែលគ្នា អ្នកចូរប្រាប់នូវឈ្មោះនៃអ្នកឯទៀតផង នៃខ្លួនផង។

[២៣៧] (ព្រះឥន្ទ្រពោលថា) បពិត្រព្រះរាជា ទេវតាទាំងឡាយ មិនកាន់យកនូវនាមនិងគោត្រ ព្រះខីណាស្រព អ្នកដល់នូវការស្ងប់ទាំងប្រព្រឹត្តតាមផ្លូវត្រង់ ប៉ុន្តែខ្ញុំនឹងសូមប្រាប់ឈ្មោះ (ខ្លួនខ្ញុំ) ដល់ព្រះអង្គ ខ្ញុំជាសក្កៈ ជាធំជាងទេវតាជាន់តាវត្តិង្ស។

[២៣៨] (ព្រះរាជា សួរថា) បុគ្គលណា ឃើញនូវភិក្ខុ អ្នកបរិបូណ៌ដោយចរណៈ ហើយផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាងមុខ បពិត្រទេវរាជ ខ្ញុំសូមសួរនូវដំណើរនុ៎ះ ចំពោះព្រះអង្គ បុគ្គលនោះ លុះច្យុតចាកលោកនេះទៅ រមែងបានសេចក្តីសុខដូចម្តេច។

[២៣៩] (ព្រះឥន្ទ្រ ឆ្លើយថា) បុគ្គលណា ឃើញនូវភិក្ខុ ដែលបរិបូណ៌ដោយចរណៈ ហើយផ្គងអញ្ជលីនមស្ការ តម្កល់ទុកក្នុងខាងមុខ បុគ្គលនោះ រមែងបាននូវសេចក្តីសរសើរ ក្នុងបច្ចុប្បន្ន លុះបុគ្គលនោះបែកធ្លាយសរីរកាយ រមែងទៅកាន់ឋានសួគ៌។

[២៤០] (ព្រះរាជា ត្រាស់ថា) ឱហ្ន៎ សិរីរបស់អញកើតឡើងក្នុងថ្ងៃនេះ ព្រោះអញបាន ឃើញនូវវាសវៈ ជាម្ចាស់នៃភូត បពិត្រសក្កៈ ខ្ញុំនឹងធ្វើនូវបុណ្យជាច្រើន ព្រោះបានឃើញនូវភិក្ខុផង ព្រះអង្គផង។

[២៤១] (ព្រះឥន្ទ្រ ពោលថា) បុគ្គលណា ប្រកបដោយបញ្ញា ជាពហុស្សូត អាចគិតឃើញនូវហេតុជាច្រើន (ព្រះអង្គ) គប្បីសេពគប់

(បុគ្គលនោះ) ដោយពិត បពិត្រព្រះរាជា ព្រោះព្រះអង្គបានឃើញភិក្ខុ និងខ្ញុំ សូមធ្វើបុណ្យជាច្រើនចុះ។

[២៤២] (ព្រះរាជា ត្រាស់ថា) បពិត្រព្រះអង្គជាធំជាងទេវតា ខ្ញុំនឹងជាអ្នកមិនមានសេចក្តីក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកគួរដល់អ្នកដំណើរ និងស្មូមទាំងអស់ សង្កត់សង្កិននូវមានះ ថ្វាយបង្គំ ព្រោះបានស្តាប់នូវសុភាសិត (របស់ព្រះអង្គ)។

ចប់ បព្វជិតវិហេឋកជាតក ទី៦។

## ឧបសិង្ឃបុប្ផជាតក ទី៧

CS sut.kn.jat.392 | ភាគទី ៥៩

### (៣៩២. សិង្ឃបុប្ផជាតកំ (៦-២-៧))

[២៤៣] (នាងទេវធីតា ពោលថា) បពិត្រលោក លោកស្រូបក្លិនផ្កាកើតអំពីទឹក (ផ្កាឈូក) ដែលគេមិនបានឲ្យ នុ៎ះជាចំណែកមួយនៃការលួច លោកជាអ្នកលួចក្លិន។

[២៤៤] (តាបសពោធិសត្វ ពោលថា) អាត្មាមិនលួចទេ មិនកាច់យកទេ អាត្មាគ្រាន់តែស្រូបក្លិនផ្កាឈូក អំពីចម្ងាយ កាលបើដូច្នេះ ហេតុអ្វី ទើបអ្នកពោលថា លោកជាអ្នកលួចក្លិន។

[២៤៥] បុរសណា ជីកយកក្រអៅឈូក កាច់យកផ្កាឈូកស បុរសនោះ ដែលមានការងារអាក្រក់យ៉ាងនេះ ព្រោះហេតុអ្វីក៏អ្នកមិនថា។

[២៤៦] (នាងទេវធីតា ពោលថា) ពាក្យសំដីរបស់ខ្ញុំ មិនមានចំពោះបុរសដែលជាអ្នកល្មោភអាក្រក់ ប្រឡាក់ (ដោយបាបធម៌) ដូចជាសំពត់មេនំទេ ខ្ញុំគួរនិយាយតែនឹងលោក។

[២៤៧] បាបរបស់បុរស អ្នកមិនមានទីទួល គឺកិលេស អ្នកស្វែងរកនូវអំពើដ៏ស្អាតជានិច្ច ប្រមាណប៉ុនចុងនៃរោមកន្ទុយសត្វ រមែងប្រាកដដូចប៉ុនមេឃ។

[២៤៨] (តាបសពោធិសត្វ ពោលថា) ម្នាលយក្ខ នាងស្គាល់នូវអាត្មាដោយពិត មួយទៀត នាងឈ្មោះថា អនុគ្រោះនូវអាត្មា ម្នាលយក្ខ បើនាងឃើញទោសនេះ ក្នុងកាលណា នាងគប្បីប្រាប់ (ដល់អាត្មា) ទៀត ក្នុងកាលនោះ។

[២៤៩] (នាងទេវធីតា ពោលថា) ខ្ញុំមិនមែនរស់នៅព្រោះអាស្រ័យលោកទេ ទាំងមិនមែនជាអ្នកធ្វើការឈ្នួលរបស់លោកទេ បពិត្រភិក្ខុ លោកទៅកាន់សុគតិ ដោយអំពើណា លោកគប្បីដឹង (នូវអំពើនោះចុះ)។

ចប់ ឧបសិង្ឃបុប្ផជាតក ទី៧។

## វិឃាសាទជាតក ទី៨

CS sut.kn.jat.393 | ភាគទី ៥៩

### (៣៩៣. វិឃាសាទជាតកំ (៦-២-៨))

[២៥០] (ព្រះឥន្ទ្រក្លែងខ្លួនជាសេក និយាយថា) ពួកជនណា ជាអ្នកស៊ីវត្ថុសល់ដែលជននោះរមែងរស់នៅជាសុខស្រួល សេចក្តីសរសើរក្នុងបច្ចុប្បន្ន និងសុគតិ ក្នុងបរលោក រមែងមាន។

[២៥១] (ឥសីមួយរូប ពោលថា) អ្នកទាំងឡាយ ជាបណ្ឌិត ចូរកុំផ្ទៀងស្តាប់ (នូវសំដី) របស់សេកនិយាយ ម្នាលអ្នកមានពោះដ៏ស្មើទាំងឡាយ ពួកអ្នកចូរស្តាប់ពាក្យខ្ញុំនេះវិញ សេកនេះ បញ្ឆោរនូវពួកយើងទេ។

[២៥២] (សេក និយាយថា) ខ្ញុំមិនបញ្ឆោរលោកទាំងឡាយទេ បពិត្រលោកអ្នកបរិភោគនូវសាកសព លោកទាំងឡាយ ចូរស្តាប់ខ្ញុំ លោកទាំងឡាយ ជាអ្នកបរិភោគនូវភោជនសល់ លោកទាំងឡាយ មិនមែនជាអ្នកបរិភោគនូវវត្ថុសល់ដែលទេ។

[២៥៣] (ពួកឥសី និយាយថា) យើងទាំងឡាយ បួសបានវស្សា ៧ ហើយ ជាអ្នកមានកំបោយសក់ នៅក្នុងកណ្តាលព្រៃ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដ៏សល់ប៉ុណ្ណោះ បើពួកយើងត្រូវអ្នកដ៏ចំរើនតិះដៀលហើយ តើពួកជនណា គួរជាទីសរសើររបស់លោកដ៏ចំរើន។

[២៥៤] (សេកពោធិសត្វ ពោលថា) លោកទាំងឡាយ បរិភោគនូវភោជនសល់ របស់សត្វសាហាវ គឺសីហៈ និងខ្លា ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយរបស់សល់ ទើបគេសំគាល់ថា ជាអ្នកបរិភោគរបស់សល់ដែល។

[២៥៥] ពួកជនណា ឲ្យដល់ព្រាហ្មណ៍ សមណៈ និងអ្នកស្មូមឯទៀត ហើយទើបបរិភោគនូវភោជនដ៏សេសសល់ ពួកជននោះ ហៅថា ជាអ្នកបរិភោគនូវវត្ថុសល់ដែល។

ចប់ វិឃាសាទជាតក ទី៨។

## វដ្តកជាតក ទី៩

CS sut.kn.jat.394 | ភាគទី ៥៩

### (៣៩៤. វដ្តកជាតកំ (៦-២-៩))

[២៥៦] (ចាបពោធិសត្វ សួរថា) បពិត្រឪពុកធំ លោកបរិភោគនូវបាយ ទឹកដោះរាវ និងប្រេងដ៏ប្រណីត បពិត្រក្អែក កាលបើដូច្នេះ ហេតុអ្វីបានជាអ្នកស្គាំងស្គមម្ល៉េះ។

[២៥៧] (ក្អែកឆ្លើយថា) បណ្តាពួកក្អែកទាំងនោះ សត្វក្អែកនៅក្នុងកណ្តាលសត្រូវ ស្វែងរកចំណី មានសេចក្តីតក់ស្លុតជានិច្ច តើនឹងមានសេចក្តីមាំមួន អំពីណាកើត។

[២៥៨] ពួកក្អែក ជាសត្វមានពុកត្បូត តក់ស្លុតអស់កាលជានិច្ច បានដុំបាយដោយអំពើអាក្រក់ មិនដែលឆ្អែតស្កប់ស្កល់ទេ ម្នាលសត្វចាប ព្រោះហេតុនោះ ទើបខ្ញុំស្គាំងស្គម។

[២៥៩] ម្នាលចាប អ្នកបរិភោគនូវពូជស្មៅដ៏សៅហ្មង មានឱជារសតិច កាលបើដូច្នេះ ហេតុអ្វី ទើបអ្នកមានសរីរៈធាត់ម្ល៉េះ។

[២៦០] (ចាបពោធិសត្វ ពោលថា) ម្នាលក្អែក ខ្ញុំញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលខ្ញុំបាន និងមិនបាន ព្រោះខ្ញុំជាអ្នកប្រាថ្នាតិច គិតតិច ទាំងត្រាច់ទៅកាន់ទីមិនឆ្ងាយ ព្រោះហេតុនោះ ទើបខ្ញុំជាអ្នកមានសរីរៈធាត់។

[២៦១] សេចក្តីពិតថា ការប្រព្រឹត្តិចិញ្ចឹមជីវិតរបស់បុគ្គលអ្នកប្រាថ្នាតិចផង មានសេចក្តីសុខព្រោះការគិតតិចផង ដឹងប្រមាណក្នុងអាហារដែលខ្លួនកាន់យកដោយល្អផង រមែងប្រព្រឹត្តទៅបានដោយស្រួល។

ចប់ វដ្តកជាតក ទី៩។

## មណិជាតក ទី១០

CS sut.kn.jat.395 | ភាគទី ៥៩

(៣៩៥. បាវរតជាតកំ (៦-២-១០ ))

[២៦២] (ព្រាបពោធិសត្វ និយាយថា) យូរណាស់ហើយតើ ខ្ញុំទើបឃើញសំឡាញ់ ពាក់នូវកម្រងកែវមណី សំឡាញ់របស់ខ្ញុំល្អមែន ព្រោះល្អដោយការលេងពុកមាត់។

[២៦៣] (ក្អែក និយាយតបថា) ខ្ញុំមានការខ្វល់ខ្វាយច្រើនក្នុងការងារ មានក្រចកនិងរោមក្លៀកដុះទ្រុបទ្រុល យូរណាស់ហើយ គេទើបតែនឹងបោចរោមអាក្រក់ចេញក្នុងថ្ងៃនេះ ព្រោះបានជាងកោរកាត់។

[២៦៤] (ព្រាបពោធិសត្វ និយាយថា) អ្នកបានឲ្យជាងកោរកាត់ ដែលគេរកបានដោយក្រ ឲ្យបោចនូវរោមណាមែនឬ ម្នាលសម្លាញ់ កាលបើដូច្នេះ រោមបន្តិចបន្តួច ត្រង់ករបស់អ្នក (នោះ) ទុកនៅវែងអន្លាយធ្វើអ្វី។

[២៦៥] (ក្អែក និយាយតបថា) កែវមណី តែងសំយុងចុះព្ធដ៏ក នៃមនុស្សសុខុមាលជាតិ ខ្ញុំយកតម្រាប់តាមពួកមនុស្សទាំងនោះ អ្នកកុំសំគាល់ថា (ខ្ញុំ) ធ្វើដោយល្បែងឡើយ។

[២៦៦] បើអ្នកពេញចិត្តនឹងការលេងពុកមាត់ ដែលឲ្យនាយជាងធ្វើយ៉ាងល្អនេះ ម្នាលសម្លាញ់ ខ្ញុំនឹងឲ្យជាងធ្វើដល់អ្នកផង ឲ្យនូវកែវមណីដល់អ្នកផង។

[២៦៧] (ព្រាបពោធិសត្វ និយាយថា) អ្នកឯងយកកែវមណីផង យកពុកមាត់ ដែលគេធ្វើឲ្យល្អផង មកបិទបាំង ទើបខ្ញុំហៅអ្នកមក ហើយនឹងទៅ ការបានជួបប្រទះនឹងអ្នក រមែងជាទីពេញចិត្តរបស់ខ្ញុំ។

ចប់ មណិជាតក ទី១០។

ចប់ ខុរបុត្តវគ្គ ទី២។

ឧទ្ទាននៃខុរបុត្តវគ្គនោះគឺ

និយាយអំពីអ្នកចូរមើលចុះ (ជាដើម) ១ ព្រមទាំងម្ទូល ១ តុណ្ឌិលជាតក ១ ម្រឹគក្តាម ១ សត្វស្លាបដ៏ប្រសើរ ឈ្មោះ មយ្ហក: ជាគំរប់ ៥ ផ្គងអញ្ជលី ១ ផ្កាឈូក ១ កណ្តាលព្រៃ ១ សត្វចាប ១ ព្រាបដ៏ប្រសើរ ១ រួមជា ១០។

ឧទ្ទាននៃវគ្គ ក្នុងឆក្កនិបាតនោះគឺ

ខ្ញុំនឹងសំដែងនូវវគ្គ ក្នុងឆក្កនិបាត ដ៏ប្រសើរថ្លៃថ្លា វគ្គទាំងពីរ គឺអាវារិយវគ្គ និងខុរបុត្តវគ្គ មានពាក្យថា សូចិជាតក មានព្យញ្ជនៈដ៏ល្អ ដែលព្រះដ៏មានព្រះភាគសំដែងហើយ។

ចប់ ឆក្កនិបាត។

# សត្តកនិបាតជាតក

CS sut.kn.jat.v07 | ភាគទី ៥៩

(៧. សត្តកនិបាតោ)

## កុក្កុវគ្គ ទី១

CS sut.kn.jat.v07.01 | ភាគទី ៥៩

(១. កុក្កុវគ្គោ)

## កុក្កុជាតក ទី១

CS sut.kn.jat.396 | ភាគទី ៥៩

(៣៩៦. កុក្កុជាតកំ (៧-១-១))

[២៦៨] (ព្រះរាជាព្រហ្មទត្ត សួរអាមាត្យពោធិសត្វថា) កំពូល (ជហ្វា) មួយហត្ថកន្លះ រង្វង់ជុំវិញកំពូលនោះ ៨ ចំអាម កំពូលនោះ ជាឈើផ្ទង់ខ្លឹមសុទ្ធ ឥតមានស្រាយ ឋិតនៅលើអ្វីហ្ន៎ បានជាមិនជ្រុះអំពីខាងលើមក។

[២៦៩] (ពោធិសត្វ ពោលតបថា) បង្កង់ទាំងឡាយណា ចំនួន ៣០ ខ្លឹមសុទ្ធ ឥតមានស្រាយ ឋិតនៅតំរៀបគ្នាជុំវិញ (កំពូលនោះ) បង្កង់ទាំងឡាយនោះ ទល់ទ្រផង គាបដោយកំឡាំងផង ឋិតនៅស្មើភាគគ្នា ទើបមិនធ្លាក់របូតអំពីខាងលើមក។

[២៧០] បណ្ឌិតបានពួកមិត្រដ៏មាំមួន មានសភាពមិនបែកចិត្តគ្នា មានប្រាជ្ញាដ៏ស្អាត ជួយទល់ទ្រហើយ រមែងមិនសាបសូន្យចាកសិរី ដូចជាកំពូល (ជហ្វា) ដែលបង្កង់នាំទៅនូវភារៈយ៉ាងនេះឯង។

[២៧១] បុគ្គលដែលមានកាំបិតក្នុងដៃ កាលបើមិនចិតផ្លែក្រចឆ្មារ ដែលមានសម្បករឹងចេញទេ រមែងធ្វើ (ផ្លែនេះ) ឲ្យមានរសល្វីង បពិត្រម្ចាស់ផែនដី បុគ្គលកាលនាំយក (សម្បកក្រៅចេញ) រមែងធ្វើឲ្យមានរសឆ្ងាញ់ កាលបើចិតសម្បកសើ ៗ ទេ រមែងធ្វើឲ្យមានរសមិនឆ្ងាញ់ មានឧបមាយ៉ាងណាមិញ។

[២៧២] ព្រះរាជាជាបណ្ឌិត វៀរ មិនលុះអំណាចកម្មដ៏ក្លៀវក្លា វៀរ (អគតិ) ក្នុងពួកអ្នកស្រុក អ្នកនិគម ប្រមូលមកនូវទ្រព្យទាំងឡាយ ជាអ្នកប្រព្រឹត្ត ប្រតិបត្តិតាមធម៌ មិនបៀតបៀនបុគ្គលដទៃ គប្បីធ្វើឲ្យសម្រេចបាន ក៏មានឧបមេយ្យយ៉ាងនោះដែរ។

[២៧៣] ផ្កាឈូក ជាអម្ពុជជាតិ មានឫសស កើតក្នុងទឹកដ៏ស្អាត ក្នុងស្រះបោក្ខរណី រីកស្គុះស្គាយដោយសារព្រះអាទិត្យ មិនជាប់ដោយភក់ មិនជាប់ដោយធុលី មិនជាប់ដោយទឹក មានឧបមាយ៉ាងណាមិញ។

[២៧៤] កម្មក្កិលេសប្រាកដដូច្នោះ មិនប្រឡាក់ (ចំពោះស្តេច) ដែលមានវោហារ (សម្រាប់វិនិច្ឆ័យ) ដ៏ស្អាត មិនមានកម្មជាសាហ័ស មានការងារដ៏ស្អាត មានបាបកម្មប្រាសចេញហើយ ដូចជាផ្កាឈូកដែលដុះក្នុងស្រះបោក្ខរណី ក៏មានឧបមេយ្យយ៉ាងនោះដែរ។

ចប់ កុក្កុជាតក ទី១។

## មនោជជាតក ទី២

CS sut.kn.jat.397 | ភាគទី ៥៩

**(៣៩៧. មនោជជាតកំ (៧-១-២))**

[២៧៥] (ចចកឮសំឡេងសីហៈ និងសំឡេងបន្លោះធ្នូ ហើយក៏ពោលគាថាពីរនេះថា) ធ្នូទន់ខ្លួបទៅផង បន្លោះលាន់ឮផង ដោយហេតុណា មិគរាជ ឈ្មោះមនោជៈ ជាសំឡាញ់របស់អញ ត្រូវគេសម្លាប់ដោយពិត (ដោយហេតុនោះ)។

[២៧៦] បើដូច្នោះ មានតែអញនឹងចៀសចេញ ទៅកាន់ព្រៃជាទីពឹងតាមសេចក្តីសប្បាយ ក្នុងពេលឥឡូវនេះ សត្វស្លាប់បែបនេះ នឹងយកធ្វើជាសំឡាញ់មិនកើត កាលបើអញរស់នៅ គង់បានសំឡាញ់ទៀត។

[២៧៧] (មាតាបិតា បងប្អូនស្រី ប្រពន្ធ ពោលគាថាទាំង ៥ នេះថា) បុគ្គលដែលសេពគប់ជាមួយនឹងជនបាប មិនបានសេចក្តីសុខដ៏ទៀងទាត់ឡើយ អ្នកចូរមើលសីហៈ ឈ្មោះមនោជៈ កំពុងដេក (ស្លាប់នេះ ព្រោះតែជឿតាម) ពាក្យប្រៀនប្រដៅរបស់ចចកឈ្មោះគិរិយៈ។

[២៧៨] មាតា មិនបានរីករាយជាមួយនឹងកូន ព្រោះតែគប់រកសំឡាញ់អាក្រក់ អ្នកចូរមើលសីហៈឈ្មោះមនោជៈ ដេកត្រាំនៅក្នុងឈាមរបស់ខ្លួន។

[២៧៩] សត្វណាមិនធ្វើតាមពាក្យនៃជនទាំងឡាយអ្នកប្រាថ្នានូវសេចក្តីចំរើន អ្នកឃើញនូវប្រយោជន៍ (ទៅក្នុងអនាគត) សត្វនោះរមែងដល់ (នូវសេចក្តីទុក្ខ) យ៉ាងនេះផង តែងចួបប្រទះនូវទោសដ៏លាមកក្រៃលែងផង។

[២៨០] បុគ្គលដ៏ឧត្តមណា សេពគប់នឹងអធម្មជន (ជនដ៏លាមក) បុគ្គលនោះ អាក្រក់ក្រៃលែងជាងអធម្មជននោះទៅទៀត យ៉ាងនេះ អ្នកចូរមើលនូវស្តេចនៃម្រឹគដ៏ឧត្តម ដែលសេពគប់នឹងអធម្មជន ត្រូវកំឡាំងនៃព្រួញដ៏ប្រសើរ មុតហើយ។

[២៨១] (ព្រះសាស្តា ទ្រង់ត្រាស់នូវអភិសម្ពុទ្ធគាថា ក្រោយបំផុតថា) បុរសអ្នកគប់រកនូវជនថោកទាប រមែងសាបសូន្យ បុគ្គលគប់រកនូវជនស្មើ ៗ គ្នា រមែងមិនសាបសូន្យ ក្នុងកាលណាឡើយ គប់រកនូវជនដែលប្រសើរជាង រមែងចំរើនឆាប់រួសរាន់ ព្រោះហេតុនោះ បុគ្គលគួរតែគប់រកនូវបុគ្គលដែលប្រសើរជាងខ្លួន។

ចប់ មនោជជាតក ទី២។

## សុតនជាតក ទី៣

CS sut.kn.jat.398 | ភាគទី ៥៩

**(៣៩៨. សុតនុជាតកំ (៧-១-៣ ))**

[២៨២] (ពោធិសត្វ ពោលថា) ស្តេចបានបញ្ជូនភត្ត ដែលលាយដោយសាច់ដ៏ស្អាត មកឲ្យអ្នក ម្នាលទេវតាអ្នកអាស្រ័យនៅលើដើមជ្រៃក្រឹម អ្នកចូរចេញមក ចូរបរិភោគចុះ។

[២៨៣] (យក្ខ ពោលថា) នែមាណព អ្នកចូរមក ចូរអ្នកយកបាយ ព្រមទាំងសម្លដាក់ចុះមក ម្នាលមាណព អ្នកនឹងបានជាចំណី (នៃយើង) អ្នកទាំងពីរនឹងបានជាចំណី។

[២៨៤] (ពោធិសត្វ ពោលថា) ម្នាលយក្ខ អ្នកនឹងលះបង់នូវប្រយោជន៍ធំ ព្រោះតែហេតុបន្តិចបន្តួច ពួកជនអ្នករង្កៀសនឹងសេចក្តីស្លាប់ នឹងលែងយកអាហារមកឲ្យអ្នកទៀតហើយ។

[២៨៥] ម្នាលយក្ខ អ្នកនឹងបាននូវនិច្ចភត្តដ៏ស្អាតថ្លៃថ្លា ប្រកបដោយរសដ៏ឧត្តម កាលបើអ្នកទំពាស៊ីយើងហើយ ជនអ្នកនាំយកអាហារមកឲ្យអ្នក មុខជាមិនងាយនឹងរកបាន ក្នុងទីនេះទៀតឡើយ។

[២៨៦] (យក្ខមានចិត្តជ្រះថ្លាហើយ បានពោលថា) ម្នាលសុតនមាណព អ្នកនិយាយ (បែបនេះ) ជាប្រយោជន៍ដល់ខ្ញុំមែនហើយ ខ្ញុំព្រមបើកលែងអ្នកទៅហើយ ចូរអ្នកចួបនឹងមាតាដោយសួស្តីចុះ។

[២៨៧] ម្នាលមាណព ចូរអ្នកកាន់យកព្រះខាន់ ឆ័ត្រ និងភាជន៍ទៅចុះ សូមឲ្យមាតារបស់អ្នក ឃើញអ្នកដោយសួស្តី អ្នកសោត ក៏ចូរទៅចួបនឹងមាតាចុះ។

[២៨៨] (ពោធិសត្វ ពោលថា) ម្នាលយក្ខ កាលបើយ៉ាងនេះ សូមឲ្យអ្នកបានសេចក្តីសុខ ព្រមទាំងពួកញាតិទាំងអស់ ទ្រព្យក៏ខ្ញុំបានហើយ ទាំងព្រះឱង្ការ របស់ព្រះរាជា ខ្ញុំបានធ្វើរួចហើយ។

ចប់ សុតនជាតក ទី៣។

## មាតុបោសកគិជ្ឈជាតក ទី៤

CS sut.kn.jat.399 | ភាគទី ៥៩

### (៣៩៩. មាតុបោសកគិជ្ឈជាតកំ (៧-១-៤))

[២៨៩] (ត្មាតពោធិសត្វ ពោលថា) មាតាបិតាទាំងនោះចាស់ អាស្រ័យនៅឰដ៍ច្រកនៃភ្នំ នឹងធ្វើដូចម្តេចហ្ន៎ អាត្មាអញជាប់អន្ទាក់ លុះអំណាចនេសាទបុត្ត ឈ្មោះនិលិយៈហើយ។

[២៩០] (នេសាទបុត្ត ពោលថា) ម្នាលត្មាត ហេតុដូចម្តេច ក៏បានជាអ្នកខ្សឹកខ្សួល ការខ្សឹកខ្សួលរបស់អ្នកដូចម្តេចហ្ន៎ បក្សីចេះនិយាយសំដីមនុស្ស យើងមិនដែលឮ មិនដែលឃើញសោះឡើយ។

[២៩១] (ពោធិសត្វ ពោលថា) យើងចិញ្ចឹមមាតាបិតាចាស់ អាស្រ័យនៅឰដ៍ច្រកនៃភ្នំ យើងលុះក្នុងអំណាចអ្នកហើយ មាតាបិតាទាំងនោះ នឹងធ្វើដូចម្តេចហ្ន៎។

[២៩២] (នេសាទបុត្ត ពោលថា) ក្រែងត្មាត រមែងមើលឃើញសាកសព ចម្ងាយ ១០០ យោជន៍ បានឬ ចុះហេតុអ្វី បានជាអ្នកមកជាប់លប់ និងអន្ទាក់ ក៏មិនភ្ញាក់ខ្លួនសោះ។

[២៩៣] (ពោធិសត្វ ពោលថា) ពេលណាដែលមានសេចក្តីវិនាស (មកដល់) ពេលនោះ សត្វដែលនឹងអស់ជីវិត បើទុកជាមកជាប់លប់ និងអន្ទាក់ ក៏គង់មិនអាចភ្ញាក់ខ្លួនបាន។

[២៩៤] (នេសាទបុត្ត ពោលថា) អ្នកចូរទៅចិញ្ចឹមមាតាបិតាចាស់ជរា ដែលអាស្រ័យនៅឰដ៍ច្រកនៃភ្នំចុះ យើងបានបើកលែងអ្នកហើយ ចូរអ្នកទៅចួបនឹងពួកញាតិសន្តាន ដោយសួស្តីចុះ។

[២៩៥] (ពោធិសត្វ ពោលថា) ម្នាលព្រាន អ្នកចូររីករាយជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនេះចុះ យើងនឹងចិញ្ចឹមមាតាបិតាចាស់ ដែលអាស្រ័យនៅឰដ៍ច្រកនៃភ្នំ។

ចប់ មាតុបោសកគិជ្ឈជាតក ទី៤។

## ទព្ភបុប្ផជាតក ទី៥

CS sut.kn.jat.400 | ភាគទី ៥៩

### (៤០០. ទព្ភបុប្ផជាតកំ (៧-១-៥ ))

[២៩៦] (ភេដែលត្រាច់ទៅក្នុងទឹកជ្រៅ ពោលថា) ម្នាលសំឡាញ់ អ្នកត្រាច់ទៅតាមឆ្នេរដ៏ចំរើន សូមអ្នកស្ទុះមកជួយខ្ញុំ ខ្ញុំចាប់បានត្រីធំ វានាំខ្ញុំទៅ ដោយកំឡាំងដ៏ខ្លាំង។

[២៩៧] (ភេត្រាច់ទៅតាមឆ្នេរក្រៅនេះ ពោលថា) ម្នាលអ្នកត្រាច់ទៅក្នុងទឹកជ្រៅដ៏ចំរើន អ្នកចូរចាប់ដោយកំឡាំងយ៉ាងមាំ ខ្ញុំនឹងជួយយោងយកត្រីនោះ ដូចគ្រុឌដែលស្រង់ឡើងនូវពស់។

[២៩៨] (ភេទាំងពីរឃើញចចកហើយ ពោលថា) ម្នាលចចកទព្ភបុប្ផៈ ចូរអ្នកស្តាប់ពាក្យយើង វិវាទកើតដល់យើងហើយ ម្នាលសំឡាញ់ អ្នកចូររម្ងាប់នូវជំលោះ ឲ្យវិវាទ (របស់យើង) ស្ងប់រម្ងាប់ទៅ។

[២៩៩] (ចចក ពោលថា) កាលពីដើម យើងជាអ្នកបិតនៅក្នុងតំណែងជម្រះក្តី បានកាត់ក្តីឲ្យគេជាច្រើនមកហើយ ម្នាលសំឡាញ់ យើងនឹងរម្ងាប់នូវជំលោះ (របស់អ្នកទាំងឡាយ) សូមឲ្យវិវាទ (របស់អ្នកទាំងឡាយ) ស្ងប់រម្ងាប់ទៅ។

[៣០០] ម្នាលភេអ្នកត្រាច់ទៅតាមឆ្នេរ (អ្នកត្រូវបាន) កន្ទុយ ភេដែលត្រាច់ទៅក្នុងទឹកជ្រៅ (ត្រូវបាន) ក្បាល ដុំជាកណ្តាលក្រៅអំពីចំណែកពីរនេះ ត្រូវបាន (យើង) អ្នកបិតនៅក្នុងតំណែងជម្រះក្តី។

[៣០១] (ភេទាំងពីរ ត្អូញថា) ប្រសិនបើយើងកុំទាស់គ្នា (ត្រីនេះ) នឹងបានជាអាហារអស់កាលដ៏យូរ ចចកពាំយកត្រីឆ្អិន ឥតក្បាល ឥតកន្ទុយទៅព្រៃហើយ។

[៣០២] (មេចចក ពោលថា) ខត្តិយរាជ បាននូវរាជសម្បត្តិហើយរីករាយ យ៉ាងណាមិញ ក្នុងថ្ងៃនេះ ខ្ញុំឃើញប្តីដែលមានមុខរីកហើយ ក៏មានចិត្តរីករាយ យ៉ាងនោះដែរ។

[៣០៣] អ្នកជាសត្វកើតលើគោកទេ ម្តេចក៏ចាប់ត្រីក្នុងទឹកបាន ម្នាលសំឡាញ់ ខ្ញុំសួរហើយ សូមអ្នកប្រាប់ អ្នកចាប់ (ត្រី) បាន ដោយហេតុដូចម្តេច។

[៣០៤] (ចចក ពោលថា) សត្វទាំងឡាយស្គាំងស្គម ព្រោះតែការទាស់ទែងគ្នា ការអស់ទ្រព្យសម្បត្តិ ក៏ព្រោះតែទាស់ទែងគ្នាដែរ ភេ

(ទាំងពីរ) សាបសូន្យ (ចាកត្រី) ព្រោះតែទាស់ទែងគ្នា នៃនាងមាយាវី នាងចូរបរិភោគនូវត្រីឆ្អិនចុះ។

[៣០៥] (អភិសម្ពុទ្ធគាថា) ក្នុងទីណា វិវាទកើតឡើងក្នុងពួកមនុស្ស (មនុស្សទាំងឡាយ) រមែងស្ទុះស្ទាទៅពឹងចៅក្រមអ្នកកាត់ក្តី ដ្បិតចៅក្រមនោះ ជាអ្នកដឹកនាំមនុស្សទាំងនោះ មនុស្សទាំងនោះ រមែងសាបសូន្យចាកទ្រព្យ (របស់ខ្លួន) ក្នុងទីនោះ ឃ្លាំងព្រះរាជា រមែងចំរើនក៏យ៉ាងនោះដែរ។

ចប់ ទព្វបុប្ផជាតក ទី៥។

## ទសណ្ណកជាតក ទី៦

CS sut.kn.jat.401 | ភាគទី ៥៩

### (៤០១. បណ្ណកជាតកំ (៧-១-៦ ))

[៣០៦] (ព្រះរាជា ទ្រង់សួរអាមាត្យឈ្មោះអាយុរៈថា) បុរសលេបដាវមានមុខដ៏មុត ដែលកើតក្នុងដែនឈ្មោះទសណ្ណកៈ ជាដាវផឹកឈាមឆ្អែតហើយ ក្នុងកណ្តាលបរិស័ទ ចុះអំពើអ្វី ដែលគេធ្វើបានដោយកម្រ ជាងកិរិយាលេបនូវដាវនោះទៅទៀត ខ្ញុំសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃ ដែលគេធ្វើបានដោយកម្រនោះ។

[៣០៧] (អាយុរាមាត្យ ពោលថា) បុរសលេបដាវដែលផឹកឈាមឆ្អែតហើយ ព្រោះតែលោភៈ បើបុគ្គលណា ពោលថា យើងនឹងឲ្យ (នូវវត្ថុនោះដល់អ្នក) ដូច្នេះ ពាក្យរបស់បុគ្គលនោះ ពិបាកធ្វើក្រៃលែង ជាងការលេបដាវនោះទៅទៀត បពិត្រព្រះមាគធរាជ ហេតុដទៃទាំងអស់ (ក្រៅអំពីពាក្យនេះ) គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាប យ៉ាងនេះចុះ។

[៣០៨] (ព្រះរាជា ទ្រង់ចរចាជាមួយនឹងបុក្កុសាមាត្យថា) អាយុរបណ្ឌិត ជាអ្នកឈ្លាសវៃក្នុងធម៌ បានដោះស្រាយនូវសេចក្តីនៃប្រស្នាឥឡូវនេះ យើងនឹងសាកសួរ ចំពោះបុក្កុសបណ្ឌិតវិញ អំពើអ្វីដែលបុគ្គលធ្វើបានដោយកម្រ ជាងពាក្យនោះទៅទៀត យើងសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃ ដែលបុគ្គលធ្វើបានដោយកម្រនោះ (ដល់យើង)។

[៣០៩] (បុក្កុសបណ្ឌិត ពោលថា) ពួកមនុស្សរស់នៅ (ព្រោះអាស្រ័យ) នូវវាចាឥតផល ជាសំដីដែលគេពោលឥតអង្គឹមានឡើយ បុគ្គលណា បានឲ្យ (ពាក្យប្តេជ្ញា) ហើយក៏បានកាត់ផ្តាច់ចោល (នូវលោភៈ) ពាក្យប្តេជ្ញានោះ ជាការធ្វើដោយលំបាក ជាងការលេបដាវនឹងជាងពាក្យនោះទៅទៀត បពិត្រព្រះបាទមាគធរាជ ហេតុដទៃទាំងអស់ គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ។

[៣១០] (ព្រះរាជា ទ្រង់សួរសេនកបណ្ឌិតថា) បុក្កុសបណ្ឌិត ជាអ្នកឈ្លាសវៃក្នុងធម៌ បានឆ្លើយនូវសេចក្តីនៃប្រស្នារួចហើយ ឥឡូវនេះ យើងនឹងសួរចំពោះសេនកបណ្ឌិត អ្វីអេះ ដែលបុគ្គលធ្វើបានដោយលំបាក ជាងពាក្យប្តេជ្ញានោះទៅទៀត យើងសួរហើយ អ្នកចូរប្រាប់នូវហេតុដទៃ ដែលបុគ្គលធ្វើបានដោយលំបាកនោះ (ដល់យើង)។

[៣១១] (សេនកបណ្ឌិត ពោលថា) បុរសគួរឲ្យនូវទាន ទោះបីតិចក្តី ច្រើនក្តី បើបុគ្គលណាបានឲ្យហើយ មិនក្តៅក្រហាយស្តាយក្រោយអំពើនោះ ជាការធ្វើបានដោយលំបាក ជាងការលេបដាវជាដើមនោះទៅទៀត បពិត្រព្រះបាទមាគធរាជ ហេតុដទៃទាំងអស់ គេធ្វើបានដោយងាយទេ សូមព្រះអង្គទ្រង់ជ្រាបយ៉ាងនេះចុះ។

[៣១២] (ព្រះរាជា សរសើរពោធិសត្វ ហើយពោលគាថាទីបំផុតថា) អាយុរបណ្ឌិត បានឆ្លើយប្រស្នារួចហើយ ទាំងបុក្កុសបុរសក៏ដូចគ្នា សេនកបណ្ឌិត និយាយដោះស្រាយប្រស្នាទាំងអស់ តាមសមគួរ។

ចប់ ទសណ្ណកជាតក ទី៦។

## សេនកជាតក ទី៧

CS sut.kn.jat.402 | ភាគទី ៥៩

### (៤០២. សត្តុភស្តជាតកំ (៧-១-៧))

[៣១៣] (សេនកបណ្ឌិតពោធិសត្វ ពោលថា) អ្នកមានចិត្តក្រឡុក មានចក្ខុន្ទ្រិយកម្រើក ដំណក់ទឹកហូរចេញអំពីភ្នែករបស់អ្នក ម្នាលព្រាហ្មណ៍ អ្នកបាត់របស់អ្វី ឬក៏អ្នកប្រាថ្នាចង់បានរបស់អ្វី បានជាមកក្នុងទីនេះ ចូរអ្នកប្រាប់មកមើល។

[៣១៤] (ព្រាហ្មណ៍ ពោលថា) យក្ខពោលថា កាលបើខ្ញុំទៅដល់ (ផ្ទះ) ក្នុងថ្ងៃនេះ ប្រពន្ធ (របស់ខ្ញុំ) នឹងស្លាប់ កាលបើខ្ញុំទៅមិនដល់ (ផ្ទះ) ទេ ខ្ញុំនឹងស្លាប់ ដោយសេចក្តីទុក្ខនេះ បានជាខ្ញុំរន្ធត់ចិត្ត បពិត្រសេនកៈ សូមលោកប្រាប់សេចក្តីនេះដល់ខ្ញុំ។

[៣១៥] (ពោធិសត្វ ពោលថា) យើងរិះគិតនូវហេតុច្រើនយ៉ាង បណ្តាហេតុទាំងនោះ យើងនឹងប្រាប់ហេតុណាមួយ ហេតុនោះឯងជារបស់ពិត ម្នាលព្រាហ្មណ៍ យើងយល់ថា អ្នកមិនបានដឹងទេ មានពស់វែកលូនចូលក្នុងថង់ស្ងួរ។

[៣១៦] (ពោធិសត្វ ពោលថា) អ្នកចូរយកដំបងគោះថង់មើល អ្នកចូរមើលពស់ ដែលមានអណ្តាតពីរ ហៀរទឹកមាត់ចេញមក អ្នកចូរកាត់បង់នូវសេចក្តីសង្ស័យផង នូវសេចក្តីងឿងឆ្ងល់ផង ក្នុងថ្ងៃនេះ អ្នកចូរមើលពស់ អ្នកចូរទំលាក់ថង់ចោលទៅ។

[៣១៧] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ព្រាហ្មណ៍នោះ មានសភាពតក់ស្លុត ក្នុងកណ្តាលបរិស័ទ ហើយក៏បោះថង់នៃសដូវចោល ទើបពស់ជាសត្វអាសិរពិស លូនទៅដោយឫទ្ធ មានតេជះក្លា ក៏បើកពពារលូនចេញមក។

[៣១៨] (ព្រាហ្មណ៍ ពោលថា) ព្រះរាជាជនកៈអង្គណា បានជួបនឹងសេនកបណ្ឌិត អ្នកមានប្រាជ្ញាឆើត ព្រះរាជាជនកៈ (អង្គនោះ) ឈ្មោះថា មានលាភបានហើយដោយប្រពៃ (ព្រាហ្មណ៍លុះសរសើរព្រះរាជាហើយ ក៏សរសើរពោធិសត្វថា) បពិត្រព្រាហ្មណ៍អ្នកមានធម៌កំបាំង (ញេយ្យធម៌) បើកហើយ ជាអ្នកឃើញនូវធម៌ទាំងអស់ឬ បានជាញាណរបស់អ្នកគួរស្ញប់ស្ញែងម្ល៉េះ ខ្ញុំមានកហាបណៈប្រាំពីររយនេះ សូមអ្នកយកទាំងអស់ចុះ ខ្ញុំជូនអ្នក ដ្បិតខ្ញុំបានជីវិតក្នុងថ្ងៃនេះ ដោយសារអ្នក មិនតែប៉ុណ្ណោះសោត ថែមទាំងអ្នកបានធ្វើសួស្តី ដល់ភរិយា (របស់ខ្ញុំ) ទៀតផង។

[៣១៩] (ពោធិសត្វ ពោលថា) បណ្ឌិតទាំងឡាយ មិនបានទទួលយករង្វាន់ដោយពោលគាថាទាំងឡាយដ៏វិចិត្រទេ ម្នាលព្រាហ្មណ៍

(ជនទាំងឡាយ) ឲ្យទ្រព្យអំពីបាទមូលរបស់យើងនេះ ដល់អ្នក អ្នកចូរយក ហើយចូរទៅកាន់លំនៅរបស់ខ្លួនចុះ។

ចប់ សេនកជាតក ទី៧។

## អដ្ឋិសេនជាតក ទី៨

CS sut.kn.jat.403 | ភាគទី ៥៩

### (៤០៣. អដ្ឋិសេនកជាតកំ (៧-១-៨))

[៣២០] (ព្រះបាទពារាណសី សួរពោធិសត្វថា) បពិត្រតាបស ព្រះនាមអដ្ឋិសេនៈ ខ្ញុំមិនដែលស្គាល់ពួកស្មូមណា ពួកស្មូមនោះ ប្រជុំគ្នាមករកខ្ញុំ ហើយសូម (នូវវត្ថុដែលខ្លួនត្រូវការ) ហេតុអ្វីក៏លោកមិនសូមខ្ញុំ។

[៣២១] (តាបសពោធិសត្វ ពោលថា) បុគ្គលអ្នកសូម រមែងមិនជាទីស្រឡាញ់ (នៃអ្នកឲ្យ) បុគ្គលអ្នកមិនឲ្យនូវរបស់ដែលគេសូម រមែងមិនជាទីស្រឡាញ់ (នៃស្មូម) ព្រោះហេតុនោះ បានជាអាត្មាមិនសូមមហារាជ កុំឲ្យមហារាជស្អប់អាត្មាឡើយ។

[៣២២] (ព្រះរាជា ត្រាស់ថា) សមណព្រាហ្មណ៍ណា រស់ដោយការសូម តែមិនសូមវត្ថុដែលខ្លួនត្រូវសូម ក្នុងកាលគួរ (សមណព្រាហ្មណ៍នោះ) ឈ្មោះថា ញ៉ាំងបុគ្គលដទៃ ឲ្យខូចបុណ្យផង ឈ្មោះថាមិនបានរស់ស្រួល ដោយខ្លួនឯងផង។

[៣២៣] សមណព្រាហ្មណ៍ណា រស់ដោយការសូម ហើយសូមនូវវត្ថុដែលខ្លួនត្រូវការសូម ក្នុងកាលគួរ (សមណព្រាហ្មណ៍នោះ) ឈ្មោះថា ញ៉ាំងបុគ្គលដទៃឲ្យបានបុណ្យផង ឈ្មោះថា រស់នៅស្រួលដោយខ្លួនឯងផង។

[៣២៤] បុគ្គលមានប្រាជ្ញាទាំងឡាយ ឃើញពួកស្មូមមកដល់ហើយ មិនដែលប្រទូស្ត លោកជាព្រហ្មចារីបុគ្គល ជាទីស្រឡាញ់នៃខ្ញុំ លោកប្រាថ្នារបស់ណា ដែលត្រូវនិយាយសូម លោកចូរសូមចុះ។

[៣២៥] (ពោធិសត្វ ពោលថា) បុគ្គលមានប្រាជ្ញាទាំងឡាយ មិនដែលសូមទេ ស្រេចតែនឹង (ឧបដ្ឋាក) អ្នកមានប្រាជ្ញា គួរដឹង (ខ្លួនឯងចុះ) ពួកអរិយៈ គ្រាន់តែឈរឧទ្ទិសស្ងៀម ៗ ប៉ុណ្ណោះ នុ៎ះជាការសូមរបស់ពួកអរិយៈ។

[៣២៦] (ព្រះរាជា ពោលថា) បពិត្រព្រាហ្មណ៍ ខ្ញុំសូមប្រគេនមេគោមានសម្បុរក្រហម ១ ពាន់ ព្រមទាំងគោឈ្មោល ដល់លោកម្ចាស់ ដ្បិតថា បុគ្គលមានមារយាទដ៏ប្រសើរ បានស្តាប់គាថារបស់លោក ដែលប្រកបដោយធម៌ហើយ មិនឲ្យដល់បុគ្គលមានអាចារៈដ៏ប្រសើរ (ដូចគ្នា) ដូចម្តេចបាន។

ចប់ អដ្ឋិសេនជាតក ទី៨។

## កបិជាតក ទី៩

CS sut.kn.jat.404 | ភាគទី ៥៩

### (៤០៤. កបិជាតកំ (៧-១-៩))

[៣២៧] (ពានរពោធិសត្វ ពោលថា) បុគ្គលមានពៀរ អាស្រ័យនៅក្នុងទីណា បណ្ឌិតមិនគប្បីនៅក្នុងទីនោះទេ (ព្រោះ) នៅក្នុងពួកបុគ្គលមានពៀរ មួយយប់ក្តី ពីរយប់ក្តី ជាទុក្ខ។

[៣២៨] បុគ្គលអ្នកមានចិត្តស្រាល គប្បីជាសត្រូវដល់សត្វអ្នកប្រព្រឹត្តតាម សេចក្តីមិនចំរើនដែលព្រាហ្មណ៍ធ្វើហើយ ដល់ហ្វូងស្វា ព្រោះហេតុតែស្វាមួយ។

[៣២៩] បុគ្គលល្ងង់ តែប្រកាន់ខ្លួនឯងថាជាបណ្ឌិត ហើយរក្សាពួកក្រុម ជាអ្នកលុះអំណាចចិត្តរបស់ខ្លួន រមែងដេក (ស្លាប់) ដូចស្វានេះឯង។

[៣៣០] បុគ្គលល្ងង់មានកំឡាំង ជាអ្នករក្សាពួកក្រុម មិនប្រពៃទេ មិនមានសេចក្តីចំរើនដល់ពួកញាតិ ដូចទទាធ្នាក់ មិនជាប្រយោជន៍ដល់ពួកសត្វស្លាប (ដែលជាញាតិ)។

[៣៣១] ឯបុគ្គលមានប្រាជ្ញា មានកំឡាំង រក្សាពួកក្រុមវិញ ទើបប្រពៃ រមែងចំរើនដល់ពួកញាតិ ដូចជាវាសវៈទេវរាជ (ជាប្រយោជន៍) ដល់ពួកទេវតាក្នុងឋានត្រៃត្រឹង្ស។

[៣៣២] បុគ្គលណាមួយឃើញថា ខ្លួនឯងមានសីលផង មានបញ្ញាផង មានសុតៈផង (បុគ្គលនោះ) តែងប្រព្រឹត្តប្រយោជន៍ដើម្បីខ្លួន និងអ្នកដទៃទាំងពីរ។ ព្រោះហេតុនោះ អ្នកប្រាជ្ញ កាលបើគ្មេរគ្មាន់មើលខ្លួន មានសីល មានបញ្ញា និងសុតៈហើយ គប្បីថែរក្សាពួកក្រុមក៏បាន គប្បីប្រព្រឹត្តនៅតែម្នាក់ឯងក៏បាន។

ចប់ កបិជាតក ទី៩។

## ពកព្រហ្មជាតក ទី១០

CS sut.kn.jat.405 | ភាគទី ៥៩

### (៤០៥. ពកជាតកំ (៧-១-១០))

[៣៣៣] (ពកព្រហ្ម ពោលថា) បពិត្រព្រះគោតម ពួកយើង ៧២ រូប មានអំពើជាបុណ្យ ជាអ្នកមានអំណាចប្រព្រឹត្តទៅ កន្លងផុតជាតិនិងជរាបាន នេះជាការដល់នូវវេទ ជាកំណើតដ៏ប្រសើរ មានក្នុងទីបំផុត (របស់ពួកយើង) ពួកជនច្រើនរូប តែងប្រាថ្នាទីនេះ។

[៣៣៤] (ព្រះសាស្តា ត្រាស់ថា) នែពកៈ អ្នកសំគាល់ថា អាយុណាជាធម្មជាតវែង អាយុនុ៎ះខ្លីទេ មិនមែនវែងឡើយ ម្នាលព្រហ្ម តថាគតដឹងអាយុរបស់អ្នកមួយសែននិរព្វុទៈ (ប៉ុណ្ណោះឯង)។

[៣៣៥] (ពកព្រហ្ម ថា) បពិត្រព្រះមានព្រះភាគ ព្រះអង្គមានព្រះបន្ទូលថា តថាគតជាអ្នកឃើញមិនមានទីបំផុត កន្លងផុតស្រឡះនូវជាតិ និងជរាផង នូវសេចក្ដីសោកផង តើវត និងសីលវត្តរបស់ខ្ញុំ ពីដើមដូចម្ដេចខ្លះ សូមព្រះអង្គប្រាប់នូវវត និងសីលវត្ត ដែលខ្ញុំគួរដឹងនុ៎ះដល់ខ្ញុំ។

[៣៣៦] (ព្រះមានព្រះភាគ ទ្រង់ត្រាស់ថា) អ្នកបានញុំាងពួកមនុស្សច្រើន ដែលស្រេកទឹក លំបាកដោយកំដៅថ្ងៃ ឲ្យផឹកហើយ នោះឯងជាវត្តសមាទាន និងសីលវត្ត របស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង។

[៣៣៧] អ្នកបានដោះលែងនូវពួកជនឈ្លើយ ដែលចោរចាប់នាំយកទៅទៀបឆ្នេរនៃស្ទឹងឈ្មោះឯណី នោះឯង ជាវត្តសមាទាន និងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង។

[៣៣៨] អ្នកបានគំរាមដោយកំឡាំង ហើយដោះលែងនូវទូកដែលនាគរាជអាក្រក់បំរុងនឹងពន្លិចចោល ក្នុងខ្សែនៃទឹកស្ទឹង ព្រោះវាចង់ធ្វើមនុស្សឲ្យវិនាស នោះឯង ជាវត្តសមាទាន និងសីលវត្តរបស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង។

[៣៣៩] តថាគតឈ្មោះកប្បៈ ធ្លាប់ជាកូនសិស្សរបស់អ្នក តថាគតបានសំគាល់ថា អ្នកជាបុគ្គលមានប្រាជ្ញា មានវត្តប្រតិបត្តិ នោះឯងជាវត្តសមាទាន និងសីលវត្ត របស់អ្នកពីដើម តថាគតរឭកឃើញ ដូចជាបុគ្គលដេកលក់ហើយភ្ញាក់ឡើង។

[៣៤០] (ពកព្រហ្ម ពោលថា) ព្រះអង្គជ្រាបច្បាស់នូវអាយុរបស់ខ្ញុំនុ៎ះដោយពិតផង ជ្រាបច្បាស់នូវហេតុដទៃផង ព្រះអង្គជាព្រះពុទ្ធមែន នេះជាអានុភាពដ៏រុងរឿងរបស់ព្រះអង្គ ដែលញុំាងព្រហ្មលោកឲ្យភ្លឺរុងរឿង។

ចប់ ពកព្រហ្មជាតក ទី១០។

ចប់ កុក្កុវគ្គ ទី១។

ឧទ្ទាននៃជាតក ក្នុងកុក្កុវគ្គនោះគឺ

និយាយអំពីកំពូលដ៏ប្រសើរ ១ បំពង់ព្រួញដ៏ប្រសើរ ១ សុតនជាតក ១ ត្មាត ១ ត្រីឆ្កិន ១ ដាវកើតក្នុងស្រុកទសណ្ណកៈ ១ សេនកបណ្ឌិត ១ យាចក ១ បុគ្គលមានពៀរ ១ ពកព្រហ្ម ១ រួមត្រូវជា ១០។

## គន្ធារវគ្គ ទី២

CS sut.kn.jat.v07.02 | ភាគទី ៥៩

**(២. គន្ធារវគ្គោ)**

### គន្ធារជាតក ទី១

CS sut.kn.jat.406 | ភាគទី ៥៩

**(៤០៦. គន្ធារជាតកំ (៧-២-១))**

[៣៤១] (តាបសពោធិសត្វ ពោលថា) អ្នកលះបង់នូវស្រុកចំណុះ ១ ពាន់ និងឃ្លាំង ១៦ ដ៏ពេញបរិបូណ៌ (ដោយទ្រព្យ) ធ្វើនូវការសន្សំក្នុងកាលឥឡូវនេះ។

[៣៤២] (វិទេហតាបស ពោលថា) អ្នកលះបង់នូវដែនគន្ធារៈ ដែលជាដែនសម្បូណ៌ដោយទ្រព្យ និងទឹក ហើយចេញផុតអំពីទីជាទីឲ្យនូវពាក្យប្រៀនប្រដៅ (ដូចខ្ញុំដែរ) ឥឡូវនេះ (ហេតុអ្វីក៏មក) ប្រៀនប្រដៅ (យើង) ក្នុងព្រៃនេះ។

[៣៤៣] (ពោធិសត្វ ពោលថា) ម្នាលវិទេហៈ ខ្ញុំនិយាយចំពោះតែធម៌ សភាវៈមិនមែនជាធម៌ មិនគាប់ចិត្តខ្ញុំទេ កាលបើខ្ញុំនិយាយធម៌ បាបឥតប្រឡាក់បានទេ។

[៣៤៤] (វិទេហតាបស ពោលថា) បុគ្គលដទៃបាននូវសេចក្ដីក្រោធ ព្រោះពាក្យណានីមួយ បណ្ឌិតមិនគប្បីពោលនូវពាក្យនោះឡើយ បើទុកជាពាក្យមានប្រយោជន៍ដ៏ធំក៏ដោយ។

[៣៤៥] (ពោធិសត្វ ពោលថា) បុគ្គលទោះខឹងក៏ដោយ មិនខឹងក៏ដោយ ទោះរាយរាយដូចអង្កាមក៏ដោយ កាលបើខ្ញុំនិយាយធម៌ បាបមិនប្រឡាក់បានទេ។

[៣៤៦] ប្រសិនបើប្រាជ្ញារបស់ខ្លួនក្ដី វិន័យដែលសិក្សាល្អក្ដី មិនមានទេ ជនច្រើនគ្នាតែងប្រព្រឹត្តដូចជាក្របីខ្វាក់ក្នុងព្រៃ។

[៣៤៧] មួយទៀត ជនពួកខ្លះក្នុងលោកនេះ បានសិក្សាល្អ ក្នុងអាចារប្បញ្ញត្តិ ព្រោះហេតុនោះ (ធីរជន) អ្នកមានវិន័យទូន្មានហើយ រមែងមានចិត្តតាំងមាំល្អ។

ចប់ គន្ធីរជាតក ទី១។

### មហាកបិជាតក ទី២

CS sut.kn.jat.407 | ភាគទី ៥៩

**(៤០៧. មហាកបិជាតកំ (៧-២-២))**

[៣៤៨] (ព្រះរាជាពារាណសី ត្រាស់សួរថា) ម្នាលស្វាដ៏ប្រសើរ អ្នកបានធ្វើខ្លួនឲ្យជាស្ពាន ហើយចម្លង (ពួកស្វាទាំងនេះ) ឲ្យឆ្លងទៅដល់ទីសួស្ដី តើអ្នកត្រូវជាអ្វីនឹងពួកស្វាទាំងនោះ ឯស្វាទាំងនោះ ត្រូវជាអ្វីនឹងអ្នក។

[៣៤៩] (ស្ដេចស្វាពោធិសត្វ ទូលតបថា) បពិត្រព្រះបាទអរិន្ទមៈ (អ្នកបង្ក្រាបសត្រូវ) ខ្ញុំជាស្ដេច ជាឥស្សរៈលើស្វាទាំងនោះ ជាអ្នក

គ្រប់គ្រងហ្វូងស្វាទាំងនោះ ដែលត្រូវសេចក្តីសោកគ្របសង្កត់ ជាអ្នកខ្លាចព្រះអង្គ។

[៣៥០] ខ្ញុំលោតខ្លួនអំពីឈើនេះ ទៅកាន់ទីប្រមាណ ១ រយធ្នូវត្ថ ដែលគេលើកឡើង ហើយចងវល្លិផ្តៅដ៏មាំ ត្រង់សរីរៈជាខាងក្រោយនៃជើង (ចង្កេះ)។

[៣៥១] ខ្ញុំលោតទៅកាន់ដើមឈើដោយខ្យល់ ដូចជាពពកដែលខ្យល់ផ្តាច់ហើយ ខ្ញុំនោះទៅមិនដល់ ក៏លូកដៃទៅចាប់មែក (នៃឈើ) ព្វដ៏អាកាសប៉្បទេសនោះ។

[៣៥២] ពួកស្វាលើកជើងជាន់លើខ្ញុំនោះ ដែលដេកសន្ធឹងដូចខ្សែចាប៉ី ដោយមែកឈើផង ដោយវល្លិផ្តៅផង ហើយនាំគ្នាទៅដោយសួស្តី។

[៣៥៣] ខ្ញុំនោះមិនក្តៅក្រហាយនឹងការចង ខ្ញុំនឹងមិនក្តៅក្រហាយនឹងការសម្លាប់ឡើយ (ព្រោះ) ខ្ញុំសោយរាជ្យ (ត្រួតត្រា) លើពួកស្វាណា សេចក្តីសុខ ខ្ញុំបាននាំមកឲ្យពួកស្វានោះហើយ។

[៣៥៤] បពិត្រព្រះបាទអរិន្ទមៈ នេះជាសេចក្តីប្រៀបធៀបចំពោះព្រះអង្គ សូមព្រះអង្គស្តាប់នូវឱវាទនោះ ខត្តិយរាជមានប្រាជ្ញា ត្រូវផ្តល់សេចក្តីសុខដល់ពួកជនទាំងអស់ គឺអ្នកដែនផង យាន (វាហនៈសម្រាប់ទឹម) ផង ពលថ្មើរជើងផង អ្នកនិគមផង។

ចប់ មហាកបិជាតក ទី២។

## កុម្ភការជាតក ទី៣

CS sut.kn.jat.408 | ភាគទី ៥៩

### (៤០៨. កុម្ភការជាតកំ (៧-២-៣ ))

[៣៥៥] (ព្រះបច្ចេកពុទ្ធ ៤ អង្គ ពោលគាថាមួយ ៗ ថា) អាត្មាបានឃើញដើមស្វាយដុះលូតលាស់ក្នុងកណ្តាលព្រៃស្វាយ មានពណ៌ខៀវ មានផ្លែ អាត្មាឃើញស្វាយនោះបាក់ខ្ទេចខ្ទី ព្រោះហេតុតែផ្លែ លុះឃើញស្វាយនោះហើយ ទើបអាត្មាប្រព្រឹត្តនូវភិក្ខាចារ (ទៅបួស)។

[៣៥៦] នាងនារី (ម្នាក់) ពាក់កងជាវិការៈនៃកែវមណី ១ គូ ដ៏ស្អាតរលោង ដែលជនអ្នកចេះធ្វើឲ្យសម្រេចហើយ ឥតឮសូរសំឡេង (ទង្គិចគ្នាឡើយ) លុះដល់អាស្រ័យយកមកពាក់ជាមួយគ្នានឹងកងទី ២ ក៏ (ទង្គិចគ្នា) ឮសូរសំឡេង អាត្មាបានឃើញនូវកងនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ។

[៣៥៧] ពួកបក្សីច្រើនចោមរោម ដេញចឹកបក្សី ១ កំពុងពាំដុំសាច់ ព្រោះហេតុតែអាហារ អាត្មាបានឃើញបក្សីនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ។

[៣៥៨] អាត្មាឃើញគោឧសភៈ (មួយ) កណ្តាលហ្វូង មានបូកជ្រញ ៗ បរិបូណ៌ដោយសម្បុរ និងកំឡាំង អាត្មាបានឃើញគោឧសភៈនោះ ត្រូវគោឧសភៈដទៃ បុះមុត (ធ្លាយពោះវៀន) ព្រោះហេតុតែកាម លុះបានឃើញគោឧសភៈនោះហើយ ទើបប្រព្រឹត្តនូវភិក្ខាចារ។

[៣៥៩] (ពោធិសត្វ ពោលថា) ព្រះរាជារបស់អ្នកដែនកលិង្គៈ ព្រះនាមករណ្ឌកៈ ព្រះរាជារបស់អ្នកដែនគន្ធារៈ ព្រះនាមនគ្គជិ ព្រះរាជារបស់អ្នកដែនវិទេហៈ ព្រះនាមនិមិរាជ ព្រះរាជារបស់អ្នកដែនបញ្ចាលៈ ព្រះនាមទុម្មុខៈ ព្រះរាជាទាំង ៤ ព្រះអង្គនុ៎ះ លះបង់នូវដែនទាំងឡាយ ជាអ្នកឥតកង្វល់ បួសហើយ។

[៣៦០] ព្រះរាជាទាំងអស់អង្គនេះ ប្រហែលគ្នានឹងវិសុទ្ធិទេវតា បានមកចួបគ្នាហើយ ព្រះរាជាទាំងនេះ (រុងរឿងដោយគុណទាំងឡាយមានសីលគុណជាដើម) ដូចជាភ្លើងដែលភ្លឺរុងរឿងដូច្នោះឯង ម្នាលនាងមានភគ្គ ចំណែកខាងបង ក៏នឹងលះបង់នូវកាមទាំងឡាយជាចំណែកដែលខ្លួននឿយណាយហើយ ប្រព្រឹត្តតែម្នាក់ឯង។

[៣៦១] (ភរិយានោះ ពោលថា) កាលនេះ ជាកាលគួរ (នឹងបួសហើយ) ឥតមានកាលដទៃទៀតឡើយ (ព្រោះ) ដល់ទៅពេលក្រោយ បុគ្គលជាអ្នកប្រៀនប្រដៅខ្ញុំ មិនមានទេ បពិត្រអ្នកមានភគ្គ ខ្ញុំនឹងប្រព្រឹត្តតែម្នាក់ឯង ដូចជាមេបក្សីដែលរួចអំពីដៃនៃបុរស។

[៣៦២] (ព្រះមហាសត្វ ពោលថា ទារកទាំងឡាយនោះ) ស្គាល់បាយឆៅ បាយឆ្អិន ទាំងស្គាល់បាយប្រៃ និងបាយសាបហើយ លុះយើងឃើញកិរិយារបស់ទារកនោះហើយ ទើបបួស នាងចូរប្រព្រឹត្តស្វែងរកនូវភិក្ខាចារចុះ យើងក៏នឹងប្រព្រឹត្តស្វែងរកនូវភិក្ខាចារដែរ។

ចប់ កុម្ភការជាតក ទី៣។

## ទឡ្ហធម្មជាតក ទី៤

CS sut.kn.jat.409 | ភាគទី ៥៩

### (៤០៩. ទឡ្ហធម្មជាតកំ (៧-២-៤))

[៣៦៣] (មេដំរីឈ្មោះឱដ្ឋិព្យាធិ បានពោលនឹងអាមាត្យពោធិសត្វថា) ខ្ញុំកាលនាំទៅ (នូវកិច្ច) របស់ព្រះបាទទឡ្ហធម្មៈ នាំទៅនូវសរ (ដែលគេចង) ត្រង់ទ្រូង ហើយត្រាច់ទៅក្នុងទីចម្បាំង ដោយសេចក្តីប្រឹងប្រែង ក៏គង់ញ៉ាំងព្រះអង្គឲ្យសព្វព្រះរាជហឫទ័យមិនបាន។

[៣៦៤] ព្រះរាជាមិនជ្រាបនូវសេចក្តីប្រឹងប្រែងរបស់បុរសដែលខ្ញុំបានធ្វើដោយពិត ទាំងការនាំសំបុត្រចុះឡើងក្នុងសង្គ្រាម ក៏ខ្ញុំបានធ្វើល្អហើយ។

[៣៦៥] ខ្ញុំនោះជាអ្នកឥតផៅពង្ស ឥតទីពំនាក់ មុខជានឹងស្លាប់មិនខាន ព្រោះក្នុងពេលនោះ ព្រះរាជាបានទ្រង់ប្រទានខ្ញុំឲ្យជាអ្នកនាំនូវអាចម៍គោដល់ស្មូនឆ្នាំង។

[៣៦៦] (ពោធិសត្វទូលព្រះរាជាថា) បុរសប្រាជ្ញា (ប្រយោជន៍) ដរាបណា រមែងគប់រក (នឹងគេ) ដរាបនោះ ជនទាំងឡាយ រមែងលះបង់ចោលគេក្នុងពេលដែលគេសាបសូន្យចាកសេចក្តីចំរើនដូចជាក្សត្រ (លះបង់ចោល) នូវមេដំរី ឈ្មោះឱដ្ឋិព្យាធិនោះ។

[៣៦៧] បុគ្គលណា នឹកមិនឃើញនូវអំពើល្អដែលអ្នកដទៃធ្វើហើយ និងប្រយោជន៍ដែលអ្នកដទៃធ្វើហើយ (ដល់ខ្លួន) ក្នុងកាលមុន ប្រយោជន៍ទាំងឡាយ ដែលបុគ្គលនោះប្រាថ្នា រមែងសាបសូន្យ។

[៣៦៨] បុគ្គលណានឹកឃើញនូវអំពើល្អដែលអ្នកដទៃធ្វើហើយ និងប្រយោជន៍ដែលអ្នកដទៃធ្វើហើយ (ដល់ខ្លួន) ក្នុងកាលមុន ប្រយោជន៍ទាំងឡាយណា ដែលបុគ្គលនោះប្រាថ្នាហើយ រមែងចំរើន។

[៣៦៩] ព្រោះហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នកទាំងឡាយ សូមសេចក្តីចំរើន (កើតមាន) ដល់អ្នកទាំងឡាយ ដែលបានអញ្ជើញមកជួបជុំក្នុងទីនេះទាំងអម្បាលមាន អ្នកទាំងអស់គ្នា ចូរជាអ្នកដឹងនូវឧបការៈដែលអ្នកដទៃបានធ្វើហើយ (ដល់ខ្លួន) អ្នកទាំងឡាយនឹងបានឋិតនៅក្នុងឋានសួគ៌អស់កាលយូរ។

ចប់ ទទ្ទុធម្មជាតក ទី៤។

## សោមទត្តជាតក ទី៥

CS sut.kn.jat.410 | ភាគទី ៥៩

### (៤១០. សោមទត្តជាតកំ (៧-២-៥))

[៣៧០] (តាបសយំទួញរកដំរីថា) កាលពីមុន ដំរីណាមកអំពីចម្ងាយ ទទួលអាត្មាអញក្នុងព្រៃ (ឥឡូវនេះ) ដំរីឈ្មោះសោមទត្តនោះ ទៅក្នុងទីណា បានជាបាត់ មិនឃើញមក។

[៣៧១] (តាបសនោះ ឃើញដំរីនោះដួលស្លាប់ ហើយពោលថា) ដំរីដេកស្លាប់នេះ គឺដំរីនេះឯង ដំរីសោមទត្តដួលដេកលើផែនដី ដូចជាត្រួយជ្រៃដែលបុគ្គលកិ្តចហើយ ដំរី (នោះ) មិនទាន់ស្លាប់ទេហ្ន៎។

[៣៧២] (ខណៈនោះ សក្កទេវរាជពោលថា) លោកសោកស្តាយដំរីណា ដែលស្លាប់បាត់ទៅហើយ ការសោកស្តាយដំរីនោះ មិនសមគួរដល់លោកដែលចូលមកកាន់ផ្នួស ជាសមណៈមានចិត្តរួចស្រឡះសោះឡើយ។

[៣៧៣] (តាបស ពោលថា) បពិត្រសក្កៈ សេចក្តីស្រឡាញ់ រមែងកើតក្នុងហឫទ័យរបស់មនុស្សក្តី ម្រឹគក្តី ដោយសារធ្លាប់នៅជាមួយគ្នា អាត្មាមិនអាចមិនសោកស្តាយដំរីនោះបានឡើយ។

[៣៧៤] (សក្កទេវរាជពោលថា) សត្វទាំងឡាយណា យំទួញរៀបរាប់ សត្វទាំងឡាយនោះ តែងយំរកសត្វដែលស្លាប់បាត់ទៅហើយ ឬក៏សត្វដែលបម្រុងនឹងស្លាប់ នែឥសី ព្រោះហេតុនោះ លោកកុំយំឡើយ ពួកសប្បុរសពោលថា ការយំ ជាធម្មជាតឥតអំពើទេ។

[៣៧៥] បពិត្រព្រហ្ម ប្រសិនបើបុគ្គលដែលស្លាប់ទៅកាន់បរលោកហើយ គប្បីរស់ឡើងវិញដោយការយំទួញ ពួកយើងទាំងអស់ក៏គួរប្រជុំគ្នាយំរកពួកញាតិនៃគ្នានឹងគ្នាដែរ។

[៣៧៦] (តាបសពោលថា) អ្នកបានស្រោចខ្ញុំដែលត្រូវភ្លើង គឺសេចក្តីសោក កំពុងឆេះសព្វ ឲ្យត្រជាក់ត្រជុំ រំលត់នូវក្រវល់ក្រវាយទាំងអស់បាន ដូចជាបុគ្គលយកទឹកស្រោចរលត់នូវភ្លើងដែលកំពុងឆេះនូវឆ្នាំងខ្លាញ់។ អ្នកបានបន្ទោបង់សេចក្តីសោក ព្រោះកូនរបស់ខ្ញុំដែលត្រូវសេចក្តីសោកកំពុងគ្របសង្កត់ ឈ្មោះថាបានដកចោលនូវសរ គឺសេចក្តីសោកដែលអាស្រ័យនៅក្នុងហឫទ័យនៃខ្ញុំបាន។ បពិត្រវាសវៈ ខ្ញុំនោះឈ្មោះថា មានសរដកចោលហើយ ប្រាសចាកសេចក្តីសោកហើយ ឥតមានចិត្តល្អក់ ខ្ញុំលែងសោកស្តាយ លែងយំព្រោះបានស្តាប់ (នូវពាក្យរបស់អ្នក)។

ចប់ សោមទត្តជាតក ទី៥។

## សុសីមជាតក ទី៦

CS sut.kn.jat.411 | ភាគទី ៥៩

### (៤១១. សុសីមជាតកំ (៧-២-៦))

[៣៧៧] (ព្រះរាជាពោធិសត្វ ពោលថា) ម្នាលសុសីមៈ កាលពីដើម សក់ទាំងឡាយខ្មៅ ដុះលើក្បាល ជាប្រទេសដ៏សមគួរ ថ្ងៃនេះអ្នកឃើញសក់ទាំងនោះសហើយ ចូរប្រព្រឹត្តធម៌ចុះ (ព្រោះកាលនេះ) ជាកាលគួរដល់ព្រហ្មចរិយធម៌ហើយ។

[៣៧៨] (អគ្គមហេសី ពោលថា) បពិត្រព្រះសម្មតិទេព សក់ស្កូវរបស់ខ្ញុំមិនមែនរបស់ព្រះអង្គទេ ស្កូវក្បាលរបស់ខ្ញុំ ស្កូវត្បូងរបស់ខ្ញុំទេតើ បពិត្រព្រះរាជសេដ្ឋ ខ្ញុំនិយាយកុហកទេ ដោយបំណងថា អាត្មាអញនឹងធ្វើនូវសេចក្តីចំរើន (ដល់ខ្លួន) សូមព្រះអង្គទ្រង់ព្រះមេត្តាប្រោសអភ័យទោសកំហុសម្តង (ដល់ខ្ញុំ)។

[៣៧៩] បពិត្រព្រះរាជា ព្រះអង្គនៅក្មេង ឋិតនៅក្នុងបឋមវ័យនៅឡើយ មុខគួរឲ្យអ្នកផងពិតពិលរមិលមើល ដូចជាទំពាំង (ខ្ញីមានសម្បុរដ៏ស្និទ្ធ) សូមទ្រង់សោយរាជ្យផង សូមទ្រង់ទតខ្ញុំព្រះអង្គផង បពិត្រព្រះជនិន្ទៈ សូមព្រះអង្គកុំស្ទុះទៅតាមកាលិកៈឡើយ។[13]

[៣៨០] (ពោធិសត្វ ពោលថា) យើងឃើញកុមារីក្រមុំ មានសម្បុរស្បែកដ៏ផូរផង់ក្នុងខាងទាំងអស់ មានដងខ្លួនសមរម្យ ត្រង់ពាក់កណ្តាលខ្លួន សណ្ឋិតដោយល្អ (កុមារីនោះ) ធ្វើដំណើរញ៉ៀងញ៉ង ដូចជាវល្លិប្រេង មានស្លឹកខ្ចី (ដែលទន់ល្វន់) ហើយប្រលោមពួកបុរស។

[៣៨១] លុះដល់សម័យខាងក្រោយមក យើងឃើញនារីនុ៎ះ កើតបាន ៨០ ឆ្នាំ ឬ ៩០ ឆ្នាំ អំពីកំណើត កាន់ឈើច្រត់ ញ័រទទ្រើត ត្រាច់ទៅកោង ៗ ដូចជាបង្កង់ផ្ទះ។

[៣៨២] យើងនោះត្រិះរិះឃើញនូវសេចក្តីរីករាយ និងទោសរបស់រូបនោះ ដេកម្នាក់ឯង ពាក់កណ្តាលនៃដំណេក ក៏ត្រិះរិះឃើញថា អាត្មាអញ មុខជាយ៉ាងនោះដែរ ដូច្នេះហើយ ក៏លែងរីករាយក្នុងផ្ទះ (កាលនេះ) ជាកាលគួរនៃព្រហ្មចរិយៈ។

[៣៨៣] សេចក្តីត្រេកអរ (ក្នុងកាម) របស់បុគ្គលអ្នកនៅក្នុងផ្ទះនុ៎ះ ដូចជាខ្សែសម្រាប់គោង (របស់បុរសដែលមានជំងឺ) អ្នកប្រាជ្ញទាំងឡាយ កាត់ផ្តាច់នូវខ្សែនុ៎ះហើយ លែងនឹកនា លះបង់ចោលនូវកាមសុខ ទៅបួស។

ចប់ សុសីមជាតក ទី៦។

## កោដសិម្ពលិជាតក ទី៧

CS sut.kn.jat.412 | ភាគទី ៥៩

(៤១២. កោដសិម្ពលិជាតកំ (៧-២-៧))

[៣៨៤] (ស្តេចគ្រុឌឃើញដើមរកានោះកំពុងកក្រើកញាប់ញ័រ ក៏សួររកហេតុថា) យើងចាប់នាគមានប្រវែង ១ ពាន់ព្យាម យកមក (ក្នុងទីនេះ) អ្នកទ្រទ្រង់នាគនោះផង នូវយើងផង សុទ្ធតែមានកាយដ៏ធំ មិនកម្រើក។

[៣៨៥] ម្នាលកោដសិម្ពលិ លុះដល់អ្នកមកទ្រូវបក្សីតូចនេះ ដែលមានសាច់តិចជាងយើងទេ ហេតុអ្វីក៏ភ័យញ័ររន្ធត់។

[៣៨៦] (ទេវបុត្ត ពោលថា) បពិត្រព្រះរាជា ព្រះអង្គមានសាច់ជាអាហារ ឯបក្សីនេះមានផ្លែឈើជាអាហារ បក្សីនេះនឹងស៊ីនូវពូជជ្រៃ ពូជលៀប ពូជល្វាទាំងឡាយ ពូជពោធិ៍បាយទាំងឡាយ ហើយមកជុះដាក់លើដើមឈើរបស់យើង។

[៣៨៧] ឈើទាំងឡាយនោះ ដុះក្នុងទីបាំងខ្យល់ ក្បែរខាងយើង លូតលាស់ល្អ ឈើទាំងឡាយនោះ មុខជានឹងរួបរឹតយើង ធ្វើយើងមិនឲ្យនៅជាដើមឈើ។

[៣៨៨] មានឈើដទៃទៀត ដែលជាឈើបរិបូណ៌ដោយឫស បរិបូណ៌ដោយដើម ត្រូវសកុណជាតិនេះ ពាំយកពូជមកបំផ្លាញហើយដែរ។

[៣៨៩] ដ្បិត (ឈើទាំងឡាយ មានជ្រៃជាដើម) រមែងដុះសង្កត់នូវឈើជាធំក្នុងព្រៃ សូម្បីធំចំរើន បពិត្រព្រះរាជា ព្រោះហេតុនោះ យើងឃើញភ័យទៅអនាគត បានជាញាប់ញ័រ។

[៣៩០] (សុបណ្ណរាជ ឮពាក្យរុក្ខទេវតា ហើយពោលថា) អ្នកប្រាជ្ញគប្បីរង្កៀសចំពោះហេតុទាំងឡាយ ដែលគួររង្កៀស គប្បីរក្សា (ប្រយ័ត្ន) នូវភ័យជាអនាគត ទើបឈ្មោះថា រមិលមើលនូវលោកទាំងពីរ ព្រោះហេតុនៃភ័យជាអនាគត។

ចប់ កោដសិម្ពលិជាតក ទី៧។

## ធូមការិជាតក ទី៨

CS sut.kn.jat.413 | ភាគទី ៥៩

(៤១៣. ធូមការិជាតកំ (៧-២-៨ ))

[៣៩១] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ព្រះរាជាទ្រង់ព្រះនាមយុធិដ្ឋិលៈ ព្រះអង្គពេញព្រះទ័យនឹងសុចរិតធម៌ បានត្រាស់សួរវិធុរបណ្ឌិតថា ម្នាលព្រាហ្មណ៍ អ្នកដឹងឬទេ អ្នកណាតែម្នាក់ឯង សោកស្តាយច្រើន។

[៣៩២] (វិធុរបណ្ឌិតពោធិសត្វ ពោលថា) ព្រាហ្មណ៍ជាវសិដ្ឋគោត្ត មានរំកាច់ឧសច្រើន នៅក្នុងព្រៃជាមួយនឹងហ្វូងពពែ ជាអ្នកមិនខ្ជិលច្រអូស ទាំងយប់ទាំងថ្ងៃ បានបង្ហុយផ្សែង (ដើម្បីការពារកុំឲ្យមូសខាំ)។

[៣៩៣] ពួកម្រឹគឈ្មោះសរភៈ[14] ត្រូវមូសខាំ ធុំក្លិនផ្សែងនោះ ក៏ចូលទៅនៅក្នុងសំណាក់នៃព្រាហ្មណ៍ ជាអ្នកធ្វើផ្សែងនោះ ក្នុងពេលដែលមានភ្លៀងធ្លាក់ជោកជាំ។

[៣៩៤] ព្រាហ្មណ៍នោះ ចំពាក់ចិត្តនឹងពួកសរភៈ លែងរវល់នឹកដល់ពួកពពែថា (ពពែប៉ុណ្ណោះ) មកកាន់ក្រោលហើយ ឬថា (ពពែប៉ុណ្ណោះ ចេញអំពីក្រោលទៅព្រៃ) ពួកពពែទាំងនោះរបស់គាត់ ក៏វិនាសអស់ទៅ។

[៣៩៥] លុះដល់ក្នុងសរទកាល ពួកសរភៈម្រឹគ ក៏ចូលទៅកាន់ជើងភ្នំផង កាន់ដងស្ទឹងផង ក្នុងព្រៃដែលគ្មានមូស។

[៣៩៦] ចំណែកខាងព្រាហ្មណ៍ ក៏កើតរោគលឿងស្គម មានសម្បុរអាក្រក់ ព្រោះឃើញពួកសរភៈម្រឹគទៅបាត់ផង ឃើញពួកពពែវិនាសផង។

[៣៩៧] បុគ្គលណា លះបង់អជ្ឈត្តិកជន (បុរាណ) របស់ខ្លួនចោលយ៉ាងនេះ ហើយបែរជាធ្វើសេចក្តីរាប់អានចំពោះអាគន្តុកជនវិញ បុគ្គលនោះ តែម្នាក់ឯង តែងសោកស្តាយច្រើន ដូចព្រាហ្មណ៍ជាអ្នកធ្វើផ្សែង។

ចប់ ធូមការិជាតក ទី៨។

## ជាគរជាតក ទី៩

CS sut.kn.jat.414 | ភាគទី ៥៩

(៤១៤. ជាគរជាតកំ (៧-២-៩))

[៣៩៨] (រុក្ខទេវតា សួរប្រស្នាថា) កាលសត្វទាំងឡាយកំពុងភ្ញាក់ អ្នកណាជាអ្នកដេកលក់ ក្នុងលោកនេះ កាលសត្វទាំងឡាយកំពុងដេកលក់ អ្នកណាជាអ្នកភ្ញាក់ ក្នុងលោកនេះ អ្នកណាហ្ន៎ ដឹងច្បាស់នូវប្រស្នារបស់យើងនុ៎ះបាន អ្នកណាឆ្លើយតបប្រស្នាយើងនោះបាន។

[៣៩៩] (តាបសពោធិសត្វ ពោលថា) កាលសត្វទាំងឡាយកំពុងភ្ញាក់ ខ្ញុំជាអ្នកដេកលក់ កាលសត្វទាំងឡាយកំពុងដេកលក់ ខ្ញុំជាអ្នកភ្ញាក់ ខ្ញុំដឹងច្បាស់នូវប្រស្នារបស់អ្នកនុ៎ះ ខ្ញុំឆ្លើយតប (ប្រស្នានុ៎ះ) របស់អ្នកបាន។

[៤០០] (រុក្ខទេវតានោះ សួរទៀតថា) កាលសត្វទាំងឡាយកំពុងភ្ញាក់ អ្នកដេកលក់ តើដូចម្តេច កាលសត្វទាំងឡាយកំពុងដេកលក់

អ្នកភ្ញាក់ តើដូចម្តេច អ្នកដឹងច្បាស់នូវប្រស្នារបស់ខ្ញុំនុ៎ះ ដូចម្តេច អ្នកឆ្លើយតបខ្ញុំដូចម្តេច។

[៤០១] (ពោធិសត្វ ពោលថា) សត្វទាំងឡាយណា មិនដឹងច្បាស់នូវធម៌ផង មិនដឹងថា (នេះ) ជាសញ្ញមៈផង (នេះ) ជាទមៈផង កាលបើសត្វទាំងឡាយនោះដេកលក់ទាំងសេចក្តីប្រមាទហើយ ម្នាលទេវតា ខ្ញុំមែងភ្ញាក់។

[៤០២] ពួកសត្វណា លះបង់នូវរាគៈ ទោសៈ និងអវិជ្ជាបាន កាលបើពួកសត្វនោះកំពុងភ្ញាក់ ម្នាលទេវតា ខ្ញុំជាអ្នកដេកលក់។

[៤០៣] កាលបើពួកសត្វកំពុងភ្ញាក់ ខ្ញុំជាអ្នកដេកលក់យ៉ាងនេះ កាលបើពួកសត្វកំពុងដេកលក់ ខ្ញុំជាអ្នកភ្ញាក់យ៉ាងនេះ ខ្ញុំដឹងច្បាស់នូវប្រស្នារបស់អ្នកនុ៎ះ យ៉ាងនេះ ខ្ញុំឆ្លើយតបអ្នកយ៉ាងនេះ។

[៤០៤] (រុក្ខទេវតា មានចិត្តត្រេកអរ ពោលសរសើរថា) ត្រូវហើយ កាលបើពួកសត្វកំពុងភ្ញាក់ អ្នកជាបុគ្គលដេកលក់ ត្រូវហើយ កាលបើពួកសត្វកំពុងដេកលក់ អ្នកជាបុគ្គលភ្ញាក់ ត្រូវហើយ អ្នកដឹងច្បាស់នូវប្រស្នារបស់ខ្ញុំនុ៎ះ អ្នកឆ្លើយតបខ្ញុំត្រូវហើយ។

ចប់ ជាគរជាតក ទី៩។

## កុម្មាសបិណ្ឌជាតក ទី១០

CS sut.kn.jat.415 | ភាគទី ៥៩

### (៤១៥. កុម្មាសបិណ្ឌិជាតកំ (៧-២-១០))

[៤០៥] (ព្រះរាជាពោធិសត្វ បានពោលថា) បានឮថា ការបំរើព្រះបច្ចេកពុទ្ធទាំងឡាយ ដែលលោកមានពោធិញ្ញាណមិនថោកថយ មិនមែនមានផលានិសង្សតិចតួចឡើយ អ្នកចូរមើលផលនៃដុំនំកុម្មាសៈ ដែលស្ងោះកក្រោះឥតរសប្រៃ។ ដំរី គោ និងសេះដ៏ច្រើនទាំងនេះផង ទ្រព្យ ស្រូវ និងផែនដីទាំងអស់ផង នាងនារីទាំងឡាយ ដែលប្រៀបដូចជាស្ត្រីអប្សរទាំងនេះផង សុទ្ធតែជារបស់ខ្ញុំ អ្នកចូរមើលនូវផលនៃដុំនំកុម្មាសៈ។

[៤០៦] (នាងទេវី បានពោលថា) បពិត្រព្រះរាជកុញ្ជរ មានព្រះអធ្យាស្រ័យជាកុសល ទ្រង់ញ៉ាំងដែនឲ្យចំរើន ព្រះអង្គត្រាស់គាថាទាំងឡាយរឿយ ៗ ខ្ញុំព្រះអង្គសូមក្រាបបង្គំទូលសួរទ្រង់ ព្រះអង្គមានព្រះទ័យប្រកបដោយបីតិក្រៃពេក ហើយទ្រង់ត្រាស់ (គាថាទាំងនុ៎ះ)។

[៤០៧] (ព្រះមហាសត្វ បានត្រាស់គាថាទាំងនេះថា) យើងបានកើតក្នុងត្រកូលមួយ ក្នុងក្រុងនេះដែរ ជាអ្នកស៊ីឈ្នួលធ្វើការងាររបស់បុគ្គលដទៃ ជាអ្នកសង្រួមក្នុងសីល យើងចេញទៅធ្វើការងារ បានជួបនឹងសមណៈ ៤ អង្គ លោកបរិបូណ៌ដោយអាចារៈ និងសីល មានសេចក្តីត្រជាក់ ទាំងឥតមានអាសវៈឡើយ។ យើងបានញ៉ាំងចិត្តឲ្យជ្រះថ្លា ចំពោះសមណៈទាំងនោះ បាននិមន្តលោកឲ្យគង់លើកម្រាលស្លឹកឈើ លុះយើងមានចិត្តជ្រះថ្លាហើយ បានប្រគេននំកុម្មាសៈ ដល់ព្រះបច្ចេកពុទ្ធទាំងឡាយដោយដៃរបស់ខ្លួន។ ឯផលរបស់យើងប្រាកដដូច្នេះនេះ ជាផលរបស់កម្មជាកុសលនោះ យើងសោយរាជ្យដ៏ស្តុកស្តម្ភ ប្រសើរលើធរណីនេះ។

[៤០៨] (នាងទេវី ពោលថា) បពិត្រព្រះអង្គមានព្រះអធ្យាស្រ័យជាកុសល សូមព្រះអង្គទ្រង់ព្រះរាជទាន ហើយសឹមទ្រង់សោយ សូមព្រះអង្គកុំប្រមាទ (ក្នុងបុណ្យទាំងឡាយ) សូមព្រះអង្គញ៉ាំងចក្រធម៌[15] ឲ្យប្រព្រឹត្តទៅ បពិត្រព្រះរាជា មានព្រះអធ្យាស្រ័យជាកុសល ព្រះអង្គកុំជាអ្នកមិនប្រកបដោយធម៌ សូមទ្រង់រក្សានូវអនុធម៌។[16]

[៤០៩] (ព្រះមហាសត្វ ទ្រង់ត្រាស់ថា) ម្នាលនាងមានឆោមល្អ យើងនោះនឹងដើរតាមគម្រាយដែលព្រះអរិយៈធ្លាប់ប្រព្រឹត្តរឿយ ៗ មកនោះឯង ម្នាលនាងដ៏ល្អជាធីតារបស់ព្រះបាទកោសល ការបានចួបប្រទះនូវព្រះអរហន្តទាំងឡាយ ជាទីគាប់ចិត្តរបស់យើងពន់ពេក។

[៤១០] (ព្រះរាជា ទ្រង់សួរនាងទេវីថា) ម្នាលនាងសុកោសលធីតា នាងប្រៀបដូចជាស្ត្រីទេពអប្សរ ជាទេវធីតា (របស់សក្កទេវរាជ) ឆើតឆាយក្នុងកណ្តាលនៃពួកនាងនារី នាងបានធ្វើនូវកម្មដ៏ចំរើនដូចម្តេច នាងមានសម្បុរល្អដោយហេតុអ្វី។

[៤១១] (នាងទេវី ឆ្លើយថា) បពិត្រក្សត្រិយ៍ ខ្ញុំម្ចាស់ជាទាសីបម្រើអ្នកដទៃរបស់ត្រកូលអម្ពដ្ឋៈ ជាស្ត្រីសង្រួម ចិញ្ចឹមជីវិតដោយធម៌ មានសីលធម៌ មានការឃើញមិនអាក្រក់។ កាលនោះ ខ្ញុំជាស្ត្រីមានចិត្តត្រេកអររីករាយខ្លួនឯង បានប្រគេនភត្តដែលគេដួស (ទុកបម្រុងខ្ញុំ) ដល់ភិក្ខុ (ព្រះបច្ចេកពុទ្ធ) ដែលត្រាច់ទៅ (ដើម្បីបិណ្ឌបាត) ផលប្រាកដដូច្នេះនេះ គឺជាផលនៃបុញ្ញកម្មនោះ។

ចប់ កុម្មាសបិណ្ឌជាតក ទី១០។

## បរន្តបជាតក ទី១១

CS sut.kn.jat.416 | ភាគទី ៥៩

### (៤១៦. បរន្តបជាតកំ (៧-២-១១))

[៤១២] (បរន្តបទាសៈ ពោលថា) អំពើលាមកនឹងមានមកដល់ខ្ញុំ ភ័យនឹងមានមកដល់ខ្ញុំ ដ្បិតក្នុងកាលនោះ មែកឈើកម្រើកព្រោះមនុស្ស ឬម្រឹគ។

[៤១៣] (បុរោហិត ពោលថា) កាមរបស់ខ្ញុំ (កើតចំពោះនាងព្រាហ្មណី) ជាស្ត្រីខ្លាចច្រើន ដែលនៅក្នុងទីមិនឆ្ងាយ វានឹងធ្វើខ្ញុំឲ្យជាបុគ្គលស្គមស្លៀង ដូចជាមែកឈើនោះ (ដែលធ្វើ) ទាសៈ ឈ្មោះបរន្តបៈ (ឲ្យជាបុគ្គលស្គមស្លៀង)។

[៤១៤] (ថ្ងៃក្រោយ បុរោហិតនោះពោលថា) ភរិយាជាទីពេញចិត្ត កាលនៅក្នុងស្រុក ឥតមានអ្នកផងតិះដៀលបាន នឹងធ្វើខ្ញុំឲ្យរីងស្ងួត នឹងធ្វើខ្ញុំឲ្យស្គមស្លៀង ដូចជាមែកឈើនោះ (ដែលធ្វើ) ទាសៈ ឈ្មោះបរន្តបៈ (ឲ្យជាបុគ្គលស្គមស្លៀង)។

[៤១៥] (ថ្ងៃក្រោយទៀត បុរោហិតពោលថា) នៃភ្នែក ការញញឹមញញែម ឬសំដី (ដ៏ពីរោះ) ដែលនាង (ឲ្យប្រព្រឹត្តទៅហើយ) នឹងធ្វើខ្ញុំឲ្យជាបុគ្គលស្គមស្លៀង ដូចជាមែកឈើនោះ (ដែលធ្វើ) ទាសៈ ឈ្មោះបរន្តបៈ (ឲ្យជាបុគ្គលស្គមស្លៀង)។

[៤១៦] (បរន្តបទាសៈ ពោលថា) សំឡេង (នៃមែកឈើ) នោះ ប្រព្រឹត្តទៅហើយនោះ ដូចជាប្រាប់អ្នកហើយ សត្វណាញ៉ាំងមែកឈើនោះឲ្យកំរើក សត្វនោះប្រាប់ហេតុនោះហើយ។

[៤១៧] គំនិតណាដែលខ្ញុំជាបុគ្គលល្ងង់ គិតថា ក្នុងកាលនោះ មែកឈើកំរើក ព្រោះមនុស្ស ឬម្រឹគ គំនិតនេះឯង មកដល់ខ្ញុំហើយ។

[៤១៨] (លំដាប់នោះ រាជកុមារពោលថា) អ្នកបានដឹងពិតដូច្នោះមែន ព្រោះអ្នកបានសម្លាប់នូវបិតារបស់ខ្ញុំ បិទបាំងដោយមែកឈើទាំងឡាយ លាក់លៀមដោយគិតថា (ភ័យនឹងមានមកដល់អ្នក)។

ចប់ បរន្តបជាតក ទី១១។

ចប់ គន្ធារវគ្គ ទី២។

ឧទ្ទាននៃជាតកនោះ គឺ

និយាយអំពីការលះស្រុកដ៏ប្រសើរ ១ ស្វាធំ ១ ភគ្គវៈស្ទួនផ្ទាំង ១ ស្តេចព្រះនាមទទ្ទធម្ម: ១ ដំរី ១ សក់ដ៏ប្រសើរ ១ នាគ ១ វិធុរបណ្ឌិត ១ កាលជនភ្ញាក់រលឹក ១ ព្រះរាជាមានអធ្យាស្រ័យជាកុសល ១ បរន្តបទាស: ១។

ក្នុងសត្តកនិបាតនោះ មានឧទ្ទាននៃវគ្គ (ដូច្នេះ) កាលខ្ញុំសូមពោលនូវវគ្គ ក្នុងសត្តកនិបាត ចូរអ្នកស្តាប់វគ្គពីរ គឺកុក្កុវគ្គ ១ គន្ធារវគ្គ ១ ដែលព្រះសម្ពុទ្ធ ព្រះអង្គស្វែងរកនូវគុណដ៏ធំ ទ្រង់ត្រាស់ទុកហើយ។

,div centeralign>ចប់ សត្តកនិបាត។

# អដ្ឋកនិបាតជាតក

CS sut.kn.jat.v08 | ភាគទី ៥៩

(៨. អដ្ឋកនិបាតោ)

## កច្ចានិវគ្គ

CS sut.kn.jat.v08.01 | ភាគទី ៥៩

(១. កច្ចានិវគ្គោ)

### កច្ចានិជាតក ទី១

CS sut.kn.jat.417 | ភាគទី ៥៩

(៤១៧. កច្ចានិជាតកំ (១))

[៤១៩] (ព្រះឥន្ទពោធិសត្វ បានពោលថា) ម្នាលនាងកច្ចានី ថ្វីក៏បានជានាងស្លៀកដណ្តប់សំពត់សស្អាត មានសក់ទទឹក ហើយដាំឆ្នាំងលាងម្សៅល្ង និងអង្ករ បាយលាយដោយល្ង កើតមានឡើង តើព្រោះហេតុដូចម្តេច។

[៤២០] (នាងកច្ចានី បានពោលថា) ម្នាលព្រាហ្មណ៍ បាយលាយដោយល្ង ដែលខ្ញុំចំអិនដោយប្រពៃនេះ មិនមែនបម្រុងនឹងបរិភោគខ្លួនឯងទេ (ព្រោះថា) ធម៌ស្លាប់បាត់ទៅហើយ ថ្ងៃនេះ ខ្ញុំនឹងធ្វើការបូជាចំពោះធម៌នោះ ក្នុងកណ្តាលព្រៃស្មសាន។

[៤២១] (ព្រះឥន្ទ្រ ពោលថា) ម្នាលនាងកច្ចានី នាងចូរពិចារណាសិន ហើយសឹមធ្វើនូវកិច្ចដែលត្រូវធ្វើចុះ អ្នកណាប្រាប់នាងថា ធម៌ស្លាប់ទៅហើយ ព្រះសហស្សនេត្ត គឺព្រះឥន្ទ មានអានុភាពរកអ្វីថ្លែងថ្លឹងពុំបាន ជាបុគ្គលមានធម៌ដ៏ប្រសើរ មិនដែលស្លាប់ក្នុងកាលណាម្តងឡើយ។

[៤២២] (នាងកច្ចានី ពោលថា) ម្នាលព្រហ្ម ការណ៍ប្រមាណដ៏មាំរបស់ខ្ញុំក្នុងហេតុនេះ ធម៌ស្លាប់បាត់ទៅហើយ ខ្ញុំមិនមានសង្ស័យក្នុងហេតុនេះទេ ឥឡូវនេះ ពួកជនណា ៗ ដែលជាបុគ្គលលាមក ពួកជននោះ ៗ បែរជាបានសុខក្នុងកាលឥឡូវនេះ។

ដ្បិតកូនប្រសាស្រីខ្ញុំ ជាស្រីអារ វាបណ្តេញខ្ញុំ ហើយសម្រាលកូនប្រុស ឥឡូវនេះ វាបានជាធំលើត្រកូលទាំងអស់ ខ្ញុំជាស្ត្រីមិនមានទីពឹងនៅតែម្នាក់ឯង។

[៤២៣] (ព្រះឥន្ទ្រ ពោលថា) យើងនៅរស់ យើងមិនទាន់ស្លាប់នៅឡើយទេ យើងមកក្នុងទីនេះ ក៏ដើម្បីជាប្រយោជន៍ដល់នាងឯង កូនប្រសាស្រីណា ដែលបានបណ្តេញនាង ហើយបានកូនប្រុស យើងនឹងធ្វើកូនប្រសានោះ ឲ្យខ្ទេចជាផេះ ព្រមទាំងកូនប្រុសមិនខាន។

[៤២៤] (នាងកច្ចានី ពោលថា) បពិត្រទេវរាជ លោកគាប់ចិត្តយ៉ាងនេះ លោកអញ្ជើញមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំ តែសូមឲ្យខ្ញុំ និងកូនប្រុស កូនប្រសាស្រី ចៅ ជាបុគ្គលមានសេចក្តីរីករាយរកគ្នា ហើយនៅគ្រប់គ្រងផ្ទះវិញ។

[៤២៥] (ព្រះឥន្ទ្រ ពោលថា) ម្នាលនាងកច្ចានី បើនាងគាប់ចិត្តយ៉ាងនេះ នាង សូម្បីកូនប្រសាស្រីបៀតបៀនហើយ ក៏នៅតែមិនលះបង់នូវធម៌ឡើយ (ហេតុនេះ) សូមឲ្យនាង និងកូនប្រុស កូនប្រសាស្រី ចៅ ចូរជាបុគ្គលមានសេចក្តីរីករាយរកគ្នា ហើយនៅគ្រប់គ្រងផ្ទះចុះ។

[៤២៦] (ព្រះសម្ពុទ្ធ ទ្រង់ត្រាស់ថា) នាងកច្ចានី មានសេចក្តីរីករាយរកគ្នា ជាមួយនឹងកូនប្រសាស្រី ហើយនៅគ្រប់គ្រងផ្ទះ ទាំងកូនប្រុស និងចៅ ត្រូវព្រះឥន្ទ្រជាធំជាងពួកទេវតា ជួយអនុគ្រោះហើយ ក៏បាននាំគ្នាបំរើមាតានោះវិញ។

ចប់ កច្ចានិជាតក ទី១។

### អដ្ឋសទ្ទជាតក ទី២

CS sut.kn.jat.418 | ភាគទី ៥៩

(៤១៨. អដ្ឋសទ្ទជាតកំ (២))

[៤២៧] (តាបសពោធិសត្វ ទូលព្រះរាជា អំពីពាក្យកុកថា) ស្រះបោក្ខរណីនេះ ពីដើមជាទីទំនាប មានត្រីច្រើន មានទឹកច្រើន ជាទីលំនៅរបស់ស្តេចកុក ជាកេរ្តិ៍ដំណែលខាងបិតា ជាទីលំនៅរបស់យើង ថ្ងៃនេះ ពួកយើងនោះ ចិញ្ចឹមជីវិតដោយសត្វកង្កែប នៅតែមិនលះបង់ទីលំនៅចោលឡើយ។

[៤២៨] (ទូលអំពីពាក្យក្អែកថា) អ្នកណាហ្ន៎ បំបែកភ្នែកជាគំរប់ពីរ របស់ទ្រម័កដំរី ឈ្មោះពន្ទុរៈ ជាបុគ្គលទ្រុស្តសីល អ្នកណាហ្ន៎ នឹងធ្វើនូវកូនទាំងឡាយ និងសម្បុករបស់យើង ព្រមទាំងយើង ឲ្យមានសួស្តី។

[៤២៩] (ទូលអំពីពាក្យដង្កូវដួងថា) ការប្រព្រឹត្តិទៅនៃឈើស្រាយនោះ មាននៅត្រឹមណា ឈើស្រាយទាំងអស់ អស់រលីងហើយ បពិត្រមហារាជ ដង្កូវដួងអស់អាហារហើយ លែងត្រេកអរក្នុងឈើខ្លឹម។

[៤៣០] (ទូលអំពីពាក្យមេតាវៅថា) លុះអាត្មាអញនោះ បានទៅផុតអំពីព្រះរាជនិវេសន៍នេះហើយ នឹងតាំងទីលំនៅលើមែកឈើ ធ្វើខ្លួនឲ្យរីករាយ។

[៤៣១] (ទូលអំពីពាក្យម្រឹគថា) លុះអាត្មាអញនោះ បានទៅផុតអំពីព្រះរាជនិវេសន៍នេះហើយ នឹងដើរមុខហ្វូង ហើយផឹកនូវទឹកទាំងឡាយដ៏ប្រសើរ។

[៤៣២] (ទូលអំពីពាក្យស្វាថា) ព្រានព្រៃឈ្មោះភរតៈ អ្នកនៅក្នុងដែនពាហិកៈ បាននាំយើងដែលកំពុងស្រវឹងដោយកាមទាំងឡាយ ត្រេកត្រអាលជ្រប់នៅក្នុងកាមទាំងឡាយនោះមក សូមសេចក្តីចំរើន ចូរមានដល់អ្នក។

[៤៣៣] (ទូលអំពីពាក្យកិន្នរថា) ខាងលើបពិតមានថ្មស្រួច ៗ មានងងឹតចុះអ័ព្ទ ប្រពន្ធរបស់យើងនោះ បាននិយាយនឹងយើងដោយពាក្យដ៏ទន់ពីរោះថា អ្នកប្រយ័ត្ន កុំឲ្យចំពប់ជើងលើថ្ម។

[៤៣៤] (ទូលអំពីឧទានព្រះបច្ចេកពុទ្ធថា) អាត្មាអញ ជាអ្នកឃើញនូវទីបំផុត គឺព្រះនិព្វាន ជាទីអស់ទៅនៃជាតិ ដោយមិនមានសង្ស័យ នឹងមិនវិលត្រឡប់មកដេកនៅក្នុងគភ៌ទៀត ការដេកនៅក្នុងគភ៌នេះ ជាទីក្រោយបំផុតត្រឹមនេះហើយ ការវង្កាត់ទៅក្នុងភពថ្មីទៀតរបស់អាត្មាអញ អស់ហើយ។

ចប់ អដ្ឋសទ្ទជាតក ទី២។

## សុលសាជាតក ទី៣

CS sut.kn.jat.419 | ភាគទី ៥៩

(៤១៩. សុលសាជាតកំ (៣))

[៤៣៥] (នាងសុលសា ពោលទៅនឹងស្វាមីថា) គ្រឿងប្រដាប់ជាវិការៈនៃមាសនេះ និងកែវមុក្តា កែវពៃទូរ្យទាំងឡាយជាច្រើន បពិត្រអ្នកដ៏ចំរើន អ្នកចូរនាំយកនូវភណ្ឌៈទាំងអស់ចុះ មួយទៀត ចូរហៅរកខ្ញុំថា ជាទាសីចុះ។

[៤៣៦] (ចោរឈ្មោះសត្តុកៈ ជាស្វាមី ពោលនឹងភរិយាថា) នាងចូរដោះគ្រឿងប្រដាប់ ជាលំអចេញទៅ កុំយំរៀបរាប់ច្រើន ដ្បិតអញទើបនឹងមក មិនដែលស្គាល់ទ្រព្យ ដែលនាងនាំមកឡើយ។

[៤៣៧] (នាងសុលសា ពោលថា) តាំងពីកាលដែលខ្ញុំរលឹកឃើញខ្លួនដរាបមក តាំងពីខ្ញុំបានដល់នូវភាពជាអ្នកដឹងក្តីដរាបមក ខ្ញុំមិនដែលស្គាល់បុរសដទៃ ដែលជាទីស្រឡាញ់លើសលុបជាងអ្នកទេ។

[៤៣៨] អ្នកចូរអញ្ជើញមក ខ្ញុំនឹងកៀកឱបនូវអ្នក ហើយនឹងធ្វើប្រទក្សិណ ដ្បិតតាំងពីថ្ងៃនេះ ខ្ញុំ និងអ្នក លែងបានជួបគ្នាទៀតហើយ។

[៤៣៩] (ទេវតាលើភ្នំ ពោលថា) មិនមែនតែបុរសទេ ដែលជាបណ្ឌិតក្នុងហេតុទាំងពួង សូម្បីស្ត្រីក៏ជាបណ្ឌិត ឃើញច្បាស់ក្នុងហេតុនោះ ៗ បានដែរ។

[៤៤០] មិនមែនតែបុរសទេ ដែលជាបណ្ឌិត ក្នុងហេតុទាំងពួង សូម្បីតែស្ត្រី ក៏ជាបណ្ឌិត គង់គិតឃើញសេចក្តីរហ័សបានដែរ។

[៤៤១] នាងសុលសា បានគិតឃើញឆាប់រហ័ស ក្នុងកាលដែលមានហេតុយ៉ាងកៀកជិត បានសម្លាប់ចោរសត្តុកៈ ដូចជាគេសម្លាប់ម្រឹគនឹងធ្នូ ដែលមានគ្រឿងផ្សំគ្រប់គ្រាន់។

[៤៤២] បុគ្គលណា ក្នុងលោកនេះ មិនដឹងឆាប់នូវហេតុដែលកើតឡើង បុគ្គលអ្នកមានប្រាជ្ញាតិចនោះ រមែងត្រូវគេសម្លាប់ ដូចជាចោរដែលនាងសុលសា ច្រានទម្លាក់ក្នុងជ្រោះភ្នំ។

[៤៤៣] បុគ្គលណា ក្នុងលោកនេះ ដឹងឆាប់នូវហេតុដែលកើតឡើង បុគ្គលនោះ រមែងរួចចាកការបៀតបៀនរបស់សត្រូវ ដូចជានាងសុលសា រួចអំពីកណ្តាប់ដៃនៃចោរសត្តុកៈ។

ចប់ សុលសាជាតក ទី៣។

## សុមង្គលជាតក ទី៤

CS sut.kn.jat.420 | ភាគទី ៥៩

(៤២០. សុមង្គលជាតកំ (៤))

[៤៤៤] បុគ្គលជាធំ បើបានដឹងថា អាត្មាអញជាអ្នកក្រោធខ្លាំង ដូច្នេះហើយ មិនគប្បីដាក់អាជ្ញាតែម្តង ដ្បិតបុគ្គលអ្នកក្រោធ គប្បី (ធ្វើ) ទោស ដែលមិនសមគួរដល់ខ្លួនជា (ស្តេច) ហើយពោលបង្កាចនូវកម្មជាទុក្ខដ៏ខ្លាំង ដល់បុគ្គលដទៃដោយឥតហេតុ។

[៩៤៥] កាលណា បើបុគ្គលគប្បីដឹងនូវសេចក្តីជ្រះថ្លារបស់ខ្លួន ទើបគួរពិចារណានូវសេចក្តីដែលជាអំពើអាក្រក់របស់ជនដទៃ មួយទៀត គួរពិចារណាឲ្យឃើញច្បាស់ខ្លួនឯងថា នេះជាសេចក្តី ហើយសឹមដាក់អាជ្ញាដ៏សមគួរដល់បុគ្គលដទៃនោះ ក្នុងកាលនោះចុះ។

[៩៤៦] បុគ្គលណាមិនជ្រប់ដោយកិលេស (អគតិ) ពិចារណានូវហេតុដែលជាទំនង និងមិនទំនង បុគ្គលនោះ រមែងមិនញ៉ាំងខ្លួន និងមិនញ៉ាំងបុគ្គលដទៃ ឲ្យក្តៅក្រហាយទេ បុគ្គលជាធំណាក្នុងលោកនេះ ជាអ្នកទ្រទ្រង់នូវអាជ្ញា បុគ្គលនោះ រមែងមានគេគ្រប់គ្រង ដោយការសរសើរគុណ មិនសាបសូន្យចាកសិរីឡើយ។

[៩៤៧] ពួកក្សត្រណា ជាបុគ្គលមិនទាន់ពិចារណាសិនហើយធ្វើ ជាអ្នកជ្រប់នៅដោយកិលេស ប្រញាប់ដាក់អាជ្ញាដល់អ្នកដទៃដោយរូសរាន់ ពួកក្សត្រនោះ រមែងជាអ្នកប្រកបដោយពាក្យតិះដៀល លះបង់ជីវិតចេញផុតអំពីលោកនេះទៅ រមែងទៅកាន់ទុគ្គតិ។

[៩៤៨] បុគ្គលពួកណា ត្រេកអរក្នុងធម៌ដែលព្រះអរិយៈសំដែងហើយ បុគ្គលពួកនោះ ជាអ្នកប្រសើដោយកាយកម្ម វចីកម្ម និងមនោកម្ម ពួកបុគ្គលបែបនោះ ជាអ្នកឋិតនៅក្នុងខន្តិ សោរច្ចៈ និងសមាធិ រមែងទៅកាន់លោកទាំងពីរ គឺមនុស្សលោក និងទេវលោក។

[៩៤៩] ខ្លួនយើងជាស្តេចធំលើពួកជនប្រុសស្រី បើយើងខឹង យើងទប់ខ្លួន យើងហាមឃាត់នូវប្រជុំជនបែបនោះ ហើយដាក់អាជ្ញាដោយឧបាយប្រាជ្ញា ព្រោះអនុគ្រោះ។

[៩៥០] (ឧយ្យានបាល ទូលថា) បពិត្រក្សត្រិយ៍ ជាធំជាងជន សិរី គឺបរិវារសម្បត្តិ និងប្រាជ្ញា កុំលះបង់ព្រះអង្គក្នុងកាលណា ៗ ឡើយ សូមព្រះអង្គជាបុគ្គលមិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច ជាអ្នកមិនមានទុក្ខ ហើយថែរក្សាផែនដីឲ្យអស់រយឆ្នាំ។

[៩៥១] បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ប្រកបដោយគុណទាំងឡាយនុ៎ះ សូមឲ្យព្រះអង្គឋិតនៅមាំ ក្នុងការប្រព្រឹត្តិដ៏ប្រសើរ ជាបុគ្គលប្រដៅងាយ មិនមានសេចក្តីក្រោធ ជាបុគ្គលបានសេចក្តីសុខ កុំបៀតបៀនសត្វ ហើយរក្សាផែនដី លុះព្រះអង្គចេញផុតអំពីលោកនេះទៅ សូមឲ្យស្តេចយាងទៅកាន់សុគតិ។

[៩៥២] ស្តេចទ្រង់ធម៌ រមែងប្រើឧបាយណែនាំពួកជន ដោយពាក្យជាសុភាសិត ជាគ្រឿងណែនាំដ៏ល្អ តាមហេតុដ៏ប្រកបដោយធម៌ ហើយញ៉ាំងមហាជន ដែលរដើបរដោ ឲ្យត្រជាក់ស្រួល ដូចជាមហាមេឃដែលញ៉ាំងផែនដីឲ្យត្រជាក់ដោយទឹក។

ចប់ សុមង្គលជាតក ទី៤។

## គង្គមាលជាតក ទី៥

CS sut.kn.jat.421 | ភាគទី ៥៩

### (៤២១. គង្គមាលជាតកំ (៥))

[៩៥៣] (ស្តេចទ្រង់ត្រាស់សួរភតិកបុរសថា) ប្រថពី ជាផែនដីក្តៅ ដូចរងើកភ្លើងប្រកបដោយដីខ្សាច់ (ក្តៅ) ដូចផេះ (ដែលភ្លើងឆេះ) អ្នកច្រៀងនូវទំនុកទាំងឡាយ កំដៅថ្ងៃ មិនដុតកំដៅអ្នកទេឬ។ ព្រះអាទិត្យក្តៅខាងលើ ដីខ្សាច់ក្តៅខាងក្រោម អ្នកច្រៀងនូវទំនុកទាំងឡាយ កំដៅថ្ងៃ មិនដុតកំដៅអ្នកទេឬ។

[៩៥៤] (ភតិកបុរស ក្រាបទូលថា) កំដៅថ្ងៃ មិនដុតកំដៅខ្ញុំព្រះអង្គបានទេ កំដៅ គឺកាមទាំងឡាយ ទើបញ៉ាំងខ្ញុំព្រះអង្គឲ្យក្តៅបាន បពិត្រព្រះរាជា ប្រយោជន៍ទាំងឡាយ មានប្រការផ្សេង ៗ ប្រយោជន៍ទាំងនោះ តែងដុតកំដៅ ឯកំដៅថ្ងៃ មិនដុតកំដៅទេ។

[៩៥៥] ម្នាលកាម យើងបានឃើញឫសគល់របស់អ្នកហើយ ម្នាលកាម អ្នកកើតអំពីសេចក្តីត្រិះរិះ យើងលែងត្រិះរិះអ្នកទៀតហើយ ម្នាលកាម កាលបើយ៉ាងនេះ អ្នកនឹងមិនកើតមាន (តទៅទៀតទេ)។

[៩៥៦] កាមទាំងឡាយសូម្បីតិច ក៏នៅតែមិនល្មម សូម្បីច្រើន ក៏នៅតែមិនស្កប់ស្កល់ ឱ មុខគួរសង្វេគ នឹងការចរចារបស់ពួកជនពាល បុគ្គលលុះតែប្រឹងប្រកបព្យាយាម ទើបត្រាស់ដឹងបាន។

[៩៥៧] (ព្រះរាជាឧទយៈ ត្រាស់ថា) នេះជាផលកម្ម មានប្រមាណតិចរបស់យើង ឧទយៈ បានសម្រេចនូវភាពជាធំ ឱហ្ន៎ មាណពណា បានលះនូវតម្រេកក្នុងកាម ហើយបួស មាណពនោះ ឈ្មោះថា បានល្អហើយ។

[៩៥៨] (ព្រះវររាជមាតា ត្រាស់សួរថា) ពួកសត្វតែងលះបង់នូវបាបកម្ម (របស់ខ្លួន) ដោយតបៈ លះបង់នូវភាវៈនៃខ្លួនជាខ្មាន់ព្រះកេស និងស្នូនផ្ទាំង ដោយតបៈ នៃគង្គមាល ក្នុងថ្ងៃនេះ អ្នកហ៊ានរំលោភ ហៅព្រហ្មទត្ត (កូនអញ) ដោយចំឈ្មោះ ព្រោះអាងមានតបៈឬ។

[៩៥៩] (ព្រះរាជា ទ្រង់ត្រាស់ថា) បពិត្រព្រះមាតា សូមទ្រង់ទតនូវផលនៃខន្តិ និងសោរច្ចៈ ដែលអាចឃើញជាក់ច្បាស់ដោយខ្លួនឯង (ក្នុងបច្ចុប្បន្ន) ព្រះគង្គមាលបច្ចេកពុទ្ធនោះ ជាបុគ្គលដែលជនទាំងអស់ត្រូវថ្វាយបង្គំ យើងព្រមទាំងស្តេច និងអាមាត្យ នាំគ្នាថ្វាយបង្គំនូវព្រះបច្ចេកពុទ្ធនោះ។

[៩៦០] អ្នកទាំងឡាយ កុំនិយាយពាក្យតិចតួចនឹងព្រះបច្ចេកពុទ្ធឈ្មោះគង្គមាល ដែលជាអ្នកសិក្សាក្នុងគន្លងនៃប្រាជ្ញា របស់ពួកអ្នកប្រាជ្ញឡើយ ព្រោះថា ព្រះបច្ចេកពុទ្ធនេះ បានឆ្លងនូវអន្លង់ គឺវដ្តសង្សារ ដែលពួកបុគ្គលអ្នកប្រាសចាកសោក តែងឆ្លងហើយត្រាច់ទៅ។

ចប់ គង្គមាលជាតក ទី៥។

## ចេតិយរាជជាតក ទី៦

CS sut.kn.jat.422 | ភាគទី ៥៩

### (៤២២. ចេតិយជាតកំ (៦))

[៩៦១] (តាបស និយាយថា)[17] ធម៌ដែលបុគ្គលសម្លាប់ហើយ រមែងសម្លាប់វិញដោយពិត ធម៌ដែលបុគ្គលមិនបានសម្លាប់ រមែងមិនសម្លាប់វិញតិចតួចឡើយ។ ព្រោះហេតុនោះ ព្រះអង្គមិនត្រូវសម្លាប់ធម៌ ព្រះអង្គកុំឲ្យធម៌ដែលព្រះអង្គសម្លាប់ហើយ ត្រឡប់សម្លាប់ព្រះអង្គវិញបានឡើយ។

[៤៦២] កាលបើស្តេចពោលពាក្យកុហក ពួកទេវតារមែងគេចចេញ (លែងរក្សា) ស្តេចណាជ្រាប កាលគេសួរប្រស្នា ហើយព្យាករប្រស្នានោះ ដោយប្រការដទៃវិញ ព្រះឱស្ឋស្តេចនោះ រមែងមានក្លិនស្អុយផ្សាយចេញទៅ ទាំងស្តេចនោះទៀត រមែងឃ្លាតចាកកន្លែងរបស់ខ្លួន បពិត្រព្រះរាជា បើប្រសិនជាព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គឋិតនៅលើផែនដី។

[៤៦៣] ស្តេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ ភ្លៀងរមែងធ្លាក់ចុះក្នុងកាលមិនគួរ (ក្នុងដែន) របស់ស្តេចនោះ ភ្លៀងរមែងមិនធ្លាក់ចុះក្នុងកាលគួរ (ក្នុងដែនរបស់ស្តេចនោះ) បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលនូវពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដី (ត្រឹមព្រះជាណុ)។

[៤៦៤] បពិត្រព្រះអង្គជាធំក្នុងទិស ស្តេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ អណ្តាតរបស់ស្តេចនោះ រមែងបែកជាពីរ ដូចជាអណ្តាតនៃពស់ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដីក្រៃលែង (ជាងនេះ គឺត្រឹមចង្កេះ)។

[៤៦៥] បពិត្រព្រះអង្គជាធំក្នុងទិស ស្តេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ ស្តេចនោះមិនមានអណ្តាត ដូចត្រី បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដីក្រៃលែង (ជាងនេះ គឺត្រឹមផ្ចិត)។

[៤៦៦] ស្តេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះដោយប្រការដទៃវិញ ក្នុងត្រកូលស្តេចនោះ កើតតែកូនស្រី កូនប្រុសមិនកើតទេ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គ ចូលទៅកាន់ផែនដីក្រៃលែង (ជាងនេះ គឺត្រឹមដោះ)។

[៤៦៧] ស្តេចណាជ្រាប កាលគេសួរប្រស្នាហើយ ក៏ព្យាករប្រស្នានោះ ដោយប្រការដទៃវិញ កូនប្រុសរបស់ស្តេចនោះ រមែងមិនមានឡើយ បើជាមាន រមែងគេចចេញទៅកាន់ទិសតូចទិសធំបាត់អស់ បពិត្រព្រះរាជា បើព្រះអង្គទ្រង់ពោលពាក្យពិត សូមឲ្យព្រះអង្គទ្រង់ឋិតនៅដូចដើម បពិត្រព្រះបាទចេតិយៈ បើព្រះអង្គ ទ្រង់ពោលពាក្យកុហក សូមឲ្យព្រះអង្គចូលទៅកាន់ផែនដីក្រៃលែង (ជាងនេះទៅទៀត គឺលិចផុត)។

[៤៦៨] (អភិសម្ពុទ្ធគាថា) ស្តេចនោះ កាលពីដើម ត្រាច់ទៅក្នុងអាកាសបាន (ដល់មកខាងក្រោយ) ត្រូវឥសីផ្តាសាហើយ ក៏បែរជាមានសភាពសាបសូន្យ ដល់វេនរបស់ខ្លួនចូលទៅកាន់ផែនដី ព្រោះហេតុនោះ អ្នកប្រាជ្ញទាំងឡាយ ទើបមិនសរសើរនូវការលុះក្នុងអំណាចនៃសេចក្តីប្រាថ្នា បុគ្គលគួរជាអ្នកមានចិត្តមិនប្រទូស្ត ហើយពោលនូវវាចាដ៏ប្រកបដោយសច្ចៈ។

ចប់ ចេតិយរាជជាតក ទី៦។

## ឥន្ទ្រិយជាតក ទី៧

CS sut.kn.jat.423 | ភាគទី ៥៩

### (៤២៣. ឥន្ទ្រិយជាតកំ (៧))

[៤៦៩] (គ្រូឈ្មោះសរភង្គ ពោលថា) ម្នាលនារទៈ បុគ្គលណា លុះអំណាចនៃឥន្ទ្រិយទាំងឡាយព្រោះកាម បុគ្គលនោះ លះបង់នូវលោកទាំងពីរ (ហើយកើតក្នុងនរក) សូម្បីរស់នៅ រមែងរីងស្ងួត។

[៤៧០] ទុក្ខជាលំដាប់នៃសុខ សុខលំដាប់នៃទុក្ខ សូម្បីអ្នកដល់នូវទុក្ខ ព្រោះសាបសូន្យចាកឈានសុខក៏ដោយ អ្នកចូរប្រាថ្នានូវសុខដ៏ប្រសើរវិញចុះ។

[៤៧១] បុគ្គលណា ជាអ្នកអត់ទ្រាំនូវសេចក្តីលំបាក ក្នុងវេលាមានលំបាក មិនប្រព្រឹត្តកន្លងនូវសេចក្តីលំបាក បុគ្គលនោះ ជាអ្នកប្រាជ្ញរមែងបាននូវសេចក្តីសុខ ជាទីបំផុតនៃសេចក្តីលំបាក ដែលកើតអំពីសេចក្តីព្យាយាម។

[៤៧២] ខ្លួនអ្នកមិនគួរឲ្យឃ្លាតចាកធម៌ ព្រោះការប្រាថ្នាកាម ព្រោះការវិនាស ព្រោះហេតុនៃប្រយោជន៍ ទាំងព្រោះលះបង់ឈានដែលខ្លួនធ្វើបានហើយទេ។

[៤៧៣] (កាលទេវិលតាបស ពោលថា) សេចក្តីឈ្លាសវៃ ១ ការបែងចែកភោជន ១ មិនរីករាយក្នុងការបាននូវប្រយោជន៍ ១ មិនលំបាកចិត្តក្នុងកាលវិនាសចាកប្រយោជន៍ (នេះ) ជាការប្រពៃរបស់គ្រហស្ថ។

[៤៧៤] (អភិសម្ពុទ្ធគាថា) អសិតទេវិលតាបស បានពោលនូវភាពនៃបុគ្គលជាបណ្ឌិតនុ៎ះ ដោយហេតុមានប្រមាណប៉ុណ្ណោះថា មិនមានបុគ្គលណាមួយ ដែលលើសលាមកជាងបុគ្គលជាអ្នកលុះអំណាចនៃឥន្ទ្រិយទាំងឡាយនេះឡើយ។

[៤៧៥] (មនុស្សប្រេត និយាយថា) បពិត្រព្រះបាទសិវិ បុគ្គលប្រាកដស្មើនឹងខ្ញុំ រមែងដល់នូវសេចក្តីវិនាស (ដោយអំពើរបស់ខ្លួន) ដូចបុគ្គលដល់នូវសេចក្តីវិនាសក្នុងកណ្តាប់ដៃនៃសត្រូវ ខ្លួនខ្ញុំព្រោះតែញុំាងយស់ទាំងនុ៎ះ គឺកសិកម្មវិជ្ជា ភាពជាអ្នកឈ្លាសវៃ វិរិយាហមង្គល សីល និងភាពនៃចិត្តទន់ ឲ្យសាបសូន្យ ទើបមកកើត (ជាមនុស្សប្រេត) ដោយអំពើជារបស់ខ្លួន។

[៤៧៦] ខ្លួនខ្ញុំនោះ ជាបុគ្គលមិនមានផៅពង្ស មិនមានទីពំនាក់តទៅ ដូចគេសាបសូន្យ ចាកទ្រព្យរាប់ពាន់ ខ្លួនខ្ញុំ ជាអ្នកប្រាសចាកអរិយធម៌ ដូចប្រេត។

[៤៧៧] ខ្លួនខ្ញុំ ញុំាំងពួកសត្វដែលជាអ្នកប្រាថ្នានូវសុខ ឲ្យដល់នូវទុក្ខ ទើបដល់នូវគន្លងនៃទុក្ខនេះ ខ្លួនខ្ញុំនោះ មិនបាននូវសេចក្តីសុខឡើយ ឋិតនៅ (ទាំងក្តៅក្រហាយ) ដូចគេរោយដោយរងើកភ្លើង។

ចប់ ឥន្ទ្រិយជាតក ទី៧។

## អាទិត្តជាតក ទី៨

(៤២៤. អាទិត្តជាតកំ (៨))

[៤៧៨] (ព្រះបច្ចេកពុទ្ធ ជាសង្ឃត្ថេរ សំដែងថា) កាលបើផ្ទះត្រូវភ្លើងឆេះហើយ បុគ្គលនាំចេញនូវភាជន៍ណាទាន់ ភាជន៍នោះ រមែងបានជាប្រយោជន៍នៃបុគ្គលនោះ ភាជន៍ណាដែលភ្លើងឆេះក្នុងផ្ទះនោះ ភាជន៍នោះ មិនបានជាប្រយោជន៍នៃបុគ្គលនោះឡើយ។

[៤៧៩] សត្វលោក កាលបើត្រូវជរា និងមរណៈ ឆេះយ៉ាងនេះហើយ បុគ្គលគួរតែនាំចេញនូវទ្រព្យ ដោយកាឲ្យទាន (ព្រោះ) ទ្រព្យដែលបុគ្គលបានឲ្យហើយ ឈ្មោះថានាំចេញហើយដោយប្រពៃ។

[៤៨០] (ព្រះបច្ចេកពុទ្ធដ៏សេស សំដែងថា) សត្វណា បានឲ្យទានដល់បុគ្គលអ្នកបានធម៌ បានត្រាស់ដឹងធម៌ ដោយសេចក្តីព្យាយាម គឺការប្រឹងប្រែង សត្វនោះ រមែងប្រព្រឹត្តកន្លងនូវវេតរណីរបស់យមៈ (នរក) បានហើយ ចូលទៅកាន់ទីទាំងឡាយជាទិព្វ។

[៤៨១] អ្នកប្រាជ្ញទាំងឡាយពោលថា ទាន និងចម្បាំង ជារបស់ស្មើគ្នា ពួកជនសូម្បីតិចគ្នា តែជាអ្នកស៊ូលះបង់ជីវិត រមែងឈ្នះជនច្រើននាក់បាន បុគ្គលណាកាលបើជឿ ហើយឲ្យទានសូម្បីបន្តិចបន្តួច បុគ្គលនោះ រមែងបាននូវសេចក្តីសុខក្នុងលោកខាងមុខ ដោយទេយ្យវត្ថុមានប្រមាណតិចនោះ។

[៤៨២] ការពិចារណាសិន ហើយទើបឲ្យ ព្រះសុគតទ្រង់សរសើរហើយ ពួកទក្ខិណេយ្យបុគ្គលណា មាននៅក្នុងជីវលោកនេះ ទានដែលបុគ្គលឲ្យហើយ ដល់ពួកទក្ខិណេយ្យបុគ្គលនុ៎ះ មានផលច្រើន ដូចជាពូជ ដែលគេសាបព្រោះក្នុងស្រែដ៏ល្អ។

[៤៨៣] បុគ្គលណា មិនបៀតបៀននូវពួកសត្វ មិនធ្វើនូវបាប ព្រោះ (ខ្លាច) ការតិះដៀលអំពីអ្នកដទៃ អ្នកប្រាជ្ញទាំងឡាយ តែងសរសើរនូវបុគ្គលអ្នកខ្លាចបាប មិនសរសើរនូវបុគ្គលអ្នកក្លៀវក្លាក្នុងការធ្វើបាបនោះឡើយ ដ្បិតសប្បុរសទាំងឡាយ តែងមិនធ្វើបាប ព្រោះខ្លាច (ពាក្យដំណេះដំនៀលនោះ)។

[៤៨៤] បុគ្គលចូលទៅកើតក្នុងពួកក្សត្រិយ៍ ដោយព្រហ្មចរិយធម៌ដ៏ថោកទាប បុគ្គលចូលទៅកាន់ភាពជាទេវតា ដោយព្រហ្មចរិយធម៌យ៉ាងកណ្តាល បុគ្គលបរិសុទ្ធដោយព្រហ្មចរិយធម៌ដ៏ឧត្តម។

[៤៨៥] ការឲ្យទាន ពិតជាអ្នកប្រាជ្ញសរសើរដោយចំណែកច្រើន ក៏មែនហើយ តែថា ចំណែកធម៌ប៉ុណ្ណោះ ប្រសើរជាងទាន ព្រោះពួកសប្បុរសអ្នកមានប្រាជ្ញាក្នុងកាលមុន និងកាលមុនទៅទៀត បានត្រាស់ដឹងនូវនិព្វានធម៌។

ចប់ អាទិត្តជាតក ទី៨។

## អដ្ឋានជាតក ទី៩



(៤២៥. អដ្ឋានជាតកំ (៩))

[៤៨៦] (មហាធនតាបស និយាយថា) ក្នុងកាលណា ទន្លេគង្គាបែរជាមានផ្កាកុមុទ ទាំងមានទឹក និងសត្វតាវ៉ៅ បែរជាមានសម្បុរដូចស័ង្ខ ដើមព្រីង បែរជាបញ្ចេញផ្លែត្នោត កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នា ក្នុងកាលនោះដោយពិត។

[៤៨៧] ក្នុងកាលណា សំពត់បាវារៈ ៣ យ៉ាង គឺសំពត់ដែលធ្វើដោយផ្កាស្រកាអណ្តើក ១ សំពត់ដែលធ្វើដោយប៉ុយ ១ សំពត់ដែលធ្វើដោយលាយគ្នាទាំងពីរមុខ ១ ប្រែជាសំពត់សម្រាប់ដណ្តប់ក្នុងរដូវរងាបាន កាលបើយ៉ាងនេះ ទើប (យើងនឹងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៨៨] ក្នុងកាលណា គេយកជើងសត្វមូសទាំងឡាយ មកធ្វើជាសេនយ៉ាងល្អឲ្យមាំ មិនឲ្យកក្រើកបាន កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៨៩] ក្នុងកាលណា គេយកស្នែងទន្សាយ មកធ្វើជាបង្អោងសម្រាប់ឡើងកាន់ឋានសួគ៌បាន កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៩០] ក្នុងកាលណា ពួកកណ្តុរ ឡើងតាមបង្អោងទៅទំពាស៊ីនូវដួងព្រះចន្ទ ទាំងដេញរាហូឲ្យរត់ទៅបាន កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៩១] ក្នុងកាលណា ពួករុយហើរទៅទាំងហ្វូង ក្រេបផឹកនូវសុរាក្នុងក្អម ហើយសម្រេចការនៅក្នុងរងើកភ្លើងបាន កាលបើយើងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៩២] ក្នុងកាលណា សត្វលា មានបបូរមាត់ដ៏រលីងល្អ មានមុខដ៏ល្អ ជាសត្វឈ្លាសវៃក្នុងការរាំ និងការច្រៀងបាន កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៩៣] ក្នុងកាលណា ពួកក្អែក និងមៀម នាំគ្នាទៅក្នុងទីស្ងាត់ ហើយគប្បីប្រឹក្សាគ្នា គប្បីស្រឡាញ់គ្នាទៅវិញទៅមកបាន កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៩៤] ក្នុងកាលណា ស្លឹកឈូកទាំងឡាយ បែរទៅជាឆ័ត្រយ៉ាងមាំ ដើម្បីការពារភ្លៀងបាន កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៩៥] ក្នុងកាលណា សត្វបក្សីតូចឈ្មោះកុលកៈ ពាំភ្នំគន្ធមាទន៍ដោយចំពុះបាន កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

[៤៩៦] ក្នុងកាលណា កូនក្មេងតូច អាចកាន់យកសំពៅសម្រាប់ដើរសមុទ្រ ព្រមទាំងគ្រឿងយន្ត និងចង្កូតទៅបាន កាលបើយ៉ាងនេះ ទើប (យើងនិងនាង) បានចួបគ្នាក្នុងកាលនោះដោយពិត។

ចប់ អដ្ឋានជាតក ទី៩។

## ទីបិជាតក ទី១០

CS sut.kn.jat.426 | ភាគទី ៥៩

(៤២៦. ទីបិជាតកំ (១០))

[៤៩៧] (មេពពៃ និយាយនឹងខ្លាថា) បពិត្រឪពុកធំ លោកល្មមអត់ធន់បាន ល្មមញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅបានដែរឬ លោកបានសេចក្ដីសុខទេឬ ម្ដាយខ្ញុំបាននិយាយសួរសេចក្ដីសុខរបស់លោក ព្រោះថាយើងទាំងឡាយ ជាអ្នកប្រាថ្នាសេចក្ដីសុខដល់លោក។

[៤៩៨] (ខ្លាឆ្លើយតបថា) ម្នាលមេពពៃ នាងឯងបានដើរជាន់កន្ទុយរបស់អញ ធ្វើឲ្យអញលំបាក ថ្ងៃនេះ នាងឯងស្មានថា អាត្មាអញនឹងរួចទោស ដោយសារការហៅអញថា ឪពុកធំ ដូច្នេះឬ។

[៤៩៩] (មេពពៃ និយាយថា) អ្នកអង្គុយបែរមុខទៅទិសខាងកើត ចំណែកខ្ញុំ ក៏បានដើរមកចំមុខរបស់អ្នក កន្ទុយរបស់អ្នកនៅពីខាងក្រោយទេ ចុះខ្ញុំជាន់កន្ទុយរបស់អ្នក ដោយប្រការដូចម្ដេចបាន។

[៥០០] (ខ្លានិយាយថា) ទ្វីប ៤ ព្រមទាំងសមុទ្រ និងភ្នំ មាននៅត្រឹមណា កន្ទុយរបស់អញ ក៏មាននៅត្រឹមណោះដែរ ហាងឯងនឹងវៀរឲ្យផុត (ពីកន្ទុយរបស់អញ) ដូចម្ដេចបាន។

[៥០១] (មេពពៃ និយាយថា) អំពីដើមមក មាតាបិតា និងបងឈ្មោលរបស់ខ្ញុំ ក៏បានប្រាប់ហេតុនុ៎ះហើយថា កន្ទុយសត្វសាហាវវែងណាស់ (ព្រោះហេតុនោះ បានជា) ខ្ញុំហោះមកតាមអាកាស។

[៥០២] (ខ្លា និយាយថា) នែមេពពៃ ហ្វូងម្រឹគរត់បាត់អស់ទៅ ព្រោះឃើញហាងឯង ហោះមកក្នុងអាកាស ហាងឯងបំផ្លាញចំណីរបស់អញអស់។

[៥០៣] (អភិសម្ពុទ្ធគាថា) កាលដែលមេពពៃកំពុងតែនិយាយរៀបរាប់យ៉ាងនេះ ខ្លាដំបងដែលជាសត្វស៊ីឈាម ក៏ស្ទុះទៅចាប់កាច់កនៃពពៃសម្លាប់ទៅ ឱសំដីល្អមិនមានក្នុងបុគ្គលអាក្រក់ឡើយ។

[៥០៤] ការដឹកនាំ ១ ធម៌ ១ និងសំដីល្អ ១ មិនមានក្នុងបុគ្គលអាក្រក់ទេ បុគ្គល គួរគេចវាងពួកបុគ្គលអាក្រក់ ហើយប្រឹងប្រកបព្យាយាម ព្រោះពួកបុគ្គលអាក្រក់នោះ មិនត្រេកអរនឹងពួកសប្បុរសឡើយ។

ចប់ ទីបិជាតក ទី១០។

ចប់ កច្ចានិវគ្គ។

ឧទ្ទាននៃកច្ចានិវគ្គនោះគឺ

និយាយអំពីកច្ចានីបរិសុទ្ធ មិនមានមន្ទិល ទ្រទ្រង់សំពត់ ១ សម្រែកស្ដេចកុក ១ គ្រឿងប្រដាប់មាស ១ ការទ្រទ្រង់នូវអាជ្ញា ១ ផែនដីដូចរងើកភ្លើង ១ ស្ដេចចេតិយៈ ១ កាលទេវិលតាបស ១ ផ្ទះត្រូវភ្លើងឆេះ ១ ទន្លេគង្គា ១ មេពពៃ ១ រួមត្រូវជា ១០។

ចប់ អដ្ឋកនិបាត។

# នវកនិបាត

CS sut.kn.jat.v09 | ភាគទី ៥៩

(៩. នវកនិបាតោ)

## គិជ្ឈជាតក ទី១

CS sut.kn.jat.427 | ភាគទី ៥៩

(៤២៧. គិជ្ឈជាតកំ (១))

[៥០៥] (អភិសម្ពុទ្ធគាថា) មានផ្លូវលើគិជ្ឈបពិត ឈ្មោះបរិសង្កុបថៈ ជាផ្លូវមានមកតាំងអំពីបុរាណ ត្មាតមួយចិញ្ចឹមមាតាបិតាដែលចាស់ជរានៅក្នុងផ្លូវនោះ។

[៥០៦] ត្មាតនោះ បានទៅនាំយកកន្សោមខ្លាញ់ពស់ថ្លាន់ មកចិញ្ចឹមមាតាបិតាទាំងនោះដោយច្រើន ចំណែកត្មាតជាបិតា កាលបើដឹងថាត្មាតឈ្មោះសុបត្តៈជាកូន មានស្លាបបរិបូណ៌ មានតេជះ ហើរទៅកាន់ទីខ្ពស់ ទាំងហើរទៅកាន់ទីឆ្ងាយបាន ក៏និយាយដាស់តឿន។

[៥០៧] នែបា (បើ) អ្នកដឹងនូវផែនដីថា អណ្ដែត (ដូចជាស្លឹកឈូក) មានសាគរព័ទ្ធជុំវិញមូលដូចកង់ វេលាណាហើយ នែបា ចូរអ្នកត្រឡប់មកអំពីទីនោះវិញ អ្នកកុំទៅឲ្យហួសទៅនាយអំពីទីនេះឡើយ។

[៥០៨] (ត្មាតឈ្មោះសុបត្តៈ) ជាបក្សីមានកក្កូក់ មានកំឡាំងដ៏ប្រសើរជាងទិជជាតិ ហើរស្ទុះឡើង ដោយសន្ទុះដ៏ខ្លាំង រមិលមើលនូវភ្នំនិងព្រៃទាំងឡាយ។

[៥០៩] (ត្មាតឈ្មោះសុបត្តៈនោះ) បានឃើញផែនដីមានសាគរព័ទ្ធជុំវិញ មូលដូចជាកង់ សមដូចពាក្យប្រដៅរបស់បិតាដែលខ្លួនបានឮមកហើយ។

[៥១០] ត្មាតនោះ ហើរលែងទីនោះ ឆ្លងហួសទៅកាន់ទីខាងនាយ ស្រាប់តែមានខ្យល់ព្យុះយ៉ាងខ្លាំង បក់កួចត្មាតដ៏មានកំឡាំងនោះ ខ្ទេចខ្ទីអស់ទៅ។

[៥១១] បក្សីត្មាតនោះ ហើរជ្រុលហួសទៅនាយហើយ ក៏មិនអាចហើរត្រឡប់មកវិញបាន លុះក្នុងអំណាចខ្យល់ព្យុះ ក៏ដល់នូវសេចក្តីវិនាសទៅ។

[៥១២] ពួកកូន និងប្រពន្ធរបស់ត្មាតនោះក្តី ពួកត្មាតដទៃដែលរស់នៅដោយសារត្មាតនោះ (បរិវារ) ក្តី ក៏ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ព្រោះតែត្មាតសុបត្តៈនោះ មិនធ្វើតាមឱវាទ។

[៥១៣] ពួកជនណា ក្នុងលោកនេះ មិនធ្វើតាមពាក្យប្រដៅរបស់បុគ្គលចាស់ព្រឹទ្ធាចារ្យទាំងឡាយ យ៉ាងនេះហើយ ពួកជនទាំងអស់នោះ រមែងដល់នូវសេចក្តីវិនាស ព្រោះតែមិនធ្វើតាមពាក្យប្រដៅរបស់បុគ្គលចាស់ព្រឹទ្ធាចារ្យ ដូចជាត្មាតដ៏មានកំឡាំង ប្រព្រឹត្តល្មើសពាក្យប្រដៅ ហើរហួសទីព្រំប្រទល់។

ចប់ គិជ្ឈជាតក ទី ១។

## កោសម្ពិយជាតក ទី២

CS sut.kn.jat.428 | ភាគទី ៥៩

(៤២៨. កោសម្ពិយជាតកំ (២))

[៥១៤] (ព្រះសាស្តា ត្រាស់ថា) ជនសុទ្ធតែមានសម្លេងខ្លាំងស្មើគ្នា មិនមានជនណាមួយដឹងថា អាត្មាអញជាបុគ្គលពាលឡើយ កាលបើសង្ឃកំពុងបែកគ្នា ក៏មិនមានជនណាមួយ ដឹងនូវហេតុដទៃ ឲ្យក្រៃលែងជាងនេះទៅទៀត។

[៥១៥] ពួកជនអ្នកភ្លេចស្មារតី មានអាការស្រដៀងនឹងបណ្ឌិត មានវាចាជាអារម្មណ៍ ចេះតែល្មោភនិយាយ តាមដែលខ្លួនចង់និយាយ ឲ្យតែរួចពីមាត់ មានគេដឹកនាំ ដោយជំលោះណា ក៏នៅតែមិនស្គាល់នូវជំលោះនោះឡើយ។

[៥១៦] ពួកជនណា ចងសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក (ទ្រព្យ) អញដូច្នេះ ពៀររបស់ជនទាំងនោះ រមែងមិនស្ងប់រម្ងាប់បានឡើយ។

[៥១៧] លុះតែពួកជនណា មិនចងសេចក្តីក្រោធនោះទុក ដោយគិតថា ជនឯណោះ បានជេរអញ បានវាយអញ បានផ្ចាញ់អញ បានលួចយក (ទ្រព្យ) អញដូច្នេះ ទើបពៀររបស់ជននោះ ស្ងប់រម្ងាប់បាន។

[៥១៨] ពៀរទាំងឡាយក្នុងលោកនេះ មិនស្ងប់រម្ងាប់ដោយពៀរក្នុងកាលណាម្តងឡើយ មានតែស្ងប់រម្ងាប់ដោយមិនមានពៀរ នេះជាធម៌មានមកតាំងអំពីដើម។

[៥១៩] ពួកជនក្រៅពីបណ្ឌិត មិនដឹងច្បាស់ថា ពួកយើងនឹងដល់នូវសេចក្តីវិនាស ក្នុងកណ្តាលសង្ឃនេះទេ បណ្តាជនទាំងនោះ លុះតែពួកជនណាដឹងច្បាស់ (យ៉ាងនេះថា ពួកយើងនឹងដល់នូវសេចក្តីវិនាស) ទើបកលហធម៌ គឺការឈ្លោះប្រកែកទាំងឡាយ ស្ងប់រម្ងាប់អំពីសំណាក់ពួកជននោះទៅបាន។

[៥២០] អំបាលពួកជនដែលបានកាត់ឆ្អឹងគ្នា បានសម្លាប់គ្នា បានលួចយកគោ សេះ និងទ្រព្យ ប្លន់យកទាំងដែន គេគង់រួមគ្នាបាន ហេតុអ្វីក៏ពួកអ្នក រួមគ្នាមិនបាន។

[៥២១] បើបុគ្គលបានសំឡាញ់ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញត្រាច់ទៅជាមួយ មានវិហារធម៌ដ៏ប្រពៃ គប្បីគ្របសង្កត់នូវសេចក្តីអន្តរាយទាំងឡាយទាំងពួង ហើយមានចិត្តត្រេកអរ មានស្មារតី ត្រាច់ទៅជាមួយនឹងសំឡាញ់នោះចុះ។

[៥២២] បើបុគ្គលមិនបានសំឡាញ់ដែលមានប្រាជ្ញា ជាគ្រឿងរក្សាខ្លួន ជាអ្នកប្រាជ្ញ ត្រាច់ទៅជាមួយគ្នា មានវិហារធម៌ដ៏ល្អទេ គប្បីត្រាច់ទៅតែម្នាក់ឯង ដូចជាព្រះរាជាលះបង់ដែនដែលឈ្នះហើយ (ពុំនោះសោត) ដូចដំរីដ៏ប្រសើរដែលត្រាច់ទៅតែម្នាក់ឯងក្នុងព្រៃ។

[៥២៣] ការត្រាច់ទៅម្នាក់ឯង ប្រសើរជាង (ព្រោះ) សហាយតាគុណ មិនមានក្នុងបុគ្គលពាលទេ បុគ្គលគួរត្រាច់ទៅតែម្នាក់ឯង តែថាត្រូវជាអ្នកខ្វល់ខ្វាយតិច កុំធ្វើបាបទាំងឡាយឡើយ ដូចជាដំរីដ៏ប្រសើរដែលត្រាច់ទៅក្នុងព្រៃ។

ចប់ កោសម្ពិយជាតក ទី២។

## មហាសុវរាជជាតក ទី៣

CS sut.kn.jat.429 | ភាគទី ៥៩

(៤២៩. មហាសុវជាតកំ (៣))

[៥២៤] (ស្តេចហង្ស និយាយនឹងស្តេចសេកថា) កាលណាឈើមានផ្លែបរិបូណ៌ ពួកសត្វស្លាបក៏ហើរសំដៅទៅបរិភោគផ្លែឈើនោះ លុះពួកសត្វស្លាបបានដឹងថា ឈើអស់ផ្លែហើយ ក៏ហើរចេញអំពីដើមឈើនោះ ទៅកាន់ទិសផ្សេង ៗ ក្នុងវេលាជាទីអស់ទៅនៃផ្លែ។

[៥២៥] ម្នាលសេកមានចំពុះក្រហម អ្នកចូរត្រាច់ទៅកាន់ចារិក កុំឲ្យខ្លួនអ្នកស្លាប់ឡើយ ម្នាលសេក ម្តេចក៏អ្នកនៅសញ្ជប់សញ្ជឹងលើដើមឈើងាប់ (នេះ) ម្នាលសេកមានសម្បុរខៀវស្រដៀងនឹងឈើក្នុងវស្សន្តរដូវ យើងសូមដាស់តឿនអ្នក អ្នកចូរថាមកមើល ព្រោះហេតុអ្វី ក៏បានជាអ្នកមិនលះបង់នូវឈើងាប់នេះ។

[៥២៦] (ស្តេចសេក តបថា) ម្នាលហង្ស ពួកសប្បុរសណា រលឹករឿយ ៗ នូវធម៌របស់ពួកសប្បុរស លោកជាសំឡាញ់នឹងពួកសំឡាញ់ (ទៅវិញទៅមកហើយ) ពួកសប្បុរសនោះ សូម្បីដល់នូវការអស់ទៅនៃជីវិត ក៏មិនលះបង់សំឡាញ់នោះចោល ដោយគិតថាអស់ ឬមិនអស់ក្នុងកាលដែលបានសុខ និងទុក្ខឡើយ។

[៥២៧] ម្នាលហង្ស ខ្ញុំជាសប្បុរសដែរ ដើមឈើនេះ ទុកជាញាតិ ឬជាសំឡាញ់របស់ខ្ញុំក៏បាន ខ្ញុំជាអ្នកត្រូវការដោយជីវិត ក៏មិនអាចនឹងលះបង់នូវដើមឈើនោះចោលឡើយ (បើខ្ញុំដឹងថា ឈើនោះអស់ហើយ ៗ លះបង់ចោល) នុ៎ះ មិនមែនជាធម៌របស់សប្បុរសទេ។

[៥២៨] (ស្តេចហង្ស...) ម្នាលបក្សី សេចក្តីមេត្រី សេចក្តីជួបជុំ និងសេចក្តីស្និទ្ធស្នាល ដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹងធម៌នោះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន។

[៥២៩] ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅឰដ៏អាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នានូវពរណាមួយ ចូរទទួលយកនូវពរនោះចុះ។

[៥៣០] (ស្តេចសេក...) ម្នាលហង្ស អ្នកគប្បីឲ្យនូវពរដល់ខ្ញុំ សូមឲ្យដើមឈើនេះ ត្រឡប់មានអាយុរស់វិញ សូមឲ្យដើមឈើនោះមានមែក មានផ្លែ ល្អលាស់ល្អ មានផ្លែមានរសផ្អែមល្អ។

[៥៣១] (ស្តេចហង្ស...) ម្នាលសំឡាញ់ អ្នកចូរមើលដើមឈើដែលមានផ្លែដ៏លើសលុបនេះចុះ ទីលំនៅរបស់អ្នក ចូរកើតជាមួយនឹងដើមល្វា ដើមល្វានោះ ចូរមានមែក មានផ្លែល្អលាស់ល្អ មានផ្លែមានរសផ្អែមល្អ។

[៥៣២] (ស្តេចសេក...) បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្តីសុខ ព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចខ្ញុំដែលបានសេចក្តីសុខ ព្រោះបានឃើញដើមឈើ ប្រកបដោយផ្លែក្នុងថ្ងៃនេះឯង។

[៥៣៣] (អភិសម្ពុទ្ធគាថា) ព្រះឥន្ទបានឮពាក្យសេកហើយ ក៏ធ្វើនូវដើមឈើនោះ ឲ្យមានផ្លែ រួចចៀសចេញទៅកាន់នន្ទនវនឧទ្យានរបស់ពួកទេវតា ជាមួយនឹងប្រពន្ធ។

ចប់ មហាសុវរាជជាតក ទី៣។

## ចុល្លសុវករាជជាតក ទី៤

CS sut.kn.jat.430 | ភាគទី ៥៩

(៤៣០. ចូឡសុវជាតកំ (៤))

[៥៣៤] (ស្តេចហង្ស និយាយនឹងស្តេចសេកថា) ដើមឈើទាំងឡាយច្រើនណាស់ ដែលមានស្លឹកខៀវ មានផ្លែជាអនេក ព្រោះហេតុអ្វីហ្ន៎ បានជាសេកនេះ មានចិត្តរីករាយជានិច្ច តែនឹងដង្កត់ឈើពុកស្ងួត។

[៥៣៥] (ស្តេចសេក និយាយតបវិញថា) យើងបានចូលទៅបរិភោគផ្លែឈើនោះ រាប់ដោយឆ្នាំច្រើនជាអនេក ទោះបីយើងដឹងថា ឈើនោះ មិនមានផ្លែហើយ ការមេត្រីនោះ ក៏នៅដូចដើម។

[៥៣៦] (ស្តេចហង្ស និយាយថា) សត្វស្លាបទាំងឡាយ តែងលះបង់នូវដើមឈើដែលពុកស្ងួត ជ្រុះស្លឹកអស់ មិនមានផ្លែ ហើយហើរទៅ ម្នាលអ្នកជាទ្វិជាតិ អ្នកសំគាល់ឃើញទោស (ក្នុងការលះចោលនោះ) ដូចម្តេច។

[៥៣៧] (ស្តេចសេក និយាយថា) ពួកសត្វណា មានសេចក្តីត្រូវការដោយផ្លែ ហើយគប់រកនូវដើមឈើ លុះដឹងថា មិនមានផ្លែ ក៏លះចោលនូវដើមឈើនោះ ពួកសត្វស្លាបនោះ ឈ្មោះថាមានប្រាជ្ញាគិតតែប្រយោជន៍ផ្ទាល់ខ្លួន មានប្រាជ្ញាមិនល្អ រមែងញ៉ាំងចំណែកនៃសេចក្តីរាប់អានឲ្យវិនាស។

[៥៣៨] (ស្តេចហង្ស និយាយថា) ម្នាលបក្សី សេចក្តីមេត្រី សេចក្តីជួបជុំ និងសេចក្តីស្និទ្ធស្នាល ដែលអ្នកបានធ្វើហើយ ជាការប្រពៃណាស់ បើអ្នកពេញចិត្តនឹងធម៌នេះ អ្នកនឹងបានជាទីសរសើរនៃពួកវិញ្ញូជន។

[៥៣៩] ម្នាលសេក អ្នកមានស្លាបជាយាន ហើរទៅតាមអាកាស យើងឲ្យពរដល់អ្នក ម្នាលបក្សី បើអ្នកមានចិត្តប្រាថ្នានូវពរណានីមួយ ចូរទទួលយកពរនោះចុះ។

[៥៤០] (ស្តេចសេក និយាយថា) ខ្ញុំសូមឲ្យបានឃើញនូវដើមឈើនោះ មានស្លឹក និងផ្លែឡើងវិញដូចដើម ខ្ញុំគប្បីរីករាយរឿយ ៗ ដូចមនុស្សកំសត់ បានកំណប់ទ្រព្យ។

[៥៤១] (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះឥន្ទបានយកទឹកអម្រឹត មកស្រោចនូវឈើដុះលើផែនដី ដើមឈើនោះ មានមែកល្អលាស់ ត្រសាយត្រសុំ មានម្លប់ដ៏ត្រជាក់ ជាទីរីករាយនៃចិត្ត។

[៥៤២] (ស្តេចសេក និយាយថា) បពិត្រសក្កៈ កាលបើយ៉ាងនេះ សូមឲ្យព្រះអង្គបានសេចក្តីសុខ ព្រមទាំងពួកញាតិទាំងអស់ ឲ្យដូចជាខ្ញុំដែលបានសេចក្តីសុខ ព្រោះឃើញនូវដើមឈើដ៏ប្រកបដោយផ្លែក្នុងថ្ងៃនេះ។

[៥៤៣] (អភិសម្ពុទ្ធគាថា) ព្រះឥន្ទបានឮពាក្យសេកហើយ ក៏ធ្វើនូវឈើនោះ ឲ្យមានផ្លែ រួចក៏ចៀសចេញទៅកាន់នន្ទនវនឧទ្យាននៃទេវតាទាំងឡាយ ជាមួយនឹងភរិយា។

ចប់ ចុល្លសុវករាជជាតក ទី៤។

## ហារិតចជាតក ទី៥

CS sut.kn.jat.431 | ភាគទី ៥៩

(៤៣១. ហរិតចជាតកំ (៥ ))

[៥៤៤] (ព្រះបាទព្រហ្មទត្ត ទ្រង់ត្រាស់សួរតាបសថា) បពិត្រមហាព្រហ្ម ខ្ញុំបានឮថា ព្រះហារិតតាបសបរិភោគកាម ពាក្យនុ៎ះ ទទេទេឬ លោកជាបុគ្គលបរិសុទ្ធទេឬ។

[៥៤៥] (ហារិតតាបសពោធិសត្វ តបថា) បពិត្រមហារាជ ពាក្យដែលទ្រង់បានព្រះសណ្តាប់មកយ៉ាងណា ពាក្យនុ៎ះ ពិតយ៉ាងនោះហើយ អាត្មាភាពជាបុគ្គលបានដើរ ទៅកាន់ផ្លូវខុស ជ្រប់នៅក្នុងអារម្មណ៍ដែលជាទីតាំងនៃសេចក្តីវង្វេង។

[៥៤៦] (ព្រះរាជា...) បើបុគ្គលមិនអាចដើម្បីបន្ទោបង់នូវគំនិតមិនល្អ គឺរាគៈ ដែលកើតឡើង ដោយប្រាជ្ញាណាបានទេ ប្រាជ្ញានោះ នឹងចាត់ថាមានប្រយោជន៍ ជាគុណជាតិដ៏ល្អិត អាចគិតឃើញនូវរបស់ល្អដូចម្តេចបាន។

[៥៤៧] (តាបស...) បពិត្រមហារាជ ធម៌ទាំង ៤ ប្រការនេះ គឺរាគៈ ទោសៈ មទៈ និងមោហៈ ជាកិលេសមានកំឡាំងក្លៀវក្លាបំផុត ក្នុងលោក ប្រាជ្ញាមិនបានទីពំនាក់ ព្រោះតែកិលេសទាំងនោះ។

[៥៤៨] (ព្រះរាជា...) លោកដ៏ចំរើន ពួកយើងសន្មតថា ព្រះហារិតតាបស ជាព្រះអរហន្ត បរិបូណ៌ដោយសីល ជាបុគ្គលបរិសុទ្ធ ជាអ្នកប្រាជ្ញ មានប្រាជ្ញាសម្រាប់ទំលុះទំលាយកិលេស។

[៥៤៩] (តាបស...) បពិត្រព្រះរាជា វិតក្កៈទាំងឡាយដ៏លាមក ប្រកបដោយសុភនិមិត្ត និងប្រកបដោយរាគៈ តែងបៀតបៀនអ្នកប្រាជ្ញ ដែលជាអ្នកត្រេកអរក្នុងគុណធម៌របស់ឥសី។

[៥៥០] (ព្រះរាជា...) រាគៈនេះ ជាសភាពកើតអំពីសរីរៈ តែកើតឡើងហើយ រមែងប្រទូស្តនូវគុណឲ្យខូច សូមលោកលះរាគៈរបស់លោក នោះចេញ សេចក្តីចំរើន ទើបកើតមានដល់លោក ដ្បិតជនច្រើននាក់ សន្មតលោកថា ជាអ្នកប្រាជ្ញ។

[៥៥១] (តាបស...) កាមទាំងឡាយនោះ ជាគ្រឿងធ្វើឲ្យងងឹត នាំមកនូវទុក្ខច្រើន មានពិសច្រើន អាត្មាភាពនឹងស្វែងរកនូវឫសនៃកាម ទាំងឡាយនោះ នឹងកាត់ផ្តាច់នូវរាគៈ ព្រមទាំងចំណង។

[៥៥២] (អភិសម្ពុទ្ធគាថា) ឥសីឈ្មោះហារិតៈ ជាអ្នកខំប្រឹងព្យាយាម ដោយសច្ចៈ លុះពោលពាក្យនេះរួច ក៏លះបង់កាមរាគ ហើយបាន ចូលទៅកើតក្នុងព្រហ្មលោក។

ចប់ ហារិតចជាតក ទី៥។

## បទកុសលមាណវជាតក ទី៦

CS sut.kn.jat.432 | ភាគទី ៥៩

**(៤៣២. បទកុសលមាណវជាតកំ (៦))**

[៥៥៣] (ភរិយា និយាយថា) ទឹកទន្លេគង្គាកួចយកទៅនូវបុរសឈ្មោះបាដលិ ជាអ្នកចេះដឹងច្រើន ពោលនូវពាក្យដ៏វិចិត្រ នៃអ្នកដ៏ចំរើន ដែលទឹកកួចយកទៅ សូមអ្នកឲ្យនូវចំរៀងយ៉ាងខ្លីមួយដល់ខ្ញុំ។

[៥៥៤] (ស្វាមី និយាយតបថា) ពួកជនតែងស្រោចនូវបុគ្គលមានទុក្ខ ដោយទឹកណា តែងស្រោចនូវបុគ្គលដែលមានសេចក្តី ក្រវល់ក្រវាយ ដោយទឹកណា យើងគង់នឹងស្លាប់ក្នុងកណ្តាលទឹកនោះ ភ័យកើតមកអំពីវត្ថុជាទីពឹងហើយ។

[៥៥៥] (នាយស្មូនឆ្នាំង និយាយថា) ពូជទាំងឡាយតែងដុះឡើងលើផែនដីណា ពួកសត្វឋិតនៅលើផែនដីណា ផែនដីនោះ បៀតបៀន នូវក្បាលអញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ។

[៥៥៦] (បុរសម្នាក់ និយាយថា) ពួកជន គេចំអិនបាយដោយភ្លើងណា គេកំចាត់បង់នូវរងាដោយភ្លើងណា ភ្លើងនោះ ឆេះនូវកាយ របស់អញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ។

[៥៥៧] (បុរសម្នាក់ និយាយថា) ពួកព្រាហ្មណ៍ និងក្សត្រិយ៍ជាច្រើន តែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយភត្តណា ភត្តនោះ ដែលអាត្មាអញបរិភោគហើយនោះ សម្លាប់នូវអញ ភ័យកើតអំពីវត្ថុជាទីពឹងហើយ។

[៥៥៨] (បុរសម្នាក់ និយាយថា) ពួកអ្នកប្រាជ្ញ តែងប្រាថ្នាខ្យល់ក្នុងខែជាទីបំផុតនៃគិម្ហរដូវ (ឥឡូវ) ខ្យល់នោះ កាច់បំបាក់ខ្លួនខ្ញុំ ភ័យកើត អំពីវត្ថុជាទីពឹងហើយ។

[៥៥៩] (បក្សីជាធំ និយាយថា) ពួកបក្សី តែងអាស្រ័យដើមឈើណា ដើមឈើនោះ បញ្ចេញនូវភ្លើង បក្សីទាំងឡាយ ចូរគប់នូវទិស ទាំងឡាយផ្សេង ៗ ភ័យកើតអំពីវត្ថុជាទីពឹងហើយ។

[៥៦០] (មាតា និយាយថា) អញមានចិត្តសោមនស្ស ហើយនាំមកនូវកូនប្រសាស្រីណា ដែលប្រដាប់ដោយកម្រងផ្កា និងប្រស់ព្រំ ដោយខ្លឹមចន្ទន៍ (ឥឡូវ) កូនប្រសាស្រីនោះ បណ្តេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ។

[៥៦១] (បុរសម្នាក់ និយាយថា) អញត្រេកត្រអាលនឹងកូនប្រុសណា ដែលកើតហើយ និងប្រាថ្នាសេចក្តីចំរើនដល់កូនប្រុសណា (ឥឡូវ) កូនប្រុសនោះ បណ្តេញអញចេញអំពីផ្ទះ ភ័យកើតអំពីវត្ថុជាទីពឹងហើយ។

[៥៦២] (ពោធិសត្វ ពោលថា) សូមឲ្យពួកអ្នកជនបទ និងអ្នកនិគម ដែលបានមកប្រជុំស្តាប់ខ្ញុំ (ឥឡូវ) វត្ថុណាជាទឹក វត្ថុនោះ ក្លាយទៅ ជាភ្លើងហើយ សេចក្តីក្សេម កើតមកអំពីព្រះរាជាណា ភ័យកើតមកអំពីព្រះរាជានោះហើយ ព្រះរាជា និងព្រាហ្មណ៍បុរោហិត ប្លន់ជនអ្នក នៅក្នុងដែន អ្នកទាំងឡាយ ចូររក្សាខ្លួន ដ្បិតភ័យកើតអំពីវត្ថុជាទីពឹងហើយ។

ចប់ បទកុសលមាណវជាតក ទី៦។

## លោមសកស្សបជាតក ទី៧

CS sut.kn.jat.433 | ភាគទី ៥៩

**(៤៣៣. លោមសកស្សបជាតកំ (៧))**

[៥៦៣] (ព្រះឥន្ទ និយាយនឹងព្រះបាទព្រហ្មទត្តថា) បពិត្រព្រះរាជា បើព្រះអង្គញុំាងឥសីឈ្មោះលោមសកស្សបៈ ឲ្យបូជាយ័ញ្ញ ព្រះអង្គនឹងបានទៅជាបុគ្គលមិនចាស់ មិនស្លាប់ ស្មើនឹងព្រះឥន្ទដោយពិត។

[៥៦៤] (តាបសពោធិសត្វ ពោលនឹងអាមាត្យថា) បុគ្គលមិនគួរប្រាថ្នានូវផែនដី ដែលមានសមុទ្រព័ទ្ធជុំវិញ ដូចជាកុណ្ឌលក្នុងសាគរ ព្រមទាំងពាក្យតិះដៀលទេ ម្នាលសេយ្ហាមាត្យ អ្នកចូរដឹងយ៉ាងនេះចុះ។

[៥៦៥] ម្នាលព្រាហ្មណ៍ ការប្រព្រឹត្តិ (ចិញ្ចឹមជីវិត) ណា ដោយកិរិយាបំផ្លាញជីវិតគេ ឬដោយការប្រព្រឹត្តិមិនត្រូវតាមធម៌ មុខគួរឲ្យតិះដៀលនូវការបានយស និងការបាននូវទ្រព្យ ដោយការប្រព្រឹត្តិនោះ។

[៥៦៦] បុគ្គលបួសដើរបិណ្ឌបាត ការចិញ្ចឹមជីវិតនោះ ប្រសើរជាងការស្វែងរកខុសធម៌។

[៥៦៧] បុគ្គលបួសដើរបិណ្ឌបាត មិនបៀតបៀនជនដទៃក្នុងលោក ការនោះប្រសើរជាងរាជសម្បត្តិទៅទៀត។

[៥៦៨] (មហាជន និយាយថា) ព្រះចន្ទមានកំឡាំង ព្រះអាទិត្យមានកំឡាំង ពួកសមណព្រាហ្មណ៍មានកំឡាំង ច្រាំងសមុទ្រមានកំឡាំង ឯពួកស្រ្តីមានកំឡាំងលើសលុបជាងកំឡាំង (នោះ ៗ ទៅទៀត)។

[៥៦៩] ដូចជារាជធីតាឈ្មោះចន្ទវតី បានញុំាងឥសីឈ្មោះលោមសកស្សបៈមានតបៈដ៏ខ្ពង់ខ្ពស់ ឲ្យបូជានូវការបូជាឈ្មោះរាជបេយ្យៈ គឺបូជាដោយការសម្លាប់សត្វចិញ្ចឹម ដើម្បីប្រយោជន៍ដល់បិតា។

[៥៧០] (តាបស...) អំពើដែលធ្វើដោយសេចក្តីលោភនោះ ជាអំពើក្តៅក្រហាយ មានកាមជាហេតុ អាត្មានឹងស្វែងរកឫសនៃអំពើនោះ នឹងកាត់នូវរាគៈ ព្រមទាំងចំណង។

[៥៧១] មុខគួរតិះដៀលនូវកាមទាំងឡាយដ៏ច្រើនក្រៃពេកក្នុងលោក បពិត្រព្រះរាជា ការព្យាយាមដុតបំផ្លាញកិលេស ប្រសើរបំផុតជាងកាមគុណទាំងឡាយ អាត្មានឹងលះបង់កាម ហើយធ្វើព្យាយាមបំផ្លាញកិលេស ឯដែន និងនាងចន្ទវតី ចូរជារបស់ព្រះអង្គវិញចុះ។

ចប់ លោមសកស្សបជាតក ទី៧។

## ចក្កវាកជាតក ទី៨

CS sut.kn.jat.434 | ភាគទី ៥៩

**(៤៣៤. ចក្កវាកជាតកំ (៨ ))**

[៥៧២] (ក្អែកនិយាយនឹងចាក្រពាកថា) ខ្ញុំសូមសួរនូវពួកសត្វបក្សី មានសម្បុរដូចសំពត់ដែលជ្រលក់ដោយទឹកអម្ចត់ ជាសត្វមានចិត្តរីករាយ ត្រាច់ទៅទាំងគូ ៗ ចុះក្នុងពួកកំណើតជាអណ្ឌជៈ និងមនុស្សទាំងឡាយ តើគេសរសើរនូវកំណើតអណ្ឌជៈណា អ្នកចូរពោលនូវហេតុនោះមកមើល។

[៥៧៣] (ចាក្រពាក តបថា) ម្នាលក្អែក ជាសត្វបៀតបៀនមនុស្ស ពួកគេតែងពោលសរសើរយើងជាចាក្រពាកថា ជាសត្វប្រព្រឹត្តសមគួរក្នុងចំណោមនៃមនុស្សទាំងឡាយ ទាំងគេបានសន្មតយើងថា ជាសត្វមានភាពល្អ ក្នុងចំណោមនៃសត្វស្លាបទាំងឡាយ (ពួកយើងមានសភាពជាសត្វឥតភ័យ ត្រាច់ទៅផ្សេង ៗ ក្នុងស្រះឈូក) ពួកយើងមិនធ្វើបាប ព្រោះហេតុតែចំណីឡើយ។

[៥៧៤] (ក្អែក...) ម្នាលចាក្រពាកទាំងឡាយ ជាអ្នកមិនថោកទាប អ្នកទាំងឡាយបរិភោគផ្លែឈើអ្វី ទំពាស៊ីសាច់អ្វី បរិភោគភោជនអ្វីក្នុងស្រះ បានជាកំឡាំង និងសម្បុរ មានសភាពមិនតិច។

[៥៧៥] (ចាក្រពាក...) ម្នាលក្អែក ផ្លែឈើទាំងឡាយ មិនមានក្នុងស្រះទេ ពួកចាក្រពាកបានសាច់បរិភោគអំពីណា ពួកយើងជាអ្នកបរិភោគសារាយ បរិភោគតែទឹកមិនល្អក់ (ពួកយើងមិនធ្វើបាប ព្រោះហេតុតែចំណីឡើយ) ពួកយើងមានសភាពជាអ្នកឥតភ័យ ត្រាច់ទៅផ្សេង ៗ ក្នុងស្រះ។

[៥៧៦] (ក្អែក...) ម្នាលចាក្រពាក ភោជននេះ មិនគាប់ចិត្តយើងទេ ខ្លួនអ្នកមានសភាពប្រហែលនឹងភោជនក្នុងលំនៅនេះ កាលដើមខ្ញុំមានសេចក្តីត្រិះរិះ (យ៉ាងនេះ) ខាងក្រោយមក ខ្ញុំមានសេចក្តីត្រិះរិះផ្សេង សេចក្តីសង្ស័យរបស់ខ្ញុំ ក៏កើតមានក្នុងហេតុនុ៎ះ ដោយប្រការដូច្នេះឯង។

[៥៧៧] ឯខ្លួនយើង តែងបានបរិភោគសាច់ និងផ្លែឈើទាំងឡាយផង នូវចំណីអាហារដែលលាយអំបិល និងប្រេងទាំងឡាយផង ខ្លួនយើងតែងបានបរិភោគនូវរសក្នុងពួកមនុស្ស ដូចបុគ្គលក្លៀវក្លាបានឈ្នះនូវប្រធាននៃសង្គ្រាម ម្នាលចាក្រពាក ឯសម្បុររបស់ខ្ញុំ មិនដូចជាសម្បុររបស់អ្នកទេ។

[៥៧៨] ឯខ្លួនយើង តែងបានបរិភោគសាច់ និងផ្លែឈើទាំងឡាយផង នូវចំណីអាហារដែលលាយអំបិល និងប្រេងទាំងឡាយផង ខ្លួនយើងតែងបានបរិភោគនូវរសក្នុងពួកមនុស្ស ដូចបុគ្គលក្លៀវក្លាបានឈ្នះនូវប្រធាននៃសង្គ្រាម ម្នាលចាក្រពាក ឯសម្បុររបស់ខ្ញុំ មិនដូចជាសម្បុររបស់អ្នកទេ។

[៥៧៩] (ចាក្រពាក...) អ្នកជាសត្វមានអាហារមិនស្អាត តែងលបឆក់ក្នុងខណៈ (ដែលគេធ្វេសប្រហែល) អ្នកឯង តែងបាននូវចំណីអាហារ និងទឹកផឹកដោយលំបាក ម្នាលក្អែក អ្នកឯង មិនត្រេកអរដោយផ្លែឈើទាំងឡាយ មួយទៀត សាច់ទាំងឡាយណា ដែលមាននៅក្នុងកណ្តាលនៃព្រៃស្មសាន អ្នកមិនត្រេកអរនឹងសាច់នោះឡើយ។

[៥៧៩a] ម្នាលក្អែក បុគ្គលណា ជាអ្នកលបឆក់ ក្នុងខណៈ (ដែលគេធ្វេសប្រហែស) បាននូវភោគៈទាំងឡាយ ដោយអំពើដ៏អាក្រក់ ហើយបរិភោគ ដល់មកខាងក្រោយ អ្នកផងនឹងតិះដៀលបុគ្គលនោះ បុគ្គលដែលត្រូវគេតិះដៀលនោះ រមែងសាបសូន្យ ចាកសម្បុរ និងកំឡាំង។

[៥៨០] បុគ្គលបើទុកជាបរិភោគរបស់ត្រជាក់ (ឥតទោស) សូម្បីតិចតួចតែជាអ្នកមិនបៀតបៀនជនដទៃ ដោយអំពើអាក្រក់ កំឡាំង និងសម្បុរ រមែងកើតមានដល់បុគ្គលនោះ ព្រោះថា សម្បុរទាំងអស់ មិនមែនសុទ្ធតែសម្រេចមកអំពីអាហារទេ។

ចប់ ចក្កវាកជាតក ទី៨។

## ហលិទ្វរាគជាតក ទី៩

CS sut.kn.jat.435 | ភាគទី ៥៩

(៤៣៥. ហលិទ្ទិរាគជាតកំ (៩ ))

[៥៨១] (នាងកុមារិកា និយាយនឹងតាបសកុមារថា) ការដែលលោកអត់ទ្រាំក្នុងព្រៃ ជាសេនាសនៈដ៏ស្ងាត់ ជាការប្រពៃហើយ តែថាពួកជនណា អត់ទ្រាំនៅក្នុងស្រុក ពួកជននោះ ឈ្មោះថា ប្រសើរលើសលុបជាងលោកទៅទៀត។

[៥៨២] (តាបសកុមារ សួរតាបសពោធិសត្វជាបិតាថា) បពិត្របិតា លុះដល់ខ្ញុំចេញអំពីព្រៃមកកាន់ស្រុក តើគួរសេពគប់បុរសមានសីលដូចម្តេច មានវត្តដូចម្តេច ខ្ញុំសួរហើយ សូមបិតាប្រាប់ហេតុនោះ។

[៥៨៣] (តាបសពោធិសត្វ...) នែបា បើបុគ្គលណាស្និទ្ធស្នាលនឹងអ្នក ថែមទាំងគាប់ចិត្តនឹងសេចក្តីស្និទ្ធស្នាលរបស់អ្នក ហើយស្តាប់បង្គាប់ និងអត់ទ្រាំ (នូវពាក្យសំដី) អ្នកចេញអំពីព្រៃនេះទៅ ចូរសេពគប់បុគ្គលនោះចុះ។

[៥៨៤] បុគ្គលណាមិនមានអំពើអាក្រក់ ដោយកាយវាចាចិត្ត អ្នកចេញអំពីព្រៃនេះទៅ ចូរតាំងខ្លួនដូចជាកូន ហើយសេពគប់បុគ្គលនោះចុះ។

[៥៨៥] មួយទៀត បុគ្គលណាប្រព្រឹត្តតាមធម៌ ទោះបីកំពុងប្រព្រឹត្ត ក៏មិនប្រកាន់ខ្លួន លុះដល់អ្នកចេញអំពីព្រៃនេះទៅ ចូរសេពគប់នូវបុគ្គលដែលជាអ្នកធ្វើអំពើដ៏បរិសុទ្ធ ប្រកបដោយប្រាជ្ញានោះចុះ។

[៥៨៦] នែបា បុគ្គលណា មានចិត្តដូចជាសំពត់ជ្រលក់រមៀត មានចិត្តដូចស្វា ត្រេកអរហើយ បែរជាមិនត្រេកអរវិញ បើទុកជា (ក្នុងជម្ពូទ្វីបនេះ) មិនមានមនុស្សសោះ អ្នកកុំគប់រកបុរសបែបនោះឡើយ។

[៥៨៧] អ្នកចូរចៀសវាង (បុគ្គលបែបនោះ) អំពីចម្ងាយ ឲ្យដូចបុគ្គលចៀសវាងអាសីពិសដែលក្រោធ ឬចៀសវាងផ្លូវធំ ដែលប្រឡាក់ដោយលាមក ឬដូចបុគ្គលអ្នកទៅដោយយាន ចៀសវាងផ្លូវមិនស្មើ។

[៥៨៨] នែបា អំពើមិនជាប្រយោជន៍ទាំងឡាយ តែងចំរើនដល់បុគ្គលដែលគប់រកបុគ្គលពាល អ្នកកុំគប់រកបុគ្គលពាល ដែលដូចជាសត្រូវសព្វ ៗ កាលឡើយ។

[៥៨៩] នែបា ព្រោះហេតុនោះហើយ បានជាយើងសូមអង្វរអ្នក ចូរអ្នកធ្វើតាមពាក្យយើង ចូរអ្នកកុំគប់រកបុគ្គលពាលឡើយ (ព្រោះ) ការគប់រកនូវបុគ្គលពាលទាំងឡាយ តែងនាំមកនូវសេចក្តីទុក្ខ។

ចប់ ហលិទ្វរាគជាតក ទី៩។

## សមុគ្គជាតក ទី១០

CS sut.kn.jat.436 | ភាគទី ៥៩

(៤៣៦. សមុគ្គជាតកំ (១០))

[៥៩០] (តាបសពោធិសត្វ សួរអារក្សទឹកថា) នែអ្នកទាំងឡាយដ៏ចំរើន ចុះអ្នកទាំង ៣ នាក់ មកអំពីទីណា អ្នកមកស្រួលហើយ ចូរមកអង្គុយលើអាសនៈទៅ នែអ្នកដ៏ចំរើន អ្នកមានសេចក្តីសុខស្រួល មិនមានជម្ងឺដម្កាត់ទេឬ ព្រោះយូរណាស់ហើយ អ្នកទាំងឡាយទើបមកក្នុងទីនេះ។

[៥៩១] (ទានវៈ[18] តបនឹងតាបសថា) ខ្ញុំមកក្នុងទីនេះតែម្នាក់ឯងទេ ខ្ញុំមិនមានអ្នកណាមួយជាគំរប់ពីរទេ បពិត្រឥសី លោកសំដៅហេតុអ្វីបានជាពោលថា នែអ្នកដ៏ចំរើន ចុះអ្នកទាំង ៣ នាក់មកអំពីទីណា។

[៥៩២] (តាបស..) ខ្លួនអ្នកឯងម្នាក់ផង ភរិយាជាទីស្រឡាញ់របស់អ្នកដែលអ្នកដាក់ក្នុងស្មុគ្រ ហើយលេបចូលទៅក្នុងពោះផង ភរិយានោះ ដែលអ្នករក្សាហើយនៅក្នុងពោះសព្វកាល ត្រេកអរជាមួយនឹង (វិជ្ជាធរ) ជាវាយុបុត្ត ក្នុងស្មុគ្រនោះផង។

[៥៩៣] ទានវៈនោះ លុះឥសីព្យាករហើយ ក៏មានសភាពតក់ស្លុត ហើយខ្ជាក់ស្មុគ្រចេញក្នុងទីនោះ ក៏បានឃើញភរិយាមានរូបយ៉ាងស្អាត ទ្រទ្រង់នូវផ្កាកម្រង ត្រេកអរជាមួយនឹងវិជ្ជាធរ ជាវាយុបុត្តក្នុងស្មុគ្រនោះ។

[៥៩៤] ព្រះករុណាដែលជាអ្នកប្រព្រឹត្តតបៈដ៏ខ្ពង់ខ្ពស់ បានឃើញហេតុត្រឹមត្រូវមែនហើយ ពួកជនណា ជាបុគ្គលថោកទាប ពួកជននោះរមែងលុះអំណាចស្ត្រី ដូចខ្ញុំដែលបានរក្សាទុកនូវស្ត្រី ដូចជាជីវិតក្នុងទីនេះ ស្ត្រីនោះ ប្រទូស្តនឹងខ្ញុំ ហើយរីករាយនឹងបុរសដទៃវិញ។

[៥៩៥] ខ្ញុំបានទំនុកបម្រុងស្ត្រីនោះ ទាំងយប់ទាំងថ្ងៃ ដូចជាភ្លើងដែលលោកមានតបៈ នៅក្នុងព្រៃបូជាហើយ ស្ត្រីនោះ ប្រព្រឹត្តកន្លងធម៌ ហើយប្រព្រឹត្តអធម៌វិញ ការស្និទ្ធស្នាលជាមួយនឹងពួកស្ត្រី ជាសភាពមិនគួរធ្វើសោះឡើយ។

[៥៩៦] ខ្ញុំសំគាល់ស្ត្រី ដែលជាអសប្បុរស មិនសង្រួមថា (ស្ត្រីនេះ) ឋិតនៅក្នុងកណ្តាលសរីរៈ ស្ត្រីនេះជារបស់អញដូច្នេះ ស្ត្រីនោះប្រព្រឹត្តកន្លងធម៌ ហើយប្រព្រឹត្តអធម៌វិញ ការស្និទ្ធស្នាលជាមួយនឹងពួកស្ត្រី ជាសភាពមិនគួរធ្វើសោះឡើយ។

[៥៩៧] ចុះបុគ្គលគួរទុកចិត្តថា អាត្មាអញបានរក្សាស្ត្រីទុកល្អហើយដូច្នេះដោយបការដូចម្តេចបាន ព្រោះមិនមានវិធីរក្សាទុកនូវពួកស្ត្រីដែលមានចិត្តរាយមាយនេះបានទេ ដ្បិតពួកស្ត្រីទាំងនុ៎ះ ប្រហែលនឹងអន្លង់ក្នុងបាតសមុទ្រ បុគ្គលតែប្រហែសក្នុងពួកស្ត្រីទាំងនោះហើយ រមែងដល់នូវសេចក្តីវិនាស។

[៥៩៨] ព្រោះហេតុនោះឯង បុគ្គលពួកណា ជាអ្នកប្រព្រឹត្តរលាស់ខ្លួនចេញចាកពួកមាតុគ្រាម បុគ្គលពួកនោះ តែងបានសុខ ប្រាសចាកសេចក្តីសោក បុគ្គលកាលបើប្រាថ្នាសេចក្តីក្សេមដ៏ឧត្តមនុ៎ះ មិនគួរធ្វើនូវសេចក្តីស្និទ្ធស្នាលនឹងពួកមាតុគ្រាមឡើយ។

ចប់ សមុគ្គជាតក ទី១០។

## បូតិមំសជាតក ទី១១

CS sut.kn.jat.437 | ភាគទី ៥៩

(៤៣៧. បូតិមំសជាតកំ (១១))

[៥៩៩] (មេពពៃ និយាយនឹងមេចចកថា) នៃសំឡាញ់ ការក្រឡេកមើលនៃចចកឈ្មោះបូតិមំសៈ មិនគាប់ចិត្តយើងទេ បុគ្គលគួរវៀរឲ្យឆ្ងាយ អំពីសំឡាញ់បែបនេះ។

[៦០០] (ចចកឈ្មោះបូតិមំសៈ ពោលតិះដៀលមេចចកជាប្រពន្ធខ្លួនថា) មេចចកឈ្មោះវេណិនេះ ជាសត្វឆ្កួត ពោលសរសើរនូវសំឡាញ់ ប្រាប់ដល់អញជាប្តី ហើយបែរជាសោកស្រណោះ នូវមេពពៃដែលទើបនឹងមក ហើយត្រឡប់ថយទៅវិញ។

[៦០១] (មេចចក និយាយតបថា) នៃសំឡាញ់ អ្នកឯងទេតើ ជាសត្វឆ្កួតខ្លៅ មិនចេះពិចារណាអ្វីសោះ អ្នកឯងធ្វើពុតជាស្លាប់ ហើយក្រឡេកមើលខុសកាល។

[៦០២] (អភិសម្ពុទ្ធគាថា) អ្នកប្រាជ្ញមិនគប្បីក្រឡេកមើលក្នុងកាលមិនគួរទេ គប្បីក្រឡេកមើលតែក្នុងកាលដ៏គួរ បុគ្គលណា ក្រឡេកមើលក្នុងកាលមិនគួរ បុគ្គលនោះ រមែងសោកស្រណោះ ដូចចចកឈ្មោះបូតិមំសៈ។

[៦០៣] (មេចចក និយាយនឹងមេពពៃថា) ម្នាលសំឡាញ់ សេចក្តីស្រឡាញ់របស់យើង សូមឲ្យមាននៅដដែល សូមនាងឲ្យរង្វាន់ដល់យើង ប្តីរបស់យើងរស់ដោយខ្លួនឯងវិញហើយ កាលបើខ្ញុំសួរអំពីសេចក្តីស្រឡាញ់ហើយ (គប្បីមកជាមួយនឹងយើង)។

[៦០៤] (មេពពៃ...) នៃសម្លាញ់ របស់ជាទីស្រឡាញ់ ចូរមានដល់នាងដូចដែលចុះ ឥឡូវយើងឲ្យរង្វាន់ដល់នាងហើយ (តែថា) យើងនឹងមកជាមួយនឹងបរិវារច្រើន (បើដូច្នោះ) នាងចូររៀបភោជនទទួលផង។

[៦០៥] (មេចចក...) បរិវាររបស់នាង ដូចម្តេចទៅ ខ្ញុំនឹងរៀបភោជនចាំទទួលពួកបរិវាររបស់នាង បរិវារនាងទាំងអស់នោះ តើមានឈ្មោះដូចម្តេច យើងសួរ នាងចូរប្រាប់នូវបរិវារនោះ។

[៦០៦] (មេពពៃ...) (ឆ្កែ ៤ ពួក) គឺឆ្កែឈ្មោះមាលិយៈ ១ ឆ្កែឈ្មោះចតុរក្ខៈ ១ ឆ្កែឈ្មោះបិង្គិយៈ ១ ឆ្កែឈ្មោះជម្ពុកៈ ១ ឆ្កែបែបនេះ ជាបរិវាររបស់យើង នាងចូររៀបភោជនបម្រុងឆ្កែទាំងនោះចុះ។

[៦០៧] (មេចចក...) កាលបើនាងចេញទៅអំពីផ្ទះ ទ្រព្យរបស់មុខជាវិនាសមិនខាន ចាំយើងប្រាប់សេចក្តីមិនមានរោគដល់សំឡាញ់ នាងចូរនៅក្នុងទីនេះចុះ នាងកុំបាច់ទៅឡើយ។

ចប់ បូតិមំសជាតក ទី១១។

## ទទ្ទរជាតក ទី១២

CS sut.kn.jat.438 | ភាគទី ៥៩

(៤៣៨. ទទ្ទរជាតកំ (១២ ))

[៦០៨] (រុក្ខទេវតា និយាយនឹងមេទន្សងថា) តាបសណា ដែលនាងបានឲ្យអាហារ ហើយស៊ីកូនតូច ៗ ដែលមិនបានប្រទូស្ត (ដល់ខ្លួន) នាងចូរខាំនូវតាបសនោះនឹងចង្កូម កុំឲ្យតាបសនោះរួច (អំពីដៃ) នាង មានជីវិតតទៅឡើយ។

[៦០៩] (មេទន្សង តបនឹងទេវតាថា) បុរសដែលមានសេចក្តីល្មោភខ្លាំង ដ៏ប្រឡាក់ប្រឡូស ដូចជាកំណាត់សំពត់របស់មេនំ ខ្ញុំរមែងមិនឃើញនូវប្រទេសដ៏គួរ ហើយខាំដោយចង្កូមនោះបានឡើយ។

[៦១០] បុគ្គលបើទុកជាឲ្យនូវសម្បត្តិលើផែនដីទាំងអស់ ដល់បុរសអកតញ្ញូ ដែលសំឡឹងឃើញទោសជានិច្ច ក៏នៅតែធ្វើបុរសនោះឲ្យត្រេកអរមិនបាន។

[៦១១] (សីហៈ សួរថា) នែអ្នកមានដើមដៃល្អ ចុះដូចម្តេច បានជាអ្នកប្រញាប់ប្រញាល់ត្រឡប់មក ជាមួយនឹងមាណពនេះ អ្នកមានកិច្ចជាប្រយោជន៍ (ដោយមាណពនេះ) ដូចម្តេច ក្នុងទីនេះ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ។

[៦១២] (ខ្លា...) ទទាណា ដែលជាសំឡាញ់របស់លោក មានសភាពជាសប្បុរស ខ្ញុំថប់តែបុរសនេះ សម្លាប់ទទានោះ ក្នុងថ្ងៃនេះឯង ខ្ញុំឆ្លាប់បានឮអំពើរបស់បុរសនេះហើយ ទើបមិនសំគាល់ថា ទទាបានសេចក្តីសុខ ក្នុងថ្ងៃនេះឡើយ។

[៦១៣] (សីហៈ...) អ្នកធ្លាប់បានឮអំពើសម្រាប់ផ្គំនូវជីវិតឲ្យប្រព្រឹត្តទៅ របស់បុរសនេះ ដូចម្តេច មួយទៀត អ្នកធ្លាប់បានឮនូវពាក្យប្តេជ្ញារបស់បុរសនេះ ដូចម្តេច បានជាអ្នកថប់ ក្រែងតែមាណពនេះសម្លាប់ទទា។

[៦១៤] (ខ្លា...) បុរសនេះធ្លាប់សន្សំ ធ្វើជំនួញក្នុងដែនកលិង្គៈ ទាំងធ្លាប់ដើរទៅមកតាមផ្លូវមានដង្កត់សម្រាប់ចរទៅមកតាមខ្សែផ្តៅ ធ្លាប់សន្សំជាមួយនឹងពួករបាំ និងដាក់បង្កាត់ ធ្លាប់លេងគុណដំបងក្នុងកណ្តាលមហោស្រព។

[៦១៥] បុរសនេះ ធ្លាប់ទាក់ពួកសត្វបក្សី ធ្លាប់វាល់ដោយរង្វាល់អាឡ្ហកៈ ធ្លាប់ដាក់ខ្នាច់ (ឲ្យអ្នកលេងស្កា) មានកិរិយាជាអ្នកសង្រ្គម តែប្រព្រឹត្តកន្លងនូវសីល ធ្លាប់ (រកស៊ីសម្លាប់អ្នកទោស) ធ្វើមិនឲ្យឈាមហូរចេញមួយដំណក់ ក្នុងកណ្តាលរាត្រី មានដៃរលាកដោយការទទួលនូវបិណ្ឌបាតដ៏ក្តៅ (ក្នុងកាលដែលខ្លួននៅបួស)។

[៦១៦] ខ្ញុំបានឮនូវអំពើសម្រាប់ផ្គំជីវិត ឲ្យប្រព្រឹត្តទៅរបស់បុរសនេះ (បែបនេះឯង) នេះដូចជាដុំនៃរោម (ទទានៅលើក្លៀងសក់បុរសនេះ) បុរសនេះ សម្លាប់នូវគោទាំងឡាយបានទៅហើយ ណាក៏មិនហ៊ានសម្លាប់នូវសត្វទទា។

ចប់ ទទ្ទរជាតក ទី១២។

ឧទ្ទាននៃនវកនិបាតនោះគឺ

និយាយអំពីគ្មាតដ៏ប្រសើរ ១ ជនស្មើគ្នា ១ ហង្សដ៏ប្រសើរ ១ កំណប់ទ្រព្យ ១ ហរិតចកុមារ ១ អ្នករបាំឈ្មោះបាតលិកៈ ១ បុគ្គលមិនចាស់មិនស្លាប់ ១ ក្អែក ១ ការអត់ទ្រាំ ១ (អ្នកទាំង ៣ នាក់មក) ពីណា ១ ការក្រឡេកមើល ១ ទទា ១ រួមត្រូវជា ១២។

ចប់ នវកនិបាត។

# ទសកនិបាតជាតក

CS sut.kn.jat.v10 | ភាគទី ៥៩

(១០. ទសកនិបាតោ)

## ចតុទ្វារជាតក ទី១

CS sut.kn.jat.439 | ភាគទី ៥៩

(៤៣៩. ចតុទ្វារជាតកំ (១))

[៦១៧] (មិត្តវិន្ទកៈ សួររុក្ខទេវតាថា) ក្រុងនេះមានទ្វារ ៤ ជាវិការៈនៃដែក មានកំពែងដ៏មាំ ខ្ញុំត្រូវកំពែងព័ទ្ធជាប់ជុំវិញ តើខ្ញុំបានធ្វើបាបអ្វី។

[៦១៨] ទ្វារទាំងអស់បិទជិត ខ្ញុំក៏ជាប់នៅ ដូចជាសត្វស្លាប (ជាប់នៅក្នុងទ្រុង) បពិត្រយក្ខ ហេតុដូចម្តេច ទើបខ្ញុំត្រូវចក្រវិលសង្កិន។

[៦១៩] (រុក្ខទេវតា...) អ្នកបានទ្រព្យជាង ២០ សែន មិនធ្វើតាមពាក្យរបស់ញាតិទាំងឡាយ ដែលជាអ្នកជួយអនុគ្រោះដោយល្អ។

[៦២០] អ្នកស្ទុះលឿនទៅកាន់ទូក ដែលអណ្តែតទៅកាន់សមុទ្រសាគរ ជាទីសម្រេចប្រយោជន៍តិច បាននាងវេមានិកប្រេត ៤ នាក់ នាងវេមានិកប្រេត ៨ នាក់ លុះចេញអំពីវេមានិកប្រេត ៨ នាក់ ក៏បាននាងវេមានិកប្រេត ១៦ នាក់។

[៦២១] អ្នកចេញអំពីនាងវេមានិកប្រេត ១៦ នាក់ ក៏បាននាងវេមានិកប្រេត ៣២ នាក់ អ្នកជាមនុស្សមានសេចក្តីប្រាថ្នាដ៏លើសលុប បានមកប្រទះនឹងចក្រ ទាំងចក្រក៏វិលកិននូវអំបែងក្បាលនៃបុរសដែលមានសេចក្តីប្រាថ្នាគ្របសង្កត់។

[៦២២] សេចក្តីប្រាថ្នា ជាធម្មជាតិដ៏ទូលាយលើសលុប ដែលគេបំពេញបានដោយក្រ ជាផ្លូវដល់នូវសេចក្តីវិបត្តិ ព្រោះសេចក្តីប្រាថ្នា ពួកជនណា ត្រេកអរតាមសេចក្តីប្រាថ្នានោះ ពួកជននោះ រមែងជាអ្នកទ្រទ្រង់នូវចក្រ។

[៦២៣] ពួកជនណា មិនពិចារណានូវផ្លូវនេះ ដូចជាអ្នកលះបង់នូវទ្រព្យច្រើន មិនពិចារណានូវផ្លូវ (ដែលខ្លួនត្រូវដើរទៅ) ពួកជននោះ រមែងជាអ្នកទ្រទ្រង់នូវចក្រ។

[៦២៤] បុគ្គលគប្បីពិចារណានូវកិច្ចការដែលត្រូវធ្វើ និងភោគៈដ៏ច្រើន ហើយមិនគប្បីគប់រកនូវសេចក្តីប្រាថ្នា ដែលមិនប្រកបដោយប្រយោជន៍ ធ្វើតាមពាក្យរបស់ពួកជនអ្នកអនុគ្រោះ ចក្រមិនគប្បីវិលសង្កិនបុគ្គលបែបនោះបាន។

[៦២៥] (មិត្តវិន្ទកៈ ...) បពិត្រយក្ខ ចក្រនឹងឋិតនៅលើក្បាលរបស់ខ្ញុំអស់កាលយូរប៉ុន្មានហ្ន៎ ប៉ុន្មានពាន់ឆ្នាំ ខ្ញុំសួរហើយ សូមលោកប្រាប់ហេតុនោះ។

[៦២៦] (រុក្ខទេវតា...) ម្នាលមិត្តវិន្ទកៈ អ្នកចូរនឹករលឹកឲ្យក្រៃលែង នឹករលឹកឲ្យខ្ជាប់ ហើយចូរស្តាប់នូវពាក្យយើង ចក្រ (នេះ) វិលកិនក្បាលរបស់អ្នក អ្នកកាលរស់នៅ រមែងមិនទាន់រួចទេ។

ចប់ ចតុទ្វារជាតក ទី១។

## កណ្ហជាតក ទី២

CS sut.kn.jat.440 | ភាគទី ៥៩

(៤៤០. កណ្ហជាតកំ (២))

[៦២៧] (សក្កទេវរាជ ពោលថា) ឱហ្ន៎ បុរសនេះ មានសម្បុរខ្មៅ បរិភោគភោជនខ្មៅ នៅក្នុងភូមិប្រទេសក៏ខ្មៅ មិនជាទីពេញចិត្តរបស់យើងឡើយ។

[៦២៨] (កណ្ហតសីពោធិសត្វ ពោលថា) ម្នាលសុជម្បតិ មនុស្សមិនឈ្មោះថាខ្មៅ ដោយតបធម៌ទេ ព្រោះថា មនុស្សមានធម៌ជាខ្លឹមខាងក្នុង ឈ្មោះថាជាព្រាហ្មណ៍ ឯបាបកម្មមាននៅក្នុងមនុស្សណា មនុស្សនោះឯង ឈ្មោះថាខ្មៅ។

[៦២៩] (សក្កទេវរាជ...) ពាក្យនោះ អ្នកពោលល្អហើយ ជាសុភាសិតដ៏គួរ លោកប្រាថ្នាក្នុងចិត្តចំពោះពរណាមួយ ខ្ញុំនឹងឲ្យពរ (នោះ) ដល់លោក។

[៦៣០] (កណ្ហតសី...) បពិត្រសក្កៈជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មា អាត្មាប្រាថ្នានូវសេចក្តីប្រព្រឹត្តចំពោះខ្លួន គឺការមិនមានកោធៈ ១ មិនមានទោសៈ ១ មិនមានលោភៈ ១ មិនមានស្នេហា ១ សូមព្រះអង្គឲ្យនូវពរ ៤ នេះដល់អាត្មា។

[៦៣១] (សក្កទេវរាជ....) បពិត្រព្រាហ្មណ៍ លោកពិចារណាឃើញច្បាស់នូវទោសដូចម្តេច ក្នុងកោធៈ ទោសៈ លោភៈ និងស្នេហា ខ្ញុំសួរហើយ លោកចូរប្រាប់ហេតុនោះ។

[៦៣២] (កណ្ហឥសី....) សេចក្តីក្រោធ មានប្រមាណតិច រមែងទៅជាច្រើន សេចក្តីក្រោធនោះ ដែលកើតអំពីសេចក្តីមិនអត់ធន់ រមែងចំរើន សេចក្តីក្រោធ ជាហេតុឲ្យជាប់ចំពាក់ ឲ្យមានសេចក្តីចង្អៀតចង្អល់ច្រើន ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងសេចក្តីក្រោធឡើយ។

[៦៣៣] វាចារបស់អ្នកប្រកបដោយទោសៈ ជាវាចាអាក្រក់ ការប្រទាប់ (ប្រទាញទៅមក ក៏កើតឡើង) ជាលំដាប់ បន្ទាប់អំពីនោះ ដៃបន្ទាប់អំពីដៃ ដំបងមានដំណើរនៃគ្រឿងសាស្ត្រា ជាទីបំផុត ទោសៈកើតអំពីសេចក្តីក្រោធ ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងទោសៈទេ។

[៦៣៤] ការប្លន់ និងអាការកំហែង ការបោកប្រាស់ និងការបញ្ឆោត រមែងប្រាកដ ក្នុងពួកបុគ្គលអ្នកមានសេចក្តីលោភជាធម្មតា ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងលោភៈទេ។

[៦៣៥] កិលេសគ្រឿងចាក់ស្រេះ ដែលសេចក្តីស្នេហារួបរឹត ជាកិលេសក្រាស់ កើតអំពីចិត្ត រមែងដេកនៅ (ក្នុងអារម្មណ៍នោះ ៗ) កិលេសទាំងនោះ រមែងធ្វើបុគ្គលឲ្យក្តៅក្រហាយដោយក្រៃលែង ព្រោះហេតុនោះ អាត្មាមិនពេញចិត្តនឹងសេចក្តីស្នេហាទេ។

[៦៣៦] (សក្កៈ ...) ពាក្យនោះ លោកពោលល្អហើយ ជាសុភាសិតដ៏គួរ ម្នាលព្រាហ្មណ៍ លោកប្រាថ្នាក្នុងចិត្ត ចំពោះពរណាមួយ ខ្ញុំនឹងឲ្យពរ (នោះ) ដល់លោក។

[៦៣៧] (កណ្ហៈ...) បពិត្រសក្កៈជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មា ៗ សូមកុំឲ្យអាពាធដ៏ក្លៀវក្លា ធ្វើអន្តរាយកើតឡើងដល់អាត្មា ដែលនៅក្នុងព្រៃតែម្នាក់ឯងជានិច្ចឡើយ។

[៦៣៨] (សក្កៈ ...) ពាក្យនោះ លោកពោលល្អហើយ ជាសុភាសិតដ៏គួរ លោកប្រាថ្នាក្នុងចិត្ត ចំពោះពរណាមួយ ម្នាលព្រាហ្មណ៍ យើងនឹងឲ្យពរ (នោះ) ដល់លោក។

[៦៣៩] (កណ្ហៈ...) បពិត្រសក្កៈជាធំជាងពួកភូតទាំងពួង បើព្រះអង្គនឹងឲ្យពរដល់អាត្មា ៗ សូមកុំឲ្យចិត្ត ឬសរីរៈ (របស់អាត្មា) បៀតបៀនចំពោះអ្នកណាមួយ ព្រោះហេតុនៃអាត្មាក្នុងកាលណាឡើយ បពិត្រសក្កៈ សូមព្រះអង្គឲ្យនូវពរនេះ។

ចប់ កណ្ហជាតក ទី២។

## ចតុប្បោសថជាតក ទី៣

CS sut.kn.jat.441 | ភាគទី ៥៩

(៤៤១. ចតុបោសថិយជាតកំ (៣))

[៦៤០] (ព្រះបាទវរុណនាគរាជ ពោលថា) បុគ្គលណា ជាសប្បុរស មិនធ្វើនូវសេចក្តីក្រោធក្នុងបុគ្គលគួរក្រោធ និងមិនក្រោធ ក្នុងកាលណាមួយ បុគ្គលជាសប្បុរសនោះ បើទុកជាក្រោធ ក៏មិនធ្វើសេចក្តីក្រោធឲ្យប្រាកដ បណ្ឌិតទាំងឡាយ ហៅជននោះឯងថាជាសមណៈក្នុងលោក។

[៦៤១] (ព្រះបាទសុបណ្ណរាជ ពោលថា) ជនណា មានពោះធូរ អត់ទ្រាំនូវសេចក្តីស្រេកឃ្លានបាន ទូន្មាននូវឥន្ទ្រិយ ជាអ្នកមានតបធម៌ មានទឹក និងភោជនល្មមប្រមាណ មិនធ្វើនូវបាប ព្រោះហេតុនៃអាហារឡើយ បណ្ឌិតទាំងឡាយ ហៅជននោះថាជាសមណៈ ក្នុងលោក។

[៦៤២] (សក្កទេវរាជ ពោលថា) ជនណា លះបង់នូវល្បែង (ដោយកាយ និងវាចា) និងសេចក្តីត្រេកអរ (ក្នុងកាមគុណ) ទាំងពួង ទាំងមិនពោលនូវពាក្យលេះលោះតិចតួចក្នុងលោក វៀរចាកហេតុជាទីតាំងនៃការស្អិតស្អាង និងមេថុនធម្ម បណ្ឌិតទាំងឡាយហៅជននោះឯងថាជាសមណៈក្នុងលោក។

[៦៤៣] (ព្រះបាទធនញ្ជ័យ ពោលថា) ជនណា កំណត់ដឹង ហើយលះបង់នូវទ្រព្យសម្បត្តិផង លោភៈទាំងពួងផង បណ្ឌិតទាំងឡាយ ហៅជនដែលមានខ្លួនទូន្មាន មានសភាពខ្ជាប់ខ្ជួន មិនមានសេចក្តីប្រកាន់ថាអញ មិនមានសេចក្តីប្រាថ្នានោះឯង ថាជាសមណៈក្នុងលោក។

[៦៤៤] (ព្រះរាជាទាំង ៤ ព្រះអង្គនោះ ត្រាស់សួរថា) ម្នាលអ្នកមានប្រាជ្ញាមិនថោកថយ យើងទាំងឡាយ សូមសួរចំពោះអ្នក ជាអ្នកធ្វើ (នូវហេតុដែលគួរធ្វើ) ការជជែកចំពោះពាក្យទាំងឡាយ កើតមានដល់យើង សូមអ្នកកាត់នូវសេចក្តីងឿងឆ្ងល់ និងសេចក្តីសង្ស័យចេញក្នុងថ្ងៃនេះ យើងទាំងអស់គ្នា គប្បីឆ្លងនូវសេចក្តីសង្ស័យនោះ ក្នុងថ្ងៃនេះ។

[៦៤៥] (វិធុរបណ្ឌិតពោធិសត្វ ពោលថា) បណ្ឌិតណា ជាអ្នកយល់សេចក្តី បណ្ឌិតនោះ រមែងពោលដោយឧបាយនៃប្រាជ្ញាក្នុងកាលគួរក្នុងពាក្យជជែកនោះ បពិត្រព្រះអង្គជាធំជាងជនទាំងឡាយ ពួកជនអ្នកឈ្លាស គប្បីយល់នូវសេចក្តីនៃពាក្យពោលដែលគេមិនទាន់និយាយ ដោយប្រការដូចម្តេចបាន។

[៦៤៦] ស្តេចនាគ ពោលដូចម្តេច ស្តេចគ្រុឌវេនតេយ្យ ពោលដូចម្តេច ស្តេចគន្ធព្វ (ព្រះឥន្ទ) ពោលដូចម្តេច ស្តេចដ៏ប្រសើររបស់អ្នកដែនកុរុពោលដូចម្តេច។

[៦៤៧] (ព្រះរាជាទាំងឡាយនោះ ឆ្លើយថា) ស្តេចនាគ ពោលចំពោះខន្តិធម៌តែម្យ៉ាង ស្តេចគ្រុឌវេនតេយ្យ ពោលចំពោះអាហារតិច ស្តេចគន្ធព្វ ពោលចំពោះការលះបង់សេចក្តីត្រេកអរ ស្តេចដ៏ប្រសើររបស់អ្នកដែនកុរុ ពោលចំពោះការមិនមានកង្វល់។

[៦៤៨] (ព្រះពោធិសត្វ ពោលថា) ពាក្យទាំងអស់នេះ ជាសុភាសិត ពាក្យជាទុព្ភាសិត សូម្បីបន្តិចបន្តួច ក៏មិនមានក្នុងប្រស្នានេះទេ ម្យ៉ាងទៀត ពាក្យទាំងនេះ តាំងនៅស៊ប់ ប្រជុំចុះដោយល្អក្នុងបុគ្គលណា ដូចជាកាំរទេះដែលគេបញ្ចុះស៊ប់ក្នុងដុំ បណ្ឌិតទាំងឡាយហៅបុគ្គលដែលព្រមព្រៀងដោយធម៌ ៤ យ៉ាងនោះឯង ថាជាសមណៈក្នុងលោក។

[៦៤៩] (ព្រះរាជាទាំង ៤ ព្រះអង្គ...) អ្នកជាបុគ្គលប្រសើរ អ្នកជាបុគ្គលមិនមានអ្នកណាវិសេសជាង អ្នកជាបុគ្គលដល់នូវត្រើយនៃធម៌ ចេះដឹងនូវធម៌ មានយោបល់ដ៏ល្អ កំណត់ដឹងនូវប្រស្នាដោយប្រាជ្ញា អ្នកជាអ្នកប្រាជ្ញ បានផ្តាច់សេចក្តីសង្ស័យចេញហើយ អ្នកបានកាត់នូវសេចក្តីសង្ស័យ និងសេចក្តីងឿងឆ្ងល់ ដូចជាគេកាត់នូវភ្លុកនៃដំរីដោយរណារ។

[៦៥០] (សក្កទេវរាជ...) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះនូវប្រស្នា ហើយជូនសំពត់នេះ មានពន្លឺដូចផ្កាឧប្បលខៀវ មិនមានមន្ទិល ជាសំពត់កាត់ថ្លៃមិនបាន មានពណ៌ស្មើដោយផ្សែង ដើម្បីបូជានូវធម៌របស់អ្នក។

[៦៥១] (សុបណ្ណរាជ...) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះនូវប្រស្នា ហើយជូននូវកម្រងផ្កាមាសដែលរីកសំពោង ដោយត្របកច្រើនស្រទាប់ ប្រកបដោយលំអងដ៏ប្រដាប់ដោយកែវដ៏ច្រើន ដើម្បីបូជានូវធម៌របស់អ្នក។

[៦៥២] (វរុណនាគរាជ...) បពិត្រអ្នកប្រាជ្ញ ខ្ញុំត្រេកអរនឹងការដោះស្រាយនូវប្រស្នា ហើយជូននូវកែវមណី ដែលកាត់ថ្លៃមិនបាន ជាកែវដ៏រុងរឿង មានពន្លឺផ្លេក ៗ សម្រាប់ពាក់ឰដ៏ក ដែលស្អិតស្អាងដោយកែវមណី ដើម្បីបូជានូវធម៌របស់អ្នក។

[៦៥៣] (ព្រះរាជា...) ខ្ញុំត្រេកអរនឹងការដោះស្រាយនូវប្រស្នា ហើយជូននូវគោមួយពាន់ ទាំងគោឧសភៈផង ដំរីផង រថ ១០ ដែលទឹមដោយសេះអាជានេយ្យនេះផង ស្រុកសួយ ១៦ ផង ដល់អ្នក។

[៦៥៤] អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះថា ស្តេចនាគក្នុងកាលណោះ បានមកជាព្រះសារីបុត្ត ស្តេចគ្រុឌ បានមកជាកោលិតភិក្ខុ (មោគ្គល្លាន) ស្តេចគន្ធព្វ បានមកព្រះអនុរុទ្ធ ស្តេចបានមកជាអានន្ទបណ្ឌិត វិធុរពោធិសត្វ គឺតថាគត។

ចប់ ចតុបោសថជាតក ទី៣។

## សង្ខជាតក ទី៤

CS sut.kn.jat.442 | ភាគទី ៥៩

(៤៤២. សង្ខជាតកំ (៤))

[៦៥៥] (អ្នកបំរើ ពោលថា) បពិត្រសង្ខព្រាហ្មណ៍ អ្នកជាពហុស្សុត ធ្លាប់បានស្តាប់ធម៌ ទាំងសមណព្រាហ្មណ៍ អ្នកក៏បានជួបហើយ កាលបើដូច្នេះ (ហេតុអ្វី) ទើបអ្នកសំដែងនូវពាក្យរវើរវាយ ក្នុងកាលមិនមែនជាខណៈ អ្នកណាទៀតហ្ន៎ ជាអ្នកប្រឹក្សាចំពោះអ្នក ក្រៅអំពីខ្ញុំ។

[៦៥៦] (សង្ខព្រាហ្មណ៍ ពោលថា) ទេវធីតា មានមុខល្អ មានរូបល្អ មានមាសពាក់ដោយល្អ កាន់នូវ (ភត្ត) ដោយភាជន៍មាស មានសទ្ធា មានចិត្តរីករាយ និយាយនឹងយើងថា អ្នកចូរបរិភោគនូវភត្តចុះ យើងនិយាយនឹងទេវតានោះថា យើងមិន (បរិភោគ) ទេ។

[៦៥៧] (លំដាប់នោះ អ្នកបម្រើពោលថា) ម្នាលព្រាហ្មណ៍ ធម្មតាបុរសអ្នកប្រាថ្នាសេចក្តីសុខ កាលបានឃើញយក្ខប្រាកដដូច្នោះហើយ គួរណាស់តែសួរ (ឲ្យដឹង) អ្នកចូរក្រោកឡើង ហើយប្រណម្យដៃ សួរយក្ខនោះថា នាងជាទេវធីតា ឬជាមនុស្ស។

[៦៥៨] (សង្ខព្រាហ្មណ៍ពោធិសត្វ ពោលថា) នាងបានគយគន់មើលយើងដោយសេចក្តីសុខ និយាយនឹងយើងថា អ្នកចូរបរិភោគនូវភត្តចុះ ម្នាលនាងនារី អ្នកមានអានុភាពធំ យើងសូមសួរនាង តើនាងជាទេវធីតា ឬជាមនុស្ស។

[៦៥៩] (ទេវធីតា ពោលថា) បពិត្រសង្ខព្រាហ្មណ៍ ខ្ញុំជាទេវធីតាមានអានុភាពធំ មកក្នុងកណ្តាលសាគរនេះ ព្រោះខ្ញុំមានសេចក្តីអនុគ្រោះ មិនមែនមានចិត្តប្រទូស្តទេ ទើបមកក្នុងទីនេះ ដើម្បីប្រយោជន៍ចំពោះអ្នកតែម្យ៉ាង។

[៦៦០] បពិត្រសង្ខព្រាហ្មណ៍ ក្នុងសមុទ្រនេះ មានបាយ ទឹក ទីដេក ទីអង្គុយ និងយានផ្សេង ៗ ជាច្រើន អ្នកមានចិត្តប្រាថ្នាចំពោះរបស់ណាមួយ ខ្ញុំនឹងប្រគល់ឲ្យរបស់ទាំងអស់នោះដល់អ្នក។

[៦៦១] (ព្រះពោធិសត្វ ពោលថា) បពិត្រនាងទេវធីតាមានរាងខ្លួនល្អ មានភ្លៅល្អ មានរង់ចិញ្ចើមល្អ មានអវយវៈពាក់កណ្តាលខ្លួនល្អ ការបូជាធំក្តី បូជាតូចក្តី ណាមួយរបស់ខ្ញុំ នាងជាឥស្សរៈនៃបុញ្ញកម្មរបស់យើងនោះទាំងអស់ នេះជាផលនៃកម្មរបស់ខ្ញុំដូចម្តេច។

[៦៦២] (នាងទេវធីតា ពោលថា) បពិត្រសង្ខព្រាហ្មណ៍ អ្នកបានប្រគេនស្បែកជើងចំពោះភិក្ខុ ១ អង្គ (ព្រះបច្ចេកពុទ្ធ) ដែលមានជើងកំពុងរលាក ស្រេកឃ្លាន លំបាកក្នុងផ្លូវដ៏ក្តៅ ទក្ខិណាទាននោះ ឲ្យនូវសេចក្តីប្រាថ្នាដល់អ្នកក្នុងថ្ងៃនេះ។

[៦៦៣] (ព្រះពោធិសត្វ ពោលថា) សូមឲ្យកើតសំពៅដែលពាសដោយផែនក្តារ ជាសំពៅមិនលិចទឹក ប្រកបដោយក្តោង និងខ្យល់ ព្រោះថា ក្នុងសមុទ្រនេះ មិនមែនជាភូមិនៃយានដទៃឡើយ សូមនាងចម្លងខ្ញុំ ឲ្យដល់នូវក្រុងមោលិនីក្នុងថ្ងៃនេះ។

[៦៦៤] (អភិសម្ពុទ្ធគាថា) ទេវតានោះ មានចិត្តត្រេកអររីករាយសប្បាយ និម្មិតសំពៅដ៏វិចិត្រល្អ ហើយនាំសង្ខព្រាហ្មណ៍ ព្រមទាំងបុរសឧបដ្ឋាក ចូលទៅកាន់ក្រុងជាទីសុខសាន្ត។

ចប់ សង្ខជាតក ទី៤។

## ចុល្លពោធិជាតក ទី៥

CS sut.kn.jat.443 | ភាគទី ៥៩

(៤៤៣. ចូឡពោធិជាតកំ (៥))

[៦៦៥] (ព្រះរាជាពារាណសី ពោលថា) បើបុគ្គលណា ចាប់យកនាងបរិព្វាជិកា មានភ្នែកទូលាយ ជាទីស្រឡាញ់ មានមុខញញឹមនេះរបស់អ្នក ទៅដោយការកំហែង ម្នាលព្រាហ្មណ៍ តើអ្នកនឹងធ្វើអ្វី (ដល់បុគ្គលនោះ)។

[៦៦៦] (ព្រះពោធិសត្វ ពោលថា) សេចក្តីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាលរស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ឆាប់រហ័ស ឲ្យដូចជាភ្លៀងដ៏ធំឃាត់នូវធូលី។

[៦៦៧] (ព្រះរាជា...) ក្នុងកាលពីដើម លោកនិយាយអួត ឥឡូវនេះ ថ្ងៃនេះ លោកនោះដូចអាងកំលាំង នៅស្ងៀមសម្ងំដេរសង្ឃាដិវិញ។

[៦៦៨] (ព្រះមហាសត្វ...) សេចក្តីក្រោធកើតដល់អាត្មា ក៏ចេញមកមិនបាន អាត្មាកាលរស់នៅ ចេញមកមិនបានទេ អាត្មាឃាត់ឆាប់រហ័ស ឲ្យដូចជាភ្លៀងធំឃាត់នូវធូលី។

[៦៦៩] (ព្រះរាជា...) អ្វីកើតឡើងដល់លោក ចេញមកមិនបាន លោកកាលរស់នៅអ្វីចេញមកបាន លោកឃាត់អ្វី ដូចភ្លៀងធំឃាត់នូវធូលី។

[៦៧០] (ព្រះពោធិសត្វ ពោលថា) កាលសភាវៈណាកើតឡើង បុគ្គលមើលមិនឃើញ កាលមិនកើតឡើង ទើបឃើញងាយ សភាវៈនោះ គឺសេចក្តីក្រោធជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ។

[៦៧១] បុគ្គលទាំងឡាយ ជាសត្រូវ អ្នកស្វែងរកនូវសេចក្តីទុក្ខ រមែងត្រេកអរ ដោយសភាវៈណា ដែលកើតហើយ សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មា ចេញមកមិនបានទេ។

[៦៧២] កាលសភាវៈណាកើតឡើង បុគ្គលរមែងមិនយល់នូវប្រយោជន៍របស់ខ្លួន សភាវៈនោះ គឺសេចក្តីក្រោធ ជាអារម្មណ៍របស់បុគ្គលល្ងង់ កើតឡើងដល់អាត្មាមិនបានទេ។

[៦៧៣] បពិត្រមហារាជ បុគ្គលត្រូវសេចក្តីក្រោធណាគ្របសង្កត់ហើយ រមែងលះបង់នូវកុសលផង ធ្វើប្រយោជន៍ដ៏ធំទូលាយឲ្យសាបសូន្យផង សេចក្តីក្រោធនោះ មានសេនា គឺកិលេសដែលគួរខ្លាច មានកំឡាំងអាចញាំញីសត្វបាន សេចក្តីក្រោធចេញពីអាត្មាមិនបានទេ។

[៦៧៤] ធម្មតាភ្លើង រមែងកើតក្នុងឈើដែលពួត ភ្លើងនោះ កើតអំពីឈើណា ឆេះនូវឈើនោះវិញ។

[៦៧៥] កាលបុរសល្ងង់ខ្លៅ អាប់ឥតប្រាជ្ញា មិនចេះដឹងយ៉ាងនេះ សេចក្តីក្រោធ រមែងកើតអំពីការប្រណាំងប្រជែង បុរសនោះ រមែងត្រូវភ្លើង គឺសេចក្តីក្រោធនោះឆាបឆេះ។

[៦៧៦] សេចក្តីក្រោធរបស់បុគ្គលណា ចម្រើនឡើង ដូចភ្លើងកាលចម្រើនឡើង ក្នុងគំនរស្មៅ និងឈើ យសរបស់បុគ្គលនោះ រមែងសាបសូន្យ ដូចព្រះចន្ទ្រក្នុងកាឡបក្ខ។

[៦៧៧] សេចក្តីក្រោធរបស់បុគ្គលណា ស្ងប់រម្ងាប់ ដូចភ្លើងមិនមានកំញ៉ម យសរបស់បុគ្គលនោះ រមែងបរិបូណ៌ ដូចព្រះចន្ទ្រក្នុងសុក្កបក្ខ។

ចប់ ចុល្លពោធិជាតក ទី៥។

## មណ្ឌព្យជាតក ទី៦

CS sut.kn.jat.444 | ភាគទី ៥៩

### (៤៤៤. កណ្ហទីបាយនជាតកំ (៦))

[៦៧៨] (កណ្ហទីបាយនតាបស ធ្វើសច្ចកិរិយាថា) យើងមានចិត្តជ្រះថ្លា ត្រូវការដោយបុណ្យ បានប្រព្រឹត្តព្រហ្មចរិយៈអស់ ៧ ថ្ងៃគត់ មួយទៀត ព្រហ្មចរិយៈណា លើសទៅទៀត ដែលយើងបានប្រព្រឹត្តហើយ ព្រហ្មចរិយៈនេះ ជារបស់នៃយើង យើងជាអ្នកមិនប្រាថ្នា (ចំពោះបព្វជ្ជា) អស់ជាង ៥០ ឆ្នាំមកហើយ តែឥឡូវនេះ យើងខំប្រព្រឹត្តព្រហ្មចរិយៈ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន (ដល់យញ្ញទត្តកុមារ) ពិសចូរសាបរលាបបាត់ទៅ យញ្ញទត្តកុមារ ចូររស់ឡើង។

[៦៧៩] (បិតាយញ្ញទត្តកុមារ ធ្វើសច្ចកិរិយាថា) ក្នុងកាលខ្លះ ខ្ញុំឃើញភ្ញៀវក្នុងវេលាដែលមកដល់លំនៅ ក៏មិនត្រេកអរនឹងឲ្យទានទេ តែខ្ញុំមិនឲ្យពួកសមណព្រាហ្មណ៍ ទោះជាពហុស្សុត បានដឹងថា ខ្ញុំមិនស្រឡាញ់ទេ មួយទៀត ខ្ញុំទោះបីមិនប្រាថ្នា (ក្នុងទាន) ក៏នៅតែឲ្យ ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន (ដល់យញ្ញទត្តកុមារ) ពិសចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមាររស់ឡើង។

[៦៨០] (មាតាយញ្ញទត្តកុមារ ពោលថា) ម្នាលកូន អាសីរពិសណា មានតេជៈច្រើន បានលូនចេញពីរន្ធមកចឹកអ្នកក្នុងថ្ងៃនេះ ខ្ញុំនិងបិតាអ្នក មិនមានសេចក្តីប្លែកគ្នាណាមួយ ក្នុងអាសីរពិសនោះទេ (ព្រោះជាអ្នកមិនស្រឡាញ់អាសីរពិសដូចគ្នា) ដោយពាក្យសច្ចៈនេះ សូមសួស្តីកើតមាន ពិសចូរសាបរលាបបាត់ទៅ សូមយញ្ញទត្តកុមាររស់ឡើង។

[៦៨១] (នាយមណ្ឌព្យៈជាសំឡាញ់ សួរថា) ពួកជនណាបួស ជាអ្នកស្ងប់រម្ងាប់ ទូន្មានឥន្ទ្រិយ ពួកជននោះ ប្រាកដជាអ្នកប្រាថ្នា (នឹងបួស) មែន វៀរលែងតែកណ្ហទីបាយនតាបសចេញ បពិត្រទីបាយនតាបស លោកស្អប់ខ្ពើមអ្វី បានជាមិនចង់បួស ហើយទ្រាំប្រព្រឹត្តព្រហ្មចារ្យទៅវិញ។

[៦៨២] (ទីបាយនតាបស ពោលថា) បុគ្គលណាចេញ (ចាកផ្ទះបួស) ដោយសទ្ធា ហើយត្រឡប់មក (កាន់ផ្ទះ) វិញ បុគ្គលនោះឯង ឈ្មោះថា ជាមនុស្សល្ងីល្ងើ មិននឹងនួន យើងស្អប់ខ្ពើមវាទៈនេះ (សូម្បី) ជាអ្នកមិនប្រាថ្នា (បួស) ក៏ទ្រាំប្រព្រឹត្តព្រហ្មចារ្យ ដែលវិញ្ញូជនសរសើរផង ជាឋានៈរបស់ពួកសប្បុរសផង យើងជាអ្នកធ្វើនូវបុណ្យយ៉ាងនេះ។

[៦៨៣] ចំណែកអ្នក បានញាំងពួកសមណព្រាហ្មណ៍ និងអ្នកដំណើរឲ្យឆ្អែតស្កប់ស្កល់ដោយបាយ ទឹក និងភិក្ខាហារ ឯផ្ទះរបស់អ្នកនេះ មានភិក្ខាហារ (ដ៏សម្បូណ៌) ដូចជាស្រះសម្រាប់ជនចុះផឹក កាលបើដូច្នេះទេ ចុះអ្នកស្អប់ខ្ពើមពាក្យអ្វី បានជាអ្នកមិនប្រាថ្នានឹងឲ្យទាន តែនៅតែឲ្យនូវទាននេះវិញ។

[៦៨៤] (មណ្ឌព្យៈ...) មាតាបិតា និងជីដូនជីតារបស់ខ្ញុំ ជាអ្នកមានសទ្ធា ជាម្ចាស់នៃទាន ជាអ្នកដឹងនូវពាក្យស្មូម ខ្ញុំប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ ដោយតាំងចិត្តថា អាត្មាអញកុំជាអ្នកមានក្នុងទីបំផុត និងជាអ្នកកាត់នូវវង្សត្រកូល ក្នុងត្រកូលឡើយ អាត្មាអញស្អប់ខ្ពើមចំពោះពាក្យនោះ (ទោះបី) ជាអ្នកមិនមានប្រាថ្នានឹងឲ្យទាន ក៏នៅតែឲ្យនូវទាននេះ។

[៦៨៥] ម្នាលនាងមានសរីរកាយដ៏ល្អ យើងបាននាំនាងមកអំពីត្រកូលនៃញាតិ តាំងពីកាលនាងនៅជាកុមារីក្មេង មានប្រាជ្ញាមិនទាន់អង់អាចម្ល៉េះ នាងបំរើអញទាំងមិនចង់ តែមិនឲ្យដឹងថា មិនស្រឡាញ់អញ ម្នាលនាង កាលបើដូច្នេះ ការនៅរួមជាមួយយើង មានសភាពយ៉ាងនេះ តើដោយហេតុដូចម្តេច។

[៦៨៦] (ភរិយា...) យូរណាស់មកហើយ ក្នុងកាលណាក៏ដោយ ការផ្លាស់ប្តូរប្តី មិនមានក្នុងត្រកូលនេះទេ ខ្ញុំប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ ដោយតាំងចិត្តថា អាត្មាអញ កុំជាអ្នកមានក្នុងទីបំផុត និងជាអ្នកកាត់នូវវង្សត្រកូលក្នុងត្រកូលឡើយ ខ្ញុំស្អប់ខ្ពើមពាក្យនេះ ទោះបីជាអ្នកមិនមានប្រាថ្នានឹងបំរើ ក៏ប្រព្រឹត្តបំរើមិនដាច់ចំពោះអ្នក។

[៦៨៧] បពិត្រមណ្ឌព្យៈ ខ្ញុំនិយាយនូវពាក្យដែលមិនគួរនិយាយ សូមអ្នកអត់ទោសចំពោះពាក្យនោះដល់ខ្ញុំក្នុងថ្ងៃនេះ ព្រោះហេតុនៃកូនចុះរបស់ណាមួយឯទៀត ក្នុងលោកនេះ រមែងមិនមានជាងសេចក្តីស្រឡាញ់ក្នុងកូនឡើយ យញ្ញទត្តកុមាររបស់យើងនេះរស់វិញ។

ចប់ មណ្ឌព្យជាតក ទី៦។

## និគ្រោធជាតក ទី៧

CS sut.kn.jat.445 | ភាគទី ៥៩

### (៤៤៥. និគ្រោធជាតកំ (៧))

[៦៨៨] (បោតិកបុរស ពោលថា) បពិត្រនិគ្រោធ សាខសេនាបតី បាននិយាយថា អញមិនស្គាល់អ្នកនុ៎ះទេ អ្នកនេះជាអ្វី ឬជាអ្នកបម្រើរបស់អ្នកណា (ដូច្នេះ) យ៉ាងណា តើព្រះអង្គទ្រង់យល់យ៉ាងនោះ ដែរឬ។

[៦៨៩] កាលនោះ ពួកបុរសអ្នកធ្វើតាមពាក្យសាខបុរស ក៏ទះតប់មាត់ បណ្តេញខ្ញុំព្រះអង្គ ដោយការអូសកចេញ។

[៦៩០] បពិត្រព្រះអង្គជាធំជាងជន អំពើមិនប្រសើរប្រាកដដូច្នេះ សាខៈជាសំឡាញ់របស់ព្រះអង្គ ជាមនុស្សមានគំនិតអាក្រក់ ជាអកតញ្ញូ ទ្រុស្តមិត្រ បានធ្វើហើយ។

[៦៩១] (ព្រះបាទនិគ្រោធ...) ម្នាលសំឡាញ់ អ្នកប្រាប់នូវការទង់ទាញណា ដែលសាខៈធ្វើហើយដល់ខ្ញុំ ខ្ញុំមិនដឹងនូវដំណើរនុ៎ះទេ ទាំងអ្នកណាមួយ ក៏មិនបានប្រាប់ដល់ខ្ញុំដែរ។

[៦៩២] អ្នកបានធ្វើនូវការចិញ្ចឹមជីវិតងាយ ដល់សំឡាញ់ទាំង ២ នាក់ គឺខ្ញុំ និងសាខៈ ជាអ្នកឲ្យឥស្សរិយយស គឺភាពជាធំក្នុងមនុស្សដល់យើង យើងបានសេចក្តីសំរេច ក៏ព្រោះអ្នក សេចក្តីសង្ស័យក្នុងហេតុនុ៎ះ មិនមានដល់ខ្ញុំទេ។

[៦៩៣] ពូជ (ដែលដាក់) ក្នុងភ្លើង រមែងឆេះ មិនដុះយ៉ាងណាមិញ ឧបការគុណដែលបុគ្គលធ្វើហើយ ក្នុងអសប្បុរស រមែងវិនាស មិនលូតលាស់យ៉ាងនោះដែរ។

[៦៩៤] ឧបការគុណដែលបុគ្គលធ្វើហើយ ក្នុងបុរសជាកតញ្ញូ មានសីលធម៌ មានសេចក្តីប្រព្រឹត្តប្រសើរនោះ រមែងមិនវិនាសទេ ដូចពូជ (ដែលព្រោះ) ក្នុងស្រែល្អ។

[៦៩៥] រាជបុរសទាំងឡាយ ចូរយកលំពែងសម្លាប់នូវសាខៈនេះ ជាមនុស្សលាមក របិញរបុញ មានគំនិតជាអសប្បុរសចុះ យើងមិនប្រាថ្នាឲ្យវារស់នៅទេ។

[៦៩៦] (បោតិកៈ...) បពិត្រមហារាជ សូមព្រះអង្គអត់ទោស ចំពោះបុរសនេះ (ព្រោះថា) ជីវិត (របស់សត្វដែលស្លាប់ហើយ) មិនអាចនាំត្រឡប់មកវិញបានទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គអត់ទោសដល់អសប្បុរស ខ្ញុំព្រះអង្គមិនប្រាថ្នាការសម្លាប់បុរសនេះទេ។

[៦៩៧] បុគ្គលគប្បីសេពគប់នូវស្តេចនិគ្រោធប៉ុណ្ណោះ កុំនៅជាមួយសាខៈឡើយ សេចក្តីស្លាប់ ក្នុងសំណាក់ស្តេចនិគ្រោធប្រសើរជាងឯការរស់នៅក្នុងសំណាក់សាខៈ ពុំប្រសើរឡើយ។

ចប់ និគ្រោធជាតក ទី៧។

## តក្កលជាតក ទី៨

CS sut.kn.jat.446 | ភាគទី ៥៩

### (៤៤៦. តក្កលជាតកំ (៨))

[៦៩៨] (កុមារពោធិសត្វ ពោលថា) បពិត្របិតា ដំឡូងឈាមមាន់ មិនមាន ដំឡូងជ្វា មិនមាន ដំឡូងដៃខ្លា មិនមាន ដំឡូងត្នោត មិនមាន (ក្នុងទីនេះទេ) បិតា មានប្រយោជន៍អ្វី ទើបមកជីករណ្តៅ ក្នុងទីកណ្តាលស្មសាន ក្នុងព្រៃតែម្នាក់ឯង។

[៦៩៩] (បិតា ពោលថា) ម្នាលកូន ជីតារបស់អ្នក មានកំឡាំងថមថយណាស់ហើយ ត្រូវព្យាធិទុក្ខច្រើនយ៉ាងប៉ះពាល់ ថ្ងៃនេះ អញនឹងកប់គាត់ចោលក្នុងរណ្តៅ ព្រោះមិនចង់ឲ្យគាត់រស់នៅទេ។

[៧០០] (កុមារ...) សេចក្តីត្រិះរិះនោះ ជាអំពើដ៏លាមក ដែលបិតាបានហើយ បិតាធ្វើនូវកម្មមិនជាប្រយោជន៍ក្រៃពេក ជាអំពើអាក្រក់ បពិត្របិតា អ្នកកាលបើជរា ចូលគ្របសង្កត់ រមែងបានទទួលនូវកម្មប្រាកដដូច្នេះ អំពីខ្ញុំវិញ សូម្បីខ្ញុំកាលប្រព្រឹត្តតាមវត្តរបស់ត្រកូលនោះ នឹងកប់បិតាក្នុងរណ្តៅវិញ។

[៧០១] (បិតា...) ម្នាលកុមារ អ្នកគ្របសង្កត់ និយាយខ្លាំងខ្ជប់អញដោយសំដីអាក្រក់ នៃកូន អ្នកជាកូនកើតអំពីទ្រូងនៃអញ អនុគ្រោះដោយអំពើមិនមែនជាប្រយោជន៍ដល់អញ។

[៧០២] (កុមារ...) បពិត្របិតា ខ្ញុំមិនមែនអនុគ្រោះលោកដោយឥតប្រយោជន៍ទេ បពិត្របិតា ពិតណាស់ ខ្ញុំអនុគ្រោះដោយប្រយោជន៍ដល់លោកដោយពិត ប៉ុន្តែខ្ញុំមិនគួរដើម្បីនឹងហាមលោក ដែលកំពុងធ្វើកម្មអាក្រក់ដោយហេតុនោះទេ។

[៧០៣] បពិត្រសវិដ្ឋៈ បុគ្គលណា មានធម៌ដ៏លាមក បៀតបៀននូវមាតាបិតា ដែលជាអ្នកមិនប្រទូស្ត បុគ្គលនោះ លុះបែកធ្លាយរាងកាយទៅក្នុងភពខាងមុខ រមែងកើតក្នុងនរក ឥតសង្ស័យ។

[៧០៤] បពិត្រសវិដ្ឋៈ បុគ្គលណា ទំនុកបំរុងមាតាបិតាដោយបាយ និងទឹក បុគ្គលនោះ លុះបែកធ្លាយរាងកាយ ទៅក្នុងភពខាងមុខ រមែងកើតក្នុងសុគតិ ឥតសង្ស័យ។

[៧០៥] (បិតា...) ម្នាលកូន អ្នកមិនមែនអនុគ្រោះដោយឥតប្រយោជន៍ដល់យើងទេ ម្នាលកូន អ្នកអនុគ្រោះដោយប្រយោជន៍ដល់យើង

ពិត ចំណែកខាងយើង ត្រូវមាតារបស់អ្នកប្រើ ទើបមកធ្វើនូវកម្មអាក្រក់ប្រាកដដូច្នេះ។

[៧០៦] (កុមារ...) ស្ត្រីណា ជាភរិយារបស់បិតា មានសភាពមិនប្រសើរ ស្ត្រីនោះ ជាមាតាបង្កើតរបស់ខ្លួនខ្ញុំ បិតាគប្បីបណ្តេញមាតានោះចេញចាកផ្ទះរបស់ខ្លួន ព្រោះថា មាតានោះ គង់នឹងនាំទុក្ខឯទៀតមកឲ្យបិតាមិនខាន។

[៧០៧] ស្ត្រីណា ជាភរិយារបស់បិតា មានសភាពមិនប្រសើរ ស្ត្រីនោះ ជាមាតាបង្កើតរបស់ខ្លួនខ្ញុំ មាតាមានធមិដ៏លាមកនោះ បានទូន្មានខ្លួន ចុះអំណាច ដូចជាមេដំរី ចូលត្រឡប់មក (កាន់ផ្ទះ) វិញ។

ចប់ តក្កលជាតក ទី៨។

## មហាធម្មបាលជាតក ទី៩

CS sut.kn.jat.447 | ភាគទី ៥៩

### (៤៤៧. មហាធម្មបាលជាតកំ (៩ ))

[៧០៨] (អាចារ្យ សួរថា) អ្វីជាវត្តរបស់អ្នក អ្វីជាព្រហ្មចរិយៈរបស់អ្នក នេះជាផលសុចរិតធមិដូចម្តេច ដែលអ្នកសន្សំល្អហើយ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ព្រោះហេតុអ្វី ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់អ្នក មិនស្លាប់។

[៧០៩] (បិតារបស់ធម្មបាល តបថា) ពួកយើងប្រព្រឹត្តធមិ មិននិយាយកុហក វៀរនូវអំពើដ៏លាមក វៀរនូវអំពើមិនប្រសើរគ្រប់យ៉ាង ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់។

[៧១០] ពួកយើងស្តាប់ធមិរបស់អសប្បុរសផង សប្បុរសផង ប៉ុន្តែពួកយើង មិនពេញចិត្តនឹងធមិរបស់ពួកអសប្បុរសទេ ពួកយើងលះបង់អសប្បុរស មិនលះបង់សប្បុរសទេ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់។

[៧១១] ពួកយើង មានចិត្តល្អក្នុងកាលមុនឲ្យ កាលកំពុងឲ្យ ក៏មានចិត្តត្រេកអរ លុះឲ្យហើយ មិនក្តៅក្រហាយក្រោយ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់។

[៧១២] ពួកយើង បានញុំាងពួកសមណព្រាហ្មណ៍ អ្នកដំណើរ ស្មូម យាចក និងអ្នកកំសត់ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើងមិនស្លាប់។

[៧១៣] ពួកយើង មិនប្រព្រឹត្តកន្លងចិត្តភរិយាទេ ទាំងពួកភរិយា ក៏មិនប្រព្រឹត្តកន្លងចិត្តយើង ពួកយើងប្រព្រឹត្តនូវព្រហ្មចរិយធមិលើកលែងតែភរិយាទាំងនោះចេញ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់។

[៧១៤] យើងទាំងអស់គ្នា វៀរចាកបាណាតិបាត វៀរចាកអទិន្នាទានក្នុងលោក មិនផឹកទឹកស្រវឹង មិននិយាយពាក្យកុហក ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់។

[៧១៥] កូនទាំងឡាយ (របស់យើង) កើតក្នុងពួកស្ត្រីដ៏ឧត្តម រមែងជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន ជាពហុស្សូត ដឹងនូវវេទ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើងមិនស្លាប់។

[៧១៦] មាតាបិតា បងប្អូនស្ត្រី បងប្អូនប្រុស កូន ប្រពន្ធ និងយើងគ្រប់គ្នា ប្រព្រឹត្តធមិ ដើម្បីជាប្រយោជន៍ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់ពួកយើងមិនស្លាប់។

[៧១៧] ពួកខ្ញុំប្រុស ពួកខ្ញុំស្ត្រី អ្នកចិញ្ចឹមជីវិតដោយសារ អ្នកបម្រើ និងអ្នកធ្វើនូវការងារទាំងអស់ ប្រព្រឹត្តធមិ ដើម្បីប្រយោជន៍ក្នុងលោកខាងមុខ ព្រោះហេតុនោះឯង ទើបពួកជននៅក្មេង (ក្នុងត្រកូល) របស់យើងមិនស្លាប់។

[៧១៨] ធមិ រមែងរក្សាអ្នកប្រព្រឹត្តធមិដោយពិត ធមិដែលសន្សំល្អហើយ រមែងនាំសុខមកឲ្យ នេះជាអានិសង្សក្នុងធមិដែលសន្សំល្អហើយ បុគ្គលអ្នកប្រព្រឹត្តធមិ រមែងមិនទៅកាន់ទុគ្គតិ។

[៧១៩] ធមិ រមែងរក្សាអ្នកប្រព្រឹត្តធមិដោយពិត ដូចឆត្រធំ (ការពារ) ក្នុងកាលដែលភ្លៀង ធម្មបាលជាបុត្ររបស់យើង ធមិគ្រប់គ្រងហើយ ឆ្អឹង (ដែលអ្នកនាំមកនេះ) ជាឆ្អឹងសត្វដទៃ កុមារ (ជាបុត្ររបស់យើង) មានសេចក្តីសុខនៅឡើយ។

ចប់ មហាធម្មបាលជាតក ទី៩។

## កុក្កុដជាតក ទី១០

CS sut.kn.jat.448 | ភាគទី ៥៩

### (៤៤៨. កុក្កុដជាតកំ (១០))

[៧២០] (មាន់ពោធិសត្វ ពោលថា) បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងបុគ្គលដែលធ្វើបាបម្តងហើយ មិនគប្បីស្និទ្ធស្នាលនឹងបុគ្គលដែលពោលពាក្យលេះលោះ មិនគប្បីស្និទ្ធស្នាលនឹងបុគ្គលដែលមានប្រាជ្ញាគិតតែប្រយោជន៍ខ្លួន មិនគប្បីស្និទ្ធស្នាលនឹងបុគ្គល (មានពុតត្បុត) ដែលធ្វើហាក់ដូចជាស្ងប់ស្ងាត់ក្រៃលែង។

[៧២១] បុរសពួកខ្លះ ប្រកបដោយជាតិ ហាក់ដូចជាគោស្រេកទឹក ស៊ីនូវមិត្តដោយវាចា តែមិន (សង្គ្រោះដោយការងារ)។

[៧២២] បុរសពួកខ្លះ ផ្គងអញ្ជលីទទេឡើង ហើយបិទបាំងដោយវាចាជាមនុស្សស្រាយ កតញ្ញូតាធមិ មិនមានក្នុងបុគ្គលណា សប្បុរសមិនគប្បីចូលទៅជិតនូវបុគ្គលនោះទេ។

[៧២៣] បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងស្ត្រី ឬបុរសដែលមានចិត្តប្រែប្រួល (អ្នកណា) ធ្វើនូវសេចក្តីស្និទ្ធស្នាលឲ្យច្បាស់ដោយអំពើផ្សេងៗ (ហើយធ្វើនូវសេចក្តីអន្តរាយ ក្នុងកាលខាងក្រោយ) បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងបុគ្គលបែបនោះទេ។

[៧២៤] អ្នកដែលល្មោភនឹងអំពើមិនប្រសើរ មានវាចាមិនខ្ជាប់ខ្ជួន បៀតបៀននូវជនទាំងពួង ដូចជាដាវដែលសំលៀង ហើយបិទបាំងទុក បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងបុគ្គលបែបនោះទេ។

[៧២៥] បុគ្គលពួកខ្លះ ក្នុងលោកនេះ ចូលទៅជិតដោយឧបាយផ្សេង ៗ គឺដោយអំណាច ធ្វើហាក់ដូចជាមិត្ត (ដ៏ស្និទ្ធ) មានពាក្យដ៏ស្អាតផូរផង់ តែមិនមានចិត្ត (ស្អាតល្អ) បុគ្គលមិនគប្បីស្និទ្ធស្នាលនឹងបុគ្គលបែបនោះទេ។

[៧២៦] ជនឥតប្រាជ្ញាបែបនោះ ឃើញនូវអាមិសៈ ឬទ្រព្យក្នុងផ្ទះសម្លាញ់ណា រមែងធ្វើនូវសេចក្តីប្រទូស្ត បៀតបៀននូវជននោះ ហើយចៀសចេញទៅ។

[៧២៧] (អភិសម្ពុទ្ធគាថា) សត្រូវច្រើនបិទបាំងដោយសភាពហាក់ដូចជាមិត្តមកគប់រក បុគ្គលគប្បីលះបង់នូវបុរសអាក្រក់នោះចោលចេញ ដូចមាន់លះបង់ខ្លែង។

[៧២៨] បុគ្គលណា មិនឆាប់យល់នូវហេតុដែលកើតឡើង បុគ្គលនោះ រមែងលុះអំណាចសត្រូវ រមែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយ។

[៧២៩] បុគ្គលណា យល់ទាន់នូវហេតុដែលកើតឡើង បុគ្គលនោះ រមែងរួចផុតចាកការបៀតបៀនរបស់សត្រូវ ដូចជាមាន់រួចអំពីខ្លែង។

[៧៣០] ជនមានប្រាជ្ញាវាងវៃ គប្បីវៀរអំពីចម្ងាយ នូវបុគ្គលមិនប្រកបដោយធម៌ ជាអ្នកកំចាត់នូវគុណរបស់បុគ្គលដទៃជានិច្ច ប្រាកដដូចជាអន្ទាក់បញ្ឆោត ដែលគេដាក់ក្នុងព្រៃ ដូចជាមាន់វៀរខ្លែងក្នុងព្រៃឫស្សី។

ចប់ កុក្កុដជាតក ទី១០។

## មដ្ឋកុណ្ឌលិជាតក ទី១១

CS sut.kn.jat.449 | ភាគទី ៥៩

(៤៤៩. មដ្ឋកុណ្ឌលីជាតកំ (១១))

[៧៣១] (ព្រាហ្មណ៍ សួរថា) អ្នកស្អិតស្អាងដោយគ្រឿងប្រដាប់ មានកុណ្ឌលដ៏រលីង ទ្រទ្រង់នូវកម្រងផ្កា ប្រស់ព្រំដោយខ្លឹមចន្ទន៍ក្រហម ផ្គងដៃកន្ទក់កន្ទេញ ក្នុងកណ្តាលនៃព្រៃស្មសាន តើអ្នកដល់នូវសេចក្តីទុក្ខដូចម្តេច។

[៧៣២] (មាណព ឆ្លើយថា) គ្រោងនៃរថ ធ្វើដោយមាស មានរស្មីភ្លឺផ្លេក កើតឡើងហើយដើម្បីខ្ញុំ (បើ) ខ្ញុំមិនបាននូវគូនៃកង់របស់រថនោះទេ ខ្ញុំនឹងលះបង់ជីវិត ព្រោះសេចក្តីទុក្ខនោះ។

[៧៣៣] (ព្រាហ្មណ៍....) អ្នកចូរប្រាប់នូវរថដែលធ្វើដោយមាស ធ្វើដោយកែវមណី ធ្វើដោយទង់ដែង ឬធ្វើដោយប្រាក់ចុះ ខ្ញុំនឹងធ្វើរថ (នោះ) ឲ្យដល់អ្នក ខ្ញុំនឹងញុំាងអ្នក ឲ្យបាននូវគូនៃកង់ (នោះ)។

[៧៣៤] លំដាប់នោះ មាណពប្រាប់ព្រាហ្មណ៍នោះថា ព្រះចន្ទ និងព្រះអាទិត្យ រុងរឿងក្នុងវិថីទាំងពីរ រថរបស់ខ្ញុំដែលធ្វើដោយមាស ទើបសមដោយគូនៃកង់ គឺព្រះចន្ទ និងព្រះអាទិត្យនោះ។

[៧៣៥] (ព្រាហ្មណ៍....) ម្នាលមាណព អ្នកណាប្រាថ្នារបស់ដែលមិនគួរប្រាថ្នា អ្នកនោះចំជាល្ងង់មែន ខ្ញុំសំគាល់ថា អ្នកនឹងស្លាប់ អ្នកពិតជាមិនបាននូវព្រះចន្ទ និងព្រះអាទិត្យឡើយ។

[៧៣៦] (មាណព....) ការចរទៅ និងចរមក (នៃព្រះចន្ទ និងព្រះអាទិត្យទាំងពីរ) ក៏ប្រាកដ វណ្ណធាតុ (រស្មី) ក៏ប្រាកដ វិថីទាំងពីរឰដ៏អាកាសនុ៎ះ ក៏ប្រាកដ ចំណែកខាងជនធ្វើមរណកាល ទៅកាន់លោកខាងមុខហើយ មិនប្រាកដទេ បណ្តាយើងទាំងពីរនាក់ ដែលកំពុងកន្ទក់កន្ទេញ តើអ្នកណាល្ងង់ជាង។

[៧៣៧] (ព្រាហ្មណ៍....) ម្នាលមាណព អ្នកនិយាយត្រូវមែន បណ្តាយើងទាំងពីរនាក់ កំពុងកន្ទក់កន្ទេញ ខ្ញុំនឹងឯងជាបុគ្គលល្ងង់ជាង ខ្ញុំប្រាថ្នានូវកូនដែលធ្វើមរណកាល ទៅកាន់លោកខាងមុខ ដូចជាទារក យំទារនូវព្រះចន្ទ។

[៧៣៨] អ្នកបានស្រោចស្រប់នូវខ្ញុំ ដែលភ្លើង គឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រវល់ក្រវាយទាំងអស់ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចនូវភ្លើង ដែលឆេះនូវឆ្នាំងខ្លាញ់។

[៧៣៩] សរ គឺសេចក្តីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្តីសោកនោះ ខ្ញុំបានដកចេញហើយ ខ្ញុំកាលត្រូវសេចក្តីសោកគ្របសង្កត់ អ្នកបានបន្ទោបង់សេចក្តីសោក ព្រោះបុត្រនោះហើយ។

[៧៤០] ម្នាលមាណព ខ្ញុំនោះ ជាអ្នកមានសរ គឺសេចក្តីសោកដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក មានចិត្តមិនល្អក់ ម្នាលមាណព ខ្ញុំលែងសោកស្តាយ លែងយំទួញ ព្រោះបានស្តាប់ពាក្យរបស់អ្នក។

ចប់ មដ្ឋកុណ្ឌលិជាតក ទី១១។

## ពិលារកោសិយជាតក ទី១២

CS sut.kn.jat.450 | ភាគទី ៥៩

(៤៥០. ពិលារកោសិយជាតកំ (១២))

[៧៤១] (ឥន្ទ្រព្រាហ្មណ៍ ពោលថា) សប្បុរសទាំងឡាយ ទោះបីមិនបានចំអិន តែបើបានភោជនហើយ ក៏ប្រាថ្នាឲ្យដែរ អ្នកកាលចំអិនមិនឲ្យភោជនណា ការមិនឲ្យភោជននោះ មិនសមគួរទេ។

[៧៤២] បុគ្គលមិនឲ្យទាន (ដោយហេតុ ២ យ៉ាង គឺ) សេចក្តីកំណាញ់ ១ សេចក្តីប្រហែស ១ បុគ្គលអ្នកចេះដឹង កាលប្រាថ្នានូវបុណ្យ

រមែងឲ្យទាន។

[៧៤៣] (ចន្ទព្រាហ្មណ៍ ពោលថា) បុគ្គលកំណាញ់ ខ្លាចចំពោះសេចក្តីឃ្លាន និងការស្រេកណាហើយ រមែងឲ្យទានមិនកើតទេ សេចក្តីឃ្លាន និងការស្រេកនោះ ជាភ័យរបស់បុគ្គលអ្នកមិនឲ្យ បុគ្គលកំណាញ់ រមែងខ្លាចអំពីសេចក្តីឃ្លាន និងការស្រេកណា សេចក្តីឃ្លាន និងការស្រេកនោះ រមែងប៉ះពាល់នូវបុគ្គលពាលនោះឯង ក្នុងលោកនេះផង ក្នុងលោកខាងមុខផង។

[៧៤៤] ព្រោះហេតុនោះ បុគ្គលគប្បីបន្ទោបង់នូវសេចក្តីកំណាញ់ចេញ គប្បីគ្របសង្កត់នូវមន្ទិល គឺសេចក្តីកំណាញ់ ហើយឲ្យនូវទាន ព្រោះថាបុណ្យ រមែងបានជាទីពឹង របស់សត្វទាំងឡាយក្នុងលោកខាងមុខ។

[៧៤៥] (សុរិយព្រាហ្មណ៍ ពោលថា) ពួកជនជាសប្បុរស ឲ្យនូវវត្ថុដែលគេឲ្យបានដោយក្រ ធ្វើនូវអំពើដែលគេធ្វើបានដោយក្រ ឯពួកអសប្បុរស រមែងមិនធ្វើតាមឡើយ ធម៌របស់សប្បុរស គឺអសប្បុរសយល់បានដោយក្រ។

[៧៤៦] ព្រោះហេតុនោះ គតិរបស់ពួកសប្បុរស និងអសប្បុរស រមែងបែកផ្សេងគ្នាអំពីលោកនេះ គឺពួកអសប្បុរស រមែងទៅកាន់នរក ពួកសប្បុរស រមែងមានឋានសួគ៌ប្រព្រឹត្តទៅក្នុងខាងមុខ។

[៧៤៧] (មាតលិព្រាហ្មណ៍ ពោលថា) បណ្ឌិតបុរសពួកខ្លះ សូម្បីមានទេយ្យធម៌បន្តិចបន្តួច ក៏រមែងឆ្លៀតឲ្យបាន តែបុរសពួកខ្លះ (សូម្បីបរិបូណ៌) ដោយទេយ្យធម៌ដ៏ច្រើន ក៏ឲ្យមិនបាន ទក្ខិណាទានដែលបុគ្គល (រំលែក) អំពីវត្ថុមានប្រមាណតិចហើយឲ្យ រាប់ស្មើដោយទានមានប្រមាណច្រើន។

[៧៤៨] (បញ្ចសិខព្រាហ្មណ៍ ពោលថា) បុគ្គលណា ប្រព្រឹត្តស្វែងរកអាហារមកចិញ្ចឹមនូវកូន និងប្រពន្ធផង ឲ្យទានសូម្បីបន្តិចបន្តួចផង បុគ្គលនោះ ឈ្មោះថា ប្រព្រឹត្តធម៌ បុគ្គលជាឥស្សរៈទាំងសែននាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកំសត់ ដែលឲ្យទានដោយធម៌ មានបការៈដូច្នោះឡើយ។

[៧៤៩] (ពិលារកោសិយសេដ្ឋី សួរថា) យញ្ញៈ គឺការបូជានុ៎ះ ជាបូជាដ៏ទូលាយ មានថ្លៃក៏ច្រើន ហេតុអ្វី ទើបមិនដល់នូវថ្លៃនៃទានដែលបុគ្គលឲ្យហើយ តាមធម៌ដ៏ត្រឹមត្រូវ ហេតុអ្វី បុគ្គលជាឥស្សរៈទាំងសែននាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកំសត់ ដែលឲ្យទានដោយធម៌ មានបការៈដូច្នោះ។

[៧៥០] (បញ្ចសិខៈ...) ព្រោះថា បុគ្គលពួកខ្លះ តាំងនៅក្នុងកាយកម្មជាដើម មិនស្មើគ្នា បៀតបៀន សម្លាប់ ឬក៏ធ្វើគេឲ្យសោកសៅ ហើយទើបឲ្យ (នូវទក្ខិណាទាន) ទក្ខិណាទាននោះ ឈ្មោះថា មានមុខជោកដោយទឹកភ្នែក ប្រកបដោយអាជ្ញា រមែងមិនដល់នូវតម្លៃនៃទានដែលបុគ្គលឲ្យដោយធម៌ដ៏ត្រឹមត្រូវទេ បុគ្គលជាឥស្សរៈទាំងសែននាក់ ជាអ្នកបូជាទាំងពាន់នោះ មិនដល់នូវចំណិតរបស់អ្នកកំសត់ ដែលឲ្យទានដោយធម៌ មានបការៈដូច្នោះ។

ចប់ ពិលារកោសិយជាតក ទី១២។

## ចក្កវាកជាតក ទី១៣

CS sut.kn.jat.451 | ភាគទី ៥៩

**(៤៥១. ចក្កវាកជាតកំ (១៣))**

[៧៥១] (ក្អែក សួរថា) ម្នាលចាក្រពាក អ្នកមានសរីរៈដ៏មាំមួន មានសម្បុរ និងរូបដ៏ល្អ មានសម្បុរក្រហមអំពីកំណើត មានរូបដ៏សមរម្យ មានឥន្ទ្រិយ គឺមុខថ្លាផូរផង់។

[៧៥២] អ្នកទំនៅឰដ៏ឆ្នេរស្ទឹងគង្គា ប្រហែលជាស៊ីនូវភោជន គឺត្រីក្អែក ត្រីសណ្តាយ ត្រីក្បក ត្រីប្រា និងត្រីឆ្ពឹនយ៉ាងនេះឬ។

[៧៥៣] (ចាក្រពាក ឆ្លើយថា) ម្នាលសម្លាញ់ ខ្ញុំមិនបរិភោគនូវសាច់របស់សត្វគោក និងសត្វទឹក វៀរលែងតែសារាយ និងចកចេញ វត្ថុដទៃ (ក្រៅអំពីសាច់) ជាភោជនរបស់ខ្ញុំ។

[៧៥៤] (ក្អែក....) ម្នាលសម្លាញ់ ខ្ញុំមិនជឿថា សារាយ និងចកនោះ ជាភោជនរបស់ចាក្រពាកទេ ចំណែកខាងខ្ញុំ បរិភោគអាហារភោជនដែលលាយដោយអំបិល និងប្រេងក្នុងស្រុក។

[៧៥៥] (ខ្ញុំបរិភោគ) នូវបាយ លាយដោយសាច់ដ៏ស្អាត ដែលគេធ្វើក្នុងពួកមនុស្ស ម្នាលចាក្រពាក អ្នកមានសម្បុរយ៉ាងណា ខ្ញុំមិនមានសម្បុរប្រាកដដូច្នោះទេ។

[៧៥៦] (ចាក្រពាក....) អ្នកបៀតបៀននូវពួកមនុស្ស សត្វ ឃើញនូវពៀរក្នុងខ្លួន ស៊ីទាំងតក់ស្លុត ភិតភ័យ ព្រោះហេតុនោះ ទើបពណ៌សម្បុររបស់អ្នកប្រាកដដូច្នោះ។

[៧៥៧] ម្នាលក្អែក អ្នកត្រូវសត្វលោកទាំងពួងខឹង បិណ្ឌាហារដែលអ្នកបានមក ដោយអំពើដ៏អាក្រក់ បានជាមិនស្កប់ស្កល់ (ដល់អ្នក) ព្រោះហេតុនោះ ពណ៌សម្បុររបស់អ្នកប្រាកដដូច្នោះ។

[៧៥៨] ម្នាលសម្លាញ់ ខ្លួនខ្ញុំមិនបៀតបៀនពួកសត្វទាំងពួងមកស៊ីទេ ខ្ញុំមានសេចក្តីខ្វល់ខ្វាយតិច ប្រាសចាកសេចក្តីរង្កៀស មិនមានសេចក្តីសោកភ័យអំពីទីណាទេ។

[៧៥៩] អ្នកនោះ ចូរធ្វើនូវអានុភាព គឺសេចក្តីព្យាយាម ចូរផ្លាស់មារយាទចេញ កាលបើអ្នកប្រព្រឹត្តនូវការមិនបៀតបៀនគេ នឹងបានជាទីស្រឡាញ់ (របស់សត្វលោក) ដូចជាខ្ញុំដែរ។

[៧៦០] អ្នកណា មិនបៀតបៀនគេដោយខ្លួនឯង មិនប្រើគេឲ្យបៀតបៀន មិនបំផ្លាញគេដោយខ្លួនឯង មិនប្រើគេឲ្យបំផ្លាញ ជាបុគ្គលមានចំណែកនៃមេត្រីចិត្ត ក្នុងពួកសត្វទាំងពួង ពៀររបស់អ្នកនោះ នឹងមិនមាន មួយអន្លើដោយសត្វណានីមួយឡើយ។

ចប់ ចក្កវាកជាតក ទី១៣។

## ភូរិបញ្ហាជាតក ទី១៤

CS sut.kn.jat.452 | ភាគទី ៥៩

(៤៥២. ភូរិបញ្ហជាតកំ (១៤))

[៧៦១] (អាមាត្យពួកខាងអាចារ្យសេនកៈ សួរថា) បពិត្រអ្នកមានបញ្ញាក្រាស់ដូចផែនដី សិរី សេចក្តីព្យាយាម និងប្រាជ្ញាប្រាកដដូច្នោះ រមែងមិនរក្សានូវអ្នកដែលជាមនុស្សធ្លាក់ចុះ ទៅកាន់អំណាចនៃសេចក្តីមិនចំរើន ព្រោះហេតុតែអ្នកបរិភោគនូវបាយដំណើប មានសម្លតិច តើការណ៍នោះ ពិតមែនឬ។

[៧៦២] (ព្រះមហោសថពោធិសត្វ ពោលថា) ខ្ញុំញុំាងសេចក្តីសុខ (ចាស់របស់ខ្លួន) ឲ្យចំរើនដោយសេចក្តីទុក្ខ ពិនិត្យមើលនូវកាលគួរ និងកាលមិនគួរ ហើយបិទបាំង តាមសេចក្តីពេញចិត្ត (របស់ខ្លួន) បើកនូវទ្វារនៃប្រយោជន៍ ព្រោះហេតុនោះ ទើបត្រេកអរដោយបាយដំណើប។

[៧៦៣] មួយទៀត ខ្ញុំដឹងនូវកាលគួរ ហើយញុំាងប្រយោជន៍ឲ្យចំរើនដោយប្រាជ្ញា (របស់ខ្លួន) ព្រោះសេចក្តីព្យាយាមដ៏ក្លៀវក្លា ដូចសត្វសីហៈធ្វើសេចក្តីព្យាយាមដ៏រឹងប៉ឹង អ្នកឯងនឹងឃើញខ្ញុំម្តងទៀត ដោយឫទ្ធិនោះមិនខាន។

[៧៦៤] (ព្រះរាជា ត្រាស់សួរថា) ជនពួកខ្លះ ជាអ្នកមានសេចក្តីសុខ ទើបមិនធ្វើបាប ជនពួកខ្លះទៀត (មិនធ្វើបាប) ព្រោះខ្លាចអំពីការជាប់ចំពាក់ដោយតំណេះដំនៀល អ្នកជាបុគ្គលអាចមានគំនិតគិតនូវប្រយោជន៍ដ៏ទូលាយបាន ហេតុអ្វី ក៏មិនធ្វើសេចក្តីលំបាកដល់យើង។

[៧៦៥] (ព្រះពោធិសត្វ....) បណ្ឌិតទាំងឡាយ រមែងមិនប្រព្រឹត្តនូវអំពើដ៏លាមក ព្រោះហេតុនៃសេចក្តីសុខផ្ទាល់ខ្លួនទេ ទោះបីត្រូវសេចក្តីទុក្ខប៉ះពាល់ ឬឃ្លាតចាក (សម្បត្តិ) ក៏រមែងមិនលះបង់នូវធម៌ ព្រោះសេចក្តីស្រឡាញ់ និងសេចក្តីស្អប់ឡើយ។

[៧៦៦] (ព្រះរាជា....) បុគ្គលគប្បីលើកតំកើងនូវខ្លួនដ៏ក្រក្សត់ (ឲ្យតាំងនៅក្នុងសម្បត្តិ) ដោយពាក្យសរសើរ ឬដោយពាក្យដ៏ទន់ ឬក៏ដោយពាក្យទ្រគោះណានីមួយ ហើយសឹមប្រព្រឹត្តធម៌ដោយប្រពៃ ក្នុងកាលជាខាងក្រោយ។

[៧៦៧] (ពោធិសត្វ...) បុគ្គលអង្គុយ ឬដេក ក្នុងម្លប់នៃឈើណា មិនត្រូវកាច់នូវមែកនៃឈើនោះទេ ព្រោះបុគ្គលអ្នកទ្រុស្តមិត្ត ជាមនុស្សអាក្រក់។

[៧៦៨] បុរសចេះដឹងនូវធម៌ (អំពីសំណាក់) នៃអាចារ្យណា មួយទៀត សប្បុរសទាំងឡាយណា បន្ទោបង់នូវសេចក្តីសង្ស័យរបស់អ្នកនោះ ការដឹង និងការបន្ទោបង់នោះ ឈ្មោះថា ជាទីពឹង ជាទីប្រព្រឹត្តទៅរបស់បុរសនោះ បុគ្គលអ្នកមានប្រាជ្ញា មិនត្រូវញុំាងមេត្រីចិត្តឲ្យសាបសូន្យអំពីអាចារ្យនោះទេ។

[៧៦៩] គ្រហស្ថអ្នកបរិភោគកាម ខ្ជិលច្រអូស មិនល្អ បព្វជិតមិនសង្រួម មិនល្អ ព្រះរាជាធ្វើការមិនពិចារណា មិនល្អ នរណាជាបណ្ឌិតច្រើនក្រោធ សេចក្តីក្រោធនោះ មិនល្អ។

[៧៧០] បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រិយ៍គប្បីពិចារណាហើយ សឹមធ្វើ មិនគប្បីមិនបានពិចារណាហើយធ្វើទេ បពិត្រព្រះរាជា យសបរិវារក្តី កេរ្តិ៍ឈ្មោះក្តី រមែងចំរើនដល់ព្រះរាជាអ្នកពិចារណាហើយធ្វើ។

ចប់ ភូរិបញ្ហាជាតក ទី១៤។

## មហាមង្គលជាតក ទី១៥

CS sut.kn.jat.453 | ភាគទី ៥៩

(៤៥៣. មហាមង្គលជាតកំ (១៥))

[៧៧១] (តាបសជាសិស្សច្បងរបស់ពោធិសត្វ សួរថា) ក្នុងកាល (ជាទីប្រាថ្នានូវមង្គល) នរជនសែកមន្តដូចម្តេច អាស្រ័យនូវវិជ្ជាដូចម្តេច ឬ (នូវបរិយត្តិ) នៃសូត្រទាំងឡាយដូចម្តេច ជននោះ ទើបឈ្មោះថា គ្រប់គ្រងខ្លួនដោយសួស្តី ក្នុងលោកនេះ និងលោកខាងមុខ។

[៧៧២] (ពោធិសត្វ ពោលថា) ពួកទេវតាក្តី ពួកបិតា (ព្រហ្ម) ទាំងអស់ក្តី ពួកទីឃជាតិក្តី ពួកសត្វទាំងអស់ក្តី ដែលបុគ្គលណាកោតក្រែងដោយមេត្តាចិត្ត អស់កាលជានិច្ច បណ្ឌិតទាំងឡាយ ពោលនូវមេត្តាចិត្តក្នុងពួកសត្វនោះ ថាជាសួស្តីរបស់បុគ្គលនោះដោយពិត។

[៧៧៣] បុគ្គលណា ប្រព្រឹត្តឱនលំទោនចំពោះសត្វលោកទាំងអស់ ជាអ្នកអត់ទ្រាំនូវពាក្យនៃស្រីប្រុស និងក្មេងទាំងឡាយដែលពោលអាក្រក់ ជាអ្នកពោលពាក្យមិនជាទីខ្ទើម បណ្ឌិតទាំងឡាយ ពោលនូវការអត់ទ្រាំនោះ ថាជាសួស្តី (របស់បុគ្គលនោះ)។

[៧៧៤] បុគ្គលណា មានប្រាជ្ញាភ្លឺថ្លា មានបញ្ញាវាងវៃក្នុងកាលដែលកើតឡើងនៃហេតុ មិនមើលងាយនូវសម្លាញ់ និងមិត្ត ដោយសិល្បវិជ្ជា ដោយកុលសម្បត្តិ ដោយទ្រព្យ ដោយជាតិ បណ្ឌិតទាំងឡាយ បានពោលនូវការមិនមើលងាយក្នុងពួកសម្លាញ់នោះ ថាជាសួស្តី (របស់បុគ្គលនោះ)។

[៧៧៥] ពួកជនណា ជាអ្នកមិនពោលបង្ខូស ជាសប្បុរស ជាមិត្តស្និទ្ធស្នាល ជាអ្នកមិនទ្រុស្តមិត្ត ចែករលែកដោយទ្រព្យ បណ្ឌិតទាំងឡាយ បានពោលនូវការស្និទ្ធស្នាល ក្នុងមិត្តទាំងឡាយនោះ ថាជាសួស្តី (របស់ជននោះ)។

[៧៧៦] បុគ្គលណា មានភរិយាមានវ័យប្រហែលគ្នា មានសេចក្តីព្រមព្រៀងគ្នា ជាអ្នកប្រព្រឹត្តតាម ប្រាថ្នាធម៌ ជាស្រីមានកូន មានសីលធម៌ ដោយគួរដល់ត្រកូល មានវត្តដល់ប្តី ពួកបណ្ឌិត បានពោលនូវចរិយានៃភរិយាទាំងឡាយនោះ ថាជាសួស្តី (របស់ស្វាមីនោះ)។

[៧៧៧] ព្រះរាជាជាម្ចាស់របស់សត្វ មានយស តែងជ្រាបនូវសេចក្តីស្អាត និងសេចក្តីព្យាយាមរបស់រាជសេវកាមាត្យណាថា (សេវកាមាត្យនោះ) មិនបែកចិត្ត (អំពីអញ) ជាអ្នកមានចិត្តល្អចំពោះអញ បណ្ឌិតទាំងឡាយ បានពោលនូវសេចក្តីល្អ ក្នុងព្រះរាជាទាំងឡាយនោះ ថាជាសួស្តី (របស់រាជសេវកាមាត្យ)។

[៧៧៨] បុគ្គលណា មានសទ្ធា មានចិត្តជ្រះថ្លា ត្រេកអរ ឲ្យបាយ ទឹក ផ្កាកម្រង គ្រឿងក្រអូប និងគ្រឿងលាប បណ្ឌិតទាំងឡាយ បានពោលនូវសេចក្តីល្អនោះ ថាជាសួស្តី ក្នុងឋានសួគ៌ទាំងឡាយ (របស់បុគ្គលនោះ)។

[៧៧៩] ពួកបុគ្គលណា ដឹងច្បាស់ដោយញាណ រមែងញុំាងបុគ្គលណា ឲ្យស្អាត ដោយអរិយធម៌ ជាអ្នកត្រេកអរក្នុងការប្រព្រឹត្តិល្អ ជាអ្នករៀនសូត្រច្រើន ជាអ្នកស្វែងរកគុណ ជាអ្នកមានសីល បណ្ឌិតទាំងឡាយ បានពោលនូវសេចក្តីល្អ ក្នុងកណ្តាលនៃព្រះអរហន្តនោះ ថាជាសួស្តី (របស់បុគ្គលនោះ)។

[៧៨០] សួស្តីមង្គលទាំងឡាយនេះឯង វិញ្ញូជនតែងសរសើរ មានសេចក្តីសុខជាកម្រៃក្នុងលោក នរជនអ្នកប្រកបដោយប្រាជ្ញា ក្នុងលោកនេះ គប្បីសេពគប់នូវសួស្តី មង្គលទាំងឡាយនោះ វត្ថុណាមួយក្នុងមង្គល (មានទិដ្ឋមង្គលជាដើម) មិនឈ្មោះថាជាសច្ចៈទេ។

ចប់ មហាមង្គលជាតក ទី១៥។

## យតបណ្ឌិតជាតក ទី១៦

CS sut.kn.jat.454 | ភាគទី ៥៩

(៤៥៤. ឃដបណ្ឌិតជាតកំ (១៦ ))

[៧៨១] (អាមាត្យឈ្មោះរោហិនេយ្យ ពោលថា) បពិត្រព្រះអង្គជាកណ្ហាយនគោត្រ សូមព្រះអង្គក្រោកឡើង ព្រះអង្គនៅផ្ទំធ្វើអ្វី ប្រយោជន៍អ្វីរបស់ព្រះអង្គដោយការផ្ទំ ក្សត្រិយ៍ណា ជាព្រះកនិដ្ឋភាតារបស់ខ្លួនព្រះអង្គ (ស្មើដោយ) ហឫទ័យ និងព្រះនេត្រខាងស្តាំ ខ្យល់ចាប់រួមរឹតនូវហឫទ័យរបស់ក្សត្រិយ៍ ជាព្រះកនិដ្ឋភាតានោះ បពិត្រព្រះកេសវៈ ឃតបណ្ឌិត រមែងអំពាវនាវថា (អ្នកទាំងឡាយ ចូរឲ្យទន្សាយដល់យើង)។

[៧៨២] (ព្រះសាស្តា ត្រាស់ថា) ព្រះបាទកេសវៈ ទ្រង់ព្រះសណ្តាប់ពាក្យរបស់អាមាត្យឈ្មោះរោហិនេយ្យនោះហើយ ក៏ទ្រង់ក្រោកឡើង រលះរលាំង ត្រូវសេចក្តីសោកក្នុងព្រះកនិដ្ឋភាតាគ្របសង្កត់។

[៧៨៣] (ព្រះបាទកេសវៈ សួរថា) អ្នកហេតុអ្វី ក៏មានសភាពហាក់ដូចជាឆ្កួត (ត្រាច់ទៅ) កាន់នគរទ្វារវតីទាំងមូលនេះ និយាយរវើរវាយថា ទន្សាយ ៗ អ្នកណាលួចយកទន្សាយរបស់អ្នកទៅឬ។

[៧៨៤] អ្នកប្រាថ្នានូវទន្សាយមាស កែវមណី (លោហៈ) ឬប្រាក់ ឬក៏ទន្សាយធ្វើដោយស័ង្ខ ដោយសិលា ដោយកែវប្រពាឡ យើងនឹងឲ្យគេធ្វើទន្សាយនោះដល់អ្នក (បើអ្នកមិនពេញចិត្តទន្សាយនោះទេ) ទន្សាយឯទៀតក្នុងព្រៃ រកស៊ីក្នុងព្រៃ យើងនឹងឲ្យគេនាំទន្សាយទាំងនោះមកឲ្យអ្នក អ្នកត្រូវការទន្សាយបែបណា (ចូរប្រាប់យើងក្នុងកាលឥឡូវនេះ)។

[៧៨៥] (ឃតបណ្ឌិត ឆ្លើយថា) ពួកទន្សាយណា ដែលអាស្រ័យនៅលើផែនដី ខ្ញុំមិនចង់បានទន្សាយនោះទេ ខ្ញុំចង់បានទន្សាយអំពីដួងព្រះចន្ទ បពិត្រព្រះកេសវៈ សូមព្រះអង្គញុំាងទន្សាយនោះឲ្យចុះមកដើម្បីខ្ញុំ។

[៧៨៦] (ព្រះបាទកេសវៈ ....) អ្នកណាប្រាថ្នានូវរបស់ដែលមិនគួរប្រាថ្នា (ដូចជា) អ្នកប្រាថ្នានូវទន្សាយអំពីដួងព្រះចន្ទ ម្នាលអ្នកជាញាតិ អ្នកនោះ នឹងលះបង់ជីវិត ជាទីស្រឡាញ់ដោយពិត (ក៏មិនបានទន្សាយនោះដែរ)។

[៧៨៧] (ឃតបណ្ឌិត....) បពិត្រព្រះកណ្ហាយនគោត្រ បើព្រះអង្គទ្រង់ជ្រាបយ៉ាងនោះ ព្រះអង្គទ្រង់ប្រៀនប្រដៅបុគ្គលដទៃ ហេតុអ្វីព្រះអង្គសោកស្តាយនឹងបុត្រដែលទទួលមរណភាពក្នុងកាលមុន រហូតមកក្នុងថ្ងៃនេះ។

[៧៨៨] របស់ណា ដែលមនុស្ស ឬអមនុស្ស មិនគប្បីបានវិញ ដោយប្រាថ្នាថា (ព្រះអង្គប្រាថ្នានូវរបស់នោះថា) បុត្ររបស់អញកើតហើយ កុំស្លាប់ឡើយ ដូច្នេះ ព្រះអង្គនឹងគប្បីបានរបស់ដែលមិនគប្បីបានអំពីទីណាកើត។ បពិត្រព្រះកណ្ហាយនគោត្រ ព្រះអង្គសោកស្តាយនឹងបុត្តណា ដែលទៅកាន់បរលោកហើយ ព្រះអង្គអាចនាំបុត្តនោះមកវិញដោយមន្ត ដោយថ្នាំ ដែលធ្វើដោយឫសឈើ ដោយឱសថ ឬក៏ដោយទ្រព្យមិនបានឡើយ។

[៧៨៩] (ព្រះបាទកេសវៈ សរសើរថា) ពួកបុរសជាបណ្ឌិតប្រាកដដូច្នោះ ជាអាមាត្យរបស់ព្រះរាជាណា ដូចយ៉ាងអ្នក ជាបណ្ឌិតបុរសឈ្មោះឃតៈ បានពន្យល់ (ខ្ញុំ) ក្នុងថ្ងៃនេះ (សោករបស់ព្រះរាជានោះ នឹងមានមកពីណា)។ អ្នកបានស្រោចស្រពនូវយើងដែលភ្លើង គឺសេចក្តីសោកកំពុងឆេះ ឲ្យស្ងប់រម្ងាប់ ញុំាងសេចក្តីក្រវល់ក្រវាយទាំងអស់ ឲ្យរលត់ ដូចបុគ្គលយកទឹកស្រោចនូវភ្លើងកំពុងឆេះឆ្នាំងខ្លាញ់។ សរ គឺសេចក្តីសោកណា ដែលអាស្រ័យក្នុងហឫទ័យ សរ គឺសេចក្តីសោកនោះ យើងបានដកចេញហើយ អ្នកឈ្មោះថា បានបន្ទោបង់នូវសេចក្តីសោកព្រោះបុត្ររបស់យើង ដែលត្រូវសេចក្តីសោកគ្របសង្កត់។ ម្នាលមាណព យើងនោះ ជាអ្នកមានសរ គឺសេចក្តីសោកដកចេញហើយ ជាអ្នកប្រាសចាកសេចក្តីសោក ម្នាលមាណព យើងលែងសោកស្តាយ លែងយំទួញ ព្រោះបានស្តាប់នូវពាក្យរបស់អ្នក។

[៧៩០] (ព្រះសម្ពុទ្ធត្រាស់ថា) ពួកជនណា ប្រកបដោយប្រាជ្ញា ជាអ្នកអនុគ្រោះ រមែងធ្វើយ៉ាងនេះ ទើបញុំាងជនឲ្យឃ្លាតចាកសេចក្តីសោក ដូចឃតបណ្ឌិត ញុំាងព្រះជេដ្ឋា (ឲ្យរួចចាកសេចក្តីសោក)។

ចប់ ឃតបណ្ឌិតជាតក ទី១៦។

ឧទ្ទាននៃជាតកនោះ គឺ

និយាយអំពីកំពែងនៃនគរដ៏មាំមួន ១ កណ្ហតាបស ១ ស្តេចធនញ្ជ័យ ១ សង្ខព្រាហ្មណ៍ ១ ព្រះរាជាពារាណសី ១ តាបសជ្រះថ្លាចំពោះព្រហ្មចរិយធម៌អស់ ៧ ថ្ងៃ ១ សាខកុមារ ១ តក្កលជាតក ១ មហាធម្មបាលជាតក ១ កុក្កុដជាតក ១ មដ្ឋកុណ្ឌលិជាតក ១ អ្នកឲ្យនូវភោជន ១ ចក្កវាកជាតក ១ ភូរិបញ្ហាជាតក ១ ប្រកបដោយសេចក្តីសួស្តី ១ ឃតបណ្ឌិតជាតក ១។

ចប់ ទសកនិបាត។

# ឯកាទសកនិបាតជាតក

(១១. ឯកាទសកនិបាតោ)

## មាតុបោសកជាតក ទី១



(៤៥៥. មាតុបោសកជាតកំ (១ ))

[៧៩១] (ដំរីជាមាតារបស់ព្រះពោធិសត្វ ពោលថា) ដើមពោនស្វាផង ដើមខ្លែងគង់ផង ដើមទទឹម និងស្មៅធំ ឈ្មោះករវរៈផង ក្រអៅឈូក និងស្រងែផង ដុះទ្រុបទ្រុលហើយ ទាំងដើមកណិការជិតជើងភ្នំ ក៏ចេញផ្កាដែរ ព្រោះតែដំរីនោះមិននៅ។

[៧៩២] ក្នុងស្រុក ឬក្នុងក្រុងណាមួយ ព្រះរាជា ឬព្រះរាជកុមារណាមួយ មានគ្រឿងអាភរណៈ ជាវិការនៃមាស រមែងចិញ្ចឹមស្តេចដំរី ដោយដុំនៃភោជន ដ្បិតដំរីដែលព្រះរាជា ឬព្រះរាជកុមារ (គង់ហើយ) មិនតក់ស្លុត (ក្នុងសង្គ្រាម) អាចនឹងទំលុះទំលាយនូវក្រោះ (នៃពួកបច្ចាមិត្របាន)។

[៧៩៣] (ព្រះរាជា...) ម្នាលដំរី អ្នកចូរទទួលពំនូតភោជនចុះ ម្នាលដំរី អ្នកកុំស្គមឡើយ ម្នាលដំរី រាជកិច្ចទាំងឡាយមានច្រើន អ្នកនឹងធ្វើនូវរាជកិច្ចទាំងនោះ។

[៧៩៤] (ព្រះពោធិសត្វ...) មេដំរីនោះ ជាសត្វកំព្រា ខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងដង្គត់ឈើ ហើយបែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅ។

[៧៩៥] (ព្រះរាជា....) ម្នាលដំរីដ៏ប្រសើរ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងដង្គត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ តើត្រូវជាអ្វីនឹងអ្នកឯង។

[៧៩៦] (ព្រះពោធិសត្វ...) បពិត្រមហារាជ មេដំរីខ្វាក់ភ្នែក មិនមានគេដឹកនាំ ទង្គិចជើងនឹងដង្គត់ឈើ បែរមុខទៅរកភ្នំចណ្ឌោរណៈ ដួលនៅនោះ ត្រូវជាមាតារបស់ទូលព្រះបង្គំជាខ្ញុំ។

[៧៩៧] (ព្រះរាជា....) អ្នកទាំងឡាយចូរលែងនូវដំរីប្រសើរនុ៎ះ ជាសត្វចិញ្ចឹមនូវមាតា ចូរឲ្យដំរីបានជួបជុំនឹងមាតា ព្រមទាំងញាតិទាំងពួងចុះ។

[៧៩៨] (អភិសម្ពុទ្ធគាថា) ដំរីគ្រាន់តែរួចចាកចំណងដែលព្រះរាជាកាសី បានបញ្ជូនទៅ សម្រាកខ្លួនតែមួយរំពេច ក៏ដើរសំដៅទៅរកភ្នំ ដំរីនោះ ចេញទៅអំពីភ្នំនោះ ដើរទៅកាន់ព្រៃ ជាទីពួនសម្ងំដ៏ត្រជាក់ដែលដំរីធ្លាប់សេព (នៅ) ហើយដងទឹក ដោយប្រមោយ យកមកស្រោចស្រពមាតា។

[៧៩៩] (មាតាពោធិសត្វ...) ភ្លៀងអ្វីហ្ន៎ងផ្តេសផ្តាស បង្អុរចុះពុំជួកាលសោះ កូនបង្កើតរបស់អញដែលជាអ្នកបម្រើអញ ទៅបាត់ហើយតើ។

[៨០០] (ពោធិសត្វ....) បពិត្រអ្នកមេ សូមអ្នកក្រោកឡើង សម្រាន្តអ្វី ខ្ញុំជាកូនបង្កើតរបស់លោកដែលព្រះរាជាកាសីទ្រង់ប្រកបដោយប្រាជ្ញា មានយស បានលែងមកវិញហើយ។

[៨០១] (មាតាពោធិសត្វ...) ព្រះរាជាណា បានលែងកូនរបស់ខ្ញុំ ជាអ្នកកោតក្រែងចំពោះបុគ្គលចាស់សព្វ ៗ កាល សូមព្រះរាជានោះញុំាងដែនរបស់ពួកអ្នកកាសីឲ្យចំរើន គង់ព្រះជន្មនៅអស់កាលយូរអង្វែងចុះ។

ចប់ មាតុបោសកជាតក ទី១។

## ជុណ្ហជាតក ទី២



(៤៥៦. ជុណ្ហជាតកំ (២ ))

[៨០២] (ព្រាហ្មណ៍ បានពោលថា) បពិត្រព្រះអង្គធំជាងជន សូមព្រះអង្គស្តាប់ពាក្យ របស់ខ្ញុំព្រះអង្គ ខ្ញុំព្រះអង្គ មកក្នុងទីនេះ ដោយសេចក្តីត្រូវការចំពោះព្រះអង្គ ទ្រង់ព្រះនាមជុណ្ហៈ បពិត្រព្រះអង្គប្រសើរបំផុតជាងពួកសត្វជើងពីរ បណ្ឌិតទាំងឡាយ ពោលថា កាលព្រាហ្មណ៍ជាអ្នកដំណើរ កំពុងឈរ (សូម) បុគ្គលមិនត្រូវដើរ (ហួស) ទេ។

[៨០៣] (ព្រះរាជា ទ្រង់ត្រាស់ថា) ម្នាលព្រាហ្មណ៍ យើងឮ យើងឈប់នៅ អ្នកចូរនិយាយចុះ អ្នកមកក្នុងទីនេះ ដោយប្រយោជន៍ណា ឬប្រាថ្នានូវប្រយោជន៍អ្វី ចំពោះយើង ទើបមកក្នុងទីនេះ ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់នូវប្រយោជន៍នោះចុះ។

[៨០៤] (ព្រាហ្មណ៍....) សូមព្រះអង្គប្រទានស្រុកសួយ ៥ ទាសី ១០០ គោ ៧០០ និងមាសឆ្អោរ ជាង ១០០០ ដល់ទូលព្រះបង្គំ សូមប្រទានភរិយា ២ នាក់ មានរូបសណ្ឋានដូចគ្នា ដល់ទូលព្រះបង្គំផង។

[៨០៥] (ព្រះរាជា...) ម្នាលព្រាហ្មណ៍ ក្រែងអ្នកមានតបៈដ៏ខ្លាំងដែរឬ ម្នាលព្រាហ្មណ៍ ក្រែងអ្នកមានមន្តទាំងឡាយ មានសភាពដ៏វិចិត្រដែរឬ ក្រែងអ្នកមានពួកយក្សខ្លះ ជាអ្នកស្តាប់ដែរឬ ម្យ៉ាងទៀត អ្នកដឹងច្បាស់នូវប្រយោជន៍ដែលអ្នកធ្វើហើយ ចំពោះយើងឬ។

[៨០៦] (ព្រាហ្មណ៍....) ទូលព្រះបង្គំជាខ្ញុំ មិនមានតបៈ មិនមានមន្តទេ ទូលព្រះបង្គំជាខ្ញុំ មិនមានពួកយក្សខ្លះជាអ្នកស្តាប់ទេ ទូលព្រះបង្គំជាខ្ញុំ មិនដឹងច្បាស់នូវប្រយោជន៍ ដែលទូលព្រះបង្គំជាខ្ញុំធ្វើហើយចំពោះព្រះអង្គទេ ក្នុងកាលមុន (ទូលព្រះបង្គំជាខ្ញុំ និងព្រះអង្គ) គ្រាន់តែបានជួបគ្នាប៉ុណ្ណោះ។

[៨០៧] (ព្រះរាជា...) តាមខ្ញុំដឹង នេះជាការឃើញដំបូង យើងមិនស្គាល់អ្នកមុន អំពីកាលនេះទេ យើងសួរហើយ អ្នកចូរប្រាប់សេចក្តីនុ៎ះ

យើងបានជួបគ្នា ក្នុងកាលណា ឬក្នុងទីណា។

[៨០៨] (ព្រាហ្មណ៍....) បពិត្រព្រះសម្មតិទេព ពួកយើងនៅក្នុងក្រុងតក្កសិលា ជាបុរីគួរឲ្យត្រេកអររបស់ស្តេចគន្ធារៈ ក្នុងទីនោះ ពួកយើងខ្ញុំ បានទង្គិចស្មានឹងស្មា ក្នុងទីងងឹត ក្នុងរាត្រីមានអ័ព្ទដ៏ក្រាស់ បពិត្រព្រះអង្គជាធំជាងជន យើងខ្ញុំទាំងពីរនាក់នោះ ឈរក្នុងទីនោះ បានបញ្ចប់ពាក្យគួរឲ្យរឭក ក្នុងទីនោះ នោះឯងឈ្មោះថា ការជួបគ្នានៃយើងខ្ញុំ (ឯការចូបគ្នា) ខាងក្រោយ និងខាងមុខអំពីកាលនោះ មិនមានឡើយ។

[៨០៩] (ព្រះរាជា...) ម្នាលព្រាហ្មណ៍ ការចូបនឹងសប្បុរសក្នុងពួកមនុស្ស ក្នុងកាលណា ពួកបណ្ឌិតមិនដែលបំបាត់ការចូប និងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយ ក្នុងកាលមុនទេ។

[៨១០] ចំណែកខាងពួកពាល តែងបំបាត់ការចូប និងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុន គុណសូម្បីច្រើន ដែលគេធ្វើហើយ ចំពោះពួកពាល រមែងបាត់ទៅ ពិតដូច្នោះមែន ពួកពាលមានសភាពជាមនុស្សអកតញ្ញូ។

[៨១១] ចំណែកខាងពួកបណ្ឌិត មិនបំបាត់ការចូប និងសេចក្តីស្និទ្ធស្នាល ឬគុណដែលគេធ្វើហើយក្នុងកាលមុនទេ គុណសូម្បីតិច ដែលគេធ្វើហើយចំពោះពួកបណ្ឌិត រមែងមិនបាត់ ពិតដូច្នោះមែន ពួកបណ្ឌិតមានសភាពជាមនុស្សកតញ្ញូល្អ យើងនឹងឲ្យស្រុកសួយ ៥ ទាសី ១០០ នាក់ គោ ៧០០ មាសឆ្អោរជាង ១០០០ ដល់អ្នក ម្យ៉ាងទៀត យើងនឹងឲ្យភរិយាពីរ ដែលមានរូបសណ្ឋានដូចគ្នាដល់អ្នក។

[៨១២] (ព្រាហ្មណ៍....) បពិត្រព្រះរាជា ការចូបជុំសប្បុរស តែងមានយ៉ាងនេះ បពិត្រព្រះអង្គជាម្ចាស់នៃដែនកាសី ដូចយ៉ាង (ព្រះចន្ទ ឋិតនៅក្នុងកណ្តាល) នៃពួកផ្កាយ រមែងពេញឡើង យ៉ាងណាមិញ ទូលព្រះបង្គំជាខ្ញុំ (ពេញព្រៀប ដោយស្រុកសួយជាដើម ដែលព្រះអង្គប្រទានក្នុងថ្ងៃនេះ ក៏យ៉ាងនោះដែរ) ព្រោះការចូបនឹងព្រះអង្គ ខ្ញុំបានហើយ ក្នុងថ្ងៃនេះ។

ចប់ ជុណ្ហជាតក ទី២។

## ធម្មទេវបុត្តជាតក ទី៣

CS sut.kn.jat.457 | ភាគទី ៥៩

**(៤៥៧. ធម្មទេវបុត្តជាតកំ (៣))**

[៨១៣] (ធម្មទេវបុត្រ ពោលថា) ម្នាលអធម្មទេវបុត្រ ខ្ញុំឈ្មោះធម្មៈ ជាអ្នកធ្វើយស ធ្វើបុណ្យ ខ្ញុំ ដែលពួកសមណព្រាហ្មណ៍សរសើរជានិច្ច ដែលទេវតា និងមនុស្សបូជាហើយ គួរបានផ្លូវ អ្នកចូរឲ្យផ្លូវ។

[៨១៤] (អធម្មទេវបុត្រ ពោលថា) ម្នាលធម្មៈ ខ្ញុំជិះរថឈ្មោះអធម្មយានដ៏មាំ ជាអ្នកមិនតក់ស្លុត មានកម្លាំង ខ្ញុំនោះនឹងឲ្យផ្លូវដល់អ្នក ដែលមិនធ្លាប់ឲ្យហើយក្នុងថ្ងៃនេះ ព្រោះហេតុអ្វី។

[៨១៥] (ធម្មទេវបុត្រ...) ធម៌បានកើតមុន អធម៌កើតក្រោយ ក្នុងលោក ខ្ញុំជាច្បងផង ប្រសើរជាងផង មានតាំងពីព្រេងនាយផង ម្នាលប្អូន អ្នកចូរចៀសចេញអំពីផ្លូវរបស់បង។

[៨១៦] (អធម្មទេវបុត្រ...) ខ្ញុំមិនត្រូវឲ្យផ្លូវដល់អ្នកដោយសេចក្តីអង្វរ មិនត្រូវឲ្យដោយពាក្យសមគួរ មិនត្រូវឲ្យព្រោះខ្ញុំគួរបានផ្លូវ យើងទាំងពីរនាក់ ចូរច្បាំងគ្នាក្នុងថ្ងៃនេះ អ្នកណាឈ្នះក្នុងចម្បាំង ផ្លូវជារបស់អ្នកនោះ។

[៨១៧] (ធម្មទេវបុត្រ...) ម្នាលអធម្មៈ ខ្ញុំឈ្មោះធម្មៈ ជាអ្នកល្បីល្បាញសព្វទិស មានកំឡាំងច្រើន មានយសរាប់មិនអស់ មិនមានអ្នកណាផ្ទឹមបាន មានសភាពជាអ្នកប្រកបដោយគុណគ្រប់យ៉ាង អ្នកនឹងឈ្នះ (ខ្ញុំ) ដូចម្តេចបាន។

[៨១៨] (អធម្មទេវបុត្រ...) គេតែងដំមាសដោយដែក គេមិនដែលដំដែកដោយមាសទេ បើអធម្មៈ ដំធម្មៈក្នុងថ្ងៃនេះ ដូចជាដែកដំមាស បុគ្គលគួរមើលដែរ។

[៨១៩] (ធម្មទេវបុត្រ...) ម្នាលអធម្មៈ បើអ្នកមានកំឡាំងនឹងច្បាំង បុគ្គលចាស់ និងបុគ្គលជាគ្រូ មិនមានដល់អ្នក ខ្ញុំនឹងឲ្យនូវផ្លូវដល់អ្នក ដោយពាក្យជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ផង ខ្ញុំនឹងអត់ទ្រាំនូវពាក្យទ្រគោះបោះបោករបស់អ្នកផង។

[៨២០] (ព្រះភគវា បានត្រាស់ថា) អធម្មទេវបុត្រ ឮពាក្យនេះហើយ មានក្បាលសំយុងចុះ មានជើងឡើងលើ ក៏ធ្លាក់ចុះ ពោលពាក្យថា អញត្រូវការដោយចម្បាំង តែមិនបាននូវការច្បាំងឡើយ អធម្មទេវបុត្រ ក៏ស្លាប់ដោយហេតុត្រឹមប៉ុណ្ណោះឯង។

[៨២១] ធម្មទេវបុត្រ មានខន្តិធម៌ ជាកំឡាំង មានចិត្ត មានកំឡាំងក្រៃពេក មានព្យាយាមដ៏ទៀតទាត់ បានផ្ចាញ់ បានសម្លាប់នូវអធម្មទេវបុត្រដែលមានចម្បាំងជាកំឡាំង ទំលាក់ទៅលើផែនដី ហើយឡើងកាន់រថ (របស់ខ្លួន) បរទៅតាមផ្លូវដដែល។

[៨២២] បុគ្គលណា មិនបានធ្វើសក្ការៈដល់មាតាបិតា និងសមណព្រាហ្មណ៍ ក្នុងផ្ទះរបស់ខ្លួន បុគ្គលនោះ លុះដាក់ចុះនូវរាងកាយ គឺសរីរៈ បែកធ្លាយរាងកាយក្នុងលោកនេះ រមែងទៅកាន់នរក ដូចជាអធម្មទេវបុត្រដែលសំយុងក្បាលធ្លាក់ចុះ។

[៨២៣] បុគ្គលណា បានធ្វើសក្ការៈដល់មាតាបិតា និងសមណព្រាហ្មណ៍ ក្នុងផ្ទះរបស់ខ្លួន បុគ្គលនោះ លុះដាក់ចុះនូវរាងកាយ គឺសរីរៈ បែកធ្លាយរាងកាយក្នុងលោកនេះ រមែងទៅកាន់សុគតិ ដូចជាធម្មទេវបុត្រ ឡើងកាន់រថរបស់ខ្លួន ដូច្នោះ។

ចប់ ធម្មទេវបុត្តជាតក ទី៣។

## ឧទយជាតក ទី៤

CS sut.kn.jat.458 | ភាគទី ៥៩

**(៤៥៨. ឧទយជាតកំ (៤))**

[៨២៤] (សក្កទេវរាជពោធិសត្វ ពោលថា) ម្នាលនាងមានចក្ខុប្រាកដស្មើដោយភ្នែកនៃកិន្នរ នាងស្លៀកសំពត់ដ៏ស្អាត មានភ្លៅរៀបស្រួល

បួស មានអវយៈតិះដៀលមិនបាន ឡើងកាន់ប្រាសាទ អង្គុយតែម្នាក់ឯង បងសូមអង្វរនាង សូមយើងទាំងពីរនាក់នៅ (ជាមួយគ្នា) អស់មួយយប់នេះ។

[៨២៥] (ព្រះរាជធីតា ពោលថា) បុរីនេះ មានគូខាន់ ជាសង្កាត់ ៗ មានប៉មនិងខ្លោងទ្វារ យ៉ាងមាំ (មានទាហាន ១០០០០ នាក់) កាន់ព្រះខាន់គ្រប់ដៃ រក្សាហើយ ចូលបានដោយក្រ។ មិនមានប្រុសជំទង់ ឬប្រុសកម្លោះមក (ក្នុងទីនេះ ទាំងថ្មើរណោះទេ) បើយ៉ាងនេះ តើហេតុអ្វី បានជាអ្នកចង់មកជួបនឹងខ្ញុំ (ទាំងថ្មើរណោះ)។

[៨២៦] (សក្កទេវរាជ....) ម្នាលនាងកល្យាណី យើងជាយក្ខ មកក្នុងសំណាក់នាង ម្នាលនាងដ៏ចំរើន នាងចូរត្រេកអរនឹងយើង យើងនឹងឲ្យភាជន៍មាសដ៏ពេញដោយមាស ដល់នាង។

[៨២៧] (ព្រះរាជធីតា...) ម្នាលទេវបុត្រ មានអានុភាពច្រើន ខ្ញុំមិនប្រាថ្នាបុគ្គលដទៃ ទោះបីជាទេវតា យក្ស ឬមនុស្ស លើសជាងព្រះបាទឧទយៈទេ អ្នកចូរទៅចុះ លុះអ្នកទៅហើយ កុំត្រឡប់មកវិញឡើយ។

[៨២៨] (សក្កទេវរាជ....) សេចក្តីត្រេកត្រអាលណា ដ៏ឧត្តមរបស់ពួកសត្វអ្នកបរិភោគកាម ពួកសត្វប្រព្រឹត្តមិនស្មើ ព្រោះហេតុនៃសេចក្តីត្រេកត្រអាលណា នាងកុំផ្វាញ់សេចក្តីត្រេកត្រអាលនោះ ក្នុងធម្មជាតិស្អាតរបស់នាង យើងនឹងឲ្យភាជន៍ប្រាក់ ដ៏ពេញដោយមាស ដល់នាង។

[៨២៩] (ព្រះរាជធីតា...) បុរសកាលលួងលោមស្រ្តីដោយទ្រព្យ ធ្វើនូវសេចក្តីពេញចិត្តក្នុងស្រ្តីណា ក៏លើកតម្កើងស្រ្តីនោះ ទេវធម៌របស់អ្នកខុសនឹងគេ (ព្រោះថា) អ្នកមកដោយវត្ថុរឹតតែតិចដោយពិតប្រាកដ។

[៨៣០] (សក្កទេវរាជ....) ម្នាលនាងមានខ្លួនល្អ អាយុ និងវណ្ណៈរបស់ពួកមនុស្ស ក្នុងមនុស្សលោក រមែងសាបសូន្យទៅ ព្រោះហេតុនោះឯង បានជាទ្រព្យរបស់នាងក៏សាបសូន្យដែរ នាងរឹតតែចាស់ទៅក្នុងថ្ងៃនេះ។ ម្នាលរាជបុត្រីមានយស កាលយើងរមិលមើលយ៉ាងនេះ ពណ៌សម្បុររបស់នាងក៏សាបសូន្យទៅ ក្នុងកាលកន្លងទៅនៃថ្ងៃ និងយប់ទាំងឡាយ ម្នាលរាជបុត្រី មានប្រាជ្ញាល្អ នាងគប្បីប្រព្រឹត្តព្រហ្មចារ្យដោយវ័យនេះ នាងមុខជានឹងមានពណ៌សម្បុរដ៏ក្រៃលែង។

[៨៣១] (ព្រះរាជធីតា...) ទេវតាទាំងឡាយ មិនចាស់ដូចពួកមនុស្សទេ ការជ្រួញជ្រីវក្នុងខ្លួនរបស់ទេវតាទាំងនោះ មិនមានទេឬ បពិត្រយក្ខ ខ្ញុំសូមសួរលោក ដែលមានអានុភាពច្រើន រាងកាយ គឺសរីរៈរបស់ទេវតាទាំងឡាយ (មិនចាស់) តើដោយហេតុអ្វី។

[៨៣២] (សក្កទេវរាជ....) ទេវតាទាំងឡាយ មិនចាស់ ដូចពួកមនុស្សទេ ការជ្រួញជ្រីវក្នុងខ្លួនរបស់ទេវតាទាំងនោះ មិនមានឡើយ ពណ៌សម្បុរជាទិព្វ និងភោគៈដ៏ច្រើន របស់ទេវតាទាំងឡាយនោះ រឹងរឹតតែចំរើនឡើងរាល់ ៗ ថ្ងៃ។

[៨៣៣] (ព្រះរាជធីតា...) ប្រជុំជនដ៏ច្រើនក្នុងលោកនេះ ខ្លាចអ្វី (ទើបមិនទៅកាន់ទេវលោក) ម្យ៉ាងទៀត ផ្លូវ (ទៅទេវលោក) បណ្ឌិតសំដែងដោយអណ្តាង គឺកំពង់ច្រើន (ផ្លូវណា ជាផ្លូវទៅទេវលោក) បពិត្រយក្ខ មានអានុភាពច្រើន ខ្ញុំសូមសួរលោក បុគ្គល (កាលទៅ) កាន់បរលោក តើឋិតនៅក្នុងផ្លូវណា ទើបមិនខ្លាច។

[៨៣៤] (សក្កទេវរាជ....) បុគ្គលបានតាំងវាចា និងចិត្ត ដោយត្រឹមត្រូវ មិនធ្វើបាបទាំងឡាយដោយកាយ នៅគ្រប់គ្រងផ្ទះដែលមានបាយ និងទឹកដ៏ច្រើន ជាអ្នកមានសទ្ធា មានចិត្តទន់ បានចែករំលែកនូវទាន ជាអ្នកដឹងនូវពាក្យស្លូត ជាអ្នកសង្គ្រោះគេ មានវាចាផ្អែម មានវាចាល្អិតល្អ បានឋិតនៅក្នុងគំនរនៃគុណនេះហើយ (កាលនឹងទៅ) កាន់បរលោក មិនខ្លាចឡើយ។

[៨៣៥] (ព្រះរាជធីតា....) បពិត្រទេវបុត្រ លោកប្រៀនប្រដៅខ្ញុំ ដូចជាមាតា ដូចជាបិតា បពិត្រលោកមានសម្បុរដ៏លើសលុប ខ្ញុំសូមសួរលោកមានសរីរៈសមរម្យល្អ លោកជាអ្វី។

[៨៣៦] (ព្រះពោធិសត្វ...) ម្នាលនាងកល្យាណី យើងឈ្មោះឧទយៈ បានមកក្នុងទីនេះ ដើម្បីដោះពាក្យប្តេជ្ញា យើងប្រាប់នាងហើយទៅ យើងរួចចាកពាក្យប្តេជ្ញារបស់នាងហើយ។

[៨៣៧] (ព្រះរាជធីតា....) បពិត្រព្រះរាជបុត្រ ប្រសិនបើព្រះអង្គ ព្រះនាមឧទយៈ បានមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ពាក្យប្តេជ្ញា សូមព្រះអង្គប្រៀនប្រដៅខ្ញុំ ឲ្យបានចួបគ្នាទៀត។

[៨៣៨] (ព្រះមហាសត្វ....) វ័យកន្លងទៅឆាប់ ខណៈចិត្តក៏កន្លងទៅឆាប់ដូចគ្នា ការតាំងនៅ (នៃសង្ខារទាំងឡាយ) មិនមាន ពួកសត្វតែងច្យុតទៅដោយពិត សរីរៈមិនទៀង តែងទ្រុឌទ្រោមទៅ ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ។ ផែនដីទាំងមូលរបស់ស្តេចតែមួយព្រះអង្គ ដ៏ពេញដោយទ្រព្យ ជាផែនដីដែលអ្នកដទៃទ្រទ្រង់មិនបាន ឯបុគ្គលដែលមិនទាន់ប្រាសចាករាគៈ រមែងលះបង់នូវទ្រព្យនោះ ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ។ មាតា បិតា បងប្អូនប្រុស បងប្អូនស្ត្រី និងប្រពន្ធក្តី ប្តីក្តី ព្រមទាំងទ្រព្យ ឯជនទាំងនោះ រមែងលះបង់នូវគ្នានឹងគ្នា ម្នាលនាងឧទយភទ្ទា នាងកុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ។

ម្នាលនាងឧទយភទ្ទា នាងដឹងថា កាយជាចំណីនៃពួកសត្វដទៃ ដឹងថា សុគតិ និងទុគ្គតិក្នុងសង្សារ ជាលំនៅរបស់សត្វថោកទាប ដូច្នេះហើយ កុំប្រមាទ ចូរប្រព្រឹត្តធម៌ចុះ។

[៨៣៩] (ព្រះរាជធីតា....) យក្ខនេះ ពោលពីរោះណាស់ ជីវិតរបស់ពួកសត្វខ្លី លំបាកផង តិចផង ព្រោះជីវិតនោះប្រកបដោយទុក្ខ ខ្ញុំនោះនឹងលះដែនកាសី និងក្រុងសុរុន្ធនៈ បួសតែម្នាក់ឯង។

ចប់ ឧទយជាតក ទី៤។

## បានីយជាតក ទី៥

CS sut.kn.jat.459 | ភាគទី ៥៩

### (៤៥៩. បានីយជាតកំ (៥))

[៨៤០] (ព្រះបច្ចេកពុទ្ធ ទី១ បានសំដែងថា) អាត្មាភាពជាមិត្រ (នៃមិត្រម្នាក់) បានប្រើប្រាស់ទឹកដែលមិត្រនោះមិនឲ្យហើយ ហេតុនោះអាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បាន

ជាអាត្មាភាពបួស។

[៨៤១] (ព្រះបច្ចេកពុទ្ធ ទី២....) សេចក្តីប្រាថ្នា (ក្នុងកាម) កើតឡើងដល់អាត្មាភាព ព្រោះឃើញនូវប្រពន្ធរបស់បុគ្គលដទៃ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាព លែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស។

[៨៤២] (ព្រះបច្ចេកពុទ្ធ ទី៣....) បពិត្រមហារាជ ពួកចោរបានចាប់បិតារបស់អាត្មាភាពក្នុងព្រៃ អាត្មាភាព ដែលពួកចោរនោះសួរហើយ ទុកជាដឹង ក៏ប្រាប់ហេតុនោះ ដោយចំណែកដទៃវិញ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើមក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស។

[៨៤៣] (ព្រះបច្ចេកពុទ្ធ ទី៤...) ការសែនព្រេន ឈ្មោះសោមយាគ តាំងឡើងហើយ ពួកមនុស្សបានធ្វើបាណាតិបាត អាត្មាភាពក៏អនុញ្ញាតឲ្យពួកមនុស្សនោះ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស។

[៨៤៤] (ព្រះបច្ចេកពុទ្ធ ទី៥...) ពួកជនណា (ក្នុងស្រុក) របស់យើង ដែលសំគាល់សុរា និងមេរ័យ ថាដូចទឹកឃ្មុំ ជាជន (មានសភាពយ៉ាងនេះ) ជាដំបូង ពួកជននោះ បានចាត់ចែងទឹកស្រវឹង ដើម្បីសេចក្តីវិនាសដល់ពួកជនច្រើន អាត្មាភាពបានអនុញ្ញាតឲ្យពួកជននោះ ព្រោះហេតុនោះ អាត្មាភាពខ្ពើមរអើម ក្នុងកាលជាខាងក្រោយ អាត្មាភាពបានធ្វើបាបនោះហើយ អាត្មាភាពលែងធ្វើបាបទៀតហើយ ព្រោះហេតុនោះ បានជាអាត្មាភាពបួស។

[៨៤៥] (ព្រះរាជា...) គួរឲ្យតិះដៀលកាមដ៏ច្រើន ដែលមានក្លិនអាក្រក់ មានសត្រូវច្រើន ព្រោះថា អាត្មាអញបានសេពហើយ ក៏មិនបានសេចក្តីសុខ (ក្នុងឈាន) ប្រាកដដូច្នោះ។

[៨៤៦] (អគ្គមហេសី...) កាមទាំងឡាយ មានសេចក្តីរីករាយច្រើន ជាសុខ សេចក្តីសុខក្រៅអំពីកាម មិនមានទេ ពួកជនណាបានសេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងឋានសួគ៌។

[៨៤៧] (ព្រះរាជា...) កាមទាំងឡាយ មានសេចក្តីរីករាយតិច ជាទុក្ខ សេចក្តីទុក្ខក្រៅអំពីកាម មិនមានទេ ពួកជនណា សេពកាមទាំងឡាយ ពួកជននោះ តែងកើតក្នុងនរក។

[៨៤៨] កាមទាំងឡាយ មានសេចក្តីទុក្ខ លើសជាងដាវដែលសំលៀងហើយ ជាងព្រះខាន់ដែលលាបដោយថ្នាំពិស ទាំងជាងលំពែងដែលពួយត្រង់ទ្រូង។

[៨៤៩] កាមទាំងឡាយ មានសេចក្តីទុក្ខ លើសជាងរងើកភ្លើងដ៏ច្រាលឆ្អៅ ជាងរណ្តៅរងើកភ្លើង មានជម្រៅមួយទទូង ឬអណ្តាតភ្លើងដែលក្តៅពេញមួយថ្ងៃ។

[៨៥០] កាមទាំងឡាយ មានសេចក្តីទុក្ខ លើសជាងថ្នាំពុលដ៏ក្លៀវក្លា ឬប្រេងកំពុងពុះ ឬក៏ទង់ដែងរលាយ។

ចប់ បានីយជាតក ទី៥។

## យុធញ្ជយជាតក ទី៦

CS sut.kn.jat.460 | ភាគទី ៥៩

(៤៦០. យុធញ្ចយជាតកំ (៦ ))

[៨៥១] (ព្រះរាជកុមារពោធិសត្វ ពោលថា) បពិត្រព្រះរាជា ជាធំក្នុងរថ ខ្ញុំព្រះអង្គ សូមថ្វាយបង្គំ (ព្រះអង្គ) ដែលមិត្រ និងអាមាត្រចោមរោមហើយ ខ្ញុំព្រះអង្គនឹងបួស សូមព្រះសម្មតិទេព អនុញ្ញាតផ្នួសនោះ (ដល់ខ្ញុំព្រះអង្គ)។

[៨៥២] (ព្រះរាជា ទ្រង់ត្រាស់ថា) បើកូនឯងខ្វះកាមទាំងឡាយ ឪពុកនឹងបំពេញឲ្យគ្រប់គ្រាន់ដល់អ្នក បុគ្គលណាបៀតបៀនអ្នក ឪពុកនឹងឃាត់ (បុគ្គលនោះ) ម្នាលយុធញ្ជ័យ អ្នកកុំបួសឡើយ។

[៨៥៣] (ព្រះរាជកុមារ...) ខ្ញុំព្រះអង្គមិនមានសេចក្តីខ្វះកាមទាំងឡាយទេ បុគ្គលនីមួយ បៀតបៀននូវខ្ញុំព្រះអង្គ ក៏មិនមានដែរ តែថាខ្ញុំព្រះអង្គប្រាថ្នានឹងធ្វើនូវទីពឹង (ដល់ខ្លួន) ដែលជរាកំចាត់បង់មិនបាន។

[៨៥៤] (ព្រះសាស្តា...) បុត្រអង្វរនូវបិតា បិតាក៏អង្វរនូវបុត្តឱរសដែរព្រះរាជាទ្រង់ត្រាស់ថា ម្នាលកូន ជនអ្នកនៅក្នុងនិគម អង្វរអ្នក ម្នាលយុធញ្ជ័យ អ្នកកុំបួសឡើយ។

[៨៥៥] (ព្រះរាជកុមារ...) បពិត្រព្រះបិតាជាធំក្នុងរថ សូមព្រះអង្គកុំឃាត់ផ្នួសខ្ញុំព្រះអង្គនោះ កុំឲ្យខ្ញុំព្រះអង្គពោរពេញដោយកាមទាំងឡាយ ឲ្យលុះក្នុងអំណាចជរាឡើយ។

[៨៥៦] (ព្រះមាតា....) ម្នាលកូន យើងសូមអង្វរអ្នក ម្នាលកូន យើងសូមឃាត់អ្នក យើងចង់ឃើញអ្នកអស់កាលយូរ ម្នាលយុធញ្ជ័យចូរអ្នកកុំបួសឡើយ។

[៨៥៧] (ព្រះរាជកុមារ...) ទឹកសន្សើមលើចុងស្មៅ តែងធ្លាក់ចុះ (លើផែនដី) ក្នុងកាលព្រះអាទិត្យរះឡើង យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ បពិត្រព្រះមាតា សូមព្រះមាតាកុំឃាត់ខ្ញុំឡើយ។

[៨៥៨] បពិត្រព្រះបិតាជាធំក្នុងរថ សូមឲ្យ (បុរស) ចម្លងព្រះមាតា (របស់ខ្ញុំព្រះអង្គ) ឲ្យឡើងកាន់ព្រះរាជយាននេះ កុំឲ្យព្រះមាតាធ្វើនូវសេចក្តីអន្តរាយដល់ខ្ញុំព្រះអង្គ ដែលកំពុងឆ្លង។

[៨៥៩] (ព្រះមាតា....) នាងទាំងឡាយចូរស្ទុះទៅ សេចក្តីចំរើន (នឹងមាន) ដល់នាង នគររម្មកៈ មុខជានឹងសូន្យ (ព្រោះថា) យុធញ្ជយកុមារ ព្រះរាជាសព្វទត្ត អនុញ្ញាត (ឲ្យបួសហើយ)។

[៨៦០] ព្រះរាជកុមារណា នៅក្មេង មានសម្បុរផ្ទឹមនឹងមាស ប្រសើរបំផុតជាងព្រះរាជបុត្រ ១០០០ ព្រះរាជកុមារនោះ ជាអ្នកមានកំឡាំងស្លៀកសំពត់កាសាយៈ បួសហើយ។

[៨៦១] (ព្រះសាស្តា...) កុមារទាំងពីរអង្គ គឺយុធញ្ជ័យ ១ យុធិដ្ឋិលៈ ១ លះបង់នូវព្រះមាតា និងព្រះបិតា ផ្តាច់ចោលនូវគ្រឿងជាប់ចំពាក់របស់មច្ចុមារ បួសហើយ។

ចប់ យុធញ្ជយជាតក ទី៦។

## ទសរថជាតក ទី៧

CS sut.kn.jat.461 | ភាគទី ៥៩

### (៤៦១. ទសរថជាតកំ (៧ ))

[៨៦២] (រាមបណ្ឌិតកុមារ បានពោលថា) ម្នាលលក្ខណៈ និងនាងសីតា អ្នកទាំងឡាយចូរមក អ្នកទាំង ២ នាក់ចូរចុះទឹក ភរតកុមារ បាននិយាយយ៉ាងនេះថា ព្រះបាទទសរថ ទ្រង់ទិវង្គតហើយ។

[៨៦៣] (ភរតកុមារ...) បពិត្រព្រះរាម ដោយអានុភាពអ្វី ទើបទ្រង់បានឮថា ព្រះបិតាទិវង្គតហើយ មិនសោកស្តាយ របស់ដែលគួរសោកស្តាយ សេចក្តីទុក្ខមិនគ្របសង្កត់ទ្រង់។

[៨៦៤] (រាមបណ្ឌិតកុមារ....) ជីវិតណា (របស់ពួកសត្វ) បណ្តាពួកបុរសដែលរវើរវាយ បុរស (សូម្បីតែម្នាក់) ក៏មិនអាចដើម្បីរក្សាជីវិតច្រើននោះបានទេ វិញ្ញូជន ជាមេធាវីនោះ ធ្វើខ្លួនឲ្យក្តៅក្រហាយដើម្បីអ្វី។

[៨៦៥] សេចក្តីពិតថា ជនទាំងឡាយណា ទាំងក្មេង ទាំងចាស់ ទាំងល្ងង់ ទាំងប្រាជ្ញ ទាំងអ្នកមាន ទាំងអ្នកក្រ ជនទាំងអស់នោះ សុទ្ធតែមានសេចក្តីស្លាប់នៅខាងមុខ។

[៨៦៦] ផ្លែឈើទុំទាំងឡាយ មានសេចក្តីខ្លាចអំពីកិរិយាជ្រុះជានិច្ច យ៉ាងណាមិញ ពួកសត្វកើតហើយ ក៏មានសេចក្តីខ្លាចអំពីសេចក្តីស្លាប់ជានិច្ច យ៉ាងនោះដែរ។

[៨៦៧] ជនទាំងឡាយច្រើន ពួកខ្លះ គេឃើញក្នុងវេលាព្រឹក វេលាល្ងាចមិនឃើញ ជនទាំងឡាយច្រើន ពួកខ្លះ គេឃើញក្នុងវេលាល្ងាច វេលាព្រឹកមិនឃើញ។

[៨៦៨] បើបុគ្គលអ្នកវង្វេង កាលខ្សឹកខ្សួល បៀតបៀនខ្លួន ហើយគប្បីនាំមកនូវប្រយោជន៍បន្តិចបន្តួចបាន អ្នកប្រាជ្ញ ក៏គប្បីធ្វើសេចក្តីខ្សឹកខ្សួលនោះដែរ។

[៨៦៩] (បុគ្គលខ្សឹកខ្សួល) បៀតបៀនខ្លួនរបស់ខ្លួន ជាអ្នកស្គម មិនមានពណ៌សម្បុរ ពួកសត្វដែលទៅកាន់បរលោក មិនមែនញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយសេចក្តីខ្សឹកខ្សួលនោះឡើយ ព្រោះថា សេចក្តីខ្សឹកខ្សួល មិនមានប្រយោជន៍ទេ។

[៨៧០] (បណ្ឌិតបុរស) គប្បីញុំាងផ្ទះដែលភ្លើងឆេះឲ្យរលត់ ដោយទឹកបានយ៉ាងណាមិញ ធីរជន ជាមេធាវីបណ្ឌិត បានស្តាប់ហើយ គប្បីញុំាងសេចក្តីសោក ដែលកើតហើយឲ្យរលត់ឆាប់ ដូចខ្យល់បក់ផាត់នូវប៉ុយ យ៉ាងនោះដែរ។

[៨៧១] សត្វរមែងទៅកាន់បរលោកតែម្នាក់ឯង កើតក្នុងត្រកូលក៏តែម្នាក់ឯង ការសេមគប់នៃពួកសត្វទាំងអស់ គឺមានការចួបជុំ ជាការប្រសើរបំផុត។

[៨៧២] ព្រោះហេតុនោះ សេចក្តីសោកទាំងឡាយ សូម្បីធំ ក៏មិនដុតកំដៅនូវហទយវត្ថុ និងចិត្តរបស់អ្នកប្រាជ្ញ ជាពហុស្សូត ដែលឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ ព្រោះដឹងច្បាស់នូវធម៌។

[៨៧៣] យើងនោះ នឹងរក្សានូវយសផង ភោគៈផង ភរិយាទាំងឡាយផង ញាតិទាំងឡាយផង និងជនដ៏វិសេសផង នេះជាកិច្ចរបស់អ្នកប្រាជ្ញ។

[៨៧៤] ព្រះសាស្តា ទ្រង់ត្រាស់ថា ព្រះបាទរាមៈ មានព្រះសុរង្គ ដូចជារូបសំណាកមាស មានព្រះពាហុធំ បានសោយរាជ្យអស់ ១៦ ០០០ ឆ្នាំ។

ចប់ ទសរថជាតក ទី៧។

## សំវរជាតក ទី៨

CS sut.kn.jat.462 | ភាគទី ៥៩

### (៤៦២. សំវរជាតកំ (៨))

[៨៧៥] (ឧបោសថកុមារ បានពោលថា) បពិត្រមហារាជ ព្រះជនាធិបៈ (ជាព្រះបិតា) ប្រហែលទ្រង់ជ្រាបនូវសីលរបស់ព្រះអង្គហើយ បានជាព្រះអង្គបូជានូវព្រះរាជកុមារទាំងនេះ (ដោយជនបទនោះ ៗ) មិនសំគាល់នូវព្រះអង្គ ដោយជនបទណាមួយឡើយ។

[៨៧៦] កាលដែលមហារាជ គង់ព្រះជន្មនៅ ឬកាលដែលព្រះអង្គ (ជាបិតារបស់ពួកយើង) ទិវង្គតហើយ ពួកញាតិ កាលឃើញសេចក្តីចំរើនរបស់ខ្លួន បានយល់ព្រមឲ្យព្រះអង្គ (សោយរាជ្យ)។

[៨៧៧] បពិត្រព្រះបាទសំវរៈ ព្រះអង្គទ្រង់គ្របសង្កត់ (នូវបង ៩៩ ព្រះអង្គ) ដែលកើតជាមួយ តើដោយវត្តដូចម្តេច ឯពួកញាតិដែលមកប្រជុំគ្នាហើយ ក៏មិនគ្របសង្កត់នូវព្រះអង្គ តើដោយវត្តដូចម្តេច។

[៨៧៨] (ព្រះបាទសំវរៈ....) បពិត្ររាជបុត្រ ខ្ញុំមិនច្រណែន ខ្ញុំថ្វាយបង្គំព្រះបាទទាំងឡាយ របស់ពួកសមណៈ ជាតាទិបុគ្គល បាន

នមស្ការពួកសមណៈទាំងនោះដោយគោរព។

[៨៧៩] សមណៈទាំងនោះ ជាអ្នកត្រេកអរក្នុងធម្មគុណរបស់ឥសី បានប្រៀនប្រដៅខ្ញុំ ឲ្យប្រកបក្នុងធម្មគុណ ឲ្យជាអ្នកត្រងត្រាប់មិនច្រណែន។

[៨៨០] ខ្ញុំបានស្តាប់ពាក្យរបស់ពួកសមណៈ អ្នកស្វែងរកនូវគុណនោះហើយ មិនមើលងាយបន្តិចបន្តួចសោះ ចិត្តរបស់ខ្ញុំក៏ត្រេកអរក្នុងធម៌ជានិច្ច។

[៨៨១] ពួកទាហានជិះដំរី ពួកទាហានដែលបិតនៅក្នុងក្បួនទ័ព ពួកទាហានជិះរថ ពួកពលថ្មើរជើង ខ្ញុំមិនបន្ថយនូវបាយ និងថ្លៃឈ្នួលដែលពួកទាហាននោះចាត់ចែងហើយ។

[៨៨២] ពួកមហាមាត្យ ពួកមន្ត្រី ពួកអ្នកបម្រើរបស់ខ្ញុំមាន ពួកជនបានចាត់ចែងនូវសាច់ និងទឹកសុរាដ៏ច្រើន ក្នុងក្រុងពារាណសី។

[៨៨៣] មួយទៀត សូម្បីពួកពាណិជ ដែលមកអំពីដែនផ្សេង ៗ ក៏សម្បូណ៌ ខ្ញុំបានចាត់ចែងការរក្សា ចំពោះពួកពាណិជទាំងនោះ បពិត្រឧបោសថជាបង សូមព្រះបង ជ្រាបយ៉ាងនេះចុះ។

[៨៨៤] (ឧបោសថកុមារ....) បពិត្រព្រះបាទសំវរៈ ឮថាព្រះអង្គ (គ្រប់សង្កត់អានុភាព) របស់ពួកញាតិ (បង ៩៩ ព្រះអង្គ) ដោយធម៌ សូមព្រះអង្គសោយរាជ្យចុះ ព្រះអង្គជាអ្នកមានប្រាជ្ញាផង ជាបណ្ឌិតផង ទាំងជាប្រយោជន៍ដល់ពួកញាតិផង។

[៨៨៥] ពួកសត្រូវ មិនអាចគ្រប់សង្កត់ព្រះអង្គ ដែលពួកញាតិចោមរោមហើយ ជាអ្នកកុះករដោយរតនវត្ថុផ្សេង ៗ ដូចជាស្តេចអសុរមិនអាចគ្រប់សង្កត់ព្រះឥន្ទ្រ ដូច្នោះដែរ។

ចប់ សំវរជាតក ទី៨។

## សុប្បារកជាតក ទី៩

CS sut.kn.jat.463 | ភាគទី ៥៩

(៤៦៣. សុប្បារកជាតកំ (៩))

[៨៨៦] (ពួកពាណិជ បានពោលថា) មនុស្សទាំងឡាយ មានច្រមុះដូចកាំបិតកោរ ងើបមុជ (ក្នុងសមុទ្រនេះ) ពួកយើង សូមសួរលោកឈ្មោះសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី។

[៨៨៧] (ព្រះមហាសត្វ បានពោលថា) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យចេញទៅអំពីកំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា ខុរមាលី។

[៨៨៨] (ពួកពាណិជ បានពោលថា) សមុទ្រដែលប្រាកដចំពោះមុខ ហាក់ដូចជាភ្លើង និងព្រះអាទិត្យ ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី។

[៨៨៩] (ព្រះមហាសត្វ...) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា អគ្គិមាលី។

[៨៩០] (ពួកពាណិជ...) សមុទ្រដែលប្រាកដចំពោះមុខ ហាក់ដូចជាទឹកដោះជូរនិងទឹកដោះស្រស់ ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី។

[៨៩១] (ព្រះមហាសត្វ...) កាលសំពៅរបស់ពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា ទធិមាលី។

[៨៩២] (ពួកពាណិជ....) សមុទ្រដែលប្រាកដចំពោះមុខ ហាក់ដូចជាស្បូវភ្លាំង និងសំទូង ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី។

[៨៩៣] (ព្រះមហាសត្វ....) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា កុសមាលី។

[៨៩៤] (ពួកពាណិជ....) សមុទ្រដែលប្រាកដចំពោះមុខ ហាក់ដូចជាបបុស និងឫស្សី ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី។

[៨៩៥] (ព្រះមហាសត្វ...) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆៈ លឿនទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា នឡមាលី។

[៨៩៦] (ពួកពាណិជ...) សំឡេងរបស់អមនុស្ស គួរឲ្យភ័យខ្លាំង គួរឲ្យស្ញើម ដែលពួកយើងបានឮជាក់ សមុទ្រដែលប្រាកដចំពោះមុខ ហាក់ដូចជារណ្តៅ និងជ្រោះ ពួកយើងសូមសួរលោកសុប្បារកៈ សមុទ្រនេះ តើឈ្មោះអ្វី។

[៨៩៧] (ព្រះមហាសត្វ....) កាលសំពៅពួកពាណិជ អ្នកស្វែងរកទ្រព្យ ចេញទៅអំពីកំពង់ភរុកច្ឆៈ លឿទៅកាន់ប្រទេសផ្សេង សមុទ្រនេះ ហៅថា ពលវាមុខី។

[៨៩៨] (ព្រះមហាសត្វ ធ្វើសច្ចកិរិយាថា) តាំងពីកាលដែលខ្ញុំរលឹកឃើញនូវខ្លួន តាំងពីកាលដែលខ្ញុំដល់នូវភាពជាអ្នកដឹងក្តី ខ្ញុំមិនចេះភ្លេង ដើម្បីបៀតបៀនសត្វ សូម្បីតែមួយឡើយ សូមឲ្យសំពៅត្រឡប់ទៅកាន់ទីមានសួស្តី ដោយការពោលពាក្យសច្ចៈនេះចុះ។

ចប់ សុប្បារកជាតក ទី៩។

ឧទ្ទាននៃជាតកនោះ គឺ

និយាយអំពីដំរីដ៏ប្រសើរ ចិញ្ចឹមមាតា ១ ព្រះរាជាព្រះនាមជុណ្ហៈ ១ ធម្មទេវបុត្ត ១ ព្រះរាជាព្រះនាមឧទយៈ ១ ទឹកដឹក ១ ព្រះរាជាព្រះនាមយុធញ្ជ័យ ១ ព្រះរាជាព្រះនាមទសរថ ១ ព្រះរាជាព្រះនាមសំវរៈ ១ សំពៅគ្រឡប់កាន់ត្រើយ ១ ត្រូវជា ៩ ជាតក។

ចប់ ឯកាទសកនិបាត។

# ទ្វាទសនិបាតជាតក

CS sut.kn.jat.v12 | ភាគទី ៥៩

(១២. ទ្វាទសកនិបាតោ)

## ចុល្លកុណាលជាតក ទី១

CS sut.kn.jat.464 | ភាគទី ៥៩

(៤៦៤. ចូឡកុណាលជាតកំ (១ ))

[៨៩៩] (សត្វតាវ៉ៅ បានពោលថា) បុរសដែលមិនជាប់ចំពាក់ដោយទេវតា (ខ្មោចមិនចូល) មិនគួរជឿ (នូវសីល និងវត្ត) របស់ពួកស្រ្តីជាអ្នកឈ្លានពាន មានចិត្តរហ័ស មិនដឹងនូវឧបការគុណដែលគេធ្វើហើយ ជាអ្នកប្រទូស្តមិត្រទេ។

[៩០០] ស្ត្រីទាំងនោះ មិនដឹងនូវឧបការគុណដែលគេធ្វើហើយដល់ខ្លួន មិនដឹងច្បាស់នូវកិច្ច (ដែលខ្លួនត្រូវធ្វើ) មិនដឹងច្បាស់នូវមាតាបិតា ឬបងប្អូន មិនអៀនខ្មាស តែងប្រព្រឹត្តកន្លងច្បាប់ជាធម្មតា លុះក្នុងអំណាចនៃចិត្តរបស់ខ្លួន។

[៩០១] ស្ត្រីទាំងនោះ តែងលះបង់នូវបុរសនោះ ដែលជាទីស្រឡាញ់ ជាទីគាប់ចិត្ត សូម្បីនៅជាមួយគ្នាអស់កាលយូរ ជាអ្នកអនុគ្រោះ សូម្បីស្មើដោយជីវិត ក្នុងគ្រោះថ្នាក់ទាំងឡាយផង ក្នុងកិច្ចការទាំងឡាយផង ព្រោះហេតុនោះ ខ្ញុំមិនស្និទ្ធស្នាលនឹងស្ត្រីទាំងឡាយឡើយ។

[៩០២] ព្រោះថា ចិត្តរបស់ពួកស្ត្រីប្រែប្រួលដូចជាសត្វស្វា ឬដូចជាម្លប់ឈើ ចិត្តរបស់ពួកស្ត្រី ច្រាស់ច្រាល់ វិលវង់ ដូចជាខ្នងកង់កាលវិលទៅដូច្នោះ។

[៩០៣] ក្នុងកាលដែលស្ត្រីទាំងនោះ សំឡឹងឃើញទ្រព្យរបស់បុរស មានសភាពគួរយកបាន ក៏នាំបុរសនុ៎ះទៅ (កាន់អំណាចខ្លួន) ដោយសំដីដ៏ផ្អែមល្ហែមទាំងឡាយ ដូចជាពួកជនអ្នកនៅក្នុងដែនកម្ពោជៈ កាលនាំសេះទៅកាន់អំណាចខ្លួនដោយស្លែដូច្នោះ។

[៩០៤] ក្នុងកាលដែលស្ត្រីទាំងនោះ សំឡឹងមើលមិនឃើញទ្រព្យរបស់បុរស មានសភាពគួរយកបានទេ ក៏គេចចៀសបុរសនុ៎ះដោយជុំវិញ ដូចជាបុគ្គលអ្នកឆ្លងទៅដល់ត្រើយស្ទឹងហើយ ក៏វៀរបង់នូវក្បូនដូច្នោះ។

[៩០៥] ស្ត្រីទាំងឡាយនោះ មានសេចក្តីប្រៀបធៀបដោយជ័រ ដូចជាភ្លើងដែលស៊ីនូវវត្ថុគ្រប់យ៉ាង មានមាយាដ៏ក្លៀវក្លា ដូចជាស្ទឹងមានខ្សែទឹកដ៏រហ័ស ព្រោះថា ស្ត្រីទាំងនុ៎ះ តែងសេពនូវបុរសជាទីស្រឡាញ់ និងមិនជាទីស្រឡាញ់ ដូចជាទូកដែលអែបនូវច្រាំងទាំងខាងអាយទាំងច្រាំងខាងនាយដូច្នោះ។

[៩០៦] ស្ត្រីទាំងនោះ មិនមែនរបស់បុរសម្នាក់ មិនមែនរបស់បុរសពីរនាក់ទេ ដូចជារានផ្សារ ដែលគេរៀបហើយ បុរសណា សំគាល់នូវស្ត្រីទាំងនោះ ថាជារបស់អញ បុរសនោះ គប្បីចងខ្យល់ដោយសំណាញ់បាន។

[៩០៧] ស្ទឹង ផ្លូវ តៀមស្រា រោងសម្រាប់ប្រជុំ និងអណ្តូង យ៉ាងណា ធម្មតាស្ត្រីទាំងឡាយក្នុងលោក ក៏យ៉ាងនោះដែរ ឯវេលារបស់ស្ត្រីទាំងនោះ មិនមានឡើយ។

[៩០៨] ស្ត្រីទាំងនោះ ស្មើដោយភ្លើងឆេះឆ្នាំងខ្លាញ់ ឧបមាដោយក្បាលពស់វែក ឬដូចជាពួកគោស៊ីច្បិចតែចុងស្មៅដ៏ប្រសើរ ៗ ខាងក្រៅ។

[៩០៩] នរជនគប្បីសង្រួមជានិច្ច ហើយគប់រកនូវជនទាំងនេះ គឺភ្លើង ១ ដំរី ១ ពស់វែក ១ ស្តេចដែលបានមុទ្ធាភិសេកហើយ ១ ពួកស្ត្រីទាំងអស់ ១ ភាវៈទៀងទាត់របស់ជនទាំងនោះ គេស្គាល់បានដោយក្រ។

[៩១០] ស្ត្រីមានសម្បុរល្អឆើត បុរសមិនគួរសេពទេ ស្ត្រីជាទីស្រឡាញ់នៃបុរសច្រើនគ្នា បុរសមិនគួរសេពទេ ស្ត្រីប្រសប់រាំច្រៀង បុរសមិនគួរសេពទេ ស្ត្រីជាប្រពន្ធរបស់បុគ្គលដទៃ បុរសមិនគួរសេពទេ ស្ត្រី (គប់រកបុរស) ព្រោះហេតុតែទ្រព្យ បុរសមិនគួរសេពទេ ស្ត្រីទាំង ៥ ពួកនេះ បុរសមិនគួរសេពឡើយ។

ចប់ ចុល្លកុណាលជាតក ទី១។

## ភទ្ទសាលជាតក ទី២

CS sut.kn.jat.465 | ភាគទី ៥៩

(៤៦៥. ភទ្ទសាលជាតកំ (២))

[៩១១] (ព្រះរាជា ទ្រង់ត្រាស់ថា) អ្នកជាអ្វី ដែលមានសំពត់ទាំងឡាយដ៏ស្អាត បានឋិតនៅលើអាកាសវេហាស៍ ទឹកភ្នែកទាំងឡាយរបស់អ្នកហូរចេញ តើដោយហេតុអ្វី ភ័យមកចំពោះអ្នក ព្រោះអ្វី។

[៩១២] (ទេវរាជ ត្រាស់ថា) បពិត្រព្រះសម្មតិទេព ជនទាំងឡាយក្នុងដែនរបស់ព្រះអង្គ ស្គាល់ច្បាស់នូវខ្ញុំថា ជាភទ្ទសាលព្រឹក កាលខ្ញុំ

បិតនៅ (ក្នុងឧទ្យាននេះ) អស់ ៦ ម៉ឺនឆ្នាំ ជនទាំងឡាយ បានបូជាហើយ។

[៩១៣] បពិត្រព្រះអង្គជាម្ចាស់ទិស (ព្រះរាជាទាំងឡាយ ពីដើមក្នុងនគរនេះ) កាលឲ្យគេសាងទីក្រុងទាំងឡាយផង ដំណាក់ទាំងឡាយផង ប្រាសាទផ្សេង ៗ ផង មិនដែលបៀតបៀនខ្ញុំឡើយ ព្រះរាជាទាំងនោះ បូជាខ្ញុំយ៉ាងណា សូមព្រះអង្គបូជាខ្ញុំ យ៉ាងនោះដែរ។

[៩១៤] (ព្រះរាជា...) ខ្ញុំមិនធ្លាប់ឃើញអ្នកជាដើមឈើធំ ដោយកាយរបស់អ្នកទេ អ្នកជាឈើមានទ្រង់ទ្រាយដ៏ល្អដោយកំពស់ និងទំហំ និងកំណើត។

[៩១៥] ម្នាលយក្ខ ខ្ញុំនឹងឲ្យគេធ្វើប្រាសាទមានសសរតែមួយ ជាទីរីករាយនៃចិត្ត ខ្ញុំនឹងនាំយកអ្នកចូលទៅក្នុងប្រាសាទនោះ ជីវិតរបស់អ្នក (នឹងមាន) អស់កាលយូរ។

[៩១៦] (ទេវរាជ...) (បើ) ព្រះទ័យ (របស់ទ្រង់) កើតឡើងយ៉ាងនេះ សេចក្តីព្រាត់ប្រាស (ចាកភទ្ទសាលព្រឹក្ស) ជាសរីរៈ (របស់ខ្ញុំនឹងមានប្រាកដ) (កាលបើយ៉ាងនេះ) សូមព្រះអង្គ កាត់ខ្ញុំជាច្រើនកំណាត់ កាត់ជាកំណាត់តូចធំចុះ។

[៩១៧] តែសូមព្រះអង្គកាត់ត្រង់ចុង និងកណ្តាល (មុន) រួចកាត់ត្រង់គល់ ក្នុងកាលជាខាងក្រោយ កាលបើខ្ញុំត្រូវព្រះអង្គកាត់យ៉ាងនេះ សេចក្តីស្លាប់ មិនគប្បីជាទុក្ខទេ។

[៩១៨] (ព្រះរាជា...) ដូចយ៉ាងបុគ្គលកាត់ដៃ និងជើងផង ត្រចៀក និងច្រមុះផង ឲ្យស្លាប់បាត់ជីវិត តពីនោះ គេកាត់នូវក្បាលក្នុងកាលខាងក្រោយ សេចក្តីស្លាប់នោះ ក៏ជាទុក្ខដែរ។

[៩១៩] ម្នាលភទ្ទសាលព្រឹក្ស ជាម្ចាស់នៃព្រៃ ការកាត់ជាកំណាត់ស្រួលឬ ព្រោះហេតុអ្វី ប្រារព្ធហេតុអ្វី បានជាអ្នកចង់ឲ្យគេកាត់ជាកំណាត់។

[៩២០] (ទេវរាជ...) បពិត្រមហារាជ ខ្ញុំចង់ឲ្យគេកាត់ជាកំណាត់ ព្រោះអាស្រ័យហេតុដែលប្រកបដោយហេតុណា សូមព្រះអង្គទ្រង់ស្តាប់នូវហេតុនោះរបស់ខ្ញុំចុះ។

[៩២១] ពួកឈើជាញាតិរបស់ខ្ញុំ ចំរើនដុះដាលដោយសេចក្តីសុខ កើតក្នុងទីមិនមានខ្យល់ នៅជិតខាងខ្ញុំ (កាលបើទ្រង់កាប់រំលំខ្ញុំ) ខ្ញុំមុខជានឹងរលំសង្កត់ពួកឈើជាញាតិនោះ សេចក្តីទុក្ខនឹងកើតមានដល់ពួកឈើជាញាតិដទៃទៀត។

[៩២២] (ព្រះរាជា....) ម្នាលភទ្ទសាលព្រឹក្ស ជាម្ចាស់នៃព្រៃ អ្នកគិតនូវហេតុដែលមានសភាពគួរគិត អ្នកជាឈើប្រាថ្នានូវប្រយោជន៍ដល់ពួកឈើជាញាតិ ម្នាលសំឡាញ់ ខ្ញុំឲ្យអភ័យដល់អ្នក។

ចប់ ភទ្ទសាលជាតក ទី២។

## សមុទ្ទវាណិជជាតក ទី៣

CS sut.kn.jat.466 | ភាគទី ៥៩

### (៤៦៦. សមុទ្ទវាណិជជាតកំ (៣))

[៩២៣] (ព្រះសាស្តា ទ្រង់សំដែងនូវឧទានរបស់បុរសម្នាក់ថា) ពួកមនុស្សជន (ក្នុងជម្ពូទ្វីប) ទាំងនោះ អាស្រ័យចិញ្ចឹមជីវិតដោយផលនៃការងារ រមែងសាបព្រោះ ក៏មិនបានមួយចំណែកនៃកោះនេះឡើយ ឯកោះរបស់យើងនេះ ប្រសើរជាងជម្ពូទ្វីប។

[៩២៤] (ធម្មិកទេវបុត្រ បានពោលថា) កាលបើព្រះចន្ទ ដើរដល់រាត្រី ១៥ កើត សន្ទុះនៃសាគរដ៏ធំ នឹងជោរលិចកោះដ៏ធំថ្កើងនេះ សន្ទុះនៃសាគរនោះ កុំសម្លាប់អ្នកទាំងឡាយឡើយ អ្នកទាំងឡាយ ចូរទៅរកទីជ្រកកោនដទៃចុះ។

[៩២៥] (អធម្មិកទេវបុត្រ បានពោលថា) សន្ទុះនៃទឹកក្នុងសាគរនេះ មិនមែនជោរលិចកោះដ៏ធំថ្កើងនេះទេ ដំណើរនោះ យើងឃើញដោយនិមិត្តដ៏ច្រើន អ្នកទាំងឡាយកុំខ្លាចសោយសោក ព្រោះហេតុអ្វី ចូររីករាយចុះ។

[៩២៦] អ្នកទាំងឡាយ បានដល់លំនៅដ៏ធំថ្កើងនេះ ជាកន្លែងមានចំណីដ៏ច្រើន មានបាយ និងទឹកដ៏ច្រើន យើងមិនឃើញភ័យបន្តិចបន្តួចនៃអ្នកទាំងឡាយឡើយ អ្នកទាំងឡាយ ចូររីករាយជាមួយនឹងកូន និងចៅទាំងឡាយចុះ។

[៩២៧] ជាងឈើជាមនុស្សពាល បានពោលថា ទេវតាណាបិតក្នុងទិសខាងត្បូង និយាយប្រាប់សេចក្តីក្សេម ពាក្យរបស់ទេវតានោះពិត ទេវតាដែលបិតក្នុងទិសខាងជើង មិនដឹងនូវហេតុដែលគួរខ្លាច និងមិនគួរខ្លាចទេ អ្នកទាំងឡាយ កុំខ្លាចឡើយ សោយសោកធ្វើអ្វី ចូរនាំគ្នារីករាយចុះ។

[៩២៨] (ជាងឈើជាបណ្ឌិត បានពោលថា) យក្ខទាំងនេះ ពោលខុសគ្នា យក្ខម្នាក់ប្រាប់នូវភ័យ យក្ខម្នាក់ប្រាប់នូវសេចក្តីក្សេមណ្ហើយចុះ អ្នកទាំងឡាយចូរស្តាប់នូវពាក្យរបស់យើងចុះ យើងទាំងអស់គ្នា កុំវិនាសឆាប់រួសរាន់ឡើយ។

[៩២៩] យើងទាំងអស់គ្នា ចូរប្រជុំគ្នាធ្វើទូក គឺទូកកំពោលមាំ ប្រកបដោយយន្តគ្រប់យ៉ាង បើទេវតាដែលបិតក្នុងទិសខាងត្បូងនេះ និយាយពិត ទេវតាដែលបិតក្នុងទិសខាងជើងនិយាយប្រាប់នេះ មិនពិតឡើយ។

[៩៣០] ទូករបស់យើងនោះ នឹងមានប្រយោជន៍ដល់សេចក្តីអន្តរាយ (ដែលកើតខាងក្រោយ) ពួកយើងមិនលះបង់នូវកោះនេះទេ បើទេវតាដែលបិតក្នុងទិសខាងជើង និយាយពិត ទេវតាដែលបិតក្នុងទិសខាងត្បូងនេះ និយាយមិនពិតទេ។

[៩៣១] យើងទាំងអស់គ្នា ឡើងជិះទូកនោះឯង ហើយគប្បីឆ្លងទៅរកត្រើយខាងនាយ ដោយសួស្តីយ៉ាងនេះ បុគ្គលមិនគប្បីជឿដោយងាយថា ពាក្យដែលបុគ្គលទី ១ ពោលហើយ ជាពាក្យប្រសើរដូច្នេះទេ នរជនណា ក្នុងលោកនេះ កាន់យកនូវពាក្យនៃបុគ្គលទី ២ ដែលដល់នូវគន្លងនៃត្រចៀក ហើយពិចារណា (នូវពាក្យខាងដើម និងពាក្យខាងចុង) ហើយជឿនូវពាក្យជាកណ្តាល នរជននោះ រមែងដល់នូវទីដ៏ប្រសើរ។

[៩៣២] (អភិសម្ពុទ្ធគាថា) ពាណិជទាំងនោះ បានទៅដោយសួស្តី ក្នុងកណ្តាលនៃទឹកសមុទ្រ ដោយកម្មរបស់ខ្លួន យ៉ាងណាមិញ

កុលបុត្រមានប្រាជ្ញាដូចផែនដី បានដឹងច្បាស់នូវប្រយោជន៍ ជាអនាគត ហើយមិនប្រព្រឹត្តកន្លងនូវប្រយោជន៍ (របស់ខ្លួន) សូម្បីតិច កំយ៉ាងនោះដែរ។

[៩៣៣] ពួកជនពាលដែលជាប់ក្នុងរសដោយមោហៈ មិនបានដឹងច្បាស់នូវប្រយោជន៍ជាអនាគត ក៏លិចចុះក្នុងប្រយោជន៍ជាបច្ចុប្បន្ន ដូចជាមនុស្សទាំងនោះ (ដល់នូវសេចក្តីវិនាស) ក្នុងកណ្តាលសមុទ្រ។

[៩៣៤] បុគ្គលគប្បីគ្រោងទុកនូវកិច្ចជាអនាគត (ដោយបំណងថា) កិច្ចកុំបៀតបៀនអញ ក្នុងកាលដែលមានកិច្ចឡើយ ឯកិច្ចនោះ មិនបានបៀតបៀននូវបុគ្គលនោះ ជាអ្នកធ្វើកិច្ចដែលខ្លួនបានគ្រោងទុកហើយ ប្រាកដដូច្នោះ ក្នុងកាលជាទីធ្វើកិច្ច។

ចប់ សមុទ្ទវាណិជជាតក ទី៣។

## កាមជាតក ទី៤

CS sut.kn.jat.467 | ភាគទី ៥៩

### (៤៦៧. កាមជាតកំ (៤))

[៩៣៥] (ព្រះមហាសត្វ បានពោលថា) កាលបុគ្គលប្រាថ្នានូវកាម បើកាមនោះសម្រេចដល់បុគ្គលនោះ សត្វប្រាថ្នាកាមណា បានហើយ រមែងជាអ្នកមានចិត្តរីករាយក្នុងវត្ថុនោះ ដោយពិត។

[៩៣៦] កាលបុគ្គលប្រាថ្នាកាម បើកាមនោះសម្រេចដល់បុគ្គលនោះ បុគ្គលនោះ រមែងបាននូវចំណង់ដទៃជាងនោះទៅទៀត ដូចជា (បុគ្គលហត់នឿយ) បាននូវចំណង់ (ស្រេក) ក្នុងរដូវក្តៅ។

[៩៣៧] កាលគោជាសត្វមានស្នែង កំពុងចំរើន ស្នែងរមែងចំរើនដែរ យ៉ាងណា កាលសត្វអ្នកមានបញ្ញាទន់ ល្ងង់ខ្លៅ មិនដឹងអ្វី កំពុងចំរើន តណ្ហា និងសេចក្តីស្រេកឃ្លាន រមែងរឹងរឹតចំរើនឡើងយ៉ាងនោះដែរ។

[៩៣៨] ប្រសិនបើ (មាលាពនោះ) ឲ្យស្រែស្រូវខ្សាយ ឲ្យស្រែស្រូវដំណើប ឲ្យគោ សេះ និងបុរសជាខ្ញុំប្រុស លើផែនដី (ដល់បុគ្គលណាមួយ វត្ថុទាំងប៉ុណ្ណោះនេះ) ក៏មិនល្មមដល់បុគ្គលម្នាក់ឡើយ បុរសដឹងយ៉ាងនេះហើយ គប្បីប្រព្រឹត្តឲ្យស្មើ។

[៩៣៩] ស្តេចកំហែងច្បាំងឈ្នះនូវផែនដី ហើយគ្រប់គ្រងផែនដី មានសាគរជាទីបំផុត មានសភាពជាអ្នកមិនឆ្អែតនឹងត្រើយសមុទ្រខាងអាយ ក៏ចង់បាននូវត្រើយសមុទ្រខាងនាយទៀត។

[៩៤០] បុរសកាលនឹកស្រណោះនូវកាមទាំងឡាយ ដោយចិត្ត (ដរាបណា) ក៏មិនដល់នូវសេចក្តីឆ្អែតដរាបនោះ ពួកសត្វណាត្រឡប់ចិត្តចេញ គេចខ្លួនថយអំពីកាមនោះ ហើយឃើញ (ទោសកាម ដោយញាណ) ជាអ្នកឆ្អែតដោយប្រាជ្ញា ពួកសត្វនោះ ទើបឈ្មោះថា ឆ្អែតពិតមែន។

[៩៤១] បុរសនោះ មិនក្តៅក្រហាយដោយកាមទាំងឡាយ (នេះ) ជាអំពើដ៏ប្រសើរ របស់ពួកជនអ្នកឆ្អែតដោយប្រាជ្ញា តណ្ហាមិនធ្វើបុរសដែលឆ្អែតដោយប្រាជ្ញា ឲ្យលុះក្នុងអំណាចបានឡើយ។

[៩៤២] សូមព្រះអង្គកំចាត់បង់នូវកាមទាំងឡាយចេញ បុរសអ្នកមានប្រាជ្ញាប៉ុនសមុទ្រ អ្នកមានសេចក្តីប្រាថ្នាតិច អ្នកមិនលោភលន់ បុរសនោះ រមែងមិនក្តៅក្រហាយដោយកាមទាំងឡាយ។

[៩៤៣] បុគ្គលលះបង់នូវចំណែកនៃកាមទាំងឡាយណា ៗ សេចក្តីសុខក៏សម្រេច (ដល់បុគ្គលនោះ) ព្រោះចំណែកនៃកាមទាំងឡាយនោះ ៗ ដូចជាងស្បែក កាលកាត់ស្បែកជើង (តែងចៀរនូវចំនៀរ) នៃស្បែកចោល (ក៏បាននូវថ្លៃស្បែកជើង ឈ្មោះថា ជាអ្នកបានសេចក្តីសុខ) បើបុគ្គលប្រាថ្នានូវសេចក្តីសុខគ្រប់យ៉ាង ត្រូវលះកាមទាំងអស់ចេញ។

[៩៤៤] (ព្រះរាជា ទ្រង់ត្រាស់ថា) គាថាទាំងអស់ ៨ ដែលអ្នកពោលហើយ គួរដល់ថ្លៃ ១.០០០ កហាបណៈ ម្នាលមហាព្រហ្ម អ្នកចូរទទួលយក (នូវកហាបណៈទាំងនេះ) ចុះ ភាសិតរបស់អ្នកនេះ ប្រពៃណាស់។

[៩៤៥] (ព្រះមហាសត្វ...) ខ្ញុំព្រះអង្គមិនត្រូវការដោយកហាបណៈទាំងរយ ទាំងពាន់ ទាំងហ្មឺនទេ កាលដែលខ្ញុំព្រះអង្គកំពុងពោលគាថាខាងចុង ចិត្តរបស់ខ្ញុំព្រះអង្គ មិនត្រេកអរក្នុងកាមឡើយ។

[៩៤៦] (ព្រះរាជា....) អ្នកប្រាជ្ញណា កំណត់ដឹងនូវតណ្ហាដែលញ៉ាំងសេចក្តីទុក្ខឲ្យកើតឡើង អ្នកប្រាជ្ញនោះ គឺមាណពដ៏ចំរើន ដែលជាអ្នកដឹងនូវលោកទាំងមូលនេះទេតើ។

ចប់ កាមជាតក ទី៤។

## ជនសន្ធជាតក ទី៥

CS sut.kn.jat.468 | ភាគទី ៥៩

### (៤៦៨. ជនសន្ធជាតកំ (៥))

[៩៤៧] (ព្រះសាស្តា ទ្រង់ត្រាស់ថា) ព្រះបាទជនសន្ធៈ ទ្រង់មានព្រះឱង្ការថា បុគ្គលណា មិនបានធ្វើហេតុទាំង ១០ នេះ ទុកជាមុនទេ បុគ្គលនោះ តែងក្តៅក្រហាយ ក្នុងកាលជាខាងក្រោយ។

[៩៤៨] បុគ្គលមិនបានទ្រព្យ ដែលខ្លួនមិនបានឲ្យកើតឡើងក្នុងកាលមុន រមែងក្តៅក្រហាយ តែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អាត្មាអញមិនបានស្វែងរកទ្រព្យទុកក្នុងកាលមុន។

[៩៤៩] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា សិល្បៈ ជាគុណមានសភាពអង់អាច អាត្មាអញមិនបានរៀនទុកក្នុងកាលមុន ការចិញ្ចឹមជីវិតនៃបុគ្គលអ្នកមិនមានសិល្បៈ លំបាក។

[៩៥០] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា កាលពីដើម អាត្មាអញជាអ្នកប៉ិនប្រសប់ក្នុងអំពើកោងផង ជាអ្នកញុះញង់ផង ស៊ីសាច់ខ្នងគេ គឺស៊ីសំណូកផង ជាអ្នកកាចផង អាក្រក់ផង។

[៩៥១] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា កាលពីដើម អាត្មាអញជាអ្នកសំឡាប់សត្វផង កាចអាក្រក់ផង ជាអ្នកមិនប្រសើរផង មិនកោតក្រែងចំពោះពួកសត្វផង។

[៩៥២] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អើហ្ន៎ កាលដែលពួកស្ត្រីមានច្រើនគរគោក ជាស្ត្រីមិនមានអន្តរាយ (មិនមានគេកាន់កាប់សោះ) អាត្មាអញសេពនឹងប្រពន្ធគេ។

[៩៥៣] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អើហ្ន៎ កាលពីដើម អាត្មាអញមានបាយ និងទឹកច្រើនគរគោក តែមិនបានឲ្យទានសោះ។

[៩៥៤] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា កាលអាត្មាអញ មានទ្រព្យច្រើន មិនបានចិញ្ចឹមមាតា និងបិតាដែលចាស់ មានវ័យកន្លងហើយ។

[៩៥៥] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា អាត្មាអញ បានមើលងាយបិតា ដែលជាអាចារ្យ អ្នកប្រៀនប្រដៅ ជាអ្នកនាំមកនូវរសគ្រប់យ៉ាង។

[៩៥៦] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា ក្នុងកាលមុន អាត្មាអញមិនបានចូលទៅជិតពួកសមណៈ និងព្រាហ្មណ៍ អ្នកមានសីល ជាពហុស្សូតឡើយ។

[៩៥៧] បុគ្គលតែងក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយថា តបៈ គឺសុចរិតធម៌ ដែលគេសន្សំហើយផង បុគ្គលអ្នកស្ងប់ដែលគេចូលទៅអង្គុយជិតផង ជាការប្រពៃ តបៈ (មានសភាពយ៉ាងនេះ) អាត្មាអញ មិនបានសន្សំហើយ ក្នុងកាលពីដើម។

[៩៥៨] ចំណែកខាងបុគ្គលណា កាលធ្វើកិច្ចរបស់បុរសទាំងឡាយ ហើយប្រតិបត្តិនូវហេតុទាំងនេះដោយយោបល់ បុគ្គលនោះ រមែងមិនក្តៅក្រហាយរឿយ ៗ ក្នុងកាលជាខាងក្រោយឡើយ។

ចប់ ជនសន្ធជាតក ទី៥។

## មហាកណ្ហជាតក ទី៦

CS sut.kn.jat.469 | ភាគទី ៥៩

(៤៦៩. មហាកណ្ហជាតកំ (៦))

[៩៥៩] (ព្រះរាជា ត្រាស់សួរថា) ម្នាលអ្នកមានព្យាយាម ឆ្កែរបស់អ្នកខ្មៅណាស់ គួរស្ញើម មានចង្កូមសស្វាច អ្នកចងដោយខ្សែ ៥ តើវាមានប្រយោជន៍អ្វីដល់អ្នក។

[៩៦០] (សក្កទេវរាជ ពោលថា) បពិត្រព្រះបាទឧសិន្នរៈ ឆ្កែនេះ មិនមកដើម្បីប្រយោជន៍ដល់ពួកម្រឹគទេ ឆ្កែខ្មៅបំផ្លិចបំផ្លាញនូវពួកមនុស្សក្នុងកាលណា នឹងរបូតទៅ (អំពីដៃខ្ញុំ) ក្នុងកាលនោះ។

[៩៦១] ពួកសមណៈត្រងោល មានបាត្រក្នុងដៃ ឃ្លុំសង្ឃាដិ និងភ្ជួររាស់ដោយនង្គ័លទាំងឡាយ (ក្នុងកាលណា) ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវសមណៈទាំងនោះ) ក្នុងកាលនោះ។

[៩៦២] ពួកភិក្ខុនី មានតបៈ ជាអ្នកបួសត្រងោល ឃ្លុំសង្ឃាដិ នឹងទៅ (បរិភោគកាម) ក្នុងលោកក្នុងកាលណា ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវនាងភិក្ខុនីទាំងនោះ) ក្នុងកាលនោះ។

[៩៦៣] ពួកជដិល មានបបូរមាត់ខាងលើវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល នឹងទៅទារបំណុល (ក្នុងកាលណា) ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវជដិលទាំងនោះ) ក្នុងកាលនោះ។

[៩៦៤] ពួកព្រាហ្មណ៍ បានរៀនវេទទាំងឡាយផង សាវិត្តិសាស្ត្រផង យញ្ញសូត្រ ក្នុងសាវិត្តិសាស្ត្រនោះផង នឹងបូជាដើម្បីថ្លៃឈ្នួល (ក្នុងកាលណា) ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវព្រាហ្មណ៍ទាំងនោះ) ក្នុងកាលនោះ។

[៩៦៥] ពួកជនអ្នកមានទ្រព្យច្រើន នឹងមិនចិញ្ចឹមមាតាបិតាដែលជរា មានវ័យកន្លងហើយ (ក្នុងកាលណា) ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវជនអ្នកមានទ្រព្យទាំងនោះ) ក្នុងកាលនេះ។

[៩៦៦] ពួកជននឹងនិយាយទៅកាន់មាតាបិតាដែលជរា មានវ័យកន្លងហើយថា អ្នកទាំងឡាយ ជាមនុស្សពាលដូច្នេះ (ក្នុងកាលណា) ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវជនទាំងនោះ) ក្នុងកាលនោះ។

[៩៦៧] ពួកជនប្រព្រឹត្ត (សេវនកិច្ច) នឹងភរិយារបស់អាចារ្យ ភរិយារបស់សំឡាញ់ ម្តាយធំ ម្តាយមីងខាងម្តាយ ម្តាយធំ ម្តាយមីងខាងឪពុក ក្នុងលោក ក្នុងកាលណា ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវជនទាំងនោះ) ក្នុងកាលនោះ។

[៩៦៨] ពួកព្រាហ្មណ៍កាន់ដាវ និងខែល ងាព្រះខាន់ ធ្វើនូវការសំឡាប់នូវអ្នកដើរផ្លូវ ក្នុងកាលណា ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវពួកព្រាហ្មណ៍ទាំងនោះ) ក្នុងកាលនោះ។

[៩៦៩] ពួកបុរសមានស្បែកសម្បុរថ្ងៃសស្អាត មានដើមដៃថ្លោស មានអាជីវៈមិនប្រាកដ មានពំនៀរនឹងស្ត្រីមេម៉ាយ នឹងធ្វើនូវការបំបែកមិត្រ[12] (ក្នុងកាលណា) ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវបុរសនោះ) ក្នុងកាលនោះ។

[៩៧០] ពួកជនអ្នកមានមាយា ជាអ្នកបោកប្រាស់ មានគំនិតជាអសប្បុរស នឹងមានក្នុងលោក (ក្នុងកាលណា) ឆ្កែខ្មៅនឹងរបូត (ស្ទុះទៅស៊ីនូវជនមានមាយាទាំងនោះ) ក្នុងកាលនោះ។

ចប់ មហាកណ្ហជាតក ទី៦។

## កោសិយជាតក ទី៧

CS sut.kn.jat.470 | ភាគទី ៥៩

(៤៧០. កោសិយជាតកំ (៧))

[៩៧១] (កោសិយសេដ្ឋី ពោលថា) ខ្ញុំមិនទិញ មិនលក់ទេ ម្យ៉ាងទៀត ការសន្សំ (នូវទ្រព្យ) របស់ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ បាយនេះតិច មានសភាពក្រក្រៃពេក បាយអង្ករ ១ កំបង់នេះ មិនល្មមដល់ជនពីរនាក់ទេ។

[៩៧២] (សក្កទេវរាជ ពោលថា) បុគ្គលគប្បីឲ្យវត្ថុតិច អំពីវត្ថុតិច គប្បីឲ្យវត្ថុពាក់កណ្តាល អំពីវត្ថុពាក់កណ្តាល គប្បីឲ្យវត្ថុច្រើន អំពីវត្ថុច្រើន ការមិនឲ្យ មិនកើតទេ។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ។

[៩៧៣] (ចន្ទទេវបុត្រ ពោលថា) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា ឥតអំពើផង ការព្យាយាមញ៉ាំងទ្រព្យឲ្យកើតរបស់បុគ្គលនោះ ឈ្មោះថា ឥតអំពើផង។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ។

[៩៧៤] (សុរិយទេវបុត្រ ពោលថា) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា សច្ចៈផង ការព្យាយាមញ៉ាំងទ្រព្យឲ្យកើត របស់បុគ្គលនោះ ឈ្មោះថា សច្ចៈផង។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ។

[៩៧៥] (មាតលិទេវបុត្រ ពោលថា) បុរស (ចូលទៅរក) ស្រះ ហើយបូជាក្នុងទន្លេផង ក្នុងស្រះបោក្ខរណីផង ក្នុងកំពង់ឈ្មោះទោណៈផង ក្នុងកំពង់ឈ្មោះតិម្ពរុផង ក្នុងស្ទឹងធំមានខ្សែទឹកដ៏រហ័សផង។ បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ មិនបរិភោគភោជនតែម្នាក់ឯង ការបូជារបស់បុគ្គលនោះ ឈ្មោះថា មានក្នុងទីនោះផង ការព្យាយាមញ៉ាំងទ្រព្យឲ្យកើត របស់បុគ្គលនោះ ឈ្មោះថា មានក្នុងទីនោះផង។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ។

[៩៧៦] (បញ្ចសិខទេវបុត្រ ពោលថា) បុគ្គលណា កាលដែលភ្ញៀវអង្គុយហើយ បរិភោគភោជនតែម្នាក់ឯង បុគ្គលនោះ ឈ្មោះថា លេបនូវសន្ទូចមានខ្សែវែង ព្រមទាំងរនង។ ម្នាលកោសិយសេដ្ឋី ហេតុនោះ ខ្ញុំសូមនិយាយនឹងអ្នក អ្នកចូរឲ្យទានទាំងឡាយផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គផង បុគ្គលស៊ីម្នាក់ឯង មិនបានសេចក្តីសុខទេ។

[៩៧៧] (កោសិយសេដ្ឋី...) ឱហ្ន៎ ព្រាហ្មណ៍ទាំងនេះ មានវណ្ណៈដ៏លើសលុប ទាំងឆ្កែរបស់ពួកគាត់នេះ ក៏បញ្ចេញនូវពន្លឺនៃវណ្ណៈផ្សេង ៗ តើព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយ ចូរប្រាប់ដល់យើងចុះ តើពួកអ្នកជាអ្វី។

[៩៧៨] (សក្កទេវរាជ...) ទេវបុត្រទាំងពីរអង្គ គឺចន្ទទេវបុត្រ ១ សុរិយទេវបុត្រ ១ មកក្នុងទីនេះ ឯទេវបុត្រនេះ ឈ្មោះមាតលិ ជាសារថីរបស់ទេវតា យើងឈ្មោះសក្កៈ ជាធំជាងពួកទេវតាជាន់ត្រៃត្រិង្ស ឯទេវបុត្រនេះ គេហៅថា បញ្ចសិខៈ។

[៩៧៩] សំឡេងទះដៃទាំងឡាយផង សម្ភោរតូចទាំងឡាយផង សម្ភោរធំ និងស្គរធំទាំងឡាយផង រមែងញ៉ាំងបញ្ចសិខទេវបុត្រនេះ ដែលដេកលក់ ឲ្យភ្ញាក់ឡើង ឯបញ្ចសិខទេវបុត្រនេះ លុះភ្ញាក់ហើយក៏ត្រេកអរ។

[៩៨០] ពួកជនណានីមួយ ជាអ្នកកំណាញ់ស្វិតស្វាញ ប្រទេចផ្តាសានូវសមណៈ និងព្រាហ្មណ៍ទាំងឡាយ លុះទំលាក់ចោលនូវរាងកាយ គឺសរីរៈ ក្នុងលោកនេះ បែកធ្លាយរាងកាយហើយ ក៏ទៅកាន់នរក។

[៩៨១] ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិ ឋិតនៅក្នុងធម៌ ក្នុងសេចក្តីសង្រួម ក្នុងការចែករំលែក លុះទំលាក់ចោលរាងកាយ គឺសរីរៈ ក្នុងលោកនេះ បែកធ្លាយរាងកាយហើយ ក៏ទៅកាន់សុគតិ។

[៩៨២] អ្នកជាញាតិរបស់ពួកយើងក្នុងជាតិមុន អ្នកនោះ ឈ្មោះកោសិយៈ ជាអ្នកមានសេចក្តីកំណាញ់ មានធម៌ដ៏លាមក ពួកយើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់អ្នក (ដោយគិតថា) កុំឲ្យអ្នកមានធម៌ដ៏លាមក ទៅកាន់នរកឡើយ។

[៩៨៣] (កោសិយសេដ្ឋី...) ពួកលោកឈ្មោះថា ប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយពិត ព្រោះពួកលោកបានប្រៀនប្រដៅខ្ញុំ ខ្ញុំនោះនឹងធ្វើតាមពាក្យទាំងអស់ដែលពួកលោកជាអ្នកប្រាថ្នានូវប្រយោជន៍ បានពោល (រំលឹក) ហើយ ដោយបការៈដូច្នោះ។ ខ្ញុំនេះនឹងវៀរលែង (ចាកសេចក្តីកំណាញ់) នេះឯង ខ្ញុំនឹងឈប់ធ្វើបាបតិចតួចហើយ ទាំងវត្ថុតិចតួចដែលខ្ញុំមិនគប្បីឲ្យ មិនមាន ខ្ញុំបើមិនបានឲ្យទានទឹក នឹងមិនផឹកឡើយ។ បពិត្រវាសវៈ កាលបើខ្ញុំឲ្យទាន អស់កាលទាំងពួងយ៉ាងនេះ ភោគៈទាំងឡាយ ក្នុងទីនេះនឹងអស់ទៅ បពិត្រសក្កៈ តពីនោះទៅ ខ្ញុំនឹងលះបង់កាមទាំងឡាយ តាមសមគួរដល់ចំណែក ហើយនឹងបួស។

ចប់ កោសិយជាតក ទី៧។

## មេណ្ឌកបញ្ហាជាតក ទី៨

CS sut.kn.jat.471 | ភាគទី ៥៩

(៤៧១. មេណ្ឌកបញ្ហជាតកំ (៨))

[៩៨៤] (ព្រះបាទវិទេហរាស្ត្រ ទ្រង់ត្រាស់សួរពួកអ្នកប្រាជ្ញថា) តាំងពីកាលណាមកក្នុងលោកនេះ មិនធ្លាប់មានពួកសត្វណាមានជើង ៧[20] យកគ្នាជាសំឡាញ់ឡើយ សត្វទាំងពីរនោះ ជាសត្រូវនឹងគ្នាទេ (តែឥឡូវ) ត្រឡប់ជាយកគ្នាធ្វើជាសំឡាញ់ ប្រព្រឹត្តរាប់អានគ្នា តើព្រោះហេតុដូចម្តេច។

[៩៨៥] ប្រសិនបើអ្នកទាំងឡាយ មិនអាចដោះប្រស្នាយើងនុ៎ះ ក្នុងពេលបាយព្រឹក ក្នុងថ្ងៃនេះបានទេ យើងនឹងបំបរបង់អ្នកទាំងអស់គ្នា

អំពីដែន ព្រោះយើងមិនត្រូវការនឹងពួកមនុស្សឥតប្រាជ្ញាឡើយ។

[៩៨៦] (អាចារ្យសេនកៈ បែរមើលទៅពោធិសត្វ ហើយក្រាបទូលព្រះបាទវិទេហរាស្ត្រថា) កាលបើមានការប្រជុំនៃមហាជន គគ្រឹកគគ្រេង កាលបើមានការជួបជុំរដើបរដួលនៃជន កើតឡើងហើយ (យ៉ាងនេះ) យើងខ្ញុំមានចិត្តរវើរវាយ មានចិត្តមិននឹងនៅក្នុងអារម្មណ៍តែមួយ មិនអាចឆ្លើយប្រស្នានុ៎ះបានទេ។

[៩៨៧] បពិត្រព្រះបាទជនិន្ទាធិរាជ អ្នកប្រាជ្ញទាំងឡាយ ម្នាក់ ៗ មានចិត្តតាំងនៅក្នុងអារម្មណ៍តែមួយ ទៅក្នុងទីស្ងាត់ហើយ គិតនូវសេចក្តីទាំងឡាយ ពិចារណានូវកាយវិវេក និងចិត្តវិវេក ទើបក្រាបទូលសេចក្តីនុ៎ះ ក្នុងកាលជាខាងក្រោយបាន។

[៩៨៨] (អាចារ្យសេនកៈ ក្រាបទូលថា) សាច់ពពែ ជាទីពេញចិត្ត ជាទីគាប់ចិត្តរបស់កូនអាមាត្យ និងព្រះរាជបុត្រទាំងឡាយ ពួកកូនអាមាត្យ និងព្រះរាជបុត្រទាំងនោះ មិនបរិភោគសាច់ឆ្កែទេ បានជាពពែ និងឆ្កែ យកគ្នាជាសំឡាញ់។

[៩៨៩] (អាចារ្យបុក្កុសៈ ទូលថា) ពួកជនតែងពន្លះស្បែកពពែ សម្រាប់ក្រាលលើខ្នងសេះ ព្រោះហេតុចង់ឲ្យស្រួល តែពួកជនទាំងនោះមិនក្រាលស្បែកឆ្កែទេ បានជាពពែ និងឆ្កែ យកគ្នាជាសំឡាញ់។

[៩៩០] (អាចារ្យកាមិន្ទ ទូលថា) ពពែមានស្នែងជារង្វង់ ឯឆ្កែគ្មានស្នែងទេ ពពែស៊ីស្មៅ ឆ្កែស៊ីសាច់ បានជាពពែ និងឆ្កែយកគ្នាជាសំឡាញ់។

[៩៩១] (អាចារ្យទេវិន្ទ ទូលថា) ពពែស៊ីស្មៅ ស៊ីស្លឹកឈើ ឯឆ្កែមិនស៊ីស្មៅ មិនស៊ីស្លឹកឈើទេ ឆ្កែខាំតែទន្សាយ និងសំពោច បានជាពពែ និងឆ្កែ យកគ្នាជាសំឡាញ់។

[៩៩២] (ព្រះមហោសធ ទូលថា) សត្វជើង ៧ កន្លះ គឺឆ្កែមានជើងបីកន្លះ ពពែមានជើង ៤ មានក្រចក ៨ បន្តំលួចសាច់ ឯឆ្កែនេះ លួច (ស្មៅ) ឲ្យពពែនេះ ពពែនេះ លួចសាច់ឲ្យឆ្កែឯនោះ។

[៩៩៣] ឮថា ព្រះបាទវិទេហរាស្ត្រ ជាស្តេចដ៏ប្រសើរ ជាធំជាងជន ស្តេចគង់នៅលើប្រាសាទដ៏ប្រសើរ ទ្រង់ទតឃើញជាក់ច្បាស់នូវការផ្លាស់ប្តូរភោជនដល់គ្នានឹងគ្នានុ៎ះ របស់ឆ្កែ និងពពែ ដែលដើរទៅលួចអាហារពេញមាត់ មកឲ្យគ្នាបរិភោគ។

[៩៩៤] (ព្រះបាទវិទេហរាស្ត្រ ទ្រង់មានព្រះរាជឱង្ការថា) យើងហៅពេញជាមានលាភ មានសភាពមិនតិចទេ ព្រោះអ្នកប្រាជ្ញទាំងឡាយបែបនេះ មាននៅក្នុងត្រកូលរបស់យើង អ្នកប្រាជ្ញទាំងនេះ យល់អាថ៌ប្រស្នាដ៏ជ្រាលជ្រៅល្អិត ដោយសុភាសិតបាន។

[៩៩៥] យើងមានចិត្តត្រេកអរដ៏ក្រៃលែង យើងឲ្យសេះអស្សតរ និងរថមួយ ៗ ម្នាក់ ឲ្យស្រុកសួយដែលបរិបូណ៌មួយ ៗ ម្នាក់ ដល់អ្នកទាំងអស់គ្នា ជាអ្នកប្រាជ្ញ ព្រោះសុភាសិត។

ចប់ មេណ្ឌកបញ្ហាជាតក ទី៨។

## មហាបទុមជាតក ទី៩

CS sut.kn.jat.472 | ភាគទី ៥៩

### (៤៧២. មហាបទុមជាតកំ (៩))

[៩៩៦] (ពួកជន ក្រាបទូលថា) ព្រះរាជាជាឥស្សរៈ បើមិនទាន់ឃើញទោសតូចធំ ដោយសព្វគ្រប់ អំពីសំណាក់បុគ្គលដទៃ ទាំងមិនទាន់ពិចារណាឲ្យឃើញច្បាស់ដោយខ្លួនឯងទេ មិនគប្បីដាក់អាជ្ញាឡើយ។

[៩៩៧] បើក្សត្រិយ៍ណា មិនទាន់ពិចារណា ហើយធ្វើអាជ្ញា ក្សត្រិយ៍នោះ ឈ្មោះថា លេបភោជនប្រកបដោយបន្លា ប្រកបដោយរុយ ដូចជាមនុស្សខ្វាក់។

[៩៩៨] ព្រះរាជាណា ដាក់អាជ្ញាដល់បុគ្គលដែលមិនគួរដាក់អាជ្ញា មិនដាក់អាជ្ញាដល់បុគ្គលដែលគួរដាក់អាជ្ញា ព្រះរាជានោះ ឈ្មោះថាមិនដឹងការស្មើ និងមិនស្មើ ដូចជាមនុស្សខ្វាក់ ដើរតាមផ្លូវមិនរាបស្មើ។

[៩៩៩] ព្រះរាជាណា ឃើញនូវហេតុទាំងឡាយតូច និងធំនុ៎ះ ដោយសព្វគ្រប់ ជាហេតុដែលឃើញត្រឹមត្រូវហើយ សឹមប្រៀនប្រដៅព្រះរាជានោះ ទើបគួរហៅថា ព្រះរាជាបាន។

[១០០០] ព្រះរាជា ដែលមានព្រះទ័យទន់ពេក មានព្រះទ័យរឹងពេក ក៏មិនអាចតាំងខ្លួន ក្នុងភាពជាធំបានទេ ហេតុនោះ ព្រះរាជាគួរប្រព្រឹត្តនូវហេតុទាំងពីរ។

[១០០១] (ព្រោះ) ព្រះរាជា ដែលមានព្រះទ័យទន់ ត្រូវពួករាស្ត្រមើលងាយ ឯព្រះរាជាមានព្រះទ័យរឹងពេក រមែងមានពៀរ ព្រះរាជាជ្រាបហេតុទាំងពីរនោះហើយ ត្រូវប្រព្រឹត្តជាកណ្តាល។

[១០០២] បុគ្គលត្រេកអរហើយ និយាយច្រើនក៏មាន បុគ្គលខឹងហើយ និយាយច្រើក៏មាន បពិត្រមហារាជ ព្រះអង្គមិនគួរសម្លាប់ព្រះរាជបុត្រ ព្រោះហេតុតែស្ត្រីទេ។

[១០០៣] (ព្រះរាជា...) មនុស្សលោកទាំងអស់ (ជាបក្សពួកខាងកុមារ) ឯស្ត្រីនេះតែម្នាក់ឯងទេ ព្រោះហេតុនោះ យើងនឹងប្រតិបត្តិ (តាមពាក្យនាងនេះវិញ) អ្នកឯងចូរទៅទម្លាក់វា (ក្នុងជ្រោះភ្នំទៅ)។

[១០០៤] យើងជាបិតា បានឲ្យគេយកកូនឯង ទៅបោះក្នុងជ្រោះភ្នំដ៏ជ្រៅ ច្រើនជួរត្នោត មិនងាយឡើងមករួចទេ ហេតុអ្វីបានជាកូនឯងមិនស្លាប់ក្នុងជ្រោះនោះ។

[១០០៥] (មហាបទុមតាបសថា...) ក្នុងវេលានោះ នាគរាជមានកំឡាំងដ៏ខ្លាំងពូកែ អាស្រ័យនៅនឹងភ្នំ បានទទួលទ្រអាត្មាភាពដោយភ្នែនទាំងឡាយ ហេតុនោះ បានជាអាត្មាភាព មិនស្លាប់ក្នុងជ្រោះនោះ។

[១០០៦] (ព្រះរាជា...) ម្នាលរាជបុត្រ សូមលោកនិមន្តមក យើងនឹងនាំលោកទៅកាន់ផ្ទះរបស់ខ្លួនវិញ ម្នាលលោកដ៏ចំរើន សូមលោកគ្រប់គ្រងរាជសម្បត្តិចុះ លោកនៅធ្វើអ្វីក្នុងព្រៃ។

[១០០៧] (មហាបទុមតាបស...) បុគ្គលលេបផ្លែសន្ទូច ហើយទាញចេញមក លុះទាញចេញមក ព្រមទាំងឈាម គប្បីជាសុខយ៉ាងណា អាត្មាភាពឃើញច្បាស់ដោយខ្លួនឯង ក៏យ៉ាងនោះដែរ។

[១០០៨] (ព្រះរាជា...) លោកពោលថា អ្វីជាផ្លែសន្ទូច លោកពោលថា អ្វីជាឈាម លោកពោលថា អ្វីទាញចេញមក កាលបើយើងសួរហើយ លោកចូរប្រាប់រឿងនោះ។

[១០០៩] (មហាបទុមតាបស...) អាត្មាភាព ពោលនូវកាមថាជាផ្លែសន្ទូច ពោលនូវដំរី និងសេះថាជាឈាម ពោលនូវការលះចោល ថាជាគ្រឿងទាញចេញមក បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ។

[១០១០] (ប្រជុំជាតក) មាតាចុងនៃតថាគត គឺនាងចិញ្ចមាណវិកា បិតាតថាគត គឺទេវទត្ត នាគរាជ គឺអានន្ទជាអ្នកប្រាជ្ញ ទេវតា គឺសារីបុត្រ រាជបុត្រ ក្នុងកាលនោះ គឺតថាគត អ្នកទាំងឡាយ ចូរចាំទុកនូវជាតកដោយប្រការយ៉ាងនេះចុះ។

ចប់ មហាបទុមជាតក ទី៩។

## មិត្តាមិត្តជាតក ទី១០

CS sut.kn.jat.473 | ភាគទី ៥៩

(៤៧៣. មិត្តាមិត្តជាតកំ (១០))

[១០១១] (ព្រះបាទព្រហ្មទត្ត សួរមហាសត្វថា) បណ្ឌិតអ្នកមានប្រាជ្ញា ឃើញ ឬឮពួកជន កំពុងធ្វើនូវអំពើអ្វី ៗ គប្បីដឹងថា ជាអមិត្របាន តើវិញ្ញូជន គប្បីព្យាយាមដូចម្តេច។

[១០១២] (ព្រះមហាសត្វ សំដែងនូវលក្ខណៈនៃបុគ្គលជាសត្រូវនោះថា) បុគ្គលជាសត្រូវ ឃើញបុគ្គលនោះហើយ មិនញញឹម ១ មិនទទួលត្រេកអរនឹងសំដីបុគ្គលនោះ ១ មិនឲ្យភ្នែកដល់បុគ្គលនោះ ១ ប្រព្រឹត្តទទឹងទាស់ ១។

[១០១៣] បុគ្គលអែបអបនឹងពួកសត្រូវ របស់បុគ្គលនោះ ១ មិនសេពគប់នឹងពួកមិត្ររបស់បុគ្គលនោះ ១ រារាំងពួកជនអ្នកនិយាយសរសើរ ១ សរសើរពួកជនអ្នកជេរ ១។

[១០១៤] មិនប្រាប់សេចក្តីកំបាំង ដល់បុគ្គលនោះ ១ មិនលាក់សេចក្តីកំបាំងរបស់បុគ្គលនោះ ១ មិនសរសើរការងាររបស់បុគ្គលនោះ ១ មិនសរសើរប្រាជ្ញារបស់បុគ្គលនោះ ១។

[១០១៥] ត្រេកអរនឹងសេចក្តីវិនាសរបស់បុគ្គលនោះ ១ មិនត្រេកអរនឹងសេចក្តីចំរើនរបស់បុគ្គលនោះ ១ បានភោជនចំឡែក មិននឹកនាដល់បុគ្គលនោះ ១ មិនអនុគ្រោះបុគ្គលនោះ អំពីរបស់នោះថា ឱមិត្រនោះ គប្បីបានរបស់នេះខ្លះ ១។

[១០១៦] បណ្ឌិតឃើញ ឬឮ ហើយស្គាល់ថា ជាអមិត្របាន ដោយអាការទាំង ១៦ នេះ ដែលដំកល់នៅក្នុងអមិត្រដោយប្រការៈដូច្នេះ។

[១០១៧] (ព្រះបាទព្រហ្មទត្ត...) បណ្ឌិតអ្នកមានប្រាជ្ញា ឃើញ ឬឮពួកជន កំពុងធ្វើការងារអ្វី ៗ គប្បីដឹងថា ជាមិត្របាន តើវិញ្ញូជន គប្បីព្យាយាមដូចម្តេច។

[១០១៨] (មហាសត្វ...) បុគ្គលជាមិត្រ តែងនឹករលឹកដល់មិត្រដែលនៅបែកគ្នា ១ ត្រេកអរនឹងមិត្រដែលមកដល់ ១ ជាអ្នករាប់អានចំពោះមិត្រនោះ ១ ទទួលរីករាយដោយវាចា ១។

[១០១៩] គប់រកនឹងពួកមិត្ររបស់មិត្រនោះ ១ មិនសេពគប់នឹងពួកអមិត្ររបស់មិត្រនោះ ១ ហាមឃាត់នូវពួកអ្នកជេរ ១ សរសើរពួកជនដែលនិយាយសរសើរ ១។

[១០២០] ប្រាប់សេចក្តីកំបាំងដល់មិត្រនោះ ១ បិទបាំងសេចក្តីកំបាំងរបស់មិត្រនោះ ១ សរសើរការងាររបស់មិត្រនោះ ១ សរសើរប្រាជ្ញារបស់មិត្រនោះ ១។

[១០២១] ត្រេកអរនឹងសេចក្តីចំរើនរបស់មិត្រនោះ ១ មិនត្រេកអរនឹងសេចក្តីវិនាសរបស់មិត្រនោះ ១ បានភោជនចំឡែក តែងនឹកនាដល់មិត្រនោះ ១ អនុគ្រោះមិត្រនោះអំពីរបស់នោះថា ឱមិត្រនោះ គប្បីបានរបស់នេះខ្លះ ១។

[១០២២] បណ្ឌិតឃើញ ឬឮហើយ ស្គាល់ថាជាមិត្រ ដោយអាការទាំង ១៦ នេះ ដែលដំកល់នៅក្នុងមិត្រដោយបការៈដូច្នេះ។

ចប់ មិត្តាមិត្តជាតក ទី១០។

ឧទ្ទាននៃទ្វាទសនិបាតនោះគឺ

និយាយអំពីស្ត្រីចិត្តស្រាល ១ រុក្ខទេវតាឈ្មោះភទ្ទសាល ១ ពួកជនក្លួររាស់ ១ កាម ១ ហេតុ ១០ យ៉ាង ១ ផ្លែខ្មៅ ១ កោសិយសេដ្ឋី ១ ពពែដ៏ប្រសើរ ១ មហាបទុមកុមារ ១ មិត្រដ៏ប្រសើរ ១ រួមត្រូវជា ១០។

ចប់ ទ្វាទសនិបាត។

# តេរសនិបាតជាតក

CS sut.kn.jat.v13 | ភាគទី ៥៩

(១៣. តេរសកនិបាតោ)

## អម្ពជាតក ទី១

CS sut.kn.jat.474 | ភាគទី ៥៩

### (៤៧៤. អម្ពជាតកំ (១))

[១០២៣] (ព្រះបាទពារាណសី ត្រាស់សួរថា) នែអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កាលពីដើម អ្នកបានយកផ្លែស្វាយទាំងឡាយ តូចក៏មាន ធំក៏មាន មកឲ្យយើង នែព្រាហ្មណ៍ ឥឡូវនេះ ផ្លែឈើទាំងឡាយ មិនកើតប្រាកដដោយមន្តទាំងឡាយរបស់អ្នកនោះ។

[១០២៤] (ព្រាហ្មណ៍មាណព ក្រាបទូលថា) ខ្ញុំព្រះអង្គរាប់អាន នូវការប្រកបនូវនក្ខត្តឫក្ស ខ្ញុំព្រះអង្គមើលឃើញដោយមន្តតែមួយពេល មួយស្របក់ ខ្ញុំព្រះអង្គបាននូវការប្រកបនូវនក្ខត្តឫក្ស និងពេលហើយ សឹមខ្ញុំព្រះអង្គនាំយកផ្លែស្វាយឲ្យបានច្រើន មកថ្វាយព្រះអង្គពុំខានឡើយ។

[១០២៥] (ព្រះរាជា....) កាលពីដើម អ្នកមិនបាននិយាយអាងនូវការប្រកបនូវនក្ខត្តឫក្ស ពីដើមមិនឃើញរកពេល រកស្របក់ តែអ្នកបាន យកផ្លែស្វាយដ៏ច្រើន ដែលបរិបូណ៌ដោយពណ៌ ដោយក្លិន ដោយរស (មកឲ្យយើង)។

[១០២៦] នែព្រាហ្មណ៍ កាលពីដើម ផ្លែឈើទាំងឡាយ រមែងកើតប្រាកដដោយការសូធ្យសែកមន្តរបស់អ្នក ថ្ងៃនេះ អ្នកមិន សូធ្យសែកមន្ត តើធម្មតារបស់អ្នកក្នុងថ្ងៃនេះដូចម្តេច។

[១០២៧] (មាណព...) កូនចណ្ឌាលបានឲ្យមន្តទាំងឡាយដល់ខ្ញុំព្រះអង្គដោយធម៌ ទាំងបាននិយាយប្រាប់នូវប្រក្រតី គឺសេចក្តីវិនាសនៃ មន្តទាំងឡាយថា បើមានគេសួរអ្នកកុំលាក់នាម និងគោត្ររបស់ខ្ញុំ កុំឲ្យមន្តលះបង់អ្នកបាន។

[១០២៨] ខ្ញុំព្រះអង្គដែលព្រះជនិន្ទ្រាធិរាជសួរ ក្នុងប្រជុំជននោះ មានសេចក្តីលុបគុណគេគ្របសង្កត់ បានក្រាបទូលពាក្យកុហក ជាពាក្យខុសថា មន្តទាំងឡាយនេះ ជារបស់ព្រាហ្មណ៍ ខ្ញុំព្រះអង្គមានមន្តសាបសូន្យ ជាបុគ្គលកំព្រាយំទួញ។

[១០២៩] (ព្រះរាជា...) បុរសអ្នកត្រូវការដោយទឹកឃ្មុំ ទោះបានទឹកឃ្មុំអំពីដើមល្ហុងខ្វែរក្តី អំពីដើមស្តៅក្តី ឬក៏អំពីដើមរលួសបាយក្តី ឯដើមឈើនោះ ឈ្មោះថា ជាឈើដ៏ប្រសើររបស់បុរសនោះ។

[១០៣០] បុគ្គលចេះដឹងធម៌អំពីជនណា ទោះក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី អ្នកជំនួញក្តី អ្នកគ្រូក្តី ចណ្ឌាលក្តី អ្នកចោលសំរាមក្តី ជននោះ ឈ្មោះថា ជាជនដ៏ប្រសើររបស់បុគ្គលនោះ។

[១០៣១] បុរសណា ញ៉ាំងប្រយោជន៍ដ៏ឧត្តមដែលខ្លួនបានមកហើយដោយលំបាក ឲ្យវិនាសទៅ ដោយមានះ និងអតិមានះ អ្នកទាំង ឡាយ ចូរឲ្យនូវអាជ្ញាផង នូវការសម្លាប់ផង ដល់ជនអាក្រក់នេះ ហើយចាប់បុរសដ៏លាមកនេះ ត្រង់ក ហើយញាំញី។

[១០៣២] (មាណព...) បុរសស្មានថា (ទីនេះ) រាបស្មើ ក៏លោតទៅកាន់ត្រពាំង គុហា ជ្រោះ និងឈើមានឫសស្អុយក្តី ដើរជាន់ លើពស់វែក ដោយស្មានថា ខ្សែក្តី បុគ្គលខ្វាក់ដើរជាន់ភ្លើងក្តី យ៉ាងណា ៗ បពិត្រលោកប្រកបដោយប្រាជ្ញា សូមលោក (អត់ទោស) ចំពោះខ្ញុំ ដែលជាអ្នកភ្លាំងភ្លាត់ យ៉ាងនោះ ៗ ដែរ ហើយចែកមន្តឲ្យខ្ញុំ ដែលជាអ្នកមានមន្តសាបរលាបអស់ហើយ ម្តងទៀត។

[១០៣៣] (ពោធិសត្វ...) យើងបានឲ្យមន្តទាំងឡាយ ដល់អ្នកដោយធម៌ហើយ គឺមិនយករង្វាន់អ្វីឡើយ ទាំងអ្នកក៏បានទទួលរៀន យកមន្តដោយធម៌ហើយដែរ យើងមានចិត្តត្រេកអរ បានទាំងប្រាប់នូវប្រក្រតី (នៃមន្ត) ដល់អ្នកហើយ បើអ្នកតាំងនៅក្នុងធម៌ មន្តមិន លះបង់អ្នកបានទេ។

[១០៣៤] ម្នាលបុគ្គលពាល អ្នកនោះ ធ្វើមន្តដែលខ្លួនបានហើយដោយលំបាក បានមកដោយកម្រ ក្នុងមនុស្សលោក ឲ្យវិនាសទៅ ក្នុងថ្ងៃនេះ អ្នកនោះ ជាអ្នកឥតប្រាជ្ញា ពោលពាក្យកុហក ឈ្មោះថា ញ៉ាំងជីវិតដែលខ្លួនបានដោយកម្រ ឲ្យវិនាស។

[១០៣៥] យើងមិនឲ្យមន្តទាំងឡាយបែបនោះ ដល់មនុស្សល្ងង់ខ្លៅវង្វេង ជាអកតញ្ញូ ពោលពាក្យកុហក មិនសង្រួម ឯមន្តទាំងឡាយ មានមកពីណាទៀត អ្នកឯងចូរចេញទៅ អ្នកឯងមិនគាប់ចិត្តយើងទេ។

ចប់ អម្ពជាតក ទី១។

## ជន្ទនជាតក ទី២

CS sut.kn.jat.475 | ភាគទី ៥៩

### (៤៧៥. ផន្ទនជាតកំ (២))

[១០៣៦] (កាឡសីហៈ សួរថា) អ្នកជាបុរសមានដឹងក្នុងដៃ ចូលមកឈរនៅក្នុងព្រៃ នែសំឡាញ់ ខ្ញុំសួរហើយ ចូរអ្នកប្រាប់ តើអ្នក ចង់កាប់ឈើអ្វី។

[១០៣៧] (វឌ្ឍកីព្រាហ្មណ៍ តបថា) អ្នកជាកាឡសីហៈ ត្រាច់ទៅកាន់ព្រៃស្មើ និងមិនស្មើ ម្នាលសំឡាញ់ ខ្ញុំសួរហើយ អ្នកចូរប្រាប់ ឈើអ្វី ធ្វើខ្នងកង់ជាប់មាំ។

[១០៣៨] (កាឡសីហៈ...) ដើមរាំងក៏មិនជាប់ ដើមគគីរក៏មិនជាប់ ដើមត្រចៀកប្រើសក៏មិនជាប់ ដើមត្របែកក៏មិនជាប់ មានតែដើមពង្រ ឈើនោះ ធ្វើកង់រទេះជាប់មាំ។

[១០៣៩] (វឌ្ឍកី...) ស្លឹកពង្រនោះ បែបដូចម្តេច ដើមពង្រនោះ បែបដូចម្តេច ម្នាលសម្លាញ់ យើងសួរហើយ អ្នកចូរប្រាប់ យើងគប្បី ស្គាល់ដើមពង្រ យ៉ាងណា។

[១៩៤០] (កាឡសីហៈ....) មែកឈើណា សំយុងចុះផង មិនទន់ទោរផង មិនបាក់ផង ខ្ញុំឈរក្បែរគល់ឈើណា ឈើនោះហើយ

ជាដើមពង្រ។

[១០៤១] ដើមពង្រនេះ គួរដល់ការងាររបស់អ្នក ដើម្បីការទេះទាំងឡាយ ដើម្បីកង់ និងដុំរទេះទាំងឡាយ ដើម្បីចន្ទោលរទេះ និងខ្នងកង់រទេះ និងរបស់សព្វគ្រប់ ក្រៅពីនេះទាំងអស់។

[១០៤២] (អភិសម្ពុទ្ធគាថា) ព្រោះហេតុនោះ ទេវតាអាស្រ័យនៅលើដើមពង្រ បាននិយាយថា ពាក្យរបស់ខ្ញុំក៏មានដែរ ម្នាលភារទ្វាជព្រាហ្មណ៍ អ្នកឯងចូរស្តាប់ពាក្យខ្ញុំសិន។

[១០៤៣] អ្នកចូរអារយកស្បែកខ្លាឃ្មុំនេះ ត្រង់ក ចំនួន ៤ ធ្នាប់ ហើយយកស្បែកនោះមកទ្រាប់ខ្នងកង់រទេះ ធ្វើយ៉ាងនេះ ទើបជាប់មាំមួន។

[១០៤៤] ទេវតាដែលអាស្រ័យនៅលើដើមពង្រ បានសម្រេចពៀរហើយ បាននាំយកសេចក្តីទុក្ខមកឲ្យ ដល់ខ្លាឃ្មុំទាំងឡាយ ដែលកើតហើយផង ដែលមិនទាន់កើតហើយផង ដោយប្រការដូច្នេះ។

[១០៤៥] ដើមពង្រចងពៀរនឹងខ្លាឃ្មុំ ឯខ្លាឃ្មុំចងពៀរនឹងដើមពង្រ ហើយបានសម្លាប់គ្នាទៅវិញទៅមក ដោយការទាស់ទែងគ្នាទៅវិញទៅមក ដោយប្រការដូច្នេះឯង។

[១០៤៦] ខ្លាឃ្មុំ និងដើមពង្រនោះ ចងពៀរវេរាយ៉ាងណា ការទាស់ទែងរបស់មនុស្សទាំងឡាយ កើតមានក្នុងទីណា មនុស្សទាំងនោះ ឈ្មោះថា រាំដូចជាក្ងោកពង់[21] ក្នុងទីនោះ ក៏យ៉ាងនោះដែរ។

[១០៤៧] តថាគតនឹងសំដែងនូវហេតុនោះ ថ្វាយមហារាជ ពួកមនុស្ស ដែលមកប្រជុំក្នុងទីនេះ មានចំនួនប៉ុន្មាន សូមសេចក្តីចំរើនមានដល់មហាបពិត្រ មានចំនួនប៉ុណ្ណោះ សូមមហាបពិត្រ ព្រមព្រៀងគ្នា កុំទាស់ទែងគ្នា កុំឲ្យដូចខ្លាឃ្មុំ និងដើមពង្រឡើយ។

[១០៤៨] សូមមហាបពិត្រ សិក្សានូវសេចក្តីព្រមព្រៀងគ្នាតែម្យ៉ាង ព្រោះសេចក្តីព្រមព្រៀងគ្នានោះ ព្រះពុទ្ធទាំងឡាយ សរសើរហើយ បុគ្គលអ្នកត្រេកអរក្នុងសេចក្តីព្រមព្រៀងគ្នា អ្នកតាំងនៅក្នុងធម៌ រមែងមិនសាបសូន្យចាកព្រះនិព្វានជាទីក្សេម ចាកយោគៈទាំងឡាយឡើយ។

ចប់ ផន្ទនជាតក ទី២។

## ជវនហំសជាតក ទី៣

CS sut.kn.jat.476 | ភាគទី ៥៩

(៤៧៦. ជវនហំសជាតកំ (៣))

[១០៤៩] (ព្រះបាទពារាណសី មានព្រះរាជឱង្ការថា) នែហង្ស ឯងចូរទំលើតាំងមាសនេះចុះ ការឃើញឯង ជាទីពេញចិត្តរបស់អញ ឯងសមគួរជាធំហើយ របស់ណាមានក្នុងទីនេះ ឯងចូរប្រាប់មកចុះ។

[១០៥០] (រាជហង្ស...) បុគ្គលខ្លះ គ្រាន់តែឮហើយស្រឡាញ់ ក៏មាន ខ្លះគ្រាន់តែឃើញគ្នាហើយ អស់សេចក្តីស្រឡាញ់ក៏មាន ខ្លះឃើញផង ឮផង ទើបស្រឡាញ់ក៏មាន ចុះព្រះអង្គគ្រាន់តែឃើញ តើស្រឡាញ់ខ្ញុំដែរឬទេ។

[១០៥១] (ព្រះរាជា....) អញគ្រាន់តែបានឮ ស្រឡាញ់ឯងទៅហើយ លុះបានឃើញ អញរឹតតែស្រឡាញ់ឡើង នែហង្ស ឯង អញឃើញហើយស្រឡាញ់យ៉ាងនេះ ឯងចូរនៅក្នុងសំណាក់អញចុះ។

[១០៥២] (រាជហង្ស...) ខ្ញុំនៅក្នុងដំណាក់របស់ព្រះអង្គ ព្រះអង្គធ្វើសក្ការបូជា អស់កាលជានិច្ចហើយ តែក្រែងពេលណាមួយ ព្រះអង្គស្រវឹងដោយទឹកស្រវឹងហើយ ទ្រង់ត្រាស់បង្គាប់ថា នាយពិសេស ចូរចំអិនសាច់ស្តេចហង្ស យកមកឲ្យយើង។

[១០៥៣] (ព្រះរាជា...) ថ្វីយ ! ខ្ញើម ការផឹកទឹកស្រវឹង ដែលជាទីស្រឡាញ់របស់អញជាងឯង បើឯងនៅក្នុងដំណាក់អញដរាបណា អញនឹងមិនផឹកទឹកស្រវឹងដរាបនោះ។

[១០៥៤] (រាជហង្ស...) សំដីរបស់ពួកចចក និងពួកបក្សី យល់បានងាយ បពិត្រមហារាជ សំដីរបស់ពួកមនុស្ស កម្រដឹងបាន ជាងសំដីសត្វនោះទៅទៀត។

[១០៥៥] មួយទៀត បើបុរសណា កាលពីដើម មានចិត្តល្អ គេសំគាល់ថាជាញាតិ ជាមិត្រ ឬជាសម្លាញ់ តែលុះដល់ពេលខាងក្រោយមក បុរសនោះ ត្រឡប់ជាសត្រូវនឹងគ្នាទៅវិញ ក៏មាន។

[១០៥៦] បុគ្គលណាមានចិត្តស្មោះស្មើ ដោយសារសេចក្តីស្រឡាញ់ បុគ្គលនោះ ឈ្មោះថា នៅជិតជាមួយគ្នា បុគ្គលណា មានចិត្តមិនស្មោះស្មើ បុគ្គលនោះ ទោះនៅក្នុងទីជិត ក៏ហាក់ដូចជានៅក្នុងទីឆ្ងាយ។

[១០៥៧] សំឡាញ់ណា ជាអ្នកមានចិត្តជ្រះថ្លារកគ្នា បើទុកជានៅឯត្រើយសមុទ្ទខាងនាយ សំឡាញ់ដែលមានចិត្តជ្រះថ្លារកគ្នានោះ ក៏ឈ្មោះថានៅក្នុងសមុទ្ទជាមួយគ្នា សម្លាញ់ណា មានចិត្តប្រទូស្តរកគ្នា បើទុកជានៅក្នុងសមុទ្ទជាមួយគ្នា សម្លាញ់ដែលមានចិត្តប្រទូស្តគ្នានោះ ក៏ឈ្មោះថា នៅត្រើយសមុទ្ទខាងនាយវិញ។

[១០៥៨] បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ បុគ្គលទាំងឡាយណាជាសត្រូវនឹងគ្នា បើទុកជានៅជាមួយគ្នា បុគ្គលទាំងនោះ ក៏ឈ្មោះថា នៅផ្សេងគ្នា បពិត្រព្រះអង្គ ជាបុគ្គលចំរើនក្នុងដែន ពួកសប្បុរសទោះបីនៅក្នុងទីឆ្ងាយ ក៏ឈ្មោះថា នៅក្នុងទីជាមួយដោយចិត្ត។

[១០៥៩] បុគ្គលជាទីស្រឡាញ់ រមែងមិនស្រឡាញ់វិញ ព្រោះតែនៅជាមួយគ្នាយូរពេក ខ្ញុំសូមថ្វាយបង្គំលាព្រះអង្គទៅវិញ មុនពេលដែលខ្ញុំមិនជាទីស្រឡាញ់របស់ព្រះអង្គ។

[១០៦០] (ព្រះរាជា...) កាលបើយើងអង្វរយ៉ាងនេះ អ្នកមិនទទួលដឹងនូវអញ្ជលី មិនធ្វើតាមពាក្យយើង ជាអ្នកបម្រើទេ យើងសូមអង្វរអ្នកយ៉ាងនេះថា អ្នកគប្បីធ្វើនូវការត្រឡប់មកទៀត។

[១០៦១] (រាជហង្ស...) បពិត្រមហារាជ ជាអ្នកមានសេចក្តីចម្រើនក្នុងដែន កាលបើយើងនៅយ៉ាងនេះ សេចក្តីអន្តរាយនឹងមិនមានដល់ព្រះអង្គ ទាំងដល់ទូលព្រះបង្គំជាខ្ញុំ សូមឲ្យយើងបានជួបគ្នាក្នុងកាលកន្លងទៅនៃថ្ងៃ និងយប់។

ចប់ ជវនហំសជាតក ទី៣។

## ចុល្លនារទកស្សបជាតក ទី៤

CS sut.kn.jat.477 | ភាគទី ៥៩

(៤៧៧. ចូឡនារទជាតកំ (៤))

[១០៦២] (តាបសពោធិសត្វ សួរថា) អុស កូនឯងមិនពុះ ទឹក កូនឯងមិនដង ភ្លើង ក៏កូនឯងមិនបង្កាត់ កូនឯងជាមនុស្សល្ងង់ខ្លៅឬ បានជានៅសញ្ជប់សញ្ជឹង។

[១០៦៣] (តាបសកុមារ តបថា) ខ្ញុំមិនអាចនៅក្នុងព្រៃបានទេ បពិត្រកស្សបៈ ខ្ញុំសូមលាលោក ការនៅក្នុងព្រៃពិបាក ខ្ញុំចង់ទៅដែនវិញ។

[១០៦៤] ខ្ញុំចេញទៅពីព្រៃនេះ ហើយនៅក្នុងជនបទណា បពិត្រតាបសដ៏ប្រសើរ បុគ្គលគប្បីសិក្សាឫកពាយ៉ាងណា សូមព្រះបិតាប្រៀនប្រដៅទំនៀមទម្លាប់នោះ ដល់ខ្ញុំ។

[១០៦៥] (តាបស...) បើបាឯងលះបង់ព្រៃ និងមើមឈើ ផ្លែឈើ ហើយពេញចិត្តនឹងការនៅក្នុងដែនវិញ បាឯងចូរស្តាប់ទំនៀមទម្លាប់នោះ របស់អញ។

[១០៦៦] បាឯង ចូរកុំសេពថ្នាំពិស ចូរចៀសវាងអណ្តូង កុំឲ្យលិចទៅក្នុងភក់ឡើយ ចូរប្រព្រឹត្តប្រយ័ត្ននឹងពួកអាសីពិស។

[១០៦៧] (តាបសកុមារ...) អ្វីជាថ្នាំពិស ជាអណ្តូង ជាភក់ របស់អ្នកប្រព្រឹត្តព្រហ្មចរិយធម៌ លោកពោលនូវអ្វីថា ជាអាសីពិស ខ្ញុំសួរហើយ សូមលោកប្រាប់រឿងនោះ ដល់ខ្ញុំ។

[១០៦៨] (តាបសពោធិសត្វ...) នែបា គ្រឿងស្រវឹងក្នុងលោក គេហៅថា ស្រា ជារបស់ពេញចិត្ត ជារបស់ឈ្ងុយឈ្ងប់ ឆ្ងាញ់ពិសា មានឧបមាដូចរសផ្អែមតូចមួយ ម្នាលនារទៈ ព្រះអរិយទាំងឡាយ បានពោលថា ស្រានោះ ជាថ្នាំពិសរបស់បុគ្គលអ្នកប្រព្រឹត្តព្រហ្មចារ្យ។

[១០៦៩] នែបា ស្ត្រីទាំងឡាយក្នុងលោក រមែងញាំញីនូវបុរសដែលស្រវឹងហើយ ពួកស្ត្រីទាំងនោះ តែងផ្សាយចិត្តទៅរកប្រុសកំលោះ ដូចជាខ្យល់ផាត់នូវប៉ុយគរ ដែលជ្រុះអំពីដើម ម្នាលនារទៈ នោះហើយ ដែលលោកហៅថា អណ្តូងរបស់អ្នកប្រព្រឹត្តព្រហ្មចារ្យ។

[១០៧០] លាភ សេចក្តីសរសើរ សក្ការៈ និងការបូជាក្នុងត្រកូលអ្នកដទៃ ម្នាលនារទៈ នោះឯងដែលលោកហៅថា ភក់ល្បាប់របស់អ្នកប្រព្រឹត្តព្រហ្មចារ្យ។

[១០៧១] នែបា ពួកស្តេចធំ ៗ គ្រប់គ្រងផែនដីនេះ នែនារទៈកូន បាឯង (ចូរគោរព) ពួកស្តេចទាំងនោះ ដែលជាធំជាងមនុស្សដ៏ប្រសើរ ប្រាកដដូចច្នោះ។

[១០៧២] ចូរបាកុំប្រព្រឹត្តនៅផ្ទាល់ព្រះបាទានៃពួកស្តេចជាឥស្សរៈ ជាអធិបតីទាំងនោះឡើយ នែនារទៈ (នោះឯង) ដែលគេហៅថា អាសីពិសរបស់អ្នកប្រព្រឹត្តព្រហ្មចារ្យ។

[១០៧៣] បើបាត្រូវការភត្ត ក្នុងពេលភត្ត គប្បីចូលទៅកាន់ផ្ទះណា ដែលបាដឹងថា ត្រកូលណាមិនមានទោស ក្នុងស្រុកនោះ គប្បីប្រព្រឹត្តស្វែងរកអាហារក្នុងផ្ទះនោះចុះ។ លុះចូលទៅកាន់ត្រកូលដទៃ ដើម្បីទឹកក្តី ដើម្បីភោជនក្តី គប្បីទំពាស៊ីឲ្យល្មមប្រមាណ គប្បីបរិភោគឲ្យល្មមប្រមាណ តែបាកុំគប្បីពេញចិត្តនឹងរូប (ស្ត្រី) ទាំងឡាយឡើយ។

[១០៧៤] បាចូរចៀសវាងចេញឲ្យឆ្ងាយនូវទីគោឈរ តៀមស្រា មនុស្សអ្នកលេង មនុស្សអ្នកឆបោក កន្លែងប្រជុំមនុស្សច្រើន និងកន្លែងដែលគេទុកដាក់ប្រាក់មាស ឲ្យដូចជាបុគ្គលទៅដោយយាន (ដែលផ្ទុកដោយសប្បិ និងប្រេង) វៀរនូវផ្លូវមិនរាបស្មើ។

ចប់ ចុល្លនារទកស្សបជាតក ទី៤។

## ទូតជាតក ទី៥

CS sut.kn.jat.478 | ភាគទី ៥៩

(៤៧៨. ទូតជាតកំ (៥))

[១០៧៥] (ព្រះរាជា ត្រាស់សួរថា) ម្នាលព្រាហ្ម យើងបានបញ្ជូនពួកទូតមកក្នុងសំណាក់អ្នក ដែលកំពុងសុបសៅ ក្បែរច្រាំងគង្គា ពួកទូតទាំងនោះ បានសួរហើយ តែអ្នកមិនឆ្លើយប្រាប់សោះ សេចក្តីទុក្ខ (ណា) ដែលកើតឡើងដល់អ្នក សេចក្តីទុក្ខនោះ ដឹងបានតែអ្នកទេឬ។

[១០៧៦] (មហាសត្វ ទូលថា) បពិត្រព្រះអង្គជាបុគ្គលចំរើនក្នុងដែនរបស់អ្នកកាសី បើសេចក្តីទុក្ខ គប្បីកើតឡើងដល់ព្រះអង្គ បុគ្គលណាដោះទុក្ខនោះមិនបានទេ សូមព្រះអង្គកុំប្រាប់សេចក្តីទុក្ខនោះដល់បុគ្គលនោះឡើយ។

[១០៧៧] បុគ្គលណាគប្បីដោះទុក្ខព្រះអង្គនោះបានដោយធម៌ ជាចំណែកនៃសេចក្តីសុខតែម្យ៉ាង សូមព្រះអង្គប្រាប់ដល់បុគ្គលនោះដោយពិត។

[១០៧៨] សំឡេងពួកឆ្កែចចកក្តី ពួកសត្វក្រៀលក្តី ដឹងបានដោយងាយ បពិត្រមហារាជ ឯសំដីរបស់មនុស្ស ដឹងបានដោយកម្រជាងសម្លេងនោះទៅទៀត។

[១០៧៩] មួយទៀត កាលពីមុន បុរសណា មានចិត្តល្អ គេសំគាល់ថាជាញាតិសន្តាន ឬមិត្រសម្លាញ់ តែដល់មកខាងក្រោយ បុរសនោះត្រឡប់ទៅជាសត្រូវនឹងគ្នាវិញក៏មាន។

[១០៨០] ជនណា មានគេសាកសួរសេចក្តីទុក្ខរបស់ខ្លួន ហើយនិយាយប្រាប់ (នូវសេចក្តីកំបាំងរបស់ខ្លួន) ក្នុងកាលមិនគួរ មិត្រទាំងឡាយ ជាអ្នកមិនត្រេកអរចំពោះជននោះក៏មាន ជាអ្នកស្វែងរកនូវប្រយោជន៍ មានសេចក្តីទុក្ខចំពោះជននោះ ក៏មាន។

[១០៨១] អ្នកប្រាជ្ញដឹងនូវកាលគួរ (នឹងនិយាយប្រាប់) ផង ដឹងនូវមេធាវិជនថា មានចិត្តតែមួយជាមួយនឹងខ្លួនផង ទើបគួរប្រាប់នូវសេចក្តីទុក្ខទាំងឡាយ ដល់ជនឯទៀត មានប្រការដូច្នោះ ហើយគប្បីបញ្ចេញនូវពាក្យដ៏ពីរោះ ជាពាក្យមានប្រយោជន៍។

[១០៨២] អ្នកប្រាជ្ញកាលបើសំឡឹងរំពឹងឃើញនូវហិរិ និងឱត្តប្បៈ ជាក់ច្បាស់ហើយ រមែងដឹងនូវទុក្ខ ដែលខ្លួនពិបាកទ្រាំថា សេចក្តីសុខដែលនឹងមានដល់អាត្មាអញ មិនមែនមាន (ព្រោះការលើកធុរៈ ដាក់ទម្ងន់ទៅលើអ្នកដទៃទេ) ហើយក៏អត់ទ្រាំទុក្ខដ៏ខ្លាំងក្លាតែម្នាក់ឯង។

[១០៨៣] បពិត្រមហារាជ ទូលព្រះបង្គំជាអ្នកត្រូវការដោយទ្រព្យ (យកទៅបូជា) ដល់អាចារ្យ ទើបដើរសូមគេក្នុងដែន និគម និងរាជធានី។

[១០៨៤] បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គ (សូមឲ្យ) ពួកគហបតី ពួករាជបុរស ពួកព្រាហ្មណមហាសាល បានឆ្កោរមាស ៧ បពិត្រមហារាជ ឆ្កោរមាសរបស់ខ្ញុំព្រះអង្គនោះបាត់ ហេតុនោះ បានជាខ្ញុំព្រះអង្គសោកដ៏ក្រៃលែង។

[១០៨៥] បពិត្រមហារាជ ពួករាជបុរសរបស់ព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា មិនអាចដើម្បីជួយដោះខ្ញុំព្រះអង្គ ឲ្យរួចចាកទុក្ខបានទេ ហេតុនោះ ខ្ញុំព្រះអង្គ មិនប្រាប់ដល់រាជបុរសទាំងនោះឡើយ។

[១០៨៦] បពិត្រមហារាជ ចំណែកព្រះអង្គ ខ្ញុំព្រះអង្គបានត្រិះរិះដោយចិត្តថា ព្រះអង្គអាចជួយដោះទុក្ខបាន ហេតុនោះ ខ្ញុំព្រះអង្គទើបក្រាបទូលដល់ព្រះអង្គ។

[១០៨៧] (អភិសម្ពុទ្ធគាថា) ព្រះបាទពារាណសី ជាអ្នកចំរើនក្នុងដែនរបស់អ្នកកាសី មានព្រះហឫទ័យជ្រះថ្លា បានប្រទានឆ្កោរមាសសុទ្ធ ចំនួន ៦៤ ដុំ ដល់មហាសត្វនោះ។

ចប់ ទូតជាតក ទី៥។

## កាលិង្គពោធិជាតក ទី៦

CS sut.kn.jat.479 | ភាគទី ៥៩

**(៤៧៩. កាលិង្គពោធិជាតកំ (៦))**

[១០៨៨] (អភិសម្ពុទ្ធគាថា) ព្រះបាទកាលិង្គ ជាស្តេចចក្រពត្តិ គ្រប់គ្រងមនុស្សលើផែនដីដោយធម៌ ស្តេចបានមកដល់ទីជិតពោធិព្រឹក្សដោយដំរីមានអានុភាពធំ។

[១០៨៩] ភារទ្វាជព្រាហ្មណ៍បុរោហិត នៅក្នុងដែនកាលិង្គ លើកកម្បង់អញ្ជលីចំពោះព្រះរាជាចក្រពត្តិ ដែលទ្រង់ប្រសូតចាកត្រកូលសមណៈ ព្រះនាមចុល្លកាលិង្គ ក្រាបទូលពាក្យនេះថា

[១០៩០] បពិត្រមហារាជ សូមព្រះអង្គស្តេចចុះមក ចំណែកនៃផែនដីនេះ ជាប្រទេសដែលសមណៈសរសើរហើយ ព្រះពុទ្ធទាំងឡាយមានគុណថ្លឹងមិនបាន តែងត្រាស់ដឹងហើយ រុងរឿងក្នុងទីនេះ។

[១០៩១] បពិត្រមហារាជ តាមដែលខ្ញុំព្រះអង្គឮមកថា ស្មៅ និងវល្លិទាំងឡាយ ក្នុងចំណែកនៃផែនដីនេះ វិលក្បួចទៅខាងស្តាំ នេះជាផ្ចិតនៃផែនដី។

[១០៩២] ផ្ចិតនៃផែនដីនេះ ដែលមានសមុទ្រសាគរជាទីបំផុត ជាទីទ្រទ្រង់នូវសត្វទាំងពួង សូមព្រះអង្គស្តេចចុះមកធ្វើនមស្ការ។

[១០៩៣] ពួកដំរីណា ដែលកើតក្នុងឧបោសថត្រកូល ជាដំរីប្រសើរ ដំរីទាំងនោះ រមែងមិនហ៊ានចូលទៅកាន់ប្រទេស មានប្រមាណប៉ុណ្ណោះទេ។

[១០៩៤] ដំរីកើតក្នុងឧបោសថត្រកូល ក៏ពិតហើយ តែថា ប្រទេសប៉ុណ្ណោះនេះ ដំរីនុ៎ះ មិនហ៊ានចូលទៅជិតទេ សូមព្រះអង្គយកកង្វេរពេជ្រ (កាប់) បញ្ជូនដំរីដ៏ប្រសើរ ដែលគេបានបង្វឹកហើយ(ឲ្យចូលទៅលមើល)។

[១០៩៥] ព្រះបាទកាលិង្គ ទ្រង់ព្រះសណ្តាប់ពាក្យព្រាហ្មណ៍បុរោហិតនោះហើយ ទ្រង់ពិចារណាតាមពាក្យបុរោហិត ជាអ្នកមើលលក្ខណៈ ទើបបង្ខំដំរីដ៏ប្រសើរ ដែលកើតក្នុងឧបោសថត្រកូល ដោយគិតថា យើងនឹងបរ (ដំរី) ចូលទៅ តាមពាក្យបុរោហិតនេះលមើល។

[១០៩៦] ឯដំរីដែលស្តេចបរចូលទៅ ក៏មិនអាចទទួលភារៈដ៏ធ្ងន់បាន ហើយស្រែកដូចជាសត្វក្រៀល ថយក្រោយ អង្គុយ (លើអាកាស)។

[១០៩៧] ភារទ្វាជព្រាហ្មណ៍ក្នុងដែនកាលិង្គដឹងថា ដំរីនោះ អស់អាយុហើយ ក៏ប្រញាប់ក្រាបទូលព្រះបាទកាលិង្គថា បពិត្រមហារាជ សូមព្រះអង្គគង់ដំរីដទៃវិញ ព្រោះដំរីនេះ អស់អាយុហើយ។

[១០៩៨] ព្រះបាទកាលិង្គបានឮពាក្យនោះហើយ ក៏ទ្រង់ប្រញាប់ទៅកាន់ដំរី (ដទៃ) កាលបើស្តេចទ្រង់ឈានផុតទៅហើយ ដំរីក៏ដួលធ្លាក់មកលើផែនដី ក្នុងទីនោះឯង ពាក្យព្រាហ្មណ៍បុរោហិតអ្នកទាយលក្ខណៈយ៉ាងណា ដំរីក៏យ៉ាងនោះ។

[១០៩៩] ព្រះបាទកាលិង្គ មានព្រះរាជឱង្ការនេះនឹងកាលិង្គភារទ្វាជព្រាហ្មណ៍ថា អ្នកឯងជាមនុស្សចេះដឹងដោយប្រពៃ ជាសព្វញ្ញូ ឃើញការសព្វគ្រប់។

[១១០០] កាលិង្គភារទ្វាជព្រាហ្មណ៍ មិនទទួលការសរសើរនោះ ក៏ក្រាបបង្គំទូលដូច្នេះថា បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំ គ្រាន់តែជាអ្នកទាយលក្ខណៈ ព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គជាសព្វញ្ញូ។

[១១០១] ព្រះពុទ្ធទាំងឡាយ ព្រះអង្គដឹងសព្វ ជ្រាបសព្វ តែងដឹងដោយលក្ខណៈ ចំណែកយើងខ្ញុំ (ចេះដឹង) ដោយសាកំឡាំង

សិល្បសាស្ត្រ ព្រះពុទ្ធទាំងឡាយ ទើបព្រះអង្គទ្រង់ជ្រាបសព្វ។

[១១០២] ព្រះបាទកាលិង្គ ជ្រះថ្លានឹងពោធិមណ្ឌល ហើយនាំយកផ្កាកម្រង និងគ្រឿងក្រអូប គ្រឿងលាប ព្រមទាំងតូរ្យតន្ត្រីទាំងឡាយ ផ្សេង ៗ ទ្រង់ឲ្យធ្វើកំពែងព័ទ្ធជុំវិញ ហើយទើបទ្រង់យាងចេញទៅ។

[១១០៣] ព្រះបាទកាលិង្គ បានឲ្យរាជបុរសបេះផ្កាឈើទាំងឡាយ ចំនួនប្រាំមួយហ្មឺនរទេះ មកបូជាកន្លែងដាំពោធិព្រឹក្សដ៏ប្រសើរបំផុត (នោះ)។

ចប់ កាលិង្គពោធិជាតក ទី៦។

## អកិត្តិជាតក ទី៧

CS sut.kn.jat.480 | ភាគទី ៥៩

(៤៨០. អកិត្តិជាតកំ (៧))

[១១០៤] (អភិសម្ពុទ្ធគាថា) សក្កទេវរាជ ជាម្ចាស់នៃសត្វ លុះឃើញអកិត្តិបណ្ឌិត កំពុងគង់នៅ ទើបសួរថា បពិត្រមហាព្រហ្ម លោកប្រាថ្នាចង់បានអ្វី បានជាមកអង្គុយ នៅក្នុងទីក្តៅម្នាក់ឯង។

[១១០៥] (អកិត្តិតាបស ឆ្លើយថា) បពិត្រសក្កៈ ការកើតក្នុងភពថ្មីទៀត នាំមកនូវសេចក្តីទុក្ខ ការបែកធ្លាយនៃសរីរៈ នាំមកនូវសេចក្តីទុក្ខ ការស្លាប់ព្រោះតែវង្វេង ក៏នាំមកនូវសេចក្តីទុក្ខ បពិត្រវាសវៈ ហេតុនោះ បានជាអាត្មា (អង្គុយប្រាថ្នាព្រះនិព្វាន)។

[១១០៦] (សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាចង់បានពរណា ខ្ញុំប្រគេនពរនោះ ដល់លោក។

[១១០៧] (អកិត្តិ...) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា នរជនបានកូន ប្រពន្ធ ទ្រព្យស្រូវ និងវត្ថុដទៃ ជាទីស្រឡាញ់ រមែងមិនឆ្អែតស្កប់ស្កល់ ដោយលោភៈណា សូមកុំឲ្យលោភៈនោះ នៅក្នុងសន្តានរបស់អាត្មាបានឡើយ។

[១១០៨] (សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះ ដល់លោក។

[១១០៩] (អកិត្តិ...) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ពួកជនរមែងញាំងស្រែចម្ការ ប្រាក់មាស គោសេះ និងទាសបុរស ដោយទោសៈណា ដែលកើតហើយ សូមកុំឲ្យទោសៈនោះ នៅក្នុងសន្តានអាត្មាបានឡើយ។

[១១១០] (សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះ ដល់លោក។

[១១១១] (អកិត្តិ....) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា អាត្មាសូមកុំឲ្យជួបនឹងមនុស្សពាល សូមកុំឲ្យឮដំណឹងមនុស្សពាល សូមកុំឲ្យនៅរួមនឹងមនុស្សពាល សូមកុំឲ្យបានធ្វើ ទាំងកុំឲ្យពេញចិត្តនឹងការចរចាទៅមកនឹងមនុស្សពាល។

[១១១២] (សក្កៈ...) មនុស្សពាលបានធ្វើអ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វី បានជាលោក មិនប្រាថ្នាជួបមនុស្សពាល។

[១១១៣] (អកិត្តិ...) បុគ្គលពាល រមែងណែនាំនូវអំពើមិនគួរណែនាំ រមែងប្រកបក្នុងកិច្ចមិនមែនជាធុរៈ ការណែនាំទៅរកអាក្រក់ ជាការប្រសើរ (របស់បុគ្គលពាលនោះ) បុគ្គលពាល បើទុកជាគេនិយាយត្រូវ ក៏នៅតែខឹង បុគ្គលពាល រមែងមិនដឹងច្បាប់អ្វីទេ ការមិនជួបប្រទះនឹងបុគ្គលពាលនោះ ជាការប្រពៃ។

[១១១៤] (សក្កៈ...) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំប្រគេនពរនោះ ដល់លោក។

[១១១៥] (អកិត្តិ....) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គនឹងប្រទានពរដល់អាត្មា អាត្មាសូមឲ្យជួបប្រទះអ្នកប្រាជ្ញ សូមឲ្យស្តាប់អ្នកប្រាជ្ញ សូមឲ្យនៅរួមជាមួយនឹងអ្នកប្រាជ្ញ សូមឲ្យបានធ្វើ ទាំងសូមឲ្យបានចូលចិត្ត នឹងការចរចាទៅមក ជាមួយនឹងអ្នកប្រាជ្ញនោះ។

[១១១៦] (សក្កៈ....) អ្នកប្រាជ្ញបានធ្វើប្រយោជន៍អ្វីដល់លោក បពិត្រកស្សបៈ សូមលោកប្រាប់ហេតុ បពិត្រកស្សបៈ ហេតុអ្វីបាន ជាលោកចង់ជួបប្រទះអ្នកប្រាជ្ញ។

[១១១៧] (អកិត្តិ....) អ្នកប្រាជ្ញ រមែងណែនាំនូវហេតុ ដែលគួរដឹកនាំ រមែងមិនប្រកបក្នុងកិច្ច ដែលមិនមែនជាធុរៈ ការដឹកនាំល្អ ជាការប្រសើរ (របស់អ្នកប្រាជ្ញនោះ) អ្នកប្រាជ្ញ បើគេនិយាយត្រូវហើយ រមែងមិនក្រោធ អ្នកប្រាជ្ញនោះ រមែងចេះដឹងច្បាប់ ការសេពគប់ជាមួយនឹងអ្នកប្រាជ្ញនោះ ជាការប្រពៃ។

[១១១៨] (សក្កៈ....) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេនពរនោះ ដល់លោក។

[១១១៩] (អកិត្តិ....) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា នាកាលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង សូមឲ្យទិព្វភោជនកើតប្រាកដ ទាំងពួកយាចកអ្នកមានសីល (ក៏ឲ្យមក) កាលបើអាត្មាឲ្យ សូមទិព្វភោជនកុំឲ្យអស់ លុះឲ្យហើយ សូមកុំឲ្យក្តៅក្រហាយក្រោយ កាលបើកំពុងឲ្យ គប្បីឲ្យមានចិត្តជ្រះថ្លា បពិត្រសក្កៈ សូមព្រះអង្គប្រទានពរនុ៎ះចុះ។

[១១២០] (សក្កៈ....) សុភាសិតដ៏សមគួរនេះ លោកបានពោលល្អហើយ បពិត្រកស្សបៈ លោកមានចិត្តប្រាថ្នាពរណា ខ្ញុំនឹងប្រគេនពរនោះ ដល់លោក។

[១១២១] (អកិត្តិ....) បពិត្រសក្កៈ ជាធំជាងសត្វទាំងពួង បើព្រះអង្គប្រទានពរដល់អាត្មា ព្រះអង្គកុំចូលមករកអាត្មាទៀតឡើយ បពិត្រ

សក្កៈ សូមព្រះអង្គប្រទានពរនុ៎ះចុះ។

[១១២២] (សក្កៈ...) ពួកជនប្រុសស្រី តែងចង់ឃើញ (ខ្ញុំ) ដោយការប្រព្រឹត្តិវត្តដ៏ច្រើនចុះ ភ័យក្នុងការឃើញខ្ញុំ (មានដល់លោក)។

[១១២៣] (អកិត្តិ...) អាត្មាឃើញព្រះអង្គ មានភេទជាទេវតាប្រាកដដូច្នោះ មានសេចក្តីប្រាថ្នាទាំងពួងសម្រេចហើយ គប្បីប្រហែសក្នុងតបធម៌ ភ័យក្នុងការឃើញព្រះអង្គនុ៎ះ មានដល់ (អាត្មា)។

ចប់ អកិត្តិជាតក ទី៧។

## តក្ការិយជាតក ទី៨

CS sut.kn.jat.481 | ភាគទី ៥៩

(៤៨១. តក្ការិយជាតកំ (៨))

[១១២៤] (ព្រាហ្មណ៍បុរោហិត និយាយថា) ខ្ញុំឯង ជាមនុស្សល្ងង់ និយាយសំដីទាស់ ដូចជាកង្កែបហៅពស់ក្នុងព្រៃ ម្នាលតក្ការិយៈ ខ្ញុំធ្លាក់ក្នុងរណ្តៅនេះ ព្រោះឮថា បុគ្គលនិយាយហួសប្រមាណ មិនប្រពៃឡើយ។

[១១២៥] (តក្ការិយពោធិសត្វ តបថា) បុគ្គលអ្នកនិយាយហួសប្រមាណ តែងដល់នូវការចង ការសម្លាប់ សោក និងខ្សឹកខ្សួល លោកតិះដៀលខ្លួនលោក ព្រោះតែហេតុនោះ បពិត្រលោកអាចារ្យ ពួកជនកប់លោកក្នុងរណ្តៅឥឡូវនេះ។

[១១២៦] (មហាសត្វ ដំណាលពីសេដ្ឋីបុត្រ និយាយថា) ថ្វីបានជាអញសួរ អញយកអាសាតុណ្ឌិលៈ ជាបងនាងកាលី បានជាអញត្រូវគេដណ្តើមយកសំពត់ទាំងគូ ហើយជាមនុស្សអាក្រាត ដំណើរនេះឯង ប្រហែលគ្នានឹងលោកច្រើនប្រការ។

[១១២៧] (ដំណាលរឿងកុកសថា) កាលពពែទាំងពីរ កំពុងតែជល់គ្នា កុកសណា ចូលទៅត្រង់ចន្លោះពពែ កុកសនោះ ត្រូវក្បាលពពែទាំងពីរ ទង្គិចខ្ទេចក្នុងទីនោះ ដំណើរនេះ ប្រហែលគ្នានឹងលោកច្រើនយ៉ាង។

[១១២៨] (ដំណាលរឿងជន ៤ នាក់ ថា) ជន ៤ នាក់ កាន់ជាយក្រមា ចាំត្រងបុរសម្នាក់ (ដែលលោតពីចុងត្នោត) ជនទាំង ៤ នាក់នោះ បែកក្បាលដួលស្លាប់ ដំណើរនេះ ប្រហែលគ្នានឹងលោកច្រើនយ៉ាង។

[១១២៩] (ដំណាលរឿងពពែថា) ដូចជាមេពពែ ដែលចោរចងទុកក្បែរគុម្ពឫស្សី ទាក់ជើងក្រោយលេង បានជាន់កាំបិត ហេតុនោះ បានជាចោរ អារបំពង់កមេពពែនោះ ដំណើរនេះឯង ប្រហែលគ្នានឹងលោកច្រើនយ៉ាង។

[១១៣០] (ដំណាលរឿង ព្រះរាជាពារាណសី ត្រាស់ថា) កិន្នរទាំងពីរនេះ មិនមែនជាទេវតា មិនមែនជាគន្ធព្វបុត្តទេ កិន្នរទាំងនេះ ជាម្រឹគទេ កិន្នរទាំងនេះ ព្រានព្រៃបាននាំមកដោយអំណាចប្រយោជន៍ ពួកអ្នកធ្វើក្រយាស្ងោយ ចូរចំអិនកិន្នរមួយនោះ ក្នុងពេលបាយល្ងាច ចូរចំអិនកិន្នរមួយទៀត ក្នុងពេលបាយព្រឹក។

[១១៣១] (រឿងកិន្នរី ទូលព្រះរាជាថា) ពាក្យជាទុព្ភាសិតមួយសែនម៉ាត់ ក៏មិនដល់មួយចំណិតនៃពាក្យជាសុភាសិតឡើយ បុគ្គលកាលរង្កៀសនឹងពាក្យជាទុព្ភាសិត រមែងលំបាក ព្រោះហេតុនោះ កិន្នរនៅស្ងៀម មិនមែនព្រោះល្ងង់ទេ។

[១១៣២] (ព្រះរាជា ត្រាស់ថា) កិន្នរីណា បានដោះសានឹងអញ អ្នកទាំងឡាយ ចូរលែងកិន្នរីនុ៎ះចុះ ចូរនាំកិន្នរនោះ ទៅភ្នំហិមពាន្ត អ្នកទាំងឡាយ ចូរប្រគល់កិន្នរនេះ ដើម្បីរោងគ្រួ ចូរចំអិនវាក្នុងពេលបាយព្រឹក អំពីព្រលឹម។

[១១៣៣] (កិន្នរ ក្រាបទូលថា) ពួកសត្វចិញ្ចឹម មានមេឃជាទីពឹង ពួកមនុស្សមានសត្វចិញ្ចឹមជាទីពឹង បពិត្រមហារាជ ខ្ញុំមានព្រះអង្គជាទីពឹង ឯភរិយារបស់ខ្ញុំ មានខ្លួនខ្ញុំជាទីពឹង ក្នុងរវាងយើងខ្ញុំទាំងពីរនាក់ សូមឲ្យអ្នកដែលរួច (អំពីសេចក្តីស្លាប់) ដឹងថា អ្នកណាមួយ (ស្លាប់) ហើយសឹមទៅភ្នំ។

[១១៣៤] បុគ្គលមិនងាយចៀសនិន្ទាទេ បពិត្រព្រះជនិន្ទ ព្រះអង្គគប្បីសេពគប់ រាប់រកនូវពួកជន អ្នកមានសេចក្តីប្រាថ្នាផ្សេង ៗ គ្នា (លមើល) បុគ្គលពួកមួយ បាននូវសេចក្តីសរសើរដោយគុណ មានសីលគុណជាដើមណា បុគ្គលឯទៀត បាននូវពាក្យនិន្ទា ដោយគុណមានសីលគុណជាដើមនោះទៅវិញ។

[១១៣៥] សត្វលោកទាំងអស់ មានចិត្តក្លៀវក្លា ដោយចិត្តផ្សេងគ្នា សត្វលោកទាំងអស់ មានចិត្តប្រព្រឹត្តទៅក្នុងចិត្តរបស់ខ្លួន ពួកសត្វទាំងអស់ មានចិត្តផ្សេង ៗ គ្នា មានប្រភេទដ៏ច្រើន ឯក្នុងលោកនេះ បុគ្គលមិនលុះអំណាចចិត្តរបស់បុគ្គលណាបានឡើយ។

[១១៣៦] (ព្រះរាជា...) កិន្នរណា ព្រមទាំងភរិយានៅស្ងៀម ឥឡូវនេះ ភ័យហើយ បានដោះសា កិន្នរនោះ ចូររួចអំពីភ័យ ដល់នូវសេចក្តីសុខ មិនមានរោគក្នុងកាលឥឡូវនេះចុះ វាចារបស់ជនទាំងឡាយ ជាវាចាមានប្រយោជន៍។

ចប់ តក្ការិយជាតក ទី៨។

## រុរុមិគជាតក ទី៩

CS sut.kn.jat.482 | ភាគទី ៥៩

(៤៨២. រុរុមិគរាជជាតកំ (៩))

[១១៣៧] (ព្រះបាទព្រហ្មទត្ត ប្រកាសថា) នរណា ប្រាប់ម្រឹគនោះ ជាម្រឹគដ៏ឧត្តមជាងម្រឹគទាំងឡាយ ដល់យើង យើងនឹងឲ្យស្រុកសួយ និងនាងនារីដែលស្អិតស្អាងហើយ ដល់អ្នកនោះ។

[១១៣៨] (សេដ្ឋីបុត្ត ក្រាបទូលថា) សូមព្រះអង្គប្រទានស្រុកសួយ និងពួកនាងនារី ដែលស្អិតស្អាង ដល់ទូលព្រះបង្គំជាខ្ញុំចុះ ទូលព្រះបង្គំជាខ្ញុំ នឹងក្រាបទូលម្រឹគនោះ ជាម្រឹគដ៏ឧត្តមជាងម្រឹគទាំងឡាយដល់ព្រះអង្គ។

[១១៣៩] ដើមស្វាយ និងដើមសាលព្រឹក្ស ក្នុងដងព្រៃនុ៎ះ មានផ្ការីក (ផែនដី) ដំដេរដាសដោយស្មៅ មានសម្ព័ស្សស្រួល មានពណ៌ក្រហមដូចជាសម្បុរនៃសត្វមេភ្លៀង ម្រឹគនុ៎ះ ឋិតទៅក្នុងដងព្រៃនុ៎ះ។

[១១៤០] (អភិសម្ពុទ្ធគាថា) ព្រះបាទព្រហ្មទត្ត ទ្រង់យិតព្រះទម្រង់កៅទណ្ឌ ផ្ទាប់កាំសរ ហើយស្ដេចចូលតម្រង់ទៅ ឯម្រឹគក្រលេកឃើញព្រះរាជាហើយ ក៏ទូលអង្វរពីចម្ងាយថា បពិត្រមហារាជ សូមព្រះអង្គឈប់សិន បពិត្រព្រះអង្គប្រសើរក្នុងរថ សូមព្រះអង្គកុំបាញ់ទូលព្រះបង្គំជាខ្ញុំឡើយ នរណាអេះ បានក្រាបទូលដំណើរនេះដល់ព្រះអង្គថា ម្រឹគនុ៎ះ ឋិតនៅក្នុងដងព្រៃនុ៎ះ។

[១១៤១] (ព្រះរាជា....) នៃសំឡាញ់ បុរសជាអ្នកប្រព្រឹត្តអំពើលាមកនុ៎ះ ឋិតនៅអំពីចម្ងាយ បុរសនោះ បានប្រាប់ដំណើរនេះដល់យើងថា ម្រឹគនុ៎ះ ឋិតនៅក្នុងទីនុ៎ះ។

[១១៤២] (ប្រើសមាសពោធិសត្វ...) បានឮមកថា នរជនពួកខ្លះ ក្នុងលោកនេះ បានពោលពាក្យពិតយ៉ាងនេះថា កំណាត់ឈើដែលគេស្រង់ឡើង ប្រសើរជាង ឯនរជនពួកខ្លះ ដែលគេស្រង់ឡើង មិនប្រសើរទេ។

[១១៤៣] (ព្រះរាជា...) ម្នាលម្រឹគ អ្នកតិះដៀលម្រឹគទាំងឡាយ ឬបក្សីទាំងឡាយ ឬក៏មនុស្សទាំងឡាយ យើងមានភ័យច្រើន ព្រោះតែឮអ្នកនិយាយជាភាសាមនុស្ស។

[១១៤៤] (ប្រើសមាស...) ខ្ញុំបានស្រង់មនុស្សណា ដែលរសាត់ទៅក្នុងផ្លូវទឹក មានទឹកច្រើន ទឹកជ្រៅ មានខ្សែទឹកហូររហ័ស (ឥឡូវ) ភ័យមានមកដល់ទូលព្រះបង្គំជាខ្ញុំហើយ ព្រោះហេតុតែស្រង់មនុស្សនោះ បពិត្រមហារាជ ការរួបរួមនឹងអសប្បុរសតែងនាំមកនូវសេចក្ដីទុក្ខ។

[១១៤៥] (ព្រះរាជា...) យើងនឹងបាញ់ព្រួញនេះ ទៅតាមអាកាស ជាព្រួញមានស្លាបកន្ទុយ ៤ ផ្ដាច់នូវសរីរៈ (បុរសនោះ) ចំដើមទ្រូង យើងនឹងសម្លាប់មនុស្សនោះ ជាមនុស្សទ្រុស្តមិត្ត ជាអ្នកធ្វើកិច្ចដែលមិនគួរធ្វើ មិនដឹងនូវឧបការគុណ ដែលធ្វើហើយប្រាកដដូច្នោះ។

[១១៤៦] (ប្រើសមាស...) បពិត្រព្រះជនិន្ទ្រ សប្បុរសទាំងឡាយ រមែងមិនសរសើរនូវការសម្លាប់របស់អ្នកប្រាជ្ញ ឬមនុស្សពាលដោយពិត សូមឲ្យមនុស្សអ្នកមានបាបធម៌ទៅផ្ទះ តាមសេចក្ដីប្រាថ្នាចុះ ភត្តណា (ដែលព្រះអង្គត្រូវប្រទាន) ដល់បុរសនុ៎ះ សូមព្រះអង្គប្រទានភត្តនោះ ដល់បុរសនុ៎ះចុះ ចំណែកខ្ញុំ សូមធ្វើតាមសេចក្ដីប្រាថ្នារបស់ព្រះអង្គចុះ។

[១១៤៧] (ព្រះរាជា...) ម្នាលប្រើសមាស បណ្ដាសប្បុរសទាំងឡាយ អ្នកដែលមិនប្រទូស្តចំពោះមនុស្សដែលប្រទូស្តនោះ ក៏ចាត់ថាជាសប្បុរសមួយដោយពិត មនុស្សមានបាបធម៌ ចូរទៅផ្ទះរបស់ខ្លួនតាមសេចក្ដីប្រាថ្នាចុះ ភត្តណា (ដែលយើងត្រូវឲ្យ) ដល់បុរសនុ៎ះ យើងនឹងឲ្យភត្តនោះដល់បុរសនុ៎ះ មួយទៀត យើងនឹងឲ្យស្រុកស៊ួយដល់អ្នក។

[១១៤៨] (ប្រើសមាស...) បពិត្រមហារាជ សំឡេងរបស់ចចក និងក្រៀល គេដឹងបានដោយងាយ ឯសំដីរបស់មនុស្ស គេដឹងបានដោយកម្រ ជាងសំដីសត្វនោះទៅទៀត បុរសណា មានចិត្តល្អ គេសំគាល់ថា ជាញាតិ ជាមិត្រ ជាសំឡាញ់ក្នុងកាលមុន បុរសនោះ រមែងជាសត្រូវវិញ ក្នុងកាលជាខាងក្រោយ។

[១១៤៩] (អភិសម្ពុទ្ធគាថា) ពួកអ្នកជនបទ ក៏មកប្រជុំគ្នា ពួកអ្នកនិគម ក៏មកប្រជុំគ្នា (ហើយក្រាបទូលស្ដេច) ថា ពួកម្រឹគស៊ីស្រូវអស់ហើយ សូមព្រះសម្មតិទេព កំចាត់ពួកម្រឹគនោះចេញ។

[១១៥០] (ព្រះរាជា...) ចូរកុំឲ្យមានជនបទ ទាំងដែនក៏ចូរវិនាសទៅដោយពិតចុះ យើងឲ្យអភ័យដល់ពួកបក្សីហើយ មិនប្រទូស្តប្រើសមាសទេ។

[១១៥១] យើងមិនមានជនបទក្ដី ជនបទមិនមានដល់យើងក្ដី យើងឲ្យពរដល់មិគរាជហើយ មិននិយាយពាក្យកុហកទេ។

ចប់ រុរុមិគជាតក ទី៩។

## សរភជាតក ទី១០

CS sut.kn.jat.483 | ភាគទី ៥៩

### (៤៨៣. សរភមិគជាតកំ (១០))

[១១៥២] (ព្រះបាទព្រហ្មទត្ត បន្លឺឧទានថា) បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួនសម្រេចដូចសេចក្ដីប្រាថ្នា។

[១១៥៣] បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួន ដែលគេស្រង់អំពីទឹកមកលើគោក។

[១១៥៤] បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួនសម្រេចដូចសេចក្ដីប្រាថ្នា។

[១១៥៥] បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនគប្បីនឿយណាយទេ អាត្មាអញឃើញខ្លួនដែលសរភម្រឹគស្រង់អំពីទឹកមកលើគោក។

[១១៥៦] នរជនដែលប្រកបដោយប្រាជ្ញា សូម្បីដល់សេចក្ដីទុក្ខ ក៏មិនកាត់បង់សេចក្ដីប៉ុនប៉ង ដើម្បីឲ្យបានសុខ ព្រោះថា ផស្សៈ[22] ទាំងឡាយ មានច្រើន មិនជាប្រយោជន៍ក៏មាន ជាប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងចូលទៅរកសេចក្ដីស្លាប់។

[១១៥៧] ហេតុដែលយើងមិនបានគិត ក៏ប្រែជាមាន ហេតុដែលយើងបានគិតហើយ ក៏ប្រែជាវិនាសទៅវិញ ភោគៈទាំងឡាយរបស់ស្ត្រីក្ដី របស់បុរសក្ដី មិនមែនសម្រេចមកពីការគិតឡើយ។

[១១៥៨] (បុរោហិត ក្រាបបង្គំទូលថា) ពីដើម ព្រះអង្គជាប់តាមសរភម្រឹគ ក្នុងដងភ្នំ ព្រះអង្គបានរស់រួចព្រះជន្ម ដោយសារសេចក្ដីព្យាយាមរបស់សរភម្រឹគ ដែលមានចិត្តមិនរួញរា។

[១១៥៩] សរភម្រឹគណា ធ្វើនូវការប្រតោងថ្ម បានស្រង់ព្រះអង្គឡើងអំពីរណ្ដៅ ដែលមិនងាយឡើងរួច ហើយបានដោះព្រះអង្គដែលដល់នូវសេចក្ដីទុក្ខ ឲ្យរួចពីមាត់សេចក្ដីស្លាប់ ព្រះអង្គពណ៌នាសរសើរសរភម្រឹគ ដែលជាសត្វមានចិត្តមិនរួញរានោះឯង។

[១១៦០] (ព្រះរាជា...) ក្នុងពេលនោះ អ្នកឯងបាននៅក្នុងទីនោះដែរឬ ឬនរណាមួយប្រាប់ដំណើរនោះដល់អ្នក ឬក៏អ្នកជាបុគ្គលមានដម្បូល គឺកិលេសបើកហើយ ជាអ្នកឃើញហេតុសព្វ ម្នាលព្រាហ្មណ៍ អ្នកមានញាណដ៏មានកំឡាំងក្លៀវក្លាឬ។

[១១៦១] (បុរោហិត...) ក្នុងពេលនោះ ទូលព្រះបង្គំជាខ្ញុំ មិនបាននៅក្នុងព្រៃនោះទេ ទាំងគ្មាននរណាមួយ ប្រាប់ដំណើរនោះដល់ទូលបង្គំជាខ្ញុំឡើយ បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំងឡាយ តែងពិចារណាសេចក្តីនៃបទនៃគាថា និងសុភាសិតទាំងឡាយនោះ។

[១១៦២] (ព្រះឥន្ទ្រ ជ្រែកចូលក្នុងសរីរៈបុរោហិត ហើយនិយាយថា) ព្រះអង្គផ្ទាប់ព្រះទម្រង់កាំសរ មានស្លាបកន្ទុយជាគ្រឿងសម្លាប់បុគ្គលដទៃដោយសេចក្តីព្យាយាម ព្វដ៏ព្រះទម្រង់កៅទណ្ឌហើយ នៅអល់អែកអ្វីទៀត ចូរឲ្យព្រះទម្រង់កាំសរ ដែលព្រះអង្គបាញ់ទៅហើយ សម្លាប់សរភម្រឹគឲ្យឆាប់ទៅ បពិត្រមហារាជមានប្រាជ្ញាដ៏ប្រសើរ ព្រោះសរភម្រឹគនុ៎ះ នឹងបានជាក្រយាស្ងោយរបស់ព្រះរាជា។

[១១៦៣] (ព្រះរាជា...) ម្នាលព្រាហ្មណ៍ យើងដឹងថា សរភម្រឹគនោះ ជាក្រយាស្ងោយរបស់ក្សត្រិយ៍ ពិតមែនហើយ តែយើងគោរពគុណដែលសរភម្រឹគ ធ្វើហើយក្នុងកាលមុន ហេតុនោះ យើងមិនសម្លាប់សរភម្រឹគទេ។

[១១៦៤] (សក្ក...) បពិត្រមហារាជ នុ៎ះមិនមែនជាសរភម្រឹគទេ នុ៎ះជាព្រះឥន្ទ្រជាធំជាងអសុរ បពិត្រព្រះអង្គជាធំជាងមនុស្ស ព្រះអង្គសម្លាប់ព្រះឥន្ទ្រនោះហើយ ចូរបានជាស្តេចទេវតា។

[១១៦៥] បពិត្រមហារាជ បើព្រះអង្គនៅអល់អែកនឹងការសម្លាប់សរភម្រឹគ ដែលជាសំឡាញ់ហើយ បពិត្រព្រះអង្គប្រសើរដោយការព្យាយាមជាងនរជន ព្រះអង្គព្រមទាំងព្រះរាជបុត្រ ព្រះរាជទេពី នឹងធ្លាក់ទៅក្នុងវេតរណីនរកនៃព្រះយមរាជ។

[១១៦៦] (ព្រះរាជា...) យើងផង ពួកអ្នកជនបទទាំងអស់ផង បុត្រាបុត្រីផង អគ្គមហេសីផង ពួកសំឡាញ់ផង ចូរធ្លាក់ទៅក្នុងវេតរណីនរកនៃព្រះយមរាជ ដោយពិតចុះ យើងមិនត្រូវសម្លាប់សត្វដែលឲ្យជីវិតយើងឡើយ។

[១១៦៧] សរភម្រឹគនេះ ជាអ្នកឲ្យជីវិតដល់យើង ដែលដល់នូវសេចក្តីលំបាកម្នាក់ឯង ក្នុងព្រៃដ៏ពន្លឹក បពិត្រមហាព្រហ្ម យើងរលឹកដឹងនូវកិច្ចការខាងដើម បែបនោះហើយ គប្បីសម្លាប់ដូចម្តេចបាន។

[១១៦៨] (សក្កៈ...) សូមព្រះអង្គ ជាអ្នកញាំងមិត្តឲ្យត្រេកអរ គង់ព្រះជន្មអស់កាលយូរអង្វែង សូមព្រះអង្គសោយរាជសម្បត្តិនេះក្នុងធម្មគុណ សូមឲ្យមានពួកនាងនារីចោមរោម ហើយត្រេកអរក្នុងដែនរបស់ព្រះអង្គចុះ ដូចជាវាសវៈ ត្រេកអរ ក្នុងឋានត្រៃត្រឹង្ស។

[១១៦៩] ព្រះអង្គជាបុគ្គលមិនក្រោធ មានព្រះទ័យជ្រះថ្លាជានិច្ច យកសមណព្រាហ្មណ៍ ប្រកបដោយធម៌ទាំងអស់ ជាភ្ញៀវ ព្រះអង្គគួរគេសូមបាន ឲ្យទាន នឹងប្រើប្រាស់ខ្លួនឯង តាមសមគួរ សត្វលោកមិនតិះដៀលបាន សូមព្រះអង្គទៅកើតក្នុងឋានសួគ៌ចុះ។

ចប់ សរភជាតក ទី១០។

ឧទ្ទាននៃតេរសនិបាតនោះគឺ

និយាយអំពីស្វាយដ៏ប្រសើរ ១ ដឹង ១ ហង្សដ៏ប្រសើរ ១ ការនៅក្នុងព្រៃ ១ ទូតជាគំរប់ ៥ កាលិង្គពោធិព្រឹក្ស ១ អកិត្តិតាបស ១ តក្ការិយបុរោហិត ១ ម្រឹគមាស ១ សរភម្រឹគ ១។

ចប់ តេរសនិបាត។

ចប់ ភាគ៥៩។

# បកិណ្ណកនិបាតជាតក

CS sut.kn.jat.v14 | ភាគទី ៦០

(១៤. បកិណ្ណកនិបាតោ)

## សាលិកេទារជាតក ទី១

CS sut.kn.jat.484 | ភាគទី ៦០

(៤៨៤. សាលិកេទារជាតកំ (១))

[១] (បុរសអ្នករក្សាស្រែពោលថា) បពិត្រកោសិយៈ ស្រូវសាលីក្នុងស្រែ បរិបូណ៌ដែរ តែពួកសេកតែងស៊ី បពិត្រព្រាហ្មណ៍ ខ្ញុំសូមជំរាបលោក ខ្ញុំមិនអាចហាមឃាត់សេកទាំងនោះបានឡើយ បណ្តាសេកទាំងនោះ មានសេកមួយ ដែលល្អដោយចំណែកទាំងពួង ជាងសេកទាំងនោះ ស៊ីនូវស្រូវសាលី តាមសេចក្តីប្រាថ្នារួចហើយ ក៏ពាំស្រូវដោយចំពុះហើរទៅទៀត។

[២] (សាលិន្ទិយព្រាហ្មណ៍ កោសិយគោត្រពោលថា) ជនទាំងឡាយ ចូរដាក់អន្ទាក់ធ្វើដោយកន្ទុយសត្វ បក្សីនោះនឹងជាប់ ចូរអ្នកចាប់វាទាំងរស់ នាំមកក្នុងសំណាក់នៃអញ។

[៣] (ស្តេចសេកពោលថា) បក្សីទាំងនុ៎ះ ស៊ីផង ផឹកផង ហើយហើរចេញទៅ អាត្មាអញម្នាក់ឯង ជាប់អន្ទាក់ហើយ អាត្មាអញធ្វើហើយនូវអំពើលាមកដូចម្តេច។

[៤] (ព្រាហ្មណ៍...) ម្នាលសេក ពោះសេកទាំងឡាយដទៃ (ជាពោះតូចល្មម) ដោយពិត (ចំណែកខាងពោះ) របស់អ្នក ជាពោះធំជ្រុលពេក បានជាអ្នកស៊ីស្រូវសាលីតាមសេចក្តីប្រាថ្នារួចហើយ ក៏ពាំយកស្រូវដោយចំពុះហើរទៅ។ ម្នាលសេក អ្នកបំពេញជង្រុកក្នុងព្រៃរកានោះឬ ឬក៏អ្នកចងពៀរនឹងយើង ម្នាលសំឡាញ់ យើងសួរហើយ អ្នកចូរប្រាប់ អ្នកកប់ស្រូវសាលីទុកក្នុងទីណា។

[៥] (ស្តេចសេក...) ខ្ញុំមិនចងពៀរជាមួយនឹងអ្នកទេ ជង្រុករបស់ខ្ញុំ ក៏មិនមានដែរ ខ្ញុំដោះបំណុលផង ឲ្យបុលផង ខ្ញុំហើរទៅដល់ចុងរកា

កំកប់កំណាប់ទុកក្នុងព្រៃរកានោះ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះចុះ។

[៦] (ព្រាហ្មណ៍...) ការឲ្យបុលរបស់អ្នកដូចម្តេច ការដោះបំណុលដូចម្តេច អ្នកចូរប្រាប់នូវការកប់កំណាប់ កាលបើដូច្នោះ អ្នកនឹងរួចចាក
អន្ទាក់។

[៧] (ស្តេចសេក...) បពិត្រកោសិយៈ ខ្ញុំមានកូនតូចៗ មិនទាន់ដុះស្លាបនៅឡើយ កូនតូចទាំងឡាយនោះ ដែលខ្ញុំចិញ្ចឹមហើយ នឹងចិញ្ចឹមខ្ញុំវិញ ហេតុនោះ ខ្ញុំត្រូវឲ្យបុលដល់កូនតូចៗ ទាំងនោះ។ ម្យ៉ាងទៀត ខ្ញុំមានមាតា បិតាចាស់គ្រាំគ្រា មានវ័យកន្លងហើយ ខ្ញុំពាំ (នូវស្រូវសាលី) ដោយចំពុះ យកទៅជូនមាតាបិតាទាំងនោះ ខ្ញុំត្រូវដោះបំណុលដែលគាត់ធ្វើហើយមុន។

ក្នុងព្រៃរកានោះ មានបក្សីទាំងឡាយដទៃទៀត ដែលជ្រុះស្លាបអស់ហើយ ថមថយកំឡាំង ខ្ញុំត្រូវការដោយបុណ្យ ក៏ឲ្យដល់បក្សីទាំងនោះ បណ្ឌិតទាំងឡាយពោលថា បុញ្ញកម្មនោះជាកំណប់។ ការឲ្យបុលរបស់ខ្ញុំយ៉ាងនេះ ការដោះបំណុលរបស់ខ្ញុំយ៉ាងនេះ ខ្ញុំប្រាប់នូវការកប់កំណាប់ បពិត្រកោសិយៈ អ្នកចូរជ្រាបយ៉ាងនេះ។

[៨] (ព្រាហ្មណ៍...) បក្សីមានកំណើតពីរដងនេះ ប្រសើរណាស់តើ ជាសត្វប្រកបដោយធម៌ដ៏ក្រៃលែង មនុស្សពួកខ្លះ មិនមានធម៌នេះទេ។ អ្នកចូរបរិភោគនូវស្រូវសាលី ជាមួយនឹងពួកញាតិទាំងអស់ តាមប្រាថ្នាចុះ ម្នាលសេក សូមឲ្យយើងឃើញអ្នកទៀត ដ្បិតការបានចួបប្រទះ នឹងអ្នក (នេះ) ជាទីស្រឡាញ់របស់យើង។

[៩] (ស្តេចសេក...) បពិត្រកោសិយៈ ខ្ញុំបានបរិភោគផង ផឹកផង ក្នុងលំនៅអ្នករួចហើយ ខ្ញុំមិនអាចនឹងនៅក្នុងសំណាក់នៃអ្នកអស់រាត្រីមួយទេ អ្នកចូរឲ្យទាន (ចំពោះសមណព្រាហ្មណ៍) ដែលមានអាជ្ញាដាក់ចុះហើយផង ចូរចិញ្ចឹមមាតាបិតា ដែលចាស់គ្រាំគ្រាផង។

[១០] (ព្រាហ្មណ៍...) លក្ខី (សិរី បុណ្យ និងប្រាជ្ញា) បានកើតឡើងហើយដល់យើងក្នុងថ្ងៃនេះ ដ្បិតយើងបានជួបនឹងស្តេចសេកដ៏ប្រសើរជាងពួកបក្សីទាំងឡាយ យើងនឹងធ្វើបុណ្យឲ្យច្រើន ព្រោះបានស្តាប់នូវសុភាសិតរបស់សេក។

[១១] (អភិសម្ពុទ្ធគាថា) សាលិទ្ទិយព្រាហ្មណ៍ ជាកោសិយគោត្រនោះ មានចិត្តរីករាយ មានចិត្តខ្ពស់ឯក មានចិត្តជ្រះថ្លា បានចាត់ចែងនូវបាយ និងទឹក ហើយញុំាំងសមណៈ និងព្រាហ្មណ៍ទាំងឡាយ ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក។

ចប់ សាលិកេទារជាតក ទី១។

## ចន្ទកិន្នរជាតក ទី២

CS sut.kn.jat.485 | ភាគទី ៦០

### (៤៨៥. ចន្ទកិន្នរីជាតកំ (២ ))

[១២] (ចន្ទកិន្នរពោលថា) ម្នាលនាងចន្ទា ជីវិតនេះប្រហែលជាជិតដាច់ហើយ ព្រោះក្រពុលដោយឈាម អញនឹងលះបង់នូវជីវិតក្នុងថ្ងៃនេះឯង ម្នាលនាងចន្ទា ជីវិតរបស់អញនឹងរលត់។ ជីវិតរបស់អញជាទុក្ខពៀបចុះហើយ ហឫទ័យរបស់អញក្តៅណាស់ អញលំបាកក្រៃពេក ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ។ អញនឹងស្វិតស្រពោនដូចជាស្មៅ (ដែលគេដាក់លើថ្មក្តៅ) ដូចជាដើមឈើ (ដែលកាត់ផ្តាច់ឫសហើយ) អញនឹងរីងស្ងួតដូចជាស្ទឹងដែលមានទឹកមិនពេញ ព្រោះនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃទេ។ ទឹកភ្នែកទាំងឡាយរបស់អញនេះហូរទៅ ដូចជាភ្លៀងក្បែរជើងភ្នំហូរទៅ ព្រោះហេតុនាងចន្ទាកំពុងសោក មិនមែនព្រោះការសោកដទៃឡើយ។

[១៣] (នាងចន្ទាកិន្នរី ពោលផ្តាសាថា) រាជបុត្តណា បាញ់នូវប្តីដែលអញជាអ្នកកំព្រាប្រាថ្នាហើយ រាជបុត្ត (នោះ) អាក្រក់មែន ប្តីរបស់អញនោះ ដែលត្រូវសរមុតហើយ ដេកលើផែនដីទៀបគល់ឈើ។ នៃរាជបុត្ត សេចក្តីសោកក្នុងហឫទ័យណានៃអញ ដែលកំពុងសំឡឹងមើលនូវកិន្នរ សូមមាតារបស់អ្នក បាននូវសេចក្តីសោកក្នុងហឫទ័យដូចអញនេះដែរ។ នៃរាជបុត្ត សេចក្តីសោកក្នុងហឫទ័យណារបស់អញ ដែលកំពុងសំឡឹងមើលនូវកិន្នរ សូមប្រពន្ធរបស់អ្នក បាននូវសេចក្តីសោកក្នុងហឫទ័យដូចអញនេះដែរ។ នៃរាជបុត្ត បុគ្គលណាបានសម្លាប់កិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ សូមកុំឲ្យម្តាយរបស់អ្នក (នោះ) បានឃើញកូនផង សូមកុំឲ្យបានឃើញប្តីផង។ នៃរាជបុត្ត អ្នកណាបានសម្លាប់កិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ សូមកុំឲ្យប្រពន្ធរបស់អ្នកនោះ បានឃើញកូនផង សូមកុំឲ្យបានឃើញប្តីផង។

[១៤] (ព្រះរាជាទ្រង់ត្រាស់ថា) ម្នាលនាងចន្ទាមានភ្នែកដូចផ្កានៃតិមិរព្រឹក្សក្នុងព្រៃ នាងកុំយំ កុំសោកឡើយ នាងនឹងបានជាអគ្គមហេសីនៃយើង និងមាននាងនារីបូជាក្នុងរាជត្រកូល។

[១៥] (កិន្នរី...) នៃរាជបុត្រ អ្នកណាបានសម្លាប់នូវកិន្នរ ដែលជាសត្វមិនប្រទូស្ត ព្រោះការចង់បានអញ អញស៊ូតែស្លាប់ អញនឹងមិនធ្វើ (ជាប្រពន្ធ) របស់អ្នក (នោះ) ទេ។

[១៦] (ព្រះរាជា...) ម្នាលនាងកិន្នរី ដែលជាស្រីមានសេចក្តីខ្លាចផង ចង់រស់នៅផង នាងជាមេម្រឹគ មានស្លឹកកំញាន និងស្លឹកក្រស្នាជាភោជន ចូរនាងទៅកាន់ព្រៃហិមវន្តចុះ ពួកម្រឹគដទៃនឹងត្រេកត្រអាលចំពោះនាង។

[១៧] (កិន្នរី...) ភ្នំទាំងឡាយនោះផង ជ្រោះភ្នំទាំងឡាយនោះផង គូហាភ្នំទាំងឡាយនោះផង បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ យើងទាំងឡាយ រមែងត្រេកត្រអាលជាមួយគ្នាលើភ្នំទាំងឡាយណា បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំទាំងឡាយនោះ តើនឹងធ្វើដូចម្តេច។ ភ្នំទាំងឡាយនោះ ដេរដាសដោយស្លឹកឈើ គួរឲ្យរីករាយ ដែលពួកម្រឹគសាហាវធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ ភ្នំទាំងឡាយនោះ ដេរដាសដោយផ្កាឈើគួរឲ្យរីករាយ ដែលពួកម្រឹគសាហាវធ្លាប់ដើរទៅមកញឹកញយ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ ស្ទឹងលើភ្នំ និងស្ទឹងក្នុងព្រៃទាំងឡាយ មានទឹកដ៏ថ្លា កាលហូរទៅ មានផ្កាឈើអណ្តែតទៅតាមខ្សែទឹកព្រោងព្រាត បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌ខៀវ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌លឿង គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានពណ៌ក្រហម គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ កំពូលទាំងឡាយនៃភ្នំហិមវន្ត មានចុងស្រួច គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ កំពូលទាំងឡាយនៃភ្នំហិមវន្ត ដែលមានពណ៌ស គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្តេច។ កំពូលទាំងឡាយ

នៃភ្នំហិមវន្តដ៏វិចិត្រ គួរឲ្យរមិលមើល បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកក្នុងទីនោះ តើនឹងធ្វើដូចម្ដេច។ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំគន្ធមាទន៍នោះ ដែលពួកភុម្មទេវតាសេពហើយ ជាភ្នំដេរដាសដោយឱសថទាំងឡាយ តើនឹងធ្វើដូចម្ដេច។ បពិត្រកិន្នរ ខ្ញុំកាលមិនឃើញអ្នកលើភ្នំគន្ធមាទន៍នោះ ដែលពួកកិន្នរសេពហើយ ជាភ្នំដ៏ដេរដាសដោយឱសថទាំងឡាយ តើនឹងធ្វើដូចម្ដេច។

[១៨] បពិត្រព្រហ្មជាម្ចាស់ ខ្ញុំសូមថ្វាយបង្គំនូវព្រះបាទទាំងឡាយរបស់លោក ព្រោះលោកបានស្រោចប្ដី ដែលខ្ញុំជាស្រីកំព្រាប្រាថ្នាហើយ ដោយទឹកអម្រឹត ដែលជាទីស្រឡាញ់ដោយវិសេសក្នុងទីដែលលោកជួបគ្នា។

[១៩] ឥឡូវនេះ យើងទាំងឡាយនឹងត្រាច់ទៅកាន់ស្ទឹងក្បែរភ្នំ និងស្ទឹងក្នុងព្រៃទាំងឡាយ ដែលមានផ្កាឈើអណ្ដែតទៅតាមខ្សែទឹក ព្រោងព្រាតទាំងមានឈើផ្សេងៗដុះហែរវិញ យើងទាំងឡាយនឹងពោលនូវពាក្យជាទីស្រឡាញ់ទៅវិញទៅមក។

ចប់ ចន្ទកិន្នរជាតក ទី២។

## មហាឧក្កុសជាតក ទី៣

CS sut.kn.jat.486 | ភាគទី ៦០

### (៤៨៦. មហាឧក្កុសជាតកំ (៣))

[២០] (ខ្លែងញីពោលថា) ម្នាលខ្លែងឈ្មោល ពួកអ្នកជនបទ ចងគប់ភ្លើងទាំងឡាយ ក្នុងកោះតូចៗ ប្រាថ្នានឹងស៊ីនូវកូនតូចៗរបស់ខ្ញុំ អ្នកចូរហៅនូវមិត្តផង សំឡាញ់ផង អ្នកចូរក្រាបទូលនូវសេចក្ដីវិនាសរបស់ពួកបក្សីជាញាតិ (នៃយើង ដល់ស្ដេចអកផង)។

[២១] (ខ្លែងឈ្មោល ក៏ទៅក្រាបទូលស្ដេចអកថា) បពិត្រស្ដេចអក ព្រះអង្គជាទិជជាតិផង ជាបក្សីប្រសើរជាងពួកទិជជាតិផង ខ្ញុំសូមយកព្រះអង្គជាទីពឹង ដ្បិតពួកអ្នកជនបទ អាក្រក់ណាស់ ប្រាថ្នានឹងស៊ីកូនតូចៗរបស់ខ្ញុំ សូមព្រះអង្គ (មេត្តាស្រោចស្រង់) ខ្ញុំ ឲ្យបានសេចក្ដីសុខ។

[២២] (ស្ដេចអកពោលថា) បណ្ឌិតទាំងឡាយ ជាអ្នកស្វែងរកសេចក្ដីសុខ ក្នុងកាលគួរ និងកាលមិនគួរ រមែងចងមិត្រផង សំឡាញ់ផង ម្នាលខ្លែងឈ្មោល យើងនឹងធ្វើនូវប្រយោជន៍នុ៎ះ ដល់អ្នកបាន ដ្បិតអរិយជនតែងធ្វើនូវកិច្ចដល់អរិយជន (ដូចគ្នា)។

[២៣] (ខ្លែង...) អំពើណាដែលអរិយជនជាអ្នកអនុគ្រោះ គប្បីធ្វើដល់អរិយជន អំពើនោះព្រះអង្គបានធ្វើហើយ សូមទ្រង់រក្សានូវព្រះអង្គចុះ សូមទ្រង់កុំក្ដៅក្រហាយឡើយ កាលបើព្រះអង្គរស់នៅ យើងគង់នឹងបាននូវកូនទាំងឡាយ (ទៀត)។

[២៤] (ស្ដេចអក...) យើងខំធ្វើនូវការរក្សា និងកិរិយាការពារនោះឯង ត្រាតែបែកធ្លាយនូវសរីរៈ ក៏មិនតក់ស្លុតដែរ ដ្បិតសំឡាញ់ទាំងឡាយនេះ តែងលះបង់ជីវិតជួយធ្វើ (កិច្ចការ) ដល់សំឡាញ់ផងគ្នា នេះជាធម៌របស់សប្បុរសទាំងឡាយ។

[២៥] (អភិសម្ពុទ្ធគាថា) ស្ដេចអកនេះ ជាសត្វស្លាបកើតអំពីស៊ុត បានធ្វើនូវអំពើដែលគេធ្វើដោយកម្រក្រៃពេក ដើម្បីប្រយោជន៍ (និងរក្សា) នូវកូនខ្លែងទាំងឡាយ ដរាបដល់ពាក់កណ្ដាលអធ្រាត្រ។

[២៦] (ខ្លែង...) បុគ្គលពួកខ្លះ ឃ្លាតចាក (យស ឬទ្រព្យ) ក៏មាន ភ្លាំងភ្លាត់ដោយកម្មរបស់ខ្លួន ក៏មាន ហើយត្រឡប់តាំងខ្លួនបានដោយសារសេចក្ដីអនុគ្រោះរបស់ពួកមិត្ត កូនទាំងឡាយរបស់ខ្ញុំ មានសេចក្ដីក្ដៅក្រហាយ ខ្ញុំមក (យកអ្នក) ជាគតិ (ទីពឹង) បពិត្រសត្វត្រាច់ទៅក្នុងទឹក ចូរអ្នកប្រព្រឹត្តប្រយោជន៍ដល់ខ្ញុំ។

[២៧] (អណ្ដើក...) បណ្ឌិតទាំងឡាយ តែងចងមិត្ត និងសំឡាញ់ដោយទ្រព្យផង ដោយស្រូវផង ដោយខ្លួនផង ម្នាលខ្លែង យើងនឹងធ្វើប្រយោជន៍នេះដល់អ្នកបាន ដ្បិតអរិយជនតែងធ្វើកិច្ចដល់អរិយជនដូចគ្នា។

[២៨] (កូនអណ្ដើក...) បពិត្រឪពុក អ្នកចូរជាបុគ្គលមានសេចក្ដីខ្វល់ខ្វាយតិច អង្គុយស្ងៀមចុះ កូនតែងប្រព្រឹត្តប្រយោជន៍ដល់ឪពុក ខ្ញុំនឹងជួយការពារនូវកូនខ្លែង ហើយប្រព្រឹត្តនូវប្រយោជន៍ជំនួសលោក។

[២៩] (អណ្ដើក...) ម្នាលកូន នេះជាធម៌របស់សប្បុរសទាំងឡាយ កូនត្រូវតែប្រព្រឹត្តប្រយោជន៍ដើម្បីឪពុកពិតមែនហើយ តែពួកអ្នកជនបទ មិនគប្បីបៀតបៀននូវកូនរបស់ខ្លែង ព្រោះឃើញនូវអញដែលមានកាយធំ។

[៣០] (ខ្លែង...) បពិត្រព្រះអង្គប្រសើរដោយសេចក្ដីព្យាយាមក្នុងពួកម្រឹគ ពួកសត្វចិញ្ចឹម និងពួកមនុស្សត្រូវភ័យគ្របសង្កត់ហើយ រមែងចូលទៅពឹងបុគ្គលដ៏ប្រសើរ កូនទាំងឡាយរបស់ខ្ញុំ មានសេចក្ដីក្ដៅក្រហាយ (ព្រោះហេតុនោះ) ខ្ញុំមក (យកព្រះអង្គ) ជាគតិ ព្រះអង្គជាស្ដេចរបស់យើង សូមព្រះអង្គមេត្តា (ស្រោចស្រង់) ខ្ញុំឲ្យបានសេចក្ដីសុខ។

[៣១] (សីហៈ...) ម្នាលខ្លែងឈ្មោល យើងនឹងធ្វើនូវប្រយោជន៍នុ៎ះដល់អ្នក មក យើងនឹងទៅសម្លាប់ពួកសត្រូវនោះរបស់អ្នក ធម្មតាអ្នកប្រាជ្ញ ជាអ្នកអាចនឹងសម្លាប់នូវសត្រូវបាន ដឹងច្បាស់ (នូវភ័យកើតឡើងដល់មិត្រ) មិនគប្បីប្រឹងប្រែងរក្សានូវជនដែលទុកដូចជាខ្លួនដូចម្ដេចកើត។

[៣២] (ខ្លែងញីនិយាយនឹងខ្លែងឈ្មោលថា) បុគ្គលគួរធ្វើ (នូវបុគ្គលណាមួយ) ឲ្យជាមិត្រផង ឲ្យជាសំឡាញ់ផង គួរធ្វើ (នូវបុគ្គលណាមួយ) ឲ្យជាម្ចាស់ផង ដើម្បីបាននូវសេចក្ដីសុខ យើងទាំងឡាយ (អាចកំចាត់បង់នូវពួកសត្រូវបាន ដោយកំឡាំងនៃមិត្ត) ហើយនឹងបានមូលមិត្រគ្នា រីករាយជាមួយនឹងកូនទាំងឡាយ ដូចជាបុគ្គលដែលមានអាវក្រោះពាក់ហើយ អាចរារាំងនូវកូនសរទាំងឡាយបានដូច្នោះ។

[៣៣] កូនតូចទាំងឡាយ (បញ្ចេញសម្លេងដ៏ពិរោះ) គួរឲ្យខ្លោចចិត្ត ហើយស្រែកហៅ (ខ្ញុំ) ដែលកំពុងស្រែកយំដោយសារសេចក្ដីព្យាយាមរបស់សីហៈជាមិត្ររបស់ខ្លួន ជាសំឡាញ់ ជាសត្វមិនរត់។

[៣៤] បណ្ឌិតនោះប្រើប្រាស់នូវកូន នូវសត្វចិញ្ចឹម ឬក៏នូវទ្រព្យ ព្រោះអាស្រ័យមិត្រសំឡាញ់ ខ្ញុំក្ដី ពួកកូនក្ដី ប្ដីរបស់ខ្ញុំក្ដី បានមូលមិត្រគ្នាដោយសេចក្ដីអនុគ្រោះរបស់ពួកមិត្ត។ បុគ្គល មានស្ដេចផង មានមិត្រដ៏ក្លៀវក្លាផង (ជាមិត្រហើយ) អាចសម្រេចប្រយោជន៍បាន ដ្បិតសំឡាញ់ទាំងឡាយនុ៎ះ រមែងមានដល់បុគ្គល ដែលបរិបូណ៌ដោយសំឡាញ់ បពិត្រស្វាមី អ្នកប្រាថ្នានូវកាម បុគ្គលអ្នកមានមិត្រ មានយស មានសេចក្ដីខ្ពង់ខ្ពស់នោះ រមែងរីករាយក្នុងលោកនេះ។

[៣៥] បពិត្រខ្លែងឈ្មោល បុគ្គលសូម្បីក្រខ្សត់ កំគួរធ្វើនូវមិត្តធម៌ អ្នកចូរមើលចុះ យើងទាំងឡាយ បានព្រមព្រៀងគ្នាជាមួយនឹងញាតិទាំងឡាយ ដោយសេចក្តីអនុគ្រោះរបស់មិត្រ។ បពិត្រខ្លែងឈ្មោល បក្សីណាធ្វើនូវមិត្រជាមួយនឹងបុគ្គលក្លៀវក្លា ជាមួយនឹងបុគ្គលមានកំឡាំង បក្សីនោះ រមែងបានសេចក្តីសុខយ៉ាងនេះ ដូចខ្ញុំ និងអ្នក។

ចប់ មហាឧក្កុសជាតក ទី៣។

## ឧទ្ទាលកជាតក ទី៤

CS sut.kn.jat.487 | ភាគទី ៦០

### (៤៨៧. ឧទ្ទាលកជាតកំ (៤))

[៣៦] (ព្រះរាជាទ្រង់ត្រាស់ថា) ពួកជដិលណា ដណ្តប់ស្បែកខ្លាឃ្មុំទាំងក្រចក មានធ្មេញប្រឡាក់ដោយមន្ទិល មានភ្នែកមិនបន្តក់ មានរូបអាក្រក់ កំពុងរាយនូវមន្ត ជដិលទាំងនោះ បានដឹងនូវការប្រព្រឹត្តិនូវតបៈ និងការស្វាធ្យាយន៍នូវមន្តនេះ ក្នុងសេចក្តីព្យាយាមជារបស់មនុស្ស នឹងបានរួចចាកអបាយដែរឬ។

[៣៧] (បុរោហិតក្រាបទូលថា) បពិត្រមហារាជ បើបុគ្គលជាពហុស្សូត មិនប្រព្រឹត្តធម៌ ធ្វើតែអំពើលាមកទាំងឡាយ បុគ្គលនោះ សូម្បីចេះនូវវេទមួយពាន់ ហើយអាស្រ័យនូវភាពជាពហុស្សូតនោះ តែមិនទាន់បានសម្រេចនូវចរណៈ (សមាបត្តិប្រាំបី) ទេ ក៏មិនគប្បីរួចចាកទុក្ខឡើយ។

[៣៨] (ឧទ្ទាលកតាបសពោលថា) បុគ្គលសូម្បីចេះនូវវេទមួយពាន់ហើយ អាស្រ័យនូវភាពជាពហុស្សូតនោះ តែមិនទាន់បានសម្រេចនូវចរណៈ (សមាបត្តិប្រាំបី) ទេ ក៏មិនគប្បីរួចចាកទុក្ខឡើយ ខ្ញុំសំគាល់ថាវេទទាំងឡាយ ជាសភាពឥតផល មានតែចរណៈដែលប្រកបដោយការសង្រួម ទើបជាការពិតប្រាកដ។

[៣៩] (បុរោហិត...) ខ្ញុំមិនមែនពោលថា វេទទាំងឡាយ ជាសភាពឥតផលទេ តែចរណៈដែលប្រកបដោយការសង្រួម ជារបស់ពិតមែន ឯបុគ្គលរៀននូវវេទទាំងឡាយ គ្រាន់តែបាននូវកិត្តិសព្ទ បុគ្គលអ្នកទូន្មានដោយចរណៈហើយ ទើបបានដល់នូវការស្ងប់រម្ងាប់ (និព្វាន)។

[៤០] (ឧទ្ទាលក...) មាតាបិតា និងផៅពង្ស ត្រូវតែកូនចិញ្ចឹម អាត្មាកើតអំពីបុគ្គលណា បុគ្គលនោះឯង នៅជាបុគ្គលនោះដដែល អាត្មាឈ្មោះឧទ្ទាលកៈ ជាអ្នកតវង្សត្រកូលនៃសោត្ថិយគោត្រដ៏ចំរើន។

[៤១] (បុរោហិត...) ម្នាលអ្នកដ៏ចំរើន បុគ្គលឈ្មោះថាព្រាហ្មណ៍ តើដោយប្រការដូចម្តេច បុគ្គលមានគុណធម៌បរិបូណ៌ តើដោយប្រការដូចម្តេច មួយទៀត ការរលត់កិលេស តើដោយប្រការដូចម្តេច បុគ្គលដែលគេហៅថា អ្នកតាំងនៅក្នុងធម៌ តើដោយប្រការដូចម្តេច។

[៤២] (ឧទ្ទាលកៈ...) បុគ្គលកាន់យកនូវភ្លើងហើយ ធ្វើនូវការបំរើមិនឲ្យមានចន្លោះ ឈ្មោះថាព្រាហ្មណ៍ ព្រាហ្មណ៍កាលស្រោចទឹក (អភិសេក) បូជា (នូវយ័ញ្ញ) ហើយលើកនូវសសរយ័ញ្ញ ព្រាហ្មណ៍ធ្វើយ៉ាងនេះ ឈ្មោះថាជាអ្នកមានសេចក្តីក្សេម (ជនទាំងឡាយហៅព្រាហ្មណ៍នោះ) ថា ជាអ្នកស្ថិតនៅក្នុងធម៌ដោយហេតុនោះ។

[៤៣] (បុរោហិត...) សេចក្តីបរិសុទ្ធិពុំមែនមានដោយការស្រោចទឹកទេ បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ អ្នកបរិបូណ៌ដោយគុណធម៌ ខន្តិសោរច្ចៈ និងបុគ្គលអ្នករំលត់ទុក្ខបាននោះ មិនមាន (ដោយការស្រោចទឹក ជាដើមទេ)។

[៤៤] (ឧទ្ទាលកៈ...) នែអ្នកដ៏ចំរើន បុគ្គលដែលឈ្មោះថាព្រាហ្មណ៍ តើដោយប្រការដូចម្តេច បុគ្គលដែលជាអ្នកមានគុណធម៌ដ៏បរិបូណ៌ តើដោយប្រការដូចម្តេច ម្យ៉ាងទៀត ការរំលត់កិលេស តើដោយប្រការដូចម្តេច បុគ្គលដែលគេហៅថាជាអ្នកឋិតនៅក្នុងធម៌ តើដូចម្តេច។

[៤៥] (បុរោហិត...) បុគ្គលមិនមានស្រែចំការ មិនមានផៅពង្ស មិនមានសេចក្តីប្រកាន់ មិនមានសេចក្តីប្រាថ្នា មិនមានសេចក្តីលោភដ៏លាមក អស់សេចក្តីជាប់ជំពាក់ក្នុងភព ព្រាហ្មណ៍ធ្វើយ៉ាងនេះ ទើបឈ្មោះថា ជាអ្នកដល់នូវសេចក្តីក្សេម (ជនទាំងឡាយ) ហៅ (ព្រាហ្មណ៍នោះ) ថាជាអ្នកឋិតនៅក្នុងធម៌ដោយហេតុនោះ។

[៤៦] (ឧទ្ទាលកៈ...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកចណ្ឌាល និងជនអ្នកកើបសម្រាម ពួកជនទាំងអស់ឈ្មោះថាជាអ្នកស្លូតបូត ជាអ្នកទូន្មានឥន្ទ្រិយបានហើយ ពួកជនទាំងអស់ឈ្មោះថា មានទុក្ខរលត់ហើយ គុណដ៏ប្រសើរ និងទោសដ៏លាមក មានដល់ជនទាំងអស់ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំ (ដែរឬ)។

[៤៧] (បុរោហិត...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាល និងជនអ្នកកើបសម្រាម ពួកជនទាំងអស់ដែលជាអ្នកស្លូតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួនជនទាំងអស់ ឈ្មោះថាមានទុក្ខរលត់ហើយ គុណដ៏ប្រសើរ និងទោសដ៏លាមកមិនមានដល់ពួកជនទាំងអស់ ដែលជាអ្នកមានសេចក្តីត្រជាក់ត្រជំឡើយ។

[៤៨] (ឧទ្ទាលកៈ...) ពួកក្សត្រ ពួកព្រាហ្មណ៍ ពួកអ្នកជំនួញ ពួកអ្នកងារ ពួកជនចណ្ឌាល និងជនអ្នកកើបសម្រាម ពួកជនទាំងអស់ដែលជាអ្នកស្លូតបូត មានឥន្ទ្រិយទូន្មានបានហើយ ពួកជនទាំងអស់ ឈ្មោះថាមានទុក្ខរលត់ហើយ គុណដ៏ប្រសើរ និងទោសដ៏លាមកមិនមានដល់ជនទាំងអស់ ដែលមានសេចក្តីត្រជាក់ត្រជំឡើយ (កាលបើយ៉ាងនេះ) អ្នកប្រព្រឹត្តនូវភាពនៃខ្លួនជាព្រហ្ម គួរឲ្យគេសរសើរហើយ ញុំាងវង្សត្រកូលនៃសោត្ថិយគោត្រ (ឲ្យវិនាស)។

[៤៩] (បុរោហិត...) វិមានដែលគេប្រក់ដោយសំពត់ទាំងឡាយ មានពណ៌ក្រហមផ្សេងៗ ស្រមោលរបស់សំពត់ទាំងនោះ មិនផ្សេងគ្នាឡើយ (មានសម្បុរតែមួយបែប) ការជ្រលក់នោះ ក៏មិនផ្សេងគ្នាដែរ (យ៉ាងណាមិញ) សូម្បីមនុស្សទាំងឡាយ ក៏យ៉ាងនោះដែរ ពួកមាណពបរិសុទ្ធ (ដោយអរិយមគ្គ) ក្នុងកាលណា ពួកជនមានវត្តល្អ បានដឹងនូវនិព្វានធម៌ ក៏មិនសាកសួរនូវជាតិរបស់មាណពទាំងនោះ (ក្នុងកាលនោះ) ឡើយ។

ចប់ ឧទ្ទាលកជាតក ទី៤។

## ភិសជាតក ទី៥

CS sut.kn.jat.488 | ភាគទី ៦០

[៥០] (ឧបកាញ្ចនតាបស ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបាននូវសេះផង គោផង ប្រាក់ផង មាសផង ប្រពន្ធជាទីគាប់ចិត្តក្នុងលោកនេះផង ចូរនៅមូលមិត្រគ្នាដោយកូន និងប្រពន្ធទាំងឡាយចុះ។

[៥១] (តាបសទី២ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរទ្រទ្រង់នូវផ្កាកម្រងផង នូវសំពត់ដែលគេនាំមកអំពីដែនកាសី និងខ្លឹមចន្ទន៍ផង ចូរឲ្យបុគ្គលនោះមានកូនច្រើនផង ចូរឲ្យ (បុគ្គលនោះ) ធ្វើនូវសេចក្ដីអាឡោះអាល័យដ៏ក្លៀវក្លាក្នុងកាមទាំងឡាយផង។

[៥២] (តាបសទី៣ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូករបស់លោក (បុគ្គលនោះ) ចូរមានស្រូវច្រើន មានកសិកម្ម មានយស (បាន) នូវកូនទាំងឡាយ ជាគ្រហស្ថមានទ្រព្យ ចូរ (បាន) នូវកាមគ្រប់យ៉ាង ចូរកុំឲ្យឃើញនូវវ័យ (របស់ខ្លួន) នៅគ្រប់គ្រងផ្ទះចុះ។

[៥៣] (តាបសទី៤ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបានជាក្សត្រ អ្នកធ្វើនូវការរឹបជាន់ ជារាជាធិរាជ មានពល មានយស ចូរបានគ្រប់គ្រងផែនដី ដែលមានសមុទ្រទាំង ៤ ជាទីបំផុតចុះ។

[៥៤] (តាបសទី៥ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះចូរជាព្រាហ្មណ៍ មិនប្រាសចាករាគៈ ចូរប្រកបក្នុងគន្លងក្បួនយាម និងនក្ខត្តឫក្ស បុគ្គលជាម្ចាស់នៃដែន (ស្ដេច) ដែលមានយស ចូរបូជាព្រាហ្មណ៍នោះចុះ។

[៥៥] (តាបសទី៦ ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក លោកទាំងអស់ ចូរសំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកស្វាធ្យាយនូវវេទ ព្រមទាំងមន្តគ្រប់យ៉ាង ថាជាអ្នកមានតបៈ ពួកអ្នកជនបទ ចូរឃើញហើយ បូជានូវបុគ្គលនោះចុះ។

[៥៦] (តាបសជាសំឡាញ់ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបរិភោគនូវស្រុកសួយដ៏ស្ដុកស្ដម្ភ ដែលកុះករដោយវត្ថុ[23] ៤ យ៉ាង ហាក់ដូចស្ដេចវាសវៈប្រទានឲ្យ ចូរដល់នូវមរណៈ ទាំងមិនទាន់បានប្រាសចាករាគៈចុះ។

[៥៧] (តាបសជាខ្ញុំប្រុស ស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គលណាលួចក្រអៅឈូកទាំងឡាយរបស់លោក បុគ្គលនោះ ចូរបានជាធំក្នុងស្រុក ចូររីករាយដោយការរាំ និងច្រៀងទាំងឡាយក្នុងកណ្ដាលនៃសំឡាញ់ កុំឲ្យបាននូវសេចក្ដីវិនាសតិចតួចអំពីស្ដេចឡើយ។

[៥៨] (នាងកាញ្ចនទេវី ស្បថថា) បពិត្រព្រាហ្មណ៍ ស្រីណាលួចក្រអៅឈូកទាំងឡាយរបស់លោក សូមឲ្យស្ដេចឯករាជដែលទ្រង់ឈ្នះនូវផែនដី លើកដំកើង (ស្រីនោះ) ឲ្យប្រសើរលើសជាងស្រីទាំងមួយពាន់ សូមឲ្យ (ស្រីនោះ) បានជាស្រីប្រសើរលើសជាងស្រីទាំងឡាយចុះ។

[៥៩] (នាងទាសីស្បថថា) បពិត្រព្រាហ្មណ៍ ទាសីណាលួចក្រអៅឈូកទាំងឡាយរបស់លោក ក៏បណ្ដាទាសីទាំងឡាយ ទាសីនោះ ចូរកុំញាប់ញ័រ (ក្នុងកណ្ដាល) នៃម្ចាស់ទាំងឡាយដែលជួបជុំគ្នាទាំងអស់ ចូរបរិភោគនូវវត្ថុមានរសឆ្ងាញ់ (ទាសីនោះ) ចូរប្រព្រឹត្តនិយាយកុហក ព្រោះហេតុតែលាភចុះ។

[៦០] (ទេវតាស្បថថា) បពិត្រព្រាហ្មណ៍ បុគ្គណាលួចក្រអៅឈូកទាំងឡាយរបស់លោក (បុគ្គលនោះ) ចូរបានជាចៅអាវាសក្នុងមហាវិហារចុះ ចូរធ្វើនូវនវកម្ម ក្នុងនគរឈ្មោះគជង្គលៈចុះ ចូរធ្វើនូវបង្អួចឲ្យហើយតែមួយថ្ងៃចុះ។

[៦១] (ដំរីស្បថថា) បពិត្រព្រាហ្មណ៍ ដំរីណាលួចក្រអៅឈូកទាំងឡាយរបស់លោក ដំរីនោះ ចូរជាប់ដោយអន្ទាក់ច្រើន ត្រង់កន្លែងទាំង ៦ (គឺជើងទាំង ៤ ក និងចង្កេះ) ចូរឲ្យគេនាំអំពីព្រៃជាទីរីករាយ ទៅកាន់រាជធានីចុះ ដំរីនោះ ចូរឲ្យគេចាក់ដោយកង្វេរទាំងឡាយ ដែលមានដងវែងមានបន្លាពីរចុះ។

[៦២] (ស្វាស្បថថា) បពិត្រព្រាហ្មណ៍ ស្វាណាលួចក្រអៅឈូកទាំងឡាយរបស់លោក (ស្វានោះ) ចូរមានប្រឡៅក ហើយគេចោះត្រចៀក បំពាក់សំណរចុះ ឲ្យហ្មពស់វាយដោយរំពាត់ ហើយចូរទៅរកមាត់ពស់ចុះ ឲ្យគេចងយ៉ាងមាំ ហើយដើរទៅកាន់ច្រកល្ហកចុះ។

[៦៣] (ព្រះមហាសត្វស្បថថា) នៃអ្នកដ៏ចំរើនទាំងឡាយ បុគ្គលណា ពោលនូវចំណែកដែលមិនបាត់ ថាបាត់ ម្យ៉ាងទៀត បុគ្គលណារង្កៀសបន្តិចបន្តួច (ចំពោះអ្នកទាំងឡាយ) បុគ្គលនោះ ចូរបាន និងចូរបរិភោគនូវកាមទាំងឡាយចុះ ចូរស្លាប់ក្នុងកណ្ដាលនៃផ្ទះចុះ។

[៦៤] (សក្កទេវរាជពោលថា) (សត្វទាំងឡាយ) រមែងស្វែងរកនូវវត្ថុកាម និងកិលេសកាមណាហើយ ត្រាច់ទៅក្នុងលោក វត្ថុកាម និងកិលេសកាមនុ៎ះ ជាទីប្រាថ្នាផង ជាទីរីករាយផង ជាទីស្រឡាញ់ផង ជាទីពេញចិត្តរបស់ទេវតា និងមនុស្សច្រើនគ្នា ក្នុងជីវលោកនេះ ចុះហេតុអ្វី ក៏ពួកឥសីមិនសរសើរនូវកាមទាំងឡាយ។

[៦៥] (មហាសត្វពោលថា) ជនទាំងឡាយ ត្រូវគេវាយ ត្រូវគេចង ព្រោះតែកាមទាំងឡាយ សេចក្ដីទុក្ខផង ភ័យផង ដែលកើតឡើង ក៏ព្រោះតែកាមទាំងឡាយ បពិត្រព្រះភូតាធិបតី ស័ត្វទាំងឡាយស្រវឹងព្រោះកាមទាំងឡាយ ធ្វើនូវអំពើទាំងឡាយដ៏លាមក ព្រោះវង្វេង។ ជនមានធម៌ដ៏លាមកទាំងឡាយនោះ ទទួលនូវបាប លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក ព្រោះហេតុនោះ បានជាពួកឥសីមិនសរសើរនូវកាមទាំងឡាយ ព្រោះឃើញទោសក្នុងកាមគុណទាំងឡាយ។

[៦៦] (សក្ក...) ខ្ញុំល្បងមើលទេ ខ្ញុំយកក្រអៅឈូកទាំងឡាយរបស់ឥសីក្បែរឆ្នេរទៅកប់ទុកលើគោក (ឥឡូវនេះ ខ្ញុំដឹងហើយថា) ឥសីទាំងឡាយ ជាអ្នកបរិសុទ្ធ មិនមានបាប បពិត្រលោកជាព្រហ្មចារី នុ៎ះក្រអៅឈូកទាំងឡាយរបស់លោក។

[៦៧] (មហាសត្វ...) ម្នាលទេវរាជ ជាសហស្សនេត្ត (ពួកយើង) មិនមែនជាអ្នករបាំរបស់អ្នកទេ ទាំងមិនមែនជាបុគ្គលគួរអ្នកលេងទេ មិនមែនជាផៅពង្ស ទាំងមិនមែនជាសំឡាញ់របស់អ្នកទេ ហេតុអ្វីក៏អ្នក (ធ្វើ) នូវសេចក្ដីមើលងាយចំពោះបុគ្គលដទៃ ហើយលេងជាមួយនឹងពួកឥសី។

[៦៨] (សក្ក...) បពិត្រតាបសដ៏ប្រសើរ លោកម្ចាស់ជាអាចារ្យរបស់ខ្ញុំផង ជាបិតារបស់ខ្ញុំផង ម្លប់ព្រះបាទរបស់លោកម្ចាស់នេះ សូមជាទីពឹង (របស់ខ្ញុំ) ដែលមានសេចក្ដីភ្លាំងភ្លាត់ហើយ បពិត្រតាបសមានប្រាជ្ញាដូចជាផែនដី សូមលោកម្ចាស់អត់នូវកំហុសម្ដង បណ្ឌិតទាំងឡាយ មិនមានសេចក្ដីក្រោធជាកំឡាំងទេ។

[៦៩] (មហាសត្វ...) កាលដែលពួកឥសី (នៅក្នុងព្រៃ) សូម្បីតែមួយយប់ ក៏ឈ្មោះថាបាននៅល្អហើយ ព្រោះថា យើងទាំងឡាយបានជួប

និងព្រះវាសវៈជាម្ចាស់នៃទេវតា ពួកអ្នកដ៏ចំរើនទាំងអស់គ្នា ចូរតាំងចិត្តឲ្យល្អចុះ ដ្បិតព្រាហ្មណ៍ (ជាអាចារ្យរបស់អ្នកទាំងឡាយ) បាននូវក្រអៅឈូកវិញហើយ។

[៧០] (អភិសម្ពុទ្ធគាថា) បងប្អូនប្រាំពីរនាក់ក្នុងកាលនោះគឺ តថាគត ១ សារីបុត្ត ១ មោគ្គល្លាន ១ កស្សប ១ អនុរុទ្ធ ១ បុណ្ណ ១ អានន្ទ ១។ ក្នុងកាលនោះ ប្អូនស្រី គឺនាងឧប្បលវណ្ណា ទាសី គឺនាងខុជ្ជុត្តរា ក្នុងកាលនោះ ខ្ញុំប្រុស គឺគហបតិឈ្មោះចិត្តៈ ទេវតា គឺសាតាគិរយក្ខ។ ក្នុងកាលនោះ ដំរីដ៏ប្រសើរ គឺដំរីឈ្មោះបាលិលេយ្យ ស្វាដ៏ប្រសើរ គឺមធុទៈ ក្នុងកាលនោះ ទេវរាជឈ្មោះសក្កៈ គឺកាឡុទាយី អ្នកទាំងឡាយចូរចាំទុកនូវជាតកយ៉ាងនេះចុះ។

ចប់ ភិសជាតក ទី៥។

## សុរុចិជាតក ទី៦

CS sut.kn.jat.489 | ភាគទី ៦០

### (៤៨៩. សុរុចិជាតកំ (៦ ))

[៧១] (នាងសុមេធាទេវី ពោលថា) ខ្ញុំជាមហេសីភរិយារបស់ព្រះបាទសុរុចិ ដែលព្រះអង្គទ្រង់នាំមកមុនដំបូង ព្រះបាទសុរុចិនាំខ្ញុំមកអស់មួយម៉ឺនឆ្នាំហើយ។ បពិត្រព្រាហ្មណ៍ ខ្ញុំនោះមិនដែលដឹងថា ខ្ញុំបានមើលងាយព្រះរាជាសុរុចិ ជាធំក្នុងដែនវិទេហៈ ព្រះអង្គគ្រប់គ្រងនូវក្រុងមិថិលា ដោយកាយ ដោយវាចា ឬដោយចិត្ត ក្នុងទីវាល ឬក្នុងទីកំបាំងមុខឡើយ។ បពិត្រឥសី សូមឲ្យបុត្តកើត (ក្នុងផ្ទៃរបស់ខ្ញុំ) ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ។

[៧២] ព្រះភស្តាផង ព្រះមាតាក្មេកផង ព្រះបិតាក្មេកផង ព្រះមាតាបង្កើត និងបិតាបង្កើតផង ជាទីគាប់ចិត្ត ជាទីស្រឡាញ់ (របស់ខ្ញុំ) បពិត្រព្រហ្ម ព្រះបិតាក្មេក និងព្រះមាតាក្មេកទាំងពីរនោះ រស់នៅដរាបណា ក៏ទូន្មានខ្ញុំដរាបនោះ។ ខ្ញុំនោះជាស្រីប្រកបដោយសេចក្តីមិនត្រេកអរ គឺការមិនបៀតបៀន ជាអ្នកប្រព្រឹត្តធម៌ដោយពិតប្រាកដ មិនខ្ជិលច្រអូស បានបំរើព្រះមាតាក្មេក និងព្រះបិតាក្មេកនោះដោយសេចក្តីគោរពទាំងយប់ទាំងថ្ងៃ។ បពិត្រឥសី សូមឲ្យបុត្រកើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ។

[៧៣] បពិត្រព្រាហ្មណ៍ ខ្ញុំមិនមានសេចក្តីប្រច័ណ្ឌ ឬសេចក្តីក្រោធចំពោះពួកស្រីទាំងមួយម៉ឺនប្រាំមួយពាន់ ដែលជាភរិយាជាមួយគ្នាក្នុងកាលណាម្តងឡើយ។ ខ្ញុំត្រេកអរ ចំពោះស្ត្រីទាំងនោះដោយប្រយោជន៍ ស្រីណាមួយ មិនជាទីស្រឡាញ់របស់ខ្ញុំ ឥតមានឡើយ ខ្ញុំអនុគ្រោះពួកស្ត្រីរួមប្តីទាំងអស់ សព្វៗ កាល ដូចជាខ្លួនឯង។ បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ។

[៧៤] ខ្ញុំមានឥន្ទ្រិយស្រស់ស្រាយសព្វៗកាល បានចិញ្ចឹមនូវទាសៈទាំងឡាយផង កម្មករទាំងឡាយផង បុគ្គលដែលត្រូវចិញ្ចឹមទាំងឡាយផង ពួកជនដទៃដែលរស់នៅដោយសារផង តាមសមគួរដល់ហេតុ។ បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ។

[៧៥] ខ្ញុំមានដៃលាងហើយ បានផ្គត់ផ្គង់នូវពួកសមណៈផង នូវពួកព្រាហ្មណ៍ផង នូវពួកវណិព្វកៈដទៃផង ដោយបាយ និងទឹកសព្វៗកាល។ បពិត្រឥសី សូមឲ្យបុត្រកើត ដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ។

[៧៦] ខ្ញុំជាស្ត្រីសង្រួមក្នុងសីលទាំងឡាយសព្វៗ កាល បានរក្សានូវឧបោសថ ប្រកបដោយអង្គទាំង ៨ អស់ថ្ងៃទី ១៤ ផង អស់ថ្ងៃទី ១៥ ផង អស់ថ្ងៃទី ៨ នៃបក្ខ័ផង អស់បាដិហារិយបក្ខផង។ បពិត្រឥសី សូមឲ្យបុត្រ កើតដោយកិរិយាពោលនូវពាក្យសច្ចៈនេះ កាលបើខ្ញុំនិយាយកុហក សូមឲ្យក្បាល (របស់ខ្ញុំ) បែកជាប្រាំពីរភាគចុះ។

[៧៧] (សក្កទេវរាជពោលថា) ម្នាលនាងរាជបុត្រីមានយសដ៏ចំរើន នាងបានថ្លែងនូវធម្មគុណទាំងឡាយណា (ដែលមាន) ក្នុងខ្លួន ធម្មគុណនោះទាំងអស់ មានបរិបូណ៌ចំពោះនាងមែនហើយ។ ព្រះរាជបុត្រជាក្សត្របរិបូណ៌ដោយជាតិ កើតបរិសុទ្ធអំពីចំណែកទាំងពីរ មានយស ជាស្តេចប្រកបដោយធម៌ របស់ជនទាំងឡាយ អ្នកនៅក្នុងដែនវិទេហៈ នឹងកើតដល់នាង។

[៧៨] (នាងសុមេធាទេវី...) អ្នកមានភ្នែកភ្លឺថ្លា ទ្រទ្រង់នូវលំអង ឋិតនៅលើអាកាសទទេ ពោលវាចាជាទីពេញចិត្ត ដែលជាវាចាចូលទៅក្នុងហឫទ័យរបស់ខ្ញុំ។ ចុះអ្នកជាទេវតា ទើបនឹងមកអំពីឋានសួគ៌ ឬជាឥសីអ្នកមានឫទ្ធិច្រើន ម្យ៉ាងទៀត អ្នកជាអ្វី បានមកដល់ (ក្នុងទីនេះ) ចូរអ្នកប្រកាសខ្លួនឲ្យជាក់ដល់ខ្ញុំ។

[៧៩] (សក្កទេវរាជ...) ពួកទេវតាប្រជុំគ្នាក្នុងរោងឈ្មោះសុធម្មា ហើយថ្វាយបង្គំនូវខ្ញុំណា ខ្ញុំនោះឈ្មោះសក្កៈ ជាអ្នកឃើញនូវហេតុមួយពាន់ (ដោយមួយរំពេច) បានមកក្នុងសំណាក់នាង។ ស្ត្រីទាំងឡាយណា ក្នុងជីវលោក ដែលជាអ្នកប្រព្រឹត្តស្មើ មានប្រាជ្ញា មានសីល ទុកម្តាយក្មេកដូចជាទេវតា មានវត្តចំពោះប្តី។ ទេវតាទាំងឡាយមិនមែនជាមនុស្ស មកចួបនឹងនាងនារី ជាមនុស្សដែលមានបញ្ញាល្អ មានការងារដ៏ស្អាត ប្រាកដស្មើដោយស្ត្រីទាំងនោះ។ ម្នាលនាងដ៏ចំរើន នាងបានមកកើតក្នុងរាជត្រកូលនេះ ជាស្ត្រីអាចសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាង ដោយសារអំពើសុចរិត ដែលនាងបានសាងសន្សំមកក្នុងកាលមុន។

ម្នាលនាងរាជបុត្រី នេះឯងជាកិរិយាកាន់យកនូវជ័យនៃនាង ក្នុងលោកទាំងពីរ គឺកិរិយាកើតក្នុងទេវលោក ១ កេរ្តិ៍ឈ្មោះក្នុងជីវិតនេះ ១។ ម្នាលនាងសុមេធា សូមឲ្យនាងមានសេចក្តីសុខអស់កាលយូ នាងចូររក្សានូវធម៌ក្នុងខ្លួនចុះ យើងនឹងទៅកាន់ឋានត្រៃត្រឹង្សវិញ ការបានចួបនឹងនាង រាប់ថាជាទីស្រឡាញ់ពេញចិត្តរបស់យើង។

ចប់ សុរុចិជាតក ទី៦។

## បញ្ចុបោសថិកជាតក ទី៧

CS sut.kn.jat.490 | ភាគទី ៦០

### (៤៩០. បញ្ចុបោសថិកជាតកំ (៧ ))

[៨០] (តាបសពោលថា) ម្នាលព្រាប ឥឡូវនេះ អ្នកមានសេចក្តីខ្វល់ខ្វាយតិច ម្នាលបក្សី អ្នកមិនមានសេចក្តីត្រូវការដោយចំណីសោះ ម្នាលព្រាប អ្នកខំអត់ទ្រាំនូវគំលាន និងសម្រេក ជាសត្វរក្សានូវឧបោសថ តើព្រោះហេតុអ្វី។

[៨១] (ព្រាបពោលថា) ក្នុងកាលមុន ខ្ញុំមានចិត្តជាប់នឹងមេព្រាប យើងខ្ញុំទាំងពីរនាក់កំពុងតែរីករាយ (ក្នុងកាម) ក្នុងប្រទេសនោះ ស្រាប់តែសត្វខ្លែង មកឆាប់យកមេព្រាបទៅ ខ្ញុំក៏អស់សេចក្តីប្រាថ្នា ព្រោះប្រាសចាកមេព្រាបនោះ។ ខ្ញុំរងនូវវេទនាធំក្នុងចិត្ត ព្រោះព្រាត់ប្រាសចាកមេព្រាបនោះ ហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យរាគៈគ្របសង្កត់ខ្ញុំបានទៀតឡើយ។

[៨៣] (តាបស...) ម្នាលពស់ ជាឧរគជាតិលូនទៅមិនត្រង់ មានអណ្តាតពីរ អ្នកមានចង្កូមជាអាវុធ មានពិសដ៏ពន្លឹក ម្នាលសត្វមានខ្លួនវែង អ្នកអត់ទ្រាំនូវគំលាន និងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី។

[៨៣] (ពស់...) គោឈ្មោលឡើងក របស់អ្នកស្រុក ជាគោមានកំលាំង មានបូកដ៏យុរយារ បរិបូណ៌ដោយសម្បុរ និងកំលាំង គោនោះដើរជាន់ខ្ញុំ ខ្ញុំខឹង បានចឹកវា ៗ ត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏ស្លាប់ទៅ។ លំដាប់នោះ ពួកជនចេញអំពីស្រុកកន្ទក់កន្ទេញ យំទួញ ហើយដើរចៀសចេញទៅ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យសេចក្តីក្រោធ គ្របសង្កត់ខ្ញុំបានទៀតឡើយ។

[៨៤] (តាបស...) ក្នុងព្រៃស្មសាន មានសាច់របស់សត្វស្លាប់ដ៏ច្រើន សាច់ទាំងនុ៎ះជាភោជនជាទីគាប់ចិត្តរបស់អ្នក ម្នាលចចក អ្នកខំអត់ទ្រាំនូវគំលាន និងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី។

[៨៥] (ចចក...) ខ្ញុំជាសត្វត្រេកអរក្នុងសាកសព ញ៉ាំមក្នុងសាច់ដំរីទាំងឡាយ បានចូលទៅក្នុងពោះនៃដំរីធំ ខ្យល់ដ៏ក្តៅផង រស្មីព្រះអាទិត្យដ៏ក្លៀវក្លាផង របស់ទាំងនោះ ញាំងទ្វារអាហាចាស់នៃដំរីនោះ ឲ្យស្ងួតក្រៀម។ បពិត្រលោកម្ចាស់ដ៏ចំរើន ខ្ញុំស្គមស្លៀង (ក្នុងពោះនៃដំរីនោះ) ខ្ញុំរកផ្លូវចេញមកវិញមិនរួច ស្រាប់តែភ្លៀងធំបង្អុរចុះភ្លាម (ក្នុងពេលនោះ) ភ្លៀងនោះ ធ្វើទ្វារអាហារចាស់នៃដំរីនោះ ឲ្យទទឹកសើម។ បពិត្រលោកម្ចាស់ដ៏ចំរើន លំដាប់នោះ ទើបខ្ញុំចេញមក ដូចជាព្រះចន្ទ ដែលរួចអំពីមាត់នៃរាហុ ព្រោះហេតុនោះ បានជាខ្ញុំរក្សានូវឧបោសថ កុំឲ្យលោភៈគ្របសង្កត់ខ្ញុំបានទៀតឡើយ។

[៨៦] (តាបស...) កាលពីដើម អ្នកធ្លាប់ស៊ីនូវកណ្តៀរទាំងឡាយលើក្បាលដំបូក ម្នាលខ្លាឃ្មុំ អ្នកខំអត់ទ្រាំនូវគំលាន និងសម្រេក ហើយរក្សានូវឧបោសថ តើព្រោះហេតុអ្វី។

[៨៧] (ខ្លាឃ្មុំ...) ខ្ញុំមើលងាយនូវលំនៅរបស់ខ្លួន បានចូលទៅកាន់ស្រុកនៃមល្លជន ព្រោះតែសេចក្តីប្រាថ្នាលើសលប់ គ្រានោះ ពួកជនចេញមកពីស្រុក ហើយក៏វាយខ្ញុំដោយធ្នូរ។ ខ្ញុំនោះបែកក្បាល ប្រឡាក់ឈាមអស់ទាំងខ្លួន ហើយត្រឡប់មកកាន់លំនៅរបស់ខ្លួនវិញ ព្រោះហេតុនោះ បានជាខ្ញុំរក្សាឧបោសថ កុំឲ្យសេចក្តីប្រាថ្នាលើសលប់គ្របសង្កត់បានទៀតឡើយ។

[៨៨] (សត្វទាំង ៤...) បពិត្រលោកម្ចាស់ដ៏ចំរើន លោកម្ចាស់បានសាកសួរនូវសេចក្តីណា ចំពោះយើងទាំងឡាយ យើងទាំងអស់គ្នាក៏បានឆ្លើយនូវសេចក្តីនោះ តាមទំនងដែលខ្លួនបានដឹងរួចហើយ បពិត្រលោកម្ចាស់ដ៏ចំរើន ពួកយើងសូមសួរលោកម្ចាស់វិញ បពិត្រព្រហ្មលោកម្ចាស់បានរក្សាឧបោសថ តើព្រោះហេតុអ្វី។

[៨៩] (តាបស...) ព្រះបច្ចេកពុទ្ធ មិនប្រឡាក់ (ដោយកិលេស) គង់ក្នុងអាស្រមរបស់យើងមួយរំពេច ព្រះអង្គបានញ៉ាំងយើង ឲ្យដឹងនូវទីដែលត្រូវទៅ និងទីដែលត្រូវមកផង នូវនាមផង នូវគោត្រផង នូវសេចក្តីប្រព្រឹត្តទាំងអស់ផង។ បើទុកជាយ៉ាងនេះ ក៏យើងនៅតែមិនថ្វាយបង្គំព្រះបាទានៃព្រះបច្ចេកពុទ្ធនោះ ម្យ៉ាងទៀត យើងមិនបានសាកសួរ ព្រោះលុះក្នុងអំណាច ហេតុនោះ បានជាយើងរក្សាឧបោសថ កុំឲ្យមានះគ្របសង្កត់យើងបានទៀតឡើយ។

ចប់ បញ្ចុបោសថិកជាតក ទី៧។

## មហាមោរជាតក ទី៨

CS sut.kn.jat.491 | ភាគទី ៦០

### (៤៩១. មហាមោរជាតកំ (៨ ))

[៩០] (ស្តេចក្ងោកពោធិសត្វពោលថា) ម្នាលសំឡាញ់ ប្រសិនបើអ្នកចាប់ខ្ញុំ ព្រោះហេតុនៃទ្រព្យ អ្នកកុំសម្លាប់ខ្ញុំឡើយ សូមចាប់ខ្ញុំទាំងរស់ ហើយនាំខ្ញុំទៅកាន់សំណាក់ព្រះរាជាចុះ អ្នកទំនងជានឹងបាននូវទ្រព្យដ៏ច្រើន។

[៩១] (កូនព្រានព្រៃពោលថា) ធ្នូដ៏ប្រសើរ និងព្រួញនេះ ខ្ញុំមិនមែនឃឹត ប្រុងប្រៀបដើម្បីនឹងបាញ់អ្នក្នុងថ្ងៃនេះទេ ខ្ញុំនឹងបាញ់ផ្តាច់អន្ទាក់របស់អ្នកទេតើ (ដោយគិតថា) ស្តេចក្ងោកចូរទៅតាមសប្បាយចុះ។

[៩២] (ស្តេចក្ងោក...) អ្នកខំអត់ទ្រាំនូវសេចក្តីស្រេកឃ្លាន ទាំងយប់ទាំងថ្ងៃ ដើរជាប់តាមខ្ញុំអស់ប្រាំពីរឆ្នាំហើយ កាលបើយ៉ាងនេះ ព្រោះហេតុអ្វី ក៏អ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ ឲ្យរួចអំពីអន្ទាក់វិញ។ អ្នកទើបនឹងវៀរថាកបាណាតិបាតក្នុងថ្ងៃនេះឬ ឬក៏អ្នកឲ្យអភ័យដល់សត្វទាំងពួង បានជាអ្នកចង់ដោះខ្ញុំ ដែលកំពុងជាប់អន្ទាក់ ឲ្យរួចចាកអន្ទាក់វិញ។

[៩៣] (កូនព្រានព្រៃ...) ម្នាលស្តេចក្ងោក អ្នកចូរប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួងផង ខ្ញុំសូមសួរអ្នកត្រង់សេចក្តីនុ៎ះ បុគ្គលនោះច្យុតអំពីលោកនេះទៅ នឹងបាននូវសេចក្តីសុខដូចម្តេចខ្លះ។

[៩៤] (ស្តេចក្ងោក...) ខ្ញុំនឹងប្រាប់អំពីបុគ្គលដែលវៀរចាកបាណាតិបាតផង អ្នកដែលឲ្យនូវអភ័យដល់សត្វទាំងពួង បុគ្គលនោះរមែងបាននូវសេចក្តីសរសើរ ក្នុងបច្ចុប្បន្នផង លុះបែកធ្លាយសរីរៈទៅ នឹងបានទៅកើតនៅឋានសួគ៌ផង។

[៩៥] (កូនព្រាប...) សមណព្រាហ្មណ៍ពួកខ្លះ បានពោលថា ទេវតាទាំងឡាយ មិនមានទេ ជីវៈក្នុងលោកនេះ រមែងដល់នូវសេចក្តីដាច់សូន្យ ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ រមែងដល់នូវសេចក្តីដាច់សូន្យដូចគ្នា ទាំងពោលថា ទានជាគុណជាតិ គឺមនុស្សល្ងង់បញ្ញត្តហើយ ខ្ញុំជឿពាក្យរបស់សមណព្រាហ្មណ៍ ជាព្រះអរហន្តទាំងនោះ ហេតុនោះបានជាខ្ញុំសម្លាប់សត្វស្លាបទាំងឡាយ។

[៩៦] (ស្តេចក្ងោក...) ព្រះចន្ទ និងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿងទៅឰដ៏អាកាស ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ (ជារបស់) លោកនេះ ឬលោកដទៃ (ពួកជន) ក្នុងមនុស្សលោកហៅព្រះចន្ទ និងព្រះអាទិត្យទាំងនោះថាជាអ្វី។

[៩៧] (កូនព្រាន...) ព្រះចន្ទ និងព្រះអាទិត្យទាំងពីរ ជារបស់ឃើញងាយ ភ្លឺរុងរឿងទៅព្ធដំអាកាស ព្រះចន្ទ និងព្រះអាទិត្យទាំងនោះ (ជារបស់) លោកដទៃ មិនមែនរបស់លោកនេះទេ ពួកជនក្នុងមនុស្សលោក ហៅព្រះចន្ទ នឹងព្រះអាទិត្យទាំងនោះ ថាជាទេវតា។

[៩៨] (ស្តេចក្ងោក...) សមណព្រាហ្មណ៍ណាមិនពោលអាងកម្ម មិនពោលអាងផលនៃកម្ម ដែលសត្វធ្វើល្អ ធ្វើអាក្រក់ មួយទៀត សមណព្រាហ្មណ៍ណា ពោលថា ទានជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយ សមណព្រាហ្មណ៍ទាំងនោះ ជាអ្នកហីនវាទ ជាអ្នកអហេតុកវាទ ត្រូវគេដេញជើង ទាល់ក្នុងព្យាករណ៍នេះមិនខាន។

[៩៩] (កូនព្រានព្រៃ...) ពាក្យរបស់អ្នកនុ៎ះទៀងពិត ព្រោះទានជាគុណជាតឥតផលដូចម្តេចកើត ផលនៃអំពើដែលសត្វធ្វើល្អ ធ្វើអាក្រក់ក៏ដូចគ្នា ម្យ៉ាងទៀត (ទាន) ជាគុណជាតដែលមនុស្សល្ងង់បញ្ញត្តហើយដូចម្តេចកើត។ ខ្ញុំធ្វើអំពើដូចម្តេច ធ្វើដោយហេតុដូចម្តេច ប្រព្រឹត្តដូចម្តេច សេពនូវអ្វី ដោយគុណនៃតបៈដូចម្តេច មិនគប្បីធ្លាក់ទៅក្នុងនរកយ៉ាងណា ម្នាលស្តេចក្ងោក អ្នកសូមប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ ដោយឧបាយយ៉ាងនោះ។

[១០០] (ស្តេចក្ងោក...) ពួកសមណៈណាមួយនៅលើផែនដី ជាអ្នកស្លៀកសំពត់កាសាវៈ ប្រព្រឹត្តក្នុងភេទនៃបុគ្គលគ្មានផ្ទះ ត្រាច់ទៅបិណ្ឌបាតអំពីព្រឹក ក្នុងកាលគួរ វៀរចាកកិរិយាត្រាច់ទៅក្នុងកាលខុស ជាអ្នកស្ងប់រម្ងាប់។ អ្នកចូរចូលទៅរកសមណៈទាំងនោះ តាមកាលគួរក្នុងទីនោះ ហើយចូរសាកសួរចុះ ប្រយោជន៍ណា ដែលជាទីពេញចិត្តរបស់អ្នក លោកនឹងប្រាប់នូវប្រយោជន៍នោះ ជាប្រយោជន៍ក្នុងលោកនេះ និងក្នុងលោកខាងមុខ (ដល់អ្នក) តាមទំនងនៃការចេះដឹង (របស់លោក)។

[១០១] (កូនព្រានព្រៃបានត្រាស់ជាព្រះបច្ចេកពុទ្ធ ហើយក៏សំដែងថា) ភាពជាព្រានព្រៃនុ៎ះ អាត្មាអញបានលះបង់ហើយ អាត្មាអញបានលះបង់នូវភាពនៃខ្លួនជាព្រានព្រៃក្នុងថ្ងៃនេះ ដូចពស់សកនូវសំណកចាស់ជាន់មុន ឬក៏ដូចដើមឈើមានស្លឹកខៀវ (ជម្រុះចោល) នូវស្លឹកលឿង។

[១០២] (បច្ចេកពុទ្ធធ្វើសច្ចកិរិយាថា) ពួកបក្សីណាច្រើនរយ ដែលអាត្មាអញបានចងទុកក្បែរលំនៅ (របស់ខ្លួន) អាត្មាអញនឹងឲ្យនូវជីវិតដល់សត្វទាំងឡាយនោះ ក្នុងថ្ងៃនេះ អាត្មាអញបានរួចចាកកិលេសហើយ សត្វទាំងនោះ ចូរទៅកាន់លំនៅរបស់ខ្លួនចុះ។

[១០៣] (អភិសម្ពុទ្ធគាថា) ព្រានព្រៃមានអន្ទាក់ក្នុងដៃ ត្រាច់ទៅក្នុងព្រៃ ដើម្បីទាក់នូវស្តេចក្ងោក ដែលមានយស លុះទាក់នូវស្តេចក្ងោកដែលមានយសបានហើយ ក៏បានរួចចាកសេចក្តីទុក្ខ ដូចតថាគតដែលបានរួច (ចាកទុក្ខ ដោយសយម្ភូញាណ) ដូច្នោះដែរ។

ចប់ មហាមោរជាតក ទី៨។

## តច្ឆសូករជាតក ទី៩

CS sut.kn.jat.492 | ភាគទី ៦០

### (៤៩២. តច្ឆសូករជាតកំ (៩))

[១០៤] (ជ្រូកឈ្មោះតច្ឆកៈពោលថា) យើងកាលស្វែងរកពួកញាតិណា ដើរទៅកាន់ភ្នំ និងព្រៃទាំងឡាយ យើងតាមស្វែងរកពួកញាតិដ៏ច្រើន ឯពួកញាតិទាំងនោះ យើងបានជួបហើយ។ មើមឈើ និងផ្លែឈើនេះដ៏ច្រើនផង ភក្សាហារនេះច្រើនផង ភ្នំ និងស្ទឹងទាំងនេះជាទីរីករាយផង ជាលំនៅដ៏សប្បាយ។ យើងនឹងមិនមានសេចក្តីខ្វល់ខ្វាយ មិនមានសេចក្តីរង្កៀស មិនមានសេចក្តីសោក មិនមានភ័យអំពីទីណា នឹងនៅក្នុងទីនេះឯង ជាមួយនឹងពួកញាតិទាំងអស់។

[១០៥] (ពួកជ្រូកឯទៀតពោលថា) ម្នាលតច្ឆកៈ អ្នកចូរស្វែងរកទីជ្រកកោនឯទៀតវិញចុះ (ដ្បិត) ក្នុងទីនេះ មានសត្រូវចំពោះពួកយើង សត្រូវនោះ តែងមកក្នុងទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយ (សំដៅតែជ្រូកណា) ដែលធាត់ៗ។

[១០៦] (តច្ឆកៈ...) សត្វណាជាសត្រូវនឹងពួកយើងក្នុងទីនេះ សត្វណាកំចាត់បង់នូវញាតិ កំពុងនៅចួបជុំគ្នា ដែលសត្រូវកំចាត់បង់បានដោយក្រ អ្នក ខ្ញុំសួរហើយ ចូរប្រាប់នូវហេតុនោះ។

[១០៧] (ពួកជ្រូក...) ម្រឹគ (មួយ) ជាស្តេចនៃម្រឹគ មានក្រឡានៃសរីរៈខាងលើ មានកំលាំងកាយ មានចង្កូមជាអាវុធ ម្នាលតច្ឆកៈ ម្រឹគនោះមកក្នុងទីនេះ ហើយសម្លាប់ជ្រូកទាំងឡាយដែលធាត់ៗ។

[១០៨] (តច្ឆកៈ...) ខ្នាយទាំងឡាយរបស់ពួកយើង មិនមែនជាមិនមានទេ កំលាំងក៏ប្រជុំចុះក្នុងកាយ បើពួកយើងទាំងអស់ជាអ្នកព្រមព្រៀងគ្នា នឹងធ្វើខ្លាតែម្នាក់ឯងនោះ ឲ្យលុះអំណាចបាន។

[១០៩] (ពួកជ្រូក...) ម្នាលតច្ឆកៈ អ្នកពោលនូវពាក្យជាទីគាប់ចិត្ត គាប់ត្រចៀកណាស់ ដូច្នេះ ប្រសិនបើជ្រូកណា បោលចោលគ្នាក្នុងចំបាំង យើងនឹងសម្លាប់ជ្រូកនោះ ក្នុងកាលជាខាងក្រោយ។

[១១០] (កូដជដិល...) ម្នាលអ្នកមានព្យាយាមជាងពួកម្រឹគ ក្នុងថ្ងៃនេះ អ្នកវៀរចាកបាណាតិបាតឬ ឬក៏អ្នកឲ្យអភ័យដល់ពួកសត្វទាំងអស់ ឬមួយអ្នកមិនមានចង្កូម បានជាអ្នកទៅចួបនឹងហ្វូង (ជ្រូក) ហើយសញ្ជប់សញ្ជឹង ដូចជាសត្វកំព្រា។

[១១១] (ខ្លា...) ខ្ញុំមិនមែនជាមិនមានចង្កូមទេ កំឡាំងក៏ប្រជុំចុះក្នុងកាយ ខ្ញុំម្នាក់ឯង បានឃើញពួកញាតិរបស់ជ្រូកព្រមព្រៀងគ្នាក្នុងទីតែមួយ ហេតុនោះ បានជាសញ្ជប់សញ្ជឹងក្នុងព្រៃ។

បានឮថា ក្នុងកាលមុន ជ្រូកទាំងឡាយនេះ តែងទៅកាន់ទិសតូចធំ លុះភ័យគ្របសង្កត់ហើយ ក៏ស្វែងរកទីជ្រកកោនផ្សេងៗ គ្នា ឥឡូវនេះ ជ្រូកទាំងនោះឋិតនៅក្នុងទីណា ដែលខ្ញុំគ្របសង្កត់បានដោយលំបាក ជ្រូកទាំងនោះក៏មកនៅចួបជុំជាមួយគ្នា (ក្នុងទីនោះ)។

ជ្រូកទាំងឡាយនោះ បរិបូណ៌ដោយនាយក ប្រុងប្រៀបខ្លួន មូលមាត់គ្នា ព្រមព្រៀងគ្នា គប្បីបៀតបៀននូវខ្ញុំ ព្រោះហេតុនោះ ខ្ញុំមិនប្រាថ្នានូវជ្រូកទាំងនោះទេ។

[១១២] (កូដជដិល...) ព្រះឥន្ទ្រតែមួយអង្គ ឈ្នះនូវពួកអសុរៈ ខ្លែងតែមួយ សង្គ្រុបឆាបយកនូវពួកបក្សីបាន ខ្លាតែមួយ ចួបប្រទះនឹងម្រឹគក៏សម្លាប់នូវម្រឹគដែលធាត់ៗ បាន ដ្បិតថាកំលាំង (នៃខ្លានោះ) ប្រាកដដូច្នោះ។

[១១៣] (ខ្លា...) មិនថាព្រះឥន្ទ្រ មិនថាខ្លែង មិនថាខ្លា ជាស្តេចនៃម្រឹគទេ ខ្លាមិនធ្វើ (នូវពួកជ្រូក) ដែលមានញាតិព្រមព្រៀងគ្នាប្រុងប្រៀបខ្លួនទុក ឲ្យលុះក្នុងអំណាចបានឡើយ។

[១១៤] (កូដជដិល...) ពួកបក្សីតូចៗ ឈ្មោះកុម្ភិលិកា មានហ្វូងហើរទៅទាំងហ្វូង រីករាយរកគ្នា ហើរទៅរកចំណីក៏ជាមួយគ្នា បានចំណីហើយ ហើរទៅ (តាមអាកាស) ក៏ជាមួយគ្នា។ កាលបក្សីទាំងនោះ កំពុងមូលមិត្រគ្នា បណ្តាបក្សីទាំងនោះ គង់មានបក្សីមួយហើរឃ្លាតពីគេ មិនខាន ខ្លែងឆាបយកនូវបក្សីដែលហើរឃ្លាតពីគេនោះបាន នោះជាគតិរបស់ខ្លា។

[១១៥] (អភិសម្ពុទ្ធគាថា) (ខ្លានោះ) ត្រូវជដិលអាក្រក់ ដែលមានភ្នែកសំឡឹងតែអាមិសបញ្ឆោរហើយ អាងខ្លួនមានចង្កូម ស្មានថាដូចមុន ក៏ស្ទុះទៅរកពួកជ្រូក ដែលមានខ្នាយដែរ។

[១១៦] (រុក្ខទេវតា...) គួរឲ្យសរសើរដែរ ពួកញាតិច្រើនរូប សូម្បីតែឈើដែលដុះក្នុងព្រៃ (ក៏គួរឲ្យសរសើរ) ខ្លា (ម្នាក់ឯង) ត្រូវពួកជ្រូកព្រមគ្នា សម្លាប់បានក្នុងផ្លូវតែមួយ។

[១១៧] (អភិសម្ពុទ្ធគាថា) ជ្រូកទាំងឡាយបានសម្លាប់នូវព្រាហ្មណ៍ និងខ្លាធំ ទាំងពីរនាក់បានហើយ ក៏ត្រេកអររីករាយ ស្រែកនូវសម្រែកដ៏ខ្លាំង។

[១១៨] ជ្រូកទាំងឡាយនោះ ប្រជុំគ្នាទៀបគល់នៃល្វា អភិសេកជ្រូកឈ្មោះតច្ឆកៈថា សូមព្រះអង្គជាស្តេច ជាឥស្សរៈរបស់ពួកយើង។

ចប់ តច្ឆសូករជាតក ទី៩។

## មហាវាណិជជាតក ទី១០

CS sut.kn.jat.493 | ភាគទី ៦០

### (៤៩៣. មហាវាណិជជាតកំ (១០ ))

[១១៩] (ព្រះសាស្តាទ្រង់ត្រាស់ថា) ពាណិជទាំងឡាយ ជាអ្នកស្វែងរកទ្រព្យ មកអំពីដែនផ្សេងៗ ធ្វើនូវការប្រជុំ (ក្នុងក្រុងពារាណសី) ធ្វើបុគ្គលម្នាក់ឲ្យជាធំ ហើយចៀសចេញទៅ។ ពាណិជទាំងឡាយនោះ មកដល់ផ្លូវឆ្ងាយដាច់ស្រយាលនោះ ជាផ្លូវមិនមានស្បៀងអាហារ មិនមានទឹក បានឃើញនូវដើមជ្រៃធំ មានម្លប់ត្រជាក់ជាទីរីករាយនៃចិត្ត។ ឯពាណិជទាំងនោះ ជាបុគ្គលល្ងង់ ត្រូវមោហៈបិទបាំង ក៏អង្គុយក្រោមម្លប់ឈើនោះក្នុងទីនោះ ហើយប្រឹក្សាគ្នាថា យីអើ ឈើនេះហាក់ដូចជាសើមដោយទឹក ហាក់ដូចជាមានទឹកហូរទៅ បើដូច្នោះ យើងជាពួកឈ្មួញ នឹងកាប់នូវមែកឈើខាងកើត។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាប់ដាច់ភ្លាម ក៏ស្រក់ទឹកចេញ ឯទឹកក៏ថ្លាមិនល្អក់ ពាណិជទាំងនោះ បានងូតផឹកក្នុងទីនោះ ដរាបដល់អស់ចំណង់។ ពួកឈ្មួញពាល ត្រូវមោហៈបិទបាំង ប្រឹក្សានូវហេតុទី ២ ថា បើដូច្នោះ ពួកយើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងត្បូងនោះទៀត។ សោតឯមែកឈើនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវបាយនៃស្រូវសាលី ដ៏លាយដោយសាច់ដ៏ច្រើន នូវនំកុម្មាស ហាក់ដូចជាបាយាសមានទឹកតិច នូវសម្លកក្កូរ និងសម្លសណ្តែកបាយ ពាណិជទាំងនោះ បានបរិភោគទំពារស៊ីក្នុងទីនោះដរាបទាល់តែអស់ចំណង់។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សាគ្នានូវហេតុទី ៣ ថា បើដូច្នោះ យើងជាពួកឈ្មួញនឹងកាត់មែកឈើខាងលិចនោះទៀត។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ចេញនូវពួកនាងនារី មានខ្លួនតាក់តែងហើយ មានសំពត់ និងគ្រឿងអាភរណៈដ៏វិចិត្រ ពាក់កែវមណី និងកុណ្ឌល។ គួរសរសើរដែរ ពាណិជទាំងឡាយមាននាងនារីម្នាក់ៗ ចំណែកខាងនាងនារី ២៥ នាក់ ចោមរោម (នូវនាយឈ្មួញជាធំ) ក្រោមម្លប់ឈើនោះដោយជុំវិញ ពាណិជទាំងនោះ ត្រូវនាងនារីទាំងនោះចោមរោមហើយ ដរាបអស់ចំណង់។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី ៤ ថា បើដូច្នោះ យើងជាពួកឈ្មួញ នឹងកាត់នូវមែកឈើខាងជើងនោះទៀត។ សោតឯមែកនោះ គ្រាន់តែត្រូវពួកឈ្មួញកាត់ដាច់ភ្លាម ក៏ហូរចេញនូវកែវមុក្តា និងកែវពៃទូរ្យដ៏ច្រើនផង នូវប្រាក់ផង នូវមាសផង នូវកម្រាលសម្រាប់ក្រាលលើខ្នងដំរីជាដើមផង នូវកម្រាលរោមសត្វជាដើមផង នូវសំពត់ដែលគេធ្វើក្នុងដែនកាសីផង នូវសំពត់កម្ពលឈ្មោះឧទ្ទិយានៈផង ពាណិជទាំងនោះ ក៏វេចយកនូវភារៈ ដរាបទាល់តែអស់ចំណង់ក្នុងទីនោះ។ ពួកពាណិជល្ងង់ ដែលត្រូវមោហៈបិទបាំង ក៏ប្រឹក្សានូវហេតុទី ៥ ថា បើដូច្នោះ ពួកយើងនឹងកាត់ត្រង់គល់ឈើនោះ មុខជានឹងបានច្រើនជាងនេះទៅទៀត គ្រានោះ ពួកឈ្មួញធំក្រោកឡើង ផ្គងអញ្ជលីអង្វរថា ដើមជ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចំរើនចូរមានដល់អ្នកចុះ។ មែកខាងកើត បានឲ្យទឹកងូតផង មែកខាងត្បូង បានឲ្យបាយ នឹងទឹកផង មែកខាងលិច បានឲ្យនាងនារីទាំងឡាយផង មែកខាងជើង បានឲ្យនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងផង ដើមជ្រៃប្រទូស្តពួកអ្នកដូចម្តេច ម្នាលពាណិជទាំងឡាយ សេចក្តីចំរើនចូរមានដល់អ្នកចុះ។ បុគ្គលអង្គុយ ឬដេកក្រោមម្លប់នៃឈើណា មិនត្រូវកាច់បំបាក់មែកឈើនោះឡើយ ព្រោះថាបុគ្គលអ្នកប្រទូស្តមិត្ត ជាមនុស្សអាក្រក់។ ឯឈ្មួញទាំងនោះច្រើនគ្នា មិនអើពើនូវពាក្យនៃឈ្មួញជាធំម្នាក់ឯងនោះ ក៏ចូលទៅដើម្បីនឹងកាត់នូវដើមជ្រៃនោះត្រង់គល់ ដោយប៉ូវថៅទាំងឡាយ ដែលខ្លួនសំលៀងហើយ។

[១២០] (អភិសម្ពុទ្ធគាថា) លំដាប់នោះ នាគទាំងឡាយ ២៥ សៀតគ្រឿងក្រោះហើយផង ពួកនាគខ្មាន់ធ្នូ ៣០០ ផង ពួកទាហានកាន់ខែលប្រាំមួយពាន់ផង ក៏ចេញមក។

[១២១] (នាគរាជ...) អ្នកទាំងឡាយចូរសម្លាប់ ចូរចងនូវពាណិជទាំងនុ៎ះ អ្នកទាំងឡាយកុំលែងនូវជីវិតឡើយ អ្នកទាំងឡាយ ចូរធ្វើនូវពួកពាណិជទាំងអស់នោះ ឲ្យទៅជាផេះ ទុកតែពាណិជជាធំម្នាក់ប៉ុណ្ណោះ។

[១២២] (អភិសម្ពុទ្ធគាថា) ព្រោះហេតុនោះ បណ្ឌិតបុរស កាលបើបានឃើញច្បាស់នូវប្រយោជន៍របស់ខ្លួន មិនគប្បីលុះអំណាចនៃលោភៈឡើយ ត្រូវតែកំចាត់បង់នូវចិត្តដែលប្រកបដោយលោភៈប្រាកដដូច្នោះ ភិក្ខុបើបានដឹងនូវទោស (ក្នុងលោភៈ) យ៉ាងនេះ ដឹងនូវការកើតឡើងនៃទុក្ខ ព្រោះតណ្ហាយ៉ាងនេះហើយ គប្បីប្រព្រឹត្តជាអ្នកមានតណ្ហាទៅប្រាសហើយ មិនមានសេចក្តីប្រកាន់មាំ មានស្មារតី។

ចប់ មហាវាណិជជាតក ទី១០។

## សាធិនរាជជាតក ទី១១

CS sut.kn.jat.494 | ភាគទី ៦០

### (៤៩៤. សាធិនជាតកំ (១១ ))

[១២៣] (ពួកអ្នកនគរពោលថា ស្តេចរបស់យើង) ចំឡែកណាស់តើ គួរឲ្យព្រឺរោម កើតឡើងក្នុងលោក រថជាទិព្យបានកើតប្រាកដ

ដល់ស្តេចវិទេហៈ ព្រះអង្គមានយស។

[១២៤] (អភិសម្ពុទ្ធគាថា) ទេវបុត្រឈ្មោះមាតលី ជាទេវសារថី មានឫទ្ធិច្រើនបានអញ្ជើញព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលាថា បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គយាងឡើងកាន់រថនេះ ទេវតាទាំងឡាយជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយរលឹកព្រះអង្គ នៅរង់ចាំក្នុងរោងឈ្មោះសុធម្មា។ លំដាប់នោះឯង ព្រះបាទវិទេហៈ ព្រះនាមសាធិន ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ទ្រង់យាងឡើងកាន់រថ ទឹមដោយសេះច្រើន ហើយបានយាងទៅក្នុងសំណាក់នៃទេវតាទាំងឡាយ (ព្រះរាជាជាធំទ្រង់ប្រថាប់លើទិព្វយានឈ្មោះហាយវាហី ដែលទឹមដោយសេះច្រើន កំពុងយាងទៅ ក៏បានទតឃើញទេវសភានេះ) ពួកទេវតាបានឃើញព្រះរាជានោះមកដល់ហើយ ក៏ត្រេកអរស្មោះចំពោះថា បពិត្រមហារាជ ព្រះអង្គយាងមកស្រួលហើយ មិនមែនយាងមកដោយមិនស្រួលទេ បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរ ឥឡូវនេះ សូមព្រះអង្គទ្រង់គង់ក្នុងសំណាក់នៃទេវរាជចុះ។ ឯព្រះឥន្ទ ក៏ទទួលរាក់ទាក់ចំពោះព្រះបាទវិទេហៈ ព្រះអង្គគ្រប់គ្រងក្រុងមិថិលា ព្រះឥន្ទបានអញ្ជើញដោយកាមទាំងឡាយផង ដោយអាសនៈផងថា ប្រពៃណាស់ហើយ ព្រះអង្គបានដល់អាវាសរបស់ទេវតាទាំងឡាយ ដែលញុំាងគេឲ្យប្រព្រឹត្តក្នុងអំណាចខ្លួន បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងពួកទេវតាដែលសម្រេចនូវកាមគ្រប់យ៉ាងបាន សូមព្រះអង្គសោយនូវកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្ស ក្នុងពួកទេវតាជាន់តាវត្តិង្សចុះ។

[១២៥] (ព្រះបាទសាធិនរាជ...) កាលពីដើម ខ្ញុំមកនៅក្នុងឋានសួគ៌ រីករាយដោយរបាំចម្រៀង និងប្រគុំទាំងឡាយ ឥឡូវនេះ ក្នុងថ្ងៃនេះ ខ្ញុំមិនត្រេកអរក្នុងឋានសួគ៌ទេ បពិត្រព្រះជនិន្ទដ៏ប្រសើរ អាយុ (របស់ខ្ញុំ) នឹងអស់ឬ ឬសេចក្តីស្លាប់ (ឋិតនៅ) ក្នុងទីជិត ឬក៏ខ្ញុំជាបុគ្គលវង្វេង។

[១២៦] (សក្កៈ...) បពិត្រព្រះអង្គដ៏ប្រសើរ មានព្យាយាមជាងជន អាយុរបស់ព្រះអង្គមិនទាន់អស់ទេ ទាំងសេចក្តីស្លាប់របស់ព្រះអង្គ (ក៏ឋិតនៅ) ក្នុងទីឆ្ងាយ មួយវិញទៀត ព្រះអង្គមិនមែនជាមនុស្សវង្វេងទេ តែថា ព្រះអង្គសោយនូវផលនៃបុណ្យណា ក្នុងទេវលោកនេះ បុណ្យរបស់ព្រះអង្គនោះតិច បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស សូមព្រះអង្គគង់នៅដោយទេវានុភាពចុះ សូមព្រះអង្គសោយនូវកាមទាំងឡាយ មិនមែនជារបស់មនុស្ស ក្នុងទេវលោកជាន់តាវត្តិង្សចុះ។

[១២៧] (ព្រះរាជា...) យានដែលខ្ចីគេ និងទ្រព្យដែលខ្ចីគេ មានឧបមាយ៉ាងណាមិញ ទ្រព្យណាដែលគេបាន ព្រោះបុគ្គលដទៃឲ្យជាបច្ច័យ ទ្រព្យនុ៎ះឯង ក៏មានឧបមេយ្យយ៉ាងនោះដែរ ទ្រព្យណាដែលគេបាន ព្រោះបុគ្គលដទៃឲ្យជាបច្ច័យ ខ្ញុំមិនចង់បានទ្រព្យនុ៎ះឡើយ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយដោយខ្លួនឯង បុណ្យនោះ ទុកជាទ្រព្យរបស់ខ្ញុំជាប់តាមខ្លួន ខ្ញុំនោះ នឹងទៅធ្វើកុសលឲ្យច្រើនក្នុងពួកមនុស្ស ដោយឲ្យទានផង កិរិយាប្រព្រឹត្តធម៌ស្មើផង កិរិយាសង្រួមដោយសីលផង កិរិយាទូន្មាននូវឥន្ទ្រិយផង ព្រោះថាបុគ្គលធ្វើកុសលហើយ រមែងដល់នូវសេចក្តីសុខ ទាំងមិនក្តៅក្រហាយរឿយៗ ក្នុងកាលជាខាងក្រោយ។

[១២៨] (សាធិនរាជ ពោលនឹងស្តេចនារទៈថា) ស្រែទាំងឡាយនេះផង ទទឹកប្រកបដោយកុណ្ឌល[24] ដ៏ល្អនេះផង ផែនដីដ៏ដេរដាសដោយស្មៅពណ៌ខៀវនេះផង ស្ទឹងទាំងឡាយដែលកំពុងហូរនេះផង ស្រះបោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចាកក្រពាកយំហើយ ដ៏ដេរដាសដោយចង្កុលឈើ ដោយផ្កាឈូក និងផ្កាឧប្បលនេះផង ពួកជនណា រាប់អាននូវទីទាំងឡាយនេះថាជារបស់អញ ជនទាំងនោះទៅកាន់ទិសណាហ្ន៎។

ម្នាលនារទៈ ស្រែទាំងឡាយ នៅជាស្រែទាំងនោះដដែល ភូមិភាគ នៅជាភូមិភាគនោះដដែល ឧបចារៈនៃសួនច្បារទាំងឡាយ ក៏នៅជាឧបចារៈនោះដដែល តែថា កាលយើងមិនឃើញនូវជនទាំងនោះ ទិសប្រាកដដល់យើងហាក់ដូចជាសូន្យឈឹង។

[១២៩] (ព្រះរាជា...) វិមានទាំងឡាយ ញុំាងទិសទាំង ៤ ឲ្យភ្លឺចិញ្ចែងចំពោះមុខទេវរាជផង ចំពោះមុខពួកទេវតាជាន់ត្រៃត្រឹង្សផង យើងបានឃើញហើយ។ ភពជាទិព្វ យើងបាននៅរួចហើយ កាមទាំងឡាយមិនមែនជារបស់មនុស្ស យើងបានបរិភោគរួចហើយក្នុងពួកទេវតាជាន់តាវត្តិង្ស អាចសម្រេចនូវសេចក្តីប្រាថ្នាគ្រប់យ៉ាងបាន។ យើងនោះ បានលះបង់សម្បត្តិទិព្វប្រាកដដូច្នោះហើយ មកក្នុងទីនេះ ដើម្បីធ្វើបុណ្យ យើងនឹងប្រព្រឹត្តធម៌តែម្យ៉ាង យើងមិនមានសេចក្តីត្រូវការដោយរាជសម្បត្តិទេ។ ព្រះពុទ្ធទាំងឡាយដែលមានវត្តល្អស្តេចយាងទៅតាមផ្លូវណា យើងនឹងដើរទៅតាមផ្លូវនោះ ដែលព្រះសម្មាសម្ពុទ្ធសំដែងហើយ ជាផ្លូវដែលបុគ្គលមិនមានអាជ្ញាគប្បីត្រាច់ទៅ។

ចប់ សាធិនរាជជាតក ទី១១។

## ទសព្រាហ្មណជាតក ទី១២

CS sut.kn.jat.495 | ភាគទី ៦០

(៤៩៥. ទសព្រាហ្មណជាតកំ (១២ ))

[១៣០] (ព្រះសាស្តាទ្រង់ត្រាស់ថា) ព្រះរាជា ជាយុធិដ្ឋិលគោត្រ ព្រះអង្គប្រាថ្នានូវធម៌ បានត្រាស់នឹងអាមាត្យឈ្មោះវិធុរៈថា ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយ ដែលជាអ្នកមានសីល ជាពហុស្សុត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន ម្នាលសំឡាញ់ យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៣១] (អាមាត្រឈ្មោះវិធុរៈ ក្រាបទូលថា) បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សុត វៀរចាកមេថុនធម្ម គួរនឹងបរិភោគនូវភោជនរបស់ព្រះអង្គ គេរកបានដោយក្រ។ បពិត្រមហារាជ ឮថា ជាតិព្រាហ្មណ៍ទាំងឡាយណា មាន ១០ យ៉ាង សូមព្រះអង្គ ទ្រង់ព្រះសណ្តាប់នូវការចែករំលែក និងការពិនិត្យពិច័យ នូវព្រាហ្មណ៍ទាំងនោះ តាមប្រាជ្ញារបស់ទូលព្រះបង្គំជាខ្ញុំ ដោយពិស្តារចុះ។ ព្រាហ្មណ៍ទាំងឡាយ កាន់ការុងទាំងឡាយ ដែលពេញដោយឫសឈើ ចងមាត់ជិត ហើយតែងក្បួនថ្នាំទាំងឡាយផង ផ្ងូតទឹកឲ្យគេផង សែកនូវ (ភូតវិជ្ជា) ផង។ បពិត្រព្រះរាជា ឯព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយពេទ្យ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ទូលព្រះបង្គំជាខ្ញុំ បានក្រាបទូលចំពោះព្រះអង្គរួចហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ។

[១៣២] (ព្រះរាជាកោរព្យៈ...) ពួកព្រាហ្មណ៍ទាំងនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សុត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៣៣] (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយនោះ កាន់ឃ្មោះទាំងឡាយ ហើយឃោស្នាឮដ៏ខាងមុខ (នៃស្តេច និងអាមាត្រ) ក៏មាន ទៅកាន់

ទីសម្រាប់បម្រើគេក៏មាន សិក្សាខាងសិល្បរថក៏មាន។ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ស្មើដោយជនអ្នកបំរើ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ។

[១៣៤] (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកនូវព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៣៥] (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយ កាន់ឃ្លោកដាក់ទឹកផង ដំបងភ្លូកផង ចូលទៅឯបអបនឹងស្តេចទាំងឡាយ ក្នុងស្រុក ឬនិគម (ដោយគិតគ្នាថា) កាលបើគេមិនឲ្យ (វត្ថុអ្វីមួយ) ក្នុងស្រុក ឬនិគម យើងនឹងមិនក្រោកឡើយ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នករឹបជាន់ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបបង្គំទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ។

[១៣៦] (ព្រះរាជាកោរព្យៈ...) ព្រាហ្មទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យហើយ ចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៣៧] (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយនោះ មានរោមក្លៀក និងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល រោយរាយដោយធូលី និងលំអងដី ត្រាច់ទៅសូម (ទ្រព្យផ្សេងៗ) បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកដកនូវដង្កត់ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ។

[១៣៨] (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យហើយចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៣៩] (វិធុរៈ...) បពិត្រព្រះជនាធិបតី (ព្រាហ្មណ៍ទាំងឡាយ) ជួញសម៉ផង កន្ទួតព្រៃផង ស្វាយផង ព្រីងផង សម៉ពិភេកផង ខ្នុរសម្លួផង ឈើស្ទន់ផង ល្មៀតផង ពទ្រាផង ឈើកែសផង ទឹកអំពៅ និងស្ករអំពៅផង ខ្សៀផង ទឹកឃ្មុំ និងថ្នាំបន្តក់ភ្នែកផង ជួញភណ្ឌៈមានតម្លៃតិច ឬមានតម្លៃច្រើនផង បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយពាណិជ ហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ។

[១៤០] (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៤១] (វិធុរៈ...) (ព្រាហ្មណ៍ទាំងឡាយ) នាំគ្នាធ្វើនូវកសិកម្ម និងពាណិជ្ជកម្មផង ចិញ្ចឹមពពែ និងចៀមផង ទំនុកបម្រុងពួកកុមារីផង រៀបចំអាពាហ៍ពិពាហ៍ផង ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយកុដុម្ពិកៈ និងគហបតី គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ។

[១៤២] (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៤៣] (វិធុរៈ...) មានព្រាហ្មណ៍ពួកខ្លះ ជាបុរោហិត (បរិភោគនូវភិក្ខាដែលគេទុកបំរុងឲ្យខ្លួន) ពួកជនច្រើនគ្នា តែងសាកសួរព្រាហ្មណ៍នោះ ព្រាហ្មណ៍ទាំងនោះជាអ្នកក្រៀវពង (គោជាដើម) ផង ជាគ្រសាក់ផង សម្លាប់សត្វចិញ្ចឹម គឺក្របី ជ្រូក និងពពែផង ក្នុងផ្ទះនោះ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយបុគ្គលអ្នកសម្លាប់គោ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកព្រាហ្មណ៍បែបដូច្នោះឬ។

[១៤៤] (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៤៥] (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយ កាន់ដាវ និងខែល កាន់ព្រះខាន់ ឈរឯបនៅក្បែរផ្លូវជាទីទៅនៃពួកឈ្មួញ នាំពួកឈ្មួញឲ្យផុត (អំពីពួកចោរ) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយពួកជនអ្នកឃ្វាលគោ និងពួកអ្នកនេសាទ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងនឹងចូលទៅរកពួកព្រាហ្មណ៍បែបដូច្នោះឬ។

[១៤៦] (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធុរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៤៧] (វិធុរៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ធ្វើខ្ទមក្នុងព្រៃ ធ្វើអន្ទាក់វែទាំងឡាយ បៀតបៀននូវទន្សាយ និងខ្លាត្រីផង នូវទន្សង ត្រី

និងអណ្តើកផង បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយព្រានព្រៃ ព្រាហ្មណ៍ទាំងនោះ គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងនោះ) ខ្ញុំព្រះអង្គបានក្រាបទូល ចំពោះព្រះអង្គហើយ យើងនឹងចូលទៅស្វែងរកព្រាហ្មណ៍បែបដូច្នោះឬ។

[១៤៨] (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៤៩] (វិធូរៈ...) ព្រាហ្មណ៍ទាំងឡាយដទៃទៀត ចង់បានទ្រព្យ ក៏ដេកខាងក្រោមគ្រែ កាលសោមយាគ[25] ប្រាកដហើយ ស្តេចទាំងឡាយក៏ស្រង់ទឹក ពួដ៏ខាងលើនៃគ្រែ បពិត្រព្រះរាជា ព្រាហ្មណ៍ទាំងឡាយនោះ ប្រាកដស្មើដោយជនអ្នកដុសក្អែល គេហៅថាព្រាហ្មណ៍ដែរ បពិត្រមហារាជ (ព្រាហ្មណ៍ទាំងឡាយនេះ) ខ្ញុំព្រះអង្គបានក្រាបទូលចំពោះព្រះអង្គហើយ យើងចូលទៅរកពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ។

[១៥០] (ព្រះរាជាកោរព្យៈ...) ព្រាហ្មណ៍ទាំងឡាយនោះ ប្រាសចាកភាពជាព្រាហ្មណ៍ តែព្រាហ្មណ៍ទាំងឡាយនោះ គេមិនហៅថាព្រាហ្មណ៍ទេ ម្នាលវិធូរៈ អ្នកចូរស្វែងរកព្រាហ្មណ៍ទាំងឡាយដទៃវិញ ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម ឲ្យមកបរិភោគនូវភោជនរបស់យើង ម្នាលសំឡាញ់ ទក្ខិណាទានដែលគេឲ្យចំពោះបុគ្គលណា ជាទានមានផលច្រើន យើងនឹងឲ្យនូវទក្ខិណាទាន (ចំពោះបុគ្គលនោះ)។

[១៥១] (វិធូរៈ...) បពិត្រព្រះសម្មតិទេព ពួកព្រាហ្មណ៍ដែលជាអ្នកមានសីល ជាពហុស្សូត វៀរចាកមេថុនធម្ម គួរនឹងបរិភោគភោជនរបស់ព្រះអង្គ មានដែរ។ ព្រាហ្មណ៍ទាំងនោះ បរិភោគនូវភត្តតែម្តង ទាំងមិនផឹកនូវទឹកស្រវឹង បពិត្រមហារាជ (ពួកព្រាហ្មណ៍នេះ) ខ្ញុំព្រះអង្គបានក្រាបទូលព្រះអង្គហើយ យើងនឹងចូលទៅអញ្ជើញពួកព្រាហ្មណ៍ប្រាកដដូច្នោះឬ។

[១៥២] (ព្រះរាជា...) ម្នាលវិធូរៈ បើពួកព្រាហ្មណ៍នុ៎ះឯង ជាអ្នកមានសីល ជាពហុស្សូតពិតមែន ម្នាលវិធូរៈ អ្នកចូរស្វែងរកពួកព្រាហ្មណ៍នុ៎ះចុះ ចូរអញ្ជើញព្រាហ្មណ៍ទាំងនោះមកឆាប់ៗ។

ចប់ ទសព្រាហ្មណជាតក ទី១២។

## ភិក្ខាបរម្បរជាតក ទី១៣

CS sut.kn.jat.496 | ភាគទី ៦០

### (៤៩៦. ភិក្ខាបរម្បរជាតកំ (១៣))

[១៥៣] (កុដុម្ពិកៈទូលថា) ខ្ញុំព្រះអង្គបានឃើញព្រះអង្គ មានព្រះរូបទន់ភ្លន់ ចេញចាកដែនមកកាន់ព្រៃស្ងាត់ ប្រកបដោយផ្ទះកំពូលដ៏ប្រសើរ មានអាសនៈដ៏ថ្លៃថ្លា ដែលគេក្រាលបំរុងទុក ទើបថ្វាយក្រយាស្ងោយដ៏ឧត្តម ជាភត្តនៃស្រូវសាលីដ៏វិចិត្រ លាយដោយសាច់ដ៏ស្អាត ចំពោះព្រះអង្គនោះ ដោយសេចក្តីស្រឡាញ់ ព្រះអង្គទទួលក្រយាស្ងោយនោះហើយ តែមិនសោយដោយព្រះអង្គឯង ត្រឡប់ជាប្រទានដល់ព្រាហ្មណ៍វិញ សូមក្រាបថ្វាយបង្គំចំពោះព្រះអង្គ តើការណ៍នេះជាសភាពដូចម្តេច។

[១៥៤] (ព្រះរាជាត្រាស់ថា) ព្រាហ្មណ៍ (នេះ) ជាអាចារ្យរបស់យើង ជាអ្នកខ្វល់ខ្វាយក្នុងកិច្ចតូច និងកិច្ចធំផង ជាបុគ្គលគួរគោរពផង គួរឲ្យយើងហៅរកផង (ព្រោះហេតុនោះ) យើងគួរឲ្យភោជន។

[១៥៥] (កុដុម្ពិកៈ...) ឥឡូវនេះ ខ្ញុំសូមសួរព្រាហ្មណ៍ ជាគោតមគោត្ត ដែលស្តេចតែងបូជា ព្រះរាជាបានប្រទានភត្តដែលលាយដោយសាច់ដ៏ស្អាតដល់អ្នក អ្នកបានទទួលភត្តនោះហើយ ក៏បានប្រគេននូវភោជនដល់ឥសីវិញ អ្នកប្រហែលជាដឹងថា ខ្លួនមិនមែនជាខេត្តនៃទាន ខ្ញុំសូមថ្វាយបង្គំចំពោះអ្នក តើការណ៍នេះជាសភាពដូចម្តេច។

[១៥៦] (ព្រាហ្មណ៍តបថា) ខ្ញុំតែងចិញ្ចឹមកូន និងប្រពន្ធផង ចំពាក់ចិត្តក្នុងផ្ទះទាំងឡាយផង ប្រៀនប្រដៅព្រះរាជាថា សូមព្រះអង្គសោយនូវកាមទាំងឡាយ ជារបស់នៃមនុស្សផង ហេតុនោះបានជាខ្ញុំគួរប្រគេនភោជនដល់ឥសីវិញ ដែលនៅក្នុងព្រៃ មានតបៈអស់កាលវែង ចំរើនដោយគុណ មានចិត្តចំរើនហើយ។

[១៥៧] (កុដុម្ពិកៈ...) ឥឡូវនេះ ខ្ញុំសូមសួរឥសី ដែលស្គមរីមរវាមដោយសរសៃ មានរោមក្លៀក និងក្រចកដុះវែង មានធ្មេញប្រកបដោយមន្ទិល មានធូលីលើក្បាល លោកនៅក្នុងព្រៃម្នាក់ឯង មិនស្តាយជីវិត លោកបានប្រគេនភោជនដល់ភិក្ខុណា ភិក្ខុនោះប្រសើរជាងលោកដោយគុណដូចម្តេច។

[១៥៨] (តាបសតបថា) អាត្មាជីកដំឡូងឈ្មោះអាលុកលម្ពៈ និងតាលកន្ទៈទាំងឡាយផង ដំឡូងឈ្មោះពិលាលិ និងតក្កលៈទាំងឡាយផង ច្រតស្រងៃ និងស្ពៅ (យកមក) បែនបុក (បរិភោគ) ផង នាំយកគ្រឿងអន្លក់ និងក្រអៅឈូក ទឹកឃ្មុំ សាច់ ពុទ្រា និងកន្ទួតព្រៃ មកបរិភោគផង នោះជាកំណាន់របស់អាត្មា អាត្មាជាបុគ្គលដាំស្ល មានសេចក្តីខ្វល់ខ្វាយ មានសេចក្តីប្រកាន់នៅឡើយ គួរប្រគេនភោជនដល់ភិក្ខុដែលជាអ្នកមិនដាំស្ល មិនមានតណ្ហា មិនមានសេចក្តីប្រកាន់។

[១៥៩] (កុដុម្ពិកៈ...) ឥឡូវនេះ ខ្ញុំសូមសួរភិក្ខុដែលអង្គុយស្ងៀមមានវត្តល្អ ដូចតទៅនេះ (ឥសី) បានប្រគេនភត្តដែលលាយដោយសាច់ដ៏ស្អាតដល់លោក លោកទទួលភត្តនោះហើយ ក៏បរិភោគស្ងៀមៗ ម្នាក់ឯង មិនបានអញ្ជើញបុគ្គលដទៃណាមួយ (ឲ្យបរិភោគផង) ឡើយ ខ្ញុំសូមថ្វាយបង្គំចំពោះលោក តើការណ៍នេះជាសភាពដូចម្តេច។

[១៦០] (ព្រះបច្ចេកពុទ្ធ) អាត្មាមិនដាំស្លខ្លួនឯង មិនប្រើឲ្យគេដាំស្ល មិនកាត់ខ្លួនឯង មិនប្រើគេឲ្យកាត់ ហេតុនោះបានជាឥសីដឹងថាអាត្មាជាអ្នកមិនមានសេចក្តីកង្វល់ ជាអ្នកប្រាសចាកបាបគ្រប់ចំពូក ទើបកាន់ចង្ហាន់ដោយដៃឆ្វេង កាន់សម្បកឃ្លោកដោយដៃស្តាំ ហើយប្រគេនភត្តដែលលាយដោយសាច់ដ៏ស្អាតនោះដល់អាត្មា។ តាមពិត ជនទាំងឡាយ (មានស្តេចជាដើម) នុ៎ះ ជាអ្នកប្រកាន់ថារបស់អញ មានសេចក្តីហួងហែង គួរតែឲ្យទាន (ដល់បុគ្គលប្រាកដស្មើដោយអាត្មា) បុគ្គលណា អញ្ជើញនូវអ្នកឲ្យទាន (មកបរិភោគ) អាត្មាសំគាល់ (នូវបុគ្គលនោះ) ថាជាអ្នកប្រតិបត្តិខុសទំនង។

[១៦១] (កុដុម្ពិកៈ...) ក្នុងថ្ងៃនេះ ព្រះរាជាព្រះអង្គប្រសើរលើរថ បានយាងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ខ្ញុំមែនហើយ ដ្បិតខ្ញុំបាន

ដឹងច្បាស់ក្នុងថ្ងៃនេះថា ទានដែលគេឲ្យហើយ ចំពោះបុគ្គលណា ជាទានមានផលច្រើន។ ស្ដេចទាំងឡាយ ជាប់ចំពាក់ក្នុងផែនដី ពួកព្រាហ្មណ៍ ជាប់ចំពាក់ក្នុងកិច្ចតូច នឹងកិច្ចធំ ពួកឥសីជាប់ចំពាក់ក្នុងមើមឈើ និងផ្លែឈើ ឯពួកភិក្ខុ ទើបរួចស្រឡះចាកកិលេស។

ចប់ ភិក្ខាបរម្បរជាតក ទី១៣។

ឧទ្ទាននៃបកិណ្ណកនិបាតនោះគឺ

និយាយអំពីសេក ១ កិន្នរ ១ គប់ភ្លើង ១ ជដិលដណ្ដប់ស្បែកខ្លាឃ្មុំទាំងក្រចក ១ ក្រអៅឈូក ១ អគ្គមហេសី ១ ព្រាបដ៏ប្រសើរ ១ ក្ងោក ១ ជ្រូក ឈ្មោះតច្ឆក: ១ ពាណិជ ១ សាធិនរាជ ១ ព្រាហ្មណ៍ ១ ចង្ហាន់ឲ្យតៗគ្នា១។

ចប់ បកិណ្ណកនិបាត។

# វីសតិនិបាតជាតក

CS sut.kn.jat.v15 | ភាគទី ៦០

(១៥. វីសតិនិបាតោ)

## មាតង្គជាតក ទី១

CS sut.kn.jat.497 | ភាគទី ៦០

(៤៩៧. មាតង្គជាតកំ (១))

[១៦២] (មណ្ឌព្យកុមារសួរថា) អ្នកមកអំពីទីណា បានជាមានប្រដាប់ស្លៀកពាក់អាក្រក់ លាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ដែលគេចោលលើគំនរសម្រាមឰដ៏ក ខ្លួនអ្នកជាបុគ្គលផ្ដេសផ្ដាស មិនមែនជាទក្ខិណេយ្យបុគ្គលទេ។

[១៦៣] (មាតង្គមហាសត្វឆ្លើយថា) គ្រឿងបរិភោគនេះបរិបូណ៌ដោយបរិវារ អ្នកបានតាក់តែងហើយ ពួកជនតែងទំពាស៊ី បរិភោគ ផឹកនូវគ្រឿងបរិភោគនោះ អ្នកស្គាល់ហើយនូវយើង ថាជាអ្នកចិញ្ចឹមជីវិតដោយសារអ្នកដទៃឲ្យ សូមឲ្យមនុស្សចណ្ឌាលបាននូវដុំបាយដែលបុគ្គលគប្បីទៅឈរជិត។

[១៦៤] (មណ្ឌព្យកុមារ...) គ្រឿងភោជននេះ ខ្ញុំបានតាក់តែងបម្រុងពួកព្រាហ្មណ៍ នេះជាភោជនរបស់ខ្ញុំដែលជឿចំពោះសេចក្ដីចំរើនរបស់ខ្លួន អ្នកចូរចៀសចេញអំពីទីនេះ អ្នកមកឋិតនៅក្នុងទីនេះធ្វើអ្វី នៃបុគ្គលថោកទាប បុគ្គលទាំងឡាយប្រហែលយើង មិនឲ្យភោជនដល់អ្នកទេ។

[១៦៥] (ព្រះមហាសត្វ...) ពួកអ្នកប្រាថ្នាផលស្រូវ រមែងព្រោះពូជក្នុងទីទួល ឬទីទំនាប និងទីដែលមិនមែនជាស្រែ អ្នកចូរឲ្យទានដោយសទ្ធាបែបនេះចុះ សូមអ្នកញុំាងទក្ខិណេយ្យបុគ្គលឲ្យត្រេកអរផង។

[១៦៦] (មណ្ឌព្យកុមារ...) យើងព្រោះពូជទាំងឡាយក្នុងស្រែណា ស្រែទាំងនោះក្នុងលោក យើងស្គាល់ច្បាស់ ពួកព្រាហ្មណ៍ណា ជាអ្នកប្រកបដោយជាតិ នឹងមន្ត ពួកព្រាហ្មណ៍ទាំងនោះ មានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ។

[១៦៧] (មហាសត្វ...) សេចក្ដីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្ដីស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មាននៅក្នុងពួកបុគ្គលណា បុគ្គលពួកនោះ មិនមែនជាអ្នកមានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះឡើយ។ សេចក្ដីស្រវឹងព្រោះជាតិ ១ ភាពជាបុគ្គលមើលងាយគេ ១ លោភៈ ១ ទោសៈ ១ សេចក្ដីស្រវឹង ១ មោហៈ ១ ទោសទាំងអស់នេះ មិនមានក្នុងពួកបុគ្គលណា បុគ្គលពួកនោះ ទើបឈ្មោះថា មានសីលជាទីស្រឡាញ់ដ៏ក្រៃលែង ដូចជាស្រែក្នុងលោកនេះ។

[១៦៨] (មណ្ឌព្យកុមារ...) (ឆ្មាំទ្វារ ៣ នាក់) ឈ្មោះឧបជោតិយៈ ១ ឈ្មោះឧបជ្ឈាយៈ ១ ឈ្មោះភណ្ឌកុច្ឆិ ១ ទៅក្នុងទីណា អ្នកទាំងឡាយចូរវាយសម្លាប់នូវមនុស្សលាមកនេះ ហើយចាប់ត្រង់ក អូសទាញចេញទៅ។

[១៦៩] (មហាសត្វ...) អ្នកណាជេរប្រទេចនូវឥសី អ្នកនោះឈ្មោះថាជីកភ្នំដោយក្រចក ឈ្មោះថាខាំទំពាដែកដោយធ្មេញ ឈ្មោះថាព្យាយាមលេបភ្លើង។

[១៧០] (អភិសម្ពុទ្ធគាថា) ឥសីឈ្មោះមាតង្គៈ ជាអ្នកមានសេចក្ដីព្យាយាមទៀងទាត់ លុះពោលពាក្យនេះហើយ ក៏ចេញទៅឰដ៏អាកាស ចំពោះមុខពួកព្រាហ្មណ៍កំពុងក្រឡេកមើល។

[១៧១] (នាងទិដ្ឋមង្គលិកាពោលថា) ក្បាល (របស់កូនអញ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅ មិនគួរដល់ការងារ ភ្នែកទាំងឡាយស ដូចជាបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនអញនេះឲ្យទៅជាយ៉ាងនេះ។

[១៧២] (ពួកមាណពពោលថា) មានសមណៈ (មួយរូប) មកក្នុងទីនេះ មានប្រដាប់ស្លៀកពាក់អាក្រក់លាមក ដូចជាបិសាចលើអាចម៍ដី ពាក់នូវកំណាត់សំពត់ ដែលគេចោលលើគំនរសម្រាមឰដ៏ក សមណៈនោះបានធ្វើនូវកូនរបស់នាងនេះ ឲ្យយ៉ាងនេះ។

[១៧៣] (នាងទិដ្ឋមង្គលិកា...) សមណៈមានប្រាជ្ញាក្រាស់ដូចផែនដីនោះ ទៅក្នុងទិសដូចម្ដេច ម្នាលមាណពទាំងឡាយ អ្នកទាំងឡាយចូរប្រាប់នូវសេចក្ដីនុ៎ះដល់ខ្ញុំ យើងនឹងទៅសូមខមាទោសចំពោះសមណៈនោះ ធ្វើម្ដេចហ្ន៎ យើងនឹងបានកូននោះ មានជីវិតរស់នៅ។

[១៧៤] (ពួកមាណព...) សមណៈមានប្រាជ្ញាក្រាស់ដូចផែនដី បានទៅក្នុងអាកាស ដូចព្រះចន្ទក្នុងថ្ងៃ ១៥ កើត ដើរទៅតាមផ្លូវនៃអាកាស មួយទៀត សមណៈនោះជាឥសី មានការប្ដេជ្ញាដ៏ទៀងទាត់ មានសភាពដ៏ល្អ បានទៅកាន់ទិសខាងកើតហើយ។

[១៧៥] (នាងទិដ្ឋមង្គលិកា...) ក្បាល (របស់កូនខ្ញុំ) រមួលទៅខាងក្រោយ ដើមដៃលាតចេញទៅ មិនគួរដល់ការងារ ភ្នែកទាំងឡាយស ដូចភ្នែកបុគ្គលស្លាប់ អ្នកណាហ្ន៎ ធ្វើកូនខ្ញុំនេះឲ្យទៅជាយ៉ាងនេះ។

[១៧៦] (ព្រះមហាសត្វ...) ពួកយក្សមានអានុភាពច្រើន (មកដោយគិតថា) ពួកឥសីមានសភាពដំល្អ មកហើយ (ក្នុងទីនេះ) ពួកយក្ខដឹងថា (កូនរបស់នាង) មានចិត្តប្រទូស្ត ក្រោធខឹង ហើយបានធ្វើនូវកូននាងឲ្យយ៉ាងនេះ។

[១៧៧] (នាងទិដ្ឋមង្គលិកា...) បើពួកយក្ខបានធ្វើកូនរបស់ខ្ញុំឲ្យយ៉ាងនេះហើយ សូមលោកជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ កុំខឹងចំពោះខ្ញុំ នាងខ្ញុំជាស្រីសូមដល់នូវបាទារបស់លោកជាទីពឹង បពិត្រភិក្ខុ ខ្ញុំមកដោយសេចក្តីសោកចំពោះកូន។

[១៧៨] (ព្រះមហាសត្វ...) កាលនោះក៏ដោយ ឥឡូវនេះក៏ដោយ យើងមិនមានការប្រទូស្តក្នុងចិត្តតិចតួចទេ តែកូនរបស់នាងជាអ្នកស្រវឹង ដោយសេចក្តីស្រវឹងក្នុងវេទ រៀនវេទហើយមិនស្គាល់សេចក្តីចំរើន។

[១៧៩] (នាងទិដ្ឋមង្គលិកា...) បពិត្រភិក្ខុ សញ្ញារបស់បុរស រមែងភ្លេចភ្លាំងដោយមួយរំពេចជាប្រាកដ បពិត្រលោកមានប្រាជ្ញាក្រាស់ដូចផែនដី សូមលោកអត់នូវទោសកំហុសម្តងចុះ អ្នកប្រាជ្ញទាំងឡាយ រមែងមិនមានក្រោធជាកំឡាំង។

[១៨០] (ព្រះមហាសត្វ...) ចូរឲ្យមណ្ឌព្យកុមារ ដែលជាបុគ្គលមានប្រាជ្ញាតិច ជាបុត្ររបស់នាង បរិភោគនូវដុំបាយ ដែលយើងឈរហើយបានមកនេះ ចំណែកខាងពួកយក្ខ នឹងលែងបៀតបៀននូវកូនរបស់នាង ទាំងកូនរបស់នាងនោះ នឹងទៅជាបុគ្គលមិនមានរោគ។

[១៨១] (នាងទិដ្ឋមង្គលិកា...) ម្នាលមណ្ឌព្យៈ អ្នកជាបុគ្គលពាល មានប្រាជ្ញាស្តួចស្តើង អ្នកជាបុគ្គលមិនស្គាល់នូវបុញ្ញក្ខេត្តទាំងឡាយ អ្នកឲ្យទានចំពោះតែពួកជន ដែលមានទឹកចត់ គឺកិលេសដ៏ច្រើន មានអំពើដ៏សៅហ្មង ជាអ្នកមិនសង្រួម។ (ពួកជនខ្លះ) បួងសក់ ស្លៀកនូវស្បែកខ្លាឃ្មុំ មានមុខទ្រុបទ្រុល (ដោយពុកមាត់ ពុកចង្កា) ដូចរណ្តៅទឹកដ៏ចាស់ អ្នកទាំងឡាយ ចូរមើលពួកសត្វដែលមានសភាពអាក្រក់នេះចុះ ដ្បិតក្នងសក់ និងស្បែកខ្លាឃ្មុំ ការពារនូវបុគ្គលដែលមានប្រាជ្ញាតិចមិនបានទេ។ ពួកបុគ្គលណា លះបង់រាគៈ ទោសៈ និងអវិជ្ជា ពួកបុគ្គលនោះ ឈ្មោះថា ជាអរហន្តខីណាស្រព ទានដែលបុគ្គលឲ្យចំពោះពួកបុគ្គលទាំងនោះ ទើបជាទានមានផលច្រើន។

[១៨២] (អភិសម្ពុទ្ធគាថា) ស្តេចក្នុងដែនមេជ្ឈៈ បៀតបៀននូវចិត្តរបស់មាតង្គតាបសជាអ្នកមានយស ស្តេចក្នុងដែនមេជ្ឈៈ ព្រមទាំងបរិស័ទក៏ដាច់សូន្យ ដែនឈ្មោះមេជ្ឈៈ ក៏ទៅជាព្រៃក្នុងកាលនោះ។

ចប់ មាតង្គជាតក ទី១។

## ចិត្តសម្ភូតជាតក ទី២

CS sut.kn.jat.498 | ភាគទី ៦០

### (៤៩៨. ចិត្តសម្ភូតជាតកំ (២))

[១៨៣] (ព្រះរាជាត្រាស់ថា) សេចក្តីខ្វល់ខ្វាយដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ខ្ញុំឃើញសម្ភូតបណ្ឌិតមានអានុភាពច្រើន ជាអ្នកបរិបូណ៌ដោយផលនៃបុណ្យដោយការងាររបស់ខ្លួន។ សេចក្តីខ្វល់ខ្វាយដោយការងារទាំងអស់ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ ចិត្តរបស់បណ្ឌិតឈ្មោះចិត្តៈនោះសម្រេចដូចចិត្តអាត្មាអញដែរឬហ្ន៎។

[១៨៤] (ទារកច្រៀងទូលថា) សេចក្តីខ្វល់ខ្វាយដោយការងារទាំងអស់ ដែលនរជនទាំងឡាយសន្សំហើយដោយប្រពៃ រមែងប្រកបដោយផល មិនមែនឥតអំពើទេ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់ជ្រាបនូវបណ្ឌិតឈ្មោះចិត្តៈនោះ មានចិត្តសម្រេចដូចព្រះរាជហឫទ័យព្រះអង្គដែរ។

[១៨៥] (ព្រះរាជា...) (សំដីនេះ) អ្នកបានឮមក (អំពីសំណាក់) បណ្ឌិតឈ្មោះចិត្តៈដ៏ចំរើនឬ ឬជនណាមួយប្រាប់សេចក្តីនុ៎ះដល់អ្នក គាថា (នេះ) អ្នកច្រៀងពីរោះហើយ ខ្ញុំមិនមានសេចក្តីសង្ស័យទេ ខ្ញុំឲ្យស្រុកសួយមួយរយដល់អ្នក។

[១៨៦] (ទារក...) ខ្ញុំព្រះអង្គមិនបានឮ (អំពីសំណាក់) បណ្ឌិតឈ្មោះចិត្តៈទេ តែឥសី (មួយរូប) បានប្រាប់នូវសេចក្តីនេះដល់ខ្ញុំព្រះអង្គថា អ្នកចូរទៅច្រៀងគាថាតនឹងព្រះរាជា ក្រែងលោស្តេចសព្វព្រះរាជហឫទ័យនឹងប្រោសប្រទាននូវរបស់ដ៏ប្រសើរដល់អ្នក។

[១៨៧] (ព្រះរាជា...) អ្នកទាំងឡាយចូរទឹមនូវរាជរថទាំងឡាយ ដែលធ្វើយ៉ាងល្អ គ្រឿងប្រដាប់ដ៏ពិចិត្ត ចូរចងនូវខ្សែដង្កន់ ពាក់នូវគ្រឿងប្រដាប់ក នៃដំរីទាំងឡាយ។ អ្នកទាំងឡាយ ចូរវាយស្គរ និងសំភោរ ផ្លុំនូវស័ង្ខផង ចូរទឹមនូវយានទាំងឡាយដ៏លឿនៗផង ថ្ងៃនេះឯងអញនឹងទៅមើលឥសី ដែលគង់ក្នុងអាស្រមណា អញនឹងទៅកាន់អាស្រមនោះ។

[១៨៨] ឱហ្ន៎ អាត្មាអញ មានលាភល្អណាស់តើ គាថាដែលអាត្មាអញច្រៀងពីរោះហើយ ក្នុងកណ្តាលបរិស័ទ អាត្មាអញបានឃើញនូវឥសីដ៏បរិបូណ៌ដោយសីល និងវត្ត ហើយក៏ត្រេកអររីករាយ។

[១៨៩] សូមលោកដ៏ចំរើនទទួលនូវអាសនៈ ទឹក និងប្រេងលាបជើងរបស់យើងចុះ បពិត្រម្ចាស់ថ្លៃ ខ្ញុំសួរលោកដ៏ចំរើនក្នុងវត្ថុមានដំឡៃ សូមលោកដ៏ចំរើនទទួលនូវវត្ថុមានដំឡៃរបស់យើងខ្ញុំ។

[១៩០] ពួកជនចូរធ្វើនូវលំនៅ ឲ្យជាទីរីករាយដល់លោកផង សូមលោកឲ្យពួកនារីបំរើផង សូមលោកធ្វើនូវឱកាស ដើម្បីអនុគ្រោះយើងនឹងធ្វើជាធំនេះ ទាំងពីរនាក់។

[១៩១] (ចិត្តបណ្ឌិតពោលថា) បពិត្រព្រះរាជា អាត្មាភាពបានឃើញនូវផលនៃទុច្ចរិត និងផលដ៏ប្រសើររបស់ធម៌ ដែលបានសន្សំដោយប្រពៃ អាត្មាភាពនឹងសង្រួមនូវខ្លួនតែម្យ៉ាង អាត្មាភាពមិនប្រាថ្នានូវកូន ឬសត្វចិញ្ចឹម ឬទ្រព្យទេ។

១០ ឆ្នាំ ១០ ដងនេះ ជាជីវិតរបស់ពួកសត្វក្នុងលោកនេះ ជីវិតនោះមិនដល់កំណត់នោះនៅឡើយ ក៏ស្វិតស្រពោនទៅ ដូចជាដើមបបុសដែលគេកាត់ហើយ។ កាលបើជីវិតនោះ (ស្រពោនទៅយ៉ាងនេះ) តើរីករាយដូចម្តេចកើត លេងសើចដូចម្តេចកើត ត្រេកអរដូចម្តេចកើត ស្វែងរកទ្រព្យដូចម្តេចកើត បពិត្រព្រះរាជា អាត្មាភាពមានប្រយោជន៍ដោយកូន និងប្រពន្ធ ដូចម្តេចកើត អាត្មាភាពជាបុគ្គលផុតចាកចំណងហើយ។ អាត្មាភាពនោះ ដឹងច្បាស់យ៉ាងនេះ មច្ចុរាជមិនមើលងាយចំពោះអាត្មាភាពទេ កាលបើអាត្មាភាពត្រូវមច្ចុរាជគ្របសង្កត់ (យ៉ាងនេះ) តើត្រេកអរដូចម្តេចកើត ស្វែងរកទ្រព្យដូចម្តេចកើត។ បពិត្រព្រះអង្គជាធំជាងជន ជាតិរបស់ពួកសត្វ ជាធម្មជាតិដ៏ថោកទាបកំណើតមនុស្សចណ្ឌាលលាមក ជាងពួកសត្វក្នុងពួកសត្វជើងពីរ យើងបាននៅក្នុងគភ៌មនុស្សចណ្ឌាលក្នុងកាលមុន ព្រោះតែអំពើជារបស់ខ្លួន ដ៏លាមកក្រៃលែង។

យើងបានកើតជាមនុស្សចណ្ឌាល ក្នុងដែនអវន្តី ហើយបែរមកកើតជាម្រឹគ ប្របឆ្នេរស្ទឹងនេរញ្ជរា រួចកើតជាសត្វអកខ្មៅ[26] ទៀបឆ្នេរស្ទឹងរម្មទាក្នុងថ្ងៃនោះ យើងជាព្រាហ្មណ៍ និងក្សត្រិយ៍។

[១៩២] ជីវិត គឺអាយុមានប្រមាណតិច ត្រូវជរានាំចូលទៅ (កាន់សេចក្តីស្លាប់) កាលបើសត្វត្រូវជរានាំចូលទៅ (កាន់សេចក្តីស្លាប់ហើយ) ទីពឹងពុំមានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយ ដែលមានកំរៃជាទុក្ខឡើយ។ ជីវិត គឺអាយុមានប្រមាណតិច ត្រូវជរានាំទៅ (កាន់សេចក្តីស្លាប់) កាលបើសត្វត្រូវជរានាំទៅ (កាន់សេចក្តីស្លាប់ហើយ) ទីពឹងពុំមានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយ ដែលមានផលជាទុក្ខឡើយ។ ជីវិត គឺអាយុមានប្រមាណតិច ត្រូវជរានាំទៅ (កាន់សេចក្តីស្លាប់) កាលបើសត្វត្រូវជរានាំទៅ (កាន់សេចក្តីស្លាប់ហើយ) ទីពឹងពំនាក់ពុំមានទេ បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើទាំងឡាយ ដែលជាប្រធាននៃធូលី គឺកិលេសឡើយ។ ជីវិត គឺអាយុមានប្រមាណតិច ត្រូវជរានាំទៅ (កាន់សេចក្តីស្លាប់) ជរាតែងកំចាត់បង់នូវសម្បុររបស់សត្វ ដែលកំពុងគ្រាំគ្រា បពិត្រព្រះបាទបញ្ចាលៈ សូមទ្រង់ធ្វើតាមពាក្យអាត្មាភាពចុះ ទ្រង់កុំធ្វើនូវអំពើដើម្បីកើតក្នុងនរកឡើយ។

[១៩៣] (ព្រះរាជា...) ពាក្យ (របស់លោក) នោះ ពេញជាពិតមែនហើយ បពិត្រឥសី លោកពោលយ៉ាងណា សេចក្តីនុ៎ះយ៉ាងនោះ បពិត្រភិក្ខុ តែកាមទាំងឡាយរបស់ខ្ញុំ មានសភាពមិនតិចទេ កាមទាំងនោះ បុគ្គលប្រហែលខ្ញុំ លះបង់បានដោយក្រ។ ដំរីជាប់នៅក្នុងកណ្តាលភក់ មិនអាចរើខ្លួនទៅកាន់ទីគោកដោយខ្លួនឯងយ៉ាងណា ខ្ញុំក៏ជាបុគ្គលជាប់នៅក្នុងភក់ គឺកាម មិនអាចបួសតាមផ្លូវ (ឱវាទ) របស់លោកជាភិក្ខុយ៉ាងនោះដែរ។ មាតាបិតា ប្រៀនប្រដៅបុត្ត (ដោយឧបាយថា) ធ្វើម្តេច បុត្តនឹងបានសេចក្តីសុខយ៉ាងណា បពិត្រលោកដ៏ចំរើន សូមលោកប្រៀនប្រដៅខ្ញុំតាមសមគួរ ល្មមឲ្យខ្ញុំលះលោកនេះទៅហើយ បានសេចក្តីសុខជាអង្វែង ក៏យ៉ាងនោះដែរ។

[១៩៤] (ចិត្តបណ្ឌិត...) បពិត្រព្រះអង្គជាធំជាងជន បើព្រះអង្គមិនអាចនឹងលះបង់នូវកាមទាំងឡាយជារបស់មនុស្សនេះបានទេ បពិត្រព្រះរាជា សូមព្រះអង្គតាំងទុកនូវពលីប្រកបដោយធម៌ ឯការងារដែលមិនប្រកបដោយធម៌ ក៏សូមកុំឲ្យមានក្នុងដែនរបស់ព្រះអង្គឡើយ។ សូមឲ្យទូតទាំងឡាយ (របស់ព្រះអង្គ) ជាអ្នកនិមន្តនូវពួកព្រាហ្មណ៍ ចេញទៅកាន់ទិសទាំង ៤ (និមន្តមិនរើសមុខ) សូមឲ្យព្រះអង្គទំនុកបម្រុងនូវសមណព្រាហ្មណ៍ទាំងនោះ ដោយបាយ ទឹក សំពត់ និងសេនាសនប្បច្ច័យ។ សូមព្រះអង្គមានព្រះទ័យជ្រះថ្លា ហើយញុំាងសមណព្រាហ្មណ៍ឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹក លុះព្រះអង្គឲ្យទាន និងប្រើប្រាស់ (ទ្រព្យ) តាមសមគួរដល់រាជានុភាពហើយ ឥតមានអ្នកផងតិះដៀល ហើយសូមឲ្យទៅកើតក្នុងឋានសួគ៌។ បពិត្រព្រះរាជា បើសេចក្តីស្រវឹងគ្របសង្កត់ព្រះអង្គដែលមានពួកនារីចោមរោមបំរើ សូមព្រះអង្គធ្វើទុកក្នុងព្រះទ័យ ចំពោះគាថានេះចុះ មួយទៀត សូមព្រះអង្គ (ឧស្សាហ៍) ប្រើគេឲ្យពោលនូវគាថានេះ ក្នុងកណ្តាលបរិស័ទថា

សត្វណាដេកក្នុងទីវាល ពៅដោះមាតាកំពុងដើរ ជាសត្វច្របូកច្របល់ដោយពួកសុនខ សត្វនោះគេហៅថាព្រះរាជា ក្នុងថ្ងៃនេះ។

ចប់ ចិត្តសម្ភូតជាតក ទី២។

## សីវិរាជជាតក ទី៣

CS sut.kn.jat.499 | ភាគទី ៦០

### (៤៩៩. សិវិជាតកំ (៣))

[១៩៥] (ព្រះឥន្ទតំណែងខ្លួនជាមនុស្សចាស់ ពោលថា) ខ្ញុំព្រះអង្គជាបុគ្គលចាស់ជរា មើលមិនឃើញឆ្ងាយ មកដើម្បីសុំនូវព្រះនេត្រ ខ្ញុំព្រះអង្គជាអ្នកមានភ្នែកម្ខាង កាលបើខ្ញុំសុំហើយ សូមព្រះអង្គប្រទាននូវព្រះនេត្រដល់ខ្ញុំព្រះអង្គ។

[១៩៦] (ព្រះបាទសីវិរាជពោធិសត្វត្រាស់សួរថា) នែស្មូម អ្នកណាប្រាប់អ្នក ទើបអ្នកមកក្នុងទីនេះ បម្រុងសុំនូវភ្នែកទាំងឡាយ ជនទាំងឡាយពោលនូវភ្នែកណា ថាជារបស់ដែលបុរសលះបានដោយក្រ អ្នកសុំនូវភ្នែក ជាអវយវៈដ៏ខ្ពង់ខ្ពស់នោះដែលគេលះបានដោយក្រក្រៃលែង។

[១៩៧] (ព្រះឥន្ទ...) ពួកទេវតាបានពោលនូវទេវតាវិសេសណា ថាសុជម្បតិ ក្នុងទេវលោក ពួកជនបានពោលនូវទេវតាវិសេសនោះថាមឃវៈ ក្នុងមនុស្សលោក ខ្លួនខ្ញុំជាស្មូម ដែលទេវតាវិសេសនោះប្រាប់ ទើបមកក្នុងទីនេះ បម្រុងសុំព្រះនេត្រទាំងឡាយ។ ខ្លួនខ្ញុំជាស្មូម ការសូមជាកិច្ចឧត្តមរបស់ខ្ញុំ កាលបើខ្ញុំសូមព្រះនេត្រទាំងឡាយ សូមព្រះអង្គប្រទាន ពួកជនបានពោលនូវភ្នែកណា ថាជារបស់ដែលបុរសលះបានដោយក្រ សូមព្រះអង្គប្រទាននូវព្រះនេត្រដ៏ប្រសើរនោះដល់ខ្ញុំព្រះអង្គ។

(ព្រះបាទសិវិរាជ...) ខ្លួនអ្នកមកដោយប្រយោជន៍ណា ប្រាថ្នានូវប្រយោជន៍ណា សេចក្តីត្រិះរិះនូវប្រយោជន៍នោះ សូមឲ្យសម្រេចដល់អ្នកចុះ ម្នាលព្រាហ្មណ៍ អ្នកចូរបាននូវភ្នែកទាំងឡាយ។ កាលបើអ្នកសូមភ្នែកមួយ យើងនឹងឲ្យភ្នែកទាំងពីរ កាលជនកំពុងមើល សូមអ្នកនោះជាបុគ្គលមានភ្នែកទៅចុះ អ្នកប្រាថ្នានូវរបស់ណា របស់នោះចូរសម្រេចដល់អ្នក។

[១៩៨] (ពួកជនពោលថា) បពិត្រព្រះសម្មតិទេព សូមទ្រង់កុំប្រទាននូវព្រះនេត្រ សូមទ្រង់កុំលះបង់នូវពួកយើងទាំងអស់គ្នាឡើយ បពិត្រមហារាជ សូមទ្រង់ប្រទាននូវព្រះរាជទ្រព្យ គឺកែវមុក្តា និងកែវពិទូរ្យដ៏ច្រើនវិញចុះ។ បពិត្រព្រះសម្មតិទេព សូមទ្រង់ប្រទាននូវរថដែលទឹមដោយសេះអាជានីយ ដែលប្រដាប់ហើយ បពិត្រមហារាជ សូមព្រះអង្គប្រទាននូវដំរីទាំងឡាយ ប្រកបដោយគ្រឿងប្រដាប់ក្បាល គឺបណ្តាញមាសវិញចុះ។ រទាំងពួង ព្រមទាំងខ្សែ ព្រមទាំងរាជរថចោមរោមព្រះអង្គដោយជុំវិញគ្រប់កាល ដោយប្រការៈណា បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ សូមព្រះអង្គប្រទានដោយប្រការៈនោះចុះ។

[១៩៩] (ព្រះរាជា...) បុគ្គលណាពោលថា អាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះ ឈ្មោះថាយកអន្ទាក់ដែលធ្លាក់លើផែនដីមកពាក់ព្វដ៏ក។ បុគ្គលណាពោលថា អាត្មាអញនឹងឲ្យ ហើយធ្វើនូវចិត្តក្នុងការមិនឲ្យវិញ បុគ្គលនោះ ឈ្មោះថាជាបុគ្គលលាមកក្រៃលែងជាងបុគ្គលលាមក ហើយដល់នូវឋាននរក ជាទីសម្រេចរបស់ព្រះយមរាជ។ ស្មូមសូមនូវរបស់ណា បុគ្គលគួរតែឲ្យនូវរបស់នោះ មិនសូមនូវរបស់ណា មិនត្រូវឲ្យរបស់នោះទេ ព្រាហ្មណ៍សូមនូវរបស់ណានឹងអាត្មាអញ អាត្មាអញនោះនឹងឲ្យនូវរបស់នោះឯង។

[២០០] (ពួករាជអាមាត្យ...) បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គប្រាថ្នានូវរបស់អ្វី គឺអាយុ ឬពណ៌សម្បុរ ឬសេចក្តីសុខ ឬក៏កំឡាំង ទើបព្រះអង្គប្រទាន (ព្រះនេត្រ) ព្រះរាជាទ្រង់ប្រសើរជាងជនអ្នកនៅក្នុងដែនសីវិទាំងឡាយ មិនសមបើប្រទានព្រះនេត្រទាំងឡាយ ព្រោះហេតុនៃប្រយោជន៍ក្នុងបរលោក។

[២០១] (ព្រះរាជា...) អញមិនមែនឲ្យចក្ខុនេះ ព្រោះយសទេ មិនមែនប្រាថ្នាកូន មិនមែនប្រាថ្នាទ្រព្យ មិនមែនប្រាថ្នានូវដែនទេ ធម៌

គឺប្រវេណីនៃការឲ្យទានជាផ្លូវបុរាណ ដែលពួកសប្បុរសធ្លាប់ប្រព្រឹត្តមកហើយ ចិត្តរបស់អញ តែងរីករាយក្នុងការឲ្យ ដោយប្រការដូច្នេះឯង។

[២០២] (អភិសម្ពុទ្ធគាថា) ភ្នែកទាំងពីរមិនជាទីស្អប់របស់តថាគតទេ តថាគតមិនមែនស្អប់ខ្លួនរបស់តថាគតទេ សព្វញ្ញុតញ្ញាណជាទីស្រឡាញ់របស់តថាគត ព្រោះហេតុនោះបានជាតថាគតឲ្យនូវភ្នែក។

[២០៣] (ព្រះរាជា...) ម្នាលពេទ្យឈ្មោះសីវិកៈ ខ្លួនអ្នកជាសំឡាញ់ ជាមិត្តរបស់យើង អ្នកមានវិជ្ជាពេទ្យសិក្សាល្អហើយ ចូរធ្វើតាមសំដីរបស់យើងដោយប្រពៃចុះ កាលយើងកំពុងប្រាថ្នា អ្នកចូរឆ្កៀលនូវភ្នែកទាំងឡាយ (របស់យើង) ហើយដាក់លើដៃរបស់ស្មូមចុះ។

[២០៤] (អភិសម្ពុទ្ធគាថា) ពេទ្យឈ្មោះសីវិកៈ លុះព្រះរាជាទ្រង់ព្រះនាមសីវិ តឿន (យ៉ាងនេះហើយ) ក៏ធ្វើតាមព្រះបន្ទូល ហើយឆ្កៀលនូវព្រះនេត្រទាំងពីររបស់ព្រះរាជា បង្អោនទៅឲ្យព្រាហ្មណ៍ ចំណែកព្រាហ្មណ៍ ក៏ទៅជាបុគ្គលមានភ្នែក ព្រះរាជាទៅជាបុគ្គលខ្វាក់។

[២០៥] (អភិសម្ពុទ្ធគាថា) តអំពីនោះមក ប្រមាណពីរបីថ្ងៃ លុះដល់ព្រះនេត្រទាំងពីរដុះឡើង ព្រះរាជាជាអ្នកញ៉ាំងដែនឲ្យចំរើនដល់ពួកជនអ្នកសីវិ ទ្រង់ត្រាស់បង្គាប់នាយសារថីថា នែនាយសារថី អ្នកចូរទឹមយាន លុះទឹមហើយ ចូរប្រាប់យើង យើងនឹងទៅកាន់ទីឧទ្យាន ដែលមានស្រះបោក្ខរណី និងព្រៃព្រឹក្សា។ ព្រះបាទសីវិនោះ ទ្រង់បានចូលទៅគង់ពែនព្រះភ្នែន ប្របឆ្នេរស្រះបោក្ខរណី ទេវរាជឈ្មោះសក្កៈ ជាសុជម្បតិ ក៏មកដល់ចំពោះព្រះអង្គ។

[២០៦] (ព្រះឥន្ទ្រ...) ខ្ញុំជាទេវរាជឈ្មោះសក្កៈ ជាធំជាងទេវតា មកក្នុងសំណាក់ព្រះអង្គ បពិត្រស្តេចឥសី ព្រះអង្គប្រាថ្នាក្នុងព្រះទ័យចំពោះពរណាមួយ សូមត្រេកអរនឹងពរនោះចុះ។

[២០៧] (ព្រះបាទសីវិ...) បពិត្រសក្កៈ ទ្រព្យនឹងពលរបស់ខ្ញុំ មានច្រើនហើយ ទាំងឃ្លាំងរបស់ខ្ញុំ មិនមែនមានតិចទេ កាលបើខ្ញុំនៅតែខ្វាក់ក្នុងកាលឥឡូវនេះ ខ្ញុំពេញចិត្តចំពោះសេចក្តីស្លាប់តែម្យ៉ាង។

[២០៨] (ព្រះឥន្ទ្រ...) បពិត្រក្សត្រិយ៍ជាធំជាងជនមានជើងពីរ សូមព្រះអង្គពោលនូវពាក្យទាំងឡាយដែលជាសច្ចៈចុះ កាលបើព្រះអង្គពោលនូវពាក្យសច្ចៈ ព្រះនេត្រនឹងមានឡើងវិញ។

[២០៩] (ព្រះបាទសីវិ...) ពួកស្មូមណាមានគោត្រផ្សេងៗគ្នា មកដើម្បីសូមចំពោះយើង បណ្តាស្មូមទាំងនោះ ស្មូមណាសូមយើង ស្មូមនោះជាទីស្រឡាញ់នៃចិត្តរបស់យើង សូមឲ្យភ្នែកកើតមានដល់យើង ដោយការពោលនូវពាក្យសច្ចៈនេះ។

[២១០] ព្រាហ្មណ៍នោះមកដើម្បីសូមនូវភ្នែកណានឹងយើងថា សូមព្រះអង្គប្រទាននូវភ្នែក យើងក៏បានឲ្យនូវភ្នែកទាំងឡាយនោះ ដល់ព្រាហ្មណ៍ដែលសូមនោះហើយ។ បីតិ និងសោមនស្សដ៏ច្រើន ក៏កើតឡើងដល់យើងដោយក្រៃលែង សូមឲ្យភ្នែកជាគំរប់ពីរ កើតមានដល់យើងដោយពោលពាក្យសច្ចៈនេះ។

[២១១] (ព្រះឥន្ទ្រ...) បពិត្រក្សត្រិយ៍ អ្នកញ៉ាំងដែនរបស់អ្នកដែនសីវិឲ្យចំរើន គាថាដែលព្រះអង្គពោលតាមធម៌ សូមឲ្យព្រះនេត្រទាំងពីររបស់ព្រះអង្គនេះ ប្រាកដដូចជាទិព្វ។ ព្រះនេត្រទាំងពីររបស់ព្រះអង្គនោះ សូមឲ្យបាននូវការឃើញធ្លុះធ្លាយទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ។

[២១២] (ព្រះបាទសីវិ...) អ្នកណាមួយក្នុងលោកនេះ ដែលគេសូម ហើយមិនឲ្យនូវទ្រព្យដ៏ពេញចិត្ត ឬទ្រព្យដ៏ថ្លៃថ្លា ជាទីស្រឡាញ់ដ៏ក្រៃលែងរបស់ខ្លួន នែអ្នកដែនសីវិទាំងអស់ដែលមកប្រជុំគ្នា ចូរអ្នកទាំងឡាយមើលនូវភ្នែកទាំងពីររបស់អញ ដែលជាទិព្វក្នុងថ្ងៃនេះចុះ។ ចក្ខុទាំងពីររបស់យើង រមែងបាននូវការឃើញធ្លុះធ្លាយទៅខាងក្រៅជញ្ជាំង ខាងក្រៅភ្នំថ្ម អស់ទីចំនួនមួយរយយោជន៍ដោយជុំវិញ។ (វត្ថុណាមួយ) ក្នុងជីវិតរបស់សត្វទាំងឡាយនេះ រមែងមិនប្រសើរជាងចាគៈទេ (ខ្លួនយើង) បានឲ្យនូវចក្ខុជារបស់មនុស្សហើយ បាននូវចក្ខុទិព្វដែលមិនមែនជារបស់មនុស្ស។ ម្នាលអ្នកដែនសីវិទាំងឡាយ អ្នកទាំងឡាយបានឃើញហេតុនេះហើយ ចូរឲ្យទាន ចូរបរិភោគ លុះឲ្យហើយ បរិភោគហើយ តាមសមគួរដល់អានុភាព សូមឲ្យជាអ្នកមិនមានអ្នកណាតិះដៀលបាន ហើយចូរទៅកាន់ឋានសួគ៌ចុះ។

ចប់ សីវិរាជជាតក ទី៣។

## សិរិមន្ទជាតក ទី៤

CS sut.kn.jat.500 | ភាគទី ៦០

### (៥០០. សិរិមន្តជាតកំ (៤))

[២១៣] (ព្រះរាជាវិទេហៈត្រាស់សួរថា) នែសេនកៈ យើងសួរនូវសេចក្តីនុ៎ះ គឺបុគ្គលប្រកបដោយប្រាជ្ញា ប្រាសចាកសិរីសម្បត្តិ ១ បុគ្គលមានយស ប្រាសចាកប្រាជ្ញា ១ អ្នកប្រាជ្ញទាំងឡាយពោលថា បណ្តាបុគ្គលទាំងពីរនោះ បុគ្គលណាប្រសើរជាង។

[២១៤] (អាចារ្យសេនកៈ...) បពិត្រព្រះអង្គជាធំជាងជន ពួកអ្នកប្រាជ្ញ ពួកជនពាល ពួកជនអ្នកបរិបូណ៌ដោយសិល្បៈ និងពួកជនមិនមានសិល្បៈ សូម្បីជាអ្នកមានជាតិខ្ពស់ រមែងជាអ្នកធ្វើនូវការបំរើជនអ្នកមានយស ដែលមិនមានជាតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។

[២១៥] (ព្រះរាជា...) ម្នាលមហោសធ អ្នកមានប្រាជ្ញាមិនថោកថយ ជាអ្នកឃើញនូវហេតុដោយសព្វគ្រប់ យើងសូមសួរអ្នក អំពីបុគ្គលពាលមានយស បណ្ឌិតគ្មានភោគៈ តើអ្នកប្រាជ្ញទាំងឡាយពោលថា បណ្តាបុគ្គលទាំងពីរនោះ បុគ្គលណាប្រសើរជាង។

[២១៦] (មហោសធបណ្ឌិត...) ពួកជនពាល តែងធ្វើនូវអំពើអាក្រក់ទាំងឡាយ ហើយសំគាល់ថា អំពើនេះឯង ជាអំពើប្រសើរ ជាអ្នកឃើញត្រឹមតែលោកនេះ មិនឃើញនូវលោកខាងមុខទេ បុគ្គលពាលតែងកាន់យកនូវទោសក្នុងលោកទាំងពីរ ខ្ញុំព្រះអង្គបានឃើញហេតុនេះ សូមទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ។

[២១៧] (អាចារ្យសេនកៈ...) សិល្បៈនេះ រមែងមិនដល់នូវភោគសម្បត្តិទេ បុគ្គលមានផៅពង្ស ក៏មិនដល់នូវបុគ្គលមានភោគសម្បត្តិដែរ ទាំងបុគ្គលអ្នកមានឱកាសនៃសរីរៈ (មានរូបឆោមល្អ) ក៏មិនដល់នូវបុគ្គលមានភោគសម្បត្តិដែរ សូមទ្រង់ទតចុះ អ្នកផងតែងគប់រកនូវគោរិន្ទសេដ្ឋី ជាមនុស្សហៀរទឹកមាត់ដល់នូវសេចក្តីសុខ ជាអ្នកសាបសូន្យចាកសិរី ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។

[២១៨] (មហោសធ...) បុគ្គលអប្បប្រាជ្ញា បានសេចក្ដីសុខហើយ រមែងស្រវឹង លុះត្រូវសេចក្ដីទុក្ខប៉ះពាល់វិញ ក៏ដល់នូវសេចក្ដីវង្វេង បុគ្គលអប្បប្រាជ្ញា ត្រូវសេចក្ដីសុខ និងទុក្ខមកថ្មីប៉ះពាល់ហើយ ក៏រមែងញាប់ញ័រ ដូចជាវារិចរ (សត្វត្រាច់ទៅក្នុងទឹក) ដែលញាប់ញ័រក្នុងកាលក្ដៅ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ។

[២១៩] (អាចារ្យសេនកៈ...) ពួកសត្វបក្សី តែងហើរសំដៅទៅចោមរោមដើមឈើ ដែលមានផ្លែដ៏ឆ្ងាញ់ក្នុងព្រៃ យ៉ាងណា ជនជាច្រើនតែងគប់រកនូវបុគ្គលស្ដុកស្ដម្ភ បរិបូណ៌ដោយទ្រព្យ និងភោគៈ ព្រោះហេតុតែប្រយោជន៍ ក៏យ៉ាងនោះដែរ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។

[២២០] (មហោសធ...) បុគ្គលពាលមានកំឡាំង រមែងបាននូវទ្រព្យ (ព្រោះតែធ្វើ) នូវកម្មដ៏ក្លៀវក្លា មិនល្អទេ ពួកនិរយបាលតែងទាញកន្ត្រាក់នូវបុគ្គលពាលឥតប្រាជ្ញា ដែលកន្ទក់កន្ទេញនោះ យកទៅកាន់នរកដ៏ក្លៀវក្លា ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលអ្នកមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ។

[២២១] (អាចារ្យសេនកៈ...) ទឹកស្ទឹងទាំងឡាយណាមួយ រមែងហូរចាក់ទៅក្នុងទន្លេគង្គា ទឹកស្ទឹងទាំងអស់នោះ រមែងលះបង់នូវនាម និងគោត្រ ទឹកទន្លេគង្គា កាលបើហូរដល់សមុទ្រ (រមែងបានឈ្មោះថាមហាសមុទ្រយ៉ាណា) បុគ្គលដែលមានប្រាជ្ញា ជាគ្រឿងសម្រេច ក៏មិនប្រាកដក្នុងលោកយ៉ាងនោះដែរ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។

[២២២] (មហោសធ...) លោកសេនកៈបានពោលនូវមហាសមុទ្រណាថាជា សមុទ្រធំ ទឹកស្ទឹងទាំងឡាយតែងហូរទៅក្នុងសមុទ្រនោះរាប់មិនបាន អស់កាលទាំងពួង សមុទ្រនោះ មានសន្ទុះដ៏លើសលប់ជានិច្ចក៏មែន តែថា ទឹកមហាសមុទ្រក៏មិនកន្លងនូវច្រាំងបានទេ ការប្រឹក្សារបស់មនុស្សពាល ក៏យ៉ាងនោះដែរ តាំងពីកាលណាមក បុគ្គលអ្នកមានសិរី រមែងមិនកន្លងនូវបុគ្គលមានប្រាជ្ញាបានឡើយ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ។

[២២៣] (អាចារ្យសេនកៈ...) បុគ្គលមានយសបិតនៅក្នុងទីវិនិច្ឆ័យ បើទុកជាមិនព្រៀងទុក ក៏អាចប្រាប់នូវសេចក្ដីចំពោះពួកជនដទៃបាន សំដីរបស់បុគ្គលមានយសនោះឯង រមែងលូតលាស់ក្នុងកណ្ដាលនៃពួកញាតិ អ្នកផងមិនអាចញ៉ាំងបុគ្គលដែលមានប្រាជ្ញា តែសាបសូន្យចាកសិរី ឲ្យធ្វើការ (អ្វី) បានទេ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។

[២២៤] (មហោសធ...) បុគ្គលពាលអប្បប្រាជ្ញា រមែងនិយាយកុហក ព្រោះហេតុនៃអ្នកដទៃ ឬខ្លួនឯង បុគ្គលពាលនោះ ត្រូវគេតិះដៀលក្នុងកណ្ដាលទីប្រជុំ ក្នុងកាលខាងក្រោយ បុគ្គលពាលនោះ រមែងទៅកាន់ទុគ្គតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលដែលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរ។

[២២៥] (អាចារ្យសេនកៈ...) បុគ្គលមានប្រាជ្ញាក្រាស់ដូចផែនដី មិនមានទីលំនៅ មិនមានទ្រព្យធន ជាបុគ្គលក្រីក្រ បើទុកជាពោលនូវសេចក្ដី (ណាមួយ) ពាក្យសំដីរបស់បុគ្គលដែលមានប្រាជ្ញានោះ ក៏មិនលូតលាស់ក្នុងកណ្ដាលនៃពួកញាតិ ទាំងសិរីរបស់បុគ្គលមានប្រាជ្ញា ក៏មិនមាន ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។

[២២៦] (មហោសធ...) បុគ្គលអ្នកមានប្រាជ្ញាក្រាស់ដូចផែនដី រមែងមិននិយាយពាក្យលេះលោះ ព្រោះហេតុនៃបុគ្គលដទៃ ឬខ្លួនឯងទេ បុគ្គលអ្នកមានប្រាជ្ញានោះ មានគេបូជាក្នុងកណ្ដាលទីប្រជុំ លុះកាលខាងក្រោយ អ្នកមានប្រាជ្ញានោះ រមែងទៅកាន់សុគតិ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ។

[២២៧] (អាចារ្យសេនកៈ...) ដំរី គោ សេះ កែវមណី កុណ្ឌល និងនារី តែងកើតមានក្នុងត្រកូលដ៏ស្ដុកស្ដម្ភ ដំរី គោ សេះ ជាដើមទាំងអស់នោះ ជារបស់មិនមានឫទ្ធិ ទើបជាគ្រឿងឧបភោគ (ប្រើប្រាស់) របស់បុរសជាឥស្សរៈ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។

[២២៨] (មហោសធ...) សិរី គឺឥស្សរិយយស រមែងលះបង់នូវបុគ្គលពាល ដែលមិនចេះចាត់ចែងនូវការងារ ជាអ្នកមានគំនិតអាក្រក់ ឥតប្រាជ្ញា ដូចពស់ដែលលះចោលនូវសំណកចាស់ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញាហ្នឹងឯង ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ។

[២២៩] (អាចារ្យសេនកៈ...) បពិត្រព្រះអង្គដ៏ចំរើន ពួកខ្ញុំព្រះអង្គទាំង ៥ នាក់ សុទ្ធសឹងជាបណ្ឌិត ប្រណម្យដៃបំរើព្រះអង្គទាំងអស់គ្នា ព្រះអង្គជាធំលើសលប់ពួកខ្ញុំព្រះអង្គ ដូចជាទេវរាជឈ្មោះសក្កៈ ជាម្ចាស់នៃទេវតា ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលថោកទាប ឯបុគ្គលមានសិរី ជាបុគ្គលប្រសើរ។

[២៣០] (មហោសធ...) បុគ្គលពាលដែលមានយស ទុកដូចជាទាសៈរបស់បុគ្គលអ្នកមានប្រាជ្ញា នាកាលហេតុទាំងឡាយប្រាកដដូច្នោះកើតហើយ អ្នកប្រាជ្ញតាក់តែងនូវប្រស្នាដ៏ល្អិតណា បុគ្គលពាលរមែងដល់នូវការវង្វេងក្នុងប្រស្នាដ៏ល្អិតនោះ ខ្ញុំព្រះអង្គបានឃើញហេតុនេះហើយ ទើបទូលថា បុគ្គលមានប្រាជ្ញា ជាបុគ្គលប្រសើរ ឯបុគ្គលពាលមានយស មិនប្រសើរទេ។

[២៣១] តាមពិត ពួកសប្បុរស តែងសរសើរប្រាជ្ញាតែម្យ៉ាង ពួកមនុស្សតែងត្រេកអរចំពោះភោគៈ សិរីគ្រាន់តែជាទីត្រេកអររបស់ (ពួកមនុស្សពាល) មួយទៀត ញាណនៃអ្នកប្រាជ្ញទាំងឡាយ មិនមានអ្វីប្រៀបផ្ទឹមបានទេ តាំងពីកាលណាមក បុគ្គលអ្នកមានសិរី រមែងមិនកន្លងនូវបុគ្គលមានប្រាជ្ញាបានឡើយ។

[២៣២] (ព្រះបាទវិទេហរាជ...) ម្នាលមហោសធៈ ជាអ្នកឃើញធម៌សព្វគ្រប់ យើងបានសួរនូវប្រស្នាណា អ្នកបានថ្លែងដោះស្រាយនូវប្រស្នានោះដល់យើង យើងត្រេកអរដោយការដោះស្រាយនូវប្រស្នា (របស់យើង) យើងសូមឲ្យទ្រព្យទាំងនេះ គឺគោមួយពាន់ មានគោឧសភ (ជាដើម) ផង ដំរីផង រថដែលទឹមដោយសេះអាជានេយ្យ ១០ ផង ស្រុកសួយ ១៦ ផង ដល់អ្នក។

ចប់ សិរីមន្ទជាតក ទី៤។

## រោហានមិគជាតក ទី៥

## (៥០១. រោហណមិគជាតកំ (៥ ))

[២៣៣] (រោហនៈម្រឹកពោធិសត្វពោលថា) ម្នាលចិត្តកៈ ហ្វូងម្រឹគទាំងនេះ ខ្លាចសេចក្តីស្លាប់ ទើបរត់ចេញទៅ សូមអ្នករត់ទៅចុះ កុំសង្ស័យឡើយ ហ្វូងម្រឹគទាំងឡាយនឹងរស់នៅជាមួយនឹងអ្នក។

[២៣៤] (ចិត្តៈម្រឹគជាប្អូនពោលថា) បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំ ត្រូវសេចក្តីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះ។

(រោហន...) មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំទេ នឹងស្លាប់មិនខាន អ្នកចូរទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនឹងអ្នក។

(ចិត្តកៈ...) បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំត្រូវសេចក្តីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងដែលជាប់អន្ទាក់ទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះ។

[២៣៥] (រោហនៈម្រឹគពោលថា) ម្នាលនាងជាអ្នកភិតភ័យ នាងចូរទៅចុះ រត់ទៅចុះ ខ្លួនយើងជាប់ក្នុងអន្ទាក់កោងគន្លឹះដែក ចូរនាងទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនាង។

[២៣៦] (សុតនាម្រឹគីពោលថា) បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំត្រូវសេចក្តីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់ចោលអ្នកបងទេ ខ្ញុំនឹងស៊ូលះបង់ជីវិតក្នុងទីនេះឯង។

(រោហនៈ...) មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំ មុខជានឹងស្លាប់មិនខាន នាងចូរទៅចុះ កុំសង្ស័យឡើយ មាតាបិតានឹងរស់នៅជាមួយនឹងនាង។

(សុតនាម្រឹគី...) បពិត្ររោហនៈ ខ្ញុំមិនទៅទេ ហឫទ័យរបស់ខ្ញុំត្រូវសេចក្តីសោកទាញកន្ត្រាក់ ខ្ញុំមិនលះបង់អ្នកបងដែលជាប់អន្ទាក់ទេ ខ្ញុំនឹងស៊ូលះបង់ជីវិត ក្នុងទីនេះឯង។

[២៣៧] (រោហនៈម្រឹគ...) ព្រានណានឹងសំឡាប់យើង ក្នុងថ្ងៃនេះ ដោយព្រួញ ឬដោយលំពែង ព្រាននោះមានរូបដ៏អាក្រក់ មានទាំងអាវុធជាប់ជាមួយ កំពុងដើរមក។

[២៣៨] (អភិសម្ពុទ្ធគាថា) សុតនាម្រឹគីនោះជាសត្វភិតភ័យ លុះត្រូវភ័យគ្របសង្កត់គំរាមហើយ ក៏រត់ទៅ អស់កាលមួយស្របក់ ត្រឡប់មកដើម្បីសេចក្តីស្លាប់វិញ ឈ្មោះថាបានធ្វើនូវអំពើដ៏កម្រក្រៃពែក។

[២៣៩] (ព្រានសួរថា) ម្រឹគទាំងនេះ ត្រូវជាអ្វីនឹងអ្នក រួចចាកអន្ទាក់ហើយ ចូលមករកអន្ទាក់វិញ ម្រឹគទាំងនោះសូម្បីមានហេតុដល់ជីវិត ក៏មិនប្រាថ្នាលះបង់អ្នក។

[២៤០] (រោហនៈម្រឹគ...) ម្នាលព្រាន ម្រឹគទាំងនេះជាបងប្អូនរបស់ខ្ញុំ កើតក្នុងផ្ទៃជាមួយគ្នា មានមាតាតែមួយ សូម្បីមានហេតុដល់ជីវិត ក៏មិនប្រាថ្នាលះបង់ចោលខ្ញុំ។

[២៤១] (ចិត្តៈម្រឹគ...) ម្នាលព្រាន មាតាបិតាទាំងនោះ ជាសត្វខ្វាក់ មិនមានអ្នកដឹកនាំ នឹងស្លាប់មិនខាន សូមអ្នកឲ្យនូវជីវិតដល់ម្រឹគទាំង ៥ សូមអ្នកលែងរោហនៈម្រឹគជាបងឲ្យទាន។

[២៤២] (ព្រាន...) ខ្ញុំនឹងលែងនូវម្រឹគ ដែលជាអ្នកចិញ្ចឹមនូវមាតាបិតា ឲ្យដល់អ្នកទាំងឡាយ មាតាបិតាចូររីករាយ ព្រោះឃើញនូវម្រឹគដ៏ប្រសើរដែលរួចហើយចុះ។

[២៤៣] (ចិត្តៈម្រឹគ...) ម្នាលព្រាន ថ្ងៃនេះខ្ញុំត្រេកអរ ព្រោះបានឃើញនូវម្រឹគដ៏ប្រសើរដែលរួចហើយ យ៉ាងណា សូមអ្នកត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ។

[២៤៤] (ម្រឹគជាមាតាសួរថា) កាលបើជីវិតចូលទៅជិត (កាន់សេចក្តីស្លាប់) ហើយ តើអ្នកបានរួចដោយហេតុអ្វី នែកូន ព្រានបានដោះអ្នកចេញចាកអន្ទាក់កោង តើដោយហេតុដូចម្តេច។

[២៤៥] (រោហនៈម្រឹគ...) ចិត្តៈម្រឹគនិយាយពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ អាស្រ័យនូវហឫទ័យ បានដោះខ្ញុំ (ចាកអន្ទាក់) ដោយពាក្យជាសុភាសិត។ សុតនាម្រឹគីនិយាយពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ អាស្រ័យនូវហឫទ័យ បានដោះខ្ញុំ (ចាកអន្ទាក់) ដោយពាក្យជាសុភាសិត។ លុះព្រានបានស្តាប់ពាក្យជាសុខដល់ត្រចៀក ជាពាក្យចូលទៅកាន់ហឫទ័យ អាស្រ័យនូវហឫទ័យហើយ ក៏បានដោះខ្ញុំ (ចាកអន្ទាក់) ព្រោះស្តាប់ពាក្យជាសុភាសិត។

[២៤៦] (ម្រឹគជាមាតាបិតាពោលថា) ថ្ងៃនេះ យើងត្រេកអរ ព្រោះបានឃើញរោហនៈម្រឹគដែលមកដល់យ៉ាងណា សូមឲ្យព្រានត្រេកអរដោយកូន និងប្រពន្ធទាំងឡាយ យ៉ាងនោះដែរ។

[២៤៧] (ព្រះរាជាត្រាស់សួរថា) ម្នាលព្រាន អ្នកបាននិយាយថា ខ្ញុំព្រះអង្គនឹងនាំម្រឹគ ឬស្បែកម្រឹគមក មិនមែនឬ ចុះហេតុដូចម្តេច ទើបអ្នកមិននាំយកម្រឹគ ឬស្បែកម្រឹគមក។

[២៤៨] (ព្រាន...) ម្រឹគនោះបានមកដល់កណ្តាប់ដៃ ជាប់នៅក្នុងអន្ទាក់កោងហើយ តែម្រឹគដទៃដែលផុត (ចាកអន្ទាក់) ក៏ (ចូលមករកស្តេចម្រឹគនោះ។ សេចក្តីតក់ស្លុត ការព្រួចព្រឺរោម ដែលមិនធ្លាប់កើត ក៏កើតមានដល់ខ្ញុំព្រះអង្គនោះ ថាបើខ្ញុំព្រះអង្គនឹងសម្លាប់ម្រឹគនេះទៅ ខ្ញុំព្រះអង្គនឹងលះបង់នូវជីវិតក្នុងថ្ងៃនេះឯង។

[២៤៩] (ព្រះរាជា...) ម្នាលព្រាន ពួកម្រឹគទាំងនោះមានអាការដូចម្តេច ពួកម្រឹគមានធម៌ដូចម្តេច មានវណ្ណៈដូចម្តេច មានសីលដូចម្តេច ទើបអ្នកសរសើរប្រាប់យើងខ្លាំងម្ល៉េះ។

[២៥០] (ព្រាន...) ពួកម្រឹគទាំងនោះ មានស្នែងស មានរោមកន្ទុយស្អាត មានស្បែកឧបមាដូចមាស មានជើងក្រហម មានភ្នែកដ៏ថ្លា

បីដូចជាគេបន្តក់ គួរជាទីរីករាយនៃចិត្ត។

[២៥១] បពិត្រព្រះសម្មតិទេព ពួកម្រឹគទាំងនោះ មានអាការដូច្នេះ ពួកម្រឹគមានធម៌ដូច្នេះ បពិត្រព្រះសម្មតិទេព ពួកម្រឹគទាំងនោះ ជាសត្វចិញ្ចឹមមាតាបិតា ខ្ញុំព្រះអង្គមិនហ៊ាននាំយកម្រឹគទាំងនោះមកទេ។

[២៥២] (ព្រះរាជា...) នៃព្រាន យើងនឹងឲ្យនូវវត្ថុនៃមាសជាច្រើនផង នូវកែវមណី និងកុណ្ឌល ក៏ក្រាស់ក្រៃលផង នូវបល្ល័ង្កបួនជ្រុង ដ៏រុងរឿង ដូចជាផ្កាត្រកៀតផង (ដល់អ្នក)។ ម្នាលព្រាន អ្នកមានឧបការៈច្រើនដល់យើង យើង (នឹងឲ្យ) នូវភរិយាពីរនាក់ ដែលមានរូប និងភោគៈសម្បត្តិប្រហែលគ្នាផង នូវគោមួយរយ មានទាំងគោឧសភផង យើងនឹងសោយរាជ្យតាមធម៌។ ម្នាលព្រាន អ្នកចូរចិញ្ចឹមកូន និងប្រពន្ធដោយហេតុនេះគឺ កសិកម្ម ពាណិជកម្ម ឥណទានកម្ម (ការបុល) និងការស្វែងរករបរ (ជាសម្មាអាជីវៈចុះ) អ្នកកុំធ្វើនូវបាបទៀតឡើយ។

ចប់ រោហនមិគជាតក ទី៥។

## ហំសជាតក ទី៦

CS sut.kn.jat.502 | ភាគទី ៦០

(៥០២. ចូឡហំសជាតកំ (៦))

[២៥៣] (ស្តេចហង្សពោធិសត្វពោលថា) ពួកហង្ស មានកក្កក់ទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ ម្នាលសុមុខៈ មានសម្បុរដូចមាស អ្នកចូរគៀសខ្លួនទៅចុះ។ ពួកបក្សីជាញាតិលះបង់នូវយើងម្នាក់ឯង ដែលលុះអំណាចអន្ទាក់ ឥតមានអាឡោះអាល័យ ហើរទៅហើយ ខ្លួនអ្នកតែម្នាក់ឯង សម្ងំនៅដូចម្តេចបាន។ ការដែលហើរចេញទៅរបស់ពួកសត្វស្លាប ជាការប្រសើរ ការប្រព្រឹត្តិនៅជាមួយអ្នកដែលជាប់ចំណង ជាការប្រសើរ មិនមែនទេ អ្នកកុំធ្វើសេចក្តីព្យាយាម ឲ្យសាបសូន្យ ដោយសេចក្តីទុក្ខឡើយ ម្នាលសុមុខៈ អ្នកចូរគៀសខ្លួនចេញទៅតាមប្រាថ្នាចុះ។

[២៥៤] (សុមុខៈហង្សពោលថា) បពិត្រស្តេចហង្សឈ្មោះធតរដ្ឋ ព្រះអង្គត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ ខ្ញុំព្រះអង្គមិនលះបង់ចោលព្រះអង្គទេ ការរស់ ឬការស្លាប់របស់ខ្ញុំព្រះអង្គ នឹងមាននៅជាមួយព្រះអង្គ។

[២៥៥] (ស្តេចហង្ស...) ម្នាលសុមុខៈ អ្នកពោលនូវពាក្យណា ពាក្យនុ៎ះជាពាក្យល្អរបស់អរិយជន ចំណែកខាងខ្ញុំ ល្បងមើលអ្នក ក្នុងការហើរចេញទៅ ទើបពោលពាក្យ (យ៉ាងនេះ) នឹងអ្នក។

[២៥៦] (កូនព្រានព្រៃពោលថា) សត្វបក្សីជាសត្វត្រាច់ទៅក្នុងអាកាស រមែងទៅកាន់ផ្លូវតាមអាកាសដែលមិនមែនជាផ្លូវ ម្នាលអ្នកដ៏ប្រសើរជាងពួកបក្សីហង្ស (ម្តេចក៏) អ្នកមិនដឹងនូវអន្ទាក់អំពីចម្ងាយ។

[២៥៧] (ស្តេចហង្ស...) សេចក្តីវិនាសមានមកក្នុងកាលណា សត្វកាលបើជីវិតត្រូវអស់ហើយ ទោះបីប្រទះនូវសំណាញ់ ឬអន្ទាក់ រមែងមិនដឹងក្នុងកាលនោះ។

[២៥៨] (ព្រានពោលនឹងសុមុខៈហង្សថា) ពួកបក្សីហង្សមានកក្កក់ទាំងនេះ លុះត្រូវភ័យគ្របសង្កត់ហើយ ក៏ហើរអស់ទៅ ម្នាលអ្នកមានស្បែកដ៏ខៀវ មានវណ្ណៈដូចមាស អ្នកម្នាក់ឯងសម្ងំនៅ។ ពួកបក្សីទាំងនេះ ជាសត្វទៅតាមអាកាស ឥតមានអាល័យ ជាសត្វមានកក្កក់ លុះស៊ីហើយ ផឹកហើយ ក៏ហើរចេញទៅ អ្នកតែម្នាក់ឯងចូលមកវិញ។ បក្សីនេះត្រូវជាអ្វីនឹងអ្នក ទើបអ្នកដែលផុត (ចាកអន្ទាក់) ចូលមករកបក្សីដែលជាប់វិញ ពួកបក្សីនាំគ្នាហើរចោលអស់ទៅហើយ ហេតុដូចម្តេច អ្នកសម្ងំនៅតែម្នាក់ឯង។

[២៥៩] (សុមុខៈហង្ស...) បក្សីនេះជាស្តេចរបស់យើងផង ជាមិត្ររបស់យើងផង ជាសំឡាញ់ស្មើដោយជីវិតរបស់យើងផង ខ្លួនយើងនឹងមិនលះបង់នូវបក្សីនោះ ដរាបអស់កាលនៃជីវិត។

[២៦០] (ព្រាន...) អ្នកណាប្រាថ្នាលះបង់ជីវិត ព្រោះហេតុសំឡាញ់ យើងនឹងលែងនូវសំឡាញ់របស់អ្នកនោះ ក្នុងកាលឥឡូវនេះ សូមឲ្យស្តេចរបស់អ្នកទៅជាមួយនឹងអ្នកចុះ។

[២៦១] (សុមុខៈហង្ស...) ម្នាលព្រាន ក្នុងថ្ងៃនេះ យើងត្រេកអរព្រោះបានឃើញនូវស្តេចបក្សីរួចចាកចំណងយ៉ាងណា អ្នកក៏ចូរត្រេកអរជាមួយនឹងពួកញាតិទាំងអស់ យ៉ាងនោះដែរ។

[២៦២] (ស្តេចហង្ស...) ព្រះអង្គមានសេចក្តីសុខស្រួលទេឬ ព្រះអង្គមិនមានជម្ងឺដម្កាត់ទេឬ ព្រះអង្គតែងប្រៀនប្រដៅនូវអ្នកដែនដ៏ធំទូលាយនេះ តាមធម៌ទេឬ។

[២៦៣] (ព្រះរាជាតបថា) ម្នាលហង្ស យើងមានសេចក្តីសុខស្រួលទេ ម្នាលហង្ស យើងមិនមានជម្ងឺដម្កាត់ទេ ខ្លួនយើងក៏បានប្រៀនប្រដៅនូវអ្នកដែនដ៏ធំទូលាយនេះតាមធម៌។

[២៦៤] (ស្តេចហង្ស...) ពួកអាមាត្យរបស់ព្រះអង្គ មិនមានកំហុសណាមួយទេឬ ពួកសត្រូវនៃព្រះអង្គក្នុងទីឆ្ងាយ ដូចជាស្រមោល (ដែលមិនមាន) ក្នុងទិសខាងត្បូងទេឬ។

[២៦៥] (ព្រះរាជា...) ពួកអាមាត្យរបស់យើង មិនមានកំហុសណាមួយទេ ទាំងសត្រូវរបស់យើងក្នុងទីឆ្ងាយ ក៏ដូចស្រមោល (ដែលមិនមាន) ក្នុងទិសខាងត្បូងដូច្នោះ។

[២៦៦] (ស្តេចហង្ស...) ភរិយារបស់ព្រះអង្គមានចិត្តស្មើគ្នា ជាស្រីស្តាប់បង្គាប់ព្រះអង្គ ស្រដីនូវពាក្យជាទីស្រឡាញ់ បរិបូណ៌ដោយបុត្ត និងរូប និងយសបរិវារ លុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គដែរឬ។

[២៦៧] (ព្រះរាជា...) ភរិយារបស់យើងមានចិត្តស្មើគ្នា ជាស្រីស្តាប់បង្គាប់យើង ស្រដីពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត និងរូប និងយសបរិវារ លុះអំណាចសេចក្តីប្រាថ្នារបស់យើងទេ។

[២៦៨] (ស្តេចហង្ស...) បពិត្រព្រះអង្គអ្នកញុំាងដែនឲ្យចំរើន ព្រះអង្គមានព្រះរាជបុត្តច្រើន កើតឡើងដោយល្អ បរិបូណ៌ដោយសន្ទុះ

នៃប្រាជ្ញា ស្រុះស្រួលរកគ្នា ក្នុងហេតុនោះៗ ដែរឬ។

[២៦៩] (ព្រះរាជា...) ម្នាលស្តេចហង្សឈ្មោះធតរដ្ឋ យើងមានកូនមួយរយនាក់ ដែលអ្នកផងឮសុះសាយថា យើងជាអ្នក (មានកូនច្រើន) កូនទាំងនោះ រមែងមិនខឹងនឹងសំដីរបស់អ្នកទេ សូមអ្នកប្រាប់នូវអំពើដែលត្រូវធ្វើដល់កូនទាំងនោះចុះ។

[២៧០] (ស្តេចហង្ស...)បុគ្គលបើទុកជាបរិបូណ៌ដោយជាតិ និងច្បាប់ តែបើក្នុងកាលជាខាងក្រោយ គឺកាលដែលខ្លួនចាស់ ធ្វើនូវសេចក្តីព្យាយាមក្នុងកិច្ចការ រមែងលិចចុះក្នុងសេចក្តីអន្តរាយ។ កាលបុគ្គលចាស់នោះ មានប្រាជ្ញារវើរវាយ ទោសក៏កើតឡើងជាច្រើនយ៉ាង បុគ្គលចាស់នោះ រមែងឃើញបានតែត្រឹមរូបធំៗ ដូចបុគ្គលងងឹតក្នុងវេលាយប់។ បុគ្គលចាស់ ដឹងនូវសេចក្តីព្យាយាមក្នុងលទ្ធិមិនមានខ្លឹមថាលទ្ធិមានខ្លឹម រមែងមិនបាននូវប្រាជ្ញា តែងលិចចុះក្នុងសេចក្តីអន្តរាយមិនខាន ដូចជាសត្វសរភៈ លិចចុះក្នុងជ្រោះនៃភ្នំ។ ជនបើទុកជាមានជាតិថោកថយ តែជាអ្នកមានការប្រឹងប្រែង មានប្រាជ្ញា បរិបូណ៌ដោយអាចារសីល រមែងរុងរឿងដូចជាភ្លើងក្នុងរាត្រី។ សូមព្រះអង្គធ្វើសេចក្តីនេះឯង ឲ្យជាគ្រឿងប្រៀបធៀប ហើយញ៉ាំងពួកព្រះរាជបុត្ត ឲ្យប្រតិស្ឋានក្នុងវិជ្ជាទាំងឡាយ ដ្បិតអ្នកប្រាជ្ញតែងលូតលាស់ល្អ ដូចពូជដែលលូតលាស់ក្នុងស្រែក្នុងកាលដែលមានភ្លៀង។

ចប់ ហង្សជាតក ទី៦។

## សត្តិគុម្ពជាតក ទី៧

CS sut.kn.jat.503 | ភាគទី ៦០

### (៥០៣. សត្តិគុម្ពជាតកំ (៧))

[២៧១] (ព្រះមានព្រះភាគត្រាស់ថា) មហារាជដូចជាព្រានម្រឹគ ជាបុគ្គលប្រសើរលើរថរបស់អ្នកដែនបញ្ចាល បានយាងទៅជាមួយនឹងសេនា សាបសូន្យចាកពួកស្តេចចូលមកកាន់ព្រៃ។ បានឃើញស្រុករបស់ពួកចោរនៅក្នុងព្រៃនោះ សត្វសេកហើរចេញអំពីស្រុកនោះហើយ និយាយនូវសំដីដ៏អាក្រក់ថា ព្រះរាជាជាបុរសកំឡោះ បរិបូណ៌ដោយពាហនៈ មានកុណ្ឌលដ៏រលើង មានព្រះឧណ្ហីសៈ (ក្បាំង) ដ៏ក្រហមច្រាល ល្អរុងរឿងដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ។ ឥឡូវនេះ ព្រះរាជាព្រមទាំងនាយសារថីដេកលក់ក្នុងវេលាថ្ងៃត្រង់ បើដូច្នោះ យើងនឹងយកគ្រឿងប្រដាប់ទាំងពួងរបស់ព្រះរាជានោះដោយរហ័ស។ ឥឡូវនេះ ស្តេច ព្រមទាំងនាយសារថី ដេកលក់ក្នុងទីស្ងាត់ ដូចនៅកណ្តាលអធ្រាត្រ យើងនឹងយកសំពត់កែវមណី និងកុណ្ឌល ហើយសម្លាប់ រួចគ្របដោយមែកឈើ។

[២៧២] (បតិកោលុម្ពចោរពោលថា) ម្នាលសត្តិគុម្ពៈ ឯងនិយាយដូចជាឆ្កួតទេឬ ព្រោះថា ព្រះរាជាទាំងឡាយ យាងមកអំពីចម្ងាយ ទ្រង់រុងរឿងដូចជាភ្លើងកំពុងឆេះ។

[២៧៣] (សត្តិគុម្ពៈពោលថា) ម្នាលបតិកោលុម្ពៈ អ្នកឯងដូចជាបុគ្គលស្រវឹង ទើបកំញើញយើងយ៉ាងខ្លាំង អ្នកស្អប់ខ្ពើម (ចោរកម្ម) ព្រោះមាតារបស់ខ្ញុំអាក្រាតឬអ្វី។

[២៧៤] (ព្រះរាជាត្រាស់ថា) នែនាយសារថីសំឡាញ់ ចូរអ្នករលះរលាំងក្រោកឡើង ចូរទឹមរថទៅ យើងមិនពេញចិត្តនឹងបក្សីទេ យើងនឹងទៅកាន់អាស្រមដទៃវិញ។

[២៧៥] (នាយសារថីទូលថា) បពិត្រមហារាជ ទូលព្រះបង្គំបានទឹមរថ ទឹមពាហនៈដ៏មានកំឡាំងហើយ បពិត្រមហារាជ សូមព្រះអង្គឡើងគង់ចុះ យើងនឹងទៅកាន់អាស្រមដទៃ។

[២៧៦] (សត្តិគុម្ព...) ពួកចោរក្នុងអាស្រម ទៅក្នុងទីណាអស់ទៅអេះ ស្តេចក្នុងដែនបញ្ចាលនុ៎ះទៅផុតអំពីការមិនឃើញរបស់ពួកចោរទាំងនោះហើយ។ អ្នកទាំងឡាយចូរចាប់ធ្នូ ដាវ និងលំពែង ស្តេចក្នុងដែនបញ្ចាលនុ៎ះកំពុងតែទៅ អ្នកទាំងឡាយកុំលែងជីវិតឡើយ។

[២៧៧] (អភិសម្ពុទ្ធគាថា) ក្នុងកាលនោះ សត្វសេកដទៃទៀត មានចំពុះដ៏ក្រហម បានទទួលរាក់ទាក់ថា បពិត្រមហារាជ ព្រះអង្គស្តេចមកស្រួលហើយ មួយទៀត ដំណើរមករបស់ព្រះអង្គមិនទាស់ទេ ព្រះអង្គជាធំយាងមកដល់ហើយ សូមទ្រង់មានព្រះបន្ទូលប្រាប់នូវព្រះរាជបំណង ដែលមានក្នុងដំណើរយាងមកនេះចុះ។ បពិត្រព្រះរាជា សូមព្រះអង្គសោយនូវផ្លែទន្លាប់ ជាទីគាប់ចិត្តព្រះហឫទ័យ ផ្លែស្រគំ និងផ្លែដង្កៀបក្តាមតូចៗ ដ៏ប្រសើរប្រសើរចុះ។ បពិត្រមហារាជ ទឹកនេះសោតក៏ត្រជាក់ ដែលពួកឥសីនាំមកអំពីជ្រោះភ្នំ សូមព្រះអង្គសោយ (នូវទឹក) អំពីជ្រោះនោះចុះ បើព្រះអង្គប្រាថ្នា។ ពួកឥសីអ្នកនៅក្នុងអាស្រមនេះ ទៅកាន់ព្រៃដើម្បីស្វែងរក (អាហារ) ហើយ សូមព្រះអង្គក្រោកឡើង យកដោយព្រះអង្គឯងចុះ ខ្ញុំព្រះអង្គមិនមានដៃថ្វាយទេ។

[២៧៨] (ព្រះរាជា...) សត្វបក្សីទិជាតិនេះល្អ ប្រកបដោយធម៌ណាស់តើ ចំឡែកតែបក្សីសេកក្រៅពីនេះនុ៎ះ និយាយពាក្យអាក្រក់ថា អ្នកទាំងឡាយ ចូរសម្លាប់ ចូរចងនូវស្តេចនេះ អ្នកទាំងឡាយកុំលែងជីវិតឡើយ កាលសេកនោះកំពុងនិយាយយ៉ាងនេះ យើងក៏បានចេញមកដល់ទីអាស្រមនេះដោយសួស្តី។

[២៧៩] (សេកបុប្ផកៈ...) បពិត្រមហារាជ យើងខ្ញុំទាំងពីរជាបងប្អូនរួមផ្ទៃ មានមាតាជាមួយគ្នា ធំឡើងនៅលើដើមឈើតែមួយ តែឃ្លាតទៅក្នុងខេត្តផ្សេងគ្នា។ សត្តិគុម្ពៈទៅក្នុងសំណាក់នៃពួកចោរ ឯខ្ញុំព្រះអង្គមកនៅក្នុងសំណាក់នៃពួកឥសីក្នុងទីនេះ សត្តិគុម្ពៈ (ចូលទៅកាន់សំណាក់) នៃពួកអសប្បុរស ខ្ញុំព្រះអង្គ (ចូលមកកាន់សំណាក់) នៃពួកសប្បុរស (ហេតុនោះ) សត្តិគុម្ពៈនិងខ្ញុំ មិនវៀរចាកធម៌[27] នោះទេ។

[២៨០] ការសម្លាប់ក្តី ចងក្តី ការបន្លំក្តី បញ្ឆោតក្តី ការប្លន់ក្តី ការកំហែងក្តី មាននៅក្នុងសំណាក់ចោរណា សត្តិគុម្ពៈ រមែងសិក្សាអំពើទាំងនោះក្នុងសំណាក់ចោរនោះ។ សេចក្តីពិតក្តី សុចរិតក្តី ការមិនបៀតបៀនក្តី ការសង្រួមសីលក្តី ការទូន្មានឥន្ទ្រិយក្តី មាននៅក្នុងទីនេះ បពិត្រព្រះភារតៈ ខ្ញុំព្រះអង្គធំឡើងនៅលើចង្កេះនៃពួកឥសីអ្នកឲ្យអាសនៈនិងទឹក។

[២៨១] បពិត្រព្រះរាជា ពិតណាស់ បុគ្គលគប់រកនូវបុគ្គលណា ទោះជាសប្បុរស ឬអសប្បុរស មានសីល ឬឥតសីល រមែងលុះអំណាចបុគ្គលនោះឯង។ បុគ្គលធ្វើនូវបុគ្គលបែបណា ឲ្យជាមិត្រ ចូលទៅគប់រកនូវបុគ្គលបែបណា បុគ្គលនោះ ក៏មានអាការបែបនោះ ឯការនៅរួមក៏ប្រាកដដូច្នោះ។ កូនសិស្សគប់រកនូវអាចារ្យផ្តេសផ្តាស អាចារ្យនោះដែលកូនសិស្សគប់រកហើយ រមែងប្រឡាក់កូនសិស្សដែលមិនប្រឡាក់ (ដោយបាបធម៌) ដូចសរ ដែលជ្រលក់ដោយថ្នាំពិសតែងប្រឡាក់បំពង់សរ។ ព្រោះភ័យអំពីការប្រឡាក់ អ្នកប្រាជ្ញទើបមិនយកបុគ្គលលាមកជាសំឡាញ់ ជនណាខ្ចប់នូវត្រីស្អុយដោយចុងស្បូវភ្លាំង សូម្បីស្បូវភ្លាំងក៏មានក្លិនស្អុយ ផ្សាយចេញ ការគប់រកនូវបុគ្គលពាល (របស់ជននោះ) ក៏យ៉ាងនោះដែរ។ ជនណាខ្ចប់ខ្លឹមក្រស្នាដោយស្លឹកឈើ សូម្បីស្លឹកឈើក៏មានក្លិនក្រអូបផ្សាយចេញ ការគប់រកអ្នកប្រាជ្ញ (របស់ជននោះ) ក៏យ៉ាងនោះដែរ ព្រោះហេតុនោះ បុគ្គលជាអ្នកប្រាជ្ញ ដឹងច្បាស់នូវបញ្ញាចាស់ទុំរបស់ខ្លួន ដូចជាកញ្ចប់

ស្លឹកឈើ មិនគួរគប់រកពួកអសប្បុរស គួរគប់រកតែពួកសប្បុរស (ដ្បិត) ពួកអសប្បុរស តែងនាំទៅនរក ពួកសប្បុរសតែងផ្តល់នូវសុគតិ។

ចប់ សត្តិគុម្ពជាតក ទី៧។

## ភល្លាតិយជាតក ទី៨

CS sut.kn.jat.504 | ភាគទី ៦០

### (៥០៤. ភល្លាតិយជាតកំ (៨ ))

[២៨២] (ព្រះមានព្រះភាគត្រាស់ថា) ព្រះរាជាព្រះនាមភល្លាតិយៈ បានលះបង់នូវដែន ហើយត្រាច់ចេញទៅកាន់ទីសម្លាប់ម្រឹគ ព្រះអង្គបានយាងទៅដល់ភ្នំដ៏ប្រសើរឈ្មោះគន្ធមាទន៍ មានឈើផ្ការីកស្គុះស្គាយដ៏ដេរដាសដោយពួកកិន្នរ។ ព្រះអង្គប្រាថ្នាដើម្បីពោលពាក្យ (នឹងពួកកិន្នរ) ទើបហាមឃាត់ហ្វូងឆ្កែ ហើយដាក់ចុះនូវធ្នូ និងបំពង់ព្រួញ រួចចូលទៅត្រង់កន្លែងដែលពួកកិន្នរឋិតនៅ។ (ព្រះរាជាសួរថា) កាលកន្លងហេមន្តរដូវទៅហើយ ម្តេចឡើយអ្នកទាំងឡាយឋិតនៅក្នុងទីនេះ ប្រឹក្សាគ្នារឿយៗ ប្របឆ្នេរស្ទឹងហេមវតី យើងសូមសួរពួកអ្នកដែលមានរាងកាយ និងសម្បុរដូចជាមនុស្ស គេស្គាល់អ្នកទាំងឡាយបានក្នុងមនុស្សលោកដោយប្រការដូចម្តេច។

[២៨៣] (កិន្នរីឆ្លើយថា) ម្នាលព្រាន ពួកយើងតែងត្រាច់ទៅកាន់ភ្នំ ឈ្មោះមាលាគិរិ ភ្នំឈ្មោះបណ្ឌរកៈ ភ្នំត្រៃកូដ និងស្ទឹងមានទឹកដ៏ត្រជាក់ ពួកយើងជាម្រឹគមានភេទប្រាកដដូចជាពួកមនុស្ស គេស្គាល់ពួកយើងថាជាកិន្នរ។

[២៨៤] (ព្រះរាជា...) អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ ឱបរិតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយ និងសម្បុរដូចមនុស្ស អ្នកទាំងឡាយ អាក់អន់ចិត្តដូចម្តេច ទើបទួញយំក្នុងព្រៃនេះ អ្នកទាំងពីរមានសភាពដូចជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱបរិតហើយ យើងសូមសួរនូវពួកអ្នកដែលមានរាងកាយ និងសម្បុរដូចជាមនុស្ស អ្នកទាំងឡាយ អាក់អន់ចិត្តដូចម្តេច ទើបយំរៀបរាប់ក្នុងព្រៃនេះ។ អ្នកទាំងពីរ មានសភាពដូចជាទុក្ខក្រៃលែង ទួញយំ អ្នកគួរជាទីស្រឡាញ់ ត្រូវនាងកិន្នរីជាទីស្រឡាញ់ឱបរិតហើយ យើងសូមសួរនូវពួកអ្នក ដែលមានរាងកាយនិងសម្បុរដូចជាមនុស្ស អ្នកអាក់អន់ចិត្តដូចម្តេច ទើបសោកស្តាយក្នុងព្រៃនេះ។

[២៨៥] (កិន្នរី...) ម្នាលព្រាន យើងទាំងឡាយ ជាអ្នកព្រាត់ប្រាស់គ្នា អស់មួយរាត្រី រលឹកគ្នាទៅវិញទៅមក មិនដាច់អាល័យ ក្តៅក្រហាយនឹងរាត្រីមួយនោះ ទើបយំសោក រាត្រីនោះនឹងមិនមានទៀត។

[២៨៦] (ព្រះរាជា...) អ្នកទាំងឡាយក្តៅក្រហាយនឹងរាត្រីមួយណា ដូចបុគ្គលក្តៅក្រហាយនឹងទ្រព្យដែលបាត់ និងមាតាបិតា ដែលទៅកាន់បរលោក យើងសូមសួរនូវពួកអ្នកដែលមានរាងកាយ និងសម្បុរដូចមនុស្ស ចំពោះរាត្រី (នោះ) តើអ្នកទាំងឡាយសម្រេចនូវទីនៅផ្សេងគ្នាដូចម្តេច។

[២៨៧] (កិន្នរី...) អ្នកឃើញនូវស្ទឹងណា ដែលមានខ្សែទឹកដ៏រហ័ស ជាស្ទឹងបិទបាំងដោយដើមឈើផ្សេងៗ មានមាត់ច្រាំងដ៏ហើយដោយថ្ម កិន្នរ (ជាប្តី) ជាទីស្រឡាញ់របស់ខ្ញុំ បានហែលឆ្លងស្ទឹងនោះ ក្នុងកាលរដូវភ្លៀង ដោយគិតថា កិន្នរីមកតាមក្រោយអាត្មាអញដែរ។ ចំណែកខាងខ្ញុំ កំពុងតែបេះផ្កាព្រុស ផ្កាទន្លា ផ្កាម្លិះរួត និងផ្កាយុថ្កា ដោយបំណងថា កិន្នរ (ជាប្តី) ជាទីស្រឡាញ់របស់អាត្មាអញនឹងបានប្រដាប់កម្រងផ្កា ទាំងអាត្មាអញជាអ្នកប្រដាប់កម្រងផ្កា នឹងបានចូលទៅរកកិន្នរ (ជាប្តី) នោះ (ក្នុងដំណេក)។ មួយទៀត ខ្ញុំបេះផ្កាកុរវកៈ ទាំងផ្ការាជព្រឹក្ស និងផ្កាច្រនៀងក៏ខ្ញុំបេះ ដោយបំណងថា កិន្នរ (ជាប្តី) ជាទីស្រឡាញ់របស់អាត្មាអញ នឹងជាអ្នកប្រដាប់កម្រងផ្កា ទាំងអាត្មាអញ ក៏ជាអ្នកប្រដាប់កម្រងផ្កា នឹងចូលទៅរកកិន្នរ (ជាប្តី) នោះ (ក្នុងដំណេក)។ មួយទៀត ខ្ញុំបានបេះនូវផ្កាសាលព្រឹក្ស ដែលរីកស្គុះស្គាយ ធ្វើជាគ្រឿងប្រដាប់ដោយបំណងថា ថ្ងៃនេះយើងនឹងនៅក្នុងទីណា អស់រាត្រីមួយ គ្រឿងប្រដាប់នេះ នឹងបានជាកម្រាលរបស់យើងក្នុងទីនោះ។ មួយទៀត ខ្ញុំមានសភាពជាអ្នកធ្វេសប្រហែស កិនខ្លឹមក្រស្នា និងខ្លឹមចន្ទន៍លើថ្ម ដោយបំណងថា កិន្នរជាប្តីជាទីស្រឡាញ់របស់អាត្មាអញ នឹងបានលាបខ្លួនប្រាណ ទាំងខ្លួនអញ ក៏បានលាបស្រឡាប ហើយនឹងចូលទៅរកកិន្នរជាប្តីនោះក្នុងដំណេក។ លំដាប់នោះ ទឹកស្ទឹងមានខ្សែដ៏រហ័ស ហូរគួចយកផ្កាសាលព្រឹក្ស ផ្កាស្រល់ និងផ្កាកណ្ណិការ (ដែលខ្ញុំបេះទុក ក្នុងទីទៀបមាត់ច្រាំង) មានទឹកដ៏ពេញដោយមួយរំពេច ទាំងស្ទឹងនោះ ខ្ញុំក៏ឆ្លងបានដោយកម្រក្រៃលែង។ គ្រានោះ យើងទាំងពីរនាក់ក៏ឈរប្របឆ្នេរស្ទឹងម្ខាងម្នាក់ មើលឃើញគ្នាទៅវិញទៅមក ម្តងយំ ម្តងសើច រាត្រីនោះ របស់យើងក៏កន្លងទៅដោយក្រ។ ម្នាលព្រាន កាលបើព្រះអាទិត្យរះឡើងក្នុងវេលាព្រឹក យើងទាំងពីរនាក់ក៏ឆ្លងស្ទឹងទទេ (ស្ទឹងមិនមានទឹក) ហើយ ឱបរឹតគ្នាទៅវិញទៅមក ម្តងយំ ម្តងសើច។ ម្នាលព្រាន កាលមុន យើងបានព្រាត់ប្រាសគ្នាអស់មួយរាត្រី កន្លងមកចំនួន ៧០០ ខ្វះ ៣ ឆ្នាំ (៦៩៧ឆ្នាំ) ម្នាលភូមិបាល ជីវិត (របស់អ្នក) នេះ ត្រឹមតែមួយរយឆ្នាំ អ្នកណាហ្ន៎ ក្នុងលោកនេះ នៅផ្សេងគ្នាអំពីភរិយាជាទីត្រេកអរបាន។

[២៨៨] (ព្រះរាជា...) នែសំឡាញ់ ចុះអាយុរបស់អ្នកទាំងឡាយ ចំនួនប៉ុន្មាន បើអ្នកដឹង ចូរអ្នកប្រាប់អាយុ (ដល់យើង) ទោះបីអ្នកបានឮ (អំពីអ្នកណាមួយ) ក្តី ចាំតមកអំពីពួកជនចាស់ទុំក្តី សូមអ្នកកុំញញើតប្រាប់សេចក្តីនោះដល់យើង។

[២៨៩] (កិន្នរី...) ម្នាលព្រាន អាយុរបស់យើងមួយពាន់ឆ្នាំ បើមិនមានរោគដ៏អាក្រក់ ក្នុងចន្លោះអាយុទេ ឯសេចក្តីទុក្ខមានប្រមាណតិច សេចក្តីសុខហ្នឹងឯង មានច្រើនក្រៃលែង ពួកយើងមិនប្រាសចាកសេចក្តីត្រេកអរ (ស្រឡាញ់គ្នា) ទាល់តែលះជីវិតទៅ។

[២៩០] (អភិសម្ពុទ្ធគាថា) ព្រះរាជាព្រះនាមភល្លាតិយៈ លុះទ្រង់ព្រះសណ្តាប់ពាក្យរបស់ពួកកិន្នរនេះហើយ ក៏វិលត្រឡប់មក (ព្រះរាជនិវេសន៍) ដោយរំពឹងឃើញថា ជីវិតនេះ មានប្រមាណតិចណាស់ រួចឈប់ត្រាច់ទៅកាន់ទីជាទីសម្លាប់ម្រឹគទៀត ទ្រង់បានបរិច្ចាគទាន ទ្រង់បានប្រើប្រាស់នូវភោគសម្បត្តិ (តាមធម្មតា)។

[២៩១] (ព្រះសាស្តាទ្រង់ឲ្យឱវាទថា) សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនេះហើយ ចូររួសរាយ កុំធ្វើនូវជម្លោះឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកំដៅនូវព្រះអង្គ ដូចជារាត្រីមួយរបស់ពួកកិន្នរ ដុតកំដៅនូវកិន្នរទាំងនោះ សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ពួកកិន្នរនេះហើយ ចូររួសរាយ កុំធ្វើនូវការវិវាទឡើយ កំហុសនៃអំពើរបស់ខ្លួន កុំដុតកំដៅនូវព្រះអង្គ ដូចជារាត្រីមួយរបស់ពួកកិន្នរ ដុតកំដៅនូវកិន្នរទាំងនោះ។

[២៩២] (ព្រះនាងមល្លិកាទេវីទូលថា) ខ្ញុំម្ចាស់មានចិត្តត្រេកអរស្តាប់ធម្មទេសនាមានហេតុផ្សេងៗ គន្លងនៃព្រះបន្ទូលរបស់ព្រះអង្គប្រកបដោយប្រយោជន៍ ព្រះអង្គបញ្ចេញវាចាបន្ទោបង់សេចក្តីក្រវល់ក្រវាយរបស់ខ្ញុំម្ចាស់ បពិត្រព្រះសមណៈ ព្រះអង្គអ្នកនាំសេចក្តីសុខមកឲ្យ សូមព្រះអង្គគង់ព្រះជន្មនៅអស់កាលយូរ។

ចប់ ភល្លាតិយជាតក ទី៨។

## (៥០៥. សោមនស្សជាតកំ (៩))

[២៩៣] (ព្រះបាទរេណុត្រាស់សួរថា) នរណាប្រហារលោក ជេរលោក ម្ដេចក៏លោកអាក់អន់ចិត្ត មិនត្រេកអរ សោកសង្រេងម្ល៉េះ ថ្ងៃនេះ ចង់មាតាបិតារបស់នរណាទ្រូញយំ ថ្ងៃនេះ ចង់នរណាត្រូវគេបៀតបៀនដេកលើផែនដី (ក៏លោកមិនត្រូវជាអុកជាទុក្ខទេ)។

[២៩៤] (កុហកតាបស ឆ្លើយថា) បពិត្រព្រះសម្មតិទេព អាត្មាភាពត្រេកអរ ដោយការបានឃើញនូវព្រះអង្គ បពិត្រព្រះភូមិបាល អាត្មាភាព ឃើញព្រះអង្គយូរហើយ បពិត្រព្រះសម្មតិទេពព្រះនាមរេណុ អាត្មាភាព មិនមែនជាអ្នកបៀតបៀនទេ ប៉ុន្តែអាត្មាភាព ត្រូវព្រះរាជបុត្ររបស់ព្រះអង្គចូលមកបៀតបៀនហើយ។

[២៩៥] (ព្រះរាជា...) ពួកអ្នកចាំទ្វារ មានព្រះខ័នកាន់ហើយ ពួកពេជ្ឈឃាដចូរមក ចូរទៅខាងក្នុងបុរី ចូរសម្លាប់សោមនស្សកុមារនោះ កាត់ក្បាលដ៏ប្រសើរ នាំមកឲ្យអញ។ ពួករាជទូត ដែលព្រះរាជាទ្រង់បញ្ជូនទៅហើយ បាននិយាយនឹងព្រះរាជកុមារ យ៉ាងនេះថា បពិត្រក្សត្រ ព្រះអង្គទ្រង់ឆ្លងផុតចាកឥស្សរភាពហើយ ព្រះអង្គដល់នូវសេចក្ដីស្លាប់ហើយ។ ព្រះរាជបុត្រនោះ ក៏ទ្រង់បរិទេវនាការ ផ្គងក្រពុំម្រាមព្រះហស្តទាំង ១០ ថា បពិត្រព្រះអង្គជាធំជាងជន ចំណែកទូលព្រះបង្គំជាខ្ញុំចង់ឃើញព្រះអង្គ អ្នកទាំងឡាយចូរនាំយើងទាំងរស់ទៅក្រាបបង្គំថ្វាយ (ដល់ព្រះមហាក្សត្រ) ចុះ។

ពួករាជទូតបានស្ដាប់វាចារបស់ព្រះរាជបុត្រនោះហើយ ក៏នាំព្រះរាជបុត្រទៅថ្វាយព្រះរាជា ចំណែកខាងព្រះរាជបុត្រ លុះបានឃើញព្រះរាជបិតាហើយ ក៏ក្រាបបង្គំទូលអំពីចម្ងាយថា បពិត្រព្រះជនិន្ទ ពួកអ្នកចាំទ្វារ មានព្រះខ័នកាន់ហើយ ពួកពេជ្ឈឃាដមក ដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ ថ្ងៃនេះទូលព្រះបង្គំជាខ្ញុំ មានកំហុសដូចម្ដេចក្នុងរឿងនេះ ទូលព្រះបង្គំសួរហើយ សូមទ្រង់ប្រាប់សេចក្ដីនុ៎ះ។

[២៩៦] (ព្រះរាជា...) ទិព្វចក្ខុតាបស ជាអ្នកមិនធ្វេសប្រហែស ធ្វើការស្រោចទឹកបូជាភ្លើង រាល់ពេលល្ងាចព្រឹក ព្រោះហេតុអ្វីបានជាឯងហៅទិព្វចក្ខុតាបសនោះ ដែលជាអ្នកមានសេចក្ដីសង្រួម ជាអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ មានសភាពដូច្នោះ ថាជាគហបតី។

[២៩៧] (សោមនស្សកុមារ...) បពិត្រព្រះសម្មតិទេព វត្ថុទាំងឡាយនៃកុលុបកៈនោះ មានច្រើនយ៉ាងណាស់ គឺផ្លែត្នោតផង ត្រាវនិងដំឡូងផង ផ្លែឈើវល្លិ៍ទាំងឡាយផង កុលុបកតាបស របស់ព្រះអង្គនោះ ជាអ្នកមិនមានសេចក្ដីធ្វេសប្រហែស តែងគ្រប់គ្រងរក្សានូវវត្ថុទាំងនោះ ព្រោះហេតុនោះ បានជាទូលព្រះបង្គំជាខ្ញុំហៅតាបសនោះថា គហបតី។

[២៩៨] (ព្រះរាជា...) ម្នាលកុមារ អ្នកនិយាយពាក្យនេះពិតមែន របស់ទាំងឡាយនៃកុលុបកតាបសនោះ មានច្រើនយ៉ាង កុលុបកតាបសនោះ ជាអ្នកមិនធ្វេសប្រហែស តែងគ្រប់គ្រងរក្សានូវរបស់ទាំងនោះ ព្រោះហេតុនោះ ព្រាហ្មណ៍ក្លាយជាគហបតី។

[២៩៩] (សោមនស្សកុមារ...) បរិស័ទ ព្រមទាំងអ្នកនិគម អ្នកជនបទ ដែលបានមកជួបជុំទាំងអស់គ្នា ចូរស្ដាប់ពាក្យរបស់ខ្ញុំ ព្រះរាជានេះ ជាបុគ្គលពាល ស្ដាប់តែពាក្យតាបសពាល ប្រើគេឲ្យសម្លាប់ខ្ញុំ ដោយការមិនសមហេតុ។

[៣០០] នាកាលឫសគល់ចំរើនមាំធំឡើង ឫស្សីដែលបែកមែកហើយ បុគ្គលមិនងាយនឹងគាស់ចេញទេ បពិត្រព្រះជនិន្ទ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះបាទាព្រះអង្គ បពិត្រព្រះសម្មតិទេព សូមព្រះអង្គទ្រង់អនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំសូមចេញបួស។

[៣០១] (ព្រះរាជា...) ម្នាលកុមារ អ្នកចូរបរិភោគនូវភោគៈទាំងឡាយដ៏ច្រើនចុះ បិតានឹងប្រគល់ឥស្សរិយយសទាំងអស់ដល់អ្នក អ្នកចូរសោយរាជ្យ ជាស្ដេចរបស់អ្នកកុរុ ក្នុងថ្ងៃនេះឯង អ្នកកុំបួសឡើយ ដ្បិតថា បព្វជ្ជាជាកិច្ចលំបាកណាស់។

[៣០២] (សោមនស្សកុមារ...) បពិត្រព្រះសម្មតិទេព ភោគសម្ប័ទរបស់ព្រះអង្គ រាប់ថាមានដូចម្ដេចកើត ក្នុងមនុស្សលោកនេះ ក្នុងកាលមុន ទូលព្រះបង្គំជាខ្ញុំ ធ្លាប់បានត្រេកអរដោយរូប សំឡេង រស ក្លិន ផ្សព្វ ជាទីសំរើបចិត្ត ក្នុងទេវលោកមកហើយ។ បពិត្រព្រះសម្មតិទេព ឯភោគសម្ប័ទទាំងឡាយ ទូលព្រះបង្គំជាខ្ញុំធ្លាប់បរិភោគហើយ ក្នុងទេវលោកឈ្មោះតាវត្តិង្ស ទូលព្រះបង្គំជាខ្ញុំ ជាបុគ្គលធ្លាប់មានពួកស្រីអប្សរចោមរោមហើយ ឯទូលព្រះបង្គំជាខ្ញុំស្គាល់ព្រះអង្គថា ជាមនុស្សពាល ដែលត្រូវតែគេដឹកនាំបាន (ទូន្មាន) ទូលព្រះបង្គំជាខ្ញុំមិនត្រូវនៅក្នុងរាជត្រកូលបែបព្រះអង្គទេ។

[៣០៣] (ព្រះរាជា...) នែកូន បើបិតាជាមនុស្សពាល ដែលត្រូវតែគេដឹកនាំ ក៏សូមអ្នកអត់ទោសកំហុសម្ដងដល់យើងចុះ ម្នាលសោមនស្ស បើទោសយ៉ាងនេះនឹងមានម្ដងទៀត ចូរអ្នកធ្វើតាមមតិចុះ។

[៣០៤] (សោមនស្សកុមារ...) ការងារដែលបុគ្គលមិនបានពិចារណាហើយធ្វើ គំនិតដែលបុគ្គលមិនកំណត់ហើយគិត រមែងមានផលអាក្រក់ ដូចជាការផ្សំថ្នាំខុសដូច្នោះ។ ឯការងារដែលបុគ្គលពិចារណាហើយទើបធ្វើ គំនិតដែលបុគ្គលកំណត់ត្រឹមត្រូវហើយទើបគិត រមែងមានផលដ៏ចំរើន ដូចជាការផ្សំថ្នាំត្រូវដូច្នោះឯង។ គ្រហស្ថអ្នកបរិភោគកាម ខ្ជិល មិនល្អ អ្នកបួសមិនសង្រួម មិនល្អ ព្រះរាជា អ្នកមិនពិចារណាហើយធ្វើ មិនល្អ បណ្ឌិតដែលមានសេចក្ដីក្រោធ ការក្រោធនោះ ក៏មិនល្អឡើយ។ បពិត្រព្រះអង្គជាធំក្នុងទិស ក្សត្រត្រូវពិចារណាហើយសឹមធ្វើ មិនត្រូវធ្វើទាំងមិនពិចារណាទេ បពិត្រព្រះរាជា ដ្បិតថាយស និងសេចក្ដីសរសើរ រមែងចំរើនដល់បុគ្គលអ្នកពិចារណាហើយទើបធ្វើ។ បពិត្រព្រះភូមិបាល បុគ្គលជាធំ ត្រូវតែពិចារណាហើយសឹមដាក់អាជ្ញា ការដែលបុគ្គលធ្វើដោយរួសរាន់ រមែងក្ដៅក្រហាយ ម្យ៉ាងទៀត ប្រយោជន៍ទាំងឡាយដែលនរជនផ្ដឹងឡើងត្រឹមត្រូវនោះ រមែងជាប្រយោជន៍ មិនក្ដៅក្រហាយខាងក្រោយ។ ជនទាំងឡាយ បែងចែកហើយទើបធ្វើការងារទាំងឡាយ ដែលមិនមានសេចក្ដីក្ដៅក្រហាយក្នុងលោក ការងារទាំងនោះ ជាអំពើដែលអ្នកប្រាជ្ញសរសើរហើយថា មានសេចក្ដីសុខជាកំរៃ ជាអំពើដែលអ្នកប្រាជ្ញចុះអនុមតិហើយ។ បពិត្រព្រះអង្គ ជាធំជាងជន ពួកឆ្មាំទ្វារ មានព្រះខាន់កាន់ហើយ ពួកពេជ្ឈឃាត មកដើម្បីសម្លាប់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ អង្គុយលើព្រះឧរូនៃមាតា ត្រូវពួកទូតទាំងនោះ ទង់ទាញមកដោយរហ័ស ទូលព្រះបង្គំជាខ្ញុំ បានដល់នូវមរណភ័យ ក៏ក្ដៅក្រហាយយ៉ាងចង្អៀត លំបាកក្រៃពេក បពិត្រព្រះរាជា ជីវិតដែលជាទីស្រឡាញ់ដូចមធុរស ទូលព្រះបង្គំជាខ្ញុំបានហើយ ថ្ងៃនេះទូលព្រះបង្គំជាខ្ញុំ បានរួចចាកការសម្លាប់ដោយលំបាក ទូលព្រះបង្គំជាខ្ញុំ មានចិត្តឱនឆ្ពោះទៅក្នុងបព្វជ្ជាតែម្យ៉ាង។

[៣០៥] (ព្រះរាជា...) ម្នាលសុធម្មាទេវី សោមនស្សកុមារជាបុត្ររបស់នាងនេះ នៅក្មេង ជាអ្នកអនុគ្រោះ ថ្ងៃនេះខ្ញុំអង្វរករកុមារនោះពុំបានសោះ ក្រែងតែនាងទើបអង្វរករនូវកុមារនោះបាន។

[៣០៦] (សុធម្មាទេវី...) ហៃបា ចូរអ្នកត្រេកអរក្នុងភិក្ខាចរិយវត្តចុះ ចូរអ្នកពិចារណាធម៌ទាំងឡាយហើយបួសចុះ អ្នកចូរទំលាក់ចោលនូវ

អាជ្ញាក្នុងពួកសត្វទាំងអស់ចេញ មិនមានអ្នកណានិន្ទាបាន ហើយចូរទៅកាន់ឋានព្រហ្មលោកចុះ។

(ព្រះរាជា...) ម្នាលនាងសុធម្មា នាងនិយាយពាក្យណា (ពាក្យនោះ) ជាអស្ចារ្យក្រៃពេក នាងឈ្មោះថាញុំាងខ្ញុំដែលដល់នូវសេចក្តីទុក្ខ ឲ្យរឹតតែបានទុក្ខឡើង កាលខ្ញុំនិយាយថា ចូរនាងអង្វរករបុត្រ នាងបែរជាញុំាងកុមារឲ្យប្រឹងប្រែងវិញ។

[៣០៧] (សុធម្មាទេវី...) ព្រះអរិយៈទាំងឡាយណា រួចស្រឡះហើយ (ចាកពាគាទិក្កិលេស) ជាអ្នកបរិភោគនូវភោជនមិនមានទោស រំលត់ហើយ តែងត្រាច់ទៅកាន់លោកនេះ ខ្ញុំម្ចាស់មិនអាចហាមឃាត់ព្រះរាជកុមារ ដែលកំពុងដើរទៅកាន់ផ្លូវរបស់ព្រះអរិយៈនោះបានទេ។

[៣០៨] (ព្រះរាជា...) ជនទាំងឡាយណា ប្រកបដោយប្រាជ្ញា ជាពហុស្សុត ជាអ្នកគិតនូវហេតុច្រើនប្រការ នាងសុធម្មាទេវីនេះ ជាស្ត្រីមានសេចក្តីខ្វល់ខ្វាយតិច ប្រាសចាកសេចក្តីសោក ព្រោះបានស្តាប់ពាក្យសុភាសិតទាំងឡាយនៃពួកជនណា ជនទាំងនោះ គួរអ្នកផងគប់រកដោយពិត។

ចប់ សោមនស្សជាតក ទី៩។

## ចម្បេយ្យជាតក ទី១០

CS sut.kn.jat.506 | ភាគទី ៦០

(៥០៦. ចម្បេយ្យជាតកំ (១០))

[៣០៩] (ព្រះបាទពារាណសីត្រាស់សួរថា) នាងជាអ្វី មានពន្លឺដូចជាផ្លេកបន្ទោរ ឬដូចជាផ្កាយព្រឹក នាងជាស្ត្រីទេវតា ឬជាស្ត្រីគន្ធព្វ យើងមិនសំគាល់នាងថាជាស្ត្រីមនុស្សទេ។

[៣១០] (នាងនាគីក្រាបបង្គំទូលថា) បពិត្រមហារាជ ខ្ញុំម្ចាស់មិនមែនជាស្ត្រីទេវតា មិនមែនជាស្ត្រីគន្ធព្វ មិនមែនជាស្ត្រីមនុស្ស បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំម្ចាស់ជានាគកញ្ញា មកក្នុងទីនេះដោយសេចក្តីត្រូវការ។

[៣១១] (ព្រះរាជា...) នាងមានចិត្តតក់ស្លុត មានឥន្ទ្រិយញ័ររន្ធត់ តំណក់ទឹកភ្នែកទាំងឡាយ ហូរសស្រាក់ចាកភ្នែកទាំងឡាយរបស់នាង ចុះវត្ថុអ្វីរបស់នាងបាត់ ម្នាលនារី នាងចង់បានរបស់អ្វី បានជាមកក្នុងទីនេះ ចូរនាងប្រាប់ហេតុនោះមកចុះ។

[៣១២] (នាងនាគី...) បពិត្រព្រះអង្គជាធំជាងជន ពួកជនបានហៅសត្វណា ថាឧរគៈ មានតេជៈដ៏ខ្ពង់ខ្ពស់ តែងហៅសត្វនោះថានាគ បុរសអ្នកត្រូវការចិញ្ចឹមជីវិត បានចាប់នាគនោះមកហើយ សូមព្រះអង្គលែងនាគនោះពីចំណងទៅ នាគនោះជាប្តីរបស់ខ្ញុំម្ចាស់។

[៣១៣] (ព្រះរាជា...) នាគរាជនេះ បរិបូណ៌ដោយកម្លាំង និងព្យាយាម ហេតុដូចម្តេច ក៏ស្តេចមកលុះក្នុងកណ្តាប់ដៃនៃមនុស្សកំសត់ទៅវិញ ម្នាលនាគកញ្ញា ចូរនាងប្រាប់ហេតុនោះដល់យើង ធ្វើម្តេចទើបយើងស្គាល់នាគដែលគេចាប់មក (នោះ) បាន។

[៣១៤] (នាងនាគី...) ពិតដូច្នោះមែន នាគរាជនោះបរិបូណ៌ដោយកំឡាំង និងព្យាយាម អាចធ្វើសូម្បីនូវនគរឲ្យជាផេះបាន ប៉ុន្តែនាគរាជនោះគោរពធម៌ ព្រោះហេតុនោះ ទើបខំតែធ្វើតបធម៌។

[៣១៥] បពិត្រព្រះរាជា នាគរាជជាអ្នករក្សាចាតុទ្ទសីឧបោសថ និងបណ្ណរសីឧបោសថ នៅជិតផ្លូវត្រឡែងកែង បុរសអ្នកត្រូវការចិញ្ចឹមជីវិត បានចាប់នាគរាជនោះមកហើយ សូមព្រះអង្គលែងនាគរាជនោះពីចំណង នាគរាជនុ៎ះជាប្តីរបស់ខ្ញុំម្ចាស់។

[៣១៦] នាងនាគជាស្រីស្នំរបស់នាគរាជ ដប់ប្រាំមួយពាន់ ពាក់កុណ្ឌលជាវិការៈនៃកែវមណី មានផ្ទះជាទីដេកក្នុងទឹក នាងនាគទាំងនោះឯង ក៏ដល់នូវនាគរាជនោះជាទីពឹង។ សូមព្រះអង្គលែង (នាគរាជនោះ) ដោយនូវគន្លងធម៌ ដោយអំពើមិនអាក្រក់ គឺដោយស្រុកសួយ ដោយមាសឆ្តោរ ដោយគោមួយរយ ចូរឲ្យនាគមានកាយរួចស្រឡះហើយ ត្រាច់ទៅចុះ (នាគ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ។

[៣១៧] (ព្រះរាជា...) យើងដោះលែង (នាគរាជ) ដោយនូវគន្លងធម៌ដោយអំពើមិនអាក្រក់ គឺដោយស្រុកសួយ ដោយមាសឆ្តោរ ដោយគោមួយរយ ចូរឲ្យនាគមានកាយរួចស្រឡះ ហើយត្រាច់ទៅចុះ (នាគ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ។ ម្នាលព្រាន យើងឲ្យមាសឆ្តោរមួយរយផង កុណ្ឌលជាវិការៈនៃកែវមណីដ៏ច្រើនផង បល្ល័ង្កមានជ្រុង ៤ មានពណ៌ដូចផ្កាត្រកៀតផង ភរិយាស្មើគ្នា (ដោយវ័យជាដើម) នេះពីរនាក់ផង គោឧសភមួយរយផង នាគមានកាយរួចស្រឡះហើយ ចូរត្រាច់ទៅចុះ (នាគ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ។

[៣១៨] (អាលម្ពាយ...) បពិត្រព្រះអង្គជាធំជាងជន ព្រះរាជឱង្ការរបស់ព្រះអង្គវៀរចាកព្រះរាជអំណោយក៏បាន ទូលព្រះបង្គំសូមលែងនាគនោះអំពីចំណង នាគមានកាយរួចស្រឡះហើយ ចូរត្រាច់ទៅចុះ (នាគ) អ្នកត្រូវការដោយបុណ្យ ចូររួចពីចំណងចុះ។

[៣១៩] (អភិសម្ពុទ្ធគាថា) ចម្បេយ្យកនាគ បានរួចហើយ ក្រាបបង្គំទូលព្រះរាជាថា បពិត្រព្រះរាជាក្នុងដែនកាសី សូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គ អ្នកញុំាងដែនកាសីឲ្យចំរើន សូមថ្វាយបង្គំព្រះអង្គ ទូលព្រះបង្គំជាខ្ញុំ សូមផ្គងក្រពុំប្រម៉ាមដៃចំពោះព្រះអង្គ ទូលព្រះបង្គំជាខ្ញុំចង់បង្ហាញនូវលំនៅរបស់ទូលព្រះបង្គំជាខ្ញុំ (ដល់ព្រះអង្គ)។

[៣២០] (ព្រះរាជា...) មនុស្សស្និទ្ធស្នាលនឹងពួកអមនុស្ស ដោយហេតុណា អ្នកប្រាជ្ញទាំងឡាយ ពោលនូវហេតុនុ៎ះថា ជាសេចក្តីស្និទ្ធស្នាលអាក្រក់ដោយពិត ប៉ុន្តែបើអ្នកអង្វររឿងនុ៎ះនឹងយើង ម្នាលនាគ យើងនឹងទៅមើលលំនៅរបស់អ្នក។

[៣២១] (នាគរាជ...) បើទុកជាខ្យល់គួចយកភ្នំទៅបាន ព្រះចន្ទ្រ និងព្រះអាទិត្យជ្រុះចុះមកលើផែនដី ទោះស្ទឹងទាំងពួងហូរច្រាសបាន បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំ ក៏មិនពោលពាក្យកុហកទេ។ ផ្ទៃអាកាសបែកធ្លាយក្តី សមុទ្ររីងស្ងួតក្តី ផែនដីជាទីទ្រសត្វទ្រទ្រព្យ គប្បីខ្ទេរទាំងភ្នំមេរុសណ្តកឡើង ព្រមទាំងឫសក្តី បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំ មិនពោលពាក្យកុហកទេ។

[៣២២] (ព្រះរាជា...) មនុស្សស្និទ្ធស្នាលនឹងពួកអមនុស្ស ដោយហេតុណា អ្នកប្រាជ្ញទាំងឡាយ ពោលនូវហេតុនុ៎ះថា ជាសេចក្តីស្និទ្ធស្នាលអាក្រក់ដោយពិត ប៉ុន្តែបើអ្នកអង្វររឿងនុ៎ះនឹងយើង ម្នាលនាគ យើងនឹងទៅមើលលំនៅរបស់អ្នកដែរ។

[៣២៣] ពួកអ្នកសោត ក៏ជាសត្វមានពិសខ្លាំងក្លាពន្លឹកណាស់ មានតេជៈច្រើនឆាប់ខឹង អ្នករួចអំពីចំណងបាន ព្រោះហេតុនៃយើង

អ្នកគួរដឹងនូវឧបការគុណ ដែលយើងបានធ្វើហើយ។

[៣២៤] (នាគរាជ...) បុគ្គលណាមិនស្គាល់នូវបុគ្គលមានកុសលកម្មធ្វើហើយ (ធ្វើបុណ្យ) ប្រាកដដូចព្រះអង្គ បុគ្គលនោះចូរឆេះក្នុងនរក មានសភាពគួរស្បើម កុំឲ្យបានសេចក្ដីសុខប្រព្រឹត្តទៅក្នុងកាយបន្តិចបន្តួចសោះ ចូរជាប់នៅក្នុងទ្រុង ដល់នូវសេចក្ដីស្លាប់ចុះ។

[៣២៥] (ព្រះរាជា...) ពាក្យប្ដេជ្ញារបស់អ្នកនុ៎ះ ជាពាក្យសត្យ អ្នកចូរកុំមានសេចក្ដីក្រោធ អ្នកចូរកុំចងសេចក្ដីក្រោធទុក ពួកគ្រុឌក៏ចូរវៀរលែងត្រកូលនាគទាំងអស់របស់អ្នក ដូចពួកមនុស្សវៀរចាកគំនរភ្លើងក្នុងគិម្ហសម័យដូច្នោះចុះ។

[៣២៦] (នាគរាជ...) បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គអនុគ្រោះនូវត្រកូលនាគ ដូចជាមាតាអនុគ្រោះកូនប្រុសតែម្នាក់ដែលជាទីស្រឡាញ់ស្មោះ ចំណែកខាងទូលព្រះបង្គំជាខ្ញុំ ព្រមទាំងត្រកូលនាគ នឹងធ្វើនូវការខ្វល់ខ្វាយបំរើ ចំពោះព្រះអង្គដ៏លើសលុប។

[៣២៧] (ព្រះរាជា...) នែវីយ ពួកភ្នាក់ងារគ្រប់តំណែង ចូរទឹមរាជរថដ៏វិចិត្រដោយប្រពៃ ចូរទឹមអស្សតរដែលកើតក្នុងដែនកម្ពុជៈ ជាពាហនៈទូន្មានបានបទល្អហើយ ចូររៀបដំរី ប្រដាប់ដោយគ្រឿងមាស យើងនឹងទៅមើលលំនៅរបស់នាគ។

[៣២៨] (អភិសម្ពុទ្ធគាថា) ពួកស្គរធំ ស្គរតូច ត្រែ ស័ង្ខរបស់ព្រះរាជាព្រះនាមឧគ្គសេន ក៏លាន់ឮឡើង ព្រះរាជាទ្រង់ព្រះលំអច្រើនប្រការ ទ្រង់ស្ដេចយាងទៅក្នុងកណ្ដាលនៃពួកនារីដែលចោមរោមជុំវិញ។

[៣២៩] ព្រះរាជាអ្នកញុំាងដែនកាសីឲ្យចំរើន បានទតផែនដីដ៏វិចិត្រដោយមាស និងប្រាសាទទាំងឡាយជាវិការៈនៃមាស ដែលក្រាលដោយបន្ទះកែវពៃទូរ្យ។ ព្រះរាជាអង្គនោះ ទ្រង់ចូលទៅកាន់នាគពិភពដ៏សម្បើម ជាទីនៅនៃចម្បេយ្យនាគរាជ ដ៏ភ្លឺស្វាងដូចជាពណ៌នៃព្រះអាទិត្យមានរស្មីផ្លេកៗ ដូចផ្លេកបន្ទោរពណ៌មាស។ ព្រះបាទកាសីនោះ ទ្រង់ទតនិវេសនដ្ឋានរបស់ចម្បេយ្យនាគរាជ ដ៏ដេរដាសដោយឈើទាំងឡាយផ្សេងៗ ដ៏ផ្សព្វផ្សាយដោយក្លិនក្រអូបផ្សេងៗ។ កាលដែលព្រះបាទកាសី ទ្រង់ចូលទៅហើយ តូរ្យតន្ត្រីទាំងឡាយជាទិព្វ ក៏លាន់ឮឡើង នាគកញ្ញាទាំងឡាយក៏រាំថ្វាយ ក្នុងរាជនិវេសន៍នៃចម្បេយ្យនាគរាជ។

ព្រះរាជនិវេសន៍នោះ ដេរដាសដោយពួកនៃនាគកញ្ញា ព្រះរាជាកាសីទ្រង់ជ្រះថ្លា ឡើងគង់លើបល្ល័ង្ក ជាវិការៈនៃមាស មានបង្អែកដ៏លាបលនដោយខ្លឹមចន្ទន៍។

[៣៣០] ព្រះបាទកាសីនោះ ទ្រង់សោយ ទ្រង់រីករាយក្នុងនាគពិភពនោះ ហើយមានព្រះរាជឱង្ការចំពោះចម្បេយ្យនាគរាជថា វិមានដ៏ប្រសើរទាំងឡាយរបស់អ្នកនេះ មានពណ៌ដូចព្រះអាទិត្យដ៏ភ្លឺផ្លេកៗ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី។ ពួកនាងនាគកញ្ញានោះ ពាក់នូវគ្រឿងប្រដាប់មាស មានសម្លៀកបំពាក់ដ៏ល្អ មានម្រាមដៃមូល ប្រកបដោយផ្ទៃ (ដៃនិងជើង) ដ៏ក្រហម មានសម្បុរមិនអន់អាប់ លើក (នូវទិព្វបានៈ) ទៅថ្វាយដើម្បីសោយ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី។ ស្ទឹងទាំងឡាយមានទឹកត្រជាក់ មានត្រីមានស្រកាក្រាស់ មានអាទាសបក្សីយំពីរោះ មានកំពង់ល្អ ធម្មជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី។ ហ្វូងក្រៀល ក្ងោក ហង្ស តាវៅ ដ៏ជាទិព្វ ស្រែកនូវសម្រែកដ៏ពីរោះ ហើរទំពីព្រឹក្សាមួយ ទៅរកព្រឹក្សាមួយ ធម្មជាតដែលប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី។ ដើមស្វាយ ដើមសាលព្រឹក្ស ដើមមៀន ដើមព្រីង ដើមរាជព្រឹក្ស ដើមជ្រនៀងទាំងឡាយ មានផ្ការីកស្គុះស្គាយ រុក្ខជាតដែលប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី។ ក្លិនដ៏ជាទិព្វទាំងឡាយ រមែងបក់ផ្សាយជុំវិញស្រះបោក្ខរណីទាំងនេះជានិច្ច គន្ធជាតប្រាកដដូច្នេះ មិនមានក្នុងមនុស្សលោកទេ ម្នាលនាគ អ្នកធ្វើតបធម៌ដើម្បីអ្វី។

[៣៣១] (នាគរាជ...) បពិត្រព្រះអង្គជាធំជាងជន ទូលព្រះបង្គំជាខ្ញុំ ធ្វើតបធម៌ មិនមែនព្រោះហេតុចង់បានកូន មិនមែនចង់បានទ្រព្យ ឬថា មិនមែនព្រោះហេតុចង់បានអាយុទេ ទូលព្រះបង្គំជាខ្ញុំ ចង់បានកំណើតជាមនុស្ស ព្រោះហេតុនោះ ទើបខំប្រឹងធ្វើតបធម៌។

[៣៣២] (ព្រះរាជា...) អ្នកមានភ្នែកក្រហម មានរស្មីភ្លឺច្រាលឆ្អៅ មានខ្លួនប្រដាប់ហើយ មានសក់ និងពុកមាត់កោរកាត់ហើយ ប្រស់ព្រំយ៉ាងល្អ ដោយចន្ទន៍ក្រហម ភ្លឺផ្សាយទៅសព្វទិស ដូចជាគន្ធព្វរាជ។ អ្នកមានឫទ្ធិដូចជាទេវតា មានអានុភាពច្រើន បរិបូណ៌ដោយកាមទាំងឡាយគ្រប់យ៉ាង។ ម្នាលនាគរាជ មនុស្សលោកប្រសើរដោយវិសេសជាងនាគពិភពនេះ ដោយហេតុអ្វី យើងសូមសួរអ្នកចំពោះហេតុនុ៎ះឯង។

[៣៣៣] (នាគរាជ...) បពិត្រព្រះអង្គជាធំជាងជន សេចក្ដីបរិសុទ្ធិក្ដី ការសង្រួមក្ដី បើវៀរចាកមនុស្សលោកចេញហើយ ឥតមានទេ បើទូលព្រះបង្គំជាខ្ញុំ បានកំណើតជាមនុស្សហើយ នឹងធ្វើនូវទីបំផុតនៃជាតិ និងមរណៈ។

[៣៣៤] (ព្រះរាជា...) ពួកជនដែលប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ គេត្រូវគប់រកដោយពិត ម្នាលនាគរាជ ចំណែកខាងយើង បានឃើញនូវពួកនាងនារីផង នូវអ្នកផង នឹងធ្វើបុណ្យទាំងឡាយយ៉ាងច្រើន។

[៣៣៥] (នាគរាជ...) ពួកជនដែលប្រកបដោយប្រាជ្ញា ជាពហុស្សូត ជាអ្នកគិតនូវហេតុច្រើនប្រការ គេត្រូវគប់រកដោយពិត បពិត្រព្រះរាជា ព្រះអង្គទតឃើញនូវពួកនាងនារីផង នូវទូលព្រះបង្គំជាខ្ញុំផង សូមព្រះអង្គធ្វើនូវបុណ្យទាំងឡាយយ៉ាងច្រើនចុះ។

[៣៣៦] ប្រាក់របស់ទូលព្រះបង្គំជាខ្ញុំនេះច្រើនណាស់ ទាំងគំនរមាស ក៏ប្រហែលកំពស់ដើមត្នោត សូមព្រះអង្គឲ្យរាជបម្រើនាំអំពីនាគពិភពនេះ ទៅកសាងព្រះរាជដំណាក់ ជាវិការៈនៃមាស ពួកជាងចូរធ្វើកំពែងជាវិការៈនៃប្រាក់ចុះ។ គំនរកែវមុក្ដា មានប្រាំពាន់វាហៈ (រទេះ) គំនរកែវពៃទូរ្យ (ប្រាំពាន់វាហៈ) នេះ សូមពួកជននាំទៅអំពីនាគពិភពនេះ ហើយក្រាលលើផែនដីខាងក្នុងបុរី ឲ្យជាទីមិនមានភក់ មិនមានធូលី។ បពិត្រព្រះរាជាដ៏ប្រសើរ សូមព្រះអង្គគ្រប់គ្រងក្រុងពារាណសី ឲ្យជាវិមានប្រសើរ មានលំអច្រើនអន្លើ ជានគរស្ដុកស្ដម្ភទូលំទូលាយ មានសភាពដូច្នេះចុះ បពិត្រព្រះអង្គមានប្រាជ្ញាមិនថោកថយ សូមព្រះអង្គសោយរាជ្យចុះ។

ចប់ ចម្បេយ្យជាតក ទី១០។

## មហាបលោភនជាតក ទី១១

CS sut.kn.jat.507 | ភាគទី ៦០

### (៥០៧. មហាបលោភនជាតកំ (១១))

[៣៣៧] (ព្រះមានព្រះភាគទ្រង់ត្រាស់សំដែងជាតកនេះថា) ទេវបុត្រមានឫទ្ធិច្រើន ច្យុតចាកព្រហ្មលោក បានកើតជាបុត្រនៃព្រះរាជាទ្រង់បិតនៅក្នុងសម្បត្តិជាគ្រឿងញុំាងសេចក្ដីប្រាថ្នាទាំងពួងឲ្យសម្រេច។ កាមទាំងឡាយក្ដី កាមសញ្ញាក្ដី មិនមានក្នុងព្រហ្មលោកទេ

ព្រះរាជបុត្រនោះនឿយណាយចាកកាមទាំងឡាយ ព្រោះឈានសញ្ញា (ដែលកើតក្នុងព្រហ្មលោក) នោះឯង។ កំក្នុងព្រះរាជវាំងនៃព្រះរាជានោះ មានព្រះរាជដំណាក់សម្រាប់ចំរើនឈាន ដែលគេកសាងហើយដោយល្អ ព្រះរាជបុត្រនោះ ទ្រង់សម្ងំតែមួយព្រះអង្គឯង ចំរើនឈានក្នុងទីកំបាំងក្នុងព្រះរាជដំណាក់នោះ។ ព្រះបាទកាសីនោះ ទ្រង់បរិទេវនាការចង្អៀតចង្អល់ដោយសេចក្ដីសោកព្រោះព្រះរាជបុត្រថា ព្រះរាជបុត្រតែមួយរបស់យើងនេះ មិនបរិភោគកាម។ ឧបាយក្នុងរឿងនេះដូចម្ដេចហ្ន៎ ឬថា នរណាហ្ន៎ ចេះខ្វល់ខ្វាយក្នុងរឿងនេះ អ្នកណាអាចប្រលោមកូនអញ ឲ្យប្រាថ្នាកាមទាំងឡាយបាន។

[៣៣៨] ក្នុងព្រះរាជវាំងនោះឯង មានកុមារីម្នាក់ ជាស្ត្រីមានសម្បុរ និងរូបល្អ ជាស្ត្រីឈ្លាសវាងវៃក្នុងការរាំច្រៀង ទាំងបានសិក្សាល្អក្នុងការប្រគុំ កុមារីនោះ ចូលទៅគាល់ក្នុងទីនោះហើយ ក្រាបបង្គំទូល (ព្រះរាជា) ថា បើព្រះរាជឱរសនឹងបានជាព្រះភស្ដានៃខ្ញុំម្ចាស់ ខ្ញុំម្ចាស់អាចនឹងប្រលោមព្រះរាជឱរសនោះឲ្យខាងតែបាន។

[៣៣៩] ព្រះរាជា ទ្រង់មានព្រះរាជឱង្ការដូច្នេះនឹងកុមារីដែលនិយាយដូច្នោះនោះថា ចូរនាងប្រលោមព្រះរាជឱរសនោះចុះ ព្រះរាជឱរសនោះ នឹងជាភស្ដារបស់នាង។

[៣៤០] កុមារីនោះក៏ទៅខាងក្នុងព្រះរាជវាំង ហើយ (ច្រៀង) នូវចម្រៀង ដែលប្រកបដោយកាមច្រើនប្រការ ពោលគាថាដ៏វិចិត្រ ជាទីស្រឡាញ់ ជ្រួតជ្រាបក្នុងហឫទ័យ។

[៣៤១] ចំណង់ក្នុងកាមកើតឡើង ដល់ព្រះរាជបុត្រនោះ ព្រោះបានស្ដាប់សម្លេងរបស់នារីច្រៀងថ្វាយនោះឯង ព្រះរាជឱរសនោះ ទ្រង់សាកសួរជនថា យីអើ នុ៎ះជាសម្លេងនរណា ឬថា នរណានោះពោលពាក្យខ្ពស់ទាបច្រើន ដ៏ជ្រួតជ្រាបក្នុងហឫទ័យ ជាទីស្រឡាញ់ ជាសុខត្រចៀករបស់អញ។

[៣៤២] បពិត្រព្រះសម្មតិទេព នុ៎ះឯងជាស្ត្រី ស្ត្រីនុ៎ះចេះល្បែងច្រើនប្រការ បើព្រះអង្គទ្រង់សោយនូវកាមទាំងឡាយណា កាមទាំងឡាយនោះ នឹងញ៉ាំងព្រះអង្គ ឲ្យរីងរឹតតែគាប់ព្រះទ័យ។

[៣៤៣] អើបើដូច្នោះ ចូរកុមារីមកអាយចុះ ចូរច្រៀងក្នុងទីជិតចុះ ចូរច្រៀងក្នុងទីជិតអាស្រមក្នុងសំណាក់នៃយើងចុះ។

[៣៤៤] កុមារីនោះ ច្រៀងក្នុងទីខាងក្រៅជញ្ជាំង ហើយចូលទៅក្នុងព្រះរាជដំណាក់សំរាប់ចំរើនឈាន ដើម្បីចងព្រះរាជកុមារនោះ តាមលំដាប់ ដូចជាហ្មដំរីចងដំរីក្នុងព្រៃ។

[៣៤៥] ធម៌ច្រណែនបានកើតព្រោះដឹងនូវកាមរសនៃកុមារីនោះ យើងត្រូវតែបរិភោគកាមទាំងឡាយតែម្នាក់ឯងប៉ុណ្ណោះ កុំឲ្យមានបុរសដទៃឡើយ។ តពីនោះទៅ ព្រះរាជកុមារទ្រង់កាន់ដាវ ព្យាយាមដើម្បីសម្លាប់បុរសទាំងឡាយ ដោយគិតថា អញត្រូវបរិភោគកាមតែម្នាក់ឯងប៉ុណ្ណោះ កុំគប្បីមានបុរសដទៃ។

[៣៤៦] ក្នុងកាលនោះ អ្នកជនបទទាំងអស់មកប្រជុំគ្នា កន្ទក់កន្ទេញថា បពិត្រមហារាជ ព្រះរាជបុត្ររបស់ព្រះអង្គនេះ បៀតបៀននូវជនដែលមិនប្រទូស្ដ។

[៣៤៧] ព្រះរាជាជាក្សត្រ ទ្រង់បំបរបង់ព្រះរាជបុត្រចេញចាកដែននោះថា ទីដែនរបស់អញមានត្រឹមណា ឯងមិនត្រូវនៅត្រឹមនោះទេ។

[៣៤៨] លំដាប់នោះ ព្រះរាជកុមារនោះ ទ្រង់នាំភរិយាចូលទៅជិតសមុទ្រ ធ្វើនូវបណ្ណសាលា ហើយចូលទៅកាន់ព្រៃដើម្បីស្វែងរកផលាផល។

[៣៤៩] លំដាប់នោះ ឥសីមកខាងលើៗសមុទ្រដល់ក្នុងទីនុ៎ះ ឥសីនោះបានឃើញផ្ទះរបស់ព្រះរាជកុមារនោះក្នុងកាលភត្តដល់ហើយ។

[៣៥០] ឯភរិយាក៏ប្រលោមតាបសនោះ (ម្នាលភិក្ខុ) អ្នកចូរមើលអំពើអាក្រក់គួរស្មើម (នោះ) ចុះ តាបសនោះឃ្លាតចាកព្រហ្មចរិយធម៌ ហើយ ក៏សាបសូន្យចាកឫទ្ធិ។

[៣៥១] ចំណែកខាងព្រះរាជបុត្រ ដល់វេលាល្ងាច ក៏នាំយកមើមឈើ និងផ្លែឈើជាច្រើន មកអំពីទីស្វែងរកផលាផលដោយអម្រែក ហើយចូលទៅកាន់អាស្រម។

[៣៥២] ឯឥសីបានឃើញស្ដេចហើយ ក៏ចូលទៅជិតសមុទ្រដោយគិតថា អញនឹងទៅកាន់អាកាស តែឥសីនោះ លិចចុះក្នុងសមុទ្រ។

[៣៥៣] មហាក្សត្របានឃើញឥសីកំពុងលិចក្នុងសមុទ្រ ហើយពោលគាថាទាំងនេះ ដោយសេចក្ដីអនុគ្រោះដល់តាបសនោះថា

[៣៥៤] តាបសមកលើទឹកមិនបែក ដោយឫទ្ធិខ្លួនឯង ហើយលិចក្នុងសមុទ្រ ព្រោះដល់នូវសេចក្ដីច្រឡូកច្រល់ដោយស្ត្រី។ ធម្មតាពួកស្រី ជាអ្នកនាំឲ្យវិលវល់ណាស់ មានមាយាច្រើន ជាអ្នកញ៉ាំងព្រហ្មចរិយធម៌ឲ្យកម្រើក តែងនាំពន្លិច បុគ្គលដឹងច្បាស់នូវហេតុនោះហើយ គប្បីវៀរអំពីចម្ងាយ។ ពួកស្រីមានសំដីឥតទោស មានសំដីទន់ភ្លន់ ស្មើដោយស្ទឹង ព្រោះគេបំពេញបានដោយកម្រ តែងនាំពន្លិច បុគ្គលអ្នកដឹងច្បាស់នូវហេតុនោះហើយ គប្បីវៀរចេញអំពីចម្ងាយ។ ស្រីទាំងនុ៎ះ ចូលទៅគប់រកបុរសណា ព្រោះសេចក្ដីពេញចិត្តក្ដី ព្រោះទ្រព្យក្ដី រមែងដុតបំផ្លាញបុរសនោះយ៉ាងឆាប់ ដូចភ្លើងព្រៃដុតនូវឋានទីរបស់ខ្លួន។

[៣៥៥] សេចក្ដីនឿយណាយ ក៏កើតមានឡើងដល់ឥសី ព្រោះបានស្ដាប់ព្រះរាជបន្ទូលរបស់មហាក្សត្រ ហើយត្រឡប់បាននូវផ្លូវចាស់ (ឈានវិសេស) ក៏ទៅតាមអាកាសវិញ។

[៣៥៦] ព្រះមហាក្សត្រជាអ្នកប្រាជ្ញ លុះបានឃើញឥសីទៅតាមអាកាសហើយ ក៏បាននូវសេចក្ដីតក់ស្លុត ទ្រង់គាប់ព្រះរាជហឫទ័យស៊ប់ចំពោះបព្វជ្ជា។

លំដាប់នោះ ព្រះមហាក្សត្រនោះ ទ្រង់បព្វជ្ជាហើយ ក៏នឿយណាយចាកកាមរាគ លុះនឿយណាយចាកកាមរាគហើយ បានចូលទៅកើតក្នុងព្រហ្មលោក។

ចប់ មហាបលោភនជាតក ទី១១។

## បញ្ចបណ្ឌិតជាតក ទី១២

(៥០៨. បញ្ចបណ្ឌិតជាតកំ (១២))

[៣៥៧] (ព្រះបាទវិទេហៈត្រាស់ថា) អ្នកប្រាជ្ញទាំង ៥ នាក់មកជួបជុំគ្នាហើយ ប្រស្នាភ្លឺច្បាស់ដល់យើង អ្នកទាំងឡាយចូរស្តាប់ប្រស្នានោះ អ្នកជងឯគួរសំដែង (ប្រាប់) នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំងដល់នរណា។

[៣៥៨] (អាចារ្យសេនកៈទូលថា) បពិត្រព្រះភូមិបាល សូមព្រះអង្គធ្វើឲ្យជាក់ច្បាស់ដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ព្រះអង្គជាអ្នកចិញ្ចឹម ជាអ្នកអត់ធន់នូវរាជកិច្ចដ៏ធ្ងន់ សូមព្រះអង្គទ្រង់ពោលប្រស្នានុះមុន បពិត្រព្រះជនិន្ទ អ្នកប្រាជ្ញទាំង ៥ នាក់ពិចារណានូវរបស់ជាទីស្រឡាញ់ និងជាទីគាប់ព្រះទ័យរបស់ព្រះអង្គ ហើយនឹងក្រាបទូលក្នុងកាលជាខាងក្រោយ។

[៣៥៩] (ព្រះរាជា...) ភរិយាណា មានសីលពិត ដែលបុរសដទៃលួច (សម្ផស្ស) មិនបាន ជាស្រីប្រព្រឹត្តតាមអំណាចនៃសេចក្តីប្រាថ្នារបស់ភស្តា ជាទីស្រឡាញ់ ជាទីពេញចិត្តនៃភស្តា បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំង ដល់ភរិយា (នោះ) ឬ។

[៣៦០] (អាចារ្យសេនកៈ...) សំឡាញ់ណាជាទីរលឹក ជាគតិ ជាទីពឹងរបស់អ្នក ដែលដល់នូវសេចក្តីលំបាក អ្នកដែលក្តៅក្រហាយ បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរដែលជាអាថ៌កំបាំងដល់សំឡាញ់ (នោះ)។

[៣៦១] (អាចារ្យបុក្កុសៈ...) បងប្អូនណា ទោះបីជាបងបង្អស់ក្តី កណ្តាលក្តី ជាប្អូនពៅក្តី បើបងប្អូននោះដំកល់នៅស៊ប់ក្នុងសីល មានចិត្តនឹងនួន បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរ ដែលជាអាថ៌កំបាំង ដល់បងប្អូន (នោះ)។

[៣៦២] (អាចារ្យកាមិន្ទ...) កូនប្រុស អ្នកប្រព្រឹត្តទៅក្នុងអំណាចនៃហឫទ័យរបស់បិតា ជាអ្នកធ្វើតាមពាក្យ ជាអនុជាតបុត្រ មានប្រាជ្ញាមិនអន់ថយជាងបិតា បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរដែលជាអាថ៌កំបាំងដល់កូនប្រុស (នោះ)។

[៣៦៣] (អាចារ្យទេវិន្ទ...) បពិត្រព្រះអង្គជាធំជាងជន ដ៏ប្រសើរជាងមនុស្ស មាតាណាចិញ្ចឹមកូននោះ ដោយសេចក្តីស្រឡាញ់ពេញចិត្ត បុគ្គលគួរប្រាប់នូវសេចក្តីដែលគួរនិន្ទា ឬគួរសរសើរដែលជាអាថ៌កំបាំង ដល់មាតា (នោះ)។

[៣៦៤] (មហោសធបណ្ឌិត) សេចក្តីពិតថា ការលាក់នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់នូវអាថ៌កំបាំង គេមិនសរសើរទេ អ្នកប្រាជ្ញកាលបើសេចក្តីប្រាថ្នាមិនទាន់សម្រេចនៅឡើយ ត្រូវអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយតាមសប្បាយចុះ។

[៣៦៥] (នាងឧទុម្ពរាទេវី...) បពិត្រព្រះរាជាដ៏ប្រសើរ ព្រះអង្គទ្រង់មានព្រះទ័យប្រែប្រួលឬ បពិត្រព្រះអង្គជាធំជាងមនុស្ស ខ្ញុំម្ចាស់ស្តាប់ព្រះតម្រាស់របស់ព្រះអង្គនោះហើយ តើព្រះអង្គទ្រង់ព្រះចិន្តាដូចម្តេច បានជាទ្រង់តូចព្រះទ័យ បពិត្រព្រះសម្មតិទេព ខ្ញុំម្ចាស់មិនមានកំហុសទេឬ។

[៣៦៦] (ព្រះរាជា...) មហោសធ ត្រូវគេសម្លាប់ព្រោះតែប្រស្នា មហោសធ ជាអ្នកមានប្រាជ្ញាដូចផែនដី ខ្ញុំបង្គាប់គេឲ្យសម្លាប់ហើយ ខ្ញុំគិតរឿងនោះ បានជាតូចចិត្ត ម្នាលនាងទេវី កំហុសរបស់នាងមិនមានទេ។

[៣៦៧] (ព្រះរាជា...) អ្នកឯង ទើបតែទៅផ្ទះក្នុងពេលព្រលប់សោះ ឥឡូវនេះ ស្រាប់តែមកវិញភ្លាម អ្នកឯងឮដំណឹងដូចម្តេច ចិត្តរបស់អ្នកឯងរង្កៀសដូចម្តេច ម្នាលអ្នកមានប្រាជ្ញាដូចផែនដី នរណាបានប្រាប់ដំណឹងដូចម្តេចដល់អ្នក យើងចង់ស្តាប់ពាក្យនោះ អ្នកចូរប្រាប់ពាក្យនោះដល់យើង។

[៣៦៨] (មហោសធ...) បពិត្រព្រះអង្គជាធំជាងជន ព្រះអង្គស្តេចទៅក្នុងទីស្ងាត់ បានប្រាប់នូវអាថ៌កំបាំង ដែលព្រះអង្គប្រឹក្សាហើយក្នុងពេលព្រលប់ ដល់ព្រះអគ្គមហេសីថា មហោសធត្រូវគេសម្លាប់ ព្រោះតែប្រស្នា ក្នុងកាលណា សេចក្តីកំបាំងឈ្មោះថាព្រះអង្គធ្វើឲ្យប្រាកដហើយ ក្នុងកាលនោះ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ។

[៣៦៩] អាចារ្យសេនកៈបានធ្វើអំពើអាក្រក់ ជាអំពើមានសភាពមិនល្អក្នុងឱទ្យាន ដ៏ដេរដាសដោយដើមសាលព្រឹក្ស បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់សំឡាញ់ សេចក្តីកំបាំងណាដែលអាចារ្យសេនកៈធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនោះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ។

[៣៧០] បពិត្រព្រះអង្គជាធំជាងជន រោគ (ឃ្លង់) កើតឡើងដល់បុក្កុសបុរស របស់ព្រះអង្គ រោគនោះមិនសមគួរដល់ព្រះរាជាទេ គាត់បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់បងប្អូនប្រុស សេចក្តីកំបាំងណា ដែលអាចារ្យបុក្កុសៈធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ។

[៣៧១] អាចារ្យកាមិន្ទនេះ មានអាពាធដ៏អាក្រក់ គឺត្រូវនរទេវយក្ខចូល បានទៅក្នុងទីស្ងាត់ ហើយប្រាប់ដល់កូនប្រុស សេចក្តីកំបាំងណា ដែលអាចារ្យកាមិន្ទធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ។

[៣៧២] ព្រះឥន្ទ្របានថ្វាយមណិរតន៍មានជ្រុង ៨ ដ៏ថ្លៃថ្លា (ដល់ព្រះបាទកុសរាជ) ជាព្រះអយ្យកោរបស់ព្រះអង្គ ថ្ងៃនេះមណិរតន៍នោះទៅនៅក្នុងកណ្តាប់ដៃនៃអាចារ្យទេវិន្ទហើយ អាចារ្យទេវិន្ទទៅក្នុទីស្ងាត់ ហើយប្រាប់ដល់មាតា សេចក្តីកំបាំងណា ដែលអាចារ្យទេវិន្ទធ្វើឲ្យប្រាកដហើយ សេចក្តីកំបាំងនុ៎ះ ទូលព្រះបង្គំជាខ្ញុំបានឮហើយ។

[៣៧៣] សេចក្តីពិតថា ការលាក់នូវអាថ៌កំបាំង ជាការប្រពៃ ការប្រាប់នូវអាថ៌កំបាំង គេមិនសរសើរទេ អ្នកប្រាជ្ញ កាលបើសេចក្តីប្រាថ្នាមិនទាន់សម្រេច ត្រូវអត់សង្កត់ទុក លុះសម្រេចប្រយោជន៍ហើយ ទើបគួរនិយាយតាមសប្បាយចុះ។ បុគ្គលមិនគប្បីបើកនូវអាថ៌កំបាំង គប្បីរក្សានូវអាថ៌កំបាំងនោះ ដូចជារក្សានូវកំណប់ ដ្បិតថា អាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់មិនធ្វើឲ្យប្រាកដ ជាការប្រពៃ។ អ្នកប្រាជ្ញមិនគប្បីនិយាយប្រាប់នូវអាថ៌កំបាំងដល់ស្រី ដល់ជនជាសត្រូវ ដល់ជនឡើបឡេប់ដោយអាមិស ដល់ជនលួចគំនិតគ្នា ជនណាតែងញាំងអាថ៌កំបាំង ដែលមិនទាន់មានគេដឹង ឲ្យគេដឹង អ្នកប្រាជ្ញតែងអត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចជាមនុស្សខ្ញុំគេ។ ជនទាំងឡាយប៉ុន្មាននាក់ដឹងនូវមន្តជាអាថ៌កំបាំងរបស់បុរស សេចក្តីតក់ស្លុតប៉ុណ្ណោះ តែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញមិនគប្បីផ្សាយនូវអាថ៌កំបាំង។

ក្នុងវេលាថ្ងៃ អ្នកប្រាជ្ញ គប្បីនិយាយអាថ៌កំបាំងក្នុងទីស្ងាត់ មិនគប្បីបញ្ចេញសម្លេងក្នុងវេលាយប់ឲ្យហួសកម្រិត ព្រោះថា ពួកអ្នកឈ្លបស្តាប់រមែងឮនូវអាថ៌កំបាំង ដែលប្រឹក្សាគ្នា ព្រោះហេតុនោះ គំនិតនឹងដល់នូវការបែកធ្លាយយ៉ាងឆាប់។

ចប់ បញ្ចបណ្ឌិតជាតក ទី១២។

## ហត្ថិបាលជាតក ទី១៣

CS sut.kn.jat.509 | ភាគទី ៦០

(៥០៩. ហត្ថិបាលជាតកំ (១៣))

[៣៧៤] (ហត្ថិបាលកុមារពោលថា) យូរណាស់ហើយ យើងទើបនឹងឃើញព្រាហ្មណ៍មានភេទដូចទេវតា មានផ្នួងសក់ធំ មានធូលីលើព្រះសិរ។ យូរណាស់ហើយ យើងទើបនឹងឃើញឥសី អ្នកត្រេកអរក្នុងធម្មគុណ ស្លៀកដណ្តប់សំពត់កាសាយៈ មានសំបកឈើជាគ្រឿងបិទបាំង។ សូមលោកដ៏ចំរើន ទទួលនូវអាសនៈ ទឹក និងប្រេងសម្រាប់លាបជើងរបស់យើងខ្ញុំចុះ យើងខ្ញុំសូមសួរនូវរបស់មានតម្លៃ ចំពោះលោកដ៏ចំរើន សូមលោកដ៏ចំរើន ប្រាប់នូវរបស់មានតម្លៃដល់យើងខ្ញុំ។

[៣៧៥] (បុរោហិតជាឥសី...) ហៃបា អ្នកចូររៀននូវវេទទាំងឡាយ ហើយស្វែងរកទ្រព្យ ដំកល់ទុកនូវកូនទាំងឡាយក្នុងផ្ទះ សោយនូវក្លិន និងរសទាំងឡាយផង នូវវត្ថុកាមគ្រប់បែបផង ព្រៃប្រពៃដល់អ្នកបួសឯចាស់ បុគ្គលនោះជាអ្នកប្រាជ្ញដែលព្រះអរិយៈទាំងឡាយសរសើរហើយ។

[៣៧៦] (ហត្ថិបាលកុមារ...) វេទទាំងឡាយជាសភាវៈមិនទៀង ការបាននូវទ្រព្យ ក៏មិនទៀងដែរ ជនទាំងឡាយឃាត់ជរាដោយការបាននូវកូនមិនបានទេ សប្បុរសទាំងឡាយសរសើរនូវការរួចចាកក្លិន និងរស កិរិយាសម្រេចផល រមែងមានតាមកម្មរបស់ខ្លួន។

[៣៧៧] (ព្រះបាទឯសុការីជាឥសី...) ពាក្យរបស់អ្នកនុ៎ះ ជាពាក្យពិត ដ្បិតថា កិរិយាសម្រេចផល រមែងមានតាមកម្មរបស់ខ្លួន ប៉ុន្តែមាតានិងបិតារបស់អ្នកនេះ ចាស់ហើយ លោកតែងចង់ឃើញនូវអ្នក ជាបុគ្គលមិនមានរោគអស់រយនៃឆ្នាំ។

[៣៧៨] (ហត្ថិបាលកុមារ...) បពិត្រព្រះរាជា អ្នកទ្រទ្រង់នូវសេចក្តីព្យាយាមវិសេសជាងជន ភាពជាសំឡាញ់ដោយមរណៈ សេចក្តីមេត្រីដោយជរា គប្បីមានដល់ជនណា ម្យ៉ាងទៀត ជនណា គប្បីដឹងថា អញនឹងមិនស្លាប់ក្នុងកាលណាមួយទេ មាតាបិតាគួរឃើញនូវជននោះ ជាបុគ្គលមិនមានរោគអស់រយនៃឆ្នាំ។ បុរសចែវទូកក្នុងទឹក នាំទូកនុ៎ះទៅកាន់ត្រើយ (ខាងនាយ) យ៉ាងណា សេចក្តីឈឺចាប់ និងសេចក្តីគ្រាំគ្រា រមែងនាំសត្វចូលទៅកាន់អំណាចនៃសេចក្តីស្លាប់អ្នកធ្វើនូវទីបំផុតជារឿយៗ យ៉ាងនោះដែរ។

[៣៧៩] (អស្សបាលកុមារ...) កាមទាំងឡាយជាភក់ផង កាមទាំងឡាយជាល្បាប់ផង ជាគ្រឿងនាំមកនូវសេចក្តីពេញចិត្ត ជាគ្រឿងឆ្លងបានដោយកម្រ ជាលំនៅនៃមច្ចុ ពួកសត្វដែលលិចចុះក្នុងភក់ ក្នុងល្បាប់នេះ ជាសត្វមានចិត្តថោកទាប ជាសភាវៈឆ្លងទៅកាន់ត្រើយ (ព្រះនិព្វាន) ពុំបានឡើយ។ អត្តភាពរបស់ទូលព្រះបង្គំជាខ្ញុំនេះ បានធ្វើនូវអំពើអាក្រក់ក្នុងកាលមុន ផលនៃកម្មនោះ ទូលព្រះបង្គំជាខ្ញុំបានកាន់យកហើយ ការរួចចាកផលអកុសលនោះ មិនមានដល់ទូលព្រះបង្គំជាខ្ញុំឡើយ។ ទូលព្រះបង្គំ នឹងបិទរក្សានូវអត្តភាពនោះ កុំឲ្យអត្តភាពនេះធ្វើអំពើអាក្រក់ទៀតឡើយ។

[៣៨០] (គោបាលកុមារ...) បពិត្រព្រះរាជា ដូចបុរសកាលមិនឃើញគោ ស្វែងរកគោដែលបាត់ក្នុងព្រៃ យ៉ាងណា បពិត្រព្រះរាជា ទ្រង់ព្រះនាមឯសុការី ប្រយោជន៍ (បព្វជ្ជា) របស់ទូលព្រះបង្គំជាខ្ញុំវិនាសបាត់ទៅ ក៏យ៉ាងនោះដែរ បពិត្រព្រះរាជា ទូលព្រះបង្គំជាខ្ញុំ មិនគប្បីស្វែងរកដូចម្តេចបាន។

[៣៨១] បុរសបង្អង់ (នូវការងារដែលត្រូវធ្វើ) ថា ចាំថ្ងៃស្អែកៗ ដូច្នេះ រមែងសាបសូន្យ អ្នកប្រាជ្ញដឹងថា អនាគតនេះមិនមានដូច្នេះហើយ អ្នកប្រាជ្ញណា នឹងបន្ទោបង់នូវសេចក្តីប៉ុនប៉ងដែលកើតឡើងហើយបាន។

[៣៨២] (អជបាលកុមារ...) ទូលព្រះបង្គំជាខ្ញុំ បានឃើញកុមារីនៅក្មេង (ទ្បេះទ្បោះ) ដូចជាមនុស្សឆ្កួត មានភ្នែកដូចត្របកនៃផ្កាកាកែសបិតនៅក្នុងបឋមវ័យ មិនទាន់បរិភោគនូវភោគៈទាំងឡាយ ស្រាប់តែមច្ចុនាំយកកុមារី (នោះទៅ)។ ប្រុសកម្លោះមានកំណើតល្អ មានមុខស្រស់បស់ គួរជាទីរមិលមើល មានសម្បុរលឿងដូចមាស មានពុកមាត់ដេរដាសដូចកេសរនៃផ្កាដកគាំ (មច្ចុបាននាំយកនូវប្រុសកម្លោះនោះទៅ) ខ្ញុំព្រះអង្គនឹងលះបង់នូវកាមទាំងឡាយ ហើយគេចចេញចាកផ្ទះ (ទៅបួស) បពិត្រព្រះសម្មតិទេព សូមព្រះអង្គអនុញ្ញាតទូលព្រះបង្គំជាខ្ញុំ ទូលព្រះបង្គំជាខ្ញុំនឹងបួស។

[៣៨៣] (បុរោហិត...) អនុបាទិន្នកសង្ខារ បានឈ្មោះថា ដើមឈើ ព្រោះតែមែកទាំងឡាយ មួយទៀត ជនទាំងឡាយហៅនូវដើមឈើដែលមានមែកលះបង់អស់ហើយថា ដង្កត់ ម្នាលនាងវាសេដ្ឋីដ៏ចំរើន ថ្ងៃនេះជាកាលគួរ ដើម្បីត្រាច់ទៅស្វែងរកភិក្ខារបស់ខ្ញុំ ដែលមានកូនលះបង់ហើយ។

[៣៨៤] (ព្រាហ្មណីបន្លឺឧទានថា) ពួកក្រៀល ហើរទៅឰដ៏អាកាស ក្នុងរដូវអស់ទឹកភ្លៀង ហង្សទាំងឡាយ ទំលាយនូវមងដែលពីងពាងធ្វើហើយ យ៉ាងណា កូនទាំងឡាយផង ប្តីផងរបស់អញ (ទំលាយមង គឺកាមហើយ) ក៏ទៅ យ៉ាងនោះដែរ អញនោះ កាលបើដឹងច្បាស់ហើយ មិនទៅតាមដូចម្តេចកើត។

[៣៨៥] (ព្រះរាជទេពី...) បក្សី (ត្មាត) ទាំងឡាយនេះ បរិភោគ (នូវសាច់) ហើយក្អែចេញ ទើបហើរចៀសចេញទៅរួច ចំណែកខាងត្មាតទាំងឡាយណា បរិភោគហើយមិនក្អែចេញទេ ត្មាតទាំងនោះ មកលុះក្នុងកណ្តាប់ដៃរបស់ខ្ញុំម្ចាស់ហើយ។ ព្រាហ្មណ៍បានខ្ជាក់ចោលនូវកាមទាំងឡាយចេញហើយ ព្រះអង្គនោះត្រឡប់ជាលេបវិញ បពិត្រព្រះរាជា បុរសណា ស៊ីនូវកញ្ជក់ បុរសនោះមិនគួរគេសរសើរទេ។

[៣៨៦] (ព្រះរាជា...) បុរសអ្នកមានកំឡាំង អាចស្រង់នូវបុរសមានកំឡាំងខ្សោយ ដែលលិចក្នុងភក់ល្បាប់បាន យ៉ាងណា ម្នាលរាជធីតារបស់ព្រះបាទបញ្ចាលដ៏ចំរើន នាងឯងក៏ញុំាងយើងឲ្យឆ្លងឡើង (ចាកកាម) ដោយគាថាទាំងឡាយជាសុភាសិត យ៉ាងនោះដែរ។

[៣៨៧] មហារាជទ្រង់ព្រះនាមឯសុការី ជាម្ចាស់ក្នុងទិស ទ្រង់ត្រាស់គាថានេះហើយ ទ្រង់លះបង់នូវដែនចេញទៅ ទ្រង់ព្រះផ្នួស ដូចជាដំរីដ៏ប្រសើរ ផ្តាច់នូវចំណងដូច្នោះ។

[៣៨៨] (មហាជន...) ព្រះរាជាមានព្យាយាមវិសេសជាងជន ទ្រង់សព្វព្រះរាជហឫទ័យចំពោះបព្វជ្ជា លះបង់នូវដែន ចំណែកខាងព្រះនាង សូមដូចជាព្រះរាជារបស់យើងចុះ ព្រះនាងដែលពួកយើងគ្រប់គ្រងហើយ ចូរសោយរាជសម្បត្តិចុះ។

[៣៨៩] (ព្រះរាជទេពី...) ព្រះរាជាមានព្យាយាមវិសេសជាងជន ទ្រង់សព្វព្រះរាជហឫទ័យចំពោះបព្វជ្ជា ទ្រង់លះបង់នូវដែន ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ ដែលញុំាងចិត្តឲ្យត្រេកអរចេញ ហើយជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក។ ព្រះរាជាមានព្យាយាម

វិសេស់ជាងជន ទ្រង់សព្វព្រះរាជហឫទ័យចំពោះបព្វជ្ជា ទ្រង់លះបង់នូវដែន ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយតាមចំណែក ហើយជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក។ កាលទាំងឡាយ តែងកន្លងហួសទៅ រាត្រីទាំងឡាយ តែងញុំាង (អាយុសង្ខារ) ឲ្យឆ្លងទៅ គំនរនៃវ័យទាំងឡាយ រមែងរលត់ទៅតាមលំដាប់ ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយ ជាទីញុំាងចិត្តឲ្យត្រេកអរ ហើយជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក។ កាលទាំងឡាយ រមែងកន្លងហួសទៅ រាត្រីទាំងឡាយ រមែងញុំាង (អាយុសង្ខារ) ឲ្យឆ្លងទៅ គំនរនៃវ័យទាំងឡាយ រមែងលះបង់ទៅតាមលំដាប់ ចំណែកខាងខ្ញុំ នឹងលះបង់នូវកាមទាំងឡាយតាមចំណែក ហើយជាស្ត្រីម្នាក់ឯង ត្រាច់ទៅក្នុងលោក។ កាលទាំងឡាយ រមែងកន្លងហួសទៅ រាត្រីទាំងឡាយ រមែងញុំាង (អាយុសង្ខារ) ឲ្យឆ្លងទៅ គំនរនៃវ័យទាំងឡាយ រមែងលះបង់ទៅជាលំដាប់ ចំណែកខាងខ្ញុំ នឹងកន្លងបង់នូវគ្រឿងជ្ពក់ទាំងអស់ ហើយជាស្ត្រីត្រជាក់ម្នាក់ឯង ត្រាច់ទៅក្នុងលោក។

ចប់ ហត្ថិបាលជាតក ទី១៣។

## អយោឃរជាតក ទី១៤

CS sut.kn.jat.510 | ភាគទី ៦០

### (៥១០. អយោឃរជាតកំ (១៤))

[៣៩០] (អយោឃរកុមារពោធិសត្វ...) សត្វនៅក្នុងគភ៌ អស់រាត្រីណាមួយជាដំបូង សត្វនោះប្រព្រឹត្តទៅ ដូចជាពពកដែលតាំងឡើង សត្វនោះកាលទៅ រមែងមិនត្រឡប់វិញទេ។

[៣៩១] មិនមែនពួកនរៈកាលច្បាំង មិនមែនពួកនរៈបរិបូរណ៍ដោយកំលាំង មិនគ្រាំគ្រ មិនស្លាប់ទេ ព្រោះថា បាណមណ្ឌលទាំងអស់នោះ គឺជាតិ និងជរា តែងចូលទៅជិតបៀតបៀន ហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៣៩២] ព្រះរាជាទាំងឡាយ ជារដ្ឋាធិបតី គ្របសង្កត់នូវសេនាប្រកបដោយអង្គ ៤ ជាសេនាមានសភាពគួរខ្លាចក្រៃពេក រមែងឈ្នះបាន ប៉ុន្តែមិនអាចឈ្នះនូវសេចក្តីស្លាប់បាន ព្រោះហេតុនោះ គំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៣៩៣] ព្រះរាជាទាំងឡាយអង្គខ្លះ ដែលមានពលដំរី ពលសេះ ពលរថ ពលថ្មើរជើងចោមរោមហើយ រួច (អំពីកណ្តាប់ដៃពួកបច្ចាមិត្ត) បាន ប៉ុន្តែមិនអាចរួចចាកសេចក្តីស្លាប់បាន ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៣៩៤] ព្រះរាជាទាំងឡាយក្លៀវក្លា រមែង (ញុំាងនគរទាំងឡាយរបស់ពួកស្តេចជាបច្ចាមិត្ត) ឲ្យខ្ទេចខ្ទី ឲ្យខ្ចាត់ខ្ចាយ ដោយពលដំរី ពលសេះ ពលរថ ពលថ្មើរជើងបាន ប៉ុន្តែមិនអាចកំទេចនូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៣៩៥] ដំរីទាំងឡាយ ចុះប្រេង មានប្រេងធ្លាយហូរហៀរ តែងញុំាញីនូវនគរទាំងឡាយ សម្លាប់នូវជនបាន ប៉ុន្តែមិនអាចញុំាញីនូវសេចក្តីស្លាប់បានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៣៩៦] ខ្មាន់ធ្នូទាំងឡាយ ទុកជាមានដៃហាត់ហើយ ជាអ្នកក្លៀវក្លា អាចញុំាងព្រួញឲ្យធ្លាក់ក្នុងទីឆ្ងាយបាន បាញ់មិនខុស ក៏មិនអាចបាញ់នូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៣៩៧] ទឹកស្រះទាំងឡាយ រមែងអស់ទៅ ផែនដី ព្រមទាំងភ្នំ និងដងព្រៃ រមែងអស់ទៅ វត្ថុដែលប្រព្រឹត្តទៅក្នុងអំណាចនៃសង្ខារទាំងអស់នោះ ក៏រមែងអស់ទៅ ក្នុងចន្លោះនៃកាលដ៏វែង ដ្បិតថា វត្ថុទាំងអស់នោះ គប្បីបាក់បែកក្នុងកំណត់កាលជាទីវិនាស ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៣៩៨] ជីវិតរបស់នារី និងនរៈក្នុងលោកនេះទាំងអស់ តែងប្រែប្រួលដូចជាសម្ពត់របស់អ្នកលេង[28] ដូចឈើដុះក្បែរច្រាំង យ៉ាងនោះដែរ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៣៩៩] ផ្លែឈើទាំងឡាយ (រមែងជ្រុះចុះ) យ៉ាងណា មាណពទាំងឡាយ ទាំងក្មេង ទាំងចាស់ ទាំងស្រី ទាំងប្រុស ទាំងមជ្ឈិមបុរស (បណ្ឌក និងឧភតោព្យញ្ជនក) រមែងមានសរីរៈបែកធ្លាយជ្រុះចុះ (យ៉ាងនោះ) ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០០] វ័យនេះ មិនដូចស្តេចផ្កាយ (ព្រះចន្ទ្រ) ទេ វ័យណាកន្លងទៅហើយ ឥឡូវនេះ វ័យនោះ ទៀងតែទៅមែនពិត បុគ្គលចាស់ឥតមានតម្រេក (ក្នុងកាមគុណ[29]) សុខនឹង (មាន) មកពីណា ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០១] ពួកយក្ខ បិសាច ឬប្រេតទាំងនោះខឹងហើយ រមែងផ្លុំសម្លាប់នូវពួកមនុស្ស ប៉ុន្តែមិនអាចផ្លុំសម្លាប់នូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០២] មនុស្សទាំងឡាយ រមែងធ្វើនូវការអង្វរករចំពោះពួកយក្ខ ពួកបិសាច ឬពួកប្រេត ដែលខឹងហើយនោះបាន ប៉ុន្តែមិនអាចអង្វរករមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០៣] ព្រះរាជាទាំងឡាយ ទ្រង់ជ្រាបច្បាស់នូវទោស ហើយដាក់អាជ្ញាចំពោះពួកជនអ្នកមានកំហុស អ្នកប្រទូស្ត និងអ្នកបៀតបៀនបាន ប៉ុន្តែមិនអាចដាក់អាជ្ញា ដល់មច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០៤] ពួកជនអ្នកមានកំហុស អ្នកប្រទូស្ត អ្នកបៀតបៀន តែងអង្វរករព្រះរាជាទាំងឡាយនោះបាន ប៉ុន្តែ ធ្វើនូវកិរិយាអង្វរករមច្ចុពុំបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០៥] មិនថាក្សត្រ មិនថាព្រាហ្មណ៍ មិនថាអ្នកស្តុកស្តម្ភ អ្នកមានកំឡាំង អ្នកមានតេជះទេ សេចក្តីយល់មុខរបស់មច្ចុរាជ មិនមានឡើយ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០៦] ខ្លាធំ ទាំងខ្លាដំបង តែងគំរាមនូវជនដែលកំពុងញាប់ញ័រ ហើយទំពាស៊ីបាន ប៉ុន្តែមិនអាចទំពាស៊ីនូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំកើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០៧] ពួកជនអ្នកធ្វើមាយា (អ្នកលេងកល) កាលធ្វើ (នូវមាយា) ក្នុងទីពាក់កណ្តាលរង្គ រមែងធ្វើនូវភ្នែកទាំងឡាយរបស់ជន ឲ្យភាន់ច្រឡំបានដោយពិត ប៉ុន្តែមិនអាចញ៉ាំងមច្ចុឲ្យភាន់ច្រឡំបានឡើយ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០៨] សត្វអាសីពិសទាំងឡាយ មានតេជះដ៏ក្លាខ្លាំង ខឹងហើយ រមែងចឹកសម្លាប់នូវមនុស្សទាំងឡាយនោះក៏បាន ប៉ុន្តែមិនអាចចឹកនូវមច្ចុបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤០៩] សត្វអាសីពិសទាំងឡាយក្រោធហើយ ចឹកនរណា ពួកពេទ្យអ្នករក្សា រមែងកំចាត់នូវពិសនៃសត្វអាសីពិសទាំងនោះបាន ប៉ុន្តែកំចាត់នូវពិសដែលមច្ចុចឹកហើយពុំបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤១០] ពេទ្យទាំងឡាយ ឈ្មោះធម្មន្តរី ១ វេត្តរុណ ១ ភោជៈ ១ សម្លាប់នូវពិសទាំងឡាយនៃភុជង្គ (នាគ) បាន ពួកពេទ្យទាំងនោះ គេឮថាធ្វើមរណកាលទៅហើយដូចគ្នាដែរ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤១១] ពួកវិជ្ជាធរ រៀននូវឃោរវិជ្ជា រមែងដល់នូវការបំបាំងខ្លួនដោយថ្នាំទាំងឡាយបាន ប៉ុន្តែមិនដល់នូវការបំបាំងមច្ចុរាជបានទេ ព្រោះហេតុនោះ បានជាគំនិតរបស់ទូលព្រះបង្គំជាខ្ញុំ កើតឡើងថា អញនឹងប្រព្រឹត្តធម៌។

[៤១២] ធម៌រមែងរក្សានូវបុគ្គលអ្នកប្រព្រឹត្តធម៌ដោយពិត ធម៌ដែលបុគ្គលប្រព្រឹត្តដោយល្អហើយ រមែងនាំមកនូវសេចក្តីសុខ នេះជាអានិសង្សក្នុងធម៌ ដែលបុគ្គលប្រព្រឹត្តដោយល្អហើយ បុគ្គលអ្នកប្រព្រឹត្តធម៌ រមែងមិនទៅកាន់ទុគ្គតិ។

[៤១៣] សភាវៈទាំងឡាយពីរ គឺធម៌ ១ អធម៌ ១ មិនមែនមានផលស្មើគ្នាទេ អធម៌នាំសត្វទៅកាន់នរក ធម៌ញ៉ាំងសត្វឲ្យដល់នូវសុគតិ។

ចប់ អយោឃរជាតក ទី១៤។

ឧទ្ទាននៃវីសតិនិបាតនោះគឺ

មាតង្គជាតក ១ ចិត្តសម្ភូតជាតក ១ សីវិរាជជាតក ១ សិរិមន្តជាតក ១ រោហនមិគជាតក ១ ហង្សជាតក ១ សត្តិគុម្ពជាតក ១ ភល្លាតិយជាតក ១ សោមនស្សជាតក ១ ចម្បេយ្យជាតក ១ មហាបលោភនជាតក ១ បញ្ចបណ្ឌិតជាតក ១ ហត្ថិបាលជាតក ១ អយោឃរជាតក ១។

ចប់ វីសតិនិបាត។

# តឹសនិបាតជាតក

CS sut.kn.jat.v16 | ភាគទី ៦០

(១៦. តឹសនិបាតោ)

## កឹឆន្ទជាតក ទី១

CS sut.kn.jat.511 | ភាគទី ៦០

(៥១១. កិំឆន្ទជាតកំ (១))

[៤១៤] (ទេវតាពោលថា) បពិត្រព្រាហ្មណ៍ លោកពេញចិត្តនឹងអ្វី ប៉ុនប៉ងអ្វី ប្រាថ្នាអ្វី ស្វែងរកអ្វី ទើបអង្គុយម្នាក់ឯងក្នុងរដូវក្តៅដោយប្រយោជន៍អ្វី។

[៤១៥] (តាបសពោលតបថា) ក្អមដាក់នូវទឹកដ៏ធំ មានទ្រង់ទ្រាយស្អាតបាត មានឧបមាយ៉ាងណា ផ្លែស្វាយទុំ ដ៏ឧតម្តដោយពណ៌ និងក្លិន និងរស ក៏មានឧបមេយ្យយ៉ាងនោះ។ ម្នាលនាងមានអវយវៈត្រង់កណ្តាល (ចង្កេះ) មិនមានមន្ទិល អាត្មាបានឃើញផ្លែស្វាយនោះអណ្តែតតាមខ្សែទឹក ក៏ចាប់ផ្លែស្វាយនោះដោយដៃទាំងពីរ ហើយនាំយកទៅកាន់រោងបូជាភ្លើង។ លំដាប់នោះ អាត្មាបានដាក់ផ្លែស្វាយលើស្លឹកចេកទាំងឡាយដោយខ្លួនឯង ចិតនូវផ្លែស្វាយនោះដោយកាំបិត ហើយ (ឆាន់) ផ្លែស្វាយនោះ នាំចេញនូវសេចក្តីស្រេកឃ្លានរបស់អាត្មាបាន។ អាត្មានោះ ប្រាសចាកសេចក្តីក្រវល់ក្រវាយ លុះផ្លែស្វាយអស់ហើយ ក៏អត់ទ្រាំបានដោយលំបាក មិនបានសេចក្តីត្រេកអរក្នុងផ្លែឈើទាំងឡាយឯទៀតណាមួយ។ ផ្លែស្វាយនោះ នឹងនាំមកនូវសេចក្តីស្លាប់ដល់អាត្មាដោយពិត ព្រោះរីងស្ងួមព្រោះផ្លែស្វាយមានរសឆ្ងាញ់ មានរសផ្អែមលើសលប់ ជាទីពេញចិត្ត។ អាត្មាបានស្រង់ផ្លែស្វាយដែលកំពុងអណ្តែតក្នុងអន្លង់ដ៏ធំអំពីស្ទឹង អាត្មានៅ (ដោយសេចក្តីស្រេកឃ្លាន) ព្រោះហេតុណា ហេតុនោះទាំងអស់ អាត្មាបានប្រាប់ដល់នាង។ អាត្មាអង្គុយអាស្រ័យនូវស្ទឹងជាទីរីករាយ ស្ទឹងនេះធំទូលាយប្រកបដោយត្រី នាងកុំអាលរត់ទៅ ចូរប្រាប់ខ្លួននោះដល់អាត្មាសិន។ ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានអវយវៈត្រង់កណ្តាល (ចង្កេះ) ដ៏ល្អ នាងមានរូបដូចកដម្បូរមាសដ៏រលីង (មានដំណើរ) ដូចជាកូនខ្លាដែលកើតក្នុងញកភ្នំ (មកក្នុងទីនេះ) ដើម្បីអ្វី។ នាងនារីទាំងឡាយណា ជាអ្នកបំរើពួកទេវតា ក្នុងទេវតាទាំងឡាយផង ស្រីទាំងឡាយណាប្រកបដោយរូប ក្នុងមនុស្សលោកផង ស្រីទាំងឡាយនោះ ប្រាកដស្មើដោយរូបនៃនាង មិនមានក្នុងទេវគន្ធព្វ និងមនុស្សលោកឡើយ ម្នាលនាងមានអវយវៈខាងដើម (ភ្លៅ) ដ៏ល្អ អាត្មាសួរហើយ ចូរប្រាប់នាម និងគោត្រផង ផៅពង្សទាំងឡាយផង។

[៤១៦] (ទេវតា...) បពិត្រព្រាហ្មណ៍ លោកគង់នៅអាស្រ័យស្ទឹងឈ្មោះកោសិកី ជាទីរីករាយណា ខ្ញុំមានលំនៅត្រង់ខ្សែទឹកដ៏កាចមានអន្លង់ជាទីហូរទៅនៃទឹកដ៏ប្រសើរ អាស្រ័យនៅហើយ (ក្នុងស្ទឹងនោះ)។ ជ្រោះភ្នំដ៏ច្រើន កុះករដោយឈើផ្សេងៗ រមែងមានក្នុងទីចំពោះមុខខ្ញុំ រមែងហូរទៅ ក្នុងរដូវភ្លៀង។ម្យ៉ាងទៀត ស្ទឹងដ៏ច្រើន មានទឹកហូរចេញអំពីព្រៃ ទ្រទ្រង់នូវគំនរទឹកដ៏ខៀវ ស្ទឹងដ៏ច្រើន មានរូបភាពដូចជានាគ រមែងញ៉ាំងខ្ញុំឲ្យពេញដោយទឹក។ ដើមស្វាយ ដើមព្រីង ដើមខ្នុរសម្ល ដើមក្ទម្ព ដើមត្នោត និងដើមល្វា ជលជាតទាំងឡាយដ៏ច្រើន រមែងចូលទៅកាន់ស្ទឹងទាំងនោះរឿយៗ។ ផ្លែឈើណាមួយ នៅក្បែរមាត់ច្រាំងទាំងពីរ រមែងជ្រុះទៅក្នុងទឹក ផ្លែឈើនោះ រសាត់ទៅតាមអំណាចនៃខ្សែទឹកដោយឥតសង្ស័យ។ បពិត្រលោកជាអ្នកប្រាជ្ញ មានប្រាជ្ញាច្រើន លោកជ្រាបហេតុនុះហើយ សូមស្តាប់ពាក្យខ្ញុំចុះ បពិត្រព្រះជនាធិបតី សូមលោកកុំពេញចិត្តឡើយ ចូរបដិសេធនូវការជាប់ចំពាក់ដោយតណ្ហា។ បពិត្រព្រះរាជឫសីអ្នកញ៉ាំងដែនឲ្យចំរើន លោកកំពុងចំរើន (ដោយសាច់ និងឈាម) ប្រាថ្នាសេចក្តីស្លាប់ ដោយហេតុណា ខ្ញុំពុំសំគាល់នូវលោកថា ជាអ្នកចំរើនដោយប្រាជ្ញា

ដោយហេតុនោះទេ។ បិតាទាំងឡាយ (ព្រហ្ម) និងគន្ធព្វ ព្រមទាំងទេវតា រមែងដឹងនូវភាពនៃបុគ្គលនោះថា ជាអ្នកលុះក្នុងអំណាចនៃតណ្ហា ម្យ៉ាងទៀត ឥសីទាំងឡាយណាក្នុងលោក ជាអ្នកមានចិត្តសង្រួមហើយ មានតបៈ ឥសីទាំងឡាយនោះ រមែងដឹងឥតសង្ស័យ (សូម្បី) ពួកអ្នកមានយសជាអ្នកបម្រើ (ឥសីទាំងនោះ ក៏ដឹងការនោះតៗ គ្នាទៀត)។

[៤១៧] (តាបស...) បើ (នរជនណា) មិនគិតសម្លាប់បុគ្គលនោះទេ បាបក៏មិនចំរើនដល់នរជននោះ ដែលដឹងច្បាស់នូវធម៌ទាំងពួង របស់អ្នកប្រាជ្ញ យ៉ាងនេះផង ដឹងនូវការបែកធ្លាយ និងច្យុតិនៃជីវិតផង ម្នាលនាងជាធំ ដែលពួកឥសីដឹងច្បាស់ហើយ ប្រយោជន៍នៃសត្វលោក នាងដឹងច្បាស់ហើយយ៉ាងនេះ នាងឈ្មោះថាស្វែងរកនូវបាបកម្ម (ចំពោះខ្លួន) ព្រោះប្រទេចពាក្យមិនប្រសើរ។ ម្នាលនាងទេវធីតា មានត្រគាកសាយល្អ បើយើងនឹងស្លាប់លើត្រើយរបស់នាង កាលបើយើងស្លាប់ហើយ ដំណឹះដំនៀលនឹងបានមកនាងឯង ឥតសង្ស័យឡើយ។ ម្នាលនាងមានអវយវៈត្រង់កណ្តាលដ៏ល្អ ព្រោះហេតុនោះ នាងឯងចូររក្សានូវកម្មអាក្រក់ កាលបើយើងស្លាប់ហើយ កុំឲ្យជនទាំងអស់ជេរប្រទេចនាង ក្នុងកាលជាខាងក្រោយឡើយ។

[៤១៨] (ទេវតា...) ហេតុនេះ ខ្ញុំម្ចាស់ដឹងច្បាស់ហើយ ធម្មតា ស្តេចនេះមិនងាយអត់ទ្រាំបានទេ ណ្ហើយចុះ ខ្ញុំម្ចាស់នឹងប្រគេននូវខ្លួនខ្ញុំម្ចាស់ផង ប្រគេននូវស្វាយនោះផង ដល់លោកម្ចាស់ ដ្បិតលោកម្ចាស់បានលះបង់នូវកាមគុណទាំងឡាយ ដែលគេលះបង់បានដោយក្រ ហើយបានអធិដ្ឋាននូវសីល ជាគ្រឿងស្ងប់រម្ងាប់ផង នូវសុចរិតធម៌ផង។

បុគ្គលណា លះបង់នូវចំណងខាងដើម ហើយឋិតនៅក្នុងចំណងខាងចុងផង ប្រព្រឹត្តនូវអធម៌ផង បាបតែងចំរើនឡើងដល់បុគ្គលនោះ។ សូមលោកម្ចាស់មកចុះ ខ្ញុំម្ចាស់នឹងនាំលោកម្ចាស់ទៅឲ្យដល់ព្រៃស្វាយនោះ សូមលោកម្ចាស់មានសេចក្តីខ្វល់ខ្វាយតិចដោយពិតចុះ ខ្ញុំម្ចាស់នឹងនាំទៅដាក់ក្នុងព្រៃស្វាយដ៏ត្រជាក់នោះ សូមលោកម្ចាស់គង់នៅកុំមានសេចក្តីខ្វល់ខ្វាយ។ បពិត្រអរិន្ទមៈ ព្រៃស្វាយនោះ ពួកសត្វបក្សីមានកក្កុក់ស្រវឹងដោយរសនៃផ្កាឈើ ស្រែកបន្លឺឡើងហើយ ពួកក្រៀល ពួកក្ងោក ជាទិព្វ ពួកសត្វស្លាបឈ្មោះកោយដ្ឋិ និងឈ្មោះមធុសាលិយៈ យំជាមួយនឹងពួកហង្ស ពួកតាវៅ ដែលនៅក្នុងព្រៃស្វាយនោះ ក៏ញុំាងពួកសត្វទាំងនោះឲ្យភ្ញាក់ឡើងហើយ។ ដើមស្វាយទាំងឡាយក្នុងព្រៃនោះ មានចុងមែកដាបចុះ (ព្រោះទម្ងន់ផ្លែ) ប្រាកដស្មើដោយទីលានដែលពេញដោយកណ្តាប់ស្រូវ ដើមដកគាំ ស្រល់ និងកំទម្ពទាំងឡាយ មានចង្កោមផ្លែសំយុងចុះ ដូចធ្លាយផ្លែត្នោតទុំ។

[៤១៩] (តាបសនិយាយទៅនឹងប្រេតថា) អ្នកទ្រទ្រង់នូវផ្កាកម្រង ទ្រទ្រង់នូវឈ្នួត ប្រដាប់ដោយគ្រឿងអាភរណៈ ពាក់នូវពាហុរក្សវ័ត្ត (កងកន់) ប្រស់ព្រំដោយខ្លឹមចន្ទន៍ ឲ្យគេបម្រើក្នុងវេលាយប់ សោយនូវទុក្ខវេទនាក្នុងវេលាថ្ងៃ។ ស្រីទាំងឡាយ ១៦០០០ នេះ ជាស្រីបំរើរបស់អ្នក អ្នកជាបុគ្គលមានអានុភាពច្រើនយ៉ាងនេះ អស្ចារ្យគួរឲ្យព្រឺរោម។ ក្នុងកាលមុន អ្នកបានធ្វើអំពើបាបនាំមកនូវទុក្ខដល់ខ្លួនដូចម្តេច ដែលអ្នកធ្វើក្នុងមនុស្សលោក បានជាស៊ីនូវសាច់ខ្នង (របស់ខ្លួន)។

[៤២០] (ប្រេត...) ខ្ញុំបានរៀននូវវេទទាំងឡាយ ហើយជាប់ចំពាក់ក្នុងកាមទាំងឡាយ បានប្រព្រឹត្តមិនជាប្រយោជន៍ដល់ជនដទៃ អស់កាលដ៏យូរអង្វែង។ បុគ្គលណា ជាអ្នកស៊ីនូវសាច់ខ្នង (ញុះញង់គេ) បុគ្គលនោះ ក៏ខ្វារស៊ីនូវសាច់ខ្នងរបស់ខ្លួន ដូចខ្ញុំស៊ីក្នុងថ្ងៃនេះដែរ។

ចប់ កឹឆន្ទជាតក ទី១។

## កុម្ភជាតក ទី២

CS sut.kn.jat.512 | ភាគទី ៦០

### (៥១២. កុម្ភជាតកំ (២))

[៤២១] (ព្រះបាទសព្វមិត្ត ត្រាស់សួរថា) អ្នកជាអ្វី មកប្រាកដអំពីភពតាវត្តិង្ស (ប្រតិស្ឋាន) លើអាកាសនេះ រស្មីទាំងឡាយរបស់អ្នក ផ្សាយចេញអំពីខ្លួន ដូចព្រះចន្ទភ្លឺស្វាងក្នុងវេលាយប់ ឬដូចផ្លេកបន្ទោរ ឆ្វៀលឆ្វាត់ព្ធដ៏អាកាស។ អ្នកឯងដើរទៅមិនមានខ្យល់ ព្ធដ៏អាកាស អ្នកដើរក្តី ឈរក្តី ព្ធដ៏អាកាស ឫទ្ធិរបស់ពួកទេវតា ដែលមិនបាច់ដើរទៅកាន់ផ្លូវឆ្ងាយ (ដោយជើង) អ្នកបានធ្វើឲ្យដូចជាទីដំកល់ ចំរើនល្អ។ អ្នកឋិតនៅ ព្រោះអាស្រ័យនូវការទៅព្ធដ៏អាកាស តើអ្នកជាអ្វី (អ្នកនិយាយ) នូវសេចក្តីណាថា អ្នកទាំងឡាយ ចូរទិញឆ្នាំងចុះ ដូច្នេះ តើឆ្នាំងនេះសម្រាប់ធ្វើអ្វី ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុះដល់ខ្ញុំ។

[៤២២] (ព្រះឥន្ទ្រាធិរាជតបថា) នេះមិនមែនជាក្អមសប្បិទេ មិនមែនជាក្អមប្រេងទេ មិនមែនជាក្អមស្ករអំពៅទេ មិនមែនជាក្អមទឹកឃ្មុំទេ ទោសរបស់ក្អមមានច្រើន សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវទោសដ៏ច្រើន ដែលតាំងនៅក្នុងក្អមចុះ។ បុគ្គលដើរភ្លាត់ធ្លាក់ជ្រោះរណ្តៅ គុហា អណ្តូងជ្រាំ រណ្តៅជ្រាំ ទាំងបរិភោគនូវរបស់ដែលមិនគួរបរិភោគដ៏ច្រើន ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ បុគ្គលមិនជាធំក្នុងចិត្ត តែងដើរចប្រប់ ដូចគោស៊ីនូវបាយ សុរា ជាអ្នកមិនមានទីពឹង តែងចូលទៅច្រៀង ឬរាំ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ បុគ្គលអាក្រាត ដូចជាពួកអចេលកៈ ដើរទៅកាន់ចន្លោះថ្នល់ ក្នុងស្រុក មានចិត្តវង្វេង ដេកហួសវេលា ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ បុគ្គលក្រោកឡើង ទ្រេតទ្រោត ញ័រក្បាល ញ័រដើមដៃ បុគ្គលនោះ រាំដូចជារូបយន្តដែលធ្វើដោយឈើ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ជនទាំងឡាយ ត្រូវភ្លើងឆេះ រមែងដេកនៅ ឬត្រូវពួកចចកខាំស៊ី បានដល់នូវទោសត្រូវគេចង គេសម្លាប់ ទាំងសាបសូន្យនូវភោគៈ ព្រោះតែផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ បុគ្គលនិយាយនូវពាក្យ ដែលគេមិនគួរនិយាយ អង្គុយក្នុងទីប្រជុំ របូតសំពត់ស្លៀក ប្រឡាក់ប្រឡូស ដេកជ្រមុជក្នុងកំអួត ដល់នូវសេចក្តីវិនាសព្រោះផឹកសុរាណា សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ បុគ្គលលើកកំពើស មានភ្នែកក្រហម សំគាល់ថា ផែនដីទាំងមូលសុទ្ធតែជារបស់អញ សូម្បីស្តេចជាធំលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត ក៏មិនស្មើនឹងអញដែរ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ សុរាណា ដែលនាំឲ្យកើតមានះ និងការមើលងាយ នាំឲ្យឈ្លោះប្រកែក នាំឲ្យញុះញង់ នាំឲ្យមានពណ៌សម្បុរអាក្រក់ នាំឲ្យអាក្រាតសំពត់ ឲ្យរត់ផ្តេសផ្តាស ជាគតិ ជាលំនៅរបស់ពួកអ្នកលេងជាន់ចាស់ សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ត្រកូលទាំងឡាយស្តុកស្តម្ភ សាយភាយ (ដោយសំពត់ និងទ្រព្យសម្បត្តិ) មានទ្រព្យច្រើនពាន់ ត្រូវសុរានេះ ធ្វើកេរ្តិ៍មតិក ឲ្យដាច់សូន្យក្នុងលោក សូមព្រះអង្គទិញក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ជនទាំងឡាយ ញុំាទ្រព្យសម្បត្តិ ប្រាក់មាស ស្រែចម្ការ និងគោក្របី ឲ្យវិនាសអស់ ព្រោះតែសុរាណា (ម្យ៉ាងទៀត សុរាណា) ផ្តាច់បង់នូវត្រកូលអ្នកមានទ្រព្យទាំងឡាយ សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ បុរសមានសភាពភ្លើតភ្លើន តែងជេរនូវមាតា និងបិតា ទាំងចាប់ទោសម្តាយក្មេក ឬចាប់ទោសកូនប្រសាស្រី ព្រោះផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ស្រីមានសភាពភ្លើតភ្លើន តែងជេរនូវឪពុកក្មេក និងប្តី ចាប់ទោសខ្ញុំប្រុស ចាប់ទោសអ្នកបំរើ ព្រោះតែផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ បុគ្គលបៀតបៀនសមណៈ ឬព្រាហ្មណ៍ ដែលតាំងនៅក្នុងធម៌ តែងទៅកាន់អបាយ ដែលមានសេចក្តីបៀតបៀននោះជាហេតុ ព្រោះផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ជនទាំងឡាយប្រព្រឹត្តអាក្រក់ ដោយកាយ វាចា និងចិត្ត លុះប្រព្រឹត្តអាក្រក់ហើយ ទៅកាន់នរក ព្រោះផឹកសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ជនទាំងឡាយសូម្បីចំណាយប្រាក់ដ៏ច្រើន អង្វរមិនបាននូវបុរសណា

(ដែលមិនទាន់ផឹកសុរា) ក្នុងកាលមុនថា (អ្នកចូរពោលមុសាវាទ) បុរសនោះ លុះផឹកនូវសុរានោះរួចហើយ ក៏ពោលនូវពាក្យមុសាវាទបាន សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ កាលបើកិច្ចប្រញាប់កើតហើយ បុគ្គលនោះគេបញ្ជូនទៅក្នុងការបម្រើ ត្រូវគេសួរថា (អ្នកឯងមករកអ្វី) រមែងមិនដឹងសេចក្តី (ដែលគេសួរ) ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ពួកជនមានចិត្តប្រកបដោយសេចក្តីអៀនខ្មាស ធ្វើនូវភាពជាអ្នកមិនអៀនខ្មាសឲ្យប្រាកដក្តី ពួកជនជាអ្នកប្រាជ្ញ មានចិត្តស្ងប់រម្ងាប់ ទៅជាអ្នកប្រមាទដោយសេចក្តីស្រវឹង ហើយនិយាយពាក្យច្រើនក្តី ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ពួកជនដេកប្រគរគ្នា (ដូចជាកូនជ្រូក) មិនសីបាយ ដល់នូវការដេកជាទុក្ខលើផែនដីផង ដល់នូវភាពជាអ្នកមានសម្បុរអាក្រក់ផង ដល់នូវដំណិះដំនៀលផង ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ពួកជនដេកធ្លាក់កទន់រងៀក ដូចជាគោដែលគេសំពងនឹងញញួរ កម្លាំងនៃសុរា មិនមែននរជន គ្របសង្កត់បានដោយងាយទេ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ពួកមនុស្ស វៀរបង់នូវសុរាណា ដូចជាវៀរនូវពស់ ដែលមានពិសដ៏ពន្លឹក នរជនណា គួរផឹកនូវសុរានោះ ដែលមានពិស ស្មើដោយថ្នាំពិសក្នុងលោក សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ព្រះរាជបុត្តរបស់ព្រះបាទអន្ធកវេណ្ឌុ: (ជាបងប្អូនគ្នា) បានយាងទៅក្បែរឆ្នេរសមុទ្រ ក៏ប្រហារគ្នាទៅវិញទៅមកដោយអង្រែទាំងឡាយ ព្រោះផឹកនូវសុរាណា សូមព្រះអង្គទិញនូវក្អមនេះ ដ៏ពេញដោយសុរានោះចុះ។ ពួកអសុរជាអ្នកស្រវឹង ហើយច្យុតចាកតាវត្តិង្សទេវលោក ដែលទៀងទាត់ (ដោយអាយុ) ព្រមទាំងមាយា (របស់អសុរ) ព្រោះផឹកនូវសុរាណា បពិត្រមហារាជ អ្នកប្រាជ្ញកាលដឹងនូវទឹកស្រវឹងនេះថា ជារបស់ឥតប្រយោជន៍ ប្រាកដដូច្នោះ តើគួរផឹកនូវទឹកស្រវឹងនោះដូចម្តេចកើត។ ទឹកដោះជូរ ឬទឹកឃ្មុំ មិនមានក្នុងក្អមនោះទេ បពិត្រព្រះរាជា ព្រះនាមសព្វមិត្រ ព្រះអង្គជ្រាបច្បាស់យ៉ាងនេះហើយ សូមព្រះអង្គទិញនូវសុរាក្នុងក្អមនេះ ដែលខ្ញុំព្រះអង្គក្រាបទូលតាមសភាវៈយ៉ាងនេះចុះ។

[៤២៣] (ព្រះរាជា...) លោកមិនមែនជាឪពុក ឬម្តាយរបស់ខ្ញុំទេ ជាបុគ្គលទីទៃពីគ្នា តែជាអ្នកសង្គ្រោះដោយប្រយោជន៍ លោកប្រាថ្នានូវប្រយោជន៍ដ៏ឧត្តម ខ្ញុំនោះនឹងធ្វើតាមពាក្យលោកក្នុងថ្ងៃនេះ។ ខ្ញុំនឹងឲ្យនូវស្រុកសួយ ៥ ផង ខ្ញុំស្រី ១០០ ផង គោ ៧០០ ផង រាជរថ ១០ ទឹមដោយសេះអាជានេយ្យទាំងនេះផង ដល់លោក ។ជាអាចារ្យ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំ។

[៤២៤] (ព្រះឥន្ទ្រ...) បពិត្រព្រះរាជា ខ្ញុំស្រី ១០០ ចូរជារបស់ព្រះអង្គវិញចុះ ស្រុកសួយ និងគោទាំងឡាយ ចូរជារបស់ព្រះអង្គវិញចុះ រាជរថទាំងឡាយ ដែលទឹមដោយសេះអាជានេយ្យ ចូរជារបស់ព្រះអង្គវិញដែរ ខ្ញុំជាព្រះឥន្ទ្រ ជាធំជាងទេវតាជាន់តាវត្តិង្ស។ សូមព្រះអង្គសោយនូវក្រយាស្ងោយ ដែលលាយដោយសាច់ផង នូវបាយាសដែលលាយដោយសប្បិផង សូមព្រះអង្គសោយនូវនំសណ្តែកទាំងឡាយដ៏ផ្អែមផង បពិត្រព្រះជនិន្ទ សូមព្រះអង្គត្រេកអរក្នុងធម៌យ៉ាងនេះ អ្នកផងមិនតិះដៀលទេ ទៅកើតក្នុងឋានសួគ៌ចុះ។

ចប់ កុម្ភជាតក ទី២។

## ជយទ្ទិសជាតក ទី៣

CS sut.kn.jat.513 | ភាគទី ៦០

### (៥១៣. ជយទ្ទិសជាតកំ (៣ ))

[៤២៥] (មនុស្សយក្ស[30] ពោលថា) យូរណាស់ហើយ អាហារដ៏ច្រើនទើបកើតឡើងដល់យើងក្នុងពេលបាយ ក្នុងថ្ងៃទី ៧ នាថ្ងៃនេះ អ្នកទើបនឹងមកពីណា មួយទៀត អ្នកជាអ្វី អ្នកចូរប្រាប់រឿងនោះ (ដល់យើង) អ្នកចូរប្រាប់ជាតិ ឈ្មោះឲ្យយើងដឹងបាន។

[៤២៦] (ព្រះបាទជយទ្ទិសៈទ្រង់តបថា) ខ្ញុំជាស្តេចក្នុងក្រុងបញ្ចាល ឈ្មោះជយទ្ទិសៈ បើអ្នកឮហើយ ចូលមកកាន់ទីសម្លាប់ម្រឹគត្រាច់ទៅកាន់ទីខាងភ្នំ និងព្រៃទាំងឡាយ សូមអ្នកពិសារបស់ទម្រឹគ[31] នេះចុះ សូមលែងខ្ញុំក្នុងថ្ងៃនេះ។

[៤២៧] (យក្ស...) អ្នកឯងបៀតបៀនលោះ (នូវខ្លួន) ដោយម្រឹគជារបស់យើងដដែល អ្នកពោលនូវបសទម្រឹគណា បសទម្រឹគនុ៎ះជាអាហាររបស់យើងស្រាប់ យើងស៊ីនូវបសទម្រឹគនោះ បើចង់ស៊ី នឹងស៊ីជាខាងក្រោយ កាលនេះ មិនមែនជាកាលវិលាបទេ។

[៤២៨] (ព្រះរាជា...) បើខ្ញុំមិនរួចដោយការលោះទេ (អ្នកចូរកាន់យកពាក្យប្តេជ្ញា) ដើម្បី (ឲ្យខ្ញុំ) ទៅហើយត្រឡប់មកវិញក្នុងពេលព្រឹក ខ្ញុំជាអ្នករក្សានូវពាក្យសច្ចៈ ឲ្យនូវពាក្យប្តេជ្ញានោះដល់ព្រាហ្មណ៍ ហើយនឹងត្រឡប់មកវិញ។

[៤២៩] (យក្ស...) បពិត្រព្រះរាជា កម្មដូចម្តេច ដុតកំដៅព្រះអង្គដែលចូលមកកៀកនឹងសេចក្តីស្លាប់ហើយ សូមព្រះអង្គប្រាប់ដល់ខ្ញុំ ក្រែងយើងអាចអនុញ្ញាតឲ្យព្រះអង្គត្រឡប់មកក្នុងវេលាព្រឹកបាន។

[៤៣០] (ព្រះរាជា...) គោលបំណងក្នុងទ្រព្យ ខ្ញុំបានធ្វើហើយ ចំពោះព្រាហ្មណ៍ ពាក្យប្តេជ្ញានោះ ក៏ជាប់នៅមិនទាន់ដោះ ខ្ញុំជាអ្នករក្សានូវសច្ចៈ ឲ្យនូវពាក្យប្តេជ្ញានោះ ដល់ព្រាហ្មណ៍ហើយ នឹងត្រឡប់មកវិញ។

[៤៣១] (យក្ស...) គោលបំណងក្នុងទ្រព្យ ព្រះអង្គបានធ្វើហើយ ចំពោះព្រាហ្មណ៍ ពាក្យប្តេជ្ញានោះ ក៏ជាប់នៅមិនទាន់ដោះ ព្រះអង្គជាអ្នករក្សានូវសច្ចៈ ឲ្យនូវពាក្យប្តេជ្ញានោះ ដល់ព្រាហ្មណ៍ ហើយចូរត្រឡប់មកវិញ។

[៤៣២] (អភិសម្ពុទ្ធគាថា) ព្រះបាទជយទ្ទិសៈនោះ មានសេចក្តីប្រាថ្នាក្នុងកាម បានរួចអំពីដៃបោរិសាទៈ (អ្នកស៊ី) ហើយ យាងទៅកាន់ព្រះរាជមន្ទីររបស់ព្រះអង្គ ប្រទានពាក្យប្តេជ្ញានោះដល់ព្រាហ្មណ៍ ហើយក៏ត្រាស់ហៅព្រះរាជបុត្តព្រះនាមអលីនសត្តុមកថា។ (នែកូនយើងប្រគល់) នូវរាជសម្បត្តិ (ដល់អ្នកឯង) ក្នុងថ្ងៃនេះ បាឯងចូរអភិសេកចុះ បាឯង ចូរ (រក្សា) ធម៌ ក្នុងដែនទាំងឡាយផង ក្នុងពួកប្រជាជនផង ជនអ្នកមិនរក្សាធម៌ កុំឲ្យមានក្នុងដែនរបស់បាឯងឡើយ យើងនឹងទៅក្នុងសំណាក់នៃបោរិសាទ។

[៤៣៣] (អលីនសត្តុកុមារ) បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំ ធ្វើអំពើដូចម្តេច ទៀបព្រះបាទានៃព្រះអង្គ ឲ្យព្រះអង្គមិនសប្បាយព្រះហឫទ័យ ព្រះអង្គឲ្យទូលព្រះបង្គំជាខ្ញុំតាំងនៅក្នុងរាជ្យក្នុងថ្ងៃនេះ ដោយអំពើដែលនាំឲ្យព្រះអង្គមិនសប្បាយណា ទូលព្រះបង្គំជាខ្ញុំចង់ស្តាប់នូវអំពើដែលនាំឲ្យព្រះអង្គមិនសប្បាយនោះ ទូលព្រះបង្គំជាខ្ញុំ បើវៀរចាកព្រះអង្គហើយ មិនចង់បាននូវរាជ្យទេ។

[៤៣៤] (ព្រះរាជា...) ម្នាលកូន យើងនឹកមិនឃើញកំហុសរបស់អ្នក ព្រោះអំពើ និងវាចានេះទេ តែយើងបានធ្វើ (ពាក្យសច្ចៈ) ជាមួយនឹងបោរិសាទ យើងជាអ្នករក្សានូវពាក្យសច្ចៈ នឹងវិលទៅវិញ។

[៤៣៥] (ព្រះរាជកុមារ...) ទូលព្រះបង្គំជាខ្ញុំនឹងទៅ សូមព្រះអង្គគង់នៅក្នុងទីនេះចុះ ការរួចអំពីសំណាក់នៃបោរិសាទៈនោះ មិនមានដល់បុគ្គលកាលរស់នៅទេ បពិត្រព្រះរាជា បើព្រះអង្គយាងទៅ ទូលព្រះបង្គំជាខ្ញុំក៏ទៅដែរ ព្រះអង្គ និងទូលព្រះបង្គំជាខ្ញុំ ទាំងពីរនាក់នឹងមិននៅទេ។

[៩៣៦] (ព្រះរាជា...) ម្នាលកូន ធម៌នុ៎ះ ជាធម៌របស់ពួកសប្បុរសមែនហើយ ប៉ុន្តែយក្សមានជើងពពាល ដុតឆ្អើរអ្នកឯងជិតគល់ឈើស្រួច ហើយកំហែងស៊ីពេញទំហឹង ក្នុងកាលណា ការនោះ ទុកជាសេចក្តីស្លាប់របស់យើងក្នុងកាលនោះ។

[៩៣៧] (អលីនសត្តកុមារ) ទូលព្រះបង្គំជាខ្ញុំ នឹងយកជីវិតទៅប្តូរជីវិតរបស់ព្រះអង្គ សូមព្រះអង្គកុំយាងទៅក្នុងសំណាក់នៃបោរិសាទៈឡើយ ទូលព្រះបង្គំជាខ្ញុំ នឹងយកជីវិតនោះទៅប្តូរជីវិតរបស់ព្រះអង្គ ហេតុនោះ ទូលព្រះបង្គំជាខ្ញុំ ប្រាថ្នានូវសេចក្តីស្លាប់ ដើម្បីជីវិត (របស់ព្រះអង្គ)។

[៩៣៨] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះរាជបុត្តអ្នកមានប្រាជ្ញា ក៏ក្រាបថ្វាយបង្គំព្រះបាទាមាតា និងបិតា (ហើយចេញទៅ)។ ព្រះមាតានៃព្រះរាជកុមារនោះ មានសេចក្តីទុក្ខ ក៏ដួលក្រាបលើប្រឹថពី ឯព្រះបិតានៃព្រះរាជកុមារនោះ ផ្គងព្រះហស្តហើយទ្រង់ព្រះកន្សែង។

[៩៣៩] ព្រះបិតាជ្រាបនូវព្រះរាជកុមារនោះកំពុងយាងទៅ (ថាកូនរបស់អញ) ទៅក្នុងទីកំបាំងមុខ ហើយទ្រង់ផ្គងអញ្ជលី ថ្វាយបង្គំទេវតាថា សូមឲ្យព្រះរាជាព្រះនាមសោមៈ ព្រះរាជាព្រះនាមវរុណៈ ព្រះរាជាព្រះនាមបជាបតិ ព្រះចន្ទ្រ និងព្រះអាទិត្យទាំងនុ៎ះ គ្រប់គ្រងអ្នកម្នាលកូន អ្នក (ដែលយក្ស) អនុញ្ញាតហើយ ចូរត្រឡប់មកអំពីសំណាក់បោរិសាទៈដោយសុវត្ថិភាពចុះ។

[៩៤០] (ព្រះមាតា...) មាតានៃបុរសឈ្មោះរាមៈ ដែលទៅ (ក្នុងដែន) នៃព្រះរាជាទណ្ឌកី ជាស្ត្រីគ្រប់គ្រងល្អ បានធ្វើនូវសួស្តីណា យើងក៏ធ្វើនូវសួស្តីនោះដល់អ្នក ទេវតាទាំងឡាយ សូមរលឹកឃើញដោយពាក្យពិតនោះចុះ ម្នាលកូន បើយក្សអនុញ្ញាតឲ្យហើយ អ្នកចូរត្រឡប់មកវិញដោយសួស្តីចុះ។

[៩៤១] (ព្រះកនិដ្ឋភគិនី...) ខ្ញុំមិនរលឹកឃើញនូវសេចក្តីប្រទូស្តក្នុងចិត្តចំពោះអលីនសត្តកុមារ ក្នុងទីចំពោះមុខ ឬកំបាំងមុខដោយពិត សូមពួកទេវតារលឹកឃើញដោយពាក្យពិតនោះចុះ បពិត្រអ្នកបង បើយក្សអនុញ្ញាត សូមអ្នកបងត្រឡប់មកដោយសួស្តីចុះ។

[៩៤២] (អគ្គមហេសី...) បពិត្រស្វាមី ព្រះអង្គមិនប្រព្រឹត្តកន្លងចិត្តខ្ញុំម្ចាស់ផង ព្រះអង្គមិនមែនមិនជាទីស្រឡាញ់ដោយចិត្តរបស់ខ្ញុំម្ចាស់ផង ដោយហេតុណា (ហេតុនោះ) សូមទេវតាទាំងឡាយរលឹកឃើញដោយពាក្យសច្ចៈនុ៎ះចុះ បពិត្រស្វាមី បើយក្សអនុញ្ញាតហើយ សូមព្រះអង្គត្រឡប់មកវិញដោយសួស្តីចុះ។

[៩៤៣] (យក្ស...) អ្នកជាបុគ្គលមានមាឌធំ មានកាយត្រង់ មានមុខស្រស់ តើអ្នក (មក) អំពីទីណា អ្នកមិនដឹងនូវយើងដែលនៅក្នុងព្រៃទេ (ឬ) អ្នកណាដឹងនូវយើងជាបុគ្គលអាក្រក់ ជាអ្នកស៊ីនូវបុរស ហើយគប្បីមកក្នុងទីនេះ អ្នកទំនងជាមិនដឹងនូវសុវត្ថិភាព បានជាមកឬ។

[៩៤៤] (អលីនសត្តកុមារ) បពិត្រព្រានព្រៃ ខ្ញុំស្គាល់ថា អ្នកជាបុគ្គលស៊ីនូវបុរស ខ្ញុំមិនមែនជាមិនស្គាល់អ្នកដែលនៅក្នុងព្រៃទេ ឯខ្ញុំជាព្រះរាជបុត្តនៃព្រះបាទជយទ្ទិសៈ សូមអ្នកពិសាខ្ញុំក្នុងថ្ងៃនេះចុះ ឲ្យតែព្រះបិតារួច។

[៩៤៥] (យក្ស...) ខ្ញុំស្គាល់ថា អ្នកជាបុត្តរបស់ព្រះបាទជយទ្ទិសៈ សម្បុរមុខ របស់អ្នកទាំងពីរក៏ដូចគ្នា អ្នកណាប្រាថ្នាស្លាប់ ព្រោះឲ្យតែបិតារួច អំពើរបស់អ្នកនោះ ដែលអ្នកធ្វើហើយ ជាអំពើដែលគេធ្វើបានដោយកម្រក្រៃពេក។

[៩៤៦] (ព្រះរាជកុមារ...) ខ្ញុំមិនសំគាល់នូវអំពើបន្តិចបន្តួចថា គេធ្វើបានដោយក្រក្នុងហេតុនេះទេ បុគ្គលណា ប្រាថ្នាស្លាប់ ព្រោះឲ្យតែបិតារួចផង ព្រោះហេតុនៃមាតាផង បុគ្គលនោះ លុះទៅកាន់បរលោក ក៏ប្រកបដោយសេចក្តីសុខក្នុងឋានសួគ៌។

[៩៤៧] ខ្ញុំរលឹកមិនបាន នូវកិរិយាអាក្រក់របស់ខ្លួន ក្នុងទីវាល ឬទីកំបាំងដោយពិត ខ្ញុំជាអ្នកមានការកើត និងសេចក្តីស្លាប់កំណត់ដឹងហើយ ខ្ញុំ (មិនផុតពីសេចក្តីស្លាប់) ក្នុងលោកនេះយ៉ាងណា ក្នុងលោកខាងមុខក៏យ៉ាងនោះដែរ។ បពិត្រលោកមានអានុភាពច្រើន ឥឡូវនេះ លោកចូរពិសាខ្ញុំក្នុងថ្ងៃនេះចុះ ចូរលោកធ្វើនូវកិច្ចទាំងឡាយ ចំពោះសរីរៈនេះចុះ មួយទៀត ខ្ញុំនឹងទម្លាក់ខ្លួនអំពីចុងឈើជូនលោក កាលលោកឃ្លាន ចូរពិសាសាច់ខ្ញុំចុះ។

[៩៤៨] (យក្ស...) បពិត្ររាជបុត្ត អ្នកពេញចិត្តនឹងអំពើនេះ អ្នកលះបង់នូវជីវិត ព្រោះឲ្យបិតារួច ព្រោះហេតុនោះ អ្នកចូរជាអ្នកមានសភាពរួសរាន់ កាប់ឧសបង្កាត់ភ្លើងចុះ។

[៩៤៩] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះរាជបុត្តមានប្រាជ្ញា ក៏ប្រមូលនូវឧស ហើយដុតភ្លើងឲ្យឆេះធំឡើង រួចប្រាប់យក្សថា ឥឡូវនេះ ភ្លើងដ៏ធំនេះ ខ្ញុំបានបង្កាត់ឆេះហើយ។

[៩៥០] ឥឡូវនេះ លោកជាអ្នកធ្វើនូវការកំហែងខ្ញុំ ចូរពិសាខ្ញុំក្នុងថ្ងៃនេះចុះ លោកព្រឺរោមហើយសម្លឹងខ្ញុំញយៗ តើព្រោះហេតុអ្វី លោកឃ្លានចង់ស៊ីខ្ញុំយ៉ាងណាៗ ខ្ញុំនឹងធ្វើតាមពាក្យរបស់លោកយ៉ាងនោះៗ។

[៩៥១] (យក្ស...) នរណា គួរស៊ីបុគ្គលតាំងនៅក្នុងធម៌ និយាយពាក្យពិត ដឹងនូវពាក្យពេចន៍បែបអ្នក បុគ្គលណា ហ៊ានស៊ីនូវបុគ្គលពោលពាក្យសច្ចៈបែបអ្នក ក្បាលរបស់បុគ្គលនោះនឹងបែកជា ៧ ភាគ។

[៩៥២] (ព្រះរាជកុមារ...) អម្បាលដូចជាទន្សាយនោះ កាលសំគាល់នូវហេតុនេះ បានញ៉ាំងឥន្ទព្រាហ្មណ៍ ឲ្យនៅ (ដើម្បីឲ្យ) សរីរៈនៃខ្លួនម្នាលយក្ស ហេតុនោះឯង បានជាចន្ទិមទេវបុត្ត បង្ហូរចេញនូវសេចក្តីប្រាថ្នានោះ មានរូបទន្សាយបិតនៅសព្វថ្ងៃនេះ។

[៩៥៣] (យក្ស...) ព្រះចន្ទ្រ និងព្រះអាទិត្យរួចអំពីមាត់រាហូ ហើយរុងរឿងក្នុងថ្ងៃ ១៥ កើត យ៉ាងណាមិញ បពិត្រអ្នកមានអានុភាពច្រើន អ្នកបានរួចអំពីយើងឈ្មោះបោរិសាទហើយ ចូររុងរឿងក្នុងក្រុងកបិល្លពស្តុចុះ រួចចូរញ៉ាំងបិតា និងមាតាឲ្យរីករាយ ទាំងពួកញាតិទាំងអស់របស់អ្នក ក៏ចូរត្រេកអរចុះ។

[៩៥៤] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះរាជបុត្តមានប្រាជ្ញា ព្រះនាមអលីនសត្ត ដែលបោរិសាទនោះអនុញ្ញាតហើយ ក៏ធ្វើអញ្ជលីផ្គងឡើងចំពោះបោរិសាទ រួចត្រឡប់មកកាន់នគរកបិល្លពស្តុវិញដោយសួស្តី បានសេចក្តីសុខ ឥតមានរោគឡើយ។

[៩៥៥] ពួកមនុស្សនៅក្នុងនិគមក្តី ពួកមនុស្សនៅក្នុងជនបទក្តី ពួកពលដំរីក្តី ពលរថក្តី ពលថ្មើរជើងក្តីទាំងអស់ ក៏ប្រណម្យអញ្ជលីនមស្ការ ចូលទៅជិតអលីនសត្តកុមារថា យើងខ្ញុំសូមថ្វាយបង្គំចំពោះព្រះអង្គ ព្រះអង្គទ្រង់ធ្វើនូវអំពើដែលគេធ្វើបានដោយក្រ។

ចប់ ជយទ្ទិសជាតក ទី៣។

(៥១៤. ឆទ្ទន្តជាតកំ (៩ ))

[៤៥៦] (ព្រះបាទពារាណសីត្រាស់សួរថា) ម្នាលនាងសុភទ្ទា ជាស្រីមានអវយវៈដូចមាស មានសម្បុរលឿងខ្ចី មានសម្បុរដ៏ប្រសើរ ថ្វីក៏បានជានាងសោយសោក ម្នាលនាងមានភ្នែកពិសាល ថ្វីក៏បានជានាងស្រពោន ដូចផ្កាឈូកដែលគេច្របាច់។

[៤៥៧] (នាងសុភទ្ទាទេវីទូលថា) បពិត្រមហារាជ ចំណង់ប្លែក កើតឡើងដល់ខ្ញុំម្ចាស់ដោយការយល់សប្តិ តែចំណង់ប្លែករបស់ខ្ញុំម្ចាស់នោះ ហាក់ដូចជាមិនងាយរកបានទេ។

[៤៥៨] (ព្រះរាជា...) កាមគុណទាំងឡាយណាមួយជារបស់មនុស្សក្នុងលោកជាទីត្រេកអរនេះ កាមគុណទាំងអស់នោះ មានច្រើន សុទ្ធតែជារបស់យើង យើងនឹងឲ្យនូវចំណង់ប្លែកដល់នាង។

[៤៥៩] (នាងសុភទ្ទាទេវី...) បពិត្រព្រះសម្មតិទេព សូមឲ្យព្រានទាំងឡាយ ដែលមាននៅក្នុងដែនរបស់ព្រះអង្គ មកប្រជុំគ្នា ខ្ញុំម្ចាស់នឹងប្រាប់នូវចំណង់ប្លែករបស់ខ្ញុំម្ចាស់ ដល់ព្រានទាំងឡាយនុ៎ះ។

[៤៦០] (ព្រះរាជា...) ម្នាលនាងទេវី ពួកព្រានព្រៃទាំងនេះ ជាអ្នកមានថ្វីដៃ ជាអ្នកក្លៀវក្លា ស្គាល់ព្រៃផង ស្គាល់ម្រឹគផង សឹងតែជាអ្នកស៊ូលះបង់នូវជីវិត ក្នុងប្រយោជន៍របស់យើង។

[៤៦១] (នាងសុភទ្ទាទេវី...) ម្នាលលុទ្ទបុត្រទាំងឡាយ អ្នកទាំងឡាយ ទាំងប៉ុន្មាននាក់ ដែលមកប្រជុំគ្នាក្នុងទីនេះ ចូរស្តាប់ (ពាក្យរបស់ខ្ញុំចុះ) ខ្ញុំបានយល់សប្តិឃើញដំរីស មានភ្លុកប្រាំមួយ ខ្ញុំត្រូវការដោយភ្លុកដំរីសនោះ ជីវិត (របស់ខ្ញុំ) នឹងមិនមាន ព្រោះការមិនបានភ្លុកនោះ។

[៤៦២] (ពួកលុទ្ទបុត្រ...) បិតា និងជីតារបស់ទូលព្រះបង្គំជាខ្ញុំ មិនដែលឃើញ មិនដែលឮ នូវដំរីមានភ្លុកប្រាំមួយ ដែលព្រះរាជបុត្រីបានទ្រង់ព្រះសុបិនឃើញនោះទេ សូមព្រះនាងទ្រង់សវនិយប្រាប់នូវដំរីដ៏ប្រសើរប្រាកដដូច្នោះ ដល់ពួកទូលព្រះបង្គំជាខ្ញុំចុះ។

[៤៦៣] បណ្តាទិសទាំង ១០ នេះគឺ ទិសធំ ៤ ទិសតូច ៤ ទិសខាងលើ ១ ទិសខាងក្រោម ១ តើព្រះរាជបុត្រីទ្រង់ព្រះសុបិនឃើញដំរីដ៏ប្រសើរ មានភ្លុកប្រាំមួយ ឋិតនៅក្នុងទិសណា។

[៤៦៤] (ព្រះនាងសុភទ្ទាទេវី...) អ្នកចេញអំពីទីនេះ ដើរត្រង់ទៅទិសខាងជើង រំលងភ្នំធំទាំង ៧ ទៅ នឹងឃើញភ្នំធំលើសលុបមួយឈ្មោះសុវណ្ណបស្សៈ ជាភ្នំមានផ្កាឈើរីកព្រោងព្រាត កុះករដោយពួកកិន្នរ។ អ្នកចូរឡើងកាន់ភ្នំ ជាលំនៅរបស់ពួកកិន្នរនោះ ហើយរមិលមើលនូវទីជិតនៃជើងភ្នំ គ្រានោះ អ្នកនឹងឃើញនូវស្តេចជ្រៃមួយដើម មានឫស ៨០០០ មានពណ៌ប្រាកដស្មើដោយមេឃ។ ឯស្តេចដំរីមានភ្លុកប្រាំមួយ មានខ្លួនសសុទ្ធ ដែលពួកដំរីដទៃគ្របសង្កត់បានដោយក្រ តែងនៅជិតដើមជ្រៃនោះ ដំរីទាំងឡាយ ៨០០០ មានភ្លុកងដូចចន្ទោលរទេះ មានប្រក្រតីទៅប្រហារដោយសន្ទុះដូចជាខ្យល់ តែងរក្សានូវស្តេចដំរីនោះ។ ពួកដំរីទាំង ៨០០០ នោះ ឈរដកដង្ហើមខ្លាំងៗ តែងក្រោធចំពោះវត្ថុ សូម្បីដែលខ្យល់បក់ត្រូវហើយ មួយទៀត បើវាឃើញមនុស្សក្នុងទីនោះហើយ ក៏ធ្វើឲ្យទៅជាផេះ សូម្បីតែធូលី គឺផេះរបស់មនុស្សនោះ ក៏មិនឲ្យមានឡើយ។

[៤៦៥] (សោណុត្តរព្រានព្រៃ...) បពិត្រព្រះនាងទេវី គ្រឿងប្រដាប់ទាំងឡាយដ៏ច្រើន ដែលគេធ្វើដោយមាសក្តី កែវមុក្តាក្តី កែវមណីក្តី គ្រឿងប្រដាប់ជាវិការៈនៃកែវពៃទូរ្យក្តី សឹងមានក្នុងរាជត្រកូល ចុះព្រះនាងមានប្រាថ្នានឹងសម្លាប់ដំរីមានភ្លុកប្រាំមួយ យកមកធ្វើគ្រឿងប្រដាប់ជាវិការៈនៃភ្លុកឬ ឬក៏ព្រះនាងចង់សម្លាប់ពួកលុទ្ទបុត្រ (កូនព្រាន)។

[៤៦៦] (ព្រះនាងសុភទ្ទាទេវី...) ម្នាលព្រានព្រៃ (មិនមែនដូច្នោះទេ) យើងជាស្រីច្រណែនផង ជាស្រីដល់នូវសេចក្តីទុក្ខផង យើងរឭកឃើញ (នូវពៀរ) ក្នុងខាងដើម (ដែលដំរីនោះធ្វើហើយដល់យើង) ផង បានជាចេះតែស្គាំងស្គម ម្នាលព្រានព្រៃ អ្នកចូរធ្វើសេចក្តីនេះដល់យើងចុះ យើងនឹងឲ្យស្រុកសួយ ៥ ដល់អ្នក។

[៤៦៧] (សោណុត្តរព្រានព្រៃ...) ដំរីឆទ្ទន្តនោះ តែងនៅត្រង់ទីណា តែងចូលទៅឈរក្នុងកន្លែងណា ផ្លូវដូចម្តេចដែលដំរីឆទ្ទន្តចុះទៅងូតទឹក ស្តេចដំរីឆទ្ទន្តនោះ ងូតទឹកតើដូចម្តេច យើងខ្ញុំធ្វើម្តេចនឹងដឹងដំណើរនៃដំរីនោះបាន។

[៤៦៨] (ព្រះនាងសុភទ្ទាទេវី...) ត្រង់ទីកន្លែងដែលដំរីនៅនោះ មានស្រះបោក្ខរណីនោះនៅជិត ជាស្រះគួររីករាយផង មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើនផង (មានកុមុទ ឧត្បល និងឈូក) មានផ្ការីកស្គុះស្គាយផង ដេរដាសដោយពួកភមរជាតិផង ស្តេចដំរីដ៏ប្រសើរនោះ តែងងូតទឹកក្នុងស្រះនុ៎ះឯង។ ដំរីឆទ្ទន្តនោះ ជាដំរីសសុទ្ធ មានស្បៀក និងអវយវៈស ដូចផ្កាឈូកស លាងជំរះនូវក្បាល រួចហើយក៏ទ្រទ្រង់នូវផ្កាឧត្បលជាដើម ត្រេកអររីករាយពន់ពេក ក៏ឲ្យមេដំរីជាមហេសីឈ្មោះនាងសព្វសុភទ្ទា ដើរពីខាងមុខ ហើយដើរសំដៅទៅកាន់ទីកន្លែងនៅរបស់ខ្លួន។

[៤៦៩] (អភិសម្ពុទ្ធគាថា) ព្រានព្រៃនោះ បានរៀនពាក្យក្នុងទីនោះហើយ ក៏ចាប់យកនូវបំពង់ព្រួញ និងធ្នូ (ដើររម្លង) ភ្នំធំទាំង ៧ ក៏ពិចារណាមើលទៅ (ឃើញ) ភ្នំធំខ្ពស់មួយ ឈ្មោះសុវណ្ណបស្សៈ។ ព្រានព្រៃបានឡើងទៅកាន់ភ្នំ ជាកន្លែងនៅនៃពួកកិន្នរ ក៏រមិលមើលនូវទីជិតនៃជើងភ្នំ បានឃើញស្តេចជ្រៃធំមួយដើម មានសម្បុរប្រាកដស្មើដោយមេឃ មានឫស ៨០០០ ជិតជើងភ្នំនោះ។ បានឃើញដំរីមានភ្លុក ៦ ជាដំរីសសុទ្ធ ដែលពួកដំរីដទៃ គ្របសង្កត់បានដោយក្រ នៅក្រោមដើមជ្រៃនោះ ពួកដំរីទាំង ៨០០០ មានភ្លុកង ដូចជាចន្ទោលរថ មានប្រក្រតីទៅប្រហារពួកដំរីជាបច្ចាមិត្ត ដោយសន្ទុះដ៏លឿនដូចជាខ្យល់ តែងរក្សានូវស្តេចដំរីនោះ។ បានឃើញស្រះបោក្ខរណី នៅជិតដើមជ្រៃនោះ ជាទីគួររីករាយ មានកំពង់ទឹកដ៏ល្អផង មានទឹកដ៏ច្រើនផង (មានផ្កាកុមុទ ឧត្បល និងឈូក) រីកស្គុះស្គាយផង ដេរដាសដោយពួកភមរជាតិផង ជាទីសម្រាប់ងូតរបស់ស្តេចដំរីដ៏ប្រសើរនោះ។ បានឃើញនូវការដើរទៅ និងការឈរនៅ នៃដំរីដ៏ប្រសើរផង ឃើញផ្លូវរបស់ដំរីដ៏ប្រសើនោះទៅងូតទឹកផង ព្រានព្រៃជាអនរិយជន បានប្រកប (កិច្ចការស្រេច) ដោយការលុះក្នុងអំណាចនៃចិត្ត ក៏បានជីករណ្តៅ។

[៤៧០] (អភិសម្ពុទ្ធគាថា) ព្រានព្រៃ ជាអ្នកធ្វើអំពើអាក្រក់ ជីករណ្តៅហើយ គ្របដោយផែនក្តារទាំងឡាយ រួចបញ្ចូលខ្លួន និងធ្នូរ (ទៅក្នុងរណ្តៅនោះ) ហើយបាញ់នូវដំរី ដែលដើរមកក្បែរខាង (រណ្តៅរបស់ខ្លួន) ដោយព្រួញដ៏ថ្លោស។ ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយ ក៏បន្លឺនូវកោញ្ចនាទដ៏ពន្លឹក ពួកដំរីទាំងអស់ ក៏បន្លឺនូវសម្លេងមានសភាពដ៏ពន្លឹក ដំរីទាំងនោះ ក៏ធ្វើនូវស្មៅ និងមែកឈើឲ្យខ្ទេចខ្ទី ហើយស្ទុះស្ទារទៅទាំង ៨ ទិសជុំវិញ។ ដំរីដ៏ប្រសើរ ក៏ចាប់ព្រាននោះ ដោយបំណងថា អញនឹងសម្លាប់ព្រានព្រៃនុ៎ះ ក៏ឃើញនូវសំពត់កាសាវៈ ដែលជា

ទង់ជ័យរបស់ពួកឥសី ដំរីដ៏ប្រសើរត្រូវសេចក្តីទុក្ខប៉ះពាល់ហើយ កំមានសញ្ញាកើតឡើងថា ធម្មតា បុគ្គលប្រើប្រាស់ទង់ជ័យព្រះអរហន្ត មានសភាពដែលសប្បុរសមិនគួរសម្លាប់។

[៤៧១] (ដំរីឆទ្ទន្ត...) បុគ្គលណា មិនទាន់អស់ទឹកចត់ គឺកិលេស ជាអ្នកប្រាសចាកការទូន្មាននូវឥន្ទ្រិយ និងវចីសច្ចៈ និងស្លៀកដណ្តប់សំពត់កាសាវៈ បុគ្គលនោះ មិនគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈទេ។ ចំណែកបុគ្គលណា ខ្ជាក់ចោលនូវទឹកចត់ គឺកិលេស តាំងមាំក្នុងសីលទាំងឡាយ ជាអ្នកប្រកបដោយការទូន្មាននូវឥន្ទ្រិយ និងវចីសច្ចៈ បុគ្គលនោះឯង ទើបគួរនឹងស្លៀកដណ្តប់សំពត់កាសាវៈ។

[៤៧២] (អភិសម្ពុទ្ធគាថា) ដំរីដ៏ប្រសើរ ត្រូវព្រានព្រៃបាញ់ហើយដោយសរដ៏ថ្លោស មិនមានចិត្តប្រទូស្ត បាននិយាយនឹងព្រានព្រៃថា នែសម្លាញ់ អ្នកត្រូវការអ្វី តើព្រោះហេតុអ្វី បានជាអ្នកសម្លាប់យើង ម្យ៉ាងទៀត ការប្រកបនេះ របស់បុគ្គលណា។

[៤៧៣] (ព្រានព្រៃ...) បពិត្រដំរីដ៏ចំរើន ព្រះមហេសីរបស់ស្តេចក្នុងដែនកាសីនោះ ឈ្មោះនាងសុភទ្ទា ដែលគេបូជាហើយក្នុងរាជត្រកូល ព្រះនាងបានឃើញអ្នក ហើយប្រាប់ខ្ញុំ ព្រះនាងក៏មានព្រះសវនីយនឹងខ្ញុំថា យើងត្រូវការដោយភ្លុកទាំងឡាយ។

[៤៧៤] (ដំរីឆទ្ទន្ត...) ព្រះរាជបុត្រីនោះ ដឹងថា គូនៃភ្លុកទាំងឡាយរបស់បិតា និងជីតាទាំងឡាយរបស់យើង មានច្រើនណាស់ តែនាងជាស្រីក្រោធ ត្រូវការសម្លាប់ ជាស្រីល្ងង់ បានចងពៀរ (នឹងយើង)។ នែព្រានព្រៃ អ្នកចូរក្រោកឡើង ចាប់នូវរណារ ហើយអារនូវភ្លុកទាំងគូនេះចុះ ទាន់ខ្ញុំមិនទាន់ស្លាប់ អ្នកឯងគប្បីទូលព្រះរាជបុត្រី ដែលមានសេចក្តីក្រោធនោះថា ដំរីដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំបានសម្លាប់ហើយ សូមព្រះនាងទទួលយក នេះជាភ្លុករបស់ដំរីនោះ។

[៤៧៥] ព្រានព្រៃនោះ ក្រោកឈរឡើង ហើយចាប់រណារ អារនូវភ្លុកនៃដំរីដ៏ប្រសើរ ហើយក៏យកនូវភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី រួចដើរចៀសចេញទៅអំពីទីនោះយ៉ាងឆាប់។

[៤៧៦] (អភិសម្ពុទ្ធគាថា) ពួកដំរី ត្រូវភ័យ (អំពីសេចក្តីស្លាប់) បៀតបៀនហើយ ដល់នូវសេចក្តីទុក្ខព្រួយ ព្រោះគេសម្លាប់នូវដំរីដ៏ប្រសើរ បានស្ទុះទៅគ្រប់ទិសទាំង ៨ លុះមិនឃើញបុរសជាសត្រូវនឹងដំរី ក៏ត្រឡប់មកកាន់ទីរបស់ស្តេចដំរីដ៏ប្រសើរវិញ។

[៤៧៧] ដំរីដ៏ប្រសើរទាំងនោះ កន្ទក់កន្ទេញ ពាទ់ក្នុងទីនោះ ហើយរោយរាយនូវអាចម៍ដី លើក្បាលរបស់ខ្លួន ដំរីទាំងអស់នោះ ក៏ឲ្យមេដំរីជាមហេសី ឈ្មោះសព្វសុភទ្ទា ដើរមុខ មកកាន់ទីនៅរបស់ខ្លួន។

[៤៧៨] ព្រានព្រៃនោះ បាននាំយកភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ជាភ្លុកល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ភ្លឺសព្វដោយរស្មីមានពណ៌ដូចជាមាស ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះ ក៏បង្អោននូវភ្លុកទាំងឡាយថ្វាយព្រះរាជកញ្ញាថា ដំរីដ៏ប្រសើរ ទូលព្រះបង្គំជាខ្ញុំសម្លាប់បានហើយ សូមព្រះនាងទទួលយក នេះជាភ្លុករបស់ដំរីនោះ។

[៤៧៩] ព្រះរាជកញ្ញានោះ ទតឃើញភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ដែលធ្លាប់ជាប្តីជាទីស្រឡាញ់អំពីជាតិមុន ក៏បែកហឫទ័យក្នុងទីនោះឯង ហេតុនោះ ព្រះនាងជាស្រីល្ងង់ បានសោយព្រះវិលាល័យទៅ។

[៤៨០] (ព្រះធម្មសង្គាហកត្ថេរ...) ព្រះពុទ្ធ ព្រះអង្គបានសម្រេចនូវសម្ពោធិញ្ញាណផង មានអានុភាពច្រើនផង បានធ្វើនូវការញញឹមក្នុងកណ្តាលពពួកបរិស័ទ ពួកភិក្ខុមានចិត្តរួចស្រឡះ ក៏ក្រាបបង្គំទូលសួរថា ព្រះពុទ្ធទាំងឡាយ មិនដែលធ្វើនូវការញញឹម ឲ្យប្រាកដដោយឥតហេតុទេ។

អ្នកទាំងឡាយ បានឃើញនាងកុមារីណានៅជំទង់ ស្លៀកសំពត់កាសាវៈ ជាអ្នកបួស នាងកុមារីនោះ ក្នុងកាលនោះ គឺព្រះរាជកញ្ញា ឯស្តេចដំរីក្នុងកាលនោះ គឺតថាគតឯង ព្រានព្រៃណា កាន់យកនូវភ្លុកទាំងឡាយនៃដំរីដ៏ប្រសើរ ជាភ្លុកដ៏ល្អស្អាត មិនមានភ្លុកឯទៀតប្រៀបផ្ទឹមបានលើផែនដី ហើយចូលទៅកាន់កាសីបុរី ព្រានព្រៃនោះក្នុងកាលនោះ គឺទេវទត្ត។ ព្រះពុទ្ធ ព្រះអង្គប្រាសចាកសេចក្តីក្រវល់ក្រវាយ ប្រាសចាកសេចក្តីសោក ប្រាសចាកនូវកូនសរ គឺរាគៈ បានជ្រាបច្បាស់ដោយព្រះអង្គឯង ហើយទ្រង់សំដែងនូវចរិតខ្ពស់ និងទាបអំពីដើមនេះ ដែលអន្ទោលទៅអស់កាលដ៏យូរ ហាក់ដូចមិនកន្លងថ្ងៃ។

ម្នាលភិក្ខុទាំងឡាយ កាលនោះ តថាគតនៅក្នុងទីនោះ កាលនោះ តថាគតជាស្តេចដំរី អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ។

ចប់ ឆទ្ទន្តជាតក ទី៤។

## សម្ភវជាតក ទី៥

CS sut.kn.jat.515 | ភាគទី ៦០

### (៥១៥. សម្ភវជាតកំ (៥ ))

[៤៨១] (ព្រះបាទធនញ្ជយកោរព្យៈ ត្រាស់សួរថា) នែសុចីរតៈ យើងបាននូវរាជសម្បត្តិផង បាននូវភាពជាធំផង យើងប្រាថ្នាដើម្បីដល់នូវភាពជាធំ ប្រាថ្នាដើម្បីគ្រួតត្រានូវផែនដីនេះ។ (យើងប្រកប) ដោយធម៌ មិនប្រកបដោយអធម៌ទេ ព្រោះអធម៌មិនពេញចិត្តដល់យើងឡើយ ម្នាលសុចីរតៈ ធម៌ជាចរិតរបស់ព្រះរាជា ពួកជនត្រូវតែធ្វើ។ នែព្រាហ្មណ៍ យើងដែលពួកជនមិននិន្ទា ក្នុងលោកនេះ ដោយអត្ថ និងធម៌ណាផង មិននិន្ទាក្នុងបរលោក ដោយអត្ថ និងធម៌ណាផង គប្បីដល់នូវឥស្សរិយយស ក្នុងទេវលោក និងមនុស្សលោក ដោយអត្ថ និងធម៌ណាផង។ នែព្រាហ្មណ៍ យើងប្រាថ្នាដើម្បីធ្វើនូវអត្ថ និងធម៌នោះៗ នែព្រាហ្មណ៍ អ្នកដែលយើងសួរហើយ ចូរប្រាប់នូវអត្ថ និងធម៌នោះ។

[៤៨២] (សុចីរតព្រាហ្មណ៍ ក្រាបទូលថា) បពិត្រព្រះខត្តិយរាជ ព្រះអង្គប្រាថ្នាដើម្បីធ្វើនូវអត្ថ និងធម៌ណា តែវៀរចាកវិធុរព្រាហ្មណ៍ហើយ បុគ្គលដទៃ មិនគួរនឹងប្រាប់នូវអត្ថ និងធម៌នោះបានទេ។

[៤៨៣] (ព្រះរាជា...) នែសុចីរតៈ អ្នកចូរមកនេះ អ្នកឯងត្រូវយើងប្រើទៅ អ្នកចូរទៅកាន់សំណាក់នៃវិធុរព្រាហ្មណ៍ ចូរនាំយកនូវផ្កានៃមាសនេះទៅចុះ អ្នកចូរឲ្យនូវផ្កានៃមាសនេះ ជាគ្រឿងបូជាដល់ការប្រៀនប្រដៅនូវអត្ថ និងធម៌។

[៤៨៤] (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់នៃវិធុរព្រាហ្មណ៍ សុចីរតៈ ជាមហាព្រាហ្មណ៍ ក៏បានឃើញវិធុរព្រាហ្មណ៍នោះ កំពុងតែបរិភោគក្នុងផ្ទះរបស់ខ្លួន។

[៩៨៥] (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់មានព្រះឱង្ការថា អ្នកចូរសួរនូវអត្ថ និងធម៌ បពិត្រវិធុរ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថ និងធម៌នោះ។

[៩៨៦] (វិធុរព្រាហ្មណ៍...) ម្នាលព្រាហ្មណ៍ ខ្ញុំ (គិតថា) អញនឹងបិទនូវទន្លេគង្គា តែមិនអាចបិទនូវទន្លេដ៏ធំនោះបាន ព្រោះហេតុនោះ ឱកាសនោះ នឹងមានដូចម្ដេចកើត ខ្ញុំដែលអ្នកសួរហើយ មិនអាចដើម្បីប្រាប់នូវអត្ថ និងធម៌បានទេ។ តែខ្ញុំមានកូនប្រុសមួយឈ្មោះភទ្រការ ជាឱរស ជាកូនបង្កើតរបស់ខ្ញុំ ម្នាលព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរអត្ថ និងធម៌ ចំពោះភទ្រការនោះចុះ។

[៩៨៧] (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់ភទ្រការកុមារ សុចីរតៈ ជាមហាព្រាហ្មណ៍ បានឃើញភទ្រការកុមារនោះ កំពុងអង្គុយនៅក្នុងផ្ទះរបស់ខ្លួន។

[៩៨៨] (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថ និងធម៌ ម្នាលភទ្រការកុមារ ព្រោះហេតុនោះ អ្នកចូរប្រាប់នូវអត្ថ និងធម៌ដល់ខ្ញុំ។

[៩៨៩] (ភទ្រការកុមា...) ខ្ញុំទើបទម្លាក់ចោលនូវអម្រែកសាច់ហើយ ដេញតាមនូវទន្សោង ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់នូវអត្ថ និងធម៌បានទេ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ឈ្មោះសញ្ជ័យ បពិត្រសុចីរតព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរនូវអត្ថ និងធម៌ ចំពោះសញ្ជ័យនោះចុះ។

[៩៩០] (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់សញ្ជយកុមារ សុចីរតៈ ជាមហាព្រាហ្មណ៍ បានឃើញនូវសញ្ជ័យកុមារនោះ អង្គុយក្នុងកណ្ដាលបរិស័ទរបស់ខ្លួន។

[៩៩១] (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូត ព្រះបាទធនញ្ជយកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទធនញ្ជយកោរព្យៈ ជាយុធិដ្ឋិលគោត្រ មានព្រះឱង្ការថា អ្នកចូរសួរនូវអត្ថ និងធម៌ ម្នាលសញ្ជយកុមារ ព្រោះហេតុនោះ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថ និងធម៌។

[៩៩២] (សញ្ជយកុមារ...) បពិត្រសុចីរតព្រាហ្មណ៍ មច្ចុតែងលេបខ្ញុំរាល់ល្ងាចរាល់ព្រឹក សព្វៗ កាល ខ្ញុំដែលអ្នកសួរហើយ មិនអាចនឹងប្រាប់នូវអត្ថ និងធម៌ដល់អ្នកបានទេ។ បពិត្រសុចីរតព្រាហ្មណ៍ ខ្ញុំមានប្អូនប្រុសម្នាក់ ឈ្មោះសម្ភវៈ បពិត្រព្រាហ្មណ៍ ព្រោះហេតុនោះ អ្នកចូរទៅសួរនូវអត្ថ និងធម៌ចំពោះសម្ភវៈនោះចុះ។

[៩៩៣] (សុចីរតព្រាហ្មណ៍...) ម្នាលអ្នកដ៏ចំរើន បញ្ហាធម៌ក៏អស្ចារ្យម្ល៉េះ សម្ភវកុមារនេះ យើងមិនពេញចិត្តទេ ព្រោះជន ៣ នាក់ ឪពុក និងកូនទាំងនោះ មិនដឹងច្បាស់ដោយប្រាជ្ញាទៅហើយ។ អ្នកទាំងឡាយដែលខ្ញុំសួរហើយ មិនអាចប្រាប់នូវអត្ថ និងធម៌បាន ចំណង់បើកូនក្មេង ដែលខ្ញុំសួរអត្ថ និងធម៌ហើយ គប្បីដឹងដូចម្ដេចកើត។

[៩៩៤] (សញ្ជយកុមារ...) បពិត្រសុចីរតព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះថា នៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថ និងធម៌។ ព្រះចន្ទ្រ ប្រាសចាកមន្ទិល កាលដើរទៅតាមអាកាសធាតុ រុងរឿងកន្លងនូវពួកផ្កាយទាំងអស់ក្នុងលោក ដោយពន្លឺ យ៉ាងណាមិញ បពិត្រសុចីរតព្រាហ្មណ៍ សម្ភវកុមារ ពិតជានៅក្មេងមែន (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ លោកកុំសំគាល់នូវសម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថ និងធម៌។ បពិត្រព្រាហ្មណ៍ បណ្ដាខែខាងគិម្ហរដូវទាំងឡាយ ខែចែត្ររុងរឿងដោយផ្កាឈើទាំងឡាយ ជាងខែទាំងឡាយដទៃឯទៀត យ៉ាងណាមិញ។ សម្ភវកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់សម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថ និងធម៌។ បពិត្រព្រាហ្មណ៍ ភ្នំគន្ធមាទនៈមានទឹកសន្សើម ជាលំនៅនៃពួកទេវតា ដេរដាសដោយដើមឈើផ្សេងៗទាំងឡាយផង ដោយឱសធជាទិព្វទាំងឡាយផង រមែងញុំាងទិសទាំងឡាយឲ្យភ្លឺច្បាស់ផង ផ្សាយទៅកាន់ទិសទាំងឡាយ (ដោយក្លិនក្រអូប) ផង យ៉ាងណាមិញ។ សម្ភវកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថ និងធម៌។ បពិត្រព្រាហ្មណ៍ ភ្លើងប្រក្រតី ប្រកបដោយអណ្ដាត មានអំណាច កាលឆេះនូវគុម្ពឈើក្នុងព្រៃ មិនចេះឆ្អែត រមែងញុំាងពណ៌ខ្មៅឲ្យប្រព្រឹត្តទៅ ជាសភាវៈឆេះនូវខ្លាញ់ មានផ្សែងជាទង់ ឆេះនូវដងព្រៃស្ងួត មានរបស់សម្រាប់ឆេះដ៏ច្រើន រមែងរុងរឿងលើកំពូលភ្នំ ក្នុងវេលាយប់យ៉ាងណាមិញ។ សម្ភវកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថ និងធម៌។ ជនទាំងឡាយ ស្គាល់សេះដ៏ចំរើនដោយល្បឿនផង ស្គាល់គោបម្រើក្នុងការផ្ទុកផង ស្គាល់មេគោដោយរីតនូវទឹកដោះផង ស្គាល់អ្នកប្រាជ្ញកាលនិយាយផង យ៉ាងណាមិញ។ សម្ភវកុមារ ពិតមែនតែនៅក្មេង (តែរុងរឿងកន្លងនូវពួកបណ្ឌិតដ៏សេស) ដោយបញ្ញា និងការព្យាយាម ក៏យ៉ាងនោះដែរ បពិត្រព្រាហ្មណ៍ លោកកុំសំគាល់នូវសម្ភវកុមារនោះថានៅក្មេង ហើយមិនសួរ ត្រូវតែសួរនូវសម្ភវកុមារ ទើបដឹងនូវអត្ថ និងធម៌។

[៩៩៥] (អភិសម្ពុទ្ធគាថា) សុចីរតព្រាហ្មណ៍ ជាភារទ្វាជគោត្រនោះ បានទៅកាន់សំណាក់នៃសម្ភវកុមារ សុចីរតៈ ជាមហាព្រាហ្មណ៍ បានឃើញនូវសម្ភវកុមារនោះ កំពុងលេងខាងក្រៅទីលំនៅ។

[៩៩៦] (សុចីរតព្រាហ្មណ៍...) ខ្ញុំជាទូតរបស់ព្រះបាទកោរព្យៈដ៏មានយស ទ្រង់ប្រើមក ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ ទ្រង់ត្រាស់ថា អ្នកចូរសួរនូវអត្ថ និងធម៌ នៃសម្ភវកុមារ ព្រោះហេតុនោះ នាងឯង ដែលខ្ញុំសួរហើយ ចូរប្រាប់នូវអត្ថ និងធម៌។

[៩៩៧] (សម្ភវកុមារ...) បើដូច្នោះ អ្នកឈ្លាសវៃ (និយាយ) យ៉ាងណា ខ្ញុំនឹងប្រាប់អ្នកយ៉ាងនោះ ព្រះរាជានឹងទ្រង់ជ្រាបនូវប្រស្នានោះ ទោះបីព្រះអង្គធ្វើតាមក្ដី មិនធ្វើតាមក្ដី។

[៩៩៨] បពិត្រសុចីរតព្រាហ្មណ៍ បុគ្គលដែលព្រះរាជាសួរថា (យើងធ្វើកុសល) ក្នុងថ្ងៃនេះឬ គប្បីក្រាបទូលថា ក្នុងថ្ងៃស្អែកវិញ កាលបើសេចក្ដីត្រូវការ កើតឡើងហើយ ព្រះបាទកោរព្យៈ ជាយុធិដ្ឋិលគោត្រ កុំធ្វើតាមពាក្យ (នោះ) ហើយនៅស្ងៀមឡើយ បុគ្គលដែលព្រះរាជាសួរហើយ គប្បីក្រាបបង្គំទូលនូវខន្ធបញ្ចកៈ ជាខាងក្នុងតែម្យ៉ាង សូមព្រះរាជាកុំសេពនូវផ្លូវខុស ដូចបុគ្គលវង្វេងដោយឥតចេតនា។ ព្រះរាជាកុំប្រព្រឹត្តកន្លងនូវអត្តភាព កុំប្រព្រឹត្តនូវអធម៌ កុំចម្លងគេក្នុងទីមិនមែនជាកំពង់ កុំប្រកបក្នុងសេចក្ដីវិនាសឡើយ។ លុះតែក្សត្រិយ៍ណា ទ្រង់ជ្រាបហើយ ធ្វើនូវហេតុទាំងឡាយនេះ ព្រះរាជានោះទើបចំរើនរាល់ពេល ដូចជាព្រះចន្ទ្រក្នុងសុក្កបក្ស។ ព្រះរាជានោះ ប្រកបដោយប្រាជ្ញា រមែងជាទីស្រឡាញ់នៃពួកញាតិផង រុងរឿងក្នុងពួកមិត្តផង លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងឋានសួគ៌។

ចប់ សម្ភវជាតក ទី៥។

## មហាកបិជាតក ទី៦



(៥១៦. មហាកបិជាតកំ (៦ ))

[៤៩៩] (ព្រះសាស្តាទ្រង់សំដែងថា) ព្រះរាជាក្នុងក្រុងពារាណសី ព្រះអង្គញាំងដែនរបស់ពួកជនអ្នកដែនកាសីឲ្យចំរើន ព្រះអង្គមានពួកមិត្ត និងអាមាត្យហែហមហើយ ស្តេចទៅកាន់មិគាជិនឧទ្យាន។ បានទតឃើញព្រាហ្មណ៍ម្នាក់ កើតឃ្លង់ស ឃ្លង់ពពាល កើតស្រែងមានសាច់លៀនចេញ ដូចជាផ្ការលួសផ្អុង ស្គមឡើងសរសៃរវាម ក្នុងមិគាជិនឧទ្យាននោះ។ ព្រះរាជាទ្រង់ទតឃើញជនមានសេចក្តីលំបាកដល់នូវភាពគួរអាណិតក្រៃលែង ទ្រង់ស្ញើប ទ្រង់ត្រាស់សួរថា បណ្តាពួកយក្ស អ្នកជាយក្សអ្វី។ ដៃ និងជើងរបស់អ្នកសផង ក្បាលរបស់អ្នកសលើសជាងដៃ និងជើងនោះផង ខ្លួនរបស់អ្នក មានសម្បុរពព្រះផង មានស្រែងដ៏ច្រើនផង។ ខ្នងរបស់អ្នក រដិបរដុប ដូចជាលួសដែលវេញផង អវយវៈរបស់អ្នក ដូចវល្លិ៍សែនពែនផង យើងមិនដែលឃើញបុគ្គលដទៃបែបនេះឡើយ។ អ្នកមានជើងប្រឡាក់ដោយធូលី ជាអ្នកតក់ស្លុត ស្គម ឡើងសរសៃរវាម ស្រេកឃ្លាន មានសភាពជាអ្នកមិនឆ្អែត តើអ្នកមកអំពីទីណា នឹងទៅក្នុងទីណា។ អ្នកជាបុគ្គលលំបាកមើលមិនមានទ្រង់ទ្រាយ មានសម្បុរមិនល្អ មើលទៅគួរខ្លាច សូម្បីតែមាតាបង្កើតរបស់អ្នក ក៏មិនចង់ឃើញអ្នកដែរ។ អ្នកបានធ្វើនូវអំពើដូចម្តេចក្នុងកាលមុន អ្នកបានបៀតបៀននូវសត្វដែលមិនគួរសម្លាប់ដូចម្តេច អ្នកធ្វើនូវអំពើអាក្រក់ណា ក៏បាននូវសេចក្តីទុក្ខនេះ។

[៥០០] (ព្រាហ្មណ៍ក្រាបបង្គំទូលថា) បើដូច្នោះ អ្នកឈ្លាសវៃ (និយាយ) យ៉ាងណា ទូលព្រះបង្គំជាខ្ញុំនឹងទូលយ៉ាំនោះ ព្រោះថា ក្នុងលោកនេះ អ្នកប្រាជ្ញាទាំងឡាយ តែងសរសើរបុគ្គលអ្នកនិយាយពាក្យពិត។ ទូលព្រះបង្គំជាខ្ញុំតែម្នាក់ឯង កាលដើររកគោ ក៏វង្វេងដើរចូលទៅក្នុងព្រៃស្ងួនស្ងាត់ជាព្រៃដាច់ទឹក ព្រៃស្ងាត់ឈឹង ដែលពួកដំរីផ្សេងៗ នៅហើយ។ ទូលព្រះបង្គំជាខ្ញុំ វង្វេងផ្លូវក្នុងព្រៃ ដែលពួកម្រឹគកាចដើរទៅមក ជាអ្នកមានសេចក្តីស្រេកឃ្លាន អស់ ៧ ថ្ងៃ ដើរទៅក្នុងព្រៃនោះ។ ទូលព្រះបង្គំជាខ្ញុំ ត្រូវសេចក្តីស្រេកឃ្លានគ្របសង្កត់ ក៏បានឃើញដើមទន្លាប់ក្នុងព្រៃនោះ ដុះនៅក្នុងទីមិនស្មើ សំយុងទៅកាន់ជ្រោះ ជាឈើទ្រទ្រង់នូវផ្លែមានរសផ្អែម។ ទូលព្រះបង្គំជាខ្ញុំ បានទទួលទានផ្លែឈើទាំងឡាយ ដែលខ្យល់បក់ធ្លាក់ចុះមក ផ្លែឈើទាំងនោះ ពេញចិត្តទូលព្រះបង្គំជាខ្ញុំយ៉ាងក្រៃលែង ទូលព្រះបង្គំជាខ្ញុំមិនឆ្អែត ក៏ឡើងលើដើម ដោយគិតថានឹងស៊ីឲ្យឆ្អែតស្កប់ស្កល់លើដើមនោះ។ ទូលព្រះបង្គំជាខ្ញុំ ទទួលទានផ្លែទន្លាប់មួយហើយ ប្រាថ្នាផ្លែជាគំរប់ពីរទៀត លំដាប់នោះ មែកឈើនោះ ក៏បាក់ហាក់ដូចជាគេកាប់នឹងប៉ូរថៅ។ ទូលព្រះបង្គំជាខ្ញុំនោះ ក៏ជាប់មកជាមួយនឹងមែកឈើ មានជើងឡើងលើ មានក្បាលចុះក្រោម ធ្លាក់ចុះទៅក្នុងជ្រោះភ្នំ ដែលមិនមានទីឈរ មិនមានទីតោង។ ទឹកជ្រៅ មានត្រឹមណា ទូលព្រះបង្គំជាខ្ញុំមិនធ្លាក់ដល់ត្រឹមណោះទេ មិនមានសេចក្តីត្រេកអរ មិនមានទីពឹង ដេកក្នុងជ្រោះនោះអស់ ១០ រាត្រីគត់។ គ្រានោះ ស្វាមានកន្ទុយ ដូចជាកន្ទុយគោ ត្រាច់ទៅតាមជ្រោះភ្នំ មកដល់ទីនោះ លោតពីមែកមួយ ទៅកាន់មែកមួយ បានស៊ីនូវផ្លែឈើ ស្វានោះបានឃើញនូវទូលព្រះបង្គំជាខ្ញុំ ដែលស្គមស្លេកស្លាំង ក៏ធ្វើនូវសេចក្តីករុណាចំពោះទូលព្រះបង្គំជាខ្ញុំ។ សួរថា ម្នាលអ្នកដ៏ចំរើន អ្នកឯងនេះជាអ្វី ត្រូវទុក្ខគ្របសង្កត់ក្នុងទីនេះយ៉ាងនេះ អ្នកជាមនុស្ស ឬមិនមែនមនុស្ស ចូរប្រាប់ខ្លួនដល់យើង។ ទូលព្រះបង្គំជាខ្ញុំ ក៏ប្រណម្យអញ្ជលីចំពោះស្វានោះហើយពោលនូវពាក្យនេះថា ខ្ញុំជាមនុស្សដល់នូវអំណាចនៃ (សេចក្តីវិនាស) ខ្ញុំទៅអំពីទីនេះមិនបានទេ ព្រោះហេតុនោះ ខ្ញុំជំរាបអ្នក សូមសេចក្តីចំរើនមានដល់អ្នក សូមអ្នកជាទីពឹងរបស់ខ្ញុំ។ ស្វាដ៏ប្រសើរ ត្រាច់ទៅលើភ្នំ ក៏យកនូវថ្មដ៏ធ្ងន់ ចងខ្សែនឹងថ្ម ហើយពោលនូវពាក្យនេះថា អ្នកចូរមក ចូរឡើងជិះខ្នងខ្ញុំ ហើយតោងកខ្ញុំដោយដៃទាំងពីរ ខ្ញុំនឹងស្រង់អ្នកចាកជ្រោះភ្នំដោយកម្លាំង។ ទូលព្រះបង្គំជាខ្ញុំបានឮពាក្យស្តេចស្វាដ៏មានសិរីនោះ ក៏ឡើងជិះខ្នងនៃស្វាជាអ្នកប្រាជ្ញ ហើយតោងក ដោយដៃទាំងពីរ។ ស្វានោះ មានតេជៈ មានកម្លាំងនឿយហត់ ដោយសេចក្តីលំបាក បានស្រង់ទូលព្រះបង្គំជាខ្ញុំចាកជ្រោះភ្នំដោយរហ័ស។ ស្វាជាសប្បុរសដ៏ប្រសើរ លុះស្រង់ទូលព្រះបង្គំជាខ្ញុំរួចហើយ ក៏ពោលនូវពាក្យនេះថា នែសំឡាញ់ អ្នកចូររក្សានូវខ្ញុំផង ខ្ញុំនឹងសម្រាកមួយរំពេច។ បើពួកសត្វរាជសីហ៍ក្តី ពួកខ្លាធំក្តី ពួកខ្លាដម្បងក្តី ពួកខ្លាឃ្មុំក្តី ពួកឆ្កែព្រៃក្តី ពួកខ្លារខិនក្តី ពួកសត្វកាចទាំងនោះ មកបៀតបៀនខ្ញុំដែលធ្វេសប្រហែសហើយ បើអ្នកឃើញនូវសត្វសាហាវទាំងនោះ ចូររារាំងផង។ ស្វានោះ ត្រូវទូលព្រះបង្គំជាខ្ញុំការពារយ៉ាងនេះ ហើយក៏ដេកលក់មួយស្របក់ទៅ គ្រានោះទូលព្រះបង្គំជាខ្ញុំ បានទិដ្ឋិដ៏លាមកដោយមិនត្រូវទំនងថា ស្វានេះ ជាអាហាររបស់ពួកមនុស្ស ដូចពួកម្រឹគដទៃក្នុងព្រៃដែរ បើដូច្នោះ អាត្មាអញឃ្លានហើយ គប្បីសម្លាប់នូវស្វានេះស៊ី។ អញស៊ីហើយ នឹងយកសាច់ជាស្បៀងដើរទៅ នឹងឆ្លងផ្លូវឆ្ងាយ ស្បៀងអញក៏មានស្រាប់។ លំដាប់នោះ ទូលព្រះបង្គំជាខ្ញុំ ចាប់យកដុំថ្មគប់ក្បាល (ស្វានោះ) កាលទូលព្រះបង្គំជាខ្ញុំ លំបាកដោយបាយ ការប្រហារ ក៏មានកំឡាំងថយ។ ឯស្វានោះ ក៏ស្ទុះក្រោកឡើងដោយរហ័ស ប្រឡាក់ដោយឈាម មានភ្នែកពេញដោយទឹកភ្នែក យំសម្លឹងមើលទូលព្រះបង្គំជាខ្ញុំ។ និយាយថា បពិត្រអ្នកដ៏ចំរើន អ្នកជាម្ចាស់ កុំធ្វើបាបខ្ញុំឡើយ អ្នកឯងធ្វើអំពើអាក្រក់បែបនេះ ម្នាលអ្នកដ៏មានអាយុវែង អ្នកឯងគួរតែហាមឃាត់នូវពួកសត្វដទៃ។ យីអើហ្ន៎ នែបុរសចង្រៃ ជាមនុស្សធ្វើអំពើអាក្រក់ដល់ម្ល៉េះ អញបានស្រង់ឯង ឲ្យរួចពីជ្រោះជ្រៅស្រទ្បូងបែបនេះ។ អញនាំអ្នកឯងមក (នេះ) ដូចជានាំមកពីបរលោក អ្នកឯងសំគាល់យើងថា គួរប្រទូស្ត អំពើដ៏លាមកនោះ អ្នកឯងនោះជាមនុស្សលាមក ជាមនុស្សបាប គិតហើយ។ នែអ្នកមិនឋិតនៅក្នុងធម៌ អ្នកឯងកុំប៉ះពាល់នូវទុក្ខវេទនាដ៏ខ្លោចផ្សាឡើយ អំពើដ៏លាមកនោះ កុំសម្លាប់អ្នកឯងដូចជាផ្លែឫស្សី ដែលសម្លាប់ដើមឯងវិញឡើយ។ នែអ្នកជាមនុស្សមានធម៌ដ៏លាមក មិនសង្រួម យើងលែងមានសេចក្តីទុកចិត្តចំពោះអ្នក អ្នកឯងចូរមក អ្នកឯងចូរមានសរីរៈប្រាកដក្នុងទីជិត ដើរតាមក្រោយយើងចុះ។ អ្នកឯងរួចផុតពីកណ្តាប់ដៃនៃពួកម្រឹគកាចហើយ អ្នកឯងបានដល់ឧបចារៈជារបស់នៃមនុស្សហើយ នែអ្នកមិនឋិតនៅក្នុងធម៌ នុ៎ះផ្លូវ អ្នកឯងចូរដើរទៅឲ្យសុខសប្បាយតាមផ្លូវនោះចុះ។ ស្វាដែលត្រាច់ទៅលើភ្នំ លុះបានពោលពាក្យនេះហើយ ទើបលាងឈាមក្បាលរបស់ខ្លួន ហើយជូតទឹកភ្នែកឲ្យជ្រះលំដាប់នោះ ក៏លោតឡើងទៅលើភ្នំ។ ទូលព្រះបង្គំជាខ្ញុំនោះ ជាបុគ្គលដែលស្វានោះផ្តាសាហើយ ត្រូវសេចក្តីក្តៅក្រហាយបៀតបៀន មានខ្លួនក្តៅអន្ទះអន្ទែង បានចូលទៅរកទទួលទានទឹក។ អន្លង់ទឹកទាំងអស់ ក៏ក្តៅសព្វ ហាក់ដូចជាភ្លើងឆេះ ជាអន្លង់ហាក់ដូចជាប្រឡាក់ឈាមហាក់ដូចជាខ្ទុះ និងឈាមប្រាកដដល់ខ្ញុំ។ ដំណក់ទឹកមានចំនួនប៉ុន្មាន ស្រក់លើកាយរបស់ទូលព្រះបង្គំជាខ្ញុំ បូសមានចំនួនប៉ុណ្ណោះប្រាកដស្មើដោយផ្លែព្នៅមួយចំហៀង ក៏កើតឡើង។ ទូលព្រះបង្គំជាខ្ញុំ ទៅក្នុងស្រុក និងនិគមទាំងឡាយ តាមផ្លូវណាៗ បូសទាំងឡាយក៏បែកធ្លាយ ខ្ទុះ និងឈាមដ៏ស្អុយហូរចេញ (ពីសរីរៈ) របស់ទូលព្រះបង្គំជាខ្ញុំ (តាមផ្លូវនោះៗ)។ ពួកស្ត្រី និងបុរស មានដំបងក្នុងដៃ ដែលត្រូវក្លិនស្អុយគ្របសង្កត់ហើយ ឃាត់ទូលព្រះបង្គំជាខ្ញុំថា អ្នកឯងកុំចូលមកខាងអាយឡើយ។ សេចក្តីទុក្ខលំបាកនេះ ប្រាកដដូច្នេះ មានដល់ទូលព្រះបង្គំជាខ្ញុំ អស់ ៧ ឆ្នាំ ហើយដល់មកឥឡូវនេះ ទូលព្រះបង្គំជាខ្ញុំ នៅតែទទួលរងកម្មជារបស់ខ្លួន ដែលខ្លួនធ្វើអាក្រក់ហើយក្នុងកាលមុន។ ព្រោះហេតុនោះ ទូលព្រះបង្គំជាខ្ញុំ សូមក្រាបបង្គំទូលចំពោះព្រះអង្គ សូមសេចក្តីចំរើនមានដល់ព្រះអង្គ ពួកអ្នកដែលមកជួបជុំគ្នាក្នុងទីនេះ សូមកុំប្រទូស្តពួកមិត្តឡើយ ព្រោះថា បុគ្គលប្រទូស្តមិត្ត ជាមនុស្សអាក្រក់។

(អភិសម្ពុទ្ធគាថា) បុគ្គលណា ប្រទូស្តមិត្តទាំងឡាយ ក្នុងលោកនេះ បុគ្គលនោះ រមែងកើតឃ្លង់ផង កើតស្រែងផង បុគ្គលអ្នកប្រទូស្តមិត្តនោះ លុះបែកធ្លាយរាងកាយ រមែងទៅកើតក្នុងនរក។

ចប់ មហាកបិជាតក ទី៦។

## ទករក្ខសជាតក ទី៧

(៥១៧. ទករក្ខសជាតកំ (៧))

[៥០១] (នាងភេរីបរិព្វជិកាសួរថា) កាលពួកជនទាំង ៧ នាក់[32] របស់ព្រះអង្គ រសាត់ទៅក្នុងអន្លង់ទឹកជ្រៅ អារក្សទឹកកាលស្វែងរកគ្រឿងបូជារបស់មនុស្ស គប្បីចាប់ទូក (ព្រះអង្គព្រះរាជទាននូវជន) តាមលំដាប់ដូចម្តេច ទើបរួចអំពីអារក្សទឹកបាន។

[៥០២] (ព្រះបាទចូឡនីត្រាស់ថា) ខ្ញុំឲ្យមាតាជាមុន រួចឲ្យភរិយា ឲ្យប្អូន លំដាប់អំពីនោះ ឲ្យសំឡាញ់ និងឲ្យព្រាហ្មណ៍ជាគំរប់ ៥ ទើបឲ្យខ្លួនជាគំរប់ ៦ មិនឲ្យមហោសធទេ។

[៥០៣] (នាងភេរី...) ព្រះមាតាជាអ្នកចិញ្ចឹមព្រះអង្គផង ជាអ្នកបង្កើតផង អនុគ្រោះព្រះអង្គអស់កាលដ៏យូរផង កាលបើឆព្ពិព្រាហ្មណ៍ប្រទូស្តចំពោះព្រះអង្គ ព្រះមាតាជាបណ្ឌិត ជាអ្នកស្គាល់ឧបាយ ធ្វើនូវរបស់ដទៃជាគ្រឿងបន្លំ ហើយដោះព្រះអង្គ ឲ្យរួចអំពីការសម្លាប់ ព្រះអង្គព្រះរាជទានដល់អារក្សទឹកនូវព្រះមាតា ដែលមានព្រះគុណប្រាកដដូច្នោះ ជាអ្នកឲ្យនូវជីវិត ជាអ្នកឲ្យព្រះអង្គកើតអំពីឱរា ជាអ្នកទ្រទ្រង់នូវគភ៌នោះ តើព្រោះទោសដូចម្តេច។

[៥០៤] (ព្រះរាជា...) ព្រះមាតាខ្ញុំ ទ្រទ្រង់គ្រឿងអលង្ការដែលមិនគួរតាក់តែងដូចស្ត្រីក្មេង សើចក្អាកក្អាយហួសវេលា (ជាមួយ) នឹងនាយឆ្មាំទ្វារ និងពពួកពលសេនា មិនតែប៉ុណ្ណោះ ថែមទាំងបញ្ជូននូវទូតទាំងឡាយដល់ពួកបដិរាជ (ព្រះរាជានៅក្រោមអំណាច) ដោយខ្លួនឯង ខ្ញុំឲ្យព្រះមាតាដល់អារក្សទឹក ព្រោះទោសនោះឯង។

[៥០៥] (នាងភេរី...) អគ្គមហេសី ជាស្ត្រីប្រសើរជាងពួកស្ត្រី ពោលពាក្យជាទីស្រឡាញ់ដ៏ក្រៃលែង ជាស្ត្រីមានសណ្តាប់ធ្នាប់ មានសីលធម៌ ធ្លាប់ជាប់តាម (ព្រះអង្គ) ដូចជាស្រមោល ជាស្ត្រីមិនក្រេវក្រោធ ជាអ្នកមានបុណ្យ ជាបណ្ឌិតឃើញនូវប្រយោជន៍ ព្រះអង្គព្រះរាជទាននាងឧព្វរីដល់អារក្សទឹក តើព្រោះទោសដូចម្តេច។

[៥០៦] (ព្រះរាជា...) នាងនន្ទាទេវីនោះ (បានដឹងច្បាស់) នូវខ្ញុំ ថាជាអ្នកប្រកបដោយសេចក្តីត្រេកអរក្នុងល្បែង ទាំងជាអ្នកលុះអំណាចនៃកិលេស ដែលមិនមានប្រយោជន៍ នាងបានសូមចំពោះខ្ញុំនូវទ្រព្យនៃកូនទាំងឡាយរបស់ខ្លួន ដែលជាទ្រព្យមិនគួរសូម ខ្ញុំនោះកំពុងត្រេកត្រអាល ក៏បានឲ្យទ្រព្យប្រសើរ និងថោកទាបច្រើនយ៉ាង លុះខ្ញុំលះបង់នូវទ្រព្យដែលគេលះបង់បានដោយក្រហើយ ក៏មានចិត្តអាក់អន់សោកស្តាយក្នុងកាលជាខាងក្រោយ ខ្ញុំឲ្យនាងឧព្វរីដល់អារក្សទឹក ព្រោះទោសនោះឯង។

[៥០៧] (នាងភេរី...) ពួកអ្នកជនបទចំរើនហើយ ព្រោះព្រះកនិដ្ឋភាតាណា ទាំងព្រះអង្គដែលព្រះកនិដ្ឋភាតាណា នាំមកកាន់ព្រះរាជដំណាក់វិញ ព្រះរាជទ្រព្យជាច្រើនយ៉ាង ដែលព្រះកនិដ្ឋភាតាណា រឹបជាន់នាំមកអំពីពួកស្តេចដទៃ ព្រះអង្គព្រះរាជទានព្រះកនិដ្ឋភាតាជាបុគ្គលប្រសើរជាងពួកខ្មាន់ធ្នូ ជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត (នោះ) ដល់អារក្សទឹក តើព្រោះទោសដូចម្តេច។

[៥០៨] (ព្រះរាជា...) ពួកអ្នកជនបទចំរើនហើយ ព្រោះកនិដ្ឋភាតាណា ទាំងខ្ញុំ (ដែលកនិដ្ឋភាតាណា) នាំមកកាន់ដំណាក់វិញ ព្រះរាជទ្រព្យជាច្រើនយ៉ាង (ដែលកនិដ្ឋភាតាណា) រឹបជាន់ហើយ នាំមកអំពីពួកស្តេចដទៃ កនិដ្ឋភាតានោះ មើលងាយថា អញប្រសើរជាងពួកខ្មាន់ធ្នូ ជាអ្នកក្លៀវក្លា មានប្រាជ្ញាដ៏មុត ឯព្រះរាជានេះដូចជាក្មេង បានសេចក្តីសុខព្រោះតែអញ បពិត្រនាងជាម្ចាស់ មិនតែប៉ុណ្ណោះ កនិដ្ឋភាតានោះ មិនមកកាន់ទីបំរើខ្ញុំដូចក្នុងកាលពីដើមទេ ខ្ញុំឲ្យកនិដ្ឋភាតា (នោះ) ដល់អារក្សទឹក ព្រោះទោសនោះឯង។

[៥០៩] (នាងភេរី...) ជនទាំងពីរនាក់ គឺព្រះអង្គ និងធនុសេខកុមារ ជាសំឡាញ់មានវ័យស្មើគ្នា ធ្លាប់នៅក្នុងបញ្ចាលនគរ ជាបុគ្គលពីរនាក់កើតក្នុងបញ្ចាលនគរនេះ ក្នុងរាត្រីតែមួយ ធនុសេខកុមារ មានទុក្ខសុខជាមួយគ្នានឹងព្រះអង្គ ជាប់តាមព្រះអង្គ ក្នុងការត្រាច់ទៅកាន់ (ជនបទ) ជាអ្នកខ្មីឃ្មាត ខ្វល់ខ្វាយក្នុងកិច្ចទាំងពួង ដើម្បីព្រះអង្គទាំងថ្ងៃទាំងយប់ ព្រះអង្គព្រះរាជទានសំឡាញ់នេះដល់អារក្សទឹក តើព្រោះហេតុដូចម្តេច។

[៥១០] (ព្រះរាជា...) បពិត្រនាងម្ចាស់ ធនុសេខកុមារនេះ (ជាប់តាម) ខ្ញុំ ក្នុងការត្រាច់ទៅ (កាន់ជនបទ) សើចក្អាកក្អាយជាមួយនឹងខ្ញុំក្នុងកាលមុន សូម្បីក្នុងថ្ងៃនេះ ក៏នៅតែសើចក្អាកក្អាយ ហួសវេលាតាមទំនងនោះដែរ បពិត្រនាងម្ចាស់ ខ្ញុំនៅក្នុងទីស្ងាត់ ក៏ពុងប្រឹក្សាជាមួយនឹងនាងឧព្វរី ឯសេខកុមារ ខ្ញុំមិនបានហៅ មិនបានឲ្យដំណឹងខ្ញុំជាមុនទេ ស្រាប់តែចូលមក ជាបុគ្គលមានទ្វារបានហើយ មានឱកាសធ្វើឲ្យហើយ ខ្ញុំឲ្យនូវសំឡាញ់ ជាមនុស្សមិនមានសេចក្តីអៀនខ្មាស មិនអើពើ ដល់អារក្សទឹក ព្រោះទោសនោះឯង។

[៥១១] (នាងភេរី...) ព្រាហ្មណ៍បុរោហិត ជាអ្នកឈ្លាសវៃក្នុងនិមិត្តទាំងពួង ជាអ្នកដឹងនូវសំឡេងស្រែក ជាអ្នកឈ្លាសក្នុងឧត្បាទ ជាអ្នកចេះកាត់សុបិន ជាអ្នកឈ្លាសវៃក្នុងការចេញ និងការចូលផង លើផែនដី និងលើអាកាសផង ជាអ្នកឈ្លាវៃ ក្នុងចំណែកនក្ខត្តឫក្ស ព្រះអង្គព្រះរាជទានព្រាហ្មណ៍បុរោហិត ដល់អារក្សទឹក តើព្រោះទោសដូចម្តេច។

[៥១២] (ព្រះរាជា...) បពិត្រនាងម្ចាស់ ព្រាហ្មណ៍បុរោហិត បើកភ្នែកសំឡក់ចំពោះខ្ញុំក្នុងកណ្តាលបរិស័ទ ព្រោះហេតុនោះ ទើបខ្ញុំឲ្យបុរោហិតអាក្រក់ មានចិញ្ចើមក្រញូវ ដល់អារក្សទឹក។

[៥១៣] (នាងភេរី...) ព្រះអង្គគ្រប់គ្រងនូវផែនដីដ៏ធំ មានសមុទ្រព័ទ្ធជុំវិញ ជាកុណ្ឌលរបស់សាគរ ព្រះអង្គមានអាមាត្យចោមរោមជាឥស្សរៈលើផែនដី មានសមុទ្រទាំង ៤ ជាទីបំផុត មានដែនដ៏ច្រើន ជាអ្នកឈ្នះសង្គ្រាម មានពលច្រើន ជាព្រះរាជាឯកលើផែនដី យសរបស់ព្រះអង្គក៏ដល់នូវភាពដ៏ធំថ្កើង មានពួកនារីមកអំពីជនបទផ្សេងៗ ជាស្ត្រីស្នំ ១៦ ពាន់ ពាក់គ្រឿងកុណ្ឌលជាវិការៈនៃកែវមណី ល្អល្អះដូចស្រីទេពកញ្ញា បពិត្រក្សត្រ អ្នកប្រាជ្ញទាំងឡាយបានពោលចំពោះជីវិតដែលវែង បរិបូណ៌ដោយអង្គទាំងពួង សម្រេចនូវសេចក្តីប្រាថ្នាទាំងពួងថា ជាទីស្រឡាញ់របស់សត្វទាំងឡាយ អ្នកដល់នូវសេចក្តីសុខយ៉ាងនេះ កាលបើដូច្នោះ ព្រះអង្គរក្សាទុកនូវបណ្ឌិត ត្រឡប់ជាលះបង់ព្រះជន្ម ដែលគេលះបង់បានដោយកម្រ តើដោយដំណើរដូចម្តេច ឬក៏ដោយហេតុដូចម្តេច។

[៥១៤] (ព្រះរាជា...) បពិត្រនាងម្ចាស់ តាំងអំពីកាលដែលមហោសធបណ្ឌិត មកតាំងនៅក្នុងកណ្តាប់ដៃនៃខ្ញុំ ខ្លួនខ្ញុំក៏មិនដែលឃើញនូវអំពើអាក្រក់ សូម្បីបន្តិចបន្តួចរបស់មហោសធបណ្ឌិតជាអ្នកប្រាជ្ញទេ ថាបើសេចក្តីស្លាប់គប្បីមានដល់ខ្ញុំមុន ក្នុងកាលណាមួយ មហោសធបណ្ឌិត គប្បីញ៉ាំងបុត្រទាំងឡាយ និងចៅទាំងឡាយរបស់ខ្ញុំ ឲ្យសុខ មហោសធបណ្ឌិត តែងពិចារណាឃើញនូវប្រយោជន៍ទាំងពួង ក្នុងអនាគត និងបច្ចុប្បន្ន (ព្រោះហេតុនោះ) ខ្ញុំមិនឲ្យនូវមហោសធបណ្ឌិតជាអ្នកមានការងារមិនដែលមានកំហុស (ដល់អារក្សទឹកទេ)។

[៥១៥] (នាងភេរី...) ពួកអ្នកនគរបញ្ចាលទាំងឡាយ ចូរស្តាប់នូវភាសិតនេះ របស់ព្រះបាទចូឡនីចុះ ព្រះរាជាទ្រង់រក្សានូវបណ្ឌិត ស៊ូលះបង់នូវព្រះជន្ម ដែលគេលះបានដោយក្រ ព្រះរាជាក្នុងបញ្ចាលនគរលះបង់នូវជីវិតរបស់ជន ៦ រូប គឺព្រះមាតា ១ ព្រះមហេសី ១ ព្រះកនិដ្ឋភាតា ១ សំឡាញ់ ១ ព្រាហ្មណ៍ ១ ព្រះអង្គ ១ បញ្ញាជាគុណជាតិដ៏ល្អិត សម្រាប់គិតនូវប្រយោជន៍ដ៏ល្អ មានឫទ្ធិច្រើនយ៉ាងនេះ ប្រព្រឹត្តទៅដើម្បីប្រយោជន៍ក្នុងបច្ចុប្បន្ននេះផង ដើម្បីសេចក្តីសុខក្នុងបរលោកផង។

ចប់ ទករក្ខសជាតក ទី៧។

## បណ្ឌរកជាតក ទី៨

CS sut.kn.jat.518 | ភាគទី ៦០

(៥១៨. បណ្ឌរនាគរាជជាតកំ (៨))

[៥១៦] (បណ្ឌរកនាគរាជពោលថា) ភ័យខ្លួនឯង រមែងជាប់តាមនូវបុគ្គលដែលមានវាចាល្ហហាច មានមន្តមិនលាក់ទុក ជាអ្នកមិនសង្រួម មិនចេះពិចារណា ជាអ្នកល្ងង់នោះ ដូចជាគ្រុឌចាប់យកនាគឈ្មោះបណ្ឌរកៈ។ ជនណាវីករាយប្រាប់មន្តដែលគួរលាក់ គួររក្សាទុក ព្រោះសេចក្តីវង្វេង ភ័យរមែងជាប់តាមនូវជនដែលមានមន្តបែកធ្លាយនោះដោយឆាប់ ដូចជាគ្រុឌចាប់យកនាគឈ្មោះបណ្ឌរកៈ។

មិត្តគ្រាន់តែបណ្តោយតាម គេមិនគួរឲ្យដឹងនូវហេតុជាទម្ងន់ដែលគួរលាក់ ទាំងមិត្តល្អ ជាអ្នកមិនយល់ការ ឬយល់ការដែរ តែជាអ្នកមិនប្រព្រឹត្តប្រយោជន៍ (ក៏គេមិនគួរឲ្យដឹងដែរ)។

អញដល់នូវសេចក្តីទុកចិត្តអចេល អចេលនេះ ជាសមណៈ គេរាប់អានហើយ មានចិត្តចំរើនហើយ អញក៏ប្រាប់ បើកនូវអាថ៌កំបាំងដល់អចេលនោះ បានជាអញមានប្រយោជន៍កន្លងហួស ហើយទួញយំកំព្រាម្នាក់ឯង។ បពិត្រគ្រុឌដ៏ប្រសើរ ព្រោះខ្ញុំមិនអាចនឹងសង្រួមវាចាដ៏ប្រសើរកំបាំងនេះ ដល់អចេលនោះ បានជាភ័យមកដល់ខ្ញុំ អំពីចំណែកនៃអចេលនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រា ហើយទួញយំ។ ជនណាសំគាល់នូវបុគ្គលថា មានចិត្តល្អ ប្រាប់នូវអាថ៌កំបាំងចំពោះជនមានត្រកូលដ៏អាក្រក់ ព្រោះទោសាគតិ ភយាគតិ ឬត្រេកអរដោយអំណាចរាគៈ ជននោះជាមនុស្សល្ងង់ ឈ្មោះថា ភ្លាត់ហើយដោយឥតសង្ស័យ។ ជនណាមានវាចាចេញទៅខាងក្រៅ រាប់ចូលក្នុងពួកអសប្បុរស កំចាយនូវពាក្យ (កំបាំងរបស់គេ) ក្នុងទីប្រជុំ អ្នកប្រាជ្ញទាំងឡាយ ហៅជននោះថា ជាអ្នកមានមាត់អាក្រក់ ដូចអាសិរពិស បុគ្គលគប្បីចៀសចាកបុគ្គលបែបនោះឲ្យឆ្ងាយចេញអំពីចម្ងាយ។ យើងលះបង់នូវកាមទាំងពួង គឺបាយ ទឹក សំពត់ក្នុងដែនកាសី និងខ្លឹមចន្ទន៍ ពួកស្រ្តីជាទីគាប់ចិត្ត កម្រងផ្កា និងគ្រឿងប្រស់ព្រំ បពិត្រសុបណ្ណៈ យើងសូមដល់នូវលោក (ជាទីពឹង) ស្មើដោយជីវិត។

[៥១៧] (សុបណ្ណរាជសួរថា) ម្នាលនាគរាជ បណ្តាជនទាំង ៣ នាក់ ក្នុងទីនេះ តើសត្វណា គឺសមណៈ ឬគ្រុឌ ឬអ្នកឯងគួរដល់នូវសេចក្តីតិះដៀលបាន ក្នុងលោកនេះ ម្នាលបណ្ឌរកៈ (អ្នកឯងត្រូវខ្ញុំ) ចាប់បាន ព្រោះហេតុដូចម្តេច។

[៥១៨] (បណ្ឌរកៈ...) អចេលជាសមណៈ ជាបុគ្គលមានសភាពដែលខ្ញុំរាប់អានហើយ ជាទីស្រឡាញ់ដោយចិត្តរបស់ខ្ញុំ មានខ្លួនចំរើនហើយ ខ្ញុំប្រាប់បើកអាថ៌កំបាំងដល់សមណៈនោះ ទើបខ្ញុំជាបុគ្គលមានប្រយោជន៍កន្លងហួស កំព្រា ហើយទួញយំ។

[៥១៩] (សុបណ្ណរាជ...) ធម្មតា សត្វលើផែនដី ឈ្មោះថាមិនស្លាប់ មិនមានទេ ចំណែកនៃបញ្ញា ជាធម្មជាតិដែលបុគ្គលមិនគួរតិះដៀលនូវជនក្នុងលោកនេះ រមែងនាំមកនូវគុណវិសេសដែលបុគ្គលមិនគួរបាន ដោយវចីសច្ចៈ ១ ដោយសុចរិតធម៌ ១ ដោយធិតិ គឺបញ្ញា ១ ដោយការទូន្មាននូវឥន្ទ្រិយ ១។ មាតាបិតា ជាបុគ្គលប្រសើរជាងផៅពង្សទាំងឡាយ សត្វជាគំរប់ ៣ (ក្រៅអំពីមាតាបិតា) ឈ្មោះថាជាអ្នកអនុគ្រោះដល់បុគ្គលនោះមិនមានទេ បុគ្គលកាលរង្កៀសនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់ការស្ងាត់កំបាំងក្រៃលែងដល់មាតាបិតា។ មាតាបិតា បងប្អូនស្រី បងប្អូនប្រុស និងសំឡាញ់ ឬញាតិទាំងពីរប៉ែក របស់បុគ្គលនោះ បុគ្គលកាលរង្កៀសនូវការបែកធ្លាយមន្ត មិនគប្បីប្រាប់នូវការស្ងាត់កំបាំងដ៏ក្រៃលែង ដល់មាតាបិតា ជាដើមនោះឡើយ។ បើទុកជាភរិយា ជាស្រីក្មេង ពោលពាក្យជាទីស្រឡាញ់ មានបុត្រមានរូបល្អ មានយស ដែលពួកញាតិចោមរោម ជាស្រ្តីរៀបរុស (ដទៃ) បុគ្គលកាលបើរៀរនូវការបែកធ្លាយនៃមន្ត មិនគប្បីប្រាប់នូវការស្ងាត់កំបាំងដ៏ក្រៃលែងដល់ភរិយានោះទេ។

[៥២០] បុគ្គលមិនគប្បីបើកនូវអាថ៌កំបាំងទេ គប្បីរក្សានូវអាថ៌កំបាំង ឲ្យដូចជារក្សាកំណប់ ដ្បិតអាថ៌កំបាំងដែលបុគ្គលអ្នកដឹងច្បាស់មិនប្រាប់គេ ជាការប្រពៃ។ អ្នកប្រាជ្ញ មិនគប្បីនិយាយប្រាប់អាថ៌កំបាំងដល់ស្រ្តី ដល់ជនជាសត្រូវ ដល់ជនវៀបវប្បដោយអាមិសៈ ដល់ជនលួចគំនិតគ្នា។ ជនណាញ៉ាំងគេឲ្យដឹងអាថ៌កំបាំងដែលគេមិនទាន់ដឹង អ្នកប្រាជ្ញតែងអត់សង្កត់មិនប្រាប់ដល់ជននោះ ព្រោះខ្លាចបែកការដែលគិតទុក ដូចមនុស្សខ្ញុំគេ។ ជនទាំងឡាយមានចំនួនប៉ុន្មាននាក់ ដឹងនូវមន្តជាអាថ៌កំបាំងរបស់បុរស សេចក្តីតក់ស្លុតមានចំនួនប៉ុណ្ណោះ តែងកើតឡើងដល់បុរសនោះ ព្រោះហេតុនោះ អ្នកប្រាជ្ញមិនគប្បីផ្សាយនូវអាថ៌កំបាំងឡើយ។

នៅវេលាថ្ងៃ អ្នកប្រាជ្ញគប្បីនិយាយអាថ៌កំបាំងក្នុងទីដ៏ស្ងាត់ នៅវេលារាត្រី មិនគប្បីបញ្ចេញសម្លេងឲ្យហួសកម្រិត ព្រោះថា ពួកជនអ្នកឈ្លបស្តាប់ រមែងឮនូវមន្ត[33] ព្រោះហេតុនោះ មន្តក៏រមែងដល់នូវការបែកធ្លាយដោយឆាប់។

[៥២១] ក្រុងប្រកបដោយកំពែងដែកដ៏ធំ មិនមានទ្វារ (ចេញចូលមិនបាន) ធ្វើអំពើដែលប្រកបដោយសាលា គឺរានផ្សារដ៏ល្អ ប្រកបដោយគូដែលគេជីកដោយជុំវិញ យ៉ាងណា បុរសមានមន្តដែលគួរលាក់ទុកក្នុងលោកនេះ ប្រាកដដល់ខ្ញុំយ៉ាងនោះដែរ។ ម្នាលអ្នកមានអណ្តាតពីរ ពួកជនណាជាអ្នកមានមន្តគួរលាក់ទុក មានវាចាមិនល្ហល្ហាច ជាអ្នកមាំមួនក្នុងប្រយោជន៍របស់ខ្លួន សត្រូវទាំងឡាយរមែងចៀសចេញឆ្ងាយអំពីពួកជននោះ ដូចពពួកនៃសត្វ ចៀសចេញអំពីអាសិរពិស។

[៥២២] (បណ្ឌរកៈ...) អចេល ជាអ្នកបួសលះបង់ផ្ទះ អាក្រាត ត្រងោល ប្រព្រឹត្ត ព្រោះហេតុតែអាហារ ខ្ញុំបើកបង្ហាញនូវអាថ៌កំបាំងចំពោះអចេលនោះឯង (ព្រោះហេតុនោះ) បានជាយើងឃ្លាតចាកអត្ថ និងធម៌។ បពិត្រសុបណ្ណរាជ បុគ្គលធ្វើដូចម្តេច មានសីលធម៌ដូចម្តេច ប្រព្រឹត្តវត្តដូចម្តេច ឈ្មោះថាសមណៈ ប្រព្រឹត្តលះបង់នូវសេចក្តីរាប់អាន (តណ្ហា) សមណៈនោះ ធ្វើដូចម្តេច ទើបទៅកាន់ឋានសួគ៌។

[៥២៣] (សុបណ្ណរាជ...) បុគ្គលប្រកបដោយហិរិ ដោយខន្តិ គឺសេចក្តីអត់ធន់ ដោយការទូន្មាន (នូវឥន្ទ្រិយ) ជាអ្នកមិនខឹង លះបង់នូវពាក្យញុះញង់ ទើបឈ្មោះថាសមណៈ ប្រព្រឹត្តលះបង់នូវសេចក្តីរាប់អាន ឯសមណៈនោះ ធ្វើយ៉ាងនេះឯង ទើបចូលទៅកាន់ឋានសួគ៌បាន។

[៥២៤] (បណ្ឌរកៈ...) មាតាឃើញកូនខ្ចីដែលកើតអំពីខ្លួន ហើយបបោសអង្អែលសព្វសពាង្គកាយ យ៉ាងណាមិញ បពិត្រលោកជាធំជាងបក្សី លោកជាអ្នកអនុគ្រោះ ប្រាកដដល់ខ្ញុំដូចជាមាតា (អនុគ្រោះ) នូវបុត្រយ៉ាងនោះ។

[៥២៥] (សុបណ្ណរាជ...) នែអ្នកមានអណ្តាតពីរ អ្នកចូររួចអំពីការសម្លាប់ក្នុងថ្ងៃនេះចុះ ព្រោះថា បុត្តមាន ៣ គឺ សិស្ស ១ កូនគេឲ្យ ១ កូនកើតអំពីខ្លួន ១ បុត្តក្រៅពីនេះមិនមានឡើយ អ្នកចូរត្រេកអរចុះ អ្នកទុកជាបុត្តណាមួយរបស់ខ្ញុំហើយ។

[៥២៦] (អភិសម្ពុទ្ធគាថា) ស្តេចគ្រុឌមានកំណើតពីរ (លុះពោលពាក្យ) យ៉ាងនេះហើយ ក៏បិតនៅលើផែនដី លែងសត្វមានអណ្តាតពីរដោយពាក្យថា អ្នករួចក្នុងថ្ងៃនេះ កន្លងនូវភ័យទាំងពួងហើយ អ្នកត្រូវតែខ្ញុំគ្រប់គ្រងក្នុងទីគោគ និងទឹកហើយ។ ខ្ញុំជាទីពឹងរបស់អ្នក ដូចជា

ពេទ្យដំឈ្លាស (ជាទីពឹង) របស់ពួកអ្នកមានជម្ងឺ ឬដូចជាអន្លង់ទឹកត្រជាក់ (ជាប្រយោជន៍) របស់ពួកអ្នកស្រេកទឹក ឬក៏ដូចផ្ទះ (ជាទីត្រូវការ) របស់ពួកបុគ្គលដែលលំបាកដោយសន្សើមត្រជាក់។

[៥២៧] (សុបណ្ណរាជ...) ម្នាលអ្នកជាជលាពុជៈ អ្នកធ្វើសេចក្តីស្និទ្ធស្នាល ជាមួយនឹងអណ្ឌជៈជាសត្រូវ ហើយនៅបើកបង្ហាញចង្កូម (ធ្វើអ្វីទៀត) ភ័យនឹងមកដល់អ្នកអំពីទីណា។

[៥២៨] (បណ្ឌរកៈ...) បុគ្គលត្រូវតែរង្កៀសក្នុងបុគ្គលជាសត្រូវ មិនត្រូវទុកចិត្តបុគ្គលសូម្បីជាមិត្ត (ព្រោះ) ភ័យរមែងកើតឡើងអំពីបុគ្គលដែលមិនគួរភ័យ រមែងកាត់ សូម្បីនូវឫសគល់ (ជីវិត)។ បុគ្គលធ្វើនូវជំលោះនឹងជនណា គប្បីទុកចិត្តជននោះដូចម្តេចកើត បុគ្គលគប្បីឋិតនៅដោយប្រុងប្រយ័ត្នជានិច្ច បុគ្គលនោះ រមែងមិនត្រេកអរនឹងសត្រូវ។

បុគ្គលគប្បីធ្វើឲ្យគេទុកចិត្ត ប៉ុន្តែមិនត្រូវទុកចិត្តគេ បុគ្គលដែលគេមិនរង្កៀសហើយ ប៉ុន្តែគប្បីរង្កៀសនឹងគេ បុគ្គលដទៃមិនដឹងនូវភាព (របស់ខ្លួន) យ៉ាងណាៗ វិញ្ញូបុរស គប្បីប្រឹងប្រែងដោយប្រការយ៉ាងនោះៗ។

[៥២៩] (អភិសម្ពុទ្ធគាថា) បុរិសនាគទាំងពីរនោះ មានវណ្ណៈដូចជាទេវតា មានសភាពជាសុខុមាលជាតិស្មើគ្នា មានវ័យដ៏ល្អ មានគំនរនៃបុណ្យ កៀកដៃគ្នា ដូចជាសេះគេទឹម បានចូលទៅកាន់សំណាក់នៃអចេល ឯកំពង់ករម្បិយៈ។

[៥៣០] លំដាប់នោះឯង បណ្ឌរកនាគរាជ បានចូលទៅកាន់សំណាក់នៃអចេលដោយខ្លួនឯង ហើយពោលពាក្យនេះថា ខ្ញុំរួច (អំពីការសម្លាប់) កន្លងនូវភ័យទាំងពួងក្នុងថ្ងៃនេះហើយ យើងមិនជាទីស្រឡាញ់របស់លោកដោយចិត្តពិតប្រាដកទេ។

[៥៣១] (អចេល...) សុបណ្ណរាជ ជាទីស្រឡាញ់របស់ខ្ញុំ ជាងបណ្ឌរកនាគរាជមែន ឥតសង្ស័យ (នេះ) ជាពាក្យពិត ខ្ញុំនោះជាអ្នកត្រេកអរដោយរាគៈ ជាអ្នកដឹងច្បាស់ បានធ្វើនូវអំពើអាក្រក់នុ៎ះ មិនមែនព្រោះមោហៈទេ។

[៥៣២] (បណ្ឌរកៈ...) បព្វជិត កាលឃើញច្បាស់នូវលោកនេះ និងលោកខាងមុខ រមែងមិនមានគំនិតថា វត្ថុជាទីស្រឡាញ់ ឬមិនជាទីស្រឡាញ់របស់អញដូច្នេះទេ អ្នកជាបុគ្គលមិនសង្រួម ប្រព្រឹត្តក្នុងលោកនេះ ដោយភេទរបស់បុគ្គលអ្នកសង្រួមល្អ។ អ្នកឯងបន្លំជាអរិយៈ តែមិនមែនជាអរិយៈទេ អ្នកមិនសង្រួម តែមានភាពហាក់ដូចជាអ្នកសង្រួម មានជាតិខ្មៅ មានសភាពមិនប្រសើរ បានប្រព្រឹត្តនូវអំពើដ៏លាមកទុច្ចរិតច្រើនយ៉ាង។

[៥៣៣] ម្នាលអ្នកប្រទូស្ត អ្នកជាបុគ្គលប្រទូស្តមិត្តដែលមិនបានប្រទូស្តវិញផង ជាអ្នកញុះញង់ផង ដោយពាក្យសច្ចៈនេះ សូមឲ្យក្បាលរបស់អ្នកឯង បែកជា ៧ ភាគ។

[៥៣៤] (អភិសម្ពុទ្ធគាថា) ព្រោះហេតុនោះ បុគ្គលមិនត្រូវប្រទូស្តមិត្តទាំងឡាយឡើយ ព្រោះថា សភាវៈដទៃ លាមកជាងការទ្រុស្តមិត្តមិនមានទេ អចេលអ្នកសង្រួម ត្រូវសត្វអាសីពិសប្រទេចផ្តាសា ក៏ខ្ទាត់ចេញអំពីផែនដី វិនាសតាមពាក្យរបស់នាគរាជដ៏ប្រសើរ។

ចប់ បណ្ឌរកជាតក ទី៨។

## សម្ពុលាជាតក ទី៩

CS sut.kn.jat.519 | ភាគទី ៦០

### (៥១៩. សម្ពុលាជាតកំ (៩))

[៥៣៥] (ទានវៈ[34] សួរថា) ម្នាលនាងមានភ្លៅមូល នាងឈ្មោះអ្វី រងាញ័រលើជ្រោះនៃភ្នំ ឈរនៅតែម្នាក់ឯង ម្នាលនាងមានអវយវៈត្រង់កណ្តាលគួរវាស់ដោយដៃ (ចង្កេះរៀវ) យើងសួរហើយ នាងចូរប្រាប់នូវនាម និងផៅពង្សដល់យើង។ ម្នាលនាងកល្យាណី នាងជាអ្វី ម្នាលនាងមានអវយវៈពាក់កណ្តាលដ៏ល្អ នាងជាធីតារបស់អ្នកណា នាងញ៉ាំងព្រៃជាទីរីករាយ ដែលសីហៈ និងខ្លាធំអាស្រ័យនៅ ឲ្យភ្លឺរុងរឿង ម្នាលនាងដ៏ចំរើន យើងឈ្មោះទានវៈ សូមសំពះនាង សូមគោរពចំពោះនាង។

[៥៣៦] (នាងសម្ពុលាឆ្លើយថា) អ្នកណាជាបុត្ររបស់ព្រះរាជាក្នុងដែនកាសី អ្នកផងតែងស្គាល់អ្នកនោះថា ព្រះនាមសោត្ថិសេន ខ្ញុំឈ្មោះនាងសម្ពុលា ជាភរិយារបស់ព្រះរាជបុត្តព្រះនាមសោត្ថិសេននោះ បពិត្រទានវៈ លោកចូរដឹងយ៉ាងនេះចុះ បពិត្រលោកដ៏ចំរើន ខ្ញុំឈ្មោះសម្ពុលា សូមសំពះ សូមគោរពចំពោះលោក។ បពិត្រលោកដ៏ចំរើន ព្រះរាជបុត្ររបស់ព្រះរាជាវិទេហៈ ប្រឈួនក្តៅក្រហាយ គង់នៅក្នុងព្រៃ ខ្ញុំជាស្ត្រីម្នាក់ឯង បំរើព្រះរាជបុត្រ ដែលមានរោគបៀតបៀនមួយអង្គឯងនោះ។ មិនតែប៉ុណ្ណោះ ខ្ញុំ (ត្រាច់ទៅ) ដើម្បីស្វែងរកផ្លែឈើក្នុងព្រៃ នាំមកនូវទឹកឃ្មុំ និងសាច់ដែលជាអម្ពាររបស់ម្រឹគណា (ស្វាមីរបស់ខ្ញុំ) មានទឹកឃ្មុំ និងសាច់ ជាអម្ពាររបស់ម្រឹគនោះ ជាអាហារ (កាលបើមិនមានអាហារទេ សរីរៈ) របស់ស្វាមីខ្ញុំនោះ នឹងទ្រាំទ្រមិនបាន ក្នុងថ្ងៃនេះដោយពិត។

[៥៣៧] (ទានវៈ...) ម្នាលនាងសម្ពុលា នាងធ្វើ (នូវការមូលមិត្ត) នឹងព្រះរាជបុត្រ ប្រឈួនក្តៅក្រហាយ ដែលរោគប៉ះពាល់នៅក្នុងព្រៃធ្វើអ្វី ខ្ញុំសូមជាភស្តារបស់នាង។

(នាងសម្ពុលា...) ខ្ញុំរាប់ថាមានរូបដូចម្តេចកើត ព្រោះខ្ញុំជាស្ត្រីមានសេចក្តីសោកគ្របសង្កត់ មានខ្លួនដ៏លំបាក បពិត្រលោកដ៏ចំរើន លោកចូរស្វែងរកស្ត្រីឯទៀត ដែលល្អជាងខ្ញុំចុះ។

(ទានវៈ...) នាងចូរមកចុះ ចូរឡើងកាន់ភ្នំនេះ ប្រពន្ធរបស់ខ្ញុំមាន ៤០០ នាក់ នាងចូរជាស្ត្រីដ៏ប្រសើរជាងភរិយាទាំងនោះ ចូរសម្រេចតាមសេចក្តីប្រាថ្នាគ្រប់យ៉ាង។ ម្នាលនាងមានពន្លឺដូចផ្កាយ នាងប្រាថ្នាក្នុងចិត្តចំពោះវត្ថុណាមួយ វត្ថុទាំងអស់នោះរបស់ខ្ញុំមានគរគោគ ចូរនាងត្រេកអរជាមួយនឹងយើងក្នុងថ្ងៃនេះចុះ។ ម្នាលនាងសម្ពុលា បើនាងមិនធ្វើនូវភាពជាមហេសីរបស់ខ្ញុំទេ នាងគួរជាអាហារក្នុងពេលព្រឹក នឹងជាចំណីរបស់ខ្ញុំអំពីព្រហាម។

ចំណែកទានវៈ មានភ្នួងសក់ ៧ ជាន់ ជាជាតិអាក្រក់ មានចង្កូម ជាអ្នកស៊ីនូវបុរស បានចាប់នាងសម្ពុលានោះត្រង់ដើមដៃ ដែលមិនឃើញនូវទីពឹងក្នុងព្រៃ។ នាងសម្ពុលា ដែលបិសាចអាក្រក់ មានភ្នែកប្រកបដោយអាមិសគ្របសង្កត់ ជាស្ត្រីលុះក្នុងអំណាចនៃសត្រូវហើយ ក៏សោកសៅ រកតែស្វាមីថា

យក្សស៊ីនូវខ្ញុំដោយហេតុណា ហេតុនេះ មិនមែនជាទុក្ខនៃខ្ញុំទេ ក្រែងតែព្រះហឫទ័យនៃអយ្យបុត្តរបស់ខ្ញុំ ទៅជាបការៈដទៃ (ប្រច័ណ្ឌ) ដោយហេតុណា ហេតុនោះ (ទើបជាទុក្ខនៃខ្ញុំ)។ មិនមានពួកទេវតានៅគ្រប់គ្រងដោយពិត ទាំងពួកទេវតា អ្នករក្សាលោក ក្នុងលោកនេះ

កំមិនមានដោយពិត ទេវតាទាំងឡាយ អ្នកហាមឃាត់នូវពួកជនជាអ្នកមិនសង្រួម ជាអ្នកធ្វើដោយការកំហែង កំមិនមានដោយពិត។

[៥៣៨] (សក្កៈ...) ស្ត្រីនេះជាស្ត្រីមានយស ជាស្ត្រីប្រសើរជាងស្ត្រីទាំងឡាយ ជាស្ត្រីស្ងប់ស្ងៀម មានកិរិយាដ៏ស្មើ មានតេជះរុងរឿងដូចជាភ្លើង បើអ្នកឯងស៊ីនាងកញ្ញានោះ ក្បាលអ្នកឯងនឹងបែកជា ៧ ភាគមិនខាន អ្នកឯងកុំកំដៅ (នូវនាងសម្ពុលា) អ្នកឯងចូរលែងនាងទៅ ព្រោះនាងជាស្ត្រីគោរពប្តី។

[៥៣៩] (អភិសម្ពុទ្ធគាថា) នាងសម្ពុលា លុះរួចអំពីបោរិសាទ បានត្រឡប់មកកាន់អាស្រមវិញ ដូចជាមេបក្សីបែកខ្វែកកូន ហើយមកកាន់ទ្រនំ ឬដូចមេគោ មកកាន់លំនៅ (ដែលមានកូនទៅបាត់ហើយ)។ ព្រះរាជបុត្រីនោះ ជាស្ត្រីមានយស ព្រះនាមសម្ពុលា មានភ្នែកស្រទន់ ព្រោះរដូវ កាលមិនឃើញព្រះស្វាមីជាទីពឹងក្នុងព្រៃហើយ ក៏ទ្រង់ព្រះកន្សែងក្បែរអាស្រមនោះថា ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំពួកសមណព្រាហ្មណ៍ និងឥសីទាំងឡាយ ដែលមានការប្រព្រឹត្តិបរិបូណ៌ ខ្ញុំសូមដល់នូវលោកជាទីពឹង។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវពួកសីហៈ ខ្លាធំ និងពួកម្រឹគដទៃក្នុងព្រៃ ខ្ញុំសូមដល់នូវលោកជាទីពឹង។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំស្មៅ វល្លិ៍ ឈើជាឱសថភ្នំ និងព្រៃទាំងឡាយ ខ្ញុំសូមដល់នូវលោកជាទីពឹង។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវរបៀបផ្កាយក្នុងរាត្រី ដែលមានពណ៌ដូចជាផ្ការាជព្រឹក្ស ខ្ញុំសូមដល់នូវលោកជាទីពឹង។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវស្ទឹងឈ្មោះភគិរសី ជាទីទទួលនូវស្ទឹងទាំងឡាយដែលហូរមក ខ្ញុំសូមដល់នូវលោកជាទីពឹង។ ខ្ញុំមិនឃើញព្រះរាជបុត្រ សូមថ្វាយបង្គំនូវភ្នំហិមពាន្ត ជាស្តេចភ្នំដ៏ប្រសើរ ខ្ញុំសូមដល់នូវលោកជាទីពឹង។

[៥៤០] (សោត្ថិសេន...) រាជបុត្រី ជាស្ត្រីមានយស មកក្នុងវេលាល្ងាចម្ល៉េះ តើថ្ងៃនេះ នាងជួបប្រទះនឹងអ្នកណាហ្ន៎ អ្នកណាជាទីស្រឡាញ់របស់នាងជាងខ្ញុំ។

[៥៤១] (នាងសម្ពុលា...) ខ្ញុំម្ចាស់ដែលសត្រូវនោះចាប់បាន ក៏បានពោលពាក្យនេះថា យក្សទំពាស៊ីខ្ញុំម្ចាស់ដោយហេតុណា ហេតុនោះមិនមែនជាទុក្ខនៃខ្ញុំម្ចាស់ទេ ក្រែងតែព្រះហឫទ័យព្រះអយ្យបុត្ររបស់ខ្ញុំម្ចាស់ទៅជាបការៈដទៃ ដោយហេតុណា ហេតុនោះ (ទើបជាទុក្ខនៃខ្ញុំម្ចាស់)។

[៥៤២] (សោត្ថិសេន...) ពាក្យសច្ចៈក្នុងពួកស្រីចោរ មានមាយាច្រើន គេរកបានដោយក្រណាស់ ភាព គឺឫកមារយាទរបស់ស្ត្រីទាំងឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក។

[៥៤៣] (នាងសម្ពុលា...) ខ្ញុំម្ចាស់មិនធ្លាប់ស្គាល់នូវបុគ្គលដទៃជាទីស្រឡាញ់ជាងព្រះអង្គយ៉ាងណា បើ (ដំណើរ) របស់ខ្ញុំម្ចាស់ (នោះ) ជាសច្ចៈ យ៉ាងនោះ សូមសច្ចៈរក្សាព្រះអង្គ ទាំងរក្សានូវខ្ញុំម្ចាស់ ដោយពាក្យសច្ចៈនេះ សូមព្យាធិរបស់ព្រះអង្គស្ងប់រម្ងាប់។

[៥៤៤] (តាបស...) ដំរីទាំងឡាយច្រើនប្រមាណ ៧០០ មានអាវុធដែលយោធាប្រកបហើយ ទាំងពួកខ្មាន់ធ្នូមួយពាន់ប្រាំមួយរយតែងរក្សាទាំងយប់ទាំងថ្ងៃ ម្នាលនាងដ៏ចំរើន តើនាងនៅឃើញពួកសត្រូវដូចម្តេច។

[៥៤៥] (នាងសម្ពុលា...) ស្វាមីឃើញពួកស្ត្រី ដែលតាក់តែងកាយ មានសម្បុរស្បែកល្អ ដូចស្រទាប់ផ្កាឈូក មានចង្កេះរៀវ មានសំឡេងដូចហង្ស ទ្រង់ព្រះសណ្តាប់នូវចម្រៀង និងប្រគំដែលគេគួររាប់ របស់ពួកស្ត្រីទាំងនោះ បពិត្រព្រះបិតា ឥឡូវនេះ ព្រះស្វាមីរបស់ខ្ញុំម្ចាស់មិនប្រព្រឹត្តដូចកាលមុន យ៉ាងនោះទេ។ បពិត្រព្រះបិតា ពួកស្ត្រីមានរូបល្អ ទ្រទ្រង់នូវប្រដាប់សម្រាប់រឹតដោះ ជាវិការៈនៃមាស តាក់តែងខ្លួនជាស្ត្រីមនុស្ស ដូចស្ត្រីទេពអប្សរ ជាទីស្រឡាញ់នៃព្រះរាជាព្រះនាមសោត្ថិសេន ជាស្ត្រីមានរាងកាយតិះដៀលមិនបាន ជាខត្តិយកញ្ញាតែងប្រលោមព្រះរាជានោះ។ បពិត្រព្រះបិតា ប្រសិនបើខ្ញុំម្ចាស់ចិញ្ចឹមព្រះស្វាមីនោះ ដោយការស្វែងរកនូវផ្លែឈើក្នុងព្រៃ ដូចក្នុងកាលមុនយ៉ាងនោះទៀត ព្រះស្វាមីគប្បីរាប់អានខ្ញុំម្ចាស់ ទាំងមិនមើលងាយខ្ញុំម្ចាស់ទេ បពិត្រព្រះបិតា ព្រោះហេតុនោះ (ព្រៃ) របស់ខ្ញុំម្ចាស់ (នោះឯង) ប្រសើរជាងរាជសម្បត្តិ ក្នុងក្រុងពារាណសីនេះ។ នារីណា (កើតក្នុងផ្ទះត្រកូល) មានបាយ និងទឹកបរិបូណ៌ ដែលគេចាត់ចែងហើយ ជាស្ត្រីមានគ្រឿងប្រដាប់ដ៏ស្អាតវិសេស តាក់តែងខ្លួនប្រកបដោយអង្គគ្រប់យ៉ាង តែមិនជាទីស្រឡាញ់របស់ប្តី បានសំឡាប់ (ខ្លួន) ហើយ សេចក្តីស្លាប់របស់នារីនោះ ប្រសើរជាងការរស់នៅដោយរាវាសនោះទៅទៀត។ បើស្ត្រីណា ទាល់ក្រ កំព្រា មិនមានបបុស គឺមានតែកន្ទេលជាគំរប់ពីរ តែស្ត្រីនោះជាទីស្រឡាញ់របស់ប្តី ស្ត្រីណាទោះកំព្រា តែជាទីស្រឡាញ់ (របស់ប្តី) ស្ត្រីនេះឯងប្រសើរជាងស្ត្រីដែលប្រកបដោយអង្គគ្រប់យ៉ាង ដែលមិនជាទីស្រឡាញ់ (របស់ប្តី)។

[៥៤៦] (តាបស...) ស្ត្រីណាជាគុណរបស់បុរស ស្ត្រីនោះគេរកបានក្រក្រៃលែង ភស្តាណាជាគុណរបស់ស្ត្រី ភស្តានោះគេរកបានដោយក្រ ម្នាលបា ជាធំជាងជន ភរិយារបស់អ្នក ជាគុណ (នៃអ្នក) ផង ជាស្ត្រីមានសីលផង អ្នកចូរប្រព្រឹត្តធម៌ចំពោះនាងសម្ពុលា។

[៥៤៧] (ព្រះរាជាសោត្ថិសេន...) ម្នាលនាងសម្ពុលាមានភោគៈបានហើយដ៏ច្រើន បើនាងឆ្លងផុតចាកសេចក្តីប្រាថ្នា ដល់នូវមរណៈ អញ និងពួករាជកញ្ញាទាំងអស់របស់នាងនេះ នឹងធ្វើតាមពាក្យរបស់នាង។

ចប់ សម្ពុលាជាតក ទី៩។

## ភណ្ឌុតិណ្ឌុកជាតក ទី១០

CS sut.kn.jat.520 | ភាគទី ៦០

### (៥២០. គន្ធតិន្ទុកជាតកំ (១០))

[៥៤៨] (ភណ្ឌុតិណ្ឌុកទេវតាពោធិសត្វពោលថា) សេចក្តីមិនប្រហែសជាឧបាយឲ្យបាននូវព្រះនិព្វាន ឈ្មោះអមតៈ សេចក្តីប្រហែសជាផ្លូវនៃសេចក្តីស្លាប់ ពួកជនអ្នកមិនប្រហែស ឈ្មោះថាមិនស្លាប់ ពួកជនណា ជាអ្នកប្រហែស ពួកជននោះដូចជាស្លាប់ហើយ។ សេចក្តីប្រហែស រមែងកើតឡើង ព្រោះសេចក្តីស្រវឹង ការអស់ទៅ (នៃញាតិជាដើម) រមែងកើតឡើង ព្រោះសេចក្តីប្រហែស សេចក្តីប្រទូស្តទាំងឡាយ រមែងកើតឡើង ព្រោះការអស់ទៅ (នៃញាតិជាដើម) បពិត្រព្រះអង្គដ៏ប្រសើរ មានភារៈ (ក្នុងដែន) ព្រះអង្គកុំប្រហែសឡើយ។ ពួកក្សត្រិយ៍ច្រើនអង្គ មានសេចក្តីប្រហែស ញុំាងសេចក្តីចំរើន និងញុំាងដែនឲ្យវិនាស ចំណែកពួកមេស្រុក អ្នកស្រុក អ្នកបួស គ្រហស្ថក៏វិនាស។ បពិត្រព្រះរាជា ព្រះអង្គញុំាងដែនឲ្យចំរើន ភោគៈទាំងអស់ក្នុងដែនរបស់ក្សត្រជាអ្នកប្រហែសរមែងវិនាស សេចក្តីវិនាសនោះជាទុក្ខរបស់ព្រះរាជា។ បពិត្រមហារាជ សេចក្តីប្រហែសនេះ មិនមែនជាធម៌ (របស់ពួកព្រះរាជាបុរាណទេ) ព្រះអង្គប្រហែសហួសប្រមាណ ពួកចោរកំចាត់នូវជនបទដែលសម្បូណ៌ថ្កុំថ្កើងនោះ។ ពួកបុត្ររបស់ព្រះអង្គមិនមាន ទាំងប្រាក់ក៏មិនមាន ទាំងទ្រព្យក៏មិនមាន កាលបើចោរប្លន់រាស្ត្រ (យ៉ាងនេះ) ព្រះអង្គនឹងសាបសូន្យចាកភោគៈគ្រប់យ៉ាង។ ពួកញាតិមិត្រ និងសំឡាញ់ រមែងមិនទទួលដឹងនូវក្សត្រនោះដែលជាព្រះរាជាសាបសូន្យចាកភោគៈទាំងពួង ជាបុគ្គលដែលគួរទទួលដឹងទេ។ ពួកពលដំរី ពួកសេនា ពលរថ ពលថ្មើរជើង និងពួកកម្មករដែលអាស្រ័យចិញ្ចឹមជីវិតនឹងព្រះរាជានោះឯង ក៏មិនទទួលដឹងនូវព្រះរាជាដែលគួរទទួលដឹងនោះ។ សិរី គឺយសសម្បត្តិ រមែងលះបង់

នូវបុគ្គលពាល អ្នកមិនចាត់ចែងនូវការងារ មានគំនិតអាក្រក់ អាប់ឥតប្រាជ្ញា ដូចជាពស់លះបង់នូវសំណកចាស់។ ភោគៈទាំងអស់ រមែងចំរើនដល់បុគ្គលអ្នកចាត់ចែងការងារដោយល្អ ក្រោកឡើងទាន់កាល ជាអ្នកមិនខ្ជិលច្រអូស ដូចជាគោប្រព្រឹត្តទៅមួយអន្លើដោយគោឧសភ។ បពិត្រមហារាជ សូមព្រះអង្គយាងទៅកាន់ទីជាទីចាំស្តាប់ ក្នុងជនបទ ក្នុងដែន លុះទតឃើញ និងទ្រង់ព្រះសណ្តាប់ ក្នុងដែននោះហើយ ក៏យកការណ៍ តាមរាជកិច្ចនោះ តាមដំណើរនោះ។

[៥៤៩] (បុរសចាស់ម្នាក់ជេរថា) ខ្លួនអញត្រូវបន្លាមុតហើយ វេទនាក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យព្រះបាទបញ្ចាល ត្រូវសរក្នុងសង្គ្រាមហើយវេទនាយ៉ាងនោះដែរ។

[៥៥០] (បុរោហិតសួរថា) អ្នកជាមនុស្សចាស់ មានភ្នែកទុពិល មើលរូបមិនឃើញដោយស្រួលទេ បន្លាមុតអ្នកឯង ដោយហេតុណា (ទោស) របស់ព្រះរាជាព្រហ្មទត្តចំពោះហេតុនោះ តើដូចម្តេច។

[៥៥១] (បុរសចាស់...) ម្នាលព្រាហ្មណ៍ ក្នុងហេតុនេះ ទោសរបស់ព្រះរាជាព្រហ្មទត្ត មានច្រើន (បានជា) ខ្ញុំនោះ (ធ្លាក់) ក្នុងផ្លូវ (មានបន្លា) ព្រោះពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀតបៀនដោយពលិកម្ម (ស្វយសារអាករ) មិនប្រកបដោយធម៌។ ក្នុងវេលាយប់ ពួកចោរស៊ី (ប្លន់) ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ី ក្នុងដែនរបស់ព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌ មានច្រើន។ ម្នាលអ្នក កាលបើភ័យបែបនេះ កើតហើយ មនុស្សទាំងឡាយដែលត្រូវភ័យគ្របសង្កត់ តែងនាំយកនូវបន្លាក្នុងព្រៃ មកធ្វើជាទីសម្រាប់ពឹងពួន។

[៥៥២] (ស្ត្រីទុគ៌តម្នាក់ ជេរថា) ពួកកុមារីជាស្ត្រីគ្មានប្តីរហូតចាស់ ក្នុងដែននៃព្រះរាជាព្រហ្មទត្តណា កាលណាហ្ន៎ ព្រះរាជាព្រហ្មទត្តនេះនឹងស្លាប់ទៅ។

[៥៥៣] (បុរោហិតឃាត់ថា) នែនាងលាមក ជាស្ត្រីមិនឈ្លាសក្នុងឧបាយនៃសេចក្តីចំរើន ពាក្យនាង ជាពាក្យអាក្រក់ ព្រះរាជានឹងស្វែងរកប្តីឲ្យពួកនាងកុមារីក្នុងទីណា។

[៥៥៤] (ស្ត្រីចាស់...) នែព្រាហ្មណ៍ ពាក្យរបស់ខ្ញុំមិនអាក្រក់ទេ ខ្ញុំជាស្ត្រីឈ្លាសវៃក្នុងផ្លូវចំរើន ព្រោះពួកអ្នកជនបទ ស្តេចមិនរក្សាទ្រង់បៀតបៀនដោយសារស្វយអាករ មិនប្រកបដោយធម៌។ ក្នុងវេលាយប់ ពួកចោរស៊ី (ប្លន់) ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ីក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន កាលបើរាស្ត្ររស់នៅដោយលំបាក ចិញ្ចឹមប្រពន្ធបានដោយលំបាក តើពួកនាងកុមារីបានប្តីអំពីណា។

[៥៥៥] (អ្នកភ្ជួរជេរថា) គោឈ្មោះសាលិយៈនេះ ត្រូវផាលមុតហើយ ដេកស្រតឹកយ៉ាងណា សូមឲ្យព្រះរាជាក្រុងបញ្ចាល ត្រូវគេសម្លាប់ដោយលំពែងក្នុងសង្គ្រាម ដេកយ៉ាងនោះចុះ។

[៥៥៦] (បុរោហិត...) នែបុរសលាមក អ្នកណាខុសខ្លួនឯង ហើយផ្តាសាព្រះរាជា អ្នក (នោះ) ឈ្មោះថា ខឹងចំពោះព្រះរាជាព្រហ្មទត្តដោយហេតុមិនត្រូវតាមធម៌ទេ។

[៥៥៧] (អ្នកភ្ជួរ...) ម្នាលព្រាហ្មណ៍ ខ្ញុំខឹងចំពោះព្រះរាជាព្រហ្មទត្ត ដោយហេតុត្រឹមត្រូវតាមធម៌ (ព្រោះថា) ពួកអ្នកជនបទ ស្តេចមិនរក្សាទ្រង់បៀតបៀន ដោយស្វយសារអាករ មិនប្រកបដោយធម៌។ ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ីក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន។ ស្ត្រីជាអ្នកនាំបាយមកនោះ ប្រាកដជាដាំម្តងទៀត បានជានាំបាយមកក្នុងវេលារសៀល ខ្ញុំកំពុងរកមើលនូវស្ត្រីអ្នកនាំបាយមក គោឈ្មោះសាលិយៈ ក៏ត្រូវផាលមុត។

[៥៥៨] (អ្នករូតទឹកដោះជេរថា) ក្នុងថ្ងៃនេះ ខ្លួនអញ (ត្រូវមេគោ) ធាក់ ទាំងទឹកដោះរបស់អញកំពប់ទៅយ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលនគរ ត្រូវគេសម្លាប់ដោយដាវក្នុងសង្គ្រាម វិនាសយ៉ាងនោះចុះ។

[៥៥៩] (បុរោហិត...) សត្វចិញ្ចឹមនេះ ចាក់ចោលនូវទឹកដោះ សត្វចិញ្ចឹមបៀតបៀននូវផាល អ្នកដ៏ចំរើនតិះដៀលយើង ដោយហេតុណា កំហុសដូចម្តេច របស់ព្រះរាជាព្រហ្មទត្តក្នុងហេតុនោះ។

[៥៦០] (អ្នករូតទឹកដោះ...) ម្នាលព្រាហ្មណ៍ ព្រះរាជាបញ្ចាលនគររបស់រាជត្រកូលព្រហ្មទត្ត គួរអ្នកផងតិះដៀលហើយ ព្រោះថា ពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀតបៀន ដោយស្វយអាករ មិនប្រកបដោយធម៌។ ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ីក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន។ មេគោកាច ផ្លាង យើងមិនបានរូតនូវទឹកដោះណាក្នុងកាលមុន ក្នុងថ្ងៃនេះ ឥឡូវនេះ ពួកយើងក៏ត្រូវពួករាជបុរសអ្នកប្រាថ្នានូវទឹកដោះមករឹបជាន់ ទើបរូតនូវទឹកដោះនោះ។

[៥៦១] (ពួកក្មេងអ្នកស្រុកជេរថា) មេគោកំព្រា ជាសត្វព្រាត់ប្រាសនេះ ស្ទុះឆ្លេឆ្លាយ៉ាងណា សូមឲ្យព្រះរាជាបញ្ចាលនគរព្រាត់ប្រាសនិរាស រីងស្ងួត កន្ទក់កន្ទេញ យ៉ាងនោះចុះ។

[៥៦២] បុរោហិត...) សត្វចិញ្ចឹមរបស់អ្នករក្សានូវសត្វចិញ្ចឹម ស្ទុះឆ្លេឆ្លាក្តី ស្រែកក្តី ដោយហេតុណា កំហុសដូចម្តេចរបស់ព្រះរាជាព្រហ្មទត្ត ក្នុងហេតុនេះ។

[៥៦៣] (ពួកក្មេងអ្នកស្រុក...) បពិត្រមហាព្រាហ្មណ៍ កំហុសរបស់ព្រះរាជាព្រហ្មទត្ត (មានពិត) ព្រោះថា ពួកអ្នកជនបទ ព្រះរាជាមិនរក្សា ទ្រង់បៀតបៀន ដោយស្វយសារអាករ មិនប្រកបដោយធម៌។ ក្នុងវេលាយប់ ពួកចោរស៊ី ក្នុងវេលាថ្ងៃ ពួកអ្នករាជការបៀតបៀនស៊ីក្នុងដែនព្រះរាជាខូចកាច ជនមិនប្រកបដោយធម៌មានច្រើន ហេតុដូចម្តេចហ្ន៎ កូនគោរបស់យើងកំពុងបៅដោះ មានប្រយោជន៍ដល់ស្រោមដាវ ត្រូវរាជបុរសសម្លាប់។

[៥៦៤] (កង្កែបជេរថា) អញជាសត្វកើតក្នុងព្រៃ ត្រូវពួកក្អែកក្នុងស្រុកចឹកស៊ីក្នុងថ្ងៃនេះយ៉ាងណា សូមឲ្យស្តេចបញ្ចាលនគរ ព្រមទាំងបុត្រ ត្រូវគេកាប់ក្នុងចម្បាំងដាច់ខ្ទេចខ្ទី យ៉ាងនោះចុះ។

[៥៦៥] (បុរោហិត...) នែដង្កែប ព្រះរាជាទាំងឡាយ ក្នុងមនុស្សលោក មិនចាត់ចែងនូវការរក្សាក្នុងពួកសត្វទាំងពួងទេ ពួកក្អែកស៊ីនូវសត្វទាំងរស់ដូចជាឯង ដោយហេតុណា ព្រះរាជាមិនឈ្មោះថាមិនប្រព្រឹត្តធម៌ ដោយហេតុមានប្រមាណប៉ុណ្ណេះ។

[៥៦៦] (កង្កែប...) ឱអ្នកជាព្រហ្មចារី តែមានសភាពមិនប្រកបដោយធម៌សោះ ពោលនូវពាក្យសរសើរចំពោះក្សត្រិយ៍ កាលបើប្រជាជនជាច្រើន ដែលព្រះរាជារឹបជាន់ អ្នកនៅតែបូជាចំពោះព្រះរាជា ជាអ្នកមានវាទៈដ៏ក្រៃលែង។ នែព្រាហ្មណ៍ ប្រសិនបើដែននេះមានអ្នករាជការល្អ រមែងជាដែនស្តុកស្តម្ភ មានរាស្ត្ររីករាយជ្រះថ្លា ទាំងពួងក្អែក ក៏ស៊ីនូវដុំបាយដ៏ប្រសើរ ជាគ្រឿងបូជា (របស់មនុស្ស) ពួកក្អែកមិនគប្បី

ស៊ីសត្វទាំងរស់ប្រាកដដូចជាខ្ញុំទេ។

ចប់ ភណ្ឌុតិណ្ឌុកជាតក ទី១០។

ឧទ្ទាននៃតឹសនិបាតនោះគឺ

និយាយអំពីកឹឆន្ទជាតក ១ កុម្ភជាតក ១ ជយទ្ទិសជាតក ១ ឆទ្ទន្តជាតក ១ សម្ភវជាតក ១ មហាកបិជាតក ១ ទករក្ខសជាតក ១ នាគដ៏ប្រសើរឈ្មោះបណ្ឌរកៈ ១ សម្ពុលាជាតក ១ តិណ្ឌុកជាតក ១។

ចប់ តឹសនិបាត។

# ចត្តាលីសនិបាតជាតក

CS sut.kn.jat.v17 | ភាគទី ៦០

(១៧. ចត្តាលីសនិបាតោ)

## តេសកុណជាតក ទី១

CS sut.kn.jat.521 | ភាគទី ៦០

(៥២១. តេសកុណជាតកំ (១))

[៥៦៧] (ព្រះបាទព្រហ្មទត្តសួរថា) ម្នាលសត្វស្លាប អញសូមសួរអ្នកឈ្មោះវេស្សន្តរៈ សេចក្តីចំរើន ចូរមានដល់អ្នក កិច្ចដូចម្តេច ដែលអញជាអ្នកប្រាថ្នាដើម្បីសោយរាជ្យ ធ្វើហើយប្រសើរ។

[៥៦៨] (មៀមឈ្មោះវេស្សន្តរៈទូលថា) យូរណាស់ហើយ បិតារបស់ខ្ញុំព្រះអង្គព្រះនាម កំសៈ ជាអ្នកសង្គ្រោះក្រុងពារាណសី ទ្រង់ប្រហែស ជាបិតាចិញ្ចឹម បានចោទសួរនូវខ្ញុំព្រះអង្គ ជាកូនមិនប្រហែស។

[៥៦៩] (ខ្ញុំទូលថា) មុនដំបូង ព្រះរាជាត្រូវហាមឃាត់នូវពាក្យឃ្លៀងឃ្លាត សេចក្តីក្រោធ និងការសើចរទ្បេះរទ្បោះ តពីនោះ គប្បីធ្វើនូវកិច្ចទាំងឡាយ បពិត្រក្សត្រ បុរាណកបណ្ឌិតទាំងឡាយ បានពោលនូវពាក្យដែលខ្ញុំព្រះអង្គក្រាបទូលនោះ ថាជាវត្ត។ បពិត្រព្រះបិតា កម្មចំពោះហេតុដ៏ក្តៅក្រហាយណា ដែលព្រះអង្គធ្វើហើយ ក្នុងកាលមុន ឥតសង្ស័យ ព្រះអង្គត្រេកត្រអាលក្តី ទ្រង់ខ្វាល់ក្តី ធ្វើនូវកម្មណា ព្រះអង្គមិនត្រូវធ្វើនូវកម្មនោះ តទៅទៀតទេ។ បពិត្រព្រះអង្គអ្នកញ៉ាំងរាស្ត្រឲ្យចំរើន កាលបើក្សត្រិយ៍ប្រហែសហើយ ភោគសម្បត្តិទាំងអស់ក្នុងដែន នឹងវិនាសទៅ សេចក្តីវិនាសនោះ លោកពោលថាជាទុក្ខរបស់ព្រះរាជា។ បពិត្រព្រះបិតា បុគ្គលមានសិរី និងបុគ្គលមានបុណ្យ ដែលសុចិបរិវារសេដ្ឋីសួរហើយ បានពោលពាក្យនេះថា ខ្ញុំត្រេកអរចំពោះបុរសមានសេចក្តីខ្មីឃ្មាត មានសេចក្តីប្រឹងប្រែង ជាអ្នកមិនច្រណែន។ បពិត្រមហារាជ បុគ្គលកាឡកណ្ណី ជាអ្នកកាច់បំបាក់នូវចក្រ គឺកុសល តែងត្រេកអរក្នុងបុរសជាអ្នកច្រណែន មានចិត្តអាក្រក់ ជាអ្នកប្រទូស្តចំពោះកល្យាណកម្ម។ សូមព្រះអង្គមានហ្ឫទ័យល្អចំពោះពួកជនទាំងពួង សូមព្រះអង្គរក្សានូវពួកជនទាំងពួង បពិត្រមហារាជ សូមព្រះអង្គបណ្តេញនូវបុគ្គលឥតបុណ្យចេញ សូមព្រះអង្គយកបុគ្គលមានបុណ្យ មកជាទីពំនាក់វិញ។ បពិត្រព្រះអង្គជាម្ចាស់ដែនកាសី ព្រោះថាបុរសមានបុណ្យ បរិបូណ៌ដោយបញ្ញា តាំងនៅក្នុងអធ្យាស្រ័យដ៏ធំ រមែងកាត់បង់នូវគល់ និងចុង នៃសត្រូវទាំងឡាយបាន។ បពិត្រព្រះអង្គជាម្ចាស់នៃមនុស្ស ដូចយ៉ាងព្រះឥន្ទ្រក៏មិនប្រហែសក្នុងការខ្មីឃ្មាតដែរ លោកធ្វើនូវការព្យាយាមចំពោះកម្មដ៏ល្អ ទាំងធ្វើព្រះហ្ឫទ័យក្នុងការខ្មីឃ្មាត (ជាដរាប)។ ពួកគន្ធព្វ ពួកបិតា (ព្រហ្ម) ពួកទេវតា មានអាជីវៈអាស្រ័យនឹងព្រះរាជា ដែលមានអំណរនឹងបុញ្ញកម្មយ៉ាងនោះ ពួកទេវតាតែងតាមថែ (រក្សា) នូវព្រះរាជា ជាអ្នកខ្មីឃ្មាតមិនប្រហែស។ បពិត្រព្រះបិតា ព្រះអង្គជាអ្នកមិនប្រហែស មិនក្រោធ សូមធ្វើនូវកិច្ចទាំងឡាយចុះ សូមព្រះអង្គប្រឹងប្រែងក្នុងកិច្ចទាំងឡាយរបស់ព្រះអង្គ បុគ្គលខ្ជិលច្រអូស រមែងមិនបានសេចក្តីសុខទេ។ នោះជាវត្តបទក្នុងបញ្ហានោះឯង នុ៎ះឯងជាអនុសាសនី (របស់ព្រះអង្គ) ព្រះរាជា កាលប្រព្រឹត្តយ៉ាងនេះ ទើបអាចញ៉ាំងពួកមិត្តឲ្យបានសុខផង អាចញ៉ាំងពួកសត្រូវ ឲ្យបានទុក្ខផង។

[៥៧០] (ព្រះរាជា...) ម្នាលនាងកុណ្ឌលិនី នាងអាច (ឆ្លើយប្រស្នាបាន) នាងជាពង្សនៃមហាសេនគុត្ត[35] ឈ្មោះខត្តៈ ដឹង (នូវអាថិប្រស្នា) កិច្ចដូចម្តេចដែលយើងប្រាថ្នាដើម្បីសោយរាជ្យ ធ្វើហើយប្រសើរ។

[៥៧១] (សារិកាឈ្មោះកុណ្ឌលិនី) បពិត្រព្រះបិតា ប្រយោជន៍ និងសេចក្តីសុខទាំងអស់ តាំងនៅក្នុងបទណា បទនោះមានពីរយ៉ាង គឺការបាននូវរបស់ដែលមិនធ្លាប់បាន ១ រក្សានូវរបស់ដែលបានមកហើយ ១។ បពិត្រព្រះបិតា សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយ ដែលមានប្រាជ្ញាឈ្លាសវៃចំពោះប្រយោជន៍ បពិត្រព្រះបិតា សូមព្រះអង្គជ្រាបនូវអាមាត្យទាំងឡាយ ដែលមិនលេងល្បែងភ្នាល់ មិនបោកប្រាស មិនជាអ្នកលេងស៊ីផឹក មិនជាអ្នកបំផ្លាញព្រះរាជទ្រព្យ។ បពិត្រព្រះបិតា អាមាត្យណាគប្បីរក្សានូវទ្រព្យរបស់ព្រះអង្គដែលមានដូចនាយសារថីប្រុងប្រយ័ត្ននូវរថ អាមាត្យនោះ ព្រះអង្គគប្បីឲ្យធ្វើនូវកិច្ចការទាំងឡាយរបស់ព្រះអង្គ។ សូមព្រះអង្គដែលមានជនខាងក្នុងសង្គ្រោះល្អ ត្រួតត្រាមើលនូវព្រះរាជទ្រព្យដោយព្រះអង្គឯង មិនគួរធ្វើនូវកំណប់ទ្រព្យ និងការឲ្យជាបំណុលដោយជឿអ្នកដទៃទេ។ ព្រះអង្គគប្បីជ្រាបនូវសេចក្តីចំរើន និងសេចក្តីវិនាសដោយព្រះអង្គឯង គប្បីជ្រាបនូវកិច្ចការដែលបានធ្វើ និងមិនបានធ្វើដោយព្រះអង្គឯង គប្បីសង្កត់សង្កិននូវបុគ្គលដែលគួរសង្កត់សង្កិន គប្បីលើកតំកើងនូវបុគ្គលដែលគួរលើកតំកើង។ បពិត្រព្រះអង្គជាធំលើរថ សូមព្រះអង្គប្រៀនប្រដៅនូវប្រយោជន៍ដល់អ្នកជនបទដោយព្រះអង្គឯង ពួករាជបុរសអ្នកប្រកបការមិនត្រឹមត្រូវតាមធម៌ សូមកុំឲ្យញ៉ាំងទ្រព្យ និងដែនរបស់ព្រះអង្គឲ្យវិនាស។ មួយទៀត សូមព្រះអង្គកុំធ្វើ ឬប្រើគេឲ្យធ្វើនូវរាជកិច្ចទាំងឡាយដោយរួសរាន់ ព្រោះមនុស្សល្ងង់ខ្លៅ តែងក្តៅក្រហាយរឿយៗ ក្នុងកាលខាងក្រោយ ចំពោះការងារដែលខ្លួនធ្វើដោយរួសរាន់។ សូមព្រះអង្គកុំបញ្ចេញនូវព្រះហ្ឫទ័យក្រោធខ្លាំងពេក ចំពោះអកុសល (របស់អ្នកដទៃ) ដែលប្រព្រឹត្តកន្លង (នូវការកុសល) ព្រោះថា ត្រកូលទាំងឡាយដែលថ្កុំថ្កើងហើយ ច្រើនដល់នូវភាវៈមិនមែនជាត្រកូលទៅវិញ ព្រោះសេចក្តីក្រោធ។ បពិត្រព្រះបិតា សូមព្រះអង្គកុំបណ្តោយ (មហាជន) ឲ្យធ្លាក់ទៅក្នុងសេចក្តីវិនាស ដោយគិតថា ខ្លួនអញជាឥស្សរៈ ការកើតឡើងនៃទុក្ខលំបាក កុំឲ្យមានដល់ស្ត្រីបុរសទាំងឡាយក្នុងដែនរបស់ព្រះអង្គ។ ភោគសម្បត្តិទាំងអស់របស់ព្រះរាជា ជាអ្នកប្រាសចាកការព្រឺរោម (ឥតកោតញញើត) តាមចំណង់ នឹងវិនាសទៅ (ដោយពិត) ការវិនាសនោះ លោកពោលថាជាទុក្ខរបស់ព្រះរាជា។ នោះជាវត្តបទក្នុងបញ្ហានោះឯង នុ៎ះឯងជាអនុសាសនី ឥឡូវនេះ សូមព្រះអង្គសង្វាតធ្វើបុណ្យ កុំជាអ្នកលេង កុំញ៉ាំងប្រយោជន៍ឲ្យវិនាស បពិត្រមហារាជ សូមព្រះអង្គមានសីល (ព្រោះថា) បុគ្គលអ្នកទ្រុស្តសីល ឈ្មោះថាជាអ្នកញ៉ាំងខ្លួនឲ្យធ្លាក់ចុះ។

[៥៧២] (ព្រះរាជា...) អញបានសួរវេស្សន្តរៈ ជាកោសិយគោត្រ និងនាងកុណ្ឌលិនី ដោយប្រការដូច្នោះហើយ ម្នាលជម្ពុកៈ ឥឡូវនេះ អ្នកចូរពោលនូវកំឡាំងដ៏ឧត្តម ជាងកំឡាំងទាំងឡាយ។

[៥៧៣] (សេកជម្ពុកពោធិសត្វ...) កំឡាំងក្នុងលោក មាន ៥ យ៉ាង រមែងមានក្នុងបុរសដែលមានអធ្យាស្រ័យធំ បណ្តាកំឡាំងទាំងនោះ កំឡាំងដៃ (កាយ) បណ្ឌិតពោលថាជាកំឡាំងថោកទាប បពិត្រព្រះអង្គមានព្រះជន្មវែង កំឡាំងភោគៈ បណ្ឌិតពោលថាជាកំឡាំង ទី ២។ បពិត្រព្រះអង្គមានព្រះជន្មវែង កំឡាំងអាមាត្យ បណ្ឌិតពោលថាជាកំឡាំងទី ៣ កំឡាំងជាតិខ្ពស់ ជាកំឡាំងទី ៤ ឥតសង្ស័យ បុគ្គលជាបណ្ឌិត រមែងគ្របសង្កត់នូវកំឡាំងទាំងអស់នេះ។ កំឡាំងបញ្ញានោះ ជាកំឡាំងប្រសើរ ជាកំឡាំងខ្ពង់ខ្ពស់ជាងកំឡាំងទាំងឡាយ បណ្ឌិតដែលមានកំឡាំងបញ្ញាជ្រោមជ្រែងហើយ រមែងបាននូវសេចក្តីចំរើន។ បុគ្គលមានបញ្ញាទន់ ទោះបីបាននូវផែនដីស្តុកស្តម្ភប្រសើរ កាលបើបុគ្គលមានបញ្ញាទន់នោះ មិនមានប្រាថ្នា បុគ្គលដែលមានបញ្ញាដទៃ ធ្វើនូវការកំហែង ហើយគ្រប់គ្រងនូវផែនដីនោះ។ បពិត្រព្រះអង្គជាម្ចាស់ដែនកាសី បើទុកជាបុគ្គលមានជាតិខ្ពង់ខ្ពស់ ជាក្សត្របាននូវរាជ្យ តែអ័ប្បបញ្ញា ក៏រមែងមិនរស់នៅ ដោយរាជ្យទាំងពួងបាន។ បញ្ញាជាធម្មជាតិសម្រាប់វិនិច្ឆ័យក្នុងសេចក្តីដែលបានស្តាប់ បញ្ញាជាគ្រឿងញ៉ាំងកេរ្តិ៍ឈ្មោះ និងលាភសក្ការៈឲ្យចំរើន នរជនប្រកបដោយបញ្ញា ក្នុងលោកនេះ សូម្បីទុក្ខ (កើតឡើង) ក៏រមែងបានសុខទាំងឡាយវិញ។ មួយទៀត បុគ្គលណាមួយ មិនស្តាប់ដោយគោរព មិនជឿនូវបុគ្គលជាពហុស្សុត មិនឈ្វេងយល់នូវកិច្ចការដែលឋិតនៅក្នុងសភាវៈ រមែងមិនបាននូវបញ្ញា។ លុះតែបុគ្គលណាជាអ្នកដឹងនូវចំណែកនៃធម៌ ប្រឹងប្រែងក្នុងកាលគួរ មិនខ្ជិលច្រអូស ប្រឹងប្រែងរឿយៗ តាមកាលគួរ ផលកើតអំពីការងារ ទើបសម្រេចដល់បុគ្គលនោះ។ កាលបុគ្គលមិនមានសីលជាទីកើត (នៃលាភ យស សុខ) សេពគប់នូវបុគ្គលទ្រុស្តសីល មិនជាទីកើត (នៃលាភ យស សុខ) ធ្វើការធុញទ្រាន់ ប្រយោជន៍រមែងមិនឲ្យផលដោយប្រពៃទេ។ លុះតែបុគ្គលប្រកបកិច្ចខាងក្នុងសន្តាន សេពគប់នូវបុគ្គលមានសីលជាទីកើត (នៃលាភ យស សុខ) ដូច្នោះ ធ្វើការងារមិនធុញទ្រាន់ ប្រយោជន៍រមែងឲ្យផលដោយប្រពៃ។ បពិត្របិតា សូមព្រះអង្គគប់រកនូវហេតុទាំងឡាយនោះ គឺបញ្ញាជាចំណែកនៃព្យាយាម ក្នុងហេតុដែលគួរប្រកប និងការថែទាំទុកនូវទ្រព្យដែលព្រះអង្គបាន ព្រះអង្គកុំ (ញ៉ាំងទ្រព្យ) ឲ្យវិនាសដោយការងារមិនគួរ ព្រោះថា បុគ្គលឥតបញ្ញា រមែងលិចចុះ (ក្នុងសេចក្តីវិនាស) ដោយហេតុមិនមែនជាការងារ ដូចផ្ទះដែលគេធ្វើដោយដើមបបុស។

[៥៧៤] បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការបំរើមាតាបិតាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺការសង្គ្រោះចំពោះបុត្តភរិយាទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះមិត្រ និងអាមាត្រទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះពាហនៈ និងពលទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះជនអ្នកស្រុក និងអ្នកនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែន និងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះពួកសមណៈ និងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ គឺឲ្យអភ័យចំពោះពួកម្រឹគ និងសត្វបក្សីទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ (ព្រោះថា) ធម៌ដែលព្រះអង្គប្រព្រឹត្តហើយ រមែងនាំមកនូវសេចក្តីសុខ បពិត្រព្រះរាជា លុះព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ព្រោះពួកព្រះឥន្ទ្រ ទេវតា ព្រមទាំងព្រហ្ម បានដល់នូវទិព្វសម្បត្តិ ដោយធម៌ដែលខ្លួនប្រព្រឹត្តល្អ បពិត្រព្រះរាជា សូមព្រះអង្គកុំប្រហែសចំពោះធម៌។ នោះជាវត្តបទក្នុងបញ្ហានោះឯង នុ៎ះឯងជាអនុសាសនី សូមព្រះអង្គសេពគប់នូវបុគ្គលមានបញ្ញា សូមមានគុណធម៌ដ៏ល្អ ជ្រាបច្បាស់នូវធម៌នោះដ៏បរិបូណ៌ដោយព្រះអង្គឯង (ប្រតិបត្តិតាមពាក្យប្រៀនប្រដៅចុះ)។

ចប់ តេសគុណជាតក ទី១។

## សរភង្គជាតក ទី២

CS sut.kn.jat.522 | ភាគទី ៦០

### (៥២២. សរភង្គជាតកំ (២ ))

[៥៧៥] (អនុសិស្សតាបសសួរថា) បពិត្រលោក រថទាំងឡាយប្រសើរ លោកទាំងឡាយ មានខ្លួនប្រដាប់ហើយ មានកុណ្ឌល មានសំពត់ស្លៀកល្អ សៀតព្រះខ័នមានដងប្រដាប់ដោយកែវពៃទូរ្យ និងកែវមុក្តា ឈរនៅ (លើរថតែមួយ) លោកទាំងឡាយឈ្មោះអ្វី ពួកជនក្នុងមនុស្សលោក ស្គាល់លោកទាំងឡាយដូចម្តេច។

[៥៧៦] (ព្រះរាជាព្រះនាមអដ្ឋកៈត្រាស់ថា) ខ្ញុំជាព្រះរាជាឈ្មោះអដ្ឋកៈ នេះជាព្រះរាជាព្រះនាមភីមរថ នេះជាព្រះរាជាព្រះនាមកាលិង្គ ដែលមានតេជានុភាព មានកិត្តិស័ព្ទល្បីល្បាញ យើងទាំងឡាយមកក្នុងទីនេះ ដើម្បីឃើញនូវឥសីទាំងឡាយដែលសង្រួមល្អហើយ ដើម្បីសួរនូវប្រស្នាទាំងឡាយ។

[៥៧៧] (អនុសិស្សតាបស...) លោកឋិតនៅឰដ៏អាកាស ជាទីរីករាយនៃសត្វស្លាប ដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត ដែលឋិតនៅនាគន្លងផ្លូវឆ្ងាយ (អាកាស) បពិត្រយក្ស អាត្មាសូមសួរលោកដែលមានអានុភាពធំ ពួកជនក្នុងមនុស្សលោក នឹងស្គាល់លោកដូចម្តេច។

[៥៧៨] (សក្កទេវរាជ...) ទេវតាទាំងឡាយក្នុងពួកទេវតា បានហៅខ្ញុំណាថា មឃវា ខ្ញុំនោះ ជាទេវរាជមកកាន់ទីនេះ ក្នុងថ្ងៃនេះ ដើម្បីឃើញឥសីទាំងឡាយ អ្នកសង្រួមល្អហើយ។

[៥៧៩] ឥសីទាំងឡាយរបស់យើងខ្ញុំ ដែលជួបជុំគ្នា មានឫទ្ធិធំ ប្រកបដោយគុណ គឺឫទ្ធិ ល្បីទៅក្នុងទីឆ្ងាយ ខ្ញុំមានចិត្តជ្រះថ្លា សូមថ្វាយបង្គំលោកម្ចាស់ទាំងឡាយ ដែលប្រសើរក្នុងពួកមនុស្សក្នុងជីវលោកនេះ។

[៥៨០] (អនុសិស្សតាបស...) ក្លិនរបស់ឥសីទាំងឡាយដែលបួសយូរ រមែងផ្សាយចេញចាកកាយទៅតាមខ្យល់ បពិត្រសហស្សនេត្ត សូមព្រះអង្គថយចេញចាកទីនេះ បពិត្រទេវរាជ ក្លិនរបស់ឥសីទាំងឡាយមិនស្អាតទេ។

[៥៨១] (សក្កទេវរាជ...) ក្លិនរបស់ឥសីទាំងឡាយដែលបួសយូរ ចូរផ្សាយចេញចាកកាយទៅតាមខ្យល់ចុះ បពិត្រលោកដ៏ចំរើន យើងខ្ញុំរមែងប្រាថ្នានូវក្លិននុ៎ះ ដូចបុគ្គលប្រាថ្នានូវកម្រងផ្កា មានផ្កាដ៏វិចិត្រ មានក្លិនក្រអូប ព្រោះទេវតាទាំងឡាយ ជាអ្នកមិនមានសេចក្តីសំគាល់ក្នុងក្លិននុ៎ះ ថាជាបដិកូលទេ។

[៥៨២] (អនុសិស្សតាបស...) ទេវរាជនោះឈ្មោះបុរិន្ទទៈ ឈ្មោះភូតបតី ជាអ្នកមានយស ឈ្មោះទេវានមិន្ទៈ ឈ្មោះមឃវា ឈ្មោះសុជម្បតិ ជាអ្នកញាំញី (នូវពួក) អសុរ ទ្រង់ប្រាថ្នានូវឱកាសដើម្បីសួរប្រស្នា។ ក្នុងទីនេះ បណ្ដាឥសីជាបណ្ឌិតទាំងឡាយនេះ បណ្ឌិតណាហ្ន៎ ដែលព្រះរាជាទាំង ៣ ព្រះអង្គ ជាធំជាងមនុស្ស និងព្រះវាសវៈជាធំជាងពួកទេវតា ត្រាស់សួរប្រស្នាដ៏ល្អិតហើយ នឹងឆ្លើយបាន។

[៥៨៣] (ពួកឥសី...) ឥសីឈ្មោះសរភង្គៈនេះ មានតបៈ ជាអ្នកវៀរចាកមេថុនធម្ម តាំងអំពីកើតមក ជាបុត្រនៃបុរោហិតដែលជាអាចារ្យ (របស់ព្រះរាជាពារាណសី) មានសភាពរៀបរយល្អហើយ ឥសីឈ្មោះសរភង្គៈនោះ នឹងឆ្លើយនូវប្រស្នាទាំងឡាយរបស់ព្រះរាជាទាំងនោះបាន។

[៥៨៤] (អនុសិស្សតាបស...) បពិត្រកោណ្ឌញ្ញៈ សូមលោកឆ្លើយនូវប្រស្នាទាំងឡាយ ឥសីទាំងឡាយមានសភាពដ៏ល្អ អារាធនាលោក បពិត្រកោណ្ឌញ្ញៈ ការដោះប្រស្នានុ៎ះ ជាទំនៀមតែងមានក្នុងពួកមនុស្ស ប្រស្នាណា មកកាន់សេចក្ដីចំរើន ប្រស្នានុ៎ះ ជាភារៈរបស់លោក។

[៥៨៥] (សរភង្គតាបស...) លោកដ៏ចំរើនទាំងឡាយ ខ្ញុំធ្វើឱកាសឲ្យហើយ ចូរសួរនូវប្រស្នាណានីមួយ ដែលលោកទាំងឡាយប្រាថ្នាហើយដោយចិត្តចុះ ព្រោះថា ខ្ញុំដឹងនូវលោកនេះ និងលោកខាងមុខដោយខ្លួនឯង នឹងឆ្លើយនូវប្រស្នានោះៗ ប្រាប់លោកទាំងឡាយបាន។

[៥៨៦] (អភិសម្ពុទ្ធគាថា) លំដាប់នោះ ទេវរាជបុរិន្ទទៈ មឃវា សក្កៈ អ្នកឃើញនូវប្រយោជន៍ បានសួរប្រស្នាជាដំបូងដែលខ្លួនប៉ងទុកហើយថា បុគ្គលសម្លាប់អ្វីមិនក្រៀមក្រំ ក្នុងកាលណាម្ដងឡើយ ឥសីទាំងឡាយ សរសើរនូវការលះបង់អ្វី បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ ដែលបុគ្គលណាពោលហើយក្នុងលោកនេះ បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំ។

[៥៨៧] (សរភង្គតាបស...) បុគ្គលសម្លាប់សេចក្ដីក្រោធ រមែងមិនក្រៀមក្រំក្នុងកាលណាម្ដងឡើយ ឥសីទាំងឡាយ រមែងសរសើរនូវការលះបង់នូវសេចក្ដីលុបគុណគេ បុគ្គលគប្បីអត់ធន់ចំពោះពាក្យអាក្រក់ ដែលបុគ្គលទាំងពួងពោលហើយ ពួកសប្បុរសពោលនូវសេចក្ដីអត់ធន់នុ៎ះ ថាជាគុណជាតិដ៏ឧត្តម។

[៥៨៨] (សក្កទេវរាជ...) បុគ្គលអាចអត់ធន់នូវពាក្យរបស់ជនទាំងពីរពួកបាន គឺបុគ្គលស្មើគ្នា និងបុគ្គលប្រសើរជាង ចុះបុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលថោកទាប តើដូចម្ដេច បពិត្រកោណ្ឌញ្ញៈ សូមលោកប្រាប់សេចក្ដីនុ៎ះដល់ខ្ញុំ។

[៥៨៩] (សរភង្គតាបស...) បុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលដ៏ប្រសើរ ព្រោះសេចក្ដីខ្លាច ឯបុគ្គលអត់ធន់នូវពាក្យរបស់បុគ្គលស្មើៗ គ្នា ព្រោះហេតុនៃការប្រណាំងប្រជែង ចំណែកបុគ្គលណា ក្នុងលោកនេះ អត់ធន់នូវពាក្យរបស់បុគ្គលថោកទាបបាន សប្បុរសទាំងឡាយពោលនូវសេចក្ដីអត់ធន់នុ៎ះ (របស់បុគ្គលនោះ) ថាជាគុណជាតិដ៏ខ្ពង់ខ្ពស់។

[៥៩០] ធ្វើដូចម្ដេច បុគ្គលគប្បីដឹងច្បាស់នូវបុគ្គលប្រសើរជាង ឬបុគ្គលស្មើៗ គ្នា ឬក៏បុគ្គលថោកទាប ដែលមានសភាពបិទបាំងដោយឥរិយាបថ ៤ បាន សប្បុរសទាំងឡាយ តែងប្រព្រឹត្តតាមរូបនៃបុគ្គលផ្សេងៗ គ្នា ព្រោះហេតុនោះ បុគ្គលគួរអត់ធន់នូវពាក្យរបស់បុគ្គលទាំងពួង។

[៥៩១] សប្បុរសអ្នកមានខន្តី គប្បីបាននូវសេចក្ដីចំរើនណា សេនាធំព្រមដោយព្រះរាជា កាលច្បាំងគ្នា មិនគប្បីបាននូវសេចក្ដីចំរើននុ៎ះទេ ពៀរទាំងឡាយរបស់បុគ្គលអ្នកមានខន្តីជាកំឡាំង រមែងស្ងប់រម្ងាប់បាន។

[៥៩២] (សក្កទេវរាជ...) ខ្ញុំរីករាយនឹងសុភាសិតរបស់លោកហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកពោលប្រស្នានោះដូចយ៉ាងព្រះបាទទណ្ឌកី ព្រះបាទនាលិកីរៈ ព្រះបាទអជ្ជុនៈ និងព្រះបាទកលាពុ សូមលោកប្រាប់នូវគតិរបស់ស្ដេចទាំងនោះ ដែលមានបាបកម្មដ៏ធ្ងន់ តើព្រះរាជាទាំងនោះ ជាអ្នកបៀតបៀននូវឥសីទាំងឡាយ ទៅកើតក្នុងទីណា។

[៥៩៣] (សរភង្គតាបស...) ព្រះបាទទណ្ឌកី ព្រមទាំងជន ទាំងអ្នកដែន បានស្ដោះដាក់តាបសឈ្មោះកីសវច្ឆៈ ព្រះអង្គមានមូលដាច់ហើយ ឆេះក្នុងនរកឈ្មោះកុក្កុលៈ រងើកភ្លើងទាំងឡាយធ្លាក់មិនដាច់ លើកាយនៃព្រះអង្គ។ ព្រះបាទនាលិកីរៈណា បានបៀតបៀនបព្វជិតទាំងឡាយ ជាអ្នកសង្រួម ជាអ្នករម្ងាប់បាប មិនប្រទូស្ត កំពុងសំដែងធម៌ ឆ្កែទាំងឡាយចោមខាំស៊ីនូវព្រះបាទនាលិកីរៈនោះ ឲ្យរអន្ទះអន្ទែងក្នុងបរលោក។ ឯព្រះបាទអជ្ជុនៈ មានព្រះសិរចុះក្រោម មានព្រះបាទឡើងលើ ធ្លាក់ក្នុងនរកឈ្មោះសត្តិសូលៈ ព្រោះតែបៀតបៀននូវឥសីឈ្មោះអង្គីរសៈ ជាគោតមគោត្រ ជាអ្នកអត់ធន់ មានតបៈ ប្រព្រឹត្តធម៌ដ៏ប្រសើរអស់កាលយូរ។ ព្រះបាទកលាពុណា បានកាត់ឲ្យជាកំណាត់តូច និងកំណាត់ធំ នូវបព្វជិតដែលពោលនូវខន្តិ ជាអ្នករម្ងាប់បាប ជាអ្នកមិនប្រទូស្ត ព្រះបាទកលាពុ (នោះ) ក៏កើតឆេះនៅក្នុងនរកឈ្មោះអវីចិ មានកំដៅដ៏ខ្លាំង មានវេទនាដ៏ផ្សាក្ដៅ ជាទីគួរខ្លាច។ បណ្ឌិតបានឮនូវនរកទាំងឡាយនេះផង នូវនរកទាំងឡាយដទៃដ៏លាមកលើសជាងនរកនេះផង គួរប្រព្រឹត្តធម៌ក្នុងសមណព្រាហ្មណ៍ទាំងឡាយ លុះធ្វើយ៉ាងនេះហើយ រមែងកើតក្នុងឋានសួគ៌។

[៥៩៤] (សក្កទេវរាជ...) ខ្ញុំត្រេកអរនឹងសុភាសិតរបស់លោកម្ចាស់ហើយ សូមសួរនូវប្រស្នាដទៃ ចំពោះលោកម្ចាស់ទៀត សូមលោកម្ចាស់ប្រាប់នូវប្រស្នានោះ បណ្ឌិតទាំងឡាយពោលនូវបុគ្គលបែបដូចម្ដេច ថាជាអ្នកមានសីល ពោលនូវបុគ្គលបែបដូចម្ដេច ថាជាអ្នកមានប្រាជ្ញា ពោលនូវបុគ្គលបែបដូចម្ដេច ថាជាសប្បុរស សិរីមិនលះបង់នូវបុគ្គលបែបដូចម្ដេច។

[៥៩៥] (សរភង្គតាបស...) បុគ្គលណាក្នុងលោកនេះ ជាអ្នកសង្រួមដោយកាយ ដោយវាចា ទាំងមិនធ្វើនូវបាបតិចតួចដោយចិត្ត មិនពោលពាក្យឡេះឡោះ ព្រោះហេតុនៃខ្លួន បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះ ថាជាអ្នកមានសីល។ បុគ្គលណា កាលគិតនូវប្រស្នាដ៏ជ្រាលជ្រៅដោយចិត្ត ហើយមិនធ្វើនូវអំពើអាក្រក់ ដែលកន្លងនូវប្រយោជន៍ មិនលះបង់នូវចំណែកនៃប្រយោជន៍ ដែលមកក្នុងកាលគួរ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះ ថាជាអ្នកមានបញ្ញា។ បុគ្គលណា ជាកតញ្ញូកតវេទី មានប្រាជ្ញា មានមិត្រល្អ មានការសេពគប់មាំ ធ្វើនូវកិច្ចដោយគោរព ចំពោះបុគ្គលអ្នកដល់នូវសេចក្ដីទុក្ខ បណ្ឌិតទាំងឡាយ ពោលនូវបុគ្គលបែបនោះ ថាជាអ្នកសប្បុរស។ បុគ្គលណា ជាអ្នកប្រកបដោយគុណទាំងពួងនេះ ជាអ្នកមានសទ្ធា មានចិត្តទន់ ជាអ្នកចែករំលែក ជាអ្នកដឹងនូវពាក្យ (របស់ស្មូម) សិរីមិនលះបង់នូវបុគ្គលជាអ្នកសង្គ្រោះ មានវាចាពីរោះ មានវាចា មដ្ឋចត់បែបនោះទេ។

[៥៩៦] (សក្កទេវរាជ...) ខ្ញុំរីករាយនឹងសុភាសិតរបស់លោកហើយ សូមសួរនូវប្រស្នាដទៃនឹងលោកទៀត សូមលោកម្ចាស់ប្រាប់នូវប្រស្នានោះ បណ្ឌិតទាំងឡាយ ពោលនូវសីលផង សិរីផង ធម៌របស់សប្បុរសផង ប្រាជ្ញាផង តើគុណជាតិណាប្រសើរបំផុត។

[៥៩៧] (សរភង្គតាបស...) អ្នកឈ្លាសវៃទាំងឡាយ ពោលថាប្រាជ្ញាជាគុណជាតិប្រសើរបំផុត ដូចស្ដេចនៃផ្កាយ (ព្រះចន្ទ្រ) ដ៏ប្រសើរជាងផ្កាយទាំងឡាយ ទុកជាសីលក្ដី សិរីក្ដី ធម៌របស់សប្បុរសក្ដី ក៏ប្រព្រឹត្តទៅតាមបុគ្គលអ្នកមានប្រាជ្ញា។

[៥៩៨] (សក្កទេវរាជ...) ខ្ញុំរីករាយនឹងសុភាសិតរបស់លោកហើយ សូមសួរប្រស្នាដទៃនឹងលោកទៀត សូមលោកប្រាប់ប្រស្នានោះ បុគ្គលក្នុងលោកនេះ ធ្វើដូចម្ដេច ធ្វើការងារអ្វី ប្រព្រឹត្តដូចម្ដេច សេពនូវអ្វី ទើបបាននូវប្រាជ្ញា សូមលោកម្ចាស់ ប្រាប់នូវបដិបទានៃប្រាជ្ញា

ក្នុងកាលឥឡូវនេះ បុគ្គលធ្វើដូចម្តេច ទើបជាអ្នកមានប្រាជ្ញា។

[៥៩៩] (សរភង្គតាបស...) បុគ្គលគប្បីសេពគប់នូវពួកអ្នកចំរើន (ដោយប្រាជ្ញា) អាចដឹងនូវហេតុដ៏ល្អិត ជាពហុស្សូត គប្បីជាអ្នករៀនផង ជាអ្នកសាកសួរផង គប្បីស្តាប់នូវសុភាសិតទាំងឡាយដោយគោរពផង បុគ្គលធ្វើយ៉ាងនេះ ទើបជាអ្នកមានប្រាជ្ញា។ បុគ្គលជាអ្នកប្រាជ្ញនោះ ឃើញច្បាស់នូវកាមគុណទាំងឡាយ ថាមិនទៀង ថាជាទុក្ខ ថាជារោគ បុគ្គលឃើញច្បាស់យ៉ាងនេះ ទើបលះបង់នូវឆន្ទៈ ក្នុងកាមទាំងឡាយ ដែលជាទុក្ខ ជាភ័យធំបាន។ បុគ្គលនោះ ប្រាសចាករាគៈ កំចាត់បង់នូវទោសៈហើយ គប្បីចំរើននូវមេត្តចិត្ត រកប្រមាណមិនបាន ដាក់ចុះនូវអាជ្ញា ក្នុងសត្វទាំងពួង ជាអ្នក គឺបុគ្គលណាមួយតិះដៀលមិនបាន រមែងទៅកើតក្នុងឋានព្រហ្ម។

[៦០០] បពិត្រព្រះបាទអដ្ឋកៈ ការយាងមកនៃព្រះអង្គផង នៃព្រះបាទភីមរថៈផង នៃព្រះបាទកាលិង្គៈ ដែលមានតេជានុភាពដ៏រុងរឿងផង ជាព្រះរាជដំណើរមានឫទ្ធិដ៏ច្រើន (ព្រោះ) កាមរាគនៃព្រះអង្គទាំងអស់ បានលះបង់ហើយ។

[៦០១] (ព្រះរាជាទាំង ៣ ព្រះអង្គ ទ្រង់សរសើរថា) លោកម្ចាស់បានដឹងច្បាស់នូវចិត្តរបស់បុគ្គលដទៃនុះយ៉ាងនេះឯង ឯកាមរាគ យើងខ្ញុំទាំងអស់គ្នាបានលះហើយ សូមលោកម្ចាស់ធ្វើឱកាស ដើម្បីអនុគ្រោះ (បព្វជ្ជា) ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក។

[៦០២] (សរភង្គតាបស...) អាត្មាភាពធ្វើឱកាសដើម្បីអនុគ្រោះ ព្រោះថា មហារាជទាំងឡាយបានលះបង់នូវកាមរាគ ដោយប្រការដូច្នោះមែន មហារាជទាំងឡាយ ចូរញ៉ាំងកាយ ឲ្យជ្រួតជ្រាបដោយបីតិដ៏កើត (អំពីឈាន) ដ៏ធំទូលាយ ឲ្យមហារាជទាំងឡាយបានដល់នូវគតិរបស់អាត្មាភាព។

[៦០៣] (ព្រះរាជាទាំង ៣ ព្រះអង្គ...) បពិត្រលោក អ្នកមានប្រាជ្ញាដូចផែនដី លោកម្ចាស់ពោលពាក្យណាៗ យើងខ្ញុំនឹងធ្វើតាមពាក្យរបស់លោកទាំងអស់នោះៗ យើងខ្ញុំនឹងញ៉ាំងកាយឲ្យជ្រួតជ្រាបដោយបីតិដ៏ធំទូលាយ ឲ្យយើងខ្ញុំបានដល់នូវគតិរបស់លោក។

[៦០៤] (សរភង្គតាបស...) ការបូជានេះ ពួកឥសីបានធ្វើហើយ ដល់ឥសីឈ្មោះកីសវច្ឆៈ ឥសីទាំងឡាយដ៏ចំរើន មានសភាពល្អ ចូរទៅចុះ អ្នកទាំងឡាយ ចូរត្រេកអរក្នុងឈាន មានចិត្តតាំងមាំសព្វៗកាលចុះ នេះជាសេចក្តីត្រេកអរដ៏ប្រសើររបស់បព្វជិត។

[៦០៥] (អភិសម្ពុទ្ធគាថា) ទេវតាទាំងឡាយនោះ មានយស បានស្តាប់នូវគាថាទាំងឡាយដ៏ប្រកបដោយប្រយោជន៍ដ៏ក្រៃលែង ដែលឥសីជាបណ្ឌិត ពោលល្អហើយ ជាអ្នកបានចេះដឹងហើយ អនុមោទនា ចៀសចេញទៅកាន់ទេវបុរី។ គាថាទាំងឡាយនេះ មានអត្ថ មានព្យញ្ជនៈដ៏បរិសុទ្ធ ដែលឥសីជាបណ្ឌិតពោលល្អហើយ បុគ្គលឯណានីមួយ ស្តាប់គាថាទាំងឡាយនេះ ធ្វើខ្លួនឲ្យមានប្រយោជន៍ រមែងបាននូវគុណវិសេសខាងដើម និងខាងចុង លុះបានគុណវិសេស ខាងដើម និងខាងចុងហើយ គប្បីដល់នូវព្រះនិព្វាន ជាគុណមិនឃើញនូវមច្ចុរាជ។

[៦០៦] (ទ្រង់ប្រជុំជាតកថា) សាលិស្សរតាបស គឺសារីបុត្រ មេណ្ឌិស្សរតាបស គឺកស្សប បព្វតតាបស គឺអនុរុទ្ធ ទេវិលតាបស គឺកច្ចាយនៈ អនុសិស្សតាបស គឺអានន្ទ កីសវច្ឆតាបស គឺកោលិតៈ នារទតាបស គឺឧទាយិត្ថេរ បរិស័ទ (របស់ពួកតាបស) គឺពុទ្ធបរិស័ទ សរភង្គតាបស ជាពោធិសត្វ គឺតថាគត អ្នកទាំងឡាយ ចូរចាំទុកនូវជាតកយ៉ាងនេះចុះ។

ចប់ សរភង្គជាតក ទី២។

## អលម្ពុសាជាតក ទី៣

CS sut.kn.jat.523 | ភាគទី ៦០

### (៥២៣. អលម្ពុសាជាតកំ (៣))

[៦០៧] (អភិសម្ពុទ្ធគាថា) គ្រានោះ ព្រះឥន្ទ្រជាធំ គ្របសង្កត់នូវអសុរឈ្មោះវត្រៈ ទ្រង់ជាបិតារបស់ទេវបុត្រ អ្នកឈ្នះ (សង្គ្រាម) ទ្រង់ឈ្វេងយល់នូវនាងទេវកញ្ញាឈ្មោះអលម្ពុសា ដែលនៅក្នុងរោងឈ្មោះធម្មសភា ហើយបានត្រាស់ថា

[៦០៨] ម្នាលនាង (អ្នកធ្វើបុរស) ឲ្យច្រឡូកច្រឡំ (ដោយកិលេស) ទេវតាទាំងឡាយ ក្នុងជាន់តាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ អង្វរនាង ម្នាលនាងអលម្ពុសា ជាស្ត្រីលួងលោមនូវឥសី ចូរនាងទៅរកព្រះឥសីសិង្គៈ។[36]

[៦០៩] តាបសនេះ មានវត មានព្រហ្មចរិយធម៌ ត្រេកអរក្រៃលែងក្នុងព្រះនិព្វាន ជាអ្នកចំរើន (ដោយគុណ) កុំឲ្យលោកប្រព្រឹត្តកន្លងនូវយើងទាំងឡាយបានមុន នាងចូរបិទផ្លូវទាំងឡាយរបស់លោក។

[៦១០] (នាងអលម្ពុសា...) បពិត្រទេវរាជ ហេតុអ្វីព្រះអង្គធ្វើយ៉ាងនេះ ព្រះអង្គឃើញខ្ញុំម្ចាស់ហើយក៏ត្រាស់ថា ម្នាលនាង ជាស្រីលួងលោមឥសី នាងចូរទៅចុះ ដូច្នេះ ដ្បិតស្រីអប្សរទាំងឡាយដទៃប្រហែលនឹងខ្ញុំម្ចាស់ ទាំងប្រសើរជាងខ្ញុំម្ចាស់ ក៏មាន ក្នុងព្រៃដែលមិនមានសេចក្តីសោក មានតែសេចក្តីរីករាយ សូមផ្លាស់ឲ្យស្រីទេពអប្សរទាំងឡាយនោះទៅវិញ ស្រីអប្សរជាអ្នកអាចលួងលោមទាំងនោះ ចូរទៅចុះ។

[៦១១] (សក្កទេវរាជ...) នាងពោលនូវពាក្យពិតមែន ឯស្រីអប្សរទាំងឡាយដទៃ ប្រហែលដូចនាង ទាំងប្រសើរជាងនាង ក៏មានក្នុងព្រៃមិនមានសេចក្តីសោក មានតែសេចក្តីរីករាយ។ ម្នាលនារី មានអវយវៈទាំងពួងដ៏ល្អ នាងដឹងនូវការផ្គាប់ (ប្រុស) ប្រាកដ យ៉ាងណា នាងទេពអប្សរទាំងឡាយនោះ ទៅដល់ប្រុសហើយ រមែងមិនដឹងនូវការផ្គាប់ យ៉ាងនោះទេ។ ម្នាលនាងកល្យាណី នាងឯងចូរទៅចុះ ព្រោះថា នាងជាស្ត្រីប្រសើរជាងស្ត្រីទាំងឡាយ នាងនឹងញ៉ាំង (តាបស) ឲ្យលុះអំណាចដោយវណ្ណៈ និងរូបរបស់នាង។

[៦១២] (នាងអលម្ពុសា...) ខ្ញុំម្ចាស់ដែលព្រះអង្គជាទេវរាជទ្រង់ប្រើហើយ នឹងខានទៅមិនបាន ប៉ុន្តែខ្ញុំម្ចាស់ខ្លាចចំពោះឥសីសិង្គៈនោះត្រេកអរ ព្រោះថា ឥសីសិង្គនោះ ជាព្រាហ្មណ៍ មានតេជៈខ្ពង់ខ្ពស់។ ជនទាំងឡាយច្រើននាក់ ញ៉ាំងឥសីឲ្យត្រេកអរ ហើយទៅកាន់នគរ បានដល់នូវការអន្ទោលវែងឆ្ងាយ ព្រោះសេចក្តីវង្វេង ហេតុនោះទើបខ្ញុំម្ចាស់ព្រឺរោម។

[៦១៣] (អភិសម្ពុទ្ធគាថា) ស្រីអប្សរឈ្មោះអលម្ពុសា មានវណ្ណៈគួរប្រាថ្នា ជាស្រីញ៉ាំងបុរសឲ្យច្រឡូកច្រឡំ ប្រាថ្នាញ៉ាំងឥសីសិង្គៈឲ្យច្រឡូកច្រឡំ (ដោយកិលេស) លុះពោលនូវពាក្យនេះហើយ ក៏ចៀសចេញទៅ។ នាងអលម្ពុសានោះ ចូលទៅកាន់ព្រៃដែលឥសីសិង្គៈរក្សាហើយនោះ ជាព្រៃដេរដាសដោយវល្លិ៍បាសក្រហមមានទំហំកន្លះយោជន៍ដោយជុំវិញ។ នាងចូលទៅរកឥសីសិង្គៈ ដែលកំពុងបោសរោងភ្លើង ជិតសម័យជាទីរះឡើងនៃព្រះអាទិត្យ ក្នុងវេលាមុនបរិភោគអាហារ ក្នុងពេលព្រឹកព្រហាម។

[៦១៤] (ឥសីសិង្គៈ...) នាងជាអ្វី មានគ្រឿងប្រដាប់ដៃដ៏វិចិត្រ ពាក់កុណ្ឌលជាវិការៈនៃកែវមណី ភ្លឺដូចផ្លេកបន្ទោរ ឬដូចផ្កាយព្រឹក។ នាងមានសម្បុរប្រហែលពណ៌នៃព្រះអាទិត្យ មានក្លិនក្រអូបដូចខ្លឹមចន្ទន៍ក្រហម មានភ្លៅមូលល្អ មានមាយាច្រើន ជាកុមារីមានលំអគួរមើល។ ជើងទាំងឡាយរបស់នាង មិនខូងកណ្តាល ជាជើងទន់ល្មើយ ស្អាត ជាន់សិប់ល្អ ជើងទាំងពីរនោះ កាលដើរទៅ គួរឲ្យប្រាថ្នា ដឹកនាំនូវចិត្តរបស់អាត្មាបាន។ ភ្លៅទាំងឡាយរបស់នាង រៀវជាលំដាប់ ប្រៀបស្មើដោយប្រមោយដំរី ត្រគាករបស់នាងសាយ ដូចជាផែននៃមាស។ ផ្ចិតរបស់នាងស្ទួល្អពេញ ដូចបណ្តុលផ្កាឧប្បល ប្រាកដអំពីចម្ងាយដូចជាផ្កាអញ្ជ័នដ៏ខៀវ។ ដោះទាំងពីរ កើតឰដ៏ទ្រូង ជាដោះមិនមានទង លៀនចេញល្អ ទ្រទ្រង់នូវទឹកដោះ មិនធ្លាក់យារ (ដោះក្បំ) ប្រាកដស្មើដោយផ្លែឃ្លោកពាក់កណ្តាល។ ក (របស់នាង) ប្រហែលដម្បារមាស វែងដូចកទ្រាយ បបូរមាត់ល្អ ដូចជាចិត្តជាគំរប់ ៤ គឺអណ្តាត។ ធ្មេញទាំងឡាយរបស់នាង មិនមានទោស ជាធ្មេញដុះស្មើទាំងពីរខាង ទាំងខាងលើ ទាំងខាងក្រោម ដែលជំរះហើយដោយឈើស្ទន់ ជាធ្មេញគួររមិលមើលក្រៃពេក។ ភ្នែកទាំងឡាយរបស់នាងដ៏ខ្មៅមានចុងក្រហម ប្រហែលដោយផ្លែទំពាំងបាយជូរ ដ៏វែងទូលាយ ជាភ្នែកគួររមិលមើលក្រៃពេក។ សក់ទាំងឡាយរបស់នាង ដែលដុះលើក្បាលមិនវែងពេក ជាសក់រលើប ដែលសិតដោយក្រាសមាស ក្រអូបសាយដោយក្លិននៃខ្លឹមចន្ទន៍។ ការភ្ជួររាស់ និងការរក្សាគោ (នៃជនទាំងឡាយណា) ក្តី គតិណានៃពាណិជទាំងឡាយក្តី សេចក្តីព្យាយាម (ណា) នៃឥសីទាំងឡាយអ្នកសង្រួម អ្នកមានតបៈក្តី កាលប្រព្រឹត្តទៅ អាត្មាមិនឃើញនូវជនទាំងនោះ លើមណ្ឌលនៃផែនដីនេះ ឲ្យសមស្មើ (នឹងនាង) អ្នកជាអ្វី ជាកូននៃអ្នកណា យើងនឹងដឹងនូវអ្នកដូចម្តេចបាន។

[៦១៥] (នាងអលម្ពុសា...) បពិត្រកស្សបដ៏ចំរើន កាលបើចិត្តរបស់លោកប្រព្រឹត្តទៅហើយយ៉ាងនេះ កាលនេះមិនមែនជាកាលនៃប្រស្នាទេ នៃសំឡាញ់ លោកចូរមក យើងទាំងពីរនាក់នឹងត្រេកត្រអាលក្នុងអាស្រមរបស់យើង លោកចូរមក ខ្ញុំនឹងឱបលោក ចូរលោកជាអ្នកឈ្លាសក្នុងសេចក្តីត្រេកអរ។

[៦១៦] (អភិសម្ពុទ្ធគាថា) ស្រីអប្សរឈ្មោះអលម្ពុសា មានវណ្ណៈគួរប្រាថ្នា ជាស្រីធ្វើបុរសឲ្យច្រឡូកច្រឡំ កាលប្រាថ្នានឹងញុំាងឥសីសិង្គៈឲ្យច្រឡូកច្រឡំ (ដោយកិលេស) លុះពោលពាក្យនេះហើយ ក៏ចៀសចេញទៅ។

[៦១៧] ឯឥសីសិង្គៈនោះ ក៏ផ្តាច់បង់នូវសេចក្តីខ្ជះខ្ជែងដ៏យឺត ហើយស្ទុះទៅដោយប្រញាប់ប្រញាល់ ដល់ហើយ ក៏ស្ទាបអង្អែលនាងអលម្ពុសានោះ ឰដ៏ក្នុងសក់ដ៏ឧត្តម។ នាងកល្យាណី មានលំអដ៏ល្អ ងាកមកឱបរឹតតាបសនោះដែរ តាបសនោះ ឃ្លាតចាកព្រហ្មចារ្យនោះ ព្រោះលោកត្រេកត្រអាលចំពោះនាង ក្នុងកាលនោះ (ដូចចំណងដែលសក្កទេវរាជប្រាថ្នាហើយនោះ)។ នាងក៏នឹកដល់ព្រះឥន្ទ្រ ដែលកំពុងប្រថាប់នៅក្នុងនន្ទនវ័ន ឯយវាទេវកុញ្ជរ ក៏ជ្រាបនូវសេចក្តីត្រិះរិះរបស់នាងហើយ ទ្រង់បញ្ជូនបល្ល័ង្កមាស មានទាំងបរិវារ មានទាំងសំពត់សម្រាប់គ្រប់បិទទ្រូង ៥០ មានទាំងកម្រាល ១០០ ដ៏ឆាប់ នាងល្អ ក៏ផ្តេកនូវតាបសនោះលើទ្រូង លើបល្ល័ង្កទិព្វនោះ។ នាងអលម្ពុសាផ្តេកតាបសនោះទុកអស់ ៣ ឆ្នាំ ហាក់ដូចជាមួយរំពេច ព្រាហ្មណ៍ (ដេកលើទ្រូងនាងអលម្ពុសា) អស់ ៣ ឆ្នាំ ក៏បាត់សន្លប់ភ្ញាក់ឡើងវិញ។ បានឃើញពួកឈើមានស្លឹកខៀវ (ដុះព័ទ្ធ) រោងភ្លើងជុំវិញ និងព្រៃដ៏ដេរដាសដោយស្លឹកថ្មីៗ មានផ្ការីក ដ៏គឹកកង ដោយពួកតាវ៉ៅ។ តាបសក្រឡេកមើលឃើញច្បាស់ជុំវិញហើយ ក៏យំសម្រក់ទឹកភ្នែកថា អាត្មាអញមិនបូជាភ្លើង មិនរាយមន្ត ការបូជាភ្លើងក៏សាបសូន្យអស់។ បុគ្គលណាហ្ន៎ លួងលោមចិត្តរបស់អាត្មាអញ ដោយការផ្គាប់ក្នុងកាលមុន កាលអាត្មាអញនៅក្នុងព្រៃ បុគ្គលណាញុំាងឈានគុណ ដែលកើតព្រមដោយតេជានុភាពរបស់អាត្មាអញឲ្យវិនាស ដូចជាបុគ្គលញុំាងទូកដ៏ពេញដោយកែវផ្សេងៗ ឲ្យវិនាសក្នុងសមុទ្រ បុគ្គលនោះឈ្មោះអ្វីហ្ន៎។

[៦១៨] (នាងអលម្ពុសា...) ខ្ញុំដែលទេវរាជត្រាស់ប្រើមក ដើម្បីផ្គាប់លោក បានសម្លាប់ចិត្ត (របស់លោក) ដោយចិត្ត (របស់ខ្ញុំ) លោកមិនជ្រាប ព្រោះតែសេចក្តីធ្វេសប្រហែស។

[៦១៩] (តាបស...) បានស្តាប់មកថា កស្សបជាបិតា បានប្រៀនប្រដៅនូវពាក្យទាំងនេះចំពោះអាត្មាអញថា នែមាណព ស្ត្រីទាំងឡាយប្រាកដស្មើដោយផ្កានារីផល អ្នកគប្បីស្គាល់នូវស្ត្រីទាំងឡាយនោះចុះ។ នែមាណព អ្នកគប្បីស្គាល់នូវស្ត្រីទាំងឡាយដែលមានបូសពីរឰដ៏ទ្រូង អ្នកគប្បីស្គាល់ថា ស្ត្រីទាំងឡាយនោះ បិតាទំនុកបម្រុងអាត្មាអញ យ៉ាងណា ក៏ប្រៀនប្រដៅអាត្មាអញយ៉ាងនោះ ដោយប្រការដូច្នោះ។ តែអាត្មាអញមិនបានធ្វើតាមពាក្យប្រដៅរបស់បិតាជាអ្នកចំរើនដោយគុណសម្បត្តិនោះឡើយ ថ្ងៃនេះអាត្មាអញតែម្នាក់ឯងសញ្ជប់សញ្ជឹងក្នុងព្រៃដែលមិនមានមនុស្ស។ ថ្វីយ ជិវិតរបស់អញ គួរតិះដៀល អញនឹងធ្វើយ៉ាងនោះវិញ តែបើអញជាបុគ្គលមានឈានប្រាកដដូច្នោះទៀត សេចក្តីស្លាប់ នឹងមានដល់អញ។

[៦២០] (អភិសម្ពុទ្ធគាថា) នាងអលម្ពុសា លុះដឹងនូវតេជៈ នូវសេចក្តីព្យាយាម និងប្រាជ្ញាដ៏ខ្ជាប់ខ្ជួន របស់ឥសីសិង្គៈនោះហើយ ក៏ឱនក្បាលទៀបជើងឥសីសិង្គៈ ពោលថា បពិត្រលោក អ្នកមានព្យាយាមធំ សូមលោកកុំខ្ញាល់នឹងខ្ញុំ បពិត្រមហាឥសី សូមលោកកុំខ្ញាល់នឹងខ្ញុំ ដ្បិតប្រយោជន៍ដ៏ធំ ខ្ញុំបានប្រព្រឹត្តហើយ ដើម្បីទេវតាទាំងឡាយជាន់តាវត្តិង្ស ជាអ្នកមានយស ឯទេវបុរីទាំងមូល លោកបានឲ្យកំរើកញាប់ញ័រហើយ ក្នុងកាលនោះ។

[៦២១] (ឥសីសិង្គៈ...) ម្នាលនាងដ៏ចំរើន ទេវតាទាំងឡាយក្នុងជាន់តាវត្តិង្សក្តី ព្រះវាសវៈ (ជាឥស្សរៈ) របស់ទេវតាទាំងឡាយជាន់តាវត្តិង្សក្តី ខ្លួននាងក្តី ចូរមានសេចក្តីសុខចុះ ម្នាលនាងកញ្ញា នាំងចូរទៅតាមសប្បាយចុះ។

[៦២២] នាងអលម្ពុសា ឱនក្បាលទៀបជើងនៃតាបស រួចធ្វើប្រទក្សិណតាបសនោះ ប្រណម្យអញ្ជលី ហើយចៀសចេញទៅចាកទីនោះ។ បល្ល័ង្កមាសណា ដែលមានទាំងបរិវារ មានទាំងសំពត់សំរាប់គ្របបិទទ្រូង ៥០ មានទាំងកម្រាល ១០០០ របស់នាង នាងក៏ឡើងកាន់បល្ល័ង្កមាសនោះ ហើយទៅក្នុងសំណាក់នៃទេវតាទាំងឡាយ។ សក្កទេវិន្ទទ្រង់មានបីតិសោមនស្សរីករាយព្រះទ័យ ចំពោះនាងអលម្ពុសានោះ ដែលមកដូចកោះ រុងរឿងដូចផ្លេកបន្ទោរ ហើយប្រទានពរ។

[៦២៣] (នាងអលម្ពុសា...) បពិត្រសក្កទេវរាជ ជាឥស្សរៈជាងភូតទាំងពួង បើព្រះអង្គប្រទានពរដល់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់សូមកុំបានទៅប្រលោមលួងលោមឥសីទៀត បពិត្រសក្កទេវរាជ ខ្ញុំម្ចាស់សូមពរនេះ។

ចប់ អលម្ពុសាជាតក ទី៣។

## សង្ខបាលជាតក ទី៤

CS sut.kn.jat.524 | ភាគទី ៦០

### (៥២៤. សង្ខបាលជាតកំ (៤))

[៦២៤] (ព្រះបាទពារាណសីត្រាស់សួរថា) លោកជាអ្នកមានឱកាសនៃសរីរៈដ៏ប្រសើរ មានព្រះនេត្រថ្លា ខ្ញុំសំគាល់ថា លោកដ៏ចំរើនជាអ្នកចេញចាកត្រកូល ហើយបួស ចុះលោកអ្នកមានប្រាជ្ញា លះបង់នូវទ្រព្យ និងភោគៈទាំងឡាយ ចេញចាកផ្ទះហើយបួស តើដោយ

ហេតុដូចម្តេច។

[៦២៥] (អាឡារតាបស ថ្វាយព្រះពរថា) បពិត្រព្រះរាជា ជានរទេព អាត្មាភាពជាអ្នកបួសដោយសទ្ធា ព្រោះបានឃើញវិមានរបស់ពស់ធំ (នាគ) ដែលមានអានុភាពច្រើន ដោយខ្លួនឯងផង ព្រោះបានឃើញផលដ៏ធំ នៃបុណ្យទាំងឡាយផង។

[៦២៦] (ព្រះរាជា...) បព្វជិតទាំងឡាយ មិនពោលនូវវាចាកុហកព្រោះប្រាថ្នាកាម ព្រោះខ្លាច ព្រោះទោសៈទេ ខ្ញុំសួរហើយ សូមលោកប្រាប់សេចក្តីនុ៎ះ សេចក្តីជ្រះថ្លានឹងកើតដល់ខ្ញុំព្រោះស្តាប់។

[៦២៧] (អាឡារតាបស...) បពិត្រព្រះអង្គជាធំក្នុងដែន អាត្មាភាព កាលនៅ (ជាគ្រហស្ថ) កំពុងដើរទៅដោយបំណងថា (អញនឹងធ្វើ) នូវជំនួញ ក៏បានឃើញនូវពួកភោជបុត្រ[37] ក្នុងផ្លូវ សែងពស់ដ៏ធំ មានកាយធាត់ កំពុងសប្បាយរីករាយដើរ។ បពិត្រព្រះអង្គជាធំជាងជន លុះអាត្មាភាពនោះ មកជួបនឹងពួកភោជបុត្រទាំងនោះហើយ ក៏ព្រឺរោមខ្លាច ហើយសួរថា ម្នាលពួកភោជបុត្រ នាគនេះ មានកាយគួរខ្លាច តើអ្នកទាំងឡាយនាំទៅក្នុងទីណា អ្នកទាំងឡាយ នឹងយកនាគនេះទៅធ្វើអ្វី។

(ពួកភោជបុត្រប្រាប់ថា) នាគដ៏ធំ ជាសត្វទៅដោយទ្រូង មានកាយដ៏ធាត់នេះ យើងយកទៅបរិភោគ (ព្រោះ) សាច់វា មានរសឆ្ងាញ់ផង ក្រាស់ផង ទន់ផង នៃកូនអ្នកស្រុកវិទេហៈ អ្នកមិនដឹងនូវរសទេឬ។ ពួកយើងចេញអំពីទីនេះ ទៅកាន់លំនៅរបស់ខ្លួន ហើយយកកាំបិតចិញ្ច្រាំសាច់ទាំងឡាយ ហើយបរិភោគរីករាយសប្បាយ ព្រោះថា ពួកយើងជាសត្រូវចំពោះនាគទាំងឡាយ។

(អាត្មាភាព ពោលថា) ពស់ដ៏ធំនេះ ជាសត្វទៅដោយទ្រូង មានកាយដ៏ធាត់ ប្រសិនបើអ្នកទាំងឡាយ យកនាគនេះទៅបរិភោគ យើងនឹងឲ្យគោឧសភ ១៦ ដល់អ្នកទាំងឡាយជំនួសនាគ អ្នកទាំងឡាយចូរស្រាយនាគនេះអំពីចំណងចុះ។

(ពួកភោជបុត្រពោលថា...) ពស់នេះជាអាហារជាទីពេញចិត្តរបស់ពួកយើងណាស់ តែពស់ជាច្រើន ពួកយើងធ្លាប់បរិភោគហើយ បពិត្រអាឡារៈ ពួកយើងនឹងធ្វើតាមពាក្យរបស់អ្នកនោះ នៃកូនអ្នកស្រុកវិទេហៈ អ្នកចូរជាមិត្ររបស់យើងទាំងឡាយ។

ពួកភោជបុត្រទាំងនោះ ក៏ស្រាយនាគរាជនោះអំពីចំណង (ដែលគេដោតចូល) ទៅតាមច្រមុះ ហើយបញ្ចូលទៅក្នុងអន្ទាក់ ឯនាគរាជនោះ លុះរួចអំពីចំណងហើយ ក៏មានមុខឆ្ពោះទៅកាន់បាចីនទិស ចៀសចេញទៅមួយរំពេច។ នាគរាជនោះ មានមុខឆ្ពោះទៅកាន់បាចីនទិស លូនទៅមួយរំពេច មានភ្នែកពេញដោយទឹកភ្នែក ហើយសំឡឹងមើលអាត្មាភាព កាលនោះ អាត្មាភាព បានដើរទៅតាមក្រោយនៃនាគនោះ ហើយផ្គងម្រាមទាំង ១០ (ពោលថា) អ្នកចូរប្រញាប់ទៅចុះ កុំឲ្យពួកសត្រូវចាប់អ្នកទៀត ព្រោះថា ការជួបប្រទះដោយព្រានទាំងឡាយម្តងទៀត រមែងនាំមកនូវសេចក្តីទុក្ខ អ្នកចូរទៅកាន់ទីដែលពួកភោជបុត្រមិនឃើញ។ នាគរាជនោះ បានទៅកាន់អន្លង់ទឹកដ៏ថ្លា មានពណ៌ខៀវ មានកំពង់ល្អគួររីករាយ ដ៏ទន់ទោរដោយជម្ពូព្រឹក្ស និងវេទិសាព្រឹក្ស ជាសត្វមិនមានភ័យ មានតែការរីករាយ ក៏ចូលទៅ (កាន់នាគពិភព)។ បពិត្រព្រះជនិន្ទ្រ នាគនោះ លុះចូលទៅកាន់ភពនាគនោះហើយ មិនយូរប៉ុន្មាន ក៏វិលមកប្រាកដ (ខាងមុខ) នៃអាត្មាភាព ដោយបរិវារជាទិព្វ ហើយបំរើអាត្មាភាព ហាក់ដូចកូនបំរើបិតា បានពោលនូវពាក្យត្រេកត្រអាលចិត្ត ស្រលគ្រចៀកថា បពិត្រអាឡារៈ លោកទុកដូចមាតា និងបិតារបស់ខ្ញុំ លោកប្រាជកស្មើដោយសាច់ខាងក្នុង គឺដួងហឫទ័យ ជាអ្នកឲ្យនូវជីវិត ជាសំឡាញ់ ម្យ៉ាងទៀត ខ្ញុំត្រឡប់បាននូវឫទ្ធិរបស់ខ្លួន បពិត្រអាឡារៈ សូមលោកមើលនិវេសនដ្ឋានរបស់ខ្ញុំ ភពនាគមានចំណីច្រើន មានបាយទឹកដ៏ច្រើន ដូចមស័ក្កសារ គឺទេពនគរ របស់វាសវទេវរាជដូច្នោះ។

[៦២៨] ពភនាគនោះ ប្រកបដោយភូមិភាគ ជាភូមិមិនមានក្រួស ទន់ល្អ មានស្មៅដ៏ទាប មិនមានធូលី ជាទីនាំមកនូវសេចក្តីជ្រះថ្លា ជាទីលះបង់នូវសេចក្តីសោកបាន។ (ក្នុងភពនាគនោះ មានស្រះបោក្ខរណី) មិនក្រហេងក្រហូង មានកែវពៃទូរ្យពណ៌ខៀវ មានសួនស្វាយ គួរជាទីរីករាយដោយប្រពៃ តាំងនៅក្នុងទិសទាំង ៤ (នៃស្រះបោក្ខរណី) ដើមស្វាយទាំងឡាយ ក្នុងអម្ពវននោះ មានផ្លែទុំក៏មាន ផ្លែស្រគាលក៏មាន ផ្លែខ្ចីក៏មាន ក្តឹបក៏មាន ជាឈើមានផ្លែសព្វៗ រដូវ។

[៦២៩] បពិត្រព្រះនរទេព លំនៅជាវិការៈនៃមាស មានសន្ទះទ្វារជាវិការៈនៃប្រាក់ មានរស្មីផ្លេកៗ រុងរឿងក្រៃលែងក្នុងកណ្តាលនៃព្រៃឈើទាំងឡាយនោះ ដូចជាផ្លេកបន្ទោរឰដ៏អាកាស។ បពិត្រព្រះរាជា (ក្នុងប្រាសាទនោះ មានផ្ទះកំពូល និងល្វែង) ជាវិការៈនៃកែវមណី ទាំងជាវិការៈនៃមាស រុងរឿងដ៏វិចិត្រជាអនេក ដែលនិម្មិតល្អហើយរៀបៗ ពេញដោយពួកនាងកញ្ញា ដ៏ទ្រទ្រង់ដោយគ្រឿងប្រដាប់មាស។ សង្ខបាលនាគរាជនោះ មានសម្បុរមិនថោកទាប (បានចាប់ដៃអាត្មាភាព) មានសភាពរួសរាន់ ឡើងកាន់ប្រាសាទដែលមានសសរមួយពាន់ មានអានុភាពថ្លឹងមិនបាន ដែលជាទីនៅនៃភរិយា ជាមហេសីរបស់សង្ខបាលនាគរាជនោះ។ នាងនារីម្នាក់ មានសភាពរួសរាន់ កាន់យកនូវកែវមណីដ៏ស្អាត ប្រកបដោយកែវមណីដទៃ មានជាតិសុទ្ធ ជាស្ត្រីដែលនាគរាជនោះមិនបាច់តឿន ក៏ក្រាលនូវអាសនៈជាវិការៈនៃកែវពៃទូរ្យមានតម្លៃច្រើន។ លំដាប់នោះ នាគរាជចាប់ដៃអាត្មាភាព ឲ្យអង្គុយលើអាសនៈជាប្រមុខ (ពោលថា) នេះអាសនៈ សូមលោកដ៏ចំរើនអង្គុយលើអាសនៈនេះ ព្រោះថា បណ្តាបុគ្គលដែលគួរគោរពទាំងឡាយ លោកដ៏ចំរើន ទុកជាបុគ្គលគួរគោរពមួយរបស់ខ្ញុំ។ បពិត្រព្រះជនិន្ទ្រ នាងនារីដទៃមានសភាពរហ័សរហួន នាំទឹកចូលមកលាងជើងអាត្មាភាព ដូចជាប្រពន្ធលាងជើងភស្តាជាទីស្រឡាញ់។ មាននាងនារីម្នាក់ទៀត មានសភាពរួសរាន់ បានលើកនូវបាយ មានសម្លដ៏ច្រើន និងម្ហូបក្រៀមផ្សេងៗ ដោយភាជន៍ ជាវិការៈនៃមាស ហើយបង្អោនចូលមកជិត។ បពិត្រព្រះភារតៈ នាងនារីទាំងឡាយ បានដឹងនូវចិត្តនៃព្រះភស្តា (របស់ខ្លួន) ហើយបំរើអាត្មាភាព ដែលជាអ្នកបរិភោគរួចហើយ ដោយតូរ្យតន្ត្រីទាំងឡាយ នាគរាជនោះ ប្រណិប័តន៍អាត្មាភាព ដោយកាមគុណជាទិព្វដ៏ឱឡារិកមានប្រមាណច្រើន ដ៏ក្រៃលែងជាងតូរ្យតន្ត្រីនោះ។

[៦៣០] បពិត្រអាឡារៈ ភរិយាទាំងឡាយរបស់ខ្ញុំនុ៎ះ ៣០០ នាក់ ភរិយាទាំងអស់ មានពាក់កណ្តាលខ្លួន (រៀវល្អ) មានរស្មីដ៏ក្រៃលែង ហាក់ដូចជាពណ៌នៃផ្កាឈូក បពិត្រអាឡារៈ លោកចូរធ្វើសេចក្តីស្រឡាញ់ចំពោះស្ត្រីទាំងនុ៎ះ ខ្ញុំនឹងឲ្យដល់លោក ៗ ចូរឲ្យស្ត្រីទាំងនោះបំរើចុះ។

[៦៣១] អាត្មាភាពបានទទួលដឹងរសនៃកាមគុណជាទិព្វ អស់មួយឆ្នាំ កាលនោះ អាត្មាភាពសួរតទៅទៀតថា ព្រះអង្គជានាគ បាននូវសម្បត្តិនេះ ព្រោះធ្វើនូវកម្មអ្វី ព្រះអង្គបានវិមានដ៏ប្រសើរ ដោយប្រការដូចម្តេច។ ព្រះអង្គបានដោយមិនមានហេតុ ឬកើតអំពីបុគ្គលណាមួយ បង្អោនមកថ្វាយព្រះអង្គ ព្រះអង្គធ្វើឯង ឬពួកទេវតាថ្វាយ បពិត្រនាគរាជ ខ្ញុំសួរសេចក្តីនេះនឹងព្រះអង្គៗ បានវិមានដ៏ប្រសើរដោយប្រការដូចម្តេច។

[៦៣២] វិមាននេះ មិនមែនខ្ញុំបានដោយមិនមានហេតុទេ មិនមែនកើតអំពីបុគ្គលណាបង្អោនមកថ្វាយខ្ញុំទេ ខ្ញុំមិនមែនធ្វើដោយខ្លួនឯង ទាំងមិនមែនទេវតាឲ្យខ្ញុំទេ វិមាននេះ ខ្ញុំបានដោយកម្មរបស់ខ្លួន ជាអំពើឥតបាប គឺជាបុណ្យ។

[៦៣៣] វត្តរបស់ព្រះអង្គដូចម្តេច ព្រហ្មចារ្យ តើដូចម្តេច នេះជាវិបាកនៃកម្មដែលប្រព្រឹត្តល្អហើយដូចម្តេច បពិត្រនាគរាជ សូមព្រះអង្គប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ វិមាននេះ តើព្រះអង្គបានហើយ ដោយប្រការដូចម្តេច។

[៦៣៤] ខ្ញុំជាស្តេចឈ្មោះទុយ្យោធនៈ ជាធំក្នុងដែនមគធៈ មានអានុភាពធំ ខ្ញុំនោះបានដឹងច្បាស់នូវជីវិត ជារបស់ថោកទាបមិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា។ ខ្ញុំមានចិត្តជ្រះថ្លា បានឲ្យបាយ និងទឹកជាទានបរិបូណ៌ដោយគោរព ក្នុងកាលនោះ ផ្ទះរបស់ខ្ញុំ ជាទីប្រជុំរបស់សមណៈ (ព្រាហ្មណ៍) ដូចជាអណ្តូង ព្រោះថា សមណព្រាហ្មណ៍ទាំងឡាយ ខ្ញុំបានឲ្យឆ្អែតស្កប់ស្កល់ហើយ។ ខ្ញុំបានឲ្យផ្តាកម្រង គ្រឿងក្រអូប គ្រឿងលាប ប្រទីប យានី លំនៅ សំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក និងបាយទឹក ជាទានដោយគោរពក្នុងទីនោះ។ អំពើនោះ ជាវត្តរបស់ខ្ញុំ អំពើនោះជាព្រហ្មចារ្យរបស់ខ្ញុំ នេះជាវិបាកនៃកម្មដែលប្រព្រឹត្តល្អហើយនោះ ព្រោះហេតុនោះឯង វិមាននេះ ទើបមានចំណីដ៏ច្រើន មានបាយ និងទឹកដ៏ច្រើន ដែលខ្ញុំបានហើយ។

[៦៣៥] វិមាននេះ សម្បូរដោយការរាំ ទាំងសម្បូរដោយការច្រៀង តាំងនៅអស់កាលយូរ តែមិនទៀងទាត់សោះទេ ពួកអ្នកមានអានុភាពតិច មិនមានតេជៈ រមែងបៀតបៀនព្រះអង្គ ដែលមានអានុភាពច្រើន មានតេជៈ បពិត្រព្រះអង្គមានចង្កូមជាអាវុធ ព្រះអង្គមកលុះកណ្តាប់ដៃនៃពួកភោជបុត្រ តើព្រោះអាស្រ័យអ្វី ព្រោះហេតុអ្វី។ តេជៈរបស់ព្រះអង្គទៅតាមភ័យដ៏ធំឬ ឬពិសរបស់ព្រះអង្គទៅតាមគល់ធ្មេញ បពិត្រព្រះអង្គ មានចង្កូមជាអាវុធ ព្រះអង្គដល់នូវសេចក្តីលំបាក (ក្នុងសំណាក់) នៃពួកភោជបុត្រ តើព្រោះអាស្រ័យអ្វី ព្រោះហេតុអ្វី។

[៦៣៦] តេជៈរបស់ខ្ញុំមិនមែនទៅតាមភ័យដ៏ធំទេ តេជៈ គឺពិសរបស់ខ្ញុំ ពួកភោជបុត្រទាំងនោះ មិនអាចនឹងបៀតបៀនទេ ធម៌ទាំងឡាយ ពួកសប្បុរសសំដែងល្អហើយ ជាធម៌លះបង់បានដោយក្រ ដូចច្រាំងសមុទ្រ។ បពិត្រអាឡារៈ ខ្ញុំរក្សាឧបោសថ ក្នុងថ្ងៃទី ១៤ និងថ្ងៃទី ១៥ ជានិច្ច គ្រានោះ ពួកភោជបុត្រ ១៦ នាក់ កាន់ខ្សែ និងអន្ទាក់ដ៏មាំដើរមក។ ព្រានទាំងឡាយទំលាយ (សរីរៈ) យកខ្សែខ្លួសច្រមុះ ហើយសែងនាំយកខ្ញុំទៅ ខ្ញុំញ៉ាំងឧបោសថ មិនឲ្យកម្រើក ខំអត់ទ្រាំនូវសេចក្តីទុក្ខទាំងនេះ។

[៦៣៧] (ពួកភោជបុត្រទាំងនោះ) បានឃើញព្រះអង្គជាអ្នកបរិបូណ៌ដោយកំឡាំង និងសម្បុរ ក្នុងផ្លូវជាទីដើរទៅនៃបុគ្គលតែម្នាក់ ព្រះអង្គជាអ្នកចំរើនដោយសិរី និងបញ្ញា បពិត្រនាគរាជ ព្រះអង្គខំប្រឹងធ្វើតបៈ តើដើម្បីអ្វី។

[៦៣៨] បពិត្រអាឡារៈ (ខ្ញុំធ្វើតបៈ) មិនមែនព្រោះហេតុកូន មិនមែនព្រោះហេតុទ្រព្យ មិនមែនព្រោះហេតុអាយុទេ ខ្ញុំប្រាថ្នាចំពោះកំណើតនៃមនុស្ស ព្រោះហេតុនោះ បានជាខ្ញុំប្រឹងប្រែងធ្វើតបៈ។

[៦៣៩] ព្រះអង្គមានចក្ខុក្រហម មានរស្មីព្រោងព្រាត មានខ្លួនប្រដាប់ហើយ មានសក់ និងពុកមាត់កាត់កោរហើយ លាបដោយខ្លឹមចន្ទន៍ក្រហម ហើយញ៉ាំងទិសទាំងឡាយ ឲ្យភ្លឺច្បាស់ដូចស្តេចគន្ធព្វ។ ព្រះអង្គដល់នូវឫទ្ធិដូចជាឫទ្ធិនៃទេវតា មានអានុភាពធំ ប្រកបដោយកាមទាំងពួង បពិត្រនាគរាជ ខ្ញុំសូមសួរនូវសេចក្តីនុ៎ះ ចំពោះព្រះអង្គថា មនុស្សលោកប្រសើរជាងភពនាគនេះ តើដោយហេតុអ្វី។

[៦៤០] បពិត្រអាឡារៈ សេចក្តីបរិសុទ្ធិក្តី ការសង្រួមក្តី វៀរចាកមនុស្សលោកហើយ រមែងមិនមានឡើយ ខ្ញុំបើបានកំណើតនៃមនុស្សហើយ នឹងធ្វើនូវទីបំផុតនៃជាតិ នឹងមរណៈ។

[៦៤១] ខ្ញុំនៅក្នុងសំណាក់នៃព្រះអង្គអស់មួយឆ្នាំហើយ ព្រះអង្គក៏បានទំនុកបំរុងដោយបាយ និងទឹក បពិត្រនាគរាជ ខ្ញុំសូមលាត្រឡប់ទៅវិញ បពិត្រព្រះវិនិន្ទ ខ្ញុំឃ្លាត (ពីមនុស្សលោក) យូរហើយ។

[៦៤២] កូនប្រពន្ធ និងពួកជនជាអ្នករស់នៅដោយសារខ្ញុំៗ បានប្រៀនប្រដៅជានិច្ច ឲ្យបំរើលោក តើអ្នកណាមួយ មិនបានថែទាំលោកខ្លះឬទេ បពិត្រអាឡារៈ ព្រោះថាខ្ញុំមានការស្រឡាញ់ពេញចិត្តចំពោះការជួបប្រទះនូវលោក។

[៦៤៣] បពិត្រនាគរាជ ដូចយ៉ាងកូនជាទីស្រឡាញ់របស់មាតា និងបិតា ដែលមាតាបិតាបានថែរក្សាហើយ ឲ្យនៅក្នុងផ្ទះ (ការនៅ) របស់ខ្ញុំក្នុងទីនេះ ប្រសើរជាងការនៅរបស់កូននោះទៅទៀត ព្រោះថា ចិត្តរបស់អ្នកជ្រះថ្លាចំពោះខ្ញុំ។

[៦៤៤] កែវមណីរបស់ខ្ញុំមានពណ៌ក្រហម ជាគ្រឿងនាំមកនូវទ្រព្យ លោកចូរយកកែវមណីដ៏ថ្លៃថ្លា ទៅផ្ទះរបស់ខ្លួនចុះ លុះបានទ្រព្យហើយ ចូរទុកកែវមណីនោះ (ក្នុងពាងទឹក)។

[៦៤៥] បពិត្រព្រះរាជា កាមគុណទាំងឡាយ សូម្បីជារបស់មនុស្ស អាត្មាភាពបានឃើញហើយ ថាជារបស់មិនទៀង មានសេចក្តីប្រែប្រួលជាធម្មតា លុះអាត្មាភាពឃើញទោសក្នុងកាមគុណទាំងឡាយ ទើបបួសដោយសទ្ធា។ បពិត្រព្រះរាជា មនុស្សទាំងឡាយ ក្មេងក្តីចាស់ក្តី កាលមានសរីរៈបែកធ្លាយហើយ រមែងធ្លាក់ចុះ ដូចជាផ្លែឈើទាំងឡាយដូច្នោះដែរ អាត្មាភាពឃើញហេតុនេះហើយ ទើបចេញបួសសាមញ្ញគុណ គឺបព្វជ្ជា ជាធម៌ប្រតិបត្តិមិនខុស ជាធម៌ដ៏ប្រសើរ។

[៦៤៦] (ព្រះរាជា...) ពួកជនណាមានប្រាជ្ញា ជាពហុស្សុត ជាអ្នកគិតនូវហេតុដ៏ច្រើន ពួកជននោះ បុគ្គលគប្បីសេពគប់ បពិត្រអាឡារតាបស ខ្ញុំនឹងធ្វើនូវបុណ្យដ៏ច្រើន ព្រោះបានស្តាប់ (នូវពាក្យ) របស់នាគរាជផង របស់លោកផង។

[៦៤៧] (អាឡារតាបស...) ពួកជនណា មានប្រាជ្ញា ជាពហុស្សុត ជាអ្នកគិតនូវហេតុដ៏ច្រើន ពួកជននោះ បុគ្គលគប្បីសេពគប់ បពិត្រព្រះរាជា ព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់អាត្មាភាព និងនាគហើយ សូមព្រះអង្គធ្វើបុណ្យឲ្យច្រើន។

ចប់ សង្ខបាលជាតក ទី៤។

## ចុល្លសុតសោមជាតក ទី៥

CS sut.kn.jat.525 | ភាគទី ៦០

### (៥២៥. ចូឡសុតសោមជាតកំ (៥))

[៦៤៨] (ព្រះបាទសុតសោម ត្រាស់ថា) ខ្ញុំប្រាប់អ្នកនិគម មិត្រអាមាត្យ និងបរិស័ទឲ្យដឹងថា ស្កូវកើតលើក្បាលហើយ ឥឡូវនេះ ខ្ញុំពេញចិត្តនឹងបព្វជ្ជា។

[៦៤៩] (អាមាត្យម្នាក់ ក្រាបទូលថា) ព្រះអង្គទ្រង់ត្រាស់ព្រះឱង្ការ មិនចំរើនដល់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះសម្មតិទេព ព្រះអង្គហាក់ដូចជាញ៉ាំងកូនសរ ឲ្យប្រហារត្រង់ដើមទ្រូងរបស់ទូលព្រះបង្គំជាខ្ញុំ ចុះស្រីស្នំរបស់ព្រះអង្គចំនួន ៧០០ នាក់ ស្រីស្នំរបស់ព្រះអង្គទាំងនោះ នឹងទៅជាដូចម្តេច។

[៦៥០] (ព្រះរាជា...) ស្រីស្នំក្មេងៗ ទាំងនេះ នឹងប្រាកដ (តាមអំពើរបស់ខ្លួនៗ) ឬក៏ស្រីស្នំទាំងនោះ នឹងទៅរកស្តេចដទៃ ឯខ្ញុំប្រាថ្នា

ឋានសួគ៌ ព្រោះហេតុនោះ ខ្ញុំនឹងបួស។

[៦៥១] (ព្រះវររាជមាតា...) នៃសុតសោម ខ្ញុំបានអ្នកដោយកម្រណាស់ នៃព្រះសម្មតិទេព ព្រោះខ្ញុំជាមាតារបស់អ្នក កាលខ្ញុំកំពុងយំសោក អ្នកឥតមានសេចក្តីអាឡោះអាល័យ (ចេញទៅ) បួស។ នៃសុតសោម ខ្ញុំបានអ្នកដោយកម្រណាស់ នៃព្រះសម្មតិទេព ខ្ញុំបានប្រសូតអ្នកមក កាលខ្ញុំកំពុងយំសោក អ្នកឥតមានសេចក្តីអាឡោះអាល័យ (ចេញទៅ) បួស។

[៦៥២] (ព្រះវររាជបិតា...) នៃសុតសោម នេះជាទំនៀមឈ្មោះអ្វី បព្វជ្ជាឈ្មោះអ្វី នៃព្រះសម្មតិទេព ព្រោះអ្នកជាកូនរបស់យើង លះបង់នូវយើងដែលជាមនុស្សចាស់ជរា ឥតអាឡោះអាល័យសោះ (ចេញទៅ) បួស។

[៦៥៣] បុត្រ និងធីតារបស់អ្នកមានច្រើន ហើយនៅក្មេង មិនទាន់ដល់នូវវ័យ មានពាក្យពីរោះ យើងយល់ថា បុត្រ និងធីតាទាំងនោះ កាលមិនឃើញអ្នក និងដល់នូវសេចក្តីទុក្ខ។

[៦៥៤] (ព្រះរាជា...) ការតាំងនៅអស់កាលយូរ ហើយព្រាត់ប្រាសចាកបុត្រ និងធីតារបស់ខ្ញុំទាំងនុ៎ះ ដែលនៅក្មេងមិនទាន់ដល់នូវវ័យ មានពាក្យពីរោះផង ចាកសង្ខារទាំងពួងផង ចាកព្រះអង្គផង (ជាសភាវៈទៀង)។

[៦៥៥] (ស្រីស្នំទាំង ៧០០ នាក់...) ព្រះហឫទ័យរបស់ព្រះអង្គកាត់ដាច់ហើយឬ ឬថាមិនមានសេចក្តីករុណាចំពោះពួកយើងទាំងឡាយទេ បពិត្រព្រះសម្មតិទេព ព្រះអង្គ (លះបង់) ពួកយើង ដែលកំពុងកន្ទក់កន្ទេញ ព្រះអង្គឥតមានសេចក្តីអាឡោះអាល័យ (ចេញទៅ) បួស។

[៦៥៦] (ព្រះរាជា...) ហឫទ័យរបស់យើងមិនបានកាត់ ទាំងសេចក្តីករុណារបស់យើង ក៏នៅមានក្នុងពួកនាង តែយើងប្រាថ្នានូវឋានសួគ៌ ព្រោះហេតុនោះ បានជាយើងនឹងបួស។

[៦៥៧] (អគ្គមហេសី...) បពិត្រព្រះអង្គ ទ្រង់ព្រះនាមសុតសោម (ទីអគ្គមហេសី) ឈ្មោះថាខ្ញុំម្ចាស់បានដោយកម្រ ខ្ញុំម្ចាស់ជាអគ្គមហេសីរបស់ព្រះអង្គ បពិត្រព្រះសម្មតិទេព កាលខ្ញុំម្ចាស់កំពុងតែយំសោក ព្រះអង្គឥតមានសេចក្តីអាឡោះអាល័យ (ចេញទៅ) បួស។ បពិត្រព្រះអង្គ ទ្រង់ព្រះនាមសុតសោម (ទីអគ្គមហេសី) ឈ្មោះថាខ្ញុំម្ចាស់បានដោយកម្រ ខ្ញុំម្ចាស់ជាអគ្គមហេសីរបស់ព្រះអង្គ បពិត្រព្រះសម្មតិទេព ព្រះអង្គ (លះបង់) នូវបដិសន្ធិក្នុងផ្ទៃរបស់ខ្ញុំម្ចាស់ ឥតមានសេចក្តីអាឡោះអាល័យ (ចេញទៅ) បួស។ គភ៌ដែលតាំងនៅក្នុងផ្ទៃរបស់ខ្ញុំម្ចាស់ ចាស់ហើយ (សូមព្រះអង្គរង់ចាំ) ទំរាំខ្ញុំម្ចាស់ប្រសូតគភ៌នោះសិន កុំឲ្យខ្ញុំម្ចាស់ជាស្ត្រីមេមាយម្នាក់ឯង បានឃើញសេចក្តីទុក្ខក្នុងកាលជាខាងក្រោយឡើយ។

[៦៥៨] (ព្រះរាជា...) គភ៌ដែលតាំងនៅក្នុងផ្ទៃរបស់នាងចាស់ហើយ ណ្ហើយ នាងចូរប្រសូតបុត្រ ដែលមានសម្បុរមិនថោកទាប (ដោយសួស្តី) យើងនឹងលះបង់បុត្រ ហើយ (ចេញទៅ) បួស។

[៦៥៩] ម្នាលនាងចន្ទាទេវី មានព្រះនេត្រស្មើដោយផ្កាកណ្ណិការភ្នំ នាងកុំយំ កុំសោកឡើយ ចូរឡើងកាន់ប្រាសាទដ៏ប្រសើរវិញចុះ យើងមិនមានសេចក្តីអាឡោះអាល័យទេ នឹងចេញទៅ (បួស)។

[៦៦០] (ព្រះរាជបុត្រច្បង...) បពិត្រព្រះមាតា បុគ្គលណាធ្វើឲ្យព្រះមាតា ទ្រង់ព្រះក្រោធ ព្រះមាតាទ្រង់ព្រះកន្សែងផង ទ្រង់សំឡក់ចំពោះខ្ញុំយ៉ាងខ្លាំងផង តើព្រោះហេតុអ្វី បណ្តាញាតិដែលកំពុងរមិលមើល ខ្ញុំសម្លាប់ញាតិណា ដែលជាមនុស្សដែលគេមិនគួរសម្លាប់។

[៦៦១] (ព្រះរាជមាតា...) ម្នាលកូន បុគ្គលណាជាអ្នកឈ្នះសង្គ្រាម ញ៉ាំងអញឲ្យក្រោធ បុគ្គលនោះ កូនឯងមិនអាចសម្លាប់បានទេ ម្នាលកូន ព្រះរាជបិតារបស់កូនឯង បានត្រាស់នឹងម្តាយថា យើងមិនមានសេចក្តីអាឡោះអាល័យទេ នឹងទៅ (បួស)។

[៦៦២] (ព្រះរាជឱរសច្បង...) ក្នុងកាលមុន ខ្ញុំទៅកាន់សួនឧទ្យានដោយរថ បានច្បាំងនឹងដំរីចុះប្រេងទាំងឡាយ កាលបើព្រះបិតាទ្រង់ព្រះនាមសុតសោម ទ្រង់ព្រះផ្នួសហើយ ឥឡូវនេះ ខ្ញុំនឹងធ្វើដូចម្តេចហ្ន៎។

[៦៦៣] (ព្រះរាជឱរសប្អូន...) កាលព្រះមាតារបស់ទូលព្រះបង្គំជាខ្ញុំកំពុងទ្រង់ព្រះកន្សែងផង កាលព្រះជេដ្ឋភាតានៃទូលព្រះបង្គំជាខ្ញុំមិនប្រាថ្នា (នឹងឲ្យព្រះអង្គទ្រង់ព្រះផ្នួស) ផង ទូលព្រះបង្គំជាខ្ញុំនឹងចាប់ព្រះហស្តរបស់ព្រះអង្គទុក កាលបើពួកទូលព្រះបង្គំជាខ្ញុំមិនចង់ឲ្យព្រះអង្គទ្រង់ផ្នួស ព្រះអង្គនឹងយាងទៅមិនបានទេ។

[៦៦៤] (ព្រះបិតា...) ម្នាលមេនំ នាងចូរក្រោកឡើង (ចូរកាន់យកនូវកែវមណីនេះ) ហើយញ៉ាំងកុមារនេះឲ្យត្រេកអរក្នុងទីដទៃចុះ កាលបើអញកំពុងប្រាថ្នាឋានសួគ៌ កុំឲ្យកុមារនេះ ធ្វើនូវសេចក្តីអន្តរាយដល់អញឡើយ។

[៦៦៥] (ស្រីមេនំ...) ណ្ហើយចុះ អញនឹងថ្វាយនូវកែវមណីមានរស្មីល្អនេះទៅវិញចុះ កែវមណីនេះមានប្រយោជន៍អ្វីដល់អញ កាលបើព្រះរាជាទ្រង់ព្រះនាមសុតសោម ទ្រង់ព្រះផ្នួសហើយ អញនឹងធ្វើកែវមណីនេះដូចម្តេច។

[៦៦៦] (មហាសេនគុត្ត...) បពិត្រព្រះសម្មតិទេព ឃ្លាំងតូចរបស់ព្រះអង្គពេញ ឃ្លាំងធំរបស់ព្រះអង្គពេញ ទាំងផែនដី ព្រះអង្គក៏ទ្រង់ឈ្នះហើយ សូមព្រះអង្គទ្រង់រីករាយ សូមព្រះអង្គកុំទ្រង់ព្រះផ្នួស។

[៦៦៧] (ព្រះរាជា...) ឃ្លាំងតូចរបស់ខ្ញុំក៏ពេញ ឃ្លាំងធំរបស់ខ្ញុំក៏ពេញ ទាំងផែនដី ខ្ញុំក៏បានឈ្នះហើយ ខ្ញុំនឹងលះបង់នូវទ្រព្យទាំងនោះហើយទៅបួស។

[៦៦៨] (កុលពន្ធនសេដ្ឋី...) បពិត្រព្រះសម្មតិទេព ទ្រព្យរបស់ទូលព្រះបង្គំជាខ្ញុំមានច្រើន ទូលព្រះបង្គំជាខ្ញុំមិនអាចនឹងរាប់បាន ទូលព្រះបង្គំជាខ្ញុំនឹងថ្វាយទ្រព្យទាំងនោះដល់ព្រះអង្គ សូមព្រះអង្គទ្រង់ត្រេកអរ សូមកុំទ្រង់ព្រះផ្នួស។

[៦៦៩] (ព្រះរាជា...) ម្នាលកុលពន្ធនវឌ្ឍនៈ ខ្ញុំដឹងថាទ្រព្យរបស់អ្នកមានច្រើន អ្នកបូជាខ្ញុំហើយ ក៏ប៉ុន្តែខ្ញុំប្រាថ្នាឋានសួគ៌ ហេតុនោះ ខ្ញុំនឹងបួស។

[៦៧០] ម្នាលសោមទត្ត ខ្ញុំជាអ្នកអផ្សុកយ៉ាងខ្លាំង សេចក្តីមិនត្រេកអរ (ក្នុងការគ្រប់គ្រងផ្ទះ) មកគ្របសង្កត់ខ្ញុំហើយ សេចក្តីអន្តរាយមានច្រើនណាស់ ខ្ញុំនឹងបួសក្នុងថ្ងៃនេះមិនខាន។

[៦៧១] (ព្រះកនិដ្ឋភាតាព្រះនាមសោមទត្ត...) បពិត្រព្រះរាជាទ្រង់ព្រះនាមសុតសោម បព្វជ្ជាកម្មនេះ ព្រះអង្គទ្រង់ពេញព្រះទ័យហើយ

ឥឡូវនេះ សូមព្រះអង្គបួសក្នុងថ្ងៃនេះចុះ ទាំងទូលព្រះបង្គំជាខ្ញុំសោតទៀត ក៏នឹងបួសដែរ (ព្រោះ) ទូលព្រះបង្គំជាខ្ញុំ បើវៀរចាកព្រះអង្គហើយ នឹងមិនអាចឋិតនៅបានទេ។

[៦៧២] (ព្រះរាជា...) អ្នកឯងមិនអាចនឹងបួសបានទេ ព្រោះថា បុគ្គលនីមួយក្នុងនគរ ឬក្នុងជនបទ នឹងមិននាំគ្នាចំអិនអាហារឡើយ។

[៦៧៣] (មហាជន...) កាលបើព្រះបាទសុតសោមទ្រង់ព្រះផ្នួសហើយ តើឥឡូវនេះ ពួកយើងនឹងធ្វើដូចម្តេចហ្ន៎។

[៦៧៤] (ព្រះរាជា...) យើងសំគាល់ថា ជីវិតនេះ រមែងរីងស្ងួតទៅ ដូចទឹកដ៏តិច (ដែលគេដាក់) ក្នុងពាងធ្លុះ កាលបើជីវិតតិចយ៉ាងនេះ កាលនេះមិនមែនជាកាលគួរប្រមាទឡើយ។ យើងសំគាល់ថា ជីវិតនេះ រមែងរីងស្ងួតទៅ ដូចទឹកដ៏តិចក្នុងពាងធ្លុះ កាលជីវិតតិចយ៉ាងនេះ កោតតែជនពាលទាំងឡាយប្រមាទ។ ជនពាលទាំងនោះ រមែងញ៉ាំងនរក តិរច្ឆានកំណើត និងបេតវិស័យ ឲ្យចំរើន ជាអ្នកជាប់ដោយគ្រឿងចង គឺតណ្ហា រមែងញ៉ាំងអសុរកាយឲ្យចំរើន។

[៦៧៥] (មហាជន...) គំនរធូលី ហុយឡើងក្នុងទីជិតបុប្ផកប្រាសាទ ពួកយើងសំគាល់គំនរធូលីនោះថាជាព្រះកេសាដែលព្រះធម្មរាជព្រះអង្គមានយស របស់យើង ទ្រង់កាត់ហើយ។

[៦៧៦] ព្រះរាជា ដែលពួកស្រីស្នំហែហមហើយ យាងទៅក្នុងប្រាសាទណា ប្រាសាទនេះរបស់ព្រះរាជានោះដ៏ដេរដាសដោយផ្កាមាស និងកម្រងផ្កាផ្សេងៗ។ ព្រះរាជាដែលពួកព្រះញាតិហែហមហើយ យាងទៅក្នុងប្រាសាទណា ប្រាសាទនេះ របស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាស និងកម្រងផ្កាផ្សេងៗ។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងបន្ទប់សម្រាប់ផ្ទំណា បន្ទប់សម្រាប់ផ្ទំនេះ របស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាស និងកម្រងផ្កាផ្សេងៗ។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងបន្ទប់សម្រាប់ផ្ទំណា បន្ទប់សម្រាប់ផ្ទំនេះ របស់ព្រះរាជានោះ ដ៏ដេរដាសដោយផ្កាមាស និងកម្រងផ្កាផ្សេងៗ។ ព្រះរាជាដែលស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងទីព្រៃឈើអសោកណា ទីព្រៃឈើអសោកនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងទីព្រៃឈើអសោកណា ទីព្រៃឈើអសោកនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងឱទ្យានណា ឱទ្យាននេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងឱទ្យានណា ឱទ្យាននេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងព្រៃឈើកណិការណា ព្រៃឈើកណិការនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងព្រៃឈើកណិការណា ព្រៃឈើកណិការនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងព្រៃច្រនៀងណា ព្រៃច្រនៀងនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងព្រៃច្រនៀងណា ព្រៃច្រនៀងនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកស្រីស្នំ ហែហមហើយ ទ្រង់យាងទៅក្នុងព្រៃស្វាយណា ព្រៃស្វាយនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងព្រៃស្វាយណា ព្រៃស្វាយនេះ របស់ព្រះរាជានោះ មានផ្ការីកល្អសព្វៗ កាល គួរជាទីរីករាយចិត្ត។ ព្រះរាជាដែលពួកស្រីស្នំហែហមហើយ ទ្រង់យាងទៅក្នុងស្រះបោក្ខរណីណា ស្រះបោក្ខរណីនេះ របស់ព្រះរាជានោះ ដ៏ដេរដាស (ដោយផ្កាជលជាត និងផ្កាថលជាត) ដ៏កុះករដោយពួកអណ្ឌជៈ (គួរជាទីរីករាយចិត្ត)។ ព្រះរាជាដែលពួកញាតិហែហមហើយ ទ្រង់យាងទៅក្នុងស្រះបោក្ខរណីណា ស្រះបោក្ខរណីនេះ របស់ព្រះរាជានោះ ដ៏ដេរដាស (ដោយផ្កាជលជាត និងផ្កាថលជាត) ដ៏កុះករដោយពួកអណ្ឌជៈ (គួរជាទីរីករាយចិត្ត)។

[៦៧៧] ព្រះរាជាទ្រង់ព្រះនាមសុតសោម បានលះបង់រាជសម្បត្តិនេះហើយ ក៏ទ្រង់ព្រះផ្នួស ទ្រង់ព្រះពស្ត្រកាសាយៈ ស្តេចយាងទៅតែមួយព្រះអង្គឯង ដូចជាដំរីត្រាច់ទៅតែម្នាក់ឯង។

[៦៧៨] (ព្រះរាជា...) អ្នកទាំងឡាយ កុំរឭកការលេងដោយសេចក្តីត្រេកអរ និងការសើចក្នុងកាលមុនឡើយ កាមទាំងឡាយកុំបៀតបៀនពួកអ្នកឡើយ នគរឈ្មោះសុទស្សនៈ ជាទីគួររីករាយ (អ្នកទាំងឡាយកុំរឭកឡើយ)។ អ្នកទាំងឡាយ ចូរចំរើនមេត្តចិត្ត រកប្រមាណមិនបាន ទាំងថ្ងៃទាំងយប់ ទើបពួកអ្នកនឹងទៅកាន់ទេពបុរី ដែលជាលំនៅពួកអ្នកមានបុញ្ញកម្ម។

ចប់ ចុល្លសុតសោមជាតក ទី៥។

ឧទ្ទាននៃចត្តាលីសនិបាតនោះគឺ

និយាអំពីសេកជាអ្នកប្រាជ្ញឈ្មោះជម្ពុកៈ ១ ពួកព្រះរាជាមានកុណ្ឌល ១ ជាតកនាងអលម្ពុសា ជាកញ្ញាដ៏ប្រសើរ ១ នាគរាជមានសិរីឈ្មោះសង្ខបាលដ៏ប្រសើរ ១ អរិន្ទមរាជដ៏ប្រសើរ ព្រះនាមសុតសោម ១។

ចប់ ចត្តាលីសនិបាត។

ចប់ ភាគ៦០។

# បញ្ញាសនិបាតជាតក

CS sut.kn.jat.v18 | ភាគទី ៦១

## (១៨. បណ្ណាសនិបាតោ)

## នឡិនិកាជាតក ទី១

CS sut.kn.jat.526 | ភាគទី ៦១

## (៥២៦. និឡិនិកាជាតកំ (១))

[១] (ព្រះបាទព្រហ្មទត្ត ត្រាស់ថា) ម្នាលនាងនឡិនិកា ជនបទក្តៅស្ងួត ទាំងដែនក៏វិនាស ចូរនាងមក ចូរនាងទៅញ៉ាំងព្រាហ្មណ៍ (អ្នកធ្វើនូវសេចក្តីវិនាស) ដល់អញនោះ ឲ្យមកលុះអំណាចរបស់ខ្លួន។

[២] (នាងនឡិនិកា ក្រាបទូលថា) បពិត្រព្រះរាជា ខ្ញុំម្ចាស់អត់ទ្រាំសេចក្ដីលំបាកពុំបាន ខ្ញុំម្ចាស់មិនស្ទាត់ផ្លូវឆ្ងាយ ខ្ញុំម្ចាស់នឹងទៅកាន់ព្រៃដែលមានដំរីនៅអាស្រ័យ ដូចម្ដេចបាន។

[៣] (ព្រះរាជា...) ម្នាលនាងនឡិនិកា នាងចូរទៅកាន់ជនបទដ៏ស្ដុកស្ដម្ភ ហើយទៅដោយដំរីផង ដោយរថផង ដោយយាន (ទូក) ដែលគេគាបដោយឈើផង យ៉ាងនេះចុះ។ ម្នាលខត្តិយានី ចូរនាងយកដំរី សេះ រថ និងពលថ្មើរជើងទៅចុះ ចូរនាងនាំព្រាហ្មណ៍ឥសិសិង្គៈនោះមកកាន់អំណាច (ខ្លួន) ដោយសម្បុរ និងរូបឆោមរបស់នាង។

[៤] (ពួកព្រានព្រៃបង្ហាញថា) នុ៎ះ ប្រាកដជាអាស្រមរបស់តាបស ឈ្មោះឥសិសិង្គៈ ជាទីគួររីករាយ មានដើមចេកជាទង់ ជាគ្រឿងសំគាល់ មានដើមស្មាច់ដុះព័ទ្ធជុំវិញ។ នុ៎ះ ភ្លើងដែលឥសិសិង្គៈនោះ តាក់តែង (ដោយឈាន) នុ៎ះ ផ្សែងដែលឃើញប្រាកដ ខ្ញុំសំគាល់ថា ឥសិសិង្គៈ អ្នកមានឫទ្ធិច្រើន មិនញ៉ាំងភ្លើងឲ្យសាបសូន្យទេ។

[៥] (អភិសម្ពុទ្ធគាថា) ឥសិសិង្គៈ បានឃើញនាងនឡិនិកានោះ ពាក់កុណ្ឌលកែវមណី កំពុងដើរមក ក៏ភិតភ័យ ចូលទៅកាន់អាស្រមដែលប្រក់ដោយស្លឹក។ ឯនាងនឡិនិកានោះ ក៏បង្ហាញនូវអវយវៈទាំងឡាយផង បញ្ចេញនូវកេរ្ដិ៍ខ្មាសដ៏កំបាំងផង ហើយលេងកូនឃ្លីក្បែរទ្វារអាស្រមនៃឥសិសិង្គៈនោះ។

[៦] អ្នកមានជដា (ឥសិសិង្គៈ) នៅក្នុងបណ្ណសាលា ឃើញនាងនឡិនិកានោះ កំពុងលេង ចេញអំពីអាស្រមមកនិយាយពាក្យនេះថា ម្នាលអ្នកដ៏ចំរើន ឈើរបស់អ្នកនោះ ឈ្មោះអ្វី ដែលមានផ្លែបែបនេះ សូម្បីអ្នកបោះទៅក្នុងទីឆ្ងាយហើយ ក៏វិលត្រឡប់មកវិញ មិនទៅចោលអ្នក។

[៧] (នាងនឡិនិកា ...) បពិត្រតាបសដ៏ប្រសើរ ផ្លែបែបនេះនៃឈើណា សូម្បីខ្ញុំបោះទៅក្នុងទីឆ្ងាយ ក៏ត្រឡប់មកវិញ មិនទៅចោលខ្ញុំទេ ឈើបែបនោះ មានក្នុងទីជិតអាស្រមនៃខ្ញុំ នាភ្នំគន្ធមាទន៍។

[៨] (ឥសិសិង្គៈ...) អ្នកដ៏ចំរើន ចូរមកកាន់អាស្រមនេះចុះ ចូរបរិភោគអាហារចុះ ចូរទទួលថ្នាំសម្រាប់លាបជើងផង ភក្សាហារផង ខ្ញុំជូន (ដល់អ្នក) នេះអាសនៈ អ្នកដ៏ចំរើន ចូរអង្គុយលើអាសនៈនេះ អ្នកដ៏ចំរើនចូរពិសាមើមឈើ និងផ្លែឈើក្នុងទីនេះចុះ។

[៩] (ឥសិសិង្គៈ សួរថា) អ្វីនេះ កំពុងល្អ (ដូចមាត់ខ្យងបៀ) នៅត្រង់ចន្លោះភ្លៅរបស់អ្នក ប្រាកដដូចជាវត្ថុមានពណ៌ខ្មៅ ៗ ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្ដីនុ៎ះ អវយវៈដ៏ឧត្តម (លិង្គ) របស់អ្នកលិចចូលទៅក្នុងស្រោម (សរីរៈ) ឬ។

[១០] (នាងនឡិនិកា...) ខ្ញុំត្រាច់ទៅកាន់ទីស្វែងរកមើមឈើផ្លែឈើក្នុងព្រៃ បានចោលខ្លាឃ្មុំមានរូបដ៏សម្បើម ខ្លាឃ្មុំនោះ ស្ទុះមកសង្គ្រុបខ្ញុំដោយរហ័ស ផ្ដួលខ្ញុំ ហើយខាំដកយកអវយវៈដ៏ឧត្តមទៅ។ ដំបៅនោះឯង ឈឺពេកផង រមាស់ផង ខ្ញុំមិនបានសេចក្ដីសុខ សព្វ ៗ កាលទេ អ្នកដ៏ចំរើនអាចនាំចេញនូវរោគរមាស់នេះចេញបាន អ្នកដ៏ចំរើនដែលខ្ញុំអង្វរហើយ សូមធ្វើនូវប្រយោជន៍ដល់ព្រាហ្មណ៍។

[១១] (ឥសិសិង្គៈ...) ដំបៅរបស់អ្នកមានសភាពដ៏ជ្រៅ មានសម្បុរក្រហម មិនស្អុយទេ គ្រាន់តែមានក្លិនខ្មោះ (បន្តិចៗ) ហើយថែមទាំងធំផង ខ្ញុំនឹងប្រកបដោយថ្នាំដុសលាបឲ្យអ្នកបន្តិចមើល ដើម្បីនឹងឲ្យអ្នកដ៏ចំរើនបានសេចក្ដីសុខស្រួល។

[១២] (នាងនឡិនិកា...) បពិត្រតាបសដ៏ប្រសើរ ការប្រកបដោយមន្តទាំងឡាយ ក៏មិនត្រូវ ការប្រកបដោយថ្នាំដុសទាំងឡាយក៏មិនត្រូវ ឱសថទាំងឡាយក៏មិនត្រូវ អវយវៈណារបស់លោកដ៏ទន់ ៗ ចូរលោកនាំចេញនូវរោគរមាស់ដោយអវយវៈនោះ ទើបខ្ញុំមានសេចក្ដីសុខស្រួលតទៅ។

[១៣] (ឥសិសិង្គៈ...) អាស្រមរបស់អ្នកដ៏ចំរើន នៅខាងណាអំពីទីនេះ ម្នាលអ្នកដ៏ចំរើន អ្នកអភិរម្យក្នុងព្រៃដែរឬ អ្នកមានមើមឈើផ្លែឈើច្រើនដែរឬ សត្វសាហាវទាំងឡាយ មិនបៀតបៀនអ្នកដ៏ចំរើនទេឬ។

[១៤] (នាងនឡិនិកា...) អាស្រមរបស់ខ្ញុំជាទីគួររីករាយ (នៅ) ក្បែរឆ្នេរនៃស្ទឹងឈ្មោះខេមា ដែលហូរទៅអំពីព្រៃហិមវន្ត នាទិសខាងជើងត្រង់អំពីទីនេះ ធ្វើដូចម្ដេចហ្ន៎ អ្នកដ៏ចំរើនគប្បីឃើញអាស្រមរបស់ខ្ញុំ។ (ទៀបអាស្រមរបស់ខ្ញុំ) មានដើមស្វាយ រាំងភ្នំ ទន្លាប់ ព្រីង រាជព្រឹក្សច្រនៀង មានផ្កាកើសស្ពះស្ពាយ ធ្វើដូចម្ដេចហ្ន៎ អ្នកដ៏ចំរើនគប្បីឃើញអាស្រមរបស់ខ្ញុំដែលមានកិន្នរច្រៀងពីរោះដោយជុំវិញ។ ក្នុងទីជិតអាស្រមរបស់ខ្ញុំនុ៎ះ មានដើមត្នោតទាំងឡាយផង មើមឈើទាំងឡាយផង ផ្លែឈើទាំងឡាយផង ធ្វើដូចម្ដេចហ្ន៎ ទើបអ្នកដ៏ចំរើនគប្បីឃើញនូវអាស្រមរបស់ខ្ញុំ ដែលប្រកបដោយពណ៌ និងក្លិនដែលប្រកបដោយភូមិភាគទាំងឡាយ (ដ៏រាបស្មើ) នោះ។ ផ្លែឈើទាំងឡាយផង មើមឈើទាំងឡាយផង មានគរគោកក្នុងអាស្រមនេះ ប្រកបដោយពណ៌ ក្លិន និងរស តែពួកព្រានព្រៃ តែងមកកាន់ប្រទេសនោះ កុំឲ្យពួកវាលួចមើមឈើ និងផ្លែឈើរបស់ខ្ញុំ អំពីអាស្រមនោះឡើយ។

[១៥] (ឥសិសិង្គៈ...) បិតារបស់ខ្ញុំ ទៅកាន់ទីស្វែងរកមើមឈើ ផ្លែឈើ នឹងមកក្នុងកាលល្ងាច ឥឡូវនេះ ចាំបិតាមកអំពីទីស្វែងរកមើមឈើ និងផ្លែឈើសិន សឹមយើងទាំងពីរនាក់ ទៅកាន់អាស្រមនោះ។

[១៦] (នាងនឡិនិកា...) មានពួកព្រាហ្មណ៍ជាឥសី និងពួកព្រះរាជាជាឥសីដទៃទៀតជាច្រើន ដែលជាមនុស្សត្រឹមត្រូវ នៅក្បែរផ្លូវជាលំដាប់ ចូរអ្នកសួររកអាស្រមខ្ញុំ នឹងឥសីទាំងនោះចុះ ឥសីទាំងនោះ នឹងនាំអ្នកទៅឯសំណាក់ខ្ញុំ (មិនខាន)។

[១៧] (ពោធិសត្វជាបិតាសួរថា) ឧសក៏អ្នកមិនពុះ ទឹកក៏អ្នកមិនដង ទាំងភ្លើង ក៏អ្នកមិនបង្កាត់ ហេតុអ្វីបានជាអ្នកជ្រប់ស្រពោន។ ម្នាលកូនសព្រហ្មចារី ឧសទាំងឡាយ អ្នកធ្លាប់តែពុះ ភ្លើងអ្នកធ្លាប់តែបង្កាត់ ទាំងភ្លើងសម្រាប់អាំង ក៏អ្នកធ្លាប់ចាត់ចែង តាំង ក៏អ្នកធ្លាប់រៀបចំសម្រាប់អញ ទឹកក៏អ្នកធ្លាប់តែដឹកលំទុកសម្រាប់អញ កាលពីមុន អ្នកជាមនុស្សប្រសើរ តែងរីករាយ (ក្នុងអាស្រមនេះ)។ (ឥឡូវនេះ) អ្នកមិនពុះឧស មិនដងទឹក មិនបង្កាត់ភ្លើង មិនស្ងោរវត្ថុសម្រាប់បរិភោគ នៃកូនរបស់អញ ថ្ងៃនេះអ្នកមិនហៅរកអញ អ្នកបាត់របស់អ្វីឬ ឬក៏អ្នកកើតទុក្ខក្នុងចិត្តដូចម្ដេច។

[១៨] (ឥសិសិង្គៈ...) ជដិលជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរមកក្នុងទីនេះ ជាមនុស្សគួរគេយគន់ មានដងខ្លួនទ្រទេសទ្រទន់ មិនខ្ពស់ពេកមិនទាបពេក ញ៉ាំងអាស្រមបទឲ្យភ្លឺស្វាយពាសពេញដោយសក់ទាំងឡាយ ដែលខ្មៅស្រិលដូចជាពណ៌នៃស្លាបកន្លង់ របស់ជដិលដ៏ចំរើន (នោះ)។ (ជដិលនោះ) មិនទាន់ដុះពុកមាត់នៅឡើយទេ ទើបនឹងបួសថ្មីៗ មានទាំងរបស់មានសណ្ឋានដូចជើងបាត្រ ពាក់ត្រង់ករបស់គាត់ មានពកពីរជាគូ ភ្លឺបំព្រង ដូចជាផ្លែទន្លាប់មាស ដុះក្បែរល្អត្រង់ទ្រូង។ មុខជដិលនោះ គួរគេយគន់ក្រៃពេក មានកំពូលនៃគ្រឿងប្រដាប់ត្រចៀកទាំងឡាយសំយុងចុះ ពួជត្រចៀកទាំងឡាយ កាលមាណព (នោះ) ត្រាច់ទៅ គ្រឿងប្រដាប់នៃត្រចៀកទាំងនោះក៏រុងរឿងផ្លេកៗផង មានទាំងខ្សែស្រយរុំព័ទ្ធផ្នួងសក់ទាំងឡាយផង។ មាណពនោះ មានគ្រឿងប្រដាប់ដទៃទៀតមានពន្លឺ ៤ ពណ៌គឺ ពណ៌ខៀវ លឿង ក្រហម ស កាលបើមាណព (នោះ) ដើរទៅ គ្រឿងប្រដាប់ទាំងនោះញ័រៗ ដូចជាពួកនៃសត្វមេភ្លៀង ក្នុងពេលកំពុងភ្លៀង។ (មាណពនោះ)

មិនពាក់សង្វារស្មៅយាប្លងទេ មិនប្រើប្រាស់សំពត់សំបកឈើទេ មិនប្រើប្រាស់សំពត់ដែលត្បាញដោយស្មៅជំណោកទន្សាយទេ គ្រឿងប្រដាប់ទាំងនោះ ជាប់នៅត្រង់ចន្លោះនៃស្មង ភ្លឺដូចជាផ្លេកបន្ទោរ ដែលចាំងឮដ៏អាកាស។ (មាណពនោះ មានគ្រឿងប្រដាប់ដេរដោយសូត្រ) មិនមានស្នាមគ្រោតគ្រាតផង មិនមានទង (អាចម៍ដង្កូវ) ផង ចងព័ទ្ធត្រង់ចង្កេះ ពីត្រឹមផ្ចិតចុះទៅខាងក្រោម គ្រឿងប្រដាប់ទាំងនោះ ទុកជាឥតមានអ្វីប៉ះពាល់សោះ ក៏ធ្វើនូវល្បែងជានិច្ច គឺញ័រររីចជាប្រក្រតី បពិត្រឋិតាដ៏ចំរើន គ្រឿងប្រដាប់ទាំងនោះ ឈ្មោះថាផ្លែឈើអ្វី។ ផ្នូងសក់របស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក (បើមើល) ជាងមួយរយដង (ក៏មិនអស់ចិត្ត) មានចុងងខ្វង់ មានក្លិនក្រអូប (មាណពនោះ) មានសក់ក្បាលញែកជាពីរ សិតញែកស្អាតបាត ធ្វើដូចម្តេចហ្ន៎ នឹងបានឲ្យផ្នូងសក់របស់ខ្ញុំល្អដូច្នោះផង។ មាណពនោះ រំសាយសក់ក្នុងកាលណា ផ្នូងសក់ទាំងឡាយនោះ ក៏ប្រកបដោយពណ៌ ដោយក្លិន ក្នុងកាលនោះ អាស្រមនេះ ក៏ផ្សព្វផ្សាយទៅ (ដោយក្លិន) ដូចជាផ្កាឧប្បលខៀវ ដែលខ្យល់បក់ត្រូវដូច្នោះ។ សម្បុររបស់មាណពនោះ គួរឲ្យចង់មើលក្រៃពេក កាយរបស់មាណពនោះ មិនដូចជាកាយរបស់ខ្ញុំឡើយ កាយរបស់មាណពនោះ កាលបើត្រូវខ្យល់បក់មក ផ្សព្វផ្សាយក្លិនដូចជាព្រៃឈើ ដែលមានផ្ការីកស្គុះស្គាយក្នុងខាងចុងនៃគិម្ហរដូវ។ មាណពនោះ តែងទះនូវផ្លែឈើ មានសភាពដ៏វិចិត្រល្អរុងរឿង គួរឲ្យចង់មើល បោះទៅលើផែនដី ផ្លែឈើនោះ រមែងត្រឡប់មក រកដៃរបស់មាណពនោះវិញ បពិត្របិតាដ៏ចំរើន នោះជាផ្លែឈើអ្វី។ ធ្មេញទាំងឡាយរបស់មាណពនោះ ក៏គួរឲ្យចង់មើលក្រៃពេក ស្អាតស្មើដូចជាស័ង្ខដែលគេខាត់យ៉ាងសំខាន់ កាលដែលគាត់ហាមាត់ឡើង តែងញុំាងចិត្តឲ្យជ្រះថ្លា ដ្បិតមាណពនោះ មិនទំពាស៊ីនូវបន្លែ ដោយធ្មេញទាំងឡាយនោះទេ។ សំដីរបស់មាណពនោះ និយាយឡើងមិនជាសំដីអាក្រក់ មិនភ្លាត់ ពីរោះ ស្រទន់ត្រង់ៗ មិនរាយមាយ មិនឮកោកកាក ជាសំដីញុំាងចិត្តឲ្យរីករាយ គួរចាប់ចិត្ត ដូចជាសំឡេងនៃសត្វករវិកយាសយំ ចិត្តរបស់ខ្ញុំត្រេកអរខ្លាំងណាស់។ (មាណពនោះ) មានសំឡេងមូល មានពាក្យមិនសូវក្បោះក្បាយពេកទេ មិនមែនជាអ្នកខ្វល់ខ្វាយក្នុងការស្វាធ្យាយ (មន្ត) ដោយពិត ខ្ញុំចង់ឃើញមាណពនោះម្តងទៀត ដ្បិតមាណព (នោះ) ជាមិត្តរបស់ខ្ញុំតាំងពីមុនដម្បូងមក។ ដំបៅ (ត្រង់ចន្លោះភ្លៅរបស់មាណពនោះ) ជិតស្និទ្ធល្អ រលីងស្អាតសព្វអន្លើ ក្រាស់ ក្បាល្អ ដូចជាផ្កាឈូកក្រពុំ មាណព (នោះ) គ្របសង្កត់ខ្ញុំដោយដំបៅនោះឯង សើយភ្លៅហើយគាបខ្ញុំដោយស្មង។ (ស្មើដូចមាស ដែលផ្សាយចេញអំពីសរីរកាយនៃមាណពនោះ) ភ្លឺត្រចះត្រចង់ ភ្លឺស្វាងរុងរឿង ភ្លឺផ្លេក ៗ ដូចជាផ្លេកបន្ទោរឆ្វៀលឆ្វាត់លើអាកាស ដើមដៃទាំងពីរទន់ភ្លន់ មានរោមប្រហែលកេសរផ្កាអញ្ជ័ន មាណពនោះ មានម្រាមដៃមូល ៗ ដ៏វិចិត្រល្អ។ ម្យ៉ាងទៀត (មាណពនោះ) មានអវយវៈតូចធំ មិនរដិបរដុប (ដោយមុន និងឫសជាដើម) ទេ មានរោមមិនវែងពេកទេ ឯក្រចករបស់មាណពនោះ វែងៗ មានចុងក្រហមៗ (មាណពនោះ) មានរូបល្អ ឱបរិត (ខ្ញុំ) ដោយដើមដៃទាំងពីរដ៏ទន់ល្វន់ (ផ្គាប់ផ្គួនខ្ញុំ) ឲ្យរីករាយ។ ដៃទាំងពីររបស់មាណពនោះ ដូចជាប៉ុយឈើ មានរស្មីផ្លេកៗ មានបាតដៃមូល និងឆវីវណ្ណស្រស់បំព្រង ដូចផ្ទៃកញ្ចក់ ជាវិការៈនៃមាស មាណពនោះ ពាល់ខ្ញុំដោយដៃទាំងពីរ នោះហើយ ទៅពីទីនេះទៅ បពិត្របិតា មាណពនោះ ដុតរោលខ្ញុំ (ឲ្យក្តៅក្រហាយ) ដោយសម្ផស្សនៃដៃនោះ។ មាណពនោះ ប្រហែលជាមិនដែលនាំទៅនូវវត្ថុមានទម្ងន់មួយខារី (មួយអំរែក) ទេ មាណពនោះ មិនដែលពុះឧសទាំងឡាយខ្លួនឯងទេ មាណពនោះ មិនដែលកាប់ឈើទាំងឡាយដោយកាំបិតទេ បានជាដៃរបស់មាណពនោះ មិនក្រិនសោះ។ មានខ្លាឃ្មុំមួយធ្វើមាណពនោះឲ្យដំបៅ គេបាននិយាយនឹងខ្ញុំថា សូមឲ្យអ្នកធ្វើខ្ញុំឲ្យបានសេចក្តីសុខស្រួល ខ្ញុំក៏បានធ្វើគាត់ឲ្យបានសុខស្រួល ដោយអវយវៈដ៏ឧត្តមនោះរបស់ខ្ញុំ បពិត្របិតាដ៏ប្រសើរ មាណពនោះបាននិយាយប្រាប់ខ្ញុំថា ខ្ញុំបានសេចក្តីសុខស្រួលហើយ។ នេះកម្រាលនៃស្លឹកឈើទាល មានសភាពរាត់រាយ ដែលខ្ញុំ និងគេដេកប្រកៀកប្រឱបលើគ្នា យើងទាំងពីរនាក់នោះអស់កម្លាំង ក៏ចុះងូតទឹក ហើយចូលទៅកាន់បណ្ណកុដិរឿយៗ។ បពិត្របិតា ខ្ញុំមិនបានជួបនឹងព្រហ្មចារីនោះ ដរាបណា មន្តទាំងឡាយមិនជាក់ច្បាស់ដល់ខ្ញុំក្នុងថ្ងៃនេះផង ខ្ញុំមិនពេញចិត្តនឹងការបូជាភ្លើងផង មិនពេញចិត្តនឹងការបូជាយញ្ញផង ទាំងមិនបរិភោគមើមឈើ និងផ្លែឈើរបស់លោកផង ដរាបនោះ។ បពិត្របិតា ចំណែកលោកជ្រាបច្បាស់ប្រាកដ ព្រហ្មចារី (នោះ) នៅក្នុងទិសណា បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ទិសនោះយ៉ាងឆាប់ កុំឲ្យខ្ញុំស្លាប់ក្នុងអាស្រមរបស់លោកឡើយ ដ្បិតខ្ញុំបានឮថា ព្រៃ (ជាទីនៅនៃព្រហ្មចារីនោះ) មានផ្ការីកស្គុះស្គាយដ៏វិចិត្រ ហើយជាទីគឹកកងដោយបក្សី ជាទីដែលពួកបក្សីនៅអាស្រ័យ (ជានិច្ច) បពិត្របិតា សូមលោកជូនខ្ញុំទៅឲ្យដល់ព្រៃនោះឆាប់ៗ មុនខ្ញុំនឹងលះជីវិតក្នុងអាស្រមរបស់លោក។

[១៩] (ព្រះមហាសត្វ...) សេចក្តីពិតថា បុគ្គលមិនគួរដល់នូវសេចក្តីអផ្សុកបែបនេះ ក្នុងព្រៃដែលរុងរឿងដោយពន្លឺ ជាទីគឹកកងដោយពួកគន្ធព្វ និងស្រីទេពអប្សរ ជាទីនៅនៃឥសីទាំងឡាយ ជាព្រៃមានតាំងពីយូរយារណាស់ហើយនេះឡើយ។ មិត្រទាំងឡាយ មានខ្លះមិនមានខ្លះ ជនទាំងឡាយគួរធ្វើនូវសេចក្តីស្រឡាញ់ចំពោះញាតិ និងមិត្រ មនុស្សណាមិនដឹងថា អាត្មាអញកើតមកពីណា មនុស្សនេះគម្រក់ ត្រូវមាតុគ្រាមបង្វឹកបានទាំងថ្ងៃ ដោយហេតុអ្វី។ ធម្មតាមិត្រទាំងឡាយ រមែងជាប់តគ្នា ដោយការនៅរួមរឿយៗ មិត្រនោះឯង រមែងលាកចិត្តដោយការមិនបាននៅរួមគ្នារបស់បុរសដែលមិនបានទៅមករកគ្នា។ បើអ្នកឃើញនូវព្រហ្មចារី (នោះទៀត) បើអ្នកចរចាជាមួយនឹងព្រហ្មចារី (នោះទៀត) អ្នកនឹងបំផ្លាញនូវតបោគុណនេះយ៉ាងឆាប់មិនខាន ដូចជាសន្ទូងដ៏ល្អបរិបូណ៌ ដែលទឹកធំបំផ្លាញដូច្នោះ។ បើអ្នកនឹងឃើញនូវព្រហ្មចារី (នោះ) ទៀត បើអ្នកចរចាជាមួយនឹងព្រហ្មចារី (នោះ) ទៀត អ្នកនឹងបំផ្លាញនូវតេជៈរបស់សមណៈនេះយ៉ាងឆាប់មិនខាន ដូចជាសន្ទូងល្អបរិបូណ៌ ដែលទឹកធំបំផ្លាញដូច្នោះ។ នែកូន ភូតទាំងឡាយនេះ តែងត្រាច់ទៅក្នុងមនុស្សលោក ដោយបែបភាពនៃរូបផ្សេងៗ ជនអ្នកមានប្រាជ្ញា មិនត្រូវគប់រកនឹងភូតទាំងឡាយនោះឡើយ បុគ្គលជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ តែងវិនាសទៅ (ព្រោះដល់) នូវការជាប់ចំពាក់ (នឹងភូតបែបនោះឯង)។

ចប់ នឡិនិកាជាតក ទី១។

## ឧម្មាទន្តីជាតក ទី២

CS sut.kn.jat.527 | ភាគទី ៦១

### (៥២៧. ឧម្មាទន្តីជាតកំ (២))

[២០] (ព្រះបាទសិវិ ត្រាស់សួរសារថីថា) ហៃសុនន្ទៈ នេះជាទីលំនៅរបស់នរណាហ្ន៎ ដែលព័ទ្ធព័ទ្ធដោយកំពែង ធ្វើដោយឥដ្ឋពណ៌ក្រហម ស្រ្តីអ្វីប្រាកដដូចអណ្តាតភ្លើង ក្នុងទីឆ្ងាយ ឬដូចជាអណ្តាតភ្លើង ឮដ៏អាកាសលើកំពូលភ្នំ។ ម្នាលសុនន្ទៈ ស្រ្តីនេះជាធីតារបស់នរណាហ្ន៎ ស្រ្តីនេះជាកូនប្រសាររបស់នរណាហ្ន៎ ឬជាភរិយារបស់នរណា ប្រសិនបើ (ស្រ្តីនេះ) មិនទាន់មានគេហួងហែងក្តី មានភស្តាក្តី ខ្ញុំសួរហើយ ចូរអ្នកប្រាប់យ៉ាងឆាប់ ក្នុងកាលឥឡូវនេះកុំខាន។

[២១] (សារថីក្រាបបង្គំទូលថា) បពិត្រព្រះជនិន្ទៈ ខ្ញុំព្រះអង្គស្គាល់ស្រ្តីនុ៎ះជាក់លាក់ អំពីចំណែកខាងមាតាផង អំពីចំណែកខាងបិតាផង ទាំងស្វាមីរបស់ស្រ្តីនោះ ក៏ខ្ញុំព្រះអង្គស្គាល់ បពិត្រព្រះភូមិបាល ស្វាមីនោះ ជាបុរសរបស់ព្រះអង្គហ្នឹងឯង ជាអ្នកមិនប្រហែសធ្វេសក្នុងប្រយោជន៍របស់ព្រះអង្គទាំងយប់ទាំងថ្ងៃ។ បពិត្រព្រះជនិន្ទៈ ព្រះអង្គមានអាមាត្យម្នាក់ ជាអ្នកស្តុកស្តម្ភមាំមួនថ្កុំថ្កើង បពិត្រព្រះរាជា ស្រ្តីនោះឈ្មោះនាងឧម្មាទន្តី ជាប្រពន្ធរបស់អាមាត្យឈ្មោះអភិបារកៈនោះឯង។

[២២] (ព្រះរាជា...) រ៉ឺយ រ៉ឺយ ឈ្មោះនេះ ដែលមាតាបិតាបានឲ្យដល់នាងនេះ ត្រូវល្អណាស់ បានជាថាដូច្នោះ ព្រោះនាងឧម្មាទន្តី កាលក្រឡេកមើលអញ ធ្វើអញឲ្យឆ្កួត។

[២៣] ស្ត្រីណាមានភ្នែកស្រទន់ដូចភ្នែកម្រឹគ មានសរីរៈសម្បុរដូចផ្កាឈូកក្រហម អង្គុយអែប (ក្បែរបង្អួច) ក្នុងរាត្រីដែលមានព្រះចន្ទពេញវង់ អញបានឃើញស្ត្រីនោះ ដែលមានសំលៀកបំពាក់ក្រហមដូចជាជើងព្រាប ក៏ស្មានថាជាព្រះចន្ទពេញវង់ពីរ។ (នាងឧម្មាទន្តី) ប្រលោមអញ ដោយអាការទ្រទេសទ្រទន់ល្អស្រស់ ជាប្រធាននៃការដ៏វិសេស ម៉ឹកម៉ក់ក្រឡេកមើលអញ ចិត្តរបស់អញក៏រេរីរាយ ដូចជាក្នុងកាលដែលកិន្នរញីកើតក្នុងព្រៃភ្នំ (ហិមពាន្តធ្វើកិន្នរឈ្មោល ឲ្យមានចិត្តរេរីរាយដូច្នោះ)។ ដ្បិតក្នុងកាលនោះ នាងនារីមានសម្បុរលឿង ពាក់កុណ្ឌលកែវមណី មានសំលៀកបំពាក់តែមួយ ក្រឡេកមើល (អញ) ដូចជាមេម្រឹគផ្អើល។ កាលណាហ្ន៎ នឹងបាននារីមានក្រចកក្រហមទុំ មានរោមល្អ មានដើមដៃទន់ភ្លន់ លាបស្រឡាបដោយខ្លឹមចន្ទន៍ មានម្រាមដៃមូល ប្រសប់ខាងធ្វើម៉ឹកម៉ូក់ ល្អផុតចុងសក់ មកឱបអង្អែលអញ។ កាលណាហ្ន៎ អញនឹងបានធីតារបស់សេដ្ឋីឈ្មោះតិរិដិ ដែលមានគ្រឿងប្រដាប់ទ្រូងជាវិការនៃមាស មានដងខ្លួនរៀវ មកឱបរឹតអញដោយដើមដៃទាំងពីរដ៏ទន់ភ្លន់ ដូចជាព្ធរជ្រៃដែលរួបរឹតដើមឈើដុះក្នុងព្រៃធំ។ កាលណាហ្ន៎ អញនឹងបាន (នារី) ដែលមានសម្បុរល្អស្រស់ ដូចជាទឹកល័ក្តក្រហម មានដោះក្បុំដូចជាពពុះទឹក មានសរីរៈសម្បុរដូចផ្កាឈូកក្រហម បង្អោនមុខមកប៉ះនឹងមុខ (អញ) ដូចជាអ្នកលេង (ដែលហុច) កែវសុរាឲ្យដល់អ្នកលេងផងគ្នា។ អញបានឃើញនារីនោះ មានខ្លួនសមរម្យសព្វអន្លើ ជាតម្រេកនៃចិត្តកំពុងឈរក្នុងកាលណា អញមិនបានជាឥស្សរៈ (លើចិត្តរបស់ខ្លួន) មិនស្គាល់នារីនោះ ថាជាអ្វីឡើយ ក្នុងកាលនោះ។ អញបានឃើញនាងឧម្មាទន្តី ដែលពាក់កុណ្ឌលជាវិការៈនៃកែវមណី ក៏ដេកមិនលក់ទាំងថ្ងៃទាំងយប់ ដូចជាគេផ្ចាញ់អស់មួយពាន់ដង។ បើសក្កទេវរាជប្រទានពរដល់អញ សូមឲ្យអញបានពរនោះថា អភិបារកសេនាបតី សូមត្រេកត្រអាលជាមួយនឹងនាងឧម្មាទន្តីតែមួយយប់ ពីរយប់ប៉ុណ្ណោះចុះ តពីនោះទៅ សូមព្រះបាទសិវិរាជ (ត្រេកត្រអាលជាមួយនឹងនាងឧម្មាទន្តីវិញ)។

[២៤] (អភិបារកសេនាបតី...) បពិត្រព្រះអង្គជាម្ចាស់នៃជន កាលដែលទូលព្រះបង្គំជាខ្ញុំសំពះទេវតាទាំងឡាយ មានទេវតា (មួយអង្គ) មកពោលពាក្យដូច្នេះថា ព្រះទ័យរបស់ព្រះរាជា ជាប់ចំពាក់នឹងនាងឧម្មាទន្តី ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយព្រះអង្គ សូមព្រះអង្គឲ្យនាងឧម្មាទន្តីនោះបំរើចុះ។

[២៥] (ព្រះរាជា...) ខ្ញុំគប្បីឃ្លាតចាកបុណ្យផង ខ្ញុំមិនមែនជាមិនស្លាប់ផង អ្នកផងដឹងនូវអំពើអាក្រក់របស់ខ្ញុំនេះផង សេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យ (នាងឧម្មាទន្តី) ជាទីស្រឡាញ់ ហើយមិនបានឃើញទៀតផង។

[២៦] (អភិបារក...) បពិត្រព្រះជនិន្ទៈ លើកលែងតែព្រះអង្គ និងទូលព្រះបង្គំជាខ្ញុំចេញ អ្នកទាំងពួងមិនគប្បីដឹងនូវអំពើដែលទូលព្រះបង្គំជាខ្ញុំថ្វាយនាងឧម្មាទន្តី ដល់ព្រះអង្គទេ បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ គឺតណ្ហា ឲ្យខ្លាំងក្លាចុះ (បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យហើយ សូមលះបង់ចុះ)។

[២៧] (ព្រះរាជា...) មនុស្សណា ធ្វើអំពើអាក្រក់ មនុស្សនោះ តែងសំគាល់ថា ជនទាំងឡាយដទៃ ពុំដឹងនូវអំពើអញនេះឡើយ តែពួកភូតនិងពួកនរជនដែលប្រកប (ដោយឫទ្ធិ) លើផែនដី រមែងឃើញបុគ្គលដែលធ្វើបាបកម្មនុ៎ះ។ ជនដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿចិត្តអ្នកថា នាង (ឧម្មាទន្តី) មិនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ហើយ មិនបានឃើញទៀត។

[២៨] (អភិបារក...) បពិត្រព្រះជនិន្ទៈ នាងឧម្មាទន្តីនុ៎ះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ សូមសេចក្តីចំរើនចូរមានដល់ព្រះអង្គ សូមព្រះអង្គយាងទៅកាន់សំណាក់នាងឧម្មាទន្តីកុំខាន ដូចជាសីហៈឈ្មោលចូលទៅកាន់គុហាកែវមណី (ជាលំនៅរបស់សីហៈញី) ដូច្នោះ។

[២៩] (ព្រះរាជា...) អ្នកប្រាជ្ញទាំងឡាយ (បើទុកជា) ត្រូវសេចក្តីទុក្ខក្នុងខ្លួនបៀតបៀនហើយ ក៏មិនលះបង់នូវអំពើដែលមានផលជាសុខឡើយ ឬទោះបើវង្វេងជ្រុលជ្រប់ក្តី ស្រវឹងដោយសេចក្តីសុខក្តី ក៏គង់មិនប្រព្រឹត្តធ្វើបាបកម្មទេ។

[៣០] (អភិបារក...) ព្រះអង្គដូចជាមាតាបិតា ជាអ្នកចិញ្ចឹម ជាម្ចាស់ ជាអ្នកបីបាច់រក្សា ទាំងជាទេវតារបស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះបាទសិវិ ខ្ញុំព្រះអង្គ ព្រមទាំងកូនប្រពន្ធ ជាទាសៈរបស់ព្រះអង្គ សូមទ្រង់ធ្វើសេចក្តីប្រាថ្នាតាមសប្បាយចុះ។

[៣១] (ព្រះរាជា...) បុគ្គលណាអាងថា អាត្មាអញជាធំដូច្នេះហើយ ធ្វើនូវអំពើអាក្រក់ បុគ្គលនោះលុះបានធ្វើរួចហើយ ក៏មិនរអែងនឹងពួកជនដទៃ ព្រោះអំពើនោះ បុគ្គលនោះ មិនរស់នៅអស់កាលជាអង្វែង ទាំងពួកទេវតាក៏តែងរំពៃមើលបុគ្គលនោះ ដោយអំពើអាក្រក់។

[៣២] (អភិបារក...) បុគ្គលទាំងឡាយណា តាំងនៅក្នុងធម៌ ទទួលយកនូវទាន ដែលគេមិនស្គាល់ ដែលម្ចាស់ទាំងឡាយប្រគល់ឲ្យហើយ បុគ្គលជាអ្នកទទួលទាំងឡាយ (នោះ) ផង អ្នកឲ្យទាំងឡាយផង ឈ្មោះថាធ្វើនូវអំពើមានផលជាសុខក្នុងហេតុនោះ។

[៣៣] (ព្រះរាជា...) បុគ្គលដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿអ្នកថា (នាងឧម្មាទន្តី) មិនមែនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ ហើយមិនបានឃើញទៀតផង។

[៣៤] (អភិបារក...) បពិត្រព្រះជនិន្ទៈ នាងឧម្មាទន្តីនុ៎ះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំដោយពិត បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ នាងឧម្មាទន្តី ទូលព្រះបង្គំជាខ្ញុំបានថ្វាយហើយ ចំពោះព្រះអង្គដោយហេតុណា បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ គឺតណ្ហា ឲ្យខ្លាំងក្លាចុះ (បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យ) សូមលះបង់ចុះ។

[៣៥] (ព្រះរាជា...) បុគ្គលណាឲ្យទុក្ខដល់ជនដទៃ ដោយទុក្ខរបស់ខ្លួន ឬដណ្តើមសុខដើម្បីខ្លួន អំពីសុខ (របស់ជនដទៃ) (បុគ្គលនោះឈ្មោះថាមិនស្គាល់ធម៌) លុះតែបុគ្គលណា ដឹងច្បាស់យ៉ាងនេះថា សុខទុក្ខរបស់អញនេះយ៉ាងណា សុខទុក្ខរបស់ជនដទៃក៏យ៉ាងនោះដែរ បុគ្គលនោះទើបឈ្មោះថា អ្នកដឹងធម៌។

[៣៦] បុគ្គលដទៃណាហ្ន៎ លើផែនដីក្នុងលោក គប្បីជឿអ្នកថា (នាងឧម្មាទន្តី) មិនមែនជាទីស្រឡាញ់របស់អញដូច្នេះ ទាំងសេចក្តីចង្អៀតចង្អល់ចិត្ត គប្បីមានដល់អ្នកយ៉ាងខ្លាំង ព្រោះអ្នកឲ្យនាងឧម្មាទន្តីជាទីស្រឡាញ់ហើយ មិនបានឃើញទៀតផង។

[៣៧] (អភិបារក...) បពិត្រព្រះជនិន្ទៈ ព្រះអង្គគង់ជ្រាបថា នាងឧម្មាទន្តីនុ៎ះ ជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះភូមិបាល នាងនោះមិនមែនមិនជាទីស្រឡាញ់របស់ទូលព្រះបង្គំជាខ្ញុំទេ បពិត្រព្រះជនិន្ទៈ ទូលព្រះបង្គំជាខ្ញុំ សូមថ្វាយនាងឧម្មាទន្តីជាទីស្រឡាញ់ ចំពោះព្រះអង្គ ដោយចិត្តជាទីស្រឡាញ់ បពិត្រព្រះសម្មតិទេព បុគ្គលអ្នកឲ្យនូវវត្ថុជាទីស្រឡាញ់ទាំងឡាយ រមែងបាននូវវត្ថុជាទីស្រឡាញ់វិញ។

[៣៨] (ព្រះរាជា...) អញនោះមុខជានឹងសម្លាប់ខ្លួន ព្រោះមានកាមជាហេតុដោយពិត អញនឹងមិនអាចដើម្បីសម្លាប់នូវធម៌ដោយអធម៌ឡើយ។

[៣៩] (អភិបារក...) បពិត្រព្រះជនិន្ទ: ទ្រង់មានព្យាយាមក្នុងពួកជនដ៏ប្រសើរ បើព្រះអង្គមិនសព្វព្រះរាជហឫទ័យនឹងនាងឧម្មាទន្តី ដែលជារបស់ទូលព្រះបង្គំជាខ្ញុំទេ ទូលព្រះបង្គំជាខ្ញុំនឹងលះបង់នាងនាកណ្ដាលជនទាំងពួង តពីនោះទៅ ព្រះអង្គគប្បីនាំយកនាងឧម្មាទន្តីនោះ ដែលទូលព្រះបង្គំជាខ្ញុំលះបង់ហើយ។

[៤០] (ព្រះរាជា...) នែអភិបារក: បើអ្នកលះបង់ (នាងឧម្មាទន្តី) ដែលមិនមានទោស នៃ អ្នកធ្វើ (ប្រយោជន៍ដល់ខ្ញុំ) ការលះបង់នោះ គប្បីមិនជាប្រយោជន៍ដល់អ្នកផង ពាក្យតំណេះតំនៀលយ៉ាងច្រើន គប្បីមានដល់អ្នកផង ប័ក្ខពួករបស់អ្នកក្នុងនគរ មិនគប្បីមានផង។

[៤១] (អភិបារក...) បពិត្រព្រះភូមិបាល ទូលព្រះបង្គំជាខ្ញុំនឹងអត់ទ្រាំនូវពាក្យតំណេះតំនៀលនុ៎ះផង នូវនិន្ទាផង នូវសេចក្ដីសរសើរផង និងការពោលទោសគ្រប់យ៉ាងថា ហេតុទាំងនុ៎ះ ចូរមកដល់ទូលព្រះបង្គំជាខ្ញុំចុះ បពិត្រព្រះបាទសីវិ សូមទ្រង់ធ្វើនូវសេចក្ដីប្រាថ្នាតាមសប្បាយចុះ។

បុគ្គលណា មិនអើពើនឹងនិន្ទា មិនអើពើនឹងសេចក្ដីសរសើរ មិនអើពើនឹងពាក្យពោលទោស មិនអើពើនឹងការបូជា សិរីក្ដី បញ្ញាក្ដី រមែងទៅប្រាសចាកបុគ្គលនោះដូចជាទឹក គឺទឹកភ្លៀងយ៉ាងស្រួល ដែលទៅប្រាសចាកទីទួលដូច្នោះ។ ទូលព្រះបង្គំជាខ្ញុំនឹងទទួលនូវសេចក្ដីទុក្ខផង នូវសេចក្ដីសុខផង នូវអំពើអាក្រក់ហួសផ្លូវធម៌ផង នូវសេចក្ដីចង្អៀតចង្អល់ចិត្តគ្រប់យ៉ាង តាមតែយ៉ាងណាក៏ដោយ អំពីដំណើរនេះដោយផ្ទាល់ទ្រូង ដូចជាផែនដី (ដែលទទួលនូវវត្ថុណាមួយ) របស់ពួកជនអ្នកមាំមួន គឺព្រះអរហន្ត និងរបស់ពួកជនអ្នកតក់ស្លុត គឺបុថុជ្ជន។

[៤២] (ព្រះរាជា...) ខ្ញុំមិនប្រាថ្នាអំពើអាក្រក់ហួសផ្លូវធម៌ផង សេចក្ដីទុក្ខជាគ្រឿងចង្អៀតចង្អល់ចិត្តផង ដល់ជនទាំងឡាយដទៃទេ ខ្ញុំតែម្នាក់ឯង ឋិតនៅក្នុងធម៌ មិនញុំាងប្រយោជន៍បន្តិចបន្តួចឲ្យសាបសូន្យទៅទេ ហើយនឹងផ្លងនូវភារៈ គឺសេចក្ដីទុក្ខនេះ។

[៤៣] (អភិបារក...) បពិត្រព្រះជនិន្ទ: ព្រះអង្គកុំធ្វើនូវបុញ្ញកម្ម ជាគ្រឿងញុំាងសត្វឲ្យកើតក្នុងឋានសួគ៌របស់ទូលព្រះបង្គំជាខ្ញុំ ឲ្យអន្តរាយឡើយ ទូលព្រះបង្គំជាខ្ញុំ ជ្រះថ្លា ថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គ ដូចជាព្រះរាជា (ដែលទ្រង់ព្រះរាជទាន) នូវទ្រព្យក្នុងការបូជាដល់ពួកព្រាហ្មណ៍។

[៤៤] (ព្រះរាជា...) ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គលមានប្រយោជន៍ដល់ខ្ញុំដោយពិត នាងឧម្មាទន្តី និងអ្នកជាសំឡាញ់របស់ខ្ញុំ ពួកទេវតា និងទេវតាជាបិតា និងអ្នកទាំងអស់ មុខជានិន្ទា ទាំងខ្ញុំក៏មុខជានឹងឃើញនូវបាបក្នុងអភិសម្បរាយភពពុំខាន។

[៤៥] (អភិបារក...) បពិត្រព្រះបាទសិវិ ពួកអ្នកនិគម និងពួកអ្នកជនបទទាំងអស់គ្នា មិនគប្បីពោលនូវអំពើដែលទូលព្រះបង្គំជាខ្ញុំបានថ្វាយនាងឧម្មាទន្តីចំពោះព្រះអង្គនុ៎ះ ថាជាធម៌ទេ បពិត្រព្រះរាជា សូមព្រះអង្គធ្វើនូវព្រៃ (តណ្ហា) ឲ្យខ្លាំងក្លា (បើ) ព្រះអង្គ (លែងសព្វព្រះរាជហឫទ័យហើយ) សូមលះបង់ចុះ។

[៤៦] (ព្រះរាជា...) ម្នាលអ្នកធ្វើនូវប្រយោជន៍ អ្នកជាបុគ្គលមានប្រយោជន៍ ដល់ខ្ញុំដោយពិត នាងឧម្មាទន្តី និងអ្នកជាសំឡាញ់របស់ខ្ញុំ ធម៌ទាំងឡាយ ដែលពួកសប្បុរសបានសំដែងល្អហើយ ខ្ញុំប្រព្រឹត្តកន្លងបានដោយកម្រ ដូចជាសមុទ្រ និងច្រាំង។

[៤៧] (អភិបារក...) ព្រះអង្គជាអាហុនេយ្យបុគ្គល ជាអ្នកអនុគ្រោះដោយប្រយោជន៍ ជាអ្នកទ្រទ្រង់ ជាអ្នកចាត់ចែង (ឥស្សរិយសុខ) និងជាអ្នករក្សានូវសេចក្ដីប្រាថ្នារបស់ទូលព្រះបង្គំជាខ្ញុំ បពិត្រព្រះរាជា នាងឧម្មាទន្តីដែលទូលព្រះបង្គំជាខ្ញុំ បានថ្វាយព្រះអង្គ នឹងមានផលច្រើន សូមទ្រង់ទទួលយកនាងឧម្មាទន្តី តាមសេចក្ដីប្រាថ្នារបស់ទូលព្រះបង្គំជាខ្ញុំ។

[៤៨] (ព្រះរាជា...) ម្នាលអភិបារក:ជាកូនរបស់សេនាបតី ជាអ្នកធ្វើនូវប្រយោជន៍ អ្នកមិនមែនជាបុគ្គលប្រព្រឹត្តនូវធម៌ទាំងអស់ដល់ខ្ញុំដោយពិត ជនមានជើងពីរដទៃ តើរូបណាក្នុងជីវលោកនេះ ជាអ្នកធ្វើនូវសួស្ដីដល់អ្នកក្នុងពេលអរុណរះ។

[៤៩] (អភិបារក...) ព្រះអង្គជាបុគ្គលប្រសើរផុត ព្រះអង្គជាបុគ្គលខ្ពង់ខ្ពស់ផុត ព្រះអង្គជាអ្នកដល់នូវធម៌ ជ្រាបច្បាស់នូវធម៌ មានព្រះប្រាជ្ញាប្រពៃ ទ្រង់ជាអ្នកគ្រប់គ្រងនូវធម៌ សូមទ្រង់មានព្រះជន្មាយុអស់កាលដ៏អង្វែង បពិត្រព្រះធម្មបាល សូមទ្រង់សំដែងធម៌ដល់ទូលព្រះបង្គំជាខ្ញុំ។

[៥០] (ព្រះរាជា...) បើដូច្នោះ ម្នាលអភិបារក: អ្នកចូរស្ដាប់ពាក្យខ្ញុំ ខ្ញុំនឹងសំដែងធម៌ដែលពួកសប្បុរសធ្លាប់សេពដល់អ្នក។ ព្រះរាជាជាអ្នកគាប់ចិត្តដោយធម៌ទើបល្អ ជនមានប្រាជ្ញាទើបល្អ ការមិនប្រទូស្ដមិត្តទើបល្អ កិរិយាមិនធ្វើបាបទើបសុខ។ មនុស្សទាំងឡាយ គប្បីនៅជាសុខក្នុងផ្ទះរបស់ខ្លួន ក្នុងម្លប់ដ៏ត្រជាក់ ក្នុងដែននៃស្ដេច ដែលមិនមានក្រោធ មានច្បាប់ឋិតថេរ។ ខ្ញុំមិនគាប់ចិត្តនឹងអំពើដែលមិនពិចារណា ហើយធ្វើ ដែលធ្វើមិនប្រពៃនុ៎ះទេ ម្យ៉ាងទៀត ជនទាំងឡាយណា ដឹងថា (មិនប្រពៃ) ហើយ មិនធ្វើដោយខ្លួនឯង (អំពើរបស់ជនទាំងឡាយនោះ ទើបខ្ញុំពេញចិត្ត) អ្នកស្ដាប់ពាក្យប្រៀបធៀបនេះរបស់ខ្ញុំចុះ។ កាលគោទាំងឡាយកំពុងឆ្លងទៅ បើគោបាទៅវៀចផ្លូវ កាលបើគោអ្នកនាំផ្លូវទៅវៀចហើយ ពួកមេគោទាំងអស់នោះ ក៏ដើរវៀចដែរ។ បណ្ដាមនុស្សទាំងឡាយ ក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតថាប្រសើរផុត បើជននោះ ប្រព្រឹត្តនូវអធម៌ទៅហើយ នឹងចាំបាច់និយាយទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ រាស្ត្រទាំងអស់ តែងដេកជាទុក្ខ។ កាលបើគោទាំងឡាយកំពុងឆ្លងទៅ គោបាទៅត្រង់ កាលបើគោអ្នកនាំផ្លូវទៅត្រង់ហើយ ពួកមេគោទាំងអស់នោះ ក៏ដើរទៅត្រង់។ បណ្ដាមនុស្សទាំងឡាយក៏ដូច្នោះ ជនណាដែលអ្នកផងសន្មតថាប្រសើរផុត បើជននោះ ប្រព្រឹត្តធម៌ នឹងចាំបាច់ពោលទៅថ្វីដល់ប្រជាជនក្រៅនេះ បើព្រះរាជាទ្រង់ប្រកបដោយធម៌ រាស្ត្រទាំងអស់រមែងដេកជាសុខ។ ម្នាលអភិបារក: ខ្ញុំមិនប្រាថ្នានូវភាពនៃខ្លួនជាទេវតាដោយអធម៌ទេ ម្យ៉ាងទៀត (ខ្ញុំមិនប្រាថ្នា) ដើម្បីឈ្នះនូវផែនដីទាំងមូលនេះ (ដោយអធម៌ទេ)។ ថ្វីបើក្នុងមនុស្សលោកនេះ មានរតនវត្ថុណាមួយ គឺគោទាំងឡាយ ខ្ញុំ ប្រាក់ សំពត់ និងខ្លឹមចន្ទន៍ក្រហមដោយពិតដូច្នោះ។ ព្រះចន្ទ និងព្រះអាទិត្យទាំងឡាយនេះ រក្សាទុកនូវរតនៈណាមួយ គឺសេះ និងស្ត្រីទាំងឡាយ កែវមណី បុគ្គលមិនគួរប្រព្រឹត្តនូវធម៌មិនស្មើ ព្រោះហេតុនៃរតនវត្ថុនោះៗ ទេ យើងដូចជាគោឧសភ កើតក្នុងចំណោមនៃពួកជនអ្នកនៅក្នុងដែនសិវិ។ ខ្ញុំនោះជាអ្នកដឹកនាំ ជាអ្នកស្វែងរកប្រយោជន៍ ល្បីល្បាញរក្សានូវដែន លំអុតលំឱនចំពោះប្រពៃណី (របស់ស្ដេចជាន់មុន) នៃអ្នកសិវិរាស្ត្រទាំងឡាយ ជាអ្នកត្រិះរិះតែធម៌ ព្រោះហេតុនោះ ខ្ញុំមិនលុះក្នុងអំណាចនៃចិត្តរបស់ខ្លួនទេ។

[៥១] (អភិបារក...) បពិត្រមហារាជ ព្រះអង្គនឹងសោយរាជសម្បត្តិទៀងទាត់ មិនវិនាស ក្សេមក្សាន្ត បានយូរយារដោយពិត ដ្បិតប្រាជ្ញារបស់ព្រះអង្គប្រាកដដូច្នោះ។ ព្រះអង្គមិនប្រមាទចំពោះធម៌ណា ទូលព្រះបង្គំជាខ្ញុំសូមអនុមោទនាចំពោះធម៌នុ៎ះរបស់ព្រះអង្គ ក្សត្រជាឥស្សរៈ ប្រមាទចំពោះធម៌ហើយ រមែងឃ្លាតចាកដែន។ បពិត្រខត្តិយ មហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងមាតាបិតាទាំងឡាយ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងព្រះរាជបុត្ត និងអគ្គមហេសី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកមិត្រ និងអាមាត្យ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកវាហនៈផង ក្នុងពួកពលផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ

សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកអ្នកស្រុកផង ក្នុងពួកអ្នកនិគមផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងពួកអ្នកដែនផង ក្នុងពួកអ្នកជនបទផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ក្នុងសមណៈផង ក្នុងពួកព្រាហ្មណ៍ផង បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រខត្តិយមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ ក្នុងពួកម្រឹគ និងបក្សី បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ (ដ្បិត) ធម៌ដែលគេសន្សំហើយ តែងនាំមកនូវសេចក្តីសុខ បពិត្រព្រះរាជា ព្រះអង្គប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមទ្រង់ប្រព្រឹត្តធម៌ចុះ (ដ្បិត) ព្រះឥន្ទ្រទាំងឡាយ ទេវតាទាំងឡាយ ព្រមទាំងព្រហ្ម បានដល់នូវអត្តភាពជាទិព្វ ដោយសារធម៌ ដែលគេបានសន្សំទុកល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រមាទចំពោះធម៌ឡើយ។

ចប់ ឧម្មាទន្តីជាតក ទី២។

## មហាពោធិជាតក ទី៣

CS sut.kn.jat.528 | ភាគទី ៦១

**(៥២៨. មហាពោធិជាតកំ (៣))**

[៥២] (ព្រះបាទព្រហ្មទត្តត្រាស់សួរថា) បពិត្រព្រាហ្មណ៍ ហេតុអ្វីក៏លោកប្រញាប់ប្រញាល់កាន់យកឈើច្រត់ផង ស្បែកខ្លាឃ្មុំផង ឆត្រផង ស្បែកជើងផង ទំពក់ផង បាត្រផង សង្ឃាដិផង លោកប្រាថ្នា (ដើម្បីទៅ) កាន់ទិសណាហ្ន៎។

[៥៣] (ព្រះមហាសត្តឆ្លើយថា) អាត្មាភាពនៅក្នុងសំណាក់ព្រះអង្គអស់ ១២ ឆ្នាំនេះហើយ មិនដែលស្គាល់សំឡេងដែលផ្លែក្រហម ព្រះម្តងឡើយ។ ឆ្កែនោះបញ្ចេញចង្កូមសស្វាច ព្រុះដូចជាសាហាវ ព្រោះឮ (ព្រះបន្ទូល) របស់ព្រះអង្គ ព្រមទាំងអគ្គមហេសី ដែលមានជំនឿ ទៅប្រាសហើយ ក្នុងរវាងអាត្មាភាព។

[៥៤] (ព្រះរាជា...) បពិត្រព្រាហ្មណ៍ ទោសនុ៎ះខ្ញុំបានធ្វើហើយ ដូចជាលោកពោល ខ្ញុំនោះ ជ្រះថ្លាលើសដើម បពិត្រព្រាហ្មណ៍ សូមលោកគង់នៅ ចូរកុំទៅ។

[៥៥] (ព្រះមហាសត្វ...) កាលពីដើម បាយសសុទ្ធ តពីនោះមក បាយពព្រះ ឥឡូវនេះ បាយក្រហមសុទ្ធ (កាលនេះ) ជាកាលគួរអាត្មាភាពចៀសចេញទៅហើយ។ ពីដើម អាសនៈរបស់ (អាត្មាភាព) នៅខាងក្នុង (ប្រាសាទ) តមកនៅកណ្តាល (ក្បាលជណ្តើរ) តពីនោះមកទៀត នៅខាងក្រៅ អាត្មាភាពនឹងចេញទៅខ្លួនឯង មុនការបណ្តេញ។ បុគ្គលមិនត្រូវសេពគប់បុគ្គលប្រាសចាកសទ្ធា ដែលទុកដូចអណ្តូងមិនមានទឹក ប្រសិនបើបុគ្គលកកាយអណ្តូងនោះ (ទឹកដែលចេញអំពីអណ្តូងនោះ) មុខជាប្រកបដោយក្លិនភក់ពុំខាន។ បុគ្គលត្រូវសេពគប់ចំពោះតែជនដែលជ្រះថ្លា ត្រូវវៀរចាកជនដែលមិនជ្រះថ្លា ត្រូវចូលទៅអង្គុយជិតជនដែលជ្រះថ្លា ដូចជាបុគ្គលត្រូវការដោយទឹក (ចូលទៅរក) អន្លង់ទឹកដូច្នោះ។ បុគ្គលគួរគប់រកបុរសដែលគប់រក (ខ្លួន) មិនគួរគប់រកបុរសដែលមិនគប់រក (ខ្លួន) ទេ បុគ្គលណាមិនគប់រកបុគ្គលដែលគប់រក (ខ្លួន) បុគ្គលនោះឈ្មោះថាកាន់ធម៌របស់អសប្បុរស។ បុគ្គលណា មិនគប់រកបុគ្គលដែលគប់រក (ខ្លួន) មិនសេពគប់ចំពោះបុគ្គលដែលសេពគប់ (នឹងខ្លួន) បុគ្គលនោះឯង ជាមនុស្សអាក្រក់ផុត ដូចជាម្រឹគ ដែលអាស្រ័យនៅលើមែកឈើ (ស្វា)។ មិត្តទាំងឡាយ លាកចិត្តពីគ្នាដោយហេតុនេះ គឺដោយនៅច្រឡូកច្រឡំគ្នាញឹកពេក ១ ដោយការមិនជួបគ្នាសោះ ១ ដោយការសូមក្នុងកាលមិនគួរ ១។ ព្រោះហេតុនោះ បុគ្គលមិនត្រូវទៅញឹកៗ ផង មិនត្រូវទៅ (ឃ្លាតគ្នា) យូរពេកផង គប្បីសូមនូវរបស់ដែលគួរសូមតាមកាលផង យ៉ាងនេះ ទើបមិត្រទាំងឡាយ មិនលាក់ចិត្តពីគ្នា។ បុគ្គលធ្លាប់ជាទីស្រឡាញ់ ទៅជាមិនជាទីស្រឡាញ់វិញ ព្រោះនៅរួមគ្នាយូរពេក អាត្មាភាពសូមលាព្រះអង្គទៅមុន យើងទាំងឡាយនោះ មិនជាទីស្រឡាញ់គ្នាទេ។

[៥៦] (ព្រះរាជា...) បើលោកម្ចាស់មិនទទួលដឹងនូវអញ្ជលីរបស់យើងទាំងឡាយ ដែលអង្វរយ៉ាងនេះ មិនធ្វើតាមពាក្យយើង ដែលជាសត្វបំរើទេ យើងខ្ញុំសូមអង្វរលោកម្ចាស់យ៉ាងនេះ សូមលោកម្ចាស់ធ្វើនូវសេចក្តីប្រាថ្នា (ដើម្បីមកក្នុងទីនេះ) ម្តងៗ។

[៥៧] (ពោធិសត្ត...) បពិត្រមហារាជ ទ្រង់មានសេចក្តីចំរើនក្នុងដែន កាលបើយើងទាំងឡាយនៅ (ផ្សេងគ្នា) យ៉ាងនេះ អន្តរាយនឹងមានដល់ព្រះអង្គផង ដល់អាត្មាភាពផង សូមយើងទាំងឡាយ ជួបគ្នាក្នុងកាលកន្លងទៅមួយថ្ងៃមួយយប់។

[៥៨] (ព្រះមហាសត្វទំលាយនូវវាទៈរបស់អាមាត្យជាអហេតុកវាទីថា) បើពាក្យ (របស់អ្នកថា) សត្វប្រព្រឹត្តទៅតាមសង្គតិ[38] (នៃអភិជាតិទាំង ៦) និងសភាវៈ សត្វធ្វើនូវអំពើដែលមិនគួរធ្វើ (បាប) ឬអំពើដែលគួរធ្វើ (បុណ្យ) តើនរណា ក្នុងលោកនេះ ប្រឡាក់ដោយបាប ព្រោះអំពើដែលធ្វើដោយការមិនចង់។ បើ (សេចក្តីនៃភាសិតរបស់អ្នក គឺអហេតុកវាទ) នោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើនជាពាក្យពិត ពានរក៏ឈ្មោះថាអាត្មាសម្លាប់ត្រូវហើយ។ បើអ្នកដឹងនូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើនបែបនោះ។

[៥៩] (ព្រះមហាសត្តទំលាយនូវវាទៈរបស់អាមាត្យ ជាឥស្សរករណវាទីថា) ប្រសិនបើព្រះឥសូរ ចាត់ចែងជីវិតរបស់សត្វលោកទាំងអស់ផង ចាត់ចែងនូវឫទ្ធិ គឺឥស្សរិយយសផង នូវភាពនៃសេចក្តីវិនាសផង នូវកម្មល្អ និងអាក្រក់ផង មានបុរស (ណាមួយ) ជាអ្នកធ្វើតាមបង្គាប់ (របស់ព្រះឥសូរនោះ) ព្រះឥសូរទេតើ តែងប្រឡាក់ជិតដាមដោយអំពើអាក្រក់នោះ (ដោយខ្លួនឯង)។ បើ (សេចក្តីនៃភាសិតរបស់អ្នក) នោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើនជាពាក្យពិត ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើនបែបនោះ។

[៦០] (ព្រះមហាសត្តទម្លាយនូវវាទៈ នៃអាមាត្យដែលជាបុព្វេកតហេតុវាទីថា) បើបុគ្គលដល់នូវសុខទុក្ខ ព្រោះហេតុនៃអំពើដែលខ្លួនធ្វើក្នុងកាលមុន បុគ្គលនោះឯង រមែងរួចចាកបំណុលនោះ ដែលជាអំពើអាក្រក់ គឺខ្លួនធ្វើពីដើមមក (កាលបើយ៉ាងនេះ) អាត្មាក៏ឈ្មោះថាបានរួចចាកបំណុលចាស់ តើនរណាក្នុងលោកនេះ ប្រឡាក់ដោយបាប។ បើ (សេចក្តីនៃភាសិតរបស់អ្នក) នោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើនជាពាក្យពិត ពានរក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើនបែបនោះ។

[៦១] (ព្រះមហាសត្តទំលាយនូវវាទៈរបស់អាមាត្យជាឧច្ឆេទវាទីថា) រូបក្ខន្ធរបស់សត្វទាំងឡាយ តែងកកើតឡើង ព្រោះអាស្រ័យនូវភូតរូបទាំង ៤ (មានដីជាដើម) ឯរូប (នោះ) កកើតឡើងអំពីភូតរូបណា (ដល់ពេលរលត់) ក៏ត្រឡប់ទៅក្នុងភូតរូបនោះវិញ។ ជីវៈរស់នៅក្នុងលោកនេះ លុះរំលាងខន្ធទៅហើយ នឹងសាបសូន្យក្នុងបរលោក លោកនេះដាច់សូន្យ ជនទាំងឡាយ ទាំងពាល ទាំងបណ្ឌិត (រមែងសូន្យដូចគ្នា) កាលបើលោកនេះដាច់សូន្យហើយ តើនរណា ក្នុងលោកនេះ ប្រឡាក់ដោយបាប។ បើ (សេចក្តីនៃភាសិតរបស់អ្នក)

នោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើនជាពាក្យពិត ពានរក៏ឈ្មោះថាអាត្មាសម្លាប់ត្រូវហើយ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើនបែបនោះ។

[៦២] (ព្រះមហាសត្តទំលាយនូវវាទៈរបស់អាមាត្យជាខត្តវិជ្ជវាទីថា) ជនទាំងឡាយអ្នកមានខត្តវិជ្ជា (វិជ្ជាខាងការគាស់រំលើង) ក្នុងលោក ជាជនពាលសោះទេ តែមានមានះ ថាជាបណ្ឌិត ពោលថាបុគ្គលសម្លាប់មាតាក៏បាន បិតាក៏បាន ពុំនោះសោតទេ សម្លាប់បងប្អូន ឬកូនប្រពន្ធក៏បាន ប្រសិនបើមានប្រយោជន៍បែបនោះ។

[៦៣] (មហាសត្តប្រកាសនូវលទ្ធិរបស់ខ្លួនថា) បុគ្គលអង្គុយក្តី ដេកក្តី ក្រោមម្លប់ឈើណា មិនត្រូវកាច់មែកឈើនោះទេ ដ្បិតបុគ្គលប្រទូស្តមិត្រ ជាមនុស្សអាក្រក់។ (ចំណែកខាងអ្នក ពោលថា) កាលបើប្រយោជន៍កើតឡើង (ចំពោះខ្លួន) ហើយ បុគ្គលគប្បីគាស់រំលើងសូម្បីទាំងឫសក៏បាន (ដូច្នេះ) ពានរ ក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ ព្រោះអាត្មាត្រូវការដោយស្បៀង។ បើសេចក្តីនៃភាសិតរបស់អ្នកនោះ ជាអត្ថផង ជាធម៌ផង ល្អ មិនអាក្រក់ទេ បើពាក្យរបស់អ្នកដ៏ចំរើនជាពាក្យពិត ពានរ ក៏ឈ្មោះថា អាត្មាសម្លាប់ត្រូវហើយ។ បើអ្នកដឹងច្បាស់នូវកំហុសនៃវាទៈរបស់ខ្លួន អ្នកមិនត្រូវតិះដៀលអាត្មាទេ ដ្បិតវាទៈរបស់អ្នកដ៏ចំរើនបែបនោះ។

[៦៤] (ព្រះមហាសត្ត សំដែងធម៌ដល់ព្រះរាជាថា) (បុរសអ្នកលុះក្នុងអំណាចនៃទិដ្ឋិ ៥ នាក់គឺ) បុរសជាអហេតុវាទ ១ ជាឥស្សរកតវាទ ១ ជាបុព្វេកតវាទ ១ ជាឧច្ឆេទវាទ ១ ជាខត្តវិជ្ជវាទ ១ នេះជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុរសបែបនោះ ធ្វើបាប (ខ្លួនឯង) ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅច្រឡូកច្រឡំនឹងអសប្បុរស មានទុក្ខជាទីបំផុត មានសេចក្តីក្តៅក្រហាយជាកម្រៃ។

[៦៥] កាលពីដើម មានសត្វកុកមួយមានរូបដូចចៀម កាលបើឥតគេសង្ស័យ ក៏ចូលទៅរកហ្វូងពពែ សម្លាប់មេចៀមផង មេពពែផង ពពែឈ្មោលផង លុះសម្លាប់បានហើយ ក៏ហើរទៅតាមបំណងរបស់ខ្លួន។ សមណព្រាហ្មណ៍ពួកខ្លះ ក៏បែបនោះដែរ ធ្វើនូវគ្រឿងបិទបាំង ហើយបញ្ឆោតមនុស្សទាំងឡាយ (ពួកខ្លះ) ជាអ្នកមិនបរិភោគអាហារ (ពួកខ្លះ) ជាអ្នកដេកលើផែនដី (ពួកខ្លះ) ទុកក្អែល (ពួកខ្លះ) ព្យាយាមអង្គុយច្រហោង (ពួកខ្លះ) បរិភោគបាយដោយកំណត់ថ្ងៃ (ពួកខ្លះ) មិនផឹកទឹក មានមារយាទអាក្រក់ នាំគ្នាពោលថា ខ្លួនជាអរហន្ត។ ជនទាំងនុ៎ះ ជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុគ្គលបែបនោះ ធ្វើបាប (ខ្លួនឯង) ផង ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅច្រឡូកច្រឡំដោយអសប្បុរស មានទុក្ខជាទីបំផុត មានសេចក្តីក្តៅក្រហាយជាកម្រៃ។ ពួកជនណាពោលថា ព្យាយាមឥតអំពើផង មិនពោលអាងហេតុផង ពណ៌នានូវអំពើរបស់បុគ្គលដទៃ និងអំពើរបស់ខ្លួន ថាជាអំពើសូន្យទទេផង។ ពួកជននុ៎ះ ជាអសប្បុរសក្នុងលោក ជាមនុស្សពាល តែប្រកាន់ខ្លួនថាជាបណ្ឌិត បុរសបែបនោះ ធ្វើបាប (ខ្លួនឯង) ផង ថែមទាំងញុំាងអ្នកដទៃឲ្យធ្វើបាបទៀតផង ការនៅច្រឡូកច្រឡំដោយអសប្បុរស មានទុក្ខជាទីបំផុត មានសេចក្តីក្តៅក្រហាយជាកម្រៃ ប្រសិនបើការព្យាយាមឥតអំពើ មិនមានអំពើល្អ និងអាក្រក់ទេ ព្រះរាជាមិនគប្បីចិញ្ចឹមនូវជាងឈើ ទាំងមិនគប្បីឲ្យគេធ្វើនូវយន្តទាំងឡាយឡើយ។ ព្រោះហេតុតែការព្យាយាមមានផង អំពើល្អ និងអាក្រក់មានផង បានជាព្រះរាជាតែងចាត់ឲ្យធ្វើនូវយន្តទាំងឡាយ តែងចិញ្ចឹមនូវជាងឈើ។ ប្រសិនបើភ្លៀងខានបង្អុរចុះ រហូតមួយរយឆ្នាំ ទាំងទឹកសន្សើម ក៏មិនធ្លាក់ចុះសោះ មុខជាលោកនេះ នឹងសូន្យឈឹង ពពួកសត្វនេះ នឹងវិនាស។ ព្រោះហេតុតែភ្លៀងបង្អុរចុះផង ទាំងទឹកសន្សើម ក៏ផ្សើមរឿយៗ ផង បានជាសន្ទូងទាំងឡាយលូតលាស់ល្អ ទាំងអ្នកដែន ក៏ព្រះរាជាទ្រង់រក្សាអស់កាលជាអង្វែងផង។ កាលពួកគោ កំពុងឆ្លងទៅ (កាន់ទីណាមួយ) បើគោបាទៅវៀច កាលបើគោបានាំពួកគោទៅវៀច មេគោទាំងអស់នោះក៏ទៅវៀច។ បណ្តាពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលអ្នកផងសន្មតថា ប្រសើរផុត បើបុគ្គលនោះប្រព្រឹត្តអធម៌ហើយ នឹងចាំបាច់និយាយថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាមិនប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាទុក្ខ។ កាលពួកគោកំពុងឆ្លងទៅ បើគោបាទៅត្រង់ កាលបើគោបានាំគេទៅត្រង់ មេគោទាំងអស់នោះក៏ទៅត្រង់។ ពួកមនុស្សក៏ដូច្នោះដែរ បុគ្គលណាដែលអ្នកផងសន្មតថា ប្រសើរផុត ប្រសិនបើបុគ្គលនោះប្រព្រឹត្តធម៌ នឹងចាំបាច់និយាយថ្វី ដល់ប្រជាជនក្រៅនេះ បើព្រះរាជាប្រកបដោយធម៌ អ្នកដែនទាំងអស់ក៏ដេកជាសុខ។ បុគ្គលណា បេះផ្លែខ្ចីនៃឈើធំដែលមានផ្លែ (បុគ្គលនោះ) រមែងមិនដឹងនូវរសនៃផ្លែឈើនោះផង ទាំងពូជនៃផ្លែឈើនោះ ក៏វិនាសទៅផង។ ព្រះរាជាណា គ្រប់គ្រងដែនដែលប្រៀបដូចដើមឈើធំ ដោយអធម៌ (ព្រះរាជានោះ) ឈ្មោះថា មិនជ្រាបនូវរសរបស់ដែននោះផង ទាំងដែនរបស់ព្រះរាជានោះក៏វិនាសផង។ បុគ្គលណា បេះផ្លែឈើទុំនៃដើមឈើធំ ដែលមានផ្លែ បុគ្គលនោះ រមែងដឹងនូវរសនៃផ្លែឈើនោះផង ទាំងពូជរបស់ផ្លែឈើនោះ ក៏មិនវិនាសផង។ ព្រះរាជាណា គ្រប់គ្រងដែនដែលប្រៀបដូចជាដើមឈើធំដោយធម៌ (ព្រះរាជានោះ) ឈ្មោះថាបានជ្រាបនូវរសរបស់ដែននោះផង ទាំងដែនរបស់ព្រះរាជានោះ ក៏មិនវិនាសផង។ ព្រះរាជាណាមួយ គ្រប់គ្រងជនបទដោយអធម៌ (លុះអំណាចអគតិ) ព្រះរាជាជាខត្តិយៈនោះ ឈ្មោះថា សាបសូន្យចាកដើមឈើដែលត្រូវជាឱសថទាំងអស់។ មួយទៀត (ព្រះរាជាអង្គណា) បៀតបៀនពួកកុដុម្ពិក៍ ដែលនៅក្នុងនិគម (ផង) បៀតបៀនពួកពាណិជដែលប្រឹកបក្នុងការលក់ចេញទិញចូល ជាអ្នកធ្វើនូវការថ្វាយពន្ធដារ និងពលិការ (ផង) ព្រះរាជានោះ ឈ្មោះថាសាបសូន្យចាកឃ្លាំង។ ព្រះរាជាណា បៀតបៀននូវខ្មាន់ធ្នូ ដែលជាអ្នកដឹងនូវកន្លែងយ៉ាងតំណំ ដែលគួរប្រហារ និងពួកទាហានធំ ដែលជាអ្នកពិចារណាធ្វើការក្នុងសង្គ្រាម និងមហាមាត្យ ដែលមានស័ក្តិធំៗ ព្រះរាជានោះ ឈ្មោះថាសាបសូន្យចាកពល។ ក្សត្រណាប្រព្រឹត្តនូវអធម៌ បៀតបៀនពួកឥសី អ្នកសង្រួមប្រព្រឹត្តធម៌ដ៏ប្រសើរ ដូចជាបៀតបៀននូវពួកអ្នកនិគមដូច្នោះ ក្សត្រនោះ ឈ្មោះថា សាបសូន្យចាកឋានសួគ៌។ម្យ៉ាងទៀត ព្រះរាជាណា មិនឋិតនៅក្នុងធម៌ សម្លាប់អគ្គមហេសីដែលជាអ្នកមិនប្រទូស្ត ព្រះរាជានោះ ឈ្មោះថាបានចូបប្រទះនូវឋានៈដ៏អាក្រក់ផង ឈ្មោះថាសាបសូន្យចាកកូនទាំងឡាយផង។ ព្រះរាជាត្រូវតែប្រព្រឹត្តធម៌ផង មិនត្រូវបៀតបៀនអ្នកជនបទ និងអ្នកនិគមផង ពួកពលផង ពួកឥសីផង គប្បីប្រព្រឹត្តស្មោះស្មើចំពោះកូន និងប្រពន្ធផង។ ព្រះរាជានោះ ទើបឈ្មោះថាជាម្ចាស់នៃផែនដី ឈ្មោះថាអ្នកគ្រប់គ្រងនូវដែន ឈ្មោះថាជាអ្នកមិនក្រោធ រមែងញុំាងពួកអ្នកដែនជិតខាងឲ្យរំភើបញាប់ញ័រ ដូចព្រះឥន្ទ ជាធំជាងអសុរ។

ចប់ មហាពោធិជាតក ទី៣។

ឧទ្ទាននៃបញ្ញាសនិបាតនោះ គឺ

និទ្ទេសទី ១ ប្រកបដោយនាងរាជធីតាព្រះនាម នឡិនិកា ១ និទ្ទេសទី ២ ប្រកបដោយសេដ្ឋីធីតាឈ្មោះឧម្មាទន្តីដ៏ប្រសើរ ១ និទ្ទេសទី ៣ ប្រកបដោយតាបសមានសិរីឈ្មោះ ពោធិ ១ និទ្ទេសទាំង ៣ ដ៏ល្អ (នេះ) ព្រះជិនស្រីទ្រង់សំដែងទុកមកហើយ។

ចប់ បញ្ញាសនិបាត។

# សដ្ឋិនិបាតជាតក

CS sut.kn.jat.v19 | ភាគទី ៦១

(១៩. សដ្ឋិនិបាតោ)

## (៥២៩. សោណកជាតកំ (១))

[៦៦] (ព្រះរាជាព្រះនាមអរិន្ទមៈ ទ្រង់ត្រាស់ថា) អ្នកណាបានឮ អញនឹងឲ្យទ្រព្យមួយរយ អ្នកណាបានឃើញសោណកៈ អញនឹងឲ្យទ្រព្យមួយពាន់ អ្នកណានឹងប្រាប់អញនូវសោណកៈជាសំឡាញ់ដែលលេងដីជាមួយគ្នា។

(អភិសម្ពុទ្ធគាថា) គ្រានោះ មាណពក្មេងមានជុក ៥ បានក្រាបបង្គំទូលថា ទូលព្រះបង្គំជាខ្ញុំបានឮ សូមព្រះអង្គប្រទានទ្រព្យមួយរយ ទូលព្រះបង្គំជាខ្ញុំបានឃើញសោណកៈ សូមព្រះអង្គប្រទានទ្រព្យមួយពាន់ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលដល់ព្រះអង្គនូវសោណកៈជាសំឡាញ់ ដែលលេងដីជាមួយគ្នា។

[៦៧] (ព្រះរាជា...) សោណកៈនោះ នៅក្នុងជនបទណា ក្នុងដែនណា ក្នុងនិគមណា ឯងបានឃើញសោណកៈក្នុងទីណា អញសួរហើយ ឯងចូរប្រាប់ពីសោណកៈនោះ។

[៦៨] (កុមារ...) បពិត្រព្រះសម្មតិទេព ត្រង់ទីឧទ្យានរបស់ព្រះអង្គ ក្នុងដែនរបស់ព្រះអង្គហ្នឹងឯង មានពួកឈើធំ មានដើមត្រង់ មានពន្លឺខៀវ ជាតម្រេកនៃចិត្ត ពួកឈើទាំងនោះ មានពណ៌ដូចផ្ទៃមេឃ គួរឲ្យត្រេកអរ ដុះទាក់ទងគ្នាទៅវិញទៅមក កាលពួកសត្វលោកមានគ្រឿងឆេះ កំពុងត្រូវភ្លើងឆេះ សោណកៈ មិនមានគ្រឿងឆេះ ជាបុគ្គលរលត់ហើយ កំពុងចំរើនឈានជិតគល់ឈើទាំងនោះ។

[៦៩] (អភិសម្ពុទ្ធគាថា) លំដាប់នោះ ព្រះរាជាទ្រង់ប្រើបំរើឲ្យចាត់ចែងធ្វើផ្លូវរាបស្មើ យាងចេញទៅដោយសេនាមានអង្គ ៤ សំដៅទៅត្រង់កន្លែងដែលព្រះបច្ចេកពុទ្ធព្រះនាមសោណកៈគង់នៅ។ លុះព្រះរាជាទ្រង់យាងទៅដល់ទីឧទ្យានហើយ ទ្រង់ត្រាច់ទៅក្នុងព្រៃធំ បានទតឃើញព្រះសោណកបច្ចេកពុទ្ធ កាលដែលពួកសត្វលោកកំពុងត្រូវភ្លើងឆេះ លោកជាបុគ្គលរលត់ គង់នៅហើយ។

[៧០] (ព្រះរាជា...) ភិក្ខុត្រងោលដណ្ដប់សង្ឃាដិ មិនមានមាតានេះ កំព្រាណាស់តើ ស្ងួតស្ងប់ជិតគល់ឈើ។

[៧១] (អភិសម្ពុទ្ធគាថា) ព្រះសោណកបច្ចេកពុទ្ធ ស្ដាប់ព្រះបន្ទូលនេះហើយ បានថ្វាយព្រះពរយ៉ាងនេះថា បពិត្រព្រះរាជា បុគ្គលដែលពាល់ត្រូវនូវធម៌ដោយកាយ មិនមែនឈ្មោះថា កំព្រាទេ។ បុគ្គលណា ក្នុងលោកនេះ លះធម៌ចោលហើយ ប្រព្រឹត្តតាមអធម៌វិញ បពិត្រព្រះរាជា បុគ្គលនោះ ទើបឈ្មោះថា កំព្រា ជាបុគ្គលអាក្រក់ ជាទីសង្ឃឹមរបស់បុគ្គលអាក្រក់។

[៧២] (ព្រះរាជា...) ខ្ញុំឈ្មោះអរិន្ទមៈ អ្នកផងស្គាល់ខ្ញុំថាកាសិរាជ បពិត្រព្រះសោណកៈ លោកដ៏ចំរើនមកដល់ក្នុងទីនេះ សិងនៅជាសុខទេឬ។

[៧៣] (ព្រះបច្ចេកពុទ្ធ...) សេចក្ដីចំរើន (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ សព្វកាល គឺ (ទ្រព្យ និងធញ្ញជាតិទាំងឡាយ) របស់ភិក្ខុទាំងនោះ លែងចូលទៅក្នុងជង្រុក លែងចូលទៅក្នុងឆ្នាំង លែងចូលទៅក្នុងក្រឡប៉ីទៀតហើយ លោកមានវត្តល្អ មានការស្វែងរកសម្រេចហើយ រមែងញុំាងអត្តភាពឲ្យប្រព្រឹត្តទៅដោយបិណ្ឌបាតនោះ។ សេចក្ដីចំរើនទីពីរ (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺបរិភោគដុំបាយ ដែលមិនមានទោស កិលេសណាមួយបៀតបៀនមិនបានទេ។ សេចក្ដីចំរើនទីបី (តែងមាន)ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺឆាន់ដុំបាយដ៏ត្រជាក់ (មិនជាថេយ្យបរិភោគជាដើម) កិលេសណាមួយបៀតបៀនមិនបានទេ។ សេចក្ដីចំរើនទីបួន (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺសេចក្ដីជាប់ចំពាក់ មិនមានដល់ភិក្ខុដែលផុតស្រឡះ (ចាកត្រកូល) ត្រាច់ទៅក្នុងដែន។ សេចក្ដីចំរើនទីប្រាំ (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺកាលបើនគរកំពុងត្រូវភ្លើងឆេះ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ភ្លើងមិនឆេះទេ។ សេចក្ដីចំរើនទីប្រាំមួយ (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ កាលបើដែនកំពុងត្រូវចោរប្លន់ វត្ថុបន្តិចបន្តួចរបស់ភិក្ខុនោះ ចោរមិនលួចទេ។ សេចក្ដីចំរើនទីប្រាំពីរ (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុមានវត្តល្អ នាំយកបាត្រ និងចីវរដើរទៅកាន់ផ្លូវដែលពួកចោរ និងពួកគយដទៃរក្សាដោយស្រួល។ សេចក្ដីចំរើនទីប្រាំបី (តែងមាន) ដល់ភិក្ខុមិនមានទ្រព្យ មិនមានផ្ទះ គឺភិក្ខុនោះដើរទៅកាន់ទិសណាៗ ទៅបានដោយមិនមាននឹកនា។

[៧៤] (ព្រះរាជា...) បពិត្រភិក្ខុ លោកសរសើរនូវសេចក្ដីចំរើនរបស់ភិក្ខុទាំងនោះច្រើនមែន បពិត្រព្រះសោណកៈ តែខ្ញុំជក់ចិត្តក្នុងកាមទាំងឡាយ តើនឹងធ្វើយ៉ាងណា។ កាមទាំងឡាយជារបស់មនុស្ស ជាទីស្រឡាញ់របស់ខ្ញុំ មួយទៀត កាមជាទិព្វ ក៏ជាទីស្រឡាញ់របស់ខ្ញុំ បើដូច្នេះ តើយើងនឹងបាននូវកាមទាំងពីរក្នុងលោកដោយហេតុដូចម្ដេច។

[៧៥] (ព្រះបច្ចេកពុទ្ធ...) ពួកជនអ្នកជក់ចិត្តក្នុងកាម ត្រេកអរក្នុងកាម ងប់ក្នុងកាម រមែងធ្វើបាបទាំងឡាយ ហើយទៅកាន់ទុគ្គតិ។ ចំណែកពួកជនណា លះបង់កាម ហើយចេញទៅ មិនមានភ័យអំពីកិលេសណាមួយ បាននូវភាពជាបុគ្គលឯក ពួកជននោះ មិនទៅកាន់ទុគ្គតិ។ បពិត្រព្រះអរិន្ទមៈ អាត្មាភាពនឹងធ្វើសេចក្ដីឧបមាថ្វាយព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់សេចក្ដីឧបមានោះ ព្រោះពួកបណ្ឌិតខ្លះក្នុងលោកនេះ តែងយល់សេចក្ដីដោយសារឧបមា។ ក្អែកឥតប្រាជ្ញា ឥតសេចក្ដីគ្នេរគ្នាន់ ឃើញសាកសព (ដំរី) កំពុងអណ្ដែតតាមទន្លេគង្គាទៅក្នុងសមុទ្រ ហើយគិតថា អែយ៉ា! អញបានយាននេះហើយផង ដំរីនេះ នឹងបានជាចំណីអញយ៉ាងច្រើនផង ចិត្តរបស់ក្អែកនោះ ក៏ត្រេកអរក្នុងដំរីនោះទាំងថ្ងៃទាំងយប់។ ក្អែកចឹកស៊ីសាច់ដំរី ផឹកទឹកទន្លេគង្គា ឃើញព្រៃដែលគេសន្មតថា ចេតិយ ក៏មិនហើរទៅ។ ទន្លេគង្គាហូរទៅ បាននាំក្អែកនោះ ដែលប្រហែសធ្វេស ត្រេកអរក្នុងសាកសព ទៅកាន់សមុទ្រដែលមិនមែនជាទីទៅនៃបក្សី។ សត្វហើរនោះអស់ចំណីរលីងហើយ ក៏ហើរឡើងទៅទិសខាងលិចមិនរួច ទៅទិសខាងកើតមិនរួច ទៅទិសខាងជើងមិនរួច ទៅទិសខាងត្បូងមិនរួច។ ក្អែកនោះទៅកាន់សមុទ្រ ដែលមិនមែនជាទីទៅនៃពួកបក្សី ក៏មិនបាននូវទីពឹង ធ្លាក់ទៅក្នុងសមុទ្រនោះឯង ដូចជាបុគ្គលមានកំឡាំងថយ។ ពួកត្រី ក្រពើ មករ ឆ្លាម ដែលកើតក្នុងសមុទ្រ កំហែងខាំក្អែកនោះ ដែលមានស្លាបរបោចហើយ កំពុងបម្រះ (យ៉ាងណាមិញ)។ បពិត្រព្រះរាជា ព្រះអង្គ និងពួកជនដទៃអ្នកបរិភោគកាម ក៏យ៉ាងនោះដែរ បើពួកជនដែលជក់ចិត្តហើយមិនខ្ជាក់ (កាម) ចោលចេញទេ បណ្ឌិតទាំងឡាយ (ស្គាល់) ពួកជននោះ (ថាមានប្រាជ្ញាស្មើ) ដោយប្រាជ្ញារបស់ក្អែក។ បពិត្រព្រះរាជា ឧបមាជាគ្រឿងបំភ្លឺនូវសេចក្ដីនេះ អាត្មាភាពបានធ្វើថ្វាយព្រះអង្គហើយ បើព្រះអង្គធ្វើ ឬមិនធ្វើ ព្រះអង្គនឹងប្រាកដតាមហេតុនោះ។

[៧៦] បុគ្គលអ្នកឈឺឆ្អាល គប្បីនិយាយត្រឹមតែមួយម៉ាត់ ឬពីរម៉ាត់ មិនគប្បីនិយាយឲ្យលើសហួសពីនោះទៅ ដូចទាសៈនិយាយក្នុងសំណាក់នៃម្ចាស់។

[៧៧] (អភិសម្ពុទ្ធគាថា) លុះព្រះសោណកបច្ចេកពុទ្ធ មានប្រាជ្ញារាប់មិនបាន ពោលពាក្យនេះប្រៀនប្រដៅក្សត្រិយ៍ហើយ ទើបចៀសចេញទៅឰដ៏អាកាសវេហាស៍។

[៧៨] (ព្រះរាជា...) ពួកជនអ្នករៀបចំអភិសេកបុគ្គល ដែលគួរដល់រាជ្យ ជាអ្នកបង្កក់ប្រសិទ្ធនេះ ចាំស្ងាត់ នៅក្នុងទីណា អញនឹងប្រគល់រាជ្យឲ្យ អញមិនត្រូវការដោយរាជ្យទេ។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក អញលែងលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតហើយ។

[៧៩] (ពួកអាមាត្យ...) ព្រះរាជបុត្ររបស់ព្រះអង្គ ព្រះនាមទីឃាវុនៅក្មេង ជាអ្នកញ៉ាំងដែនឲ្យចំរើន សូមព្រះអង្គអភិសេកព្រះរាជបុត្រនោះក្នុងរាជ្យចុះ ព្រះរាជបុត្រនោះ នឹងបានជាព្រះរាជារបស់យើងខ្ញុំ។

[៨០] (ព្រះរាជា...) អ្នកទាំងឡាយ ចូរនាំយកកុមារឈ្មោះទីឃាវុ អ្នកញ៉ាំងដែនឲ្យចំរើនមកឲ្យឆាប់ អញនឹងអភិសេកកុមារនោះក្នុងរាជ្យ កុមារនោះ នឹងជាព្រះរាជារបស់អ្នកទាំងឡាយ។

[៨១] (អភិសម្ពុទ្ធគាថា) លំដាប់នោះ ពួកអាមាត្យក៏បាននាំកុមារឈ្មោះទីឃាវុ អ្នកញ៉ាំងដែនឲ្យចំរើនមកថ្វាយ ព្រះរាជាទតឃើញទីឃាវុកុមារនោះ ជាបុត្រតែមួយ ជាទីត្រេកអរ ពេញព្រះទ័យហើយ ទ្រង់ត្រាស់ថា នែបុត្រ ស្រុកទាំង ៦០,០០០ បរិបូណ៌ដោយវត្ថុទាំងពួង ចូរបាថែទាំស្រុកទាំងនោះចុះ អញនឹងប្រគល់រាជ្យដល់បា។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ។ ដំរី ៦០,០០០ ស្អិតស្អាងដោយ គ្រឿងប្រដាប់គ្រប់យ៉ាង មានខ្សែដង្កូនធ្វើអំពីមាស បិទបាំងដោយកម្រាលដែលធ្វើអំពីមាស ជាដំរីកើតក្នុងព្រៃមាតង្គៈ។ ដំរីណាដែលពួកហ្មដំរីមានដៃកាន់អាវុធ និងកង្វេរ ឡើងជិះ នែបុត្រ អ្នកចូរថែទាំពួកដំរីទាំងនោះចុះ អញប្រគល់រាជ្យដល់អ្នក។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ។ សេះ ៦០,០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង ជាសេះអាជានីយដោយកំណើត ជាសេះសិន្ធវៈ ជាពាហនៈយ៉ាងលឿន ដែលពួកសារថីកាន់សែ្វ និងធ្នូជិះ នែបុត្រ បាចូរថែទាំសេះទាំងនោះចុះ អញប្រគល់រាជ្យដល់បា។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ។ រថ ៦០,០០០ ដែលគេទឹមហើយ ដោតទង់ជ័យ ស្រោបដោយស្បែកខ្លាដំបង ស្រោបដោយស្បែកខ្លាធំ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង។ អ្នកបររថ មានដៃកាន់ធ្នូ សៀតខែល ហើយឡើងជិះ នែបុត្រ បាចូរថែទាំរថទាំងនោះចុះ អញប្រគល់រាជ្យដល់បា។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយ ដូចជាក្អែកឆោតឡើយ។ មេគោ ៦០,០០០ ជាមេគោក្រហម ប្រកបដោយគោខ្លាំង (គោបា) នែបុត្រ បាចូរថែទាំមេគោទាំងនោះចុះ អញប្រគល់រាជ្យដល់បា។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយដូចជាក្អែកឆោតឡើយ។ ស្ត្រី ១៦,០០០ ស្អិតស្អាងដោយគ្រឿងប្រដាប់គ្រប់យ៉ាង មានសំពត់ និងអាភរណៈដ៏វិចិត្រ ពាក់កុណ្ឌលកែវមណី នែបុត្រ បាចូរថែទាំស្ត្រីទាំងនោះចុះ អញប្រគល់រាជ្យដល់បា។ អញនឹងបួសក្នុងថ្ងៃនេះឯង អ្នកណាគប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក កុំឲ្យអញលុះក្នុងអំណាចនៃកាមទាំងឡាយដូចជាក្អែកឆោតឡើយ។

[៨២] (ព្រះរាជកុមារ...) បពិត្រព្រះវរបិតា កាលដែលទូលព្រះបង្គំជាខ្ញុំនៅក្មេងនៅឡើយ ទូលព្រះបង្គំជាខ្ញុំបានឮថា ព្រះវរមាតាទ្រង់សោយវិលាល័យទៅហើយ បពិត្រព្រះវរបិតា ទូលព្រះបង្គំជាខ្ញុំព្រាត់ប្រាសចាកព្រះអង្គហើយ មិនអាចនឹងរស់នៅបានទេ។ កូនដំរីរមែងទៅតាមក្រោយដំរីដែលនៅក្នុងព្រៃ ដើរទៅក្នុងជង្ហុកនៃភ្នំទាំងឡាយ ដែលរាបស្មើ និងមិនរាបស្មើ យ៉ាងណាមិញ។ ទូលព្រះបង្គំជាខ្ញុំនាំយកកូនទៅតាមព្រះអង្គ ក៏យ៉ាងនោះដែរ ទូលព្រះបង្គំជាខ្ញុំ ជាបុគ្គលព្រះអង្គចិញ្ចឹមងាយ ពុំមែនព្រះអង្គពិបាកចិញ្ចឹមឡើយ។

[៨៣] (ព្រះរាជា...) សត្រូវជាអ្នកបំផ្លាញ គប្បីចាប់សំពៅដែលដើរក្នុងសមុទ្ររបស់ពួកពាណិជដែលស្វែងរកទ្រព្យក្នុងសមុទ្រនោះ ពួកពាណិជត្រូវវិនាសយ៉ាងណាមិញ នែកូនលាមក ឯងនេះធ្វើសេចក្តីអន្តរាយដល់អញ ក៏យ៉ាងនោះដែរ។

[៨៤] អ្នកទាំងឡាយ ចូរញ៉ាំងកុមារនេះឲ្យដល់ប្រាសាទ ដែលញ៉ាំងតម្រេកឲ្យចំរើន ក្នុងប្រាសាទនោះ មានពួកស្ត្រីមានដៃស្អិតស្អាងដោយគ្រឿងអាភរណៈធ្វើអំពីមាស ស្ត្រីទាំងនោះនឹងត្រេកអរចំពោះកុមារនោះក្នុងប្រាសាទនោះ ដូចជាពួកស្ត្រីអប្សរត្រេកអរនឹងសក្កទេវរាជ កុមារនុ៎ះ នឹងត្រេកអរដោយស្ត្រីទាំងនោះ។

[៨៥] (អភិសម្ពុទ្ធគាថា) លំដាប់អំពីនោះមក ពួកអាមាត្យបានញ៉ាំងកុមារឲ្យដល់ប្រាសាទ ដែលញ៉ាំងតម្រេកឲ្យចំរើន ឯពួកនាងកញ្ញាឃើញទីឃាវុកុមារនោះ ជាអ្នកញ៉ាំងដែនឲ្យចំរើនហើយ ក៏បានពោលថា លោកជាទេវតា ឬជាគន្ធព្វ ឬក៏ជាព្រះឥន្ទ្រ ឈ្មោះបុរិន្ទទៈ លោកជាអ្វី ជាបុត្រនៃអ្នកណា ធ្វើដូចម្តេច យើងនឹងអាចស្គាល់លោកបាន។

[៨៦] (ព្រះរាជកុមារ...) យើងមិនមែនជាទេវតា មិនមែនជាគន្ធព្វ ទាំងមិនមែនជាព្រះឥន្ទ្រឈ្មោះបុរិន្ទទៈទេ យើងជាកូននៃព្រះរាជាក្នុងដែនកាសី ឈ្មោះទីឃាវុ ជាអ្នកញ៉ាំងដែនឲ្យចំរើន នាងទាំងឡាយ ចូរប្រាថ្នាយើងចុះ សេចក្តីចំរើននឹងមានដល់ពួកនាងទាំងឡាយ យើងជាភស្តារបស់ពួកនាង។

[៨៧] (អភិសម្ពុទ្ធគាថា) ពួកនាងកញ្ញា បានទូលសួរទីឃាវុកុមារនោះដែលញ៉ាំងដែនឲ្យចំរើន ក្នុងប្រាសាទនោះថា ព្រះរាជាស្តេចយាងទៅក្នុងទីណា ព្រះរាជាស្តេចចេញអំពីទីនេះ ទៅក្នុងទីណា។

[៨៨] (ព្រះរាជកុមារ...) ព្រះរាជាទ្រង់បានឈានកន្លងភក់ (រាគាទិក្កិលេស) ព្រះរាជា ទ្រង់បានឋិតនៅស៊ប់លើគោក (ផ្នួស) ទ្រង់យាងទៅកាន់ផ្លូវធំ (ជាទីទៅកាន់សួគ៌ និងព្រះនិព្វាន) ដែលមិនមានបន្លា មិនមានព្រៃញាតស្បាត (រាគៈ)។ ចំណែកយើងជាអ្នកដើរទៅកាន់ផ្លូវជាទីទៅកាន់ទុគ្គតិ ប្រកបដោយបន្លា ប្រកបដោយព្រៃញាតស្បាត សម្រាប់ទៅកាន់ទុគ្គតិរបស់ពួកសត្វ។

[៨៩] (ពួកនាងកញ្ញា...) បពិត្រព្រះរាជា ព្រះអង្គនោះយាងមកល្អហើយ ហាក់ដូចជាសីហៈដែលមកកាន់គិរិព្វជៈ (គុហាមាស) បពិត្រមហារាជ សូមព្រះអង្គគ្រប់គ្រងចុះ ព្រះអង្គជាម្ចាស់របស់ពួកខ្ញុំម្ចាស់ទាំងអស់គ្នា។

ចប់ សោណកជាតក ទី១។

## សង្កិច្ចជាតក ទី២

CS sut.kn.jat.530 | ភាគទី ៦១

### (៥៣០. សំកិច្ចជាតកំ (២ ))

[៩០] (អភិសម្ពុទ្ធគាថា) (ឧយ្យានបាលនោះ) ឃើញព្រះរាជាទ្រង់ព្រះនាមព្រហ្មទត្ត ប្រសើរក្នុងរថហើយ ក្រាបទូលព្រះរាជានោះក្នុងគ្រានោះថា ព្រះអង្គជាបុគ្គលឈឺឆ្អាលដល់ឥសីណា។ ឥសីឈ្មោះសង្កិច្ចនេះ ដែលគេសន្មតថាជាសប្បុរសរបស់ពួកឥសី មកដល់ហើយ សូមព្រះអង្គប្រញាប់ប្រញាល់ យាងចេញទៅជួបនឹងមហាឥសីឲ្យឆាប់។ លំដាប់នោះ ព្រះរាជាប្រសើរក្នុងរថ មានមិត្រ និងអាមាត្យហែហម

ទ្រង់ប្រញាប់ឡើងកាន់រថ ដែលគេទឹមហើយ ទ្រង់យាងទៅ។ ព្រះរាជាញ៉ាំងដែននៃពួកកាសីឲ្យចំរើនទ្រង់ដាក់គ្រឿងកកុធៈ ៥ យ៉ាង គឺ
ផ្លិតរោមសត្វ ១ មកុដ ១ ព្រះខាន់ ១ ឆ័ត្រ ១ សុពណ៌បាទុកា ១។ លុះព្រះរាជាទ្រង់យាងចុះអំពីយាន ទុកគ្រឿងកកុធៈហើយ ទើបយាង
ចូលទៅរកសង្កិច្ចឥសី ដែលអង្គុយក្នុងឧទ្យានឈ្មោះទាយបស្សៈ។ ព្រះរាជានោះ ចូលទៅសំណេះសំណាលជាមួយនឹងឥសី លុះបញ្ចប់
ពាក្យនោះហើយ ក៏គង់ក្នុងទីដ៏សមគួរ។ ព្រះរាជាគង់ស៊ប់ក្នុងទីសមគួរហើយ ទើបទ្រង់ជ្រាបនូវកាលគួរប្រតិបត្តិ ដើម្បីសួរនូវបាបកម្ម
ទាំងឡាយក្នុងពេលនោះ។ យើងសូមសួរសង្កិច្ចឥសី ដែលគេសន្មតថាជាសប្បុរសរបស់ពួកឥសី ដែលពួកឥសីចោមរោមហើយ គង់ក្នុង
ទាយបស្សឧទ្យាន។ ពួកជនអ្នកប្រព្រឹត្តរំលងធម៌ លុះស្លាប់ទៅវិញ ទៅកាន់គតិណា ធម៌ គឺបិតុឃាតកម្ម ខ្ញុំបានប្រព្រឹត្តកន្លងហើយ ខ្ញុំសួរ
ហើយ សូមលោកប្រាប់សេចក្តីនោះដល់ខ្ញុំ។

[៩១] សង្កិច្ចឥសី បានពោលនឹងព្រះរាជាអ្នកញ៉ាំងដែនកាសីឲ្យចំរើន គង់ក្នុងទាយបស្សឧទ្យានថា បពិត្រមហារាជ សូមព្រះអង្គ
ទ្រង់ព្រះសណ្តាប់ពាក្យរបស់អាត្មាភាព។ អ្នកណាប្រាប់ផ្លូវដល់បុគ្គលអ្នកដើរផ្លូវខុស បើបុគ្គលនោះ ធ្វើតាមពាក្យរបស់អ្នកប្រាប់នោះ បន្លា
(ចោរ) មិនគប្បីជួបនឹងបុគ្គលអ្នកធ្វើតាមនោះទេ។ អ្នកណាប្រៀនប្រដៅធម៌ដល់បុគ្គលប្រតិបត្តិអធម៌ បើបុគ្គលនោះធ្វើតាមពាក្យរបស់
អ្នកប្រដៅនោះ បុគ្គលនោះមិនគប្បីទៅកាន់ទុគ្គតិទេ។

[៩២] បពិត្រមហារាជ ធម៌ជាផ្លូវត្រូវ ឯអធម៌ជាផ្លូវខុស អធម៌នាំសត្វទៅកាន់នរក ធម៌ញ៉ាំងសត្វឲ្យដល់សុគតិ។ បពិត្រព្រះរាជា ពួកជន
អ្នកមិនប្រព្រឹត្តធម៌ ចិញ្ចឹមជីវិតខុសគន្លងធម៌ លុះស្លាប់ទៅវិញហើយ រមែងទៅកាន់គតិ (នរក) ណា សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យ
អាត្មាភាព (ដែលសំដែងអំពីនរក) ទាំងនោះ។ សញ្ជីវនរក ១ កាឡសុត្តៈ ១ សង្ឃាដៈ ១ រោរុវៈ ២ នរកដទៃទៀត គឺមហាអវិចិ ១ តាបនៈ ១
បតាបនៈ ១។ នរកទាំង ៨ នុ៎ះ ដែលអ្នកប្រាជ្ញទាំងឡាយបានសំដែងហើយដោយប្រការដូច្នេះ កម្រមានបុគ្គលណាកន្លងរំលងបាន
តាន់តាប់ដោយពួកសត្វដែលមានកម្មអាក្រក់ ចំពោះមហានរកមួយៗ មានឧស្សទនរក ១៦។ (នរកទាំងនោះ) ជាទីកំដៅអ្នកកំណាញ់ស្វិត
ស្វាញ ជានរកដ៏ពន្លឹក មានអណ្តាតភ្លើង មានភ័យធំ មានសភាពជាទីព្រឺរោម គួរឲ្យស្បើម បណ្តាលឲ្យខ្លបខ្លាច ជាទុក្ខ។ (នរកទាំងនោះ)
មានមុំ ៤ មានទ្វារ ៤ ដែលបាបកម្មចែកវាស់ដោយចំណែក មានកំពែងដែកព័ទ្ធជុំវិញ ប្រក់ដោយក្បឿងដែក។ ភូមិរបស់នរកទាំងនោះ
ជាវិការៈនៃដែកឆេះឡើង ប្រកបដោយកំដៅ (នរកទាំងអស់នោះ) ផ្សាយទៅអស់ទី ១០០ យោជន៍ជុំវិញ ឋិតនៅសព្វៗ កាល។ ពួកជន
អ្នកតិះដៀលពួកឥសី ជាអ្នកសង្រួម មានតបៈនុ៎ះ រមែងធ្លាក់ទៅក្នុងនរក មានជើងឡើងលើ មានក្បាលចុះក្រោម។ ពួកជនអ្នកធ្វើអំពើ
អាក្រក់ ជាអ្នកបំផ្លិចបំផ្លាញសេចក្តីចំរើននោះ ត្រូវពួកនិរយបាលដុត ដូចជាពួកត្រីដែលគេធ្វើឲ្យជាចំណែក (ដោតអាំង) អស់ឆ្នាំរាប់មិន
អស់។ ពួកសត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ ទាំងខាងក្នុងខាងក្រៅជានិច្ច ស្វែងរកនូវទីចេញអំពីនរក តែមិនបាននូវទ្វារ។ ពួកសត្វនរក
នោះស្ទុះទៅទិសខាងកើត ស្ទុះអំពីទិសខាងកើតនោះ ទៅទិសខាងលិច ស្ទុះទៅទិសខាងជើង ស្ទុះអំពីទិសខាងជើង ទៅទិសខាងត្បូង
សត្វនរកទាំងនោះទៅដល់ទ្វារណាៗ ទ្វារនោះៗ ឯង ក៏បិទជិត។ ពួកជនដែលទៅកាន់នរក រងទុក្ខច្រើន ផ្គងដើមដៃកន្ទក់កន្ទេញអស់សែន
នៃឆ្នាំជាច្រើន។ បុគ្គលមិនគប្បីចូលទៅបៀតបៀននូវពួកឥសី ដែលមានសភាពជាសប្បុរស ដូចជាបុគ្គលមិនគួរចូលទៅជិតអាសីរពិស
ដែលខឹង មានតេជៈគេកន្លងរំលងបានដោយក្រ (ជនទាំងនោះ រមែងធ្លាក់ទៅក្នុងនរក ព្រោះតែបៀតបៀន) នូវពួកឥសីអ្នកសង្រួម
មានតបៈ។ ព្រះរាជាព្រះនាមអជ្ជុនៈ មានខ្នាន់ធ្នូដ៏ប្រសើរ មានពួកពលដ៏ច្រើន ជាអធិបតីក្នុងដែនឈ្មោះកេតកៈ អាចលើកធ្នូដែលពួកខ្នាន់ធ្នូ
៥០០ លើកឡើងបានដោយដើមដៃ ១,០០០ បៀតបៀនឥសីឈ្មោះគោតមៈ ហើយវិនាស។ ព្រះរាជាទណ្ឌកី បានបាចរោយធូលី (ស្តោះ)
លើតាបសឈ្មោះកីសវច្ឆៈ មិនមានធូលី (កិលេស) ព្រះរាជានោះ ក៏ដល់នូវសេចក្តីវិនាស ដូចជាដើមត្នោត ដែលគេកាត់ត្រង់គល់។
ព្រះរាជាព្រះនាមមេជ្ឈៈ ព្រមទាំងបរិស័ទ ញ៉ាំងចិត្តឲ្យប្រទូស្តក្នុងតាបសឈ្មោះមាតង្គបណ្ឌិត មានយស ហើយក៏ដល់នូវសេចក្តីវិនាស
ក្នុងកាលនោះ ដែនឈ្មោះមេជ្ឈៈក៏ទៅជាព្រៃ។ ពួកព្រះរាជា ជាវង្សអន្ធកវេន្ហុ បៀតបៀននូវឥសីឈ្មោះកណ្ហទីបាយនៈ កាន់យកអង្រែ
សំឡាប់គ្នានឹងគ្នា ហើយក៏ធ្លាក់ទៅក្នុងនរក។ ព្រះរាជាព្រះនាមចេតិយៈនេះ កាលពីដើម ហោះលើអាកាសបាន ដល់មកខាងក្រោយ ត្រូវ
កបិលឥសីផ្តាសាហើយ មានអត្តភាពសាបសូន្យ ចូលទៅកាន់ផែនដី ដល់នូវសេចក្តីស្លាប់ ព្រោះហេតុនោះ បានជាពួកបណ្ឌិតមិនសរសើរ
អគតិ ៤ មានឆន្ទាគតិជាដើមឡើយ បុគ្គលមានចិត្តមិនប្រទូស្ត គប្បីពោលពាក្យប្រកបដោយសច្ចៈ បើនរណាមានចិត្តប្រទូស្តហើយ សំឡក់
ទៅរកអ្នកប្រាជ្ញ ដែលបរិបូណ៌ដោយវិជ្ជា និងចរណៈ នរៈនោះ នឹងធ្លាក់ទៅក្នុងនរកខាងក្រោម។ ពួកជនណា មានសេចក្តីព្យាយាមអាក្រក់
ជេរប្រទេចពួកចាស់ព្រឹទ្ធាចារ្យ ពួកជននោះ (លុះទៅកើតក្នុងភពខាងមុខ) រកកូនគ្មាន រកញាតិគ្មាន ដូចត្នោតកំបុតគល់។ ជនណា សម្លាប់
បព្វជិតដែលមានកិច្ចធ្វើហើយ អ្នកស្វែងរកនូវគុណដ៏ធំ ជននោះ រមែងឆេះនៅក្នុងកាឡសុត្តនរកអស់កាលជាយូរអង្វែង។ ព្រះរាជាណា
មិនតាំងនៅក្នុងធម៌ កំចាត់កំចាយអ្នកដែន ដុតកំដៅអ្នកជនបទ ព្រះរាជានោះ លុះទ្រង់ទីវង្គតទៅ រមែងឆេះនៅក្នុងតាបននរក។ ព្រះរាជា
នោះ ក៏ឆេះអស់សែននៃឆ្នាំទិព្វ ព្រះរាជានោះត្រូវគំនរអណ្តាតភ្លើងហ៊ុំជុំវិញហើយ ក៏រងទុក្ខវេទនាខ្លាំង។ អណ្តាតភ្លើងទាំងឡាយដ៏រន្ទាល
ច្រាលឆ្អៅ ផ្សាយចេញអំពីកាយរបស់សត្វនរកនោះ ខ្លួនរបស់សត្វនរកដែលមានភ្លើងជាអាហារ (មានអណ្តាតភ្លើងតែមួយជាមួយគ្នា)
នឹងចុងរោមទាំងឡាយផង នឹងក្រចកទាំងឡាយផង។ សត្វនរកមានខ្លួនត្រូវភ្លើងឆេះហើយ ទាំងខាងក្នុង ខាងក្រៅជានិច្ច ត្រូវសេចក្តី
ទុក្ខចាក់ដោតហើយ ក៏ពោទ៍ដូចជាដំរី ដែលគេចាក់ដោយងៀងកង្វេរ។ បុរសលាមកណា សម្លាប់បិតា ព្រោះតែលោភៈ ឬព្រោះទោសៈ បុរស
លាមកនោះ រមែងឆេះនៅក្នុងកាឡសុត្តនរក អស់កាលជាយូរអង្វែង។ បុរសបែបនោះ រមែងឆេះនៅក្នុងលោហកុម្ភីនរក ពួកនិរយបាល (នាំ
ចេញ) នូវសាច់ដ៏ឆ្អិន ធ្វើមិនឲ្យមានស្បែក ហើយចាក់ដោយលំពែងទាំងឡាយ ធ្វើឲ្យខ្វាក់ ឲ្យស៊ីនូវមូត្រ និងលាមក ហើយជ្រមុជជនបែប
នោះទៅក្នុងទឹកខារ (ទឹកទង់ដែង)។ ពួកនិរយបាល (ញ៉ាំងសត្វនរកឲ្យស៊ីនូវលាមក) ក៏ពុងពុះ នឹងដុំដែកដ៏ក្តៅ ហើយយកបណ្តាញដ៏វែង
ដែលកំដៅអស់កាលយូរ មកបើកមាត់ (ហើយបោះសន្ទូចដែក) ដែលចងដោយខ្សែ (ទាញអណ្តាតចេញ ហើយបោះដុំដែក) ទៅក្នុងមាត់
ដែលច្រហានោះ។ ពួកឆ្កែក្រហម ឆ្កែពពាល ពួកត្មាត ពួកក្អែក និងពួកសត្វស្លាប (ឯទៀតច្រើនពួក) មានចំពុះដែក នាំគ្នាមកចោមរោមចឹក
ជញ្ជែងស៊ីនូវអណ្តាត (នៃពួកសត្វនរក) ដែលញាប់ញ័រ (ដូចជាស៊ី) នូវរំពា ព្រមទាំងឈាម មានឈាមកំពុងហូរចេញ។ ពួកនិរយបាល
វាយសំពងសត្វនរកនោះ ដែលភ្លើងកំពុងឆេះ មានខ្លួនរយះរយាយ ដោយតម្រេករបស់ពួកនិរយបាលនោះ ចំណែកខាងសត្វនរក
ទាំងឡាយក្រៅនេះ ក៏ដល់នូវសេចក្តីទុក្ខវេទនា ពួកជនណានីមួយក្នុងលោកនេះ ជាអ្នកសម្លាប់បិតា ពួកជននោះ តែងទៅនៅក្នុងនរក
បែបនុ៎ះ។ កូនសម្លាប់មាតា លុះទៅអំពីលោកនេះ ទៅកាន់លំនៅរបស់យមរាជ កាន់យកនូវផលនៃកម្មរបស់ខ្លួន ក៏ដល់នូវសេចក្តីទុក្ខ
យ៉ាងខ្លាំង។ ពួកអមនុស្ស (និរយបាល) ព្រហើនក្រៃលែង យកសរសៃដែក (មករុំ) នូវបុគ្គលអ្នកសម្លាប់មាតា ហើយគាប (ដោយឃ្នាបដែក)
រឿយៗ។ ពួកនិរយបាល ញ៉ាំងបុគ្គលអ្នកសម្លាប់មាតានោះ ឲ្យផឹកនូវឈាមដ៏ក្តៅ ដែលហូរចេញអំពីកាយរបស់ខ្លួន ដូចជាទឹកទង់ដែង
រលាយ។ បុគ្គលអ្នកសម្លាប់មាតានោះ ចុះទៅឋិតនៅក្នុងរណ្តៅគូរខ្ទើម ដូចជាអសុភមានក្លិនស្អុយ មានលាមក ជាភក់ មានក្លិនអាក្រក់
ប្រហែលគ្នាដោយខ្ទុះ នឹងឈាម។ ក្នុងនរកនោះ មានពួកដង្កូវមានខ្លួនធំ មានមាត់ដូចម្ជុលដែក ទុកត្បូលចូលទៅក្នុងសាច់ និងឈាម
ទំលាយស្បែកសម្បុរថ្ងៃ ហើយស៊ីសត្វនរកនោះ (ទាំងខួរក្នុងឆ្អឹង)។ បុគ្គលអ្នកសម្លាប់មាតានោះ ធ្លាក់ទៅក្នុងនរកនោះ ជ្រមុជ (ក្បាល)
ចុះទៅ ចំនួនមួយរយជួរបុរស សាកសពដ៏ស្អុយ ក៏ផ្សាយទៅកាន់ទីចម្ងាយមួយរយយោជន៍ជុំវិញ។ ព្រោះថា សូម្បីជនមានចក្ខុ ធុញទ្រាន់
ដោយក្លិននោះ ព្រោះអាស្រ័យចក្ខុ បពិត្រព្រះបាទព្រហ្មទត្ត បុគ្គលអ្នកសម្លាប់មាតា តែងបានសេចក្តីទុក្ខបែបនេះ។ ពួកស្ត្រីរំលូតគភ៌
កន្លងនូវខុរធារនរកដ៏មុត ដែលគេគ្របសង្កត់បានដោយក្រ ធ្លាក់ទៅក្នុងស្ទឹងឈ្មោះវេត្តរណី ដែលមិនរាបស្មើ។ ដើមរកាទាំងឡាយ
ជាវិការៈនៃដែក មានបន្លាប្រវែង ១៦ ធ្នាប់ សំយុងចុះមកត្រង់ត្រើយទាំងពីរខាងនៃស្ទឹងឈ្មោះវេត្តរណី ដែលមិនរាបស្មើ។ ដើមរកា
ទាំងនោះ ត្រូវភ្លើងឆេះ មានអណ្តាតខ្ពស់ឡើងទៅលើ ១ យោជន៍ ដូចជាគំនរភ្លើងអំពីឆ្ងាយ។ ពួកស្រីប្រព្រឹត្តក្បត់ចិត្តប្តី និងពួកប្រុស
ដែលគប់រកប្រពន្ធគេ ជនទាំងនុ៎ះ រមែងធ្លាក់ទៅក្នុងសិម្ពលីនរកដែលក្តៅ មានបន្លាស្រួច។ ពួកសត្វនរកទាំងនោះ មានក្បាលចុះក្រោម
ត្រូវពួកនិរយបាលចាក់ (ដោយអាវុធ) ច្រើនដង ក៏វិលធ្លាក់មកវិញ មានខ្លួនធ្លុះធ្លាយ រមែងដេក រមែងភ្ញាក់ អស់កាលជាយូរអង្វែងសព្វៗ
កាល។ (ពួកសត្វនរក ត្រូវពួកនិរយបាលចាប់បោះទៅ) ក្នុងនរកឈ្មោះលោហកុម្ភី មានឧបមាដោយភ្នំដ៏ធំ មានទឹកស្មើនឹងភ្លើងដ៏ក្តៅ រមែង

ឆេះអស់កាលកន្លលទៅនៃរាត្រីជាយូរអង្វែង។ ពួកមនុស្សទ្រុស្តសីល (គប់រកប្រពន្ធគេ) ដែលមោហៈគ្របសង្កត់ហើយ រមែងរងកម្មរបស់ខ្លួន ដែលខ្លួនធ្វើអាក្រក់ក្នុងកាលមុន ទាំងថ្ងៃទាំងយប់យ៉ាងនេះ។ ប្រពន្ធណា ដែលគេទិញមកដោយទ្រព្យ មើលងាយប្តី ម្តាយក្មេក ឪពុកក្មេក បងថ្លៃប្រុស បងថ្លៃស្រី ពួកនិរយបាល តែងទាញដកអណ្តាតព្រមទាំងគល់ របស់នាងនោះ ព្រមទាំងចំណងដោយសន្ទូច។ សត្វនរកនោះ ឃើញអណ្តាតរបស់ខ្លួនប្រមាណមួយព្យាម ពេញដោយដង្កូវ មិនអាចអង្វរ (ពួកនិរយបាល) បាន លុះស្លាប់ទៅ រមែងឆេះនៅក្នុងតាបននរកទៀត។ ពួកអ្នកសម្លាប់ចៀម សម្លាប់ជ្រូក សម្លាប់ត្រី ទាក់ម្រឹគ ពួកចោរ ពួកអ្នកសម្លាប់គោ ពួកព្រាន ពួកអ្នកធ្វើគុណក្នុងទោស (អ្នកញុះញង់)។ ពួកសត្វនរកនោះ ត្រូវពួកនិរយបាលបៀតបៀនដោយលំពែង ដោយញញួរលោហៈ ដោយសំសែ ដោយព្រួញទាំងឡាយ មានក្បាលសំយុងចុះ ធ្លាក់ទៅក្នុងស្ទឹងខារ។ អ្នកធ្វើអំពើវៀច ត្រូវពួកនិរយបាលដំដោយញញួរដែកទាំងឡាយទាំងល្ងាចទាំងព្រឹក ហើយស៊ីនូវកំអួតរបស់ពួកសត្វនរកដទៃ ដែលមានអត្តភាពអាក្រក់នោះសព្វៗ កាល។ ពួកក្អែក ចចក ត្មាត ក្អែកព្រៃមានចំពុះដែក នាំគ្នាចឹកប្រជែងនូវជនអ្នកធ្វើអំពើអាក្រក់កំពុងញាប់ញ័រ។ ពួកជនណាសម្លាប់ម្រឹគ[39] ដោយម្រឹគ សម្លាប់បក្សី[40] ដោយបក្សី ពួកជននោះជាអសប្បុរស បិទបាំងដោយធូលី គឺរាគាទិក្កិលេស រមែងទៅកាន់ឧស្សទនរក។

[៩៣] ពួកសប្បុរសក្នុងលោកនេះ មានកម្មសន្សំល្អហើយ តែងទៅកាន់លោកខាងលើ សូមព្រះអង្គទតមើលផលនៃអំពើដែលគេបានសន្សំល្អ ដូចពួកទេវតា ព្រមទាំងព្រះឥន្ទ្រ ព្រមទាំងព្រះព្រហ្ម បពិត្រមហារាជ អាត្មាភាពពោលហេតុនោះនឹងព្រះអង្គ បពិត្រព្រះអង្គជាម្ចាស់នៃដែន សូមព្រះអង្គប្រព្រឹត្តធម៌ បពិត្រព្រះរាជា អំពើដែលព្រះអង្គប្រព្រឹត្តល្អនោះ មិនគប្បីដុតកំដៅរឿយៗ ក្នុងកាលជាខាងក្រោយយ៉ាងណាៗ សូមព្រះអង្គប្រព្រឹត្តធម៌យ៉ាងនោះៗ ចុះ។

ចប់ សង្កិច្ចជាតក ទី២។

ឧទ្ទាននៃសដ្ឋិនិបាត

អ្នកទាំងឡាយ ចូរស្តាប់ភាសិតរបស់ខ្ញុំ ក្នុងសដ្ឋិនិបាត បន្ទាប់អំពីបញ្ញាសនិបាតនោះគឺ និយាយអំពីឈ្មោះជាតកដ៏ប្រសើរ ដែលហៅថា សោណកតាបស និងព្រះរាជាទ្រង់ព្រះនាមអរិន្ទមៈ ១ ព្រះរាជាដ៏ប្រសើរ ក្នុងរថដែលយើងពោលហើយដូច្នោះ និងសង្កិច្ចឥសី ១។

ចប់ សដ្ឋិនិបាត។

# សត្តតិនិបាតជាតក

CS sut.kn.jat.v20 | ភាគទី ៦១

(២០. សត្តតិនិបាតោ)

## កុសជាតក ទី១

CS sut.kn.jat.531 | ភាគទី ៦១

(៥៣១. កុសជាតកំ (១))

[៩៤] (ព្រះបាទកុសរាជពោធិសត្វ ត្រាស់ថា) បពិត្រព្រះមាតា ដែនរបស់ព្រះមាតានេះ ប្រកបដោយទ្រព្យ ប្រកបដោយយាន ប្រកបដោយគ្រឿងសំរាប់រាជ្យ បរិបូណ៌ដោយកាមគ្រប់យ៉ាង សូមព្រះមាតាត្រួតត្រាដែនរបស់ព្រះមាតានេះចុះ ខ្ញុំនឹងទៅកាន់នគរ ជាទីនៅរបស់នាងបភាវតីជាទីស្រឡាញ់។

[៩៥] (នាងបភាវតី ពោលថា) ព្រះអង្គមានព្រះទ័យមិនត្រង់ នាំយកអម្រែកធំ (រងទុក្ខ) ទាំងថ្ងៃទាំងយប់ ទាំងពេលអធ្រាត្រ សូមព្រះអង្គត្រឡប់ទៅក្រុងកុសាវតីវិញឲ្យឆាប់ ខ្ញុំម្ចាស់មិនចង់បានព្រះអង្គ ដែលមានរាងរៅអាក្រក់ មកនៅ (ក្នុងទីនេះ) ទេ។

[៩៦] (ព្រះពោធិសត្វ ...) ហៃនាងបភាវតី អញនឹងមិនទៅអំពីទីនេះ កាន់ក្រុងកុសាវតីទេ ព្រោះអញជាប់ចិត្តនឹងវណ្ណៈរបស់នាង ទើបត្រេកអរក្នុងដំណាក់ជាទីត្រេកអររបស់ព្រះបាទមទ្ទៈ ស៊ូលះបង់ដែន មកត្រេកអរក្នុងការឃើញនាង។ ហៃនាងបភាវតី អញជាប់ចិត្តនឹងវណ្ណៈរបស់នាង មានសភាពវង្វេង ត្រាច់រង្គាត់ទៅកាន់ផែនដី មិនស្គាល់ទិសថា អញមកអំពីទីណា ហៃនាងមានភ្នែកថ្លាដូចភ្នែកម្រឹគ អញជាមនុស្សរក់ចិត្តក្នុងនាង។ ហៃនាងមានគ្រឿងសម្លៀករំលេចដោយមាស មានខ្សែក្រវាត់ល្អជាវិការៈនៃមាស មានចង្កេះល្អ អញមិនត្រូវការដោយរាជសម្បត្តិ ព្រោះតែសេចក្តីប្រាថ្នាចំពោះនូវនាង។

[៩៧] (នាងបភាវតី...) បពិត្រព្រះអង្គដ៏ចំរើន សេចក្តីមិនចំរើនតែងមានដល់បុគ្គលដែលប្រាថ្នា បុគ្គលកាលមិនប្រាថ្នា (ខ្លួន) បពិត្រព្រះរាជា ព្រះអង្គមិនជាទីស្រឡាញ់ ចង់បានស្ត្រីជាទីស្រឡាញ់ ដែលមិនមានសេចក្តីប្រាថ្នាដោយកាមទាំងឡាយ។

[៩៨] (ព្រះពោធិសត្វ...) ជនណាបាននាងជាទីស្រឡាញ់ ទោះមិនមានសេចក្តីប្រាថ្នាក្តី មានសេចក្តីប្រាថ្នាក្តី យើងសរសើរនូវការបានរបស់ជននុ៎ះ បណ្តាការបាន និងមិនបាននោះ ឯការមិនបាន ចាត់ថាជារបស់លាមក។

[៩៩] (នាងបភាវតី...) ព្រះអង្គចង់បានស្ត្រីដែលគេមិនចង់បាន ព្រះអង្គដូចជាគេជីកខ្លឹមថ្មដោយដើមកណិការ ឬដូចជាគេទាក់ខ្យល់ដោយសំណាញ់។

[១០០] (ព្រះពោធិសត្វ...) ហៃនាងមានលក្ខណៈទន់ភ្លន់ អញមកអំពីជនបទខាងក្រៅ មិនបានសេចក្តីស្រួល (ក្នុងសំណាក់) របស់នាង ឈ្មោះថា នាងយកថ្មសង្កត់លើហ្ឫទ័យ (នៃអញ) ដោយពិត។ ព្រះរាជបុត្រីធ្វើមុខក្រញូវ ហើយសំឡឹងមើលម៉ែកអញ ក្នុងវេលាណា អញក៏នៅជានាយពិសេសក្នុងវាំងរបស់ព្រះបាទមទ្ទៈក្នុងវេលានោះ។ ព្រះរាជបុត្រី ញញឹមញញែម ក្រឡេកមើលអញក្នុងវេលាណា អញមិននៅជានាយពិសេស ក្នុងវេលានោះទេ អញនឹងជាព្រះបាទកុសៈក្នុងវេលានោះវិញ។

[១០១] (នាងបភាវតី...) ប្រសិនបើពាក្យរបស់ហោរពិតមែន ព្រះអង្គមិនត្រូវបានជាភស្តារបស់ខ្ញុំម្ចាស់ទេ ស៊ូឲ្យគេកាត់ (ខ្ញុំម្ចាស់) ជាប្រាំពីរកំណាត់ចុះ។

[១០២] (ព្រះពោធិសត្វ...) ប្រសិនបើពាក្យរបស់ហោរដទៃ ឬរបស់អញពិតមែន ភស្តារបស់នាងក្រៅអំពីព្រះបាទកុសៈ ដែលមាន

ព្រះសូរស័ព្ទស្មើនឹងសំឡេងសីហៈ ក៏មិនមានទេ។

[១០៣] នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីក្រឡេកមើលអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អោរដល់នាង។ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីហៅរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ ក ជាវិការៈនៃមាសឆ្អោរដល់នាង។ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីញញឹមញញែមរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អោរដល់នាង។ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីសើចក្អាកក្អាយរកអញ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អោរដល់នាង។ នែនាងគម បើនាងបភាវតីមានភ្លៅដូចជាប្រមោយដំរី គប្បីមកប៉ះពាល់អញដោយដៃទាំងឡាយ លុះអញទៅដល់ក្រុងកុសាវតី នឹងឲ្យគេធ្វើគ្រឿងប្រដាប់សម្រាប់ពាក់ក ជាវិការៈនៃមាសឆ្អោរដល់នាង។

[១០៤] (ស្ត្រីគម...) ព្រះរាជបុត្រីនេះ មិនបាននូវសេចក្តីស្រួលចិត្តទៅរកព្រះបាទកុសៈ ជាបុរសនាយពិសេសអ្នកស៊ីឈ្នួលមិនត្រូវការដោយថ្លៃឈ្នួលទេ។

[១០៥] (នាងបភាវតី...) ស្ត្រីគមនេះ មិនហ៊ានកាត់អណ្តាតដោយកាំបិតដ៏មុតដោយពិត តែហ៊ាននិយាយពាក្យជាទុព្ភាសិតយ៉ាងនេះ។

[១០៦] (ស្ត្រីគម...) បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ (និងទំហំរបស់ខ្លួននាង) ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានយសធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ (ចំពោះព្រះបាទកុសៈនោះ) ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានទ្រព្យច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានកម្លាំងច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានដែនធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) ជាព្រះរាជាធំ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងស្មើនឹងសំឡេងនៃសីហៈ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងដ៏ពីរោះ ហើយធ្វើនូវសេចក្តីស្រឡាញចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងមូល ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងល្អ ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសំឡេងដ៏ផ្អែមល្ហែម ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) មានសិល្បៈច្រើន ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) ជាក្សត្រិយ៍ (សុទ្ធ) ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។ បពិត្រព្រះនាងបភាវតី ព្រះនាងកុំប្រៀបផ្ទឹមនូវព្រះបាទកុសៈនោះ ដោយរូប ដោយកំពស់ឡើយ បពិត្រព្រះនាងស្រស់ប៉ប្រែ ព្រះនាងសូមធ្វើទុក (ក្នុងហឫទ័យថា ព្រះបាទកុសៈនោះ) ជាព្រះរាជាមាននាមស្មើនឹងស្បូវភ្លាំង (ដែលព្រះឥន្ទ្រប្រទាន) ហើយធ្វើនូវសេចក្តីស្រឡាញ់ចុះ។

[១០៧] (អាមាត្យទាំងឡាយ...) ព្រះរាជាដ៏ប្រសើរទាំងអស់នុ៎ះ ជាព្រះរាជាគឃ្លើន មកហើយ ប្រដាប់ដោយគ្រឿងក្រោះ (សូមព្រះអង្គផ្ញើព្រះរាជសារទៅថា) អ្នកទាំងឡាយ ចូរនាំព្រះនាងបភាវតីនុ៎ះមក (បញ្ជូនទៅថ្វាយព្រះរាជាទាំងនោះ) កុំឲ្យទំលាយកំពែងមុនទាន់។

[១០៨] (ព្រះរាជា...) អញនឹងធ្វើនាងបភាវតីនុ៎ះ ឲ្យជា ៧ កំណាត់ ហើយឲ្យដល់ពួកក្សត្រិយ៍ដែលមកក្នុងទីនេះដើម្បីសម្លាប់អញ។

[១០៩] (អភិសម្ពុទ្ធគាថា) ព្រះរាជបុត្រីមានសម្បុរលឿង ទ្រង់ព្រះពស្ត្រ ជាវិការៈនៃសូត្រ (រំលេចដោយមាស) ដែលពួកទាសីហែហមមាននេត្រាដ៏ពេញដោយព្រះអស្សុជល បានក្រោក (ចាកអាសនៈ)។

[១១០] (នាងបភាវតី...) បពិត្រព្រះមាតា មុខ (របស់ខ្ញុំ) នោះ ធ្លាប់លាបស្រឡាបគ្រឿងលំអិត ឆ្លុះកញ្ចក់មានក្របជាវិការៈនៃភ្លុក ជាមុខល្អ មានភ្នែកល្អ រលីងរាបធេង ត្រូវពួកក្សត្រិយ៍លះចោលហើយ នឹងតាំងនៅក្នុងព្រៃ។ ពួកត្មាតនឹងលើកជើងទាំងឡាយ កកាយនូវសក់ទាំងនោះរបស់ខ្ញុំ ជាសក់ខ្មៅមានចុងង ទន់ លាបដោយខ្លឹមចន្ទន៍ ឲ្យច្របូកច្របល់ ក្នុងកណ្តាលព្រៃស្មសាន ក្អែកចឹកដៃរបស់ខ្ញុំនោះ ដែលមានក្រចកក្រហម មានរោមល្អ ទន់ លាបដោយខ្លឹមចន្ទន៍ ដាច់ខ្ចាត់ខ្ចាយ ដែលពួកក្សត្រិយ៍ចោលក្នុងព្រៃ ហើយហើរទៅតាមប្រាថ្នា។ ចចក (ឃើញស្តនរបស់ខ្ញុំ) នោះ ស្រដៀងគ្នានឹងផ្លែត្នោត មិនយារ លាបដោយខ្លឹមចន្ទន៍ដ៏ល្អិត ហើយបៀមនូវស្តនរបស់ខ្ញុំនោះ ដូចជាកូនខ្ចីបង្កើតដែលបៀមនូវស្តនរបស់មាតា។ ហ្វូងចចកជញ្ជែងត្រគាក (របស់ខ្ញុំ) នោះ ជាអវយវៈទូលាយ ដែលគេដំល្អហើយ ពាក់ដោយខ្សែក្រវាត់មាសទាំងឡាយ ដាច់ខ្ចាត់ខ្ចាយ ដែលពួក ក្សត្រិយ៍ចោលក្នុងព្រៃ។ ពួកឆ្កែ ក្អែក ចចក និងសត្វឯទៀត ដែលមានចង្កូម ស៊ីនាងបភាវតី មុខជានឹងមិនចាស់គ្រាំគ្រាដោយពិត។ ប្រសិនបើពួកក្សត្រិយ៍ ដែលទៅឆ្ងាយ នាំ យកសាច់ទាំងឡាយ (របស់ខ្ញុំ) ទៅ បពិត្រព្រះមាតា ចូរព្រះអង្គសូមយកឆ្អឹងទាំងឡាយ ហើយដុតឆ្អឹងនោះ ក្នុងទីបន្ទាប់ផ្លូវ (ក្នុងចន្លោះនៃផ្លូវដើរ និងផ្លូវធំ)។ បពិត្រព្រះមាតា សូមព្រះមាតាប្រើគេធ្វើសួនច្បារ ហើយដាំដើមកណិការក្នុងសួនច្បារនុ៎ះ ក្នុងវេលាណាដែលដើមកណិការទាំងនោះមានផ្កា ក្នុងអំណើះទៅនៃកាលជាទីធ្លាក់នៃទឹកសន្សើមក្នុងហេមន្តរដូវ បពិត្រព្រះមាតា សូមព្រះមាតា រឭកខ្ញុំថា នាងបភាវតី មានវណ្ណៈយ៉ាងនេះ។

[១១១] (អភិសម្ពុទ្ធគាថា) ក្សត្រិយ៍មានវណ្ណៈដូចវណ្ណៈទេវតា ជាមាតារបស់នាងបភាវតីនោះ ក្រោកចាកអាសនៈទៅកាន់សំណាក់ព្រះរាជាហើយ បានឃើញដាវ និងជ្រញ់ ក្នុងព្រះរាជវាំងព្រះបាទមទ្ទៈ។

[១១២] (ព្រះមាតា...) បពិត្រព្រះបាទមទ្ទៈ ព្រះអង្គនឹងសម្លាប់ធីតាដែលគេចំណាំបានដោយងាយ មានចង្កេះរៀវ ដោយប៉ូវថៅនេះ ហើយប្រទានដល់ពួកក្សត្រិយ៍ដោយពិត។

[១១៣] ហៃបុត្រី នាងមិនបានធ្វើតាមពាក្យរបស់អញដែលប្រាថ្នាប្រយោជន៍ នាងមុខជានឹងពេញពាសដោយឈាម ហើយទៅកាន់ភពរបស់មច្ចុរាជក្នុងថ្ងៃនេះ។ បើសត្វដែលមិនធ្វើតាមពាក្យរបស់ពួកជនដែលបង្ហាញសេចក្តីចំរើន បង្ហាញប្រយោជន៍ហើយ តែងប៉ះ

ទង្គិចយ៉ាងនេះផង តែងជួបប្រទះនូវសេចក្តីអាក្រក់ជាង (នេះ) ផង។ បើក្នុងថ្ងៃនេះ នាងនឹងបានទ្រទ្រង់កុមារស្រស់ប៉ប្រៃ ជាក្សត្រិយ៍ ដែលកើតព្រោះព្រះបាទកុសៈ មានខ្សែក្រវាត់ជាវិការៈនៃមាស និងកែវមណីដែលពួកញាតិបូជាហើយ នាងនឹងមិនទៅកាន់លំនៅយមរាជទេ នៃនាងដ៏ចំរើន ស្លូវលាន់ឮក្តី ដំរីស្រែកក្តី ក្នុងខត្តិយត្រកូលណា (នាងឃើញ) អ្វីដែលជាសុខក្រៃលែងជាងខត្តិយត្រកូលនោះ (បានជានាងមកក្នុងទីនេះ)។ សេះក្លាប្រធីប្រូបទ្វារ កុមារអ្នករបាំប្រគំក្នុងខត្តិយត្រកូលណា នៃនាងដ៏ចំរើន (នាងឃើញ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយត្រកូលនោះ។ កាលបើក្ងោក និងក្រៀលយំ និងតាវៅយំឮទ្រហឹងអឹងកងក្នុងខត្តិយត្រកូលណា នៃនាងដ៏ចំរើន (នាងឃើញ) អ្វី ដែលជាសុខក្រៃលែងជាងខត្តិយត្រកូលនោះ។

[១១៤] ព្រះបាទកុសៈជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់ព្រះរាជាដទៃ មានប្រាជ្ញាឆើត គប្បីដោះយើងឲ្យរួចចាកទុក្ខបានតើនៅក្នុងទីណា។

[១១៥] (នាងបភាវតី...) ព្រះបាទកុសៈជាអ្នកញាំញីខ្មាំងសត្រូវ ញាំញីដែនរបស់ព្រះរាជាដទៃ មានប្រាជ្ញាឆើត សម្លាប់ក្សត្រិយ៍ទាំងអស់នោះ នៅក្នុងទីនេះឯង។

[១១៦] (ព្រះមាតា...) នាងជាស្រីឆ្កួត ជាស្រីអន្ធពាល ចេះតែនិយាយ (ឲ្យរួចតែពីមាត់) បើព្រះបាទកុសៈគប្បីមក ពួកយើងធ្វើដូចម្តេចនឹងស្គាល់ព្រះបាទកុសៈនោះបាន។

[១១៧] (នាងបភាវតី...) (ព្រះបាទកុសៈ) គឺបុរសនាយពិសេសនុ៎ះ ចងក្បិនយ៉ាងមាំឱនលាងឆ្នាំង (សូមព្រះមាតាទត) ត្រង់ចន្លោះដំណាក់កុមារី។

[១១៨] (ព្រះមាតា...) នាងជាស្រីនៃត្រកូលជាងចាំង ជាស្រីចណ្ឌាល ឬជាស្រីទ្រុស្ត ត្រកូលទេឬ នាងកើតក្នុងត្រកូលព្រះបាទមទ្ទៈ គួរធ្វើស្វាមី (របស់ខ្លួន) ឲ្យជាទាសៈ ដូម្តេចកើត។

[១១៩] (នាងបភាវតី...) ខ្ញុំមិនមែនជាស្រីត្រកូលជាងចាំង មិនមែនស្រីចណ្ឌាល មិនមែនជាស្រីទ្រុស្តត្រកូលទេ បពិត្រព្រះមាតា (ព្រះបាទកុសៈនោះ) ជាបុត្ររបស់ព្រះបាទឱក្កាកៈ (ចំណែកខាង) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ។

[១២០] ព្រះបាទកុសៈណា ញាំងពួកព្រាហ្មណ៍ទាំងម្ភៃពាន់ ឲ្យបរិភោគសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទឱក្កាកៈ (ចំណែកខាង) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ។ ពួកជនតែងទឹមដំរីទាំងម្ភៃពាន់របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទ ឱក្កាកៈ (ចំណែកខាង) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ។ ពួកជនតែងទឹមសេះទាំងម្ភៃពាន់របស់ព្រះបាទកុសៈណា សព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទឱក្កាកៈ (ចំណែកខាង) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ។ ពួកជនតែងទឹមរថទាំងម្ភៃពាន់របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទឱក្កាកៈ (ចំណែកខាង) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ។ ពួកជនតែងរឹតទឹកដោះមេគោទាំងម្ភៃពាន់របស់ព្រះបាទកុសៈណាសព្វកាល បពិត្រព្រះមាតា ព្រះបាទកុសៈនោះ ជាបុត្ររបស់ព្រះបាទឱក្កាកៈ (ចំណែកខាង) ព្រះមាតាទេតើ សំគាល់ថាជាទាសៈទៅវិញ។

[១២១] (ព្រះរាជា...) ម្នាលស្រីពាល ហាងឯងធ្វើខ្ចីខ្ចាដល់ក្សត្រិយ៍ដែលមានកម្លាំងច្រើន ដូចជាដំរី ដោយភេទនៃកង្កែប នាងមិនបានប្រាប់ក្សត្រិយ៍នោះ ដែលយាងមកហើយ។

[១២២] បពិត្រមហារាជ ជាបុគ្គលប្រសើរលើរថ សូមព្រះអង្គទ្រង់អត់កំហុស ដល់យើង ព្រោះយើងមិនបានដឹងថា ទ្រង់យាងមកក្នុងទីនេះ ដោយក្លែងភេទសោះ។

[១២៣] (ព្រះមហាសត្ត...) បពិត្រព្រះសម្មតិទេព ដំណើរដែលទូលព្រះបង្គំជាខ្ញុំ ធ្វើជានាយពិសេសនោះ មិនកំបាំងដល់ជនដូចទូលព្រះបង្គំជាខ្ញុំទេ សូមព្រះអង្គជ្រះថ្លានឹងទូលបង្គំជាខ្ញុំចុះ អំពើខ្ចីខ្ចារបស់ព្រះអង្គមិនមានទេ។

[១២៤] (ព្រះរាជា...) ម្នាលស្រីពាល នាងឯងចូរទៅសូមខមាលទោសនឹងព្រះបាទកុសៈ ដែលមានកម្លាំងច្រើន ព្រះបាទកុសៈនោះ កាលបើនាងសូមខមាលទោសហើយ នឹងប្រទានជីវិតដល់នាង។

[១២៥] (អភិសម្ពុទ្ធគាថា) នាងបភាវតី មានវណ្ណៈដូចជាវណ្ណៈនៃទេវតា ឮព្រះឱង្ការ របស់ព្រះបិតា (ក៏ក្រាប) ដោយសីសៈ អាចចាប់ព្រះបាទកុសៈដ៏មានកម្លាំងច្រើន ត្រង់ព្រះបាទាបាន។

[១២៦] (នាងបភាវតី...) បពិត្រព្រះសម្មតិទេព រាត្រីទាំងនោះ វៀរចាកព្រះអង្គកន្លងទៅ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ ខ្ញុំម្ចាស់សូម (ក្រាប) ដោយក្បាល ថ្វាយបង្គំព្រះបាទទាំងគូររបស់ព្រះអង្គ សូមព្រះអង្គកុំខ្ញាល់នឹងខ្ញុំម្ចាស់។ បពិត្រមហារាជ ខ្ញុំម្ចាស់សូមប្តេជ្ញាពាក្យពិតចំពោះព្រះអង្គ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យរបស់ខ្ញុំ ម្ចាស់ៗ លែងធ្វើនូវការមិនស្រឡាញ់ព្រះអង្គទៀតហើយ។ កាលបើខ្ញុំម្ចាស់អង្វរករ យ៉ាងនេះហើយ បើព្រះអង្គនឹងមិនធ្វើតាមពាក្យខ្ញុំម្ចាស់ទេ ព្រះរាជបិតាមុខជានឹងសម្លាប់ខ្ញុំម្ចាស់ឥឡូវនេះ ហើយប្រទានដល់ពួកក្សត្រិយ៍មិនខាន។

[១២៧] (ព្រះមហាសត្ត...) កាលបើនាងអង្វរករយ៉ាងនេះហើយ យើងនឹងមិនធ្វើតាមពាក្យរបស់នាងឯណាបាន នៃនាងបភាវតីស្រីកល្យាណី បងលែងខឹងនឹងនាងហើយ នាងកុំភ័យឡើយ។ នៃរាជបុត្រី យើងសូមប្តេជ្ញាពាក្យពិតចំពោះនាងៗ ចូរស្តាប់ពាក្យរបស់យើងៗ លែងធ្វើនូវសេចក្តីមិនជាទីស្រឡាញ់នាងទៀត។ នៃនាងបភាវតី ជាស្រីមានចង្កេះរៀវ យើងអត់ទ្រាំសេចក្តីទុក្ខច្រើនដង ព្រោះតែចង់បាននាង យើងហ៊ានសម្លាប់ត្រកូលរបស់ព្រះបាទមទ្ទៈជាច្រើន ហើយនាំយកនាងទៅបាន។

[១២៨] ពួកជនទាំងឡាយ ចូរទឹមសេះដ៏រំលេចដោយគ្រឿងប្រដាប់ផ្សេងៗ ជាសត្វរៀបរយក្នុងរថ កាលបើទឹមហើយ អ្នកទាំងឡាយមុខជានឹងឃើញកម្លាំងរបស់ខ្ញុំ ដែលកំចាត់ពួកខ្មាំងបាន។

(អភិសម្ពុទ្ធគាថា) ពួកស្រីក្នុងព្រះរាជវាំងរបស់ព្រះបាទមទ្ទៈ (នាំគ្នាបើកបង្អួច) អើតមើលព្រះបាទកុសៈនោះ ដែលកំពុងមិតពត់ កំពុងទង្គិចដើមដៃទាំងពីរខាង ដូចជាសីហៈ ក្នុងទីនោះ។

[១២៩] ព្រះបាទកុសៈ លើកព្រះនាងបភាវតី ឡើងកាន់កដំរី លុកលុយចូលទៅក្នុងសង្គ្រាម ហើយក៏បន្លឺនូវសីហនាទ។ ពួកក្សត្រិយ៍ឮព្រះបាទកុសៈនោះបន្លឺសីហនាទនោះ ត្រូវភ័យអំពីសំឡេងគម្រាមនៃព្រះបាទកុសៈបៀតបៀនហើយ ក៏នាំគ្នារត់បែកខ្ញែកដូចជាពួកម្រឹគដទៃ (ដែលភ័យនឹងសម្រែក) នៃសីហៈ។ ពួកទាហានដំរី ទាហានសេះ ទាហានរថ ទាហានថ្មើរជើង ត្រូវភ័យអំពីសំឡេងនៃព្រះបាទ

កុសៈបៀតបៀនហើយ ក៏រត់ជាន់គ្នាទៅវិញទៅមក។ ទេវរាជជាធំជាងទេវតា បានឃើញហើយ ក៏មានព្រះហឫទ័យរីករាយ បានប្រទានកែវមណីឈ្មោះវិរោចនៈ ដល់ព្រះបាទកុសៈក្នុងប្រធាននៃសង្គ្រាមនោះ។ ព្រះរាជានោះ លុះឈ្នះសង្គ្រាមនោះ បានកែវមណីឈ្មោះវេរោចនៈ ហើយគង់លើ ក ដំរី ក៏យាងចូលទៅកាន់បុរី។ ព្រះបាទកុសៈ បានចាប់យកក្សត្រិយ៍ទាំង ៧ អង្គទាំងរស់ ចងនាំមកថ្វាយដល់ព្រះបិតាក្មេកថា បពិត្រព្រះសម្មតិទេព ក្សត្រិយ៍ទាំង ៧ នេះហើយជាសត្រូវរបស់ព្រះអង្គ។ ពួកក្សត្រិយ៍ជាសត្រូវទាំងអស់ ជាអ្នកបៀតបៀនព្រះអង្គ លុះក្នុងអំណាចរបស់ព្រះអង្គហើយ សូមព្រះអង្គធ្វើតាមបំណងរបស់ព្រះអង្គចុះ ទោះព្រះអង្គលែងក្សត្រិយ៍ទាំងនោះ ឬសម្លាប់នូវក្សត្រិយ៍ទាំងនោះចុះ។

[១៣០] (ព្រះរាជា...) បពិត្រមហារាជ ព្រះរាជាទាំងនុ៎ះ ជាសត្រូវរបស់ព្រះអង្គ ព្រះរាជាទាំងនោះ មិនមែនជាសត្រូវរបស់ខ្ញុំទេ ព្រះអង្គ (ជាឥស្សរៈ) របស់ពួកយើងស្រាប់ហើយ ទោះលែងក្សត្រិយ៍ទាំងនោះ ឬសម្លាប់នូវក្សត្រិយ៍ទាំងនោះចុះ។

[១៣១] (ព្រះមហាសត្ត...) ធីតាទាំងឡាយរបស់ព្រះអង្គទាំង ៧ នេះ ល្អ មានឧបមាដោយទេវកញ្ញា សូមព្រះអង្គប្រទានធីតាមួយអង្គៗ ដល់ព្រះរាជាទាំងនោះៗ ចូរជាកូនប្រសារ របស់ព្រះអង្គចុះ។

[១៣២] (ព្រះបាទមទ្ទៈ...) បពិត្រមហារាជ ព្រះអង្គជាឥស្សរៈរបស់ពួកយើងទាំងអស់គ្នា គឺ (ព្រះរាជាទាំង ៧ នេះផង) ខ្ញុំផង ធីតាទាំងនោះផង ព្រះអង្គប្រាថ្នានឹង (ប្រទាន) ធីតា ណា (ដល់ព្រះរាជាណា) សូមប្រទាន (ធីតានោះ) ដល់ព្រះរាជានោះចុះ។ '

[១៣៣] (អភិសម្ពុទ្ធគាថា) ព្រះបាទកុសៈ មានព្រះវាចាស័ព្ទស្មើនឹងសំឡេងសីហៈ បានប្រទានពួកធីតារបស់ព្រះបាទមទ្ទៈមួយអង្គៗ ដល់ក្សត្រិយ៍ទាំងនោះមួយអង្គៗ។ ពួកក្សត្រិយ៍ទាំង ៧ អង្គ មានព្រះហឫទ័យស្កប់ស្កល់ដោយលាភនោះហើយ ក៏ត្រេកអរ ចំពោះព្រះបាទកុសៈ ដែលមានព្រះសូរវាចាស្មើនឹងសំឡេងសីហៈ បានទៅកាន់ដែនទាំងឡាយរៀងខ្លួនក្នុងលំដាប់នោះឯង។ ចំណែកឯព្រះបាទកុសៈមានកម្លាំងច្រើន បាននាំយកនាងបភាវតី និងកែវមណី ឈ្មោះវេរោចនៈដ៏ល្អ ហើយទ្រង់ស្តេចវិលត្រឡប់ទៅកាន់ក្រុងកុសាវតីវិញ។ ក្សត្រិយ៍ទាំងនោះ គង់លើរថជាមួយគ្នា បរសំដៅចូលទៅកាន់ក្រុងកុសាវតី ស្មើគ្នាដោយវណ្ណៈ និងរូប មិនរុងរឿងជាងគ្នាប៉ុន្មានទេ។ ព្រះមាតាបានជួបជុំដោយបុត្រ ចំណែកអគ្គមហេសី នឹងព្រះរាជស្វាមីទាំងពីរព្រះអង្គនោះ បានព្រមព្រៀងគ្នា នៅគ្រប់គ្រងរាជធរណីដ៏សម្បូណ៌សប្បាយក្នុងកាលនោះ។

ចប់ កុសជាតក ទី១។

## សោណនន្ទជាតក ទី២

CS sut.kn.jat.532 | ភាគទី ៦១

### (៥៣២. សោណនន្ទជាតកំ (២))

[១៣៤] (ព្រះរាជាព្រះនាមមនោជៈ ត្រាស់សួរថា) លោកជាទេវតា ឬជាគន្ធព្វ ជាសក្កបុរិន្ទទៈ ឬជាមនុស្សមានឫទ្ធិ ធ្វើដូចម្តេច យើងនឹងស្គាល់លោកបាន។

[១៣៥] (តាបសឈ្មោះនន្ទបណ្ឌិតពោលថា) អាត្មាភាព មិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ អាត្មាភាពជាមនុស្សមានឫទ្ធិ បពិត្រព្រះរាជា ទ្រទ្រង់នូវភារៈ (ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះចុះ។

[១៣៦] (ព្រះបាទមនោជៈ...) ការខ្វល់ខ្វាយបំរើ មានភាពដែលលោកដ៏ចំរើនធ្វើហើយ នេះជាការមិនមែនតិច កាលដែលភ្លៀងកំពុងធ្លាក់ចុះ លោកដ៏ចំរើនអាចធ្វើមិនឲ្យមានភ្លៀងបាន។ តអំពីនោះមក លោកដ៏ចំរើនអាចធ្វើឲ្យម្លប់ដ៏ត្រជាក់បាន ក្នុងទីមានខ្យល់និងកំដៅថ្ងៃដ៏ខ្លាំង តពីនោះមក លោកដ៏ចំរើនអាចធ្វើគ្រឿងការពារព្រួញ ក្នុងកណ្តាលនៃសត្រូវទាំងឡាយបាន។ តពីនោះមក លោកដ៏ចំរើនអាចធ្វើដែនទាំងឡាយ ដ៏សម្បូណ៌ (និង) អ្នកដែនទាំងនោះឲ្យលុះក្នុងអំណាច (របស់យើងខ្ញុំ) តពីនោះមក លោកដ៏ចំរើនអាចធ្វើក្សត្រិយ៍ ១០១ ឲ្យជាចំណុះ (នៃយើងខ្ញុំបាន)។ យើងខ្ញុំត្រេកអរនឹងលោកដ៏ចំរើន លោកចង់បានរតនៈ (ណា) ចូរទទួលយករតនៈនោះចុះ យើងខ្ញុំប្រគេនយានដំរី រថ សេះ ពួកនាងនារីដែលប្រដាប់ស្រេច ទាំងលំនៅគួរឲ្យត្រេកអរទាំងឡាយដល់លោកដ៏ចំរើន។ មួយទៀត យើងខ្ញុំប្រគេនដែនអង្គៈ ឬមគធៈ ដល់លោកដ៏ចំរើន មួយទៀត យើងខ្ញុំសប្បាយចិត្ត ប្រគេនដែនអស្សកៈ ឬដែនអវន្តិដល់លោក។ យើងខ្ញុំប្រគេនរាជ្យពាក់កណ្តាល ដល់លោកដ៏ចំរើន បើលោកត្រូវការដោយរាជ្យ លោកចង់បានរបស់ណា សូមត្រួតត្រារបស់នោះចុះ។'

[១៣៧] (នន្ទបណ្ឌិតតាបស...) អាត្មាភាព មិនត្រូវការដោយរាជ្យ ដោយនគរ ឬដោយទ្រព្យ ទាំងមិនត្រូវការដោយជនបទទេ។

[១៣៨] ក្នុងព្រៃក្នុងដែនជាអាណាខែត្ររបស់ព្រះអង្គដ៏ចំរើន មានអាស្រមមួយ បិតាមាតារបស់អាត្មាភាពទាំងពីរនាក់ នៅក្នុងអាស្រមនោះ។ អាត្មាភាពមិនបានធ្វើបុណ្យ ចំពោះបុព្វាចារ្យទាំងនោះ យើងធ្វើព្រះអង្គដ៏ចំរើនឲ្យប្រសើរលើសលុប ឲ្យសូមនូវការរួបរួមជាមួយនឹងសោណបណ្ឌិតតាបស។

[១៣៩] (ព្រះរាជា...) បពិត្រព្រាហ្មណ៍ ខ្ញុំធ្វើតាមពាក្យរបស់លោកដែលលោកពោលនឹងខ្ញុំ សូមលោកប្រាប់ហេតុនោះ ដល់យើងខ្ញុំ តើឲ្យពួកជនប៉ុន្មាននាក់ ជាអ្នកជួយ អង្វរករ។

[១៤០] (នន្ទបណ្ឌិតតាបស...) ពួកគហបតីមហាសាលជាងមួយរយ ពួកព្រាហ្មណ៍មហាសាលជាងមួយរយ និងពួកក្សត្រិយ៍ទាំងអស់ដែលមានជាតិដ៏ខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចំរើន ទើបល្មមជាអ្នកជួយអង្វរករ។

[១៤១] (ព្រះរាជា...) ពួកអ្នករក្សាដំរី ពួកអ្នករក្សាសេះ ចូរនាំគ្នាចាត់ចែងនូវពួកដំរី ពួកសេះ ម្នាលសារថី អ្នកចូរជ្រាមរថ អ្នកទាំងឡាយចូរយកគ្រឿងប្រដាប់សម្រាប់ចង (ឯដំរីសេះរថ) ជនទាំងឡាយ ចូរលើកទង់ជ័យ ត្រង់ជើងទង់ជ័យដែលដំកល់លើរថ អញនឹងទៅកាន់អាស្រមជាទីនៅនៃកោសិយគោត្ត។

[១៤២] (អភិសម្ពុទ្ធគាថា) លំដាប់ពីនោះមក ព្រះរាជាបានយាងទៅដោយសេនាប្រកបដោយអង្គ ៤ ទ្រង់ស្តេចទៅកាន់អាស្រមជាទីរីករាយ ជាទីនៅនៃកោសិយគោត្ត។

[១៤៣] (ព្រះបាទមនោជៈ...) ដងរែក ជាវិការៈនៃឈើក្ទម្ពរបស់អ្នកណា ដែលទៅដងទឹក ហើយមិនប៉ះពាល់ស្មា ទៅលើអាកាសចំនួន ៤ ធ្នាប់។

[១៤៤] (ព្រះមហាសត្ត...) បពិត្រមហារាជ អាត្មាភាពជាតាបសឈ្មោះសោណៈ ប្រកបដោយវត្ត មិនខ្ជិលច្រអូស ចិញ្ចឹមមាតាបិតាទាំងយប់ទាំងថ្ងៃ។ បពិត្រព្រះអង្គជាម្ចាស់នៃទិស អាត្មាភាព រលឹកឃើញឧបការៈដែលមាតាបិតាធ្វើក្នុងកាលមុន ហើយក៏យកផ្លែឈើ និងមើមឈើក្នុងព្រៃ មកចិញ្ចឹមមាតាបិតា។

[១៤៥] (ព្រះរាជា...) យើងខ្ញុំចង់ទៅកាន់អាស្រម ជាទីនៅរបស់កោសិយគោត្ត បពិត្រព្រះសោណៈ សូមលោកម្ចាស់ប្រាប់ផ្លូវដល់យើង យើងនឹងទៅកាន់អាស្រម។

[១៤៦] (ព្រះមហាសត្ត...) បពិត្រព្រះរាជា ផ្លូវដើរចុះតែជើង ១ នេះ មានព្រៃ មានពណ៌ដូចជាផ្ទៃមេឃ ដ៏ដេរដាសដោយដើមរលួស ផ្អុងនុំ ជាទីនៅរបស់កោសិយគោត្ត។

[១៤៧] (អភិសម្ពុទ្ធគាថា) លុះមហាឥសីពោលពាក្យនេះទូលប្រាប់ពួកក្សត្រិយ៍ហើយ ប្រញាប់ប្រញាល់ចៀសចេញទៅ (កាន់ស្រះអនោតត្ត) តាមអាកាសវេហាស៍ មហាឥសី ក៏បោសសំអាតអាស្រម រៀបចំអាសនៈ ចូលទៅកាន់បណ្ណសាលាហើយជំរាបបិតាឲ្យជ្រាបថា បពិត្រមហាឥសី ព្រះរាជាទាំងនេះ មានជាតិខ្ពស់ មានយស យាងមក សូមព្រះបិតាចេញអំពីអាស្រមមកគង់ចាំទទួល។ មហាឥសី ឮពាក្យនោះរបស់កូននោះហើយ ក៏ប្រញាប់ប្រញាល់ ចេញអំពីអាស្រម មកអង្គុយជិតទ្វារ។

[១៤៨] កោសិយគោត្តតាបស បានឃើញស្ដេចនោះ ដូចជារុងរឿងដោយតេជៈ មានពួកក្សត្រិយ៍ហែហម កំពុងយាងមក ហើយបានពោលពាក្យនេះថា ស្គរ សម្ភោរ ស័ង្ខ ស្គរតូច និងមហោរធិករបស់អ្នកណាញ៉ាំងស្ដេចជាបុគ្គលប្រសើរលើរថ ឲ្យរីករាយទៅខាងមុខ។ (ទីបំផុតថ្ងាស) នៃអ្នកណា (បិទបាំង) ដោយដំបារមាសដ៏ធំ មានព័ណ៌ដូចជាផ្លេកបន្ទោរ ប្រសក់ឡោះណា សៀតបំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក។ អ្នកណាមានមុខរុងរឿងភ្លឺចាំង ដូចជាមាសភ្លឺចិញ្ចាចត្រង់មាត់ឡបារ ស្រដៀងនឹងរងើកភ្លើងនៃឪសគគីរ រុងរឿងដោយសិរី ហើយដើរមក។ អ្នកណាបាំងឆ័ត្រ ព្រមទាំងឆ្អឹង ជាទីរីករាយនៃចិត្ត ការពាររស្មីព្រះអាទិត្យ អ្នកណារុងរឿងដោយសិរី ហើយដើរមក។ ពួកជនបិទបាំងជុំវិញខ្លួននៃអ្នកណា ដែលមានបុណ្យដ៏ប្រសើរ កំពុងជិះលើ ក នៃដំរី ដោយផ្លិតរោមសត្វដ៏ឧត្តម ហើយដើរទៅ។ ពួកឆ័ត្រស និងពួកអាជានេយ្យ ប្រដាប់ដោយក្រោះខ្នាន់ខ្នាប់ជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរី ហើយដើរមក។ ពួកក្សត្រិយ៍មួយរយមួយ សុទ្ធតែមានយសជាស្ដេចចំណុះ ដើរហែហមជុំវិញនៃអ្នកណា អ្នកណារុងរឿងដោយសិរី ដើរមក។ ពួកសេនាប្រកបដោយអង្គ ៤ គឺដំរី ១ សេះ ១ រថ ១ ពលថ្មើរជើង ១ ដើរហែហមជុំវិញ (នៃអ្នកណា) អ្នកណារុងរឿងដោយសិរី ដើរមក។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យរំភើបបាន មិនមានទីបំផុត ដូចជារលកនៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃអ្នកណា។

[១៤៩] (ព្រះមហាសត្ត...) ព្រះបាទមនោជៈ ជាព្រះរាជាប្រសើរជាងពួកព្រះរាជា ដូចជាព្រះឥន្ទ្រជាធំជាងពួកទេវតា ក្នុងឋានត្រៃត្រឹង្ស ដែលមានជ័យជំនះ បានដល់នូវភាពជាបរិស័ទនៃនន្ទតាបស មកកាន់អាស្រមនៃពួកព្រហ្មចារីបុគ្គល (ដើម្បីខមាទោសនឹងយើង)។ សេនាដ៏ធំនេះ មិនមានអ្នកណាមួយឲ្យរំភើបបាន មិនមានទីបំផុតដូចជារលក នៃសាគរ ប្រព្រឹត្តទៅតាមខាងក្រោយនៃព្រះបាទមនោជៈនោះ។

[១៥០] (អភិសម្ពុទ្ធគាថា) ពួកព្រះរាជាទាំងអស់ លាបស្រឡាបដោយខ្លឹមចន្ទន៍ ទ្រង់កាសិកព័ស្ត្រដ៏ឧត្តម បានផ្គងអញ្ជលីចូលទៅរកពួកឥសី។

[១៥១] (ព្រះបាទមនោជៈ...) លោកដ៏ចំរើនមានសេចក្ដីសុខស្រួលទេឬ លោកដ៏ចំរើនមានអនាម័យទេឬ លោកទាំងឡាយចិញ្ចឹមជីវិតដោយការស្វែងរកឬ មើមឈើ និងផ្លែឈើ មានច្រើនដែរឬ។ ពួករបោម មូស ពស់ មានតិចតួចដែរឬ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ មិនបៀតបៀនទេឬ។

[១៥២] (កោសិយគោត្ត...) បពិត្រព្រះរាជា អាត្មាភាព មានសេចក្ដីស្រួលទេ បពិត្រព្រះរាជា មួយទៀត អាត្មាភាព មិនមានសេចក្ដីឈឺចាប់ទេ អាត្មាភាព ចិញ្ចឹមជីវិតដោយការស្វែងរក (ផលាផល) ស្រួលទេ ទាំងមើមឈើ និងផ្លែឈើក៏មានច្រើន។ មួយទៀត ពួករបោម មូស ពស់ ក៏មានតិចតួចទេ ក្នុងព្រៃដ៏ដេរដាសដោយម្រឹគសាហាវ ក៏មិនបៀតបៀនអាត្មាភាពទេ។ អាត្មាភាព មកនៅក្នុងអាស្រមនេះ អស់ប្រជុំនៃឆ្នាំជាច្រើន មិនដែលស្គាល់អាពាធ មិនជាទីត្រេកអរនៃចិត្តកើតឡើងទេ។ បពិត្រមហារាជ ព្រះអង្គយាងមកល្អហើយ មួយទៀត ព្រះអង្គមិនមែនយាងមកអាក្រក់ទេ ព្រះអង្គជាឥស្សរៈ យាងមកដល់ហើយ វត្ថុមានក្នុងទីនេះ សូមព្រះអង្គមានព្រះបន្ទូល។ បពិត្រព្រះរាជា សូមព្រះអង្គសោយផ្លែទន្លាប់ ផ្លែទ្រយឹង ផ្លែស្រគំ ផ្លែមាក់ដោក មានរសឆ្ងាញ់ពិសា ដូចជាទឹកឃ្មុំ។ ទឹកត្រជាក់នេះ អាត្មាភាព បានដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ សូមព្រះអង្គសោយទឹកនោះចុះ ប្រសិនបើទ្រង់ត្រូវការ។

[១៥៣] (ព្រះរាជា...) របស់ណាដែលលោកឲ្យហើយ (របស់នោះ) ឈ្មោះថា យើងខ្ញុំទទួលហើយ ទាំងបានធ្វើឲ្យជាជំនូនដល់ជនទាំងពួង លោកទាំងឡាយ ចូរស្ដាប់ពាក្យនន្ទបណ្ឌិតតាបស លោកនឹងនិយាយឥឡូវនេះ ពួកយើងជាបរិស័ទនៃនន្ទបណ្ឌិតតាបស បានមកកាន់សំណាក់នៃលោកដ៏ចំរើន សោណបណ្ឌិតដ៏ចំរើន ចូរស្ដាប់ពាក្យនៃខ្ញុំផង នៃបរិស័ទរបស់នន្ទបណ្ឌិតតាបសផង។

[១៥៤] (នន្ទបណ្ឌិតតាបស...) ពួកគហបតីមហាសាល ជាងមួយរយ ពួកព្រាហ្មណ៍មហាសាលជាងមួយរយ និងពួកក្សត្រិយ៍ទាំងអស់ ដែលមានជាតិខ្ពស់ មានយសនេះ ទាំងព្រះបាទមនោជៈដ៏ចំរើន សូមជ្រាបតាមសំដីរបស់អាត្មាភាពចុះ។ ពួកជនដែលមកជួបជុំគ្នា ពួកយក្ស ពួកភូត និងទេវតា ក្មេងមានក្នុងអាស្រមក្នុងព្រៃនេះ ចូរស្ដាប់នូវពាក្យរបស់អាត្មា។ អាត្មាធ្វើនមស្ការដល់ពួកភូតហើយ នឹងនិយាយចំពោះឥសី (ឈ្មោះសោណបណ្ឌិត) ដែលមានវត្តល្អថា ខ្ញុំនោះហើយ ដែលកោសិយគោត្តសន្មតថា ជាដើមដៃស្ដាំរបស់លោក។ បពិត្រអ្នកមានព្យាយាម ការទំនុកបំរុងមាតាបិតានេះ ជាបុណ្យរបស់ខ្ញុំដែលជាអ្នកប្រាថ្នាចិញ្ចឹមមាតា និងបិតារបស់ខ្ញុំ បពិត្រព្រះកោសិយៈ សូម លោកកុំឃាត់ខ្ញុំឡើយ។ ការទំនុកបំរុងមាតាបិតានុ៎ះ ពួកសប្បុរសបានដឹងហើយ សូម លោកលះនូវការទំនុកបំរុងមាតាបិតានេះឲ្យដល់ខ្ញុំ លោកបានធ្វើ (កុសល) ដោយការ ខ្នះខ្នែងនឹងការបំរើយូរយារណាស់មកហើយ (ឥឡូវនេះ ខ្ញុំចង់ធ្វើ) បុណ្យទាំងឡាយ ដល់មាតា និងបិតា សូមលោកប្រគល់សួគ៌ទេវលោកដល់ខ្ញុំ។ បពិត្រឥសី លោកដឹងផ្លូវទៅកាន់សួគ៌ទេវលោកយ៉ាងណា ពួកមនុស្សក៏ដឹងចំណែកធម៌ក្នុងធម៌ ក៏យ៉ាងនោះដែរ។ កិរិយានាំមកនូវសេចក្ដីសុខដល់មាតាបិតា ដោយការខ្នះខ្នែងនឹងការបំរើ ឥឡូវនេះ ជន (សោណបណ្ឌិត) ហាមឃាត់ខ្ញុំនោះចាកបុណ្យ ឈ្មោះថា ជាអ្នករារាំងផ្លូវដ៏ប្រសើរ (ឋានសួគ៌)។

[១៥៥] (ព្រះមហាសត្ត...) លោកដ៏ចំរើនទាំងឡាយ ដែលជាបរិស័ទនៃប្អូនរបស់ខ្ញុំ សូមស្ដាប់ពាក្យរបស់ខ្ញុំ បពិត្រមហារាជ អ្នកណាមិនប្រព្រឹត្តធម៌ ចំពោះបុគ្គលជាច្បងទាំងឡាយ ញ៉ាំងប្រវេណីពីបុរាណឲ្យសាបសូន្យ អ្នកនោះរមែងទៅកើតក្នុងនរក។ បពិត្រព្រះអង្គជាម្ចាស់នៃទិស ពួកជនណាឈ្លាសវៃក្នុងធម៌ (ជេដ្ឋាបចាយនធម៌) ជាប្រវេណីអំពីបុរាណ ព្រមទាំងបរិបូណ៌ដោយសណ្ដាប់ធ្នាប់ ពួកជននោះ រមែងមិនទៅកាន់ទុគ្គតិទេ។ បពិត្រព្រះអង្គជាអ្នកទ្រទ្រង់នូវបន្ទុក (ដែន) សូមព្រះអង្គជ្រាបយ៉ាងនេះថា មាតាបិតាបងប្អូនប្រុសស្រី ញាតិ និងផៅពង្សទាំងអស់នោះ ជាភារៈរបស់កូនច្បង។ បពិត្រព្រះអង្គជាបុគ្គលប្រសើរលើរថ អាត្មាភាពដូចជានាយសំពៅ អាចនាំយកនូវភារៈដ៏ធ្ងន់ អាត្មាភាពពុំប្រមាទនូវជេដ្ឋាបចាយនធម៌ទេ ព្រោះអាត្មាភាពជាច្បង។

[១៥៦] (ព្រះរាជាទាំងឡាយ...) ពួកយើងបានញាណដូចបុគ្គលបានអណ្ដាតភ្លើងអំពីភ្លើង ក្នុងទីងងឹត កោសិយតាបសដ៏ចំរើន

បានឆ្លុះបញ្ចាំងធម៌ដល់ពួកយើង យ៉ាងនេះឯង។ ព្រះអាទិត្យដែលបំភ្លឺនូវទ្រព្យ ធ្វើពន្លឺកាលរះឡើង តែងឆ្លុះបញ្ចាំងនូវរូបល្អ អាក្រក់ ដល់សត្វទាំងឡាយយ៉ាងណា កោសិយៈដ៏ចំរើនបានឆ្លុះបញ្ចាំងនូវធម៌ដល់ពួកយើង ក៏យ៉ាងនោះដែរ។

[១៥៧] (នន្ទបណ្ឌិតតាបស...) កាលបើខ្ញុំអង្វរយ៉ាងនេះហើយ លោកនៅតែមិនទទួលអញ្ជលី ខ្ញុំនឹងជាអ្នកប្រព្រឹត្តតាមពាក្យ ជាអ្នកប្រឹងបំរើលោក។

[១៥៨] (ព្រះមហាសត្ត...) ម្នាលនន្ទ អ្នកស្គាល់ច្បាស់នូវព្រះសទ្ធម្មដែលពួកសប្បុរសសំដែងហើយមែន អ្នកជាមនុស្សល្អ មានឫកពាល្អ ត្រូវចិត្តយើងហើយ។ ខ្ញុំសូមនិយាយនឹងបិតាដ៏ចំរើន នឹងបិតាដ៏ចំរើន សូមលោកទាំងឡាយស្តាប់ពាក្យរបស់ខ្ញុំ ភារៈនេះ មិនមែនគ្រាន់តែជាភារៈរបស់ខ្ញុំក្នុងកាលម្តងៗ ទេ។ នន្ទៈធ្វើនូវខ្ញុំដែលជាអ្នកបំរើ នាំមកនូវសេចក្តីសុខដល់មាតា និងបិតានោះ ឲ្យជាធំ ហើយសូមដើម្បីការបំរើដែរ។ បណ្តា (មាតា និងបិតា) ជាព្រហ្មចារី បើលោកណាម្នាក់ចង់បាន សូមលោកទទួលយកនន្ទៈ តាមប្រាថ្នាចុះ តើឲ្យនន្ទៈបំរើលោកណា។

[១៥៩] (មាតា...) នែសោណៈកូន យើងអាស្រ័យនឹងអ្នក អ្នកអនុញ្ញាតហើយ គួរបានដើម្បីចូលទៅថើបក្បាលនន្ទៈ ជាព្រហ្មចារី។

[១៦០] ដួងហឫទ័យរបស់ម្តាយរំជួល ព្រោះខានឃើញនន្ទៈអស់កាលយូរហើយ ដូចជាស្លឹកខ្ទីរបស់អស្សត្ថព្រឹក្សដែលត្រូវខ្យល់បក់។ វេលាណា ម្តាយដេកលក់ យល់សប្តិឃើញនន្ទៈមក ក៏មានចិត្តត្រេកអរ មានចិត្តរីករាយ (ដោយគិតថា) នន្ទៈរបស់យើងនេះ មកហើយ។ វេលាណា ម្តាយភ្ញាក់ឡើង មិនឃើញនន្ទៈមកទេ សេចក្តីសោក និងទោមនស្សជាច្រើន រឹងរឹតតែបណ្តាលឡើង។ យូរណាស់ហើយ ស្រាប់តែក្នុងថ្ងៃនេះ ម្តាយនោះឃើញនន្ទៈមកដល់ នន្ទៈជាទីស្រឡាញ់នៃស្វាមីរបស់ម្តាយផង នៃម្តាយផង បានចូលមកកាន់ផ្ទះរបស់ពួកយើង។ នន្ទៈជាទីស្រឡាញ់ក្រៃលែងរបស់បិតា កុំឲ្យនន្ទៈ ទៅប្រាសចាកអំពីផ្ទះ នៃកូន ឯនន្ទៈ (ចង់បានអ្នកណា) ចូរបានអ្នកនោះចុះ នន្ទៈចូរបំរើនូវអញចុះ។

[១៦១] (ព្រះមហាសត្ត...) ម្នាលឥសី មាតាជាអ្នកឈឺឆ្អាល ជាទីពឹង ជាអ្នកឲ្យរស (ទឹកក្សីរ) ដល់ពួកយើងជាមុន ជាផ្លូវនៃសួគ៌ទេវលោក ចង់បានអ្នក។ មាតាជាអ្នកឲ្យរសជាមុន ជាអ្នកគ្រប់គ្រង ដែលយើងចូលទៅអាស្រ័យបុណ្យ ជាផ្លូវនៃសួគ៌ទេវលោក ម្នាលឥសី មាតាចង់បានអ្នក។

[១៦២] មាតា កាលប្រាថ្នាចង់បានផ្លែ គឺកូន រមែងនមស្ការទេវតា សួរនក្ខត្តឫក្សទាំងឡាយផង សួររដូវ និងឆ្នាំទាំងឡាយផង។ កាលមាតានោះ មានរដូវលាងស្អាតហើយ សត្វក៏ចុះមកកាន់គភ៌ស៊ប់ មាតាជាស្ត្រីមានសេចក្តីចាញ់ផ្ទៃដោយហេតុនេះ ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា សុហទា (មានដួងហឫទ័យល្អ)។ មាតារក្សា (ផ្ទៃ) អស់មួយឆ្នាំ ឬថយពីមួយឆ្នាំ ហើយប្រសូតបុត្រមក ព្រោះហេតុនោះ បានជាបណ្ឌិតហៅមាតានោះថា ជនយន្តីផង ជនេត្តីផង (អ្នកបង្កើតកូន)។ មាតាញ៉ាំងកូនដែលកំពុងយំឲ្យត្រេកអរ ដោយទឹកក្សីរផង ដោយការបំពេផង ដោយការឱបក្រសោបផង ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា តោសេន្តី (អ្នកញ៉ាំងកូនឲ្យត្រេកអរ)។ តពីនោះមក មាតាធ្វើនូវសេចក្តីស្រឡាញ់រាប់អាន ហើយក្រឡេកមើលទារកដែលនៅពុំទាន់ដឹងក្តី ក្នុងទីមានខ្យល់ និងកំដៅថ្ងៃដ៏ពន្លឹក ព្រោះហេតុនោះ បានជាបណ្ឌិតហៅថា បោសេន្តី (អ្នកចិញ្ចឹមកូន)។ ទ្រព្យណាខាងមាតាផង ទ្រព្យណាខាងបិតាផង មាតាក៏គ្រប់គ្រងទ្រព្យទាំងពីរចំណែកដើម្បីកូននោះ (ដោយបំណងថា ទ្រព្យនេះ) ត្រូវមានដល់កូនរបស់យើង។ មាតារមែងលំបាកដោយការបង្ហាត់បង្រៀនកូនដូច្នេះថា ម្នាលកូន (ឯងចូរកុំប្រមាទក្នុងរាជត្រកូលជាដើម) យ៉ាងនេះ ម្នាលកូន (ឯងចូរធ្វើការ) ឯណោះ។ កាលបើកូនមានវ័យចំរើនឡើងហើយ មាតា (បានដឹង) កូននោះប្រមាទក្នុងប្រពន្ធរបស់អ្នកដទៃក្នុងពេលអធ្រាត្រ ហើយមិនមកក្នុងវេលាល្ងាច ក៏រមែងលំបាកចិត្តដូច្នេះ។ សត្វដែលមាតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបំរើមាតា ប្រព្រឹត្តខុសក្នុងមាតានោះ តែងទៅកើតក្នុងនរក។ សត្វដែលបិតាចិញ្ចឹមដោយត្រដាបត្រដួសយ៉ាងនេះ ហើយមិនបំរើបិតា ប្រព្រឹត្តខុសក្នុងបិតានោះ តែងទៅកើតក្នុងនរក។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាក ព្រោះមិនបំរើមាតា។ យើងបានឮមកថា សូម្បីតែទ្រព្យរបស់កូនអ្នកចង់បានទ្រព្យ តែងវិនាសទៅវិញ ឬកូននោះ រមែងក្រីក្រលំបាកព្រោះមិនបំរើបិតា។ បណ្ឌិតបំរើមាតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗកាល។ បណ្ឌិតបំរើបិតា គប្បីបាននូវសុខនុ៎ះ គឺសេចក្តីត្រេកអររីករាយ ការសើចលេងសព្វៗ កាល។ ទាន ១ វាចាជាទីស្រឡាញ់ ១ ការប្រព្រឹត្តិជាប្រយោជន៍ក្នុងលោកនេះ ១ ភាពនៃបុគ្គលមានខ្លួនប្រព្រឹត្តស្មើក្នុងជេដ្ឋាបចាយនធម៌នោះៗ តាមសមគួរ ១។ សង្គហធម៌ទាំង ៤ នុ៎ះឯង រមែងប្រព្រឹត្តទៅក្នុងលោក ដូចជាភ្លៅនៃកង់រថដែលវិលទៅ បើសង្គហធម៌ទាំងនុ៎ះមិនមានទេ មាតាមិនត្រូវបាននូវសេចក្តីរាប់អាន និងការបូជា ព្រោះហេតុនៃកូន ទាំងបិតា ក៏មិនត្រូវបាននូវសេចក្តីរាប់អាន និងការបូជា ព្រោះហេតុនៃកូន។ ពួកបណ្ឌិត រមែងឃើញដោយល្អនូវសង្គហធម៌ទាំងនុ៎ះ ព្រោះហេតុនោះ បណ្ឌិតទាំងនោះ រមែងដល់នូវភាពជាធំ ទាំងជាអ្នកគួរសរសើរ។ មាតាបិតា ជាអ្នកអនុគ្រោះដល់ពួកសត្វ គឺបុត្រ បណ្ឌិតហៅថា ព្រហ្មផង បុព្វាចារ្យផង អាហុនេយ្យៈផង របស់កូនទាំងឡាយ។ ព្រោះហេតុនោះ បណ្ឌិតគប្បីនមស្ការ ធ្វើសក្ការៈចំពោះមាតាបិតានោះ ដោយបាយ ទឹក សំពត់ ទីដេក គ្រឿងអប់ ដោយការផ្ងូត និងការលាងជើង។ បណ្ឌិតទាំងឡាយ រមែងសរសើរនូវបុគ្គលនោះ ព្រោះតែការបំរើចំពោះមាតាបិតានោះ លុះបុគ្គលនោះ លះលោកនេះទៅ រមែងរីករាយក្នុងឋានសួគ៌។

ចប់សោណនន្ទជាតក ទី២។

ឧទ្ទាននៃសត្តតិនិបាតនោះ គឺ

រឿងព្រះរាជាប្រសើរក្នុងក្រុងកុសាវតី ក្នុងនិបាតដ៏ប្រសើរគំរប់ចិតសិប និងរឿងសោណតាបស និងនន្ទតាបសដ៏ប្រសើរ ក្នុងសូត្រគំរប់ចិតសិប។

ចប់ សត្តតិនិបាត។

# អសីតិនិបាតជាតក

CS sut.kn.jat.v21 | ភាគទី ៦១

(២១. អសីតិនិបាតោ)

## ចុល្លហំសជាតក ទី១

CS sut.kn.jat.533 | ភាគទី ៦១

(៥៣៣. ចូឡហំសជាតកំ (១))

[១៦៣] (រាជហង្សឈ្មោះធតរដ្ឋៈពោលថា) ម្នាលហង្សឈ្មោះសុមុខៈ ពួកបក្សី កាលមិនគយគន់មើល ហើរចេញទៅ អ្នកចូរទៅចុះ កុំប្រាថ្នា (នៅក្នុងទីនេះឡើយ ព្រោះថា) ភាពនៃអ្នកជាសំឡាញ់នឹងយើងដែលជាប់ចំណាង មិនមានទេ។

[១៦៤] (ហង្សសេនាបតីឈ្មោះសុមុខៈ ក្រាបបង្គំទូលថា) ទូលព្រះបង្គំជាខ្ញុំទៅក្តី មិនទៅក្តី ទូលព្រះបង្គំជាខ្ញុំមិនមែនមិនស្លាប់ដោយការទៅ ឬការមិនទៅនោះទេ ទូលព្រះបង្គំជាខ្ញុំចូលទៅរកព្រះអង្គដែលដល់នូវសេចក្តីសុខហើយ នឹងលះព្រះអង្គដែលដល់នូវសេចក្តីទុក្ខដូចម្តេចកើត។ សេចក្តីស្លាប់ជាមួយនឹងព្រះអង្គក្តី ការរស់នៅវៀរចាកព្រះអង្គក្តី សេចក្តីស្លាប់នោះប្រសើរជាង ទូលព្រះបង្គំជាខ្ញុំតែវៀរចាកព្រះអង្គហើយ រស់នៅ មិនប្រសើរសោះឡើយ។ បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំលះចោលព្រះអង្គដែលដល់ (នូវសេចក្តីទុក្ខ) យ៉ាងនេះដោយសភាវៈណា សភាវៈនោះ មិនមែនជាធម៌ទេ បពិត្រព្រះអង្គជាធំលើបក្សី ដំណើរណា របស់ព្រះអង្គ ដំណើរនោះទូលព្រះបង្គំជាខ្ញុំក៏គាប់ចិត្តដែរ។

[១៦៥] (រាជហង្ស...) ដំណើរដូចម្តេចរបស់ខ្ញុំ ដែលជាប់អន្ទាក់ហើយ ដទៃអំពីរោងគ្រួ ដំណើរនោះ ទៅជាពេញចិត្តដល់អ្នកដែលមានប្រាជ្ញា ជាអ្នកផុតអំពីអន្ទាក់ដូចម្តេច។ ម្នាលអ្នកជាបក្សី កាលបើយើងទាំងពីរនាក់អស់ជីវិតហើយ អ្នកឃើញនូវប្រយោជន៍ដូចម្តេចរបស់ខ្ញុំផង របស់អ្នកផង របស់ពួកញាតិដ៏សេសផង។ ម្នាលអ្នកមានស្លាបទាំងពីរដូចជាមាស ការលះបង់នូវជីវិតរបស់អ្នកណា ការលះបង់នូវជីវិតរបស់អ្នកនោះ ហាក់ដូចជាធ្វើក្នុងទីងងឹតដោយសេចក្តីល្ងិតល្ងង់ អ្នកកាលលះបង់នូវជីវិត ព្រោះគុណដែលមិនជាក់ច្បាស់ដូច្នោះ តើព្រោះឆ្លុះឃើញនូវប្រយោជន៍អ្វី។

[១៦៦] (ហង្សសេនាបតី...) បពិត្រព្រះអង្គដ៏ប្រសើរផុត ព្រះអង្គមិនជ្រាបនូវប្រយោជន៍ដែលធ្លាក់ចុះក្នុងធម៌ដូចម្តេច ដ្បិតធម៌ដែលពួកសត្វគោរពហើយ រមែងបង្ហាញនូវសេចក្តីចំរើនដល់សត្វទាំងឡាយ។ ទូលព្រះបង្គំជាខ្ញុំនោះ កាលឃើញនូវធម៌ផង នូវប្រយោជន៍ដែលកើតអំពីធម៌ផង ពិចារណាឃើញនូវសេចក្តីស្រឡាញ់ចំពោះព្រះអង្គផង បានជាមិនប្រាថ្នាជីវិតទេ។ មិត្តណា កាលរឭកឃើញនូវធម៌ ហើយមិនលះបង់មិត្រក្នុងកាលដែលមានសេចក្តីអន្តរាយ ព្រោះហេតុនៃជីវិត ធម៌របស់មិត្រនោះ ឈ្មោះថា ជាធម៌របស់សប្បុរសទាំងឡាយដោយពិត។

[១៦៧] (រាជហង្ស...) ធម៌នោះ អ្នកបានសន្សំហើយ ទាំងសេចក្តីស្រឡាញ់ចំពោះយើង ៗ ក៏បានដឹងច្បាស់ហើយ អ្នកចូរធ្វើតាមសេចក្តីប្រាថ្នារបស់យើងនុ៎ះ អ្នក គឺយើងបានអនុញ្ញាតហើយ ចូរទៅចុះ។ ម្នាលអ្នកបរិបូណ៌ដោយប្រាជ្ញា មួយទៀត ការបែកបាក់នៃពួកញាតិណាដែលយើងបានបិទបាំងហើយ ក្នុងកាលដែលប្រព្រឹត្តទៅយ៉ាងនេះ ការបែកបាក់នៃពួកញាតិនោះ អ្នកគួរបិទបាំងទុកឲ្យល្អចុះ។

[១៦៨] (អភិសម្ពុទ្ធគាថា) កាលដែលអរិយហង្សទាំងឡាយ ជាសត្វមានការប្រព្រឹត្តិដ៏ប្រសើរ កំពុងតែប្រឹក្សាគ្នាយ៉ាងនេះ ស្រាប់តែនាយនេសាទមកប្រាកដដូចជាសេចក្តីស្លាប់ ដែលប្រាកដដល់បុគ្គលឈឺ។ ហង្សទាំងពីរនោះ មានប្រយោជន៍ (ដល់គ្នានឹងគ្នា) យូរអង្វែងហើយ បានឃើញច្បាស់នូវសត្រូវ ក៏ទំនៅស្ងៀមទាំងពីរនាក់ មិនកក្រើកចាកទ្រនំឡើយ។ ព្រានព្រៃជាសត្រូវនៃសត្វស្លាប បានឃើញហង្សឈ្មោះសុមុខៈ និងរាជហង្សឈ្មោះធតរដ្ឋៈជាស្តេចនៃបក្សី កាលខិតចូលមករកគ្នាអំពីទីនោះ ៗ ក៏ស្ទុះទៅដោយប្រញាប់។ លុះនាយនេសាទនោះស្ទុះដោយប្រញាប់ ទៅជិតពួកបក្សីប្រសើរហើយ ក៏គិតថា សត្វហង្សទាំងពីរនេះជាប់ហើយ ញាប់ញ័រ។ ក៏នាយនេសាទបានឃើញសត្វហង្សមួយ ជាប់អន្ទាក់ហើយទំនៅ និងសត្វហង្សមួយទៀត ដែលមិនជាប់អន្ទាក់ ចូលមករកសត្វហង្សដែលជាប់អន្ទាក់ហើយទំនៅ សំឡឹងមើលនូវហង្សដែលមានទោស។ លំដាប់អំពីនោះទៅ នាយនេសាទនោះ មានសេចក្តីសង្ស័យ ក៏បានសួរនូវសត្វហង្សមានពណ៌ស មានកាយដ៏ធំ ជាអធិបតីលើហ្វូងនៃបក្សីថា សត្វហង្សដែលជាប់អន្ទាក់ដ៏ធំដល់ម្លោះ មិនធ្វើនូវទិស (ដើម្បីហើរទៅ) ដោយហេតុណា (ហេតុនោះ គួរហើយ) ម្នាលសត្វស្លាប ចុះអ្នក មិនជាប់អន្ទាក់ទេ ជាសត្វមានកំឡាំង ហេតុអ្វីក៏មិនហើរទៅ។ សត្វបក្សីនេះ ត្រូវជាអ្វីនឹងអ្នក អ្នករួច (អំពីអន្ទាក់ហើយ) ចូលមករកបក្សី ដែលជាប់អន្ទាក់វិញ បក្សីទាំងឡាយនាំគ្នាហើរចោលទៅអស់ហើយ ថ្វីក៏អ្នកក្រាញ់នៅតែម្នាក់ឯង។

[១៦៩] (ហង្សសេនាបតី...) បពិត្រនាយនេសាទជាសត្រូវនៃសត្វបក្សី ឯហង្សនោះ ជាព្រះរាជានៃខ្ញុំផង ជាសំឡាញ់ស្មើដោយជីវិតនៃខ្ញុំផង ខ្ញុំនឹងមិនលះបង់នូវហង្សនោះ ដរាបដល់សេចក្តីស្លាប់មកដល់។

[១៧០] (នាយនេសាទ...) ចុះហេតុអ្វី ហង្សនេះក៏មិនឃើញនូវអន្ទាក់ដែលគេដាក់ហើយ ដំណើរនេះហើយ ដែលជាដំណើរសម្រាប់ពួកសត្វធំៗ ពួកសត្វធំៗ គួរដឹងនូវសេចក្តីអន្តរាយ។

[១៧១] (ហង្សសេនាបតី...) កាលណាដែលសត្វជាអ្នកមានសេចក្តីវិនាស ក្នុងកាលជាទីអស់ទៅនៃជីវិត កាលនោះ សត្វនោះ សូម្បីចូលមកជិតដល់សំណាញ់ និងអន្ទាក់ ក៏នៅតែមិនដឹងឡើយ។

[១៧២] (នាយនេសាទ...) ម្នាលសត្វមានប្រាជ្ញាច្រើន មែនហើយ អន្ទាក់ទាំងឡាយ យើងបានដាក់ហើយជាច្រើន កាលបើសត្វមានជីវិតអស់ទៅយ៉ាងនេះ សត្វស្លាបទាំងឡាយ តែងចូលមកជាប់នឹងអន្ទាក់ដ៏កំបាំង។

[១៧៣] (ហង្សសេនាបតី...) សូមឲ្យការនៅរួមជាមួយនឹងអ្នកនេះ មានសុខជាកម្រៃ សូមអ្នកអនុញ្ញាតយើងខ្ញុំ សូមអ្នកឲ្យជីវិតដល់យើងខ្ញុំ។

[១៧៤] (នាយនេសាទ...) ឯងមិនជាប់ (អន្ទាក់) អញទេ ទាំងអញទៀតសោត ក៏មិនប្រាថ្នាសម្លាប់ឯងដែរ ចូរឯងទៅអំពីទីនេះតាមប្រាថ្នាយ៉ាងឆាប់ ហើយរស់នៅមិនមានទុក្ខអស់កាលជាអង្វែងចុះ។

[១៧៥] (ហង្សសេនាបតី...) ខ្ញុំប្រាសចាកជីវិតនៃបក្សីនោះហើយ មិនប្រាថ្នាជីវិតទេ។ បើអ្នកត្រេកអរដោយហង្សមួយ ចូរអ្នកលែងនូវហង្សនេះទៅ ចូរបរិភោគនូវខ្ញុំវិញចុះ។ យើងទាំងពីរអ្នកនោះ មានកំពស់ ទំហំ និងវ័យស្មើៗ គ្នា អ្នកមិនមែនសាបសូន្យចាកលាភទេ សូមអ្នកប្តូរយកខ្ញុំដោយហង្សនេះ។ ចូរអ្នកសង្កេតមើលដំណើរនេះចុះ សេចក្តីជាប់ចិត្តរបស់អ្នកចំពោះយើងទាំងឡាយ សូមលើកទុកសិន ចូរអ្នកយកអន្ទាក់ចងខ្ញុំមុនសិនចុះ រួចសឹមលែងស្តេចបក្សីជាខាងក្រោយ។ លាភរបស់អ្នកក៏នៅដដែលផង សេចក្តីអង្វរនេះក៏ឈ្មោះថាអ្នកបានធ្វើតាមផង សេចក្តីរាប់អានដោយរាជហង្សឈ្មោះធតរដ្ឋៈ គប្បីមានដល់អ្នក ដរាបដល់អស់ជីវិតផង។

[១៧៦] (នាយនេសាទ...) ពួកសត្វបក្សីជាច្រើន ដែលជាមិត្រអាមាត្យក្តី មាតាបិតាក្តី កូនប្រពន្ធក្តី ជាផៅពង្សក្តី ចូរចួបនូវរាជហង្សនេះដែលរួចហើយព្រោះអ្នក ហើរទៅអំពីទីនេះ។ ពួកមិត្ររបស់ពួកសត្វដទៃជាច្រើន ដែលប្រហែលគ្នានឹងមិត្ររបស់អ្នក ដូចអ្នកជាសំឡាញ់ស្មើជីវិតនឹងរាជហង្សឈ្មោះធតរដ្ឋៈនេះ មិនមានក្នុងទីនេះទេ។ ខ្ញុំនោះ បានលែងនូវរាជហង្សជាសំឡាញ់របស់អ្នក ព្រះរាជារបស់អ្នកចូរទៅតាមអ្នកចុះ អ្នកទាំងឡាយ ចូរហើរទៅអំពីទីនេះតាមប្រាថ្នាជាឆាប់ ហើយរុងរឿងក្នុងកណ្តាលពួកញាតិចុះ។

[១៧៧] (អភិសម្ពុទ្ធគាថា) ហង្សឈ្មោះសុមុខៈនោះ មានចិត្តត្រេកអរ ព្រោះម្ចាស់ផុតចាកចំណង ជាសត្វគោរពម្ចាស់ កាលពោលនូវវាចាដ៏ស្រួលដល់ត្រចៀក ទើបពោលថា បពិត្រនាយនេសាទ យើងត្រេកអរព្រោះបានឃើញនូវស្តេចបក្សី ដែលរួចចាកអន្ទាក់ក្នុងថ្ងៃនេះយ៉ាងណា លោកចូរត្រេកអរជាមួយនឹងពួកញាតិទាំងអស់យ៉ាងនោះចុះ។

[១៧៨] លោកចូរមកនេះ ខ្ញុំប្រៀនប្រដៅលោកឲ្យបានលាភ រាជហង្សឈ្មោះធតរដ្ឋៈនេះ ឥតឃើញសេចក្តីអាក្រក់របស់លោកតិចតួចទេ។ លោកចូរ (នាំយើងខ្ញុំ) ទៅក្នុងរាជបុរីជាឆាប់ ហើយបង្ហាញចំពោះព្រះរាជា នូវយើងខ្ញុំទាំងពីរនាក់ ដែលមិនជាប់ចំណង មានសភាពជាប្រក្រតីឋិតនៅលើអម្រែកទាំងពីរខាង។ (លោកក្រាបទូលថា) បពិត្រមហារាជ ហង្សទាំងពីរនេះ កើតក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះ ជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះ ជាសេនាបតី។ ព្រះរាជា ជាអធិបតីលើពួកជន ទ្រង់បានទតឃើញរាជហង្សនេះហើយ មុខជាទ្រង់មានព្រះរាជហឫទ័យត្រេកអររីករាយ នឹងប្រទាននូវទ្រព្យជាច្រើនដល់អ្នកឥតសង្ស័យ។

[១៧៩] នាយនេសាទ លុះបានស្តាប់ពាក្យហង្សឈ្មោះសុមុខៈនោះហើយ ក៏បង្ហើយកិច្ចការ រួច (នាំហង្សទាំងពីរ) ទៅខាងក្នុងបុរីយ៉ាងឆាប់ ហើយបង្ហាញចំពោះព្រះរាជា នូវហង្សទាំងពីរដែលមិនជាប់អន្ទាក់ មានសភាពតាមប្រក្រតី ឋិតនៅលើអម្រែកទាំងពីរខាងថា បពិត្រមហារាជ ហង្សទាំងពីរនេះ កើតក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះ ជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះ ជាសេនាបតី។

[១៨០] (ព្រះរាជា...) ហង្សទាំងនេះ មកឋិតនៅក្នុងកណ្តាប់ដៃរបស់អ្នក តើដោយហេតុដូចម្តេច អ្នកជានាយព្រាន បានដល់នូវភាពជាធំជាងសត្វហង្សដ៏ធំៗ ទាំងឡាយ ក្នុងទីនេះ ដោយហេតុដូចម្តេច។

[១៨១] (ព្រានព្រៃ...) បពិត្រព្រះអង្គជាធំជាងជន ទូលព្រះបង្គំជាខ្ញុំ ស្គាល់នូវកន្លែងជាទីប្រជុំនៃពួកសត្វស្លាបណាៗ ជាទីធ្វើឲ្យអស់ទៅនៃជីវិតនៃពួកសត្វស្លាប ទូលព្រះបង្គំជាខ្ញុំ បានដាក់អន្ទាក់ទាំងនេះលើភក់ទាំងឡាយ (ក្នុងកន្លែងនោះៗ)។ រាជហង្ស បានមកជាប់អន្ទាក់ប្រាកដដូច្នោះ ចំណែកហង្សជាសេនាបតីនេះ មិនជាប់អន្ទាក់ទេ តែចូលទៅទំជិតនឹងរាជហង្សនោះ ហើយបាននិយាយនឹងទូលព្រះបង្គំជាខ្ញុំ។ ហង្សជាសេនាបតីនេះ (បានធ្វើ) នូវអំពើដែលពួកជនមិនមែនជាអរិយៈធ្វើបានដោយក្រ ជាសត្វប្រកបដោយធម៌ សង្វាតក្នុងប្រយោជន៍របស់ម្ចាស់ បានប្រកាសនូវភាពនៃខ្លួនជាសត្វដ៏ឧត្តម។ ហង្សជាសេនាបតីនេះ ជាសត្វគួរនឹងរស់នៅ តែស៊ូលះបង់នូវជីវិតនៃខ្លួន កាលសរសើរ (នូវគុណនៃម្ចាស់) ហើយទំនើ បានសុំនូវជីវិតម្ចាស់។ ទូលព្រះបង្គំជាខ្ញុំ បានស្តាប់ពាក្យនោះរបស់ហង្សសេនាបតីនោះហើយ ទើបដល់នូវសេចក្តីជ្រះថ្លា លំដាប់នោះ ទូលព្រះបង្គំបានដោះរាជហង្សនោះចាកអន្ទាក់ ទាំងបានអនុញ្ញាតឲ្យទៅដោយស្រួល។ ហង្សជាសេនាបតីនោះ ក៏មានចិត្តរីករាយ ព្រោះម្ចាស់បានរួចហើយ ជាសត្វគោរពម្ចាស់ កាលនឹងពោលវាចាដ៏ស្រួលដល់ត្រចៀក បានពោលយ៉ាងនេះថា បពិត្រព្រានព្រៃ ថ្ងៃនេះ ខ្ញុំរីករាយ ព្រោះបានឃើញស្តេចបក្សីដែលរួចហើយយ៉ាងណា សូមឲ្យលោករីករាយ ជាមួយនឹងពួកញាតិទាំងអស់យ៉ាងនោះ។ លោកចូរមកនេះ ខ្ញុំនឹងប្រៀនប្រដៅឲ្យបាននូវលាភ រាជហង្សឈ្មោះធតរដ្ឋៈនេះ ឥតឃើញសេចក្តីអាក្រក់តិចតួចរបស់លោកទេ។ លោកចូរនាំយើងខ្ញុំទៅក្នុងបុរីជាឆាប់ ហើយបង្ហាញព្រះរាជានូវយើងខ្ញុំទាំងពីរនាក់ ដែលមិនជាប់ចំណង មានសភាពជាប្រក្រតី ឋិតនៅលើអម្រែកទាំងពីរខាង។ (លោកក្រាបទូលថា) បពិត្រមហារាជ ហង្សទាំងនេះ កើតនៅក្នុងត្រកូលធតរដ្ឋៈ ជាអធិបតីលើពួកហង្ស ឯហង្សនេះ ជាព្រះរាជារបស់ហង្សទាំងឡាយ ហង្សមួយទៀតនេះ ជាសេនាបតី។ ព្រះរាជាជាធំលើពួកជន បានទតឃើញរាជហង្សនេះហើយ មុខជានឹងមានព្រះទ័យត្រេកអរ សោមនស្សរីករាយ និងព្រះរាជទាននូវទ្រព្យដ៏ច្រើន ដល់លោកដោយពិត។ ទូលព្រះបង្គំជាខ្ញុំ បាននាំហង្សទាំងពីរនេះមក តាមពាក្យហង្សជាសេនាបតីនេះយ៉ាងនេះ ព្រោះថា ទូលព្រះបង្គំជាខ្ញុំ បានបើកលែងហង្សទាំងពីរនេះ ក្នុងទីនោះរួចទៅហើយ។ សត្វបក្សីនោះ ជាទ្វិជាត មានដំណើរយ៉ាងនេះ ប្រកបដោយធម៌ដ៏ក្រៃលែង ព្រោះថា សត្វបក្សីនោះ បានញុំាងចិត្តដ៏ទន់ឲ្យកើតដល់ព្រានព្រៃ ប្រាកដដូចជាទូលព្រះបង្គំជាខ្ញុំ។ បពិត្រព្រះសម្មតិទេព ទូលព្រះបង្គំជាខ្ញុំមិនឃើញដង្វាយដទៃ ក្នុងស្រុកនៃព្រានបក្សីដ៏សមគួរដល់ព្រះអង្គឡើយ បពិត្រព្រះអង្គជាធំជាងពួកមនុស្ស សូមព្រះអង្គទតមើលនូវដង្វាយនោះ។

[១៨២] រាជហង្សបានឃើញព្រះរាជា ទ្រង់គង់នៅលើតាំងជាវិការៈនៃមាសដ៏ស្អាត កាលនឹងពោលនូវវាចាឲ្យស្រួលដល់ត្រចៀក បានពោលថា ព្រះអង្គបានសេចក្តីសុខស្រួលទេឬ ព្រះអង្គមិនមានជម្ងឺអ្វីទេឬ មួយទៀត ព្រះអង្គគ្រប់គ្រងដែនដ៏ធំទូលាយនេះ តាមធម៌ដែរឬ។

[១៨៣] (ព្រះរាជា...) ម្នាលហង្ស យើងមានសេចក្តីសុខស្រួលទេ ម្នាលហង្ស យើងមិនមានជម្ងឺអ្វីទេ ម្យ៉ាងទៀត យើងគ្រប់គ្រងដែនដ៏ធំទូលាយនេះ តាមធម៌ហើយ។

[១៨៤] (រាជហង្ស...) កំហុសបន្តិចបន្តួចរបស់ព្រះអង្គ មិនមានក្នុងពួកអាមាត្យទេឬ ពួកអាមាត្យទាំងនោះ មិនអាល័យជីវិតព្រោះប្រយោជន៍ទាំងឡាយរបស់ព្រះអង្គទេឬ។

[១៨៥] (ព្រះរាជា...) កំហុសបន្តិចបន្តួចរបស់យើង មិនមានក្នុងពួកអាមាត្យទេ អាមាត្យទាំងនោះ មិនអាល័យជីវិតព្រោះប្រយោជន៍ទាំងឡាយរបស់យើងទេ។

[១៨៦] (រាជហង្ស...) អគ្គមហេសីរបស់ព្រះអង្គដែលមានជាតិស្មើគ្នា ជាស្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ររូប និងយស លុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គដែរឬ។

[១៨៧] (ព្រះរាជា...) អគ្គមហេសីរបស់យើង ដែលមានជាតិស្មើគ្នា ជាស្រីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ររូប និងយស លុះអំណាចសេចក្តីប្រាថ្នារបស់យើង។

[១៨៨] អ្នកដ៏ចំរើន លុះក្នុងកណ្តាប់ដៃសត្រូវដ៏ធំ ដល់នូវសេចក្តីទុក្ខដ៏ធំ ក្នុងអន្តរាយទីមួយនោះដែរឬ។ ព្រានព្រៃបានស្ទុះចូលទៅសំពងអ្នកដោយដម្បងដែរឬ ដ្បិតអំពើយ៉ាងនេះ តែងមានជាធម្មតា ដល់ពួកអ្នកធ្វើអំពើអាក្រក់ក្នុងខណៈនោះ។

[១៨៩] (រាជហង្ស...) បពិត្រមហារាជ ទូលព្រះបង្គំជាខ្ញុំបានសេចក្តីក្សេមក្សាន្តទេ កាលបើមានហេតុយ៉ាងនេះ ព្រានព្រៃនេះ មិនដល់ (នូវភាពនៃខ្លួន) ដូចជាសត្រូវចំពោះទូលព្រះបង្គំជាខ្ញុំតិចតួចឡើយ។ ព្រានព្រៃនេះ ថយបន្តិចៗ ក៏បានសាកសួរទូលព្រះបង្គំជាមុន គ្រានោះហង្សឈ្មោះសុមុខៈ ជាបណ្ឌិតបាននិយាយតបវិញ។ ព្រានព្រៃបានស្តាប់ពាក្យហង្សឈ្មោះសុមុខៈនោះហើយ ក៏បានដល់នូវសេចក្តីជ្រះថ្លា លំដាប់នោះ ព្រានព្រៃបានដោះទូលព្រះបង្គំជាខ្ញុំអំពីអន្ទាក់ ទាំងបានអនុញ្ញាតឲ្យទៅដោយស្រួលផង។ ដំណើរមកក្នុងសំណាក់នៃព្រះអង្គនេះ គឺហង្សឈ្មោះសុមុខៈ ចង់បានទ្រព្យដល់ព្រានព្រៃនុ៎ះ បានគិតហើយដើម្បីប្រយោជន៍ដល់ព្រានព្រៃនុ៎ះ។

[១៩០] (ព្រះរាជា...) ដំណើរមករបស់អ្នកដ៏ចំរើនទាំងឡាយ ជាការស្រួលណាស់ហើយ យើងមានចិត្តត្រេកអរព្រោះការបានឃើញអ្នក

ឯព្រានព្រៃនេះ ចូរបានទ្រព្យជាច្រើនដរាបទល់អស់ចំណង់ចុះ។

[១៩១] (អភិសម្ពុទ្ធគាថា) ព្រះរាជាជាធំជាងមនុស្ស បានញ៉ាំងនាយនេសាទឲ្យឆ្អែតស្កប់ស្កល់ដោយភោគៈតាមដំណើរដែលសត្វបក្សីហង្សនិយាយនូវពាក្យដ៏សុខស្រួលដល់ត្រចៀក បានពោលហើយ។

[១៩២] (ព្រះរាជា...) អំណាច (របស់យើង) ប្រព្រឹត្តទៅអស់ទីជាទីទ្រង់ទុកនូវធម៌ (ច្បាប់) ណា អ្នកដ៏ចំរើន ចូរជាធំក្នុងទីទាំងអស់នោះ សូម្បីតិចតួច ចូរគ្រប់គ្រងនូវទីជាទីប្រាថ្នាចុះ។ ម្យ៉ាងទៀត ទ្រព្យណា ដទៃអាចសម្រេចដើម្បីនឹងឲ្យទាន ឬជាគ្រឿងប្រើប្រាស់ យើងឲ្យនូវទ្រព្យនោះដល់អ្នក យើងនឹងលះនូវភារៈជាធំដល់អ្នក។

[១៩៣] ប្រសិនបើហង្សឈ្មោះសុមុខៈ ជាបណ្ឌិត បរិបូណ៌ដោយប្រាជ្ញានេះ ពោលនូវពាក្យដល់យើងតាមសេចក្តីប្រាថ្នា ពាក្យនោះ ជាទីស្រឡាញ់របស់យើងក្រៃពេក។

[១៩៤] (ហង្សសេនាបតី...) បពិត្រព្រះមហារាជ ទូលព្រះបង្គំជាខ្ញុំ ដូចជានាគរាជ (ចូលទៅ) កាន់ចន្លោះ (នៃភ្នំ) មិនអាចនឹងក្រាបទូលតបបានទេ ដ្បិតការក្រាបទូលតបនោះ មិនមែនជាច្បាប់សម្រាប់ទូលព្រះបង្គំជាខ្ញុំឡើយ។ រាជហង្សប្រសើរបំផុតជាងពួកទូលព្រះបង្គំជាខ្ញុំនោះផង ព្រះអង្គជាសត្វដ៏ឧត្តម រក្សាផែនដីជាធំជាងមនុស្សផង គួរទូលព្រះបង្គំជាខ្ញុំ បូជាដោយហេតុដ៏ច្រើន។ បពិត្រព្រះអង្គជាធំជាងមនុស្ស កាលដែលការវិនិច្ឆ័យកំពុងប្រព្រឹត្តទៅ អាមាត្យជាអ្នកបំរើ មិនគប្បីក្រាបទូលក្នុងចន្លោះនៃព្រះអង្គទាំងពីរកំពុងមានព្រះបន្ទូលនោះឡើយ។

[១៩៥] (ព្រះរាជា...) បានឮថា នាយព្រាន បានសរសើរអ្នកដោយធម៌ថា អ្នកជាបក្សីបណ្ឌិត ប្រាជ្ញាបែបនេះ មិនគប្បីមានដល់សត្វដែលមានអត្តភាពមិនទាន់សម្រេច។ អ្នកមានប្រក្រតីដ៏ប្រសើរយ៉ាងនេះ ជាសត្វខ្ពង់ខ្ពស់យ៉ាងនេះ សត្វទាំងឡាយទាំងប៉ុន្មានដែលយើងបានឃើញហើយ យើងមិនដែលឃើញនូវសត្វដទៃបែបនេះ។ យើងត្រេកអរដោយបានឃើញអ្នកទាំងពីរជាដំបូងផង ដោយពាក្យដ៏ពីរោះផង នុ៎ះជាសេចក្តីពេញចិត្តរបស់យើង យើងគប្បីចូបនូវអ្នកទាំងពីរអស់កាលជាអង្វែង។

[១៩៦] (រាជហង្ស...) អំពើណា ដែលត្រូវធ្វើចំពោះមិត្តដ៏ប្រសើរ អំពើនោះ ព្រះអង្គបានធ្វើហើយចំពោះទូលព្រះបង្គំទាំងពីរ សេចក្តីរាប់អានណា របស់ព្រះអង្គចំពោះទូលព្រះបង្គំទាំងពីរ ទូលព្រះបង្គំទាំងពីរឃ្លាតហើយចាកព្រះអង្គ ដោយឥតសង្ស័យ។ សេចក្តីទុក្ខងណោះ បានកើតឡើងហើយក្នុងបក្សីជាច្រើន ព្រោះមិនឃើញនូវទូលព្រះបង្គំជាខ្ញុំទាំងពីរក្នុងចន្លោះនៃពួកញាតិជាច្រើនដោយពិត។ យើងទាំងពីរដែលព្រះអង្គអនុញ្ញាតហើយ ដើម្បីកំចាត់បង់នូវសេចក្តីសោករបស់បក្សីទាំងនោះ បពិត្រព្រះអង្គជាអ្នកទូន្មាននូវសត្រូវ ទូលព្រះបង្គំជាខ្ញុំទាំងពីរ សូមធ្វើប្រទក្សិណព្រះអង្គ ហើយទៅចួបនឹងពួកញាតិ។ ទូលព្រះបង្គំជាខ្ញុំ បានសេចក្តីត្រេកអរដ៏ធំទូលាយ ព្រោះបានជួបព្រះអង្គដោយពិត ម្យ៉ាងទៀត ប្រយោជន៍ធំនេះ កើតមានព្រោះតែសេចក្តីស្និទ្ធស្នាលចំពោះញាតិ។

[១៩៧] (អភិសម្ពុទ្ធគាថា) លុះរាជហង្សឈ្មោះធតរដ្ឋៈ (និងហង្សឈ្មោះសុមុខៈ) បានពោលពាក្យនេះ ចំពោះព្រះរាជាជាធំលើជនរួចហើយ ក៏ហើរសំដៅទៅរកពួកញាតិ អាស្រ័យនូវសន្ទុះដ៏ឧត្តម។ សត្វហង្សទាំងឡាយ បានឃើញនូវហង្សដ៏ឧត្តមទាំងពីរនោះមិនមានរោគមកដល់ហើយ ក៏បានធ្វើនូវសម្លេងថា កេកា ៗ សូរសំឡេងយ៉ាងខ្លាំង ក៏កើតមានឡើង។ បក្សីទាំងនោះ មានសេចក្តីត្រេកអរព្រោះម្ចាស់រួចហើយ ជាសត្វគោរពចំពោះម្ចាស់ ជាសត្វបាននូវទីពឹង ហើយហើរក្រឡឹងជុំវិញ។

[១៩៨] ប្រយោជន៍ទាំងអស់ របស់ពួកជនអ្នកមានមិត្ត រមែងសម្រេចសេចក្តីសុខយ៉ាងនេះ ដូចជាហង្សឈ្មោះធតរដ្ឋៈ និងហង្សឈ្មោះសុមុខៈ បានហើរចូលទៅរកពួកញាតិដូច្នោះ។

ចប់ ចុល្លហង្សជាតក ទី១។

## មហាហំសជាតក ទី២

CS sut.kn.jat.534 | ភាគទី ៦១

### (៥៣៤. មហាហំសជាតកំ (២))

[១៩៩] (រាជហង្សពោលថា) ហង្សទាំងឡាយនេះ ត្រូវភ័យគំរាមហើយ នាំគ្នាហើរទៅ ម្នាលសុមុខៈ អ្នកមានស្បែកដូចមាស មានសម្បុរដូចមាស អ្នកចូរហើរទៅតាមប្រាថ្នាចុះ។ ពួកបក្សីជាញាតិបានលះចោលនូវយើង ដែលលុះអំណាចនៃអន្ទាក់តែម្នាក់ឯង មិនអាល័យហើរទៅ អ្នកក្រាញនៅតែម្នាក់ឯងដូចម្តេច។ ម្នាលអ្នកដ៏ប្រសើរជាងពួកបក្សី អ្នកចូរហើរទៅចុះ ព្រោះថា ភាពជាសំឡាញ់នឹងយើងដែលជាប់ចំណង មិនមានទេ អ្នកកុំធ្វើខ្លួនឲ្យសាបសូន្យចាកសេចក្តីសុខឡើយ ម្នាលសុមុខៈ អ្នកចូរហើរទៅតាមប្រាថ្នាចុះ។

[២០០] (ហង្សសេនាបតីឈ្មោះសុមុខៈពោលថា) បពិត្រព្រះបាទធតរដ្ឋៈ ទូលព្រះបង្គំជាខ្ញុំ សូម្បីសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏មិនគប្បីលះចោលព្រះអង្គ ជីវិត ឬសេចក្តីស្លាប់របស់ទូលព្រះបង្គំជាខ្ញុំ នឹងមានជាមួយព្រះអង្គ។ បពិត្រព្រះបាទធតរដ្ឋៈ ទូលព្រះបង្គំជាខ្ញុំ សូម្បីសេចក្តីទុក្ខគ្របសង្កត់ហើយ ក៏មិនគប្បីលះចោលព្រះអង្គ ទាំងព្រះអង្គ ក៏មិនគួរប្រកបទូលព្រះបង្គំជាខ្ញុំ ក្នុងអំពើមិនប្រសើរទេ។ ទូលព្រះបង្គំជាខ្ញុំ ជាកុមារមានវ័យស្មើគ្នា ជាសំឡាញ់នឹងព្រះអង្គ ឋិតនៅក្នុងអំណាចចិត្តរបស់ព្រះអង្គ ដែលជាចិត្តប្រព្រឹត្តទៅដោយប្រពៃ បពិត្រព្រះអង្គដ៏ប្រសើរខ្ពង់ខ្ពស់ជាងពួកនៃហង្ស ទូលព្រះបង្គំជាខ្ញុំ ប្រាកដជាសេនាបតីរបស់ព្រះអង្គ លុះទូលព្រះបង្គំជាខ្ញុំហើរទៅអំពីទីនេះ នឹងថ្លែងសេចក្តីក្នុងកណ្តាលញាតិដោយប្រការដូចម្តេច បពិត្រព្រះអង្គដ៏ប្រសើរជាងពួកបក្សី ទូលព្រះបង្គំលះចោលព្រះអង្គ ហើយទៅអំពីទីនេះ នឹងប្រាប់ (ដំណឹង) របស់ព្រះអង្គដូចម្តេច ទូលព្រះបង្គំនឹងលះបង់ជីវិតក្នុងទីនេះ មិនអាចនឹងធ្វើអំពើមិនប្រសើរទេ។

[២០១] (រាជហង្ស...) ម្នាលសុមុខៈ នុ៎ះជាធម៌ (របស់បោរាណកបណ្ឌិតទាំងឡាយ) ព្រោះថា អ្នកឋិតនៅក្នុងគន្លងរបស់ជនដ៏ប្រសើរ មិនអាចលះបង់នូវយើងដែលជាម្ចាស់ផង ជាសំឡាញ់ផង។ ដ្បិតថា កាលយើងសំឡឹងមើលអ្នក សេចក្តីភ័យក៏មិនកើតសោះទេ អ្នកបានញ៉ាំងយើង ដែលមានសភាពយ៉ាងនេះ ឲ្យបាននូវជីវិត។

[២០២] (អភិសម្ពុទ្ធគាថា) កាលដែលហង្សដ៏ប្រសើរ (ពីរ) មានការប្រព្រឹត្តិដ៏ប្រសើរ កំពុងប្រឹក្សាគ្នា យ៉ាងនេះដូច្នេះ នាយនេសាទកាន់ដម្បងប្រញាប់មកដល់ភ្លាម។ ហង្សឈ្មោះសុមុខៈ លុះបានឃើញនាយនេសាទនោះមកដល់ ក៏ឋិតនៅខាងមុខរាជហង្ស ហើយលួងលោមរាជហង្សដែលកំពុងភ័យ រួចបានស្រែកថា បពិត្រព្រះអង្គដ៏ប្រសើរជាងសត្វស្លាប ព្រះអង្គកុំភ័យឡើយ ព្រោះថាបក្សីទាំងឡាយប្រហែលព្រះអង្គ រមែងមិនភ័យទេ ទូលព្រះបង្គំជាខ្ញុំ នឹងប្រកបសេចក្តីព្យាយាមដ៏សមគួរ ដែលអាស្រ័យនូវធម៌ ព្រះអង្គនឹងរួចចាកអន្ទាក់ជាឆាប់ ដោយសេចក្តីព្យាយាមនោះមិនខាន។

[២០៣] នាយនេសាទ បានឮសុភាសិតរបស់ហង្សឈ្មោះសុមុខៈនោះហើយ កំព្រឹរោម បង្អោននូវអញ្ជលី ចំពោះហង្សឈ្មោះសុមុខៈនោះថា អ្នកជាបក្សីពោលនូវភាសារបស់មនុស្ស ពោលពាក្យដ៏ប្រសើរ បញ្ចេញនូវវាចាជារបស់មនុស្ស ដែលអញមិនធ្លាប់ឮ មិនធ្លាប់ឃើញ។ បក្សីនេះត្រូវជាអ្វីនឹងអ្នក អ្នកជាសត្វរួចហើយ ចូលមករកសត្វជាប់ ពួកបក្សីហើរចោលអស់ទៅហើយ ម្តេចក៏អ្នកក្រាញនៅតែម្នាក់ឯង។

[២០៤] (ហង្សសេនាបតី...) ឱព្រានព្រៃជាសត្រូវនឹងបក្សី ឯរាជហង្សនោះជាព្រះរាជារបស់ខ្ញុំ ខ្ញុំជាសេនាបតីរបស់រាជហង្សនោះ ខ្ញុំមិនអាចលះចោលស្តេចបក្សីនោះ ក្នុងកាលមានសេចក្តីអន្តរាយទេ។ ព្រះរាជារបស់ខ្ញុំនេះ ជាម្ចាស់នៃពួកហង្សដ៏ច្រើន កុំដល់នូវសេចក្តីវិនាសតែម្នាក់ឯងឡើយ បពិត្រនាយនេសាទជាសំឡាញ់ ព្រោះថា រាជហង្សនេះជាម្ចាស់ ខ្ញុំតែងត្រេកអររីករាយ (ក្នុងសំណាក់រាជហង្សនោះ)។

[២០៥] (ព្រានព្រៃ...) ម្នាលសត្វហង្ស អ្នកណា បានគោរពដុំអាហារ (ដែលបានអំពីម្ចាស់) អ្នកនោះឈ្មោះថា ប្រព្រឹត្តធម៌ដ៏ប្រសើរ យើងនឹងលែងនូវម្ចាស់របស់អ្នកនោះ អ្នកទាំងពីរ ចូរទៅតាមស្រួលចុះ។

[២០៦] (ហង្សសេនាបតី...) នែសំឡាញ់ បើលោកដាក់អន្ទាក់ពួកហង្ស និងបក្សីដ៏សេស ដោយសេចក្តីព្យាយាមរបស់ខ្លួន យើងខ្ញុំនឹងទទួលនូវអភយទាននេះ របស់លោក បើលោកមិនដាក់អន្ទាក់ពួកហង្ស និងបក្សីដ៏សេស ដោយសេចក្តីព្យាយាមរបស់ខ្លួនទេ បពិត្រនាយនេសាទ លោកមិនមែនជាធំ កាលលែងនូវយើងខ្ញុំ ឈ្មោះថា ធ្វើនូវការលួច។

[២០៧] លោកជាបុគ្គលស៊ីឈ្នួលរបស់ព្រះរាជាណា លោកចូរនាំយើងខ្ញុំ ឲ្យដល់ទៅព្រះរាជានោះតាមប្រាថ្នាចុះ ព្រះរាជាព្រះនាមសំយមៈ នឹងធ្វើតាមគាប់ព្រះទ័យក្នុងព្រះរាជនិវេសន៍នោះ។

[២០៨] (អភិសម្ពុទ្ធគាថា) លុះហង្សឈ្មោះសុមុខៈ និយាយយ៉ាងនេះហើយ នាយនេសាទ ក៏យកដៃស្ទួយនូវហង្សទាំងពីរ ដែលមានសម្បុរ និងស្បែកដូចមាស ហើយដាក់ទៅក្នុងទ្រុង។ ព្រានព្រៃបាននាំយកបក្សីឈ្មោះសុមុខៈ ១ ឈ្មោះធតរដ្ឋៈ ១ ទាំងពីរ មានសម្បុរដ៏ភ្លឺថ្លែក ទំនៅក្នុងទ្រុងនោះហើយចៀសចេញទៅ។

[២០៩] រាជហង្សឈ្មោះធតរដ្ឋៈ ដែលព្រានព្រៃកំពុងនាំទៅ បានពោលពាក្យនេះ នឹងហង្សឈ្មោះសុមុខៈថា ម្នាលសុមុខៈ ខ្ញុំខ្លាច (សេចក្តីស្លាប់) នៃនាងបក្សីឈ្មោះសុហេមា ដែលមានសម្បុរដូចមាស មានភ្លៅប្រកបដោយលក្ខណៈខ្លាំងណាស់ តែនាងសុហេមាបានដឹងថា គេសម្លាប់នូវយើងទាំងពីរហើយ មុខជានឹងសម្លាប់នូវខ្លួនដែរ។ ម្នាលសុមុខៈ នាងបក្សីឈ្មោះសុហេមា ជាធីតានៃបាកហង្ស ដែលមានស្បែកល្អដូចមាស ជាសត្វកំព្រា ទួញយំដោយពិត ដូចជាក្រៀលញី ទួញយំប្របឆ្នេរសមុទ្រដូច្នោះ។

[២១០] (ហង្សសេនាបតី...) ព្រះអង្គជាធំជាងហង្ស មានគុណប្រមាណមិនបាន ជាម្ចាស់នៃហ្វូងហង្សជាច្រើនយ៉ាងនេះហើយ សោកស្តាយនូវមេហង្សមួយ ការយំនេះ ហាក់ដូចជាមិនសមគួរដល់ព្រះអង្គដែលមានប្រាជ្ញាឡើយ។ ព្រះអង្គសោកស្តាយ ព្រោះតែស្ត្រីទាំងឡាយ ធម្មតា ស្ត្រីទាំងឡាយដូចជាខ្យល់ក្ងួចយកនូវក្លិនទាំងល្អ ទាំងអាក្រក់ទាំងពីរ ឬដូចជាក្មេងល្ងង់ ចាប់យកផ្លែឈើទាំងខ្ចីទាំងទុំពុំនោះសោត ដូចមនុស្សខ្វាក់ ជាអ្នកស្រេកឃ្លាន កាន់យកអាមិសៈ (ទាំងល្អ ទាំងអាក្រក់)។ ព្រះអង្គមិនដឹងនូវការវិនិច្ឆ័យក្នុងប្រយោជន៍ទាំងឡាយ ដូចជាមនុស្សល្ងង់ ប្រាកដដល់ទូលព្រះបង្គំ លុះដល់កាលជាទីស្លាប់ នៅតែមិនដឹងអំពើដែលគួរធ្វើ និងមិនគួរធ្វើឡើយ។ ព្រះអង្គជាបុគ្គលឆ្កួតពាក់កណ្តាល និយាយផ្តេសផ្តាស ព្រោះថា ព្រះអង្គសំគាល់នូវស្ត្រីទាំងឡាយថាប្រសើរបំផុត ព្រោះថា ស្ត្រីទាំងនេះជាសាធារណៈដល់ជនច្រើន ដូចជារោងសុរា ជាសាធារណៈដល់ពួកអ្នកលេង។ មួយទៀត ស្ត្រីទាំងនេះ មានមាយាដូចជាថ្ងៃបណ្តើរកូន ជាទីសោយសោក ជាទីកើតនៃរោគ ជាទីឧបទ្រព ស្ត្រីទាំងនេះ មានអធ្យាស្រ័យដ៏រឹងរូស ជាចំណងសម្រាប់ចង ជាអន្ទាក់នៃសេចក្តីស្លាប់ ជាគុហាសម្រាប់នៅ (របស់មច្ចុរាជ) បុរសណា ទុកចិត្តក្នុងស្ត្រីទាំងនោះ បណ្តាបុរសទាំងឡាយ បុរសនោះឈ្មោះថា បុរសថោកទាប។

[២១១] (រាជហង្ស...) (វត្ថុ គឺស្ត្រី) ណា ដែលពួកជនអ្នកចំរើនដោយប្រាជ្ញា បញ្ញត្តហើយ បុគ្គលណា គួរតិះដៀលនូវស្ត្រីនោះបាន ធម្មតាស្ត្រីទាំងឡាយមានគុណច្រើន ហើយកើតឡើងក្នុងលោក (មុនគេ)។ ល្បែងគេតាំងទុកក្នុងស្ត្រីទាំងនោះ សេចក្តីត្រេកអរក៏តាំងនៅក្នុងស្ត្រីទាំងនោះដែរ ពូជទាំងឡាយរមែងលូតលាស់ឡើងក្នុងស្ត្រីទាំងនោះ គឺពួកសត្វទាំងអស់ តែងកើត (ត្រូវអាស្រ័យស្ត្រីទាំងនោះ) បុរសដូចម្តេច ប្តូរជីវិតដោយជីវិតហើយ គប្បីនឿយណាយក្នុងស្ត្រីទាំងនោះ។ ម្នាលសុមុខៈ អ្នកឯងហ្នឹងហើយ មិនមែនជាអ្នកដទៃ រមែងប្រកបក្នុងប្រយោជន៍ចំពោះពួកស្ត្រី ភ័យកើតឡើងដល់អ្នកក្នុងថ្ងៃនេះ គំនិតរបស់អ្នកក៏កើតឡើងដោយសេចក្តីភ័យ។ ជនទាំងអស់ ដល់នូវសេចក្តីសង្ស័យ ក្នុងជីវិត ហើយជាអ្នករន្ធត់ ប្រឹងអត់ទ្រាំនូវសេចក្តីខ្លាច ចំណែកពួកបណ្ឌិត ជាអ្នកឋិតនៅក្នុងទីដ៏ប្រសើរ តែងប្រកបក្នុងប្រយោជន៍ដែលគេប្រកបបានដោយក្រ។ ព្រះរាជាទាំងឡាយ តែងប្រាថ្នានូវមន្ត្រីដែលមានសេចក្តីក្លៀវក្លា ដើម្បីប្រយោជន៍ការពារនូវអន្តរាយនេះ ព្រោះមន្ត្រីដែលក្លៀវក្លា រមែងឃាត់នូវសេចក្តីអន្តរាយ និងការពារនូវខ្លួនបាន។ ពួកពិសេសរបស់ព្រះរាជា កុំវះនូវយើងក្នុងរោងគ្រ ក្នុងថ្ងៃនេះ យ៉ាងណា (អ្នកចូរធ្វើ) យ៉ាងនោះចុះ ដ្បិតសម្បុរស្លាបសម្លាប់អ្នក (និង) យើង ដូចផ្លែឫស្សីសម្លាប់នូវដើមឫស្សី។ អ្នករួច (ជាមួយនឹងយើង) ហើយមិនចង់ហើរទៅ ចូលមករកចំណងដោយខ្លួនឯងវិញ ថ្ងៃនេះ អ្នកនោះដល់នូវសេចក្តីសង្ស័យ (ក្នុងជីវិត) អ្នកចូរកាន់យកនូវប្រយោជន៍ចុះ កុំបានតែមាត់ឡើយ។

[២១២] អ្នកនោះ ចូរប្រកបព្យាយាមដ៏សមគួរ ប្រកបដោយធម៌ ប្រព្រឹត្តនូវការស្វែងរកនូវជីវិតឲ្យដល់យើង ដោយព្យាយាមរបស់អ្នកចុះ។

[២១៣] (ហង្សសេនាបតី...) បពិត្រព្រះអង្គដ៏ប្រសើរជាងសត្វស្លាប ព្រះអង្គកុំខ្លាចឡើយ ដ្បិតសត្វទាំងឡាយប្រហែលព្រះអង្គ រមែងមិនខ្លាច ទូលព្រះបង្គំជាខ្ញុំនឹងប្រកបនូវព្យាយាមដ៏សមគួរ ប្រកបដោយធម៌ ព្រះអង្គនឹងរួចចាកអន្ទាក់យ៉ាងឆាប់ដោយព្យាយាមរបស់ទូលព្រះបង្គំជាខ្ញុំ។

[២១៤] (អភិសម្ពុទ្ធគាថា) ព្រានព្រៃនោះ បានចូលទៅកាន់ទ្វារព្រះរាជវាំងទាំងអម្រែក ហង្ស (ពោលថា) អ្នកទាំងឡាយ ចូរក្រាបទូលព្រះរាជាថា ខ្ញុំជារាជហង្សឈ្មោះធតរដ្ឋៈនេះមកហើយ។

[២១៥] ព្រះរាជា ព្រះនាមសំយមៈ ទតឃើញហង្សទាំងពីរនោះ ប្រាកដស្មើដោយបុណ្យដែលសន្មតថា មានលក្ខណៈល្អ ទ្រង់ត្រាស់ទៅនឹងពួកអាមាត្យថា អ្នកទាំងឡាយ ចូរឲ្យសំពត់ បាយ ទឹក និងភោជន ដល់នាយព្រាន ចូរបំពេញសេចក្តីប្រាថ្នាដោយប្រាក់ដែលព្រាននេះប្រាថ្នាចុះ។

[២១៦] ព្រះរាជាក្នុងដែនកាសី ទ្រង់បានទតឃើញព្រានព្រៃមានចិត្តរីករាយ ទ្រង់ត្រាស់យ៉ាងនេះថា ម្នាលខេមកៈជាសំឡាញ់ បើស្រះបោក្ខរណីពេញពាសដោយពួកហង្ស។ អ្នកមានដៃកាន់អន្ទាក់ ចូលទៅរកហង្សដែលឋិតនៅក្នុងកណ្តាលនៃពួកហង្សដ៏រុងរឿង ដោយប្រការដូចម្តេច អ្នកចាប់ហង្សដ៏ឧត្តមដែលនៅលាយឡំដោយពួកហង្សជាញាតិ ដោយប្រការដូចម្តេច។

[២១៧] (ព្រានព្រៃ...) កាលទូលព្រះបង្គំជាខ្ញុំ ចូលទៅកាន់ទីជាទីកាន់យកនូវចំណី (របស់ហង្ស) ថ្ងៃនេះ ជារាត្រីគំរប់ ៧ ទូលព្រះបង្គំជាខ្ញុំ

ស្វែងរកនូវស្នាមជើងនៃហង្សនោះ ឥតមានធ្វេសប្រហែស អាស្រ័យនៅតែក្នុងពាង។ លុះទូលព្រះបង្គំជាខ្ញុំ បានឃើញស្នាមជើងនៃរាជហង្សនោះ ត្រាច់ស្វែងរកទីជាទីកាន់យកចំណីហើយ ទើបទូលព្រះបង្គំជាខ្ញុំ បានដាក់អន្ទាក់ក្នុងទីនោះរួចចាប់យករាជហង្សនោះ ដោយឧបាយយ៉ាងនេះ។

[២១៨] (ព្រះរាជា...) ម្នាលនាយព្រាន បក្សីនេះ ចុះហេតុអ្វីក៏បានជាអ្នកពោលថា បក្សីមួយ ចិត្តរបស់អ្នកប្រែប្រួលឬ ឬមួយអ្នកប្រាថ្នាដូចម្តេចវិញ។

[២១៩] (ព្រានព្រៃ...) ឆ្អឹតក្រហមល្អ ភ្លឺរុងរឿង បិតនៅផ្ទាល់នឹងទ្រូងនៃហង្សណា ហង្សនោះ បានចូលមកជាប់អន្ទាក់របស់ទូលព្រះបង្គំជាខ្ញុំ ចំណែកបក្សីដែលភ្លឺផ្លេកនេះ មិនបានជាប់អន្ទាក់ទេ ចំរើននូវអរិយធម៌ បានឈរនិយាយវាចាជារបស់មនុស្សនឹងបក្សីដែលជាប់ចំណងកំពុងតែក្តៅក្រហាយ (ដោយទុក្ខ)។

[២២០] (ព្រះរាជា...) ម្នាលសុមុខៈ ឥឡូវនេះ អ្នកឈរទល់ចង្កា (បិតមាត់) តើព្រោះហេតុអ្វី ឬក៏អ្នកមកកណ្តាលបរិស័ទរបស់យើងហើយមានសេចក្តីភ័យខ្លាច ទើបមិនពោល។

[២២១] (ហង្សសេនាបតី...) បពិត្រព្រះអង្គ ជាធំក្នុងដែនកាសី ទូលព្រះបង្គំជាខ្ញុំ មិនមែនខ្លាច ព្រោះតែចូលមកកាន់បរិស័ទរបស់ព្រះអង្គទេ ទូលព្រះបង្គំជាខ្ញុំ មិនមែនជានឹងមិននិយាយព្រោះខ្លាចទេ កាលបើមានហេតុប្រាកដដូច្នោះហើយ ទូលព្រះបង្គំជាខ្ញុំ មុខជានឹង (បញ្ចេញ) នូវវាចា។

[២២២] (ព្រះរាជា...) យើងមិនឃើញទាហាន មិនឃើញពលរថ មិនឃើញពលថ្មើរជើង មិនឃើញខែល មិនឃើញជនអ្នកកាន់អម្បែង មិនឃើញជនអ្នកពាក់អាវក្រោះ មិនឃើញអ្នកកាន់ធ្នូរបស់អ្នកឡើយ។ ម្នាលសុមុខៈ យើងមិនឃើញប្រាក់ ឬមាស ឬនគរ ដែលគេសាងល្អហើយ ជានគរមានគូដ៏ដេរដាស មិនងាយទៅមកបាន ជានគរមានប៉ម និងក្លោងទ្វារដ៏មាំទេ ជាកន្លែងដែលអ្នកចូលទៅហើយ មិនខ្លាចនូវហេតុដែលគេគួរខ្លាច។

[២២៣] (ហង្សសេនាបតី...) ទូលព្រះបង្គំជាខ្ញុំ មិនត្រូវការដោយទាហាន ដោយនគរ ឬដោយទ្រព្យទេ ពួកទូលព្រះបង្គំជាខ្ញុំ តែងទៅកាន់ផ្លូវតាមផ្លូវ មិនមែនជាផ្លូវដែលព្រះអង្គទៅបានទេ ទូលព្រះបង្គំជាខ្ញុំ ត្រាច់ទៅឰដ៏អាកាស។ ព្រះអង្គបានទ្រង់ឮហើយថា ពួកទូលព្រះបង្គំជាខ្ញុំ ជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវអាថ៌កំបាំង បើព្រះអង្គប្រតិស្ឋានក្នុងសច្ចៈ ពួកទូលព្រះបង្គំជាខ្ញុំនឹងពោលនូវវាចាដែលមានប្រយោជន៍។ ឯវាចាជាសុភាសិត ដែលព្រះអង្គមិនមានសច្ចៈ ជាបុគ្គលមិនប្រសើរបានពោលដល់ព្រានព្រៃជាអ្នកល្មោភនិយាយកុហកដែរ នឹងធ្វើដូចម្តេច។

[២២៤] ព្រះអង្គបានឲ្យគេធ្វើស្រះបោក្ខរណីឈ្មោះខេមានោះ តាមសំដីនៃពួកព្រាហ្មណ៍ ម្យ៉ាងទៀត ព្រះអង្គឲ្យគេឃោសនានូវអភ័យគ្រប់ទិសទាំង ១០ នេះ។ ថាបើកឲ្យសត្វបក្សីចុះកាន់ស្រះបោក្ខរណីដែលមានទឹកដ៏ថ្លាស្អាតចុះ ដ្បិតមានវត្ថុសម្រាប់ទំពាស៊ី ក្នុងស្រះនោះជាច្រើន ទាំងមិនមានការបៀតបៀននូវពួកសត្វបក្សីក្នុងស្រះនោះទេ។ ពួកទូលព្រះបង្គំជាខ្ញុំបានឮនូវអភ័យនេះ ដែលព្រះអង្គឲ្យឃោសនាហើយ បានជាមកក្នុងសំណាក់នៃព្រះអង្គ ទូលព្រះបង្គំជាខ្ញុំទាំងនោះ ជាប់ដោយអន្ទាក់របស់ព្រះអង្គ នេះហើយជាសំដីកុហករបស់ព្រះអង្គ។ បុគ្គលធ្វើនូវមុសាវាទផង នូវសេចក្តីលោភ គឺសេចក្តីប្រាថ្នាដ៏លាមកផង ឲ្យជាប្រធាន រមែងកន្លងនូវបដិសន្ធិក្នុងលោកទាំងពីរ ហើយចូលទៅកាន់ទីមិនមានសេចក្តីត្រេកអរ (នរក)។

[២២៥] (ព្រះរាជា...) ម្នាលសុមុខៈ យើងមិនមែនប្រទូស្តអ្នកទេ យើងមិនមែនចាប់អ្នក ព្រោះសេចក្តីលោភទេ យើងបានឮថា អ្នកទាំងឡាយ ជាបណ្ឌិត មានប្រាជ្ញាដ៏ល្អិត ជាអ្នកគិតនូវអាថ៌កំបាំង។ ធ្វើម្តេចហ្ន៎ ហង្សទាំងឡាយបានមកក្នុងទីនេះ ពោលនូវវាចាមានប្រយោជន៍ ម្នាលសុមុខៈជាសំឡាញ់ ព្រោះហេតុនោះ បានជាយើងប្រាប់នាយនេសាទនេះ ឲ្យចាប់ (អ្នក)។

[២២៦] (ហង្សសេនាបតី...) បពិត្រព្រះអង្គជាធំក្នុងដែនកាសី យើងទាំងឡាយ ជាសត្វ កាលបើជីវិតចូលទៅរក (សេចក្តីស្លាប់) ហើយដល់នូវកាលកំណត់ដែលត្រូវស្លាប់ហើយ ពោលនូវពាក្យដែលមានប្រយោជន៍មិនបានទេ។ បុគ្គលណា សម្លាប់ម្រឹគដោយម្រឹគ ឬបក្សីដោយបក្សី ម្យ៉ាងទៀត បៀតបៀននូវបុគ្គលដែលមានឈ្មោះល្បី ដោយរបស់ដែលមានឈ្មោះល្បី អំពើអ្វីដែលអាក្រក់ជាងអំពើរបស់បុគ្គលនោះទៅទៀត។ បុគ្គលណា និយាយសំដីដ៏ប្រសើរ ប៉ុន្តែជាបុគ្គលមិនប្រព្រឹត្តធម៌ដ៏ប្រសើរ បុគ្គលនោះ រមែងឃ្លាតចាកលោកទាំងពីរ គឺលោកនេះ និងលោកខាងមុខ។ បុគ្គលដែលបាននូវយស មិនគួរស្រវឹង ដល់នូវការសង្ស័យក្នុងជីវិត មិនគួរទុក្ខលំបាកឡើយ គួរព្យាយាមក្នុងកិច្ចទាំងឡាយផង គួរបិទនូវប្រហោង គឺ (ទោស) ទាំងឡាយផង។ ពួកបុគ្គលណា ចំរើនដោយគុណ ដល់កាលកំណត់ដែលត្រូវស្លាប់ មិនល្មើសធម៌ ទាំងបានប្រព្រឹត្តធម៌ ក្នុងលោកនេះ ពួកបុគ្គលនោះ រមែងទៅកើតក្នុងត្រៃត្រឹង្សយ៉ាងនេះ។ បពិត្រព្រះអង្គជាធំក្នុងដែនកាសី ព្រះអង្គទ្រង់ព្រះសណ្តាប់នូវពាក្យនេះហើយ សូមរក្សានូវធម៌ក្នុងព្រះអង្គចុះ ម្យ៉ាងទៀត សូមព្រះអង្គទ្រង់ដោះលែងនូវរាជហង្សឈ្មោះធតរដ្ឋៈ ដ៏ប្រសើរលើសជាងពួកហង្ស។

[២២៧] (ព្រះរាជា...) ពួកអ្នកបំរើ ចូរនាំមកនូវទឹក (សម្រាប់លាងជើង) ផង នូវប្រេងសម្រាប់លាបជើងផង នូវអាសនៈដែលមានថ្លៃច្រើនផង យើងនឹងដោះនូវរាជហង្សឈ្មោះធតរដ្ឋៈដ៏មានយសចេញអំពីទ្រុង។ ម្យ៉ាងទៀត ហង្សណា កាលបើព្រះរាជាបានសេចក្តីសុខ ខ្លួនក៏បានសេចក្តីសុខដែរ ព្រះរាជាបានសេចក្តីទុក្ខ ខ្លួនក៏បានសេចក្តីទុក្ខដែរ យើងនឹងលែងនូវហង្សនោះ ជាសេនាបតី ជាអ្នកប្រាជ្ញមានប្រាជ្ញាល្អិត អ្នកគិតនូវអាថ៌កំបាំង។ បុគ្គលបែបនេះ ទើបគួរបរិភោគដុំបាយរបស់ម្ចាស់បាន ដូចជាហង្សសេនាបតីឈ្មោះសុមុខៈនេះ ជាសំឡាញ់មានជីវិតស្មើនឹងស្តេច។

[២២៨] (អភិសម្ពុទ្ធគាថា) រាជហង្សឈ្មោះធតរដ្ឋៈ បានចូលទៅទំលើតាំង ជាវិការៈនៃមាសសុទ្ធមានជើងប្រាំ ជាទីរីករាយនៃចិត្ត ជាតាំងដ៏រលីង ក្រាលដោយសំពត់អ្នកដែនកាសី។ ចំណែកហង្សសេនាបតី ឈ្មោះសុមុខៈ បានចូលទៅទំលើកៅអីជាវិការៈនៃមាសសុទ្ធដែលពាសដោយស្បែកខ្លា ក្នុងទីជាលំដាប់នៃរាជហង្សឈ្មោះធតរដ្ឋៈ។ ពួកអ្នកដែនកាសីជាច្រើន បាននាំយកនូវភោជនមានរសដ៏ប្រសើរ ដែលគេបញ្ជូនទៅថ្វាយព្រះរាជា ដោយភាជន៍ជាវិការៈនៃមាសទាំងឡាយ ហើយក៏បង្អោនទៅដល់ហង្សទាំងនោះ។

[២២៩] រាជហង្សឈ្លាសវៃក្នុងបដិសណ្ឋារធម៌ លុះបានឃើញទឹក និងភោជនដ៏ប្រសើរដែលគេនាំមក ដែលព្រះរាជាក្នុងដែនកាសីទ្រង់បញ្ជូនមកហើយ សួរក្នុងកាលជាលំដាប់នោះថា ព្រះអង្គទ្រង់បានសេចក្តីសុខស្រួលដែរឬ ព្រះអង្គមិនមានជម្ងឺជម្កាត់អ្វីទេឬ ព្រះអង្គគ្រប់គ្រងដែនដ៏ធំទូលាយនេះ ដោយធម៌ដែរឬ។

[២៣០] (ព្រះរាជា...) ម្នាលហង្ស យើងមានសេចក្តីសុខស្រួលដែរ ម្នាលហង្ស យើងមិនមានជម្ងឺជម្កាត់អ្វីទេ យើងគ្រប់គ្រងដែនដ៏ធំទូលាយនេះត្រឹមត្រូវដោយធម៌ហើយ។

[២៣១] (រាជហង្ស...) ទោសតិចតួចរបស់ព្រះអង្គមិនមានក្នុងពួកអាមាត្យទេឬ អាមាត្យទាំងនោះ មិនអាល័យក្នុងជីវិតចំពោះប្រយោជន៍ទាំងឡាយរបស់ព្រះអង្គទេឬ។

[២៣២] (ព្រះរាជា...) ទោសតិចតួចរបស់យើង មិនមានក្នុងពួកអាមាត្យទេ អាមាត្យទាំងនោះ មិនអាល័យក្នុងជីវិតចំពោះប្រយោជន៍ទាំងឡាយរបស់យើងទេ។

[២៣៣] (រាជហង្ស...) អគ្គមហេសីដែលមានជាតិស្មើនឹងព្រះអង្គ ជាស្រ្តីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ ប្រកបដោយបុត្ត រូប និងយស ជាស្រ្តីលុះអំណាចសេចក្តីប្រាថ្នារបស់ព្រះអង្គទេឬ។

[២៣៤] (ព្រះរាជា...) អគ្គមហេសីដែលមានជាតិស្មើនឹងយើង ជាស្រ្តីស្តាប់បង្គាប់ ពោលនូវពាក្យជាទីស្រឡាញ់ បានប្រកបដោយបុត្ត រូប និងយស ជាស្រ្តីលុះអំណាចសេចក្តីប្រាថ្នារបស់យើង។

[២៣៥] (រាជហង្ស...) ព្រះអង្គមិនបៀតបៀនអ្នកដែន ដែលមិនមានឧបទ្រពអំពីទីណា គ្រប់គ្រងដោយអាការមិនរួសរាន់តាមធម៌ដ៏ស្មើទេឬ។

[២៣៦] (ព្រះរាជា...) យើងមិនបានបៀតបៀនអ្នកដែន ដែលមិនមានឧបទ្រពអំពីទីណា គ្រប់គ្រងដោយការមិនរួសរាន់តាមធម៌ដ៏ស្មើ។

[២៣៧] (រាជហង្ស...) ព្រះអង្គទ្រង់បានគោរពពួកសប្បុរស វៀរបង់ពួកអសប្បុរស មិនលះបង់នូវធម៌ ហើយប្រព្រឹត្តនូវអធម៌ទេឬ។

[២៣៨] (ព្រះរាជា...) យើងបានគោរពនូវពួកសប្បុរស វៀរបង់នូវពួកអសប្បុរស យើងបានលះបង់នូវអធម៌ ហើយប្រព្រឹត្តតាមធម៌តែម្យ៉ាង។

[២៣៩] (រាជហង្ស...) បពិត្រក្សត្រ ព្រះអង្គទ្រង់រំពឹងនូវកាលជាអនាគតដ៏វែងដែរឬ ព្រះអង្គស្រវឹងក្នុងអារម្មណ៍ ជាទីតាំងនៃសេចក្តីស្រវឹងហើយ មិនតក់ស្លុតនឹងបរលោកទេឬ។

[២៤០] (ព្រះរាជា...) ម្នាលបក្សី យើងតែងប្រមើលមើលនូវកាលអនាគតដ៏វែង យើងឋិតនៅក្នុងធម៌ ១០ ប្រការ មិនតក់ស្លុតនឹងបរលោកឡើយ។ (ធម៌ ១០ ប្រការ គឺ) ទាន ១ សីល ១ បរិច្ចាគ ១ ភាពនៃចិត្តត្រង់ ១ ភាពនៃចិត្តទន់ ១ តបៈ គឺឧបោសថសីល ១ ការមិនក្រោធ ១ ការមិនបៀតបៀន ១ ខន្តី ១ កិរិយាមិនភ្លាត់ ១។ យើងឃើញនូវកុសលធម៌ទាំងនេះ ឋិតនៅក្នុងខ្លួន លំដាប់នោះ បីតិ និងសោមនស្សជាច្រើន កើតឡើងដល់យើង ដោយប្រការដូច្នេះ។ ឯបក្សីឈ្មោះសុមុខៈ មិនបានគិត ហើយបញ្ចេញនូវវាចាដ៏ទ្រគោះ ព្រោះតែមិនបានដឹងច្បាស់នូវការប្រទូស្តក្នុងចិត្តរបស់យើង។ បក្សីនោះ លុះខឹងហើយ ក៏បញ្ចេញនូវវាចាដ៏ទ្រគោះ ដោយឥតគំនិត (ពោល) នូវទោសទាំងឡាយដែលមិនមានក្នុងពួកយើង ពាក្យនេះមិនមែនដូចពាក្យនៃបុគ្គលមានប្រាជ្ញា (ពោលហើយ) ទេ។

[២៤១] (ហង្សសេនាបតី...) បពិត្រព្រះអង្គជាធំជាងពួកមនុស្ស ទូលព្រះបង្គំជាខ្ញុំ មានសេចក្តីភ្លាំងភ្លាត់នោះ ព្រោះពោលពាក្យដោយរួសរាន់ពេក ដ្បិតកាលដែលរាជហង្ស ឈ្មោះធតរដ្ឋៈ ជាប់ចំណង ទូលព្រះបង្គំជាខ្ញុំមានសេចក្តីទុក្ខដ៏ធំ។ បពិត្រព្រះអង្គជារាជកុញ្ជរ ព្រះអង្គ (ជាទីពឹង) នៃពួកទូលព្រះបង្គំជាខ្ញុំ ដូចជាបិតា (ជាទីពឹង) នៃកូន ឬដូចធរណី (ជាទីពឹង) នៃពួកភូត សូមព្រះអង្គអត់ទោសដល់ទូលព្រះបង្គំជាខ្ញុំទាំងឡាយ ដែលត្រូវសេចក្តីខុសគ្របសង្កត់។

[២៤២] (ព្រះរាជា...) យើងរីករាយចំពោះអ្នកយ៉ាងនេះ ព្រោះថា អ្នកមិនលាក់នូវភាវៈនៃចិត្តដ៏កំបាំងរបស់ខ្លួន ម្នាលបក្សី អ្នកបានទំលាយចោលនូវចិត្តរឹងត្អឹង ម្នាលបក្សី អ្នកជាសត្វមានចិត្តត្រង់។

[២៤៣] រតនៈណាមួយ គឺប្រាក់ មាស កែវមុក្តា កែវពៃទូរ្យជាច្រើន មាននៅក្នុងព្រះរាជនិវេសន៍ក្នុងដែនកាសី។ មួយទៀត កែវមណី ស័ង្ខ (ជាទក្ខិណាវដ្ត) កែវមុក្តា (មានសណ្ឋានមូលដូចផ្លែកន្ទួតព្រៃ) សំពត់ខ្លឹមចន្ទន៍ក្រហម ស្បែកខ្លាឃ្មុំ ភ័ណ្ឌៈជាវិការៈនៃភ្លុក លោហៈក្រហម និងលោហៈខ្មៅដ៏ច្រើន យើងឲ្យនូវទ្រព្យទាំងនេះដល់អ្នក យើងនឹងលះបង់នូវភាវៈជាធំដល់អ្នក។

[២៤៤] (រាជហង្ស...) បពិត្រព្រះអង្គដ៏ប្រសើរក្នុងរថ ព្រះអង្គបានគោរព ធ្វើសក្ការៈ (ដល់យើងទាំងឡាយ) ដោយពិត សូមព្រះអង្គជាអាចារ្យរបស់យើង ដែលជាអ្នកប្រព្រឹត្តក្នុងធម៌ទាំងឡាយ។ បពិត្រព្រះអង្គជាអាចារ្យ ព្រះអង្គបានអនុញ្ញាត បើកយើងទាំងឡាយឲ្យទៅដោយស្រួលហើយ បពិត្រព្រះអង្គជាអ្នកទូន្មាននូវសត្រូវ យើងទាំងឡាយ សូមធ្វើប្រទក្សិណនូវព្រះអង្គ ហើយទៅជួបនឹងពួកញាតិ។

[២៤៥] (អភិសម្ពុទ្ធគាថា) ព្រះរាជាក្នុងដែនកាសី ទ្រង់បានគិត បានប្រឹក្សានូវហេតុដ៏គួរតាមពិត ពេញមួយរាត្រី ហើយទ្រង់អនុញ្ញាតឲ្យរាជហង្សដ៏ប្រសើរខ្ពង់ខ្ពស់ជាងពួកហង្សហើរទៅ។

[២៤៦] លំដាប់នោះ កាលដែលរាត្រីនោះអស់ហើយ ព្រះអាទិត្យក៏រះឡើង កាលព្រះរាជាក្នុងដែនកាសី ទ្រង់កំពុងទតមើល សត្វហង្សទាំងពីរក៏ហើរចេញទៅអំពីទីនៅរបស់ព្រះរាជា។

[២៤៧] ហង្សទាំងឡាយ លុះបានឃើញបក្សីហង្សដ៏ប្រសើរទាំងពីរនោះ មិនមានរោគ មកដល់ហើយ ក៏ធ្វើនូវសម្លេងថា កេកា ៗ ដូច្នេះ សូរសព្ទរំពងក៏កើតឡើង។ បក្សីហង្សជាអណ្ឌជាតិទាំងនោះ មានចិត្តរីករាយ ព្រោះម្ចាស់រួចហើយ ជាសត្វគោរពម្ចាស់ ជាសត្វបាននូវទីពឹង ក៏ចោមរោមម្ចាស់ដោយជុំវិញ។

[២៤៨] ប្រយោជន៍គ្រប់យ៉ាងរបស់ពួកជនអ្នកមានមិត្តល្អ រមែងជាប្រយោជន៍គួរចំរើន ដូចហង្សឈ្មោះធតរដ្ឋៈ និងហង្សឈ្មោះសុមុខៈ បានចូលទៅចួបនឹងពួកញាតិ។

ចប់ មហាហង្សជាតក ទី២។

## សុធាភោជនជាតក ទី៣

CS sut.kn.jat.535 | ភាគទី ៦១

### (៥៣៥. សុធាភោជនជាតកំ (៣))

[២៤៩] (កោសិយសេដ្ឋី ពោលថា) ខ្ញុំមិនមែនទិញ មិនមែនលក់ទេ មួយទៀត ការសន្សំទុករបស់ខ្ញុំ ក៏មិនមានក្នុងទីនេះដែរ របស់នេះ

មានប្រមាណតិច មានសភាពដំក្រណាស់ បាយចំនួនអង្ករមួយនាឡិនេះ មិនល្មមដល់ជនពីរនាក់ទេ។

[២៥០] (សក្កទេវរាជ ពោលថា) បុគ្គលគប្បីឲ្យវត្ថុតិចអំពីវត្ថុតិច គួរឲ្យវត្ថុពាក់កណ្តាលអំពីវត្ថុពាក់កណ្តាល គួរឲ្យវត្ថុច្រើនអំពីវត្ថុច្រើន ការមិនឲ្យ មិនកើតទេ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យនូវទានផង ចូរបរិភោគផង អ្នកចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ។

[២៥១] (ចន្ទទេវបុត្រ...) បុគ្គលណា កាលបើភ្លៀវអង្គុយហើយ បរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការឥតអំពើ ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ (របស់បុគ្គលនោះ) ក៏ឥតអំពើដែរ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាកឯង មិនបានសេចក្តីសុខទេ។

[២៥២] (សុរិយទេវបុត្ត...) បុគ្គលណា កាលបើភ្ញៀវអង្គុយហើយ មិនបរិភោគនូវភោជនម្នាក់ឯង ការបូជារបស់បុគ្គលនោះ ជាការបូជាពិតមែន ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យ (របស់បុគ្គលនោះ) ក៏ជាការព្យាយាមពិតមែន។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសេចក្តីសុខទេ។

[២៥៣] (មាតលិទេវបុត្រ...) បុរសបូជាស្រះក្តី ទន្លេឈ្មោះពហុកា ឬស្រះបោក្ខរណីឈ្មោះគយាក្តី កំពង់ឈ្មោះទោណៈ ឬកំពង់ឈ្មោះតិម្ពរុក្តិ ទន្លេដ៏ធំមានខ្សែទឹកដ៏រហ័សក្តី។ ការបូជារបស់បុរសនោះក្នុងទីនោះ រមែងមាន (ផល) ទាំងការព្យាយាមជាហេតុឲ្យកើតទ្រព្យរបស់បុរសនោះ ក្នុងទីទាំងនោះ ក៏មានផលដែរ ព្រោះថា បុរសនោះ កាលបើភ្ញៀវអង្គុយនៅហើយ មិនគួរបរិភោគភោជនម្នាក់ឯងទេ។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង បរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគភោជនម្នាក់ឯង មិនបានសេចក្តីសុខទេ។

[២៥៤] (បញ្ចសិក្ខទេវបុត្ត...) បុគ្គលណា កាលបើភ្ញៀវអង្គុយនៅហើយ បរិភោគភោជនម្នាក់ឯង បុគ្គលនោះឈ្មោះថាលេបសន្ទូចដែលមានខ្សែដ៏វែង ព្រមទាំងចំណង។ ម្នាលកោសិយៈ ព្រោះហេតុនោះ យើងនិយាយនឹងអ្នក ចូរអ្នកឲ្យទានផង ចូរបរិភោគផង ចូរឡើងកាន់អរិយមគ្គ ព្រោះថា បុគ្គលអ្នកបរិភោគម្នាក់ឯង មិនបានសុខទេ។

[២៥៥] (កោសិយសេដ្ឋី...) អើហ្ន៎ ព្រាហ្មណ៍ទាំងនេះ ពេញជាមានសម្បុរល្អលើសលុប ចុះឆ្កែនេះរបស់ពួកអ្នក ក្លែងខ្លួនឲ្យមានពណ៌រុងរឿងប្លែកៗ ព្រោះហេតុអ្វី ម្នាលព្រាហ្មណ៍ទាំងឡាយ អ្នកទាំងឡាយចូរប្រាប់យើង អ្នកទាំងឡាយជាអ្វី។

[២៥៦] (ព្រះឥន្ទ្រ...) ព្រាហ្មណ៍ទាំងពីរនាក់ដែលមកក្នុងទីនេះ គឺចន្ទទេវបុត្ត និងសុរិយទេវបុត្ត ចំណែកព្រាហ្មណ៍នេះ គឺមាតលិទេវបុត្តដែលជាទេវសារថី ឯយើងជាសក្កៈ ជាធំជាងពួកទេវតាក្នុងជាន់តាវត្តឹង្ស ឯព្រាហ្មណ៍នេះ គេហៅថាបញ្ចសិខៈ។

[២៥៧] ល្បែងទះដៃក្តី ស្គរសំភោរក្តី ស្គរតូច និងស្គរធំក្តី តែងញុំាងបញ្ចសិខទេវបុត្តនេះដែលដេកលក់ ឲ្យភ្ញាក់ឡើងបាន លុះបញ្ចសិខទេវបុត្តនោះភ្ញាក់ឡើងហើយ រមែងរីករាយ។

[២៥៨] ពួកជនណានីមួយ មានសេចក្តីកំណាញ់ស្វិតស្វាញ ជាអ្នកប្រទេចផ្តាសានូវសមណព្រាហ្មណ៍ ពួកជននោះ ដាក់ចុះនូវរាងកាយគឺសរីរៈក្នុងលោកនេះ លុះបែកធ្លាយរាងកាយហើយ រមែងទៅកើតក្នុងនរក។ ពួកជនណានីមួយ កាលប្រាថ្នានូវសុគតិ ឋិតនៅក្នុងធម៌ គឺការសង្រួម និងការចែករំលែកនូវទាន ពួកជននោះ ដាក់ចុះនូវរាងកាយ គឺសរីរៈក្នុងលោកនេះ លុះបែកធ្លាយរាងកាយ រមែងទៅកាន់សុគតិ។

[២៥៩] អ្នកជាញាតិរបស់យើងក្នុងជាតិមុន អ្នកនោះឈ្មោះកោសិយៈ ជាបុគ្គលកំណាញ់ មានធម៌ដ៏លាមក យើងមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់អ្នកតែម្យ៉ាងថា ញាតិរបស់យើងដែលមានធម៌ដ៏លាមក កុំទៅកាន់នរកឡើយ។

[២៦០] (កោសិយៈសេដ្ឋី...) អ្នកទាំងឡាយនោះ ជាអ្នកប្រាថ្នានូវប្រយោជន៍ដល់ខ្ញុំដោយពិត ព្រោះថា អ្នកទាំងឡាយបានប្រៀនប្រដៅខ្ញុំដោយល្អ ខ្ញុំនោះនឹងធ្វើតាមពាក្យទាំងអស់ ដែលអ្នកទាំងឡាយជាអ្នកស្វែងរកប្រយោជន៍ បានពោលហើយដូច្នោះ។ ខ្ញុំនោះវៀរចាកសេចក្តីកំណាញ់ ក្នុងថ្ងៃនេះឯង ខ្ញុំមិនធ្វើអំពើអាក្រក់តិចតួច ខ្ញុំមិនមែនជាមិនឲ្យវត្ថុតិចតួចទេ បើខ្ញុំមិនទាន់បានឲ្យទានទឹក មិនផឹកនូវទឹកទេ។ បពិត្រព្រះវាសវៈ កាលខ្ញុំឲ្យទានសព្វកាលយ៉ាងនេះ ភោគៈទាំងឡាយរបស់ខ្ញុំ មុខជានឹងអស់ទៅ បពិត្រសក្កៈ តអំពីនេះទៅ ខ្ញុំនឹងលះនូវកាមទាំងឡាយ តាមចំណែក ហើយបួស។

[២៦១] (អភិសម្ពុទ្ធគាថា) ពួកទេវធីតានោះ ដែលទេវរាជរក្សាហើយ ក៏រីករាយលើភ្នំគន្ធមាទន៍ដ៏ប្រសើរ ដែលជាភ្នំខ្ពង់ខ្ពស់ គ្រានោះឥសីដ៏ប្រសើរ ជាអ្នកអាចទៅកាន់លោកទាំងអស់ បានកាន់យកនូវផ្កាទុមវរសាខា ដែលរីកស្គុះស្គាយ និមន្តមក។ ផ្កានោះ ជាផ្កាស្អាត មានក្លិនក្រអូប ដែលពួកទេវតាក្នុងជាន់ត្រៃត្រឹង្សធ្វើសក្ការៈហើយ ជាផ្កាដ៏ឧត្តម ដែលពួកទេវតាដ៏ប្រសើរសេពហើយ ពួកមនុស្សដទៃក្តី ពួកអសុរក្តី វៀរលែងតែពួកទេវតា មិនដែលបានឡើយ ព្រោះថា ផ្កានោះ ជាប្រយោជន៍ដ៏សមគួរដល់ (ពួកទេវតាទាំងនោះ)។ លំដាប់នោះ នារីទាំងបួន ដែលជាធំលើសអស់ពួកស្រី មានស្បែកភ្លឺដូចមាស ឈ្មោះអាសា ១ សទ្ធា ១ សិរី ១ ហិរី ១ បានក្រោកឡើង ហើយទូលសួរនារទតាបស ជាអ្នកប្រាជ្ញ ទាំងជាព្រាហ្មណ៍ដ៏ប្រសើរដូច្នេះថា បពិត្រមហាមុនីដ៏ប្រសើរ បើផ្កាបរិច្ឆត្តព្រឹក្សនេះ លោកមិនឧទ្ទិស (អ្នកណាទេ) សូមលោកឲ្យដល់ពួកយើង គតិ (នៃចិត្ត) ទាំងពួង សូមសម្រេចដល់លោក ទោះបីលោក ក៏សូម (ឲ្យមានមេត្តា) ចំពោះពួកយើង ដូចជាព្រះវាសវៈដែរ។ នារទតាបស បានឃើញពួកនារីមកសុំនូវផ្កានោះ ក៏ពោលថា នាងនិយាយនូវពាក្យនាំឲ្យបង្កជំលោះ ប្រយោជន៍តិចតួចដោយផ្កាឈើទាំងនេះ មិនមានដល់យើងទេ នាងណា ដែលចម្បងជាងនាងទាំងឡាយ នាងនោះ ចូរប្រដាប់ផ្កានេះចុះ។

[២៦២] (ពួកទេវធីតា...) បពិត្រនារទតាបសដ៏ឧត្តម សូមលោករមិលមើលនូវពួកយើងចុះ បើលោកប្រាថ្នានឹងឲ្យដល់នាងណា សូមលោកបោះផ្កានោះសំដៅទៅនាងនោះ បពិត្រនារទតាបស ព្រោះថា បណ្តាពួកយើង បើលោកឲ្យដល់នាងណា នាងនោះឯង យើងសន្មតថា ប្រសើរបំផុតជាងគេ។

[២៦៣] (នារទតាបស...) នែនាងមានខ្លួនដ៏ល្អ សំដីនេះមិនគួរទេ បុគ្គលដូចម្តេច ដែលហៅថាព្រាហ្មណ៍ បុគ្គលដូចម្តេច គួរពោលពាក្យដែលនាំបង្កជំលោះ បើនាងទាំងឡាយមិនដឹងធម៌ដ៏ខ្ពង់ខ្ពស់ក្នុងលោកនេះទេ ចូរទៅសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាចុះ។

[២៦៤] ពួកទេវធីតាទាំងនោះ ដែលនារទតាបសបានពោលយ៉ាងនេះហើយ ក៏មានចិត្តក្រេវក្រោធយ៉ាងក្រៃលែង ជាស្ត្រីស្រវឹងដោយសេចក្តីស្រវឹងនឹងសម្បុរ ហើយបានទៅកាន់សំណាក់ព្រះឥន្ទ្រ ជាសហស្សចក្ខុ រួចសួរនូវព្រះឥន្ទ្រដែលជាធំជាងពួកទេវតាថា (បណ្តាពួកយើង) នាងណាប្រសើរជាងគេ។

[២៦៥] ព្រះឥន្ទ្រដ៏ប្រសើរជាងពួកទេវតា ដែលពួកទេវតាតែងប្រណម្យអញ្ជលី លុះបានឃើញនូវពួកទេវធីតាទាំងនោះ មានចិត្តខ្វល់ខ្វាយ ក៏បានពោលតបដូច្នេះថា នែនាងមានជោគល្អ នាងទាំងអស់ប្រហែលៗ គ្នាទេ ម្នាលនាងដ៏ចំរើន ចុះបុគ្គលណាហ្ន៎ បានពោលពាក្យដែលនាំបង្កជំលោះ។

[២៦៦] (ពួកទេវធីតា...) នារទតាបសណា ជាមហាមុនី អាចត្រាច់ទៅក្នុងលោកទាំងអស់បាន ឋិតនៅក្នុងធម៌ មានព្យាយាមដ៏ទៀងទាត់ នារទតាបសនោះ បានពោលនឹងពួកយើងលើភ្នំដ៏ប្រសើរ ឈ្មោះគន្ធមាទន៍ថា បើនាងទាំងឡាយ មិនដឹងនូវធម៌ដ៏ឧត្តមក្នុងលោកនេះទេ ចូរទៅសួរព្រះឥន្ទ្រ ដែលជាធំជាងពួកទេវតាចុះ។

[២៦៧] (ព្រះឥន្ទ្រ...) ម្នាលនាងមានខ្លួនដ៏ប្រសើរ តាបសឯណោះ ជាមហាមុនី ជាអ្នកត្រាច់ទៅក្នុងព្រៃធំ បើមិនទាន់ឲ្យទាន មិនបរិភោគនូវភត្តទេ កោសិយតាបសនោះ ពិចារណាហើយ ទើបឲ្យនូវទានទាំងឡាយ ព្រោះថា តាបសនោះ នឹងឲ្យផ្កាដល់នាងណា នាងនោះឯងពេញជាប្រសើរជាងគេ។

[២៦៨] តាបសឯណោះនោះ គង់នៅក្នុងទិសខាងត្បូងនៃភ្នំហិមវន្ត ប្របឆ្នេរទន្លេគង្គា កោសិយតាបសនោះ បានទឹក និងភោជនដោយកម្រ ម្នាលមាតលិទេវបុត្ត ជាទេវសារថិ អ្នកចូរញ៉ាំងសុធាភោជន ឲ្យសម្រេចដល់កោសិយតាបសចុះ។

[២៦៩] មាតលិទេវបុត្តនោះ លុះព្រះឥន្ទ្រប្រសើរជាងទេវតាប្រើហើយ ក៏ឡើងជិះទេវរថ ដែលទឹមដោយសេះមួយពាន់ ហើយចូលទៅកាន់អាស្រមយ៉ាងរហ័ស មិនបង្ហាញកាយឲ្យឃើញ ស្រាប់តែប្រគេននូវសុធាភោជន ដល់តាបសជាអ្នកប្រាជ្ញ។

[២៧០] (កោសិយតាបស...) កាលដែលអាត្មាអញបំរើនូវការបូជាភ្លើង និងព្រះអាទិត្យដ៏ឧត្តម ដែលបន្ទោបង់នូវងងឹតក្នុងលោក អ្នកណាហ្ន៎ ដូចព្រះវាសវៈ កន្លងនូវពួកទេវតាទាំងអស់ ដាក់សុធាភោជនលើដៃទាំងពីររបស់អញឬ។ សុធាភោជននោះ ដ៏សដូចជាស័ង្ខ គួររមិលមើល រកអ្វីប្រៀបគ្មាន ជាភោជនស្អាត មានក្លិនក្រអូប មានសភាពគួរពេញចិត្តយ៉ាងចំឡែក ភ្នែករបស់អញតាំងអំពីកើតមក មិនដែលឃើញសោះឡើយ ទេវតាណាហ្ន៎ ដាក់នូវសុធាភោជនលើដៃទាំងពីររបស់អញឬ។

[២៧១] (មាតលិទេវបុត្ត...) បពិត្រលោកជាមហាមុនី អ្នកស្វែងរកនូវគុណដ៏ធំ ខ្ញុំដែលព្រះឥន្ទ្រជាធំបានប្រើមក ខ្ញុំក៏បាននាំសុធាភោជនយ៉ាងរួសរាន់ លោកបានស្គាល់នូវខ្ញុំថាឈ្មោះមាតលិទេវបុត្ត ជាទេវសារថិ សូមលោកឆាន់នូវភត្តដ៏ឧត្តមចុះ លោកកុំប្រកែករារាំងឡើយ។ ឯសុធាភោជននោះ លុះលោកបរិភោគហើយ រមែងកំចាត់បង់បាបធម៌ ១២ យ៉ាងបាន គឺសេចក្តីឃ្លាន ១ ការស្រេក ១ សេចក្តីអផ្សុក ១ ក្រវល់ក្រវាយ កាយ ១ លំបាកកាយ ១ ក្រោធ ១ ចងសេចក្តីក្រោធក្នុងចិត្ត ១ ឈ្លោះប្រកែក ១ ញុះញង់ ១ ត្រជាក់ ១ ក្តៅ ១ ខ្ជិល ៦ ដ្បិតភោជននេះ មានរសដ៏ឧត្តម។

[២៧២] (កោសិយៈ...) ម្នាលទេវបុត្តឈ្មោះមាតលិ ការដែលអាត្មាមិនបានឲ្យទានជាមុនសិន ហើយបរិភោគ មិនគួរទេ ព្រោះវត្ថុនេះជាវត្ថុឧត្តមរបស់អាត្មា ឯការបរិភោគតែម្នាក់ឯង ជាអំពើដែលព្រះអរិយៈមិនបូជាឡើយ មួយទៀត បុគ្គលអ្នកមិនបានចែករំលែក រមែងមិនបាននូវសេចក្តីសុខទេ។

[២៧៣] ពួកជនណាមួយ ជាអ្នកសម្លាប់ស្ត្រី ជាអ្នកប្រព្រឹត្តបរទារកកម្ម ឬក៏ពួកជនណា ជាអ្នកប្រទូស្តមិត្ត ជេរប្រទេចពួកបុគ្គលអ្នកមានវត្តល្អ ជនទាំងអស់នោះ សុទ្ធតែមានសេចក្តីកំណាញ់ដ៏ថោកទាបជាគំរប់ប្រាំ ព្រោះហេតុនោះ អាត្មាបើមិនបានឲ្យ សូម្បីនូវទឹក ក៏មិនបរិភោគទេ។ មួយទៀត អាត្មានោះ ត្រូវតែឲ្យទានដែលអ្នកប្រាជ្ញសរសើរហើយ ដល់ស្ត្រី ឬបុរស ដ្បិតបុគ្គលអ្នកមានសទ្ធា អ្នកដឹងនូវពាក្យស្អូម ប្រាសចាកសេចក្តីកំណាញ់ទាំងនុ៎ះ លោកសន្មតថា ជាអ្នកមានសច្ចៈដ៏ស្អាតក្នុងលោកនេះ។

[២៧៤] (អភិសម្ពុទ្ធគាថា) លំដាប់នោះ នាងកញ្ញាទាំង ៤ នាក់ ដែលមានស្បែកដូចជាមាសឈ្មោះ អាសា ១ សទ្ធា ១ សិរី ១ ហិរី ១ ដែលព្រះឥន្ទ្រប្រសើរជាងទេវតា បានយល់ព្រមប្រើទៅហើយ នាងក៏មកកាន់អាស្រមជាទីនៅនៃកោសិយតាបសនោះ។ កោសិយតាបសបានឃើញនាងកញ្ញាទាំង ៤ នោះ ដែលមានចិត្តត្រេកអរយ៉ាងលើសលុបទាំងអស់គ្នា មានវណ្ណៈដ៏ល្អដូចអណ្តាតភ្លើងឋិតនៅក្នុងទិសទាំងបួន ហើយបានពោលដូច្នេះក្នុងទីចំពោះមុខនៃមាតលិទេវបុត្តថា ម្នាលទេវតា នាងជាអ្វី មានកាយប្រដាប់ហើយ បានញ៉ាំងទិសខាងកើតឲ្យភ្លឺ ដូចជាផ្កាយព្រឹកដ៏ប្រសើរ ម្នាលនាងមានរាងកាយដូចជារូបប្រៀប ជាវិការៈនៃមាស អាត្មាសូមសួរនាង ចូរនាងប្រាប់អាត្មា នាងជាទេវតាឈ្មោះអ្វី។

[២៧៥] (នាងសិរី...) ខ្ញុំជាទេវធីតាឈ្មោះសិរី ដែលគេបូជាក្នុងពួកមនុស្ស មិនចូលទៅគប់រកនូវសត្រូវលាមកគ្រប់កាល មកកាន់សំណាក់លោក ព្រោះទាស់ទែងគ្នាអំពីសុធាភោជន បពិត្រលោកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ។ បពិត្រលោកជាមហាមុនី ខ្ញុំប្រាថ្នាសុធាភោជនរបស់ជនណា ជននោះឯង រមែងរីករាយដោយកាមគ្រប់យ៉ាង បពិត្រលោកដ៏ខ្ពង់ខ្ពស់ជាងពួកជនអ្នកបូជាភ្លើង សូមលោកដឹងនូវខ្ញុំថាជាទេវធីតាឈ្មោះសិរី បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ។

[២៧៦] (កោសិយៈ...) ពួកជនដែលប្រកបដោយសិល្បៈវិជ្ជាសរណៈ និងប្រាជ្ញា ជាអ្នកស្ទាត់ជំនាញដោយអំពើរបស់ខ្លួន ត្រឡប់ជាថោកទាបជាងនាងវិញ មិនបានយស ឬសេចក្តីសុខនោះតិចតួចសោះឡើយ អំពើណា ដែលនាងបានធ្វើហើយ អំពើនោះ មិនប្រពៃទេ។ អាត្មាបានឃើញនូវជនខ្ជិលច្រអូស បរិភោគច្រើន ទាំងមានត្រកូលថោកទាប មានរូបអាក្រក់ បុរសនោះ ដែលនាងបានរក្សាហើយ ក៏បែរទៅជាអ្នកមានសិរី អាចប្រើនូវជនដែលមានជាតិខ្ពស់ ដូចជនអ្នកមានភោគៈ មានសេចក្តីសុខ ប្រើនូវខ្ញុំកំដរ។ ព្រោះហេតុនោះ យើងដឹងនូវនាងជាស្រីមិនមានសច្ចៈ គប់រកឥតរើសមុខ ជាស្រីល្ងង់ បៀតបៀនអ្នកប្រាជ្ញ ស្រីប្រហែលដូចនាង មិនគួរទទួលអាសនៈ និងទឹកទេ សុធាភោជន នឹងមានពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ។

[២៧៧] នាងជាអ្វី មានចង្កូមស ពាក់កុណ្ឌល មានគ្រឿងប្រដាប់ដើមដៃដ៏វិចិត្រ ទ្រទ្រង់គ្រឿងប្រដាប់មាសដ៏រលើងស្អាត ស្លៀកដណ្តប់សំពត់មានពណ៌ដូចទនៃទឹក ដែលគេស្រោចចុះ សៀតត្រយឈើ មានពណ៌ក្រហមដូចភ្លើងឆេះស្បូវ ល្អរុងរឿង។ នាងដូចមេម្រឹគដែលព្រានព្រៃបាញ់ខុសហើយ ក៏ភ្ញាក់ផ្អើលក្រឡេកមើលភ្លៀកៗ ដូច្នោះម្នាលនាងមានភ្នែកស្រទន់ បុគ្គលណាជាគំរប់ពីរនឹងនាងក្នុងទីនេះ នាងតែម្នាក់ឯង នៅក្នុងព្រៃធំ មិនខ្លាចទេឬ។

[២៧៨] (នាងអាសា...) បពិត្រកោសិយតាបស ក្នុងទីនេះ មិនមានបុគ្គលជាគំរប់ពីរនឹងខ្ញុំទេ ខ្ញុំជាទេវតាឈ្មោះអាសា កើតក្នុងភពតាវត្តឹង្ស មកកាន់សំណាក់លោកដោយ (សេចក្តីប៉ុនប៉ង) នូវសុធាភោជន បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើរ ព្រោះហេតុនោះ សូមលោកចែកនូវសុធាភោជនដល់ខ្ញុំ។

[២៧៩] (កោសិយៈ...) ពួកពាណិជអ្នកស្វែងរកទ្រព្យ ឡើងសំពៅទៅក្នុងសមុទ្រ ព្រោះសេចក្តីប្រាថ្នា ពាណិជទាំងនោះ ជួនកាល

លិចចុះក្នុងសមុទ្រនោះ ជួនកាល សាបសូន្យចាកទ្រព្យ បាត់ទាំងដើមទុន។ ពួកភ្ជួររាស់បានភ្ជួរស្រែទាំងឡាយ ព្រោះនូវពូជទាំងឡាយ ធ្វើ (កិច្ចនោះៗ) ដោយឧបាយ ក៏មិនបាននូវផលិតផលបន្តិចបន្តួចអំពីសន្ទូងនោះ ដោយសេចក្តីអន្តរាយ ឬគ្មានភ្លៀង ព្រោះតែសេចក្តីប្រាថ្នា។ ពួកជនអ្នកស្វែងរកសេចក្តីសុខ បានធ្វើនូវសេចក្តីប្រាថ្នាជាប្រធាន ទើបធ្វើនូវសេចក្តីព្យាយាមក្នុងទីយុទ្ធភូមិ ដើម្បីម្ចាស់ ជនទាំងនោះធ្វើនូវប្រយោជន៍ដល់ម្ចាស់ ត្រូវពួកបច្ចាមិត្តបៀតបៀនយ៉ាងខ្លាំង មិនបាននូវឥស្សរិយយសនោះតិចតួច ក៏រត់ទៅកាន់ទិសទាំងឡាយ។ ពួកជនអ្នកចង់ទៅកាន់ឋានសួគ៌ ស្វែងរកសេចក្តីសុខ ក៏លះបង់នូវស្រូវ ទ្រព្យ និងពួកញាតិ ហើយដុតកំដៅនូវតបៈដ៏សៅហ្មងអស់កាលយូរអង្វែង តែបែរជាឡើងកាន់ផ្លូវខុស ត្រឡប់ទៅកាន់ទុគ្គតិ ព្រោះតែសេចក្តីប្រាថ្នា។ នៃនាងអាសា នាងឯងដែលឈ្មោះថា អាសា គេសន្មតថាជាស្រីបោកប្រាស់នូវជនទាំងនេះ (ហេតុនោះ) នាងចូរបន្ទោបង់នូវសុធាភោជន ចំពោះខ្លួនឯងចុះ ស្រីប្រហែលនាង មិនគួរទទួលអាសនៈ និងទឹកទេ សុធាភោជន នឹងមានអំពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ។

[២៨០] នាងជាស្រីមានយស រុងរឿងដោយយស ជាធំក្នុងទិស គេហៅដោយឈ្មោះថោកទាប ម្នាលនាងមានរាងកាយដូចរូបប្រៀបជាវិការនៃមាស អាត្មាសួរនាង នាងចូរប្រាប់ដល់អាត្មា នាងជាទេវតាឈ្មោះអ្វី។

[២៨១] (នាងសទ្ធា...) ខ្ញុំជានាងទេវីឈ្មោះសទ្ធា ដែលគេបូជាក្នុងពួកមនុស្ស មិនសេពគប់នូវសត្វដ៏លាមកសព្វៗកាល មកកាន់សំណាក់លោកដោយការឈ្លោះប្រកែក ព្រោះសុធាភោជន បពិត្រលោកអ្នកមានប្រាជ្ញាដ៏ប្រសើ ព្រោះហេតុនោះ សូមលោកចែករំលែកនូវសុធាភោជនដល់ខ្ញុំ។

[២៨២] (កោសិយៈ...) ជួនកាល មនុស្សទាំងឡាយពឹងផ្អែកលើសទ្ធា ទើបធ្វើនូវទាន នូវការទូន្មានឥន្ទ្រិយ នូវការបរិច្ចាគ និងការសង្រួមក៏មាន មនុស្សពួកខ្លះ ដែលឃ្លាតអំពីនាង (សទ្ធា) វិញ ក៏ធ្វើនូវការលួច កុហក បន្លំ និងញុះញង់ក៏មាន។ បុរសអ្នកប្រាជ្ញាក្នុងភរិយាទាំងឡាយ ដែលមានគុណសម្បត្តិស្មើគ្នា ជាស្រីបរិបូណ៌ដោយសីល មានវត្តចំពោះប្តី តែលះបង់នូវសេចក្តីប្រាថ្នាក្នុងពួកស្រីដែលមានត្រកូលល្អ ហើយធ្វើនូវការជឿចំពោះកុម្ភទាសីវិញក៏មាន។ ម្នាលនាងសទ្ធា នាងឯងគប់រកនូវប្រពន្ធរបស់ជនដទៃ ហើយធ្វើនូវអំពើដ៏លាមក លះចោលនូវកុសល ស្រីប្រហែលនាង មិនគួរទទួលនូវអាសនៈ និងទឹកទេ សុធាភោជននឹងមានអំពីណា នាងចូរទៅចុះ អាត្មាមិនពេញចិត្តនឹងនាងទេ។

[២៨៣] ទិសខាងកើតឯណា មានសម្បុររូបដ៏ឧត្តម ប្រាកដច្បាស់ក្នុងវេលាអរុណរះឡើង ក្នុងទីបំផុតនៃរាត្រី ម្នាលនាងទេវធីតា នាងប្រាកដច្បាស់ដល់អាត្មា ដូចជាទិសខាងកើតនោះដែរ នាងចូរប្រាប់អាត្មា នាងជាស្រីអប្សរអ្វី។ នាងឈ្មោះអ្វី ដូចជាវល្លិ៍ប្រេង ដែលត្រូវខ្យល់ មានរបៀបនៃស្លឹកដ៏ក្រហមក្នុងនិទាឃរដូវ ឬដូចជាអណ្តាតភ្លើង ពុំនោះសោត ដូចម្រឹគស្មាវ កាលក្រឡេកមើល នាងហាក់ដូចជាមានប្រាថ្នានឹងនិយាយ តែមិនបញ្ចេញនូវវាចាទៅវិញ។

[២៨៤] (នាងហិរី...) ខ្ញុំជានាងទេវីឈ្មោះហិរី ដែលគេបូជាក្នុងពួកមនុស្ស ជាស្រីមិនសេពគប់នូវសត្វដ៏លាមកសព្វៗកាល មកកាន់សំណាក់លោកដោយការឈ្លោះប្រកែក ព្រោះសុធាភោជន តែខ្ញុំនោះមិនអាចនឹងសុំនូវសុធាភោជនទេ ធម្មតាការសុំគេនៃស្រី ដូចជាការបើកបង្ហាញកេរ្តិ៍ខ្មាស។

[២៨៥] (កោសិយៈ...) ម្នាលនាងមានរាងកាយល្អ នាងនឹងបាន (នូវសុធាភោជន) តាមសភាពតាមហេតុ នេះពិតជាធម៌ហើយ ដ្បិតថាសុធាភោជន គេមិនបានព្រោះការសុំទេ ព្រោះហេតុនោះ អាត្មានឹងអញ្ជើញនាងដែលមិនសុំ នាងប្រាថ្នានូវសុធាភោជនណាៗ អាត្មានឹងឲ្យនូវសុធាភោជននោះៗ ដល់នាង។ ម្នាលនាងមានរាងកាយដូចរូបប្រៀប ជាវិការៈនៃមាស នាងនោះអាត្មានឹងអញ្ជើញទៅក្នុងអាស្រមរបស់អាត្មាក្នុងថ្ងៃនេះ នាងជាស្រីគួរអាត្មាបូជាដោយវត្ថុមានរសគ្រប់យ៉ាង អាត្មាលុះបូជានាងហើយ ទើបនឹងបរិភោគនូវសុធាភោជនដែរ។

[២៨៦] (អភិសម្ពុទ្ធគាថា) នាងហិរីនោះ ជាស្រីមិនសេពគប់នូវសត្វលាមកសព្វៗកាល ដែលកោសិយតាបសមានអានុភាពដ៏រុងរឿងអនុញ្ញាតហើយ ក៏ចូលទៅកាន់អាស្រម ជាទីរីករាយ ជាអាស្រមមានទឹក មានផ្លែឈើ ដែលពួកអរិយជនបូជាហើយ។ ជិតអាស្រមនោះ មានព្រៃឈើស៊ុមទ្រុមដ៏ច្រើន មានផ្ការីកហើយ ដើមស្វាយ ដើមទ្រយឹង ដើមខ្នុរ ដើមចារ ដើមម្រម ដើមលោទ ដើមភ្លៅកង្អែប ដើមលំចេក ដើមចន្ទន៍ ដើមត្រមូំច មានផ្ការីកហើយ។ ជិតអាស្រមនោះ មានដើមឈើច្រើន គឺដើមរាំង ដើមថ្គាន់ ដើមព្រីង ដើមពោធិ៍បាយ ដើមជ្រៃ ដើមស្រគំ មានមែកទោរទន់ចុះ និងដើមរាជព្រឹក្ស ដើមច្រនៀង ដើមជ្រៃពួរ ដើមរាំងអន្លក់ និងដើមលំចេក មានក្លិនផ្សព្វផ្សាយគួរគាប់ចិត្ត។ ជិតអាស្រមនោះ មានអបរណ្ណជាតិ អំពៅខ្មៅ សណ្តែកព្រៃ ដើមទន្លាប់ ស្រងៃ និងគែលលក សណ្តែករាជមាស ចេកមានគ្រាប់ និងស្រូវស្រូវក្រហមជាច្រើន ផ្លែចេញជាអង្ករគួរបរិភោគបាន។ នៅខាងជើងនៃទីអាស្រមនោះ មានជាតស្រះបោក្ខរណីដ៏ក្សេម មិនមានវត្ថុអាក្រក់ មានកំពង់មិនចោទ ជាស្រះដ៏ស្អាតប្រកបដោយទឹកមានក្លិនមិនគួរខ្ពើម។ ក្នុងស្រះនោះ មានពួកត្រី ត្រេកត្រអាល ជាសត្វមានសេចក្តីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺត្រីផ្ទក់ ត្រីខ្ចឹង ត្រីក្រាយ បង្កង ត្រីឆ្តិន ត្រីស្លាត និងត្រីក្អែក ក៏ហែបហែលទៅមកដេរដាស។ ក្នុងស្រះនោះ មានពួកសត្វស្លាបត្រេកត្រអាល ជាសត្វមានសេចក្តីក្សេម មានគ្រឿងបរិភោគដ៏ច្រើន គឺហង្ស ក្រៀល ក្ងោក ចាកក្រពាក អក តាវៅ ក្ងោកមាស ទោម ព្រហីត ដ៏ច្រើន។ មានពួកសត្វ គឺហ្វូងនៃម្រឹគផ្សេងៗ ជាច្រើន គឺសីហៈ ខ្លាធំ ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន រមាស គោព្រៃ ក្របី រមាំង ប្រើស ទ្រាយ ជ្រូកព្រៃ ក្តាន់ និងជ្រូកស្រុក មកប្រជុំគ្នាក្បែរស្រះនោះ។ មានឈ្លូស ឆ្មា ទន្សាយ និងខ្ទីងជាច្រើន ផែនដី និងភ្នំពេញពាសដោយផ្កាដ៏វិចិត្រ កងរំពងដោយសម្លេងនៃសត្វបក្សី មានហ្វូងបក្សីគប់រកជានិច្ចក្បែរស្រះនោះ។

[២៨៧] នាងហិរីនោះ មានស្បែកដ៏ល្អ តោងដើមឈើមានពណ៌ដ៏ខៀវ បានចូលទៅ (កាន់អាស្រម) ហាក់ដូចជាផ្លេកបន្ទោររបស់មហាមេឃ កោសិយតាបស បានរៀបចំកៅអី ដែលមានបណ្តាញប្រទាក់គ្នាដ៏ល្អ ជាវិការៈនៃស្បូវភ្លាំងដ៏ស្អាត មានក្លិនដ៏ល្អ ពាសដោយស្បែកខ្លាឃ្មុំ បម្រុងនាងហិរីនោះ បានពោលពាក្យនេះនឹងនាងហិរីថា ម្នាលនាងមានលំអ នាងចូរអង្គុយឲ្យស្រួលចុះ នេះជាអាសនៈ។ កាលដែលនាងហិរីនោះបិតនៅលើកៅអី ប្រាថ្នានូវសុធាភោជនណា គ្រានោះ កោសិយតាបស អ្នកទ្រទ្រង់នូវផ្នួងស័ក់ដ៏រុងរឿង ជាមហាមុនីប្រញាប់ប្រញាល់ បាននាំមកនូវសុធាភោជននោះ ព្រមទាំងទឹកដោយស្លឹកឈូកថ្មីៗ ដោយខ្លួនឯង។ នាងហិរីនោះ មានចិត្តត្រេកអរ បានទទួលនូវសុធាភោជននោះ ដោយដៃទាំងពីរ ហើយពោលនឹងកោសិយតាបស អ្នកទ្រទ្រង់នូវផ្នួងសក់ដូច្នេះថា បពិត្រព្រហ្ម ឥឡូវនេះ ខ្ញុំដែលលោកបូជាហើយ ជាបុគ្គលមានជ័យជំនះ សូមទៅកាន់ភពត្រៃត្រឹង្សវិញ។ នាងហិរីនោះ ដែលកោសិយតាបសមានអានុភាពដ៏រុងរឿង បានអនុញ្ញាតហើយ ជាស្រីស្រវឹងដោយការស្រវឹងនឹងវណ្ណៈ ក៏ទៅក្នុងសំណាក់ព្រះឥន្ទ្រជាសហស្សចក្ខុ រួចក្រាបទូលថា បពិត្រព្រះវាសវៈ នេះជាសុធាភោជន សូមព្រះអង្គទ្រង់ប្រទាននូវជ័យជំនះដល់ខ្ញុំ។ នាងហិរីនោះ ដែលពួកទេវតា និងមនុស្សផ្គងអញ្ជលីបូជាហើយ ក៏ចូលទៅអង្គុយលើកៅអីដ៏ថ្មីក្នុងកាលណា ព្រះឥន្ទ្រ ព្រមទាំងពួកទេវតា ក៏បូជានាងហិរីនោះ ជាទេវធីតាដ៏ឧត្តមក្នុងកាលនោះ។

[២៨៨] សហស្សនេត្ត ជាធំជាងពួកទេវតាជាន់ត្រៃត្រឹង្ស ទ្រង់បានត្រាស់នឹងមាតលិទេវបុត្តនោះម្តងទៀតថា អ្នកចូរទៅសួរកោសិយតាបស តាមពាក្យរបស់យើងថា បពិត្រកោសិយៈ នាងហិរី ដទៃអំពីនាងអាសា នាងសទ្ធា នាងសិរី បាននូវសុធាភោជន ដោយហេតុអ្វី។

[២៨៩] មាតលិទេវបុត្ត បានឡើងជិះរថនោះ អណ្តែតទៅដោយស្រួលដំរុងរឿងប្រហែលនឹងគ្រឿងឧបករណ៍ មានចន្ទោលជាវិការៈនៃមាសជម្ពូនទ ភ្លឺដូចជាអណ្តាតភ្លើង ដែលបុញ្ញឫទ្ធិប្រដាប់ស្រស់ល្អ ប្រកបដោយកម្រាលជាវិការៈនៃមាស វិចិត្រដោយកែវ ៧ ប្រការ។ ក្នុងរថនុ៎ះ មានរូបព្រះចន្ទជាវិការៈនៃមាស រូបដំរី គោ សេះ កិន្នរ ខ្លាធំ ខ្លាដម្បង ទ្រាយជាច្រើនក្នុងរថនោះ មានរូបបក្សីជាវិការៈនៃកែវផ្សេងៗ ក្នុងរថនោះ មានទាំងរូបម្រឹគប្រកបដោយហ្វូងជាវិការៈនៃកែវពៃទូរ្យក្នុងរថនោះ។ ពួកទេវតា បានទឹមនូវស្តេចសេះ មានសម្បុរលឿងមួយពាន់ក្នុងរថនោះ ជាសេះមានសម្បុរដូចមាស ប្រហែលនឹងដំរីស្វារ ប្រដាប់ដោយគ្រឿងអលង្ការ មានគ្រឿងប្រដាប់ទ្រូងជាវិការៈនៃបណ្តាញមាស មានគ្រឿងប្រដាប់ពាក់ត្រចៀក ស្ទុះទៅដោយគ្រាន់តែឮសម្លេង ជាសេះមានសន្ទុះដ៏លឿន។ មាតលិទេវបុត្ត បានឡើងជិះរថនោះ ជាយានដ៏ប្រសើរ ហើយញុំាងទិសទាំង ១០ នេះ ឲ្យគឹកកងរំពង ទាំងញុំាងអាកាសភ្នំ ឈើម្ចាស់ព្រៃ សាគរ និងផែនដី ឲ្យរំភើបញាប់ញ័រ។ មាតលិទេវបុត្តនោះ ចូលទៅកាន់អាស្រមជាឆាប់ ពានាសំពត់ទិព្វជាស្រេច រួចផ្គងអញ្ជលីពោលទៅនឹងកោសិយតាបស ជាទេវព្រាហ្មណ៍ ដែលជាពហុស្សុត ជាអ្នកចំរើនដោយគុណ មានអាចរិយវត្តទូន្មានហើយ ដូច្នេះថា បពិត្រកោសិយៈ សូមលោកស្តាប់ពាក្យព្រះឥន្ទ្រ ខ្ញុំឯងជាទូតព្រះឥន្ទ្រ សូមសួរលោកថា បពិត្រកោសិយៈ ចុះនាងហិរី ដទៃអំពីនាងអាសា នាងសទ្ធា និងនាងសិរី តើបាននូវសុធាភោជនដោយហេតុអ្វី។

[២៩០] (កោសិយ...) ម្នាលមាតលិ ជាទេវសារថី នាងសិរីប្រាកដច្បាស់ដល់អាត្មា ថាជាស្ត្រីស្តុកស្តម្ភស្រាប់ហើយ ចំណែកនាងសទ្ធា ប្រាកដដល់អាត្មាថាជាស្ត្រី មិនទៀង នាងអាសា ក៏ប្រាកដដល់អាត្មា ថាជាស្រីដែលគេសន្មត ថាជាស្ត្រីបោកប្រាស់ ឯនាងហិរី តាំងនៅស៊ប់ក្នុងគុណដ៏ប្រសើរ។

[២៩១] ពួកនាងកុមារីណា ដែលត្រកូលរក្សាហើយក្តី ពួកស្ត្រីចាស់ៗ (ស្ត្រីមេម៉ាយ) ណាក្តី ពួកស្ត្រីណា ដែលមានប្តីក្តី ស្ត្រីទាំងនោះ (ដឹងច្បាស់) នូវឆន្ទរាគដែលកើតឡើងក្នុងពួកបុរស ហើយរារាំងនូវចិត្តរបស់ខ្លួនដោយហិរិ។ កាលជនទាំងឡាយ បរាជ័យ ក្នុងប្រធាននៃសង្គ្រាម ដែលប្រកបដោយព្រួញ និងលំពែង ស្ទុះរត់ទៅ ជនទាំងនោះ បានលះបង់នូវជីវិត ក៏ត្រឡប់វិលវិញដោយហិរិ មានចិត្តប្រកបដោយហិរិ ទទួលយក (ម្ចាស់) វិញ។ ច្រាំងជាគ្រឿងរារាំងនូវកំឡាំងនៃរលកទឹកក្នុងសមុទ្រយ៉ាងណា ហិរិនេះ ក៏ឃាត់នូវជនចាកបាប យ៉ាងនោះដែរ។ ម្នាលទេវសារថី ព្រោះហេតុនោះ អ្នកចូរក្រាបទូលព្រះឥន្ទ្រថា ហិរិនោះ ត្រូវអរិយជនបូជាហើយក្នុងលោកទាំងពួង។

[២៩២] (មាតលិទេវបុត្ត...) បពិត្រកោសិយៈ បុគ្គលណាជាព្រហ្ម ឬព្រះឥន្ទ្រ ឬបជាបតិ ប្រកាន់តាមសេចក្តីយល់របស់លោកនេះថា ធីតារបស់ព្រះឥន្ទ្រ ជាស្ត្រីស្វែងរកនូវគុណដ៏ប្រសើរ ដែលគេសន្មតថាជាស្ត្រីប្រសើរបំផុតក្នុងពួកទេវតា ព្រោះតែហិរិ។

[២៩៣] បើដូចនោះ ឥឡូវនេះ សូមលោកមក សូមលោកទៅកាន់ឋានត្រៃត្រឹង្ស សូមលោកឡើងជិះរថ ដែលជាទីគាប់ចិត្តនេះ បពិត្រលោកអ្នកមានគោត្រស្មើដោយព្រះឥន្ទ្រ ព្រះឥន្ទ្រទន្ទឹងលោក សូមលោកទៅនៅរួមជាមួយនឹងព្រះឥន្ទ្រក្នុងថ្ងៃនេះ។

[២៩៤] (អភិសម្ពុទ្ធគាថា) ពួកសត្វអ្នកមិនធ្វើនូវអំពើបាប រមែងបរិសុទ្ធយ៉ាងនេះ មួយទៀត ផលនៃកុសល ដែលបុគ្គលបានសន្សំល្អហើយ រមែងមិនសាបសូន្យទេ ពួកសត្វណាមួយ បានឃើញនូវសុធាភោជន (ក្នុងកាលនោះ) សត្វទាំងអស់នោះឯង រមែងដល់នូវការនៅរួមជាមួយនឹងព្រះឥន្ទ្រ។

[២៩៥] នាងហិរីទេវធីតា គឺនាងឧប្បលវណ្ណាភិក្ខុនី កោសិយតាបស គឺភិក្ខុជាម្ចាស់ទាន បញ្ចសិខទេវបុត្ត គឺអនុរុទ្ធភិក្ខុ មាតលិទេវបុត្ត គឺអានន្ទ សុរិយទេវបុត្ត គឺកស្សបភិក្ខុ ចន្ទទេវបុត្ត គឺមោគ្គល្លាន នារទតាបស គឺសារីបុត្ត ឯព្រះវាសៈ គឺតថាគតជាព្រះសម្ពុទ្ធ។

ចប់ សុធាភោជនជាតក ទី៣។

## កុណាលជាតក ទី៤

CS sut.kn.jat.536 | ភាគទី ៦១

### (៥៣៦. កុណាលជាតកំ (៤))

[២៩៦] ហេមវន្តប្រទេស ដែលគេតែងពោលយ៉ាងនេះ តែងឮយ៉ាងនេះ មានសេចក្តីតំណាលថា បក្សីកុណាល (តាវៅ) មានសម្បុរដ៏វិចិត្រក្រៃលែង មានស្លាបជាគ្រឿងបិទបាំងដ៏វិចិត្រក្រៃលែង តែងនៅអាស្រ័យក្នុងដងព្រៃជាទីរីករាយ មានសភាពយ៉ាងនេះ ជាប្រទេសទ្រទ្រង់នូវធរណី ប្រកបដោយឱសថគ្រប់យ៉ាង រយោងរយានដោយចង្កោមផ្កាជាច្រើន ជាប្រទេសជាទីចរទៅមករឿយៗ នៃដំរី គោ ក្របី ប្រើសមាស ចាមរី ក្តាន់ រមាស ខ្ទីង សីហៈ ខ្លាធំ ខ្លាដម្បង ខ្លាឃ្មុំ ឆ្កែព្រៃ ខ្លារខិន ភេ ឈ្លូស ខ្លាត្រី ទន្សាយ រមាំង ជាទីអាស្រ័យនៅនៃហ្វូងដំរីតូចៗ និងដំរីធំ និងមេដំរីក្នុងនាគត្រកូល ដ៏ដេរដាស ជាទីអាស្រ័យនៅនៃខ្លាឃ្មុំ ស្វាសរភៈ ម្រឹគ ទ្រាយ ក្តាន់បុរិសាលុ (យក្ខិនីមានមុខដូចសេះ) កិន្នរ យក្ស អារក្សទឹក ជាព្រៃដ៏ដេរដាសដោយពួកឈើជាច្រើនយ៉ាង គឺឈើមានផ្កាក្រពុំ ឈើមានត្រយលាស់រហង់ សឹងដ៏ខៀវខ្វារដោយហ្វូងបក្សីជាច្រើន គឺសត្វអក លលកទ្រាំង ហាត្ថិលិង្គ ក្ងោក ទីទុយ ប៉ោលតោក ចាប កុកក្រក ស៊ម្បុកត្រពាំង ករវិក ជាប្រទេសដ៏ប្រដាប់ដោយវត្ថុជាទីត្រេកអរច្រើនយ៉ាង គឺថ្មមនោសិលាមានពណ៌ខៀវដូចផ្កាអញ្ចាន់ ជាតិហិង្គុល មាស ប្រាក់ មាសស្រយ និងលោហធាតុជាច្រើនយ៉ាង។ បក្សីតាវៅនោះឯង មានបក្សីញីចំនួន ៣៥០០ សុទ្ធតែបក្សីជំទង់ចាំបំរើ។ មានសេចក្តីដំណាលថា គ្រានោះ បក្សីញីជំទង់ពីរ ពាំមែកឈើដោយចំពុះ ឲ្យបក្សីតាវៅឈ្មោលនោះទំត្រង់កណ្តាលមែកឈើ ហើរឡើងទៅដោយគិតថា សូមកុំឲ្យមានសេចក្តីលំបាកក្នុងផ្លូវឆ្ងាយបៀតបៀនបក្សីតាវៅឈ្មោលនោះឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០០ ក៏ហើរពីខាងក្រោមៗ ដោយគិតថា បើបក្សីតាវៅនេះធ្លាក់ពីបង្គង យើងនឹងទទួលបក្សីតាវៅនោះដោយស្លាបទាំងឡាយ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរ អំពីខាងលើៗ ដោយគិតថា សូមកុំឲ្យកំដៅក្តៅដល់បក្សីតាវៅឈ្មោលនោះឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០០ ម្ខាងៗ ហើរអមអំពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ ក្តៅ ស្មៅធូលី ខ្យល់ ឬទឹកសន្សើមប៉ះពាល់ត្រូវបក្សីតាវៅឈ្មោលនោះឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅអំពីខាងមុខៗ ដោយគិតថា សូមកុំឲ្យគង្វាលគោ គង្វាលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំឧស អ្នកធ្វើការងារក្នុងព្រៃ ប្រហារនូវបក្សីតាវៅឈ្មោលនោះ ដោយកំណាត់ឈើ ដោយអម្បែង ដោយដៃ (ដោយដុំថ្ម) ដោយដុំដី ដោយដម្បង ដោយសាស្ត្រាវុធ ឬដោយដុំក្រួសទាំងឡាយឡើយ សូមកុំឲ្យបក្សីតាវៅនោះប៉ះទង្គិចនឹងគុម្ពឈើ វល្លិ៍ ដើមឈើ មែកឈើ សសរ ថ្មភ្នំ ឬពួកបក្សីមានកម្លាំងឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរអមអំពីខាងក្រោយៗ និយាយឆ្លើយឆ្លងគ្នា ដោយពាក្យស្រទន់ផូរផង់ពីរោះផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យបក្សីតាវៅនេះ អផ្សុកនៅលើទ្រនំឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០០ ហើរទៅគ្រប់ទិស នាំយកផ្លែឈើផ្សេងៗ ចំឡែកជាច្រើន ដោយគិតថា សូមកុំឲ្យបក្សីតាវៅនេះ លំបាកដោយការស្រេក ឃ្លានឡើយ។ គ្រានោះ ពួកហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំបក្សីតាវៅនោះអំពីសួនច្បារទៅកាន់សួនច្បារ អំពីឧទ្យាន ទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹងទៅកាន់កំពង់ស្ទឹង អំពីកំពូលភ្នំទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីងទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្លទៅកាន់ព្រៃខ្នុរសម្ល អំពីព្រៃដូងទៅកាន់ព្រៃដូង ដើម្បីសេចក្តីសប្បាយរីករាយដោយឆាប់រហ័ស។ គ្រានោះឯង បក្សីតាវៅនោះ ដែលពួកបក្សីកញ្ញាទាំងនោះចោមរោមហើយពេញមួយថ្ងៃ ក៏បណ្តោញយ៉ាងនេះថា នែមេចង្រៃ ហាងឯងទាំងឡាយ ចូរចៀសចេញទៅ នែមេចង្រៃជាចោរ ជាស្រីអ្នកលេងហីនហោច មានចិត្តស្រាល មិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នករហើរហោចក្នុងកាមដូចជាខ្យល់ ហាងឯងទាំងឡាយចូរវិនាសទៅ។

[២៩៧] មានសេចក្ដីដំណាលថា ក្នុងភាគទិសខាងកើតនៃស្ដេចភ្នំហិមវន្តនោះឯង មានស្ទឹងហូរនាំយកនូវស្មៅខៀវខ្ចីអំពីភ្នំដែលមានទឹកដ៏ល្អសុខុមផ្កាឈ្ងុំ។ មានសេចក្ដីដំណាលថា តាវើសឈ្មោះបុណ្ណមុខ: មានសម្លេងដ៏ពីរោះក្រលួច មានភ្នែកក្រឡៀត ដូចភ្នែកអ្នកស្រវឹង តែងអាស្រ័យនៅក្នុងដងព្រៃជាទីសប្បាយរីករាយ មានសភាពយ៉ាងនេះ គឺប្រទេសជាទីពេញចិត្តរីករាយដោយផ្កាឧប្បលឈូកក្រហម កុមុទ ឈូកស ឈូកមានស្រទាប់ជាច្រើន ចង្កូលណីមានក្លិនក្រអូបឈ្ងុយឈ្ងប់ ទើបនឹងដុះឡើងថ្មីៗ ជាព្រៃដេរដាសដោយកុរវកព្រឹក្ស រាំងអន្លក់ កេតកព្រឹក្ស វេទិសព្រឹក្ស ដើមជ្រៃ ដើមបុន្នាគ ពកុល ទ្រមូច ទ្រមូង ក្ទម្ព ផ្ទង់រាំងភ្នំ ស្រឡៅ ចម្បក អសោកព្រឹក្ស ខ្នឹងស្មាច់ លោទ្ធ និងចន្ទក្រហម ជាព្រៃញាតស្បាតដោយដើមឈើខ្មៅ បិយង្គុមានពណ៌ក្រហម ទេពទារូ ចេកមានគ្រាប់ ជាព្រៃទ្រទ្រង់នូវដើមថ្វាន់ ខ្លែងគង់ ព្រស ម៉ៃសាក់ កណិការ ដើមច្បារ ដើមប្រមោយដំរី ដើមរលួសផ្ទង ដើមចារ ដើមយុថ្កា និងចង្កោមផ្កាម្លិះព្រៃ ក្ដាំងងាចម្បា ចម្បី នូនស្រី ជាព្រៃដ៏ដេរដាសដោយម្លិះរួត ចេកទេស ច្រនៀង ដើមទ្រាំង ក្រឹស្នា ស្បូវភ្លាំង និងគុម្ពឈើជាពួកៗ ជាប្រទេសដ៏ប្រដាប់ដោយដើមឈើដ៏ដេរដាស គឺដើមរំដួល និងវល្លិ៍មានផ្កាដ៏ល្អ ជាព្រៃឮសូរសម្រែកនៃសត្វហង្ស ទុង ប្រវឹក ក្អែកទឹក ជាទីដែលពួកវិទ្យាធរសមណ: និងតាបសឥសីស័ក្ដសិទ្ធ នៅអាស្រ័យ ជាប្រទេសដែលនរជន ទេវតា យក្ស អារក្សទឹក អសុរ គន្ធព្វ និងកិន្នរអាស្រ័យនៅជាច្រើន។ មានសេចក្ដីដំណាលថា សត្វតាវើសឈ្មោះបុណ្ណមុខ:នោះឯង មានបក្សីកញ្ញាចំនួន ៣៥០ ជាអ្នកបម្រើ។ មានសេចក្ដីដំណាលថា គ្រានោះឯង មានបក្សីកញ្ញាពីរ ពាំមែកឈើដោយមាត់ ហើយឲ្យសត្វតាវើសឈ្មោះបុណ្ណមុខ:នោះទុំត្រង់កណ្ដាល ហើរទៅដោយគិតថា កុំឲ្យមានសេចក្ដីលំបាកក្នុងផ្លូវឆ្ងាយប៉ះពាល់តាវើសឈ្មោះបុណ្ណមុខ:នោះឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០ ក៏ហើរពីខាងក្រោមៗ ដោយគិតថា បើតាវើសឈ្មោះបុណ្ណមុខ:នេះ នឹងធ្លាក់អំពីបង្គង ពួកយើងនឹងទទួលតាវើសនោះ ដោយស្លាបទាំងឡាយ។ ពួកបក្សីកញ្ញាចំនួន ៥០ ក៏ហើរអំពីខាងលើៗ ដោយគិតថា សូមកុំឲ្យកំដៅក្ដៅដល់តាវើសឈ្មោះបុណ្ណមុខ:នោះឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០ (ម្ខាង) ក៏ហើរអមអំពីខាងទាំងពីរ ដោយគិតថា សូមកុំឲ្យត្រជាក់ ក្ដៅ ស្មៅ ធូលី ខ្យល់ ឬទឹកសន្សើម ប៉ះពាល់ត្រូវតាវើសឈ្មោះបុណ្ណមុខ:នោះឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរទៅអំពីខាងមុខៗ ដោយគិតថា សូមកុំឲ្យគង្វាលគោ គង្វាលសត្វចិញ្ចឹម អ្នកនាំស្មៅ អ្នកនាំឧសអ្នកធ្វើការងារក្នុងព្រៃ ប្រហារស្ដេចសត្វតាវើសឈ្មោះបុណ្ណមុខ:នោះដោយកំណាត់ឈើ ដោយអម្បែង ដោយដៃ (ដោយដុំថ្ម) ដោយដុំដីដោយដម្បង ដោយសាស្ត្រាវុធ ដោយដុំក្រួសទាំងឡាយ សូមកុំឲ្យតាវើសឈ្មោះបុណ្ណមុខ:នេះ ប៉ះទង្គិចនឹងគុម្ពឈើ វល្លិ៍ ដើមឈើមែកឈើ សសរ ដុំថ្មភ្នំ ឬក៏ពួកបក្សីមានកម្លាំងឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរអំពីខាងក្រោយៗ និយាយឆ្លើយឆ្លងគ្នាដោយពាក្យដ៏ស្រទន់ផ្អែមល្ហែម ដោយគិតថា សូមកុំឲ្យតាវើសឈ្មោះបុណ្ណមុខ: អផ្សុកលើទ្រនំឡើយ។ ពួកបក្សីកញ្ញាចំនួន ៥០ ហើរទៅគ្រប់ទិស នាំយកផ្លែឈើផ្សេងៗ ចំឡែកជាច្រើនយ៉ាង ដោយគិតថា សូមកុំឲ្យតាវើសឈ្មោះបុណ្ណមុខ:នេះ លំបាកដោយការស្រេកឃ្លានឡើយ។ គ្រានោះ ពួកហ្វូងបក្សីកញ្ញាទាំងនោះ ហើរនាំតាវើសឈ្មោះបុណ្ណមុខ:អំពីសួនច្បារ ទៅកាន់សួនច្បារ អំពីឧទ្យានទៅកាន់ឧទ្យាន អំពីកំពង់ស្ទឹង ទៅកាន់កំពង់ស្ទឹង អំពីកំពូលភ្នំ ទៅកាន់កំពូលភ្នំ អំពីព្រៃស្វាយ ទៅកាន់ព្រៃស្វាយ អំពីព្រៃព្រីង ទៅកាន់ព្រៃព្រីង អំពីព្រៃខ្នុរសម្លូ ទៅកាន់ព្រៃខ្នុរសម្លូ អំពីព្រៃដូង ទៅកាន់ព្រៃដូង ដើម្បីសេចក្ដីសប្បាយរីករាយដោយឆាប់រហ័ស។ គ្រានោះឯង តាវើសឈ្មោះបុណ្ណមុខ: ដែលពួកបក្សីកញ្ញាទាំងនោះ បំរើឈ្ងុយឆ្ងុយអស់ថ្ងៃមួយ សរសើរយ៉ាងនេះថា ម្នាលនាងទាំងឡាយ ប្រពៃណាស់ៗ នាងទាំងឡាយ បំរើប្ដីដោយហេតុណា ម្នាលនាងទាំងឡាយ ហេតុនោះឯង ជាកិច្ចដ៏សមគួរដល់នាងទាំងឡាយ ជាធីតាក្នុងត្រកូលហើយ។

[២៩៨] គ្រានោះ តាវើសឈ្មោះបុណ្ណមុខ: ចូលទៅរកកុណាលសកុណ: (តាវើខ្មៅ)។ បក្សីកញ្ញាជាអ្នកបំរើកុណាលសកុណ: បានឃើញតាវើសឈ្មោះបុណ្ណមុខ:នោះមកពីចម្ងាយ លុះឃើញហើយ នាំចូលទៅរកតាវើសឈ្មោះបុណ្ណមុខ: លុះចូលទៅដល់ហើយ និយាយពាក្យនេះនឹងតាវើសឈ្មោះបុណ្ណមុខ:នោះថា បពិត្របុណ្ណមុខ:សម្លាញ់ កុណាលសកុណ:នេះ អាក្រក់ក្រៃលែង មានសំដីអាក្រក់ក្រៃលែង ពួកយើងសូមពឹងផ្អែកនូវលោក ក្រែងបានវាចាជាទីស្រឡាញ់ (អំពីកុណាល:)។ តាវើស ឆ្លើយតបថា ឱប្អូនស្រីទាំងឡាយ យ៉ាងនោះឬ ហើយក៏ចូលទៅរកកុណាលសកុណ: លុះចូលទៅដល់ហើយ ក៏និយាយសំណេះសំណាល ជាមួយនឹងកុណាលសកុណ: ហើយទំក្នុងទីដ៏សមគួរ។ លុះតាវើសឈ្មោះបុណ្ណមុខ: ទំក្នុងទីដ៏សមគួរហើយ និយាយពាក្យនេះនឹងកុណាលសកុណ:នោះថា នៃកុណាល:សម្លាញ់ ហេតុអ្វី អ្នកប្រតិបត្តិខុសចំពោះតាវើញី ដែលមានជាតិល្អ ជាធីតាក្នុងត្រកូល ជាអ្នកប្រតិបត្តិល្អ នៃកុណាល:សម្លាញ់ ឮថា អ្នកគួរនិយាយសំដីជាទីពេញចិត្ត ទៅរកពួកតាវើញី សូម្បីនិយាយសំដីមិនជាទីគាប់ចិត្ត នឹងបាច់និយាយថ្វីដល់ពួកតាវើញី ជាសត្វនិយាយសំដីជាទីពេញចិត្ត។ កាលបើតាវើសនិយាយយ៉ាងនេះហើយ កុណាលសកុណ: ក៏បណ្ដេញតាវើសឈ្មោះបុណ្ណមុខ:នោះថា នៃសំឡាញ់ ជាសត្វអាក្រក់ចង្រៃ អ្នកចូរចៀសចេញ នៃសំឡាញ់ជាសត្វអាក្រក់ចង្រៃ អ្នកចូរវិនាសទៅ នរណាឡើយ ជាអ្នកឈ្លាសវៃជាងអ្នកជាអ្នកចាញ់ស្រី។ ចំណែកខាងតាវើសឈ្មោះបុណ្ណមុខ: ត្រូវកុណាលសកុណ: បណ្ដេញយ៉ាងនេះហើយ ក៏ត្រឡប់មកអំពីទីនោះវិញ។

[២៩៩] គ្រានោះឯង លុះសម័យខាងក្រោយមក កន្លងទៅមិនយូរប៉ុន្មាន តាវើសឈ្មោះបុណ្ណមុខ: មានជម្ងឺជាទម្ងន់។ មានវេទនាយ៉ាងខ្លាំង គឺរោគធ្លាក់ឈាម រៀបដល់នូវមរណ:។ គ្រានោះ ពួកបក្សីកញ្ញា ជាអ្នកបំរើតាវើសឈ្មោះបុណ្ណមុខ: មានសេចក្ដីត្រិះរិះយ៉ាងនេះថា តាវើសឈ្មោះបុណ្ណមុខ:នេះ មានជម្ងឺជាខ្លាំង ធ្វើដូចម្ដេច លោកនឹងបានសះស្បើយចាកជម្ងឺនេះ។ ពួកបក្សីកញ្ញាបោះបង់តាវើសនោះ ឲ្យនៅតែម្នាក់ឯង មិនឲ្យមានគ្នាជាគំរប់ពីរ ហើយនាំគ្នាចូលទៅរកកុណាលសកុណ:។ កុណាលសកុណ:នោះ បានឃើញពួកបក្សីកញ្ញាទាំងនោះ កំពុងមកពីចម្ងាយ លុះឃើញហើយ និយាយពាក្យនេះនឹងពួកបក្សីកញ្ញានោះថា នៃមេចង្រៃរាល់គ្នា ចុះប្ដីរបស់ហាងឯងទៅក្នុងទីណា។ ពួកបក្សីកញ្ញាទាំងនោះតបថា បពិត្រកុណាល:ជាម្ចាស់ តាវើសឈ្មោះបុណ្ណមុខ: មានជម្ងឺជាខ្លាំង ធ្វើដូចម្ដេចលោកនឹងបានសះស្បើយចាកជម្ងឺនោះ។ កាលពួកបក្សីកញ្ញាឆ្លើយតបយ៉ាងនេះហើយ កុណាលសកុណ: ក៏បណ្ដេញពួកបក្សីកញ្ញាទាំងនោះយ៉ាងនេះថា នៃពួកមេចង្រៃ ហាងឯងចូរចៀសចេញទៅ នៃមេចង្រៃជាចោរ ជាស្រីអ្នកលេង ហីនហោច មានចិត្តស្រាល មិនធ្វើតបចំពោះឧបការគុណដែលគេធ្វើហើយ ជាអ្នករហើរហោចក្នុងកាមដូចជាខ្យល់ ហាងឯងទាំងឡាយ ចូរវិនាសទៅ លុះពោលដូច្នេះហើយ ក៏ចូលទៅរកតាវើសឈ្មោះបុណ្ណមុខ: លុះចូលទៅដល់ហើយ ទើបនិយាយពាក្យនេះនឹងតាវើសឈ្មោះបុណ្ណមុខ:នោះថា នៃបុណ្ណមុខ:សំឡាញ់ ម្ដេចទៅហ៎។ តាវើសឆ្លើយថា ឱកុណាល:សំឡាញ់។ គ្រានោះ កុណាលសកុណ:ជួយគ្រាហ៍តាវើសឈ្មោះបុណ្ណមុខ:នោះ ដោយស្លាបទាំងឡាយផង ដោយចំពុះផង ឲ្យក្រោកឡើង ទើបឲ្យផឹកថ្នាំផ្សេងៗ។ គ្រានោះ ជម្ងឺរបស់តាវើសឈ្មោះបុណ្ណមុខ:នោះ ក៏ជាសះស្បើយ។

[៣០០] គ្រានោះ កុណាលសកុណ: បាននិយាយពាក្យនេះនឹងតាវើសឈ្មោះបុណ្ណមុខ: ដែលសះស្បើយចាកជម្ងឺ ដែលស្រាកស្រាន្តចាកភាពនៃខ្លួនជាអ្នកឈឺ មិនយូរប៉ុន្មានថា នៃបុណ្ណមុខ:សំឡាញ់ កុមារីឈ្មោះនាងកណ្ហា មានបិតាពីរ មានប្ដី ៥ នាក់ ជាប់ចំពាក់ចិត្តក្នុងបុរសទី ៦ គឺក្នុងបុរសខ្វិនគម (ដូចខ្មោចកំបុតក) ក៏ខ្ញុំបានឃើញហើយ។ ពាក្យក្នុងរឿងនោះ មានដូចតទៅនេះ

ស្ត្រីប្រព្រឹត្តកន្លងប្ដីទាំង ៥ នាក់នុ៎ះគឺ អជ្ជុនរាជកុមារ ១ នកុលរាជកុមារ ១ ភីមសេនរាជកុមា ១ យុធិដ្ឋិលរាជកុមារ ១ សហទេវរាជកុមារ ១ ធ្វើនូវអំពើដ៏លាមកគឺ សេពមេថុនធម្មជាមួយបុរសគមទាបតឿ។

នៃបុណ្ណមុខ:សំឡាញ់ នាងសមណីឈ្មោះបញ្ចតបារី កាលនៅកណ្ដាលព្រៃស្មសាន រំលងចោលនូវបាយ ៤ ដង បានធ្វើនូវអំពើដ៏លាមកជាមួយនឹងអ្នកលេងសុរា ខ្ញុំបានឃើញហើយ។ នៃបុណ្ណមុខ:សំឡាញ់ នាងទេវីឈ្មោះកាករតី កាលនៅកណ្ដាលសមុទ្រ ជាភរិយារបស់វេនតេយ្យ បានធ្វើនូវអំពើដ៏លាមក ជាមួយនឹងបុរសឈ្មោះនដកុវេរ: ខ្ញុំក៏បានឃើញហើយ។ នៃបុណ្ណមុខ:សំឡាញ់ ព្រះអគ្គមហេសីមានព្រះលោមាល្អ ព្រះនាមកុរុង្គទេវី កាលចង់បានឯឡកកុមារ ធ្វើនូវអំពើដ៏លាមកជាមួយនឹងបុរសអ្នកនៅដោយទ្រព្យ (របស់ខ្ញុំគេ) ឈ្មោះឆឡង្គកុមារ ខ្ញុំក៏បានឃើញហើយ។ សេចក្ដីពិត រឿងដូចគ្នានេះ ខ្ញុំដឹងហើយយ៉ាងនេះថា ព្រះវរមាតារបស់ព្រះបាទព្រហ្មទត្ត លះបង់ព្រះបាទកោសល ទៅធ្វើអំពើដ៏លាមកជាមួយនឹងព្រាហ្មណកុមារឈ្មោះបញ្ចាលចណ្ឌ:។

ពួកស្ត្រីទាំងនុ៎ះក្តី ពួកស្ត្រីឯទៀតក្តី បានធ្វើនូវអំពើដ៏លាមក ព្រោះហេតុនោះ ទើបខ្ញុំមិនទុកចិត្ត មិនសរសើរស្ត្រីទាំងឡាយទេ ពួកស្ត្រីដូចផែនដី ជាទីដើរទៅ ជាទីទ្រទ្រង់ មានសេចក្តីត្រេកអរស្មើ ជាទីតំកល់ទុកនៃវត្ថុគ្រប់យ៉ាង អត់ធន់ចំពោះអារម្មណ៍ទាំងពួង មិនញាប់ញ័រ មិនកម្រើក នរជនមិនគប្បីទុកចិត្តស្ត្រីទាំងនោះទេ សីហៈជាម្រឹគសាហាវ ជាសត្វស៊ីឈាម និងសាច់ មានអាវុធ ៥ សាហាវក្រៃលែង ត្រេកអរក្នុងការបៀតបៀនសត្វដទៃ កំហែងខាំស៊ីយ៉ាងណាមិញ ពួកស្ត្រីទាំងនោះក៏ដូច្នោះដែរ នរជនមិនត្រូវទុកចិត្តឡើយ។

នែបុណ្ណមុខៈសំឡាញ់ ស្រីទាំងឡាយមិនមែនឈ្មោះថាពេស្យា ថានារី ថាជាទីគប់រកទេ ស្រីទាំងនុ៎ះ មិនមែនគ្រាន់តែឈ្មោះថាអ្នកកោងកាច អ្នកចងទុក (នូវបុរស) ទេ ស្រីទាំងនុ៎ះ គឺស្រីពេស្យា នារីជាទីគប់រក ឈ្មោះថា ស្រីសម្លាប់ (ប្តី)។ ពួកស្រីស្អិតស្អាងផ្ទងសក់ដូចចោរ ដូចគ្រឿងស្រវឹងដែលលាយដោយថ្នាំពិស បិទបាំងដោយវាចា ដូចពាណិជ មានអាការប្រែប្រួល ដូចកុយរមាស មានអណ្តាតពីរដូចពស់ បិទបាំង (នូវកាយ) ដូចជាគេបិទបាំងរណ្តៅ បំពេញបានដោយក្រ ដូចសមុទ្រ ត្រេកអរបានដោយក្រ ដូចអារក្សទឹក នាំទៅដោយដាច់ខាតដូចយមបាល ស៊ីនូវវត្ថុគ្រប់មុខដូចភ្លើង នាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង ប្រព្រឹត្តរហើរហាចដូចខ្យល់ ធ្វើនូវវត្ថុមិនឲ្យប្លែកគ្នាដូចភ្នំនេរុ ផ្លែជានិច្ច ដូចឈើមានពិសពុល។ ពាក្យក្នុងរឿងនេះ មានតទៅទៀតថា

ពួកស្រីមានកលមាយាដូចចោរ មានពិសខ្លាំងដូចសុរាដែលលាយថ្នាំពិស និយាយបិទបាំងទោសដូចពាណិជ មានអាការប្រែប្រួលដូចកុយរមាស មានអណ្តាតពីរដូចពស់។ ពួកស្រីបិទបាំង (នូវកាយ) ដូចជាគេបិទបាំងរណ្តៅ បំពេញបានដោយក្រដូចសមុទ្រ ត្រេកអរបានដោយក្រដូចអារក្សទឹក នាំយកទៅដោយដាច់ខាតដូចយមបាល។ ពួកស្រីដូចភ្លើង នាំយកនូវវត្ថុគ្រប់យ៉ាងដូចស្ទឹង មានអាការរហើរហាចក្នុងកាមដូចខ្យល់ មិនឲ្យមានប្លែកដូចភ្នំនេរុ មានផ្លែជានិច្ច ដូចឈើមានពិសពុល ពួកស្រីតែងញុំាងភោគៈក្នុងផ្ទះឲ្យវិនាស ធ្វើសេចក្តីអន្តរាយនូវរតនវត្ថុទាំងឡាយ។

[៣០១] នែបុណ្ណមុខៈសំឡាញ់ ទ្រព្យណា ដែលបុគ្គលមិនត្រូវឲ្យនៅក្នុងត្រកូលនៃជនដទៃ ទ្រព្យទាំងនេះ មាន ៤ យ៉ាងគឺ គោឈ្មោល ១ មេគោ ១ យាន ១ ភរិយា ១ បណ្ឌិតមិនត្រូវញុំាងទ្រព្យទាំង ៤ យ៉ាងនេះ ឲ្យនៅប្រាសចាកផ្ទះឡើយ។

បុគ្គលមិនគប្បីញុំាងគោឈ្មោល ១ គោញី ១ យាន ១ ភរិយា ១ ឲ្យនៅក្នុងត្រកូលញាតិទេ (ព្រោះថា) ពួកបុគ្គល មិនមានរទេះ រមែងប្រើប្រាស់រទេះ បៀតបៀននូវគោឈ្មោល ដោយការដឹកនាំហួសកម្លាំង បៀតបៀនមេគោ ដោយការរូតទឹកដោះ ភរិយារមែងប្រព្រឹត្តខូច (ក្បត់ចិត្តប្តី) ក្នុងត្រកូលនៃញាតិ។

[៣០២] នែបុណ្ណមុខៈសំឡាញ់ វត្ថុ ៦ យ៉ាងនេះ រមែងមិនបានជាប្រយោជន៍ចំពោះកិច្ចការ ដែលកើតឡើងទេ (វត្ថុ ៦ យ៉ាង) គឺ ធ្នូគ្មានបន្លោះ ១ ភរិយា (ដែលនៅ) ក្នុងត្រកូលញាតិ ១ ទូកនៅឯត្រើយម្ខាង ១ រទេះបាក់ភ្លៅ ១ មិត្តនៅក្នុងទីឆ្ងាយ ១ សំឡាញ់ដ៏លាមក ១ (ទាំងនេះ) រមែងមិនបានជាប្រយោជន៍ចំពោះកិច្ចការដែលកើតឡើងទេ។

[៣០៣] នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងមើលងាយប្តីដោយហេតុ ៨ យ៉ាងគឺ សេចក្តីទ័លក្រ ១ សេចក្តីឈឺចាប់ជានិច្ច ១ សេចក្តីចាស់គ្រាំគ្រា ១ ភាពជាអ្នកលេងផឹកសុរា ១ ភាពល្ងង់ខ្លៅ ១ សេចក្តីធ្វេសប្រហែស ១ ការមិនប្រព្រឹត្តធ្វើរឿយៗ ក្នុងកិច្ចការទាំងពួង ១ ការមិនញុំាងទ្រព្យសម្បត្តិគ្រប់យ៉ាងឲ្យកើតមាន ១ នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងមើលងាយប្តីដោយហេតុ ៨ យ៉ាងនេះឯង។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ស្រីមើលងាយប្តី (ដោយហេតុ ៨ យ៉ាង) គឺ ប្តីទ័លក្រ ១ ប្តីឈឺជានិច្ច ១ ប្តីចាស់គ្រាំគ្រា ១ ប្តីជាអ្នកលេងផឹកសុរា ១ ប្តីធ្វេសប្រហែស ១ ប្តីដល់នូវភាពល្ងង់ខ្លៅ ១ ប្តីខ្ជិលច្រអូសក្នុងកិច្ចការ ១ ប្តីញុំាងសេចក្តីប្រាថ្នាក្នុងវត្ថុដែលគួរប្រាថ្នាគ្រប់យ៉ាងឲ្យវិនាស ១។

[៣០៤] នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងនាំមកនូវការប្រព្រឹត្តិខូចដោយហេតុ ៩ យ៉ាងគឺ ស្រីទៅកាន់សួនច្បាររឿយៗ ១ ទៅកាន់ឧទ្យានរឿយៗ ១ ទៅកាន់កំពង់ស្ទឹងរឿយៗ ១ ទៅកាន់ត្រកូលញាតិរឿយៗ ១ ទៅកាន់ត្រកូលដទៃរឿយៗ ១ ប្រកបរឿយៗ ក្នុងការលៃលកតែខាងកញ្ចក់ និងសំពត់ នឹងគ្រឿងស្អិតស្អាងជាប្រក្រតី ១ ផឹកនូវទឹកស្រវឹងជាប្រក្រតី ១ មានការលបមើលបុរសមិនដាច់ជាប្រក្រតី ១ ឈរបង្ហាញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១ នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងនាំមកនូវការខូចកាចដោយហេតុ ៩ យ៉ាងនេះឯង។ ពាក្យក្នុងរឿងនេះ មានតទៅទៀត

ពួកស្រី តែងនាំមកនូវការខូច ដោយហេតុ ៩ យ៉ាង គឺជាអ្នកទៅកាន់សួនច្បាររឿយៗ ១ ទៅកាន់ឧទ្យាន ១ ទៅកាន់ស្ទឹង ១ ទៅកាន់ត្រកូលញាតិ ១ ទៅកាន់ត្រកូលដទៃ ១ ប្រកបរឿយៗ តែខាងសំពត់ នឹងគ្រឿងស្អិតស្អាង ១ ជាស្រីផឹកទឹកស្រវឹង ជាប្រក្រតី ១ មានការលបមើលបុរសមិនដាច់ជាប្រក្រតី ១ ឈរបង្ហាញខ្លួនទៀបមាត់ទ្វារជាប្រក្រតី ១។

[៣០៥] នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងចែចង់បុរសដោយហេតុ ៤០ យ៉ាងគឺ កាច់រាង ១ បន្ទន់ខ្លួន ១ កែក្រាយ ១ ក្រអិមក្រអៀម ១ យកក្រចកផ្ទាត់ក្រចក ១ យកជើងជាន់ជើង ១ យកកំណាត់ឈើគូសផែនដី ១ លើកកូនក្មេងដោយខ្លួនឯង ១ ឲ្យកូនក្មេងលើកខ្លួនវិញ ១ លេងកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យលេង ១ ថើបកូនក្មេងដោយខ្លួនឯង ១ ញុំាងកូនក្មេងឲ្យថើបវិញ ១ ស៊ីខ្លួនឯង ១ ញុំាងកូនក្មេងឲ្យស៊ី ១ ឲ្យវត្ថុទៅកូនក្មេង ១ សុំល្ងងលោមយកមកវិញ ១ ធ្វើត្រាប់តាម (ក្មេង) ដែលវាធ្វើ ១ និយាយខ្លាំង ១ និយាយតិច ១ និយាយបើកចំហមាត់ ១ និយាយលាក់លៀម ១ (ធ្វើនូវនិមិត្ត) ដោយអាការរាំច្រៀងប្រគំ យំរាប់រៀបម៉្ញីកម៉្ញក់ស្អិតស្អាង ១ សើចក្អាកក្អាយ ១ សំឡឹងសំឡក់ ១ ញាក់ចង្កេះ ១ ញុំាងទ្រព្យកំបាំងឲ្យកំរើក ១ បើកបង្ហាញភ្លៅ ១ បិទភ្លៅទៅវិញ ១ បង្ហាញដោះ ១ បង្ហាញក្លៀក ១ បង្ហាញផ្ចិត ១ មិចភ្នែក ១ ញាក់ចិញ្ចើម ១ ខាំបបូរមាត់ ១ លៀនអណ្តាត ១ ច្បូតសំពត់ ១ ស្លៀកសំពត់វិញ ១ រំសាយសក់ ១ បួងសក់វិញ ១ នែបុណ្ណមុខៈសំឡាញ់ ស្រីរមែងចែចង់បុរសដោយហេតុ ៤០ យ៉ាងនេះឯង។

[៣០៦] នែបុណ្ណមុខៈសំឡាញ់ ស្រីដែលខូច បណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាង គឺស្រីសរសើរការនៅឃ្លាតអំពីប្តី ១ មិនរឭកប្តីដែលនៅឃ្លាតគ្នា ១ មិនត្រេកអរនឹងប្តីដែលទើបមកដល់ ១ ពោលទោសប្តីនោះ ១ មិននិយាយសរសើរគុណប្តីនោះ ១ ប្រព្រឹត្តនូវសេចក្តីវិនាសដល់ប្តីនោះ ១ មិនប្រព្រឹត្តសេចក្តីចំរើនដល់ប្តីនោះ ១ ធ្វើតែអំពើដែលមិនគួរធ្វើដល់ប្តីនោះ ១ មិនធ្វើអំពើដែលគួរធ្វើដល់ប្តីនោះ ១ ស្លៀកជាប់មាំមួនដេក ១ លបដេកកំបាំងមុខ ១ ដេកបម្រះននៀល ១ បង្កជម្លោះ ១ ដកដង្ហើមចេញវែង (ដូចជា) រងទុក្ខ ១ ទៅកាន់ទីឧច្ចារៈបស្សាវៈរឿយៗ ១ ប្រព្រឹត្តទទឹងទាស់ ១ ឮសម្លេងប្រុសឯទៀត ខំផ្ទៀងត្រចៀកស្តាប់ ១ ជាស្រីបំផ្លាញទ្រព្យ ១ ធ្វើនូវសន្ថវកិច្ចនឹងប្រុសទាំងឡាយដែលស្និទ្ធស្នាល ១ បានតែខាងជើងចេញដើរ ១ ជាស្រីប្រព្រឹត្តដើរលេងរឿយៗ ក្នុងវេលាយប់ ប្រព្រឹត្តកន្លងចិត្តប្តី ១ មិនគោរពប្តី ១ មានចិត្តគំនិតខូចកាច ១ ឈរទៀបមាត់ទ្វារញយៗ ១ បង្ហាញក្លៀក រាងកាយ ដោះ ដើរទៅកាន់ទិសទាំងពួងហើយក្រឡេកមើល ១ នែបុណ្ណមុខៈសំឡាញ់ ស្រីដែលខូច បណ្ឌិតគប្បីដឹងដោយហេតុ ២៥ យ៉ាងនេះឯង។ ពាក្យក្នុងរឿងនុ៎ះ ដូចមានតទៅទៀត

ស្រីសរសើរនូវការនៅឃ្លាតអំពីប្តីនោះ ១ មិននឹកស្រណោះរកប្តីដែលទៅហើយ ១ ឃើញប្តីមកដល់ មិនត្រេកអរ ១ មិនពោលសរសើរគុណប្តីក្នុងកាលណាម្តង ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច។ ស្រីជាអ្នកមិនសង្រួម ប្រព្រឹត្តនូវសេចក្តីវិនាសដល់ប្តីនោះ ១ ញុំាងប្រយោជន៍ឲ្យវិនាស ១ ជាអ្នកធ្វើនូវកិច្ចដែលមិនគួរធ្វើ ១ ស្លៀកជាប់មាំមួនដេក ១ ដេកក្ដុំងទីកំបាំងមុខ ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច។

ស្រីដេកបម្រះននៀល ១ បង្កដង្ហោះ ១ ដកដង្ហើមវែង (ហាក់ដូចជា) រងទុក្ខវេទនា ១ ទៅកាន់ទីឧច្ចារៈ បស្សាវៈរឿយៗ ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច។ ស្រីជាអ្នកមិនធ្វើការងារ តែងប្រព្រឹត្តទទឹងទាស់ ១ ផ្ទៀងស្តាប់សម្លេងរបស់បុរសដទៃនិយាយ ១ បំផ្លាញទ្រព្យ ១ ធ្វើសន្ថវកិច្ច (នឹងបុរសដទៃ) ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច។ បំផ្លាញទ្រព្យសម្បត្តិដែលប្តីបានមកដោយក្រ នាំមកដោយលំបាក បានមកដោយទុក្ខ ១ ធ្វើសន្ថវកិច្ចនឹងពួកបុរសអ្នកស្និទ្ធស្នាល ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច។ ស្រីបានតែខាងជើងចេញដើរ ១ ដើរលេងរឿយៗ ក្នុងវេលាយប់ ១ មានចិត្តប្រទូស្តចំពោះប្តីជានិច្ច ១ ប្រព្រឹត្តកន្លងចិត្តប្តី ១ ប្រាសចាកសេចក្តីគោរព ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច។ ស្រីឈរទៀបមាត់ទ្វារញយៗ ១ បង្ហាញដោះ និងក្លៀក ១ មានចិត្តភ្ញាក់ផ្អើល ក្រឡេកមើលទិសទាំងពួង ១ ទាំងនេះជាលក្ខណៈរបស់ស្រីខូច។ ស្ទឹងទាំងអស់ មានដំណើរវៀច ព្រៃទាំងអស់សម្រេចអំពីឈើ (យ៉ាងណាមិញ) ពួកស្រីទាំងអស់ (វៀរលែងតែស្រីដែលមានកិលេសស្តើង) កាលបើមានបុគ្គលអ្នកខ្សឹបខ្សៀវ ក៏តែងធ្វើនូវអំពើលាមកបាន (យ៉ាងនោះដែរ)។ ពួកស្រី បាននូវឱកាស ឬទីកំបាំង ឬក៏បាននូវបុគ្គលខ្សឹបខ្សៀវប្រាកដដូច្នោះ ពួកស្រីទាំងអស់ មិនបាននូវបុរសដទៃ ក៏គប្បីធ្វើនូវអំពើលាមក ជាមួយបុរសខ្វិនបាន។ ពួកបុរស ទោះបីធ្វើនូវអំណរចំពោះនារីទាំងឡាយ ជាអ្នកធ្វើនូវសេចក្តីត្រេកអរដល់ពួកបុរស ជាស្រីមានចិត្តច្រើន ដែលគេផ្ទញ់ផ្ទាល់មិនបានដោយប្រការទាំងពួង បុគ្គលមិនត្រូវស្និទ្ធស្នាលទេ ព្រោះថា ស្រីទាំងឡាយ ស្មើដោយកំពង់ទឹក។

[៣០៧] បុគ្គលឃើញ (នូវហេតុនៃសេចក្តីនឿយណាយ) របស់ព្រះរាជាព្រះនាមកិន្នរៈ និងព្រះនាងកិន្នរី (គប្បីដឹងចុះ) ពួកស្រីទាំងអស់ រមែងមិនត្រេកអរក្នុងផ្ទះ (របស់ស្វាមីទេ) ដូចជាភរិយា (របស់ព្រះរាជាកិន្នរៈ) លះបង់នូវសត្វគឺ (ស្វាមី) បែបនោះ ព្រោះឃើញនូវបុរសផ្តេសផ្តាសដទៃជាបុរសខ្វិន។

[៣០៨] ភរិយារបស់ព្រះបាទពកៈ និងព្រះបាទពាវរិយៈ ជាព្រះរាជាល្មោភកាមដ៏ក្រៃលែង បានប្រព្រឹត្តក្បត់ចំពោះបុរសអ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា ស្រីមិនប្រព្រឹត្តកន្លងស្វាមីនឹងបុរសដទៃនោះឯណាកើត។

[៣០៩] នាងបិង្គិយានី ជាភរិយាជាទីស្រឡាញ់នៃព្រះបាទព្រហ្មទត្ត ព្រះអង្គជាធំក្នុងលោកទាំងមូល បានប្រព្រឹត្តក្បត់ចំពោះបុរសអ្នកលុះក្នុងអំណាចដែលខ្លួនប្រាថ្នា នាងបិយង្គិយានី ជាអ្នកល្មោភក្នុងកាមនោះ មិនបាននូវបុរសគង្វាលសេះនោះផង (នូវទីអគ្គមហេសីផង)។

[៣១០] បុរសដែលមិនមែនខ្មោចចូល មិនគួរជឿពួកស្រីដែលអាក្រក់ មានចិត្តរហ័ស ជាស្រីមិនដឹងគុណដែលគេធ្វើដល់ខ្លួន ជាស្រីប្រទូស្ត (ប្តី) ទេ។ ពួកស្រីទាំងនោះ មិនដឹងនូវឧបការៈដែលគេធ្វើហើយ (ដល់ខ្លួន) មិនដឹងនូវកិច្ចការដែលគួរធ្វើ មិនស្គាល់ម្តាយ មិនស្គាល់ឪពុក មិនស្គាល់បងប្អូន មិនមានអរិយធម៌ មានការប្រព្រឹត្តិកន្លងជាធម្មតា តែងលុះអំណាចចិត្តរបស់ខ្លួន។ ពួកស្រីតែងលះបង់ប្តីជាទីស្រឡាញ់ ជាទីពេញចិត្ត ជាអ្នកអនុគ្រោះស្មើដោយជីវិត ដែលភប់ប្រសព្វអស់កាលដ៏យូរ ឬលះបង់នូវប្តី ក្នុងកិច្ចមានអន្តរាយ ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ។ ព្រោះថា ចិត្តរបស់ស្រីដូចគ្នានឹងចិត្តពានរ ហឫទ័យរបស់ពួកស្រី ចុះឡើងញាប់ញ័រដូចជាម្លប់ឈើ តែងវិលទៅ ដូចកង់រទេះ។ ពួកស្រីទាំងនោះ កាលក្រឡេកមើលឃើញទ្រព្យរបស់ប្រុស ដែលគួរកាន់យកក្នុងកាលណា ក៏កៀរគរប្រុសនោះ ដោយសំដីដ៏ផ្អែមល្ហែមក្នុងកាលណោះ ដូចពួកជនអ្នកកម្ពោជៈ បញ្ឆោតចាប់សេះដោយសារាយ។ ពួកស្រីកាលបើក្រឡេកមើល មិនឃើញទ្រព្យរបស់ប្រុសដែលគួរកាន់យកក្នុងកាលណា ក៏វៀរប្រុសនោះដោយជុំវិញក្នុងកាលណោះ ដូចគេឆ្លងទៅដល់ត្រើយស្ទឹង ហើយលះបង់នូវក្បូន។ ពួកស្រីឧបមាដូចជ័រ (ជាទីជាប់ស្អិតនៃចិត្តបុរស) ដូចភ្លើងស៊ីនូវវត្ថុគ្រប់យ៉ាង មានមាយាដ៏រហ័ស ដូចស្ទឹងមានខ្សែទឹកដ៏រហ័ស ពួកស្រីទាំងនេះ តែងសេពគប់បុរស ទាំងជាទីស្រឡាញ់ ទាំងមិនជាទីស្រឡាញ់ ដូចទូកតែងជួបប្រទះទាំងច្រាំងខាងអាយ និងច្រាំងខាងនាយ។ ពួកស្រីទាំងនោះ មិនមែនជារបស់ប្រុសម្នាក់ ឬពីរនាក់ទេ ដូចជារានផ្សារដែលបើកហើយ បុគ្គលណា សំគាល់នូវពួកស្រីទាំងនោះ ថាជារបស់អញ បុគ្គលនោះ ដូចគេយកសំណាញ់ខ្ទប់ខ្យល់។ ស្ទឹង ផ្លូវ រោងសុរា រោងជាទីប្រជុំ និងអណ្តូងទឹក យ៉ាងណា ធម្មតាពួកស្រីក្នុងលោក ក៏យ៉ាងនោះដែរ វេលា (នៃសេចក្តីស្រើបក្នុងកាម) របស់ពួកស្រីទាំងនោះ មិនមានឈប់ឈរទេ។ ពួកស្រីទាំងនេះ ស្មើដោយអណ្តាតភ្លើង មានឧបមាដូចក្បាលពស់វែក ដូចពួកគោស៊ីនូវស្មៅដ៏ល្អៗ ខាងក្រៅ។ នរៈគប្បីគប់រកដោយការប្រយ័ត្ននូវវត្ថុទាំងនេះ គឺភ្លើង ១ ដំរី ១ ពស់វែក ១ ព្រះរាជាដែលគេអភិសេកហើយ ១ ពួកស្រីទាំងអស់ ១ ព្រោះភាពទៀងទាត់នៃវត្ថុទាំងនោះ ដឹងបានដោយក្រណាស់។ ពួកស្រីមានពណ៌សម្បុរដ៏ល្អលើសលុបពេក បុគ្គលមិនត្រូវសេពគប់ ១ ស្រីជាទីស្រឡាញ់ពេញចិត្តរបស់ពួកជនច្រើន បុគ្គលមិនត្រូវសេពគប់ ១ ស្រីឆ្លៀវឆ្លាសក្នុងការរាំ និងច្រៀង បុគ្គលមិនត្រូវសេពគប់ ១ ប្រពន្ធអ្នកដទៃ បុគ្គលមិនត្រូវសេពគប់ ១ ស្រី (សេពគប់) ព្រោះហេតុនៃទ្រព្យ បុគ្គលក៏មិនត្រូវសេពគប់ ១ ស្រី ៥ ពួកនេះ បុគ្គលមិនត្រូវសេពគប់ទេ។

[៣១១] ដំណាលថា គ្រានោះ ស្តេចត្មាតឈ្មោះអានន្ទ បានដឹងនូវគាថាជាខាងដើម កណ្តាល និងខាងចុង របស់កុណាលសកុណៈ ហើយបានពោលគាថានេះ ក្នុងវេលានោះថា

បុរស ទោះបីឲ្យនូវផែនដី ដែលពេញដោយទ្រព្យ ដល់ស្ត្រីដែលសន្មតហើយ ស្រីនោះលុះបានឱកាស រមែងមើលងាយប្រុសនោះវិញ (ព្រោះហេតុនោះ) បុរសមិនត្រូវលុះអំណាចនៃស្រីទាំងនោះឡើយ។ ពួកស្រីរមែងលះបង់នូវប្តីក្មេង ដែលជាអ្នកមានព្យាយាមក្រោកឡើង មានការប្រព្រឹត្តិមិនរួញរា គួរជាទីស្រឡាញ់ពេញចិត្តផង លះបង់នូវប្តីនោះ ព្រោះកិច្ចដែលមានអន្តរាយផង ព្រោះហេតុនោះ ខ្ញុំមិនទុកចិត្តចំពោះស្រីទាំងឡាយទេ។ បុរសមិនត្រូវទុកចិត្តស្រីដោយគិតថា ស្រីនោះចង់បានអញ មិនត្រូវទុកចិត្តស្រីដោយគិតថា ស្រីនោះ យំរំដែចំពោះអញ (ដូច្នេះទេ) ព្រោះថា ស្រីទាំងនោះ រមែងគប់រកនូវបុរស ទាំងជាទីស្រឡាញ់ ទាំងមិនជាទីស្រឡាញ់ ដូចទូកជួបប្រទះទាំងច្រាំងខាងអាយ និងច្រាំងខាងនាយ។ បុគ្គលមិនត្រូវទុកចិត្តមែកឈើចាស់ ដែលគេក្រាលទុកទេ មិនត្រូវទុកចិត្តចោរជើងចាស់ជាមិត្តទេ មិនត្រូវទុកចិត្តថា ព្រះរាជា ជាសំឡាញ់របស់អញដូច្នេះទេ មិនត្រូវទុកចិត្តស្រីជាមាតារបស់បុត្ត ១០ នាក់ (យាយចាស់) ទេ។ បុគ្គលមិនត្រូវទុកចិត្តចំពោះពួកនារីអ្នកធ្វើនូវសេចក្តីត្រេកអរ អ្នកកន្លងសីលធម៌ មិនសង្រួមទេ មិនត្រូវទុកចិត្តភរិយា ដែលមានសេចក្តីស្រឡាញ់ក្រៃពេក ព្រោះថានារីទាំងឡាយទុកស្មើកំពង់ទឹក។ ពួកស្រី រមែងសម្លាប់ (ប្រុស) ខ្លះ កាត់ (កប្រុស) ខ្លួនឯងខ្លះ ប្រើគេឲ្យកាត់ខ្លះ កាត់កហើយផឹកឈាមខ្លះ បុគ្គលកុំធ្វើសេចក្តីស្នេហាចំពោះពួកស្រី ដែលមានសេចក្តីប្រាថ្នាថោកទាបជាអ្នកមិនសង្រួម មានចិត្តដូចកំពង់ទឹក។ ពាក្យកុហករបស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យពិត ឯពាក្យពិតរបស់ពួកស្រីទាំងនោះ ក៏ដូចជាពាក្យកុហក (ពួកស្រី) ដូចគោ ស៊ីច្បិចតែស្មៅល្អៗ ខាងក្រៅ។ ពួកស្រីទាំងនោះ តែងប្រឡោម (ប្រុស) ដោយដំណើរផង ដោយអាការដែលក្រឡេកមើលផង ដោយសំណើចផង ឬដោយសំពត់ដែលស្លៀកអាក្រក់ផង ដោយពាក្យពីរោះផង។ ពិតណាស់ ស្រីទាំងនេះដូចចោរ មានចិត្តរឹងត្អឹង ខូចកាច តែមានសំដីផ្អែមដូចស្ករ ការបញ្ឆោតណាក្នុងពួកមនុស្ស ពួកស្រីទាំងនោះ មិនមែនជាមិនដឹងការបញ្ឆោតណាមួយ (នោះ) ទេ។ ធម្មតា ពួកស្រីក្នុងលោក (ច្រើនតែ) លាមក វេលារបស់ពួកស្រីទាំងនោះមិនមានទេ ពួកស្រីជាអ្នកស្រើបស្រាលផង ឃ្លើសឃ្លងផង ដូចភ្លើងស៊ីវត្ថុគ្រប់យ៉ាង។ ប្រុសឈ្មោះថាជាទីស្រឡាញ់របស់ពួកស្រី មិនមាន ទាំងមិនជាទីស្រឡាញ់ក៏មាន ព្រោះថា ពួកស្រីទាំងនេះ តែងគប់រកបុរសជាទីស្រឡាញ់ ទាំងមិនស្រឡាញ់ ដូចទូកតែងចួបប្រទះទាំងច្រាំងខាងអាយ និងច្រាំងខាងនាយ។ ប្រុស ឈ្មោះថាជាទីស្រឡាញ់របស់ពួកស្រីមិនមាន ទាំងមិនជាទីស្រឡាញ់ក៏មិនមាន ពួកស្រីតែងរួបរ័ទ្ធ (ប្រុស) ដើម្បីទ្រព្យសម្បត្តិ ដូចវល្លិ៍ តោងដើមឈើ។ ស្រីទាំងឡាយ តែងរត់តាមប្រុសឃ្វាលដំរី ឃ្វាលសេះ ឃ្វាលគោ ប្រុសចណ្ឌាល អ្នកដុតខ្មោច និងអ្នកចោលសម្រាមដែលមានទ្រព្យ។ ស្រីទាំងឡាយ តែងលះបង់នូវកូនអ្នកមានត្រកូល ដែលមិនមានទ្រព្យតិចតួច ទុកស្មើសាកសព នារីទាំងឡាយ (ច្រើនតែ) គប់រកប្រុស ព្រោះហេតុតែទ្រព្យ។

[៣១២] សេចក្តីដំណាលថា គ្រានោះ ទេវព្រាហ្មណ៍ឈ្មោះនារទៈ បានដឹងនូវគាថាជាខាងដើម កណ្តាល និងទីបំផុត របស់ស្តេចត្មាតឈ្មោះអានន្ទហើយ ក៏ពោលគាថាទាំងឡាយនេះក្នុងវេលានោះថា

បពិត្រលោកជាម្ចាស់នៃបក្សី សូមលោកស្តាប់ពាក្យដែលខ្ញុំនឹងនិយាយដូចតទៅនេះ ជន ៤ ពួកនេះគឺ សមុទ្រ ១ ព្រាហ្មណ៍ ១ ព្រះរាជា ១ ស្រី ១ រមែងមិនពេញ។ ស្ទឹងណាមួយដែលអាស្រ័យនូវប្រឹថពីដែលហូរទៅកាន់សាគរ ស្ទឹងទាំងនោះ ក៏ញ៉ាំងសមុទ្រឲ្យពេញមិនបាន ព្រោះថា សមុទ្ររមែងមិនពេញ ចេះតែនៅខ្វះខាត។ ព្រាហ្មណ៍រៀននូវវេទ មានគម្ពីរឈ្មោះឥតិហាសៈ ជាគំរប់ ៥ ហើយតែងប្រាថ្នានូវការចេះដឹងឲ្យក្រៃលែង ព្រោះថា ព្រាហ្មណ៍នោះ រមែងមិនពេញ ចេះតែខ្វះខាត។ ចំណែកព្រះរាជាឈ្នះគ្រប់គ្រងផែនដីទាំងអស់ ព្រមទាំងសមុទ្រ និងភ្នំហើយ តែងប្រាថ្នារកច្រាំងសមុទ្រ និងផ្ទៃសមុទ្រ ដែលសម្បូរដោយរតនៈ មិនមានទីបំផុត ព្រោះថាព្រះរាជានោះ រមែងមិនគ្រប់គ្រាន់ ចេះតែខ្វះខាត។ ស្រីម្នាក់ៗ មានប្តីប្រាំបីៗ ហើយប្តីនោះ ជាអ្នកក្លៀវក្លាផង មានកម្លាំងផង នាំមកនូវរសនៃសេចក្តីប្រាថ្នាគ្រប់យ៉ាង ក៏គង់ធ្វើនូវសេចក្តីប្រាថ្នាក្នុងប្តីទី ៩ ទៀត ព្រោះថាស្រីនោះ រមែងមិនគ្រប់គ្រាន់ ចេះតែខ្វះខាត។ ពួកស្រីទាំងអស់ ដូចភ្លើងស៊ីនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចស្ទឹងនាំទៅនូវវត្ថុគ្រប់យ៉ាង ពួកស្រីទាំងអស់ ដូចមែកឈើមានបន្លា ពួកស្រីទាំងអស់ គប់រក (ប្តី) ព្រោះហេតុតែទ្រព្យ។ នរជនណា ផ្តេកផ្តាក់នូវភាព គឺការងារទាំងពួងលើពួកស្រី នរជននោះ ទុកដូចគេយកបណ្តាញចាប់ខ្យល់ ឬដូចគេបាចទឹកសមុទ្រដោយដៃម្ខាង ពុំនោះ ដូចគេយកដៃមួយ ទះឲ្យឮសូរគឹកកង។ ពួកស្រីដែលដូចជាចោរ មានពុតត្បុតច្រើន មានពាក្យសច្ចៈ គេរកបានដោយកម្រណាស់ ភាពនៃស្រីទាំងឡាយ គេដឹងបានដោយក្រ ដូចដំណើរនៃត្រីក្នុងទឹក។ ពួកស្រីទាំងនោះ មានមារយាទរបិញរបុញ មានសំដីទន់ ទុកស្មើដោយស្ទឹង បំពេញបានដោយក្រ តែងលិចចុះ (ក្នុងអបាយ ព្រោះហេតុតែកាម) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីវៀរឲ្យឆ្ងាយចេញ។ ពួកស្រីជាអ្នកញ៉ាំងចិត្តប្រុសឲ្យត្រឡប់ត្រឡិន មានមាយាច្រើន ញ៉ាំងព្រហ្មចរិយធម៌ឲ្យកម្រើក តែងលិចចុះ (ក្នុងអបាយ) បុគ្គលដឹងច្បាស់នូវដំណើរនោះហើយ គប្បីចៀសឲ្យឆ្ងាយចេញ។ ពួកស្រីទាំងនោះ ចូលទៅគប់រកប្រុសណា ដោយសេចក្តីប្រាថ្នា ឬដោយទ្រព្យសម្បត្តិ រមែងដុតកំដៅប្រុសនោះដោយឆាប់រហ័ស ដូចភ្លើងឆេះនូវទីរបស់ខ្លួន។

[៣១៣] សេចក្តីដំណាលថា គ្រានោះ កុណាលសកុណៈ ដឹងនូវគាថាជាខាងដើម កណ្តាល និងទីបំផុត នៃទេវព្រាហ្មណ៍ឈ្មោះនារទៈ ហើយក៏ពោលគាថានេះ ក្នុងវេលានោះថា

បណ្ឌិត គួរចរចា (ជាមួយ) នឹងបុគ្គលមានដៃកាន់ដាវសម្លៀងហើយ (ជាមួយ) នឹងបុគ្គលប្រទូស្តដូចជាបិសាច ឬក៏ចូលទៅរកពស់ ដែលមានពិសដ៏ពន្លឹក (ប្រសើរជាង) ប្រសម្នាក់ឯង មិនគួរនិយាយចរចា ចំពោះស្រីម្នាក់ឯងទេ។ ព្រោះថា នារីទាំងឡាយ ជាអ្នកញ៉ាំញីនូវចិត្តនៃមនុស្សលោក ជាអ្នកមានការរាំច្រៀង និយាយ សើច ញញឹម ជាអាវុធ តែងបៀតបៀននូវប្រុសដែលមិនបានតម្កល់ស្មារតី ដូចពួកស្រីអារក្សទឹក ក្នុងកោះបៀតបៀនពួកពាណិជ។ ពួកស្រីទាំងនោះមិនមានវិន័យ មិនមានសំវរៈ ពួកស្រីទាំងនោះ ជាអ្នកល្មោភទឹកស្រវឹង និងសាច់ ជាអ្នកមិនសង្រម តែងលេបទ្រព្យសម្បត្តិរបស់បុរស ដូចត្រីធំឈ្មោះតិមិង្គល លេបនូវមករក្នុងសាគរ។ ពួកស្រីមានសេចក្តីត្រេកអរក្នុងបញ្ចកាមគុណ៍ជាអារម្មណ៍ មានអាការឆ្មើងឆ្មៃ មិនទៀង មិនសង្រម ឃ្លាំរកតែបុរសអ្នកប្រមាទ ដូចទឹកស្ទឹង តែងហូរចុះទៅរកទីមានទឹកប្រៃ (សមុទ្រ)។ នារីទាំងឡាយ រមែងនិយាយស្រស់ស្រាយរកជនណា ដោយសេចក្តីស្រឡាញ់ ឬដោយតម្រេក ឬក៏ដោយទ្រព្យ ជាស្រីសម្លាប់ប្រុសដោយរាគៈ និងទោសៈ រមែងដុតពោលនរជននោះ សូម្បីប្រុសរុងរឿងដូចភ្លើងជាអ្នកនឹងនួន។ ពួកស្រីដឹងថា បុរសអ្នកស្តុកស្តម្ភ មានទ្រព្យច្រើន រមែងក្រវែលរកប្រុសដែលមានទ្រព្យដោយខ្លួនឯង រួបរុំបុរសដែលមានចិត្តត្រេកអរ ដូចពួរជ្រៃក្នុងព្រៃរួបព័ទ្ធដើមរាំង។ នារីទាំងឡាយនោះ មានខ្លួន និងមុខដ៏វិចិត្រតាក់តែងហើយ ផ្គាប់ផ្គុន (បុរស) ដោយសេចក្តីប្រាថ្នាផ្សេងៗ ជាអ្នកយល់កលមាយាទាំងរយ រមែងសើច រមែងញញឹម តែហាក់ដូចជាសង្រម។ នារីទាំងឡាយ ស្អិតស្អាងខ្លួនដោយមាស កែវមណី និងកែវមុក្តា ដែលគេធ្វើសក្ការៈក្នុងត្រកូលរបស់ប្តី ដែលគេរក្សាហើយ ក៏នៅតែប្រព្រឹត្តក្បត់ស្វាមីបាន ដូចជាប្រពន្ធដែលអាស្រ័យនៅក្នុងចន្លោះហឫទ័យប្រព្រឹត្តក្បត់អសុរិវិញបាន។ នរជន សូម្បីមានតេជៈ មានប្រាជ្ញាវាងវៃ ដែលអ្នកផងច្រើនគ្នាធ្វើសក្ការបូជា លុះក្នុងអំណាចនៃស្រីទាំងឡាយហើយ រមែងមិនរុងរឿង ដូចព្រះចន្ទ្រដែលត្រូវរាហូចាប់។ ចោរអ្នកក្រោធមានចិត្តអាក្រក់ (ឃើញ) ចោរជាសត្រូវ (នឹងខ្លួន) មកប្រទះគ្នាហើយ ធ្វើនូវសេចក្តីវិនាសណា បុគ្គលអ្នកមានត័ណ្ហា លុះក្នុងអំណាចនៃស្រីទាំងឡាយ រមែងដល់នូវសេចក្តីវិនាសក្រៃលែងជាងសេចក្តីវិនាសនោះទៅទៀត។ នារីទាំងឡាយ ដែលមានសក់របោច មានស្នាមដាច់ដោយក្រចក ដែលត្រូវគេវាយ គេធាក់ដោយជើង ដៃ និងដំបងក៏នៅតែចូលទៅកាន់អាការថោកទាបវិញ នៅតែត្រេកអរ (ក្នុងកាមទៀត) ដូចរុយត្រេកអរនឹងសាកសព។ បុរសអ្នកមានបញ្ញាចក្ខុ ត្រូវការដោយសេចក្តីសុខ គប្បីវៀរស្រីទាំងឡាយនោះ (ដែលនៅ) ក្នុងត្រកូលទាំងឡាយក្តី ក្នុងចន្លោះច្រកក្តី ក្នុងរាជធានីក្តី ក្នុងនិគមក្តី ឬក៏វៀរនូវអារម្មណ៍ដូចជាអន្ទាក់ និងបង្កាត់របស់មារ ដែលកិលេសមារដាក់ហើយក្តី។ បុគ្គលណា លះបង់នូវតបោគុណ (គុណ គឺសេចក្តីព្យាយាម) ជាកុសលហើយ ប្រព្រឹត្តនូវចរិតមិនប្រសើរ បុគ្គលនោះ (លុះច្យុត) ចាកទេវតាហើយ នឹងមកកាន់នរកវិញ ដូចពាណិជ (មានទ្រព្យច្រើនដូរយក) ក្អមកំបែក។ ប្រុស (ដែលលុះក្នុងអំណាចស្រី) នោះ ត្រូវគេតិះដៀលក្នុងលោកនេះផង ក្នុងលោកខាងមុខផង ជាមនុស្សមានគំនិតអាក្រក់ ត្រូវកម្មរបស់ខ្លួនបៀតបៀន ជាបុគ្គលមិនទៀង តែងភ្លាត់ទៅកាន់អបាយភូមិ ដូចរថដែលទឹមលាកាច ដើរទៅក្នុងទីខុសផ្លូវ។ ប្រុសនោះ រមែងចូលទៅកាន់នរក ជាទីញ៉ាំងសត្វឲ្យក្តៅ នៅអាស្រ័យនឹងព្រៃរកា មានបន្លាដូចលំពែង ធ្វើអំពីដែកផង កំណើតតិរច្ឆានផង វិស័យនៃប្រេត និងអសុរកាយផង រមែងមិនអាចរួចបានទេ។ ស្រីទាំងឡាយ រមែងញ៉ាំងល្បែងជាទិព្វ ឬញ៉ាំងតម្រេក ក្នុងទីជាទីរីករាយ ឬញ៉ាំងសម្បត្តិចក្រពត្តិ ក្នុងទីជារបស់មនុស្សនៃបុគ្គលអ្នកប្រមាទ ឲ្យវិនាស ពួកស្រី រមែងញ៉ាំងប្រុសនោះ ឲ្យដល់នូវទុគ្គតិ។ ល្បែងជាតម្រេកទិព្វ សម្បត្តិស្តេចក្រពត្តិ ក្នុងទីជារបស់មនុស្ស និងពួកស្រីអប្សរ មានវិមានមាសជាលំនៅ ជាសម្បត្តិដែលបុគ្គលមិនត្រូវការដោយពួកស្រ្តី ហើយប្រព្រឹត្ត (ព្រហ្មចរិយធម៌) មិនមែនបានដោយក្រទេ។ គតិជាទីកន្លងផុតចាកកាមធាតុ គឺការកើតក្នុងរូបធាតុ និងការកើតក្នុងសុទ្ធាវាស ជាវិស័យរបស់អ្នកប្រាសចាករាគៈ ជាសម្បត្តិដែលបុគ្គលមិនត្រូវការ ដោយពួកស្រី ហើយប្រព្រឹត្ត (ព្រហ្មចរិយធម៌) មិនមែនបានដោយក្រទេ។ គុណជាតិដ៏ក្សេមក្សាន្ត គឺព្រះនិព្វាន ជាទីកន្លងផុតចាកទុក្ខទាំងពួង ជាអច្ចន្តសុខ មិនកម្រើក មិនមានបច្ច័យតាក់តែង បុគ្គលមិនត្រូវការដោយស្រី ហើយប្រព្រឹត្ត (ព្រហ្មចរិយធម៌) ជាអ្នកស្អាត មានកិលេសរលត់ មិនមែនបានដោយក្រទេ។

[៣១៤] (ព្រះសាស្តា ទ្រង់ប្រជុំជាតកនេះថា) ក្នុងកាលណោះ កុណាលបក្សី បានមកជាតថាគត បុស្សកោកិលបក្សី បានមកជាឧទាយិភិក្ខុ ស្តេចត្មាត បានមកជាអានន្ទ នារទព្រាហ្មណ៍ បានមកជាសារីបុត្ត ពួកបរិស័ទបានមកជាពុទ្ធបរិស័ទ អ្នកទាំងឡាយចូរចាំទុកជាតកយ៉ាងនេះ។

ចប់ កុណាលជាតក ទី៤។

## មហាសុតសោមជាតក ទី៥

CS sut.kn.jat.537 | ភាគទី ៦១

**(៥៣៧. មហាសុតសោមជាតកំ (៥ ))**

[៣១៥] (សេនាបតី សួរថា) ម្នាលរសកៈ (នាយពិសេស) ព្រោះហេតុអ្វី អ្នកធ្វើនូវអំពើដ៏លាមកក្រៃលែងប្រាកដដូច្នេះ អ្នកជាបុគ្គលវង្វេង សម្លាប់ពួកស្រី និងប្រុស ព្រោះហេតុសាច់ ឬព្រោះហេតុទ្រព្យ។

[៣១៦] (នាយពិសេស ជំរាបថា) ខ្ញុំសម្លាប់ មិនមែនព្រោះហេតុខ្លួនឯង មិនមែនព្រោះហេតុទ្រព្យ មិនមែនព្រោះហេតុកូនប្រពន្ធ ឬសំឡាញ់ និងញាតិទេ បពិត្រលោកដ៏ចំរើន ព្រោះថា ព្រះភូមិបាលអ្នកមានបុណ្យ ជាម្ចាស់នៃខ្ញុំ ទ្រង់សោយនូវសាច់ប្រាកដដូច្នេះ។

[៣១៧] (សេនាបតី...) បើអ្នកឯងខ្វល់ខ្វាយក្នុងកិច្ចរបស់ព្រះរាជាជាម្ចាស់ ហើយធ្វើនូវអំពើដំលាមកក្រៃលែង អ្នកឯងលុះព្រឹកឡើង ចូលទៅខាងក្នុងព្រះរាជវាំងហើយ គប្បីនិយាយនូវដំណើរនោះប្រាប់ខ្ញុំ ក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា។

[៣១៨] (នាយពិសេស...) បពិត្រសេនាបតីឈ្មោះកាឡហត្ថីដ៏ចំរើន លោកនិយាយយ៉ាងណា ខ្ញុំនឹងធ្វើយ៉ាងនោះ ព្រឹកឡើងខ្ញុំនឹងចូលទៅខាងក្នុងព្រះរាជវាំង ហើយថ្លែងសេចក្តីនោះ ជំរាបលោកក្នុងទីចំពោះព្រះភក្ត្រនៃព្រះរាជា។

[៣១៩] (អភិសម្ពុទ្ធគាថា) គ្រានោះ កាលដែលវេលារាត្រីភ្លឺច្បាស់ ព្រះអាទិត្យរះឡើងប្រាកដ សេនាបតីឈ្មោះកាឡហត្ថី បាននាំរសេកៈចូលទៅគាល់ព្រះរាជា លុះចូលទៅដល់ហើយ ក៏ក្រាបទូលពាក្យនេះ ចំពោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គប្រើរសេកៈឲ្យទៅសម្លាប់ស្រីប្រុស ព្រះអង្គទ្រង់សោយសាច់មែនឬ។

[៣២០] (ព្រះរាជា...) ម្នាលកាឡហត្ថី ខ្ញុំបានប្រើរសេកៈដូច្នោះមែន ហេតុអ្វីអ្នកជេរប្រទេចរសេកបុរស ដែលធ្វើប្រយោជន៍ឲ្យខ្ញុំនុ៎ះ។

[៣២១] (កាឡហត្ថី...) ត្រីឈ្មោះអានន្ទ ជាប់ចិត្តនឹងរស ស៊ីនូវពួកត្រីទាំងពួង កាលបើត្រីជាបរិវារអស់ហើយ ក៏ខាំស៊ីកន្ទុយខ្លួនឯងស្លាប់ទៅ។ ព្រះអង្គជាអ្នកប្រមាទ ត្រេកអរក្នុងរសដែលគួរគោរព បើព្រះអង្គនៅជាបុគ្គលពាល មិនយល់ហេតុអ្វីតទៅយ៉ាងនេះទេ ព្រះអង្គនឹងឃ្លាតបោះបង់នូវបុត្រទាំងឡាយផង នូវពួកញាតិផង ដូចត្រីឈ្មោះអានន្ទត្រឡប់ស៊ីខ្លួនឯង។ បពិត្រព្រះរាជា សូមសេចក្តីប្រាថ្នារបស់ព្រះអង្គប្រាសចេញទៅ ព្រោះបានទ្រង់ព្រះសណ្តាប់នូវពាក្យនេះ សូមព្រះអង្គកុំសោយសាច់មនុស្ស បពិត្រព្រះអង្គជាធំជាងសត្វជើងពីរ សូមព្រះអង្គកុំធ្វើដែននេះឲ្យសោះសូន្យ ដូចត្រីឈ្មោះអានន្ទ ធ្វើមហាសមុទ្រទាំងមូលនេះឲ្យសូន្យ (ចាកត្រី)។

[៣២២] (ព្រះរាជា...) កូនបង្កើតរបស់សុជាតកុដុម្ពីនោះ ឈ្មោះសុជាតដោយឈ្មោះ មិនបានសាច់ព្រីងហើយស្លាប់ទៅ ព្រោះអស់សាច់ព្រីងនោះ (យ៉ាងណា) ម្នាលកាឡហត្ថី ខ្ញុំបរិភោគនូវអាហារមានរសដ៏ឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែលជានឹងលះបង់នូវជីវិតក៏យ៉ាងនោះដែរ។

[៣២៣] (កាឡហត្ថីនាំរឿងព្រាហ្មណ៍ថា) ម្នាលមាណពកូន អ្នកមានរូបស្រស់បស់ កើតក្នុងត្រកូលសោត្ថិយៈ ម្នាលកូន អ្នកមិនគួរស៊ីនូវអាហារដែលមិនគួរស៊ីទេ។

[៣២៤] (មាណព...) បណ្តារសទាំងឡាយ ទឹកសុរានេះ រាប់ថាជាទឹកមានរសមួយដែរ ព្រោះហេតុអ្វី ទើបលោកឪពុកឃាត់ខ្ញុំ ខ្ញុំបាននូវទឹកសុរានេះក្នុងទីណា ខ្ញុំនឹងទៅក្នុងទីនោះ។ បពិត្រព្រាហ្មណ៍ឪពុក បើលោកឪពុកមិនត្រេកអរនឹងការឃើញខ្ញុំណា ខ្ញុំនោះ នឹងដេញចេញ (អំពីស្រុក) ខ្ញុំមិននៅក្នុងសំណាក់លោកឪពុកទេ។

[៣២៥] (ព្រាហ្មណ៍...) នែមាណពកូន យើងនឹងបាននូវកូនទាំងឡាយឯទៀត ទទួលមត៌កដោយពិត នែកូនជូជាតិ ឯងចូរវិនាសចុះ លំនៅដែលកូនទៅដល់ក្នុងទីណា សូមកុំឲ្យអញឮនូវទីនោះ។

[៣២៦] (កាឡហត្ថី...) បពិត្រព្រះមហាក្សត្រិយ៍ ជាធំជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំ ពួកប្រជាជន នឹងបណ្តេញព្រះអង្គចាកដែន ដូចមាណព អ្នកលេងស៊ីផឹកដូច្នោះ។

[៣២៧] (ព្រះរាជា...) សាវ័ករបស់ពួកឥសី អ្នកមានខ្លួនអប់រំហើយ ជាសាវ័កឈ្មោះសុជាតៈ ប្រាថ្នានូវស្រីអប្សរ ទើបសាវ័កនោះ មិនស៊ីមិនផឹកទេ។ បុគ្គលយកទឹកដោយចុងស្មៅមកប្រៀបផ្ទឹមនឹងទឹកក្នុងសមុទ្រយ៉ាងណា កាមទាំងឡាយជារបស់មនុស្ស (ប្រៀបផ្ទឹម) ក្នុងសំណាក់នៃកាមជាទិព្វ ក៏យ៉ាងនោះដែរ។ ម្នាលកាឡហត្ថី ខ្ញុំបរិភោគនូវអាហារមានរសដ៏ឧត្តម បើមិនបានសាច់មនុស្សទេ ប្រហែលជាលះបង់ជីវិត យ៉ាងនោះឯង។

[៣២៨] (កាឡហត្ថី...) ដូចយ៉ាងពួកបក្សីហង្សឈ្មោះធតរដ្ឋៈទាំងនោះ ជាសត្វហើរឰដ៏អាកាស ដល់នូវសេចក្តីវិនាសទាំងអស់គ្នា ព្រោះស៊ីនូវចំណីមិនគួរ។ បពិត្រព្រះរាជា ជាធំជាងសត្វជើងពីរ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ខ្ញុំ បពិត្រព្រះរាជា ព្រះអង្គកុំសោយអាហារដែលមិនគួរសោយ ក៏យ៉ាងនោះឯង ពួកប្រជាជននឹងបណ្តេញព្រះអង្គ (ចាកដែន) ក៏យ៉ាងនោះដែរ។

[៣២៩] (ព្រះរាជា...) អ្នកកាលដែលខ្ញុំនិយាយថា អ្នកឈប់សិន ហើយចេះតែដើរទៅមុខ ម្នាលអ្នកជាព្រហ្មចារិនី អ្នកមិនឈប់ តែនិយាយថា ខ្ញុំឈប់ហើយ ពាក្យនេះមិនគួរដល់អ្នកជាសមណៈទេ អ្នកសំគាល់នូវដាវរបស់ខ្ញុំ គួរដល់សេចក្តីសង្ស័យដែរឬ។

[៣៣០] (ទេវតា...) បពិត្រព្រះរាជា អាត្មាជាអ្នកឈប់ ក្នុងព្រះសទ្ធម្មទាំងឡាយ មិនត្រឡប់ប្រែនាម និងគោត្រទេ អ្នកប្រាជ្ញទាំងឡាយតែងពោលនូវចោរថាមិនឈប់ក្នុងលោក ដែលច្យុតអំពីលោកនេះទៅ ជាអ្នកទៅកាន់អបាយ កាន់នរក។ បពិត្រព្រះរាជា បើព្រះអង្គជឿ ចូរព្រះអង្គចាប់សុតសោមជាក្សត្រិយ៍ មកបូជាយញ្ញ ព្រះអង្គនឹងទៅកាន់ឋានសួគ៌ ដោយការបូជានោះ។

[៣៣១] (ព្រះរាជាសុតសោម...) ជាតិភូមិរបស់អ្នក ក្នុងដែនណា មួយទៀត អ្នកមកដល់ក្នុងទីនេះ ដោយប្រយោជន៍ដូចម្តេច ម្នាលព្រាហ្មណ៍ អ្នកចូរប្រាប់សេចក្តីនុ៎ះដល់ខ្ញុំ អ្នកប្រាថ្នារបស់អ្វី ខ្ញុំនឹងឲ្យនូវរបស់នោះ តាមដែលអ្នកប្រាថ្នាក្នុងថ្ងៃនេះ។

[៣៣២] (នន្ទព្រាហ្មណ៍...) បពិត្រព្រះអង្គជាមហិស្សរៈលើដែនដី គាថាទាំងឡាយ ៤ បទ មានអត្ថដ៏ជ្រៅ ប្រសើរក្រៃលែង ប្រៀបដូចជាសាគរ ខ្ញុំមកក្នុងទីនេះ ដើម្បីប្រយោជន៍ដល់ព្រះអង្គតែម្យ៉ាង សូមព្រះអង្គទ្រង់ព្រះសណ្តាប់នូវគាថា ដែលប្រកបដោយប្រយោជន៍ដ៏ប្រសើរ។

[៣៣៣] (ព្រះបាទបោរិសាទ...) បណ្ឌិតទាំងឡាយណា ជាអ្នកមានយោបល់ប្រកបដោយបញ្ញា ជាពហុស្សុត្រ គិតនូវហេតុបានច្រើនយ៉ាង រមែងមិនយំទេ បណ្ឌិតទាំងឡាយនោះ ជាអ្នកបន្ទោបង់នូវសេចក្តីសោក ដោយហេតុណាពិត ហេតុនុ៎ះជាទីពឹងដ៏ក្រៃលែងរបស់ជនទាំងឡាយ។ បពិត្រព្រះបាទសុតសោម ព្រះអង្គសោកស្តាយចំពោះខ្លួន ញាតិ ឬកូនប្រពន្ធ ស្រូវ ទ្រព្យ ប្រាក់ មាស ឬអ្វី បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ យើងនឹងស្តាប់ពាក្យរបស់លោក។

[៣៣៤] (ព្រះបាទសុតសោម...) ខ្ញុំមិនសោកស្តាយចំពោះខ្លួន មិនសោកស្តាយចំពោះកូន ប្រពន្ធ មិនសោកស្តាយចំពោះទ្រព្យ មិនសោកស្តាយចំពោះដែនទេ (មាន) បុរាណធម៌ ជាចរិតរបស់សប្បុរសទាំងឡាយ ខ្ញុំសោកស្តាយនឹងការប្តេជ្ញានោះ ចំពោះព្រាហ្មណ៍។ ការប្តេជ្ញានឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរភាពក្នុងដែនរបស់ខ្លួន បានធ្វើហើយ ខ្ញុំជាអ្នករក្សាខ្ជាប់នូវសច្ចៈ និងដោះនូវការប្តេជ្ញានោះរបស់ព្រាហ្មណ៍ ហើយនឹងត្រឡប់មកវិញ។

[៣៣៥] (ព្រះបាទបោរិសាទ...) ខ្ញុំមិនជឿនូវពាក្យនុ៎ះថា ជនមានសេចក្តីសុខ បានរួចអំពីមាត់នៃមច្ចុហើយ ត្រឡប់មករកដៃនៃសត្រូវ

វិញដូច្នេះទេ បពិត្រព្រះបាទកោរព្យៈដ៏ប្រសើរ ទ្រង់នឹងមិនមករកខ្ញុំទេ។ បពិត្រព្រះរាជា ទ្រង់បានរួចអំពីដៃនៃព្រះបាទបោរិសាទហើយ មានប្រាថ្នាទៅកាន់មន្ទីររបស់ខ្លួន ហើយបាននូវជីវិតជាទីស្រឡាញ់ពេញចិត្ត កាលណា ទ្រង់នឹងមកកាន់សំណាក់របស់ខ្ញុំវិញ។

[៣៣៦] (ព្រះបាទសុតសោម...) បុគ្គលអ្នកមានសីលបរិសុទ្ធ រមែងប្រាថ្នានូវសេចក្តីស្លាប់ ឯបុគ្គលអ្នកមានធម៌ដ៏លាមក ដែលគួរអ្នកផងតិះដៀល មិនគួរចង់រស់ឡើយ បុគ្គលទ្រុស្តសីល ពោលនូវពាក្យមិនពិត ព្រោះហេតុខ្លួនណា ខ្លួននោះ រមែងមិនរក្សានូវជននោះចាកទុគ្គតិបានឡើយ។ បើទុកជាខ្យល់បក់ភើចភ្នំប៉ានក្តី ព្រះចន្ទ្រ និងព្រះអាទិត្យ ធ្លាក់មកលើផែនដីក្តី ទឹកស្ទឹងទាំងអស់ ហូរច្រាសខ្សែទឹកក្តី បពិត្រព្រះរាជា ខ្ញុំក៏មិនពោលពាក្យកុហកទេ។

[៣៣៧] មេឃបែកធ្លាយ ទឹកសមុទ្ររីងស្ងួត ឬផែនដីជាទីទ្រទ្រង់នូវសត្វប្រែត្រឡប់ ឬក៏ភ្នំឈ្មោះមេរុ រលើងទាំងឫស ខ្ញុំក៏មិនពោលពាក្យកុហកទេ។

[៣៣៨] ខ្ញុំចាប់ដាវ និងលំពែង បពិត្រទ្រង់ជាសំឡាញ់ ខ្ញុំនឹងធ្វើនូវសម្បថចំពោះទ្រង់ ខ្ញុំរួចចេញអំពីទ្រង់ ជាអ្នកមិនមានបំណុល រក្សានូវសច្ចៈ នឹងត្រឡប់មកវិញ។

[៣៣៩] (ព្រះបាទបោរិសាទ...) ការប្តេជ្ញាណា ជាមួយនឹងព្រាហ្មណ៍ដែលព្រះអង្គឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួន បានធ្វើហើយ សូមព្រះអង្គជាអ្នករក្សានូវសច្ចៈ ដោះនូវការប្តេជ្ញានោះនឹងព្រាហ្មណ៍ហើយ ចូរត្រឡប់មកវិញ។

[៣៤០] (ព្រះបាទសុតសោម...) ការប្តេជ្ញាណា ជាមួយនឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួន បានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ នឹងដោះនូវការប្តេជ្ញានោះនឹងព្រាហ្មណ៍ហើយ នឹងត្រឡប់មកវិញ។

[៣៤១] (អភិសម្ពុទ្ធគាថា) ព្រះបាទសុតសោមនោះ រួចពីព្រះហស្តនៃព្រះបាទបោរិសាទ ហើយទៅ បានពោលពាក្យនេះនឹងព្រាហ្មណ៍នោះថា ម្នាលព្រហ្ម ខ្ញុំសូមស្តាប់នូវគាថាទាំងឡាយ ដែលគួរដល់ថ្លៃ ១០០ កហាបណៈ ជាគាថាដែលខ្ញុំស្តាប់ហើយ មានប្រយោជន៍។

[៣៤២] (ព្រាហ្មណ៍...) បពិត្រព្រះបាទសុតសោម ការចួបប្រទះដោយសប្បុរសទាំងឡាយ អស់វារៈតែម្តង ការជួបប្រទះនោះ រមែងរក្សានូវបុគ្គលនោះបាន ឯការចួបជុំដោយពួកអសប្បុរសជាច្រើនដង រមែងមិនរក្សានូវបុគ្គលនោះបានទេ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើរ រមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកឡើយ។ រាជរថទាំងឡាយ ដែលគេរចនាល្អហើយ រមែងគ្រាំគ្រាទៅវិញ សូម្បីសរីរៈ (នៃពួកសត្វ) ក៏រមែងដល់នូវសេចក្តីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរសទាំងឡាយ រមែងមិនដល់នូវសេចក្តីគ្រាំគ្រាទេ ពួកសប្បុរស រមែងចរចាដោយពួកសប្បុរស។ អាកាស និងដីឋិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយ បានពោលនូវច្រាំងសមុទ្រថាឆ្ងាយ បពិត្រព្រះរាជា អ្នកប្រាជ្ញទាំងឡាយ បានពោលនូវធម៌របស់ពួកសប្បុរស និងពួកអសប្បុរសថា ឆ្ងាយជាងនោះទៅទៀត។

[៣៤៣] (ព្រះបាទសុតសោម...) គាថាទាំងនេះ គួរដល់ថ្លៃ ១ ពាន់កហាបណៈ គាថាទាំងនេះ មិនគួរដល់ថ្លៃត្រឹម ១០០ កហាបណៈទេ ម្នាលព្រាហ្មណ៍ លោកចូរទទួលយកកហាបណៈ ៤ ពាន់ជាប្រញាប់ចុះ។

[៣៤៤] (ព្រះវរបិតា...) គាថាមានថ្លៃ ៨០ កហាបណៈ ៩០ កហាបណៈ និងគាថាគួរដល់ថ្លៃ ១០០ កហាបណៈ ម្នាលសុតសោម អ្នកចូរដឹងដោយខ្លួនឯងចុះ គាថាដូចម្តេច ដែលឈ្មោះថាគួរដល់ថ្លៃ ១ ពាន់កហាបណៈ។

[៣៤៥] (ព្រះបាទសុតសោម...) ខ្ញុំព្រះអង្គប្រាថ្នានូវសេចក្តីចំរើនដោយសុតៈ គឺការចេះដឹងដើម្បីខ្លួន សប្បុរសទាំងឡាយ អ្នកមានចិត្តស្ងប់ គប្បីគប់រកនូវខ្ញុំព្រះអង្គ បពិត្រព្រះបិតា ខ្ញុំព្រះអង្គ មិនឆ្អែតដោយសុភាសិត ដូចជាមហាសមុទ្រមិនឆ្អែតដោយទឹកស្ទឹង ដែលហូរចូលទៅ។ ភ្លើងកាលឆេះស្មៅ នឹងឈើ រមែងមិនឆ្អែត សាគររមែងមិនឆ្អែតដោយទឹកស្ទឹងយ៉ាងណា បពិត្រព្រះរាជាដ៏ប្រសើរ បណ្ឌិតទាំងឡាយនោះ បានស្តាប់ហើយ ក៏មិនឆ្អែតដោយសុភាសិតក៏យ៉ាងនោះដែរ។ បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គស្តាប់នូវគាថាដែលមានប្រយោជន៍របស់ទាសៈនៃខ្លួន ក្នុងកាលណា ក្នុងកាលណោះ ខ្ញុំព្រះអង្គតែងផ្ទៀងស្តាប់នូវគាថានោះឯងដោយគោរព បពិត្រព្រះបិតា ខ្ញុំព្រះអង្គ មិនមានសេចក្តីឆ្អែតក្នុងធម៌ទាំងឡាយទេ។

[៣៤៦] ដែនរបស់ព្រះអង្គនេះ ព្រមទាំងទ្រព្យ ព្រមទាំងយាន ព្រមទាំងគ្រឿងប្រដាប់កាយ បរិបូរណ៍ដោយវត្ថុគួរប្រាថ្នាគ្រប់យ៉ាង ព្រះអង្គជេរប្រទេចខ្ញុំព្រះអង្គ ព្រោះហេតុនៃសេចក្តីប្រាថ្នាដូចម្តេច ខ្ញុំព្រះអង្គនឹងទៅកាន់សំណាក់នៃព្រះបាទបោរិសាទ។

[៣៤៧] (ព្រះបិតា...) ដ្បិតពួកពលទាំងនុ៎ះ គឺពលដំរី ពលរថ ពលថ្មើរជើង ពលសេះ និងខ្មាន់ធ្នូ ក៏មានសម្រាប់រក្សាខ្លួន យើងនឹងលើកពលសេនាទៅសម្លាប់សត្រូវ។

[៣៤៨] (ព្រះបាទសុតសោម...) ព្រះបាទបោរិសាទ បានធ្វើនូវអំពើដ៏កម្រក្រៃលែង ចាប់ខ្ញុំព្រះអង្គទាំងរស់ ហើយលែងវិញ បពិត្រព្រះអង្គជាធំជាងជន ខ្ញុំព្រះអង្គ រឭកឃើញនូវឧបការគុណក្នុងកាលមុនប្រាកដដូច្នោះ ខ្ញុំនឹងប្រទូស្តចំពោះស្តេចបោរិសាទនោះដូចម្តេចកើត។

[៣៤៩] (អភិសម្ពុទ្ធគាថា) ព្រះបាទសុតសោម ក្រាបថ្វាយបង្គំលាព្រះបិតាមាតា ប្រៀនប្រដៅអ្នកនិគម និងពលសេនា ព្រះអង្គពោលនូវពាក្យសច្ចៈ រក្សានូវពាក្យសច្ចៈ ហើយក៏ទៅកាន់សំណាក់នៃព្រះបាទបោរិសាទ។

[៣៥០] (ព្រះបាទសុតសោម...) កាប្តេជ្ញានឹងព្រាហ្មណ៍ ដែលខ្ញុំឋិតនៅក្នុងឥស្សរភាព ក្នុងដែនរបស់ខ្លួនបានធ្វើហើយ ខ្ញុំជាអ្នករក្សានូវសច្ចៈ ដោះប្តេជ្ញានឹងព្រាហ្មណ៍ ហើយត្រឡប់មកវិញ បពិត្រព្រះបាទបោរិសាទ ចូរព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ។

[៣៥១] (ព្រះបាទបោរិសាទ...) ទ្រង់មិនបាត់ទេ ចាំខ្ញុំស៊ីជាខាងក្រោយចុះ ព្រោះជើងថ្ករនេះ ប្រកបដោយផ្សែងនៅឡើយ សាច់ដែលចំអិនលើភ្លើងឥតផ្សែង ជាសាច់ឆ្អិនល្អ ហើយនឹងស្តាប់នូវគាថារបស់ទ្រង់ ដែលគួរដល់ថ្លៃ ១០០ កហាបណៈសិន។

[៣៥២] (ព្រះបាទសុតសោម...) ព្រះអង្គជាអធម្មិករាជ ជាអ្នកស៊ីនូវបុរស ខ្ចាត់ភ្លាត់អំពីដែន ព្រោះហេតុតែពោះ គាថាទាំងឡាយនេះ រមែងប្រកាសសុចរិតធម៌ ចំណែកធម៌ និងអធម៌ ស្របគ្នាក្នុងទីណាកើត។ ព្រះអង្គជាអធម្មិករាជ ព្រះហស្តប្រឡាក់ឈាមជានិច្ច មិនមានសច្ចៈ ធម៌នឹងមានមកអំពីណា ព្រះអង្គនឹងធ្វើអ្វីដោយការស្តាប់។

[៣៥៣] (ព្រះបាទបោរិសាទ...) បុគ្គលណាត្រាច់ទៅកាន់ទីសម្លាប់ម្រឹគ ព្រោះហេតុតែសាច់ ឬសម្លាប់បុរស ព្រោះហេតុតែខ្លួន បុគ្គលទាំងពីរនោះ ស្មើគ្នាក្នុងលោកខាងមុខ ហេតុអ្វីព្រះអង្គហៅខ្ញុំថាជាអធម្មិករាជ។

[៣៥៤] (ព្រះបាទសុតសោម...) ក្សត្រិយ៍ជាអ្នកចេះដឹង មិនគួរសោយនូវពួកសត្វ ៥ នឹង ៥ ទេ បពិត្រព្រះរាជា ព្រះអង្គសោយនូវសាច់ដែលមិនគួរសោយ ព្រោះហេតុនោះ ទើបព្រះអង្គឈ្មោះថាជាអធម្មិករាជ។

[៣៥៥] (ព្រះបាទបោរិសាទ...) លោកបានរួចអំពីដៃបោរិសាទហើយ ទៅកាន់មន្ទីររបស់ខ្លួនតាមសេចក្តីប្រាថ្នា ហើយត្រឡប់មករកដៃរបស់សត្រូវវិញ បពិត្រព្រះរាជា ព្រះអង្គជាបុគ្គលមិនឈ្លាសក្នុងខត្តិយធម៌ទេ។

[៣៥៦] (ព្រះបាទសុតសោម...) ពួកបុគ្គលណា ជាអ្នកឈ្លាសក្នុងខត្តិយធម៌ ពួកបុគ្គលនោះ ច្រើនតែធ្លាក់ទៅក្នុងនរក ព្រោះហេតុនោះ បានជាខ្ញុំលះបង់នូវខត្តិយធម៌ ជាអ្នករក្សានូវសច្ចៈ ត្រឡប់មកវិញ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយនូវខ្ញុំចុះ។

[៣៥៧] (ព្រះបាទបោរិសាទ...) ប្រាសាទជាទីនៅលើផែនដី គោ និងសេះ ពួកស្រីដែលគួរប្រាថ្នា និងខ្លឹមចន្ទន៍ក្នុងដែនកាសី ទ្រង់បាននូវវត្ថុទាំងអស់ក្នុងទីនោះ ដោយភាពជាម្ចាស់ ចុះទ្រង់ឃើញនូវអានិសង្សនៃពាក្យសច្ចៈដូចម្តេច។

[៣៥៨] (ព្រះបាទសុតសោម...) រសឯណានីមួយ មាននៅលើផែនដី សច្ចៈ ជារសល្អក្រៃលែងជាងរសទាំងឡាយនោះ ពួកសមណៈ និងព្រាហ្មណ៍ ដែលតាំងនៅក្នុងសច្ចៈ រមែងឆ្លងទៅកាន់ត្រើយនៃជាតិ និងមរណៈបាន។

[៣៥៩] (ព្រះបាទបោរិសាទ...) ទ្រង់បានរួចអំពីដៃបោរិសាទហើយ បានទៅកាន់មន្ទីររបស់ខ្លួនវិញ តាមសេចក្តីប្រាថ្នា ត្រឡប់មករកដៃសត្រូវវិញ បពិត្រទ្រង់ជាធំជាងជន ភ័យអំពីសេចក្តីស្លាប់ មិនមានដល់ទ្រង់ដោយពិត ទ្រង់ជាអ្នកពោលនូវពាក្យសច្ចៈ ទាំងមានចិត្តក៏មិនរួញរា។

[៣៦០] (ព្រះបាទសុតសោម...) យ័ញ្ញ (ការបូជា) មានច្រើនប្រការ ជាកល្យាណធម៌ ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែលអ្នកប្រាជ្ញតែងសរសើរ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់។ យ័ញ្ញមានច្រើនប្រការ ជាកល្យាណធម៌ ដែលខ្ញុំបានធ្វើហើយ បូជាហើយ ជាបូជាដ៏ធំទូលាយ ដែលអ្នកប្រាជ្ញតែងសរសើរ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយខ្ញុំចុះ។ មាតា និងបិតា ខ្ញុំបានបំរើហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់។ បិតា និងមាតា ខ្ញុំក៏បានបំរើហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយនឹងទៅបរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយខ្ញុំចុះ។ ខ្ញុំបានធ្វើឧបការកិច្ចចំពោះពួកញាតិ និងមិត្តហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់។ ខ្ញុំបានធ្វើឧបការកិច្ចចំពោះពួកញាតិ និងមិត្តហើយ ឥស្សរភាព ខ្ញុំគ្រប់គ្រងហើយតាមធម៌ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមព្រះអង្គបូជាយ័ញ្ញ សូមព្រះអង្គសោយខ្ញុំចុះ។ ការឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏បានឲ្យហើយ ទាំងពួកសមណព្រាហ្មណ៍ ខ្ញុំក៏បានផ្គត់ផ្គង់ហើយ ផ្លូវសម្រាប់បរលោក ខ្ញុំក៏បានជម្រះហើយ អ្នកណាឋិតនៅក្នុងធម៌ហើយ នឹងខ្លាចសេចក្តីស្លាប់។ ការឲ្យទានដល់ពួកជនជាច្រើន ដោយអាការច្រើនយ៉ាង ខ្ញុំក៏បានឲ្យហើយ ទាំងសមណព្រាហ្មណ៍ ខ្ញុំក៏បានផ្គត់ផ្គង់ហើយ ខ្ញុំមិនក្តៅក្រហាយនឹងទៅកាន់បរលោកទេ បពិត្រព្រះបាទបោរិសាទ សូមទ្រង់បូជាយ័ញ្ញ សូមទ្រង់សោយខ្ញុំចុះ។

[៣៦១] (ព្រះបាទបោរិសាទ...) បុគ្គលណា ស៊ីនូវជនអ្នកពោលពាក្យសច្ចៈ ប្រាកដដូច្នោះ ក្បាលរបស់បុគ្គលនោះ នឹងបែកជា ៧ ភាគ ដូចបុរសស្គាល់នូវថ្នាំពិស ហើយស៊ីនូវថ្នាំពិស (ឬដូចគេចាប់) ពស់អាសិរពិសដែលមានពិសកាចមានតេជះខ្លាំង។

[៣៦២] ជនទាំងឡាយ បានស្តាប់ធម៌ហើយ រមែងដឹងច្បាស់នូវបុណ្យ និងបាប ប៉ុនអម្បាលចិត្តរបស់ខ្ញុំ គង់ត្រេកអរក្នុងធម៌ ព្រោះបានស្តាប់នូវគាថាទាំងឡាយ។

[៣៦៣] (ព្រះបាទសុតសោម...) បពិត្រមហារាជ ការចួបប្រទះដោយសប្បុរសទាំងឡាយអស់វារៈតែម្តង ការចួបប្រទះនោះ រមែងរក្សានូវបុគ្គលនោះបាន ការចួបជុំដោយពួកអសប្បុរសច្រើនដង រមែងមិនរក្សាបុគ្គលបានទេ។ បុគ្គលគប្បីគប់រកនឹងពួកសប្បុរស គប្បីធ្វើនូវការស្និទ្ធស្នាលនឹងពួកសប្បុរស គុណធម៌ដ៏ប្រសើរ រមែងកើតមាន ព្រោះដឹងនូវព្រះសទ្ធម្មរបស់ពួកសប្បុរស មិនមែនជាទោសដ៏លាមកទេ។ រាជរថទាំងឡាយ ដែលគេរចនាល្អហើយ រមែងគ្រាំគ្រា សូម្បីសរីរៈ (របស់ពួកសត្វ) ក៏រមែងដល់នូវសេចក្តីគ្រាំគ្រាដោយពិត ឯធម៌របស់សប្បុរស មិនដល់នូវសេចក្តីគ្រាំគ្រាទេ សប្បុរសទាំងឡាយ រមែងចរចាដោយពួកសប្បុរសបាន។ អាកាស និងដី ឋិតនៅក្នុងទីឆ្ងាយពីគ្នា អ្នកប្រាជ្ញទាំងឡាយបានពោលនូវច្រាំងសមុទ្រនោះថាឆ្ងាយ បពិត្រព្រះរាជា បណ្ឌិតទាំងឡាយ រមែងពោលថា ធម៌របស់ពួកសប្បុរស និងពួកអសប្បុរស ឆ្ងាយជាងនោះទៅទៀត។

[៣៦៤] (ព្រះបាទបោរិសាទ...) បពិត្រទ្រង់ជាធំជាងជន គាថាទាំងឡាយនេះ មានអត្ថ មានព្យញ្ជនៈដ៏ល្អ ទ្រង់សំដែងពីរោះណាស់ ខ្ញុំបានស្តាប់ហើយ ក៏ត្រេកអររីករាយ មានចិត្តល្អជ្រះថ្លា បពិត្រទ្រង់ជាសម្លាញ់ ខ្ញុំសូមថ្វាយពរ ៤ ប្រការដល់ទ្រង់។

[៣៦៥] (ព្រះបាទសុតសោម...) ទ្រង់មិនដឹងនូវសេចក្តីស្លាប់របស់ខ្លួន ទាំងអំពើមានប្រយោជន៍ និងឥតប្រយោជន៍ ទាំងនរក និងឋានសួគ៌ទេ បពិត្រព្រះអង្គមានធម៌ដ៏លាមក ព្រះអង្គជាប់ចំពាក់ក្នុងរស (នៃសាច់មនុស្ស) តាំងនៅស៊ប់ក្នុងទុច្ចរិតធម៌ ធ្វើម្តេចនឹងឲ្យពរកើត។ បើខ្ញុំពោលថា សូមព្រះអង្គប្រទានពរនោះ ព្រះអង្គប្រទានហើយ ត្រឡប់ជាមិនប្រទានវិញ តើបណ្ឌិតណាកាលដឹង នឹងហ៊ានចូលទៅរកជំលោះ និងវិវាទដ៏ជាក់ស្តែងនេះ។

[៣៦៦] (ព្រះបាទបោរិសាទ...) ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រទ្រង់ជាសម្លាញ់ សូមទ្រង់កុំញាប់ញ័រ សូមទទួល (ពរ) ចុះ ខ្ញុំសូម្បីលះបង់ជីវិត ក៏នៅតែថ្វាយទ្រង់។

[៣៦៧] (ព្រះបាទសុតសោម...) ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ រមែងស្របគ្នានឹងអរិយៈ របស់បុគ្គលមានប្រាជ្ញា រមែងស្របគ្នានឹងបុគ្គលមានប្រាជ្ញា ខ្ញុំសូមឃើញព្រះអង្គមានជន្មាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្តាពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ១ នុ៎ះ។

[៣៦៨] (ព្រះបាទបោរិសាទ...) ធម៌ជាបន្ទាល់សាក្សីរបស់អរិយៈ រមែងស្របគ្នានឹងអរិយៈ របស់បុគ្គលមានប្រាជ្ញា រមែងស្របគ្នានឹងបុគ្គលមានប្រាជ្ញា ទ្រង់សូមឃើញនូវខ្ញុំ មានអាយុ ១០០ ឆ្នាំ ឥតមានរោគ បណ្តាពរទាំងឡាយ ខ្ញុំនឹងថ្វាយពរទី ១ នេះ។

[៣៦៩] (ព្រះបាទសុតសោម...) ពួកក្សត្រិយ៍ណា រក្សាផែនដីក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ មានព្រះនាមសម្រេចហើយ ព្រះអង្គជាម្ចាស់ផែនដី កុំសោយនូវពួកក្សត្រិយ៍ទាំងនោះឡើយ បណ្តាពរទាំងឡាយ ខ្ញុំប្រាថ្នានូវពរទី ២ នេះ។

[៣៧០] (ព្រះបាទបោរិសាទ...) ពួកក្សត្រិយ៍ណា រក្សាផែនដីក្នុងទ្វីបនេះ បានមុទ្ធាភិសេកហើយ មានព្រះនាមសម្រេចហើយ ខ្ញុំជា

ម្ចាស់ផែនដី កំលែងស៊ីនូវពួកក្សត្រិយ៍ទាំងនោះដែរ បណ្តាពរទាំងឡាយ ខ្ញុំនឹងថ្វាយនូវពរទី ២ នេះ។

[៣៧១] (ព្រះបាទសុតសោម...) ពួកក្សត្រិយ៍ជាងរយនាក់ ដែលព្រះអង្គចាប់ដោតបាតដៃ មានមុខជោកដោយទឹកភ្នែក កំពុងទួញយំ សូមព្រះអង្គឲ្យក្សត្រិយ៍ទាំងនោះ ត្រឡប់ទៅក្នុងដែនរបស់ខ្លួនវិញ បណ្តាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៣ នេះ។

[៣៧២] (ព្រះបាទបោរិសាទ...) ពួកក្សត្រិយ៍ជាងរយនាក់ ដែលខ្ញុំចាប់ដោត បាតដៃ មានមុខជោកដោយទឹកភ្នែក កំពុងទួញយំ ខ្ញុំនឹងឲ្យពួកក្សត្រិយ៍ទាំងនោះ ត្រឡប់ នៅក្នុងដែនរបស់ខ្លួនវិញ បណ្តាពរទាំងឡាយ ខ្ញុំនឹងថ្វាយពរទី ៣ នេះ។

[៣៧៣] (ព្រះបាទសុតសោម...) ដែនរបស់ព្រះអង្គ ជាដែនប្រហោង (មិនសូវមានប្រជាជន) ព្រោះពួកប្រជាជនជាច្រើនញាប់ញ័រហើយ ព្រោះភ័យគ្របសង្កត់ ហើយរត់ចូលទៅកាន់ទីពឹងពួន បពិត្រព្រះរាជា សូមព្រះអង្គវៀរសាច់មនុស្សទៅ បណ្តាពរទាំងឡាយ ខ្ញុំប្រាថ្នាពរទី ៤ នេះ។

[៣៧៤] (ព្រះបាទបោរិសាទ...) អាហារនោះ ជាទីពេញចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនុ៎ះឯង នឹងវៀរចាកសាច់មនុស្សនុ៎ះ ដូចម្តេចបាន បណ្តាពរទាំងឡាយ សូមទ្រង់ប្រាថ្នានូវពរទី ៤ដទៃវិញ។

[៣៧៥] (ព្រះបាទសុតសោម...) បពិត្រព្រះអង្គ ជាធំជាងជន បុគ្គលប្រហែលដូចព្រះអង្គ លះបង់នូវខ្លួនចោល ដោយគិតថា នេះជាទីស្រឡាញ់របស់អញដូច្នេះ រមែងមិនបានគប់រកនូវវត្ថុជាទីស្រឡាញ់ទេ ខ្លួនហ្នឹងហើយ ជាសភាវៈប្រសើរ ឈ្មោះថា ប្រសើរក្រៃលែង បុគ្គលអ្នកមានចិត្តសន្សំហើយ គប្បីបាននូវគុណជាទីស្រឡាញ់ ក្នុងកាលជាខាងក្រោយ។

[៣៧៦] (ព្រះបាទបោរិសាទ...) បពិត្រព្រះបាទសុតសោម សូមទ្រង់ជ្រាបនូវសាច់មនុស្ស ថាជាទីស្រឡាញ់របស់ខ្ញុំ ទ្រង់មិនអាចឃាត់ខ្ញុំបានទេ បពិត្រទ្រង់ជាសម្លាញ់ សូមទ្រង់ប្រាថ្នាពរឯទៀតវិញ។

[៣៧៧] (ព្រះបាទសុតសោម...) បុគ្គលណា ជាអ្នករក្សានូវវត្ថុជាទីស្រឡាញ់ ដោយគិតថា វត្ថុនេះជាទីស្រឡាញ់របស់អញដូច្នេះ លះបង់ខ្លួន ហើយនៅសេពគប់វត្ថុជាទីស្រឡាញ់ បុគ្គលនោះ រមែងជាទុក្ខក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចជាអ្នកលេងសុរា ផឹកទឹកស៊ុរាដែលលាយដោយថ្នាំពិស។ ចំណែកខាងបុគ្គលណា ក្នុងលោកនេះ បានពិចារណា លះបង់នូវវត្ថុជាទីស្រឡាញ់ ហើយបែរមកគប់រកនូវអរិយធម៌ សូម្បីដោយលំបាក បុគ្គលនោះ រមែងបានសុខក្នុងកាលខាងមុខ ព្រោះអំពើនោះឯង ដូចបុគ្គលដល់នូវសេចក្តីទុក្ខ ព្រោះផឹកនូវឱសថ។

[៣៧៨] (ព្រះបាទបោរិសាទ...) ខ្ញុំលះបង់បិតាមាតា និងបញ្ចកាមគុណ ជាទីពេញចិត្ត ហើយចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនោះ ខ្ញុំនឹងថ្វាយនូវពរនោះដល់ទ្រង់ ដូចម្តេចបាន។

[៣៧៩] (ព្រះបាទសុតសោម...) បណ្ឌិតទាំងឡាយជាសប្បុរស ជាអ្នកប្តេជ្ញាដោយពាក្យសច្ចៈ មិនពោលនូវពាក្យពីរជាន់ទេ ព្រះអង្គបានពោលនឹងខ្ញុំថា បពិត្រទ្រង់ជាសំឡាញ់ សូមទ្រង់ទទួលពរចុះ ព្រះអង្គបានពោលដូច្នេះហើយ (តែពាក្យនោះ) របស់ព្រះអង្គ មិនស្របគ្នាទេ។

[៣៨០] (ព្រះបាទបោរិសាទ...) ខ្ញុំដល់នូវភាពជាអ្នកមិនមានបុណ្យ មិនមានយស មិនមានកេរ្តិ៍ឈ្មោះ មានបាប មានទុច្ចរិតសៅហ្មងជាច្រើន ក៏ព្រោះហេតុតែសាច់មនុស្ស ខ្ញុំនឹងថ្វាយនូវពរនោះដល់ទ្រង់ ដូចម្តេចកើត។

[៣៨១] (ព្រះបាទសុតសោម...) (ទ្រង់មានបន្ទូលហើយថា) ជនឲ្យនូវពរណា ហើយត្រឡប់ជាមិនឲ្យវិញ មិនគួរឲ្យពរនោះទេ បពិត្រទ្រង់ជាសំឡាញ់ សូមទ្រង់កុំញាប់ញ័រ សូមទទួលយក (ពរ) ចុះ ខ្ញុំសូម្បីលះបង់ជីវិត ក៏នៅតែថ្វាយទ្រង់ដែរ។

[៣៨២] នុ៎ះជាធម៌របស់ពួកសប្បុរស ធម្មតា ពួកសប្បុរស ជាអ្នកប្តេជ្ញាដោយពាក្យសច្ចៈ តែងលះបង់នូវជីវិត ព្រះអង្គឲ្យពរហើយ ចូរឲ្យរហ័ស បពិត្រព្រះរាជាដ៏ប្រសើរ សូមព្រះអង្គសម្រេចដោយធម៌ និងពាក្យសច្ចៈនុ៎ះចុះ។ ជនគប្បីលះបង់នូវទ្រព្យ ព្រោះហេតុនៃអវយវៈដ៏ប្រសើរ កាលបើរក្សានូវជីវិត ក៏គប្បីលះបង់នូវអវយវៈ កាលបើពួកឃើញនូវធម៌ គប្បីលះបង់ទាំងអវយវៈ ទ្រព្យ និងជីវិតទាំងអស់។

[៣៨៣] បុរសចេះដឹង នូវធម៌អំពីបុគ្គលណា ឬក៏ពួកសប្បុរសណា បន្ទោបង់នូវសេចក្តីសង្ស័យរបស់បុគ្គលនោះបាន ដំណើរនោះឈ្មោះថាជាទីពឹង ជាទីពំនាក់របស់បុគ្គលនោះ បុគ្គលអ្នកមានប្រាជ្ញា មិនត្រូវបំបាត់មេត្រីចិត្តអំពីបុគ្គលនោះទេ។

[៣៨៤] (ព្រះបាទបោរិសាទ...) អាហារនោះ ជាទីគាប់ចិត្តរបស់ខ្ញុំដោយពិត ខ្ញុំចូលព្រៃ ព្រោះហេតុតែសាច់មនុស្សនុ៎ះ បើទ្រង់ទទូចសូមសេចក្តីនុ៎ះនឹងខ្ញុំ បពិត្រទ្រង់ជាសំឡាញ់ ខ្ញុំក៏ឲ្យពរនោះដល់ទ្រង់។

[៣៨៥] ព្រះអង្គជាសាស្តារបស់ខ្ញុំផង ជាសំឡាញ់របស់ខ្ញុំផង បពិត្រព្រះអង្គជាសំឡាញ់ ខ្ញុំនឹងធ្វើតាមព្រះឱង្ការរបស់ព្រះអង្គ ព្រះអង្គក៏ចូរធ្វើតាមពាក្យរបស់ខ្ញុំដែរ យើងទាំងពីរនាក់ ទៅដោះលែង (ពួកក្សត្រិយ៍ទាំងនោះជាមួយគ្នា)។

[៣៨៦] (ព្រះបាទសុតសោម...) ខ្ញុំជាសាស្តារបស់ព្រះអង្គផង ជាសំឡាញ់របស់ព្រះអង្គផង បពិត្រព្រះអង្គជាសំឡាញ់ បើព្រះអង្គធ្វើតាមពាក្យខ្ញុំ ទាំងខ្ញុំក៏ធ្វើតាមពាក្យព្រះអង្គដែរ យើងទាំងពីរនាក់ទៅដោះលែង (ពួកក្សត្រិយ៍ទាំងនោះជាមួយគ្នា)។

[៣៨៧] ពួកយើងដែលត្រូវព្រះរាជាជើងពពាល បៀតបៀនដោតបាតដៃ មានមុខជោកដោយទឹកភ្នែក ស្រែកយំ (ឥឡូវនេះ) អ្នកទាំងឡាយ លែងប្រទូស្តនឹងព្រះរាជានេះចុះ អ្នកទាំងឡាយចូរទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងទាត់របស់ខ្ញុំចុះ។

[៣៨៨] (ពួកក្សត្រិយ៍...) ពួកយើងដែលត្រូវព្រះរាជាជើងពពាលបៀតបៀនដោតបាតដៃ មានមុខជោកដោយទឹកភ្នែក ស្រែកយំ (ឥឡូវនេះ) ពួកយើមិនប្រទូស្តចំពោះព្រះរាជានេះទេ ពួកយើងនឹងទទួលស្តាប់ពាក្យប្តេជ្ញាដ៏ទៀងទាត់របស់ព្រះអង្គ។

[៣៨៩] (ព្រះបាទសុតសោម...) បិតា ឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចំរើនដល់បុត្រទាំងឡាយ យ៉ាងណាមិញ ចំណែកព្រះរាជានេះ ចូរមានដល់លោកទាំងឡាយ ក៏យ៉ាងនោះដែរ ទាំងលោកទាំងឡាយ ក៏សូមដូចជាបុត្រ។

[៣៩០] (ពួកក្សត្រិយ៍...) បិតា ឬមាតា ជាអ្នកអនុគ្រោះ ប្រាថ្នានូវសេចក្តីចំរើនដល់បុត្តទាំងឡាយ យ៉ាងណាមិញ ចំណែកខាងព្រះរាជានេះ ចូរមានដល់យើងទាំងឡាយ យ៉ាងនោះដែរ ទាំងពួកយើងក៏ដូចបុត្តដែរ។

[៣៩១] (ព្រះបាទសុតសោម...) ព្រះអង្គធ្លាប់សោយនូវសាច់នៃសត្វជើង ៤ ឬសត្វបក្សី ដែលពួកនាយពិសេសចាត់ចែងល្អ សម្រេច

ដោយល្អ ជាទីត្រេកអរ ដូចព្រះឥន្ទ្រ សោយនូវសុធាភោជន ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្ដេចកើត។ ពួកនាងខត្តិយានីនោះ មានគ្រឿងប្រដាប់ភ្លឺផ្លេក និងចង្កេះដ៏រៀវ តាក់តែងខ្លួនគាល់ត្រៀបត្រា ញុំាងព្រះអង្គឲ្យរីករាយ ដូចជាស្ត្រីអប្សរ បំរើព្រះឥន្ទ្រក្នុងទេវលោក ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្ដេចកើត។ ព្រះអង្គផ្ទំលើព្រះបន្ទំ មានខ្នើយពណ៌ក្រហម មានព្រំមានរោមច្រើន ដែលតាក់តែងក្នុងទីព្រះបន្ទំទាំងអស់ដ៏ល្អ ជាសុខសប្បាយ ក្នុងទីពាក់កណ្ដាលនៃព្រះបន្ទំ ហើយលះបង់ចោល ត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្ដេចកើត។ ក្នុងវេលារាត្រី មានសូរសំឡេងគង និងស្គរ ទាំងតូរ្យតន្ត្រី ឥតមានបុរសនៅលាយ មានទាំងចម្រៀងដ៏ពីរោះ និងប្រគំក៏ពីរោះជាច្រើនយ៉ាង ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃម្នាក់ឯង ដូចម្ដេចកើត។ ឧទ្យាន (ឈ្មោះមិគាជិន) ក៏មានផ្កាច្រើនបរិបូណ៌ បុរីប្រកបដោយឈ្មោះតាមឧទ្យានមិគាជិន ជាបុរីគួរជាទីសប្បាយក្រៃពេក សម្បូរដោយពាហណៈ សេះ ដំរី រថ ព្រះអង្គលះបង់ចោល ហើយត្រេកអរក្នុងព្រៃតែម្នាក់ឯង ដូចម្ដេចកើត។

[៣៩២] (ព្រះបាទបោរិសាទ...) ព្រះចន្ទក្នុងកាឡប័ក្ខ (រនោច) រមែងអស់ទៅរាល់ៗថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការសមាគមនឹងពួកអសប្បុរស ឧបមាដូចព្រះចន្ទ្រក្នុងកាឡប័ក្ខ។ ដូចយ៉ាងខ្ញុំ អាស្រ័យរសកៈអ្នកស្លដណ្ដាំ ជាបុរសអាក្រក់លាមក ហើយបានធ្វើនូវកម្មអាក្រក់ ជាហេតុទៅកាន់ទុគ្គតិ។ ព្រះចន្ទ្រក្នុងសុក្កប័ក្ខ រមែងចំរើនឡើងរាល់ៗ ថ្ងៃ យ៉ាងណាមិញ បពិត្រព្រះរាជា ការចូបប្រទះនឹងពួកសប្បុរស ឧបមាដូចជាព្រះចន្ទ្រក្នុងសុក្កប័ក្ខ។ បពិត្រព្រះបាទសុតសោម សូមព្រះអង្គជ្រាបចុះ ដូចយ៉ាងខ្ញុំ អាស្រ័យព្រះអង្គ ហើយធ្វើការកុសល ជាហេតុទៅកាន់សុគតិ។

បពិត្រព្រះអង្គជាធំជាងជន ទឹកដែលបង្អុរចុះលើទីទួល មិនដក់នៅ មិនឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកអសប្បុរសរបស់ខ្ញុំ មិនតាំងនៅ អស់កាលយូរ ដូចទឹកលើទីទួលយ៉ាងនោះដែរ។ បពិត្រព្រះអង្គជាធំជាងជន មានព្យាយាមដ៏ប្រសើរជាងជន ទឹកដែលបង្អុរចុះក្នុងស្រះ ឋិតនៅអស់កាលយូរ យ៉ាងណាមិញ ការសមាគមនឹងពួកសប្បុរសរបស់ខ្ញុំ ឋិតនៅអស់កាលយូរ ដូចទឹកក្នុងស្រះ យ៉ាងនោះដែរ។ សមាគមនឹងពួកសប្បុរស រមែងមិនឃ្លាតចេញទេ គប្បីឋិតនៅដរាបអស់ជីវិត ការសមាគមនឹងពួកអសប្បុរស រមែងវិនាសទៅឆាប់ ដោយប្រការដូច្នេះឯង ព្រោះហេតុនោះ ធម៌របស់ពួកសប្បុរស រមែងឆ្ងាយអំពីពួកអសប្បុរស។

[៣៩៣] (ព្រះបាទសុតសោម...) ព្រះរាជាណា ផ្ចាញ់នូវបុគ្គលមិនគួរផ្ចាញ់ (មាតា បិតា) ព្រះរាជានោះ មិនមែនជាព្រះរាជាទេ សំឡាញ់ណា ផ្ចាញ់នូវសំឡាញ់ សំឡាញ់នោះ មិនមែនជាសំឡាញ់ទេ ភរិយាណា មិនខ្លាចប្ដី ភរិយានោះមិនមែនជាភរិយាទេ ពួកបុត្រណា មិនចិញ្ចឹមមាតាបិតាជាបុគ្គលចាស់ទុំ ពួកបុត្រនោះ មិនមែនជាកូនទេ។ ពួកសប្បុរស មិនមានក្នុងទីប្រជុំណា ទីនោះ មិនមែនទីប្រជុំទេ ពួកជនណាមិនពោលនូវធម៌ ពួកជននោះ មិនមែនជាសប្បុរសទេ លុះតែពួកជនលះបង់នូវរាគៈ ទោសៈ និងមោហៈហើយ ពោលនូវធម៌ ទើបឈ្មោះថា សប្បុរស។ បណ្ឌិតកាលបើមិនពោល (នូវធម៌) ជាអ្នកច្រឡូកច្រឡំដោយពួកជនពាល ពួកអ្នកផង រមែងស្គាល់មិនបាន លុះតែពោល សំដែងនូវអមតបទ ទើបពួកអ្នកផងស្គាល់បាន។ បណ្ឌិតគប្បីពោលបំភ្លឺនូវធម៌ ផ្គងឡើងនូវធម៌ ជាទង់ជ័យនៃពួកឥសី ពួកឥសីមានសុភាសិតជាទង់ជ័យ ព្រោះជាធម៌ ទុកដូចជាទង់ជ័យនៃពួកឥសី។

ចប់ សុតសោមជាតក ទី៥។

ឧទ្ទាននៃជាតកនោះគឺ

ចូឡហង្សឈ្មោះសុមុខៈ ១ មហាហង្សដ៏ប្រសើរ ១ តាបសឲ្យនូវសុធាភោជនដ៏ប្រសើរដទៃ ១ ស្ដេចបក្សីឈ្មោះកុណាល ១ ព្រះរាជាដ៏ប្រសើរព្រះនាមសុតសោម ១។

ចប់ អសីតិនិបាត។

ចប់ ភាគ៦១។

# មហានិបាតជាតក

CS sut.kn.jat.v22 | ភាគទី ៦២

(២២. មហានិបាតោ)

## តេមិយជាតក ទី១

CS sut.kn.jat.538 | ភាគទី ៦២

(៥៣៨. មូគបក្ខជាតកំ (១ ))

[១] (ទេវតាពោលថា) អ្នកកុំប្រកាសនូវភាពជាអ្នកប្រាជ្ញ ចូរឲ្យជនទាំងពួងដឹងថាជាមនុស្សល្ងង់ ជនទាំងអស់ចូរមើលងាយអ្នកចុះ សេចក្ដីចំរើននឹងមានដល់អ្នកដោយវិធីយ៉ាងនេះ។

[២] (ព្រះមហាសត្វត្រាស់ថា) បពិត្រទេវតា អ្នកនិយាយពាក្យណានឹងខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នកនោះ បពិត្រទេវតា អ្នកឈ្មោះថាប្រាថ្នានូវសេចក្ដីចំរើនដល់ខ្ញុំ បពិត្រទេវតា អ្នកឈ្មោះថា ប្រាថ្នានូវប្រយោជន៍ (ដល់ខ្ញុំ)។

[៣] (ព្រះមហាសត្វ) នែនាយសារថី អ្នកប្រញាប់ប្រញាល់ជីករណ្ដៅ តើព្រោះហេតុអ្វី ម្នាលសំឡាញ់ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់មកចុះ អ្នកនឹងធ្វើនូវអ្វីដោយរណ្ដៅ។

[៤] (នាយសារថី) ព្រះរាជបុត្តកើតមកហើយ គផង ខ្វិនផង ដូចជាឥតចិត្ត ឯខ្ញុំនោះ ព្រះរាជាទ្រង់ត្រាស់ប្រើមកហើយថា អ្នកត្រូវជីកកប់កូនអញក្នុងព្រៃចុះ។

[៥] (ព្រះមហាសត្វ) ខ្ញុំមិនថ្លង់ មិនគ មិនខ្វិនទេ មិនមែនវិកលវិការទេ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសធម៌ អ្នកចូរមើលភ្លៅ និងដើមដៃខ្ញុំ ទាំងចូរស្ដាប់សំដីខ្ញុំ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសធម៌។

[៦] (នាយសារថី) អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាបុរិន្ទទសក្កទេវរាជ អ្នកជាអ្វី ទាំងជាកូនអ្នកណា យើងនឹងស្គាល់អ្នកបានដោយប្រការ

ដូចម្ដេច។

[៧] (ព្រះមហាសត្វ) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាបុរិន្ទទសក្កទេវរាជទេ អ្នកកប់បុគ្គលណាក្នុងរណ្ដៅ បុគ្គលនោះគឺខ្ញុំ ជាកូនរបស់ព្រះបាទកាសិក: អ្នករស់នៅដោយស្រួល (ព្រោះអាស្រ័យ) នូវព្រះរាជាណា ខ្ញុំជាកូនរបស់ព្រះរាជានោះ នែនាយសារថី បើអ្នកនឹងកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសធម៌ បុគ្គលគប្បីអង្គុយ ឬដេកក្រោមម្លប់ឈើណា មិនគប្បីកាច់បំបាក់មែកឈើនោះទេ ព្រោះថាអ្នកទ្រុស្តមិត្រ ជាមនុស្សលាមក នែនាយសារថី ព្រះរាជាទុកដូចជាដើមឈើ ខ្លួនខ្ញុំទុកដូចជាមែកឈើដែរ អ្នកឯងទុកដូចបុរសដែលចូលទៅជ្រកក្រោមម្លប់ឈើដូច្នោះ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសធម៌។

[៨] បុគ្គលណា មិនទ្រុស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះបើចេញផុតអំពីផ្ទះរបស់ខ្លួនហើយ ជាអ្នកមានភក្ខាហារច្រើន ជនច្រើននាក់តែងចិញ្ចឹមជីវិត (អាស្រ័យ) បុគ្គលនោះ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះ ទៅកាន់ជនបទ និគម រាជធានីណា ៗ គេតែងបូជាក្នុងទីទាំងអស់នោះ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្រទាំងឡាយ ពួកចោរមិនកំហែងបុគ្គលនោះ ក្សត្រ ក៏មិនមើលងាយបុគ្គលនោះ បុគ្គលនោះ រមែងកន្លងនូវសត្រូវទាំងអស់។ បុគ្គលណា មិនទ្រុស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះមិនខឹង មកកាន់ផ្ទះរបស់ខ្លួន ជាអ្នកគេទទួលរីករាយក្នុងរោងសម្រាប់ប្រជុំ ជាបុគ្គលឧត្ដមរបស់ពួកញាតិ។ បុគ្គលធ្វើសក្ការៈចំពោះ (មិត្រ) រមែងត្រូវមិត្រធ្វើសក្ការៈវិញ ជាអ្នកគោរព (មិត្រ) រមែងបានសេចក្ដីគោរពវិញ បុគ្គលមិនប្រទូស្តមិត្រ រមែងពេញដោយគុណ និងកិត្តិសព្ទ។ បុគ្គលអ្នកបូជាមិត្រ រមែងបានការបូជាវិញ ជាអ្នកសំពះមិត្រ រមែងបានការសំពះតបវិញ បុគ្គលមិនប្រទូស្តមិត្រ រមែងដល់នូវយសបរិវារ និងកិត្តិសព្ទ។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ បុគ្គលនោះ រមែងរុងរឿងដូចភ្លើង រុងរឿងដូចទេវតា ជាអ្នកមិនលះបង់ចាកសិរីឡើយ។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ គោទាំងឡាយរបស់បុគ្គលនោះ សម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះសាបព្រោះក្នុងស្រែ រមែងដុះដាល បុគ្គលនោះ រមែងបរិភោគផ្លែនៃពូជទាំងឡាយ ដែលខ្លួនសាបព្រោះហើយ។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ បុគ្គលនោះ សូម្បីធ្លាក់ទៅក្នុងជ្រោះក្ដី អំពីភ្នំក្ដី អំពីដើមឈើក្ដី ធ្លាក់ហើយ រមែងបានទីពឹង។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ សត្រូវទាំងឡាយគ្រប់សង្កត់បុគ្គលនោះមិនបាន ដូចខ្យល់មិនអាចគ្រប់សង្កត់ដើមជ្រៃ ដែលមានឫស និងពួរដុះហើយ។

[៩] (នាយសារថី) បពិត្រព្រះរាជបុត្រ សូមទ្រង់ស្ដេចមក ទូលព្រះបង្គំជាខ្ញុំ នឹងនាំទ្រង់ទៅកាន់ដំណាក់របស់ព្រះអង្គ សូមទ្រង់សោយរាជ្យចុះ សេចក្ដីចំរើននឹងមានដល់ទ្រង់ ទ្រង់នឹងធ្វើអ្វីក្នុងព្រៃ។

[១០] (ព្រះមហាសត្វ) នែនាយសារថី រាជសម្បត្តិណា ដែលខ្ញុំគប្បីបានដោយអធម្មចរិយៈ ខ្ញុំមិនត្រូវការដោយរាជសម្បត្តិនោះ ឬដោយជនជាញាតិ ឬក៏ដោយទ្រព្យទេ។

[១១] (នាយសារថី) បពិត្រព្រះរាជបុត្រ សូមទ្រង់ស្ដេចទៅអំពីទីនេះ ហើយញុំាងទូលព្រះបង្គំជាខ្ញុំ ឲ្យបាននូវរង្វាន់ជាទីត្រេកអរ បពិត្រព្រះរាជបុត្រ កាលបើព្រះអង្គស្ដេចទៅហើយ ព្រះរាជបិតា និងព្រះមាតា គប្បីប្រទាន (រង្វាន់) ដល់ទូលព្រះបង្គំជាខ្ញុំ។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្ដេចទៅហើយ ពួកស្រីស្នំ និងរាជកុមារ ពួកឈ្មួញ និងពួកព្រាហ្មណ៍ ជនទាំងអម្បាលនោះមានចិត្តត្រេកអរ គប្បីឲ្យ (រង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ)។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្ដេចទៅហើយ ពួកហ្មដំរី ពួកពលរក្សាព្រះអង្គ ពួកពលរថ ពួកថ្មើរជើង ជនទាំងអម្បាលនោះ មានចិត្តត្រេកអរ គប្បីឲ្យ (រង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ)។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្ដេចទៅ ពួកអ្នកជនបទ និងពួកអ្នកនិគម មានធញ្ញាហារច្រើន មកប្រជុំគ្នា គប្បីឲ្យគ្រឿងបណ្ណាការទាំងឡាយដល់ទូលព្រះបង្គំជាខ្ញុំ។

[១២] (ព្រះមហាសត្វ...) ខ្ញុំដែលព្រះបិតាមាតា អ្នកដែន អ្នកនិគម និងពួករាជកុមារទាំងពួង បានលះចោលហើយ ផ្ទះរបស់ខ្លួនខ្ញុំមិនមានទេ។ ខ្ញុំដែលព្រះមាតាបានអនុញ្ញាតឲ្យទទួលរាជ្យ ៧ ថ្ងៃហើយ ខ្ញុំដែលព្រះបិតាលះចោលស្រឡះហើយ ខ្ញុំនឹងបួសនៅក្នុងព្រៃតែម្នាក់ឯង មិនប្រាថ្នានូវកាមទាំងឡាយឡើយ។

[១៣] សេចក្ដីប្រាថ្នាជាផល តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ (អស់ ១៦ ឆ្នាំ) ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹងមានភ័យអំពីណា។

[១៤] (នាយសារថី...) ទ្រង់នោះមានព្រះបន្ទូលពីរោះ មានព្រះបន្ទូលក្បោះក្បាយយ៉ាងនេះ ហេតុអ្វីបានជាទ្រង់មិនមានព្រះបន្ទូលក្នុងសំណាក់នៃព្រះបិតា ព្រះមាតាក្នុងពេលនោះ។

[១៥] (ព្រះមហាសត្វ...) ខ្ញុំមិនមែនខ្វិនព្រោះមិនមានសន្លាក់ទេ ខ្ញុំមិនមែនថ្លង់ព្រោះមិនមានសោតប្រសាទទេ ខ្ញុំមិនមែនគព្រោះមិនមានជិវ្ហាប្រសាទទេ អ្នកកុំសំគាល់ខ្ញុំថា ជាមនុស្សគឡើយ។ ខ្ញុំរលឹកឃើញនូវជាតិមុន ជាជាតិដែលខ្ញុំបានសោយរាជ្យ លុះខ្ញុំបានសោយរាជ្យក្នុងជាតិនោះហើយ ក៏ធ្លាក់នរកគួរស្ញើប។ ខ្ញុំសោយរាជ្យក្នុងជាតិនោះអស់ ២០ ឆ្នាំ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ។ ខ្ញុំខ្លាចរាជ្យនោះ កុំឲ្យព្រះមាតា បិតាអភិសេកខ្ញុំក្នុងរាជ្យ ព្រោះហេតុនោះ បានជាខ្ញុំមិននិយាយក្នុងសំណាក់នៃព្រះបិតាមាតាក្នុងកាលនោះ។ ព្រះរាជបិតាបានឲ្យខ្ញុំអង្គុយលើព្រះឧរុ ហើយទ្រង់វិនិច្ឆ័យក្ដីថា អ្នកទាំងឡាយ ចូរសំឡាប់ចោរ ១ នាក់ ចូរចងចោរ ១ នាក់ (ធ្វើចោរ ១ នាក់) ឲ្យប្រឡាក់ដោយទឹកក្បុង។ ចូរដោតចោរ ១ នាក់លើឈើស្រួច ព្រះរាជបិតាត្រាស់បង្គាប់មហាជន ដោយប្រការដូច្នេះ លុះខ្ញុំស្ដាប់នូវវាចាដ៏អាក្រក់នោះ ដែលព្រះរាជបិតា ទ្រង់ត្រាស់ហើយ។ ខ្ញុំមិនគទេ តែមានភេទដូចបុគ្គលគ ខ្ញុំមិនខ្វិនទេ តែសន្មតថាដូចជាខ្វិន ខ្ញុំបាននៅជ្រមុជជ្រមុលក្នុងមូត្រ និងករីសរបស់ខ្លួន។ ជីវិត (របស់សត្វ) លំបាកផង តិចផង ជីវិតនោះ ប្រកបដោយទុក្ខ បុគ្គលណាអាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរដោយហេតុណានីមួយ។ បុគ្គលណាអាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរដោយហេតុណានីមួយ ព្រោះមិនបានបញ្ញាផង ព្រោះមិនឃើញធម៌ផង។ សេចក្ដីប្រាថ្នាជាផល តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំ កាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹងមានភ័យអំពីណា។

[១៦] (នាយសារថី) បពិត្រព្រះរាជបុត្រ ទូលព្រះបង្គំជាខ្ញុំនឹងបួសក្នុងសំណាក់ព្រះអង្គ បពិត្រព្រះរាជបុត្រដ៏ចំរើន សូមទ្រង់ត្រាស់ហៅទូលព្រះបង្គំជាខ្ញុំ (ឲ្យបួសផង) ទូលព្រះបង្គំជាខ្ញុំ ពេញចិត្តនឹងបព្វជ្ជាដែរ។

[១៧] (ព្រះមហាសត្វ) នែនាយសារថី អ្នកចូរប្រគល់នូវរថ ហើយជាអ្នកមិនមានបំណុល សឹមមកចុះ ព្រោះថា បព្វជ្ជា (រមែងសម្រេច) ដល់បុគ្គលមិនមានបំណុល បព្វជ្ជាកម្មនេះ ពួកឥសីសរសើរហើយ។

[១៨] (នាយសារថី) សេចក្ដីចំរើន ចូរមានដល់ទ្រង់ ពាក្យណាដែលទ្រង់បានថ្លែងហើយ ទូលព្រះបង្គំជាខ្ញុំនឹងធ្វើតាមពាក្យនោះ ទ្រង់ដែលទូលព្រះបង្គំជាខ្ញុំអង្វរហើយ គួរធ្វើតាមពាក្យរបស់ទូលព្រះបង្គំជាខ្ញុំនោះផង។ សូមទ្រង់ស្ដេចគង់នៅក្នុងទីនេះ ដរាបដល់ទូលព្រះបង្គំជាខ្ញុំនាំព្រះរាជាមកដល់ ព្រះបិតារបស់ទ្រង់ទតឃើញហើយ សមជាមានព្រះហឫទ័យត្រេកអររីករាយ។

[១៩] (ព្រះមហាសត្វ) នែនាយសារថី អ្នកនិយាយពាក្យណានឹងខ្ញុំ ៗ នឹងធ្វើតាមពាក្យរបស់អ្នកនោះ ឯខ្ញុំមានបំណងដើម្បីជួបព្រះបិតារបស់ខ្ញុំ ដែលទ្រង់ស្តេចយាងមកក្នុងទីនេះដែរ។ ម្នាលសំឡាញ់ អ្នកទៅហើយចូរមកវិញ ចូរត្រឡប់ទៅសិនចុះ អ្នកប្រាប់នូវសេចក្តីសុខដល់ញាតិទាំងឡាយ អ្នកដែលខ្ញុំប្រាប់ហើយ គប្បីក្រាបទូលនូវការថ្វាយបង្គំចំពោះព្រះមាតាបិតា។

[២០] (អភិសម្ពុទ្ធគាថា) នាយសារថី ចាប់ព្រះបាទានៃព្រះមហាសត្វនោះ ហើយក៏ធ្វើប្រទក្សិណព្រះមហាសត្វនោះ រួចឡើងជិះរថ បរចូលទៅកាន់រាជទ្វារ។

[២១] ព្រះមាតាទតឃើញរថទទេ ក៏មានព្រះនេត្រដ៏ពេញពោរដោយព្រះអស្សុ ទ្រង់ព្រះកន្សែង មៀងមើលទៅនាយសារថីនោះ ដែលមកវិញតែឯង ដោយគិតថា នាយសារថីនេះ សម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ។ កូនរបស់អញ ចំរើនផែនដី នាយសារថីកប់ក្នុងផែនដីដោយពិត ពួកសត្រូវរមែងត្រេកអរដោយពិត ពួកជនមានពៀរ ត្រេកអរហើយដោយពិត ព្រោះឃើញនាយសារថីសម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ។ ព្រះមាតាទតឃើញរថទទេ ក៏មានព្រះនេត្រដ៏ពេញពោរដោយព្រះអស្សុ ទ្រង់ព្រះកន្សែង សួរទៅនាយសារថីនោះ ដែលមកវិញតែម្នាក់ឯងថា កូនរបស់ខ្ញុំនោះ ជាមនុស្សគឬអ្វី ជាមនុស្សខ្វិនឬអ្វី កាលអ្នកកប់ក្នុងផែនដី ក្នុងកាលនោះ កូនរបស់ខ្ញុំពិលាបដែរឬ ម្នាលនាយសារថី អ្នកចូរប្រាប់នូវរឿងនោះដល់ខ្ញុំ។ (កូនរបស់ខ្ញុំនោះ) ជាមនុស្សគ ជាមនុស្សខ្វិន កាលអ្នកកប់ក្នុងផែនដី បានកម្រើកដៃ និងជើងដូចម្តេចដែរ (ម្នាលនាយសារថី) អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់រឿងនោះ។

[២២] (នាយសារថី) បពិត្រព្រះនាងជាម្ចាស់ (បើ) ព្រះនាងឲ្យអភ័យដល់ទូលព្រះបង្គំជាខ្ញុំ ហេតុណាដែលខ្ញុំបានឮហើយ ឬបានឃើញហើយ ក្នុងសំណាក់នៃព្រះរាជបុត្រ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលនូវហេតុនោះដល់ព្រះនាង។

[២៣] (ព្រះរាជទេវី) ម្នាលសារថីសំឡាញ់ ខ្ញុំឲ្យអភ័យដល់អ្នក ហេតុណាដែលអ្នកបានឮហើយ ឬបានឃើញហើយក្នុងសំណាក់នៃព្រះរាជបុត្រ អ្នកកុំភិតភ័យ ចូរប្រាប់នូវហេតុនោះចុះ។

[២៤] (នាយសារថី) ព្រះរាជបុត្រនោះ មិនមែនគទេ ព្រះរាជបុត្រនោះ មិនមែនខ្វិនទេ ឯព្រះរាជបុត្រនោះ មានព្រះបន្ទូលក្បោះក្បាយ បានឮថា ព្រះរាជបុត្រនោះ ទ្រង់ខ្លាចរាជ្យ ទើបបានជាធ្វើនូវពុតត្បុតច្រើនយ៉ាង។ ព្រះរាជបុត្រនោះ ទ្រង់រឭកឃើញនូវជាតិមុន ជាជាតិដែលបានទ្រង់សោយរាជ្យ លុះសោយរាជ្យក្នុងទីនោះហើយ ធ្លាក់នរកគួរស្ញែង។ ព្រះរាជបុត្រនោះ បានសោយរាជ្យក្នុងទីនោះអស់ ២០ ឆ្នាំគត់ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ។ ព្រះរាជបុត្រនោះ ទ្រង់ខ្លាចរាជ្យនោះហើយ (ក៏តាំងព្រះរាជហឫទ័យថា) ព្រះរាជមាតាបិតាកុំអភិសេកអញក្នុងរាជ្យ ព្រោះហេតុនោះ ទើបព្រះរាជបុត្រមិនមានបន្ទូលក្នុងសំណាក់នៃព្រះបិតា និងព្រះមាតាក្នុងកាលនោះ។ ព្រះរាជបុត្រនោះ បរិបូណ៌ដោយអវយវៈតូចធំ មានកំពស់ និងទំហំ (ដ៏ស័ក្តិសម) មានព្រះបន្ទូលដ៏ក្បោះក្បាយ មានបញ្ញា ទ្រង់ឋិតនៅក្នុងផ្លូវសួគ៌។ បើព្រះនាងមានប្រាថ្នាដើម្បីឃើញព្រះរាជបុត្រ ជាកូនបង្កើតរបស់ព្រះនាង សូមព្រះនាងយាងទៅចុះ តេមិយកុមារគង់នៅក្នុងទីណា ទូលព្រះបង្គំជាខ្ញុំនឹងនាំព្រះនាងឲ្យដល់ទីនោះ។

[២៥] (ព្រះបាទកាសិកៈ) នាយសារថីទាំងឡាយ ចូរទឹមសេះក្នុងរថ អ្នកទាំងឡាយ ចូរចងដង្កន់នាដំរី ស័ង្ខ និងស្គរ ចូរលាន់សំឡេងឡើង ស្គរមានមុខតែម្ខាង ចូរលាន់សំឡេងឡើង។ ស្គរដែលគេពាសល្អហើយ ចូរបន្លឺសំឡេង ស្គរមានសំឡេងពីរោះ ចូរលាន់សំឡេងឡើង ទាំងពួកអ្នកនិគម ចូរទៅតាមយើងចុះ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង។ ពួកស្រីស្នំ និងរាជកុមារ ពួកឈ្មួញ និងពួកព្រាហ្មណ៍ ចូរនាំគ្នាទឹមយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង។ ពួកហ្មដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង ចូរនាំគ្នាទឹមយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង។ អ្នកជនបទមកប្រជុំគ្នា ទាំងអ្នកនិគម ក៏មកប្រជុំគ្នា ហើយចូរទឹមនូវយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង។

[២៦] (អភិសម្ពុទ្ធគាថា) ឯពួកនាយសារថី (បាននាំយក) នូវសេះសិន្ធពទាំងឡាយ ជាពាហនៈមានសន្ទុះដ៏លឿន ដែលទឹមហើយ ចូលមកកាន់រាជទ្វារ (ក្រាបបង្គំទូលថា) បពិត្រព្រះសម្មតិទេព សេះទាំងឡាយនេះ ទូលព្រះបង្គំជាខ្ញុំបានទឹមរួចហើយ។

[២៧] (ព្រះរាជា) ពួកសេះធាត់ៗ រមែងសាបសូន្យចាកសន្ទុះ ពួកសេះស្គមៗ រមែងសាបសូន្យចាកកំឡាំង អ្នកទាំងឡាយ ត្រូវវៀរបង់នូវពួកសេះស្គម និងសេះធាត់ចេញ ហើយទឹមតែពួកសេះដែលប្រកប (ដោយវ័យ សម្បុរ សន្ទុះ កំឡាំង) វិញ។

[២៨] លំដាប់នោះ ព្រះរាជាទ្រង់ប្រញាប់ប្រញាល់ឡើងគង់រថ ដែលនាយសារថីទឹមហើយ ទ្រង់ត្រាស់ទៅនឹងស្ត្រីស្នំថា នាងទាំងអស់គ្នា ចូរទៅតាមយើងចុះ។ នាងទាំងឡាយចូរប្រដាប់ដោយមាសទាំងឡាយ ហើយកាន់មកនូវផ្លិត មកុដ ព្រះខាន់ ស្វេតច្ឆត្រ និងស្បែកជើង រួចឡើងជិះរថមក។ បន្ទាប់ពីនោះមក ព្រះរាជាបានឲ្យនាយសារថីដើរមុខ ហើយទ្រង់ស្តេចយាងទៅ តេមិយកុមារនៅក្នុងទីណា ក៏យាងទៅក្នុងទីនោះយ៉ាងឆាប់។

[២៩] តេមិយៈទតឃើញព្រះបិតានោះ កំពុងស្តេចយាងមក ហាក់ដូចជារុងរឿងដោយតេជៈ ដែលពួកអាមាត្យអ្នកកាន់ព្រះខាន់ហែហមហើយ ទើបត្រាស់សួរព្រះបិតានោះថា បពិត្រព្រះបិតា ព្រះអង្គមានសេចក្តីសុខសប្បាយទេឬ បពិត្រព្រះបិតា ព្រះអង្គមិនមានព្រះអាពាធទេឬ រាជកញ្ញាទាំងអស់ ជាព្រះមាតារបស់ខ្ញុំមិនមានរោគទេឬ។

[៣០] (ព្រះវរបិតា) នែកូន ខ្ញុំសុខសប្បាយទេ នែកូន ខ្ញុំមិនមានជំងឺដម្កាត់ទេ រាជកញ្ញាទាំងអស់ជាមាតារបស់អ្នក មិនមានរោគទេ។

[៣១] (មហាសត្វ) បពិត្រព្រះបិតា ព្រះអង្គមិនសោយទឹកស្រវឹងទេឬ សុរាមិនពេញព្រះទ័យរបស់ព្រះអង្គទេឬ ព្រះទ័យរបស់ព្រះអង្គត្រេកអរក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទានដែរឬ។

[៣២] (ព្រះវរបិតា) នែកូន ខ្ញុំមិនផឹកទឹកស្រវឹងទេ មួយទៀត សុរាមិនពេញចិត្តខ្ញុំទេ ឯចិត្តរបស់ខ្ញុំ តែងត្រេកអរក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទាន។

[៣៣] (មហាសត្វ) យានរបស់ព្រះអង្គមិនខូចទេឬ វាហនៈរបស់ព្រះអង្គតែងប្រព្រឹត្តទៅបានដែរឬ ព្យាធិទាំងឡាយជាគ្រឿងដុតកំដៅសរីរៈ មិនមានដល់ព្រះអង្គទេឬ។

[៣៤] (ព្រះវរបិតា) ឯយានរបស់ខ្ញុំឥតមានខូចទេ វាហនៈរបស់ខ្ញុំក៏ប្រព្រឹត្តទៅបានដោយស្រួល ព្យាធិទាំងឡាយជាគ្រឿងដុតកំដៅសរីរៈ មិនមានដល់ខ្ញុំទេ។

[៣៥] (មហាសត្វ) ជនបទនៅទីប្រទល់ដែនរបស់ព្រះអង្គ (ស្រុក និងនិគម) របស់ព្រះអង្គទាំងមូល ដែលតាំងនៅកណ្តាលផែនដី ជាស្រុកសម្បូណ៌ដែរឬ ឃ្លាំង និងជង្រុក ព្រះអង្គបានតម្កល់ទុកស្រួលបួលទេឬ។

[៣៦] (ព្រះវរបិតា) ជនបទនៅទីប្រទល់ដែនរបស់ខ្ញុំ (ស្រុក និងនិគម) ទាំងមូលរបស់ខ្ញុំ ដែលតាំងនៅកណ្ដាលដែន ជាស្រុកសម្បូណ៌ ឃ្លាំង និងជង្រុកទាំងអស់ ខ្ញុំបានតម្កល់ទុកស្រួលបួលហើយ។

[៣៧] (មហាសត្វ) បពិត្រមហារាជ ព្រះអង្គស្ដេចយាងមកល្អហើយ មួយទៀត ព្រះអង្គស្ដេចមក មិនមែនអាក្រក់ទេ រាជបុរសចូររៀបចំបល្ល័ង្កជាទីគង់របស់ព្រះរាជា។

[៣៨] ព្រះអង្គគង់លើកម្រាលស្លឹកឈើ ដែលគេតែងតាំងហើយ សូមព្រះអង្គ យកទឹកអំពីទីនេះ លាងព្រះបាទារបស់ព្រះអង្គចុះ។

[៣៩] បពិត្រព្រះរាជា ស្លឹកនេះដែលអាត្មាភាពចម្អិនហើយ ជារបស់មិនមានរសប្រៃ បពិត្រមហារាជ្យ សូមព្រះអង្គស្ដេចសោយចុះ ព្រះអង្គទើបស្ដេចយាងមកដល់ ទុកជាភ្ញៀវរបស់អាត្មាភាព។

[៤០] (ព្រះវរបិតា) ខ្ញុំមិនបរិភោគស្លឹកនេះទេ ព្រោះស្លឹកឈើនេះ មិនមែនជាភោជនរបស់ខ្ញុំ ខ្ញុំបរិភោគតែបាយនៃស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាត។

[៤១] សេចក្ដីអស្ចារ្យកើតប្រាកដដល់ខ្ញុំ ព្រោះឃើញ (លោក) នៅស្ងាត់តែម្នាក់ឯង កាលលោកបរិភោគភោជនបែបនេះ សម្បុរនៅតែស្រស់ថ្លាដោយហេតុដូចម្ដេច។

[៤២] (មហាសត្វ) បពិត្រព្រះរាជា អាត្មាភាពម្នាក់ឯង សិងលើកម្រាលស្លឹក ដែលតាំងទុកហើយ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាពស្រស់ថ្លាដោយដំណេកម្នាក់ឯងនោះ ។ ពួកអ្នករក្សាព្រះរាជា ដែលសៀតព្រះខាន់ មិនប្រាកដដល់អាត្មាភាពទេ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាព ថ្លាស្រស់ដោយដំណេកម្នាក់ឯងនោះ។ អាត្មាភាព មិនតាមសោក និងអារម្មណ៍ដែលកន្លងហើយ មិនប្រាថ្នានូវអារម្មណ៍ដែលមិនទាន់មកដល់ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលលើកឡើងចំពោះមុខ ហេតុនោះ បានជាវណ្ណៈរបស់អាត្មាភាព រមែងថ្លាស្រស់។ ជនពាលទាំងឡាយ តែងរីងស្ងួត ព្រោះសេចក្ដីប្រាថ្នាអារម្មណ៍ដែលមិនទាន់មកដល់ ព្រោះសេចក្ដីតាមសោកស្ដាយអារម្មណ៍ដែលកន្លងទៅហើយនេះ ដូចជាដើមបបុសមានសម្បុរខៀវ ដែលគេដកហាលថ្ងៃដូច្នោះ។

[៤៣] (ព្រះវរបិតា) នែកូន ខ្ញុំនឹងឲ្យនូវពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកជនពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក។ មួយទៀត ខ្ញុំឲ្យនូវស្រីស្នំដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន ចូរអ្នកគ្រប់គ្រងនូវស្ត្រីទាំងនោះចុះ អ្នកជាព្រះរាជារបស់យើង។ ស្ត្រីរបាំ ជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង បានសិក្សា (ក្នុងកិច្ចស្ត្រី) ញ៉ាំងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ។ ខ្ញុំនឹងនាំយករាជកញ្ញាដែលមានខ្លួនប្រដាប់ហើយអំពីពួកព្រះរាជាដទៃដល់អ្នក អ្នកចូរញ៉ាំងកូនទាំងឡាយ ឲ្យកើតក្នុងស្ត្រីទាំងនោះ ហើយសិមបួសក្នុងកាលជាខាងក្រោយ។ អ្នកនៅក្មេងកម្លោះ ប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យ សេចក្ដីចំរើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ។

[៤៤] (មហាសត្វ) បុគ្គលនៅកម្លោះ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីជាកម្លោះ ព្រោះថា បព្វជ្ជារបស់បុគ្គលនៅកម្លោះនេះ ពួកឥសីទាំងឡាយសរសើរហើយ។ បុគ្គលនៅកម្លោះ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីនៅកម្លោះ អាត្មាភាព នឹងប្រព្រឹត្តព្រហ្មចរិយធម៌ អាត្មាភាព មិនត្រូវការដោយរាជ្យទេ។ បពិត្រព្រះមាតា និងបិតា អាត្មាភាពឃើញនរជននៅក្មេង ទើបនឹងចេះនិយាយ ជាកូនជាទីស្រឡាញ់ដែលមាតាបិតាបានដោយលំបាក មិនទាន់ចាស់គ្រាំគ្រា ហើយស្លាប់។ អាត្មាភាព ឃើញនាងកុមារីមានសម្បុរដូចមាស ដែលមច្ចុរាជចាប់ដកក្ស័យជីវិតហើយ ដូចជាដកនូវទំពាំងឫស្សីដ៏ខ្ចី។ នរជនទាំងឡាយ ឬនាងនារីទាំងឡាយ សូម្បីនៅក្មេង ក៏តែងស្លាប់ តើសត្វណា គប្បីទុកចិត្តក្នុងជីវិតនោះថា អាត្មាអញនៅក្មេងដូច្នេះ។ អាយុនៃកុមារណា មានប្រមាណតិច ដោយការកន្លងទៅនៃយប់ និងថ្ងៃ ភាពនៃខ្លួនជាកុមារក្នុងវ័យនោះ នឹងធ្វើដូចម្ដេចកើត ដូចទីមានទឹកតិចរបស់ត្រីទាំងឡាយ។ សត្វលោក ត្រូវសត្រូវបៀតបៀនជានិច្ចផង ត្រូវសត្រូវរួបរឹតជានិច្ចផង កាលយប់ និងថ្ងៃទាំងឡាយមិនកន្លងទៅទទេទេ តើព្រះអង្គនឹងអភិសេកអាត្មាភាពក្នុងរាជ្យដូចម្ដេច។

[៤៥] (ព្រះរាជា) សត្វលោកនេះ ត្រូវសត្រូវអ្វីបៀតបៀនផង ត្រូវសត្រូវអ្វីរួបរឹតផង ធម្មជាតិដូចម្ដេច មិនកន្លងទៅទទេ ខ្ញុំសួរហើយ អ្នកចូរប្រាប់នូវដំណើរនោះ។

[៤៦] (ព្រះមហាសត្វ) សត្វលោកត្រូវមច្ចុបៀតបៀនផង ត្រូវជរារួបរឹតផង

រាត្រីទាំងឡាយ រមែងកន្លងទៅមិនទទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ។ កាលតម្បាញដែលបុគ្គលត្បាញរបស់ណា ៗ ដែលបុគ្គលនឹងត្បាញរបស់ដែលត្រូវត្បាញ (នោះៗ) ជារបស់នៅសល់តិច យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ។ ផ្លូវទឹកដ៏ពេញ កាលហូរទៅ មិនត្រឡប់ថយក្រោយវិញ យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ កាលកន្លងទៅ មិនត្រឡប់វិញយ៉ាងនោះដែរ។ ផ្លូវទឹកដ៏ពេញ គប្បីបន្សាត់ទៅនូវដើមឈើទាំងឡាយ ដែលដុះក្បែរច្រាំង យ៉ាងណាមិញ សត្វទាំងអស់ ត្រូវជរា និងមរណៈបន្សាត់ទៅក៏យ៉ាងនោះដែរ។

[៤៧] (ព្រះវរបិតា) នែកូន ខ្ញុំនឹងឲ្យពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកពលពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក។ មួយទៀត យើងនឹងឲ្យស្ត្រីស្នំដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន អ្នកចូរគ្រប់គ្រងពួកស្ត្រីទាំងនោះចុះ អ្នកនឹងជារាជារបស់យើង ស្ត្រីរបាំជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង សិក្សា (ក្នុងកិច្ចរបស់ស្ត្រី) នឹងញ៉ាំងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ។ យើងនឹងនាំយកពួករាជកញ្ញាដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជាដទៃដល់អ្នក អ្នកញ៉ាំងកូនទាំងឡាយឲ្យកើតក្នុងពួកនាងកញ្ញាទាំងនោះ ហើយសិមបួសក្នុងកាលជាខាងក្រោយចុះ។ អ្នកនៅក្មេងកម្លោះ ប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យចុះ សេចក្ដីចំរើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ។ នែកូន ខ្ញុំនឹងឲ្យឃ្លាំង ជង្រុក វាហនៈ ពល និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក។ អ្នកដែលក្រុមនៃរាជកញ្ញាមានចំណែកដ៏ល្អចោមរោមហើយ មានពួកនៃខ្ញុំស្ត្រីហែហមហើយ ចូរសោយរាជ្យចុះ សេចក្ដីចំរើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ។

[៤៨] (ព្រះមហាសត្វ) ប្រយោជន៍អ្វីដោយទ្រព្យដល់អាត្មាភាព ព្រោះទ្រព្យតែងអស់ទៅ ប្រយោជន៍អ្វីដោយភរិយា ព្រោះភរិយាក៏គង់ស្លាប់ ប្រយោជន៍អ្វីដោយវ័យដែលគ្រាំគ្រា ជាវ័យត្រូវជរាគ្របសង្កត់ហើយ។ ក្នុងលោកសន្និវាសនេះ នៅមានសេចក្ដីត្រេកអរអ្វី ការលេងសើចអ្វី ការរីករាយអ្វី ការស្វែងរកទ្រព្យអ្វី អាត្មាភាពត្រូវការអ្វីដោយកូន និងប្រពន្ធ បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះចាកបំណងហើយ។ អាត្មាភាពដឹងច្បាស់យ៉ាងនេះថា មច្ចុមិនធ្វេសប្រហែសចំពោះអញឡើយ អាត្មាភាពនោះ ត្រូវសេចក្ដីស្លាប់គ្របសង្កត់ហើយ នៅមានសេចក្ដីត្រេកអរដូចម្ដេច ការស្វែងរកទ្រព្យដូចម្ដេចទៀត។ ផ្លែឈើទុំទាំងឡាយ តែងមានភ័យអំពីការជ្រុះជានិច្ច យ៉ាងណាមិញ សត្វទាំងឡាយ កើតមកហើយ តែងមានភ័យអំពីសេចក្ដីស្លាប់ជានិច្ចយ៉ាងនោះដែរ។ ជនជាច្រើន ពួកខ្លះដែលគេឃើញក្នុងវេលាព្រឹក តែគេមិនឃើញក្នុងវេលាល្ងាច ជនជាច្រើនពួកខ្លះ ដែលគេឃើញក្នុងវេលាល្ងាច តែគេមិនឃើញក្នុងវេលាព្រឹក។ សេចក្ដី

ព្យាយាមក្នុងកុសល គេគួរធ្វើក្នុងថ្ងៃនេះឯង បុគ្គលណា គប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក ដ្បិតការបណ្តោះបណ្តែអំពីសេចក្តីស្លាប់ ដែលមានសេនាច្រើននោះ មិនមានដល់យើងទេ។ ពួកចោរទាំងឡាយ តែងប្រាថ្នាទ្រព្យ បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះហើយអំពីបំណង បពិត្រព្រះរាជា សូមព្រះអង្គមក សូមព្រះអង្គត្រឡប់ព្រះហឫទ័យទៅវិញចុះ អាត្មាភាពមិនត្រូវការដោយរាជ្យទេ។

ចប់ តេមិយជាតក ទី ១។

## មហាជនកជាតក ទី២

CS sut.kn.jat.539 | ភាគទី ៦២

(៥៣៩. មហាជនកជាតកំ (២))

[៤៩] (នាងទេវធីតាឈ្មោះមណីមេខលាសួរថា) បុគ្គលណានេះ កាលមិនឃើញត្រើយ ក៏ព្យាយាម (ហែល) ក្នុងកណ្តាលសមុទ្រ អ្នកដឹងនូវអំណាចនៃប្រយោជន៍ដូចម្តេច ក៏ព្យាយាមក្រៃពេកម្ល៉េះ។

[៥០] (ព្រះមហាសត្វត្រាស់តបថា) ម្នាលទេវតា ខ្ញុំពិចារណានូវវត្តនៃសត្វលោក និងអានិសង្សនៃសេចក្តីព្យាយាម ព្រោះហេតុដូច្នោះ ខ្ញុំសូម្បីមិនឃើញត្រើយ ក៏នៅតែព្យាយាមក្នុងកណ្តាលសមុទ្រ។

[៥១] (នាងមណីមេខលា) អ្នកមិនឃើញត្រើយនៃសមុទ្រដ៏ជ្រៅប្រមាណមិនបាន ការព្យាយាមតាមកម្លាំងបុរសរបស់អ្នក ជាព្យាយាមសោះសូន្យទទេ អ្នកមិនដល់នូវត្រើយទេ មុខជានឹងស្លាប់។

[៥២] (ព្រះមហាសត្វ) បុគ្គលធ្វើនូវកិច្ចរបស់បុរស ទើបជាអ្នកមិនមានបំណុល (ក្នុងរវាង) ពួកញាតិ ពួកទេវតា និងពួកបិតា (ព្រហ្ម) ទាំងមិនក្តៅក្រហាយក្នុងកាលជាខាងក្រោយ។

[៥៣] (នាងមណីមេខលា) ការងារណា មិនគប្បីសម្រេច (ដោយសេចក្តីព្យាយាមទេ) ការងារនោះ ជារបស់ឥតផល មានសេចក្តីលំបាកជាកម្រៃ សេចក្តីស្លាប់ រមែងសម្រេចដល់បុគ្គលណា បុគ្គលនោះ មានប្រយោជន៍ដូចម្តេចដោយសេចក្តីព្យាយាមក្នុងការងារនោះ។

[៥៤] (ព្រះមហាសត្វ) ម្នាលទេវតា បុគ្គលណាដឹងច្បាស់ថា ការងារមិនគប្បីសម្រេចដោយពិត ហើយមិនរក្សាជីវិតរបស់ខ្លួន បុគ្គលនោះបើបន្ថយសេចក្តីព្យាយាម គង់ដឹង (នូវផលនៃសេចក្តីខ្ជិលនោះមិនខាន)។ ម្នាលទេវតា បុគ្គលពួកខ្លះក្នុងលោកនេះ (កាលឃើញ) នូវផលនៃសេចក្តីប្រាថ្នាហើយ រមែងប្រកបនូវការងារទាំងឡាយ ការងារទាំងនោះ សម្រេចខ្លះ មិនសម្រេចខ្លះ។ ម្នាលទេវតា ក្រែងអ្នកបានឃើញផលនៃកម្មដ៏ជាក់ច្បាស់ដោយខ្លួនឯងដែរឬ ជនទាំងឡាយដទៃលិចលង់ហើយ ខ្ញុំនៅឆ្លង ទាំងបានឃើញនាង ដែលឋិតនៅក្នុងទីជិតនៃខ្ញុំ។ ខ្ញុំនោះ នឹងព្យាយាមតាមសមគួរដល់សេចក្តីអស់អាច និងសមគួរដល់កម្លាំង ខ្ញុំកាលទៅដល់ត្រើយនៃសមុទ្រ នឹងធ្វើនូវសេចក្តីព្យាយាម ដែលបុរសគប្បីធ្វើ។

[៥៥] (នាងមណីមេខលា) កាលមហាសមុទ្រមានអន្លង់ទឹកដ៏ជ្រៅប្រមាណមិនបាន ប្រព្រឹត្តទៅយ៉ាងនេះ អ្នកណាប្រកបដោយសេចក្តីព្យាយាមដោយធម៌ រមែងមិនលិចចុះដោយកម្ម គឺសេចក្តីព្យាយាម ចិត្តរបស់អ្នក ត្រេកអរក្នុងទីណា អ្នកនោះ ចូរទៅក្នុងទីនោះចុះ។

[៥៦] (ព្រះបាទបោលជនក) កំណប់ធំ ១៦ នេះ គឺកំណប់ត្រង់ទីព្រះអាទិត្យរះ កំណប់ត្រង់ទីព្រះអាទិត្យលិច កំណប់ខាងក្នុង កំណប់ខាងក្រៅ កំណប់មិនមែនខាងក្នុង មិនមែនខាងក្រៅ កំណប់ធំត្រង់ទីសម្រាប់ឡើង កំណប់ត្រង់ទីសម្រាប់ចុះ កំណប់ត្រង់សាលព្រឹក្សធំទាំងបួន កំណប់ត្រង់ទីមួយយោជន៍ជុំវិញ កំណប់ធំត្រង់ចុងភ្លុកដំរីទាំងពីរ កំណប់ត្រង់ចុងកន្ទុយ កំណប់ក្នុងទឹក កំណប់ធំត្រង់ចុងឈើសហស្សថាមធ្ម បល្ល័ង ៤ ជ្រុង នឹងញ៉ាំងនាងសីវលីរាជទេវីឲ្យត្រេកអរ។

[៥៧] (ព្រះបាទមហាជនក) បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួនឯង យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ។ បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន (ដែលទេវតា) ស្រង់អំពីទឹក មកដាក់លើគោក។ បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ។ បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន (ដែលទេវតា) ស្រង់អំពីទឹក មកដាក់លើគោក។ នរជន មានប្រាជ្ញា សូម្បីសេចក្តីទុក្ខប៉ះពាល់ហើយ មិនគប្បីកាត់សេចក្តីប្រាថ្នា ដើម្បីដល់នូវសេចក្តីសុខទេ ព្រោះថាការប៉ះពាល់ដ៏ច្រើន ឥតប្រយោជន៍ក៏មាន មានប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងដល់នូវសេចក្តីស្លាប់។ ហេតុដែលបុគ្គលមិនបានគិត សម្រេចក៏មាន ហេតុដែលបុគ្គលគិតហើយ វិនាសទៅក៏មាន ព្រោះភោគៈទាំងឡាយរបស់ស្ត្រី ឬបុរស មិនមែនសម្រេចដោយការគិតទេ។

[៥៨] (មហាជន) ម្នាលគ្នាយើងដ៏ចំរើន ព្រះរាជាត្រួតនូវផែនដីទាំងមូល ជាម្ចាស់ក្នុងទិស មិនដូចអំពីដើមសោះ ថ្ងៃនេះមិនទ្រង់ក្រសាលរបាំ មិនទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះចំរៀង មិនទតម្រឹគ មិនទតឧទ្យាន មិនទតហង្ស ទ្រង់គង់នៅស្ងៀម ហាក់ដូចជាមនុស្សគមិនទ្រង់កាត់សេចក្តី។

[៥៩] (ព្រះបាទមហាជនក) ព្រះបច្ចេកពុទ្ធទាំងឡាយ ទាំងក្មេង ទាំងចាស់ អ្នកប្រាថ្នាសេចក្តីសុខ មានសេចក្តីស្ងប់ស្ងាត់ជាប្រក្រតី ប្រាសចាកចំណងជាកិលេស គង់នៅក្នុងអារាមនៃបុគ្គលណាហ្ន៎ ក្នុងថ្ងៃនេះ។ អ្នកប្រាជ្ញទាំងឡាយណា បានកន្លងនូវតណ្ហា ជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ នៅក្នុងលោកដែលកំពុងខ្វល់ខ្វាយ ខ្ញុំសូមថ្វាយបង្គំអ្នកប្រាជ្ញទាំងនោះ ជាអ្នកស្វែងរកនូវគុណដ៏ធំ។ អ្នកប្រាជ្ញទាំងឡាយនោះ កាត់ទំលាយនូវតម្បាញជាបណ្តាញដ៏មាំរបស់មច្ចុដែលមានមាយាចេញទៅរួច បុគ្គលណាគប្បីញ៉ាំងយើងឲ្យដល់នូវគតិ (លំអាន) នៃអ្នកប្រាជ្ញទាំងនោះបាន។

[៦០] កាលណាអញនឹងលះនគរមិថិលា ជាក្រុងសម្បូណ៌ ដែលជាងចែកហើយ (ដោយឋាន មានរាជនិវេសន៍ជាដើម) វាស់ហើយដោយចំណែក (នៃទ្វារ និងថ្នល់) ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ទូលាយ មានពន្លឺដោយជុំវិញ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង និងក្លោងទ្វារដ៏ច្រើន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានប៉ម និងស៊ុមទ្វារដ៏មាំមួន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដែលគេចែកល្អ មានផ្លូវធំ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរានផ្សារ ដែលគេចែកដោយល្អ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។

កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដំកុះករដោយគោ សេះ និងរថ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាល
ណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃសួន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាល
ណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃឧទ្យាន ហើយបួស ការលះបង់នោះ នឹងសម្រេច
ក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃប្រាសាទដ៏ប្រសើរ ហើយបួស ការលះបង់នោះ
នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង ៣ ជាន់ ពេញដោយរាជវង្សានុវង្ស ដែល
ព្រះបាទវិទេហៈ ព្រះនាមសោមនស្សមានយស ទ្រង់សាងទុក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញ
នឹងលះបង់ដែនវិទេហៈ ជាដែនសម្បូណ៌ បរិបូណ៌ដោយការសន្សំ (នូវធញ្ញាហារជាដើម) ដែលរក្សាតាមធម៌ ហើយបួស ការលះបង់នោះ
នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវដែនវិទេហៈ ជាដែនសម្បូណ៌ ដែលបច្ចាមិត្រផ្ចាញ់មិនបាន ជាដែនរក្សា
តាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ដែលជាទីរីករាយ ដែលជាង
ចែកវាស់ដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ជាទីរីករាយ
ដែលបូកដោយកំបោ និងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ជាទី
រីករាយ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់
នូវដំណាក់កំពូលទាំងឡាយ ដែលជាងចែកហើយ វាស់ហើយដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។
កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលបូកដោយកំបោ និងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណា
ហ្ន៎។ កាលណាអញនឹងលះនូវដំណាក់កំពូលទាំងឡាយ ដែលមានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេច
ក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលលាបល្អហើយ ប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ហើយបួស
ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវគ្រែមាសទាំឡាយ មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស
ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវបល្ល័ង្កកែវមណី មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស
ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវសំពត់អំបោះ និងសំពត់សូត្រ សំពត់ទាំងឡាយដែលកើតអំពី
ដែនខោមៈ និងកើតអំពីដែនកោទុម្ពរ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវ
ស្រះបោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចាក្រពាកយំទ្រហឹង ដេរដាសដោយចង្កុលណីទាំងឡាយផង ដោយឈូក និងព្រលិតទាំង
ឡាយផង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវហ្វូងដំរីមាតង្គៈ ដែលស្អិតស្អាងដោយ
គ្រឿងអលង្ការគ្រប់មុខ មានខ្សែដង្គន់មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរីមានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ
ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវហ្វូវសេះអាជានេយ្យអំពីជាតិ
ជាសេះសិន្ធព ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ ជាវាហនៈលឿន ដែលអ្នកបង្ហាត់សេះកាន់សៃ និងធ្នូ ឡើងជិះហើយ
ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួករថ ប្រដាប់ហើយ មានទង់លើកហើយ
ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះ
ហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួករថមាសប្រដាប់ហើយ មានទង់
លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែល
ក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថប្រាក់ ប្រដាប់ហើយ
មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ
និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមសេះ
ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី
មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមឱដ្ឋ
ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថី
មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមគោ
ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយ
សារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថ
ទឹមកែស ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង
ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញ
នឹងលះបង់នូវរថទឹមពពែ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការ
ទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណា
អញនឹងលះបង់នូវរថទឹមម្រឹគ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿង
អលង្ការទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។
កាលណាអញនឹងលះបង់នូវពួកអ្នកជិះដំរី ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មាន
លំពែងស្នែងក្របី និងកង្វេរក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះសេះ
ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវសៃ និងធ្នូ ហើយបួស ការលះបង់នោះ
នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះរថ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមាន
ពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងព្រួញក្នុងដៃ ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកខ្មាន់ធ្នូ
ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ ហើយបួស ការលះ
បង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកព្រះរាជបុត្ត ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង
កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាស និងកែវពិទូរ្យ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញ
នឹងលះបង់នូវពួកអរិយជន គឺព្រាហ្មណ៍ដែលមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ស្លៀកដណ្តប់
ដោយសំពត់ដែលបានមកអំពីដែនកាសីដ៏ឧត្តម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់
នូវពួកអាមាត្យ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ ហើយបួស
ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ដែលស្អិតស្អាងដោយគ្រឿងអលង្ការ
ទាំងពួង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ជាអ្នកសង្រួមល្អ មាន
ចង្កេះរៀវ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវស្រីស្នំ ៧០០ ជាស្ត្រីស្តាប់បង្គាប់
ពោលពាក្យជាទីស្រលាញ់ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវភាជន៍មាស មានទម្ងន់
១០០ បល្លៈ ប្រកបដោយស្នាមចំឡាក់ ១០០ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាហ្វូងដំរីមាតង្គៈ
របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង មានខ្សែដង្គន់មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរីមានលំពែង
ស្នែងក្របី និងកង្វេរក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាហ្វូងសេះ
របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាសេះអាជានេយ្យដោយជាតិ ជាសេះសិន្ធព ជាវាហនៈដ៏លឿន ដែលពួក
អ្នករក្សាសេះកាន់សៃ និងធ្នូ ឡើងជិះហើយ នឹងមិនដើរតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួករថ
របស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង

ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួករថមាសរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួករថប្រាក់របស់អញ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមសេះរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមឱដ្ឋរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមគោរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមកែសរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមពពែរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមម្រឹគរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអ្នកជិះដំរីរបស់អញ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអ្នកជិះសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវស៊ៃ និងធ្នូ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអ្នកជិះរថរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកខ្មាន់ធ្នូរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួករាជបុត្ររបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាស និងកែវពិទូរ្យ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអរិយជន គឺព្រាហ្មណ៍ អ្នកមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវសំពត់ដ៏ឧត្តមដែលបានមកអំពីដែនកាសី នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអាមាត្យរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ជាស្ត្រីសង្រ្គមល្អ មានចង្កេះរាវ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រលាញ់ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ នឹងបានទៅជាអ្នកកោរក្បាល ឃ្លុំសង្ឃាដិ កាន់បាត្រ ត្រាច់ចរទៅបិណ្ឌបាត ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ នឹងទ្រទ្រង់នូវសង្ឃាដិនៃសំពត់បង្សុកូលទាំងឡាយ ដែលគេចោលក្នុងផ្លូវធំ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ កាលដែលមេឃបង្អុរភ្លៀងចុះអស់ ៧ ថ្ងៃហើយ នឹងត្រាច់ទៅបិណ្ឌបាតទាំងចីវរទទឹក ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញនឹងចេញទៅអំពីដើមឈើមួយ ទៅកាន់ដើមឈើមួយ អំពីព្រៃមួយ ទៅកាន់ព្រៃមួយ រហូតថ្ងៃ និងយប់ទាំងអស់ ត្រាច់ទៅឥតអាឡោះអាល័យ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ នឹងលះបង់នូវភ័យគួរខ្លាច ហើយមិនមានគ្នាជាគំរប់ពីរនាក់ ដើរទៅលើជ្រោះភ្នំទាំងឡាយ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញធ្វើចិត្តឲ្យត្រង់ ដូចជាបុគ្គលដេញពិណ អាចដេញខ្សែទាំង ៧ ឲ្យជាទីរីករាយចិត្តបាន ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ នឹងកាត់នូវកាមសំយោជន៍ជាទិព្វ ទាំងជារបស់មនុស្សបាន ដូចជាជាងរថ កាលកាត់នូវស្បែកជើងដូច្នោះ។

[៦១] (អភិសម្ពុទ្ធគាថា) ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី។ ពួកស្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីសង្រ្គមល្អ មានចង្កេះរៀវ ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី។ ពួកស្រីស្នំទាំង ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រលាញ់ ផ្គងដើមដៃទួញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី។ ព្រះរាជាទ្រង់លះនូវសម្បទ បានលះបង់ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ព្រះអង្គត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ។ ព្រះរាជាទ្រង់លះបង់នូវសម្បទ បានលះបង់ពួកស្ត្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីសង្រ្គមល្អ មានចង្កេះរៀវ ត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ។ ព្រះរាជាទ្រង់លះបង់នូវសម្បទ បានលះនូវពួកស្ត្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រលាញ់ ត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ។ ព្រះរាជាទ្រង់លះបង់នូវភាជនីមាសមានទម្ងន់មួយរយបល្លៈ ប្រកបដោយស្នាមចម្លាក់មួយរយ បានកាន់យកនូវបាត្រដី ការកាន់នូវបាត្រដីនោះ ទុកជាអភិសេកទី ២។

[៦២] (ព្រះនាងសីវលីទេវី) ឃ្លាំងទាំងឡាយ គឺឃ្លាំងប្រាក់ ឃ្លាំងមាស ឃ្លាំងកែវមុក្តា ឃ្លាំងកែវពិទូរ្យ ឃ្លាំងកែវមណី ឃ្លាំងស័ង្ខ ឃ្លាំងកែវមុក្តាដ៏ច្រើន ឃ្លាំងសំពត់ ឃ្លាំងខ្លឹមចន្ទន៍ក្រហម ឃ្លាំងស្បែកខ្លាឃ្មុំ ឃ្លាំងរបស់ធ្វើពីភ្លុក ឃ្លាំងទង់ដែង និងឃ្លាំងដែកខ្មៅដ៏ច្រើន ជាឃ្លាំងដែលរាជបុរសរៀបចំដោយចំណែក ត្រូវភ្លើងឆេះ មានអណ្តាតភ្លើងស្មើគ្នា គួរខ្លាច បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យទ្រព្យរបស់ព្រះអង្គនោះវិនាស។

[៦៣] (ព្រះរាជា) កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ កាលបើក្រុងមិថិលាត្រូវភ្លើងឆេះ ភ្លើងមិនមែនឆេះនូវទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ។

[៦៤] (ព្រះនាងសីវលីទេវី) ចោរក្នុងដងព្រៃកើតឡើងហើយ បំផ្លាញដែនរបស់ព្រះអង្គ បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យដែននេះវិនាស។

[៦៥] (ព្រះរាជា) កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ កាលបើដែនត្រូវពួកចោរប្លន់ ចោរមិនបានយកទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ យើងជាអ្នកមានបីតិជាអាហារ ដូចពួក

អាភស្សរទេវតា។

[៦៦] (នារទតាបស) សំឡេងគឹកកងនៃជនច្រើននេះ តើព្រោះហេតុអ្វី ស្រ្តីនោះជាអ្វី លេងជាមួយក្នុងព្រៃ ដូចក្នុងស្រុក បពិត្រសមណៈ ខ្ញុំសួរលោកថា មហាជននុ៎ះ ប្រជុំគ្នាដើម្បីអ្វី។

[៦៧] (ព្រះរាជា) ខ្ញុំកាលលះបង់នូវមហាជន ហើយចេញទៅ បានជាមហាជនប្រជុំគ្នាក្នុងទីនេះ ខ្ញុំកន្លងនូវដែន គឺកិលេស ហើយទៅបួសដើម្បីបាននូវមោនធម៌ (ពោលគឺ ញាណរបស់អនាគារិយៈ) មុនី ខ្ញុំកាលទៅកាន់ទីច្រឡូកច្រឡំដោយសេចក្តីរីករាយទាំងឡាយ អ្នកដឹងទើបសួរឬ (ឬមិនដឹង)។

[៦៨] (នារទតាបស) ព្រះអង្គកាលទ្រទ្រង់នូវសរីរៈនេះ កុំសំគាល់ថា អញឆ្លងកិលេសហើយដូច្នេះ កម្ម (គឺកិលេស) នេះ បុគ្គលមិនគប្បីឆ្លងបានទេ ព្រោះថា សេចក្តីអន្តរាយមានច្រើន។

[៦៩] (ព្រះរាជា) ខ្ញុំណាមិនប្រាថ្នានូវកាមទាំងឡាយក្នុងមនុស្សលោក ដែលបុគ្គលឃើញហើយ មិនប្រាថ្នានូវកាមទាំងឡាយក្នុងទេវលោក ដែលបុគ្គលមិនឃើញហើយ សេចក្តីអន្តរាយដូចម្តេចហ្ន៎ នឹងមានដល់ខ្ញុំនោះ មានកិរិយាទៅយ៉ាងនេះ។

[៧០] (នារទតាបស) ដ្បិតថា សេចក្តីអន្តរាយ តាំងឡើងច្រើន គឺការដេកលក់ សេចក្តីខ្ជិល ការមិតពត់ សេចក្តីអផ្សុក ការពុលបាយ តាំងនៅក្នុងសរីរៈ រមែងកើត (ក្នុងសរីរៈវិញ)។

[៧១] (ព្រះរាជា) បពិត្រព្រាហ្មណ៍ លោកដ៏ចំរើនប្រៀនប្រដៅខ្ញុំល្អណាស់ បពិត្រព្រាហ្មណ៍ ខ្ញុំសួរលោក បពិត្រលោកនិរទុក្ខ លោកជាអ្វី។

[៧២] (នារទតាបស) ជនទាំងឡាយ ស្គាល់អាត្មាភាពដោយនាមថា នារទៈ ដោយគោត្រថា កស្សបៈ ដូច្នេះ អាត្មាភាពមកក្នុងសំណាក់ព្រះអង្គដ៏ចំរើន ដោយដឹងច្បាស់ថា សមាគមដោយសប្បុរសទាំងឡាយ ជាកិច្ចញុំាងប្រយោជន៍ឲ្យសម្រេច។ សេចក្តីត្រេកអរ (ក្នុងបព្វជ្ជា) ទាំងអស់ និងព្រហ្មវិហារ ចូរកើតដល់ព្រះអង្គនោះចុះ បរិកម្ម និងឈានណា ការខ្វះខាត (ដោយសីល និងឈាន) ណា ព្រះអង្គចូរបំពេញនូវការខ្វះខាតនោះចុះ ព្រះអង្គ (ចូរប្រកប) ដោយអធិវាសនក្ខន្តិ និងឧបសមៈ។ ព្រះអង្គចូរសោយចោលនូវសេចក្តីមើលងាយ និងសេចក្តីក្រអឺតក្រឱង ចូរធ្វើគោរពនូវកុសលកម្ម នូវវិជ្ជា និងធម៌។

[៧៣] (មិគាជិនតាបស) បពិត្រព្រះជនក ព្រះអង្គលះបង់ដំរីសេះ ពួកអ្នកនគរ និងជនបទជាច្រើន ហើយទ្រង់ព្រះផ្នួស ដល់នូវសេចក្តីត្រេកអរនឹងអម្បែង បពិត្រព្រះជនក ពួកអ្នកជនបទ មិត្រអាមាត្យ និងព្រះញាតិ បានធ្វើនូវការទ្រុស្តចំពោះព្រះអង្គខ្លះដែរឬ ព្រោះហេតុអ្វី ក៏ព្រះអង្គពេញព្រះហឫទ័យនឹងអម្បែងរបស់ព្រះអង្គនោះ។

[៧៤] (ព្រះមហាជនក) បពិត្រមិគាជិនៈ ក្នុងកាលណាមក ខ្ញុំមិនដែលផ្ចាញ់នូវញាតិណាមួយដោយអធម៌ជាដាច់ខាត ទាំងពួកញាតិក៏មិនដែលផ្ចាញ់ខ្ញុំដោយអធម៌ដែរ។

[៧៥] បពិត្រមិគាជិនៈ ខ្ញុំបានឃើញនូវប្រវេណីនៃសត្វលោក ដែលកិលេសកំពុងទំពាស៊ី ធ្វើឲ្យដូចជាភក់ បុថុជ្ជនលិចចុះហើយក្នុងកិលេសវត្ថុណា សត្វទាំងឡាយ តែងបៀតបៀនគ្នាផង តែងជាប់ក្នុងកិលេសវត្ថុនោះផង ហើយក៏ធ្វើនូវពួកបុថុជ្ជនទាំងនេះ ឲ្យជាគ្រឿងប្រៀបធៀប ទើបបួសជាភិក្ខុ។

[៧៦] (មិគាជិនតាបស) បពិត្រព្រះអង្គប្រសើរក្នុងរថ បុគ្គលមានជោគណា ជាសាស្តារបស់ព្រះអង្គ ពាក្យដ៏ពីរោះនេះ ជាពាក្យរបស់បុគ្គលណា ព្រោះថា អ្នកប្រាជ្ញទាំងឡាយ មិនរៀននូវតាបសអ្នកសម្រេចអភិញ្ញា ឬនូវព្រះបច្ចេកពុទ្ធដែលប្រកបដោយវិជ្ជា ហើយពោលនូវសមណៈថា អ្នកមានវត្តជាគ្រឿងកន្លងនូវទុក្ខទេ។

[៧៧] (ព្រះមហាជនក) បពិត្រមិគាជិនៈ ខ្ញុំមិនដែលចូលទៅគោរពសមណៈ និងព្រាហ្មណ៍ណាមួយដោយដាច់ខាត ក្នុងកាលណាម្តងឡើយ។ បពិត្រមិគាជិនៈ ខ្ញុំកាលទៅដោយអានុភាពដ៏ធំ រុងរឿងដោយសិរី កាលចម្រៀងដែលបុគ្គលកំពុងច្រៀង កាលតន្ត្រីមានសំឡេងដ៏ពីរោះ ដែលបុគ្គលកំពុងប្រគំ បានឃើញស្វាយមានផ្លែខាងក្រៅកំពែង ដែលពួកមនុស្សអ្នកត្រូវការផ្លែ បេះជិតឧទ្យានដែលគឹកកងដោយការប្រគំតន្ត្រី ជាឧទ្យានប្រកបដោយសូរប្រគំដ៏ពីរោះ បពិត្រមិគាជិនៈ ខ្ញុំនោះ បានលះបង់សិរីនោះ ហើយចុះ (អំពីដំរី) ចូលទៅកាន់គល់ស្វាយដែលមានផ្លែ និងមិនមានផ្លែ បានឃើញស្វាយមានផ្លែ ដែលបុគ្គលបៀតបៀនហើយ កំចាត់ហើយ ធ្វើមិនឲ្យមានស្លឹក និងស្វាយ ១ ដើមក្រៅនេះ មានពន្លឺខៀវ ជាទីរីករាយនៃចិត្ត សត្រូវទាំងឡាយ អាចសម្លាប់យើងដែលជាឥស្សរៈ មានបន្លាច្រើនដោយពិត ដូចដើមស្វាយដែលមានផ្លែ ដែលបុគ្គលសម្លាប់ហើយ ខ្លាដំបងត្រូវគេសម្លាប់ព្រោះស្បែក ដំរីត្រូវគេសម្លាប់ព្រោះភ្លុក បុគ្គលអ្នកមានទ្រព្យ ត្រូវគេសម្លាប់ព្រោះទ្រព្យ តើនរណា នឹងសម្លាប់បុគ្គលអ្នកមិនមានផ្ទះ មិនមានសន្ថវៈ ដើមស្វាយមានផ្លែ និងមិនមានផ្លែ ទាំងពីរនោះ ជាសាស្តារបស់ខ្ញុំ។

[៧៨] (នាងសីវលី) ជនទាំងពួង គឺសេនាដំរី ពលសេះ ពលរថ ពលថ្មើរជើង បានឮថា ព្រះរាជាទ្រង់ផ្នួសហើយ ក៏តក់ស្លុត សូមព្រះអង្គលួងលោមនូវប្រជុំជន ហើយតាំងទុកនូវការរក្សា រួចតាំងព្រះរាជឱរសក្នុងរាជសម្បត្តិ ហើយសឹមទ្រង់ព្រះផ្នួស ក្នុងកាលជាខាងក្រោយចុះ។

[៧៩] (ព្រះមហាជនក) ពួកអ្នកជនបទ មិត្រ អាមាត្យ និងញាតិទាំងឡាយ ដែលយើងលះបង់ហើយ កូនរបស់អ្នកដែនវិទេហៈ ឈ្មោះទីឃាវុកុមារ អ្នកញុំាងដែនឲ្យចំរើន ម្នាលបជាបតិ កូននោះ នឹងសោយរាជ្យក្នុងក្រុងមិថិលាចុះ។

[៨០] នាងចូរមកនេះ ពាក្យណាដែលអាត្មាពេញចិត្ត អាត្មានឹងប្រាប់នូវពាក្យនោះ នាងនឹងទៅកាន់ទុគ្គតិ ដោយកាយ វាចា ចិត្តណា នាងឯងកាលសោយរាជ្យ (ឈ្មោះថាធ្វើ) នូវបាបទុច្ចរិតដ៏ច្រើន ដោយកាយ វាចា ចិត្តនោះ អាត្មានឹងញុំាងអត្តភាព ឲ្យប្រព្រឹត្តទៅដោយដុំបាយ ដែលបុគ្គលដទៃឲ្យហើយ ដែលបុគ្គលដទៃសម្រេចហើយ (នេះ) ជាបវេណីរបស់អ្នកប្រាជ្ញ។

[៨១] (នាងសីវលី) បុគ្គលណា មិនបរិភោគអាហារក្នុងកាលនៃភត្តជាគំរប់ ៤ បុគ្គនោះគប្បីស្លាប់ដោយសេចក្តីស្រេកឃ្លាន ដូចបុគ្គលដល់នូវសេចក្តីស្លាប់ដ៏ពិត មានសភាពជាកុលបុត្រ មិនគប្បីបរិភោគដុំបាយ ដែលប្រឡាក់ដោយធូលីមិនស្អាតទេ ឬការបរិភោគនោះ មិនល្អទេ មិនប្រសើរទេ បពិត្រមហាជនក ព្រះអង្គសោយនូវដុំបាយដែលសល់អំពីឆ្កែ។

[៨២] (ព្រះរាជា) ម្នាលសីវលី វត្ថុណាដែលគ្រហស្ថ ឬសុនខលះបង់ហើយ វត្ថុនោះ មិនមែនជាអាត្មាមិនគួរឆាន់ទេ ភោគៈទាំងឡាយណានីមួយក្នុងលោកនេះ ដែលបានដោយធម៌ ភោគៈទាំងអស់នោះ លោកពោលថា ជាអាហារមិនមានទោស។

[៨៣] (ព្រះរាជា) ម្នាលនាងកុមារិកា ជាក្មេងដេកជិតមាតានៅឡើយ មានគ្រឿងប្រដាប់មិនឃ្លាតអំពីខ្លួនជានិច្ច ដៃម្ខាងរបស់នាងលាន់ឮសំឡេង ដៃម្ខាងមិនលាន់ឮសំឡេង តើព្រោះហេតុអ្វី។

[៨៤] (នាងកុមារិកា) បពិត្រសមណៈ កងពីរដែលពាក់នឹងដៃរបស់ខ្ញុំនេះ ខ្ទប់គ្នាហើយ សំឡេងក៏កើតឡើង នោះជាគតិនៃកងទាំងពីរ បពិត្រសមណៈ កង ១ ដែលពាក់នឹងដៃរបស់ខ្ញុំនេះ កងនោះ មិនមានកងឯទៀតជាគំរប់ពីរ ទើបមិនលាន់ឮសំឡេង ដូចអរិយបុគ្គល ជាអ្នកស្ងប់ស្ងៀម ឯបុគ្គលមានគ្នាជាគំរប់ពីរនាក់ រមែងដល់នូវការជជែកគ្នា បុគ្គល ១ នាក់ នឹងជជែកជាមួយនឹងបុគ្គលណាកើត ព្រះអង្គនោះ ជាអ្នកប្រាថ្នានូវឋានសួគ៌ សូមទ្រង់ពេញចិត្តនឹងភាពនៃបុគ្គលម្នាក់ឯងចុះ។

[៨៥] (ព្រះរាជា) ម្នាលនាងសីវលី នាងឮគាថាដែលនាងកុមារិកាពោលហើយឬទេ នាងកុមារិកាតិះដៀលនូវអាត្មា ដូចជាអ្នកបំរើ នោះឯងជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចំរើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវតែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាងចូរកាន់ផ្លូវ ១ អាត្មានឹងកាន់ផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថាជាប្រពន្ធទៀតដែរ។

(អភិសម្ពុទ្ធគាថា) ព្រះរាជា និងនាងសីវលី កាលពោលនូវពាក្យនេះហើយ ក៏ចូលទៅកាន់ថូណនគរ។ កាលជិតវេលាភត្ត ព្រះរាជា (ក៏ឈរ) ជិតទ្វារនៃជាងព្រួញ ជាងព្រួញនោះធ្មេចភ្នែកម្ខាង សំឡឹងមើលដងព្រួញវៀចមួយ ដែលធ្វើឲ្យត្រង់ដោយភ្នែកម្ខាង ជិតក្លោងទ្វារនោះ។

[៨៦] (ព្រះរាជា) ម្នាលជាងព្រួញ អ្នកចូរស្តាប់ពាក្យអាត្មា អ្នកធ្មេចភ្នែកម្ខាង សំឡឹងមើលដងព្រួញវៀច អ្នកមើលយ៉ាងនេះស្រួលឬ។

[៨៧] (ជាងព្រួញ) បពិត្រសមណៈ ទីប្រាកដដូចជាទូលាយដោយភ្នែកពីរ កិច្ចដោយភាវៈនៃព្រួញត្រង់ រមែងមិនសម្រេច ព្រោះមិនឃើញនូវទីវៀចខាងមុខ។ កាលបុគ្គលធ្មេចភ្នែកម្ខាង សំឡឹងមើលទីវៀចដោយភ្នែកម្ខាង កិច្ចដោយភាពនៃព្រួញត្រង់ រមែងសម្រេច ព្រោះឃើញទីវៀចខាងមុខ។ បុគ្គលជាគំរប់ពីរ រមែងដល់នូវការជជែកគ្នា បុគ្គលម្នាក់ឯង នឹងជជែកគ្នាជាមួយនឹងអ្នកណាកើត កាលព្រះអង្គនោះ ប្រាថ្នានូវឋានសួគ៌ សូមពេញព្រះទ័យនឹងភាពនៃបុគ្គលម្នាក់ឯងចុះ។

[៨៨] (ព្រះរាជា...) នៃនាងសីវលី នាងឮគាថាដែលជាងព្រួញពោលហើយឬទេ ជាងព្រួញតិះដៀលអាត្មា ដូចជាអ្នកបំរើ នោះជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចំរើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវតែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាងចូរកាន់យកផ្លូវ ១ អាត្មានឹងកាន់យកផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថាជាភរិយារបស់អាត្មាដែរ ម្នាលនាងសីវលី នាងចូរនៅម្នាក់ឯងចុះ ដូចស្មៅឃាប្លង់ដែលអាត្មាដកហើយ។

ចប់ មហាជនកជាតក ទី២។

## សុវណ្ណសាមជាតក ទី៣

CS sut.kn.jat.540 | ភាគទី ៦២

### (៥៤០. សុវណ្ណសាមជាតកំ (៣))

[៨៩] (សុវណ្ណសាមបណ្ឌិតសួរថា) នរណាហ្ន៎ បាញ់ខ្ញុំជាអ្នកដងទឹក ភ្លេចស្មារតី[41] ដោយព្រួញ ជនណាជាក្សត្រ ឬជាព្រាហ្មណ៍ ឬជាវេស្សៈ បាញ់ខ្ញុំហើយពួន។ សាច់ទាំងឡាយរបស់ខ្ញុំ មិនមែនជារបស់គួរទំពាស៊ីទេ សេចក្តីត្រូវការដោយស្បែក មិនមានទេ កាលបើដូច្នេះ តើអ្នកសំគាល់នូវខ្ញុំថាគួរបាញ់ ដោយហេតុដូចម្តេច។ អ្នកជាអ្វី ជាបុត្ររបស់អ្នកណា យើងស្គាល់អ្នកដូចម្តេចបាន ម្នាលសំឡាញ់ អ្នក ខ្ញុំសួរហើយ ចូរប្រាប់ ម្តេចក៏បានជាអ្នកបាញ់ខ្ញុំហើយពួន។

[៩០] (ព្រះបាទបិលយក្ខត្រាស់ថា) ខ្ញុំជាព្រះរាជារបស់ពួកអ្នកកាសី គេស្គាល់ខ្ញុំថា ឈ្មោះបិលយក្ខ ខ្ញុំលះបង់នូវដែនមកត្រាច់ស្វែងរកម្រឹគ ព្រោះល្មោភ (ក្នុងសាច់)។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ ជាអ្នកមានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំបាន[42] សូម្បីដំរី តែមកត្រង់មុខព្រួញរបស់ខ្ញុំហើយ មិនគប្បីរួចទេ។ ចុះអ្នកជាអ្វី ជាបុត្តរបស់អ្នកណា ដូចម្តេចទើបយើងស្គាល់អ្នកបាន សូមអ្នកប្រាប់នូវនាម និងគោត្តរបស់បិតាផង របស់ខ្លួនផង។

[៩១] (ព្រះមហាសត្វ...) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំ (ជាកូនរបស់ឥសី) ជាបុត្តរបស់នាយនេសាទ ពួកញាតិហៅទូលបង្គំជាខ្ញុំកំពុងរស់នៅថាសាមៈ ថ្ងៃនេះ ទូលបង្គំជាខ្ញុំនោះ ដល់ (មាត់មច្ចុរាជ) ហើយដេកនៅយ៉ាងនេះ។ ខ្ញុំដែលព្រះអង្គបាញ់ហើយ ហាក់ដូចម្រឹគ ដែលព្រានព្រៃបាញ់ហើយ ដោយព្រួញធំប្រកបដោយថ្នាំពិសដូច្នោះ បពិត្រព្រះរាជា សូមទ្រង់ទតចុះ ទូលបង្គំជាខ្ញុំដេកត្រាំនៅក្នុងឈាមរបស់ខ្លួន។ សូមទ្រង់ទតព្រួញដែលមុតធ្លាយទៅខាងឆ្វេង ទូលបង្គំជាខ្ញុំខ្ពុលឈាម ទូលបង្គំជាខ្ញុំចាប់ពើតណាស់ បានជាសួរព្រះអង្គរឿយៗ ម្តេចក៏ទ្រង់បាញ់ទូលបង្គំជាខ្ញុំហើយពួន។ ខ្លាដំបង គេសម្លាប់ព្រោះតែស្បែក ដំរីគេសម្លាប់ព្រោះភ្លុកទាំងឡាយ កាលបើដូច្នោះ តើព្រះអង្គសំគាល់នូវទូលបង្គំជាខ្ញុំថាគួរបាញ់ ដោយហេតុដូចម្តេច។

[៩២] (ព្រះបាទបិលយក្ខនិយាយកុហកថា) ម្រឹគមកប្រាកដចំមុខព្រួញរបស់ខ្ញុំហើយ ឃើញអ្នកហើយក៏ផ្អើលទៅ ម្នាលសាមៈ ព្រោះហេតុនោះ បានជាខ្ញុំមានសេចក្តីក្រោធគ្របសង្កត់។

[៩៣] (ព្រះមហាសត្វ...) តាំងពីកាលដែលខ្ញុំរឭកឃើញនូវខ្លួន តាំងពីកាលដែលខ្ញុំដល់នូវភាពជាអ្នកដឹងក្តី ម្រឹគទាំងឡាយសូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល (ឃើញ) ទូលបង្គំជាខ្ញុំ ហើយតក់ស្លុតទេ។ តាំងពីកាលដែលខ្ញុំស្លៀកដណ្តប់សំពត់សំបកឈើ តាំងពីកាលដែលខ្ញុំដល់នូវវ័យដ៏ចំរើន ម្រឹគទាំងឡាយ សូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល (ឃើញ) នូវខ្ញុំ ហើយតក់ស្លុតទេ។ បពិត្រព្រះរាជា កិន្នរទាំងឡាយ ដែលជាសត្វខ្លាច (នៅ) នាភ្នំគន្ធមាទន៍ (មិនដែលឃើញខ្ញុំ ហើយតក់ស្លុតទេ) យើងទាំងឡាយ តែងរីករាយជាមួយគ្នាទៅកាន់ភ្នំ និងព្រៃ កាលបើដូច្នោះ ម្រឹគទាំងឡាយ (ឃើញ) នូវទូលបង្គំជាខ្ញុំ ហើយតក់ស្លុត ដោយហេតុដូចម្តេច។

[៩៤] (ព្រះបាទបិលយក្ខ) ម្នាលសាមៈ ម្រឹគមិនមែនផ្អើលនឹងអ្នកទេ ខ្ញុំនឹងនិយាយកុហកធ្វើអ្វី ខ្ញុំមានសេចក្តីក្រោធ និងសេចក្តីលោភគ្របសង្កត់ហើយ ទើបបាញ់អ្នកនឹងព្រួញនោះ។ ម្នាលសាមៈ អ្នកមកអំពីប្រទេសណា ឬនរណាប្រើមកថា អ្នកដងទឹក ចូរទៅកាន់ស្ទឹងដូច្នេះ បានជាអ្នកមកកាន់ស្ទឹង មិគសម្មតៈ (នេះ)។

[៩៥] (ព្រះមហាសត្វ) មាតាបិតារបស់ទូលបង្គំជាខ្ញុំខ្វាក់ ទូលបង្គំជាខ្ញុំតែងចិញ្ចឹមគាត់ក្នុងព្រៃធំ ទូលបង្គំជាខ្ញុំជាអ្នកដងទឹកដើម្បីអ្នកមានគុណទាំងឡាយ បានជាមកកាន់ស្ទឹងមិគសម្មតៈ (នេះ)។

[៩៦] (ព្រះមហាសត្វពិលាប) មាតាបិតាទាំងឡាយនោះ មានត្រឹមតែភោជន កាលបើយ៉ាងនេះ (ជីវិតនឹងប្រព្រឹត្តទៅ) ត្រឹម ៦ ថ្ងៃ ព្រោះ

គាត់ខ្វាក់ មុខជានឹងស្លាប់ដោយឥតទឹកពុំខាន។ ទុក្ខនេះមិនមែនជាទុក្ខរបស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខនេះ បុរសត្រូវតែបាន ត្រង់ដែលទូលបង្គំជាខ្ញុំ ខានឃើញមាតាដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែងរបស់ទូលបង្គំជាខ្ញុំ ជាងទុក្ខនេះ (ទៅទៀត)។ ទុក្ខនេះមិនមែនជាទុក្ខរបស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខនេះបុរសត្រូវតែបាន ត្រង់ដែលទូលបង្គំជាខ្ញុំ ខានឃើញបិតាដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែងរបស់ទូលបង្គំជាខ្ញុំ ជាងទុក្ខនេះ (ទៅទៀត)។ ឱម្ល៉េះ សមមាតានៅកំព្រាទួញយំ ទាំងអឌ្ឍរាត្រ និងទីបំផុតនៃរាត្រីអស់កាលជាយូរអង្វែង មុខជានឹងរីងស្ងួតទៅ ដូចជាស្ទឹង (ក្នុងគិម្ហរដូវ) ពុំខាន។ ឱម្ល៉េះ សមបិតានៅកំព្រា ទួញយំទាំងអឌ្ឍរាត្រ និងទីបំផុតនៃរាត្រី អស់កាលជាយូរអង្វែង មុខជានឹងរីងស្ងួត ដូចជាស្ទឹងពុំខាន។ បពិត្រព្រះរាជា មួយវិញទៀត (ខ្ញុំតែងភ្ញាក់ក្នុងមួយយប់ពីរបីដង) ដើម្បីបំរើបាទាដោយព្យាយាម នឹងដើម្បីគក់ច្របាច់ ម្ល៉េះសមគាត់នឹងដើរចច្រប់ក្នុងព្រៃធំ ដង្ហោយហៅថា អើបាសាម: ដូច្នេះពុំខានឡើយ។ បើទូលបង្គំជាខ្ញុំ ខានឃើញជនខ្វាក់ទាំងពីរនាក់ដោយហេតុណា ហេតុនោះឯង ទុក្ខជាសរទីពីរ ដែលញ៉ាំងហឫទ័យរបស់ទូលបង្គំជាខ្ញុំឲ្យញាប់ញ័រ មុខជាជីវិតទូលបង្គំជាខ្ញុំនឹងវិនាសពុំខាន។

[៩៧] (ព្រះបាទបិលយក្ខ) ម្នាលសាម: ជាអ្នកមានរូបល្អគួរឲ្យគយគន់ អ្នកកុំទួញយំខ្លាំងឡើយ ខ្ញុំនឹងជាអ្នកធ្វើការងារចិញ្ចឹមនូវជនទាំងឡាយនោះក្នុងព្រៃធំ។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូស្រាប់ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំ ខ្ញុំជាអ្នកធ្វើការងារចិញ្ចឹមនូវជនទាំងឡាយនោះក្នុងព្រៃធំ។ ខ្ញុំនឹងជាអ្នកធ្វើការងារ ស្វែងរកអំពារនៃម្រឹគ និងមើមឈើ ផ្លែឈើទាំងឡាយក្នុងព្រៃ ហើយនឹងចិញ្ចឹមនូវជនទាំងឡាយនោះក្នុងព្រៃធំ។ ម្នាលសាម: មាតាបិតារបស់អ្នក នៅក្នុងព្រៃណា ព្រៃនោះដូចម្តេច អ្នកបានចិញ្ចឹមនូវមាតាបិតាយ៉ាងណា ខ្ញុំក៏នឹងចិញ្ចឹមនូវគាត់យ៉ាងនោះដែរ។

[៩៨] (ព្រះមហាសត្វ) បពិត្រព្រះរាជា ផ្លូវចុះតែជើងម្នាក់នេះ នៅខាងក្បាលដំណេកទូលបង្គំជាខ្ញុំ ព្រះអង្គយាងទៅអំពីទីនេះ តែកន្លះយោស: (នឹងឃើញ) ខ្ទមជាទីនៅរបស់មាតាបិតាទូលបង្គំជាខ្ញុំនោះ ព្រះអង្គយាងទៅអំពីទីនេះ សូមទ្រង់ចិញ្ចឹមនូវគាត់ក្នុងទីនោះផង។

[៩៩] បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះរាជា ទ្រង់មានសេចក្តីចំរើនក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះអង្គ មាតាបិតាទាំងឡាយរបស់ទូលបង្គំជាខ្ញុំ ជាមនុស្សខ្វាក់ សូមទ្រង់ចិញ្ចឹមនូវគាត់ក្នុងព្រៃធំឲ្យទាន។ ទូលបង្គំជាខ្ញុំ សូមផ្គងអញ្ជលីចំពោះព្រះអង្គ បពិត្រព្រះរាជាជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះអង្គ ទូលបង្គំជាខ្ញុំ សូមផ្តាំទុក សូមទ្រង់ជំរាបនូវការថ្វាយបង្គំចំពោះមាតាបិតារបស់ទូលបង្គំជាខ្ញុំផង។

[១០០] (អភិសម្ពុទ្ធគាថា) សាម: កម្លោះអ្នកមានរូបល្អ គួរពិតពិលរមិលមើលនោះ លុះពោលនូវពាក្យនេះរួចហើយ ក៏ជ្រប់សន្លប់ដោយកម្លាំងពិស។

[១០១] ព្រះរាជាអង្គនោះ ទ្រង់ព្រះកន្សែងរៀបរាប់នូវពាក្យដែលប្រកបដោយសេចក្តីករុណាមានប្រមាណច្រើនថា អាត្មាអញបានយល់ថា អញមិនចាស់ មិនស្លាប់ ថ្ងៃនេះ អញឃើញនូវសុវណ្ណសាមនេះ ធ្វើកាលកិរិយាហើយទើបដឹងនូវហេតុនោះ ពីដើមមិនដឹងជាការមកនៃសេចក្តីស្លាប់ មិនមែនមិនមានដូច្នេះ។ សាម:ដែលដោតដោយថ្នាំពិស កំពុងចរចាជាមួយនឹងអញ (ក្នុងកាលអម្បាញ់មិញនេះ) ឥឡូវនេះគាត់លែងនិយាយ ពាក្យតិចតួចក្នុងកាលប្រព្រឹត្តទៅយ៉ាងនេះ ក្នុងថ្ងៃនេះ អាត្មាអញ មុខជានឹងទៅកាន់នរកពុំខាន អាត្មាអញឥតមានសេចក្តីសង្ស័យក្នុងដំណើរនេះទេ។ ព្រោះថា អំពើបាបដែលអាត្មាអញធ្វើទុកហើយក្នុងគ្រានោះ នឹងជាទោសឲ្យផលលាមកអស់កាលជាអង្វែង (បើ) ក្នុងស្រុក គង់មានពួកអ្នកតិះដៀលអញនោះថា ព្រះអង្គជាអ្នកធ្វើនូវអំពើអាក្រក់ដូច្នេះ តែក្នុងអរញ្ញប្រទេសដែលឥតមនុស្ស តើនរណាតិះដៀលអញបាន។ បើក្នុងស្រុក ពួកមាណពប្រជុំគ្នា ហើយចោទប្រកាន់នូវអំពើទាំងឡាយ (របស់អញ) តែក្នុងអរញ្ញប្រទេសដែលឥតមនុស្ស តើនរណានឹងចោទប្រកាន់អញ។

[១០២] ទេវតានោះ[43] បាត់អំពីភ្នំគន្ធមាទន៍ ហើយពោលនូវគាថាទាំងឡាយនេះ ដោយអនុគ្រោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គទ្រង់បានធ្វើនូវបាបជាទម្ងន់ ដែលជាអំពើអាក្រក់ ជនទាំងបីនាក់ គឺមាតាបិតា និងបុត្ត ជាអ្នកមិនប្រទូស្ត ទ្រង់បានសម្លាប់ហើយដោយព្រួញតែមួយ។ សូមទ្រង់មក សុគតិភពនឹងគប្បីមានដល់ព្រះអង្គ យ៉ាងណា ខ្ញុំនឹងពន្យល់ព្រះអង្គយ៉ាងនោះ សូមទ្រង់ចិញ្ចឹមនូវជនខ្វាក់ទាំងពីរនាក់នោះឯង ដោយធម៌ ខ្ញុំយល់ថា សុគតិគប្បីមាន។

[១០៣] ព្រះរាជាអង្គនោះ ទ្រង់ពិលាបរៀបរាប់ ប្រកបដោយសេចក្តីករុណាមានប្រមាណច្រើន ហើយកណ្តៀតក្អមទឹកយាងឆ្ពោះទៅទិសទក្សិណ។

[១០៤] (ទុកូលបណ្ឌិតសួរ...) សូរជើងនរណាន៉ុះហ្ន៎ ដែលដើរមកនេះ ពិតជាសូរជើងមនុស្ស តែសូរជើងន៉ុះ មិនមែនជាសូរជើងសាម:ទេ ម្នាលអ្នកនិរទុក្ខ អ្នកជាអ្វីហ្នឹង។ ដ្បិតសាម: តែងដើរថ្នមៗ លើកដាក់ជើងស្រាលៗ សូរជើងន៉ុះ មិនមែនជាសូរជើងសាម:ទេ ម្នាលអ្នកនិរទុក្ខ អ្នកជាអ្វីហ្នឹង។

[១០៥] (ព្រះបាទបិលយក្ខ...) ខ្ញុំជាព្រះរាជារបស់ពួកអ្នកដែនកាសី គេស្គាល់ខ្ញុំថា បិលយក្ខ ខ្ញុំលះបង់នូវដែន ត្រាច់ស្វែងរកម្រឹគព្រោះលោភ (សាច់)។ មួយទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថាជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំបាន សូម្បីដំរីមកចំមុខព្រួញរបស់ខ្ញុំហើយ មិនគប្បីរួចទេ។

[១០៦] (ទុកូលបណ្ឌិត...) បពិត្រមហារាជ ព្រះរាជដំណើរមករបស់ព្រះអង្គល្អហើយ ព្រះដំណើរមករបស់ព្រះអង្គមិនអាក្រក់ទេ ព្រះអង្គជាធំ ទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូលចុះ។ បពិត្រព្រះរាជា ផលាផល គឺផ្លែទន្លាប់ ម:ប៉ែន ស្រគំ សឹងមានរសផ្អែមដូចទឹកឃ្មុំ អាត្មាភាព ប្រមូលមកទុកក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផលមានរសឆ្ងាញ់ៗ។ នេះទឹកត្រជាក់សម្រាប់សោយ ដែលដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ បើទ្រង់សព្វព្រះទ័យ ទ្រង់ (ដង) អំពីទីនេះសោយចុះ។

[១០៧] (ព្រះរាជា...) អ្នកទាំងពីរជាមនុស្សខ្វាក់ មិនអាចឃើញ (អ្វី) ក្នុងព្រៃទេ ចុះនរណាប្រមូលនូវផលាផលមកជូនអ្នក អាហារដែល (បាន) ដោយប្រពៃនេះ ប្រាកដដល់ខ្ញុំ ដូចជាអាហាររបស់មនុស្សមិនខ្វាក់។

[១០៨] (ទុកូលបណ្ឌិត...) សាម:កំឡោះនៅក្មេង មិនខ្ពស់ មិនទាបពេក ជាមនុស្សមានរូបល្អគួរគយគន់ មានសក់វែងខ្មៅ ទាំងមានចុងទន់ល្វន់។ សាម:នោះឯង តែងស្វែងរកផលាផល ជាអ្នកដងទឹក បានកាន់យកក្អមទឹកអំពីទីនេះទៅកាន់ស្ទឹង ប្រហែលជិតមកដល់ហើយ។

[១០៩] (ព្រះបាទបិលយក្ខ...) សាម:ជាអ្នកបំរើអ្នក អ្នកនិយាយសំដៅកុមារឈ្មោះសាម:ណា ដែលមានរូបគួរគយគន់ សាម:នោះខ្ញុំសម្លាប់ហើយ។ សាម:ដែលមានសក់វែងពណ៌ខ្មៅ ចុងទន់ល្វន់ (ឥឡូវនេះ) ខ្ញុំសម្លាប់ដួលដេកលើសក់ទាំងនោះ ប្រឡាក់ហើយដោយឈាម។

[១១០] (នាងបារិកា) បពិត្រទុកូល អ្នកប្រឹក្សាជាមួយនរណា ដែលបាននិយាយថា ខ្ញុំសម្លាប់សាមៈហើយ បេះដូងខ្ញុំញ័រចំប្រប់ ព្រោះឮថា សាមៈស្លាប់ហើយ។ ហ្ឫទ័យខ្ញុំញាប់ញ័រ ហាក់ដូចត្រួយពោធិបាយខ្ចី ដែលមានខ្យល់ប៉ះទង្គិច ព្រោះឮថា សាមៈស្លាប់ហើយ។

[១១១] (ទុកូលបណ្ឌិត...) ម្នាលនាងបារិកា នេះជាព្រះរាជា ជាធំក្នុងដែនកាសី ព្រះអង្គបាញ់សាមៈដោយព្រួញ ក្បែរស្ទឹងមិគសម្មតៈ ដោយសេចក្ដីក្រោធ យើងកុំចង់ឲ្យមានបាបដល់ព្រះអង្គឡើយ។

[១១២] (នាងបារិកា..) បុត្រដែលចិញ្ចឹមយើងងងឹតងងល់ក្នុងព្រៃ ជាបុត្តជាទីស្រឡាញ់ យើងរកបានដោយកម្រ ចិត្តមិនគប្បីរំជួលក្នុងបុរសអ្នកសម្លាប់កូនប្រុសតែមួយនោះ ដូចម្ដេចបាន។

[១១៣] (ទុកូលបណ្ឌិត...) បុត្តដែលចិញ្ចឹមយើងងងឹតងងល់ក្នុងព្រៃ ជាបុត្តជាទីស្រឡាញ់ យើងរកបានដោយកម្រ បណ្ឌិតទាំងឡាយ សរសើរសេចក្ដីមិនក្រោធ ចំពោះបុរសអ្នកសម្លាប់នូវបុត្តតែមួយនោះ។

[១១៤] (ព្រះបាទបិលយក្ខ...) អ្នកទាំងពីរ កុំគប្បីខ្សឹកខ្សួលខ្លាំងចំពោះខ្ញុំ អ្នកពោលថា សាមៈ ខ្ញុំសម្លាប់ហើយ ខ្ញុំនឹងជាអ្នកធ្វើការងារចិញ្ចឹម (អ្នកទាំងពីរ) ក្នុងព្រៃធំ។ ព្រោះខ្ញុំជាអ្នកឈ្លាវៃក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំ ខ្ញុំនឹងធ្វើការងារចិញ្ចឹម (អ្នក) ក្នុងព្រៃធំ។ ខ្ញុំនឹងធ្វើការងារស្វែងរកអំពារម្រឹគទាំងឡាយ ទាំងមើមឈើ ផ្លែឈើ ហើយចិញ្ចឹម (អ្នក) ក្នុងព្រៃធំ។

[១១៥] (ជនទាំងពីរ...) បពិត្រមហារាជ នេះមិនមែនជាទំនៀមទេ កិរិយាធ្វើនូវអំពើ (របស់ព្រះអង្គ) នេះ មិនសមគួរដល់យើងឡើយ ព្រះអង្គជាព្រះរាជារបស់យើង ៗ សូមថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ។

[១១៦] (ព្រះរាជា...) បពិត្រអ្នកនេសាទ អ្នកពោលនូវធម៌ អ្នកធ្វើនូវសេចក្ដីគោរព (ចំពោះខ្ញុំ) អ្នកទុកជាបិតារបស់ខ្ញុំ បពិត្រនាងបារិកា នាងទុកជាមាតារបស់ខ្ញុំ។

[១១៧] (ជនទាំងពីរ...) បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គ ទ្រង់ចំរើនក្នុងដែនកាសី ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ ទូលបង្គំទាំងឡាយ សូមប្រណម្យអញ្ជលីចំពោះព្រះអង្គ សូមព្រះអង្គនាំទូលបង្គំទៅដល់សាមៈ។ ទូលបង្គំទាំងឡាយ នឹងច្របាច់ជើង ស្នាបមុខល្អគួរមើលរបស់សាមៈនោះ ត្រៀមរង់ចាំនូវសេចក្ដីស្លាប់ប៉ុណ្ណោះ។

[១១៨] (ព្រះបាទបិលយក្ខ...) សាមៈ ដែលស្លាប់ហើយ ដួលដេកដូចជាព្រះចន្ទធ្លាក់មកលើប្រថពីក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រឹង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស។ សាមៈ ដែលស្លាប់ហើយ ដួលដេកដូចជាព្រះអាទិត្យធ្លាក់មកលើប្រថពីក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រឹង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស។ សាមៈដែលស្លាប់ហើយ ដួលដេកប្រឡាក់ប្រឡូសដោយអាចម៍ដីនៅក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រឹង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស។ សាមៈ ដែលស្លាប់ហើយ ដួលដេកនៅក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រឹង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស (ព្រោះហេតុនោះ) អ្នកទាំងឡាយ ចូរនៅតែក្នុងអាស្រមនេះហើយ។

[១១៩] (ជនទាំងពីរ...) បើទុកណាជាទីនោះ (មានម្រឹគសាហាវ) រយពាន់ ម៉ឺនក្ដី ទូលបង្គំទាំងពីរនាក់ ឥតមានសេចក្ដីភិតភ័យតិចតួច ព្រោះសត្វសាហាវទាំងឡាយក្នុងព្រៃទេ។

[១២០] (អភិសម្ពុទ្ធគាថា...) គ្រានោះ ព្រះរាជា ជាធំក្នុងដែនកាសី នាំជនខ្វាក់ (ទាំងពីរ) ដឹកដៃទៅក្នុងព្រៃធំ ត្រង់កន្លែងដែលសាមៈស្លាប់។

[១២១] មាតាបិតាឃើញនូវសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ហាក់ដូចព្រះចន្ទដែលធ្លាក់មកលើប្រថពី។ ឃើញនូវសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ដូចព្រះអាទិត្យដែលធ្លាក់មកលើប្រថពី ឃើញនូវសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ក៏យំរៀបរាប់គួរឲ្យអាណិត។ ឃើញសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ហើយផ្គងដើមដៃ យំទន្ទឹះខ្សឹកខ្សួលថា ហៃបាដ៏ចំរើន (ការស្លាប់នេះ) មានសភាពមិនគួរទេ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាឯងជាមនុស្សស្រវឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាជាមនុស្សភ្លើតភ្លើនខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឱបាសាមៈ អ្នកមានរូបល្អ គួរឲ្យក្រឡេកមើល បាឯងខឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាឯងដេកលក់ស៊ប់ បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ បាឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាជាបុគ្គលតូចចិត្តខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ បាឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឥឡូវនេះ នរណា នឹងរៀបចំជដា ដ៏សៅហ្មងប្រឡាក់ប្រឡូសដោយអាចម៍ដី ព្រោះសាមៈ ជាអ្នកបំរើយើងងងឹតងងល់នេះ ធ្វើមរណកាលហើយ។ នរណា នឹងកាន់អំបោសបោសអាស្រម ដើម្បីយើង ព្រោះសាមៈ ជាអ្នកបំរើយើងងងឹតងងល់នេះ ធ្វើមរណកាលហើយ។ ឥឡូវនេះ នរណានឹងផូត (យើង) ដោយទឹកត្រជាក់ ទឹកក្ដៅ ព្រោះសាមៈ ជាអ្នកបំរើយើងងងឹតងងល់នេះ ធ្វើមរណកាលហើយ។ ឥឡូវនេះ នរណានឹងឲ្យយើងបរិភោគមើមឈើ ផ្លែឈើ ព្រោះសាមៈ ជាអ្នកបំរើ យើងងងឹតងងុលនេះ ធ្វើមរណកាលហើយ។

[១២២] មាតាឃើញសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ត្រូវសេចក្ដីសោកព្រោះកូន បៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូម្បីឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូម្បីឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកពោលនូវពាក្យសត្យដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាអ្នកបំរើមាតា នឹងបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលបិតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ។

[១២៣] បិតាឃើញសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ត្រូវសេចក្ដីសោកព្រោះកូនបៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកពោលនូវពាក្យសត្យ ដោយពាក្យសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈ

ន្នុះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកចិញ្ចឹមមាតា និងបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាបុគ្គលជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលមាតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ។

[១២៤] ទេវតានោះ បាត់អំពីភ្នំគន្ធមាទន៍ បានពោលនូវពាក្យសច្ចៈនេះ ដោយសេចក្តីអនុគ្រោះសាមៈថា ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍ អស់កាលជាយូរអង្វែងហើយ ឥតមាននរណាដទៃ ដែលជាទីស្រលាញ់ ដោយវិសេសរបស់ខ្ញុំជាងសាមៈទេ ដោយការពោលសច្ចនុ៎ះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ។ នៅភ្នំគន្ធមាទន៍ សព្វព្រៃព្រឹក្សាទាំងឡាយ សុទ្ធសឹងមានក្លិនក្រអូប ដោយការពោលសច្ចៈនេះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ។ កាលបើជនទាំងនោះ កំពុងចរចារៀបរាប់នូវពាក្យប្រកបដោយសេចក្តីករុណា មានប្រមាណច្រើន សាមៈ ជាមនុស្សកំឡោះ មានរូបល្អគួរឲ្យរមិលមើល ក៏ក្រោកឡើងភ្លាម។

[១២៥] (មហាសត្វ...) ខ្ញុំឈ្មោះសាមៈ សេចក្តីបំរើន ចូរមានដល់លោកទាំងឡាយ ខ្ញុំក្រោកឡើងដោយសួស្តីហើយ សូមលោកទាំងឡាយកុំខ្សឹកខ្សួលខ្លាំងឡើយ សូមលោកទាំងឡាយចរចាចំពោះខ្ញុំដោយពាក្យពីរោះ។

[១២៦] បពិត្រមហារាជ ព្រះរាជដំណើររបស់ព្រះអង្គមកល្អហើយ ទ្រង់យាងមកមិនអាក្រក់ទេ ព្រះអង្គជាធំទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូល។ បពិត្រមហារាជ ផលាផល មានផ្លែទន្លាប់ មៈប៉ែន ស្រគំ សឹងមានរសផ្អែមដូចទឹកឃ្មុំ ទូលបង្គំជាខ្ញុំប្រមូលមកទុកក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផលដែលមានរសឆ្ងាញ់ៗ។ បពិត្រមហារាជ ទឹកសម្រាប់សោយដ៏ត្រជាក់ ទូលបង្គំជាខ្ញុំបាននាំមកអំពីជ្រោះភ្នំ បើព្រះអង្គមានសេចក្តីត្រូវការ សូមទ្រង់ដងអំពីទីនោះសោយចុះ។

[១២៧] (ព្រះបាទបិលយក្ខ...) ខ្ញុំវង្វេង ភ័ន្តភាំងស្មារតី ងងឹតងងល់សព្វទិសានុទិស ព្រោះបានឃើញសាមៈនោះធ្វើមរណកាលហើយ ម្នាលសាមៈ អ្នកដូចម្តេច ក៏រស់ឡើងវិញ។

[១២៨] (មហាសត្ត...) បពិត្រមហារាជ (សត្វលោក) តែងសំគាល់នូវបុរសដែលមានវេទនាធ្ងន់ តែនៅរស់ ឬមានសេចក្តីត្រិះរិះក្នុងចិត្តធ្លាក់ចុះក្នុងភវង្គ ដែលនៅរស់ថា ស្លាប់។ បពិត្រមហារាជ ម្យ៉ាងទៀត (សត្វលោក) តែងសំគាល់នូវបុរសដែលមានវេទនាធ្ងន់ តែនៅរស់ ឬចូលនិរោធនៅរស់នោះ ថាស្លាប់ហើយ។

[១២៩] សត្វណា តែងចិញ្ចឹមនូវមាតា និងបិតាដោយធម៌ ទេវតាទាំងឡាយ តែងរក្សានូវសត្វ អ្នកចិញ្ចឹមមាតាបិតានោះ។ សត្វណា តែងចិញ្ចឹមមាតា និងបិតាដោយធម៌ បណ្ឌិតទាំងឡាយក្នុងលោកនេះឯង តែងសរសើរនូវសត្វនោះ សត្វនោះ លុះលះបង់លោកនេះទៅ រមែងរីករាយក្នុងស្ថានសួគ៌។

[១៣០] (ព្រះបាទបិលយក្ខ...) ខ្ញុំរឹងរឹតតែវង្វេង ភ័ន្តភាំងស្មារតី ងងឹតងងល់សព្វទិសានុទិស ម្នាលសាមៈ ខ្ញុំសូមយកអ្នកជាទីពឹង អ្នកចូរជាទីពឹងរបស់ខ្ញុំ។

[១៣១] (មហាសត្ត...) បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមាតា និងបិតា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះបុត្ត និងភរិយា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមិត្ត និងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសត្វពាហនៈ និងពល បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះស្រុក និងនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែន និងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសមណៈ និងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះទ្រង់បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះម្រឹគ និងបក្សី បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ធម៌ដែលប្រព្រឹត្តល្អហើយ តែងនាំមកនូវសុខ បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ (ព្រោះ) ទេវតា ឥន្ទ ព្រហ្ម ដែលបានដល់នូវឋានសួគ៌ ក៏ព្រោះធម៌ដែលខ្លួនប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ។

ចប់ សុវណ្ណសាមជាតក ទី៣។

## នេមិរាជជាតក ទី៤

CS sut.kn.jat.541 | ភាគទី ៦២

### (៥៤១. និមិជាតកំ (៤))

[១៣២] (អភិសម្ពុទ្ធគាថា) ក្នុងកាលដែលព្រះបាទនេមិជាបណ្ឌិត អ្នកត្រូវការដោយកុសល ជាព្រះរាជាអ្នកទូន្មាននូវសត្រូវ ទ្រង់តែងឲ្យទានដល់ជនអ្នកនៅក្នុងដែនវិទេហៈទាំងឡាយគ្រប់គ្នា គ្រានោះ (មនុស្ស និងទេវតាទាំងឡាយ តែងសរសើរថា) ឱអស្ចារ្យណាស់ អ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាជាគ្រឿងពិចារណា កើតឡើងក្នុងលោកហើយ។ កាលព្រះរាជាអង្គនោះ ទ្រង់ឲ្យទាននោះ សេចក្តីត្រិះរិះកើតឡើងថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណាហ្ន៎ មានផលច្រើនជាង។

[១៣៣] ទេវរាជឈ្មោះមឃវៈ ជាទេវកុញ្ជរ ជាសហស្សនេត្រ បានជ្រាបព្រះតម្រិះរបស់ព្រះរាជានោះហើយ មកប្រាកដ (ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា) កំចាត់បង់នូវងងឹតដោយវណ្ណៈ។ ព្រះបាទនេមិរាជជាធំជាងមនុស្ស ទ្រង់ព្រឺព្រះលោមា បានសួរទេវរាជឈ្មោះវាសវៈថា អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាសក្កៈបុរិន្ទទៈ។ រស្មីប្រាកដដូច្នោះ ខ្ញុំពុំដែលឃើញ ទាំងមិនធ្លាប់ឮឡើយ បពិត្រអ្នកដ៏ចំរើន អ្នកចូរប្រាប់ខ្ញុំ ធ្វើម្តេចយើងស្គាល់អ្នកបាន។ ទេវរាជឈ្មោះវាសវៈជ្រាបថា ព្រះបាទនេមិ ព្រឺព្រះលោមាហើយ ទើបឆ្លើយថា ខ្ញុំជាព្រះឥន្ទ្រ ជាធំជាងទេវតា មកកាន់សំណាក់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងមនុស្ស ទ្រង់កុំព្រឺព្រះលោមាឡើយ ព្រះអង្គមានសេចក្តីប្រាថ្នា ដើម្បីសួរនូវប្រស្នាណា សូមទ្រង់សួរចុះ។ ចំណែកព្រះបាទនេមិរាជអង្គនោះ លុះព្រះឥន្ទ្រាធិរាជធ្វើឱកាសហើយ ក៏ទ្រង់ត្រាស់សួរនូវទេវរាជឈ្មោះវាសវៈថា បពិត្រទេវរាជជាឥស្សរៈជាងសព្វសត្វទាំងឡាយ ខ្ញុំសូមសួរព្រះអង្គថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណាមានផលច្រើនជាង។ ព្រះវាសវៈ

នោះ ដែលព្រះបាទនេមិ ជានរទេពសួរហើយ ក៏ឆ្លើយតបព្រះបាទនេមិវិញ ព្រះវាសវៈនោះ ប្រាប់នូវផលនៃព្រហ្មចរិយៈ បានទូលព្រះបាទនេមិ ដែលមិនជ្រាបថា បុគ្គលកើតក្នុងត្រកូលក្សត្រដោយព្រហ្មចរិយៈថោកទាប[44] ដល់នូវភាពជាទេវតាដោយព្រហ្មចរិយៈជាកណ្តាល[45] បរិសុទ្ធស្អាតដោយព្រហ្មចរិយៈខ្ពង់ខ្ពស់[46] ។ ពួកអ្នកបួស ប្រព្រឹត្តតបៈទាំងឡាយ ទៅកើតក្នុងពួកព្រហ្មណា ពួកព្រហ្មទាំងនុ៎ះ បុគ្គលអ្នកប្រកបក្នុងការសូមណាមួយ មិនងាយបានសោះទេ។

[១៣៤] ព្រះបាទទុទីបៈ ១ ព្រះបាទសាគរៈ ១ ព្រះបាទសេលៈ ១ ព្រះបាទមុចលិន្ទ ១ ព្រះបាទភគីរសៈ ១ ព្រះបាទឧសិន្នរៈ ១ ព្រះបាទអត្ថកៈ ១ ព្រះបាទអស្សកៈ ១ ព្រះបាទបុថុទ្ធនៈ ១។ ព្រះរាជាទាំងឡាយអង្គនេះក្តី ព្រះរាជាទាំងឡាយដទៃក្តី ពួកក្សត្រ ពួកព្រាហ្មណ៍ជាច្រើនក្តី ដែលបូជានូវគ្រឿងយញ្ញយ៉ាងច្រើន មិនប្រព្រឹត្តកន្លងនូវបេតភាព (កាមាវចរភូមិ) ឡើយ។

[១៣៥] ជនទាំងឡាយណា មិនមានគូ ជាបុគ្គលម្នាក់ឯង រមែងមិនត្រេកអរ (ត្រេកអរតែក្នុងការនៅច្រឡូកច្រឡំដោយពួក) ជនទាំងឡាយណា មិនមានបីតិ ដែលកើតអំពីវិវេកទេ ជនទាំងឡាយនោះ ទុកជាមានភោគៈស្មើដោយព្រះឥន្ទ្រ ក៏ដោយចុះ ជនទាំងឡាយនោះ ក៏ឈ្មោះថាជាបុគ្គលកំសត់ មានសេចក្តីសុខព្រោះកិរិយាអាស្រ័យនូវបុគ្គលដទៃដោយពិត។

[១៣៦] ឥសី ៧ អង្គនេះ គឺឥសីឈ្មោះយាមហនុ ១ សោមយាគៈ ១ មនោជវៈ ១ សមុទ្ទៈ ១ មាឃៈ ១ ភរតៈ ១ ឥសីឈ្មោះកាលបុរក្ខិតៈ ១ និងឥសីទាំងឡាយ ៤ អង្គ គឺឥសីឈ្មោះអង្គិរសៈ ១ កស្សបៈ ១ កីសវច្ឆៈ ១ អកន្តិ ១ ជាអនាគារបុគ្គល មានតបៈធម៌ បានកន្លង (កាមាវចរភូមិ) ដោយពិត។

[១៣៧] នៅប្រទេសហិមវន្តខាងជើង មានស្ទឹងឈ្មោះសីទា មានជម្រៅដ៏ជ្រៅ អ្នកផងឆ្លងបានដោយកម្រ (ទាំងពីរខាងឆ្នេរស្ទឹងនោះ) មានភ្នំមាស ពណ៌ដូចភ្លើងខៀវ រុងរឿងសព្វ ៗ កាល។ (ទៀបឆ្នេរនៃស្ទឹងនោះ) សឹងមានដើមក្រឹស្នាលូតលាស់ទង្គំទង្គោល មានទាំងរុក្ខជាតិផ្សេងៗ មានគុម្ពលូតលាស់ (អំពីដើមបពិត) ក្នុងកាលមុន មានពួកឥសីចាស់ៗ មួយម៉ឺនអង្គ នៅក្នុងទីនោះឯង។ ខ្ញុំជាបុគ្គលប្រសើរ ដោយការឲ្យ និងការប្រព្រឹត្តិវត្ត ដោយការសង្រួម និងការទូន្មាន (នូវឥន្ទ្រិយ) ហើយប្រព្រឹត្ត (ម្នាក់ឯង) លះបង់ (ពួក) ជាអ្នកមានចិត្តតាំងមាំ។ ខ្ញុំមិនរិះគន់នូវជនអ្នកមានជាតិទាប និងមានជាតិខ្ពស់ នមស្ការចំពោះជនអ្នកមានចិត្តត្រង់ មិនមានកំណត់កាលវេលាឡើយ ព្រោះថា សត្វទាំងឡាយមានកម្មជាផៅពង្ស។ វណ្ណ[47] ទាំងអស់ អ្នកមិនតាំងនៅក្នុងធម៌ រមែងធ្លាក់ចុះក្នុងនរក ជាខាងក្រោម វណ្ណៈទាំងអស់ បានប្រព្រឹត្តធម៌ដ៏ឧត្តមហើយ រមែងបរិសុទ្ធ។

[១៣៨] មឃវទេវរាជ សុជម្បតិ ទ្រង់ពោលពាក្យនេះ ទ្រង់ប្រៀនប្រដៅព្រះបាទនេមិជាធំក្នុងដែនវិទេហៈរួចហើយទ្រង់ចៀសចេញទៅកាន់ពួកទេវតាក្នុងឋានសួគ៌។

[១៣៩] (ព្រះឥន្ទ្រ...) ម្នាលអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយទាំងប៉ុន្មានដែលបានមកប្រជុំគ្នាហើយក្នុងទីនេះ ចូរចាំស្តាប់នូវគុណខ្ពស់ និងទាប[48] មានប្រមាណច្រើននេះ របស់មនុស្សទាំងឡាយអ្នកប្រកបដោយធម៌។ ដូចជាព្រះបាទនេមិអង្គនេះ ជាបណ្ឌិត ជាអ្នកត្រូវការដោយកុសល ជាព្រះរាជាទូន្មាននូវសត្រូវ បានឲ្យទានដល់អ្នកដែនវិទេហៈទាំងឡាយគ្រប់ៗ គ្នា។ កាលដែលព្រះរាជាអង្គនោះ កំពុងឲ្យនូវទាននោះ សេចក្តីត្រិះរិះកើតឡើងថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណា មានផលច្រើនជាង។

[១៤០] (មហាជន...) ឱហ្ន៎ សេចក្តីព្រឺរោម មិនធ្លាប់កើតមាន ក៏កើតឡើយហើយក្នុងលោក រថទិព្វកើតប្រាកដហើយ ដល់ព្រះបាទវិទេហៈមានយស។

[១៤១] (អភិសម្ពុទ្ធគាថា) មាតលិទេវបុត្រ អ្នកមានឫទ្ធិច្រើន ជាទេវសារថី បានអញ្ជើញព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលាថា បពិត្រព្រះរាជាដ៏ប្រសើរជាម្ចាស់នៃទិស សូមព្រះអង្គយាងមក ទ្រង់ស្តេចឡើងកាន់រថនេះ ដ្បិតទេវតាទាំងឡាយ នៅឋានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ ចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយនោះ តែងរលឹក (ព្រះអង្គ) កំពុងនៅប្រជុំក្នុងធម្មសភាឈ្មោះសុធម្មា។

[១៤២] លំដាប់នោះ ព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលា ទ្រង់ម្នីម្នាក្រោកចាកអាសនៈ បែរព្រះភក្ត្រឡើងកាន់រថ។ មាតលិទេវបុត្រ ទូលសួរព្រះបាទនេមិរាជនុ៎ះ ដែលស្តេចឡើងកាន់រថទិព្វហើយ ដូច្នេះថា បពិត្រព្រះរាជាដ៏ប្រសើរជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គទៅតាមផ្លូវណា តាមផ្លូវដែលសត្វមានបាបកម្ម ឬតាមផ្លូវដែលសត្វមានបុញ្ញកម្ម។

[១៤៣] (ព្រះបាទនេមិ...) ម្នាលមាតលិទេវសារថី អ្នកចូរនាំខ្ញុំទៅតាមផ្លូវទាំងពីរ គឺផ្លូវដែលសត្វមានបាបកម្មផង ផ្លូវដែលសត្វមានបុញ្ញកម្មផង។

[១៤៤] (មាតលិ...) បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គទៅតាមផ្លូវណាមុន តាមផ្លូវដែលសត្វមានបាបកម្មមុនឬ ឬតាមផ្លូវដែលសត្វមានបុញ្ញកម្មមុន។

[១៤៥] (ព្រះបាទនេមិ...) ខ្ញុំចង់ឃើញនរកជាទីនៅនៃសត្វអ្នកមានបាបកម្មទាំងឡាយ ខ្ញុំចង់ឃើញឋាននៃសត្វអ្នកមានកម្មលាមក និងគតិនៃសត្វទ្រុស្តសីលទាំងឡាយមុន។

[១៤៦] (អភិសម្ពុទ្ធគាថា) មាតលិទេវសារថី បង្ហាញព្រះរាជានូវស្ទឹងឈ្មោះវេតរណី ដែលសត្វឆ្លងបានដោយកម្រ ប្រកបព្រមដោយទឹកផ្សាប្រែកំពុងពុះ ក្តៅដូចអណ្តាតភ្លើង។

[១៤៧] ព្រះបាទនេមិ ទ្រង់ឃើញសត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី ជាទីឆ្លងឡើងបានដោយកម្រក្រៃលែង ហើយត្រាស់សួរមាតលិទេវសារថីថា ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ (សត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី) ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយនេះធ្លាក់ទៅកាន់ស្ទឹងវេតរណី តើពួកសត្វនេះ បានធ្វើបាបកម្មអ្វី។

[១៤៨] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកសត្វណាមានកំឡាំង មានធម៌ដ៏លាមក បៀតបៀនប្រទេចផ្តាសានូវពួកសត្វដែលមានកំឡាំងខ្សោយក្នុងជីវលោក ពួកសត្វមានកម្មលាមកនោះ រមែងរងបាប ពួកសត្វទាំងនោះឯង តែងធ្លាក់ទៅកាន់ស្ទឹងវេតរណី។

[១៤៩] (ព្រះបាទនេមិ...) ពួកឆ្កែព្រៃសម្បុរក្រហម និងពពាល ពួកត្មាត ពួកក្អែក ជាសត្វគួរខ្លាច តែងទំពាស៊ី (សត្វនរកដែលវាប្រទះឃើញ) ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ហ្វូងក្អែកតែងជញ្ជែងស៊ីនូវសត្វទាំងឡាយនេះ តើសត្វទាំងឡាយនេះ បានធ្វើបាបដូចម្តេច។

[១៥០] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃកម្មដែលខ្លួនដឹង ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា

សត្វទាំងឡាយណានីមួយ មានសេចក្ដីកំណាញ់ កំណាញ់ស្វិតស្វាញ មានធម៌លាមកពេក ជាអ្នកជេរប្រទេច បៀតបៀនប្រទូស្តសមណព្រាហ្មណ៍ សត្វអ្នកមានអំពើលាមកទាំងនោះ រមែងរងបាប ទើបហ្វូងក្អែកជញ្ជៀងស៊ីសត្វទាំងឡាយនោះ។

[១៥១] (ព្រះរាជា...) សត្វនរកទាំងឡាយ មានសរីរៈឆេះសន្ធោសន្ធៅ ដើរលើផែនដីដែក ថែមទាំងនាយនិរយបាលសំពងដោយដំបងដែកទាំងឡាយ ដែលភ្លើងឆេះ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាលវាយដោយដំបង ដួលដេកនេះ តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្ដេច។

[១៥២] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលបាបកម្មដែលខ្លួនដឹង ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយ មានបាបធម៌ពេញបន្ទុក បៀតបៀនប្រទេចផ្ដាសានូវបុរសស្ត្រីដែលឥតបាបធម៌ក្នុងជីវលោក ឈ្មោះថាជាអ្នកមានបាបធម៌ពេញបន្ទុក ជនអ្នកមានកម្មលាមកទាំងនោះ រមែងរងបាប ជនទាំងឡាយនោះឯងហើយ ដែលនាយនិរយបាលបៀតបៀនដោយដំបង ដួលដេកនៅ។

[១៥៣] (ព្រះរាជា...) ពួកសត្វនរកដទៃមានខ្លួនឆេះជុំវិញ កំពុងទួញយំ (ធ្លាក់ទៅ) កាន់រណ្ដៅរងើកភ្លើងហើយថ្ងូរ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយដែលធ្លាក់ទៅកាន់រណ្ដៅរងើកភ្លើង ហើយថ្ងូរ តើពួកសត្វទាំងឡាយនេះ បានធ្វើបាបដូចម្ដេច។

[១៥៤] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ពោលអាងសាក្សី (កោង) ក្នុងហេតុនៃទ្រព្យរបស់ប្រជុំជន ហើយញ៉ាំងទ្រព្យជាបំណុលនោះឲ្យវិនាស បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះ ញ៉ាំងពួកជនឲ្យវិនាសហើយ ជនទាំងឡាយអ្នកមានកម្មដ៏លាមកនោះ រមែងរងបាប ទើបជនទាំងឡាយនោះឯង (ធ្លាក់ទៅ) កាន់រណ្ដៅរងើកភ្លើង ហើយថ្ងូរដូច្នេះ។

[១៥៥] (ព្រះរាជា) ខ្ទះទង់ដែងធំ មានភ្លើងឆេះសន្ធោសន្ធៅ រន្ទាលច្រាលឆ្អៅ ប្រាកដជាក់ស្ដែង ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ (មានក្បាលសំយុងចុះ) ធ្លាក់ទៅកាន់ខ្ទះពេញដោយទឹកទង់ដែង តើពួកសត្វទាំងនេះធ្វើបាបដូចម្ដេច។

[១៥៦] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា មានធម៌ដ៏លាមកពេក បៀតបៀនប្រទេចផ្ដាសានូវសមណៈ ឬព្រាហ្មណ៍ អ្នកមានសីល ជនអ្នកមានកម្មដ៏លាមកទាំងឡាយនោះ តែងរងនូវបាប ជនទាំងនោះ (មានក្បាលសំយុងចុះ) ធ្លាក់ទៅកាន់ខ្ទះ ពេញដោយទឹកទង់ដែង។

[១៥៧] (ព្រះរាជា...) ពួកនាយនិរយបាល ត្របែងកនៃសត្វនរក ហើយកាប់ពន្លះ បោះទៅក្នុងទឹកក្ដៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ចុះពួកសត្វដែលមានក្បាលដាច់ ហើយដេកនៅនេះ តើសត្វពួកនេះ បានធ្វើបាបដូចម្ដេច។

[១៥៨] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោក មានបាបធម៌ពេញបន្ទុក តែងចាប់បៀតបៀននូវសត្វស្លាបទាំងឡាយ បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះ បៀតបៀនហើយនូវសត្វស្លាប ពួកជនអ្នកមានកម្មលាមកនោះ រមែងរងនូវបាប ជនទាំងឡាយនោះ មានក្បាលដាច់ហើយ ដេកនៅដូច្នេះ។

[១៥៩] (ព្រះរាជា...) ស្ទឹងនេះ មានទឹកច្រើន មានច្រាំងមិនជ្រៅ មានកំពង់ល្អ រាបទាបហូរទៅ សត្វដែលមានសេចក្ដីស្រេកឃ្លានគ្របសង្កត់ហើយតែងផឹក ស្រាប់តែទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាម ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ចុះទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាមវិញ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្ដេច។

[១៦០] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា។ ជនទាំងឡាយណា អ្នកមានកិច្ចការមិនបរិសុទ្ធ លាយនូវស្រូវសុទ្ធដោយអង្កាម ឲ្យដល់អ្នកទិញ បានជាទឹកដែលជនទាំងឡាយនោះកំពុងមានសេចក្ដីក្ដៅបៀតបៀន មានសេចក្ដីស្រេកឃ្លានគ្របសង្កត់ហើយ ផឹកទៅក្លាយជាអង្កាមវិញ។

[១៦១] (ព្រះរាជា...) នាយនិរយបាលទាំងឡាយ ចាក់នូវសរីរៈទាំងពីរខាងនៃសត្វនរក ដែលកំពុងកន្ទក់កន្ទេញ ដោយព្រួញទាំងឡាយក៏មាន ដោយលំពែងទាំងឡាយក៏មាន ដោយលំពែងស្នែងក្របីទាំងឡាយក៏មាន ម្នាលទេពបម្រើ សេចក្ដីភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាល បៀតបៀនហើយដោយលំពែង ដេកនៅដូច្នេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្ដេច។

[១៦២] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយដែលខ្លួនដឹង ហើយទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា។ ជនទាំងឡាយណា ក្នុងជីវលោក ជាអ្នកមានកម្មមិនល្អ លួចយកស្រូវ ទ្រព្យ ប្រាក់ មាស ទាំងសត្វចិញ្ចឹម ពពែ ចៀម និងក្របី ដែលគេមិនឲ្យ ហើយធ្វើនូវការចិញ្ចឹមជីវិត ជនអ្នកមានកម្មដ៏លាមកទាំងនោះ រមែងរងនូវបាប ទើបពួកជនទាំងនោះ ត្រូវនាយនិរយបាលបៀតបៀនហើយ ដោយលំពែងដេកនៅដូច្នេះ។

[១៦៣] (ព្រះរាជា...) ហេតុអ្វី សត្វនរកទាំងឡាយនេះ មួយពួកត្រូវនាយនិរយបាលចងកអូស ពួកដទៃត្រូវនាយនិរយបាលចិញ្ច្រាំ ពួកដទៃទៀតត្រូវនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ដួលដេកនៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ជនទាំងឡាយដែលនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ហើយដួលដេកនៅ តើពួកជនទាំងនោះ បានធ្វើនូវបាបដូចម្ដេច។

[១៦៤] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ជាអ្នកសម្លាប់ទ្រាយ សម្លាប់ជ្រូក សម្លាប់ត្រី សម្លាប់សត្វចិញ្ចឹម គឺក្របី ពពែ និងចៀម ហើយដាក់លក់ព្ធដ៏រានផ្សាលក់សាច់ ជនអ្នកមានកម្មអាក្រក់ទាំងនោះ តែងរងបាប បានជាជនទាំងនោះ ត្រូវនាយនិរយបាលធ្វើខ្ទេចខ្ទី ហើយដេកនៅ។

[១៦៥] (ព្រះរាជា...) អន្លង់នេះ ពេញពោរ ដោយមូត្រ និងករីស មានក្លិនអាក្រក់មិនស្អាត ស្អុយផ្សាយទៅ ពួកជនអ្នកមានសេចក្ដីស្រេកឃ្លានគ្របសង្កត់ហើយ ស៊ី (នូវមូត្រ និងករីសនេះ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនអ្នកបរិភោគនូវមូត្រ និងករីសនេះ តើពួកជនទាំងនេះ បានធ្វើនូវបាបដូចម្ដេច។

[១៦៦] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ជាអ្នកបង្កសេចក្តីទុក្ខ អ្នកបៀតបៀនមិត្រសំឡាញ់ អ្នកតាំងនៅក្នុងការបៀតបៀននូវជនដទៃសព្វៗកាល ពួកជនទាំងឡាយ មានអំពើលាមកនោះ រមែងរងបាប ជនពាលទាំងឡាយជាអ្នកទ្រុស្តមិត្តនោះ តែងស៊ីអាហារចាស់។

[១៦៧] (ព្រះរាជា...) អន្លង់នេះ ពេញពោរទៅដោយឈាម និងខ្ទុះ មានក្លិនអាក្រក់មិនស្អាត ស្អុយផ្សាយទៅ ពួកសត្វដែលត្រូវកំដៅបៀតបៀនហើយ ផឹក (ឈាម និងខ្ទុះនោះ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានឈាម និងខ្ទុះជាអាហារនេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច។

[១៦៨] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនជ្រាបថា ជនទាំងឡាយណាក្នុងជីវលោកនេះ សម្លាប់ព្រះអរហន្ត គឺមាតា ឬបិតា ឈ្មោះថាបារាជិក (ក្នុងភាពជាគ្រហស្ថ) ពួកជនអ្នកមានអំពើលាមកនោះ តែងរងបាប ជនទាំងនោះ មានឈាម និងខ្ទុះជាអាហារ។

[១៦៩] (ព្រះរាជា...) អ្នកចូរមើលនូវសត្វនរក មានអណ្តាតមុតដោយសន្ទូច បីដូចស្បែកដែលគេខ្វារដោយកង្វេរ ញាប់ញ័រដូចត្រីដែលជនបោះទៅលើគោក ព្រោះហេតុអ្វីហ្ន បានជាសត្វនរកទាំងនេះ យំបង្ហៀរទឹកមាត់ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលស៊ីសន្ទូចដេកនៅ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច។

[១៧០] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា មនុស្សទាំងឡាយណានីមួយ ឋិតនៅក្នុងដំណែងជាអ្នកកាត់ថ្លៃទំនិញ ញុំាងទំនិញដែលមានថ្លៃ ឲ្យសាបសូន្យចាកថ្លៃ (បន្ថោកទំនិញគេ) ប្រកបដោយអំពើកោង ធ្វើអំពើកោង ព្រោះហេតុចង់បានទ្រព្យ បីដូចជាសន្ទូចដែលគេបិទបាំង (ដោយនុយ) ដើម្បីសម្លាប់ត្រី។ ទីពឹងរបស់អ្នកធ្វើនូវអំពើកោង ជាបុគ្គលដែលកម្មរបស់ខ្លួនរួបរឹតហើយ មិនមានទេ ពួកជនអ្នកមានអំពើលាមកនោះ តែងរងបាប បានជាពួកជនទាំងនោះ ជាអ្នកស៊ីសន្ទូចដេកនៅ។

[១៧១] (ព្រះរាជា...) ពួកស្ត្រីទាំងនេះ មានខ្លួនដាច់ខ្ទេចខ្ទី មានជាតិអាក្រក់ មានខ្លួនប្រឡាក់ពាសពេញដោយឈាម និងខ្ទុះ មានខ្លួនដាច់រយះរយាយ បីដូចគោទាំងឡាយដែលគេពន្លះក្នុងទីសម្លាប់ ផ្គងដើមដៃទាំងឡាយ យំកន្ទក់កន្ទេញ ពួកស្ត្រីទាំងនោះ (មានខ្លួនត្រឹមចង្កេះ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិនសព្វៗកាល ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិជាទេវសារថី ខ្ញុំសួរអ្នក ពួកស្ត្រីដែល (មានខ្លួនត្រឹមចង្កេះ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិនសព្វ ៗ កាល តើពួកស្ត្រីទាំងនេះ បានធ្វើបាបដូចម្តេច។

[១៧២] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពួកស្ត្រីមានត្រកូលក្នុងជីវលោកនេះ មានអំពើមិនបរិសុទ្ធ បានប្រព្រឹត្តនូវអំពើជារបស់អសប្បុរស ពួកស្ត្រីទាំងនោះ មានសភាពជាអ្នកលេង លះបង់ស្វាមី ហើយត្រាច់ទៅរកបុរសដទៃ ព្រោះហេតុតែកាមគុណ និងល្បែងពាល ពួកស្ត្រីទាំងនោះ ក្នុងជីវលោក លុះញុំាងបុរសដទៃឲ្យត្រេកត្រអាល ទើបមានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិនដូច្នេះ។

[១៧៣] (ព្រះរាជា...) ព្រោះហេតុអ្វី បានជាសត្វនរកមួយពួកទៀតនេះ ត្រូវនាយនិរយបាលចាប់ជើង ឲ្យមានក្បាលសំយុងចុះ ហើយទម្លាក់ទៅក្នុងរណ្តៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ ដែលមានក្បាលសំយុងចុះ នាយនិរយបាលទម្លាក់ទៅក្នុងរណ្តៅនរក តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្តេច។

[១៧៤] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ អ្នកមានអំពើជារបស់អសប្បុរស ប្រព្រឹត្តកន្លងនូវប្រពន្ធទាំងឡាយនៃជនដទៃ សត្វទាំងឡាយប្រាកដដូច្នោះនោះ ឈ្មោះថាជាអ្នកលួចនូវរបស់ដ៏ថ្លៃថ្លា បានជាសត្វទាំងនោះ (មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្តៅ។ សត្វទាំងឡាយនោះ តែងរងនូវទុក្ខវេទនាក្នុងនរកទាំងឡាយនោះ អស់ប្រជុំនៃឆ្នាំដ៏ច្រើន ព្រោះថា ទីពឹងទាំងឡាយរបស់បុគ្គលអ្នកធ្វើបាប ជាបុគ្គលដែលកម្មរបស់ខ្លួនរួបរឹតហើយ មិនមានទេ ពួកសត្វអ្នកមានអំពើលាមកនោះ រមែងរងនូវបាប ទើបបានជាពួកជនទាំងនោះ (មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្តៅ។

[១៧៥] (ព្រះរាជា...) ពួកសត្វទាំងឡាយនេះ ខ្ពស់ និងទាបផ្សេងៗគ្នា ជាអ្នកត្រដាបត្រដួស មានរូបគួរខ្លាចពន់ពេក ប្រាកដនៅក្នុងនរកទាំងឡាយ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានសេចក្តីទុក្ខវេទនាក្លៀវក្លា ខ្លោចផ្សា ក្តៅក្រហាយក្រៃលែងនេះ តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្តេច។

[១៧៦] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណាក្នុងជីវលោកនេះ មានទិដ្ឋិលាមកក្រៃលែង តែងធ្វើអំពើដ៏ស្និទ្ធ ព្រោះមោហៈ ទាំងបបួលអ្នកដទៃ (ឲ្យយល់) ក្នុងទិដ្ឋិទាំងឡាយនោះផង ជនទាំងឡាយនោះ មានទិដ្ឋិបាប រមែងរងបាប ទើបបានជាពួកជនទាំងនោះរងទុក្ខវេទនាដ៏ក្លៀវក្លា ខ្លោចផ្សា ក្តៅក្រហាយក្រៃលែង។

[១៧៧] បពិត្រព្រះរាជា ទីលំនៅរបស់សត្វអ្នកមានបាបកម្មទាំងឡាយ ឋានរបស់សត្វអ្នកមានអំពើអាក្រក់ទាំងឡាយ និងគតិរបស់សត្វអ្នកទ្រុស្តសីលទាំងឡាយ ព្រះអង្គទ្រង់បានជ្រាបហើយ បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ធំ សូមទ្រង់ស្តេចទៅក្នុងសំណាក់ទេវរាជឥឡូវនេះ។

[១៧៨] (ព្រះបាទនេមិ...) វិមាននេះ មានកំពូលប្រាំ ដែលយើងឃើញប្រាកដ មាននាងនារីមានអានុភាពធំ ប្រដាប់ដោយកម្រងផ្កា សំដែងនូវទេវឫទ្ធិមានប្រការផ្សេង ៗ នៅកណ្តាលដំណេក ក្នុងវិមាននោះ ម្នាលទេពបម្រើ សេចក្តីរីករាយមានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក នារីដែលបានដល់ឋានសួគ៌ហើយ រីករាយក្នុងវិមាន តើនារីនេះ បានធ្វើកុសលដូចម្តេច។

[១៧៩] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពិរណីដែលទ្រង់ធ្លាប់ជ្រាបហើយ ជាទាសីកើតហើយក្នុងផ្ទៃនៃទាសី ក្នុងផ្ទះនៃព្រាហ្មណ៍ ក្នុងជីវលោក នាងពិរណីនោះដឹងថា ភិក្ខុជាភ្ញៀវ មានកាលដល់ហើយ (ហើយក៏អង្គាសចង្ហាន់ប្រគេនភិក្ខុនោះ) ហាក់ដូចជាមាតា ដែលត្រេកអរចំពោះបុត្តរបស់ខ្លួន នាងជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនាងរីករាយក្នុងវិមាន។

[១៨០] (ព្រះបាទនេមិ...) វិមានមាសទាំង ៧ ដែលបុញ្ញកម្មតាក់តែងហើយ មានពន្លឺរុងរឿងផ្សព្វផ្សាយទៅ មានទេវបុត្រមានឫទ្ធិច្រើនប្រដាប់ហើយដោយអាភរណៈគ្រប់បែប មានពួកនាងទេពធីតាចោមរោមហើយ ដើរប្រទក្សិណដោយជុំវិញ ក្នុងវិមានទាំង ៧ នោះ។

ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តនេះ បានធ្វើនូវកុសលដូចម្តេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៨១] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្រនេះ ជាគហបតី ឈ្មោះសោណទិន្ន ជាម្ចាស់នៃទាន (ក្នុងដែនកាសី) គាត់បានសាងកុដិសម្រាប់នៅ ៧ ខ្នង ឧទ្ទិសចំពោះបព្វជិត។ គាត់បានបម្រើភិក្ខុទាំងឡាយ ដែលអាស្រ័យនៅក្នុងកុដិនោះដោយគោរព បានប្រគេនចីវរសម្រាប់ស្លៀកដណ្តប់ផង ភត្តាហារផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះលោកអ្នកមានចិត្តត្រង់ទាំងឡាយ ដោយចិត្តជ្រះថ្លា។ គាត់រក្សាឧបោសថប្រកបដោយអង្គប្រាំបី អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី៨ នៃបក្ខផង បាដិហារិយបក្ខផង គាត់ជាអ្នកសង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគាត់រីករាយក្នុងវិមាន។

[១៨២] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំងជាវិការៈនៃកែវផលិក ពាសពេញដោយពួកនារីដ៏ប្រសើរ រុងរឿងដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយកិរិយារាំ និងច្រៀងទាំងពីរ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្តីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើនារីទាំងនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៨៣] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកនារីណានីមួយ ក្នុងជីវលោកនេះ មានសីល ជាឧបាសិកា ត្រេកអរក្នុងទាន មានចិត្តជ្រះថ្លាជានិច្ច តាំងនៅក្នុងសច្ចធម៌ មិនប្រមាទធ្វេសក្នុងឧបោសថ ជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនារីទាំងនោះរីករាយក្នុងវិមាន។

[១៨៤] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការៈនៃកែវពៃទូរ្យ ប្រកបដោយភូមិភាគ ចែកវាស់ដោយចំណែក។ (ក្នុងវិមាននេះ) មានសូរសំឡេងទិព្វលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំ ច្រៀង និងប្រគំ គួរស្តាប់ ជាទីរីករាយនៃចិត្ត។ សម្លេងដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ទើបតែបានដឹង។ ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំព្រោះបានឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើពួកទេវបុត្រទាំងនេះ ធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៨៥] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា មានសីល ជាឧបាសក ក្នុងជីវលោកនេះ បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន ប្រតិបត្តិព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រជាក់ ដោយគោរព ព្រមទាំងបានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។ ជនទាំងឡាយនោះ បានរក្សាឧបោសថ ប្រកបដោយអង្គប្រាំបី អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វ ៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ និងជាអ្នកចែកទាន ទើបជនទាំងឡាយនោះរីករាយក្នុងវិមាន។

[១៨៦] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតល្អហើយ រុងរឿងដោយជញ្ជាំង ជាវិការៈនៃកែវផលិក ដេរដាសដោយពួកនាងនារីដ៏ប្រសើរ ចំរើនដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយកិរិយារាំ និងច្រៀងទាំងពីរយ៉ាង មានស្ទឹងប្រកបដោយរុក្ខជាតិមានផ្កាផ្សេងៗ ហួរព័ទ្ធជុំវិញ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រនេះ បានធ្វើនូវកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៨៧] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្រអង្គនុ៎ះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះពួកព្រះអរហន្តអ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា។ បានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះរីករាយក្នុងវិមាន។

[១៨៨] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតល្អហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការៈនៃកែវផលិក ដេរដាសដោយពួកនារីដ៏ប្រសើរ ចំរើនដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយការច្រៀង និងការរាំទាំងពីរយ៉ាង មានស្ទឹងប្រកបដោយឈើមានផ្កាផ្សេងៗ ហួរព័ទ្ធជុំវិញ មានឈើទាំងឡាយជាច្រើនគឺ ដើមកេស ខ្វិត ស្វាយ សាលព្រឹក្ស ព្រីង ទន្លាប់ មៈប៉ែន សុទ្ធសឹងមានផ្លែជានិច្ច។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ រីករាយក្នុងវិមាន។

[១៨៩] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទានក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូងទឹក បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលជាអ្នកមានចិត្តត្រជាក់ បានថ្វាយនូវចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា។ គហបតីនោះ បានទាំងរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន។

[១៩០] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំងជាវិការៈនៃកែវពៃទូរ្យ ប្រកបដោយភូមិភាគ ចែកវាស់ដោយចំណែក (ក្នុងវិមាននោះ) មានសូរសព្ទជាទិព្វលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំ ច្រៀង និងប្រគំ គួរស្តាប់ ជាទីរីករាយនៃចិត្ត។ សម្លេងដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ទើបតែនឹងបានដឹង។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៩១] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ

ដែលមិនទ្រង់ជ្រាបថា ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទានក្នុងក្រុងពារាណសី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលមានចិត្តត្រជាក់ បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។ ទេវបុត្រនោះ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្រ្ទិយ ជាអ្នកចែកទាន ទើបទេវបុត្រនោះ រីករាយក្នុងវិមាន។

[១៩២] (ព្រះរាជា...) វិមាននេះ ជាវិការនៃមាសដែលបុញ្ញកម្មនិម្មិតហើយ ដូចព្រះអាទិត្យទើបរះឡើង មានពណ៌ក្រហម មានមណ្ឌលធំ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៩៣] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ទេវបុត្រអង្គនេះ ជាគហបតីជាម្ចាស់នៃទានក្នុងក្រុងសាវត្ថី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ ជាអ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។ គហបតីនោះ បានរក្សាឧបោសថប្រកបដោយអង្គ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្រ្ទិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន។

[១៩៤] (ព្រះរាជា...) វិមានទាំងឡាយនេះ ជាវិការនៃមាស មានប្រមាណច្រើន ដែលបុញ្ញកម្មនិម្មិតហើយ តាំងនៅក្នុងអាកាស មានពន្លឺដ៏រុងរឿង ដូចជាផ្លេកបន្ទោរក្នុងចន្លោះនៃមេឃ ក្នុងវិមានទាំងឡាយនោះ មានពួកទេវតាមានឫទ្ធិច្រើន សឹងប្រដាប់ដោយគ្រឿងអាភរណៈគ្រប់បែប មានពួកនាងទេពអប្សរចោមរោមហើយ ប្រទក្សិណវិលវង់ដោយជុំវិញ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកទេវបុត្រទាំងនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៩៥] មាតលិទេវសារថីដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពួកទេវបុត្រទាំងនោះ ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ តាំងនៅស៊ប់ដោយសទ្ធាក្នុងព្រះសទ្ធម្ម ដែលព្រះមានព្រះភាគទ្រង់ប្រកាសទុកល្អហើយ បានធ្វើតាមនូវពុទ្ធវចនៈរបស់ព្រះសាស្តា បពិត្រព្រះរាជា ឋានទាំងឡាយដែលទ្រង់ក្រឡេកឃើញហើយ គឺជាឋានរបស់ទេវបុត្រទាំងឡាយនោះ។

[១៩៦] បពិត្រមហារាជ ឋានរបស់សត្វអ្នកមានបាបកម្ម ទ្រង់បានជ្រាបហើយ ព្រោះទ្រង់ទតឃើញនូវលំនៅ (របស់សត្វ) ទាំងឋានរបស់សត្វអ្នកមានកល្យាណកម្ម ក៏ទ្រង់ជ្រាបហើយ បពិត្រព្រះរាជាទ្រង់ស្វែងរកកុសលធម៌ ឥឡូវនេះ សូមទ្រង់យាងទៅក្នុងសំណាក់នៃទេវរាជ។

[១៩៧] (អភិសម្ពុទ្ធគាថា) ព្រះបាទនេមិមហារាជ ទ្រង់ឋិតនៅលើទិព្វយាន មានសេះជាវាហនៈដែលទឹមដោយសេះសិន្ធព ១ ពាន់ កាលស្តេចកំពុងយាងទៅ ទ្រង់ក្រឡេកឃើញភ្នំទាំងឡាយក្នុងចន្លោះសីទន្តរសមុទ្ទ លុះទ្រង់ទតឃើញហើយ ទ្រង់ត្រាស់ហៅទេវសារថីសួរថា ភ្នំទាំងនោះ តើឈ្មោះអ្វីខ្លះ។

[១៩៨] (មាតលិ...) ភ្នំធំៗទាំងឡាយនេះ ក្នុងសមុទ្ទសីទន្តរ គឺភ្នំសុទស្សនៈ ១ ករវិក ១ ឥសិន្ធរ ១ យុគន្ធរ ១ នេមិន្ធរ ១ វិនតក ១ អស្សកណ្ណ ១ ជាភ្នំមានកំពូលខ្ពស់ឡើងតាមលំដាប់រៀងគ្នា បពិត្រមហារាជ ភ្នំដែលទ្រង់ក្រឡេកឃើញ សឹងជាលំនៅនៃមហារាជទាំងឡាយ។

[១៩៩] (ព្រះរាជា...) (ទ្វារ) មានរូបជាអនេកដ៏រុងរឿងវិចិត្រដោយរតនវត្ថុផ្សេង ៗ ដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា (ព្រៃធំ) ដែលពួកខ្លាធំចាំនៅហើយ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅថាទ្វារនេះ ឈ្មោះអ្វី ទើបជាទីរីករាយនៃចិត្តប្រាកដអំពីចម្ងាយ។

[២០០] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ទ្វារនេះឈ្មោះចិត្តកូដ ជាទីចេញចូលនៃទេវរាជ (ជាទ្វារនៃទេពនគរ ដែលតាំងនៅត្រង់ទីបំផុតនៃភ្នំព្រះសុមេរុ) ជាភ្នំគួរឲ្យចង់មើលប្រាកដ (ទ្វារនេះ) មានរូបជាអនេកដ៏រុងរឿង វិចិត្រដោយរតនៈវត្ថុផ្សេងៗ ប្រាកដជាទ្វារដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា (ព្រៃធំ) ដែលពួកខ្លារក្សាហើយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅតាមទ្វារនុ៎ះ សូមទ្រង់ជាន់នូវផែនដីទិព្វដ៏រាបស្មើ។

[២០១] (អភិសម្ពុទ្ធគាថា) ព្រះបាទនេមិមហារាជ ទ្រង់ឋិតនៅលើទិព្វយាន មានសេះជាវាហនៈដែលទឹមដោយសេះសិន្ធព ១ ពាន់ ទ្រង់យាងទៅ បានទតឃើញនូវទេវសភា (ត្រាស់សួរថា) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដោយជញ្ជាំងជាវិការនៃកែវពៃទូរ្យ ឃើញច្បាស់ដូចអាកាសមានពន្លឺខៀវក្នុងសរទកាល។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅវិមាននុ៎ះឈ្មោះអ្វី។

[២០២] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ទេវសភាដែលព្រះអង្គទតឃើញនុ៎ះឯង គេហៅថា សុធម្មា (ទេវសភានុ៎ះ) រុងរឿងដោយកែវពៃទូរ្យដ៏វិចិត្រដែលបុញ្ញានុភាពនិម្មិតដោយប្រពៃតាំងនៅ សសរមានជ្រុងប្រាំបី ដែលបុញ្ញកម្មតាក់តែងល្អ សុទ្ធសឹងជាវិការនៃកែវពៃទូរ្យទាំងអស់ ពួកទេវតានៅជាន់តាវត្តឹង្សគ្រប់អង្គ សឹងមានព្រះឥន្ទ្រជាប្រមុខ តែងប្រជុំគ្នាគិតគូរសេចក្តីចំរើនរបស់ទេវតា និងមនុស្សទាំងឡាយ បពិត្រព្រះរាជាទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅកាន់ទីអនុមោទនារបស់ទេវតាទាំងឡាយតាមទ្វារនេះ។

[២០៣] (អភិសម្ពុទ្ធគាថា) ពួកទេពនិករ បានឃើញព្រះរាជានោះស្តេចយាងមកដល់ហើយ ត្រេកអរទទួលថា បពិត្រមហារាជ ដំណើរដែលព្រះអង្គយាងមកនេះប្រពៃហើយ មិនមែនទ្រង់យាងមកអាក្រក់ទេ បពិត្រព្រះរាជា ទ្រង់ស្វែងរកនូវគុណធម៌ដ៏ប្រសើរ ឥឡូវនេះ

សូមព្រះអង្គគង់ក្នុងទីជិតនៃទេវរាជចុះ។ សក្កទេវរាជ ទ្រង់ត្រេកអរទទួលព្រះបាទវិទេហៈ គ្រប់គ្រងក្រុងមិថិលានោះ ព្រះបាទវាសវៈ អញ្ជើញព្រះអង្គដោយកាមទាំងឡាយផង ដោយអាសនៈផងថា ព្រះអង្គស្ដេចមកដល់លំនៅនៃទេវតាទាំងឡាយ ជាដំណើរប្រពៃណាស់ ព្រះរាជាទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងទេវលោកទាំងឡាយ ជាទីញុំាងសេចក្ដីប្រាថ្នាទាំងពួងឲ្យសម្រេច សូមព្រះអង្គបរិភោគកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្សក្នុងតាវត្តិង្សទេវលោកចុះ។

[២០៤] (ព្រះបាទនេមិ...) វត្ថុណាដែលបានដោយអ្នកដទៃឲ្យជាបច្ច័យ ដូចយានជារបស់សូមគេ ដូចទ្រព្យជារបស់សូមគេ វត្ថុនុ៎ះ ក៏មានឧបមេយ្យយ៉ាងនេះឯង។ ខ្ញុំឥតចង់បានវត្ថុដែលបានមកដោយអ្នកដទៃឲ្យជាបច្ច័យនោះទេ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយដោយខ្លួនឯង នោះទើបជាទ្រព្យសម្រេចដល់ខ្ញុំ។ ខ្ញុំឯងនឹងត្រឡប់ទៅធ្វើកុសលដែលបុគ្គលធ្វើហើយ រមែងដល់សេចក្ដីសុខ មិនក្ដៅក្រហាយខាងក្រោយ ឲ្យមានប្រមាណច្រើន ដោយការឲ្យផង ដោយការប្រព្រឹត្តិស្មើផង ដោយការសង្រួមឥន្ទ្រិយផង ដោយការទូន្មាននូវឥន្ទ្រិយផង ក្នុងពួកមនុស្ស។

[២០៥] មាតលិជាទេវសារថីដ៏ចំរើន ជាអ្នកមានឧបការៈច្រើនដល់យើង ព្រោះបានបង្ហាញនូវឋាននៃសត្វអ្នកមានបុញ្ញកម្ម និងឋាននៃសត្វអ្នកមានបាបកម្មទាំងឡាយ។

[២០៦] ព្រះបាទនេមិ ទ្រង់ជាឥស្សរៈក្នុងដែនវិទេហៈ គ្រប់គ្រងក្រុងមិថិលា ទ្រង់បានពោលដូច្នេះហើយ (ទើបទ្រង់លាសក្កទេវរាជត្រឡប់មកមនុស្សវិញ) ទ្រង់បានបូជាយញ្ញៈដ៏ច្រើន ហើយទ្រង់ចូលទៅរកការសង្រួម (បព្វជ្ជា)។

ចប់ នេមិរាជជាតក ទី៤។

## មហោសធជាតក ទី៥

CS sut.kn.jat.542 | ភាគទី ៦២

**(៥៤២. ឧមង្គជាតកំ (៥))**

[២០៧] (ព្រះបាទវិទេហៈត្រាស់ថា) ម្នាលមហោសធ ព្រះរាជាចូឡនីព្រហ្មទត្ត ជាម្ចាស់ក្រុងបញ្ចាល យាងមកជាមួយនឹងសេនាទាំងពួង សេនារបស់ព្រះរាជាក្រុងបញ្ចាលនោះ បុគ្គលប្រមាណមិនបាន។ (សេនាទាំងនោះ) មានពលជាងឈើ និងពលថ្មើរជើង អ្នកឈ្លាសក្នុងសង្គ្រាមទាំងពួង អាចនឹងលុកចូលទៅក្នុងពួក ជាសេនាមានសំឡេង (មិនស្ងាត់ចាកសំឡេងទាំង ១០ យ៉ាង) ញុំាងគ្នានឹងគ្នាឲ្យដឹងដោយសំឡេងស្គរ និងស័ង្ខ។ (ពួកសេនាទាំងនោះ) មានវិទ្យាក្នុងផ្លូវលោហធាតុ និងមានគ្រឿងប្រដាប់ មានទង់ជ័យ មានមនុស្សអ្នកឡើងកាន់ពាហនៈខាងឆ្វេង ទាំងបរិបូណ៌ល្អដោយពួកមនុស្សអ្នកមានសិល្ប ដែលពួកយោធាដ៏ក្លៀវក្លា (មានព្យាយាមស្មើដោយសត្វសីហៈ) តាំងទុកដោយល្អហើយ។ ក្នុងចំណោមសេនាទាំងនុ៎ះ មាននាយពល ១០ នាក់ ជាអ្នកឈ្លាស មានប្រាជ្ញាដូចផែនដី ច្រើនទៅប្រជុំប្រឹក្សាក្នុងទីស្ងាត់ នឹងមាតារបស់ព្រះរាជា ជាគំរប់ ១១ រមែងទ្រង់ប្រៀនប្រដៅសេនាក្នុងក្រុងបញ្ចាល។ បណ្ដាជនទាំងនុ៎ះ មានក្សត្រិយ៍ ១០១ សុទ្ធតែមានយស ជាចំណុះ ដែលត្រូវព្រះបាទចូឡនីព្រហ្មទត្តដណ្ដើមយកដែនហើយ មានសេចក្ដីភ័យអំពីមរណៈ ក៏លុះក្នុងអំណាចនៃព្រះបាទបញ្ចាល។ (ស្ដេចទាំង ១០១ នោះ) ជាអ្នកធ្វើតាមព្រះរាជតម្រាស់ មិនមានប្រាថ្នា ក៏ពោលពាក្យជាទីស្រឡាញ់ មិនមានប្រាថ្នា ក៏លុះអំណាចចុះចូលព្រះបាទបញ្ចាល។ មិថិលារាជធានីរបស់ពួកអ្នកវិទេហៈ ត្រូវពួកសេនានោះចោមព័ទ្ធជា ៣ ជាន់[49] (ដូចជា) ជីកគាស់ដោយជុំវិញ។ (ក្រុងមិថិលា) ត្រូវសេនាចោមព័ទ្ធជុំវិញ (ប្រាកដដោយសស្ត្រាវុធ) ដូចជាផ្កាយដែលប្រាកដក្នុងខាងលើ ម្នាលមហោសធ អ្នកឯងចូរដឹងថា សេចក្ដីរួច (ចាកទុក្ខនេះ) នឹងមានដល់ពួកយើងដោយប្រការដូចម្ដេច។

[២០៨] (ព្រះមហាសត្វក្រាបបង្គំទូលថា) បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់សណ្ដូកព្រះបាទ (ឲ្យស្រួលចុះ) សូមព្រះអង្គទ្រង់ក្រសាលរីករាយក្នុងកាមចុះ ព្រះបាទចូឡនីព្រហ្មទត្ត មុខជានឹងលះបង់សេនាក្នុងក្រុងបញ្ចាល ហើយរត់ទៅ។

[២០៩] (អាចារ្យកេវដ្តព្រាហ្មណ៍...) ព្រះរាជាចូឡនីប្រាថ្នាដើម្បីធ្វើសម្ពន្ធមិត្រ (នឹងព្រះអង្គ) ទាំងទ្រង់ថ្វាយកែវទាំងឡាយ មានស្រីកែវជាដើម ដល់ព្រះអង្គ (ចាប់ដើម) ពីថ្ងៃនេះទៅ សូមឲ្យពួករាជទូតមានវាចាពីរោះ ពោលពាក្យជាទីស្រលាញ់មក (ក្រុងមិថិលានេះបាន)។ សូមឲ្យពួករាជទូតទាំងនោះពោលវាចាដ៏ទន់ភ្លន់ ជាវាចាគួរត្រេកអរ សូមព្រះបាទបញ្ចាល និងព្រះបាទវិទេហៈទាំងពីរអង្គនោះ រួបរួមគ្នាតែមួយ។

[២១០] (ព្រះបាទវិទេហៈ...) នែកេវដ្តៈ អ្នកបានជួបនឹងមហោសធដែរឬ អ្នកចូរពោលសេចក្ដីនោះ អ្នកបានឲ្យមហោសធអត់ទោសហើយឬ មហោសធត្រេកអរហើយឬ។

[២១១] (អាចារ្យកេវដ្តៈ...) បពិត្រព្រះអង្គជាធំជាងជន មហោសធហៅពេញជាបុរសថោកទាប ពុំមានសេចក្ដីស្មោះស្មើ ជាមនុស្សរឹងរូសជាអសប្បុរស ពុំបានពោលសេចក្ដីអ្វីតិចតួចសោះ ដូចជាមនុស្សគ ឬដូចជាមនុស្សថ្លង់។

[២១២] (ព្រះបាទវិទេហៈ...) ចំណែកការដែលគិតនេះ បុរសផ្ដេសផ្ដាសឃើញបានក្រណាស់ដោយពិត សេចក្ដីបរិសុទ្ធិ នរជនអ្នកមានព្យាយាម មុខជានឹងឃើញហេតុនោះ កាយរបស់អញញាប់ញ័រ អ្នកណានឹងលះបង់នូវដែនរបស់ខ្លួន ហើយលុះក្នុងកណ្ដាប់ដៃជនដទៃវិញកើត។

[២១៣] គំនិតរបស់យើងទាំង ៦ នាក់ ដែលជាអ្នកឈ្លាស មានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ផុតដូចផែនដី ស្មើគ្នាជាឯកច្ឆន្ទ ម្នាលមហោសធ អ្នកចូរគិតមើល ទៅ ឬកុំទៅ ឬក៏ឈប់។

[២១៤] (ព្រះមហាសត្វ...) បពិត្រព្រះរាជា សូមព្រះអង្គទ្រង់ជ្រាបថា ព្រះបាទចូឡនីព្រហ្មទត្ត ជាអ្នកមានអានុភាពធំ មានពលច្រើន ឥឡូវប្រាថ្នាដើម្បីនឹងសំឡាប់ព្រះអង្គ ដូចនាយព្រានដែលសំឡាប់ម្រឹគដោយផ្ទាក់។

ត្រីជាសត្វជាប់ចិត្តក្នុងនុយស្រស់ (លេប) ផ្លែសន្ទូចដែលគេបិទបាំងដោយសាច់ មិនដឹងសេចក្ដីស្លាប់ខ្លួនយ៉ាងណា។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកជាប់ក្នុងកាម ចង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គដូចត្រីនោះឯង។ បើព្រះអង្គស្ដេចយាងទៅកាន់ក្រុងបញ្ចាល ព្រះអង្គមុខជានឹងលះចោលព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគដែលដើរទៅតាមផ្លូវ (ទៀបទ្វារនៃស្រុកដែរ)។

[២១៥] (ព្រះបាទវិទេហៈ...) យើងដែលបានពោលនូវប្រយោជន៍ដ៏ឧត្តម ក្នុងសំណាក់នៃអ្នក ត្រឡប់ទៅជាមនុស្សល្ងង់លីលាវិញ អ្នកឯងជាអ្នកចំរើនដោយចុងនង្គ័ល ម្ដេចនឹងដឹងសេចក្ដីចំរើនដូចអ្នកដទៃកើត។

[២១៦] អ្នកទាំងឡាយ ចូរចាប់អ្នកនេះឲ្យដឹក ហើយឲ្យវិនាសចាកដែនរបស់អញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបានស្រីកែវ។

[២១៧] (អភិសម្ពុទ្ធគាថា) លំដាប់នោះ មហោសធពោធិសត្វក៏ចៀសចេញអំពីសំណាក់នៃព្រះបាទវិទេហៈហើយ ទើបហៅសុវបណ្ឌិតឈ្មោះមាធុរៈ ជាទូតមកប្រាប់ថា ម្នាលសំឡាញ់មានស្លាបខៀវ អ្នកចូរមកធ្វើការបំរើអញ ដ្បិតមានសាលិកាញីមួយដែលគេចិញ្ចឹមទុកជិតទីក្រឡាបន្ទំនៃព្រះបាទបញ្ចាល។ ឯងចូរទៅសួរសាលិកានោះ ដោយសន្តរកិច្ច ព្រោះវាជាសត្វឈ្លាសក្នុងកិច្ចទាំងពួង វាដឹងការអាថ៌កំបាំងទាំងពួងរបស់ជនទាំងពីរ គឺព្រះរាជា និងកោសិយព្រាហ្មណ៍។ មាធុរៈសុវបណ្ឌិតមានស្លាបខៀវនោះ បានទទួលស្តាប់ថា បាទ ដូច្នេះហើយ ក៏ហើរទៅកាន់សំណាក់នៃនាងសាលិកា។ មាធុរៈសុវបណ្ឌិត លុះហើរទៅដល់ហើយ ទើបហៅនាងសាលិកាមានទ្រង់ល្អ ពោលពាក្យពីរោះថា នែនាងមានទ្រង់ល្អ នាងល្មមអត់ទ្រាំបានដែរឬ នែនាងជាវេសជាតិ នាងមិនមានជំងឺតម្កាត់ទេឬ នែនាំងមានទ្រង់ល្អ នាងបានលាជលាយដោយទឹកឃ្មុំដែរឬ។

(សាលិកាញី...) ម្នាលសំឡាញ់ សេចក្តីសុខស្រួលមានដល់ខ្ញុំ ម្នាលសំឡាញ់ មួយទៀត ខ្ញុំមិនមានជម្ងឺតម្កាត់ទេ ម្នាលសុវបណ្ឌិត ទាំងលាជលាយដោយទឹកឃ្មុំ ខ្ញុំក៏បានដែរ។ នែសំឡាញ់ អ្នកមកអំពីណាហ្ន៎ ឬអ្នកណាប្រើមក មួយវិញទៀត អ្នកជាសត្វដែលខ្ញុំមិនធ្លាប់ឃើញ មិនធ្លាប់ឮក្នុងកាលមុនអំពីកាលនេះទេ។

[២១៨] (សុវបណ្ឌិត...) ខ្ញុំ គេចិញ្ចឹមទុកនៅទីបន្ទំក្នុងប្រាសាទនៃព្រះបាទសិវិ ព្រះរាជានោះ ទ្រង់ឋិតនៅក្នុងធម៌ តែងទ្រង់ដោះលែងនូវសត្វទាំងឡាយដែលជាប់ចំណង ចាកចំណងអំពីទីនោះៗ។ មាននាងសាលិកាមួយ ពោលពាក្យពីរោះ ជាភរិយារបស់ខ្ញុំ ម្នាលនាងមានទ្រង់ល្អ កាលខ្ញុំកំពុងតែសំឡឹងជាប់ចិត្ត ស្រាប់តែខ្លែងសំឡាប់នាងសាលិកានោះទៅ។ ខ្ញុំបរិបូណ៌ដោយសេចក្តីប្រាថ្នាចំពោះភរិយានោះ បានជាមកក្នុងសំណាក់នៃនាង ប្រសិនបើនាងបើកឱកាស យើងទាំងពីរនាក់ នឹងនៅក្នុងទីជាមួយគ្នា។

[២១៩] (សាលិកា...) ធម្មតាសេកឈ្មោល គួរតែប្រាថ្នារកសេកញី សាលិកាឈ្មោល គួរតែប្រាថ្នារកសាលិកាញី ចុះការនៅរួមដោយសេកឈ្មោល និងសាលិកាញី ដូចម្តេចកើត។

[២២០] (សុវបណ្ឌិត...) បគ្គលណា ប្រាថ្នាស្ត្រីណាក្នុងកាម សូម្បីស្ត្រីនោះជាចណ្ឌាលក៏ដោយ ព្រោះថា ការនៅរួមទាំងអស់ដូចៗគ្នា ដែលមិនដូចគ្នាក្នុងកាម មិនមានទេ។ ព្រះមាតានៃព្រះបាទសិវិ ព្រះនាមជម្ពាវតី (ជាចណ្ឌាលសោះ) តែបានជាអគ្គមហេសី ជាទីស្រឡាញ់របស់ព្រះបាទវាសុទេវកណ្ហាយនគោត្រ។ សូម្បីនាងកិន្នរីឈ្មោះរតនវតី ញុំាងតាបសឈ្មោះវច្ឆៈ ឲ្យប្រាថ្នាដែរ។ មនុស្សរួមសំវាសជាមួយនឹងមេម្រឹគក៏មាន ការនៅរួមក្នុងកាមមិនដូចគ្នា មិនមានទេ។ នែនាងសាលិកា ពោលពាក្យពីរោះ បើដូច្នោះ យើងនឹងទៅវិញ ព្រោះពាក្យនាងនុ៎ះ ទុកជាពាក្យប្រកែក នាំងមើលងាយខ្ញុំពិត។

[២២១] (សាលិកា...) នែមាធុរៈសុវបណ្ឌិត សិរីរមែងមិនមានដល់អ្នកប្រញាប់ទេ អ្នកចូរឈប់នៅទីនេះ ដរាបបានឃើញព្រះរាជាសិន អ្នកនឹងបានស្តាប់សំឡេងសំភោរ បានឃើញអានុភាពព្រះរាជា។

[២២២] (សុវបណ្ឌិត...) សំឡេងអឹងកងនេះ ឮល្បីប្រាកដទៅជនបទខាងក្រៅថា ព្រះរាជធីតាព្រះបាទបញ្ចាល មានវណ្ណៈដូចជាផ្កាយព្រឹក ព្រះអង្គនឹងប្រទានព្រះរាជធីតានោះ ដល់ព្រះបាទវិទេហៈ ឯវិវាហមង្គលនោះ ក៏នឹងមានដែរ (តើពិតឬទេ)។

[២២៣] (សាលិកា...) នែមាធុរៈ ការរៀបចំវិវាហមង្គលប្រាកដដូចនេះរបស់ពួកសត្រូវ ដូចជាវិវាហមង្គលរបស់ព្រះបាទបញ្ចាលជាមួយនឹងព្រះបាទវិទេហៈរបស់អ្នក ចូរលើកទុកចុះ។ ព្រះរាជាដ៏ប្រសើរលើរថរបស់អ្នកក្រុងបញ្ចាល នឹងនាំព្រះបាទវិទេហៈមកហើយ នឹងសំឡាប់ព្រះបាទវិទេហៈនោះ ក្នុងវេលានោះ (ព្រះបាទចូឡនី) មិនមែនជាសំឡាញ់របស់ព្រះបាទវិទេហៈនោះទេ។

[២២៤] (សុវបណ្ឌិត...) សូមនាងអនុញ្ញាតឲ្យបងទៅត្រឹម ៧ រាត្រី ទំរាំបងទូលព្រះបាទសិវិ និងព្រះមហេសីថា ខ្ញុំបាននៅរួមក្នុងសំណាក់នាងសាលិកាហើយ។

[២២៥] (សាលិកា...) អើ ! ខ្ញុំអនុញ្ញាតឲ្យអ្នកទៅត្រឹម ៧ រាត្រី បើអ្នកមិនត្រឡប់មកកាន់សំណាក់ខ្ញុំក្នុងរវាង ៧ រាត្រីវិញទេ ខ្ញុំសំគាល់ខ្លួនខ្ញុំថាអស់ជីវិត កាលបើខ្ញុំស្លាប់ហួសទៅហើយ ទើបអ្នកនឹងមកដល់។

[២២៦] (អភិសម្ពុទ្ធគាថា) លំដាប់នោះ មាធុរៈសុវបណ្ឌិតនោះ ក៏ហើរទៅប្រាប់មហោសធថា ពាក្យនេះ ជាពាក្យរបស់នាងសាលិកា។

[២២៧] (មហោសធ...) បុរសគប្បីបរិភោគនូវភោគសម្បត្តិក្នុងផ្ទះរបស់បុគ្គលណា គប្បីធ្វើប្រយោជន៍ដល់បុគ្គលនោះឯង។

[២២៨] បពិត្រព្រះជនិន្ទ ខ្ញុំព្រះអង្គនឹងសូមទៅកាន់បុរី គួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បំរុងព្រះអង្គមានយសធំក្នុងដែនវិទេហៈ។ បពិត្រក្សត្រិយ៍ លុះខ្ញុំព្រះអង្គសាងនិវេសន៍ដើម្បីព្រះអង្គមានយសធំ ក្នុងដែនវិទេហៈស្រេចហើយ នឹងបញ្ជូនទូតមកទូលព្រះអង្គក្នុងវេលាណា ព្រះអង្គគប្បីយាងទៅក្នុងវេលានោះ។

[២២៩] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះមហោសធ ក៏បានទៅកាន់បុរីគួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បំរុងព្រះបាទវិទេហៈមានយស។ ព្រះមហោសធលុះសាងនិវេសន៍ ដើម្បីព្រះបាទវិទេហៈមានយសស្រេចហើយ ទើបបញ្ជូនទូតមកទូលព្រះបាទវិទេហៈ គ្រប់គ្រងមិថិលាថា បពិត្រមហារាជ និវេសន៍ ខ្ញុំព្រះអង្គសាងដើម្បីព្រះអង្គហើយ សូមព្រះអង្គស្តេចមកក្នុងកាលឥឡូវនេះ។

[២៣០] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះរាជាព្រមដោយសេនាមានអង្គ ៤ យាងទៅដើម្បីទតបុរីដ៏ធំទូលាយ ដែលមហោសធបណ្ឌិតសាងទុកក្នុងដែនកប្បិលៈ មានពាហនៈមិនមានទីបំផុត។

[២៣១] លំដាបនោះឯង ព្រះបាទវិទេហៈនោះ លុះស្តេចយាងទៅដល់ (ដែនកប្បិលៈ) ហើយ ទើបបញ្ជូនរាជសាសន៍ទៅថ្វាយព្រះបាទចូឡនីព្រហ្មទត្តថា បពិត្រមហារាជ ខ្ញុំមកដើម្បីថ្វាយបង្គំព្រះបាទទាំងឡាយរបស់ព្រះអង្គ។ សូមព្រះអង្គទ្រង់ប្រទាននាងនារីដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការ ជាវិការៈនៃមាស មានពួកទាសីជាបរិវារ ឲ្យជាភរិយា (របស់ខ្ញុំ) ក្នុងកាលឥឡូវនេះ។

[២៣២] (ព្រះបាទចូឡនី...) បពិត្រព្រះបាទវិទេហៈ ព្រះអង្គស្តេចមកល្អហើយ មួយទៀត ព្រះអង្គស្តេចមកមិនអាក្រក់ទេ សូមព្រះអង្គសាកសួររកនក្ខត្តឫក្សចុះ ខ្ញុំនឹងថ្វាយនាងកញ្ញា ដ៏ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសី ជាបរិវារព្រះអង្គ។

[២៣៣] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះបាទវិទេហៈសួររកនក្ខត្តឫក្សលុះសួររកនក្ខត្តឫក្សរួចហើយ ទើបបញ្ជូនរាជសាសន៍

ទៅថ្វាយព្រះបាទព្រហ្មទត្តថា សូមព្រះអង្គទ្រង់ប្រទាននារីដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសីជាបរិវារ ឲ្យជាភរិយារបស់ខ្ញុំក្នុងកាលឥឡូវនេះ។

[២៣៤] (ព្រះបាទចូឡនី...) ខ្ញុំថ្វាយនាងនារី ដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសីជាបរិវារ ឲ្យជាភរិយារបស់ព្រះអង្គ ក្នុងកាលឥឡូវនេះ។

[២៣៥] (ព្រះបាទវិទេហៈ...) ពល់ដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែលឈរនៅ (ត្រៀបត្រា) គប់ភ្លើងឆេះសន្ធោសន្ធៅ តើពួកបណ្ឌិតសំគាល់ដូចម្ដេច។

[២៣៦] (អភិសម្ពុទ្ធគាថា) ពល់ដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែលឈរនៅ (ត្រៀបត្រា) គប់ភ្លើងឆេះសន្ធោសន្ធៅ នៃបណ្ឌិត ពួកសេនាទាំងនោះ នឹងធ្វើអ្វីហ្ន៎។

[២៣៧] (មហោសធ...) បពិត្រមហារាជ ព្រះបាទចូឡនីព្រហ្មទត្ត មានពលច្រើន ប្រទូសរ៉ាយដល់ព្រះអង្គ រក្សាព្រះអង្គទុក នឹងសំឡាប់ព្រះអង្គអំពីព្រឹក។

[២៣៨] (ព្រះបាទវិទេហៈ...) ហឫទ័យរបស់យើងញ័ររន្ធត់ ទាំងមាត់របស់យើងក៏សោះស្ងួត យើងមិនបានសេចក្ដីរលត់ ដូចជាឈើត្រូវភ្លើងឆេះក្នុងកណ្ដាលកំដៅថ្ងៃ។ ចង្ក្រានរបស់ជាងមាស ឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់យើងក៏ឆេះតែខាងក្នុង មិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ។

[២៣៩] (មហោសធ...) បពិត្រក្សត្រ ព្រះអង្គស្រវឹង (ដោយកាម) ទើបប្រព្រឹត្តកន្លងការប្រឹក្សា ទំលាយការប្រឹក្សាចោល ឥឡូវនេះ សូមឲ្យបណ្ឌិត (ទាំង ៤ នាក់) ដែលជាអ្នកមានប្រាជ្ញា រក្សាព្រះអង្គចុះ។ បពិត្រព្រះរាជា ព្រះអង្គមិនធ្វើតាមពាក្យរបស់ទូលបង្គំជាអាមាត្យ ជាអ្នកប្រាថ្នាសេចក្ដីចំរើន និងស្វែងរកប្រយោជន៍ ទ្រង់ត្រេកអរដោយបីតិដ៏សៅហ្មងរបស់ព្រះអង្គ ដូចម្រឹគជាប់អន្ទាក់។ (ទូលបង្គំបានក្រាបទូលហើយថា) ត្រីជាសត្វល្មោភក្នុងនុយស្រស់ លេបនូវផ្លែសន្ទូចដ៏វៀចដែលគេបិទដោយសាច់ ត្រីមិនដឹងសេចក្ដីស្លាប់របស់ខ្លួនយ៉ាងណា។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកល្មោភក្នុងកាម ចង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គ ដូចត្រីយ៉ាងនោះឯង។ បើទ្រង់ស្ដេចទៅកាន់ក្រុងបញ្ចាល ទ្រង់មុខជានឹងលះចោលព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគ ដែលដើរទៅតាមផ្លូវ (ទៀបទ្វារនៃស្រុក)។ បពិត្រព្រះជនិន្ទ បុរសមានសភាពមិនថ្លៃថ្នូរ ដូចពស់នៅក្នុងថ្នក់ គប្បីចឹកបុរសមានប្រាជ្ញា មិនគប្បីធ្វើនូវមេត្រីភាពដោយបុរស់នោះទេ ព្រោះថា ការគប់រកដោយបុរសអាក្រក់ រមែងនាំមកនូវសេចក្ដីទុក្ខដោយពិត។ បពិត្រព្រះជនិន្ទ បណ្ឌិតបុរស ស្គាល់នូវបុគ្គលណាថា អ្នកនេះមានសីល មានការចេះដឹងច្រើនដូច្នេះ បណ្ឌិតបុរសនោះ គួរធ្វើមេត្រីភាពជាមួយនឹងបុគ្គលនោះ ព្រោះថាការសេពគប់ដោយសប្បុរសទាំងឡាយ រមែងនាំមកនូវសេចក្ដីសុខពិត។

[២៤០] បពិត្រព្រះរាជា ព្រះអង្គជាមនុស្សល្ងង់លីលា បានពោលនូវសេចក្ដីចំរើនដ៏ឧត្ដមក្នុងសំណាក់នៃខ្ញុំព្រះអង្គថា ខ្ញុំព្រះអង្គជាអ្នកចំរើនដោយចុងនង្គ័ល ធ្វើម្ដេចនឹងដឹងសេចក្ដីចំរើនដូចអ្នកដទៃ។ អ្នកទាំងឡាយ ចូរចាប់មហោសធនេះត្រង់ក ហើយឲ្យវិនាសចាកដែនរបស់អញចេញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបានស្រីកែវ។

[២៤១] (ព្រះបាទវិទេហៈ...) ម្នាលមហោសធ បណ្ឌិតទាំងឡាយ រមែងមិនចាក់ដោតដោយទោសដែលកន្លងទៅហើយទេ អ្នកចាក់ដោតយើង ដូចគេយកជន្លួញចាក់សេះដែលចងទុកហើយធ្វើអ្វី។ ប្រសិនបើអ្នកឃើញសេចក្ដីរួចរបស់យើង ឬឃើញសេចក្ដីក្សេមរបស់យើង ចូរអ្នកពន្យល់យើងដោយសោត្ថិភាពនោះចុះ អ្នកចាំបាច់ចាក់ដោតយើងដោយទោសដែលកន្លងទៅហើយធ្វើអ្វី។

[២៤២] (មហោសធ...) អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ ខ្ញុំព្រះអង្គមិនអាចនឹងដោះព្រះអង្គបានទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ជ្រាបចុះ។ ដំរីទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន ដំរីបែបនោះរបស់ព្រះរាជាណា សូមឲ្យដំរីទាំងនោះ នាំព្រះរាជានោះទៅចុះ។ សេះទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន សេះបែបនោះរបស់ព្រះរាជាណា សូមឲ្យសេះទាំងនោះ នាំព្រះរាជានោះទៅចុះ។ បក្សីទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន បក្សីបែបនោះរបស់ព្រះរាជាណា សូមឲ្យបក្សីទាំងនោះ នាំព្រះរាជានោះទៅចុះ។ យក្សទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន យក្សបែបនោះរបស់ព្រះរាជាណា សូមឲ្យយក្សទាំងនោះ នាំព្រះរាជានោះទៅចុះ។ អំពើជារបស់នៃមនុស្ស ដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ បពិត្រក្សត្រិយ៍ ខ្ញុំព្រះអង្គមិនអាចដោះព្រះអង្គទៅតាមអាកាសបានទេ។

[២៤៣] (អាចារ្យសេនកៈ...) បុរសជាអ្នកមិនឃើញត្រើយក្នុងមហាសមុទ្រ បុរសនោះបានទីពំនាក់ក្នុងប្រទេសណា គេក៏បានសេចក្ដីសុខក្នុងប្រទេសនោះ (យ៉ាងណាមិញ)។ បពិត្រមហោសធ អ្នកជាទីពឹងរបស់ពួកយើង និងព្រះរាជា ក៏យ៉ាងនោះដែរ ព្រោះអ្នកជាបុគ្គលប្រសើរជាងពួកយើង និងពួកមន្ត្រី សូមអ្នកដោះពួកយើងអំពីទុក្ខ។

[២៤៤] (មហោសធ...) អំពើជារបស់នៃមនុស្ស ដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ ខ្ញុំមិនអាចនឹងដោះអ្នកបានទេ នៃសេនកៈ អ្នកចូរដឹងចុះ។

[២៤៥] (ព្រះបាទវិទេហៈ...) អ្នកចូរស្ដាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ (ស្រាប់ហើយ) ម្នាលអាចារ្យសេនកៈ ឥឡូវនេះអញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្ដេចក្នុងរឿងនេះ។

[២៤៦] (អាចារ្យសេនកៈ...) ពួកយើងគួរដុតភ្លើងត្រង់ទ្វារ ឬកាន់កាំបិតសម្លាប់គ្នានឹងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើងឲ្យលំបាកអស់កាលយូរឡើយ។

[២៤៧] (ព្រះបាទវិទេហៈ...) អ្នកចូរស្ដាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ (ស្រាប់ហើយ) ម្នាលអាចារ្យបុក្កុសៈ ឥឡូវនេះអញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្ដេចក្នុងរឿងនេះ។

[២៤៨] (អាចារ្យបុក្កុសៈ...) ពួកយើងគួរស៊ីថ្នាំពិសឲ្យស្លាប់ នឹងលះបង់ជីវិតយ៉ាងឆាប់ កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើង ឲ្យលំបាកអស់កាលយូរឡើយ។

[២៤៩] (ព្រះបាទវិទេហៈ...) អ្នកចូរស្ដាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ (ស្រាប់ហើយ) ម្នាលអាចារ្យកាមិន្ទៈ ឥឡូវនេះអញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្ដេចក្នុងរឿងនេះ។

[២៥០] (អាចារ្យកាមិន្ទៈ...) ពួកយើងគប្បីយកខ្សែចងឲ្យស្លាប់ ឬលោតចុះទៅក្នុងអណ្តូង (ឲ្យស្លាប់) កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើងឲ្យលំបាកអស់កាលយូរឡើយ។

[២៥១] (ព្រះបាទវិទេហៈ...) អ្នកចូរស្តាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ (ស្រាប់ហើយ) ម្នាលអាចារ្យទេវិន្ទៈ ឥឡូវនេះអញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្តេច ក្នុងរឿងនេះ។

[២៥២] (អាចារ្យទេវិន្ទៈ...) ពួកយើង (បិទទ្វារ) ដុតភ្លើង ហើយកាន់កាំបិតសម្លាប់គ្នាងនឹងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ (បើ) មហោសធមិនអាចនឹងដោះពួកយើងឲ្យរួចដោយងាយទេ។

[២៥៣] (ព្រះបាទវិទេហៈ...) បុគ្គលស្វែងរកខ្លឹមនៃដើមចេក រមែងមិនបានយ៉ាងណាមិញ យើងស្វែងរក (ឧបាយជាគ្រឿងរួចចាកទុក្ខ) ក៏មិនបានប្រស្នានោះ ក៏យ៉ាងនោះដែរ។ បុគ្គលស្វែងរកខ្លឹមនៃដើមរកា រមែងមិនបាន យ៉ាងណាមិញ យើងស្វែងរក ក៏មិនបានប្រស្នានោះ ក៏យ៉ាងនោះដែរ។ ការនៅនៃដំរីទាំងឡាយ ក្នុងទីមិនមានទឹក ឈ្មោះថានៅក្នុងទីមិនមែនប្រទេស (យ៉ាងណាមិញ) កាលបើយើងនៅក្នុងទីជិតនៃពួកមនុស្សអាក្រក់ល្ងង់ខ្លៅ មិនចេះ មិនដឹង (ឈ្មោះថានៅក្នុងទីមិនមែនជាប្រទេស ក៏ដូច្នោះឯង)។ ហ្ឫទ័យរបស់យើងញ័ររន្ធត់ ទាំងមាត់របស់យើងក៏សោះស្ងួត យើងមិនបានសេចក្តីរលត់ ដូចឈើត្រូវភ្លើងឆេះក្នុងកណ្តាលកំដៅថ្ងៃ។ ចង្ក្រានរបស់ជាងមាសឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហ្ឫទ័យរបស់យើង ឆេះតែខាងក្នុង មិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ។

[២៥៤] (អភិសម្ពុទ្ធគាថា...) វេលានោះ មហោសធជាអ្នកប្រាជ្ញ មានប្រាជ្ញា ឃើញប្រយោជន៍ជាប្រក្រតីនោះ បានឃើញព្រះបាទវិទេហៈទ្រង់មានសេចក្តីទុក្ខ ទើបក្រាបបង្គំទូលថា បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះចន្ទ្រដែលរាហូចាប់ហើយ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះអាទិត្យដែលរាហូចាប់ហើយ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះដំរីផុងក្នុងភក់។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះពស់ដែលជាប់នៅក្នុងកំប្រោង។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះបក្សីដែលជាប់នៅក្នុងទ្រុង។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះត្រីទាំងឡាយដែលជាប់នៅក្នុងសំណាញ់។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គចេញ ព្រមទាំងយានវាហនៈពល និងពាហនៈ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដេញព្រះបាទបញ្ចាលឲ្យរត់ទៅ ដូចជាគេដេញក្អែក និងខ្លែងដោយដុំដី។ បុគ្គលណា មិនជួយព្រះអង្គដែលមានសេចក្តីចង្អៀត (ព្រោះមរណៈ) ឲ្យរួចចាកទុក្ខបានទេ ប្រាជ្ញា (របស់បុគ្គលនោះ) មានប្រយោជន៍អ្វី ឬអាមាត្យបែបនោះ (មានប្រយោជន៍អ្វី)។

[២៥៥] នៃមាណពទាំងឡាយ អ្នកទាំងឡាយចូរមក ចូរក្រោកឡើង អ្នកទាំងឡាយ ចូរបើកមាត់នៃគន្លឹះយន្ត ព្រះបាទវិទេហៈ មួយអន្លើដោយពួកអាមាត្យ នឹងស្តេចទៅតាមឧម្មង្គ។

[២៥៦] ពួកជនអ្នកធ្វើការបំរើរបស់មហោសធបណ្ឌិត ស្តាប់ពាក្យរបស់លោកហើយ ទើបបើកទ្វារនៃឧម្មង្គ និងគន្លឹះទ្វារដែលប្រកបដោយគ្រឿងយន្ត។

[២៥៧] អាចារ្យសេនកៈដើរមុន មហោសធដើរក្រោយ ព្រះបាទវិទេហៈ មានអាមាត្យហែហម ស្តេចយាងត្រង់កណ្តាល។

[២៥៨] ព្រះបាទវិទេហៈ ស្តេចទ្រង់ចេញអំពីឧម្មង្គ ហើយឡើងគង់លើព្រះទីនាំងនាវា មហោសធដឹងថា ព្រះរាជាឡើងគង់ហើយ ក៏ប្រៀនប្រដៅថា បពិត្រព្រះសម្មតិទេព ព្រះបាទចូឡនីព្រហ្មទត្តនេះ ជាព្រះបិតាក្មេករបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងជន ព្រះនាងនន្ទាទេវីនេះ ជាព្រះមាតាក្មេករបស់ព្រះអង្គ ការប្រតិបត្តិព្រះវររាជមាតា (របស់ព្រះអង្គ) យ៉ាងណា ការប្រតិបត្តិព្រះមាតាក្មេក ចូរមានដល់ព្រះអង្គ ក៏យ៉ាងនោះដែរ។ ព្រះរាជបុត្តច្បងរួមឧទរ មានព្រះមាតាជាមួយគ្នា យ៉ាងណា បពិត្រព្រះអង្គប្រសើរលើរថ បញ្ចាលចន្ទរាជកុមារ ព្រះអង្គគប្បីស្រឡាញ់យ៉ាងនោះដែរ។ បពិត្រព្រះអង្គប្រសើរលើរថ ព្រះនាងបញ្ចាលចន្ទីទេវីនេះ ជាព្រះរាជបុត្រី (របស់ព្រះបាទចូឡនីព្រហ្មទត្ត) ដែលព្រះអង្គទ្រង់ប្រាថ្នា សូមព្រះអង្គធ្វើសេចក្តីប្រាថ្នារបស់ព្រះអង្គចំពោះព្រះនាងនោះ ព្រះនាងជាភរិយារបស់ព្រះអង្គហើយ។

[២៥៩] (ព្រះបាទវិទេហៈ...) ម្នាលមហោសធ អ្នកចូរប្រញាប់ប្រញាល់ឡើងជិះទូកមក នៅឈរលើច្រាំងធ្វើអ្វី យើងទាំងឡាយរួចចាកទុក្ខដោយលំបាក យើងនឹងទៅឥឡូវនេះ។

[២៦០] (មហោសធ...) បពិត្រមហារាជ ខ្ញុំព្រះអង្គដែលជានាយកនៃសេនា លះបង់ចោលនូវអង្គនៃសេនា ហើយដោះយកតែខ្លួន នេះមិនមែនជាទំនៀមទេ។ បពិត្រព្រះសម្មតិទេពប្រសើរលើរថ ខ្ញុំព្រះអង្គនឹងដឹកនាំនូវអង្គនៃសេនាដែលព្រះអង្គបោះបង់ចោលក្នុងរាជនិវេសន៍ និងរបស់ដែលព្រះបាទព្រហ្មទត្តថ្វាយហើយ។

[២៦១] (ព្រះបាទវិទេហៈ...) ម្នាលបណ្ឌិត អ្នកឯងជាអ្នកមានសេនាតិច នឹងសង្កត់សង្កិនទប់ទល់ព្រះបាទចូឡនីព្រហ្មទត្ត ដែលមានសេនាច្រើនដូចម្តេចបាន អ្នកឯងជាអ្នកមានកម្លាំងខ្សោយ មុខជាលំបាកដោយព្រះបាទចូឡនីព្រហ្មទត្តដែលមានកម្លាំង។

[២៦២] (ពោធិសត្វ...) បុគ្គលមានប្រាជ្ញា សូម្បីមានសេនាតិច រមែងឈ្នះបុគ្គលមិនមានប្រាជ្ញា ដែលមានសេនាច្រើន ព្រះរាជាតែមួយព្រះអង្គ (ជាអ្នកឈ្លាសក្នុងឧបាយ) រមែងឈ្នះព្រះរាជាទាំងឡាយ (ជាអ្នកល្ងង់ក្នុងឧបាយ) ដូចព្រះអាទិត្យ ដែលរះឡើង (រមែងឈ្នះ) ងងឹតដូច្នោះឯង។

[២៦៣] (ព្រះបាទវិទេហៈ...) នៃអាចារ្យសេនកៈ ការនៅរួមជាមួយនឹងពួកបណ្ឌិត នាំមកនូវសេចក្តីសុខស្រួលណាស់ហ្ន៎ ព្រោះថាមហោសធ បានដោះពួកយើង ដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រី ដែលជាប់នៅក្នុងសំណាញ់ដូច្នោះ។

[២៦៤] (អាចារ្យសេនកៈ...) បពិត្រមហារាជ ពិតមែនហើយ បណ្ឌិតទាំងឡាយ នាំមកនូវសេចក្តីសុខយ៉ាងនោះឯង មហោសធបានដោះពួកយើងដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រី ដែលជាប់នៅក្នុងសំណាញ់ដូច្នោះ។

[២៦៥] (អភិសម្ពុទ្ធគាថា) ព្រះបាទចូឡនីព្រហ្មទត្ត មានកំឡាំងច្រើន ទ្រង់រក្សាអស់រាត្រីទាំងមូល កាលអរុណរះឡើង ក៏ស្តេចចូលទៅ

ដល់ក្រុងឧបការៈ។ ព្រះបាទចូឡនីគ្រប់គ្រងក្រុងបញ្ចាល មានកំឡាំងច្រើន ស្តេចឡើងគង់លើដំរីប្រសើរដ៏មានកំឡាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ បានត្រាស់ទៅ (នឹងសេនារបស់ព្រះអង្គ)។ ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់សៀតគ្រឿងក្រោះ ជាវិការៈនៃកែវមណី ព្រះហស្តចាប់សរ បានត្រាស់ទៅនឹងរេហ៍ពលអ្នកទទួលបំរើ (របស់ព្រះអង្គ) ជាអ្នកមានសិល្បច្រើនដែលមកចួបជុំគ្នា។ (ព្រះបាទចូឡនីត្រាស់ទៅ) នឹងពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងខ្មាន់ធ្នូ ដែលមានដៃដ៏ស្ទាត់ក្នុងសិល្បធ្នូ អាចបាញ់រោមត្រូវ ដែលមកចួបជុំគ្នា។

[២៦៦] (ព្រះបាទចូឡនី...) អ្នកទាំងឡាយ ចូរបញ្ជូនដំរីមានភ្លុក ដ៏មានកំឡាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ ចូរឲ្យដំរីទាំងឡាយញាំញីទីក្រុងដែលព្រះបាទវិទេហៈ សាងទុកហើយ។ (ពួកព្រួញ) មានសម្បុរ ស មានមុខដូចពន្លាក មានចុងដ៏មុត អាចចាក់ទំលាយនូវឆ្អឹង ដែលបាញ់ដោយកំឡាំងធ្នូ ឲ្យធ្លាក់ចុះព្រមគ្នា អំពីខាងនេះខាងនោះ។ ពួកសេនាក្មេង ៗ ក្លៀវក្លា ពាក់គ្រឿងក្រោះ មានអាវុធប្រកបដោយដងដ៏វិចិត្រ កាលបើពួកដំរីធំស្ទុះចូលមក ចូរអ្នកនាំគ្នា (តស៊ូ) ចំពោះមុខដំរីទាំងឡាយ។ លំពែងទាំងឡាយ ដែលគេលាងជម្រះដោយប្រេង មានរស្មីភ្លឺផ្លេក រុងរឿងដូចជាផ្កាយព្រឹក មានរស្មីច្រើន។ កាលបើពួកយោធា (របស់យើង) មានគ្រឿងអាវុធជាកំឡាំង ទ្រទ្រង់សង្វារ គឺគ្រឿងក្រោះប្រាកដដូច្នេះ មិនបានរត់ក្នុងសង្គ្រាមទេ ព្រះបាទវិទេហៈនឹងរួចពីដៃយើងអំពីណា បើក្រែងតែព្រះបាទវិទេហៈនឹងធ្វើដូចបក្សី (ទើបរួច)។ ពួកយោធារបស់យើងទាំងអស់ មានចំនួន ៣៩.០០០ នាក់ អាចកាត់ក្បាលសត្រូវ ហើយរើសយកក្បាលមួយ ៗ មក យើងបានដើរសព្វលើផែនដី មិនឃើញពួកយោធាណាស្មើឡើយ។ ដំរីទាំងឡាយ មានភ្លុក ប្រដាប់ហើយ មានកំឡាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ ពួកយោធានៅក្មេងៗ មានសម្បុរដូចមាស រមែងល្អលើ កនៃដំរីទាំងឡាយ។ យោធាទាំងឡាយ មានគ្រឿងអលង្ការមានពណ៌លឿង ស្លៀកសំពត់មានពណ៌លឿង ដណ្តប់សំពត់មានពណ៌លឿង រមែងល្អលើ-កនៃដំរីទាំងឡាយ ដូចទេវបុត្តទាំងឡាយក្នុងនន្ទវ័ន។ ព្រះខាន់ទាំងឡាយ មានសម្បុរដូចត្រីស្លាត ដែលលាងជំរះដោយប្រេង មានរស្មីភ្លឺផ្លេកដែលបុរសអ្នកមានព្យាយាមធ្វើសម្រេចហើយ មានមុខស្មើ ដែលគេសម្លៀងល្អហើយ។ ព្រះខាន់ទាំងឡាយមិនមានស្និម រុងរឿងដូចជាព្រះអាទិត្យ ឋិតនៅក្នុងទីពាក់កណ្តាល ដែលគេធ្វើដោយដែកថែបដ៏មាំ ដែលពួកយោធាអ្នកមានកំឡាំងជំនាញក្នុងវិធីប្រហារមាំ កាន់យកហើយ។ ព្រះខាន់ទាំងឡាយ បរិបូណ៌ដោយដងជាវិការៈនៃមាស ទ្រទ្រង់ដោយស្រោមមានពណ៌ក្រហម កាលបើគេគ្រវីឡើង រមែងល្អដូចជាផ្លេកបន្ទោរភ្លឺផ្លេកក្នុងចន្លោះនៃពពក។ ពួកខ្មាន់ធ្នូអ្នកក្លៀវក្លា ពាក់គ្រឿងក្រោះ អាចប្រព្រឹត្តទៅក្នុងអាកាសបាន អ្នកឈ្លាសក្នុងការកាន់ដាវ និងខែល ជាអ្នកហាត់ក្នុងការកាន់ធ្នូដ៏ក្រៃលែង អាចកាត់នូវកនៃដំរីឲ្យធ្លាក់ចុះបាន។ អ្នកឯងត្រូវពួកយោធាប្រាកដដូច្នេះ ព័ទ្ធហើយ អ្នកឯងមិនរួចអំពីទីនេះទេ អ្នកនឹងទៅកាន់ក្រុងមិថិលា ដោយរាជានុភាពណា យើងមិនបានឃើញរាជានុភាពនោះរបស់អ្នកទេ។

[២៦៧] (ព្រះពោធិសត្វ...) ព្រះអង្គទ្រង់ប្រញាប់ប្រញាល់បញ្ជូនដំរីដ៏ប្រសើរមក ព្រះអង្គមានព្រះហឫទ័យរីករាយយាងមក ហើយទ្រង់សំគាល់ថា អាត្មាអញ នឹងបានសម្រេចប្រយោជន៍ដូច្នេះឬហ្ន៎។ សូមព្រះអង្គដាក់ធ្នូ និងបំពង់ព្រួញនុ៎ះចេញ សូមព្រះអង្គដាក់កូនសរនុ៎ះចេញ សូមព្រះអង្គដាក់គ្រឿងក្រោះដ៏ល្អប្រហែលដោយកែវពៃទូរ្យ និងកែវមណីនុ៎ះចេញ។

[២៦៨] (ព្រះបាទចូឡនី...) អ្នកឯងជាអ្នកមានសម្បុរមុខស្រស់បស់ ទាំងនិយាយ ក៏ញញឹមញញែមជាប់ ឯការបរិបូណ៌ដោយសម្បុរបែបនេះ រមែងមានប្រាកដក្នុងមរណកាល។

[២៦៩] (មហោសធ...) បពិត្រក្សត្រជាព្រះរាជា ពាក្យដែលព្រះអង្គគម្រាមហើយ ជាពាក្យសោះសូន្យទទេ ព្រះអង្គមានការប្រឹក្សាធ្លាយហើយ ឯព្រះរាជា (របស់យើង) ព្រះអង្គមិនងាយនឹងចាប់យកបានទេ ដូចសេះសិន្ធព និងសេះខ្ទក។ ព្រះរាជា (ក្រុងមិថិលា) ព្រមដោយអាមាត្យ និងរាជបរិស័ទ ឆ្លងស្ទឹងគង្គាតាំងពីថ្ងៃម្សិលទៅហើយម្ល៉េះ ក្អែកស្ទុះតាមរាជហង្ស នឹងធ្លាក់ចុះក្នុងពាក់កណ្តាលផ្លូវ យ៉ាងណាមិញ (បើព្រះអង្គនឹងតាមព្រះរាជានោះ នឹងដល់សេចក្តីវិនាសក្នុងពាក់កណ្តាលផ្លូវ ក៏យ៉ាងនោះដែរ)។

[២៧០] ឆ្កែចចកទាំងឡាយជាម្រឹគថោកទាប ឃើញផ្កាចារដែលរីកក្នុងចំណែកនៃរាត្រី ក៏សំគាល់ថា ដុំសាច់ ហើយនាំគ្នាចោមរោម។ (ឆ្កែចចកទាំងនោះ) ជាម្រឹគថោកទាប កាលបើរាត្រីកន្លងទៅហើយ ព្រះអាទិត្យក៏រះឡើង ទើបឃើញច្បាស់ថា ជាផ្កាចារីក ក៏ដាច់សេចក្តីប្រាថ្នា (រត់ទៅ) យ៉ាងណា។ បពិត្រព្រះរាជា ព្រះអង្គចោមព័ទ្ធព្រះបាទវិទេហៈ នឹងដាច់សេចក្តីប្រាថ្នា ហើយទៅ ដូចពួកឆ្កែចចក (ចោមរោម) នូវផ្កាចាដូច្នោះដែរ។

[២៧១] (ព្រះបាទចូឡនី...) អ្នកទាំងឡាយ ចូរកាត់ដៃ និងជើង ត្រចៀក និងច្រមុះនៃមហោសធនេះ ព្រោះវាធ្វើព្រះបាទវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្តាប់ដៃយើងឲ្យរួចទៅវិញ។ សេនាទាំងឡាយ ចូរដោតគហបតីបុត្រនេះដោយឈើស្រួច ហើយចំអិនវា ដូចគេចំអិនសាច់ដែលគួរចំអិន ព្រោះវាធ្វើស្តេចវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្តាប់ដៃយើងឲ្យរួចទៅវិញ។ បុគ្គលដោតសន្ទឹងស្បែកគោលើផែនដី ពុំនោះសោត ថ្គក់ស្បែកសីហៈ ឬខ្លាធំដោយកង្វេរ យ៉ាងណា។ យើងនឹងចាក់ដោតវាដោយលំពែង យ៉ាងនោះ ព្រោះវាធ្វើព្រះបាទវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្តាប់ដៃយើងឲ្យរួចទៅវិញ។

[២៧២] (មហោសធ...) បើព្រះអង្គកាត់នូវដៃ ជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (ដៃ ជើង ត្រចៀក និងច្រមុះ) របស់ព្រះរាជបុត្រឈ្មោះបញ្ចាលចន្ទៈ យ៉ាងហ្នឹងដែរ។ បើព្រះអង្គកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (នូវដៃ ជើង ត្រចៀក និងច្រមុះ) របស់ព្រះរាជធីតាឈ្មោះបញ្ចាលចន្ទី យ៉ាងហ្នឹងដែរ។ បើព្រះអង្គកាត់ដៃ និងជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (នូវដៃជើង ត្រចៀក និងច្រមុះ) របស់អគ្គមហេសី ឈ្មោះនន្ទាទេវី យ៉ាងហ្នឹងដែរ។ បើព្រះអង្គកាត់ដៃ និងជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (នូវដៃ និងជើង ត្រចៀក និងច្រមុះ) របស់ព្រះរាជបុត្រ និងព្រះមហេសីរបស់ព្រះអង្គយ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតខ្ញុំដោយឈើអណ្តោត ហើយចំអិន ដូចគេចំអិនសាច់ដែលគួរចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជបុត្រឈ្មោះបញ្ចាលចន្ទៈ (ដោយឈើអណ្តោត) ហើយចំអិនយ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតខ្ញុំដោយឈើអណ្តោត ហើយចំអិន ដូចគេចំអិនសាច់ដែលគួរចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជធីតា ឈ្មោះបញ្ចាលចន្ទី (ដោយឈើអណ្តាត) ហើយចំអិនយ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្តោត ហើយចំអិន ដូចគេចំអិនសាច់ដែលគួរចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតអគ្គមហេសីឈ្មោះនន្ទាទេវី (ដោយឈើអណ្តោត) ហើយចំអិនយ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្តោត ហើយចំអិន ដូចគេចំអិនសាច់ដែលគួរចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជបុត្រ និងព្រះមហេសីរបស់ព្រះអង្គ (ដោយឈើអណ្តោត) ហើយចំអិនយ៉ាងហ្នឹងដែរ។ បើព្រះអង្គចាក់ដោតខ្ញុំ ដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងដោតព្រះរាជបុត្រ ឈ្មោះបញ្ចាលចន្ទៈ (ដោយលំពែង) យ៉ាងហ្នឹងដែរ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតព្រះរាជធីតា ឈ្មោះបញ្ចាលចន្ទី (ដោយលំពែង) យ៉ាងនោះដែរ។ បើព្រះអង្គចាក់ដោតខ្ញុំ ដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតអគ្គមហេសី ឈ្មោះនន្ទាទេវី (ដោយលំពែង) យ៉ាងនោះដែរ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតព្រះរាជបុត្រ និងព្រះមហេសីរបស់ព្រះអង្គ (ដោយលំពែង) យ៉ាងនោះដែរ។ យើងទាំងពីរនាក់ គឺស្តេចវិទេហៈ និងទូលព្រះបង្គំជាខ្ញុំ ប្រឹក្សាគ្នារួចស្រេចក្នុងទីស្ងាត់យ៉ាងនេះហើយ ខែលស្បែកមានទម្ងន់ ១០០ បលៈ ដែលជាងស្បែកឲ្យសម្រេចហើយដោយសស្ត្រារបស់ជាងស្បែក រមែងជួយការពារខ្លួន ដើម្បីទប់រងនូវកូនសរទាំងឡាយយ៉ាងណា។ ទូលព្រះបង្គំជាខ្ញុំជាអ្នកនាំសេចក្តីសុខមក ជួយបន្ទោបង់សេចក្តីទុក្ខនៃព្រះបាទវិទេហៈដ៏មានយស តែងទប់រងនូវកូនសរ គឺព្រះតម្រិះរបស់ព្រះអង្គដោយខែលស្បែកមានទម្ងន់ ១០០ បលៈ (សេចក្តីគិតរបស់ទូលព្រះបង្គំជាខ្ញុំ ក៏ដូច្នោះឯង)។

[២៧៣] បពិត្រមហារាជ សូមអញ្ជើញព្រះអង្គទតព្រះនេត្រមើលព្រះរាជវាំងរបស់ព្រះអង្គដែលសូន្យឈឹងចុះ បពិត្រព្រះមហាក្សត្រិយ៍ ស្រីស្នំ និងកុមារទាំងឡាយ និងព្រះវររាជមាតារបស់ព្រះអង្គ ខ្ញុំឲ្យនាំចេញចាកឧម្មង្គ នាំទៅថ្វាយព្រះបាទវិទេហៈហើយ។

[២៧៤] (ព្រះបាទចូឡនី...) បើដូច្នោះ អ្នកទាំងឡាយ ចូរទៅឯព្រះរាជវាំងរបស់អញ ហើយពិចារណាមើលហេតុនោះ តើសមដូចពាក្យរបស់មហោសធនេះពិត ឬកុហកទេ។

[២៧៥] (ពួកអាមាត្យ...) បពិត្រមហារាជ មហោសធទូលយ៉ាងណា សេចក្ដីនុ៎ះ ក៏យ៉ាងនោះឯង ព្រះរាជវាំងទាំងមូលសូន្យឈឹង ដូចឋានជាទីប្រជុំចុះនៃពួកក្អែក។

[២៧៦] (មហោសធ...) បពិត្រមហារាជ ព្រះនាងនារីនន្ទាទេវី ព្រះសព៌ាង្គកាយដ៏ល្អ មានព្រះសោណីដ៏ល្អ ដូចដម្បារមាស មានប្រក្រតីពោលពាក្យពីរោះ ដូចជាសំឡេងនៃហង្ស បានចេញទៅអំពីឧម្មង្គនេះហើយ។ បពិត្រមហារាជ ព្រះនាងនារី មានសព៌ាង្គកាយដ៏ល្អ ទ្រទ្រង់កោសេយ្យពស្ត្រ មានសរីរៈដូចមាស មានខ្សែរឹតព្រះអង្គនោះក៏ល្អវិចិត្រដោយមាស។ ព្រះនាងនារី មានព្រះបាទដ៏ក្រហមល្អ ប្រកបដោយលំអ (៥យ៉ាង) មានខ្សែរឹតជាវិការៈនៃមាស និងកែវមណី មានដួងព្រះនេត្រប្រាកដស្មើដោយភ្នែកសត្វព្រាប មានសរីរៈដ៏ល្អ មានរឹមព្រះឱស្ឋរលើង ល្អដូចជាផ្លែទន្លាប់ មានចង្កេះរៀវ។ ព្រះនាងនារីមានចង្កេះរៀវដូចវល្លិនាគលតា ដែលលូតលាស់ល្អ ឬដូចក្តារហ៊ឹង (ជាវិការៈនៃមាស) ព្រះកេសរបស់ព្រះនាងនារីនោះ វែង មានចុងខ្មៅងបន្តិច ដូចចុងកំបិត។ ព្រះនាងនន្ទាទេវី មានដួងព្រះនេត្រថ្លាយង់ ដូចជាភ្នែកនៃកូនម្រឹគកើត (បានមួយខួប) ឬដូចជាអណ្តាតភ្លើងក្នុងហេមន្តរដូវ ពុំនោះសោត ដូចជាស្ទឹងដ៏ដេរដាសដោយដើមឫស្សីតូច ៗ ទាំងឡាយ ទៀបជ្រោះភ្នំ។ ព្រះនាងនន្ទាទេវី មានព្រះឧរុល្អ ដូចប្រមោយដំរី មានស្តនទាំងគូល្អដូចផ្លែទន្លាប់ដ៏ប្រសើរ មិនខ្ពស់ពេក មិនទាបពេក មិនមែនឥតព្រះលោមា មិនមែនមានព្រះលោមាច្រើនពេក។ បពិត្រព្រះអង្គមានពាហនៈបរិបូណ៌ដោយសិរី ព្រះអង្គត្រេកអរដោយមរណៈនៃព្រះនាងនន្ទាទេវីដោយពិត ឯខ្ញុំព្រះអង្គ និងព្រះនាងនន្ទា នឹងទៅកាន់សំណាក់យមរាជដោយពិត។

[២៧៧] (ព្រះបាទចូឡនី...) អ្នកបានរៀនកលមាយាជាទិព្វ ហើយបានធ្វើឧបាយបំបាំងភ្នែកឬ បានជាអ្នកដោះលែងព្រះបាទវិទេហៈ ជាសត្រូវនៅក្នុងកណ្តាប់ដៃនៃយើងបាន។

[២៧៨] (មហោសធ...) បពិត្រមហារាជ បណ្ឌិតទាំងឡាយក្នុងលោកនេះ រមែងរៀននូវកលមាយាជាទិព្វដោយពិត ពួកបណ្ឌិតជនអ្នកមានសេចក្ដីដឹងនោះ ទើបដោះខ្លួន (ចាកទុក្ខបាន) ពួកយោធាក្មេង ៗ អ្នកបំរើរបស់ទូលព្រះបង្គំជាអ្នកឈ្លាស ជាអ្នកកាត់ផ្តាច់នូវទីតព្រះបាទវិទេហៈយាងទៅកាន់ក្រុងមិថិលាតាមផ្លូវដែលពួកជនទាំងនេះធ្វើទុកហើយ។

[២៧៩] បពិត្រមហារាជ សូមព្រះអង្គស្តេចទតឧម្មង្គ ដែលពួកជាងសាងទុកល្អហើយ សូមព្រះអង្គទតឧម្មង្គដ៏ល្អរុងរឿង (ដោយរបៀប) នៃដំរី សេះ រថ និងពលថ្មើរជើង ដែលគេធ្វើឲ្យសម្រេចហើយដោយល្អ។

[២៨០] (ព្រះបាទចូឡនី...) ម្នាលមហោសធ ជាលាភរបស់អ្នកដែនវិទេហៈដោយពិត បណ្ឌិតទាំងឡាយបែបដូចជាអ្នកនេះ នៅក្នុងដំណាក់ ក្នុងដែនរបស់ព្រះរាជាណា (ជាលាភរបស់ព្រះរាជានោះពិត)។

[២៨១] យើងនឹងឲ្យគ្រឿងចិញ្ចឹមជីវិត និងវត្ថុ គ្រឿងរក្សា គឺស្រុក និងនិគម ទាំងបាយ និងថ្លៃឈ្នួលជាទ្វេគុណដល់អ្នក ទាំងឲ្យភោគសម្បទដ៏ធំទូលាយទៀត អ្នកចូរបរិភោគ ចូររីករាយតាមប្រាថ្នាចុះ អ្នកកុំទៅរកព្រះបាទវិទេហៈឡើយ ព្រះបាទវិទេហៈ នឹងធ្វើអ្វីដល់អ្នក។

[២៨២] (មហោសធ...) បពិត្រមហារាជ បុគ្គលណា លះបង់នូវបុគ្គលអ្នកចិញ្ចឹម ព្រោះហេតុនៃទ្រព្យ បុគ្គលនោះ ត្រូវជនទាំងពីរគឺខ្លួនឯង និងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈ ទ្រង់គង់ព្រះជន្មាយុដរាបណា ខ្ញុំក៏មិនគប្បីនៅក្នុងដែននៃព្រះរាជាដទៃ (ដរាបនោះ)។ បពិត្រមហារាជ បុគ្គលណា លះបង់នូវបុគ្គលអ្នកចិញ្ចឹម ព្រោះហេតុនៃទ្រព្យ បុគ្គលនោះត្រូវជនទាំងពីរគឺ ខ្លួនឯង និងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈ ទ្រង់បិតនៅដរាបណា ខ្ញុំមិនត្រូវជាបុរសរបស់បុគ្គលដទៃ (ដរាបនោះ)។

[២៨៣] (ព្រះបាទចូឡនី...) ម្នាលមហោសធ យើងឲ្យមាសឆ្តោរ ១០០០ និងស្រុក ចំនួន ៨០ ក្នុងដែនកាសីដល់អ្នក យើងឲ្យទាសី ៤០០ និងភរិយា ១០០ ដល់អ្នក អ្នកចូរនាំអង្គនៃសេនាទាំងពួងទៅដោយសួស្តីចុះ។

[២៨៤] ជនទាំងឡាយ ចូរឲ្យវត្ថុផ្សេងៗ ជាទ្វេគុណ ដល់ពួកដំរី ពួកសេះជាកំណត់ ចូរញ៉ាំងពលរថ និងពលថ្មើរជើងឲ្យឆ្អែតស្កប់ស្កល់ដោយបាយ និងទឹកចុះ។

[២៨៥] ម្នាលបណ្ឌិត អ្នកចូរនាំយកពួកដំរី ពួកសេះ ពួករថ និងពួកពលថ្មើរជើងទៅ ព្រះបាទវិទេហៈមហារាជ ចូរទតឃើញអ្នក ដែលទៅដល់ក្រុងមិថិលាចុះ។

[២៨៦] (ព្រះបាទវិទេហៈ...) សេនាប្រកបដោយអង្គ ៤ គឺសេនាដំរី សេនាសេះ សេនារថ និងសេនាថ្មើរជើងនោះ ប្រាកដជាមានច្រើន មានសភាពគួរខ្លាច តើបណ្ឌិតទាំងឡាយសំគាល់ដូចម្តេចហ្ន៎។

[២៨៧] (អាចារ្យសេនកៈ...) បពិត្រមហារាជ សេចក្ដីត្រេកអរយ៉ាងខ្ពង់ខ្ពស់ រមែងប្រាកដដល់ព្រះអង្គ មហោសធនាំយកអង្គនៃសេនាទាំងពួងមកដល់ហើយដោយសួស្តី។

[២៨៨] (ព្រះបាទវិទេហៈ...) ម្នាលមហោសធ ជនទាំង ៤ នាក់ នាំមនុស្សស្លាប់ទៅចោលក្នុងព្រៃស្មសាន (ហើយត្រឡប់មក) យ៉ាងណា ពួកយើងបោះបង់អ្នកចោល ក្នុងដែនគប្បីលះហើយ ត្រឡប់មកក្នុងទីនេះក៏ដូច្នោះ។ កាលបើដូច្នេះ អ្នកចេះដោះខ្លួនឲ្យរួចមក ដោយហេតុដូចម្តេច ដោយបច្ច័យដូចម្តេច ដោយដំណើរដូចម្តេច។

[២៨៩] (មហោសធ...) បពិត្រក្សត្រិយ៍ព្រះនាមវិទេហៈ ទូលព្រះបង្គំបានការពារនូវសេចក្ដីដោយសេចក្ដី នូវការប្រឹក្សាដោយប្រឹក្សា ទូលព្រះបង្គំបានការពារស្តេច ដូចជាសាគរការពារជម្ពូទ្វីបដូច្នោះ។ ព្រះបាទចូឡនី បានប្រទានមាសឆ្តោរ ១០០០ និងស្រុកចំនួន ៨០ ក្នុងដែនកាសីដល់ទូលព្រះបង្គំ ប្រទានទាសី ៤០០ និងភរិយា ១០០ ដល់ទូលព្រះបង្គំ ទូលព្រះបង្គំជាអ្នកនាំអង្គនៃសេនាទាំងពួង មកក្នុងទីនេះដោយសួស្តី។

[២៩០] (ព្រះបាទវិទេហៈ...) នៃអាចារ្យសេនកៈ ការនៅរួមជាមួយនឹងអ្នកប្រាជ្ញ នាំមកនូវសេក្តីសុខស្រួលណាស់ហ្ន៎ មហោសធបានដោះពួកយើងដែលតាំងនៅក្នុងសេចក្ដីវិនាស គឺដៃនៃសត្រូវ ដូចជាគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចជាគេដោះត្រីដែលជាប់នៅក្នុងសំណាញ់។

[២៩១] (អាចារ្យសេនកៈ...) បពិត្រមហារាជ មែនពិត ពួកបណ្ឌិតរមែងនាំមកនូវសេចក្តីសុខយ៉ាងនេះឯង មហោសធ បានដោះពួកយើង ដែលតាំងនៅក្នុងសេចក្តីវិនាស គឺដៃនៃសត្រូវ ដូចជាគេដោះហ្វូងបក្សីដែលជាប់ក្នុងទ្រុង ឬដូចជាគេដោះត្រីដែលជាប់ក្នុងសំណាញ់។

[២៩២] (អភិសម្ពុទ្ធគាថា...) ពួកជនចូរដេញពិណ ចូរវាយស្គរតូច និងស្គរធំ ផ្លុំស័ង្ខដែលកើតក្នុងដែនមគធៈ និងទូងស្គរធំមានសំឡេងពីរោះ។

[២៩៣] ពួកស្រីស្នំ ពួកកុមារ ពួកវេស្សៈ និងពួកព្រាហ្មណ៍ នាំបាយ និងទឹកជាច្រើន មកជូន (មហោសធបណ្ឌិត)។ ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង នាំបាយ និងទឹកជាច្រើន មកជូនបណ្ឌិត។ ពួកអ្នកជនបទ ប្រជុំគ្នា ទាំងពួកអ្នកនិគម ក៏មកប្រជុំគ្នា នាំបាយ និងទឹកជាច្រើន មកជូនបណ្ឌិត។ ជនជាច្រើន កាលបើបានឃើញបណ្ឌិតមកដល់ហើយ ក៏មានសេចក្តីជ្រះថ្លា កាលបើបណ្ឌិតមកដល់ហើយ ការលើកឡើងនូវទង់ ក៏ប្រព្រឹត្តទៅ។

ចប់ មហោសធជាតក ទី៥។

## ភូរិទត្តជាតក ទី៦

CS sut.kn.jat.543 | ភាគទី ៦២

### (៥៤៣. ភូរិទត្តជាតកំ (៦))

[២៩៤] (នាគទាំង ៤ ក្រាបបង្គំទូលថា) រតនៈណាមួយ មានក្នុងនិវេសន៍របស់នាគរាជព្រះនាមធតរដ្ឋ រតនៈទាំងអស់នោះ ចូរមកដល់ព្រះអង្គ សូមព្រះអង្គទ្រង់ប្រទានធីតាដល់ព្រះរាជាយើង។

[២៩៥] (ព្រះបាទព្រហ្មទត្តត្រាស់ថា) វិវាហៈជាមួយនឹងពួកនាគ យើងមិនធ្លាប់ធ្វើក្នុងកាលណាម្តងទេ យើងនឹងធ្វើវិវាហៈមិនសមគួរនោះ ដូចម្តេចកើត។

[២៩៦] (នាគទាំង ៤...) បពិត្រព្រះអង្គជាធំជាងមនុស្ស ជីវិតក្តី ដែនក្តី ព្រះអង្គនឹងលះបង់ដោយពិត កាលបើនាគខឹងហើយ ព្រះរាជាទាំងឡាយប្រហែលនឹងព្រះអង្គ មិនគង់ព្រះជន្មនៅយូរទេ។ បពិត្រព្រះសម្មតិទេព ព្រះអង្គណាជាមនុស្ស ព្រះអង្គនោះ មិនមានឫទ្ធិ មើលងាយព្រះរាជាដែលមានឫទ្ធិ ជាកូនបង្កើតនៃព្រះបាទវរុណៈ ដែលកើតក្នុងទន្លេយមុនា។

[២៩៧] (ព្រះរាជា...) យើងមិនមើលងាយព្រះបាទធតរដ្ឋដ៏មានយសទេ ព្រោះថា ព្រះបាទធតរដ្ឋ ជាធំជាងនាគទាំងឡាយដ៏ច្រើន។ ពស់ទុកជាមានអានុភាពច្រើន ក៏មិនសមគួរនឹងធីតារបស់យើងទេ ចំណែកខាងយើង ជាក្សត្រិយ៍របស់អ្នកដែនវិទេហៈ ធីតា (របស់យើង) ឈ្មោះសមុទ្ទជា មានជាតិដ៏ប្រសើរ។

[២៩៨] (ព្រះបាទធតរដ្ឋ...) ពួកនាគឈ្មោះកម្ពលស្សតរា[50] ចូរក្រោកឡើង អ្នកចូរប្រាប់នាគទាំងអស់ថា នាគទាំងឡាយ ចូរទៅកាន់ក្រុងពារាណសី តែកុំបៀតបៀនបុគ្គលណាមួយឡើយ។

[២៩៩] នាគទាំងឡាយដែលមានសរីរៈធំ ចូរសំយុងខ្លួនក្នុងនិវេសនដ្ឋានទាំងឡាយ ក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុងឈើ និងលើក្លោងទ្វារ។ ចំណែកខាងខ្ញុំ មានកាយធំសសុទ្ធ នឹងព័ទ្ធបុរីដែលធំទូលាយ ដោយភ្នែនទាំងឡាយ នឹងញ៉ាំងភ័យឲ្យកើតឡើងដល់ពួកអ្នកដែនកាសី។

[៣០០] នាគទាំងឡាយ មានសម្បុរដ៏ច្រើន បានស្តាប់ពាក្យព្រះបាទធតរដ្ឋនោះហើយ ក៏ចូលទៅកាន់ក្រុងពារាណសី តែមិនបៀតបៀនបុគ្គលណាមួយឡើយ។ នាគទាំងឡាយដែលមានសរីរៈធំ ក៏សំយុងខ្លួនក្នុងនិវេសនដ្ឋាន ក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុងឈើ និងលើក្លោងទ្វារ។ នារីទាំងឡាយជាច្រើន បានឃើញនាគទាំងនុ៎ះ កំពុងសំយុងខ្លួន លុះឃើញពួកនាគបើកពពារ កំពុងឲ្យសម្លេងរឿយ ៗ ក៏កន្ទក់កន្ទេញ។ ពួកជនក្នុងពារាណសី តក់ស្លុត ក្តៅក្រហាយ ក៏លើកដៃកន្ទក់កន្ទេញថា សូមព្រះអង្គប្រទានធីតា ដល់នាគរាជ។

[៣០១] (ព្រាហ្មណ៍នេសាទ...) អ្នកជាអ្វី មានភ្នែកក្រហម មានចន្លោះស្មាទូលាយ (អង្គុយ) ក្នុងកណ្តាលនៃព្រៃ ជាទីនាំមកបូជាដោយផ្កាឈើ ស្រីទាំង ១០ នាក់ ជាអ្វី ដែលទ្រទ្រង់នូវសង្វារជាវិការៈនៃមាស មានសំពត់ដ៏ល្អ កំពុងឈរសំពះ។ អ្នកជាអ្វី មានដៃធំរុងរឿង ក្នុងកណ្តាលព្រៃ ដូចភ្លើងឆេះនូវឆ្នាំងខ្លាញ់ អ្នកជាយក្សណាមួយ ដែលមានសក្តិធំឬ ឬជានាគមានអានុភាពធំ។

[៣០២] (ភូរិទត្តនាគរាជ...) ខ្ញុំជានាគមានឫទ្ធិ មានតេជៈ ដែលគេកន្លងមិនបាន ប្រសិនជាខ្ញុំក្រោធ អាចចឹកសូម្បីនូវអ្នកជនបទ ដែលបរិបូណ៌ (ដោយភោគៈ) ដោយតេជៈបាន។ ឯមាតារបស់ខ្ញុំ ឈ្មោះសមុទ្ទជា បិតារបស់ខ្ញុំឈ្មោះធតរដ្ឋ ខ្ញុំជាប្អូននៃនាគរាជឈ្មោះសុទស្សនៈ ជនទាំងឡាយស្គាល់ខ្ញុំថា ភូរិទត្ត។

[៣០៣] លោករមែងឃើញអន្លង់ទឹកណាដ៏ជ្រៅ ដែលហូរគួចសព្វកាល ជាអន្លង់ទឹកគួរខ្លាច អន្លង់ទឹកនោះជាទិព្វ ជាលំនៅរបស់ខ្ញុំ មានជម្រៅច្រើនរយនៃជួរបុរស។ អ្នកកុំខ្លាច ចូរចូលទៅកាន់ស្ទឹងយមុនា មានទឹកខៀវ (ដែលហូរមក) អំពីកណ្តាលព្រៃ ជាកន្លែងដែលក្ងោក និងក្រៀលយំ ជាស្ទឹងត្រជាក់ក្សេមក្សាន្ត ជាលំនៅរបស់ពួកអ្នកមានវត្ត។

[៣០៤] ម្នាលព្រាហ្មណ៍ អ្នកព្រមទាំងកូនមកដល់ភពនាគនោះហើយ នឹងបានប្រពន្ធ ម្នាលព្រាហ្មណ៍ យើងនឹងបូជាអ្នកដោយកាមទាំងឡាយរបស់យើង អ្នកចូរនៅឲ្យសុខចុះ។

[៣០៥] (ព្រាហ្មណ៍នេសាទ...) ផែនដីមានផ្ទៃរាបស្មើដោយជុំវិញ មានដើមក្រឹស្នាច្រើន ដេរដាសដោយមេភ្លៀង មានស្មៅខៀវដ៏ឧត្តមល្អ។ ព្រៃជ្រុំគួររីករាយ ស្រះបោក្ខរណីទាំងឡាយដែលបុញ្ញកម្មរបស់ព្រះអង្គនិម្មិតល្អហើយ ជាទីរីករាយ ដែលហង្សយំហើយ មានផ្កាឈូកធ្លាក់ចុះ។ សសរមានជ្រុង ៨ ដែលគេធ្វើល្អហើយ ជាវិការៈនៃកែវពៃទូរ្យទាំងអស់ ប្រាសាទទាំងឡាយ មានសសរ ១ ពាន់ ដ៏ពេញដោយនាងកញ្ញាភ្លឺរុងរឿង។ ព្រះអង្គបានដល់នូវវិមានជាទិព្វ ដោយបុណ្យរបស់ព្រះអង្គ ជាវិមានមិនចង្អៀត ជាទីក្សេមគួររីករាយ ប្រកបដោយសេចក្តីសុខយ៉ាងក្រៃលែង។ ខ្ញុំសំគាល់ថាព្រះអង្គ មិនប្រាថ្នាវិមានរបស់ព្រះឥន្ទ្រ ជាសហស្សនេត្តទេ ព្រោះថាឫទ្ធិរបស់ព្រះអង្គនេះ ដ៏ធំដូចជាឫទ្ធិនៃព្រះឥន្ទ្រដ៏រុងរឿងដែរ។

[៣០៦] (ភូរិទត្តនាគរាជ...) អានុភាពរបស់ព្រះឥន្ទ្រ អានុភាពរបស់លោកបាលទាំង ៤ ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ជាអ្នកបម្រើព្រះឥន្ទ្រក្តី អ្នកមិនគប្បីដឹងដោយចិត្តបានទេ។

[៣០៧] ខ្ញុំប្រាថ្នាវិមាននោះរបស់ទេវតាទាំងឡាយ អ្នកស្វែងរកសេចក្តីសុខ បានជារក្សាឧបោសថ ហើយដេកលើក្បាលដំបូក។

[៣០៨] (ព្រាហ្មណ៍នេសាទ...) ឯខ្ញុំ ព្រមទាំងកូន ស្វែងរកម្រឹគ បានចូលទៅកាន់ព្រៃ ញាតិទាំងនោះ មិនដឹងខ្ញុំថាស្លាប់ ឬរស់ទេ។ ខ្ញុំសូមលាព្រះភូរិទត្ត ជាបុត្តព្រះរាជធីតាក្នុងដែនកាសី ព្រះអង្គមានយស យើងខ្ញុំ បើព្រះអង្គព្រមអនុញ្ញាតហើយ គប្បីឃើញពួកញាតិ។

[៣០៩] (ភូរិទត្តនាគរាជ...) ឱ នុ៎ះពិតជាសេចក្តីពេញចិត្តរបស់ខ្ញុំហើយ ត្រង់ដែលអ្នកនៅក្នុងសំណាក់នៃខ្ញុំ ព្រោះថាកាមទាំងឡាយប្រាកដដូច្នេះ អ្នកមិនងាយបានក្នុងពួកមនុស្សទេ។ អ្នកដែលខ្ញុំបូជាដោយកាមទាំងឡាយរបស់ខ្ញុំ បើមិនចង់នៅទេ ខ្ញុំនឹងអនុញ្ញាតអ្នក សូមអ្នកទៅជួបពួកញាតិដោយសួស្តីចុះ។

[៣១០] អ្នកកាលទ្រទ្រង់កែវមណីជាទិព្វនេះ រមែងបានសត្វចិញ្ចឹម និងបុត្រ អ្នកចូរមិនមានរោគ បានសេចក្តីសុខ ម្នាលព្រាហ្មណ៍ អ្នកចូរយក (នូវកែវមណីនេះ) ហើយទៅចុះ។

[៣១១] (ព្រាហ្មណ៍នេសាទ...) បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ខ្ញុំនឹងបួស ព្រោះខ្ញុំចាស់ ហើយខ្ញុំមិនប្រាថ្នាកាមទេ។

[៣១២] (ភូរិទត្តនាគរាជ...) បើមានការបែកធ្លាយព្រហ្មចរិយៈ កិច្ចការដែលត្រូវធ្វើដោយភោគៈទាំងឡាយ (រមែងមាន) អ្នកកុំមានសេចក្តីរង្កៀសឡើយ គប្បីមក យើងនឹងឲ្យទ្រព្យដ៏ច្រើនដល់អ្នក។

[៣១៣] (ព្រាហ្មណ៍នេសាទ...) បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ប្រសិនបើមានសេចក្តីត្រូវការ ខ្ញុំនឹងមកម្តងទៀត។

[៣១៤] (អភិសម្ពុទ្ធគាថា) ព្រះភូរិទត្ត លុះពោលពាក្យនេះហើយ ក៏បញ្ជូននូវនាគទាំង ៤ ថា អ្នកទាំងឡាយមកនេះ ចូរទៅ ចូរក្រោកឡើង ចូរញ៉ាំងព្រាហ្មណ៍ឲ្យដល់ (នូវផ្លូវជាទីទៅកាន់ក្រុងពារាណសី) ជាឆាប់។ នាគទាំង ៤ ត្រូវភូរិទត្តប្រើទៅហើយ បានស្តាប់ពាក្យនោះរបស់ភូរិទត្តនោះ ក៏ក្រោកឡើង ហើយបានញ៉ាំងព្រាហ្មណ៍ឲ្យដល់ឆាប់។

[៣១៥] (ព្រាហ្មណ៍នេសាទ...) អ្នកកាន់យកនូវកែវមណី ជាមង្គល ជាទ្រព្យដ៏ប្រសើរ ជាទីរីករាយនៃចិត្ត ជាថ្មបរិបូណ៌ដោយទ្រង់ទ្រាយ អ្នកបានកែវមណីនេះ អំពីទីណា។

[៣១៦] (អាលម្ពាយនព្រាហ្មណ៍...) ថ្ងៃនេះខ្ញុំទៅកាន់ផ្លូវពីព្រឹក បានកែវមណីនេះ ដែលពួកនាងនាគភ្នែកក្រហមមួយពាន់ថែរក្សាហើយ។

[៣១៧] (ព្រាហ្មណ៍នេសាទ...) កែវមណីនេះ បើបុគ្គលសន្សំទុកល្អ ថែទាំ បូជាគ្រប់គ្រងល្អ ទុកដាក់ល្អហើយសព្វកាល គប្បីញ៉ាំងប្រយោជន៍ទាំងពួងឲ្យសម្រេចបាន។ តែកាលបើបុគ្គលជាអ្នកប្រាសចាកការថែទាំក្នុងការទុកដាក់ ឬក្នុងការប្រើប្រាស់វិញ កែវមណីនេះ ដែលគេសន្សំទុកដោយមិនត្រូវទំនង នឹងដល់សេចក្តីវិនាស។ អ្នកជាបុគ្គលមិនឈ្លាស មិនគួរគ្រប់គ្រងកែវមណីជាទិព្វនេះទេ អ្នកចូរគ្រប់គ្រងមាសឆ្តោរមួយរយចុះ ចូរឲ្យកែវមណីនេះដល់ខ្ញុំ។

[៣១៨] (អាលម្ពាយនព្រាហ្មណ៍...) កែវមណីនេះ ខ្ញុំមិនគប្បីលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ កែវមណីរបស់ខ្ញុំ ដែលកើតអំពីថ្ម បរិបូណ៌ដោយទ្រង់ទ្រាយ ខ្ញុំមិនគប្បីលក់ទេ។

[៣១៩] (ព្រាហ្មណ៍នេសាទ...) បើកែវមណី អ្នកមិនលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ ចុះកែវមណី អ្នកនឹងលក់ដោយវត្ថុអ្វី ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនោះ។

[៣២០] (អាលម្ពាយនព្រាហ្មណ៍) បុគ្គលណា គប្បីបង្ហាញនាគដ៏ធំ មានតេជះដែលគេកន្លងបានដោយក្រ ដល់ខ្ញុំ ខ្ញុំនឹងឲ្យកែវមណីដ៏រុងរឿងដោយតេជះដល់បុគ្គលនោះ។

[៣២១] (ព្រាហ្មណ៍នេសាទ...) អ្នកជាអ្វី ជាគ្រុឌដ៏ប្រសើរជាងសត្វស្លាបទាំងឡាយ កាលស្វែងរកចំណីដើម្បីខ្លួន ទើបចាប់យកនាគដោយភេទជាព្រាហ្មណ៍ទេឬ។

[៣២២] (អាលម្ពាយនព្រាហ្មណ៍...) ខ្ញុំមិនមែនជាស្តេចសត្វស្លាបទេ គ្រុឌ ខ្ញុំមិនដែលឃើញទេ ខ្ញុំជាអ្នកត្រេកអរដោយអាសិរពិស ម្នាលព្រាហ្មណ៍ ជនទាំងឡាយដឹងថា ខ្ញុំជាហ្មពស់។

[៣២៣] (ព្រាហ្មណ៍នេសាទ...) កម្លាំងរបស់អ្នកដូចម្តេច សិល្បៈរបស់អ្នកដូចម្តេច ទាំងអ្នករឹងប៉ឹងព្រោះហេតុអ្វី បានជាមិនកោតខ្លាចនាគ។

[៣២៤] (អាលម្ពាយនព្រាហ្មណ៍...) គ្រុឌបានប្រាប់វិជ្ជាពិសដ៏ប្រសើរដល់ឥសីមួយ អង្គ ជាកោសិយគោត្រនៅក្នុងព្រៃ ប្រព្រឹត្តតបធម៌អស់រាត្រីយូរ។ ខ្ញុំជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ បានបម្រើឥសីមួយអង្គនោះ ដែលមានខ្លួនចំរើនហើយ កាលគង់នៅក្នុងចន្លោះភ្នំដោយសេចក្តីគោរព។ ឥសីនោះ ដែលខ្ញុំបានបម្រើហើយក្នុងកាលនោះ វត្តក្តី ព្រហ្មចរិយៈក្តី ឥសីនោះបានប្រព្រឹត្តហើយ ឥសីមានជោគនោះ ក៏បង្រៀនមន្តទិព្វ ដល់ខ្ញុំតាមសេចក្តីប្រាថ្នា។ ខ្ញុំជាអ្នករឹងប៉ឹង ព្រោះមន្តនោះ បានជាមិនខ្លាចនាគទាំងឡាយ ខ្ញុំជាអាចារ្យរបស់ពួកអ្នកសម្លាប់សត្វមានពិសទាំងឡាយ ជនទាំងឡាយស្គាល់ខ្ញុំថា អាលម្ពាយន៍។

[៣២៥] (ព្រាហ្មណ៍នេសាទ...) ម្នាលសោមទត្ត កូន យើងនឹងកាន់យកកែវមណី ចូរអ្នកដឹងចុះ យើងកុំយកដំបងទាត់ចោលសិរីដែលមកដល់ហើយ តាមសេចក្តីប្រាថ្នាឡើយ។

[៣២៦] (សោមទត្តកុមារ...) បពិត្រព្រាហ្មណ៍ ភូរិទត្តណា បានបូជាលោកដែលដល់នូវនិវេសន៍របស់ខ្លួន លោកប្រាថ្នានឹងប្រទូស្តចំពោះព្រះភូរិទត្តនោះ ដែលធ្វើអំពើល្អយ៉ាងនេះ ព្រោះសេចក្តីរង្វេងធ្វើអ្វី។ បើលោកឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទាន ចូរលោកឪពុកទៅសុំលោកចុះ លោកនឹងប្រទានទ្រព្យច្រើនដល់លោកឪពុក។

[៣២៧] (ព្រាហ្មណ៍នេសាទ...) ម្នាលសោមទត្ត យើងគួរស៊ីរបស់ឆ្អិន ដែលមកដល់ដៃ ឬដល់ភាជន៍ ប្រសើរជាង កុំឲ្យប្រយោជន៍ដែលឃើញច្បាស់នឹងភ្នែក កន្លងផុតពីយើងទៅបាន។

[៣២៨] (សោមទត្តកុមារ...) បុគ្គលជាអ្នកទ្រុស្តមិត្ត ជាអ្នកលះបង់ប្រយោជន៍ រមែងឆេះក្នុងនរកដ៏គួរខ្លាច ផែនដីក៏ស្របបុគ្គលទ្រុស្តមិត្តនោះ បុគ្គលទ្រុស្តមិត្ត សូម្បីរស់នៅក៏រីងស្ងួត (ដូចជាប្រេត) បើឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទានមិនខាន ខ្ញុំសំគាល់ថា មិនយូរប៉ុន្មាន ឪពុកនឹងដឹងច្បាស់នូវពៀរដែលខ្លួនធ្វើហើយ។

[៣២៩] (ព្រាហ្មណ៍នេសាទ...) ព្រាហ្មណ៍ទាំងឡាយ បូជាមហាយញ្ញហើយ រមែងបរិសុទ្ធយ៉ាងនេះ យើងនឹងបូជាមហាយញ្ញ គង់នឹងរួចចាកបាបដោយអាការយ៉ាងនេះ។

[៣៣០] (សោមទត្ត...) ណ្ហើយចុះ ឥឡូវនេះ ខ្ញុំនឹងគេចចេញថ្ងៃនេះ ខ្ញុំមិននៅជាមួយនឹងឪពុកទេ ខ្ញុំមិនដើរជាមួយនឹងឪពុក ដែលធ្វើអំពើអាក្រក់យ៉ាងនេះ អស់មួយជំហានទេ។

[៣៣១] (អភិសម្ពុទ្ធគាថា) សោមទត្តកុមារ ជាពហុស្សូត បានពោលពាក្យនេះនឹងបិតាហើយ ក៏ប្រកាសទេវតាទាំងឡាយ ហើយគេចចេញចាកទីនោះ។

[៣៣២] (ព្រាហ្មណ៍នេសាទ...) នាគណាមានពន្លឺដូចជាសម្បុរនៃសត្វមេភ្លៀង មានក្បាលក្រហម អ្នកចូរចាប់នាគធំនុ៎ះចុះ ហើយចូរនាំកែវមណីនុ៎ះដល់ខ្ញុំ។ កាយរបស់នាគនុ៎ះ រមែងប្រាកដដូចជាគីនរប៉ុយកប្បាស នាគនេះដេកលើដំបូក ម្នាលព្រាហ្មណ៍ អ្នកចូរចាប់យកនាគនោះចុះ។

[៣៣៣] (អភិសម្ពុទ្ធគាថា) គ្រានោះ អាលម្ពាយនព្រាហ្មណ៍ កាលជប់បទនៃមន្តទាំងឡាយ ធ្វើជាគ្រឿងការពារខ្លួន ដោយឱសថទិព្វទាំងឡាយហើយ ទើបអាចចាប់នាគនោះ ដោយវិធីយ៉ាងនេះ។

[៣៣៤] (សុទស្សននាគរាជ...) ឥន្ទ្រិយរបស់លោកមិនស្រស់បស់ ព្រះភក្ត្ររបស់លោកក៏ខ្មៅ ព្រោះឃើញខ្ញុំ ដែលសម្រេចសេចក្តីប្រាថ្នាទាំងពួង កំពុងមកគាល់ឬ។ ព្រះភក្ត្ររបស់លោកខ្មៅ ដូចជាផ្កាឈូកដែលបិតនៅក្នុងដៃ ដែលគេច្របាច់ដោយដៃ ព្រោះតែឃើញខ្ញុំប្រាកដដូច្នេះឬ។

[៣៣៥] ក្រែងបុគ្គលណាមួយ មិនរាប់អានលោកខ្លះឬ វេទនារបស់លោកមានខ្លះឬ ព្រះភក្ត្ររបស់លោកខ្មៅ ព្រោះឃើញខ្ញុំមក ដោយហេតុណា (សូមលោកប្រាប់នូវហេតុនោះដល់ខ្ញុំចុះ)។

[៣៣៦] (នាងសមុទ្ទជា...) ម្នាលកូន ក្រោយមួយខែមកហើយ អំពីថ្ងៃនេះ យើងបានឃើញសុបិនថា ហាក់ដូចជាបុរសកាត់ដៃខាងស្តាំរបស់យើង ហើយនាំយកដៃដែលប្រឡាក់ដោយឈាម ដើរចេញទៅក្នុងកាលដែលយើងកំពុងយំ។ ម្នាលសុទស្សនៈ កាលណាយើងបានឃើញសុបិន អ្នកចូរដឹងចុះថា កាលណោះ យើងមិនបានសេចក្តីសុខទាំងថ្ងៃទាំងយប់។

[៣៣៧] នាងកញ្ញាទាំងឡាយ មានរាងកាយដ៏រុងរឿង ពាក់បណ្តាញមាស បានចោមរោមភូរិទត្តណា ពីក្នុងកាលមុន (ឥឡូវនេះ) ភូរិទត្តនោះ យើងមិនឃើញទេ។ នាគទាំងឡាយដែលកាន់ព្រះខ័នដ៏ប្រសើរ ដូចជាផ្កាកណ្ណិការិក ចោមរោមភូរិទត្តណា ពីក្នុងកាលមុន (ឥឡូវនេះ) ភូរិទត្តនោះ យើងមិនឃើញទេ។ ណ្ហើយចុះ ឥឡូវនេះ យើងនឹងទៅកាន់លំនៅរបស់ភូរិទត្ត យើងគង់នឹងឃើញប្អូនរបស់អ្នក ដែលតាំងនៅក្នុងធម៌ បរិបូណ៌ដោយសីល។

[៣៣៨] (អភិសម្ពុទ្ធគាថា) ឯភរិយាទាំងឡាយរបស់ភូរិទត្ត បានឃើញព្រះមាតានៃភូរិទត្តនោះ កំពុងដើរមក ក៏ផ្គងដៃឡើងកន្ទក់កន្ទេញថា បពិត្រលោកម្តាយជាម្ចាស់ ក្រោយមួយខែមកហើយ អំពីថ្ងៃនេះ យើងមិនដឹងភូរិទត្តដ៏មានយស ជាបុត្ររបស់លោក ជាស្លាប់ ឬរស់នៅទេ។

[៣៣៩] (នាងសមុទ្ទជា...) យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចជាមេសត្វស្លាបបាត់កូន ឃើញតែសំបុកទទេដូច្នោះ។ យើងកាលមិនឃើញភូរិទត្ត នឹងឆេះដោយសេចក្តីទុក្ខអស់កាលយូរ ដូចជាមេអកបាត់កូន ឃើញតែសំបុកទទេដូច្នោះ។ យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្តីទុក្ខ អស់កាលយូរ ដូចជាមេសត្វចាក្រពាកនោះ នៅលើភក់ ដែលមិនមានទឹកដោយពិត។ ជើងក្រាននៃពួកជាងមាស ឆេះតែខាងក្នុង មិនឆេះខាងក្រៅយ៉ាងណា យើងកាលមិនឃើញភូរិទត្ត នឹងឆេះដោយសេចក្តីសោកយ៉ាងនោះ។

[៣៤០] (អភិសម្ពុទ្ធគាថា) កូន និងប្រពន្ធទាំងឡាយ ដួលដេកក្នុងនិវេសន៍របស់ព្រះភូរិទត្ត ដូចជាដើមឈើដែលត្រូវខ្យល់ញាំញីបំបាក់ដូច្នោះ។

[៣៤១] អរិដ្ឋៈ និងសុភោគនាគរាជ បានឮសម្លេងគឹកកងនៃនាគទាំងនោះ ក្នុងនិវេសន៍របស់ព្រះភូរិទត្ត ក៏ស្ទុះទៅតាមលំដាប់ ហើយពោលថា បពិត្រលោកម្តាយ សូមលោកដកដង្ហើមស្រួលចុះ កុំសោយសោកឡើយ ព្រោះថា សត្វទាំងឡាយ មានសភាពយ៉ាងនេះជាធម្មតា តែងច្យុត តែងកើតឡើងវិញ នេះជាការប្រែប្រួលនៃលោក។

[៣៤២] (នាងសមុទ្ទជា...) ម្នាលកូន យើងក៏ដឹងថា សត្វទាំងឡាយមានសភាពយ៉ាងនេះជាធម្មតាដែរ តែថាយើងកាលមិនឃើញភូរិទត្តទេ ត្រូវសេចក្តីសោកគ្របសង្កត់ហើយ ប្រសិនបើ (ភូរិទត្ត) មិនបាន (មកចួប) នឹងយើង ក្នុងថ្ងៃនេះ យប់នេះទេ ម្នាលសុទស្សនៈ អ្នកចូរដឹងចុះ យើងកាលមិនឃើញភូរិទត្តទេ យើងមុខជានឹងលះបង់នូវជីវិតពុំខាន។

[៣៤៣] (កូនទាំងឡាយ...) បពិត្រព្រះមាតា សូមលោកដកដង្ហើមស្រួលចុះ កុំសោយសោកឡើយ យើងទាំងឡាយ នឹងនាំបងមក យើងទាំងឡាយ ត្រាច់ទៅកាន់ទីស្វែងរកបង នឹងទៅកាន់ទិសតូចធំលើភ្នំ ជ្រោះភ្នំ ក្នុងស្រុក និងនិគមទាំងឡាយ លោកចូរឃើញបងដែលមកក្នុងរវាងខាងក្នុង ៧ រាត្រី។

[៣៤៤] (អាលម្ពាយនព្រាហ្មណ៍...) នាគដែលរួចអំពីដៃ (របស់យើង) ក្រាបចុះលើជើងលោកយ៉ាងខ្លាំង លោកត្រូវពស់ចឹកឬ លោកកុំខ្លាចឡើយ ចូរដល់សេចក្តីសុខចុះ។

[៣៤៥] (សុទស្សននាគរាជ...) នាគនេះ មិនអាចឲ្យទុក្ខណាមួយដល់អាត្មាទេ អ្នកចាប់ពស់មានទាំងប៉ុន្មាន មិនមែនមានច្រើនជាងអាត្មាទេ។

[៣៤៦] (អាលម្ពាយនព្រាហ្មណ៍...) អ្នកណាហ្ន៎ ភ្លីភ្លើ មានភេទដូចជាភេទនៃព្រាហ្មណ៍ មកកាន់បរិស័ទ ហើយហៅ (អញ) ច្បាំង បរិស័ទចូរស្តាប់ពាក្យរបស់យើងចុះ។

[៣៤៧] (សុទស្សននាគរាជ...) ម្នាលអាលម្ពាយន៍ អ្នកច្បាំងនឹងយើងដោយនាគ យើងក៏ច្បាំងនឹងអ្នកដោយកូនកង្កែបដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាបណៈ ៥.០០០ ជាកំណត់។

[៣៤៨] (អាលម្ពាយនព្រាហ្មណ៍...) ម្នាលមាណព យើងជាអ្នកមានទ្រព្យស្តុកស្តម្ភ អ្នកឯងជាអ្នកទាល់ក្រ តើបុគ្គលណា ជាអ្នកធានាអ្នកម្យ៉ាងទៀត ទ្រព្យដំកល់ទុកក្នុងការភ្នាល់ មានដែរឬ។ ទ្រព្យដំកល់ទុកក្នុងការភ្នាល់របស់យើង មាន ទាំងបុគ្គលជាអ្នកធានាប្រាកដដូច្នោះក៏មានដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាបណៈ ៥.០០០ ជាកំណត់។

[៣៤៩] (សុទស្សននាគរាជ...) បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្តាប់ពាក្យអាត្មាភាព សេចក្តីចំរើន ចូរមានដល់ព្រះអង្គ ព្រះអង្គមានកិត្តិគុណ សូមព្រះអង្គធានាដោយកហាបណៈ ៥.០០០ របស់អាត្មាភាព។

[៣៥០] (ព្រះរាជា...) នែព្រាហ្មណ៍ បំណុលជារបស់នៃបិតា ឬថាខ្ញុំជំពាក់ដោយខ្លួនឯង បានជាអ្នកទារយកទ្រព្យរបស់យើងច្រើន តើព្រោះហេតុអ្វី។

[៣៥១] (សុទស្សននាគរាជ...) ដ្បិតអាលម្ពាយនព្រាហ្មណ៍ ផ្ចាញ់អាត្មាភាពដោយ នាគ អាត្មាភាពនឹងញ៉ាំងកូនកង្កែបឲ្យខាំព្រាហ្មណ៍។ បពិត្រមហារាជញ៉ាំងដែនឲ្យចំរើន ព្រោះហេតុនោះ សូមព្រះអង្គមានពួកអ្នកកាន់ព្រះខ័នហែហម យាងទៅដើម្បីទតពស់ដែលគួរទត។

[៣៥២] (អាលម្ពាយនព្រាហ្មណ៍...) ម្នាលមាណព ខ្ញុំមិនមើលងាយអ្នកដោយសិប្បវាទទេ ចំណែកអ្នកមើលងាយដោយសិប្បៈ បានជាមិនកោតក្រែងនាគ។

[៣៥៣] (សុទស្សននាគរាជ...) នែព្រាហ្មណ៍ អាត្មាក៏មិនមើលងាយអ្នកដោយសិប្បវាទទេ តែអ្នកបញ្ឆោតជនច្រើនដោយនាគដែលមិនមានពិស។ អាត្មាដឹងអ្នកយ៉ាងណា ជនក៏ត្រូវដឹងអ្នកយ៉ាងនោះដែរ ម្នាលអាលម្ពាយន៍ អ្នកមិនបានអង្កាម ១ ក្តាប់ នឹងបានទ្រព្យអំពីណា។

[៣៥៤] (អាលម្ពាយនព្រាហ្មណ៍...) អ្នកស្លៀកដណ្តប់ស្បែកខ្លាទាំងក្រចក មានផ្នួងសក់ ជាមនុស្សរកខ្វក់ភ្លឺភ្លើ មកកាន់បរិស័ទ ហើយមើលងាយនាគបែបនេះថា មិនមានពិស អ្នកចូរមក ហើយគង់នឹងដឹងនាគនោះ ដែលពេញដោយតេជះរបស់នាគដ៏ខ្ពង់ខ្ពស់ ខ្ញុំសំគាល់ថា នាគនុ៎ះ នឹងធ្វើអ្នកឲ្យដូចជាគំនរផេះយ៉ាងឆាប់។

[៣៥៥] (សុទស្សននាគរាជ...) ពិសនៃពស់ផ្ទះ ពស់ទឹក ពស់ខៀវ គ្រាន់មានខ្លះ ឯពិសនៃនាគមានក្បាលក្រហម មិនមានសោះឡើយ។

[៣៥៦] (អាលម្ពាយនព្រាហ្មណ៍...) ខ្ញុំបានស្តាប់ពាក្យនេះរបស់ពួកព្រះអរហន្ត ដែលសង្រួមហើយ មានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើអ្នកមានវត្ថុតិចតួចដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ។ នាគនេះ មានឫទ្ធិច្រើន មានតេជះដែលគេកន្លងបានដោយក្រ ខ្ញុំនឹងប្រើនាគនេះឲ្យចឹកអ្នក នាគនោះនឹងធ្វើអ្នកឲ្យទៅជាផេះ។

[៣៥៧] (សុទស្សននាគរាជ...) ម្នាលសម្លាញ់ ខ្ញុំក៏បានស្តាប់ពាក្យនេះរបស់ពួកព្រះអរហន្ត ដែលសង្រួមហើយមានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើអ្នកមានវត្ថុតិចតួច ដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ។ កូនកង្កែបនេះ ឈ្មោះអច្ចិមុខី ពេញដោយតេជះរបស់ពស់ដ៏ខ្ពង់ខ្ពស់ អាត្មានឹងប្រើនាងអច្ចិមុខីនោះ ឲ្យខាំអ្នក នាងអច្ចិមុខីនោះ នឹងធ្វើអ្នកឲ្យទៅជាផេះ។ នាងអច្ចិមុខីនោះ ជាធីតារបស់ព្រះបាទធតរដ្ឋ មានមាតាផ្សេងគ្នា ជាប្អូនស្រីរបស់អាត្មាដ៏ពេញដោយតេជះរបស់ពស់ដ៏ខ្ពង់ខ្ពស់ ចូរខាំចុះ។

[៣៥៨] បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅលើផែនដី ស្មៅ វល្លិ៍ ពូកឈើ ជាឱសថ នឹងស្វិតស្រពោនគ្មានសល់។

[៣៥៩] បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅខាងលើ ភ្លៀងនឹងមិនបង្អុរចុះ ទឹកសន្សើមនឹងមិនធ្លាក់ចុះអស់ ៧ ឆ្នាំ។

[៣៦០] បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅក្នុងទឹក ត្រី និងអណ្តើក ដែលជាសត្វកើតក្នុងទឹកទាំងប៉ុន្មាន នឹងស្លាប់ទាំងអស់។

[៣៦១] (ព្រាហ្មណ៍នេសាទ ...) ទឹកដែលតាំងនៅក្នុងកំពង់បយាគៈ ដែលអញកំពុងស្រោច ជាទឹកដែលលោកសន្មតថា សម្រាប់លាងបាប ចុះខ្មោចអ្វី ជ្រមុជអញចុះទៅក្នុងស្ទឹងយមុនាដ៏ជ្រៅ។

[៣៦២] (សុភោគនាគរាជ...) នាគណា ជាធំក្នុងលោក មានយស បានមកព័ទ្ធក្រុងពារាណសីដោយជុំវិញ អញជាកូននាគដ៏ប្រសើរនោះ ម្នាលព្រាហ្មណ៍ នាគទាំងឡាយ ហៅអញថា សុភោគដូច្នេះ។

[៣៦៣] (ព្រាហ្មណ៍នេសាទ...) បើអ្នកជាកូននៃនាគដ៏ប្រសើរ ជាព្រះរាជាក្នុងដែនកាសី ជាធំជាងនាគដែលមានអាយុវែង បិតារបស់អ្នកជានាគមានស័ក្តិធំមួយដែរ បណ្តាសត្វទាំងឡាយ មាតារបស់អ្នក ក៏មិនមានស្ត្រីណាផ្ទឹមបានឡើយ បុគ្គលមានអានុភាពច្រើនដូចអ្នក មិនគួរចាប់ជ្រមុជបុគ្គល សូម្បីជាទាសៈនៃព្រាហ្មណ៍ទេ។

[៣៦៤] (សុភោគនាគរាជ...) ឯងអែបដើមឈើ ហើយបាញ់ទ្រាយដែលមកផឹក (ទឹក) ទ្រាយនោះ ដែលឯងបាញ់ហើយ ក៏ងាកមើលដោយកំឡាំងនៃសរ ក៏ស្ទុះទៅកាន់ទីឆ្ងាយ។ ឯងបានឃើញទ្រាយនោះ ដួលក្នុងព្រៃធំហើយ ក៏នាំសាច់មួយអម្រែកចូលទៅកាន់ដើមជ្រៃ ក្នុងវេលាល្ងាច ជាឈើដែលគឹកកងដោយសត្វសេក និងសាលិកា មានស្លឹកល្មៀង ដេរដាសដោយពួរ ដែលសត្វតាវៅទំយំ ជាទីគួររីករាយ មានផែនដីដុះស្មៅខៀវជានិច្ច បងរបស់អញដែលមានអានុភាពច្រើន រុងរឿងដោយឫទ្ធិ និងយស ដែលពួកនាគកញ្ញាចោមរោមហើយ ក៏ប្រាកដដល់ឯងក្នុងទីនោះ។ ឯងនោះ ដែលបងរបស់អញនោះផ្គាប់ហើយ ឲ្យស្កប់ស្កល់ដោយកាមទាំងពួង ឯងបានប្រទូស្តចំពោះបងដែលមិនប្រទូស្ត ពៀរនោះមកដល់ឯងក្នុងទីនេះហើយ។ ឯងចូរដេក ក យ៉ាងឆាប់ អញនឹងមិនឲ្យជីវិតដល់ឯងទេ អញរឭកឃើញនូវពៀរ (ដែលឯងធ្វើ) ចំពោះបង អញនឹងកាត់ក្បាលឯងឥឡូវនេះ។

[៣៦៥] (ព្រាហ្មណ៍នេសាទ...) ព្រាហ្មណ៍ជាអ្នករៀនមន្ត ១ ជាអ្នកប្រកបដោយការសូម ១ ជាអ្នកបូជាភ្លើង ១ ព្រាហ្មណ៍ប្រកបដោយហេតុទាំង ៣ នេះ អ្នកមិនគួរសម្លាប់ទេ។

[៣៦៦] (សុភោគនាគរាជ...) បុរីណា របស់ព្រះបាទធតរដ្ឋ ជាវិការៈនៃមាសទាំងអស់ ដែលចូលទៅកាន់ស្ទឹងយមុនា ទល់នឹងភ្នំហិមពាន្ត ដែលនៅជិតស្ទឹងយមុនា រមែងរុងរឿង។ បងប្អូនរបស់អញទាំងនោះ ជាបុរសក្លៀវក្លា ជាអ្នករួមផ្ទៃ នៅក្នុងបុរីនោះ បងប្អូនទាំងនោះ

ក្នុងបុរីនោះ និយាយយ៉ាងណា ឯងនឹងទៅជាយ៉ាងនោះ។

[៣៦៧] (កាណារិដ្ឋនាគរាជ...) បពិត្រសុភោគ យ័ញ្ញ និងវេទទាំងឡាយក្នុងលោកនេះ ដែលព្រាហ្មណ៍ឯទៀតប្រកបហើយ មិនមែនជារបស់ផ្តេសផ្តាសទេ ព្រោះហេតុនោះ បុគ្គលកាលតិះដៀលព្រាហ្មណ៍ដែលមិនគួរតិះដៀល ឈ្មោះថាលះបង់ទ្រព្យ និងធម៌របស់ពួកសប្បុរស។

[៣៦៨] ពួកអ្នកប្រសើរ (ព្រាហ្មណ៍) ប្រកាន់ខាងការរៀនមន្ត្ត ពួកជាធំជាងជន (ក្សត្រិយ៍) ប្រកាន់ខាងការផែនដី ពួកវេស្សៈ ប្រកាន់ខាងការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ខាងការបម្រើផ្សេងៗគ្នា តាមសមគួរដល់ប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានតាក់តែងហើយ។

[៣៦៩] ទេវរាជព្រះនាមធាតុ វិធាតុ វរុណៈ កុវេរៈ សោមៈ យមៈ ចន្ទិមៈ វាយុ សុរិយៈ ស្តេចទាំងនេះ បានបូជាយ័ញ្ញដ៏ច្រើន ទាំង (បានឲ្យ) វត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ពួកព្រាហ្មណ៍អ្នករៀនមន្ត្ត។ ព្រះបាទអជ្ជុនណា មានកម្លាំង មានសេនាគួរខ្លាច មានដៃមួយពាន់[51] មិនមានបុគ្គលណាស្មើ លើផែនដី ជាអ្នកឃិតធ្នូ ៥០០ បាន ព្រះបាទអជ្ជុននោះឯង ក៏បូជាភ្លើងក្នុងកាលនោះដែរ។

[៣៧០] បុគ្គលណា មានចិត្តជ្រះថ្លា រីករាយ បានញ៉ាំងព្រាហ្មណ៍ឲ្យបរិភោគបាយ និងទឹក អស់កាលយូរ ដ៏សមគួរតាមអានុភាព បពិត្រសុភោគ បុគ្គលនោះ នឹងបានជាទេវតាមួយអង្គ។

[៣៧១] ព្រះបាទមុជលិន្ទ អាចញ៉ាំងទេវតាភ្លើង ជាអ្នកស៊ីច្រើន មានពន្លឺមិនថោកទាប ឲ្យស្កប់ស្កល់ដោយសប្បិ បានបូជាវិធីយ័ញ្ញចំពោះទេវតាភ្លើងដ៏ប្រសើរ ទ្រង់បានទៅកាន់គតិជាទិព្យ។

[៣៧២] ព្រះរាជា ព្រះនាមទុទីបៈ មានអានុភាពច្រើន មានព្រះជន្ម ១.០០០ ឆ្នាំ បានលះបង់ដែន ព្រមទាំងសេនា មិនមានទីបំផុត ហើយបួស បានជាទក្ខិណេយ្យបុគ្គល គួររមិលមើលដ៏លើសលុប ទ្រង់បានទៅកាន់ឋានសួគ៌។

[៣៧៣] បពិត្រសុភោគ ព្រះបាទសាគរឈ្នះផែនដី មានសាគរជាទីបំផុត បានលើកសសរយ័ញ្ញដ៏ល្អ ជាវិការៈនៃមាសដ៏លើសលុប បូជាភ្លើង ទ្រង់បានជាទេវតាមួយអង្គ។ បពិត្រសុភោគ ទន្លេគង្គា ប្រព្រឹត្តទៅដោយអានុភាពនៃព្រះរាជាណា ទឹកដោះជូរដែលស្ងប់ស្ងៀមទៅជាសមុទ្រដោយអានុភាពនៃព្រះរាជាណា ព្រះរាជានោះ គឺព្រះបាទអង្គៈ មានរោមត្រង់ព្រះបាទ បម្រើភ្លើង ក៏ទ្រង់បានទៅកាន់បុរីនៃព្រះឥន្ទ្រ។

[៣៧៤] បពិត្រសុភោគ ទេវតាដ៏ប្រសើរ មានឫទ្ធិច្រើន មានយស ជាសេនាបតីនៃព្រះបាទវាសវៈ ក្នុងឋានត្រៃត្រឹង្ស ព្រោះតែបានកំចាត់បង់នូវមន្ទិល ដោយសោមយាគវិធី ក៏បានជាទេវតាមួយអង្គ។

[៣៧៥] ទេវតាដ៏ប្រសើរ ព្រហ្មមានឫទ្ធិច្រើន មានយស បានសាងលោកនេះ និងលោកដទៃ និងស្ទឹងភាគីរថីផង ភ្នំហិមពាន្តផង ភ្នំវិជ្ឈៈផង ព្រហ្មនោះឯង ក៏បានបូជាភ្លើងក្នុងកាលនោះដែរ។ ម្យ៉ាងទៀត ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ពួកព្រាហ្មណ៍ពោលថា ភ្នំទាំងនេះក្តី ភ្នំដទៃធំៗក្តី ពួកព្រាហ្មណ៍អ្នកបូជាយ័ញ្ញ បានធ្វើឲ្យវិចិត្រហើយ។

[៣៧៦] ជនទាំងឡាយ បានពោលចំពោះព្រាហ្មណ៍អ្នករៀនមន្ត្ត បរិបូណ៌ដោយគុណនៃមន្ត្ត មានតបៈក្នុងលោកនេះ ថាជាអ្នកប្រកបដោយការស្ងួម សាគរបានពន្លិចព្រាហ្មណ៍នោះ ដែលឋិតនៅលើត្រើយ កំពុងសាចទឹកសមុទ្រ ហេតុនោះ បានជាសមុទ្រមានទឹកប្រែផឹកមិនបាន។

[៣៧៧] ព្រាហ្មណ៍ទាំងឡាយ ជាវត្ថុសម្រាប់បូជា មានច្រើនលើផែនដី មានក្នុងទិសខាងកើត ទិសខាងលិច ទិសខាងត្បូង និងទិសខាងជើង តែងញ៉ាំងសេចក្តីត្រេកអរឲ្យកើតដល់វាសវៈ។

[៣៧៨] (ភូរិទត្តនាគរាជ...) ម្នាលអរិដ្ឋ ការរៀនយកនូវវេទទាំងឡាយ ជាទោសរបស់អ្នកប្រាជ្ញទាំងឡាយ តែជាអំពើរបស់បុគ្គលពាលទាំងឡាយ (ត្រៃវេទ) ជាធម៌ ដូចថ្ងៃបណ្តើរក្ងួន ព្រោះសំឡឹងមើលទៅ មិនស្មើវេទទាំងឡាយ ជាចំណែកនៃកលឧបាយ ទ្រង់ទាញអ្នកមានបញ្ញាមិនបានទេ ការពារជនអ្នកទ្រុស្តមិត្រ បំផ្លាញសេចក្តីចំរើននោះ ក៏មិនបានទេ ភ្លើងដែលបុគ្គលបម្រើហើយ រមែងមិនការពារនូវសត្វមានកម្មបានទេ ជារបស់មិនប្រសើរ ប្រកបដោយទោស។ មួយទៀត សត្វទាំងឡាយ មានទ្រព្យ មានភោគៈ យកទ្រព្យទាំងអស់លាយដោយឧស និងស្មៅហើយដុតភ្លើង មានតេជៈ មិនមានអ្វីស្មើ កាលឆេះវត្ថុដែលគេដុតហើយ ក៏មិនគប្បីឆ្អែត ម្នាលអ្នកដឹងរសដោយអណ្តាតទាំងពីរ ចុះបុគ្គលណា គប្បីធ្វើភ្លើងនោះឲ្យឆ្អែតបាន។ ខីរៈ មានការប្រែប្រួលជាធម្មតា ក្លាយទៅជាទធិ ហើយទៅជានវនីតយ៉ាងណា ភ្លើងជាតេជោធាតុ មានការប្រែប្រួលជាធម្មតា យ៉ាងនោះដែរ លុះតែប្រកបដោយគ្រឿងពួត ទើបឆេះ។ ភ្លើងដែលចូលទៅក្នុងឈើស្ងួត ឬឈើស្រស់ក៏មិនប្រាកដ ភ្លើងដែលនរជនមានឈើពំនួតក្នុងដៃ មិនបានពួត ក៏មិនឆេះ ភ្លើងមិនមែនឆេះដោយការមិនធ្វើទេ។ ប្រសិនបើភ្លើងនៅក្នុងឈើស្ងួត ឬឈើស្រស់ នៅខាងក្នុង នៅក្នុងព្រៃទាំងអស់ក្នុងលោក គប្បីស្ងួតក្រៀម ឯឈើស្ងួតទាំងឡាយគប្បីឆេះ។ ថាបើ នរជនញ៉ាំងភ្លើងដ៏ក្តៅ ប្រកបដោយផ្សែង និងអណ្តាត ឲ្យស៊ីដោយឧស និងស្មៅ ឈ្មោះថា ធ្វើបុណ្យឬ ជនអ្នកធ្វើធ្យូងអ្នកធ្វើអំបិល អ្នកធ្វើអាហារ និងអ្នកដុតសរីរៈនៃបុគ្គលស្លាប់ ឈ្មោះថា ធ្វើបុណ្យដែរឬ។ ប្រសិនបើព្រាហ្មណ៍ទាំងនុ៎ះ ញ៉ាំងការរៀនមន្ត្តនឹងភ្លើងឲ្យឆ្អែតក្នុងលោកនេះ ទើបឈ្មោះថាធ្វើបុណ្យ នរជនណាមួយក្នុងលោក កាលញ៉ាំងភ្លើងមានកំដៅប្រកបដោយផ្សែង និងអណ្តាតឲ្យស៊ី មិនឈ្មោះថាធ្វើបុណ្យទេ។ ម្នាលអ្នកដឹងរសដោយអណ្តាតពីរ (អគ្គិទេពរបស់អ្នក) ដែលលោកគោរពហើយ ម្តេចក៏ស៊ីវត្ថុមានក្លិនមិនជាទីគាប់ចិត្ត មិនជាទីត្រេកអរនៃជនដ៏ច្រើន ដែលពួកមនុស្សតែងវៀរ ជាវត្ថុមិនប្រសើរនោះ។ មនុស្សពួកខ្លះ ពោលថាភ្លើង (ជាទេវតាមួយអង្គ) ក្នុងពួកទេវតា ឯពួកមិលក្ខុជនពោលថា ទឹកជាទេវតា ជនទាំងអស់នុ៎ះពោលខុស ភ្លើងមិនមែនជាទេវតាណាមួយទេ ទឹកក៏មិនមែនដែរ។ ភ្លើងមិនមានឥន្ទ្រិយ ជាពួកមិនមានចេតនា សម្រាប់ធ្វើការងាររបស់ពួកមនុស្ស អ្នកធ្វើបាបកម្មទាំងឡាយ កាលបម្រើភ្លើងគប្បីទៅកាន់សុគតិដូចម្តេចកើត។ ពួកព្រាហ្មណ៍ជាអ្នកត្រូវការដោយជីវិតក្នុងលោកនេះ ពោលថា (មហាព្រហ្ម) ជាអ្នកគ្របសង្កត់លោកទាំងអស់ ហើយពោលថា ព្រហ្មជាអ្នកបម្រើភ្លើងដូច្នេះ បើ (មហាព្រហ្ម) មានអានុភាពជាងលោកទាំងអស់ មានអំណាច មិនមានអ្នកណាសាង ហេតុអ្វីក៏សំពះភ្លើងដែលខ្លួននិម្មិតវិញ។ ពាក្យព្រាហ្មណ៍ ជាពាក្យគួរសើច មិនគួរដល់ការពិនិត្យ ជាពាក្យមិនពិត ពួកព្រាហ្មណ៍ក្នុងកាលមុន តាក់តែង (ពាក្យមិនពិត) ព្រោះហេតុនៃសក្ការៈ ព្រាហ្មណ៍ទាំងនោះ កាលបើលាភសក្ការៈមិនកើតឡើងទេ ក៏តនូវសន្តិធម៌ពោលគឺ លទ្ធិរបស់ខ្លួនជាមួយនឹងពួកសត្វ។ ពួកអ្នកប្រសើរ (ព្រាហ្មណ៍) ប្រកាន់ការរៀនមន្ត្ត ពួកជាធំជាងដែន (ក្សត្រិយ៍) ប្រកាន់ផែនដី ពួកវេស្សៈប្រកាន់ការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ការបម្រើ ផ្សេងៗគ្នា សមគួរតាមប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានតាក់តែងហើយ។ ប្រសិនបើពាក្យនុ៎ះ ជាពាក្យពិត ដូចយ៉ាងពាក្យដែលព្រាហ្មណ៍ទាំងឡាយ ពោលហើយនេះ បុគ្គលមិនមែនជាក្សត្រិយ៍ មិនត្រូវបានរាជ្យដោយដាច់ខាត បុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីសិក្សានូវបទនៃមន្ត្ត បុគ្គលវៀរចាកពួកវេស្សៈ មិនគប្បីធ្វើការភ្ជួររាស់ ពួកសូទ្រៈមិនគប្បីរួចអំពីការប្រើនៃជនដទៃ។ ពាក្យនេះ ជាពាក្យមិនពិត ព្រោះហេតុណា (ហេតុនោះ) ព្រាហ្មណ៍ទាំងនេះពោលពាក្យកុហកដើម្បីការបំពេញផ្ទៃ បុគ្គលអ្នកមិនមានប្រាជ្ញាទាំងឡាយ រមែងជឿងស៊ប់នូវពាក្យនោះ ចំណែកខាងពួកបណ្ឌិត

រមែងឃើញហេតុនោះ ដោយខ្លួនឯង។ ពួកក្សត្រិយ៍នាំយកពលី (ហួតពន្ធ) របស់ពួកវេស្សៈ ពួកព្រាហ្មណ៍ កាន់យកគ្រឿងសស្ត្រាទាំងឡាយ ហើយដើរទៅ (សម្លាប់សត្វ) ហេតុអ្វី ព្រហ្មមិនធ្វើលោកដែលជ្រលជ្រើម បែកខ្ញែកបែបនោះៗ ឲ្យត្រង់។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុងលោកទាំងអស់ ហេតុអ្វី ក៏ចាត់ចែងលោកទាំងអស់ឲ្យមានទុក្ខ ហេតុអ្វីមិនធ្វើលោកទាំងអស់ឲ្យបានសេចក្តីសុខ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុងលោកទាំងអស់ ហេតុអ្វីក៏ធ្វើលោកឲ្យវិនាស ដោយកលឧបាយ និងការញ៉ាំញី ដោយការពោលពាក្យកុហក ដែលមិនមែនជាធម៌។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុងលោកទាំងអស់ ម្នាលអរិដ្ឋ ព្រហ្មជាម្ចាស់លើភូត មិនប្រកបដោយធម៌ទេ ព្រោះកាលបើធម៌មានបែរជាចាត់ចែងអធម៌វិញ។ បុគ្គលសម្លាប់កណ្តុប កន្ធំរុយ ពស់ កង្កែប ដង្កូវ រុយ ទើបឈ្មោះថា បរិសុទ្ធ ឯធម៌ទាំងនេះ ជាធម៌របស់ពួកជនអ្នកនៅក្នុងដែនកម្ពុជៈដ៏ច្រើន ជាធម៌មានសភាពមិនប្រសើរ ជាធម៌មិនពិត។

[៣៧៩] ប្រសិនបើអ្នកសម្លាប់នោះ បរិសុទ្ធ ឬអ្នកដែលត្រូវសម្លាប់នោះ ទៅកាន់ឋានសួគ៌បាន ពួកព្រាហ្មណ៍ គប្បីសម្លាប់ពួកព្រាហ្មណ៍ ឬសម្លាប់ពួកជនអ្នកជឿពាក្យព្រាហ្មណ៍នោះ (មុន)។ មិនមានពួកម្រឹគ មិនមានពួកសត្វចិញ្ចឹម ពួកគោណាមួយអង្វរឲ្យសម្លាប់ខ្លួនទេ សត្វទាំងឡាយក្នុងលោកនេះ សុទ្ធតែញាប់ញ័រ ត្រូវការដោយជីវិត (ព្រោះថា) ជនទាំងឡាយ ប្រារព្ធនឹងសម្លាប់សត្វទាំងឡាយ និងសត្វចិញ្ចឹម ក្នុងយញ្ញទាំងឡាយ។ ពួកបុគ្គលពាល រមែងបើកមាត់និយាយ ដោយហេតុទាំងឡាយដ៏វិចិត្រ ក្នុងការលើកឡើងនូវសសរយញ្ញៈ និងទីចងនៃសត្វចិញ្ចឹមថា សសរយញ្ញនេះ បង្ហូរសេចក្តីប្រាថ្នាដល់អ្នក ក្នុងបរលោក នឹងឲ្យសេចក្តីទៀងទាត់ក្នុងបរលោក។ ប្រសិនបើបុគ្គលគប្បីបានកែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ និងមាស ក្នុងសសរយញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ ម្យ៉ាងទៀត ប្រសិនបើសសរយញ្ញ គប្បីបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ ពួកជនអ្នកចេះត្រៃវេទដ៏ច្រើន គប្បីបូជា បុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីបូជាតិចតួចទេ។ កែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ មាស ក្នុងសសរយញ្ញ ក្នុងឈើស្ងួត នឹងឈើស្រស់ នឹងមានពីណា សសរយញ្ញនឹងបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ដូចម្តេចកើត។ ពួកព្រាហ្មណ៍ ជាអ្នកបោកប្រាស់ ចិត្តអាក្រក់ ជាពួកពាល ប្រលោមលោក តែងបើកមាត់និយាយដោយហេតុដ៏វិចិត្រថា អ្នកឯងចូរយកភ្លើងចុះ ហើយឲ្យទ្រព្យដល់យើង លំដាប់នោះ អ្នកឯងនឹងបាននូវសេចក្តីប្រាថ្នាគ្រប់យ៉ាងហើយ នឹងដល់នូវសេចក្តីសុខ។ ពួកព្រាហ្មណ៍នាំបុគ្គលជាសរណៈ (ព្រះរាជា និងមហាមាត្យ) ចូរទៅកាន់រោងសម្រាប់បូជាភ្លើងនោះ ក៏បើកមាត់និយាយដោយហេតុដ៏វិចិត្រ ឲ្យកោរសក់ ពុកមាត់ កាត់ក្រចក ហើយគាបយកទ្រព្យដោយវេទទាំងឡាយ។ ពួកព្រាហ្មណ៍ ជាអ្នកកុហកដ៏ច្រើន បានទាយកម្នាក់ ហើយក៏ចោមស៊ីបាយ ដូចជាក្អែកទាំងឡាយ ចោមចាប់មៀមក្នុងទីស្ងាត់ កុហកធ្វើឲ្យរលីង ហើយដាក់ចុះទៅក្នុងផ្លូវនៃយញ្ញ។ ទាយកតែម្នាក់នោះ ត្រូវពួកព្រាហ្មណ៍បញ្ឆោតហើយដោយអាការយ៉ាងនេះឯង ព្រាហ្មណ៍ទាំងនោះជាច្រើន ចោមប្លន់ដោយការប្រកបដោយឧបាយ ក៏នាំយកទ្រព្យដែលឃើញដោយទេវលោក ដែលមិនឃើញសោះ។ ដូចយ៉ាងពួករាជបុរស ដែលព្រះរាជាប្រើទៅហើយ ក៏នាំយកទ្រព្យនោះរបស់គេ ម្នាលអរិដ្ឋ ពួកព្រាហ្មណ៍ប្រាកដដូច្នោះ ប្រហែលគ្នានឹងពួកចោរ ជាអសប្បុរស ជាបុគ្គលគួរសម្លាប់ តែគេមិនសម្លាប់ក្នុងលោក។ ពួកព្រាហ្មណ៍ បានកាត់ដើមថា មកប្រើក្នុងវិធីយញ្ញ (ប្រាប់ថា នេះ) ជាដៃស្តាំរបស់ព្រះឥន្ទ្រ បើពាក្យនោះពិត ព្រះឥន្ទ្រទៅជាដាច់ដៃ ចុះព្រះឥន្ទ្រឈ្នះពួកអសុរ ដោយកម្លាំងដៃដូចម្តេច។ ពាក្យនោះទទេសោះ ព្រះឥន្ទ្រនៅមានដើមដៃគ្រប់គ្រាន់ ជាទេវតាដ៏ប្រសើរ មិនមានអ្នកណាសម្លាប់បាន បានកំចាត់ពួកអសុរ មន្តទាំងឡាយនេះ របស់ពួកព្រាហ្មណ៍ មានសភាពជារបស់ទទេ នេះជាការបញ្ឆោត ដែលគេឃើញច្បាស់ក្នុងលោក។ ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ភ្នំទាំងនុ៎ះក្តី ភ្នំធំ ៗ ឯទៀតក្តី ព្រាហ្មណ៍ទាំងឡាយពោលថា ពួកព្រាហ្មណ៍អ្នកបូជាយញ្ញកសាងហើយ ដ៏វិចិត្រដូច្នោះ។ ព្រាហ្មណ៍ទាំងឡាយពោលថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ កាន់យកឥដ្ឋទាំងឡាយ មានបការៈយ៉ាងណា ធ្វើវិចិត្រហើយ ភ្នំទាំងឡាយ មិនមែនមានបការៈដូច្នោះទេ ឯភ្នំទាំងឡាយ មិនដូចរបស់ដទៃទេ ជារបស់មិនកម្រើក ជាថ្មសុទ្ធដែលគេឃើញច្បាស់។ ភ្នំទាំងឡាយមិនមែនជាឥដ្ឋទេ ជាថ្មយូរយារហើយ ដែក មិនមែនកើតក្នុងឥដ្ឋនោះទេ លោហៈ ក៏មិនមែនកើតក្នុងឥដ្ឋនោះដែរ ពួកព្រាហ្មណ៍កាលសសើរនូវយញ្ញនេះ បានពោលថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយញ្ញ ធ្វើវិចិត្រហើយ។ ព្រាហ្មណ៍ទាំងឡាយក្នុងលោកនេះ បានពោលនូវព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈ ថាជាអ្នកប្រកបដោយការស្ងួម សាគរពន្លិចព្រាហ្មណ៍នោះ ដែលកំពុងសាចទឹកនៃសមុទ្រលើច្រាំង ព្រោះហេតុនោះ បានជាទឹកសមុទ្រនោះប្រៃ ផឹកមិនបាន។ ស្ទឹងទាំងឡាយក្លួចយកពួកព្រាហ្មណ៍ អ្នកបរិបូណ៌ដោយវេទ បរិបូណ៌ដោយមន្ត ច្រើនជាងពាន់នាក់ ទឹកទាំងឡាយមិនខូចរស ព្រោះហេតុនោះទេ សមុទ្រមិនមានអ្វីស្មើ មានរសប្រៃ ផឹកមិនបាន តើព្រោះហេតុអ្វី។ អណ្តូងខ្លះ ក្នុងជីវលោកនេះ មានទឹកប្រៃ ដែលពួកជនអ្នកជីកអណ្តូងបានជីកហើយ ម្នាលអ្នកដឹងរសដោយអណ្តាតទាំងពីរ ជនទាំងឡាយមិនពោលថា ទឹកក្នុងអណ្តូងទាំងនោះ មានរសប្រៃ ផឹកមិនបាន ព្រោះតែក្លួចយកព្រាហ្មណ៍ទេ។ តាំងពីមុនដម្បូងមក ស្ត្រីណា ជាភរិយារបស់បុរសណា មនោបានញ៉ាំងមនុស្សឲ្យកើតឡើងក្នុងកាលមុន មិនមានអ្នកណាមួយ ថោកទាបជាងគ្នា ដោយធម៌នោះ ព្រាហ្មណ៍ទាំងឡាយបានពោលនូវការចែក (វណ្ណៈ) ដោយការលះបង់ (ធម៌នោះ) យ៉ាងនេះឯង។ សូម្បីកូនចណ្ឌាល ជាអ្នកឈ្លាសវៃ មានប្រាជ្ញា បានរៀនវេទទាំងឡាយ ពោលមន្តទាំងឡាយ ក្បាលនៃកូនជនចណ្ឌាលនោះ មិនបែកជា ៧ ភាគទេ មន្តទាំងនេះ ពួកព្រាហ្មណ៍ធ្វើហើយ ដើម្បីសម្លាប់ខ្លួន។ វាចាកុហក ពួកព្រាហ្មណ៍ បានតាក់តែងហើយ ការចង់បាន ពួកព្រាហ្មណ៍បានតាក់តែង កាន់យកហើយ កើតឡើងតាមគន្លងនៃកាព្យឃ្លោង ដែលគេស្រាយបានដោយក្រ ចិត្តរបស់បុគ្គលពាលទាំងឡាយ ជឿស៊ប់ក្នុងអំពើមិនស្មើ បុគ្គលឥតប្រាជ្ញា រមែងជឿពាក្យនោះ។ ព្រាហ្មណ៍មិន (ប្រកប) ដោយកម្លាំងដ៏មាំ ដូចកម្លាំងនៃរាជសីហ៍ ខ្លាធំ និងខ្លាដំបង មនុស្សភាព (របស់ព្រាហ្មណ៍ទាំងនោះ) ត្រូវយល់ថា ដូចគោដែរ ព្រោះជាតិរបស់ព្រាហ្មណ៍ទាំងនោះស្មើ (ដោយគោ) ស្មើដោយសីហៈជាដើម។ ប្រសិនបើព្រះរាជាឈ្នះផែនដី ប្រកបដោយអាមាត្យ មានអ្នកស្តាប់បង្គាប់ មានបរិស័ទ ព្រះរាជានោះ គប្បីឈ្នះពួកសត្រូវដោយព្រះអង្គឯង ប្រជាជនរបស់ព្រះរាជានោះ គប្បីបានសេចក្តីសុខជានិច្ច។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ (តែក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី) មិនបានវិនិច្ឆ័យនូវអត្ថនៃមន្ត និងវេទទាំងនោះទេ ទាំងមិនដឹង ដូចបុគ្គលកាលមិនដឹងផ្លូវដែលកំបាំងដោយទឹក។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ លាភ ឥតលាភ យស និងឥតយស ទាំងអស់នេះ ជាធម៌របស់វណ្ណៈទាំង ៤ នោះ។ ពួកគហបតីជាច្រើនលើផែនដី ញ៉ាំងបុគ្គលឲ្យធ្វើការងារទាំងឡាយ ព្រោះហេតុតែទ្រព្យ និងស្រូវ យ៉ាងណា សូម្បីពួកអ្នកមានត្រៃវេទ ជាច្រើនលើផែនដី ក៏ញ៉ាំងបុគ្គលឲ្យធ្វើការងារទាំងឡាយ ក្នុងថ្ងៃនេះ យ៉ាងនោះដែរ។ ព្រាហ្មណ៍ទាំងនោះ ស្មើគ្នានឹងគហបតី ព្រាហ្មណ៍ទាំងឡាយជាច្រើនលើផែនដី ជាអ្នកខ្វល់ខ្វាយជានិច្ច ប្រកបក្នុងកាមគុណទាំងឡាយ តែងញ៉ាំងបុគ្គលឲ្យធ្វើការងារទាំងឡាយ ម្នាលអរិដ្ឋ អ្នកដឹងរសដោយអណ្តាតទាំងពីរ ព្រោះហេតុនោះ ព្រាហ្មណ៍ទាំងនោះ ជាអ្នកឥតបញ្ញា។

[៣៨០] (ព្រះបាទសាគរព្រហ្មទត្ត...) ស្គរធំ សម្ភោរ ស័ង្ខ ស្គរជ័យ និងស្គរទ័ពរបស់អ្នកណា ដែលដើរខាងមុខ ហើយញ៉ាំងព្រះរាជាដ៏ប្រសើរក្នុងរថឲ្យរីករាយ។ (សម្បុរមុខ) របស់អ្នកណា (ដ៏រុងរឿង) ដោយដម្បារមាសដ៏ក្រាស់ មានពន្លឺដូចផ្លេកបន្ទោរ អ្នកណានៅកម្លោះប្រដាប់ដោយបំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក។ មុខអ្នកណាស្រស់បស់ដូចមាសឆ្អិនលើមាត់ជើងក្រាន ឬប្រាកដស្មើដោយរងើកនៃឧសគគីរ អ្នកណារុងរឿងដោយសិរីហើយដើរមក។ ឆត្ររបស់បុគ្គលណា ជាវិការៈនៃមាសជម្ពូនទ ប្រកបដោយឆ្អឹង ជាទីរីករាយនៃចិត្ត ជាគ្រឿងបិទបាំងរស្មីនៃព្រះអាទិត្យ អ្នកណារុងរឿងដោយសិរីហើយដើរមក។ អង្គ (អ្នកកាន់ផ្លិត) បានកាន់យកវាលវិជនីដ៏ឧត្តមខាងលើក្បាលទាំងពីរខាងនៃបុគ្គលមានបញ្ញាដ៏ប្រសើរណា។ បាច់នៃកន្ទុយក្ងោកដ៏វិចិត្រផង ទន់ផង មានដងជាវិការៈនៃមាស និងកែវមណី ប្រព្រឹត្តទៅទាំងពីរខាងមុខរបស់បុគ្គលណា។ កុណ្ឌលទាំងឡាយនេះ ដ៏ល្អមានពន្លឺដូចជាពណ៌រងើកភ្លើងនៃឧសគគីរ ដ៏ភ្លឺលើមាត់ជើងក្រាន រមែងរុងរឿងទាំងពីរខាងមុខរបស់បុគ្គលណា។ សក់របស់បុគ្គលណា មានចុងដ៏ស្និទ្ធ ទន់ខ្មៅ ត្រូវខ្យល់បក់ហើយ ក៏ញ៉ាំងទីបំផុតនៃថ្ងាសឲ្យល្អ ដូចជាផ្លេកបន្ទោរដែលចេញអំពីមេឃ។ ភ្នែកទាំងនេះ វែងធំរបស់អ្នកណា អ្នកណាមានភ្នែកទូលាយសម មុខនេះរបស់អ្នកណា ភ្លឺឆ្លុះដូចកញ្ចក់មាស មាត់នេះរបស់អ្នកណាដ៏ស្អាត ដូចជាស័ង្ខដ៏ប្រសើរ ធ្មេញរបស់បុគ្គលណា កាលនិយាយឡើង ដូចជាផ្កាមណ្ឌាក្រពុំ។ ដៃ និងជើងទាំងឡាយរបស់អ្នកណា ដូចជាទឹកល័ក្ត តាំងនៅក្នុងសេចក្តីសុខ អ្នកណាមានរិមបបូរមាត់ដូចផ្លែបាសដ៏ល្អ

ដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ។ អ្នកណាមានសំពត់បាវារៈដ៏ស ដូចដើមរាំងដ៏ធំ មានផ្ការីកហើយ ក្នុងព្រៃហិមពាន្តក្នុងកាលដែលកន្លងទៅនៃទឹកសន្សើម ល្អដូចព្រះឥន្ទ្រ ដែលមានជ័យជំនះ។ អ្នកណានៅក្នុងបរិស័ទ ដោះដាវនៅលើស្មា ដែលមានដងដ៏វិចិត្រដោយកែវមណី ដ៏ដេរដាសដោយពកជាវិការៈនៃមាស។ អ្នកណាដោះស្បែកជើង ដែលប៉ាក់ដោយមាស វិចិត្រដោយកែវ ៧ ប្រការ ដេរដោយសូត្រដ៏វិចិត្ររចនាល្អហើយ ក៏ថ្វាយបង្គំតាបស អ្នកស្វែងរកគុណដ៏ធំ។

[៣៨១] (តាបស ជាបិតា...) នាគទាំងនោះ ជានាគមានឫទ្ធិ មានយស ជាកូននៃព្រះបាទធតរដ្ឋ កើតអំពីនាងសមុទ្ទជា នាគទាំងនេះ សុទ្ធតែជានាគមានឫទ្ធិច្រើន។

ចប់ ភូរិទត្តជាតក ទី៦។

## ចន្ទកុមារជាតក ទី៧



### (៥៤៩. ចន្ទកុមារជាតកំ (៧))

[៣៨២] (អភិសម្ពុទ្ធគាថា) ព្រះបាទឯករាជ អ្នកមានអំពើអាក្រក់ នៅក្នុងក្រុងបុប្ផវតីនោះ សួររកផ្លូវទៅព្រហ្មលោក និងបុរោហិត ឈ្មោះខណ្ឌហាល ជាពូជពង្សព្រហ្ម ជាមនុស្សល្ងង់វង្វេងថា ម្នាលព្រាហ្មណ៍ អ្នកជាមនុស្សឈ្លាសក្នុងធម៌វិន័យ សូមអ្នកប្រាប់ផ្លូវឋានសួគ៌ តាមទំនងដែលពួកជនធ្វើបុណ្យទាំងឡាយ ហើយចេញចាកលោកនេះ ទៅកាន់សុគតិដូច្នោះ។

[៣៨៣] (ខណ្ឌហាលព្រាហ្មណ៍បុរោហិតទូលថា) បពិត្រព្រះទេវៈ ពួកជនធ្វើបុណ្យទាំងឡាយ ឲ្យទានដ៏ក្រៃលែង សម្លាប់បុគ្គលដែលមិនគួរសម្លាប់ទាំងឡាយ ហើយទៅកាន់សុគតិយ៉ាងនេះ។

[៣៨៤] (ព្រះបាទឯករាជ...) ទានដ៏ក្រៃលែងនុ៎ះដូចម្តេច ក្នុងលោកនេះ បុគ្គលទាំងឡាយដូចម្តេច ដែលមិនគួរសម្លាប់ ចូរអ្នកប្រាប់សេចក្តីនុ៎ះដល់យើង យើងនឹងបូជា នឹងឲ្យទានទាំងឡាយ។

[៣៨៥] (ខណ្ឌហាលព្រាហ្មណ៍...) ហាពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជាដោយព្រះរាជបុត្រទាំងឡាយផង ដោយព្រះអគ្គមហេសីទាំងឡាយផង ដោយអ្នកនិគម (សេដ្ឋី) ទាំងឡាយផង បពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជាដោយគោឧសភ សេះអាជានេយ្យបួន ៗ ដោយពួកសត្វបួន ៗ ទាំងអស់។

[៣៨៦] សំឡេងគឹកកងតែមួយ សំឡេងគួរខ្លាច លាន់ឮឡើងក្នុងវាំង ព្រោះឮព្រះរាជឱង្ការនោះថា ព្រះកុមារទាំងឡាយ និងព្រះអគ្គមហេសីទាំងឡាយ ត្រូវសម្លាប់។

[៣៨៧] (ព្រះរាជា...) អ្នកទាំងឡាយ ចូរទៅប្រាប់កុមារទាំងឡាយ គឺចន្ទកុមារ ១ សុរិយកុមារ ១ ភទ្ទសេនកុមារ ១ សុរកុមារ ១ វាមគោត្តកុមារ ១ ថា អ្នកទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញ។

[៣៨៨] អ្នកទាំងឡាយ ចូរប្រាប់កុមារីទាំងឡាយ គឺកុមារីឈ្មោះឧបសេនា ១ កោកិលា ១ មុទិតា ១ នន្ទា ១ ថា នាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញ។

[៣៨៩] អ្នកទាំងឡាយ ចូរប្រាប់មហេសីអញ គឺនាងវិជយា ១ នាងឯរាវតី ១ នាងកេសិនី ១ នាងសុនន្ទា ១ ដែលជាស្រ្តីបរិបូណ៌ដោយលក្ខណៈដ៏ប្រសើរថា នាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញ។

[៣៩០] អ្នកទាំងឡាយ ចូរប្រាប់គហបតីទាំងឡាយ គឺគហបតីឈ្មោះបុណ្ណមុខៈ ១ ភទ្ទិយៈ ១ សិង្គាលៈ ១ វឌ្ឍៈ ១ ថា ចូរអ្នកទាំងឡាយមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញ។

[៣៩១] (អភិសម្ពុទ្ធគាថា) ពួកគហបតីទាំងនោះ មកជួបជុំគ្នា ដេរដាសដោយកូន និងប្រពន្ធក្នុងទីនោះ ក្រាបបង្គំទូលថា បពិត្រព្រះទេវៈ សូមព្រះអង្គធ្វើយើងខ្ញុំទាំងអស់ ឲ្យមានជុកលើក្បាលវិញ ពុំនោះសោត សូមព្រះអង្គប្រកាសនូវយើងខ្ញុំថាជាទាសៈ។

[៣៩២] (ព្រះរាជា...) អ្នកទាំងឡាយ ចូរនាំមកនូវដំរីរបស់អញឈ្មោះអភយង្ករៈ ១ នាឡាគិរី ១ អច្ចុគ្គតៈ ១ (ឈ្មោះវរុណទន្តៈ) ១ ដំរីទាំងឡាយនោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញយ៉ាងឆាប់។ អ្នកទាំងឡាយ ចូរនាំមកនូវសេះកែវរបស់អញ គឺសេះឈ្មោះកេសី ១ សុរាមុខៈ ១ បុណ្ណកៈ ១ វិនតកៈ ១ សេះទាំងឡាយនោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញយ៉ាងឆាប់។ អ្នកទាំងឡាយ ចូរនាំយកគោឧសភទាំងនោះរបស់អញ គឺគោឧសភឈ្មោះយូថបតិ ១ អនោជៈ ១ និសភៈ ១ គវម្បតិ ១ មកដល់អញ ជនទាំងឡាយ ចូរធ្វើកិច្ចការទាំងពួងក្នុងទីចំពោះមុខអញ និងបូជា និងឲ្យទានទាំងឡាយ។ អ្នកទាំងឡាយ ចូរតាក់តែងគ្រឿងបូជាគ្រប់មុខ កាលបើព្រះអាទិត្យរះឡើងហើយ អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់ពួកកុមារ មានចន្ទកុមារជាដើមថា កុមារទាំងឡាយ ចូររីករាយអស់ ១ យប់នេះចុះ។ អ្នកទាំងឡាយ ចូរដំកល់ទុកនូវគ្រឿងយ័ញ្ញគ្រប់មុខ កាលបើព្រះអាទិត្យរះឡើង អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់កុមារទាំងឡាយក្នុងកាលឥឡូវនេះថា រាត្រីថ្ងៃនេះឯង ជារាត្រីបំផុត។

[៣៩៣] (អភិសម្ពុទ្ធគាថា) ព្រះរាជមាតា (ព្រះបាទឯករាជ) ទ្រង់ព្រះកន្សែង ទ្រង់ស្តេចមកអំពីវិមាន ទ្រង់មានព្រះរាជសវនីយ៍ សួរនូវសេចក្តីនោះនឹងព្រះរាជានោះថា នែកូន ឮថា កូនឯងនឹងបូជាយ័ញ្ញ ដោយព្រះរាជបុត្រទាំង ៤ នាក់មែនឬ។

[៣៩៤] (ព្រះបាទឯករាជ...) កាលបើខ្ញុំសម្លាប់ចន្ទកុមារហើយ បុត្ររបស់ខ្ញុំទាំងអស់ ក៏ខ្ញុំលះបង់ដើម្បីបូជាយ័ញ្ញដែរ លុះខ្ញុំបូជាដោយបុត្រទាំងឡាយហើយ ខ្ញុំនឹងទៅកាន់សុគតិសួគ៌។

[៣៩៥] (ព្រះរាជមាតា...) ម្នាលកូន អ្នកកុំជឿខណ្ឌហាលព្រាហ្មណ៍នោះថា សុគតិបានដោយការបូជាបុត្រឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរក មិនមែនជាផ្លូវទៅកាន់ឋានសួគ៌ទេ។ ម្នាលកូនកោណ្ឌញ្ញគោត្រ ចូរអ្នកឲ្យទានទាំងឡាយ (អ្នក) កុំបៀតបៀនសព្វសត្វដែលកើតហើយ នឹងត្រូវកើតឡើយ នេះជាផ្លូវនៃសុគតិ ផ្លូវ (នៃសុគតិ) មិនមែនបានដោយការបូជាបុត្រទេ។

[៣៩៦] (ព្រះបាទឯករាជ...) ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យខណ្ឌហាលអាចារ្យ បូជាបុត្រទាំងឡាយ ដែលគេលះបង់បានដោយកម្រហើយ នឹងទៅកាន់សុគតិសួគ៌។

[៣៩៧] (អភិសម្ពុទ្ធគាថា) ចំណែកខាងព្រះវសវត្តី ជាព្រះរាជបិតា ត្រាស់សួរហេតុនោះ ចំពោះព្រះបាទឯករាជ ជារាជបុត្រកើតអំពីព្រះឱរានោះថា ម្នាលកូន ឮថា អ្នកនឹងបូជាយ័ញ្ញដោយបុត្រទាំង ៤ មែនឬ។

[៣៩៨] (ព្រះបាទឯករាជ...) កាលបើខ្ញុំសម្លាប់ចន្ទកុមារ (បូជា) ហើយ បុត្រទាំងឡាយទាំងអស់ ក៏ខ្ញុំលះបង់ដែរ ខ្ញុំបូជាយ័ញ្ញដោយបុត្រទាំងឡាយហើយ នឹងទៅកាន់សុគតិសួគ៌។

[៣៩៩] (ព្រះរាជបិតា...) ម្នាលកូន អ្នកកុំជឿខណ្ឌហាលព្រាហ្ម៍ថា សុគតិ មានដោយការបូជាបុត្រឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរកទេ មិនមែនជាផ្លូវទៅកាន់ឋានសួគ៌ទេ។ ម្នាលកូនកោណ្ឌញ្ញគោត្រ ចូរអ្នកឲ្យទានទាំងឡាយ (អ្នក) កុំបៀតបៀនសព្វសត្វទាំងឡាយដែលកើតហើយ និងត្រូវកើត នេះជាផ្លូវនៃសុគតិ ផ្លូវ (នៃសុគតិ) មិនមែនបានដោយការបូជាបុត្រទេ។

[៤០០] (ព្រះបាទឯករាជ...) ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យនៃខណ្ឌហាលអាចារ្យ ខ្ញុំបូជាបុត្រទាំងឡាយ ដែលគេលះបង់បានដោយកម្រ ហើយនឹងទៅកើតក្នុងសុគតិសួគ៌។

[៤០១] (ព្រះរាជបិតា...) ម្នាលកូន កោណ្ឌញ្ញគោត្រ អ្នកចូរឲ្យទានទាំងឡាយ (អ្នក) កុំបៀតបៀនសព្វសត្វដែលកើតហើយ និងត្រូវកើតទាំងឡាយឡើយ អ្នកចូរជាមនុស្សដែលកូនទាំងឡាយចោមរោមហើយ រក្សាដែន និងជនបទចុះ។

[៤០២] (ចន្ទកុមារ...) បពិត្រព្រះទេវៈ ព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំទាំងឡាយ សូមជាអ្នកជាប់ចំណង ហើយឃ្វាលដំរី និងសេះ។ បពិត្រព្រះទេវៈ ព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណងហើយ នឹងចោលអាចម៍ដំរី។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណងហើយ នឹងចោលអាចម៍សេះ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ព្រះអង្គមានប្រាថ្នា (ដើម្បីព្រះរាជទាន) ដល់ខណ្ឌហាលព្រាហ្មណ៍ណា សូមទ្រង់ព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះចុះ ពុំនោះសោត នឹងសូមព្រះអង្គបំបរបង់ទូលបង្គំជាខ្ញុំទាំងឡាយ ចេញចាកដែន ក៏ទូលបង្គំជាខ្ញុំទាំងឡាយ នឹងត្រាច់ទៅកាន់ភិក្ខាចារ។

[៤០៣] (ព្រះបាទឯករាជ...) អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយ យំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយ លែងកុមារទាំងឡាយទៅ ការបូជាយ័ញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ។

[៤០៤] (ខណ្ឌហាលព្រាហ្មណ៍) ទូលព្រះបង្គំជាខ្ញុំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយ័ញ្ញនុ៎ះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងធ្វើឲ្យកើតឡើងបានផង កាលបើគ្រឿងយ័ញ្ញដែលទូលព្រះបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វីព្រះអង្គធ្វើឲ្យខានទៅវិញ។ ជនទាំងឡាយណា បូជាយ័ញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយ័ញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយ័ញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងឡាយ ទាំងអស់នោះ រមែងទៅកាន់សុគតិ។

[៤០៥] (ចន្ទកុមារ...) ចុះព្រះអង្គឲ្យពួកព្រាហ្មណ៍ទាយសួស្តីរបស់ទូលព្រះបង្គំជាខ្ញុំ ពីមុនមកដើម្បីអ្វី បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គឲ្យគេសម្លាប់ពួកទូលបង្គំជាខ្ញុំ ដើម្បីប្រយោជន៍ដល់យ័ញ្ញដោយឥតហេតុ។ ពីដើម កាលដែលទូលព្រះបង្គំជាខ្ញុំទាំងឡាយនៅក្មេងនៅឡើយ (ម្តេចក៏) ព្រះអង្គមិនសម្លាប់ មិនឲ្យគេសម្លាប់ទៅ បពិត្រព្រះបិតា ឥឡូវនេះ ទូលបង្គំជាខ្ញុំទាំងឡាយ ជាក្មេងពេញកម្លោះ ជាអ្នកឥតប្រទូស្ត ក៏ស្រាប់តែព្រះអង្គឲ្យគេសម្លាប់។ បពិត្រមហារាជ សូមព្រះអង្គទតមើល ទូលបង្គំជាខ្ញុំទាំងឡាយ ដែលពាក់គ្រឿងក្រោះជិះដំរី ជិះសេះច្បាំងហើយ និងកំពុងច្បាំង មនុស្សទាំងឡាយបែបខ្ញុំនេះ មិនមែនជាមនុស្សសម្រាប់បូជាយ័ញ្ញទេ។ ជនទាំងឡាយ តែងបញ្ជូនពួកមនុស្សដូចទូលបង្គំជាខ្ញុំ ទៅក្នុងបច្ចន្តគ្រាម ដែលបះបោរឡើងហើយ ឬក្នុងដងព្រៃ បពិត្រព្រះបិតា កាលបើដូច្នោះ ទូលបង្គំជាខ្ញុំទាំងឡាយ មិនត្រូវព្រះអង្គឲ្យគេសម្លាប់ ក្នុងទីមិនជាឱកាស ដោយឥតហេតុទេ។ មេសត្វស្លាបទាំងឡាយណានីមួយ ធ្វើសម្បុកដោយស្មៅទាំងឡាយហើយនៅ កូនទាំងឡាយជាទីស្រឡាញ់របស់មេសត្វស្លាបទាំងនោះ បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គនៅតែឲ្យគេសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយ។ ព្រះអង្គកុំជឿពាក្យខណ្ឌហាលព្រាហ្មណ៍នោះថា ខណ្ឌហាលព្រាហ្មណ៍ មិនគប្បីសម្លាប់អញខ្ញុំដូចនេះឡើយ បពិត្រព្រះទេវៈ ព្រោះខណ្ឌហាលព្រាហ្មណ៍នោះ សម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយហើយ គប្បីសម្លាប់ព្រះអង្គក្នុងកាលជាលំដាប់។ បពិត្រមហារាជ ព្រះរាជាទាំងឡាយ តែងព្រះរាជទានស្រុកដ៏ប្រសើរផង និគមដ៏ប្រសើរផង ភោគៈផង ដល់ព្រាហ្មណ៍នោះ កាលបើដូច្នោះ ពួកព្រាហ្មណ៍ទាំងនោះ ជាអ្នកបរិភោគរាល់ ៗ ដុំបាយដ៏ថ្លៃថ្លៃង តែងបានបរិភោគរាល់ៗ ត្រកូល។ បពិត្រមហារាជ ព្រាហ្មណ៍នោះ ប្រាថ្នាដើម្បីប្រទូស្តចំពោះជនអ្នកឲ្យទាំងនោះ ដូចជាព្រះអង្គ បពិត្រព្រះទេវៈ ពួកព្រាហ្មណ៍ទាំងនុ៎ះ ជាមនុស្សអកតញ្ញូដោយច្រើន។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណងហើយ នឹងឃ្វាលដំរី និងសេះ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទាននូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយ ជាប់ចំណងហើយ នឹងចាក់អាចម៍ដំរី។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណងនឹងចាក់អាចម៍សេះ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់នូវទូលបង្គំជាខ្ញុំទាំងឡាយឡើយ ព្រះអង្គសព្វព្រះរាជហឫទ័យចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមព្រះរាជទាននូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះវិញចុះ ពុំនោះសោត ទូលបង្គំជាខ្ញុំទាំងឡាយ បើព្រះអង្គបំបរបង់ចេញចាកដែន នឹងត្រាច់ទៅកាន់ភិក្ខាចារ។

[៤០៦] (ព្រះបាទឯករាជ...) អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយយំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយលែងកុមារទាំងឡាយទៅ ការបូជាយ័ញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ។

[៤០៧] (ខណ្ឌហាលព្រាហ្មណ៍) ទូលបង្គំជាខ្ញុំ បានក្រាបទូលតាំងពីដើមមកថា ការបូជាយ័ញ្ញនុ៎ះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងឲ្យកើតឡើងបានផង កាលបើគ្រឿងយ័ញ្ញដែលទូលបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វីក៏ព្រះអង្គធ្វើឲ្យអាក់ខានទៅវិញ។ ជនទាំងឡាយណា បូជាយ័ញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយ័ញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយ័ញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងអស់ (នោះ) រមែងទៅកាន់សុគតិ។

[៤០៨] (ចន្ទកុមារ...) បើប្រាកដជាបុគ្គលទាំងឡាយបូជាយ័ញ្ញដោយបុត្រទាំងឡាយហើយ ច្យុតចាកមនុស្សលោកនេះ រមែងទៅកាន់ទេវលោក បពិត្រមហារាជ ចូរព្រាហ្មណ៍បូជាមុនចុះ សឹមព្រះអង្គបូជាជាខាងក្រោយ។ ឮថា បើប្រាកដជាបុគ្គលទាំងឡាយ បូជាយ័ញ្ញដោយបុត្រទាំងឡាយហើយ ច្យុតអំពីមនុស្សលោកនេះ រមែងទៅកាន់ទេវលោក ចូរខណ្ឌហាលព្រាហ្មណ៍ហ្នឹងឯង បូជាដោយកូនទាំងឡាយរបស់ខ្លួនចុះ។ បើខណ្ឌហាលព្រាហ្មណ៍ដឹងយ៉ាងនេះហើយ ហេតុអ្វីក៏មិនសម្លាប់កូនតូច ៗ ទាំងឡាយផង មិនសម្លាប់ជនជាញាតិទាំងអស់

ផង មិនសម្លាប់ខ្លួនឯងផង។ ជនទាំងឡាយណា បូជាយ័ញ្ញដោយខ្លួនក្តី ជនទាំងឡាយណាឲ្យគេបូជាយ័ញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយ័ញ្ញប្រាកដដូច្នេះក្តី ជនទាំងអស់ (នោះ) រមែងទៅកាន់នរក។

[៩០៩] ម្តេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា កុំទ្រង់សម្លាប់បុត្រ ដែលកើតអំពីទ្រង់ឡើយ។ ម្តេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា កុំទ្រង់សម្លាប់បុត្រ ដែលកើតអំពីខ្លួនឡើយ។ ខ្ញុំជាអ្នកប្រាថ្នាប្រយោជន៍ចំពោះព្រះរាជា ប្រយោជន៍ចំពោះអ្នកជនបទទាំងអស់ ឥតមាននរណាមួយថ្នាំងថ្នាក់ចិត្តនឹងខ្ញុំឡើយ (ហេតុអ្វីក៏) អ្នកជនបទមិនក្រាបទូលឲ្យទ្រង់ជ្រាប។

[៩១០] ម្នាលនាងយរណីទាំងឡាយ (ស្រីមេផ្ទះ) ចូរនាងទាំងឡាយ ទៅអង្វរព្រះរាជបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារទាំងឡាយ ដូចជាសីហៈ ជាអ្នកមិនប្រទូស្ត ម្នាលនាងយរណីទាំងឡាយ ចូរនាងទាំងឡាយទៅនិយាយអង្វរព្រះបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារទាំងឡាយ ជាទីអាល័យរបស់សត្វលោកទាំងអស់។

[៩១១] បើដូច្នោះ គួរតែអញកើតក្នុងត្រកូលអ្នកធ្វើរថ ឬអ្នកចោលសម្រាម ឬកើតក្នុងត្រកូលវេស្សៈ ទើបព្រះរាជានឹងមិនសម្លាប់អញ ដើម្បីយ័ញ្ញក្នុងថ្ងៃនេះ។

[៩១២] ម្នាលពួកស្រីអ្នកមានគំនិតទាំងឡាយ ចូរនាងទាំងអស់ទៅក្រាបទៀបបាទានៃខណ្ឌហាលព្រាហ្មណ៍ជាម្ចាស់ហើយ (ប្រាប់ថា) ខ្ញុំមិនឃើញកំហុសសោះ។ ម្នាលពួកស្រីជាមេផ្ទះទាំងអស់គ្នា ចូរនាងទាំងឡាយទៅក្រាបទៀបបាទានៃខណ្ឌហាលព្រាហ្មណ៍ជាម្ចាស់ហើយ (និយាយថា) បពិត្រលោកខណ្ឌហាលដ៏ចំរើន យើងទាំងឡាយបានប្រទូស្តអ្វីដល់លោក។

[៩១៣] លំដាប់នោះ ព្រះនាងសេលា ជាព្រះរាជធីតាគួរអាណិត បានឃើញព្រះភាតាទាំងឡាយ ដែលគេនាំខ្លួនទៅហើយ ទ្រង់ព្រះកន្សែងថា ឮថាយ័ញ្ញ ព្រះរាជបិតាអញ ទ្រង់ប្រាថ្នាឋានសួគ៌ឲ្យប្រព្រឹត្តទៅហើយ។

[៩១៤] (លំដាប់នោះ) វសុលរាជកុមារបម្រះននៀលក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ទ្រង់ព្រះកន្សែងអង្វរថា បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់បិតារបស់ទូលបង្គំជាខ្ញុំឡើយ ព្រោះទូលបង្គំជាខ្ញុំនៅក្មេង ពុំទាន់ធំនៅឡើយ។

[៩១៥] (ព្រះរាជា...) ម្នាលវសុលកុមារ នុ៎ះបិតារបស់ឯង ចូរឯងស្ងប់រម្ងាប់ជាមួយនឹងបិតារបស់ឯងចុះ ឯងយំស្រែកក្នុងព្រះរាជវាំង ឈ្មោះថាញ៉ាំងទុក្ខយ៉ាងខ្លាំង ឲ្យកើតឡើងដល់អញ អ្នកទាំងឡាយ ចូរលែងពួកកុមារក្នុងកាលឥឡូវនេះចុះ ការបូជាយ័ញ្ញដោយកូនរបស់អញ ស្មមលើកលែងចុះ។

[៩១៦] (ខណ្ឌហាលព្រាហ្មណ៍) ទូលបង្គំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយ័ញ្ញនេះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងឲ្យកើតឡើងបានផង កាលបើគ្រឿងយ័ញ្ញដែលទូលបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វីក៏ព្រះអង្គធ្វើឲ្យអាក់ខានទៅវិញ។ ជនទាំងឡាយណា បូជាយ័ញ្ញដោយខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយ័ញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយ័ញ្ញដែលអ្នកផងកំពុងបូជា ប្រាកដដូច្នេះក្តី ជនទាំងអស់នោះ រមែងទៅកើតក្នុងសុគតិ។

[៩១៧] បពិត្រព្រះឯករាជ យ័ញ្ញ ទូលបង្គំជាខ្ញុំចាត់ចែងរៀបចំដើម្បីព្រះអង្គ ដោយរតនៈទាំងពួងហើយ បពិត្រព្រះទេវៈ សូមព្រះអង្គយាងចេញទៅ ព្រះអង្គនឹងទៅរីករាយក្នុងឋានសួគ៌។

[៩១៨] (អភិសម្ពុទ្ធគាថា) ពួកស្ត្រីទាំង ៧០០ នុ៎ះ នៅក្មេង ៗ ដែលជាភរិយាចន្ទកុមារ រំសាយកេសា ទួញយំដើរតាមផ្លូវទៅ។ ចំណែកពួកស្ត្រីឯទៀត ក៏ចេញទៅដោយសេចក្តីសោកស្តាយ រំសាយកេសា ទួញយំដើរតាមផ្លូវទៅ ដូចជាទេវតា (ចោមរោមទេវបុត្រដែលរៀបច្យុត) ក្នុងនន្ទនវនឧទ្យាន។

[៩១៩] ចន្ទកុមារ និងសុរិយកុមារ ទ្រទ្រង់សំពត់ដ៏ស្អាតដែលកើតក្នុងដែនកាសី ជាអ្នកទ្រទ្រង់កុណ្ឌល លាបស្រឡាយដោយកំញាន និងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅដើម្បីប្រយោជន៍ដល់យ័ញ្ញនៃព្រះបាទឯករាជ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកទ្រទ្រង់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកទ្រទ្រង់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ។ ចន្ទកុមារ និងសុរិយកុមារ ដែលជាអ្នកបរិភោគសាច់ដ៏មានរស ជាអ្នកដែលខ្ទាន់ព្រះកេសផ្ចិតៗស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅដើម្បីប្រយោជន៍ដល់យ័ញ្ញនៃព្រះបាទឯករាជ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកបរិភោគនូវសាច់ដ៏មានរស ជាអ្នកដែលខ្ទាន់ព្រះកេសផ្ចិតៗស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកបរិភោគសាច់ដ៏មានរស ជាអ្នកដែលខ្ទាន់ព្រះកេសផ្ចិតៗស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ។ កាលពីមុន ពួកពលដំរី តែងតាមហែហមនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់លើខ្នងដំរីដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទទទេ។ កាលពីមុន ពួកពលសេះ តែងតាមហែនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់លើខ្នងសេះដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទទទេ។ កាលពីមុន ពួករថ តែងតាមហែនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់ក្នុងកណ្តាលរថដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទទទេ។ កាលពីមុន ចន្ទកុមារ និងសុរិយកុមារណា ស្តេចទៅដោយព្រះទីនាំងអស្សរត ដែលតាក់តែងដោយគ្រឿងមាស ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទទទេ។

[៩២០] (មហាជន...) ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកព្រះរាជបុត្រ ៤ ព្រះអង្គ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកព្រះរាជកញ្ញាទាំង ៤ ព្រះអង្គ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកព្រះមហេសីទាំង ៤ ព្រះអង្គ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកគហបតីទាំង ៤ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកដំរីទាំង ៤ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកសេះទាំង ៤ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកគោឧសភ ៤ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកសត្វបួនៗ គ្រប់មុខ បូជាយ័ញ្ញក្នុងទីនុ៎ះ។

[៩២១] ប្រាសាទនេះ ជាវិការៈនៃមាស ដេរដាសដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ផ្ទះកំពូលនេះ ជាវិការៈនៃមាស ដេរដាសដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ឱទ្យាននេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ព្រៃអសោកនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ព្រៃកណ្ណិការនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ព្រៃច្រនៀងនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ព្រៃស្វាយនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ស្រះបោក្ខរណីនេះ ដេរដាស ពាសពេញដោយផ្កាឈូកស ឈូកក្រហម ទាំងទូកដែលរចនាដោយមាស វិចិត្រដោយភ្ញីវល្លិ៍ ជាទីរីករាយចិត្តដោយក្រៃលែង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។

[៩២២] ដំរីរ័តន៍នេះ ជាដំរីឈ្មោះឯរាវ័ណ មានកំឡាំង មានភ្លុក ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ សេះរ័តន៍នេះ ជាសេះមានក្រចកមួយ មានសន្ទុះរហ័ស ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ រថសេះនេះ មានសូរសព្ទដូចសំឡេងនៃស្រវសាលី ជារថដ៏ស្អាត វិចិត្រដោយរតនវត្ថុ ជាលំអរបស់ពួកព្រះអយ្យបុត្រ ដូចជាពួកទេវតាក្នុងនន្ទនវ័ន ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ម្តេចក៏ព្រះរាជាភាន់ច្រឡំ នឹងបូជាយ័ញ្ញដោយព្រះរាជបុត្រទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត (ឥតទោស) ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍។ ម្តេចក៏ព្រះរាជាភាន់ច្រឡំ នឹងបូជាយ័ញ្ញដោយព្រះរាជកញ្ញាទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍។ ម្តេចក៏ព្រះរាជាភាន់ច្រឡំ នឹងបូជាយ័ញ្ញដោយព្រះមហេសីទាំង ៤ ព្រះអង្គ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍។ ម្តេចក៏ព្រះរាជាភាន់ច្រឡំ នឹងបូជាយ័ញ្ញដោយគហបតីទាំង ៤ នាក់ ដែលមានសម្បុរលឿង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបដោយខ្លឹមចន្ទន៍។ ស្រុក និងនិគមទាំងឡាយ សូន្យឥតមនុស្ស ក្លាយទៅជាព្រៃធំ យ៉ាងណាមិញ កាលបើចន្ទកុមារ និងសុរិយកុមារ ត្រូវព្រះរាជាយកទៅបូជាយ័ញ្ញហើយ ក្រុងបុប្ផវតី ក៏នឹង (ស្ងាត់សូន្យឈឹង) យ៉ាងនោះដែរ។

[២២៣] (ព្រះនាងគោតមីទេវី...) ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាកសេចក្តីចំរើន ប្រឡាក់ប្រឡូសដោយអាចម៍ដីពុំខាន បើជនសម្លាប់ចន្ទកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងបែកធ្លាយ។ ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាកសេចក្តីចំរើន ប្រឡាក់ប្រឡូសដោយអាចម៍ដីពុំខាន បើជនសម្លាប់សុរិយកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងបែកធ្លាយ។

[៩២៤] ស្ត្រីទាំងឡាយនេះ គឺនាងយដ្ឋិកា នាងឧបរិក្ខី នាងបោក្ខរណី និងនាងគាយិកា ជាអ្នកពោលពាក្យជាទីស្រឡាញ់ទៅរកគ្នានឹងគ្នា ម្តេចក៏មិនរាំឲ្យចន្ទកុមារ និងសុរិយកុមារសប្បាយរីករាយ (ព្រោះស្ត្រីដទៃ) ស្មើដោយស្ត្រីទាំងនោះ មិនមានទេ។

[២២៥] សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែចន្ទកុមារដែលគេនាំទៅដើម្បីសម្លាប់ នែខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯងចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែសុរិយកុមារដែលគេនាំទៅដើម្បីសម្លាប់ នែខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯងចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែចន្ទកុមារ ដែលគេនាំទៅដើម្បីសម្លាប់ នែខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង ចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែសុរិយកុមារ ដែលគេនាំយកទៅដើម្បីសម្លាប់ នែខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធរបស់អ្នក ចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ។ អ្នកឯងសម្លាប់ពួកកុមារ ដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត នែខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ។ អ្នកឯងសម្លាប់ពួកកុមារ ដែលសត្វលោកទាំងអស់ អាឡោះអាល័យ នែខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ។ អ្នកឯងសម្លាប់ពួកកុមារ ដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត នែខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯងកុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ។ អ្នកឯងសម្លាប់ពួកកុមារ ដែលសត្វលោកទាំងអស់អាឡោះអាល័យ នែខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯងកុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ។

[៩២៦] (ចន្ទកុមារ...) បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយឃ្វាលដំរី និងសេះ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយចោលអាចម៍ដំរី។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយសូមឲ្យជាអ្នកជាប់ចំណង ហើយចោលអាចម៍សេះ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំឡើយ បើព្រះអង្គសព្វព្រះទ័យចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះចុះ ពុំនោះសោត សូមព្រះអង្គបំបរបង់ឲ្យចេញចាកដែន ខ្ញុំព្រះអង្គនឹងត្រាច់ទៅកាន់ភិក្ខាចារ។ បពិត្រព្រះសម្មតិទេព នារីពួកខ្លះ សូម្បីជាស្ត្រីកំសត់ នៅតែចង់បានកូន ហើយបន់ស្រន់ទេព្តា ស៊ូលះបង់ចំណង់ប្លែក នៅតែមិនបានកូនទាំងឡាយ ក៏មាន។ នារីពួកខ្លះ ធ្វើពាក្យប្រកបដោយសេចក្តីប៉ុនប៉ងថា កូនទាំងឡាយរបស់យើង ចូរកើតបន្ទាប់ពីនោះ ចៅទាំងឡាយចូរកើតទៀត បពិត្រព្រះសម្មតិទេព កាលបើដូច្នេះ (ហេតុអ្វីក៏) ព្រះអង្គសម្លាប់ទូលព្រះបង្គំទាំងឡាយ ដើម្បីបូជាយ័ញ្ញ ដោយមិនសមហេតុ។ ពួកស្ត្រីតែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ ព្រះអង្គកុំបូជាយ័ញ្ញនេះ ដោយបុត្រទាំងឡាយ ដែលបានដោយលំបាកឡើយ។ ពួកស្ត្រីតែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមព្រះអង្គកុំញុំាងទូលព្រះបង្គំទាំងឡាយ ឲ្យព្រាត់ប្រាសចាកមាតា និងបុត្រទាំងឡាយ ដែលបានដោយលំបាក។

[៩២៧] បពិត្រព្រះមាតា ព្រះអង្គបានបង្កើតបុត្រ គឺចន្ទកុមារមក មានទុក្ខព្រួយច្រើនណាស់ ព្រោះតែការចិញ្ចឹម ខ្ញុំជាកូនសូមក្រាបថ្វាយបង្គំព្រះបាទានៃព្រះមាតា សូមឲ្យព្រះរាជបិតា បានទៅបរលោក (ដែលបរិបូណ៌ដោយសម្បត្តិ) ចុះ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងទៅកាន់ទីព្រាត់ប្រាសដើម្បីប្រយោជន៍ដល់យ័ញ្ញរបស់ព្រះបាទឯករាជ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងធ្វើសេចក្តីសោកក្នុងហឫទ័យនៃព្រះមាតា ហើយទៅកាន់ទីព្រាត់ប្រាស។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ហើយទៅកាន់ទីព្រាត់ប្រាស។

[៩២៨] (ព្រះមាតា...) ម្នាលគោតមីបុត្រ ណ្ហើយចុះ បាឯងចូរបួងមោលីដោយស្លឹកឈូក បាឯងចូរប្រដាប់ផ្កាកម្រង ដែលលាយដោយត្របកផ្កាចម្បានេះជាប្រក្រតី ពីដើមរបស់បា។ ហាក បាឯងធ្លាប់លាបស្រឡាបដោយខ្លឹមចន្ទន៍ទាំងឡាយណា ហើយល្អរុងរឿងក្នុងរាជបរិស័ទ (នេះ) ជាគ្រឿងលាបរបស់បា បាចូរលាបខ្លឹមចន្ទន៍ ជាទីបំផុតចុះ។ ហាក បាឯងស្លៀកដណ្តប់សំពត់ទាំងឡាយណា មានសាច់ទន់ ៗ រមែងល្អរុងរឿង ក្នុងរាជបរិស័ទ (នេះ) ជាសំពត់មានសាច់ទន់ បាចូរស្លៀកសំពត់ដែលកើតក្នុងដែនកាសី មានក្នុងទីបំផុតចុះ។

បាឯងល្អរុងរឿងដោយហត្ថាភរណៈណា ក្នុងរាជបរិស័ទ បាចូរពាក់នូវហត្ថាភរណៈ ដំហើយដោយកែវមុក្តា កែវមណី និងមាស (នោះចុះ)។

[៩២៩] (នាងចន្ទាទេវី...) ព្រះបាទឯករាជនេះ ជាអ្នករក្សាដែន ជាម្ចាស់ផែនដី ជាអ្នកទទួលមតិករបស់អ្នកជនបទ ជាឥស្សរៈលើលោក ទ្រង់ជាធំ តែមិនញុំាងសេចក្តីស្នេហាឲ្យកើតក្នុងព្រះរាជបុត្រដោយពិត។

[៩៣០] (ព្រះបាទឯករាជ...) បុត្រប្រុសទាំងឡាយ ជាទីស្រឡាញ់របស់អញ ម្យ៉ាងទៀត នាងឯងក្តី ភរិយាទាំងឡាយ (ឯទៀត) ក្តី ក៏ជាទីស្រឡាញ់របស់អញ ប៉ុន្តែអញចង់បានឋានសួគ៌ទេតើ បានជាអញឲ្យគេសម្លាប់ដោយហេតុនោះ។

[៩៣១] (នាងចន្ទាទេវី...) បពិត្រព្រះសម្មតិទេព សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់មុន កុំឲ្យសេចក្តីទុក្ខបំបែកហឫទ័យខ្ញុំម្ចាស់ឡើយ បពិត្រព្រះសម្មតិទេព បុត្ររបស់ព្រះអង្គ ជាអ្នកមានគ្រឿងអលង្ការប្រដាប់ហើយ ជាបុត្រល្អល្អះ ជាសុខុមាលជាតិ។ បពិត្រព្រះអង្គជាម្ចាស់គេ ណ្ហើយចុះ សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់ជាស្ត្រីមានសេចក្តីសោកជាមួយគ្នានឹងចន្ទកុមារ សូមព្រះអង្គធ្វើបុណ្យឲ្យបរិបូណ៌ចុះ យើងខ្ញុំទាំងពីរនាក់ នឹងត្រាច់ទៅក្នុងបរលោក។

[៩៣២] (ព្រះបាទឯករាជ...) ម្នាលនាងចន្ទាមានភ្នែកវិសេសវិសាល នាងកុំយំឡើយ ជនទាំងឡាយជាបងប្អូនខាងប្តីរបស់នាងជាច្រើន ជនទាំងនោះ នឹងញុំាងនាងឲ្យត្រេកអរ ព្រោះគោតមីបុត្រ ត្រូវគេបូជាយ័ញ្ញហើយ។

[៩៣៣] (អភិសម្ពុទ្ធគាថា) កាលបើព្រះបាទឯករាជ ទ្រង់ត្រាស់យ៉ាងនេះហើយ នាងចន្ទាទេវីប្រហារខ្លួនឯងដោយបាតដៃទាំងឡាយ (ទ្រង់ពិលាបថា) ការរស់នៅក្នុងលោកនេះ ល្មមប៉ុណ្ណឹងហើយ អញនឹងផឹកថ្នាំពិសឲ្យស្លាប់។ ព្រោះថា ជនទាំងឡាយ ជាញាតិមិត្រ ជាសំឡាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រទាំងឡាយ ដែលកើតអំពីព្រះឱរាដូច្នេះឡើយ។ ជនទាំងឡាយ ជាញាតិមិត្រ ជាសំឡាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រ ដែលកើតអំពីព្រះអង្គដូច្នេះឡើយ។ បុត្ររបស់ខ្ញុំម្ចាស់ទាំងឡាយនេះ ពាក់កម្រងផ្កា ទ្រទ្រង់គ្រឿងប្រដាប់ជាវិការៈនៃមាស សូមព្រះរាជាបូជាយ័ញ្ញដោយរាជបុត្រទាំងឡាយចុះ ប៉ុន្តែសូមព្រះអង្គលែងគោតមីបុត្រ។ បពិត្រមហារាជ សូមព្រះអង្គកាប់ខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយ័ញ្ញគ្រប់ទាំង ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បងដែលជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត។ បពិត្រមហារាជ សូមព្រះអង្គចិញ្ច្រាំខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយ័ញ្ញគ្រប់ទាំង ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បងដែលសត្វលោកទាំងអស់អាឡោះអាល័យឡើយ។

[៩៣៤] (ចន្ទកុមារ...) គ្រឿងអាភរណៈច្រើនយ៉ាង គឺកែវមុក្តា កែវមណី កែវពៃទូរ្យដែលប្រសើរ និងមិនប្រសើរ យើងឲ្យហើយដល់នាងក្នុងរឿងដែលនាងនិយាយល្អហើយ នេះជាអំណោយ ទីបំផុត ចូរមានដល់នាងចុះ។

[៩៣៥] (នាងចន្ទាទេវី...) កាលពីដើម ព្រះរាជបុត្រទាំងឡាយណា ដែលមានកម្រងផ្ការីកសំពោង ពាក់ហើយលើ ក ទាំងឡាយ ថ្ងៃនេះ ព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវ ដែលគេសំលៀងមុត នឹងធ្លាក់លើ ក ទាំងឡាយវិញ។ ពីដើម ព្រះរាជបុត្រទាំងឡាយណា ដែលមានកម្រងផ្កាដ៏វិចិត្រហើយ ពាក់លើ ក ទាំងឡាយ ថ្ងៃនេះ ព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវ ដែលគេសំលៀងមុត នឹងធ្លាក់លើ ក ទាំងឡាយវិញ។ មិនយូរប៉ុន្មានទេ មុខតែដាវនឹងធ្លាក់លើ ក នៃរាជបុត្រទាំងឡាយពុំខាន ហឫទ័យរបស់ខ្ញុំម្ចាស់ ខានបែកធ្លាយឯណាបាន ព្រោះចំណងយ៉ាងមាំ មានដល់ខ្ញុំម្ចាស់ហើយ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់សាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ចូរចេញទៅ ដើម្បីយ័ញ្ញនៃព្រះបាទឯករាជចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ចូរចេញទៅចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជនដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្ងូតៗល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ចូរចេញទៅដើម្បីយ័ញ្ញរបស់ព្រះបាទឯករាជចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជនដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្ងូត ៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ចូរស្តេចចេញទៅចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជនដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្ងូត ៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ។

[៩៣៦] (អភិសម្ពុទ្ធគាថា) កាលបើគ្រឿងប្រដាប់បូជាយ័ញ្ញគ្រប់យ៉ាង ដែលគេចាត់ចែងហើយ កាលបើចន្ទកុមារ និងសុរិយកុមារអង្គុយដើម្បីប្រយោជន៍ដល់យ័ញ្ញ ហើយនាងបញ្ចាលរាជធីតា លើកកំបង់អញ្ជលី ដើរចូលទៅត្រង់ចន្លោះពួកបរិស័ទទាំងពួង (ប្រកាសថា) ខណ្ឌហាលព្រាហ្មណ៍ ជាមនុស្សយល់ខុស ធ្វើបាបកម្ម ដោយពាក្យសច្ចៈណា ខ្ញុំម្ចាស់ព្រមព្រៀងជាមួយនឹងព្រះស្វាមី តាមពាក្យសច្ចៈនុ៎ះ។ ពួកអមនុស្ស ពួកទេវតា និងពួកសត្វកើតហើយ និងសត្វដែលត្រូវកើត មានក្នុងទីនេះ ចូរធ្វើនូវសេចក្តីខ្វល់ខ្វាយចំពោះខ្ញុំ ខ្ញុំសូមព្រមព្រៀង (ជាមួយ) នឹងព្រះស្វាមីហើយ។ ពួកទេវតា ពួកសត្វកើតហើយ និងសត្វដែលត្រូវកើតទាំងអស់ ដែលមកក្នុងទីនេះ សូមអ្នកទាំងឡាយរក្សាខ្ញុំជាមនុស្សអនាថា ដែលស្វែងរកទីពឹង ខ្ញុំសូមអង្វរព្រះស្វាមី ដែលពួកបច្ចាមិត្រផ្ចាញ់មិនបាន ចំពោះលោកទាំងឡាយ។

[៩៣៧] អមនុស្ស (សក្កទេវរាជ) ឮពាក្យនោះហើយ ក៏គ្រវីដម្បងដែក បំភ័យព្រះរាជានោះ ហើយនិយាយនឹងព្រះរាជាដូច្នេះថា ម្នាលស្តេចកាឡកណ្ណី ព្រះអង្គចូរដឹងចុះ កុំឲ្យខ្ញុំសំពងក្បាលព្រះអង្គឡើយ ព្រះអង្គកុំសម្លាប់បុត្រច្បង ជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត។ ម្នាលស្តេចកាឡកណ្ណី ព្រះអង្គធ្លាប់ឃើញអ្នកណា ដែលសម្លាប់បុត្រភរិយា និងសេដ្ឋី គហបតី ជាអ្នកមិនប្រទូស្ត ព្រោះប្រាថ្នាឋានសួគ៌។

[៩៣៨] ខណ្ឌហាលព្រាហ្មណ៍ បានឮពាក្យនោះ ទាំងព្រះរាជាក៏ឃើញសក្កទេវរាជដែលព្រះអង្គមិនធ្លាប់ឃើញនេះ ទើបឲ្យស្រាយចំណងពីជនទាំងពួង ឲ្យដូចជាមិនមានសេចក្តីបៀតបៀន។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកជនដែលមកប្រជុំក្នុងកន្លែងនោះ ក៏នាំគ្នាគប់មួយដុំដី ៗ ម្នាក់ នេះជាការសម្លាប់ខណ្ឌហាលព្រាហ្មណ៍។

[៩៣៩] ពួកជនទាំងពួង ធ្វើបាបកម្មហើយ ទៅកាន់នរកយ៉ាងណា ពួកជនមិនធ្វើបាបកម្ម ហើយទៅអំពីលោកនេះទៅ គប្បីបាននូវសុគតិ យ៉ាងនោះឯង។

[៩៤០] កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជបុរសមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកចួបជុំគ្នា ក្នុងទីនោះ ក៏ប្រជុំគ្នា អភិសេកចន្ទកុមារ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកចួបជុំគ្នា ក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកនូវចន្ទកុមារ។

កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជបរិស័ទដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ពួកជនជាច្រើនត្រេកអររីករាយ ប៉ាវគង ទូងអានន្ទភេរី ក្នុងកាលដែលចន្ទកុមារចូលទៅក្នុងនគរ ពួកជនបានប្រកាសការរួចចាកចំណង (របស់ពួកសត្វ)។

ចប់ ចន្ទកុមារជាតក ទី៧។

ចប់ ភាគ៦២ ។

# មហានិបាតជាតក

CS sut.kn.jat.v22 | ភាគទី ៦២

(២២. មហានិបាតោ)

## តេមិយជាតក ទី១

CS sut.kn.jat.538 | ភាគទី ៦២

(៥៣៨. មូគបក្ខជាតកំ (១))

[១] (ទេវតាពោលថា) អ្នកកុំប្រកាសនូវភាពជាអ្នកប្រាជ្ញ ចូរឲ្យជនទាំងពួងដឹងថាជាមនុស្សល្ងង់ ជនទាំងអស់ចូរមើលងាយអ្នកចុះ សេចក្តីចំរើននឹងមានដល់អ្នកដោយវិធីយ៉ាងនេះ។

[២] (ព្រះមហាសត្វត្រាស់ថា) បពិត្រទេវតា អ្នកនិយាយពាក្យណានឹងខ្ញុំ ខ្ញុំនឹងធ្វើតាមពាក្យរបស់អ្នកនោះ បពិត្រទេវតា អ្នកឈ្មោះថា ប្រាថ្នានូវសេចក្តីចំរើនដល់ខ្ញុំ បពិត្រទេវតា អ្នកឈ្មោះថា ប្រាថ្នានូវប្រយោជន៍ (ដល់ខ្ញុំ)។

[៣] (ព្រះមហាសត្វ) នែនាយសារថី អ្នកប្រញាប់ប្រញាល់ជីករណ្តៅ តើព្រោះហេតុអ្វី ម្នាលសំឡាញ់ អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់មកចុះ អ្នកនឹងធ្វើនូវអ្វីដោយរណ្តៅ។

[៤] (នាយសារថី) ព្រះរាជបុត្តកើតមកហើយ គផង ខ្វិនផង ដូចជាឥតចិត្ត ឯខ្ញុំនោះ ព្រះរាជាទ្រង់ត្រាស់ប្រើមកហើយថា អ្នកត្រូវជីកកប់កូនអញក្នុងព្រៃចុះ។

[៥] (ព្រះមហាសត្វ) ខ្ញុំមិនថ្លង់ មិនគ មិនខ្វិនទេ មិនមែនវិកលវិការទេ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសធម៌ អ្នកចូរមើលភ្លៅ និងដើមដៃខ្ញុំ ទាំងចូរស្តាប់សំដីខ្ញុំ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសធម៌។

[៦] (នាយសារថី) អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាបុរិន្ទទសក្កទេវរាជ អ្នកជាអ្វី ទាំងជាកូនអ្នកណា យើងនឹងស្គាល់អ្នកបានដោយប្រការដូចម្តេច។

[៧] (ព្រះមហាសត្វ) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាបុរិន្ទទសក្កទេវរាជទេ អ្នកកប់បុគ្គលណាក្នុងរណ្តៅ បុគ្គលនោះ គឺខ្ញុំ ជាកូនរបស់ព្រះបាទកាសិកៈ អ្នករស់នៅដោយស្រួល (ព្រោះអាស្រ័យ) នូវព្រះរាជាណា ខ្ញុំជាកូនរបស់ព្រះរាជានោះ នែនាយសារថី បើអ្នកនឹងកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសធម៌ បុគ្គលគប្បីអង្គុយ ឬដេកក្រោមម្លប់ឈើណា មិនគប្បីកាច់បំបាក់មែកឈើនោះទេ ព្រោះថាអ្នកទ្រុស្តមិត្រ ជាមនុស្សលាមក នែនាយសារថី ព្រះរាជាទុកដូចជាដើមឈើ ខ្លួនខ្ញុំទុកដូចជាមែកឈើដែរ អ្នកឯងទុកដូចបុរសដែលចូលទៅជ្រកក្រោមម្លប់ឈើដូច្នោះ នែនាយសារថី បើអ្នកកប់ខ្ញុំក្នុងព្រៃ អ្នកឈ្មោះថា ធ្វើខុសធម៌។

[៨] បុគ្គលណា មិនទ្រុស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះបើចេញផុតអំពីផ្ទះរបស់ខ្លួនហើយ ជាអ្នកមានភក្ខាហារច្រើន ជនច្រើននាក់តែងចិញ្ចឹមជីវិត (អាស្រ័យ) បុគ្គលនោះ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះ ទៅកាន់ជនបទ និគម រាជធានីណា ៗ គេតែងបូជាក្នុងទីទាំងអស់នោះ។ បុគ្គលណា មិនទ្រុស្តចំពោះមិត្រទាំងឡាយ ពួកចោរមិនក៏ហែងបុគ្គលនោះ ក្សត្រ ក៏មិនមើលងាយបុគ្គលនោះ បុគ្គលនោះ រមែងកន្លងនូវសត្រូវទាំងអស់។ បុគ្គលណា មិនទ្រុស្តចំពោះមិត្រទាំងឡាយ បុគ្គលនោះមិនខឹង មកកាន់ផ្ទះរបស់ខ្លួន ជាអ្នកគេទទួលរីករាយក្នុងរោងសម្រាប់ប្រជុំ ជាបុគ្គលឧត្តមរបស់ពួកញាតិ។ បុគ្គលធ្វើសក្ការៈចំពោះ (មិត្រ) រមែងត្រូវមិត្រធ្វើសក្ការៈវិញ ជាអ្នកគោរព (មិត្រ) រមែងបានសេចក្តីគោរពវិញ បុគ្គលមិនប្រទូស្តមិត្រ រមែងពេញដោយគុណ និងកិត្តិសព្ទ។ បុគ្គលអ្នកបូជាមិត្រ រមែងបានការបូជាវិញ ជាអ្នកសំពះមិត្រ រមែងបានការសំពះតបវិញ បុគ្គលមិនប្រទូស្តមិត្រ រមែងដល់នូវយសបរិវារ និងកិត្តិសព្ទ។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ បុគ្គលនោះ រមែងរុងរឿងដូចភ្លើង រុងរឿងដូចទេវតា ជាអ្នកមិនលះបង់ចាកសិរីឡើយ។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ គោទាំងឡាយរបស់បុគ្គលនោះ សម្រាលកូនដោយស្រួល ពូជដែលបុគ្គលនោះសាបព្រោះក្នុងស្រែ រមែងដុះដាល បុគ្គលនោះ រមែងបរិភោគផ្លែនៃពូជទាំងឡាយ ដែលខ្លួនសាបព្រោះហើយ។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ បុគ្គលនោះ សូម្បីធ្លាក់ទៅក្នុងជ្រោះក្តី អំពីភ្នំក្តី អំពីដើមឈើក្តី ធ្លាក់ហើយ រមែងបានទីពឹង។ បុគ្គលណា មិនប្រទូស្តមិត្រទាំងឡាយ សត្រូវទាំងឡាយគ្រប់សង្កត់បុគ្គលនោះមិនបាន ដូចខ្យល់មិនអាចគ្របសង្កត់ដើមជ្រៃ ដែលមានឫស និងពួរដុះហើយ។

[៩] (នាយសារថី) បពិត្រព្រះរាជបុត្រ សូមទ្រង់ស្តេចមក ទូលព្រះបង្គំជាខ្ញុំ នឹងនាំទ្រង់ទៅកាន់ដំណាក់របស់ព្រះអង្គ សូមទ្រង់សោយរាជ្យចុះ សេចក្តីចំរើននឹងមានដល់ទ្រង់ ទ្រង់នឹងធ្វើអ្វីក្នុងព្រៃ។

[១០] (ព្រះមហាសត្វ) នែនាយសារថី រាជសម្បត្តិណា ដែលខ្ញុំគប្បីបានដោយអធម្មចរិយៈ ខ្ញុំមិនត្រូវការដោយរាជសម្បត្តិនោះ ឬដោយជនជាញាតិ ឬក៏ដោយទ្រព្យទេ។

[១១] (នាយសារថី) បពិត្រព្រះរាជបុត្រ សូមទ្រង់ស្តេចទៅអំពីទីនេះ ហើយញ៉ាំងទូលព្រះបង្គំជាខ្ញុំ ឲ្យបាននូវរង្វាន់ជាទីត្រេកអរ បពិត្រព្រះរាជបុត្រ កាលបើព្រះអង្គស្តេចទៅហើយ ព្រះរាជបិតា និងព្រះមាតា គប្បីប្រទាន (រង្វាន់) ដល់ទូលព្រះបង្គំជាខ្ញុំ។ បពិត្រព្រះរាជបុត្រ

កាលទ្រង់ស្តេចទៅហើយ ពួកស្រីស្នំ និងរាជកុមារ ពួកឈ្មួញ និងពួកព្រាហ្មណ៍ ជនទាំងអម្បាលនោះមានចិត្តត្រេកអរ គប្បីឲ្យ (វង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ)។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្តេចទៅហើយ ពួកហ្មដំរី ពួកពលរក្សាព្រះអង្គ ពួកពលរថ ពួកថ្មើរជើង ជនទាំងអម្បាលនោះ មានចិត្តត្រេកអរ គប្បីឲ្យ (វង្វាន់ដល់ទូលព្រះបង្គំជាខ្ញុំ)។ បពិត្រព្រះរាជបុត្រ កាលទ្រង់ស្តេចទៅ ពួកអ្នកជនបទ និងពួកអ្នកនិគម មានធញ្ញាហារច្រើន មកប្រជុំគ្នា គប្បីឲ្យគ្រឿងបណ្ណាការទាំងឡាយដល់ទូលព្រះបង្គំជាខ្ញុំ។

[១២] (ព្រះមហាសត្វ...) ខ្ញុំដែលព្រះបិតាមាតា អ្នកដែន អ្នកនិគម និងពួករាជកុមារទាំងពួង បានលះចោលហើយ ផ្ទះរបស់ខ្លួនខ្ញុំមិនមានទេ។ ខ្ញុំដែលព្រះមាតាបានអនុញ្ញាតឲ្យទទួលរាជ្យ ៧ ថ្ងៃហើយ ខ្ញុំដែលព្រះបិតាលះចោលស្រឡះហើយ ខ្ញុំនឹងបួសនៅក្នុងព្រៃតែម្នាក់ឯង មិនប្រាថ្នានូវកាមទាំងឡាយឡើយ។

[១៣] សេចក្តីប្រាថ្នាជាផល តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ (អស់ ១៦ ឆ្នាំ) ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹងមានភ័យអំពីណា។

[១៤] (នាយសារថី...) ទ្រង់នោះមានព្រះបន្ទូលពីរោះ មានព្រះបន្ទូលក្បោះក្បាយយ៉ាងនេះ ហេតុអ្វីបានជាទ្រង់មិនមានព្រះបន្ទូលក្នុងសំណាក់នៃព្រះបិតា ព្រះមាតាក្នុងពេលនោះ។

[១៥] (ព្រះមហាសត្វ...) ខ្ញុំមិនមែនខ្វិនព្រោះមិនមានសន្លាក់ទេ ខ្ញុំមិនមែនថ្លង់ព្រោះមិនមានសោតប្រសាទទេ ខ្ញុំមិនមែនគព្រោះមិនមានជិវ្ហាប្រសាទទេ អ្នកកុំសំគាល់ខ្ញុំថា ជាមនុស្សគឡើយ។ ខ្ញុំរលឹកឃើញនូវជាតិមុន ជាជាតិដែលខ្ញុំបានសោយរាជ្យ លុះខ្ញុំបានសោយរាជ្យក្នុងជាតិនោះហើយ ក៏ធ្លាក់នរកគួរស្ញើប។ ខ្ញុំសោយរាជ្យក្នុងជាតិនោះអស់ ២០ ឆ្នាំ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ។ ខ្ញុំខ្លាចរាជ្យនោះ កុំឲ្យព្រះមាតា បិតាអភិសេកខ្ញុំក្នុងរាជ្យ ព្រោះហេតុនោះ បានជាខ្ញុំមិននិយាយក្នុងសំណាក់នៃព្រះបិតាមាតាក្នុងកាលនោះ។ ព្រះរាជបិតាបានឲ្យខ្ញុំអង្គុយលើព្រះឧរុ ហើយទ្រង់វិនិច្ឆ័យក្តីថា អ្នកទាំងឡាយ ចូរសំឡាប់ចោរ ១ នាក់ ចូរចងចោរ ១ នាក់ (ធ្វើចោរ ១ នាក់) ឲ្យប្រឡាក់ដោយទឹកក្បុង។ ចូរដោតចោរ ១ នាក់លើឈើស្រួច ព្រះរាជបិតាត្រាស់បង្គាប់មហាជន ដោយប្រការដូច្នេះ លុះខ្ញុំស្តាប់នូវវាចាដ៏អាក្រក់នោះ ដែលព្រះរាជបិតា ទ្រង់ត្រាស់ហើយ។ ខ្ញុំមិនគ៏ទេ តែមានភេទដូចបុគ្គលគ ខ្ញុំមិនខ្វិនទេ តែសន្មតថាដូចជាខ្វិន ខ្ញុំបាននៅជ្រមុជជ្រមុលក្នុងមូត្រ និងករីសរបស់ខ្លួន។ ជីវិត (របស់សត្វ) លំបាកផង តិចផង ជីវិតនោះ ប្រកបដោយទុក្ខ បុគ្គលណាអាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរដោយហេតុណានីមួយ។ បុគ្គលណាអាស្រ័យនូវជីវិតនេះហើយ គប្បីធ្វើនូវពៀរដោយហេតុណានីមួយ ព្រោះមិនបានបញ្ញាផង ព្រោះមិនឃើញធម៌ផង។ សេចក្តីប្រាថ្នាជាផល តែងសម្រេចដល់ខ្ញុំកាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ នែនាយសារថី អ្នកចូរដឹងយ៉ាងនេះចុះ។ ប្រយោជន៍ដ៏ប្រពៃ តែងសម្រេចដល់ខ្ញុំ កាលមិនប្រញាប់ប្រញាល់ ខ្ញុំជាអ្នកមានព្រហ្មចរិយធម៌ចាស់ក្លាហើយ ខ្ញុំចេញផុតហើយ នឹងមានភ័យអំពីណា។

[១៦] (នាយសារថី) បពិត្រព្រះរាជបុត្រ ទូលព្រះបង្គំជាខ្ញុំនឹងបួសក្នុងសំណាក់ព្រះអង្គ បពិត្រព្រះរាជបុត្រដ៏ចំរើន សូមទ្រង់ត្រាស់ហៅទូលព្រះបង្គំជាខ្ញុំ (ឲ្យបួសផង) ទូលព្រះបង្គំជាខ្ញុំ ពេញចិត្តនឹងបព្វជ្ជាដែរ។

[១៧] (ព្រះមហាសត្វ) នែនាយសារថី អ្នកចូរប្រគល់នូវរថ ហើយជាអ្នកមិនមានបំណុល សឹមមកចុះ ព្រោះថា បព្វជ្ជា (រមែងសម្រេច) ដល់បុគ្គលមិនមានបំណុល បព្វជ្ជាកម្មនេះ ពួកឥសីសរសើរហើយ។

[១៨] (នាយសារថី) សេចក្តីចំរើន ចូរមានដល់ទ្រង់ ពាក្យណាដែលទ្រង់បានថ្លែងហើយ ទូលព្រះបង្គំជាខ្ញុំនឹងធ្វើតាមពាក្យនោះ ទ្រង់ដែលទូលព្រះបង្គំជាខ្ញុំអង្វរហើយ គួរធ្វើតាមពាក្យរបស់ទូលព្រះបង្គំជាខ្ញុំនោះផង។ សូមទ្រង់ស្តេចគង់នៅក្នុងទីនេះ ដរាបដល់ទូលព្រះបង្គំជាខ្ញុំនាំព្រះរាជាមកដល់ ព្រះបិតារបស់ទ្រង់ទតឃើញហើយ សមជាមានព្រះហឫទ័យត្រេកអររីករាយ។

[១៩] (ព្រះមហាសត្វ) នែនាយសារថី អ្នកនិយាយពាក្យណានឹងខ្ញុំ ៗ នឹងធ្វើតាមពាក្យរបស់អ្នកនោះ ឯខ្ញុំមានបំណងដើម្បីជួបព្រះបិតារបស់ខ្ញុំ ដែលទ្រង់ស្តេចយាងមកក្នុងទីនេះដែរ។ ម្នាលសំឡាញ់ អ្នកទៅហើយចូរមកវិញ ចូរត្រឡប់ទៅសិន៍ចុះ អ្នកប្រាប់នូវសេចក្តីសុខដល់ញាតិទាំងឡាយ អ្នកដែលខ្ញុំប្រាប់ហើយ គប្បីក្រាបទូលនូវការថ្វាយបង្គំចំពោះព្រះមាតាបិតា។

[២០] (អភិសម្ពុទ្ធគាថា) នាយសារថី ចាប់ព្រះបាទានៃព្រះមហាសត្វនោះ ហើយក៏ធ្វើប្រទក្សិណព្រះមហាសត្វនោះ រួចឡើងជិះរថបរចូលទៅកាន់រាជទ្វារ។

[២១] ព្រះមាតាទតឃើញរថទទេ ក៏មានព្រះនេត្រដ៏ពេញពោរដោយព្រះអស្សុ ទ្រង់ព្រះកន្សែង មៀងមើលទៅនាយសារថីនោះ ដែលមកវិញតែឯង ដោយគិតថា នាយសារថីនេះ សម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ។ កូនរបស់អញ ចំរើនផែនដី នាយសារថីកប់ក្នុងផែនដីដោយពិត ពួកសត្រូវរមែងត្រេកអរដោយពិត ពួកជនមានពៀរ ត្រេកអរហើយដោយពិត ព្រោះឃើញនាយសារថីសម្លាប់កូនបង្កើតរបស់អញ ហើយមកវិញ។ ព្រះមាតាទតឃើញរថទទេ ក៏មានព្រះនេត្រដ៏ពេញពោរដោយព្រះអស្សុ ទ្រង់ព្រះកន្សែង សួរទៅនាយសារថីនោះ ដែលមកវិញតែម្នាក់ឯងថា កូនរបស់ខ្ញុំនោះ ជាមនុស្សគឬអ្វី ជាមនុស្សខ្វិនឬអ្វី កាលអ្នកកប់ក្នុងផែនដីក្នុងកាលនោះ កូនរបស់ខ្ញុំពិលាបដែរឬ ម្នាលនាយសារថី អ្នកចូរប្រាប់នូវរឿងនោះដល់ខ្ញុំ។ (កូនរបស់ខ្ញុំនោះ) ជាមនុស្សគ ជាមនុស្សខ្វិនកាលអ្នកកប់ក្នុងផែនដី បានកម្រើកដៃ និងជើងដូចម្តេចដែរ (ម្នាលនាយសារថី) អ្នកដែលខ្ញុំសួរហើយ ចូរប្រាប់រឿងនោះ។

[២២] (នាយសារថី) បពិត្រព្រះនាងជាម្ចាស់ (បើ) ព្រះនាងឲ្យអភ័យដល់ទូលព្រះបង្គំជាខ្ញុំ ហេតុណាដែលខ្ញុំបានឮហើយ ឬបានឃើញហើយ ក្នុងសំណាក់នៃព្រះរាជបុត្រ ទូលព្រះបង្គំជាខ្ញុំនឹងក្រាបទូលនូវហេតុនោះដល់ព្រះនាង។

[២៣] (ព្រះរាជទេវី) ម្នាលសារថីសំឡាញ់ ខ្ញុំឲ្យអភ័យដល់អ្នក ហេតុណាដែលអ្នកបានឮហើយ ឬបានឃើញហើយក្នុងសំណាក់នៃព្រះរាជាបុត្រ អ្នកកុំភិតភ័យ ចូរប្រាប់នូវហេតុនោះចុះ។

[២៤] (នាយសារថី) ព្រះរាជបុត្រនោះ មិនមែនគទេ ព្រះរាជបុត្រនោះ មិនមែនខ្វិនទេ ឯព្រះរាជបុត្រនោះ មានព្រះបន្ទូលក្បោះក្បាយបានឮថា ព្រះរាជបុត្រនោះ ទ្រង់ខ្លាចរាជ្យ ទើបបានជាធ្វើនូវពុតត្បុតច្រើនយ៉ាង។ ព្រះរាជបុត្រនោះ ទ្រង់រឭកឃើញនូវជាតិមុន ជាជាតិដែលបានទ្រង់សោយរាជ្យ លុះសោយរាជ្យក្នុងទីនោះហើយ ធ្លាក់នរកគួរស្ញែង។ ព្រះរាជបុត្រនោះ បានសោយរាជ្យក្នុងទីនោះអស់ ២០ ឆ្នាំគត់ បានឆេះក្នុងនរកអស់ ៨ ម៉ឺនឆ្នាំ។ ព្រះរាជបុត្រនោះ ទ្រង់ខ្លាចរាជ្យនោះហើយ (ក៏តាំងព្រះរាជហឫទ័យថា) ព្រះរាជមាតាបិតាកុំអភិសេកអញក្នុងរាជ្យ ព្រោះហេតុនោះ ទើបព្រះរាជបុត្រមិនមានបន្ទូលក្នុងសំណាក់នៃព្រះបិតា និងព្រះមាតាក្នុងកាលនោះ។ ព្រះរាជបុត្រនោះ បរិបូណ៌ដោយអវយវៈតូចធំ មានកំពស់ និងទំហំ (ដ៏សមស្រួន) មានព្រះបន្ទូលដ៏ក្បោះក្បាយ មានបញ្ញា ទ្រង់ឋិតនៅក្នុងផ្លូវសួគ៌។ បើព្រះនាងមានប្រាថ្នាដើម្បីឃើញព្រះរាជបុត្រ ជាកូនបង្កើតរបស់ព្រះនាង សូមព្រះនាងយាងទៅចុះ តេមិយកុមារគង់នៅក្នុងទីណា ទូលព្រះបង្គំជាខ្ញុំនឹងនាំព្រះនាងឲ្យដល់ទីនោះ។

[២៥] (ព្រះបាទកាសិក:) នាយសារថីទាំងឡាយ ចូរទឹមសេះក្នុងរថ អ្នកទាំងឡាយ ចូរចងជង្គន់នាដំរី ស័ង្ខ និងស្គរ ចូរលាន់សំឡេងឡើង ស្គរមានមុខតែម្ខាង ចូរលាន់សំឡេងឡើង។ ស្គរដែលគេពាសល្អហើយ ចូរបន្លឺសំឡេង ស្គរមានសំឡេងពីរោះ ចូរលាន់សំឡេងឡើង ទាំងពួកអ្នកនិគម ចូរទៅតាមយើងចុះ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង។ ពួកស្រីស្នំ និងរាជកុមារ ពួកឈ្មួញ និងពួកព្រាហ្មណ៍ ចូរនាំគ្នាទឹមយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង។ ពួកហ្មដំរី ពួកពលសេះ ពួកពលរថ ពួកពលថ្មើរជើង ចូរនាំគ្នាទឹមយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង។ អ្នកជនបទមកប្រជុំគ្នា ទាំងអ្នកនិគម ក៏មកប្រជុំគ្នា ហើយចូរទឹមនូវយានឲ្យឆាប់ យើងនឹងទៅឲ្យឱវាទដល់កូនរបស់យើង។

[២៦] (អភិសម្ពុទ្ធគាថា) ឯពួកនាយសារថី (បាននាំយក) នូវសេះសិន្ធពទាំងឡាយ ជាពាហនៈមានសន្ទុះដ៏លឿន ដែលទឹមហើយ ចូលមកកាន់រាជទ្វារ (ក្រាបបង្គំទូលថា) បពិត្រព្រះសម្មតិទេព សេះទាំងឡាយនេះ ទូលព្រះបង្គំជាខ្ញុំបានទឹមរួចហើយ។

[២៧] (ព្រះរាជា) ពួកសេះធាត់ៗ រមែងសាបសូន្យចាកសន្ទុះ ពួកសេះស្គមៗ រមែងសាបសូន្យចាកកំឡាំង អ្នកទាំងឡាយ ត្រូវវៀរបង់នូវពួកសេះស្គម និងសេះធាត់ចេញ ហើយទឹមតែពួកសេះដែលប្រកប (ដោយវ័យ សម្បុរ សន្ទុះ កំឡាំង) វិញ។

[២៨] លំដាប់នោះ ព្រះរាជាទ្រង់ប្រញាប់ប្រញាល់ឡើងគង់រថ ដែលនាយសារថីទឹមហើយ ទ្រង់ត្រាស់ទៅនឹងស្ត្រីស្នំថា នាងទាំងអស់គ្នា ចូរទៅតាមយើងចុះ។ នាងទាំងឡាយចូរប្រដាប់ដោយមាសទាំងឡាយ ហើយកាន់មកនូវផ្លិត មកុដ ព្រះខាន់ ស្វេតច្ឆត្រ និងស្បែកជើង រួចឡើងជិះរថមក។ បន្ទាប់ពីនោះមក ព្រះរាជាបានឲ្យនាយសារថីដើរមុខ ហើយទ្រង់ស្តេចយាងទៅ តេមិយកុមារនៅក្នុងទីណា ក៏យាងទៅក្នុងទីនោះយ៉ាងឆាប់។

[២៩] តេមិយៈទតឃើញព្រះបិតានោះ កំពុងស្តេចយាងមក ហាក់ដូចជារុងរឿងដោយតេជៈ ដែលពួកអាមាត្យអ្នកកាន់ព្រះខាន់ហែហមហើយ ទើបត្រាស់សួរព្រះបិតានោះថា បពិត្រព្រះបិតា ព្រះអង្គមានសេចក្តីសុខសប្បាយទេឬ បពិត្រព្រះបិតា ព្រះអង្គមិនមានព្រះអាពាធទេឬ រាជកញ្ញាទាំងអស់ ជាព្រះមាតារបស់ខ្ញុំមិនមានរោគទេឬ។

[៣០] (ព្រះវរបិតា) នែកូន ខ្ញុំសុខសប្បាយទេ នែកូន ខ្ញុំមិនមានជំងឺដម្កាត់ទេ រាជកញ្ញាទាំងអស់ជាមាតារបស់អ្នក មិនមានរោគទេ។

[៣១] (មហាសត្វ) បពិត្រព្រះបិតា ព្រះអង្គមិនសោយទឹកស្រវឹងទេឬ សុរាមិនពេញព្រះទ័យរបស់ព្រះអង្គទេឬ ព្រះទ័យរបស់ព្រះអង្គត្រេកអរក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទានដែរឬ។

[៣២] (ព្រះវរបិតា) នែកូន ខ្ញុំមិនផឹកទឹកស្រវឹងទេ មួយទៀត សុរាមិនពេញចិត្តខ្ញុំទេ ឯចិត្តរបស់ខ្ញុំ តែងត្រេកអរក្នុងសច្ចៈ ក្នុងធម៌ និងក្នុងទាន។

[៣៣] (មហាសត្វ) យានរបស់ព្រះអង្គមិនខូចទេឬ វាហនៈរបស់ព្រះអង្គតែងប្រព្រឹត្តទៅបានដែរឬ ព្យាធិទាំងឡាយជាគ្រឿងដុតកំដៅសរីរៈ មិនមានដល់ព្រះអង្គទេឬ។

[៣៤] (ព្រះវរបិតា) ឯយានរបស់ខ្ញុំឥតមានខូចទេ វាហនៈរបស់ខ្ញុំក៏ប្រព្រឹត្តទៅបានដោយស្រួល ព្យាធិទាំងឡាយជាគ្រឿងដុតកំដៅសរីរៈ មិនមានដល់ខ្ញុំទេ។

[៣៥] (មហាសត្វ) ជនបទនៅទីប្រទល់ដែនរបស់ព្រះអង្គ (ស្រុក និងនិគម) របស់ព្រះអង្គទាំងមូល ដែលតាំងនៅកណ្តាលផែនដី ជាស្រុកសម្បូណ៌ដែរឬ ឃ្លាំង និងជង្រុក ព្រះអង្គបានតម្កល់ទុកស្រួលបួលទេឬ។

[៣៦] (ព្រះវរបិតា) ជនបទនៅទីប្រទល់ដែនរបស់ខ្ញុំ (ស្រុក និងនិគម) ទាំងមូលរបស់ខ្ញុំ ដែលតាំងនៅកណ្តាលដែន ជាស្រុកសម្បូណ៌ ឃ្លាំង និងជង្រុកទាំងអស់ ខ្ញុំបានតម្កល់ទុកស្រួលបួលហើយ។

[៣៧] (មហាសត្វ) បពិត្រមហារាជ ព្រះអង្គស្តេចយាងមកល្អហើយ មួយទៀត ព្រះអង្គស្តេចមក មិនមែនអាក្រក់ទេ រាជបុរសចូររៀបចំបល្ល័ង្កជាទីគង់របស់ព្រះរាជា។

[៣៨] ព្រះអង្គគង់លើកម្រាលស្លឹកឈើ ដែលគេតែងតាំងហើយ សូមព្រះអង្គ យកទឹកអំពីទីនេះ លាងព្រះបាទារបស់ព្រះអង្គចុះ។

[៣៩] បពិត្រព្រះរាជា ស្លឹកនេះដែលអាត្មាភាពចម្អិនហើយ ជារបស់មិនមានរសប្រៃ បពិត្រមហារាជ្យ សូមព្រះអង្គស្តេចសោយចុះ ព្រះអង្គទើបស្តេចយាងមកដល់ ទុកជាភ្ញៀវរបស់អាត្មាភាព។

[៤០] (ព្រះវរបិតា) ខ្ញុំមិនបរិភោគស្លឹកនេះទេ ព្រោះស្លឹកឈើនេះ មិនមែនជាភោជនរបស់ខ្ញុំ ខ្ញុំបរិភោគតែបាយនៃស្រូវសាលី ដែលលាយដោយសាច់ដ៏ស្អាត។

[៤១] សេចក្តីអស្ចារ្យកើតប្រាកដដល់ខ្ញុំ ព្រោះឃើញ (លោក) នៅស្ងាត់តែម្នាក់ឯង កាលលោកបរិភោគភោជនបែបនេះ សម្បុរនៅតែស្រស់ថ្លាដោយហេតុដូចម្តេច។

[៤២] (មហាសត្វ) បពិត្រព្រះរាជា អាត្មាភាពម្នាក់ឯង សិងលើកម្រាលស្លឹក ដែលតាំងទុកហើយ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាពស្រស់ថ្លាដោយដំណេកម្នាក់ឯងនោះ ។ ពួកអ្នករក្សាព្រះរាជា ដែលសៀតព្រះខាន់ មិនប្រាកដដល់អាត្មាភាពទេ បពិត្រព្រះរាជា វណ្ណៈរបស់អាត្មាភាព ថ្លាស្រស់ដោយដំណេកម្នាក់ឯងនោះ។ អាត្មាភាព មិនតាមសោក និងអារម្មណ៍ដែលកន្លងហើយ មិនប្រាថ្នានូវអារម្មណ៍ដែលមិនទាន់មកដល់ ញ៉ាំងអត្តភាពឲ្យប្រព្រឹត្តទៅដោយវត្ថុដែលលើកឡើងចំពោះមុខ ហេតុនោះ បានជាវណ្ណៈរបស់អាត្មាភាព រមែងថ្លាស្រស់។ ជនពាលទាំងឡាយ តែងរីងស្ងួត ព្រោះសេចក្តីប្រាថ្នាអារម្មណ៍ដែលមិនទាន់មកដល់ ព្រោះសេចក្តីតាមសោកស្តាយអារម្មណ៍ដែលកន្លងទៅហើយនេះ ដូចជាដើមបបុសមានសម្បុរខៀវ ដែលគេដកហាលថ្ងៃដូច្នោះ។

[៤៣] (ព្រះវរបិតា) នែកូន ខ្ញុំនឹងឲ្យនូវពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកជនពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក។ មួយទៀត ខ្ញុំឲ្យនូវស្រីស្នំដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន ចូរអ្នកគ្រប់គ្រងនូវស្ត្រីទាំងនោះចុះ អ្នកជាព្រះរាជារបស់យើង។ ស្ត្រីរបាំ ជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង បានសិក្សា (ក្នុងកិច្ចស្ត្រី) ញ៉ាំងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ។ ខ្ញុំនឹងនាំយករាជកញ្ញាដែលមានខ្លួនប្រដាប់ហើយអំពីពួកព្រះរាជាដទៃដល់អ្នក អ្នកចូរញ៉ាំងកូនទាំងឡាយ ឲ្យកើតក្នុងស្ត្រីទាំងនោះ ហើយសិមបួសក្នុងកាលជាខាងក្រោយ។ អ្នកនៅក្មេងកម្លោះ ប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យ សេចក្តីចំរើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ។

[៤៤] (មហាសត្វ) បុគ្គលនៅកម្លោះ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីជាកម្លោះ ព្រោះថា បព្វជ្ជារបស់បុគ្គលនៅកម្លោះនេះ ពួកឥសីទាំងឡាយសរសើរហើយ។ បុគ្គលនៅកម្លោះ គប្បីប្រព្រឹត្តព្រហ្មចរិយធម៌ បុគ្គលអ្នកប្រព្រឹត្តព្រហ្មចរិយធម៌ គប្បីនៅកម្លោះ អាត្មាភាព នឹងប្រព្រឹត្តព្រហ្មចរិយធម៌ អាត្មាភាព មិនត្រូវការដោយរាជ្យទេ។ បពិត្រព្រះមាតា និងបិតា អាត្មាភាពឃើញនរជននៅក្មេង ទើបនឹងចេះនិយាយ ជាកូនជាទីស្រឡាញ់ដែលមាតាបិតាបានដោយលំបាក មិនទាន់ចាស់គ្រាំគ្រា ហើយស្លាប់។ អាត្មាភាព ឃើញនាងកុមារីមានសម្បុរដូចមាស ដែលមច្ចុរាជចាប់ដកក្ស័យជីវិតហើយ ដូចជាដកនូវទំពាំងឫស្សីដ៏ខ្ចី។ នរជនទាំងឡាយ ឬនាងនារីទាំងឡាយ សូម្បីនៅក្មេង ក៏តែងស្លាប់ តើសត្វណា គប្បីទុកចិត្តក្នុងជីវិតនោះថា អាត្មាអញនៅក្មេងដូច្នេះ។ អាយុនៃកុមារណា មានប្រមាណតិច ដោយការកន្លងទៅនៃយប់ និងថ្ងៃ ភាពនៃខ្លួនជាកុមារក្នុងវ័យនោះ នឹងធ្វើដូចម្តេចកើត ដូចទីមានទឹកតិចរបស់ត្រីទាំងឡាយ។ សត្វលោក ត្រូវសត្រូវបៀតបៀនជានិច្ចផង ត្រូវសត្រូវរួបរិតជានិច្ចផង កាលយប់ និងថ្ងៃទាំងឡាយមិនកន្លងទៅទទេទេ តើព្រះអង្គនឹងអភិសេកអាត្មាភាពក្នុងរាជ្យដូចម្តេច។

[៤៥] (ព្រះរាជា) សត្វលោកនេះ ត្រូវសត្រូវអ្វីបៀតបៀនផង ត្រូវសត្រូវអ្វីរួបរឹតផង ធម្មជាតិដូចម្តេច មិនកន្លងទៅទទេ ខ្ញុំសួរហើយ អ្នកចូរប្រាប់នូវដំណើរនោះ។

[៤៦] (ព្រះមហាសត្វ) សត្វលោកត្រូវមច្ចុបៀតបៀនផង ត្រូវជរារួបរឹតផង

រាត្រីទាំងឡាយ រមែងកន្លងទៅមិនទទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គជ្រាបយ៉ាងនេះចុះ។ កាលតម្បាញដែលបុគ្គលត្បាញរបស់ណា ៗ ដែលបុគ្គលនឹងត្បាញរបស់ដែលត្រូវត្បាញ (នោះៗ) ជារបស់នៅសល់តិច យ៉ាងណាមិញ ជីវិតរបស់សត្វទាំងឡាយ ក៏យ៉ាងនោះដែរ។ ផ្លូវទឹកដ៏ពេញ កាលហូរទៅ មិនត្រឡប់ថយក្រោយវិញ យ៉ាងណាមិញ អាយុរបស់មនុស្សទាំងឡាយ កាលកន្លងទៅ មិនត្រឡប់វិញ យ៉ាងនោះដែរ។ ផ្លូវទឹកដ៏ពេញ គប្បីបន្សាត់ទៅនូវដើមឈើទាំងឡាយ ដែលដុះក្បែរច្រាំង យ៉ាងណាមិញ សត្វទាំងអស់ ត្រូវជរា និងមរណៈបន្សាត់ទៅក៏យ៉ាងនោះដែរ។

[៤៧] (ព្រះវរបិតា) នែកូន ខ្ញុំនឹងឲ្យពលដំរី ពលរថ ពលសេះ ពលថ្មើរជើង ពួកពលពាក់គ្រឿងក្រោះ និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក។ មួយទៀត យើងនឹងឲ្យស្ត្រីស្នំដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួងដល់អ្នក នែកូន អ្នកចូរគ្រប់គ្រងពួកស្ត្រីទាំងនោះចុះ អ្នកនឹងជារាជារបស់យើង ស្ត្រីរបាំជាអ្នកឈ្លាសក្នុងការរាំ និងច្រៀង សិក្សា (ក្នុងកិច្ចរបស់ស្ត្រី) នឹងញ៉ាំងអ្នកឲ្យត្រេកអរក្នុងកាម អ្នកនឹងធ្វើអ្វីក្នុងព្រៃ។ យើងនឹងនាំយកពួករាជកញ្ញាដែលមានខ្លួនប្រដាប់ហើយ អំពីពួកព្រះរាជាដទៃដល់អ្នក អ្នកញ៉ាំងកូនទាំងឡាយឲ្យកើតក្នុងពួកនាងកញ្ញាទាំងនោះ ហើយសឹមបួសក្នុងកាលជាខាងក្រោយចុះ។ អ្នកនៅក្មេងកម្លោះ ប្រកបដោយបឋមវ័យ មានសក់ខ្មៅស្រិល ចូរសោយរាជ្យចុះ សេចក្តីចំរើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ។ នែកូន ខ្ញុំនឹងឲ្យឃ្លាំង ជង្រុក វាហនៈ ពល និងនិវេសនដ្ឋានទាំងឡាយ ជាទីត្រេកអរដល់អ្នក។ អ្នកដែលក្រុមនៃរាជកញ្ញាមានចំណែកដ៏ល្អចោមរោមហើយ មាន់ពួកនៃខ្ញុំស្ត្រីហែហម ហើយ ចូរសោយរាជ្យចុះ សេចក្តីចំរើននឹងមានដល់អ្នក អ្នកនឹងធ្វើអ្វីក្នុងព្រៃ។

[៤៨] (ព្រះមហាសត្វ) ប្រយោជន៍អ្វីដោយទ្រព្យដល់អាត្មាភាព ព្រោះទ្រព្យតែងអស់ទៅ ប្រយោជន៍អ្វីដោយភរិយា ព្រោះភរិយាក៏គង់ស្លាប់ ប្រយោជន៍អ្វីដោយវ័យដែលគ្រាំគ្រា ជាវ័យត្រូវជរាគ្របសង្កត់ហើយ។ ក្នុងលោកសន្និវាសនេះ នៅមានសេចក្តីត្រេកអរអ្វី ការលេងសើចអ្វី ការរីករាយអ្វី ការស្វែងរកទ្រព្យអ្វី អាត្មាភាពត្រូវការអ្វីដោយកូន និងប្រពន្ធ បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះចាកបំណងហើយ។ អាត្មាភាពដឹងច្បាស់យ៉ាងនេះថា មច្ចុមិនធ្វេសប្រហែសចំពោះអញឡើយ អាត្មាភាពនោះ ត្រូវសេចក្តីស្លាប់គ្របសង្កត់ហើយ នៅមានសេចក្តីត្រេកអរដូចម្តេច ការស្វែងរកទ្រព្យដូចម្តេចទៀត។ ផ្លែឈើទុំទាំងឡាយ តែងមានភ័យអំពីការជ្រុះជានិច្ច យ៉ាងណាមិញ សត្វទាំងឡាយ កើតមកហើយ តែងមានភ័យអំពីសេចក្តីស្លាប់ជានិច្ចយ៉ាងនោះដែរ។ ជនជាច្រើន ពួកខ្លះដែលគេឃើញក្នុងវេលាព្រឹក តែគេមិនឃើញក្នុងវេលាល្ងាច ជនជាច្រើនពួកខ្លះ ដែលគេឃើញក្នុងវេលាល្ងាច តែគេមិនឃើញក្នុងវេលាព្រឹក។ សេចក្តីព្យាយាមក្នុងកុសល គេគួរធ្វើក្នុងថ្ងៃនេះឯង បុគ្គលណា គប្បីដឹងថា សេចក្តីស្លាប់នឹងមានក្នុងថ្ងៃស្អែក ដ្បិតការបណ្តោះបណ្តែអំពីសេចក្តីស្លាប់ ដែលមានសេនាច្រើននោះ មិនមានដល់យើងទេ។ ពួកចោរទាំងឡាយ តែងប្រាថ្នាទ្រព្យ បពិត្រព្រះរាជា អាត្មាភាពផុតស្រឡះហើយអំពីបំណង បពិត្រព្រះរាជា សូមព្រះអង្គមក សូមព្រះអង្គត្រឡប់ព្រះហឫទ័យទៅវិញចុះ អាត្មាភាពមិនត្រូវការដោយរាជ្យទេ។

ចប់ តេមិយជាតក ទី ១។

## មហាជនកជាតក ទី២

CS sut.kn.jat.539 | ភាគទី ៦២

### (៥៣៩. មហាជនកជាតកំ (២))

[៤៩] (នាងទេវធីតាឈ្មោះមណីមេខលាសួរថា) បុគ្គលណានេះ កាលមិនឃើញត្រើយ ក៏ព្យាយាម (ហែល) ក្នុងកណ្តាលសមុទ្រ អ្នកដឹងនូវអំណាចនៃប្រយោជន៍ដូចម្តេច ក៏ព្យាយាមក្រៃពេកម្លេះ។

[៥០] (ព្រះមហាសត្វត្រាស់តបថា) ម្នាលទេវតា ខ្ញុំពិចារណានូវវត្តនៃសត្វលោក និងអានិសង្សនៃសេចក្តីព្យាយាម ព្រោះហេតុដូចច្នោះ ខ្ញុំសូម្បីមិនឃើញត្រើយ ក៏នៅតែព្យាយាមក្នុងកណ្តាលសមុទ្រ។

[៥១] (នាងមណីមេខលា) អ្នកមិនឃើញត្រើយនៃសមុទ្រដ៏ជ្រៅប្រមាណមិនបាន ការព្យាយាមតាមកម្លាំងបុរសរបស់អ្នក ជាព្យាយាមសោះសូន្យទទេ អ្នកមិនដល់នូវត្រើយទេ មុខជានឹងស្លាប់។

[៥២] (ព្រះមហាសត្វ) បុគ្គលធ្វើនូវកិច្ចរបស់បុរស ទើបជាអ្នកមិនមានបំណុល (ក្នុងរវាង) ពួកញាតិ ពួកទេវតា និងពួកបិតា (ព្រហ្ម) ទាំងមិនក្តៅក្រហាយក្នុងកាលជាខាងក្រោយ។

[៥៣] (នាងមណីមេខលា) ការងារណា មិនគប្បីសម្រេច (ដោយសេចក្តីព្យាយាមទេ) ការងារនោះ ជារបស់ឥតផល មានសេចក្តីលំបាកជាកម្រៃ សេចក្តីស្លាប់ រមែងសម្រេចដល់បុគ្គលណា បុគ្គលនោះ មានប្រយោជន៍ដូចម្តេចដោយសេចក្តីព្យាយាមក្នុងការងារនោះ។

[៥៤] (ព្រះមហាសត្វ) ម្នាលទេវតា បុគ្គលណាដឹងច្បាស់ថា ការងារមិនគប្បីសម្រេចដោយពិត ហើយមិនរក្សាជីវិតរបស់ខ្លួន បុគ្គលនោះ បើបន្ថយសេចក្តីព្យាយាម គង់ដឹង (នូវផលនៃសេចក្តីខ្ជិលនោះមិនខាន)។ ម្នាលទេវតា បុគ្គលពួកខ្លះក្នុងលោកនេះ (កាលឃើញ) នូវផលនៃសេចក្តីប្រាថ្នាហើយ រមែងប្រកបនូវការងារទាំងឡាយ ការងារទាំងនោះ សម្រេចខ្លះ មិនសម្រេចខ្លះ។ ម្នាលទេវតា ក្រែងអ្នកបានឃើញផលនៃកម្មដ៏ជាក់ច្បាស់ដោយខ្លួនឯងដែរឬ ជនទាំងឡាយដទៃលិចលង់ហើយ ខ្ញុំនៅឆ្លង ទាំងបានឃើញនាង ដែលឋិតនៅក្នុងទីជិតនៃខ្ញុំ។

ខ្ញុំនោះ នឹងព្យាយាមតាមសមគួរដល់សេចក្តីអស់អាច និងសមគួរដល់កម្លាំង ខ្ញុំកាលទៅដល់ត្រើយនៃសមុទ្រ នឹងធ្វើនូវសេចក្តីព្យាយាម ដែលបុរសគប្បីធ្វើ។

[៥៥] (នាងមណីមេខលា) កាលមហាសមុទ្រមានអន្លង់ទឹកដ៏ជ្រៅប្រមាណមិនបាន ប្រព្រឹត្តទៅយ៉ាងនេះ អ្នកណាប្រកបដោយសេចក្តីព្យាយាមដោយធម៌ រមែងមិនលិចចុះដោយកម្ម គឺសេចក្តីព្យាយាម ចិត្តរបស់អ្នក ត្រេកអរក្នុងទីណា អ្នកនោះ ចូរទៅក្នុងទីនោះចុះ។

[៥៦] (ព្រះបាទបោលជនក) កំណប់ធំ ១៦ នេះ គឺកំណប់ត្រង់ទីព្រះអាទិត្យរះ កំណប់ត្រង់ទីព្រះអាទិត្យលិច កំណប់ខាងក្នុង កំណប់ខាងក្រៅ កំណប់មិនមែនខាងក្នុង មិនមែនខាងក្រៅ កំណប់ធំត្រង់ទីសម្រាប់ឡើង កំណប់ត្រង់ទីសម្រាប់ចុះ កំណប់ត្រង់សាលព្រឹក្សធំទាំងបួន កំណប់ត្រង់ទីមួយយោជន៍ជុំវិញ កំណប់ធំត្រង់ចុងភ្លុកដំរីទាំងពីរ កំណប់ត្រង់ចុងកន្ទុយ កំណប់ក្នុងទឹក កំណប់ធំត្រង់ចុងឈើសហស្សថាមធ្នូ បល្ល័ង្ក ៤ ជ្រុង នឹងញ៉ាំងនាងសីវលីរាជទេវីឲ្យត្រេកអរ។

[៥៧] (ព្រះបាទមហាជនក) បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួនឯង យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ។ បុរសជាបណ្ឌិត ត្រូវតែប្រាថ្នា មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន (ដែលទេវតា) ស្រង់អំពីទឹក មកដាក់លើគោក។ បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន យើងប្រាថ្នាយ៉ាងណា ក៏បានយ៉ាងនោះ។ បុរសជាបណ្ឌិត ត្រូវតែព្យាយាម មិនត្រូវនឿយណាយទេ យើងឃើញច្បាស់ចំពោះខ្លួន (ដែលទេវតា) ស្រង់អំពីទឹក មកដាក់លើគោក។ នរជន មានប្រាជ្ញា សូម្បីសេចក្តីទុក្ខប៉ះពាល់ហើយ មិនគប្បីកាត់សេចក្តីប្រាថ្នា ដើម្បីដល់នូវសេចក្តីសុខទេ ព្រោះថា ការប៉ះពាល់ដ៏ច្រើន ឥតប្រយោជន៍ក៏មាន មានប្រយោជន៍ក៏មាន ពួកជនអ្នកមិនត្រិះរិះ រមែងដល់នូវសេចក្តីស្លាប់។ ហេតុដែលបុគ្គលមិនបានគិត សម្រេចក៏មាន ហេតុដែលបុគ្គលគិតហើយ វិនាសទៅក៏មាន ព្រោះភោគៈទាំងឡាយរបស់ស្ត្រី ឬបុរស មិនមែនសម្រេចដោយការគិតទេ។

[៥៨] (មហាជន) ម្នាលគ្នាយើងដ៏ចំរើន ព្រះរាជាត្រួតនូវផែនដីទាំងមូល ជាម្ចាស់ក្នុងទិស មិនដូចអំពីដើមសោះ ថ្ងៃនេះមិនទ្រង់ក្រសាលរបាំ មិនទ្រង់ធ្វើទុកក្នុងព្រះហឫទ័យចំពោះចំរៀង មិនទតម្រឹគ មិនទតឧទ្យាន មិនទតហង្ស ទ្រង់គង់នៅស្ងៀម ហាក់ដូចជាមនុស្សគមិនទ្រង់កាត់សេចក្តី។

[៥៩] (ព្រះបាទមហាជនក) ព្រះបច្ចេកពុទ្ធទាំងឡាយ ទាំងក្មេង ទាំងចាស់ អ្នកប្រាថ្នាសេចក្តីសុខ មានសេចក្តីស្ងប់ស្ងាត់ជាប្រក្រតី ប្រាសចាកចំណងជាកិលេស គង់នៅក្នុងអារាមនៃបុគ្គលណាហ្ន៎ ក្នុងថ្ងៃនេះ។ អ្នកប្រាជ្ញទាំងឡាយណា បានកន្លងនូវតណ្ហា ជាអ្នកមិនមានសេចក្តីខ្វល់ខ្វាយ នៅក្នុងលោកដែលកំពុងខ្វល់ខ្វាយ ខ្ញុំសូមថ្វាយបង្គំអ្នកប្រាជ្ញទាំងនោះ ជាអ្នកស្វែងរកនូវគុណដ៏ធំ។ អ្នកប្រាជ្ញទាំងឡាយនោះ កាត់ទំលាយនូវតម្បាញជាបណ្តាញដ៏មាំរបស់មច្ចុដែលមានមាយាចេញទៅរួច បុគ្គលណាគប្បីញ៉ាំងយើងឲ្យដល់នូវគតិ (លំអាន) នៃអ្នកប្រាជ្ញទាំងនោះបាន។

[៦០] កាលណាអញនឹងលះនគរមិថិលា ជាក្រុងសម្បូណ៌ ដែលជាងចែកហើយ (ដោយឋាន មានរាជនិវេសន៍ជាដើម) វាស់ហើយដោយចំណែក (នៃទ្វារ និងថ្នល់) ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ទូលាយ មានពន្លឺដោយជុំវិញ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង និងក្លោងទ្វារដ៏ច្រើន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានប៉ម និងស៊ុមទ្វារដ៏មាំមួន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដែលគេចែកល្អ មានផ្លូវធំ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរានផ្សារ ដែលគេចែកដោយល្អ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ ដ៏កុះករដោយគោ សេះ និងរថ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃសួន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃព្រៃឧទ្យាន ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានរបៀបនៃប្រាសាទដ៏ប្រសើរ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នគរមិថិលា ជាក្រុងសម្បូណ៌ មានកំពែង ៣ ជាន់ ពេញដោយរាជវង្សានុវង្ស ដែលព្រះបាទវិទេហៈ ព្រះនាមសោមនស្សមានយស ទ្រង់សាងទុក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់ដែនវិទេហៈ ជាដែនសម្បូណ៌ បរិបូណ៌ដោយការសន្សំ (នូវធញ្ញាហារជាដើម) ដែលរក្សាតាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវដែនវិទេហៈ ជាដែនសម្បូណ៌ ដែលបច្ចាមិត្រផ្ចាញ់មិនបាន ជាដែនរក្សាតាមធម៌ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ដែលជាទីរីករាយ ដែលជាងចែកវាស់ដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ជាទីរីករាយ ដែលបូកដោយកំបោ និងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវខាងក្នុងបុរី ជាទីរីករាយ មានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលជាងចែកហើយ វាស់ហើយដោយចំណែក ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលបូកដោយកំបោ និងដី ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះនូវដំណាក់កំពូលទាំងឡាយ ដែលមានក្លិនក្រអូប ជាទីរីករាយនៃចិត្ត ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវដំណាក់កំពូលទាំងឡាយ ដែលលាបល្អហើយ ប្រោះព្រំដោយខ្លឹមចន្ទន៍ក្រហម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវគ្រែមាសទាំឡាយ មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវបល្ល័ង្កកែវមណី មានព្រំជាកម្រាលដ៏វិចិត្រ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវសំពត់អំបោះ និងសំពត់សូត្រ សំពត់ទាំងឡាយដែលកើតអំពីដែនខោមៈ និងកើតអំពីដែនកោទុម្ពរ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវស្រះបោក្ខរណីទាំងឡាយ ជាទីរីករាយ មានសត្វចាក្រពាកយំទ្រហឹង ដេរដាសដោយចង្កូលណីទាំងឡាយផង ដោយឈូក នឹងព្រលិតទាំងឡាយផង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវហ្វូងដំរីមាតង្គៈ ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ មានខ្សែដង្កន់មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរីមានលំពែងស្ទែងក្របី និងកង្វេរក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវហ្វូងសេះអាជានេយ្យអំពីជាតិជាសេះសិន្ធព ដែលស្អិតស្អាងដោយគ្រឿងអលង្ការគ្រប់មុខ ជាវាហនៈលឿន ដែលអ្នកបង្ហាត់សេះកាន់ស៊ើ និងធ្នូ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួករថ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួករថមាសប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង នឹងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថប្រាក់ ប្រដាប់ហើយ

មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមសេះ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមឱដ្ឋ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមគោ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមកែស ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមពពែ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវរថទឹមម្រឹគ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះដំរី ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះសេះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវស៊ែ និងធ្នូ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកអ្នកជិះរថ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងព្រួញក្នុងដៃ ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកខ្មាន់ធ្នូ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកព្រះរាជបុត្ត ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាស និងកែវពិទូរ្យ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកអរិយជន គឺព្រាហ្មណ៍ដែលមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ស្លៀកដណ្តប់ដោយសំពត់ដែលបានមកអំពីដែនកាសីដ៏ឧត្តម ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកអាមាត្យ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវពួកស្រីស្នំ ៧០០ ជាអ្នកសង្រួមល្អ មានចង្កេះរៀវ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវស្រីស្នំ ៧០០ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រលាញ់ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអញនឹងលះបង់នូវភាជន៍មាស មានទម្ងន់ ១០០ បល្ល: ប្រកបដោយស្នាមចំឡាក់ ១០០ ហើយបួស ការលះបង់នោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាហ្វូងដំរីមាតង្គ: របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង មានខ្សែដង្កន់មាស មានគ្រឿងស្អាងដោយបណ្តាញមាស ដែលហ្មដំរីមានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាហ្វូងសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ជាសេះអាជានេយ្យដោយជាតិ ជាសេះសិន្ធព ជាវាហនៈដ៏លឿន ដែលពួកអ្នករក្សាសេះកាន់ស៊ែ និងធ្នូ ឡើងជិះហើយ នឹងមិនដើរតាមអញកាលទៅ ដំណើរនោះនឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួករថរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនដើរតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួករថមាសរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញ កាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួករថប្រាក់របស់អញ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមសេះរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមឱដ្ឋរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមគោរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមកែសរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមពពែរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថី មានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណារថទឹមម្រឹគរបស់អញ ប្រដាប់ហើយ មានទង់លើកហើយ ទាំងបិទបាំងដោយស្បែកខ្លាដំបង និងខ្លាធំ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ដែលពួកនាយសារថីមានធ្នូ និងខែលក្នុងដៃ ឡើងជិះហើយ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអ្នកជិះដំរីរបស់អញ ស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានលំពែងស្នែងក្របី និងកង្វេរក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអ្នកជិះសេះរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវស៊ែ និងធ្នូ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអ្នកជិះរថរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកខ្មាន់ធ្នូរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌ខៀវ ជាអ្នកក្លៀវក្លា មានធ្នូ និងបំពង់ព្រួញក្នុងដៃ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួករាជបុត្ររបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលដ៏វិចិត្រ ជាអ្នកក្លៀវក្លា ទ្រទ្រង់នូវមាស និងកែវពិទូរ្យ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអរិយជន គឺព្រាហ្មណ៍ អ្នកមានសំពត់ មានគ្រឿងប្រដាប់ហើយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ក្រហម ទ្រទ្រង់នូវសំពត់ដ៏ឧត្តមដែលបានមកអំពីដែនកាសី នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកអាមាត្យរបស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង កាន់ខែលមានពណ៌លឿង ជាអ្នកក្លៀវក្លា មានរបៀបដើរខាងមុខ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកស្ត្រីស្នំ

៧០០ របស់អញ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ជាស្ត្រីសង្រមល្អ មានចង្កេះរាវ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាពួកស្ត្រីស្នំ ៧០០ របស់អញ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រលាញ់ នឹងមិនទៅតាមអញកាលទៅ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ នឹងបានទៅជាអ្នកកោរក្បាល ឃ្លុំសង្ឃាដិ កាន់បាត្រ ត្រាច់ចរទៅបិណ្ឌបាត ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ នឹងទ្រទ្រង់នូវសង្ឃាដិនៃសំពត់បង្សុកូលទាំងឡាយ ដែលគេចោល ក្នុងផ្លូវធំ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ កាលដែលមេឃបង្អុរភ្លៀងចុះអស់ ៧ ថ្ងៃហើយ នឹងត្រាច់ទៅបិណ្ឌបាតទាំងចីវរទទឹក ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញនឹងចេញទៅអំពីដើមឈើមួយ ទៅកាន់ដើមឈើមួយ អំពីព្រៃមួយ ទៅកាន់ព្រៃមួយ រហូតថ្ងៃ និងយប់ទាំងអស់ ត្រាច់ទៅឥតអាឡោះអាល័យ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ នឹងលះបង់នូវភ័យគួរខ្លាច ហើយមិនមានគ្នាជាគំរប់ពីរនាក់ ដើរទៅលើជ្រោះភ្នំទាំងឡាយ ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញធ្វើចិត្តឲ្យត្រង់ ដូចជាបុគ្គលដេញពិណ អាចដេញខ្សែទាំង ៧ ឲ្យជាទីរីករាយចិត្តបាន ដំណើរនោះ នឹងសម្រេចក្នុងកាលណាហ្ន៎។ កាលណាអាត្មាអញ នឹងកាត់នូវកាមសំយោជន៍ជាទិព្វ ទាំងជារបស់មនុស្សបាន ដូចជាជាងរថ កាលកាត់នូវស្បែកជើងដូច្នោះ។

[៦១] (អភិសម្ពុទ្ធគាថា) ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ផ្គងដើមដៃទូញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី។ ពួកស្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីសង្រមល្អ មានចង្កេះរៀវ ផ្គងដើមដៃទូញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី។ ពួកស្រីស្នំទាំង ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រលាញ់ ផ្គងដើមដៃទូញយំថា ព្រះអង្គនឹងលះចោលពួកខ្ញុំម្ចាស់ ព្រោះហេតុអ្វី។ ព្រះរាជាទ្រង់លះនូវសម្បទ បានលះបង់ពួកស្រីស្នំទាំង ៧០០ នាក់នោះ ដែលស្អិតស្អាងដោយគ្រឿងអលង្ការទាំងពួង ព្រះអង្គត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ។ ព្រះរាជាទ្រង់លះបង់នូវសម្បទ បានលះបង់ពួកស្ត្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីសង្រមល្អ មានចង្កេះរៀវ ត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ។ ព្រះរាជាទ្រង់លះបង់នូវសម្បទ បានលះនូវពួកស្ត្រីស្នំ ៧០០ នាក់នោះ ជាស្ត្រីស្តាប់បង្គាប់ ពោលពាក្យជាទីស្រលាញ់ ត្រូវបព្វជ្ជាបញ្ចូនទៅខាងមុខហើយ។ ព្រះរាជាទ្រង់លះបង់នូវភាជន៍មាសមានទម្ងន់មួយរយបល្លៈ ប្រកបដោយស្នាមចម្លាក់មួយរយ បានកាន់យកនូវបាត្រដី ការកាន់នូវបាត្រដីនោះ ទុកជាអភិសេកទី ២។

[៦២] (ព្រះនាងសីវលីទេវី) ឃ្លាំងទាំងឡាយ គឺឃ្លាំងប្រាក់ ឃ្លាំងមាស ឃ្លាំងកែវមុក្តា ឃ្លាំងកែវពិទូរ្យ ឃ្លាំងកែវមណី ឃ្លាំងស័ង្ខ ឃ្លាំងកែវមុក្តាដ៏ច្រើន ឃ្លាំងសំពត់ ឃ្លាំងខ្លឹមចន្ទន៍ក្រហម ឃ្លាំងស្បែកខ្លាឃ្មុំ ឃ្លាំងរបស់ធ្វើពីភ្លុក ឃ្លាំងទង់ដែង និងឃ្លាំងដែកខ្មៅដ៏ច្រើន ជាឃ្លាំងដែលរាជបុរសរៀបចំដោយចំណែក ត្រូវភ្លើងឆេះ មានអណ្តាតភ្លើងស្មើគ្នា គួរខ្លាច បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យទ្រព្យរបស់ព្រះអង្គនោះវិនាស។

[៦៣] (ព្រះរាជា) កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ កាលបើក្រុងមិថិលាត្រូវភ្លើងឆេះ ភ្លើងមិនមែនឆេះនូវទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ។

[៦៤] (ព្រះនាងសីវលីទេវី) ចោរក្នុងដងព្រៃកើតឡើងហើយ បំផ្លាញដែនរបស់ព្រះអង្គ បពិត្រព្រះរាជា សូមព្រះអង្គស្តេចមក សូមស្តេចត្រឡប់វិលវិញ កុំឲ្យដែននេះវិនាស។

[៦៥] (ព្រះរាជា) កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ កាលបើដែនត្រូវពួកចោរប្លន់ ចោរមិនបានយកទ្រព្យបន្តិចបន្តួចរបស់ខ្ញុំទេ កង្វល់មិនមានដល់យើងណា យើងនោះឈ្មោះថា រស់នៅជាសុខ យើងជាអ្នកមានបីតិជាអាហារ ដូចពួកអាភស្សរទេវតា។

[៦៦] (នារទតាបស) សំឡេងគឹកកងនៃជនច្រើននេះ តើព្រោះហេតុអ្វី ស្ត្រីនោះជាអ្វី លេងជាមួយក្នុងព្រៃ ដូចក្នុងស្រុក បពិត្រសមណៈ ខ្ញុំសួរលោកថា មហាជននុ៎ះ ប្រជុំគ្នាដើម្បីអ្វី។

[៦៧] (ព្រះរាជា) ខ្ញុំកាលលះបង់នូវមហាជន ហើយចេញទៅ បានជាមហាជនប្រជុំគ្នាក្នុងទីនេះ ខ្ញុំកន្លងនូវដែន គឺកិលេស ហើយទៅបួសដើម្បីបាននូវមោនធម៌ (ពោលគឺ ញាណរបស់អនាគារិយៈ) មុនី ខ្ញុំកាលទៅកាន់ទីច្រឡូកច្រឡំដោយសេចក្តីរីករាយទាំងឡាយ អ្នកដឹងទើបសួរឬ (ឬមិនដឹង)។

[៦៨] (នារទតាបស) ព្រះអង្គកាលទ្រទ្រង់នូវសរីរៈនេះ កុំសំគាល់ថា អញឆ្លងកិលេសហើយដូច្នេះ កម្ម (គឺកិលេស) នេះ បុគ្គលមិនគប្បីឆ្លងបានទេ ព្រោះថា សេចក្តីអន្តរាយមានច្រើន។

[៦៩] (ព្រះរាជា) ខ្ញុំណាមិនប្រាថ្នានូវកាមទាំងឡាយក្នុងមនុស្សលោក ដែលបុគ្គលឃើញហើយ មិនប្រាថ្នានូវកាមទាំងឡាយក្នុងទេវលោក ដែលបុគ្គលមិនឃើញហើយ សេចក្តីអន្តរាយដូចម្តេចហ្ន៎ នឹងមានដល់ខ្ញុំនោះ មានកិរិយាទៅយ៉ាងនេះ។

[៧០] (នារទតាបស) ដ្បិតថា សេចក្តីអន្តរាយ តាំងឡើងច្រើន គឺការដេកលក់ សេចក្តីខ្ជិល ការមិតពត់ សេចក្តីអផ្សុក ការពុលបាយ តាំងនៅក្នុងសរីរៈ រមែងកើត (ក្នុងសរីរៈវិញ)។

[៧១] (ព្រះរាជា) បពិត្រព្រាហ្មណ៍ លោកដ៏ចំរើនប្រៀនប្រដៅខ្ញុំល្អណាស់ បពិត្រព្រាហ្មណ៍ ខ្ញុំសួរលោក បពិត្រលោកនិរទុក្ខ លោកជាអ្វី។

[៧២] (នារទតាបស) ជនទាំងឡាយ ស្គាល់អាត្មាភាពដោយនាមថា នារទៈ ដោយគោត្រថា កស្សបៈ ដូច្នេះ អាត្មាភាពមកក្នុងសំណាក់ព្រះអង្គដ៏ចំរើន ដោយដឹងច្បាស់ថា សមាគមដោយសប្បុរសទាំងឡាយ ជាកិច្ចញ៉ាំងប្រយោជន៍ឲ្យសម្រេច។ សេចក្តីត្រេកអរ (ក្នុងបព្វជ្ជា) ទាំងអស់ និងព្រហ្មវិហារ ចូរកើតដល់ព្រះអង្គនោះចុះ បរិកម្ម និងឈានណា ការខ្វះខាត (ដោយសីល និងឈាន) ណា ព្រះអង្គចូរបំពេញនូវការខ្វះខាតនោះចុះ ព្រះអង្គ (ចូរប្រកប) ដោយអធិវាសនក្ខន្តិ និងឧបសមៈ។ ព្រះអង្គចូររំសាយចោលនូវសេចក្តីមើលងាយ និងសេចក្តីក្រអឺតក្រឱង ចូរធ្វើគោរពនូវកុសលកម្ម នូវវិជ្ជា និងធម៌។

[៧៣] (មិគាជិនតាបស) បពិត្រព្រះជនក ព្រះអង្គលះបង់ដំរីសេះ ពួកអ្នកនគរ និងជនបទជាច្រើន ហើយទ្រង់ព្រះផ្នួស ដល់នូវសេចក្តីត្រេកអរនឹងអម្បែង បពិត្រព្រះជនក ពួកអ្នកជនបទ មិត្រអាមាត្យ និងព្រះញាតិ បានធ្វើនូវការទ្រុស្តចំពោះព្រះអង្គខ្លះដែរឬ ព្រោះហេតុអ្វីក៏ព្រះអង្គពេញព្រះហឫទ័យនឹងអម្បែងរបស់ព្រះអង្គនោះ។

[៧៤] (ព្រះមហាជនក) បពិត្រមិគាជិនៈ ក្នុងកាលណាមក ខ្ញុំមិនដែលផ្ចាញ់នូវញាតិណាមួយដោយអធម៌ជាដាច់ខាត ទាំងពួកញាតិ

កំមិនដែលផ្ចាញ់ខ្ញុំដោយអធម៌ដែរ។

[៧៥] បពិត្រមិគាជិនៈ ខ្ញុំបានឃើញនូវប្រវេណីនៃសត្វលោក ដែលកិលេសកំពុងទំពាស៊ី ធ្វើឲ្យដូចជាភក់ បុថុជ្ជនលិចចុះហើយក្នុងកិលេសវត្ថុណា សត្វទាំងឡាយ តែងបៀតបៀនគ្នាផង តែងជាប់ក្នុងកិលេសវត្ថុនោះផង ហើយក៏ធ្វើនូវពួកបុថុជ្ជនទាំងនេះ ឲ្យជាគ្រឿងប្រៀបធៀប ទើបបួសជាភិក្ខុ។

[៧៦] (មិគាជិនតាបស) បពិត្រព្រះអង្គប្រសើរក្នុងរថ បុគ្គលមានជោគណា ជាសាស្តារបស់ព្រះអង្គ ពាក្យដ៏ពីរោះនេះ ជាពាក្យរបស់បុគ្គលណា ព្រោះថា អ្នកប្រាជ្ញទាំងឡាយ មិនរៀននូវតាបសអ្នកសម្រេចអភិញ្ញា ឬនូវព្រះបច្ចេកពុទ្ធដែលប្រកបដោយវិជ្ជា ហើយពោលនូវសមណៈថា អ្នកមានវត្តជាគ្រឿងកន្លងនូវទុក្ខទេ។

[៧៧] (ព្រះមហាជនក) បពិត្រមិគាជិនៈ ខ្ញុំមិនដែលចូលទៅគោរពសមណៈ និងព្រាហ្មណ៍ណាមួយដោយដាច់ខាត ក្នុងកាលណាម្តងឡើយ។ បពិត្រមិគាជិនៈ ខ្ញុំកាលទៅដោយអានុភាពដ៏ធំ រុងរឿងដោយសិរី កាលចម្រៀងដែលបុគ្គលកំពុងច្រៀង កាលតន្រ្តីមានសំឡេងដ៏ពីរោះ ដែលបុគ្គលកំពុងប្រគំ បានឃើញស្វាយមានផ្លែខាងក្រៅកំពែង ដែលពួកមនុស្សអ្នកត្រូវការផ្លែ បេះជិតឧទ្យានដែលគឹកកងដោយការប្រគំតន្ត្រី ជាឧទ្យានប្រកបដោយសូរប្រគំដ៏ពីរោះ បពិត្រមិគាជិនៈ ខ្ញុំនោះ បានលះបង់សិរីនោះ ហើយចុះ (អំពីដំរី) ចូលទៅកាន់គល់ស្វាយដែលមានផ្លែ និងមិនមានផ្លែ បានឃើញស្វាយមានផ្លែ ដែលបុគ្គលបៀតបៀនហើយ កំចាត់ហើយ ធ្វើមិនឲ្យមានស្លឹក និងស្វាយ ១ ដើមក្រៅនេះ មានពន្លឺខៀវ ជាទីរីករាយនៃចិត្ត សត្រូវទាំងឡាយ អាចសម្លាប់យើងដែលជាឥស្សរៈ មានបន្លាច្រើនដោយពិត ដូចដើមស្វាយដែលមានផ្លែ ដែលបុគ្គលសម្លាប់ហើយ ខ្លាដំបង ត្រូវគេសម្លាប់ព្រោះស្បែក ដំរីត្រូវគេសម្លាប់ព្រោះភ្លុក បុគ្គលអ្នកមានទ្រព្យ ត្រូវគេសម្លាប់ព្រោះទ្រព្យ តើនរណា នឹងសម្លាប់បុគ្គលអ្នកមិនមានផ្ទះ មិនមានសន្ថវៈ ដើមស្វាយមានផ្លែ និងមិនមានផ្លែ ទាំងពីរនោះ ជាសាស្តារបស់ខ្ញុំ។

[៧៨] (នាងសីវលី) ជនទាំងពួង គឺសេនាដំរី ពលសេះ ពលរថ ពលថ្មើរជើង បានឮថា ព្រះរាជាទ្រង់ផ្នួសហើយ ក៏តក់ស្លុត សូមព្រះអង្គលួងលោមនូវប្រជុំជន ហើយតាំងទុកនូវការរក្សា រួចតាំងព្រះរាជឱរសក្នុងរាជសម្បត្តិ ហើយសឹមទ្រង់ព្រះផ្នួស ក្នុងកាលជាខាងក្រោយចុះ។

[៧៩] (ព្រះមហាជនក) ពួកអ្នកជនបទ មិត្រ អាមាត្យ និងញាតិទាំងឡាយ ដែលយើងលះបង់ហើយ កូនរបស់អ្នកដែនវិទេហៈ ឈ្មោះទីឃាវុកុមារ អ្នកញ៉ាំងដែនឲ្យចំរើន ម្នាលបជាបតិ កូននោះ នឹងសោយរាជ្យក្នុងក្រុងមិថិលាចុះ។

[៨០] នាងចូរមកនេះ ពាក្យណាដែលអាត្មាពេញចិត្ត អាត្មានឹងប្រាប់នូវពាក្យនោះ នាងនឹងទៅកាន់ទុគ្គតិ ដោយកាយ វាចា ចិត្តណា នាងឯងកាលសោយរាជ្យ (ឈ្មោះថាធ្វើ) នូវបាបទុច្ចរិតដ៏ច្រើន ដោយកាយ វាចា ចិត្តនោះ អាត្មានឹងញ៉ាំងអត្តភាព ឲ្យប្រព្រឹត្តទៅដោយដុំបាយ ដែលបុគ្គលដទៃឲ្យហើយ ដែលបុគ្គលដទៃសម្រេចហើយ (នេះ) ជាបវេណីរបស់អ្នកប្រាជ្ញ។

[៨១] (នាងសីវលី) បុគ្គលណា មិនបរិភោគអាហារក្នុងកាលនៃភត្តជាគំរប់ ៤ បុគ្គនោះគប្បីស្លាប់ដោយសេចក្តីស្រេកឃ្លាន ដូចបុគ្គលដល់នូវសេចក្តីស្លាប់ដ៏ពិត មានសភាពជាកុលបុត្រ មិនគប្បីបរិភោគដុំបាយ ដែលប្រឡាក់ដោយធូលីមិនស្អាតទេ ឬការបរិភោគនោះមិនល្អទេ មិនប្រសើរទេ បពិត្រមហាជនក ព្រះអង្គសោយនូវដុំបាយដែលសល់អំពីឆ្កែ។

[៨២] (ព្រះរាជា) ម្នាលសីវលី វត្ថុណាដែលគ្រហស្ថ ឬសុនខលះបង់ហើយ វត្ថុនោះ មិនមែនជាអាត្មាមិនគួរឆាន់ទេ ភោគៈទាំងឡាយណានីមួយក្នុងលោកនេះ ដែលបានដោយធម៌ ភោគៈទាំងអស់នោះ លោកពោលថា ជាអាហារមិនមានទោស។

[៨៣] (ព្រះរាជា) ម្នាលនាងកុមារិកា ជាក្មេងដេកជិតមាតានៅឡើយ មានគ្រឿងប្រដាប់មិនឃ្លាតអំពីខ្លួនជានិច្ច ដៃម្ខាងរបស់នាងលាន់ឮសំឡេង ដៃម្ខាងមិនលាន់ឮសំឡេង តើព្រោះហេតុអ្វី។

[៨៤] (នាងកុមារិកា) បពិត្រសមណៈ កងពីរដែលពាក់នឹងដៃរបស់ខ្ញុំនេះ ខ្ទប់គ្នាហើយ សំឡេងក៏កើតឡើង នោះជាគតិនៃកងទាំងពីរ បពិត្រសមណៈ កង ១ ដែលពាក់នឹងដៃរបស់ខ្ញុំនេះ កងនោះ មិនមានកងឯទៀតជាគំរប់ពីរ ទើបមិនលាន់ឮសំឡេង ដូចអរិយបុគ្គល ជាអ្នកស្ងប់ស្ងៀម ឯបុគ្គលមានគ្នាជាគំរប់ពីរនាក់ រមែងដល់នូវការជជែកគ្នា បុគ្គល ១ នាក់ នឹងជជែកជាមួយនឹងបុគ្គលណាកើត ព្រះអង្គនោះជាអ្នកប្រាថ្នានូវឋានសួគ៌ សូមទ្រង់ពេញចិត្តនឹងភាពនៃបុគ្គលម្នាក់ឯងចុះ។

[៨៥] (ព្រះរាជា) ម្នាលនាងសីវលី នាងឮគាថាដែលនាងកុមារិកាពោលហើយឬទេ នាងកុមារិកាតិះដៀលនូវអាត្មា ដូចជាអ្នកបំរើនោះឯងជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចំរើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវតែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាងចូរកាន់ផ្លូវ ១ អាត្មានឹងកាន់ផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថាជាប្រពន្ធទៀតដែរ។

(អភិសម្ពុទ្ធគាថា) ព្រះរាជា និងនាងសីវលី កាលពោលនូវពាក្យនេះហើយ ក៏ចូលទៅកាន់ថូណនគរ។ កាលជិតវេលាភត្ត ព្រះរាជា (ក៏ឈរ) ជិតទ្វារនៃជាងព្រួញ ជាងព្រួញនោះធ្មេចភ្នែកម្ខាង សំឡឹងមើលដងព្រួញវៀចមួយ ដែលធ្វើឲ្យត្រង់ដោយភ្នែកម្ខាង ជិតក្លោងទ្វារនោះ។

[៨៦] (ព្រះរាជា) ម្នាលជាងព្រួញ អ្នកចូរស្តាប់ពាក្យអាត្មា អ្នកធ្មេចភ្នែកម្ខាង សំឡឹងមើលដងព្រួញវៀច អ្នកមើលយ៉ាងនេះស្រួលឬ។

[៨៧] (ជាងព្រួញ) បពិត្រសមណៈ ទីប្រាកដដូចជាទូលាយដោយភ្នែកពីរ កិច្ចដោយភាវៈនៃព្រួញត្រង់ រមែងមិនសម្រេច ព្រោះមិនឃើញនូវទីវៀចខាងមុខ។ កាលបុគ្គលធ្មេចភ្នែកម្ខាង សំឡឹងមើលទីវៀចដោយភ្នែកម្ខាង កិច្ចដោយភាពនៃព្រួញត្រង់ រមែងសម្រេច ព្រោះឃើញទីវៀចខាងមុខ។ បុគ្គលជាគំរប់ពីរ រមែងដល់នូវការជជែកគ្នា បុគ្គលម្នាក់ឯង នឹងជជែកគ្នាជាមួយនឹងអ្នកណាកើត កាលព្រះអង្គនោះ ប្រាថ្នានូវឋានសួគ៌ សូមពេញព្រះទ័យនឹងភាពនៃបុគ្គលម្នាក់ឯងចុះ។

[៨៨] (ព្រះរាជា...) នៃនាងសីវលី នាងឮគាថាដែលជាងព្រួញពោលហើយឬទេ ជាងព្រួញតិះដៀលអាត្មា ដូចជាអ្នកបំរើ នោះជាគតិនៃបុគ្គលពីរនាក់ ម្នាលនាងដ៏ចំរើន ផ្លូវបែកជាពីរនេះ ដែលអ្នកដើរផ្លូវតែងដើរទៅ បណ្តាផ្លូវទាំងពីរនោះ នាងចូរកាន់យកផ្លូវ ១ អាត្មានឹងកាន់យកផ្លូវ ១ ដទៃទៀត នាងកុំហៅអាត្មាថាជាស្វាមីរបស់អញ អាត្មាក៏មិនហៅនាងថាជាភរិយារបស់អាត្មាដែរ ម្នាលនាងសីវលី នាងចូរនៅម្នាក់ឯងចុះ ដូចស្មៅឃាប្លងដែលអាត្មាដកហើយ។

ចប់ មហាជនកជាតក ទី២។

## សុវណ្ណសាមជាតក ទី៣

## (៥៤០. សុវណ្ណសាមជាតកំ (៣))

[៨៩] (សុវណ្ណសាមបណ្ឌិតសួរថា) នរណាហ្ន៎ បាញ់ខ្ញុំជាអ្នកដងទឹក ភ្លេចស្មារតី[52] ដោយព្រួញ ជនណាជាក្សត្រ ឬជាព្រាហ្មណ៍ ឬជាវេស្សៈ បាញ់ខ្ញុំហើយពួន។ សាច់ទាំងឡាយរបស់ខ្ញុំ មិនមែនជារបស់គួរទំពាស៊ីទេ សេចក្តីត្រូវការដោយស្បែក មិនមានទេ កាលបើដូច្នេះ តើអ្នកសំគាល់នូវខ្ញុំថាគួរបាញ់ ដោយហេតុដូចម្តេច។ អ្នកជាអ្វី ជាបុត្ររបស់អ្នកណា យើងស្គាល់អ្នកដូចម្តេចបាន ម្នាលសំឡាញ់ អ្នក ខ្ញុំសួរហើយ ចូរប្រាប់ ម្តេចក៏បានជាអ្នកបាញ់ខ្ញុំហើយពួន។

[៩០] (ព្រះបាទបិលយក្ខត្រាស់ថា) ខ្ញុំជាព្រះរាជារបស់ពួកអ្នកកាសី គេស្គាល់ខ្ញុំថា ឈ្មោះបិលយក្ខ ខ្ញុំលះបង់នូវដែនមកត្រាច់ស្វែងរកម្រឹគ ព្រោះលោភ (ក្នុងសាច់)។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ ជាអ្នកមានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំបាន[53] សូម្បីដំរី តែមកត្រង់មុខព្រួញរបស់ខ្ញុំហើយ មិនគប្បីរួចទេ។ ចុះអ្នកជាអ្វី ជាបុត្ររបស់អ្នកណា ដូចម្តេចទើបយើងស្គាល់អ្នកបាន សូមអ្នកប្រាប់នូវនាម និងគោត្តរបស់បីតាផង របស់ខ្លួនផង។

[៩១] (ព្រះមហាសត្វ...) បពិត្រព្រះអង្គដ៏ចំរើន ខ្ញុំ (ជាកូនរបស់ឥសី) ជាបុត្តរបស់នាយនេសាទ ពួកញាតិហៅទូលបង្គំជាខ្ញុំកំពុងរស់នៅថាសាមៈ ថ្ងៃនេះ ទូលបង្គំជាខ្ញុំនោះ ដល់ (មាត់មច្ចុរាជ) ហើយដេកនៅយ៉ាងនេះ។ ខ្ញុំដែលព្រះអង្គបាញ់ហើយ ហាក់ដូចម្រឹគដែលព្រានព្រៃបាញ់ហើយ ដោយព្រួញធំប្រកបដោយថ្នាំពិសដូច្នោះ បពិត្រព្រះរាជា សូមទ្រង់ទតចុះ ទូលបង្គំជាខ្ញុំដេកត្រាំនៅក្នុងឈាមរបស់ខ្លួន។ សូមទ្រង់ទតព្រួញដែលមុតធ្លាយទៅខាងឆ្វេង ទូលបង្គំជាខ្ញុំខ្ពុលឈាម ទូលបង្គំជាខ្ញុំចាប់ពើតណាស់ បានជាសួរព្រះអង្គរឿយៗ ម្តេចក៏ទ្រង់បាញ់ទូលបង្គំជាខ្ញុំហើយពួន។ ខ្លាដំបង គេសម្លាប់ព្រោះតែស្បែក ដំរីគេសម្លាប់ព្រោះភ្លុកទាំងឡាយ កាលបើដូច្នោះ តើព្រះអង្គសំគាល់នូវទូលបង្គំជាខ្ញុំថាគួរបាញ់ ដោយហេតុដូចម្តេច។

[៩២] (ព្រះបាទបិលយក្ខនិយាយកុហកថា) ម្រឹគមកប្រាកដចំមុខព្រួញរបស់ខ្ញុំហើយ ឃើញអ្នកហើយក៏ផ្អើលទៅ ម្នាលសាមៈ ព្រោះហេតុនោះ បានជាខ្ញុំមានសេចក្តីក្រោធគ្របសង្កត់។

[៩៣] (ព្រះមហាសត្វ...) តាំងពីកាលដែលខ្ញុំរឭកឃើញនូវខ្លួន តាំងពីកាលដែលខ្ញុំដល់នូវភាពជាអ្នកដឹងក្តី ម្រឹគទាំងឡាយសូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល (ឃើញ) ទូលបង្គំជាខ្ញុំ ហើយតក់ស្លុតទេ។ តាំងពីកាលដែលខ្ញុំស្លៀកដណ្តប់សំពត់សំបកឈើ តាំងពីកាលដែលខ្ញុំដល់នូវវ័យដ៏ចំរើន ម្រឹគទាំងឡាយ សូម្បីជាសត្វសាហាវក្នុងព្រៃ មិនដែល (ឃើញ) នូវខ្ញុំ ហើយតក់ស្លុតទេ។ បពិត្រព្រះរាជា កិន្នរទាំងឡាយ ដែលជាសត្វខ្លាច (នៅ) នាភ្នំគន្ធមាទន៍ (មិនដែលឃើញខ្ញុំ ហើយតក់ស្លុតទេ) យើងទាំងឡាយ តែងរីករាយជាមួយគ្នាទៅកាន់ភ្នំ និងព្រៃ កាលបើដូច្នោះ ម្រឹគទាំងឡាយ (ឃើញ) នូវទូលបង្គំជាខ្ញុំ ហើយតក់ស្លុត ដោយហេតុដូចម្តេច។

[៩៤] (ព្រះបាទបិលយក្ខ) ម្នាលសាមៈ ម្រឹគមិនមែនផ្អើលនឹងអ្នកទេ ខ្ញុំនឹងនិយាយកុហកធ្វើអ្វី ខ្ញុំមានសេចក្តីក្រោធ និងសេចក្តីលោភគ្របសង្កត់ហើយ ទើបបាញ់អ្នកនឹងព្រួញនោះ។ ម្នាលសាមៈ អ្នកមកអំពីប្រទេសណា ឬនរណាប្រើមកថា អ្នកដងទឹក ចូរទៅកាន់ស្ទឹងដូច្នេះ បានជាអ្នកមកកាន់ស្ទឹង មិគសម្មតៈ (នេះ)។

[៩៥] (ព្រះមហាសត្វ) មាតាបិតារបស់ទូលបង្គំជាខ្ញុំខ្វាក់ ទូលបង្គំជាខ្ញុំតែងចិញ្ចឹមគាត់ក្នុងព្រៃធំ ទូលបង្គំជាខ្ញុំជាអ្នកដងទឹកដើម្បីអ្នកមានគុណទាំងឡាយ បានជាមកកាន់ស្ទឹងមិគសម្មតៈ (នេះ)។

[៩៦] (ព្រះមហាសត្វពិលាប) មាតាបិតាទាំងឡាយនោះ មានត្រឹមតែភោជន កាលបើយ៉ាងនេះ (ជីវិតនឹងប្រព្រឹត្តទៅ) ត្រឹម ៦ ថ្ងៃ ព្រោះគាត់ខ្វាក់ មុខជានឹងស្លាប់ដោយឥតទឹកពុំខាន។ ទុក្ខនេះមិនមែនជាទុក្ខរបស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខនេះ បុរសត្រូវតែបាន ត្រង់ដែលទូលបង្គំជាខ្ញុំ ខានឃើញមាតាដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែងរបស់ទូលបង្គំជាខ្ញុំ ជាងទុក្ខនេះ (ទៅទៀត)។ ទុក្ខនេះមិនមែនជាទុក្ខរបស់ទូលបង្គំជាខ្ញុំប៉ុណ្ណោះទេ ព្រោះថា ទុក្ខនេះបុរសត្រូវតែបាន ត្រង់ដែលទូលបង្គំជាខ្ញុំ ខានឃើញបិតាដោយហេតុណា ហេតុនោះ ជាទុក្ខដ៏ក្រៃលែងរបស់ទូលបង្គំជាខ្ញុំ ជាងទុក្ខនេះ (ទៅទៀត)។ ឱម្ល៉េះ សមមាតានៅកំព្រាទួញយំ ទាំងអធ្រាត្រ និងទីបំផុតនៃរាត្រីអស់កាលជាយូរអង្វែង មុខជានឹងរីងស្ងួតទៅ ដូចជាស្ទឹង (ក្នុងគិម្ហរដូវ) ពុំខាន។ ឱម្ល៉េះ សមបិតានៅកំព្រា ទួញយំទាំងអធ្រាត្រ និងទីបំផុតនៃរាត្រី អស់កាលជាយូរអង្វែង មុខជានឹងរីងស្ងួត ដូចជាស្ទឹងពុំខាន។ បពិត្រព្រះរាជា មួយវិញទៀត (ខ្ញុំតែងភ្ញាក់ក្នុងមួយយប់ពីរបីដង) ដើម្បីបំរើបាទាដោយព្យាយាម នឹងដើម្បីគក់ច្របាច់ ម្ល៉េះសមគាត់នឹងដើរចច្រប់ក្នុងព្រៃធំ ដង្ហោយហៅថា អើបាសាមៈ ដូច្នេះពុំខានឡើយ។ បើទូលបង្គំជាខ្ញុំ ខានឃើញជនខ្វាក់ទាំងពីរនាក់ដោយហេតុណា ហេតុនោះឯង ទុក្ខជាសរទីពីរ ដែលញាំងហឫទ័យរបស់ទូលបង្គំជាខ្ញុំឲ្យញាប់ញ័រ មុខជាជីវិតទូលបង្គំជាខ្ញុំនឹងវិនាសពុំខាន។

[៩៧] (ព្រះបាទបិលយក្ខ) ម្នាលសាមៈ ជាអ្នកមានរូបល្អគួរឲ្យគយគន់ អ្នកកុំទួញយំខ្លាំងឡើយ ខ្ញុំនឹងជាអ្នកធ្វើការងារចិញ្ចឹមនូវជនទាំងឡាយនោះក្នុងព្រៃធំ។ មួយវិញទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូស្រាប់ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំ ខ្ញុំជាអ្នកធ្វើការងារចិញ្ចឹមនូវជនទាំងឡាយនោះក្នុងព្រៃធំ។ ខ្ញុំនឹងជាអ្នកធ្វើការងារ ស្វែងរកអំពារនៃម្រឹគ និងមើមឈើ ផ្លែឈើទាំងឡាយក្នុងព្រៃ ហើយនឹងចិញ្ចឹមនូវជនទាំងឡាយនោះក្នុងព្រៃធំ។ ម្នាលសាមៈ មាតាបិតារបស់អ្នក នៅក្នុងព្រៃណា ព្រៃនោះដូចម្តេច អ្នកបានចិញ្ចឹមនូវមាតាបិតាយ៉ាងណា ខ្ញុំក៏នឹងចិញ្ចឹមនូវគាត់យ៉ាងនោះដែរ។

[៩៨] (ព្រះមហាសត្តុ) បពិត្រព្រះរាជា ផ្លូវចុះតែជើងម្នាក់នេះ នៅខាងក្បាលដំណេកទូលបង្គំជាខ្ញុំ ព្រះអង្គយាងទៅអំពីទីនេះ តែកន្លះយោសៈ (នឹងឃើញ) ខ្ទមជាទីនៅរបស់មាតាបិតាទូលបង្គំជាខ្ញុំនោះ ព្រះអង្គយាងទៅអំពីទីនេះ សូមទ្រង់ចិញ្ចឹមនូវគាត់ក្នុងទីនោះផង។

[៩៩] បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះរាជា ទ្រង់មានសេចក្តីចំរើនក្នុងដែនកាសី ទូលបង្គំជាខ្ញុំសូមថ្វាយបង្គំព្រះអង្គ មាតាបិតាទាំងឡាយរបស់ទូលបង្គំជាខ្ញុំ ជាមនុស្សខ្វាក់ សូមទ្រង់ចិញ្ចឹមនូវគាត់ក្នុងព្រៃធំឲ្យទាន។ ទូលបង្គំជាខ្ញុំ សូមផ្គងអញ្ជលីចំពោះព្រះអង្គ បពិត្រព្រះរាជាជាធំក្នុងដែនកាសី ទូលបង្គំជាខ្ញុំ សូមថ្វាយបង្គំព្រះអង្គ ទូលបង្គំជាខ្ញុំ សូមផ្តាំទុក សូមទ្រង់ជំរាបនូវការថ្វាយបង្គំចំពោះមាតាបិតារបស់ទូលបង្គំជាខ្ញុំផង។

[១០០] (អភិសម្ពុទ្ធគាថា) សាមៈ កម្លោះអ្នកមានរូបល្អ គួរពិតពិលរមិលមើលនោះ លុះពោលនូវពាក្យនេះរួចហើយ ក៏ជ្រប់សន្លប់ដោយកម្លាំងពិស។

[១០១] ព្រះរាជាអង្គនោះ ទ្រង់ព្រះកន្សែងរៀបរាប់នូវពាក្យដែលប្រកបដោយសេចក្តីករុណាមានប្រមាណច្រើនថា អាត្មាអញបានយល់ថា អញមិនចាស់ មិនស្លាប់ ថ្ងៃនេះ អញឃើញនូវសុវណ្ណសាមនេះ ធ្វើកាលកិរិយាហើយទើបដឹងនូវហេតុនោះ ពីដើមមិនដឹងជាការមកនៃសេចក្តីស្លាប់ មិនមែនមិនមានដូច្នេះ។ សាមៈដែលដោតដោយថ្នាំពិស កំពុងចរចាជាមួយនឹងអញ (ក្នុងកាលអម្បាញ់មិញនេះ) ឥឡូវនេះ

គាត់លែងនិយាយ ពាក្យតិចតួចក្នុងកាលប្រព្រឹត្តទៅយ៉ាងនេះ ក្នុងថ្ងៃនេះ អាត្មាអញ មុខជានឹងទៅកាន់នរកពុំខាន អាត្មាអញឥតមានសេចក្តីសង្ស័យក្នុងដំណើរនេះទេ។ ព្រោះថា អំពើបាបដែលអាត្មាអញធ្វើទុកហើយក្នុងគ្រានោះ នឹងជាទោសឲ្យផលលាមកអស់កាលជាអង្វែង (បើ) ក្នុងស្រុក គង់មានពួកអ្នកតិះដៀលអញនោះថា ព្រះអង្គជាអ្នកធ្វើនូវអំពើអាក្រក់ដូច្នេះ តែក្នុងអរញ្ញប្រទេសដែលឥតមនុស្ស តើនរណាតិះដៀលអញបាន។ បើក្នុងស្រុក ពួកមាណពប្រជុំគ្នា ហើយចោទប្រកាន់នូវអំពើទាំងឡាយ (របស់អញ) តែក្នុងអរញ្ញប្រទេសដែលឥតមនុស្ស តើនរណានឹងចោទប្រកាន់អញ។

[១០២] ទេវតានោះ[៥៤] បាត់អំពីភ្នំគន្ធមាទន៍ ហើយពោលនូវគាថាទាំងឡាយនេះ ដោយអនុគ្រោះព្រះរាជាថា បពិត្រមហារាជ បានឮថា ព្រះអង្គទ្រង់បានធ្វើនូវបាបជាទម្ងន់ ដែលជាអំពើអាក្រក់ ជនទាំងបីនាក់ គឺមាតាបិតា និងបុត្ត ជាអ្នកមិនប្រទូស្ត ទ្រង់បានសម្លាប់ហើយដោយព្រួញតែមួយ។ សូមទ្រង់មក សុគតិភពនឹងគប្បីមានដល់ព្រះអង្គ យ៉ាងណា ខ្ញុំនឹងពន្យល់ព្រះអង្គយ៉ាងនោះ សូមទ្រង់ចិញ្ចឹមនូវជនខ្វាក់ទាំងពីរនាក់នោះឯង ដោយធម៌ ខ្ញុំយល់ថា សុគតិគប្បីមាន។

[១០៣] ព្រះរាជាអង្គនោះ ទ្រង់ពិលាបរៀបរាប់ ប្រកបដោយសេចក្តីករុណាមានប្រមាណច្រើន ហើយកណ្តៀតក្អមទឹកយាងឆ្ពោះទៅទិសទក្សិណ។

[១០៤] (ទុកូលបណ្ឌិតសួរ...) សូរជើងនរណានុ៎ះហ្ន៎ ដែលដើរមកនេះ ពិតជាសូរជើងមនុស្ស តែសូរជើងនុ៎ះ មិនមែនជាសូរជើងសាមៈទេ ម្នាលអ្នកនិរទុក្ខ អ្នកជាអ្វីហ្ន៎ង។ ដ្បិតសាមៈ តែងដើរថ្នមៗ លើកដាក់ជើងស្រាលៗ សូរជើងនុ៎ះ មិនមែនជាសូរជើងសាមៈទេ ម្នាលអ្នកនិរទុក្ខ អ្នកជាអ្វីហ្ន៎ង។

[១០៥] (ព្រះបាទបិលយក្ខ...) ខ្ញុំជាព្រះរាជារបស់ពួកអ្នកដែនកាសី គេស្គាល់ខ្ញុំថា បិលយក្ខ ខ្ញុំលះបង់នូវដែន ត្រាច់ស្វែងរកម្រឹគ ព្រោះលោភ (សាច់)។ មួយទៀត ខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថាជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំបាន សូម្បីដំរីមកចំមុខព្រួញរបស់ខ្ញុំហើយ មិនគប្បីរួចទេ។

[១០៦] (ទុកូលបណ្ឌិត...) បពិត្រមហារាជ ព្រះរាជដំណើរមករបស់ព្រះអង្គល្អហើយ ព្រះដំណើរមករបស់ព្រះអង្គមិនអាក្រក់ទេ ព្រះអង្គជាធំ ទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូលចុះ។ បពិត្រព្រះរាជា ផលាផល គឺផ្លែទន្លាប់ មៈប៉ែន ស្រគំ សឹងមានរសផ្អែមដូចទឹកឃ្មុំ អាត្មាភាព ប្រមូលមកទុកក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផលមានរសឆ្ងាញ់ៗ។ នេះទឹកត្រជាក់សម្រាប់សោយ ដែលដងមកអំពីជ្រោះភ្នំ បពិត្រមហារាជ បើទ្រង់សព្វព្រះទ័យ ទ្រង់ (ដង) អំពីទីនេះសោយចុះ។

[១០៧] (ព្រះរាជា...) អ្នកទាំងពីរជាមនុស្សខ្វាក់ មិនអាចឃើញ (អ្វី) ក្នុងព្រៃទេ ចុះនរណាប្រមូលនូវផលាផលមកជូនអ្នក អាហារដែល (បាន) ដោយប្រពៃនេះ ប្រាកដដល់ខ្ញុំ ដូចជាអាហាររបស់មនុស្សមិនខ្វាក់។

[១០៨] (ទុកូលបណ្ឌិត...) សាមៈកំឡោះនៅក្មេង មិនខ្ពស់ មិនទាបពេក ជាមនុស្សមានរូបល្អគួរគយគន់ មានសក់វែងខ្មៅ ទាំងមានចុងទន់ល្មន់។ សាមៈនោះឯង តែងស្វែងរកផលាផល ជាអ្នកដងទឹក បានកាន់យកក្អមទឹកអំពីទីនេះទៅកាន់ស្ទឹង ប្រហែលជិតមកដល់ហើយ។

[១០៩] (ព្រះបាទបិលយក្ខ...) សាមៈជាអ្នកបំរើអ្នក អ្នកនិយាយសំដៅកុមារឈ្មោះសាមៈណា ដែលមានរូបគួរគយគន់ សាមៈនោះខ្ញុំសម្លាប់ហើយ។ សាមៈដែលមានសក់វែងពណ៌ខ្មៅ ចុងទន់ល្មន់ (ឥឡូវនេះ) ខ្ញុំសម្លាប់ដួលដេកលើសក់ទាំងនោះ ប្រឡាក់ហើយដោយឈាម។

[១១០] (នាងបារិកា) បពិត្រទុកូល អ្នកប្រឹក្សាជាមួយនរណា ដែលបាននិយាយថា ខ្ញុំសម្លាប់សាមៈហើយ បេះដូងខ្ញុំញ័រចំប្រប់ ព្រោះឮថា សាមៈស្លាប់ហើយ។ ហឫទ័យខ្ញុំញាប់ញ័រ ហាក់ដូចត្រួយពោធិបាយខ្ចី ដែលមានខ្យល់ប៉ះទង្គិច ព្រោះឮថា សាមៈស្លាប់ហើយ។

[១១១] (ទុកូលបណ្ឌិត...) ម្នាលនាងបារិកា នេះជាព្រះរាជា ជាធំក្នុងដែនកាសី ព្រះអង្គបាញ់សាមៈដោយព្រួញ ក្បែរស្ទឹងមិគសម្មតៈ ដោយសេចក្តីក្រោធ យើងកុំចងឲ្យមានបាបដល់ព្រះអង្គឡើយ។

[១១២] (នាងបារិកា..) បុត្រដែលចិញ្ចឹមយើងងងឹតងងល់ក្នុងព្រៃ ជាបុត្តជាទីស្រឡាញ់ យើងរកបានដោយកម្រ ចិត្តមិនគប្បីរវៀលក្នុងបុរសអ្នកសម្លាប់កូនប្រុសតែមួយនោះ ដូចម្តេចបាន។

[១១៣] (ទុកូលបណ្ឌិត...) បុត្តដែលចិញ្ចឹមយើងងងឹតងងល់ក្នុងព្រៃ ជាបុត្តជាទីស្រឡាញ់ យើងរកបានដោយកម្រ បណ្ឌិតទាំងឡាយសរសើរសេចក្តីមិនក្រោធ ចំពោះបុរសអ្នកសម្លាប់នូវបុត្តតែមួយនោះ។

[១១៤] (ព្រះបាទបិលយក្ខ...) អ្នកទាំងពីរ កុំគប្បីខ្សឹកខ្សួលខ្លាំងចំពោះខ្ញុំ អ្នកពោលថា សាមៈ ខ្ញុំសម្លាប់ហើយ ខ្ញុំនឹងជាអ្នកធ្វើការងារចិញ្ចឹម (អ្នកទាំងពីរ) ក្នុងព្រៃធំ។ ព្រោះខ្ញុំជាអ្នកឈ្លាសវៃក្នុងសិល្បធ្នូ មានឈ្មោះល្បីល្បាញថា ជាអ្នកទ្រទ្រង់នូវធ្នូដ៏មាំ ខ្ញុំនឹងធ្វើការងារចិញ្ចឹម (អ្នក) ក្នុងព្រៃធំ។ ខ្ញុំនឹងធ្វើការងារស្វែងរកអំពារម្រឹគទាំងឡាយ ទាំងមើមឈើ ផ្លែឈើ ហើយចិញ្ចឹម (អ្នក) ក្នុងព្រៃធំ។

[១១៥] (ជនទាំងពីរ...) បពិត្រមហារាជ នេះមិនមែនជាទំនៀមទេ កិរិយាធ្វើនូវអំពើ (របស់ព្រះអង្គ) នេះ មិនសមគួរដល់យើងឡើយ ព្រះអង្គជាព្រះរាជារបស់យើង ។ សូមថ្វាយបង្គំព្រះបាទរបស់ព្រះអង្គ។

[១១៦] (ព្រះរាជា...) បពិត្រអ្នកនេសាទ អ្នកពោលនូវធម៌ អ្នកធ្វើនូវសេចក្តីគោរព (ចំពោះខ្ញុំ) អ្នកទុកជាបិតារបស់ខ្ញុំ បពិត្រនាងបារិកា នាងទុកជាមាតារបស់ខ្ញុំ។

[១១៧] (ជនទាំងពីរ...) បពិត្រព្រះរាជា ជាធំក្នុងដែនកាសី ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ បពិត្រព្រះអង្គ ទ្រង់ចំរើនក្នុងដែនកាសី ទូលបង្គំសូមថ្វាយបង្គំព្រះអង្គ ទូលបង្គំទាំងឡាយ សូមប្រណម្យអញ្ជលីចំពោះព្រះអង្គ សូមព្រះអង្គនាំទូលបង្គំទៅដល់សាមៈ។ ទូលបង្គំទាំងឡាយ នឹងច្របាច់ជើង ស្ទាបមុខល្អគួរមើលរបស់សាមៈនោះ គ្រៀមរង់ចាំនូវសេចក្តីស្លាប់ប៉ុណ្ណោះ។

[១១៨] (ព្រះបាទបិលយក្ខ...) សាមៈ ដែលស្លាប់ហើយ ដួលដេកដូចជាព្រះចន្ទធ្លាក់មកលើប្រថពីក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រឹង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស។ សាមៈ ដែលស្លាប់ហើយ ដួលដេកដូចជាព្រះអាទិត្យធ្លាក់មកលើប្រថពីក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រឹង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស។ សាមៈដែលស្លាប់ហើយ ដួលដេកប្រឡាក់ប្រឡូសដោយអាចម៍ដីនៅក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រឹង សឹងដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស។ សាមៈ ដែលស្លាប់ហើយ ដួលដេកនៅក្នុងព្រៃណា ព្រៃនោះឯង ជាព្រៃស្រោងស្រឹង សឹង

ដេរដាសដោយម្រឹគសាហាវ ប្រាកដដូចជាទីបំផុតនៃអាកាស (ព្រោះហេតុនោះ) អ្នកទាំងឡាយ ចូរនៅតែក្នុងអាស្រមនេះហើយ។

[១១៩] (ជនទាំងពីរ...) បើទុកណាជាទីនោះ (មានម្រឹគសាហាវ) រយពាន់ ម៉ឺនក្តី ទូលបង្គំទាំងពីរនាក់ ឥតមានសេចក្តីភិតភ័យតិចតួច ព្រោះសត្វសាហាវទាំងឡាយក្នុងព្រៃទេ។

[១២០] (អភិសម្ពុទ្ធគាថា...) គ្រានោះ ព្រះរាជា ជាធំក្នុងដែនកាសី នាំជនខ្វាក់ (ទាំងពីរ) ដឹកដៃទៅក្នុងព្រៃធំ ត្រង់កន្លែងដែលសាមៈស្លាប់។

[១២១] មាតាបិតាឃើញនូវសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ហាក់ដូចព្រះចន្ទដែលធ្លាក់មកលើប្រថពី។ ឃើញនូវសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ដូចព្រះអាទិត្យដែលធ្លាក់មកលើប្រថពី ឃើញនូវសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ដែលគេបោះបង់ចោលក្នុងព្រៃធំ ក៏យំរៀបរាប់គួរឲ្យអាណិត។ ឃើញសាមៈ ជាបុត្តដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ហើយផ្គងដើមដៃ យំទង្គឹះខ្សឹកខ្សួលថា ហៃបាដ៏ចំរើន (ការស្លាប់នេះ) មានសភាពមិនគួរទេ។ ឱបាសាមៈ មានរូបល្អ គួឲ្យក្រឡេកមើល បាឯងជាមនុស្សស្រវឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាជាមនុស្សភ្លើតភ្លើនខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឱបាសាមៈ អ្នកមានរូបល្អ គួរឲ្យក្រឡេកមើល បាឯងខឹងខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ អ្នកឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាឯងដេកលក់ស៊ប់ បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ បាឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឱបាសាមៈ មានរូបល្អ គួរឲ្យក្រឡេកមើល បាជាបុគ្គលតូចចិត្តខ្លាំង បានជាក្នុងកាលដែលដល់នូវមរណៈក្នុងថ្ងៃនេះ បាឥតនិយាយរកយើងបន្តិចបន្តួចសោះ។ ឥឡូវនេះ នរណា នឹងរៀបចំជដា ដ៏សៅហ្មងប្រឡាក់ប្រឡូសដោយអាចម៍ដី ព្រោះសាមៈ ជាអ្នកបំរើយើងងងឹតងងល់នេះ ធ្វើមរណកាលហើយ។ នរណា នឹងកាន់អំបោសបោសអាស្រម ដើម្បីយើង ព្រោះសាមៈ ជាអ្នកបំរើយើងងងឹតងងល់នេះ ធ្វើមរណកាលហើយ។ ឥឡូវនេះ នរណានឹងផ្ងូត (យើង) ដោយទឹកត្រជាក់ ទឹកក្តៅ ព្រោះសាមៈ ជាអ្នកបំរើយើងងងឹតងងល់នេះ ធ្វើមរណកាលហើយ។ ឥឡូវនេះ នរណានឹងឲ្យយើងបរិភោគមើមឈើ ផ្លែឈើ ព្រោះសាមៈ ជាអ្នកបំរើ យើងងងឹតងងុលនេះ ធ្វើមរណកាលហើយ។

[១២២] មាតាឃើញសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ត្រូវសេចក្តីសោកព្រោះកូន បៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកពោលនូវពាក្យសត្យដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាអ្នកបំរើមាតា នឹងបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលបិតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ។

[១២៣] បិតាឃើញសាមៈជាបុត្ត ដួលប្រឡាក់ប្រឡូសដោយអាចម៍ដី ត្រូវសេចក្តីសោកព្រោះកូនបៀតបៀនហើយ បានពោលនូវពាក្យសច្ចៈថា ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកប្រព្រឹត្តធម៌ដ៏ប្រសើរ ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកពោលនូវពាក្យសត្យ ដោយពាក្យសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ ក្នុងកាលមុន សាមៈនេះ ជាអ្នកចិញ្ចឹមមាតា នឹងបិតា ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាអ្នកប្រព្រឹត្តកោតក្រែងនូវបុគ្គលជាធំក្នុងត្រកូល ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ សាមៈនេះ ជាបុគ្គលជាទីស្រឡាញ់ដោយវិសេសរបស់ខ្ញុំជាងជីវិត ដោយសច្ចៈណា សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ ដោយការពោលសច្ចៈនុ៎ះ។ បុណ្យណានីមួយ ដែលខ្ញុំផង ដែលមាតារបស់អ្នកផង បានធ្វើហើយ ដោយកុសលទាំងអស់នោះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ។

[១២៤] ទេវតានោះ បាត់អំពីភ្នំគន្ធមាទន៍ បានពោលនូវពាក្យសច្ចៈនេះ ដោយសេចក្តីអនុគ្រោះសាមៈថា ខ្ញុំនៅអាស្រ័យលើភ្នំគន្ធមាទន៍ អស់កាលជាយូរអង្វែងហើយ ឥតមាននរណាដទៃ ដែលជាទីស្រលាញ់ ដោយវិសេសរបស់ខ្ញុំជាងសាមៈទេ ដោយការពោលសច្ចនុ៎ះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ។ នៅភ្នំគន្ធមាទន៍ សព្វព្រៃព្រឹក្សាទាំងឡាយ សុទ្ធសឹងមានក្លិនក្រអូប ដោយការពោលសច្ចៈនេះ សូមឲ្យពិសរបស់សាមៈ សាបរលាបទៅ។ កាលបើជនទាំងនោះ កំពុងចរចារៀបរាប់នូវពាក្យប្រកបដោយសេចក្តីករុណា មានប្រមាណច្រើន សាមៈ ជាមនុស្សកំឡោះ មានរូបល្អគួរឲ្យរមិលមើល ក៏ក្រោកឡើងភ្លាម។

[១២៥] (មហាសត្វ...) ខ្ញុំឈ្មោះសាមៈ សេចក្តីបំរើន ចូរមានដល់លោកទាំងឡាយ ខ្ញុំក្រោកឡើងដោយសួស្តីហើយ សូមលោកទាំងឡាយកុំខ្សឹកខ្សួលខ្លាំងឡើយ សូមលោកទាំងឡាយចរចាចំពោះខ្ញុំដោយពាក្យពីរោះ។

[១២៦] បពិត្រមហារាជ ព្រះរាជដំណើររបស់ព្រះអង្គមកល្អហើយ ទ្រង់យាងមកមិនអាក្រក់ទេ ព្រះអង្គជាធំទ្រង់យាងមកដល់ហើយ វត្ថុណាមានក្នុងទីនេះ សូមទ្រង់មានព្រះបន្ទូល។ បពិត្រមហារាជ ផលាផល មានផ្លែទន្លាប់ មៈប៉ែន ស្រគំ សឹងមានរសផ្អែមដូចទឹកឃ្មុំ ទូលបង្គំជាខ្ញុំប្រមូលមកទុកក្នុងទីជាមួយគ្នា សូមទ្រង់សោយនូវផលាផលដែលមានរសឆ្ងាញ់ៗ។ បពិត្រមហារាជ ទឹកសម្រាប់សោយដ៏ត្រជាក់ ទូលបង្គំជាខ្ញុំបាននាំមកអំពីជ្រោះភ្នំ បើព្រះអង្គមានសេចក្តីត្រូវការ សូមទ្រង់ដងអំពីទីនោះសោយចុះ។

[១២៧] (ព្រះបាទបិលយក្ខ...) ខ្ញុំវង្វេង ភ័ន្តភាំងស្មារតី ងងឹតងងល់សព្វទិសានុទិស ព្រោះបានឃើញសាមៈនោះធ្វើមរណកាលហើយ ម្នាលសាមៈ អ្នកដូចម្តេច ក៏រស់ឡើងវិញ។

[១២៨] (មហាសត្វ...) បពិត្រមហារាជ (សត្វលោក) តែងសំគាល់នូវបុរសដែលមានវេទនាធ្ងន់ តែនៅរស់ ឬមានសេចក្តីត្រិះរិះក្នុងចិត្តធ្លាក់ចុះក្នុងភវង្គ ដែលនៅរស់ថា ស្លាប់។ បពិត្រមហារាជ ម្យ៉ាងទៀត (សត្វលោក) តែងសំគាល់នូវបុរសដែលមានវេទនាធ្ងន់ តែនៅរស់ ឬចូលនិរោធនៅរស់នោះ ថាស្លាប់ហើយ។

[១២៩] សត្វណា តែងចិញ្ចឹមនូវមាតា និងបិតាដោយធម៌ ទេវតាទាំងឡាយ តែងរក្សានូវសត្វ អ្នកចិញ្ចឹមមាតាបិតានោះ។ សត្វណា តែងចិញ្ចឹមមាតា និងបិតាដោយធម៌ បណ្ឌិតទាំងឡាយក្នុងលោកនេះឯង តែងសរសើរនូវសត្វនោះ សត្វនោះ លុះលះបង់លោកនេះទៅ រមែងរីករាយក្នុងស្ថានសួគ៌។

[១៣០] (ព្រះបាទបិលយក្ខ...) ខ្ញុំវិងវិតតែវង្វេង ភ័ន្តភាំងស្មារតី ងងឹតងងល់សព្វទិសានុទិស ម្នាលសាមៈ ខ្ញុំសូមយកអ្នកជាទីពឹង អ្នកចូរជាទីពឹងរបស់ខ្ញុំ។

[១៣១] (មហាសត្វ...) បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមាតា និងបិតា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះបុត្ត និងភរិយា បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះមិត្ត និងអាមាត្យទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសត្វពាហនៈ និងពល បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ចំពោះស្រុក និងនិគមទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះអ្នកដែន និងអ្នកជនបទទាំងឡាយ បពិត្រព្រះរាជា លុះព្រះអង្គបានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះសមណៈ និងព្រាហ្មណ៍ទាំងឡាយ បពិត្រព្រះរាជា លុះទ្រង់បានប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជជាក្សត្រ សូមព្រះអង្គប្រព្រឹត្តធម៌ចំពោះម្រឹគ និងបក្សី បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ ធម៌ដែលប្រព្រឹត្តល្អហើយ តែងនាំមកនូវសុខ បពិត្រព្រះរាជា លុះទ្រង់ប្រព្រឹត្តធម៌ក្នុងលោកនេះហើយ នឹងទៅកាន់ឋានសួគ៌។ បពិត្រមហារាជ សូមព្រះអង្គប្រព្រឹត្តធម៌ (ព្រោះ) ទេវតា ឥន្ទ ព្រហ្ម ដែលបានដល់នូវឋានសួគ៌ ក៏ព្រោះធម៌ដែលខ្លួនប្រព្រឹត្តល្អហើយ បពិត្រព្រះរាជា ព្រះអង្គកុំប្រហែសធ្វេសនឹងធម៌ឡើយ។

ចប់ សុវណ្ណសាមជាតក ទី៣។

## នេមិរាជជាតក ទី៤

CS sut.kn.jat.541 | ភាគទី ៦២

### (៥៤១. និមិជាតកំ (៤))

[១៣២] (អភិសម្ពុទ្ធគាថា) ក្នុងកាលដែលព្រះបាទនេមិជាបណ្ឌិត អ្នកត្រូវការដោយកុសល ជាព្រះរាជាអ្នកទូន្មាននូវសត្រូវ ទ្រង់តែងឲ្យទានដល់ជនអ្នកនៅក្នុងដែនវិទេហៈទាំងឡាយគ្រប់គ្នា គ្រានោះ (មនុស្ស និងទេវតាទាំងឡាយ តែងសរសើរថា) ឱអស្ចារ្យណាស់ អ្នកប្រាជ្ញទាំងឡាយ មានប្រាជ្ញាជាគ្រឿងពិចារណា កើតឡើងក្នុងលោកហើយ។ កាលព្រះរាជាអង្គនោះ ទ្រង់ឲ្យទាននោះ សេចក្តីត្រិះរិះកើតឡើងថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណាហ្ន៎ មានផលច្រើនជាង។

[១៣៣] ទេវរាជឈ្មោះមឃវៈ ជាទេវកុញ្ជរ ជាសហស្សនេត្រ បានជ្រាបព្រះតម្រិះរបស់ព្រះរាជានោះហើយ មកប្រាកដ (ក្នុងទីចំពោះព្រះភក្ត្រព្រះរាជា) កំចាត់បង់នូវងងឹតដោយវណ្ណៈ។ ព្រះបាទនេមិរាជជាធំជាងមនុស្ស ទ្រង់ព្រឺព្រះលោមា បានសួរទេវរាជឈ្មោះវាសវៈថា អ្នកជាទេវតា ឬជាគន្ធព្វ ឬក៏ជាសក្កៈបុរិន្ទទៈ។ រស្មីប្រាកដដូច្នោះ ខ្ញុំពុំដែលឃើញ ទាំងមិនធ្លាប់ឮឡើយ បពិត្រអ្នកដ៏ចំរើន អ្នកចូរប្រាប់ខ្ញុំ ធ្វើម្តេចយើងស្គាល់អ្នកបាន។ ទេវរាជឈ្មោះវាសវៈជ្រាបថា ព្រះបាទនេមិ ព្រឺព្រះលោមាហើយ ទើបឆ្លើយថា ខ្ញុំជាព្រះឥន្ទ្រ ជាធំជាងទេវតា មកកាន់សំណាក់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងមនុស្ស ទ្រង់កុំព្រឺព្រះលោមាឡើយ ព្រះអង្គមានសេចក្តីប្រាថ្នា ដើម្បីសួរនូវប្រស្នាណា សូមទ្រង់សួរចុះ។ ចំណែកព្រះបាទនេមិរាជអង្គនោះ លុះព្រះឥន្ទ្រាធិរាជធ្វើឱកាសហើយ ក៏ទ្រង់ត្រាស់សួរនូវទេវរាជឈ្មោះវាសវៈថា បពិត្រទេវរាជជាឥស្សរៈជាងសព្វសត្វទាំងឡាយ ខ្ញុំសូមសួរព្រះអង្គថា ទានក្តី ព្រហ្មចរិយៈក្តី កុសលណាមានផលច្រើនជាង។ ព្រះវាសវៈនោះ ដែលព្រះបាទនេមិ ជានរទេពសួរហើយ ក៏ឆ្លើយតបព្រះបាទនេមិវិញ ព្រះវាសវៈនោះ ប្រាប់នូវផលនៃព្រហ្មចរិយៈ បានទូលព្រះបាទនេមិ ដែលមិនជ្រាបថា បុគ្គលកើតក្នុងត្រកូលក្សត្រដោយព្រហ្មចរិយៈថោកទាប[55] ដល់នូវភាពជាទេវតាដោយព្រហ្មចរិយៈជាកណ្តាល[56] បរិសុទ្ធស្អាតដោយព្រហ្មចរិយៈខ្ពង់ខ្ពស់[57] ។ ពួកអ្នកបួស ប្រព្រឹត្តតបៈទាំងឡាយ ទៅកើតក្នុងពួកព្រហ្មណា ពួកព្រហ្មទាំងនុ៎ះ បុគ្គលអ្នកប្រកបក្នុងការសូមណាមួយ មិនងាយបានសោះទេ។

[១៣៤] ព្រះបាទទុទីបៈ ១ ព្រះបាទសាគរៈ ១ ព្រះបាទសេលៈ ១ ព្រះបាទមុចលិន្ទ ១ ព្រះបាទភគីរសៈ ១ ព្រះបាទឧសិន្នរៈ ១ ព្រះបាទអត្ថកៈ ១ ព្រះបាទអស្សកៈ ១ ព្រះបាទបុថុទ្ជនៈ ១។ ព្រះរាជាទាំងឡាយអង្គនេះក្តី ព្រះរាជាទាំងឡាយដទៃក្តី ពួកក្សត្រ ពួកព្រាហ្មណ៍ជាច្រើនក្តី ដែលបូជានូវគ្រឿងយ័ញ្ញយ៉ាងច្រើន មិនប្រព្រឹត្តកន្លងនូវបេតភាព (កាមាវចរភូមិ) ឡើយ។

[១៣៥] ជនទាំងឡាយណា មិនមានគូ ជាបុគ្គលម្នាក់ឯង រមែងមិនត្រេកអរ (ត្រេកអរតែក្នុងការនៅច្រឡូកច្រឡំដោយពួក) ជនទាំងឡាយណា មិនមានបីតិ ដែលកើតអំពីវិវេកទេ ជនទាំងឡាយនោះ ទុកជាមានភោគៈស្មើដោយព្រះឥន្ទ្រ ក៏ដោយចុះ ជនទាំងឡាយនោះ ក៏ឈ្មោះថាជាបុគ្គលកំសត់ មានសេចក្តីសុខព្រោះកិរិយាអាស្រ័យនូវបុគ្គលដទៃដោយពិត។

[១៣៦] ឥសី ៧ អង្គនេះ គឺឥសីឈ្មោះយាមហនុ ១ សោមយាគៈ ១ មនោជវៈ ១ សមុទ្ទៈ ១ មាឃៈ ១ ភរតៈ ១ ឥសីឈ្មោះកាលបុរក្ខិតៈ ១ និងឥសីទាំងឡាយ ៤ អង្គ គឺឥសីឈ្មោះអង្គិរសៈ ១ កស្សបៈ ១ កីសវច្ឆៈ ១ អកន្តិ ១ ជាអនាគារបុគ្គល មានតបៈធម៌ បានកន្លង (កាមាវចរភូមិ) ដោយពិត។

[១៣៧] នៅប្រទេសហិមវន្តខាងជើង មានស្ទឹងឈ្មោះសីទា មានជម្រៅដ៏ជ្រៅ អ្នកផងឆ្លងបានដោយកម្រ (ទាំងពីរខាងឆ្នេរស្ទឹងនោះ) មានភ្នំមាស ពណ៌ដូចភ្លើងខៀវ រុងរឿងសព្វ ៗ កាល។ (ទៀបឆ្នេរនៃស្ទឹងនោះ) សឹងមានដើមក្រឹស្នាលូតលាស់ទង្គំទង្គោល មានទាំងរុក្ខជាតិផ្សេងៗ មានគុម្ពលូតលាស់ (អំពីជើងបពិត) ក្នុងកាលមុន មានពួកឥសីចាស់ៗ មួយម៉ឺនអង្គ នៅក្នុងទីនោះឯង។ ខ្ញុំជាបុគ្គលប្រសើរ ដោយការឲ្យ និងការប្រព្រឹត្តិវត្ត ដោយការសង្រួម និងការទូន្មាន (នូវឥន្ទ្រិយ) ហើយប្រព្រឹត្ត (ម្នាក់ឯង) លះបង់ (ពួក) ជាអ្នកមានចិត្តតាំងមាំ។ ខ្ញុំមិនរិះគន់នូវជនអ្នកមានជាតិទាប និងមានជាតិខ្ពស់ នមស្ការចំពោះជនអ្នកមានចិត្តត្រង់ មិនមានកំណត់កាលវេលាឡើយ ព្រោះថា សត្វទាំងឡាយមានកម្មជាផៅពង្ស។ វណ្ណ[58] ទាំងអស់ អ្នកមិនតាំងនៅក្នុងធម៌ រមែងធ្លាក់ចុះក្នុងនរក ជាខាងក្រោម វណ្ណៈទាំងអស់ បានប្រព្រឹត្តធម៌ដ៏ឧត្តមហើយ រមែងបរិសុទ្ធ។

[១៣៨] មឃវទេវរាជ សុជម្បតិ ទ្រង់ពោលពាក្យនេះ ទ្រង់ប្រៀនប្រដៅព្រះបាទនេមិជាធំក្នុងដែនវិទេហៈ រួចហើយទ្រង់ចៀសចេញទៅកាន់ពួកទេវតាក្នុងឋានសួគ៌។

[១៣៩] (ព្រះឥន្ទ្រ...) ម្នាលអ្នកទាំងឡាយដ៏ចំរើន អ្នកទាំងឡាយទាំងប៉ុន្មានដែលបានមកប្រជុំគ្នាហើយក្នុងទីនេះ ចូរចាំស្តាប់នូវគុណខ្ពស់ និងទាប[59] មានប្រមាណច្រើននេះ របស់មនុស្សទាំងឡាយអ្នកប្រកបដោយធម៌។ ដូចជាព្រះបាទនេមិអង្គនេះ ជាបណ្ឌិត ជាអ្នកត្រូវការដោយកុសល ជាព្រះរាជាទូន្មាននូវសត្រូវ បានឲ្យទានដល់អ្នកដែនវិទេហៈទាំងឡាយគ្រប់ៗ គ្នា។ កាលដែលព្រះរាជាអង្គនោះ

កំពុងឲ្យនូវទាននោះ សេចក្ដីត្រិះរិះកើតឡើងថា ទានក្ដី ព្រហ្មចរិយៈក្ដី កុសលណា មានផលច្រើនជាង។

[១៤០] (មហាជន...) ឱហ្ន៎ សេចក្ដីព្រឺរោម មិនធ្លាប់កើតមាន ក៏កើតឡើយហើយក្នុងលោក រថទិព្វកើតប្រាកដហើយ ដល់ព្រះបាទវិទេហៈមានយស។

[១៤១] (អភិសម្ពុទ្ធគាថា) មាតលិទេវបុត្រ អ្នកមានឫទ្ធិច្រើន ជាទេវសារថី បានអញ្ជើញព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលាថា បពិត្រព្រះរាជាដ៏ប្រសើរជាម្ចាស់នៃទិស សូមព្រះអង្គយាងមក ទ្រង់ស្ដេចឡើងកាន់រថនេះ ដ្បិតទេវតាទាំងឡាយ នៅឋានតាវត្តិង្ស ព្រមទាំងព្រះឥន្ទ្រ ចង់ឃើញព្រះអង្គ ព្រោះទេវតាទាំងឡាយនោះ តែងរលឹក (ព្រះអង្គ) កំពុងនៅប្រជុំក្នុងធម្មសភាឈ្មោះសុធម្មា។

[១៤២] លំដាប់នោះ ព្រះបាទវិទេហៈ អ្នកគ្រប់គ្រងក្រុងមិថិលា ទ្រង់ម្នីម្នាក្រោកចាកអាសនៈ បែរព្រះភក្ត្រឡើងកាន់រថ។ មាតលិទេវបុត្រ ទូលសួរព្រះបាទនេមិរាជនុ៎ះ ដែលស្ដេចឡើងកាន់រថទិព្វហើយ ដូច្នេះថា បពិត្រព្រះរាជាដ៏ប្រសើរជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គទៅតាមផ្លូវណា តាមផ្លូវដែលសត្វមានបាបកម្ម ឬតាមផ្លូវដែលសត្វមានបុញ្ញកម្ម។

[១៤៣] (ព្រះបាទនេមិ...) ម្នាលមាតលិទេវសារថី អ្នកចូរនាំខ្ញុំទៅតាមផ្លូវទាំងពីរ គឺផ្លូវដែលសត្វមានបាបកម្មផង ផ្លូវដែលសត្វមានបុញ្ញកម្មផង។

[១៤៤] (មាតលិ...) បពិត្រព្រះរាជាដ៏ប្រសើរ ជាម្ចាស់នៃទិស ទូលបង្គំជាខ្ញុំនាំព្រះអង្គទៅតាមផ្លូវណាមុន តាមផ្លូវដែលសត្វមានបាបកម្មមុនឬ ឬតាមផ្លូវដែលសត្វមានបុញ្ញកម្មមុន។

[១៤៥] (ព្រះបាទនេមិ...) ខ្ញុំចង់ឃើញនរកជាទីនៅនៃសត្វអ្នកមានបាបកម្មទាំងឡាយ ខ្ញុំចង់ឃើញឋាននៃសត្វអ្នកមានកម្មលាមក និងគតិនៃសត្វទ្រុស្តសីលទាំងឡាយមុន។

[១៤៦] (អភិសម្ពុទ្ធគាថា) មាតលិទេវសារថី បង្ហាញព្រះរាជានូវស្ទឹងឈ្មោះវេតរណី ដែលសត្វឆ្លងបានដោយកម្រ ប្រកបព្រមដោយទឹកផ្សាប្រៃកំពុងពុះ ក្ដៅដូចអណ្ដាតភ្លើង។

[១៤៧] ព្រះបាទនេមិ ទ្រង់ឃើញសត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី ជាទីឆ្លងឡើងបានដោយកម្រក្រៃលែង ហើយត្រាស់សួរមាតលិទេវសារថីថា ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ (សត្វកំពុងធ្លាក់ទៅក្នុងស្ទឹងវេតរណី) ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយនេះធ្លាក់ទៅកាន់ស្ទឹងវេតរណី តើពួកសត្វនេះ បានធ្វើបាបកម្មអ្វី។

[១៤៨] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ពួកសត្វណាមានកំឡាំង មានធម៌ដ៏លាមក បៀតបៀនប្រទេចផ្ដាសានូវពួកសត្វដែលមានកំឡាំងខ្សោយក្នុងជីវលោក ពួកសត្វមានកម្មលាមកនោះ រមែងរងបាប ពួកសត្វទាំងនោះឯង តែងធ្លាក់ទៅកាន់ស្ទឹងវេតរណី។

[១៤៩] (ព្រះបាទនេមិ...) ពួកឆ្កែព្រៃសម្បុរក្រហម និងពពាល ពួកត្មាត ពួកក្អែក ជាសត្វគួរខ្លាច តែងទំពាស៊ី (សត្វនរកដែលវាប្រទះឃើញ) ម្នាលទេវបុត្រអ្នកបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ហ្វូងក្អែកតែងជញ្ជែងស៊ីនូវសត្វទាំងឡាយនេះ តើសត្វទាំងឡាយនេះ បានធ្វើបាបដូចម្ដេច។

[១៥០] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃកម្មដែលខ្លួនដឹង ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា សត្វទាំងឡាយណានីមួយ មានសេចក្ដីកំណាញ់ កំណាញ់ស្វិតស្វាញ មានធម៌លាមកពេក ជាអ្នកជេរប្រទេច បៀតបៀនប្រទូស្ដសមណព្រាហ្មណ៍ សត្វអ្នកមានអំពើលាមកទាំងនោះ រមែងរងបាប ទើបហ្វូងក្អែកជញ្ជែងស៊ីសត្វទាំងឡាយនោះ។

[១៥១] (ព្រះរាជា...) សត្វនរកទាំងឡាយ មានសរីរៈឆេះសន្ធោសន្ធៅ ដើរលើផែនដីដែក ថែមទាំងនាយនិរយបាលសំពងដោយដំបងដែកទាំងឡាយ ដែលភ្លើងឆេះ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាលវាយដោយដំបង ដួលដេកនេះ តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្ដេច។

[១៥២] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលបាបកម្មដែលខ្លួនដឹង ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយ មានបាបធម៌ពេញបន្ទុក បៀតបៀនប្រទេចផ្ដាសានូវបុរសស្ត្រីដែលឥតបាបធម៌ក្នុងជីវលោក ឈ្មោះថាជាអ្នកមានបាបធម៌ពេញបន្ទុក ជនអ្នកមានកម្មលាមកទាំងនោះ រមែងរងបាប ជនទាំងឡាយនោះឯងហើយ ដែលនាយនិរយបាលបៀតបៀនដោយដំបងដួលដេកនៅ។

[១៥៣] (ព្រះរាជា...) ពួកសត្វនរកដទៃមានខ្លួនឆេះជុំវិញ កំពុងទូញយំ (ធ្លាក់ទៅ) កាន់រណ្ដៅរងើកភ្លើងហើយថ្ងូរ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក សត្វទាំងឡាយដែលធ្លាក់ទៅកាន់រណ្ដៅរងើកភ្លើង ហើយថ្ងូរ តើពួកសត្វទាំងឡាយនេះ បានធ្វើបាបដូចម្ដេច។

[១៥៤] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ពោលអាងសាក្សី (កោង) ក្នុងហេតុនៃទ្រព្យរបស់ប្រជុំជន ហើយញុំាងទ្រព្យជាបំណុលនោះឲ្យវិនាស បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះ ញុំាងពួកជនឲ្យវិនាសហើយ ជនទាំងឡាយអ្នកមានកម្មដ៏លាមកនោះ រមែងរងបាប ទើបជនទាំងឡាយនោះឯង (ធ្លាក់ទៅ) កាន់រណ្ដៅរងើកភ្លើង ហើយថ្ងូរដូច្នេះ។

[១៥៥] (ព្រះរាជា) ខ្ទះទង់ដែងធំ មានភ្លើងឆេះសន្ធោសន្ធៅ រន្ទាលច្រាលឆ្អៅ ប្រាកដជាក់ស្ដែង ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ (មានក្បាលសំយុងចុះ) ធ្លាក់ទៅកាន់ខ្ទះពេញដោយទឹកទង់ដែង តើពួកសត្វទាំងនេះធ្វើបាបដូចម្ដេច។

[១៥៦] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា មានធម៌ដ៏លាមកពេក បៀតបៀនប្រទេចផ្ដាសានូវសមណៈឬព្រាហ្មណ៍ អ្នកមានសីល ជនអ្នកមានកម្មដ៏លាមកទាំងឡាយនោះ តែងរងនូវបាប ជនទាំងនោះ (មានក្បាលសំយុងចុះ) ធ្លាក់ទៅកាន់ខ្ទះ ពេញដោយទឹកទង់ដែង។

[១៥៧] (ព្រះរាជា...) ពួកនាយនិរយបាល ត្របែងកនៃសត្វនរក ហើយកាប់ពន្លះ បោះទៅក្នុងទឹកក្ដៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ចុះពួកសត្វដែលមានក្បាលដាច់ ហើយដេកនៅនេះ តើសត្វពួកនេះ បានធ្វើបាបដូចម្ដេច។

[១៥៨] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោក មានបាបធម៌ពេញបន្ទុក តែងចាប់បៀតបៀននូវសត្វស្លាបទាំងឡាយ បពិត្រព្រះអង្គជាធំជាងជន ជនទាំងឡាយនោះ បៀតបៀនហើយនូវសត្វស្លាប ពួកជនអ្នកមានកម្មលាមកនោះ រមែងរងនូវបាប ជនទាំងឡាយនោះ មានក្បាលដាច់ហើយ ដេកនៅដូច្នេះ។

[១៥៩] (ព្រះរាជា...) ស្ទឹងនេះ មានទឹកច្រើន មានច្រាំងមិនជ្រៅ មានកំពង់ល្អ រាបទាបហូរទៅ សត្វដែលមានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយតែងផឹក ស្រាប់តែទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាម ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ចុះទឹកដែលសត្វទាំងឡាយនោះផឹកហើយ ក្លាយទៅជាអង្កាមវិញ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច។

[១៦០] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា។ ជនទាំងឡាយណា អ្នកមានកិច្ចការមិនបរិសុទ្ធ លាយនូវស្រូវសុទ្ធដោយអង្កាម ឲ្យដល់អ្នកទិញ បានជាទឹកដែលជនទាំងឡាយនោះកំពុងមានសេចក្តីក្តៅបៀតបៀន មានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ផឹកទៅក្លាយជាអង្កាមវិញ។

[១៦១] (ព្រះរាជា...) នាយនិរយបាលទាំងឡាយ ចាក់នូវសរីរៈទាំងពីរខាងនៃសត្វនរក ដែលកំពុងកន្ទក់កន្ទេញ ដោយព្រួញទាំងឡាយក៏មាន ដោយលំពែងទាំងឡាយក៏មាន ដោយលំពែងស្នែងក្របីទាំងឡាយក៏មាន ម្នាលទេពបម្រើ សេចក្តីភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលនាយនិរយបាល បៀតបៀនហើយដោយលំពែង ដេកនៅដូច្នេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច។

[១៦២] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មទាំងឡាយដែលខ្លួនដឹង ហើយទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា។ ជនទាំងឡាយណា ក្នុងជីវលោក ជាអ្នកមានកម្មមិនល្អ លួចយកស្រូវ ទ្រព្យ ប្រាក់ មាស ទាំងសត្វចិញ្ចឹម ពពែ ចៀម និងក្របី ដែលគេមិនឲ្យ ហើយធ្វើនូវការចិញ្ចឹមជីវិត ជនអ្នកមានកម្មដ៏លាមកទាំងនោះ រមែងរងនូវបាប ទើបពួកជនទាំងនោះត្រូវនាយនិរយបាលបៀតបៀនហើយ ដោយលំពែងដេកនៅដូច្នេះ។

[១៦៣] (ព្រះរាជា...) ហេតុអ្វី សត្វនរកទាំងឡាយនេះ មួយពួកត្រូវនាយនិរយបាលចងកអូស ពួកដទៃត្រូវនាយនិរយបាលចិញ្ច្រាំ ពួកដទៃទៀតត្រូវនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ដួលដេកនៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ជនទាំងឡាយដែលនាយនិរយបាលធ្វើឲ្យខ្ទេចខ្ទី ហើយដួលដេកនៅ តើពួកជនទាំងនោះ បានធ្វើនូវបាបដូចម្តេច។

[១៦៤] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា ជាអ្នកសម្លាប់ទ្រោយ សម្លាប់ជ្រូក សម្លាប់ត្រី សម្លាប់សត្វចិញ្ចឹម គឺក្របី ពពែ និងចៀម ហើយដាក់លក់ព្ធដ៏រានផ្សាលក់សាច់ ជនអ្នកមានកម្មអាក្រក់ទាំងនោះ តែងរងបាប បានជាជនទាំងនោះ ត្រូវនាយនិរយបាលធ្វើខ្ទេចខ្ទី ហើយដេកនៅ។

[១៦៥] (ព្រះរាជា...) អន្លង់នេះ ពេញពោរ ដោយមូត្រ និងករីស មានក្លិនអាក្រក់មិនស្អាត ស្អុយផ្សាយទៅ ពួកជនអ្នកមានសេចក្តីស្រេកឃ្លានគ្របសង្កត់ហើយ ស៊ី (នូវមូត្រ និងករីសនេះ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនអ្នកបរិភោគនូវមូត្រ និងករីសនេះ តើពួកជនទាំងនេះ បានធ្វើនូវបាបដូចម្តេច។

[១៦៦] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណានីមួយ ជាអ្នកបង្កសេចក្តីទុក្ខ អ្នកបៀតបៀនមិត្រសំឡាញ់ ផ្ចង់តាំងនៅក្នុងការបៀតបៀននូវជនដទៃសព្វៗកាល ពួកជនទាំងឡាយ មានអំពើលាមកនោះ រមែងរងបាប ជនពាលទាំងឡាយជាអ្នកទ្រុស្តមិត្តនោះ តែងស៊ីអាហារចាស់។

[១៦៧] (ព្រះរាជា...) អន្លង់នេះ ពេញពោរទៅដោយឈាម និងខ្ទុះ មានក្លិនអាក្រក់មិនស្អាត ស្អុយផ្សាយទៅ ពួកសត្វដែលត្រូវកំដៅបៀតបៀនហើយ ផឹក (ឈាម និងខ្ទុះនោះ) ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានឈាម និងខ្ទុះជាអាហារនេះ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច។

[១៦៨] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជាដែលមិនជ្រាបថា ជនទាំងឡាយណាក្នុងជីវលោកនេះ សម្លាប់ព្រះអរហន្ត គឺមាតា ឬបិតា ឈ្មោះថាបារាជិក (ក្នុងភាពជាគ្រហស្ថ) ពួកជនអ្នកមានអំពើលាមកនោះ តែងរងបាប ជនទាំងនោះ មានឈាម និងខ្ទុះជាអាហារ។

[១៦៩] (ព្រះរាជា...) អ្នកចូរមើលនូវសត្វនរក មានអណ្តាតមុតដោយសន្ទូច បីដូចស្បែកដែលគេខ្ទារដោយកង្វេរ ញាប់ញ័រដូចត្រីដែលជនបោះទៅលើគោក ព្រោះហេតុអ្វីហ្ន បានជាសត្វនរកទាំងនេះ យំបង្ហៀរទឹកមាត់ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលស៊ីសន្ទូចដេកនៅ តើពួកសត្វទាំងនេះ បានធ្វើនូវបាបដូចម្តេច។

[១៧០] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា មនុស្សទាំងឡាយណានីមួយ ឋិតនៅក្នុងដំណែងជាអ្នកកាត់ថ្លៃទំនិញ ញុំាងទំនិញដែលមានថ្លៃ ឲ្យសាបសូន្យចាកថ្លៃ (បន្ថោកទំនិញគេ) ប្រកបដោយអំពើកោង ធ្វើអំពើកោង ព្រោះហេតុចង់បានទ្រព្យ បីដូចជាសន្ទូចដែលគេបិទបាំង (ដោយនុយ) ដើម្បីសម្លាប់ត្រី។ ទីពឹងរបស់អ្នកធ្វើនូវអំពើកោង ជាបុគ្គលដែលកម្មរបស់ខ្លួនរួបរឹតហើយ មិនមានទេ ពួកជនអ្នកមានអំពើលាមកនោះ តែងរងបាប បានជាពួកជនទាំងនោះ ជាអ្នកស៊ីសន្ទូចដេកនៅ។

[១៧១] (ព្រះរាជា...) ពួកស្ត្រីទាំងនេះ មានខ្លួនដាច់ខ្ទេចខ្ទី មានជាតិអាក្រក់ មានខ្លួនប្រឡាក់ពាសពេញដោយឈាម និងខ្ទុះ មានខ្លួនដាច់រយេះរយាយ បីដូចគោទាំងឡាយដែលគេពន្លះក្នុងទីសម្លាប់ ផ្គងដើមដៃទាំងឡាយ យំកន្ទក់កន្ទេញ ពួកស្ត្រីទាំងនោះ (មានខ្លួនត្រឹមចង្កេះ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិនសព្វៗកាល ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិជាទេវសារថី ខ្ញុំសួរអ្នក ពួកស្ត្រីដែល (មានខ្លួនត្រឹមចង្កេះ) លិចចុះក្នុងផែនដី មានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិនសព្វ ៗ កាល តើពួកស្ត្រីទាំងនេះ បានធ្វើបាបដូចម្តេច។

[១៧២] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពួកស្ត្រីមានត្រកូលក្នុងជីវលោកនេះ មានអំពើមិនបរិសុទ្ធ បានប្រព្រឹត្តនូវអំពើជារបស់អសប្បុរស ពួកស្ត្រីទាំងនោះ មានសភាពជាអ្នកលេង លះបង់ស្វាមី ហើយត្រាច់ទៅរកបុរសដទៃ ព្រោះហេតុតែកាមគុណ និងល្បែងពាល ពួកស្ត្រីទាំងនោះ ក្នុងជីវលោក លុះញុំាង

បុរសដទៃឲ្យត្រេកត្រអាល ទើបមានភ្លើងឆេះសន្ធោសន្ធៅ មានភ្នំរមៀលកិនដូច្នេះ។

[១៧៣] (ព្រះរាជា...) ព្រោះហេតុអ្វី បានជាសត្វនរកមួយពួកទៀតនេះ ត្រូវនាយនិរយបាលចាប់ជើង ឲ្យមានក្បាលសំយុងចុះ ហើយទម្លាក់ទៅក្នុងរណ្ដៅ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកសត្វទាំងនេះ ដែលមានក្បាលសំយុងចុះ នាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅនរក តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្ដេច។

[១៧៤] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនជ្រាបថា ជនទាំងឡាយណា ក្នុងជីវលោកនេះ អ្នកមានអំពើជារបស់អសប្បុរស ប្រព្រឹត្តកន្លងនូវប្រពន្ធទាំងឡាយនៃជនដទៃ សត្វទាំងឡាយប្រាកដដូច្នោះនោះ ឈ្មោះថាជាអ្នកលួចនូវរបស់ដ៏ថ្លៃថ្លា បានជាសត្វទាំងនោះ (មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅ។ សត្វទាំងឡាយនោះ តែងរងនូវទុក្ខវេទនាក្នុងនរកទាំងឡាយនោះ អស់ប្រជុំនៃឆ្នាំដ៏ច្រើន ព្រោះថា ទីពឹងទាំងឡាយរបស់បុគ្គលអ្នកធ្វើបាប ជាបុគ្គលដែលកម្មរបស់ខ្លួនរួបរឹតហើយ មិនមានទេ ពួកសត្វអ្នកមានអំពើលាមកនោះ រមែងរងនូវបាប ទើបបានជាពួកជនទាំងនោះ (មានក្បាលសំយុងចុះ) ត្រូវនាយនិរយបាលទម្លាក់ទៅក្នុងរណ្ដៅ។

[១៧៥] (ព្រះរាជា...) ពួកសត្វទាំងឡាយនេះ ខ្ពស់ និងទាបផ្សេងៗគ្នា ជាអ្នកត្រដាបត្រដូស មានរូបគួរខ្លាចពន់ពេក ប្រាកដនៅក្នុងនរកទាំងឡាយ ម្នាលទេពបម្រើ ភ័យមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកជនដែលមានសេចក្ដីទុក្ខវេទនាក្លៀវក្លា ខ្លោចផ្សា ក្ដៅក្រហាយក្រៃលែងនេះ តើពួកសត្វទាំងនេះ បានធ្វើបាបដូចម្ដេច។

[១៧៦] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបាបកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណាក្នុងជីវលោកនេះ មានទិដ្ឋិលាមកក្រៃលែង តែងធ្វើអំពើដ៏ស្និទ្ធ ព្រោះមោហៈ ទាំងបបួលអ្នកដទៃ (ឲ្យយល់) ក្នុងទិដ្ឋិទាំងឡាយនោះផង ជនទាំងឡាយនោះ មានទិដ្ឋិបាប រមែងរងបាប ទើបបានជាពួកជនទាំងនោះរងទុក្ខវេទនាដ៏ក្លៀវក្លា ខ្លោចផ្សា ក្ដៅក្រហាយក្រៃលែង។

[១៧៧] បពិត្រព្រះរាជា ទីលំនៅរបស់សត្វអ្នកមានបាបកម្មទាំងឡាយ ឋានរបស់សត្វអ្នកមានអំពើអាក្រក់ទាំងឡាយ និងគតិរបស់សត្វអ្នកទ្រស្ដសីលទាំងឡាយ ព្រះអង្គទ្រង់បានជ្រាបហើយ បពិត្រព្រះរាជាអ្នកស្វែងរកគុណដ៏ធំ សូមទ្រង់ស្ដេចទៅក្នុងសំណាក់ទេវរាជឥឡូវនេះ។

[១៧៨] (ព្រះបាទនេមិ...) វិមាននេះ មានកំពូលប្រាំ ដែលយើងឃើញប្រាកដ មាននាងនារីមានអានុភាពធំ ប្រដាប់ដោយកម្រងផ្កា សំដែងនូវទេវឫទ្ធិមានប្រការផ្សេង ៗ នៅកណ្ដាលដំណេក ក្នុងវិមាននោះ ម្នាលទេពបម្រើ សេចក្ដីរីករាយមានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក នារីដែលបានដល់ឋានសួគ៌ហើយ រីករាយក្នុងវិមាន តើនារីនេះ បានធ្វើកុសលដូចម្ដេច។

[១៧៩] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពិរណីដែលទ្រង់ធ្លាប់ជ្រាបហើយ ជាទាសីកើតហើយក្នុងផ្ទៃនៃទាសី ក្នុងផ្ទះនៃព្រាហ្មណ៍ ក្នុងជីវលោក នាងពិរណីនោះដឹងថា ភិក្ខុជាភ្ញៀវ មានកាលដល់ហើយ (ហើយក៏អង្គាសចង្ហាន់ប្រគេនភិក្ខុនោះ) ហាក់ដូចជាមាតា ដែលត្រេកអរចំពោះបុត្ររបស់ខ្លួន នាងជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនាងរីករាយក្នុងវិមាន។

[១៨០] (ព្រះបាទនេមិ...) វិមានមាសទាំង ៧ ដែលបុញ្ញកម្មតាក់តែងហើយ មានពន្លឺរុងរឿងផ្សព្វផ្សាយទៅ មានទេវបុត្រមានឫទ្ធិច្រើន ប្រដាប់ហើយដោយអាភរណៈគ្រប់បែប មានពួកនាងទេពធីតាចោមរោមហើយ ដើរប្រទក្សិណដោយជុំវិញ ក្នុងវិមានទាំង ៧ នោះ។

ម្នាលទេពបម្រើ ខ្ញុំមានសេចក្ដីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្តនេះ បានធ្វើនូវកុសលដូចម្ដេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៨១] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ទេវបុត្រនេះ ជាគហបតី ឈ្មោះសោណទិន្ន ជាម្ចាស់នៃទាន (ក្នុងដែនកាសី) គាត់បានសាងកុដិសម្រាប់នៅ ៧ ខ្នង ឧទ្ទិសចំពោះបព្វជិត។ គាត់បានបម្រើភិក្ខុទាំងឡាយ ដែលអាស្រ័យនៅក្នុងកុដិនោះដោយគោរព បានប្រគេនចីវរសម្រាប់ស្លៀកដណ្ដប់ផង ភត្តាហារផង សេនាសនៈផង គ្រឿងប្រទីបផង ចំពោះលោកអ្នកមានចិត្តត្រង់ទាំងឡាយ ដោយចិត្តជ្រះថ្លា។ គាត់រក្សាឧបោសថប្រកបដោយអង្គប្រាំបី អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី៨ នៃបក្ខផង បាដិហារិយបក្ខផង គាត់ជាអ្នកសង្រួមក្នុងសីលទាំងឡាយសព្វ ៗ កាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគាត់រីករាយក្នុងវិមាន។

[១៨២] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំងជាវិការៈនៃកែវផលិក ពាសពេញដោយពួកនារីដ៏ប្រសើរ រុងរឿងដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយកិរិយារាំ និងច្រៀងទាំងពីរ។ ម្នាលទេពបម្រើ ខ្ញុំមានសេចក្ដីត្រេកអរព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើនារីទាំងនេះ បានធ្វើកុសលកម្មដូចម្ដេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៨៣] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពួកនារីណានីមួយ ក្នុងជីវលោកនេះ មានសីល ជាឧបាសិកា ត្រេកអរក្នុងទាន មានចិត្តជ្រះថ្លាជានិច្ច តាំងនៅក្នុងសច្ចធម៌ មិនប្រហែសធ្វេសក្នុងឧបោសថ ជាអ្នកសង្រួម ជាអ្នកចែកទាន ទើបនារីទាំងនោះរីករាយក្នុងវិមាន។

[១៨៤] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការៈនៃកែវពៃទូរ្យ ប្រកបដោយភូមិភាគ ចែកវាស់ដោយចំណែក។ (ក្នុងវិមាននេះ) មានសូរសំឡេងទិព្យលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំ ច្រៀង និងប្រគំ គួរស្ដាប់ ជាទីរីករាយនៃចិត្ត។ សម្លេងដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ទើបតែបានដឹង។ ម្នាលទេពបម្រើ សេចក្ដីត្រេកអរមានដល់ខ្ញុំព្រោះបានឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើពួកទេវបុត្រទាំងនេះ ធ្វើកុសលកម្មដូចម្ដេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៨៥] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ជនទាំងឡាយណា មានសីល ជាឧបាសក ក្នុងជីវលោកនេះ បានកសាងសួនច្បារ ស្រះ អណ្ដូងទឹក និងស្ពានប្រតិបត្តិព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រជាក់ ដោយគោរព ព្រមទាំងបានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។ ជនទាំងឡាយនោះ បានរក្សាឧបោសថ ប្រកបដោយអង្គប្រាំបី អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វ ៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ និងជាអ្នកចែកទាន ទើបជនទាំងឡាយនោះរីករាយក្នុងវិមាន។

[១៨៦] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតល្អហើយ រុងរឿងដោយជញ្ជាំង ជាវិការៈនៃកែវផលិក ដេរដាសដោយពួកនាង នារីដ៏ប្រសើរ ចំរើនដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយកិរិយារាំ និងច្រៀងទាំងពីរយ៉ាង មានស្ទឹងប្រកបដោយរុក្ខជាតិមានផ្កាផ្សេងៗ ហួរព័ទ្ធជុំវិញ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរ មានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រនេះ បានធ្វើនូវកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៨៧] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្រអង្គនុ៎ះ ជាគហបតី ជាម្ចាស់នៃទាន ក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយអ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះពួកព្រះអរហន្តអ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា។ បានរក្សាឧបោសថប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមនូវឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះរីករាយក្នុងវិមាន។

[១៨៨] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតល្អហើយ ដ៏រុងរឿងដោយជញ្ជាំង ជាវិការៈនៃកែវផលិក ដេរដាសដោយពួកនារីដ៏ប្រសើរ ចំរើនដោយផ្ទះកំពូល ប្រកបដោយទឹក និងភោជន ដោយការច្រៀង និងការរាំទាំងពីរយ៉ាង មានស្ទឹងប្រកបដោយឈើមានផ្កាផ្សេងៗ ហួរព័ទ្ធជុំវិញ មានឈើទាំងឡាយជាច្រើនគឺ ដើមកេស ខ្វិត ស្វាយ សាលព្រឹក្ស ព្រីង ទន្លាប់ មៈប៉ែន សុទ្ធសឹងមានផ្លែជានិច្ច។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ រីករាយក្នុងវិមាន។

[១៨៩] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទានក្នុងក្រុងមិថិលា បានសាងសួនច្បារ ស្រះ អណ្តូងទឹក បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលជាអ្នកមានចិត្តត្រជាក់ បានថ្វាយនូវចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ ដោយចិត្តជ្រះថ្លា។ គហបតីនោះ បានទាំងរក្សាឧបោសថ ប្រកបដោយអង្គ ៨ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន។

[១៩០] (ព្រះរាជា...) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដ៏រុងរឿងដោយជញ្ជាំងជាវិការៈនៃកែវពៃទូរ្យ ប្រកបដោយភូមិភាគ ចែកវាស់ដោយចំណែក (ក្នុងវិមាននោះ) មានស្គរសព្ទជាទិព្យលាន់ឮ គឺស្គរ សម្ភោរ កិរិយារាំ ច្រៀង និងប្រគំ គួរស្តាប់ ជាទីរីករាយនៃចិត្ត។ សម្លេងដែលប្រព្រឹត្តទៅយ៉ាងនេះ ពីរោះយ៉ាងនេះ ពីមុនមក ខ្ញុំមិនដែលឃើញ ទាំងមិនដែលឮឡើយ ទើបតែនឹងបានដឹង។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក តើទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៩១] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្រអង្គនេះ ជាគហបតី ជាម្ចាស់នៃទានក្នុងក្រុងពារាណសី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិចំពោះព្រះអរហន្តទាំងឡាយ ដែលមានចិត្តត្រជាក់ បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។ ទេវបុត្រនោះ បានរក្សាឧបោសថ ប្រកបដោយអង្គ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបទេវបុត្រនោះ រីករាយក្នុងវិមាន។

[១៩២] (ព្រះរាជា...) វិមាននេះ ជាវិការនៃមាសដែលបុញ្ញកម្មនិម្មិតហើយ ដូចព្រះអាទិត្យទើបរះឡើង មានពណ៌ក្រហម មានមណ្ឌលធំ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ទេវបុត្រអង្គនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៩៣] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះ ដែលមិនទ្រង់ជ្រាបថា ទេវបុត្រអង្គនេះ ជាគហបតីជាម្ចាស់នៃទានក្នុងក្រុងសាវត្ថី បានកសាងសួនច្បារ ស្រះ អណ្តូងទឹក និងស្ពាន បានប្រតិបត្តិព្រះអរហន្តទាំងឡាយ ជាអ្នកមានចិត្តត្រជាក់ ដោយគោរព បានថ្វាយចីវរ បិណ្ឌបាត សេនាសនៈ និង (គិលានប្បច្ច័យ) ចំពោះព្រះអរហន្តទាំងឡាយ អ្នកមានចិត្តត្រង់ដោយចិត្តជ្រះថ្លា។ គហបតីនោះ បានរក្សាឧបោសថប្រកបដោយអង្គ ៨ ប្រការ អស់តិថីទី ១៤ ផង តិថីទី ១៥ ផង តិថីទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង សង្រួមក្នុងសីលទាំងឡាយ សព្វៗ កាល ជាអ្នកសង្រួមឥន្ទ្រិយ ជាអ្នកចែកទាន ទើបគហបតីនោះ រីករាយក្នុងវិមាន។

[១៩៤] (ព្រះរាជា...) វិមានទាំងឡាយនេះ ជាវិការនៃមាស មានប្រមាណច្រើន ដែលបុញ្ញកម្មនិម្មិតហើយ តាំងនៅក្នុងអាកាស មានពន្លឺដ៏រុងរឿង ដូចជាផ្លេកបន្ទោរក្នុងចន្លោះនៃមេឃ ក្នុងវិមានទាំងឡាយនោះ មានពួកទេវតាមានឫទ្ធិច្រើន សឹងប្រដាប់ដោយគ្រឿងអាភរណៈគ្រប់បែប មានពួកនាងទេពអប្សរចោមរោមហើយ ប្រទក្សិណវិលវង់ដោយជុំវិញ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានប្រាកដដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក ពួកទេវបុត្រទាំងនេះ បានធ្វើកុសលកម្មដូចម្តេច ទើបដល់ឋានសួគ៌ ហើយរីករាយក្នុងវិមាន។

[១៩៥] មាតលិទេវសារថីដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ពួកទេវបុត្រទាំងនោះ ជាសាវ័ករបស់ព្រះសម្មាសម្ពុទ្ធ តាំងនៅស៊ប់ដោយសទ្ធាក្នុងព្រះសទ្ធម្ម ដែលព្រះមានព្រះភាគទ្រង់ប្រកាសទុកល្អហើយ បានធ្វើតាមនូវពុទ្ធវចនៈរបស់ព្រះសាស្តា បពិត្រព្រះរាជា ឋានទាំងឡាយដែលទ្រង់ក្រឡេកឃើញហើយ គឺជាឋានរបស់ទេវបុត្រទាំងឡាយនោះ។

[១៩៦] បពិត្រមហារាជ ឋានរបស់សត្វអ្នកមានបាបកម្ម ទ្រង់បានជ្រាបហើយ ព្រោះទ្រង់ទតឃើញនូវលំនៅ (របស់សត្វ) ទាំងឋាន

របស់សត្វអ្នកមានកល្យាណកម្ម ក៏ទ្រង់ជ្រាបហើយ បពិត្រព្រះរាជាទ្រង់ស្វែងរកកុសលធម៌ ឥឡូវនេះ សូមទ្រង់យាងទៅក្នុងសំណាក់នៃទេវរាជ។

[១៩៧] (អភិសម្ពុទ្ធគាថា) ព្រះបាទនេមិមហារាជ ទ្រង់បិតនៅលើទិព្វយាន មានសេះជាវាហនៈដែលទឹមដោយសេះសិន្ធព ១ ពាន់ កាលស្តេចកំពុងយាងទៅ ទ្រង់ក្រឡេកឃើញភ្នំទាំងឡាយក្នុងចន្លោះសីទន្តរសមុទ្ទ លុះទ្រង់ទតឃើញហើយ ទ្រង់ត្រាស់ហៅទេវសារថីសួរថា ភ្នំទាំងនោះ តើឈ្មោះអ្វីខ្លះ។

[១៩៨] (មាតលិ...) ភ្នំធំៗទាំងឡាយនេះ ក្នុងសមុទ្ទសីទន្តរ គឺភ្នំសុទស្សនៈ ១ ករវិក ១ ឥសិន្ធរ ១ យុគន្ធរ ១ នេមិន្ធរ ១ វិនតក ១ អស្សកណ្ណ ១ ជាភ្នំមានកំពូលខ្ពស់ឡើងតាមលំដាប់រៀងគ្នា បពិត្រមហារាជ ភ្នំដែលទ្រង់ក្រឡេកឃើញ សឹងជាលំនៅនៃមហារាជទាំងឡាយ។

[១៩៩] (ព្រះរាជា...) (ទ្វារ) មានរូបជាអនេកដ៏រុងរឿងវិចិត្រដោយរតនវត្ថុផ្សេង ៗ ដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា (ព្រៃធំ) ដែលពួកខ្លាធំចាំនៅហើយ។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅថាទ្វារនេះ ឈ្មោះអ្វី ទើបជាទីរីករាយនៃចិត្តប្រាកដអំពីចម្ងាយ។

[២០០] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយ ដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ទ្វារនេះឈ្មោះចិត្តកូដ ជាទីចេញចូលនៃទេវរាជ (ជាទ្វារនៃទេពនគរ ដែលតាំងនៅត្រង់ទីបំផុតនៃភ្នំព្រះសុមេរុ) ជាភ្នំគួរឲ្យចង់មើលប្រាកដ (ទ្វារនេះ) មានរូបជាអនេកដ៏រុងរឿង វិចិត្រដោយរតនៈវត្ថុផ្សេងៗ ប្រាកដជាទ្វារដ៏ដេរដាសដោយរូបទាំងឡាយ ប្រហែលរូបព្រះឥន្ទ្រ បីដូចជា (ព្រៃធំ) ដែលពួកខ្លារក្សាហើយ បពិត្រព្រះរាជា ទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅតាមទ្វារនុ៎ះ សូមទ្រង់ជាន់នូវផែនដីទិព្វដ៏រាបស្មើ។

[២០១] (អភិសម្ពុទ្ធគាថា) ព្រះបាទនេមិមហារាជ ទ្រង់បិតនៅលើទិព្វយាន មានសេះជាវាហនៈដែលទឹមដោយសេះសិន្ធព ១ ពាន់ ទ្រង់យាងទៅ បានទតឃើញនូវទេវសភា (ត្រាស់សួរថា) វិមាននេះ ដែលបុញ្ញកម្មនិម្មិតហើយ ដោយជញ្ជាំងជាវិការនៃកែវពៃទូរ្យ ឃើញច្បាស់ដូចអាកាសមានពន្លឺខៀវក្នុងសរទកាល។

ម្នាលទេពបម្រើ សេចក្តីត្រេកអរមានដល់ខ្ញុំព្រោះឃើញ ម្នាលមាតលិទេវសារថី ខ្ញុំសួរអ្នក គេហៅវិមាននុ៎ះឈ្មោះអ្វី។

[២០២] មាតលិទេវសារថី ដែលព្រះបាទនេមិសួរហើយ ក៏ព្យាករនូវផលនៃបុញ្ញកម្មទាំងឡាយដែលខ្លួនដឹងហើយ ទូលព្រះរាជានោះដែលមិនទ្រង់ជ្រាបថា ទេវសភាដែលព្រះអង្គទតឃើញនុ៎ះឯង គេហៅថា សុធម្មា (ទេវសភានុ៎ះ) រុងរឿងដោយកែវពៃទូរ្យដ៏វិចិត្រដែលបុញ្ញានុភាពនិម្មិតដោយប្រពៃតាំងនៅ សសរមានជ្រុងប្រាំបី ដែលបុញ្ញកម្មតាក់តែងល្អ សុទ្ធសឹងជាវិការនៃកែវពៃទូរ្យទាំងអស់ ពួកទេវតានៅជាន់តាវត្តិង្សគ្រប់អង្គ សឹងមានព្រះឥន្ទ្រជាប្រមុខ តែងប្រជុំគ្នាគិតគូរសេចក្តីចំរើនរបស់ទេវតា និងមនុស្សទាំងឡាយ បពិត្រព្រះរាជាទ្រង់ស្វែងរកគុណធម៌ សូមទ្រង់ចូលទៅកាន់ទីអនុមោទនារបស់ទេវតាទាំងឡាយតាមទ្វារនេះ។

[២០៣] (អភិសម្ពុទ្ធគាថា) ពួកទេពនិករ បានឃើញព្រះរាជានោះស្តេចយាងមកដល់ហើយ ត្រេកអរទទួលថា បពិត្រមហារាជ ដំណើរដែលព្រះអង្គយាងមកនេះប្រពៃហើយ មិនមែនទ្រង់យាងមកអាក្រក់ទេ បពិត្រព្រះរាជា ទ្រង់ស្វែងរកនូវគុណធម៌ដ៏ប្រសើរ ឥឡូវនេះ សូមព្រះអង្គគង់ក្នុងទីជិតនៃទេវរាជចុះ។ សក្កទេវរាជ ទ្រង់ត្រេកអរទទួលព្រះបាទវិទេហៈ គ្រប់គ្រងក្រុងមិថិលានោះ ព្រះបាទវាសវៈអញ្ជើញព្រះអង្គដោយកាមទាំងឡាយផង ដោយអាសនៈផងថា ព្រះអង្គស្តេចមកដល់លំនៅនៃទេវតាទាំងឡាយ ជាដំណើរប្រពៃណាស់ ព្រះរាជាទ្រង់ស្វែងរកនូវគុណដ៏ប្រសើរ សូមព្រះអង្គគង់នៅក្នុងទេវលោកទាំងឡាយ ជាទីញ៉ាំងសេចក្តីប្រាថ្នាទាំងពួងឲ្យសម្រេច សូមព្រះអង្គបរិភោគកាមទាំងឡាយ ដែលមិនមែនជារបស់មនុស្សក្នុងតាវត្តិង្សទេវលោកចុះ។

[២០៤] (ព្រះបាទនេមិ...) វត្ថុណាដែលបានដោយអ្នកដទៃឲ្យជាបច្ច័យ ដូចយានជារបស់សូមគេ ដូចទ្រព្យជារបស់សូមគេ វត្ថុនុ៎ះ ក៏មានឧបមេយ្យយ៉ាងនេះឯង។ ខ្ញុំឥតចង់បានវត្ថុដែលបានមកដោយអ្នកដទៃឲ្យជាបច្ច័យនោះទេ បុណ្យទាំងឡាយ ដែលខ្ញុំបានធ្វើហើយដោយខ្លួនឯង នោះទើបជាទ្រព្យសម្រេចដល់ខ្ញុំ។ ខ្ញុំឯងនឹងត្រឡប់ទៅធ្វើកុសលដែលបុគ្គលធ្វើហើយ រមែងដល់សេចក្តីសុខ មិនក្តៅក្រហាយខាងក្រោយ ឲ្យមានប្រមាណច្រើន ដោយការឲ្យផង ដោយការប្រព្រឹត្តិស្មើផង ដោយការសង្រួមឥន្ទ្រិយផង ដោយការទូន្មាននូវឥន្ទ្រិយផង ក្នុងពួកមនុស្ស។

[២០៥] មាតលិជាទេវសារថីដ៏ចំរើន ជាអ្នកមានឧបការៈច្រើនដល់យើង ព្រោះបានបង្ហាញនូវឋាននៃសត្វអ្នកមានបុញ្ញកម្ម និងឋាននៃសត្វអ្នកមានបាបកម្មទាំងឡាយ។

[២០៦] ព្រះបាទនេមិ ទ្រង់ជាឥស្សរៈក្នុងដែនវិទេហៈ គ្រប់គ្រងក្រុងមិថិលា ទ្រង់បានពោលដូច្នេះហើយ (ទើបទ្រង់លាសក្កទេវរាជត្រឡប់មកមនុស្សវិញ) ទ្រង់បានបូជាយញ្ញៈដ៏ច្រើន ហើយទ្រង់ចូលទៅរកការសង្រួម (បព្វជ្ជា)។

ចប់ នេមិរាជជាតក ទី៤។

## មហោសធជាតក ទី៥

CS sut.kn.jat.542 | ភាគទី ៦២

### (៥៤២. ឧមង្គជាតកំ (៥))

[២០៧] (ព្រះបាទវិទេហៈត្រាស់ថា) ម្នាលមហោសធ ព្រះរាជាចូឡនីព្រហ្មទត្ត ជាម្ចាស់ក្រុងបញ្ចាល យាងមកជាមួយនឹងសេនាទាំងពួង សេនារបស់ព្រះរាជាក្រុងបញ្ចាលនោះ បុគ្គលប្រមាណមិនបាន។ (សេនាទាំងនោះ) មានពលជាងឈើ និងពលថ្មើរជើង អ្នកឈ្លាសក្នុងសង្គ្រាមទាំងពួង អាចនឹងលុកចូលទៅក្នុងពួក ជាសេនាមានសំឡេង (មិនស្ងាត់ចាកសំឡេងទាំង ១០ យ៉ាង) ញ៉ាំងគ្នានឹងគ្នាឲ្យដឹងដោយសំឡេងស្គរ និងស័ង្ខ។ (ពួកសេនាទាំងនោះ) មានវិទ្យាក្នុងផ្លូវលោហធាតុ និងមានគ្រឿងប្រដាប់ មានទង់ជ័យ មានមនុស្សអ្នកឡើងកាន់ពាហនៈខាងឆ្វេង ទាំងបរិបូណ៌ល្អដោយពួកមនុស្សអ្នកមានសិល្ប ដែលពួកយោធាដ៏ក្លៀវក្លា (មានព្យាយាមស្មើដោយសត្វសីហៈ) តាំងទុកដោយល្អហើយ។ ក្នុងចំណោមសេនាទាំងនុ៎ះ មាននាយពល ១០ នាក់ ជាអ្នកឈ្លាស មានប្រាជ្ញាដូចផែនដី ច្រើនទៅប្រជុំប្រឹក្សាក្នុងទីស្ងាត់ នឹងមាតារបស់ព្រះរាជា ជាគំរប់ ១១ រមែងទ្រង់ប្រៀនប្រដៅសេនាក្នុងក្រុងបញ្ចាល។ បណ្តាជនទាំងនុ៎ះ មានក្សត្រិយ៍ ១០១

សុទ្ធតែមានយស ជាចំណុះ ដែលត្រូវព្រះបាទចូឡនីព្រហ្មទត្តដណ្តើមយកដែនហើយ មានសេចក្តីភ័យអំពីមរណៈ ក៏លុះក្នុងអំណាចនៃព្រះបាទបញ្ចាល។ (ស្តេចទាំង ១០១ នោះ) ជាអ្នកធ្វើតាមព្រះរាជតម្រាស់ មិនមានប្រាថ្នា ក៏ពោលពាក្យជាទីស្រឡាញ់ មិនមានប្រាថ្នា ក៏លុះអំណាចចុះចូលព្រះបាទបញ្ចាល។ មិថិលារាជធានីរបស់ពួកអ្នកវិទេហៈ ត្រូវពួកសេនានោះចោមព័ទ្ធជា ៣ ជាន់[60] (ដូចជា) ជីកគាស់ដោយជុំវិញ។ (ក្រុងមិថិលា) ត្រូវសេនាចោមព័ទ្ធជុំវិញ (ប្រាកដដោយសស្ត្រាវុធ) ដូចជាផ្កាយដែលប្រាកដក្នុងខាងលើ ម្នាលមហោសធ អ្នកឯងចូរដឹងថា សេចក្តីរួច (ចាកទុក្ខនេះ) នឹងមានដល់ពួកយើងដោយប្រការដូចម្តេច។

[២០៨] (ព្រះមហាសត្វក្រាបបង្គំទូលថា) បពិត្រព្រះទេវៈ សូមព្រះអង្គទ្រង់សណ្តកព្រះបាទ (ឲ្យស្រួលចុះ) សូមព្រះអង្គទ្រង់ក្រសាលរីករាយក្នុងកាមចុះ ព្រះបាទចូឡនីព្រហ្មទត្ត មុខជានឹងលះបង់សេនាក្នុងក្រុងបញ្ចាល ហើយរត់ទៅ។

[២០៩] (អាចារ្យកេវដ្តព្រាហ្មណ៍...) ព្រះរាជាចូឡនីប្រាថ្នាដើម្បីធ្វើសម្ពន្ធមិត្រ (នឹងព្រះអង្គ) ទាំងទ្រង់ថ្វាយកែវទាំងឡាយ មានស្រីកែវជាដើម ដល់ព្រះអង្គ (ចាប់ដើម) ពីថ្ងៃនេះទៅ សូមឲ្យពួករាជទូតមានវាចាពីរោះ ពោលពាក្យជាទីស្រលាញ់មក (ក្រុងមិថិលានេះបាន)។ សូមឲ្យពួករាជទូតទាំងនោះពោលវាចាដ៏ទន់ភ្លន់ ជាវាចាគួរត្រេកអរ សូមព្រះបាទបញ្ចាល និងព្រះបាទវិទេហៈទាំងពីរអង្គនោះ រួបរួមគ្នាតែមួយ។

[២១០] (ព្រះបាទវិទេហៈ...) នៃកេវដ្តៈ អ្នកបានជួបនឹងមហោសធដែរឬ អ្នកចូរពោលសេចក្តីនោះ អ្នកបានឲ្យមហោសធអត់ទោសហើយឬ មហោសធត្រេកអរហើយឬ។

[២១១] (អាចារ្យកេវដ្តៈ...) បពិត្រព្រះអង្គជាធំជាងជន មហោសធហៅពេញជាបុរសថោកទាប ពុំមានសេចក្តីស្មោះស្មើ ជាមនុស្សរឹងរូសជាអសប្បុរស ពុំបានពោលសេចក្តីអ្វីតិចតួចសោះ ដូចជាមនុស្សគ ឬដូចជាមនុស្សថ្លង់។

[២១២] (ព្រះបាទវិទេហៈ...) ចំណែកការដែលគិតនេះ បុរសផ្តេសផ្តាសឃើញបានក្រណាស់ដោយពិត សេចក្តីបរិសុទ្ធិ នរជនអ្នកមានព្យាយាម មុខជានឹងឃើញហេតុនោះ កាយរបស់អញញាប់ញ័រ អ្នកណានឹងលះបង់នូវដែនរបស់ខ្លួន ហើយលុះក្នុងកណ្តាប់ដៃជនដទៃវិញកើត។

[២១៣] គំនិតរបស់យើងទាំង ៦ នាក់ ដែលជាអ្នកឈ្លាស មានប្រាជ្ញាដ៏ខ្ពង់ខ្ពស់ផុតដូចផែនដី ស្មើគ្នាជាឯកច្ឆន្ទ ម្នាលមហោសធ អ្នកចូរគិតមើល ទៅ ឬកុំទៅ ឬក៏ឈប់។

[២១៤] (ព្រះមហាសត្វ...) បពិត្រព្រះរាជា សូមព្រះអង្គទ្រង់ជ្រាបថា ព្រះបាទចូឡនីព្រហ្មទត្ត ជាអ្នកមានអានុភាពធំ មានពលច្រើន ឥឡូវប្រាថ្នាដើម្បីនឹងសំឡាប់ព្រះអង្គ ដូចនាយព្រានដែលសំឡាប់ម្រឹគដោយផ្ទាក់។

ត្រីជាសត្វជាប់ចិត្តក្នុងនុយស្រស់ (លេប) ផ្លែសន្ទូចដែលគេបិទបាំងដោយសាច់ មិនដឹងសេចក្តីស្លាប់ខ្លួនយ៉ាងណា។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកជាប់ក្នុងកាម ចង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គដូចត្រីនោះឯង។ បើព្រះអង្គស្តេចយាងទៅកាន់ក្រុងបញ្ចាល ព្រះអង្គមុខជានឹងលះចោលព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគដែលដើរទៅតាមផ្លូវ (ទៀបទ្វារនៃស្រុកដែរ)។

[២១៥] (ព្រះបាទវិទេហៈ...) យើងដែលបានពោលនូវប្រយោជន៍ដ៏ឧត្តម ក្នុងសំណាក់នៃអ្នក ត្រឡប់ទៅជាមនុស្សល្ងង់លីលាវិញ អ្នកឯងជាអ្នកចំរើនដោយចុងនង្គ័ល ម្តេចនឹងដឹងសេចក្តីចំរើនដូចអ្នកដទៃកើត។

[២១៦] អ្នកទាំងឡាយ ចូរចាប់អ្នកនេះឲ្យដ៏ក ហើយឲ្យវិនាសចាកដែនរបស់អញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបានស្រីកែវ។

[២១៧] (អភិសម្ពុទ្ធគាថា) លំដាប់នោះ មហោសធពោធិសត្វក៏ចៀសចេញអំពីសំណាក់នៃព្រះបាទវិទេហៈហើយ ទើបហៅសុវបណ្ឌិតឈ្មោះមាធុរៈ ជាទូតមកប្រាប់ថា ម្នាលសំឡាញ់មានស្លាបខៀវ អ្នកចូរមកធ្វើការបំរើអញ ដ្បិតមានសាលិកាញីមួយដែលគេចិញ្ចឹមទុកជិតទីក្រឡាបន្ទំនៃព្រះបាទបញ្ចាល។ ឯងចូរទៅសួរសាលិកានោះ ដោយសន្តរកិច្ច ព្រោះវាជាសត្វឈ្លាសក្នុងកិច្ចទាំងពួង វាដឹងការអាថ៌កំបាំងទាំងពួងរបស់ជនទាំងពីរ គឺព្រះរាជា និងកោសិយព្រាហ្មណ៍។ មាធុរៈសុវបណ្ឌិតមានស្លាបខៀវនោះ បានទទួលស្តាប់ថា បាទ ដូច្នេះហើយក៏ហើរទៅកាន់សំណាក់នៃនាងសាលិកា។ មាធុរៈសុវបណ្ឌិត លុះហើរទៅដល់ហើយ ទើបហៅនាងសាលិកាមានទ្រូងល្អ ពោលពាក្យពីរោះថា នែនាងមានទ្រូងល្អ នាងល្មមអត់ទ្រាំបានដែរឬ នែនាងជាវេសជាតិ នាងមិនមានជំងឺតម្កាត់ទេឬ នែនាងមានទ្រុងល្អ នាងបានលាជលាយដោយទឹកឃ្មុំដែរឬ។

(សាលិកាញី...) ម្នាលសំឡាញ់ សេចក្តីសុខស្រួលមានដល់ខ្ញុំ ម្នាលសំឡាញ់ មួយទៀត ខ្ញុំមិនមានជម្ងឺតម្កាត់ទេ ម្នាលសុវបណ្ឌិត ទាំងលាជលាយដោយទឹកឃ្មុំ ខ្ញុំក៏បានដែរ។ នែសំឡាញ់ អ្នកមកអំពីណាហ្ន៎ ឬអ្នកណាប្រើមក មួយវិញទៀត អ្នកជាសត្វដែលខ្ញុំមិនធ្លាប់ឃើញ មិនធ្លាប់ឮក្នុងកាលមុនអំពីកាលនេះទេ។

[២១៨] (សុវបណ្ឌិត...) ខ្ញុំ គេចិញ្ចឹមទុកនៅទីបន្ទំក្នុងប្រាសាទនៃព្រះបាទសិវិ ព្រះរាជានោះ ទ្រង់បិតនៅក្នុងធម៌ តែងទ្រង់ដោះលែងនូវសត្វទាំងឡាយដែលជាប់ចំណង ចាកចំណងអំពីទីនោះៗ។ មាននាងសាលិកាមួយ ពោលពាក្យពីរោះ ជាភរិយារបស់ខ្ញុំ ម្នាលនាងមានទ្រូងល្អ កាលខ្ញុំកំពុងតែសំឡឹងជាប់ចិត្ត ស្រាប់តែខ្លែងសំឡាប់នាងសាលិកានោះទៅ។ ខ្ញុំបរិបូណ៌ដោយសេចក្តីប្រាថ្នាចំពោះភរិយានោះ បានជាមកក្នុងសំណាក់នៃនាង ប្រសិនបើនាងបើកឱកាស យើងទាំងពីរនាក់ នឹងនៅក្នុងទីជាមួយគ្នា។

[២១៩] (សាលិកា...) ធម្មតាសេកឈ្មោល គួរតែប្រាថ្នារកសេកញី សាលិកាឈ្មោល គួរតែប្រាថ្នារកសាលិកាញី ចុះការនៅរួមដោយសេកឈ្មោល និងសាលិកាញី ដូចម្តេចកើត។

[២២០] (សុវបណ្ឌិត...) បគ្គលណា ប្រាថ្នាស្ត្រីណាក្នុងកាម សូម្បីស្ត្រីនោះជាចណ្ឌាលក៏ដោយ ព្រោះថា ការនៅរួមទាំងអស់ដូចៗគ្នា ដែលមិនដូចគ្នាក្នុងកាម មិនមានទេ។ ព្រះមាតានៃព្រះបាទសិវិ ព្រះនាមជម្ពាវតី (ជាចណ្ឌាលសោះ) តែបានជាអគ្គមហេសី ជាទីស្រឡាញ់របស់ព្រះបាទវាសុទេវកណ្ហាយនគោត្រ។ សូម្បីនាងកិន្នរីឈ្មោះរតនវតី ញាំងតាបសឈ្មោះវច្ឆៈ ឲ្យប្រាថ្នាដែរ។ មនុស្សរួមសំវាសជាមួយនឹងមេម្រឹគក៏មាន ការនៅរួមក្នុងកាមមិនដូចគ្នា មិនមានទេ។ នែនាងសាលិកា ពោលពាក្យពីរោះ បើដូច្នោះ យើងនឹងទៅវិញ ព្រោះពាក្យនាងនុ៎ះ ទុកជាពាក្យប្រកែក នាងមើលងាយខ្ញុំពិត។

[២២១] (សាលិកា...) នែមាធុរៈសុវបណ្ឌិត សិរីរមែងមិនមានដល់អ្នកប្រញាប់ទេ អ្នកចូរឈប់នៅទីនេះ ដរាបបានឃើញព្រះរាជាសិន អ្នកនឹងបានស្តាប់សំឡេងសំភោរ បានឃើញអានុភាពព្រះរាជា។

[២២២] (សុវបណ្ឌិត...) សំឡេងអឺងកងនេះ ឮល្បីប្រាកដទៅជនបទខាងក្រៅថា ព្រះរាជធីតាព្រះបាទបញ្ចាល មានវណ្ណៈដូចជាផ្កាយព្រឹក ព្រះអង្គនឹងប្រទានព្រះរាជធីតានោះ ដល់ព្រះបាទវិទេហៈ ឯវិវាហមង្គលនោះ ក៏នឹងមានដែរ (តើពិតឬទេ)។

[២២៣] (សាលិកា...) នែមាធុរៈ ការរៀបចំវិវាហមង្គលប្រាកដដូចនេះរបស់ពួកសត្រូវ ដូចជាវិវាហមង្គលរបស់ព្រះបាទបញ្ចាល ជាមួយនឹងព្រះបាទវិទេហៈរបស់អ្នក ចូរលើកទុកចុះ។ ព្រះរាជាដ៏ប្រសើរលើរថរបស់អ្នកក្រុងបញ្ចាល នឹងនាំព្រះបាទវិទេហៈមកហើយ នឹងសំឡាប់ព្រះបាទវិទេហៈនោះ ក្នុងវេលានោះ (ព្រះបាទចូឡនី) មិនមែនជាសំឡាញ់របស់ព្រះបាទវិទេហៈនោះទេ។

[២២៤] (សុវបណ្ឌិត...) សូមនាងអនុញ្ញាតឲ្យបងទៅត្រឹម ៧ រាត្រី ទំរាំបងទូលព្រះបាទសិវិ និងព្រះមហេសីថា ខ្ញុំបាននៅរួមក្នុងសំណាក់នាងសាលិកាហើយ។

[២២៥] (សាលិកា...) អើ ! ខ្ញុំអនុញ្ញាតឲ្យអ្នកទៅត្រឹម ៧ រាត្រី បើអ្នកមិនត្រឡប់មកកាន់សំណាក់ខ្ញុំក្នុងរវាង ៧ រាត្រីវិញទេ ខ្ញុំសំគាល់ខ្លួនខ្ញុំថាអស់ជីវិត កាលបើខ្ញុំស្លាប់ហួសទៅហើយ ទើបអ្នកនឹងមកដល់។

[២២៦] (អភិសម្ពុទ្ធគាថា) លំដាប់នោះ មាធុរៈសុវបណ្ឌិតនោះ ក៏ហើរទៅប្រាប់មហោសធថា ពាក្យនេះ ជាពាក្យរបស់នាងសាលិកា។

[២២៧] (មហោសធ...) បុរសគប្បីបរិភោគនូវភោគសម្បត្តិក្នុងផ្ទះរបស់បុគ្គលណា គប្បីធ្វើប្រយោជន៍ដល់បុគ្គលនោះឯង។

[២២៨] បពិត្រព្រះជនិន្ទ ខ្ញុំព្រះអង្គនឹងសូមទៅកាន់បុរី គួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បំរុងព្រះអង្គមានយសធំក្នុងដែនវិទេហៈ។ បពិត្រក្សត្រិយ៍ លុះខ្ញុំព្រះអង្គសាងនិវេសន៍ដើម្បីព្រះអង្គមានយសធំ ក្នុងដែនវិទេហៈស្រេចហើយ នឹងបញ្ជូនទូតមកទូលព្រះអង្គក្នុងវេលាណា ព្រះអង្គគប្បីយាងទៅក្នុងវេលានោះ។

[២២៩] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះមហោសធ ក៏បានទៅកាន់បុរីគួរជាទីរីករាយរបស់ព្រះបាទបញ្ចាលជាមុន ដើម្បីសាងនិវេសន៍បំរុងព្រះបាទវិទេហៈមានយស។ ព្រះមហោសធលុះសាងនិវេសន៍ ដើម្បីព្រះបាទវិទេហៈមានយសស្រេចហើយ ទើបបញ្ជូនទូតមកទូលព្រះបាទវិទេហៈ គ្រប់គ្រងមិថិលាថា បពិត្រមហារាជ និវេសន៍ ខ្ញុំព្រះអង្គសាងដើម្បីព្រះអង្គហើយ សូមព្រះអង្គស្តេចមកក្នុងកាលឥឡូវនេះ។

[២៣០] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះរាជាព្រមដោយសេនាមានអង្គ ៤ យាងទៅដើម្បីទតបុរីដ៏ធំទូលាយ ដែលមហោសធបណ្ឌិតសាងទុកក្នុងដែនកប្បិលៈ មានពាហនៈមិនមានទីបំផុត។

[២៣១] លំដាបនោះឯង ព្រះបាទវិទេហៈនោះ លុះស្តេចយាងទៅដល់ (ដែនកប្បិលៈ) ហើយ ទើបបញ្ជូនរាជសាសន៍ទៅថ្វាយព្រះបាទចូឡនីព្រហ្មទត្តថា បពិត្រមហារាជ ខ្ញុំមកដើម្បីថ្វាយបង្គំព្រះបាទទាំងឡាយរបស់ព្រះអង្គ។ សូមព្រះអង្គទ្រង់ប្រទាននាងនារីដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការ ជាវិការៈនៃមាស មានពួកទាសីជាបរិវារ ឲ្យជាភរិយា (របស់ខ្ញុំ) ក្នុងកាលឥឡូវនេះ។

[២៣២] (ព្រះបាទចូឡនី...) បពិត្រព្រះបាទវិទេហៈ ព្រះអង្គស្តេចមកល្អហើយ មួយទៀត ព្រះអង្គស្តេចមកមិនអាក្រក់ទេ សូមព្រះអង្គសាកសួររកនក្ខត្តឫក្សចុះ ខ្ញុំនឹងថ្វាយនាងកញ្ញា ដ៏ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសី ជាបរិវារព្រះអង្គ។

[២៣៣] (អភិសម្ពុទ្ធគាថា) លំដាប់នោះឯង ព្រះបាទវិទេហៈសួររកនក្ខត្តឫក្សលុះសួររកនក្ខត្តឫក្សរួចហើយ ទើបបញ្ជូនរាជសាសន៍ទៅថ្វាយព្រះបាទព្រហ្មទត្តថា សូមព្រះអង្គទ្រង់ប្រទាននារីដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសីជាបរិវារ ឲ្យជាភរិយារបស់ខ្ញុំក្នុងកាលឥឡូវនេះ។

[២៣៤] (ព្រះបាទចូឡនី...) ខ្ញុំថ្វាយនាងនារី ដែលមានសព៌ាង្គកាយដ៏ល្អ ប្រដាប់ដោយគ្រឿងអលង្ការជាវិការៈនៃមាស មានពួកទាសីជាបរិវារ ឲ្យជាភរិយារបស់ព្រះអង្គ ក្នុងកាលឥឡូវនេះ។

[២៣៥] (ព្រះបាទវិទេហៈ...) ពល់ដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែលឈរនៅ (ត្រៀបត្រា) គប់ភ្លើងឆេះសន្ធោសន្ធៅ តើពួកបណ្ឌិតសំគាល់ដូចម្តេច។

[២៣៦] (អភិសម្ពុទ្ធគាថា) ពល់ដំរី ពលសេះ ពលរថ ពលថ្មើរជើង និងសេនាកាន់ខែលឈរនៅ (ត្រៀបត្រា) គប់ភ្លើងឆេះសន្ធោសន្ធៅ នៃបណ្ឌិត ពួកសេនាទាំងនោះ នឹងធ្វើអ្វីហ្ន៎។

[២៣៧] (មហោសធ...) បពិត្រមហារាជ ព្រះបាទចូឡនីព្រហ្មទត្ត មានពលច្រើន ប្រទូសរ៉ាយដល់ព្រះអង្គ រក្សាព្រះអង្គទុក នឹងសំឡាប់ព្រះអង្គអំពីព្រឹក។

[២៣៨] (ព្រះបាទវិទេហៈ...) ហឫទ័យរបស់យើងញ័ររន្ធត់ ទាំងមាត់របស់យើងក៏សោះស្ងួត យើងមិនបានសេចក្តីរលត់ ដូចជាឈើត្រូវភ្លើងឆេះក្នុងកណ្តាលកំដៅថ្ងៃ។ ចង្ក្រានរបស់ជាងមាស ឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់យើងក៏ឆេះតែខាងក្នុង មិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ។

[២៣៩] (មហោសធ...) បពិត្រក្សត្រ ព្រះអង្គស្រវឹង (ដោយកាម) ទើបប្រព្រឹត្តកន្លងការប្រឹក្សា ទំលាយការប្រឹក្សាចោល ឥឡូវនេះ សូមឲ្យបណ្ឌិត (ទាំង ៤ នាក់) ដែលជាអ្នកមានប្រាជ្ញា រក្សាព្រះអង្គចុះ។ បពិត្រព្រះរាជា ព្រះអង្គមិនធ្វើតាមពាក្យរបស់ទូលបង្គំជាអាមាត្យ ជាអ្នកប្រាថ្នាសេចក្តីចំរើន និងស្វែងរកប្រយោជន៍ ទ្រង់ត្រេកអរដោយបីតិដ៏សៅហ្មងរបស់ព្រះអង្គ ដូចម្រឹគជាប់អន្ទាក់។ (ទូលបង្គំបានក្រាបទូលហើយថា) ត្រីជាសត្វល្មោភក្នុងនុយស្រស់ លេបនូវផ្លែសន្ទូចដ៏វៀចដែលគេបិទដោយសាច់ ត្រីមិនដឹងសេចក្តីស្លាប់របស់ខ្លួនយ៉ាងណា។ បពិត្រព្រះរាជា ព្រះអង្គជាអ្នកល្មោភក្នុងកាម ចង់បានធីតារបស់ព្រះបាទចូឡនី មិនទ្រង់ជ្រាបមរណៈរបស់ព្រះអង្គ ដូចត្រីយ៉ាងនោះឯង។ បើទ្រង់ស្តេចទៅកាន់ក្រុងបញ្ចាល ទ្រង់មុខជានឹងលះចោលព្រះអង្គយ៉ាងឆាប់ ភ័យធំនឹងមកដល់ព្រះអង្គ ដូចភ័យធំមកដល់ម្រឹគ ដែលដើរទៅតាមផ្លូវ (ទៀបទ្វារនៃស្រុក)។ បពិត្រព្រះជនិន្ទ បុរសមានសភាពមិនថ្លៃថ្នូរ ដូចពស់នៅក្នុងថ្នក់ គប្បីចឹកបុរសមានប្រាជ្ញា មិនគប្បីធ្វើនូវមេត្រីភាពដោយបុរស់នោះទេ ព្រោះថា ការគប់រកដោយបុរសអាក្រក់ រមែងនាំមកនូវសេចក្តីទុក្ខដោយពិត។ បពិត្រព្រះជនិន្ទ បណ្ឌិតបុរស ស្គាល់នូវបុគ្គលណាថា អ្នកនេះមានសីល មានការចេះដឹងច្រើនដូច្នេះ បណ្ឌិតបុរសនោះ គួរធ្វើមេត្រីភាពជាមួយនឹងបុគ្គលនោះ ព្រោះថាការសេពគប់ដោយសប្បុរសទាំងឡាយ រមែងនាំមកនូវសេចក្តីសុខពិត។

[២៤០] បពិត្រព្រះរាជា ព្រះអង្គជាមនុស្សល្ងង់លីលា បានពោលនូវសេចក្តីចំរើនដ៏ឧត្តមក្នុងសំណាក់នៃខ្ញុំព្រះអង្គថា ខ្ញុំព្រះអង្គជាអ្នកចំរើនដោយចុងនង្គ័ល ធ្វើម្តេចនឹងដឹងសេចក្តីចំរើនដូចអ្នកដទៃ។ អ្នកទាំងឡាយ ចូរចាប់មហោសធនេះត្រង់់ក ហើយឲ្យវិនាសចាកដែន

របស់អញចេញទៅ ព្រោះវាហ៊ាននិយាយឲ្យអញអន្តរាយនូវការបានស្រីកែវ។

[២៤១] (ព្រះបាទវិទេហៈ...) ម្នាលមហោសធ បណ្ឌិតទាំងឡាយ រមែងមិនចាក់ដោតដោយទោសដែលកន្លងទៅហើយទេ អ្នកចាក់ដោតយើង ដូចគេយកជន្លួញចាក់សេះដែលចងទុកហើយធ្វើអ្វី។ ប្រសិនបើអ្នកឃើញសេចក្ដីរួចរបស់យើង ឬឃើញសេចក្ដីក្សេមរបស់យើង ចូរអ្នកពន្យល់យើងដោយសោត្ថិភាពនោះចុះ អ្នកចាំបាច់ចាក់ដោតយើងដោយទោសដែលកន្លងទៅហើយធ្វើអ្វី។

[២៤២] (មហោសធ...) អំពើជារបស់នៃមនុស្សដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ ខ្ញុំព្រះអង្គមិនអាចនឹងដោះព្រះអង្គបានទេ បពិត្រក្សត្រិយ៍ សូមព្រះអង្គទ្រង់ជ្រាបចុះ។ ដំរីទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន ដំរីបែបនោះរបស់ព្រះរាជាណា សូមឲ្យដំរីទាំងនោះ នាំព្រះរាជានោះទៅចុះ។ សេះទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន សេះបែបនោះរបស់ព្រះរាជាណា សូមឲ្យសេះទាំងនោះ នាំព្រះរាជានោះទៅចុះ។ បក្សីទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន បក្សីបែបនោះរបស់ព្រះរាជាណា សូមឲ្យបក្សីទាំងនោះ នាំព្រះរាជានោះទៅចុះ។ យក្សទាំងឡាយ មានឫទ្ធិ មានយស អាចទៅតាមអាកាសបាន យក្សបែបនោះរបស់ព្រះរាជាណា សូមឲ្យយក្សទាំងនោះ នាំព្រះរាជានោះទៅចុះ។ អំពើជារបស់នៃមនុស្ស ដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ បពិត្រក្សត្រិយ៍ ខ្ញុំព្រះអង្គមិនអាចដោះព្រះអង្គទៅតាមអាកាសបានទេ។

[២៤៣] (អាចារ្យសេនកៈ...) បុរសជាអ្នកមិនឃើញត្រើយក្នុងមហាសមុទ្រ បុរសនោះបានទីពំនាក់ក្នុងប្រទេសណា គេក៏បានសេចក្ដីសុខក្នុងប្រទេសនោះ (យ៉ាងណាមិញ)។ បពិត្រមហោសធ អ្នកជាទីពឹងរបស់ពួកយើង និងព្រះរាជា ក៏យ៉ាងនោះដែរ ព្រោះអ្នកជាបុគ្គលប្រសើរជាងពួកយើង និងពួកមន្ត្រី សូមអ្នកដោះពួកយើងអំពីទុក្ខ។

[២៤៤] (មហោសធ...) អំពើជារបស់នៃមនុស្ស ដែលកន្លងហួសទៅហើយ ជាអំពើគេកែបានដោយក្រ សម្រួលវិញបានដោយក្រ ខ្ញុំមិនអាចនឹងដោះអ្នកបានទេ នៃសេនកៈ អ្នកចូរដឹងចុះ។

[២៤៥] (ព្រះបាទវិទេហៈ...) អ្នកចូរស្ដាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ (ស្រាប់ហើយ) ម្នាលអាចារ្យសេនកៈ ឥឡូវនេះអញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្ដេចក្នុងរឿងនេះ។

[២៤៦] (អាចារ្យសេនកៈ...) ពួកយើងគួរដុតភ្លើងត្រង់ទ្វារ ឬកាន់កាំបិតសម្លាប់គ្នានឹងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើងឲ្យលំបាកអស់កាលយូរឡើយ។

[២៤៧] (ព្រះបាទវិទេហៈ...) អ្នកចូរស្ដាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ (ស្រាប់ហើយ) ម្នាលអាចារ្យបុក្កុសៈ ឥឡូវនេះអញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្ដេចក្នុងរឿងនេះ។

[២៤៨] (អាចារ្យបុក្កុសៈ...) ពួកយើងគួរស៊ីថ្នាំពិសឲ្យស្លាប់ នឹងលះបង់ជីវិតយ៉ាងឆាប់ កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើង ឲ្យលំបាកអស់កាលយូរឡើយ។

[២៤៩] (ព្រះបាទវិទេហៈ...) អ្នកចូរស្ដាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ (ស្រាប់ហើយ) ម្នាលអាចារ្យកាមិន្ទៈ ឥឡូវនេះអញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្ដេចក្នុងរឿងនេះ។

[២៥០] (អាចារ្យកាមិន្ទៈ...) ពួកយើងគប្បីយកខ្សែចងឲ្យស្លាប់ ឬលោតចុះទៅក្នុងអណ្ដូង (ឲ្យស្លាប់) កុំឲ្យព្រះបាទព្រហ្មទត្តសម្លាប់ពួកយើងឲ្យលំបាកអស់កាលយូរឡើយ។

[២៥១] (ព្រះបាទវិទេហៈ...) អ្នកចូរស្ដាប់ពាក្យរបស់យើងនេះ អ្នកឃើញភ័យធំនុ៎ះ (ស្រាប់ហើយ) ម្នាលអាចារ្យទេវិន្ទៈ ឥឡូវនេះអញសួរ តើអ្នកសំគាល់របស់ដែលគួរធ្វើដូចម្ដេច ក្នុងរឿងនេះ។

[២៥២] (អាចារ្យទេវិន្ទៈ...) ពួកយើង (បិទទ្វារ) ដុតភ្លើង ហើយកាន់កាំបិតសម្លាប់គ្នាឯងនឹងគ្នា យើងនឹងលះបង់ជីវិតយ៉ាងឆាប់ (បើ) មហោសធមិនអាចនឹងដោះពួកយើងឲ្យរួចដោយងាយទេ។

[២៥៣] (ព្រះបាទវិទេហៈ...) បុគ្គលស្វែងរកខ្លឹមនៃដើមចេក រមែងមិនបានយ៉ាងណាមិញ យើងស្វែងរក (ឧបាយជាគ្រឿងរួចចាកទុក្ខ) ក៏មិនបានប្រស្នានោះ ក៏យ៉ាងនោះដែរ។ បុគ្គលស្វែងរកខ្លឹមនៃដើមរកា រមែងមិនបាន យ៉ាងណាមិញ យើងស្វែងរក ក៏មិនបានប្រស្នានោះ ក៏យ៉ាងនោះដែរ។ ការនៅនៃដំរីទាំងឡាយ ក្នុងទីមិនមានទឹក ឈ្មោះថានៅក្នុងទីមិនមែនប្រទេស (យ៉ាងណាមិញ) កាលបើយើងនៅក្នុងទីជិតនៃពួកមនុស្សអាក្រក់ល្ងង់ខ្លៅ មិនចេះ មិនដឹង (ឈ្មោះថានៅក្នុងទីមិនមែនជាប្រទេស ក៏ដូច្នោះឯង)។ ហឫទ័យរបស់យើងញ័ររន្ធត់ ទាំងមាត់របស់យើងក៏សោះស្ងួត យើងមិនបានសេចក្ដីរលត់ ដូចឈើត្រូវភ្លើងឆេះក្នុងកណ្ដាលកំដៅថ្ងៃ។ ចង្ក្រានរបស់ជាងមាសឆេះតែខាងក្នុង មិនឆេះខាងក្រៅ យ៉ាងណាមិញ ហឫទ័យរបស់យើង ឆេះតែខាងក្នុង មិនឆេះខាងក្រៅ ក៏យ៉ាងនោះដែរ។

[២៥៤] (អភិសម្ពុទ្ធគាថា...) វេលានោះ មហោសធជាអ្នកប្រាជ្ញ មានប្រាជ្ញា ឃើញប្រយោជន៍ជាប្រក្រតីនោះ បានឃើញព្រះបាទវិទេហៈទ្រង់មានសេចក្ដីទុក្ខ ទើបក្រាបបង្គំទូលថា បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះចន្ទ្រដែលរាហូចាប់ហើយ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះព្រះអាទិត្យដែលរាហូចាប់ហើយ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះដំរីផុងក្នុងភក់។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះពស់ដែលជាប់នៅក្នុងកំព្រោង។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះបក្សីដែលជាប់នៅក្នុងទ្រុង។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គ ដូចគេដោះត្រីទាំងឡាយដែលជាប់នៅក្នុងសំណាញ់។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដោះព្រះអង្គចេញ ព្រមទាំងយានរេហ៍ពល និងពាហនៈ។ បពិត្រមហារាជ ព្រះអង្គកុំភ័យឡើយ បពិត្រព្រះអង្គប្រសើរលើរថ ព្រះអង្គកុំភ័យឡើយ ទូលព្រះបង្គំនឹងដេញព្រះបាទបញ្ចាលឲ្យរត់ទៅ ដូចជាគេដេញក្អែក និងខ្លែងដោយដុំដី។ បុគ្គលណា មិនជួយព្រះអង្គដែលមានសេចក្ដីចង្អៀត (ព្រោះមរណៈ) ឲ្យរួចចាកទុក្ខបានទេ ប្រាជ្ញា (របស់បុគ្គលនោះ) មានប្រយោជន៍អ្វី ឬអាមាត្យបែបនោះ (មានប្រយោជន៍អ្វី)។

[២៥៥] នៃមាណពទាំងឡាយ អ្នកទាំងឡាយចូរមក ចូរក្រោកឡើង អ្នកទាំងឡាយ ចូរបើកមាត់នៃគន្លឹះយន្ត ព្រះបាទវិទេហៈ មួយអន្លើដោយពួកអាមាត្យ នឹងស្ដេចទៅតាមឧម្មង្គ។

[២៥៦] ពួកជនអ្នកធ្វើការបំរើរបស់មហោសធបណ្ឌិត ស្តាប់ពាក្យរបស់លោកហើយ ទើបបើកទ្វារនៃឧម្មង្គ និងគន្លឹះទ្វារដែលប្រកបដោយគ្រឿងយន្ត។

[២៥៧] អាចារ្យសេនកៈដើរមុន មហោសធដើរក្រោយ ព្រះបាទវិទេហៈ មានអាមាត្យហែហម ស្តេចយាងត្រង់កណ្តាល។

[២៥៨] ព្រះបាទវិទេហៈ ស្តេចទ្រង់ចេញអំពីឧម្មង្គ ហើយឡើងគង់លើព្រះទីនាំងនាវា មហោសធដឹងថា ព្រះរាជាឡើងគង់ហើយ ក៏ប្រៀនប្រដៅថា បពិត្រព្រះសម្មតិទេព ព្រះបាទចូឡនីព្រហ្មទត្តនេះ ជាព្រះបិតាក្មេករបស់ព្រះអង្គ បពិត្រព្រះអង្គជាធំជាងជន ព្រះនាងនន្ទាទេវីនេះ ជាព្រះមាតាក្មេករបស់ព្រះអង្គ ការប្រតិបត្តិព្រះវររាជមាតា (របស់ព្រះអង្គ) យ៉ាងណា ការប្រតិបត្តិព្រះមាតាក្មេក ចូរមានដល់ព្រះអង្គ ក៏យ៉ាងនោះដែរ។ ព្រះរាជបុត្តច្បងរួមឧទរ មានព្រះមាតាជាមួយគ្នា យ៉ាងណា បពិត្រព្រះអង្គប្រសើរលើរថ បញ្ចាលចន្ទរាជកុមារ ព្រះអង្គគប្បីស្រឡាញ់យ៉ាងនោះដែរ។ បពិត្រព្រះអង្គប្រសើរលើរថ ព្រះនាងបញ្ចាលចន្ទីទេវីនេះ ជាព្រះរាជបុត្រី (របស់ព្រះបាទចូឡនីព្រហ្មទត្ត) ដែលព្រះអង្គទ្រង់ប្រាថ្នា សូមព្រះអង្គធ្វើសេចក្តីប្រាថ្នារបស់ព្រះអង្គចំពោះព្រះនាងនោះ ព្រះនាងជាភរិយារបស់ព្រះអង្គហើយ។

[២៥៩] (ព្រះបាទវិទេហៈ...) ម្នាលមហោសធ អ្នកចូរប្រញាប់ប្រញាល់ឡើងជិះទូកមក នៅឈរលើច្រាំងធ្វើអ្វី យើងទាំងឡាយរួចចាកទុក្ខដោយលំបាក យើងនឹងទៅឥឡូវនេះ។

[២៦០] (មហោសធ...) បពិត្រមហារាជ ខ្ញុំព្រះអង្គដែលជានាយកនៃសេនា លះបង់ចោលនូវអង្គនៃសេនា ហើយដោះយកតែខ្លួននេះមិនមែនជាទំនៀមទេ។ បពិត្រព្រះសម្មតិទេពប្រសើរលើរថ ខ្ញុំព្រះអង្គនឹងដឹកនាំនូវអង្គនៃសេនាដែលព្រះអង្គបោះបង់ចោលក្នុងរាជនិវេសន៍ និងរបស់ដែលព្រះបាទព្រហ្មទត្តថ្វាយហើយ។

[២៦១] (ព្រះបាទវិទេហៈ...) ម្នាលបណ្ឌិត អ្នកឯងជាអ្នកមានសេនាតិច នឹងសង្កត់សង្កិនទប់ទល់ព្រះបាទចូឡនីព្រហ្មទត្ត ដែលមានសេនាច្រើនដូចម្តេចបាន អ្នកឯងជាអ្នកមានកម្លាំងខ្សោយ មុខជាលំបាកដោយព្រះបាទចូឡនីព្រហ្មទត្តដែលមានកម្លាំង។

[២៦២] (ពោធិសត្វ...) បុគ្គលមានប្រាជ្ញា សូម្បីមានសេនាតិច រមែងឈ្នះបុគ្គលមិនមានប្រាជ្ញា ដែលមានសេនាច្រើន ព្រះរាជាតែមួយព្រះអង្គ (ជាអ្នកឈ្លាសក្នុងឧបាយ) រមែងឈ្នះព្រះរាជាទាំងឡាយ (ជាអ្នកល្ងង់ក្នុងឧបាយ) ដូចព្រះអាទិត្យ ដែលរះឡើង (រមែងឈ្នះ) ងងឹតដូច្នោះឯង។

[២៦៣] (ព្រះបាទវិទេហៈ...) នែអាចារ្យសេនកៈ ការនៅរួមជាមួយនឹងពួកបណ្ឌិត នាំមកនូវសេចក្តីសុខស្រួលណាស់ហ្ន៎ ព្រោះថាមហោសធ បានដោះពួកយើង ដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រី ដែលជាប់នៅក្នុងសំណាញ់ដូច្នោះ។

[២៦៤] (អាចារ្យសេនកៈ...) បពិត្រមហារាជ ពិតមែនហើយ បណ្ឌិតទាំងឡាយ នាំមកនូវសេចក្តីសុខយ៉ាងនោះឯង មហោសធបានដោះពួកយើងដែលនៅក្នុងកណ្តាប់ដៃនៃសត្រូវឲ្យរួចបាន ដូចគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចគេដោះហ្វូងត្រី ដែលជាប់នៅក្នុងសំណាញ់ដូច្នោះ។

[២៦៥] (អភិសម្ពុទ្ធគាថា) ព្រះបាទចូឡនីព្រហ្មទត្ត មានកំឡាំងច្រើន ទ្រង់រក្សាអស់រាត្រីទាំងមូល កាលអរុណរះឡើង ក៏ស្តេចចូលទៅដល់ក្រុងឧបការៈ។ ព្រះបាទចូឡនីគ្រប់គ្រងក្រុងបញ្ចាល មានកំឡាំងច្រើន ស្តេចឡើងគង់លើដំរីប្រសើរដ៏មានកំឡាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ បានត្រាស់ទៅ (នឹងសេនារបស់ព្រះអង្គ)។ ព្រះបាទចូឡនីព្រហ្មទត្ត ទ្រង់សៀតគ្រឿងក្រោះ ជាវិការៈនៃកែវមណី ព្រះហស្តចាប់សរ បានត្រាស់ទៅនឹងរេហ៍ពលអ្នកទទួលបំរើ (របស់ព្រះអង្គ) ជាអ្នកមានសិល្បច្រើនដែលមកចួបជុំគ្នា។ (ព្រះបាទចូឡនីត្រាស់ទៅ) នឹងពលដំរី ពលសេះ ពលរថ ពលថ្មើរជើង និងខ្មាន់ធ្នូ ដែលមានដៃដ៏ស្ទាត់ក្នុងសិល្បធ្នូ អាចបាញ់រោមត្រូវ ដែលមកចួបជុំគ្នា។

[២៦៦] (ព្រះបាទចូឡនី...) អ្នកទាំងឡាយ ចូរបញ្ជូនដំរីមានភ្លុក ដ៏មានកំឡាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ ចូរឲ្យដំរីទាំងឡាយញាំញីទីក្រុងដែលព្រះបាទវិទេហៈ សាងទុកហើយ។ (ពួកព្រួញ) មានសម្បុរ ស មានមុខដូចពន្លាក មានចុងដ៏មុត អាចចាក់ទំលាយនូវឆ្អឹងដែលបាញ់ដោយកំឡាំងធ្នូ ឲ្យធ្លាក់ចុះព្រមគ្នា អំពីខាងនេះខាងនោះ។ ពួកសេនាក្មេង ៗ ក្លៀវក្លា ពាក់គ្រឿងក្រោះ មានអាវុធប្រកបដោយដងដ៏វិចិត្រ កាលបើពួកដំរីធំស្ទុះចូលមក ចូរអ្នកនាំគ្នា (តស៊ូ) ចំពោះមុខដំរីទាំងឡាយ។ លំពែងទាំងឡាយ ដែលគេលាងជម្រះដោយប្រេង មានរស្មីភ្លឺផ្លេក រុងរឿងដូចជាផ្កាយព្រឹក មានរស្មីច្រើន។ កាលបើពួកយោធា (របស់យើង) មានគ្រឿងអាវុធជាកំឡាំង ទ្រទ្រង់សង្វារ គឺគ្រឿងក្រោះប្រាកដដូច្នេះ មិនបានរត់ក្នុងសង្គ្រាមទេ ព្រះបាទវិទេហៈនឹងរួចពីដៃយើងអំពីណា បើក្រែងតែព្រះបាទវិទេហៈនឹងធ្វើដូចបក្សី (ទើបរួច)។ ពួកយោធារបស់យើងទាំងអស់ មានចំនួន ៣៩.០០០ នាក់ អាចកាត់ក្បាលសត្រូវ ហើយរើសយកក្បាលមួយ ៗ មក យើងបានដើរសព្វលើផែនដី មិនឃើញពួកយោធាណាស្មើឡើយ។ ដំរីទាំងឡាយ មានភ្លុក ប្រដាប់ហើយ មានកំឡាំង ជាដំរីមានអាយុប្រមាណ ៦០ ឆ្នាំ ពួកយោធានៅក្មេងៗ មានសម្បុរដូចមាស រមែងល្អលើ កនៃដំរីទាំងឡាយ។ យោធាទាំងឡាយ មានគ្រឿងអលង្ការមានពណ៌លឿង ស្លៀកសំពត់មានពណ៌លឿង ដណ្តប់សំពត់មានពណ៌លឿង រមែងល្អលើ-កនៃដំរីទាំងឡាយ ដូចទេវបុត្តទាំងឡាយក្នុងនន្ទវ័ន។ ព្រះខាន់ទាំងឡាយ មានសម្បុរដូចត្រីស្លាត ដែលលាងជំរះដោយប្រេង មានរស្មីភ្លឺផ្លេកដែលបុរសអ្នកមានព្យាយាមធ្វើសម្រេចហើយ មានមុខស្មើ ដែលគេសម្លៀងល្អហើយ។ ព្រះខាន់ទាំងឡាយមិនមានស្នឹម រុងរឿងដូចជាព្រះអាទិត្យ ឋិតនៅក្នុងទីពាក់កណ្តាលដែលគេធ្វើដោយដែកថែបដ៏មាំ ដែលពួកយោធាអ្នកមានកំឡាំងជំនាញក្នុងវិធីប្រហារមាំ កាន់យកហើយ។ ព្រះខាន់ទាំងឡាយ បរិបូណ៌ដោយដងជាវិការៈនៃមាស ទ្រទ្រង់ដោយស្រោមមានពណ៌ក្រហម កាលបើគេគ្រវីឡើង រមែងល្អដូចជាផ្លេកបន្ទោរភ្លឺផ្លេកក្នុងចន្លោះនៃពពក។ ពួកខ្មាន់ធ្នូអ្នកក្លៀវក្លា ពាក់គ្រឿងក្រោះ អាចប្រព្រឹត្តទៅក្នុងអាកាសបាន អ្នកឈ្លាសក្នុងការកាន់ដាវ និងខែល ជាអ្នកហាត់ក្នុងការកាន់ធ្នូដ៏ក្រៃលែង អាចកាត់នូវកនៃដំរីឲ្យធ្លាក់ចុះបាន។ អ្នកឯងត្រូវពួកយោធាប្រាកដដូច្នេះ ព័ទ្ធហើយ អ្នកឯងមិនរួចអំពីទីនេះទេ អ្នកនឹងទៅកាន់ក្រុងមិថិលា ដោយរាជានុភាពណា យើងមិនបានឃើញរាជានុភាពនោះរបស់អ្នកទេ។

[២៦៧] (ព្រះពោធិសត្វ...) ព្រះអង្គទ្រង់ប្រញាប់ប្រញាល់បញ្ជូនដំរីដ៏ប្រសើរមក ព្រះអង្គមានព្រះហឫទ័យរីករាយយាងមក ហើយទ្រង់សំគាល់ថា អាត្មាអញ នឹងបានសម្រេចប្រយោជន៍ដូច្នេះឬហ្ន៎។ សូមព្រះអង្គដាក់ធ្នូ និងបំពង់ព្រួញនុ៎ះចេញ សូមព្រះអង្គដាក់កូនសរនុ៎ះចេញ សូមព្រះអង្គដាក់គ្រឿងក្រោះដ៏ល្អប្រហែលដោយកែវពៃទូរ្យ និងកែវមណីនុ៎ះចេញ។

[២៦៨] (ព្រះបាទចូឡនី...) អ្នកឯងជាអ្នកមានសម្បុរមុខស្រស់បស់ ទាំងនិយាយ ក៏ញញឹមញញែមជាប់ ឯការបរិបូណ៌ដោយសម្បុរបែបនេះ រមែងមានប្រាកដក្នុងមរណកាល។

[២៦៩] (មហោសធ...) បពិត្រក្សត្រជាព្រះរាជា ពាក្យដែលព្រះអង្គគម្រាមហើយ ជាពាក្យសោះសូន្យទទេ ព្រះអង្គមានការប្រឹក្សាធ្លាយហើយ ឯព្រះរាជា (របស់យើង) ព្រះអង្គមិនងាយនឹងចាប់យកបានទេ ដូចសេះសិន្ធព នឹងសេះខ្វក។ ព្រះរាជា (ក្រុងមិថិលា)

ព្រមដោយអាមាត្យ និងរាជបរិស័ទ ឆ្លងស្ទឹងគង្គាតាំងពីថ្ងៃម្សិលទៅហើយម៉្លេះ ក្អែកស្ទុះតាមរាជហង្ស នឹងធ្លាក់ចុះក្នុងពាក់កណ្ដាលផ្លូវ យ៉ាងណាមិញ (បើព្រះអង្គនឹងតាមព្រះរាជានោះ នឹងដល់សេចក្ដីវិនាសក្នុងពាក់កណ្ដាលផ្លូវ ក៏យ៉ាងនោះដែរ)។

[២៧០] ឆ្កែចចកទាំងឡាយជាម្រឹគថោកទាប ឃើញផ្កាចាដែលរីកក្នុងចំណែកនៃរាត្រី ក៏សំគាល់ថា ដុំសាច់ ហើយនាំគ្នាចោមរោម។ (ឆ្កែចចកទាំងនោះ) ជាម្រឹគថោកទាប កាលបើរាត្រីកន្លងទៅហើយ ព្រះអាទិត្យក៏រះឡើង ទើបឃើញច្បាស់ថា ជាផ្កាចារីក ក៏ដាច់សេចក្ដីប្រាថ្នា (រត់ទៅ) យ៉ាងណា។ បពិត្រព្រះរាជា ព្រះអង្គចោមព័ទ្ធព្រះបាទវិទេហៈ នឹងដាច់សេចក្ដីប្រាថ្នា ហើយទៅ ដូចពួកឆ្កែចចក (ចោមរោម) នូវផ្កាចាដូច្នោះដែរ។

[២៧១] (ព្រះបាទចូឡនី...) អ្នកទាំងឡាយ ចូរកាត់ដៃ និងជើង ត្រចៀក និងច្រមុះនៃមហោសធនេះ ព្រោះវាធ្វើព្រះបាទវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្ដាប់ដៃយើងឲ្យរួចទៅវិញ។ សេនាទាំងឡាយ ចូរដោតគហបតីបុត្រនេះដោយឈើស្រួច ហើយចំអិនវា ដូចគេចំអិនសាច់ដែលគួរចំអិន ព្រោះវាធ្វើស្ដេចវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្ដាប់ដៃយើងឲ្យរួចទៅវិញ។ បុគ្គលដោតសន្ទឹងស្បែកគោលើផែនដី ពុំនោះសោត ថ្កក់ស្បែកសីហៈ ឬខ្លាធំដោយកង្វេរ យ៉ាងណា។ យើងនឹងចាក់ដោតវាដោយលំពែង យ៉ាងនោះ ព្រោះវាធ្វើព្រះបាទវិទេហៈជាសត្រូវ ដែលនៅក្នុងកណ្ដាប់ដៃយើងឲ្យរួចទៅវិញ។

[២៧២] (មហោសធ...) បើព្រះអង្គកាត់នូវដៃ ជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (ដៃ ជើង ត្រចៀក និងច្រមុះ) របស់ព្រះរាជបុត្រឈ្មោះបញ្ចាលចន្ទៈ យ៉ាងហ្នឹងដែរ។ បើព្រះអង្គកាត់ដៃ ជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (នូវដៃ ជើង ត្រចៀក និងច្រមុះ) របស់ព្រះរាជធីតាឈ្មោះបញ្ចាលចន្ទី យ៉ាងហ្នឹងដែរ។ បើព្រះអង្គកាត់ដៃ និងជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (នូវដៃជើង ត្រចៀក និងច្រមុះ) របស់អគ្គមហេសី ឈ្មោះនន្ទាទេវី យ៉ាងហ្នឹងដែរ។ បើព្រះអង្គកាត់ដៃ និងជើង ត្រចៀក និងច្រមុះរបស់ខ្ញុំព្រះអង្គ ព្រះបាទវិទេហៈ មុខជានឹងកាត់ (នូវដៃ និងជើង ត្រចៀក និងច្រមុះ) របស់ព្រះរាជបុត្រ និងព្រះមហេសីរបស់ព្រះអង្គយ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតខ្ញុំដោយឈើអណ្ដោត ហើយចំអិន ដូចគេចំអិនសាច់ដែលគួរចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជបុត្រឈ្មោះបញ្ចាលចន្ទៈ (ដោយឈើអណ្ដោត) ហើយចំអិនយ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតខ្ញុំដោយឈើអណ្ដោត ហើយចំអិន ដូចគេចំអិនសាច់ដែលគួរចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជធីតា ឈ្មោះបញ្ចាលចន្ទី (ដោយឈើអណ្ដោត) ហើយចំអិនយ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្ដោត ហើយចំអិន ដូចគេចំអិនសាច់ដែលគួរចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតអគ្គមហេសីឈ្មោះនន្ទាទេវី (ដោយឈើអណ្ដោត) ហើយចំអិនយ៉ាងហ្នឹងដែរ។ បើព្រះអង្គដោតខ្ញុំនឹងឈើអណ្ដោត ហើយចំអិន ដូចគេចំអិនសាច់ដែលគួរចំអិន ព្រះបាទវិទេហៈ មុខជានឹងប្រើឲ្យគេដោតព្រះរាជបុត្រ និងព្រះមហេសីរបស់ព្រះអង្គ (ដោយឈើអណ្ដោត) ហើយចំអិនយ៉ាងហ្នឹងដែរ។ បើព្រះអង្គចាក់ដោតខ្ញុំ ដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងដោតព្រះរាជបុត្រ ឈ្មោះបញ្ចាលចន្ទៈ (ដោយលំពែង) យ៉ាងហ្នឹងដែរ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតព្រះរាជធីតា ឈ្មោះបញ្ចាលចន្ទី (ដោយលំពែង) យ៉ាងនោះដែរ។ បើព្រះអង្គចាក់ដោតខ្ញុំ ដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតអគ្គមហេសី ឈ្មោះនន្ទាទេវី (ដោយលំពែង) យ៉ាងនោះដែរ។ បើព្រះអង្គចាក់ដោតខ្ញុំដោយលំពែង ព្រះបាទវិទេហៈ មុខជានឹងចាក់ដោតព្រះរាជបុត្រ និងព្រះមហេសីរបស់ព្រះអង្គ (ដោយលំពែង) យ៉ាងនោះដែរ។ យើងទាំងពីរនាក់ គឺស្ដេចវិទេហៈ និងទូលព្រះបង្គំជាខ្ញុំ ប្រឹក្សាគ្នារួចស្រេចក្នុងទីស្ងាត់យ៉ាងនេះហើយ ខែលស្បែកមានទម្ងន់ ១០០ បលៈ ដែលជាងស្បែកឲ្យសម្រេចហើយដោយសស្ត្រារបស់ជាងស្បែក រមែងជួយការពារខ្លួន ដើម្បីទប់រងនូវកូនសរទាំងឡាយយ៉ាងណា។ ទូលព្រះបង្គំជាខ្ញុំជាអ្នកនាំសេចក្ដីសុខមក ជួយបន្ទោបង់សេចក្ដីទុក្ខនៃព្រះបាទវិទេហៈដ៏មានយស តែងទប់រងនូវកូនសរ គឺព្រះតម្រិះរបស់ព្រះអង្គដោយខែលស្បែកមានទម្ងន់ ១០០ បលៈ (សេចក្ដីគិតរបស់ទូលព្រះបង្គំជាខ្ញុំ ក៏ដូច្នោះឯង)។

[២៧៣] បពិត្រមហារាជ សូមអញ្ជើញព្រះអង្គទតព្រះនេត្រមើលព្រះរាជវាំងរបស់ព្រះអង្គដែលសូន្យឈឹងចុះ បពិត្រព្រះមហាក្សត្រិយ៍ ស្រីស្នំ និងកុមារទាំងឡាយ និងព្រះវររាជមាតារបស់ព្រះអង្គ ខ្ញុំឲ្យនាំចេញចាកឧម្មង្គ នាំទៅថ្វាយព្រះបាទវិទេហៈហើយ។

[២៧៤] (ព្រះបាទចូឡនី...) បើដូច្នោះ អ្នកទាំងឡាយ ចូរទៅឯព្រះរាជវាំងរបស់អញ ហើយពិចារណាមើលហេតុនោះ តើសមដូចពាក្យរបស់មហោសធនេះពិត ឬកុហកទេ។

[២៧៥] (ពួកអាមាត្យ...) បពិត្រមហារាជ មហោសធទូលយ៉ាងណា សេចក្ដីនុ៎ះ ក៏យ៉ាងនោះឯង ព្រះរាជវាំងទាំងមូលសូន្យឈឹង ដូចឋានជាទីប្រជុំចុះនៃពួកក្អែក។

[២៧៦] (មហោសធ...) បពិត្រមហារាជ ព្រះនាងនារីនន្ទាទេវី ព្រះសព៌ាង្គកាយដ៏ល្អ មានព្រះសោណីដ៏ល្អ ដូចដម្បារមាស មានប្រក្រតីពោលពាក្យពីរោះ ដូចជាសំឡេងនៃហង្ស បានចេញទៅអំពីឧម្មង្គនេះហើយ។ បពិត្រមហារាជ ព្រះនាងនារី មានសព៌ាង្គកាយដ៏ល្អ ទ្រទ្រង់កោសេយ្យពស្ត្រ មានសរីរៈដូចមាស មានខ្សែរឹតព្រះអង្គនោះក៏ល្អវិចិត្រដោយមាស។ ព្រះនាងនារី មានព្រះបាទដ៏ក្រហមល្អ ប្រកបដោយលំអ (៥យ៉ាង) មានខ្សែរឹតជាវិការៈនៃមាស និងកែវមណី មានដួងព្រះនេត្រប្រាកដស្មើដោយភ្នែកសត្វព្រាប មានសរីរៈដ៏ល្អ មានរឹមព្រះឱស្ឋរលីង ល្អដូចជាផ្លែទន្លាប់ មានចង្កេះរៀវ។ ព្រះនាងនារីមានចង្កេះរៀវដូចវល្លិនាគលតា ដែលលូតលាស់ល្អ ឬដូចក្ដារហ៊ីង (ជាវិការៈនៃមាស) ព្រះកេសរបស់ព្រះនាងនារីនោះ វែង មានចុងខ្មៅងបន្តិច ដូចចុងកំបិត។ ព្រះនាងនន្ទាទេវី មានដួងព្រះនេត្រថ្លាយង់ ដូចជាភ្នែកនៃកូនម្រឹគកើត (បានមួយខួប) ឬដូចជាអណ្ដាតភ្លើងក្នុងហោមន្តរដូវ ពុំនោះសោត ដូចជាស្ទឹងដ៏ដេរដាសដោយដើមឫស្សីតូច ៗ ទាំងឡាយ ទៀបជ្រោះភ្នំ។ ព្រះនាងនន្ទាទេវី មានព្រះឧរូល្អ ដូចប្រមោយដំរី មានស្តនទាំងគូល្អដូចផ្លែទន្លាប់ដ៏ប្រសើរ មិនខ្ពស់ពេក មិនទាបពេក មិនមែនឥតព្រះលោមា មិនមែនមានព្រះលោមាច្រើនពេក។ បពិត្រព្រះអង្គមានពាហនៈបរិបូណ៌ដោយសិរី ព្រះអង្គត្រេកអរដោយមរណៈនៃព្រះនាងនន្ទាទេវីដោយពិត ឯខ្ញុំព្រះអង្គ និងព្រះនាងនន្ទា នឹងទៅកាន់សំណាក់យមរាជដោយពិត។

[២៧៧] (ព្រះបាទចូឡនី...) អ្នកបានរៀនកលមាយាជាទិព្វ ហើយបានធ្វើឧបាយបំបាំងភ្នែកឬ បានជាអ្នកដោះលែងព្រះបាទវិទេហៈជាសត្រូវនៅក្នុងកណ្ដាប់ដៃនៃយើងបាន។

[២៧៨] (មហោសធ...) បពិត្រមហារាជ បណ្ឌិតទាំងឡាយក្នុងលោកនេះ រមែងរៀននូវកលមាយាជាទិព្វដោយពិត ពួកបណ្ឌិតជនអ្នកមានសេចក្ដីដឹងនោះ ទើបដោះខ្លួន (ចាកទុក្ខបាន) ពួកយោធាក្មេង ៗ អ្នកបំរើរបស់ទូលព្រះបង្គំជាអ្នកឈ្លាស ជាអ្នកកាត់ផ្ដាច់នូវទីតព្រះបាទវិទេហៈយាងទៅកាន់ក្រុងមិថិលាតាមផ្លូវដែលពួកជនទាំងនេះធ្វើទុកហើយ។

[២៧៩] បពិត្រមហារាជ សូមព្រះអង្គស្ដេចទតឧម្មង្គ ដែលពួកជាងសាងទុកល្អហើយ សូមព្រះអង្គទតឧម្មង្គដ៏ល្អរុងរឿង (ដោយរបៀប) នៃដំរី សេះ រថ និងពលថ្មើរជើង ដែលគេធ្វើឲ្យសម្រេចហើយដោយល្អ។

[២៨០] (ព្រះបាទចូឡនី...) ម្នាលមហោសធ ជាលាភរបស់អ្នកដែនវិទេហៈដោយពិត បណ្ឌិតទាំងឡាយបែបដូចជាអ្នកនេះ នៅក្នុងដំណាក់ ក្នុងដែនរបស់ព្រះរាជាណា (ជាលាភរបស់ព្រះរាជានោះពិត)។

[២៨១] យើងនឹងឲ្យគ្រឿងចិញ្ចឹមជីវិត និងវត្ថុ គ្រឿងរក្សា គឺស្រុក និងនិគម ទាំងបាយ និងថ្លៃឈ្នួលជាទេ្វគុណដល់អ្នក ទាំងឲ្យភោគសម្បទដ៏ធំទូលាយទៀត អ្នកចូរបរិភោគ ចូររីករាយតាមប្រាថ្នាចុះ អ្នកកុំទៅរកព្រះបាទវិទេហៈឡើយ ព្រះបាទវិទេហៈ នឹងធ្វើអ្វីដល់អ្នក។

[២៨២] (មហោសធ...) បពិត្រមហារាជ បុគ្គលណា លះបង់នូវបុគ្គលអ្នកចិញ្ចឹម ព្រោះហេតុនៃទ្រព្យ បុគ្គលនោះ ត្រូវជនទាំងពីរគឺ ខ្លួនឯង និងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈ ទ្រង់គង់ព្រះជន្មាយុដរាបណា ខ្ញុំក៏មិនគប្បីនៅក្នុងដែននៃព្រះរាជាដទៃ (ដរាបនោះ)។ បពិត្រមហារាជ បុគ្គលណា លះបង់នូវបុគ្គលអ្នកចិញ្ចឹម ព្រោះហេតុនៃទ្រព្យ បុគ្គលនោះត្រូវជនទាំងពីរគឺ ខ្លួនឯង និងអ្នកដទៃតិះដៀល ព្រះបាទវិទេហៈ ទ្រង់បិតនៅដរាបណា ខ្ញុំមិនត្រូវជាបុរសរបស់បុគ្គលដទៃ (ដរាបនោះ)។

[២៨៣] (ព្រះបាទចូឡនី...) ម្នាលមហោសធ យើងឲ្យមាសឆ្តោរ ១០០០ និងស្រុក ចំនួន ៨០ ក្នុងដែនកាសីដល់អ្នក យើងឲ្យទាសី ៤០០ និងភរិយា ១០០ ដល់អ្នក អ្នកចូរនាំអង្គនៃសេនាទាំងពួងទៅដោយសួស្តីចុះ។

[២៨៤] ជនទាំងឡាយ ចូរឲ្យវត្ថុផ្សេងៗ ជាទេ្វគុណ ដល់ពួកដំរី ពួកសេះជាកំណាត់ ចូរញុំាងពលរថ និងពលថ្មើរជើងឲ្យឆ្អែតស្កប់ស្កល់ ដោយបាយ និងទឹកចុះ។

[២៨៥] ម្នាលបណ្ឌិត អ្នកចូរនាំយកពួកដំរី ពួកសេះ ពួករថ និងពួកពលថ្មើរជើងទៅ ព្រះបាទវិទេហៈមហារាជ ចូរទតឃើញអ្នក ដែលទៅដល់ក្រុងមិថិលាចុះ។

[២៨៦] (ព្រះបាទវិទេហៈ...) សេនាប្រកបដោយអង្គ ៤ គឺសេនាដំរី សេនាសេះ សេនារថ និងសេនាថ្មើរជើងនោះ ប្រាកដជាមានច្រើន មានសភាពគួរខ្លាច តើបណ្ឌិតទាំងឡាយសំគាល់ដូចម្តេចហ្ន៎។

[២៨៧] (អាចារ្យសេនកៈ...) បពិត្រមហារាជ សេចក្តីត្រេកអរយ៉ាងខ្ពង់ខ្ពស់ រមែងប្រាកដដល់ព្រះអង្គ មហោសធនាំយកអង្គនៃសេនាទាំងពួងមកដល់ហើយដោយសួស្តី។

[២៨៨] (ព្រះបាទវិទេហៈ...) ម្នាលមហោសធ ជនទាំង ៤ នាក់ នាំមនុស្សស្លាប់ទៅចោលក្នុងព្រៃស្មសាន (ហើយត្រឡប់មក) យ៉ាងណា ពួកយើងបោះបង់អ្នកចោល ក្នុងដែនគប្បីលៈហើយ ត្រឡប់មកក្នុងទីនេះក៏ដូច្នោះ។ កាលបើដូច្នេះ អ្នកចេះដោះខ្លួនឲ្យរួចមក ដោយហេតុដូចម្តេច ដោយបច្ច័យដូចម្តេច ដោយដំណើរដូចម្តេច។

[២៨៩] (មហោសធ...) បពិត្រក្សត្រិយ៍ព្រះនាមវិទេហៈ ទូលព្រះបង្គំបានការពារនូវសេចក្តីដោយសេចក្តី នូវការប្រឹក្សាដោយប្រឹក្សា ទូលព្រះបង្គំបានការពារស្តេច ដូចជាសាគរការពារជម្ពូទ្វីបដូច្នោះ។ ព្រះបាទចូឡនី បានប្រទានមាសឆ្តោរ ១០០០ និងស្រុកចំនួន ៨០ ក្នុងដែនកាសីដល់ទូលព្រះបង្គំ ប្រទានទាសី ៤០០ និងភរិយា ១០០ ដល់ទូលព្រះបង្គំ ទូលព្រះបង្គំជាអ្នកនាំអង្គនៃសេនាទាំងពួង មកក្នុងទីនេះដោយសួស្តី។

[២៩០] (ព្រះបាទវិទេហៈ...) នៃអាចារ្យសេនកៈ ការនៅរួមជាមួយនឹងអ្នកប្រាជ្ញ នាំមកនូវសេក្តីសុខស្រួលណាស់ហ្ន៎ មហោសធ បានដោះពួកយើងដែលតាំងនៅក្នុងសេចក្តីវិនាស គឺដៃនៃសត្រូវ ដូចជាគេដោះហ្វូងបក្សីដែលជាប់នៅក្នុងទ្រុង ឬដូចជាគេដោះត្រីដែលជាប់នៅក្នុងសំណាញ់។

[២៩១] (អាចារ្យសេនកៈ...) បពិត្រមហារាជ មែនពិត ពួកបណ្ឌិតរមែងនាំមកនូវសេចក្តីសុខយ៉ាងនេះឯង មហោសធ បានដោះពួកយើងដែលតាំងនៅក្នុងសេចក្តីវិនាស គឺដៃនៃសត្រូវ ដូចជាគេដោះហ្វូងបក្សីដែលជាប់ក្នុងទ្រុង ឬដូចជាគេដោះត្រីដែលជាប់ក្នុងសំណាញ់។

[២៩២] (អភិសម្ពុទ្ធគាថា...) ពួកជនចូរដេញពិណា ចូរវាយស្គរតូច និងស្គរធំ ផ្លុំស័ង្ខដែលកើតក្នុងដែនមគធៈ និងទូងស្គរធំមានសំឡេងពីរោះ។

[២៩៣] ពួកស្រីស្នំ ពួកកុមារ ពួកវេស្សៈ និងពួកព្រាហ្មណ៍ នាំបាយ និងទឹកជាច្រើន មកជូន (មហោសធបណ្ឌិត)។ ពលដំរី ពលសេះ ពលរថ និងពលថ្មើរជើង នាំបាយ និងទឹកជាច្រើន មកជូនបណ្ឌិត។ ពួកអ្នកជនបទ ប្រជុំគ្នា ទាំងពួកអ្នកនិគម ក៏មកប្រជុំគ្នា នាំបាយ និងទឹកជាច្រើន មកជូនបណ្ឌិត។ ជនជាច្រើន កាលបើបានឃើញបណ្ឌិតមកដល់ហើយ ក៏មានសេចក្តីជ្រះថ្លា កាលបើបណ្ឌិតមកដល់ហើយ ការលើកឡើងនូវទង់ ក៏ប្រព្រឹត្តទៅ។

ចប់ មហោសធជាតក ទី៥។

## ភូរិទត្តជាតក ទី៦

CS sut.kn.jat.543 | ភាគទី ៦២

### (៥៤៣. ភូរិទត្តជាតកំ (៦))

[២៩៤] (នាគទាំង ៤ ក្រាបបង្គំទូលថា) រតនៈណាមួយ មានក្នុងនិវេសន៍របស់នាគរាជព្រះនាមធតរដ្ឋ រតនៈទាំងអស់នោះ ចូរមកដល់ព្រះអង្គ សូមព្រះអង្គទ្រង់ប្រទានធីតាដល់ព្រះរាជាយើង។

[២៩៥] (ព្រះបាទព្រហ្មទត្តត្រាស់ថា) វិវាហៈជាមួយនឹងពួកនាគ យើងមិនធ្លាប់ធ្វើក្នុងកាលណាម្តងទេ យើងនឹងធ្វើវិវាហៈមិនសមគួរនោះ ដូចម្តេចកើត។

[២៩៦] (នាគទាំង ៤...) បពិត្រព្រះអង្គជាធំជាងមនុស្ស ជីវិតក្តី ដែនក្តី ព្រះអង្គនឹងលះបង់ដោយពិត កាលបើនាគខឹងហើយ ព្រះរាជាទាំងឡាយប្រហែលនឹងព្រះអង្គ មិនគង់ព្រះជន្មនៅយូរទេ។ បពិត្រព្រះសម្មតិទេព ព្រះអង្គណាជាមនុស្ស ព្រះអង្គនោះ មិនមានឫទ្ធិ មើលងាយព្រះរាជាដែលមានឫទ្ធិ ជាកូនបង្កើតនៃព្រះបាទវរុណៈ ដែលកើតក្នុងទន្លេយមុនា។

[២៩៧] (ព្រះរាជា...) យើងមិនមើលងាយព្រះបាទធតរដ្ឋដ៏មានយសទេ ព្រោះថា ព្រះបាទធតរដ្ឋ ជាធំជាងនាគទាំងឡាយដ៏ច្រើន។ ពស់ទុកជាមានអានុភាពច្រើន ក៏មិនសមគួរនឹងធីតារបស់យើងទេ ចំណែកខាងយើង ជាក្សត្រិយ៍របស់អ្នកដែនវិទេហៈ ធីតា (របស់យើង) ឈ្មោះសមុទ្ទជា មានជាតិដ៏ប្រសើរ។

[២៩៨] (ព្រះបាទធតរដ្ឋ...) ពួកនាគឈ្មោះកម្ពលស្សតរា[61] ចូរក្រោកឡើង អ្នកចូរប្រាប់នាគទាំងអស់ថា នាគទាំងឡាយ ចូរទៅកាន់ក្រុងពារាណសី តែកុំបៀតបៀនបុគ្គលណាមួយឡើយ។

[២៩៩] នាគទាំងឡាយដែលមានសរីរៈធំ ចូរសំយុងខ្លួនក្នុងនិវេសនដ្ឋានទាំងឡាយ ក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុងឈើ និងលើក្លោងទ្វារ។ ចំណែកខាងខ្ញុំ មានកាយធំសសុទ្ធ នឹងព័ទ្ធបុរីដែលធំទូលាយ ដោយភ្នែនទាំងឡាយ នឹងញ៉ាំងភ័យឲ្យកើតឡើងដល់ពួកអ្នកដែនកាសី។

[៣០០] នាគទាំងឡាយ មានសម្បុរដ៏ច្រើន បានស្តាប់ពាក្យព្រះបាទធតរដ្ឋនោះហើយ ក៏ចូលទៅកាន់ក្រុងពារាណសី តែមិនបៀតបៀនបុគ្គលណាមួយឡើយ។ នាគទាំងឡាយដែលមានសរីរៈធំ ក៏សំយុងខ្លួនក្នុងនិវេសនដ្ឋាន ក្នុងស្រះ ត្រង់ផ្លូវដើរ ក្នុងព្រះលាន លើចុងឈើ និងលើក្លោងទ្វារ។ នារីទាំងឡាយជាច្រើន បានឃើញនាគទាំងនុ៎ះ កំពុងសំយុងខ្លួន លុះឃើញពួកនាគបើកពពារ កំពុងឲ្យសម្លេងរៀយ ៗ ក៏កន្ទក់កន្ទេញ។ ពួកជនក្នុងពារាណសី តក់ស្លុត ក្តៅក្រហាយ ក៏លើកដៃកន្ទក់កន្ទេញថា សូមព្រះអង្គប្រទានធីតា ដល់នាគរាជ។

[៣០១] (ព្រាហ្មណ៍នេសាទ...) អ្នកជាអ្វី មានភ្នែកក្រហម មានចន្លោះស្មាទូលាយ (អង្គុយ) ក្នុងកណ្តាលនៃព្រៃ ជាទីនាំមកបូជាដោយផ្កាឈើ ស្រីទាំង ១០ នាក់ ជាអ្វី ដែលទ្រទ្រង់នូវសង្វារជាវិការៈនៃមាស មានសំពត់ដ៏ល្អ កំពុងឈរសំពះ។ អ្នកជាអ្វី មានដៃធំរុងរឿងក្នុងកណ្តាលព្រៃ ដូចភ្លើងឆេះនូវឆ្នាំងខ្លាញ់ អ្នកជាយក្សណាមួយ ដែលមានសក្តិធំឬ ឬជានាគមានអានុភាពធំ។

[៣០២] (ភូរិទត្តនាគរាជ...) ខ្ញុំជានាគមានឫទ្ធិ មានតេជៈ ដែលគេកន្លងមិនបាន ប្រសិនជាខ្ញុំក្រោធ អាចចឹកសូម្បីនូវអ្នកជនបទ ដែលបរិបូណ៌ (ដោយភោគៈ) ដោយតេជៈបាន។ ឯមាតារបស់ខ្ញុំ ឈ្មោះសមុទ្ទជា បិតារបស់ខ្ញុំឈ្មោះធតរដ្ឋ ខ្ញុំជាប្អូននៃនាគរាជឈ្មោះសុទស្សនៈ ជនទាំងឡាយស្គាល់ខ្ញុំថា ភូរិទត្ត។

[៣០៣] លោករមែងឃើញអន្លង់ទឹកណាដ៏ជ្រៅ ដែលហូរគួចសព្វកាល ជាអន្លង់ទឹកគួរខ្លាច អន្លង់ទឹកនោះជាទិព្វ ជាលំនៅរបស់ខ្ញុំ មានជម្រៅច្រើនរយនៃជួរបុរស។ អ្នកកុំខ្លាច ចូរចូលទៅកាន់ស្ទឹងយមុនា មានទឹកខៀវ (ដែលហូរមក) អំពីកណ្តាលព្រៃ ជាកន្លែងដែលក្ងោក និងក្រៀលយំ ជាស្ទឹងត្រជាក់ក្សេមក្សាន្ត ជាលំនៅរបស់ពួកអ្នកមានវត្ត។

[៣០៤] ម្នាលព្រាហ្មណ៍ អ្នកព្រមទាំងកូនមកដល់ភពនាគនោះហើយ នឹងបានប្រពន្ធ ម្នាលព្រាហ្មណ៍ យើងនឹងបូជាអ្នកដោយកាមទាំងឡាយរបស់យើង អ្នកចូរនៅឲ្យសុខចុះ។

[៣០៥] (ព្រាហ្មណ៍នេសាទ...) ផែនដីមានផ្ទៃរាបស្មើដោយជុំវិញ មានដើមក្រឹស្នាច្រើន ដេរដាសដោយមេភ្លៀង មានស្មៅខៀវដ៏ឧត្តមល្អ។ ព្រៃជ្រុំគួររីករាយ ស្រះបោក្ខរណីទាំងឡាយដែលបុញ្ញកម្មរបស់ព្រះអង្គនិម្មិតល្អហើយ ជាទីរីករាយ ដែលហង្សយំហើយ មានផ្កាឈូកធ្លាក់ចុះ។ សសរមានជ្រុង ៨ ដែលគេធ្វើល្អហើយ ជាវិការៈនៃកែវពៃទូរ្យទាំងអស់ ប្រាសាទទាំងឡាយ មានសសរ ១ ពាន់ ដ៏ពេញដោយនាងកញ្ញាភ្លឺរុងរឿង។ ព្រះអង្គបានដល់នូវវិមានជាទិព្វ ដោយបុណ្យរបស់ព្រះអង្គ ជាវិមានមិនចង្អៀត ជាទីក្សេមគួររីករាយ ប្រកបដោយសេចក្តីសុខយ៉ាងក្រៃលែង។ ខ្ញុំសំគាល់ថាព្រះអង្គ មិនប្រាថ្នាវិមានរបស់ព្រះឥន្ទ្រ ជាសហស្សនេត្តទេ ព្រោះថាឫទ្ធិរបស់ព្រះអង្គនេះ ដ៏ធំដូចជាឫទ្ធិនៃព្រះឥន្ទ្រដ៏រុងរឿងដែរ។

[៣០៦] (ភូរិទត្តនាគរាជ...) អានុភាពរបស់ព្រះឥន្ទ្រ អានុភាពរបស់លោកបាលទាំង ៤ ញ៉ាំងអំណាចឲ្យប្រព្រឹត្តទៅ ជាអ្នកបម្រើព្រះឥន្ទ្រក្តី អ្នកមិនគប្បីដឹងដោយចិត្តបានទេ។

[៣០៧] ខ្ញុំប្រាថ្នាវិមាននោះរបស់ទេវតាទាំងឡាយ អ្នកស្វែងរកសេចក្តីសុខ បានជារក្សាឧបោសថ ហើយដេកលើក្បាលដំបូក។

[៣០៨] (ព្រាហ្មណ៍នេសាទ...) ឯខ្ញុំ ព្រមទាំងកូន ស្វែងរកម្រឹគ បានចូលទៅកាន់ព្រៃ ញាតិទាំងនោះ មិនដឹងខ្ញុំថាស្លាប់ ឬរស់ទេ។ ខ្ញុំសូមលាព្រះភូរិទត្ត ជាបុត្តព្រះរាជធីតាក្នុងដែនកាសី ព្រះអង្គមានយស យើងខ្ញុំ បើព្រះអង្គព្រមអនុញ្ញាតហើយ គប្បីឃើញពួកញាតិ។

[៣០៩] (ភូរិទត្តនាគរាជ...) ឱ នុ៎ះពិតជាសេចក្តីពេញចិត្តរបស់ខ្ញុំហើយ ត្រង់ដែលអ្នកនៅក្នុងសំណាក់នៃខ្ញុំ ព្រោះថាកាមទាំងឡាយប្រាកដដូច្នេះ អ្នកមិនងាយបានក្នុងពួកមនុស្សទេ។ អ្នកដែលខ្ញុំបូជាដោយកាមទាំងឡាយរបស់ខ្ញុំ បើមិនចង់នៅទេ ខ្ញុំនឹងអនុញ្ញាតអ្នក សូមអ្នកទៅជួបពួកញាតិដោយសួស្តីចុះ។

[៣១០] អ្នកកាលទ្រទ្រង់កែវមណីជាទិព្វនេះ រមែងបានសត្វចិញ្ចឹម និងបុត្រ អ្នកចូរមិនមានរោគ បានសេចក្តីសុខ ម្នាលព្រាហ្មណ៍ អ្នកចូរយក (នូវកែវមណីនេះ) ហើយទៅចុះ។

[៣១១] (ព្រាហ្មណ៍នេសាទ...) បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ខ្ញុំនឹងបួស ព្រោះខ្ញុំចាស់ ហើយខ្ញុំមិនប្រាថ្នាកាមទេ។

[៣១២] (ភូរិទត្តនាគរាជ...) បើមានការបែកធ្លាយព្រហ្មចរិយៈ កិច្ចការដែលត្រូវធ្វើដោយភោគៈទាំងឡាយ (រមែងមាន) អ្នកកុំមានសេចក្តីរង្កៀសឡើយ គប្បីមក យើងនឹងឲ្យទ្រព្យដ៏ច្រើនដល់អ្នក។

[៣១៣] (ព្រាហ្មណ៍នេសាទ...) បពិត្រព្រះភូរិទត្ត ស្រួលហើយ ខ្ញុំត្រេកអរនឹងព្រះបន្ទូលរបស់ព្រះអង្គ ប្រសិនបើមានសេចក្តីត្រូវការ ខ្ញុំនឹងមកម្តងទៀត។

[៣១៤] (អភិសម្ពុទ្ធគាថា) ព្រះភូរិទត្ត លុះពោលពាក្យនេះហើយ ក៏បញ្ជូននូវនាគទាំង ៤ ថា អ្នកទាំងឡាយមកនេះ ចូរទៅ ចូរក្រោកឡើង ចូរញ៉ាំងព្រាហ្មណ៍ឲ្យដល់ (នូវផ្លូវជាទីទៅកាន់ក្រុងពារាណសី) ជាឆាប់។ នាគទាំង ៤ ត្រូវភូរិទត្តប្រើទៅហើយ បានស្តាប់ពាក្យនោះរបស់ភូរិទត្តនោះ ក៏ក្រោកឡើង ហើយបានញ៉ាំងព្រាហ្មណ៍ឲ្យដល់ឆាប់។

[៣១៥] (ព្រាហ្មណ៍នេសាទ...) អ្នកកាន់យកនូវកែវមណី ជាមង្គល ជាទ្រព្យដ៏ប្រសើរ ជាទីរីករាយនៃចិត្ត ជាថ្មបរិបូណ៌ដោយទ្រង់ទ្រាយ អ្នកបានកែវមណីនេះ អំពីទីណា។

[៣១៦] (អាលម្ពាយនព្រាហ្មណ៍...) ថ្ងៃនេះខ្ញុំទៅកាន់ផ្លូវពីព្រឹក បានកែវមណីនេះ ដែលពួកនាងនាគភ្នែកក្រហមមួយពាន់ថែរក្សាហើយ។

[៣១៧] (ព្រាហ្មណ៍នេសាទ...) កែវមណីនេះ បើបុគ្គលសន្សំទុកល្អ ថែទាំ បូជាគ្រប់គ្រងល្អ ទុកដាក់ល្អហើយសព្វកាល គប្បីញ៉ាំង

ប្រយោជន៍ទាំងពួងឲ្យសម្រេចបាន។ តែកាលបើបុគ្គលជាអ្នកប្រាសចាកការថែទាំក្នុងការទុកដាក់ ឬក្នុងការប្រើប្រាស់វិញ កែវមណីនេះ ដែលគេសន្សំទុកដោយមិនត្រូវទំនង នឹងដល់សេចក្តីវិនាស។ អ្នកជាបុគ្គលមិនឈ្លាស មិនគួរគ្រប់គ្រងកែវមណីជាទិព្វនេះទេ អ្នកចូរគ្រប់គ្រងមាសផ្តោរមួយរយចុះ ចូរឲ្យកែវមណីនេះដល់ខ្ញុំ។

[៣១៨] (អាលម្ពាយនព្រាហ្មណ៍...) កែវមណីនេះ ខ្ញុំមិនគប្បីលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ កែវមណីរបស់ខ្ញុំ ដែលកើតអំពីថ្ម បរិបូណ៌ដោយទ្រង់ទ្រាយ ខ្ញុំមិនគប្បីលក់ទេ។

[៣១៩] (ព្រាហ្មណ៍នេសាទ...) បើកែវមណី អ្នកមិនលក់ដោយគោ ឬដោយរតនៈទាំងឡាយទេ ចុះកែវមណី អ្នកនឹងលក់ដោយវត្ថុអ្វី ខ្ញុំសួរហើយ អ្នកចូរប្រាប់សេចក្តីនោះ។

[៣២០] (អាលម្ពាយនព្រាហ្មណ៍) បុគ្គលណា គប្បីបង្ហាញនាគដ៏ធំ មានតេជះដែលគេកន្លងបានដោយក្រ ដល់ខ្ញុំ ខ្ញុំនឹងឲ្យកែវមណីដ៏រុងរឿងដោយតេជះដល់បុគ្គលនោះ។

[៣២១] (ព្រាហ្មណ៍នេសាទ...) អ្នកជាអ្វី ជាគ្រុឌដ៏ប្រសើរជាងសត្វស្លាបទាំងឡាយ កាលស្វែងរកចំណីដើម្បីខ្លួន ទើបចាប់យកនាគដោយភេទជាព្រាហ្មណ៍ទេឬ។

[៣២២] (អាលម្ពាយនព្រាហ្មណ៍...) ខ្ញុំមិនមែនជាស្តេចសត្វស្លាបទេ គ្រុឌ ខ្ញុំមិនដែលឃើញទេ ខ្ញុំជាអ្នកត្រេកអរដោយអាសិរពិស ម្នាលព្រាហ្មណ៍ ជនទាំងឡាយដឹងថា ខ្ញុំជាហ្មពស់។

[៣២៣] (ព្រាហ្មណ៍នេសាទ...) កម្លាំងរបស់អ្នកដូចម្តេច សិល្បៈរបស់អ្នកដូចម្តេច ទាំងអ្នករឹងប៉ឹងព្រោះហេតុអ្វី បានជាមិនកោតខ្លាចនាគ។

[៣២៤] (អាលម្ពាយនព្រាហ្មណ៍...) គ្រុឌបានប្រាប់វិជ្ជាពិសដ៏ប្រសើរដល់ឥសីមួយ អង្គ ជាកោសិយគោត្រនៅក្នុងព្រៃ ប្រព្រឹត្តតបធម៌អស់រាត្រីយូរ។ ខ្ញុំជាអ្នកមិនខ្ជិលច្រអូសទាំងយប់ទាំងថ្ងៃ បានបម្រើឥសីមួយអង្គនោះ ដែលមានខ្លួនចំរើនហើយ កាលគង់នៅក្នុងចន្លោះភ្នំដោយសេចក្តីគោរព។ ឥសីនោះ ដែលខ្ញុំបានបម្រើហើយក្នុងកាលនោះ វត្តក្តី ព្រហ្មចរិយៈក្តី ឥសីនោះបានប្រព្រឹត្តហើយ ឥសីមានជោគនោះ ក៏បង្រៀនមន្តទិព្វ ដល់ខ្ញុំតាមសេចក្តីប្រាថ្នា។ ខ្ញុំជាអ្នករឹងប៉ឹង ព្រោះមន្តនោះ បានជាមិនខ្លាចនាគទាំងឡាយ ខ្ញុំជាអាចារ្យរបស់ពួកអ្នកសម្លាប់សត្វមានពិសទាំងឡាយ ជនទាំងឡាយស្គាល់ខ្ញុំថា អាលម្ពាយន៍។

[៣២៥] (ព្រាហ្មណ៍នេសាទ...) ម្នាលសោមទត្ត កូន យើងនឹងកាន់យកកែវមណី ចូរអ្នកដឹងចុះ យើងកុំយកដំបងទាត់ចោលសិរីដែលមកដល់ហើយ តាមសេចក្តីប្រាថ្នាឡើយ។

[៣២៦] (សោមទត្តកុមារ...) បពិត្រព្រាហ្មណ៍ ភូរិទត្តណា បានបូជាលោកដែលដល់នូវនិវេសន៍របស់ខ្លួន លោកប្រាថ្នានឹងប្រទូស្តចំពោះព្រះភូរិទត្តនោះ ដែលធ្វើអំពើល្អយ៉ាងនេះ ព្រោះសេចក្តីវង្វេងធ្វើអ្វី។ បើលោកឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទាន ចូរលោកឪពុកទៅសុំលោកចុះ លោកនឹងប្រទានទ្រព្យច្រើនដល់លោកឪពុក។

[៣២៧] (ព្រាហ្មណ៍នេសាទ...) ម្នាលសោមទត្ត យើងគួរស៊ីរបស់ឆ្អិន ដែលមកដល់ដៃ ឬដល់ភាជន៍ ប្រសើរជាង កុំឲ្យប្រយោជន៍ដែលឃើញច្បាស់នឹងភ្នែក កន្លងផុតពីយើងទៅបាន។

[៣២៨] (សោមទត្តកុមារ...) បុគ្គលជាអ្នកទ្រស្តមិត្ត ជាអ្នកលះបង់ប្រយោជន៍ រមែងឆេះក្នុងនរកដ៏គួរខ្លាច ផែនដីក៏ស្របបុគ្គលទ្រស្តមិត្តនោះ បុគ្គលទ្រស្តមិត្ត សូម្បីរស់នៅក៏រីងស្ងួត (ដូចជាប្រេត) បើឪពុកចង់បានទ្រព្យ ព្រះភូរិទត្តនឹងប្រទានមិនខាន ខ្ញុំសំគាល់ថា មិនយូរប៉ុន្មាន ឪពុកនឹងដឹងច្បាស់នូវពៀរដែលខ្លួនធ្វើហើយ។

[៣២៩] (ព្រាហ្មណ៍នេសាទ...) ព្រាហ្មណ៍ទាំងឡាយ បូជាមហាយញ្ញហើយ រមែងបរិសុទ្ធយ៉ាងនេះ យើងនឹងបូជាមហាយញ្ញ គង់នឹងរួចចាកបាបដោយអាការយ៉ាងនេះ។

[៣៣០] (សោមទត្ត...) ណ្ហើយចុះ ឥឡូវនេះ ខ្ញុំនឹងគេចចេញថ្ងៃនេះ ខ្ញុំមិននៅជាមួយនឹងឪពុកទេ ខ្ញុំមិនដើរជាមួយនឹងឪពុក ដែលធ្វើអំពើអាក្រក់យ៉ាងនេះ អស់មួយជំហានទេ។

[៣៣១] (អភិសម្ពុទ្ធគាថា) សោមទត្តកុមារ ជាពហុស្សូត បានពោលពាក្យនេះនឹងបិតាហើយ ក៏ប្រកាសទេវតាទាំងឡាយ ហើយគេចចេញចាកទីនោះ។

[៣៣២] (ព្រាហ្មណ៍នេសាទ...) នាគណាមានពន្លឺដូចជាសម្បុរនៃសត្វមេភ្លៀង មានក្បាលក្រហម អ្នកចូរចាប់នាគធំនុ៎ះចុះ ហើយចូរនាំកែវមណីនុ៎ះដល់ខ្ញុំ។ កាយរបស់នាគនុ៎ះ រមែងប្រាកដដូចជាគីនរប៉ុយកប្បាស នាគនេះដេកលើដំបូក ម្នាលព្រាហ្មណ៍ អ្នកចូរចាប់យកនាគនោះចុះ។

[៣៣៣] (អភិសម្ពុទ្ធគាថា) គ្រានោះ អាលម្ពាយនព្រាហ្មណ៍ កាលជប់បទនៃមន្តទាំងឡាយ ធ្វើជាគ្រឿងការពារខ្លួន ដោយឱសថទិព្វទាំងឡាយហើយ ទើបអាចចាប់នាគនោះ ដោយវិធីយ៉ាងនេះ។

[៣៣៤] (សុទស្សននាគរាជ...) ឥន្ទ្រិយរបស់លោកមិនស្រស់បស់ ព្រះភក្ត្ររបស់លោកក៏ខ្មៅ ព្រោះឃើញខ្ញុំ ដែលសម្រេចសេចក្តីប្រាថ្នាទាំងពួង កំពុងមកគាល់ឬ។ ព្រះភក្ត្ររបស់លោកខ្មៅ ដូចជាផ្កាឈូកដែលបិតនៅក្នុងដៃ ដែលគេច្របាច់ដោយដៃ ព្រោះតែឃើញខ្ញុំប្រាកដដូច្នេះឬ។

[៣៣៥] ក្រែងបុគ្គលណាមួយ មិនរាប់អានលោកខ្លះឬ វេទនារបស់លោកមានខ្លះឬ ព្រះភក្ត្ររបស់លោកខ្មៅ ព្រោះឃើញខ្ញុំមក ដោយហេតុណា (សូមលោកប្រាប់នូវហេតុនោះដល់ខ្ញុំចុះ)។

[៣៣៦] (នាងសមុទ្ទជា...) ម្នាលកូន ក្រោយមួយខែមកហើយ អំពីថ្ងៃនេះ យើងបានឃើញសុបិនថា ហាក់ដូចជាបុរសកាត់ដៃខាងស្តាំរបស់យើង ហើយនាំយកដៃដែលប្រឡាក់ដោយឈាម ដើរចេញទៅក្នុងកាលដែលយើងកំពុងយំ។ ម្នាលសុទស្សនៈ កាលណាយើងបានឃើញសុបិន អ្នកចូរដឹងចុះថា កាលណោះ យើងមិនបានសេចក្តីសុខទាំងថ្ងៃទាំងយប់។

[៣៣៧] នាងកញ្ញាទាំងឡាយ មានរាងកាយដ៏រុងរឿង ពាក់បណ្តាញមាស បានចោមរោមភូរិទត្តណា ពីក្នុងកាលមុន (ឥឡូវនេះ)

ភូរិទត្តនោះ យើងមិនឃើញទេ។ នាគទាំងឡាយដែលកាន់ព្រះខ័នដ៏ប្រសើរ ដូចជាផ្កាកណ្ណិការិក ចោមរោមភូរិទត្តណា ពីក្នុងកាលមុន (ឥឡូវនេះ) ភូរិទត្តនោះ យើងមិនឃើញទេ។ ណ្ហើយចុះ ឥឡូវនេះ យើងនឹងទៅកាន់លំនៅរបស់ភូរិទត្ត យើងគង់នឹងឃើញប្អូនរបស់អ្នក ដែលតាំងនៅក្នុងធម៌ បរិបូណ៌ដោយសីល។

[៣៣៨] (អភិសម្ពុទ្ធគាថា) ឯភរិយាទាំងឡាយរបស់ភូរិទត្ត បានឃើញព្រះមាតានៃភូរិទត្តនោះ កំពុងដើរមក ក៏ផ្គងដៃឡើងកន្ទក់កន្ទេញថា បពិត្រលោកម្ដាយជាម្ចាស់ ក្រោយមួយខែមកហើយ អំពីថ្ងៃនេះ យើងមិនដឹងភូរិទត្តដ៏មានយស ជាបុត្ររបស់លោក ជាស្លាប់ ឬរស់នៅទេ។

[៣៣៩] (នាងសមុទ្ទជា...) យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្ដីទុក្ខ អស់កាលយូរ ដូចជាមេសត្វស្លាបបាត់កូន ឃើញតែសំបុកទទេដូច្នោះ។ យើងកាលមិនឃើញភូរិទត្ត នឹងឆេះដោយសេចក្ដីទុក្ខអស់កាលយូរ ដូចជាមេអកបាត់កូន ឃើញតែសំបុកទទេដូច្នោះ។ យើងកាលមិនឃើញភូរិទត្តទេ នឹងឆេះដោយសេចក្ដីទុក្ខ អស់កាលយូរ ដូចជាមេសត្វចាក្រពាកនោះ នៅលើភក់ ដែលមិនមានទឹកដោយពិត។ ជើងក្រាននៃពួកជាងមាស ឆេះតែខាងក្នុង មិនឆេះខាងក្រៅយ៉ាងណា យើងកាលមិនឃើញភូរិទត្ត នឹងឆេះដោយសេចក្ដីសោកយ៉ាងនោះ។

[៣៤០] (អភិសម្ពុទ្ធគាថា) កូន និងប្រពន្ធទាំងឡាយ ដួលដេកក្នុងនិវេសន៍របស់ព្រះភូរិទត្ត ដូចជាដើមឈើដែលត្រូវខ្យល់ញាំញីបំបាក់ដូច្នោះ។

[៣៤១] អរិដ្ឋៈ និងសុភោគនាគរាជ បានឮសម្លេងគឹកកងនៃនាគទាំងនោះ ក្នុងនិវេសន៍របស់ព្រះភូរិទត្ត ក៏ស្ទុះទៅតាមលំដាប់ ហើយពោលថា បពិត្រលោកម្ដាយ សូមលោកដកដង្ហើមស្រលចុះ កុំសោយសោកឡើយ ព្រោះថា សត្វទាំងឡាយ មានសភាពយ៉ាងនេះជាធម្មតា តែងច្យុត តែងកើតឡើងវិញ នេះជាការប្រែប្រួលនៃលោក។

[៣៤២] (នាងសមុទ្ទជា...) ម្នាលកូន យើងក៏ដឹងថា សត្វទាំងឡាយមានសភាពយ៉ាងនេះជាធម្មតាដែរ តែថាយើងកាលមិនឃើញភូរិទត្តទេ ត្រូវសេចក្ដីសោកគ្របសង្កត់ហើយ ប្រសិនបើ (ភូរិទត្ត) មិនបាន (មកចួប) នឹងយើង ក្នុងថ្ងៃនេះ យប់នេះទេ ម្នាលសុទស្សនៈ អ្នកចូរដឹងចុះ យើងកាលមិនឃើញភូរិទត្តទេ យើងមុខជានឹងលះបង់នូវជីវិតពុំខាន។

[៣៤៣] (កូនទាំងឡាយ...) បពិត្រព្រះមាតា សូមលោកដកដង្ហើមស្រលចុះ កុំសោយសោកឡើយ យើងទាំងឡាយ នឹងនាំបងមក យើងទាំងឡាយ ត្រាច់ទៅកាន់ទីស្វែងរកបង នឹងទៅកាន់ទិសតូចធំលើភ្នំ ជ្រោះភ្នំ ក្នុងស្រុក និងនិគមទាំងឡាយ លោកចូរឃើញបងដែលមកក្នុងរវាងខាងក្នុង ៧ រាត្រី។

[៣៤៤] (អាលម្ពាយនព្រាហ្មណ៍...) នាគដែលរួចអំពីដៃ (របស់យើង) ក្រាបចុះលើជើងលោកយ៉ាងខ្លាំង លោកត្រូវពស់ចឹកឬ លោកកុំខ្លាចឡើយ ចូរដល់សេចក្ដីសុខចុះ។

[៣៤៥] (សុទស្សននាគរាជ...) នាគនេះ មិនអាចឲ្យទុក្ខណាមួយដល់អាត្មាទេ អ្នកចាប់ពស់មានទាំងប៉ុន្មាន មិនមែនមានច្រើនជាងអាត្មាទេ។

[៣៤៦] (អាលម្ពាយនព្រាហ្មណ៍...) អ្នកណាហ្ន៎ ភ្លីភ្លើ មានភេទដូចជាភេទនៃព្រាហ្មណ៍ មកកាន់បរិស័ទ ហើយហៅ (អញ) ច្បាំង បរិស័ទចូរស្ដាប់ពាក្យរបស់យើងចុះ។

[៣៤៧] (សុទស្សននាគរាជ...) ម្នាលអាលម្ពាយន៍ អ្នកច្បាំងនឹងយើងដោយនាគ យើងក៏ច្បាំងនឹងអ្នកដោយកូនកង្កែបដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាបណៈ ៥.០០០ ជាកំណត់។

[៣៤៨] (អាលម្ពាយនព្រាហ្មណ៍...) ម្នាលមាណព យើងជាអ្នកមានទ្រព្យស្ដុកស្ដម្ភ អ្នកឯងជាអ្នកទាល់ក្រ តើបុគ្គលណា ជាអ្នកធានាអ្នកម្យ៉ាងទៀត ទ្រព្យដ៏កល់ទុកក្នុងការភ្នាល់ មានដែរឬ។ ទ្រព្យដំកល់ទុកក្នុងការភ្នាល់របស់យើង មាន ទាំងបុគ្គលជាអ្នកធានាប្រាកដដូច្នោះក៏មានដែរ ការភ្នាល់ក្នុងចម្បាំងនោះ ចូរមានដល់យើងដោយកហាបណៈ ៥.០០០ ជាកំណត់។

[៣៤៩] (សុទស្សននាគរាជ...) បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះសណ្ដាប់ពាក្យអាត្មាភាព សេចក្ដីចំរើន ចូរមានដល់ព្រះអង្គ ព្រះអង្គមានកិត្តិគុណ សូមព្រះអង្គធានាដោយកហាបណៈ ៥.០០០ របស់អាត្មាភាព។

[៣៥០] (ព្រះរាជា...) នែព្រាហ្មណ៍ បំណុលជារបស់នៃបិតា ឬថាខ្ញុំជំពាក់ដោយខ្លួនឯង បានជាអ្នកទារយកទ្រព្យរបស់យើងច្រើនតើព្រោះហេតុអ្វី។

[៣៥១] (សុទស្សននាគរាជ...) ដ្បិតអាលម្ពាយនព្រាហ្មណ៍ ផ្ចាញ់អាត្មាភាពដោយ នាគ អាត្មាភាពនឹងញាំងកូនកង្កែបឲ្យខាំព្រាហ្មណ៍។ បពិត្រមហារាជញាំងដែនឲ្យចំរើន ព្រោះហេតុនោះ សូមព្រះអង្គមានពួកអ្នកកាន់ព្រះខ័នហែហម យាងទៅដើម្បីទតពស់ដែលគួរទត។

[៣៥២] (អាលម្ពាយនព្រាហ្មណ៍...) ម្នាលមាណព ខ្ញុំមិនមើលងាយអ្នកដោយសិប្បវាទទេ ចំណែកអ្នកមើលងាយដោយសិប្បៈ បានជាមិនកោតក្រែងនាគ។

[៣៥៣] (សុទស្សននាគរាជ...) នែព្រាហ្មណ៍ អាត្មាក៏មិនមើលងាយអ្នកដោយសិប្បវាទទេ តែអ្នកបញ្ឆោតជនច្រើនដោយនាគដែលមិនមានពិស។ អាត្មាដឹងអ្នកយ៉ាងណា ជនក៏ត្រូវដឹងអ្នកយ៉ាងនោះដែរ ម្នាលអាលម្ពាយន៍ អ្នកមិនបានអង្កាម ១ ក្ដាប់ នឹងបានទ្រព្យអំពីណា។

[៣៥៤] (អាលម្ពាយនព្រាហ្មណ៍...) អ្នកស្លៀកដណ្ដប់ស្បែកខ្លាទាំងក្រចក មានផ្នួងសក់ ជាមនុស្សកខ្វក់ភ្លីភ្លើ មកកាន់បរិស័ទ ហើយមើលងាយនាគបែបនេះថា មិនមានពិស អ្នកចូរមក ហើយគង់នឹងដឹងនាគនោះ ដែលពេញដោយតេជះរបស់នាគដ៏ខ្ពង់ខ្ពស់ ខ្ញុំសំគាល់ថា នាគនុ៎ះ នឹងធ្វើអ្នកឲ្យដូចជាគំនរផេះយ៉ាងឆាប់។

[៣៥៥] (សុទស្សននាគរាជ...) ពិសនៃពស់ផ្ទះ ពស់ទឹក ពស់ខៀវ គ្រាន់មានខ្លះ ឯពិសនៃនាគមានក្បាលក្រហម មិនមានសោះឡើយ។

[៣៥៦] (អាលម្ពាយនព្រាហ្មណ៍...) ខ្ញុំបានស្ដាប់ពាក្យនេះរបស់ពួកព្រះអរហន្ត ដែលសង្រួមហើយ មានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើអ្នកមានវត្ថុតិចតួចដែលគួរឲ្យ អ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ។ នាគនេះ មានឫទ្ធិច្រើន មានតេជះដែលគេកន្លងបានដោយក្រ ខ្ញុំនឹងប្រើនាគនេះឲ្យចឹកអ្នក នាគនោះនឹងធ្វើអ្នកឲ្យទៅជាផេះ។

[៣៥៧] (សុទស្សននាគរាជ...) ម្នាលសម្លាញ់ ខ្ញុំក៏បានស្តាប់ពាក្យនេះរបស់ពួកព្រះអរហន្ត ដែលសង្រួមហើយមានតបៈថា ទាយកទាំងឡាយក្នុងលោកនេះ ឲ្យទានទាំងឡាយ រមែងទៅកាន់ឋានសួគ៌ ថាបើអ្នកមានវត្ថុតិចតួច ដែលគួរឲ្យអ្នកទាន់នៅរស់ ចូរឲ្យទានទាំងឡាយចុះ។ កូនកង្កែបនេះ ឈ្មោះអច្ចិមុខី ពេញដោយតេជះរបស់ពស់ដ៏ខ្ពង់ខ្ពស់ អាត្មានឹងប្រើនាងអច្ចិមុខីនោះ ឲ្យខាំអ្នក នាងអច្ចិមុខីនោះ នឹងធ្វើអ្នកឲ្យទៅជាផេះ។ នាងអច្ចិមុខីនោះ ជាធីតារបស់ព្រះបាទធតរដ្ឋ មានមាតាផ្សេងគ្នា ជាប្អូនស្រីរបស់អាត្មាដ៏ពេញដោយតេជះរបស់ពស់ដ៏ខ្ពង់ខ្ពស់ ចូរខាំចុះ។

[៣៥៨] បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅលើផែនដី ស្មៅ វល្លិ៍ ពួកឈើ ជាឱសថ នឹងស្វិតស្រពោនគ្មានសល់។

[៣៥៩] បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅខាងលើ ភ្លៀងនឹងមិនបង្អុរចុះ ទឹកសន្សើមនឹងមិនធ្លាក់ចុះអស់ ៧ ឆ្នាំ។

[៣៦០] បពិត្រព្រះអង្គ ព្រះនាមព្រហ្មទត្ត សូមទ្រង់ជ្រាបចុះ បើអាត្មាភាពសាចពិសទៅក្នុងទឹក ត្រី និងអណ្តើក ដែលជាសត្វកើតក្នុងទឹកទាំងប៉ុន្មាន នឹងស្លាប់ទាំងអស់។

[៣៦១] (ព្រាហ្មណ៍នេសាទ ...) ទឹកដែលតាំងនៅក្នុងកំពង់បយាគៈ ដែលអញកំពុងស្រោច ជាទឹកដែលលោកសន្មតថា សម្រាប់លាងបាប ចុះខ្មោចអ្វី ជ្រមុជអញចុះទៅក្នុងស្ទឹងយមុនាដ៏ជ្រៅ។

[៣៦២] (សុភោគនាគរាជ...) នាគណា ជាធំក្នុងលោក មានយស បានមកព័ទ្ធក្រុងពារាណសីដោយជុំវិញ អញជាកូននាគដ៏ប្រសើរនោះ ម្នាលព្រាហ្មណ៍ នាគទាំងឡាយ ហៅអញថា សុភោគដូច្នេះ។

[៣៦៣] (ព្រាហ្មណ៍នេសាទ...) បើអ្នកជាកូននៃនាគដ៏ប្រសើរ ជាព្រះរាជាក្នុងដែនកាសី ជាធំជាងនាគដែលមានអាយុវែង បិតារបស់អ្នកជានាគមានស័ក្តិធំមួយដែរ បណ្តាសត្វទាំងឡាយ មាតារបស់អ្នក ក៏មិនមានស្ត្រីណាផ្ទឹមបានឡើយ បុគ្គលមានអានុភាពច្រើនដូចអ្នក មិនគួរចាប់ជ្រមុជបុគ្គល សូម្បីជាទាសៈនៃព្រាហ្មណ៍ទេ។

[៣៦៤] (សុភោគនាគរាជ...) ឯងអែបដើមឈើ ហើយបាញ់ទ្រាយដែលមកផឹក (ទឹក) ទ្រាយនោះ ដែលឯងបាញ់ហើយ ក៏ងាកមើលដោយកំឡាំងនៃសរ ក៏ស្ទុះទៅកាន់ទីឆ្ងាយ។ ឯងបានឃើញទ្រាយនោះ ដួលក្នុងព្រៃធំហើយ ក៏នាំសាច់មួយអម្រែកចូលទៅកាន់ដើមជ្រៃ ក្នុងវេលាល្ងាច ជាឈើដែលគឹកកងដោយសត្វសេក និងសាលិកា មានស្លឹកលឿង ដេរដាសដោយពួរ ដែលសត្វតាវៅទំយំ ជាទីគួររីករាយ មានផែនដីដុះស្មៅខៀវជានិច្ច បងរបស់អញដែលមានអានុភាពច្រើន រុងរឿងដោយឫទ្ធិ និងយស ដែលពួកនាគកញ្ញាចោមរោមហើយ ក៏ប្រាកដដល់ឯងក្នុងទីនោះ។ ឯងនោះ ដែលបងរបស់អញនោះផ្គាប់ហើយ ឲ្យស្កប់ស្កល់ដោយកាមទាំងពួង ឯងបានប្រទូស្តចំពោះបងដែលមិនប្រទូស្ត ពៀរនោះមកដល់ឯងក្នុងទីនេះហើយ។ ឯងចូរដេក ក យ៉ាងឆាប់ អញនឹងមិនឲ្យជីវិតដល់ឯងទេ អញរឭកឃើញនូវពៀរ (ដែលឯងធ្វើ) ចំពោះបង អញនឹងកាត់ក្បាលឯងឥឡូវនេះ។

[៣៦៥] (ព្រាហ្មណ៍នេសាទ...) ព្រាហ្មណ៍ជាអ្នករៀនមន្ត ១ ជាអ្នកប្រកបដោយការសូម ១ ជាអ្នកបូជាភ្លើង ១ ព្រាហ្មណ៍ប្រកបដោយហេតុទាំង ៣ នេះ អ្នកមិនគួរសម្លាប់ទេ។

[៣៦៦] (សុភោគនាគរាជ...) បុរីណា របស់ព្រះបាទធតរដ្ឋ ជាវិការៈនៃមាសទាំងអស់ ដែលចូលទៅកាន់ស្ទឹងយមុនា ទល់នឹងភ្នំហិមពាន្តដែលនៅជិតស្ទឹងយមុនា រមែងរុងរឿង។ បងប្អូនរបស់អញទាំងនោះ ជាបុរសក្លៀវក្លា ជាអ្នករួមផ្ទៃ នៅក្នុងបុរីនោះ បងប្អូនទាំងនោះ ក្នុងបុរីនោះ និយាយយ៉ាងណា ឯងនឹងទៅជាយ៉ាងនោះ។

[៣៦៧] (កាណារិដ្ឋនាគរាជ...) បពិត្រសុភោគ យ័ញ្ញ និងវេទទាំងឡាយក្នុងលោកនេះ ដែលព្រាហ្មណ៍ឯទៀតប្រកបហើយ មិនមែនជារបស់ផ្តេសផ្តាសទេ ព្រោះហេតុនោះ បុគ្គលកាលតិះដៀលព្រាហ្មណ៍ដែលមិនគួរតិះដៀល ឈ្មោះថាលះបង់ទ្រព្យ និងធម៌របស់ពួកសប្បុរស។

[៣៦៨] ពួកអ្នកប្រសើរ (ព្រាហ្មណ៍) ប្រកាន់ខាងការរៀនមន្ត ពួកជាធំជាងជន (ក្សត្រិយ៍) ប្រកាន់ខាងការផែនដី ពួកវេស្សៈ ប្រកាន់ខាងការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ខាងការបម្រើផ្សេងៗគ្នា តាមសមគួរដល់ប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានតាក់តែងហើយ។

[៣៦៩] ទេវរាជព្រះនាមធាតុ វិធាតុ វរុណៈ កុវេរៈ សោមៈ យមៈ ចន្ទិមៈ វាយុ សុរិយៈ ស្តេចទាំងនេះ បានបូជាយ័ញ្ញដ៏ច្រើន ទាំង (បានឲ្យ) វត្ថុជាទីប្រាថ្នាគ្រប់យ៉ាង ដល់ពួកព្រាហ្មណ៍អ្នករៀនមន្ត។ ព្រះបាទអជ្ជុនណា មានកម្លាំង មានសេនាគួរខ្លាច មានដៃមួយពាន់(62) មិនមានបុគ្គលណាស្មើ លើផែនដី ជាអ្នកឃិតធ្នូ ៥០០ បាន ព្រះបាទអជ្ជុននោះឯង ក៏បូជាភ្លើងក្នុងកាលនោះដែរ។

[៣៧០] បុគ្គលណា មានចិត្តជ្រះថ្លា រីករាយ បានញ៉ាំងព្រាហ្មណ៍ឲ្យបរិភោគបាយ និងទឹក អស់កាលយូរ ដ៏សមគួរតាមអានុភាព បពិត្រសុភោគ បុគ្គលនោះ នឹងបានជាទេវតាមួយអង្គ។

[៣៧១] ព្រះបាទមុជលិន្ទ អាចញ៉ាំងទេវតាភ្លើង ជាអ្នកស៊ីច្រើន មានពន្លឺមិនថោកទាប ឲ្យស្កប់ស្កល់ដោយសប្បិ បានបូជាវិធីយ័ញ្ញចំពោះទេវតាភ្លើងដ៏ប្រសើរ ទ្រង់បានទៅកាន់គតិជាទិព្យ។

[៣៧២] ព្រះរាជា ព្រះនាមទុទីបៈ មានអានុភាពច្រើន មានព្រះជន្ម ១.០០០ ឆ្នាំ បានលះបង់ដែន ព្រមទាំងសេនា មិនមានទីបំផុតហើយបួស បានជាទក្ខិណេយ្យបុគ្គល គួររមិលមើលដ៏លើសលុប ទ្រង់បានទៅកាន់ឋានសួគ៌។

[៣៧៣] បពិត្រសុភោគ ព្រះបាទសាគរឈ្នះផែនដី មានសាគរជាទីបំផុត បានលើកសសរយ័ញ្ញដ៏ល្អ ជាវិការៈនៃមាសដ៏លើសលុបបូជាភ្លើង ទ្រង់បានជាទេវតាមួយអង្គ។ បពិត្រសុភោគ ទន្លេគង្គា ប្រព្រឹត្តទៅដោយអានុភាពនៃព្រះរាជាណា ទឹកដោះជូរដែលស្ងប់ស្ងៀមទៅជាសមុទ្រដោយអានុភាពនៃព្រះរាជាណា ព្រះរាជានោះ គឺព្រះបាទអង្គៈ មានរោមត្រង់ព្រះបាទ បម្រើភ្លើង ក៏ទ្រង់បានទៅកាន់បុរីនៃព្រះឥន្ទ្រ។

[៣៧៤] បពិត្រសុភោគ ទេវតាដ៏ប្រសើរ មានឫទ្ធិច្រើន មានយស ជាសេនាបតីនៃព្រះបាទវាសវៈ ក្នុងឋានត្រៃត្រឹង្ស ព្រោះតែបានកំចាត់បង់នូវមន្ទិល ដោយសោមយាគវិធី ក៏បានជាទេវតាមួយអង្គ។

[៣៧៥] ទេវតាដ៏ប្រសើរ ព្រហ្មមានឫទ្ធិច្រើន មានយស បានសាងលោកនេះ និងលោកដទៃ និងស្ទឹងភាគីរថីផង ភ្នំហិមពាន្តផង ភ្នំវិជ្ឈៈផង ព្រហ្មនោះឯង ក៏បានបូជាភ្លើងក្នុងកាលនោះដែរ។ ម្យ៉ាងទៀត ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១ ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ពួកព្រាហ្មណ៍ពោលថា ភ្នំទាំងនេះក្តី ភ្នំដទៃធំៗក្តី ពួកព្រាហ្មណ៍អ្នកបូជាយ័ញ្ញ បានធ្វើឲ្យវិចិត្រហើយ។

[៣៧៦] ជនទាំងឡាយ បានពោលចំពោះព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈក្នុងលោកនេះ ថាជាអ្នកប្រកបដោយការសូម សាគរបានពន្លិចព្រាហ្មណ៍នោះ ដែលឋិតនៅលើត្រើយ កំពុងសាចទឹកសមុទ្រ ហេតុនោះ បានជាសមុទ្រមានទឹកប្រៃផឹកមិនបាន។

[៣៧៧] ព្រាហ្មណ៍ទាំងឡាយ ជាវត្ថុសម្រាប់បូជា មានច្រើនលើផែនដី មានក្នុងទិសខាងកើត ទិសខាងលិច ទិសខាងត្បូង និងទិសខាងជើង តែងញុំាងសេចក្តីត្រេកអរឲ្យកើតដល់វាសវៈ។

[៣៧៨] (ភូរិទត្តនាគរាជ...) ម្នាលអរិដ្ឋ ការរៀនយកនូវវេទទាំងឡាយ ជាទោសរបស់អ្នកប្រាជ្ញទាំងឡាយ តែជាអំពើរបស់បុគ្គលពាលទាំងឡាយ (ត្រៃវេទ) ជាធម៌ ដូចថ្ងៃបណ្តើរកូន ព្រោះសំឡឹងមើលទៅ មិនស្មើវេទទាំងឡាយ ជាចំណែកនៃកលឧបាយ ទងទាញអ្នកមានបញ្ញាមិនបានទេ ការពារជនអ្នកទ្រុស្តមិត្រ បំផ្លាញសេចក្តីចំរើននោះ ក៏មិនបានទេ ភ្លើងដែលបុគ្គលបម្រើហើយ រមែងមិនការពារនូវសត្វមានកម្មបានទេ ជារបស់មិនប្រសើរ ប្រកបដោយទោស។ មួយទៀត សត្វទាំងឡាយ មានទ្រព្យ មានភោគៈ យកទ្រព្យទាំងអស់លាយដោយឧស និងស្មៅហើយដុតភ្លើង មានតេជៈ មិនមានអ្វីស្មើ កាលឆេះវត្ថុដែលគេដុតហើយ ក៏មិនគប្បីឆ្អែត ម្នាលអ្នកដឹងរសដោយអណ្តាតទាំងពីរ ចុះបុគ្គលណា គប្បីធ្វើភ្លើងនោះឲ្យឆ្អែតបាន។ ខីរៈ មានការប្រែប្រួលជាធម្មតា ក្លាយទៅជាទធិ ហើយទៅជានវនីតយ៉ាងណា ភ្លើងជាតេជោធាតុ មានការប្រែប្រួលជាធម្មតា យ៉ាងនោះដែរ លុះតែប្រកបដោយគ្រឿងពួត ទើបឆេះ។ ភ្លើងដែលចូលទៅក្នុងឈើស្ងួត ឬឈើស្រស់ក៏មិនប្រាកដ ភ្លើងដែលនរជនមានឈើពំនួតក្នុងដៃ មិនបានពួត ក៏មិនឆេះ ភ្លើងមិនមែនឆេះដោយការមិនធ្វើទេ។ ប្រសិនបើភ្លើងនៅក្នុងឈើស្ងួត ឬឈើស្រស់ នៅខាងក្នុង នៅក្នុងព្រៃទាំងអស់ក្នុងលោក គប្បីស្ងួតក្រៀម ឯឈើស្ងួតទាំងឡាយគប្បីឆេះ។ ថាបើ នរជនញុំាងភ្លើងដ៏ក្តៅ ប្រកបដោយផ្សែង និងអណ្តាត ឲ្យស៊ីដោយឧស និងស្មៅ ឈ្មោះថា ធ្វើបុណ្យឬ ជនអ្នកធ្វើធ្យូង អ្នកធ្វើអំបិល អ្នកធ្វើអាហារ និងអ្នកដុតសរីរៈនៃបុគ្គលស្លាប់ ឈ្មោះថា ធ្វើបុណ្យដែរឬ។ ប្រសិនបើព្រាហ្មណ៍ទាំងនុ៎ះ ញុំាងការរៀនមន្តនឹងភ្លើងឲ្យឆ្អែតក្នុងលោកនេះ ទើបឈ្មោះថាធ្វើបុណ្យ នរជនណាមួយក្នុងលោក កាលញុំាងភ្លើងមានកំដៅប្រកបដោយផ្សែង និងអណ្តាតឲ្យស៊ី មិនឈ្មោះថាធ្វើបុណ្យទេ។ ម្នាលអ្នកដឹងរសដោយអណ្តាតពីរ (អគ្គិទេពរបស់អ្នក) ដែលលោកគោរពហើយ ម្តេចក៏ស៊ីវត្ថុមានក្លិនមិនជាទីគាប់ចិត្ត មិនជាទីត្រេកអរនៃជនដ៏ច្រើន ដែលពួកមនុស្សតែងវៀរ ជាវត្ថុមិនប្រសើរនោះ។ មនុស្សពួកខ្លះ ពោលថាភ្លើង (ជាទេវតាមួយអង្គ) ក្នុងពួកទេវតា ឯពួកមិលក្ខជនពោលថា ទឹកជាទេវតា ជនទាំងអស់នុ៎ះពោលខុស ភ្លើងមិនមែនជាទេវតាណាមួយទេ ទឹកក៏មិនមែនដែរ។ ភ្លើងមិនមានឥន្ទ្រិយ ជាពួកមិនមានចេតនា សម្រាប់ធ្វើការងាររបស់ពួកមនុស្ស អ្នកធ្វើបាបកម្មទាំងឡាយ កាលបម្រើភ្លើង គប្បីទៅកាន់សុគតិដូចម្តេចកើត។ ពួកព្រាហ្មណ៍ជាអ្នកត្រូវការដោយជីវិតក្នុងលោកនេះ ពោលថា (មហាព្រហ្ម) ជាអ្នកគ្របសង្កត់លោកទាំងអស់ ហើយពោលថា ព្រហ្មជាអ្នកបម្រើភ្លើងដូច្នេះ បើ (មហាព្រហ្ម) មានអានុភាពជាងលោកទាំងអស់ មានអំណាច មិនមានអ្នកណាសាង ហេតុអ្វីក៏សំពះភ្លើងដែលខ្លួននិម្មិតវិញ។ ពាក្យព្រាហ្មណ៍ ជាពាក្យគួរសើច មិនគួរដល់ការពិនិត្យ ជាពាក្យមិនពិត ពួកព្រាហ្មណ៍ក្នុងកាលមុន តាក់តែង (ពាក្យមិនពិត) ព្រោះហេតុនៃសក្ការៈ ព្រាហ្មណ៍ទាំងនោះ កាលបើលាភសក្ការៈមិនកើតឡើងទេ ក៏តនូវសន្តិធម៌ពោលគឺ លទ្ធិរបស់ខ្លួនជាមួយនឹងពួកសត្វ។ ពួកអ្នកប្រសើរ (ព្រាហ្មណ៍) ប្រកាន់ការរៀនមន្ត ពួកជាធំជាងដែន (ក្សត្រិយ៍) ប្រកាន់ផែនដី ពួកវេស្សៈប្រកាន់ការភ្ជួររាស់ ពួកសូទ្រៈប្រកាន់ការបម្រើ ផ្សេងៗគ្នា សមគួរតាមប្រទេស ជនទាំងឡាយបានពោលថា ត្រកូលទាំង ៤ នេះ ព្រហ្មបានតាក់តែងហើយ។ ប្រសិនបើពាក្យនុ៎ះ ជាពាក្យពិត ដូចយ៉ាងពាក្យដែលព្រាហ្មណ៍ទាំងឡាយ ពោលហើយនេះ បុគ្គលមិនមែនជាក្សត្រិយ៍ មិនត្រូវបានរាជ្យដោយដាច់ខាត បុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីសិក្សានូវបទនៃមន្ត បុគ្គលវៀរចាកពួកវេស្សៈ មិនគប្បីធ្វើការភ្ជួររាស់ ពួកសូទ្រៈមិនគប្បីរួចអំពីការប្រើនៃជនដទៃ។ ពាក្យនេះ ជាពាក្យមិនពិត ព្រោះហេតុណា (ហេតុនោះ) ព្រាហ្មណ៍ទាំងនេះពោលពាក្យកុហកដើម្បីការបំពេញផ្ទៃ បុគ្គលអ្នកមិនមានប្រាជ្ញាទាំងឡាយ រមែងជឿងស៊ប់នូវពាក្យនោះ ចំណែកខាងពួកបណ្ឌិតរមែងឃើញហេតុនោះ ដោយខ្លួនឯង។ ពួកក្សត្រិយ៍នាំយកពលី (ហូតពន្ធ) របស់ពួកវេស្សៈ ពួកព្រាហ្មណ៍ កាន់យកគ្រឿងសស្ត្រាទាំងឡាយ ហើយដើរទៅ (សម្លាប់សត្វ) ហេតុអ្វី ព្រហ្មមិនធ្វើលោកដែលជ្រុលជ្រើម បែកខ្ញែកបែបនោះៗ ឲ្យត្រង់។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុងលោកទាំងអស់ ហេតុអ្វី ក៏ចាត់ចែងលោកទាំងអស់ឲ្យមានទុក្ខ ហេតុអ្វីមិនធ្វើលោកទាំងអស់ឲ្យបានសេចក្តីសុខ។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុងលោកទាំងអស់ ហេតុអ្វីក៏ធ្វើលោកឲ្យវិនាស ដោយកលឧបាយ និងការញ៉ាំញី ដោយការពោលពាក្យកុហក ដែលមិនមែនជាធម៌។ ប្រសិនបើព្រហ្មជាឥស្សរៈនោះ ជាប្រធាន ជាម្ចាស់លើភូតរបស់ពួកសត្វក្នុងលោកទាំងអស់ ម្នាលអរិដ្ឋ ព្រហ្មជាម្ចាស់លើភូត មិនប្រកបដោយធម៌ទេ ព្រោះកាលបើធម៌មានបែរជាចាត់ចែងអធម៌វិញ។ បុគ្គលសម្លាប់កណ្តាប កន្ទំរុយ ពស់ កង្កែប ដង្កូវ រុយ ទើបឈ្មោះថា បរិសុទ្ធ ឯធម៌ទាំងនេះ ជាធម៌របស់ពួកជនអ្នកនៅក្នុងដែនកម្ពុជៈដ៏ច្រើន ជាធម៌មានសភាពមិនប្រសើរ ជាធម៌មិនពិត។

[៣៧៩] ប្រសិនបើអ្នកសម្លាប់នោះ បរិសុទ្ធ ឬអ្នកដែលត្រូវសម្លាប់នោះ ទៅកាន់ឋានសួគ៌បាន ពួកព្រាហ្មណ៍ គប្បីសម្លាប់ពួកព្រាហ្មណ៍ ឬសម្លាប់ពួកជនអ្នកជឿពាក្យព្រាហ្មណ៍នោះ (មុន)។ មិនមានពួកម្រឹគ មិនមានពួកសត្វចិញ្ចឹម ពួកគោណាមួយអង្វរឲ្យសម្លាប់ខ្លួនទេ សត្វទាំងឡាយក្នុងលោកនេះ សុទ្ធតែញាប់ញ័រ ត្រូវការដោយជីវិត (ព្រោះថា) ជនទាំងឡាយ ប្រារព្ធនឹងសម្លាប់សត្វទាំងឡាយ និងសត្វចិញ្ចឹម ក្នុងយ័ញ្ញទាំងឡាយ។ ពួកបុគ្គលពាល រមែងបើកមាត់និយាយ ដោយហេតុទាំងឡាយដ៏វិចិត្រ ក្នុងការលើកឡើងនូវសសរយ័ញ្ញៈ និងទីចងនៃសត្វចិញ្ចឹមថា សសរយ័ញ្ញនេះ បង្ហូរសេចក្តីប្រាថ្នាដល់អ្នក ក្នុងបរលោក នឹងឲ្យសេចក្តីទៀងទាត់ក្នុងបរលោក។ ប្រសិនបើបុគ្គលគប្បីបានកែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ និងមាស ក្នុងសសរយ័ញ្ញ ក្នុងឈើស្ងួត និងឈើស្រស់ ម្យ៉ាងទៀត ប្រសិនបើសសរយ័ញ្ញ គប្បីបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ ពួកជនអ្នកចេះត្រៃវេទដ៏ច្រើន គប្បីបូជា បុគ្គលមិនមែនជាព្រាហ្មណ៍ មិនគប្បីបូជាតិចតួចទេ។ កែវមណី ស័ង្ខ កែវមុក្តា ស្រូវ ទ្រព្យ ប្រាក់ មាស ក្នុងសសរយ័ញ្ញ ក្នុងឈើស្ងួត នឹងឈើស្រស់ នឹងមានពីណា សសរយ័ញ្ញនឹងបង្ហូរសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងឋានសួគ៌ដូចម្តេចកើត។ ពួកព្រាហ្មណ៍ ជាអ្នកបោកប្រាស ចិត្តអាក្រក់ ជាពួកពាល ប្រលោមលោកតែងបើកមាត់និយាយដោយហេតុដ៏វិចិត្រថា អ្នកឯងចូរយកភ្លើងចុះ ហើយឲ្យទ្រព្យដល់យើង លំដាប់នោះ អ្នកឯងនឹងបាននូវសេចក្តីប្រាថ្នាគ្រប់យ៉ាងហើយ នឹងដល់នូវសេចក្តីសុខ។ ពួកព្រាហ្មណ៍នាំបុគ្គលជាសរណៈ (ព្រះរាជា និងមហាមាត្យ) ចូរទៅកាន់រោងសម្រាប់បូជាភ្លើងនោះ ក៏បើកមាត់និយាយដោយហេតុដ៏វិចិត្រ ឲ្យកោរសក់ ពុកមាត់ កាត់ក្រចក ហើយគាបយកទ្រព្យដោយវេទទាំងឡាយ។ ពួកព្រាហ្មណ៍ ជាអ្នកកុហកដ៏ច្រើន បានទាយកម្នាក់ ហើយក៏ចោមស៊ីបាយ ដូចជាក្អែកទាំងឡាយ ចោមចាប់មៀមក្នុងទីស្ងាត់ កុហកធ្វើឲ្យរលីង ហើយដាក់ចុះទៅក្នុងផ្លូវនៃយ័ញ្ញ។ ទាយកតែម្នាក់នោះ ត្រូវពួកព្រាហ្មណ៍បញ្ឆោតហើយដោយអាការយ៉ាងនេះឯង ព្រាហ្មណ៍ទាំងនោះជាច្រើន ចោមប្លន់ដោយការប្រកបដោយឧបាយ ក៏នាំយកទ្រព្យដែលឃើញដោយទេវលោក ដែលមិនឃើញសោះ។ ដូចយ៉ាងពួករាជបុរស ដែលព្រះរាជាប្រើទៅហើយ ក៏នាំយកទ្រព្យនោះរបស់គេ ម្នាលអរិដ្ឋ ពួកព្រាហ្មណ៍ប្រាកដដូច្នោះ ប្រហែលគ្នានឹងពួកចោរ ជាអសប្បុរស ជាបុគ្គលគួរសម្លាប់ តែគេមិនសម្លាប់ក្នុងលោក។ ពួកព្រាហ្មណ៍ បានកាត់ដើមចា មកប្រើក្នុងវិធីយ័ញ្ញ (ប្រាប់ថា នេះ) ជាដៃស្តាំរបស់ព្រះឥន្ទ្រ បើពាក្យនោះពិត ព្រះឥន្ទ្រទៅជាដាច់ដៃ ចុះព្រះឥន្ទ្រឈ្នះពួកអសុរ ដោយកម្លាំងដៃដូចម្តេច។ ពាក្យនោះទទេសោះ ព្រះឥន្ទ្រនៅមានដើមដៃគ្រប់គ្រាន់ ជាទេវតាដ៏ប្រសើរ មិនមានអ្នកណាសម្លាប់បាន បានកំចាត់ពួកអសុរ មន្តទាំងឡាយនេះ របស់ពួកព្រាហ្មណ៍មានសភាពជារបស់ទទេ នេះជាការបញ្ឆោត ដែលគេឃើញច្បាស់ក្នុងលោក។ ភ្នំមាលាគិរី ១ ភ្នំហិមពាន្ត ១ ភ្នំវិជ្ឈៈ ១ ភ្នំសុទស្សនៈ ១

ភ្នំនិសភៈ ១ ភ្នំកាកវេរុ ១ ភ្នំទាំងនុ៎ះក្តី ភ្នំធំ ៗ ឯទៀតក្តី ព្រាហ្មណ៍ទាំងឡាយពោលថា ពួកព្រាហ្មណ៍អ្នកបូជាយ័ញ្ញកសាងហើយ ដ៏វិចិត្រដូច្នោះ។ ព្រាហ្មណ៍ទាំងឡាយពោលថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយ័ញ្ញ កាន់យកឥដ្ឋទាំងឡាយ មានបការៈយ៉ាងណា ធ្វើវិចិត្រហើយ ភ្នំទាំងឡាយ មិនមែនមានបការៈដូច្នោះទេ ឯភ្នំទាំងឡាយ មិនដូចរបស់ដទៃទេ ជារបស់មិនកម្រើក ជាថ្មសុទ្ធដែលគេឃើញច្បាស់។ ភ្នំទាំងឡាយមិនមែនជាឥដ្ឋទេ ជាថ្មយូរយារហើយ ដែក មិនមែនកើតក្នុងឥដ្ឋនោះទេ លោហៈ ក៏មិនមែនកើតក្នុងឥដ្ឋនោះដែរ ពួកព្រាហ្មណ៍កាលសសើរនូវយ័ញ្ញនេះ បានពោលថា ភ្នំទាំងឡាយ ដែលពួកព្រាហ្មណ៍អ្នកបូជាយ័ញ្ញ ធ្វើវិចិត្រហើយ។ ព្រាហ្មណ៍ទាំងឡាយក្នុងលោកនេះ បានពោលនូវព្រាហ្មណ៍អ្នករៀនមន្ត បរិបូណ៌ដោយគុណនៃមន្ត មានតបៈ ថាជាអ្នកប្រកបដោយការស្ងួម សាគរពន្លិចព្រាហ្មណ៍នោះ ដែលកំពុងសាចទឹកនៃសមុទ្រលើច្រាំង ព្រោះហេតុនោះ បានជាទឹកសមុទ្រនោះប្រៃ ផឹកមិនបាន។ ស្ទឹងទាំងឡាយកួចយកពួកព្រាហ្មណ៍ អ្នកបរិបូណ៌ដោយវេទ បរិបូណ៌ដោយមន្ត ច្រើនជាងពាន់នាក់ ទឹកទាំងឡាយមិនខូចរស ព្រោះហេតុនោះទេ សមុទ្រមិនមានអ្វីស្មើ មានរសប្រៃ ផឹកមិនបាន តើព្រោះហេតុអ្វី។ អណ្តូងខ្លះ ក្នុងជីវលោកនេះ មានទឹកប្រៃ ដែលពួកជនអ្នកផឹកអណ្តូងបានផឹកហើយ ម្នាលអ្នកដឹងរសដោយអណ្តាតទាំងពីរ ជនទាំងឡាយមិនពោលថា ទឹកក្នុងអណ្តូងទាំងនោះ មានរសប្រៃ ផឹកមិនបាន ព្រោះតែកួចយកព្រាហ្មណ៍ទេ។ តាំងពីមុនដម្បូងមក ស្ត្រីណា ជាភរិយារបស់បុរសណា មនោបានញ៉ាំងមនុស្សឲ្យកើតឡើងក្នុងកាលមុន មិនមានអ្នកណាមួយ ថោកទាបជាងគ្នា ដោយធម៌នោះ ព្រាហ្មណ៍ទាំងឡាយបានពោលនូវការចែក (វណ្ណៈ) ដោយការលះបង់ (ធម៌នោះ) យ៉ាងនេះឯង។ សូម្បីកូនចណ្ឌាល ជាអ្នកឈ្លាសវៃ មានប្រាជ្ញា បានរៀនវេទទាំងឡាយ ពោលមន្តទាំងឡាយ ក្បាលនៃកូនជនចណ្ឌាលនោះ មិនបែកជា ៧ ភាគទេ មន្តទាំងនេះ ពួកព្រាហ្មណ៍ធ្វើហើយ ដើម្បីសម្លាប់ខ្លួន។ វាចាកុហក ពួកព្រាហ្មណ៍ បានតាក់តែងហើយ ការចង់បាន ពួកព្រាហ្មណ៍បានតាក់តែង កាន់យកហើយ កើតឡើងតាមគន្លងនៃកាព្យឃ្លោង ដែលគេស្រាយបានដោយក្រ ចិត្តរបស់បុគ្គលពាលទាំងឡាយ ជឿស៊ប់ក្នុងអំពើមិនស្មើ បុគ្គលឥតប្រាជ្ញា រមែងជឿពាក្យនោះ។ ព្រាហ្មណ៍មិន (ប្រកប) ដោយកម្លាំងដ៏មាំ ដូចកម្លាំងនៃរាជសីហ៍ ខ្លាធំ និងខ្លាដំបង មនុស្សភាព (របស់ព្រាហ្មណ៍ទាំងនោះ) ត្រូវយល់ថា ដូចគោដែរ ព្រោះជាតិរបស់ព្រាហ្មណ៍ទាំងនោះស្មើ (ដោយគោ) ស្មើដោយសីហៈជាដើម។ ប្រសិនបើព្រះរាជាឈ្នះផែនដី ប្រកបដោយអាមាត្យ មានអ្នកស្តាប់បង្គាប់ មានបរិស័ទ ព្រះរាជានោះ គប្បីឈ្នះពួកសត្រូវដោយព្រះអង្គឯង ប្រជាជនរបស់ព្រះរាជានោះ គប្បីបានសេចក្តីសុខជានិច្ច។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ (តែក្សត្រិយ៍ក្តី ព្រាហ្មណ៍ក្តី) មិនបានវិនិច្ឆ័យនូវអត្ថនៃមន្ត និងវេទទាំងនោះទេ ទាំងមិនដឹង ដូចបុគ្គលកាលមិនដឹងផ្លូវ ដែលកំបាំងដោយទឹក។ មន្តរបស់ក្សត្រិយ៍ និងវេទទាំង ៣ នេះ ស្មើគ្នាដោយអត្ថ លាភ ឥតលាភ យស និងឥតយស ទាំងអស់នេះ ជាធម៌របស់វណ្ណៈទាំង ៤ នោះ។ ពួកគហបតីជាច្រើនលើផែនដី ញ៉ាំងបុគ្គលឲ្យធ្វើការងារទាំងឡាយ ព្រោះហេតុតែទ្រព្យ និងស្រូវ យ៉ាងណា សូម្បីពួកអ្នកមានត្រៃវេទ ជាច្រើនលើផែនដី ក៏ញ៉ាំងបុគ្គលឲ្យធ្វើការងារទាំងឡាយ ក្នុងថ្ងៃនេះ យ៉ាងនោះដែរ។ ព្រាហ្មណ៍ទាំងនោះ ស្មើគ្នានឹងគហបតី ព្រាហ្មណ៍ទាំងឡាយជាច្រើនលើផែនដី ជាអ្នកខ្វល់ខ្វាយជានិច្ច ប្រកបក្នុងកាមគុណទាំងឡាយ តែងញ៉ាំងបុគ្គលឲ្យធ្វើការងារទាំងឡាយ ម្នាលអរិដ្ឋ អ្នកដឹងរសដោយអណ្តាតទាំងពីរ ព្រោះហេតុនោះ ព្រាហ្មណ៍ទាំងនោះ ជាអ្នកឥតបញ្ញា។

[៣៨០] (ព្រះបាទសាគរព្រហ្មទត្ត...) ស្គរធំ សម្ភោរ ស័ង្ខ ស្គរជ័យ និងស្គរទ័ពរបស់អ្នកណា ដែលដើរខាងមុខ ហើយញ៉ាំងព្រះរាជាដ៏ប្រសើរក្នុងរថឲ្យរីករាយ។ (សម្បុរមុខ) របស់អ្នកណា (ដ៏រុងរឿង) ដោយដម្បារមាសដ៏ក្រាស់ មានពន្លឺដូចផ្លេកបន្ទោរ អ្នកណានៅកម្លោះ ប្រដាប់ដោយបំពង់ព្រួញ រុងរឿងដោយសិរី ហើយដើរមក។ មុខអ្នកណាស្រស់បស់ដូចមាសឆ្អិនលើមាត់ជើងក្រាន ឬប្រាកដស្មើដោយរងើកនៃឧសគគីរ អ្នកណារុងរឿងដោយសិរីហើយដើរមក។ ឆត្ររបស់បុគ្គលណា ជាវិការៈនៃមាសជម្ពូនទ ប្រកបដោយឆ្អឹង ជាទីរីករាយនៃចិត្ត ជាគ្រឿងបិទបាំងរស្មីនៃព្រះអាទិត្យ អ្នកណារុងរឿងដោយសិរីហើយដើរមក។ អង្គ (អ្នកកាន់ផ្លិត) បានកាន់យកវាលវិជនីដ៏ឧត្តម ខាងលើក្បាលទាំងពីរខាងនៃបុគ្គលមានបញ្ញាដ៏ប្រសើរណា។ បាច់នៃកន្ទុយក្ងោកដ៏វិចិត្រផង ទន់ផង មានដងជាវិការៈនៃមាស និងកែវមណី ប្រព្រឹត្តទៅទាំងពីរខាងមុខរបស់បុគ្គលណា។ កុណ្ឌលទាំងឡាយនេះ ដ៏ល្អមានពន្លឺដូចជាពណ៌រងើកភ្លើងនៃឧសគគីរ ដ៏ភ្លឺលើមាត់ជើងក្រាន រមែងរុងរឿងទាំងពីរខាងមុខរបស់បុគ្គលណា។ សក់របស់បុគ្គលណា មានចុងដ៏ស្និទ្ធ ទន់ខ្មៅ ត្រូវខ្យល់បក់ហើយ ក៏ញ៉ាំងទីបំផុតនៃថ្ងាសឲ្យល្អ ដូចជាផ្លេកបន្ទោរដែលចេញអំពីមេឃ។ ភ្នែកទាំងនេះ វែងធំរបស់អ្នកណា អ្នកណាមានភ្នែកទូលាយសម មុខនេះរបស់អ្នកណា ភ្លឺផ្លេះដូចកញ្ចក់មាស មាត់នេះរបស់អ្នកណាដ៏ស្អាត ដូចជាស័ង្ខដ៏ប្រសើរ ធ្មេញរបស់បុគ្គលណា កាលនិយាយឡើង ដូចជាផ្កាមណ្ឌាក្រពុំ។ ដៃ និងជើងទាំងឡាយរបស់អ្នកណា ដូចជាទឹកល័ក្ត តាំងនៅក្នុងសេចក្តីសុខ អ្នកណាមានរិមបបូរមាត់ដូចផ្លែបាសដ៏ល្អ ដូចជាព្រះអាទិត្យក្នុងវេលាថ្ងៃ។ អ្នកណាមានសំពត់បាវារៈដ៏ស ដូចដើមរាំងដ៏ធំ មានផ្ការីកហើយ ក្នុងព្រៃហិមពាន្តក្នុងកាលដែលកន្លងទៅនៃទឹកសន្សើម ល្អដូចព្រះឥន្ទ្រ ដែលមានជ័យជំនះ។ អ្នកណានៅក្នុងបរិស័ទ ដោះដាវនៅលើស្មា ដែលមានដងដ៏វិចិត្រដោយកែវមណីដ៏ដេរដាសដោយពកជាវិការៈនៃមាស។ អ្នកណាដោះស្បែកជើង ដែលប៉ាក់ដោយមាស វិចិត្រដោយកែវ ៧ ប្រការ ដេរដោយសូត្រដ៏វិចិត្ររចនាល្អហើយ ក៏ថ្វាយបង្គំតាបស អ្នកស្វែងរកគុណដ៏ធំ។

[៣៨១] (តាបស ជាបិតា...) នាគទាំងនោះ ជានាគមានឫទ្ធិ មានយស ជាកូននៃព្រះបាទធតរដ្ឋ កើតអំពីនាងសមុទ្ទជា នាគទាំងនេះសុទ្ធតែជានាគមានឫទ្ធិច្រើន។

ចប់ ភូរិទត្តជាតក ទី៦។

## ចន្ទកុមារជាតក ទី៧

CS sut.kn.jat.544 | ភាគទី ៦២

### (៥៤៤. ចន្ទកុមារជាតកំ (៧))

[៣៨២] (អភិសម្ពុទ្ធគាថា) ព្រះបាទឯករាជ អ្នកមានអំពើអាក្រក់ នៅក្នុងក្រុងបុប្ផវតីនោះ សួររកផ្លូវទៅព្រហ្មលោក និងបុរោហិត ឈ្មោះខណ្ឌហាល ជាពូជពង្សព្រហ្ម ជាមនុស្សល្ងង់វង្វេងថា ម្នាលព្រាហ្មណ៍ អ្នកជាមនុស្សឈ្លាសក្នុងធម៌វិន័យ សូមអ្នកប្រាប់ផ្លូវឋានសួគ៌ តាមទំនងដែលពួកជនធ្វើបុណ្យទាំងឡាយ ហើយចេញចាកលោកនេះ ទៅកាន់សុគតិដូច្នោះ។

[៣៨៣] (ខណ្ឌហាលព្រាហ្មណ៍បុរោហិតទូលថា) បពិត្រព្រះទេវៈ ពួកជនធ្វើបុណ្យទាំងឡាយ ឲ្យទានដ៏ក្រៃលែង សម្លាប់បុគ្គលដែលមិនគួរសម្លាប់ទាំងឡាយ ហើយទៅកាន់សុគតិយ៉ាងនេះ។

[៣៨៤] (ព្រះបាទឯករាជ...) ទានដ៏ក្រៃលែងនុ៎ះដូចម្តេច ក្នុងលោកនេះ បុគ្គលទាំងឡាយដូចម្តេច ដែលមិនគួរសម្លាប់ ចូរអ្នកប្រាប់សេចក្តីនុ៎ះដល់យើង យើងនឹងបូជា នឹងឲ្យទានទាំងឡាយ។

[៣៨៥] (ខណ្ឌហាលព្រាហ្មណ៍...) បពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជាដោយព្រះរាជបុត្រទាំងឡាយផង ដោយព្រះអគ្គមហេសីទាំងឡាយផង ដោយអ្នកនិគម (សេដ្ឋី) ទាំងឡាយផង បពិត្រព្រះទេវៈ ព្រះអង្គគប្បីបូជាដោយគោឧសភ សេះអាជានេយ្យបួន ៗ ដោយពួកសត្វបួន ៗ ទាំងអស់។

[៣៨៦] សំឡេងគឹកកងតែមួយ សំឡេងគួរខ្លាច លាន់ឮឡើងក្នុងវាំង ព្រោះឮព្រះរាជឱង្ការនោះថា ព្រះកុមារទាំងឡាយ និង

ព្រះអគ្គមហេសីទាំងឡាយ ត្រូវសម្លាប់។

[៣៨៧] (ព្រះរាជា...) អ្នកទាំងឡាយ ចូរទៅប្រាប់កុមារទាំងឡាយ គឺចន្ទកុមារ ១ សុរិយកុមារ ១ ភទ្ទសេនកុមារ ១ សុរកុមារ ១ វាមគោត្តកុមារ ១ ថា អ្នកទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញ។

[៣៨៨] អ្នកទាំងឡាយ ចូរប្រាប់កុមារីទាំងឡាយ គឺកុមារីឈ្មោះឧបសេនា ១ កោកិលា ១ មុទិតា ១ នន្ទា ១ ថា នាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញ។

[៣៨៩] អ្នកទាំងឡាយ ចូរប្រាប់មហេសីអញ គឺនាងវិជយា ១ នាងឯរាវតី ១ នាងកេសិនី ១ នាងសុនន្ទា ១ ដែលជាស្រ្តីបរិបូណ៌ដោយលក្ខណៈដ៏ប្រសើរថា នាងទាំងឡាយ ចូរមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញ។

[៣៩០] អ្នកទាំងឡាយ ចូរប្រាប់គហបតីទាំងឡាយ គឺគហបតីឈ្មោះបុណ្ណមុខៈ ១ ភទ្ទិយៈ ១ សិង្គាលៈ ១ វឌ្ឍៈ ១ ថា ចូរអ្នកទាំងឡាយមកជួបជុំគ្នា ដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញ។

[៣៩១] (អភិសម្ពុទ្ធគាថា) ពួកគហបតីទាំងនោះ មកជួបជុំគ្នា ដេរដាសដោយកូន និងប្រពន្ធក្នុងទីនោះ ក្រាបបង្គំទូលថា បពិត្រព្រះទេវៈ សូមព្រះអង្គធ្វើយើងខ្ញុំទាំងអស់ ឲ្យមានជុកលើក្បាលវិញ ពុំនោះសោត សូមព្រះអង្គប្រកាសនូវយើងខ្ញុំថាជាទាសៈ។

[៣៩២] (ព្រះរាជា...) អ្នកទាំងឡាយ ចូរនាំមកនូវដំរីរបស់អញឈ្មោះអភយង្ករៈ ១ នាឡាគិរី ១ អច្ចុគ្គតៈ ១ (ឈ្មោះវរុណទន្តៈ) ១ ដំរីទាំងឡាយនោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញយ៉ាងឆាប់។ អ្នកទាំងឡាយ ចូរនាំមកនូវសេះកែវរបស់អញ គឺសេះឈ្មោះកេសី ១ សុរាមុខៈ ១ បុណ្ណកៈ ១ វិនតកៈ ១ សេះទាំងឡាយនោះ នឹងជាសត្វដើម្បីប្រយោជន៍ដល់ការបូជាយ័ញ្ញយ៉ាងឆាប់។ អ្នកទាំងឡាយ ចូរនាំយកគោឧសភទាំងនោះរបស់អញ គឺគោឧសភឈ្មោះយូថបតិ ១ អនោជៈ ១ និសភៈ ១ គវម្បតិ ១ មកដល់អញ ជនទាំងឡាយ ចូរធ្វើកិច្ចការទាំងពួងក្នុងទីចំពោះមុខអញ និងបូជា និងឲ្យទានទាំងឡាយ។ អ្នកទាំងឡាយ ចូរតាក់តែងគ្រឿងបូជាគ្រប់មុខ កាលបើព្រះអាទិត្យរះឡើងហើយ អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់ពួកកុមារ មានចន្ទកុមារជាដើមថា កុមារទាំងឡាយ ចូររីករាយអស់ ១ យប់នេះចុះ។ អ្នកទាំងឡាយ ចូរដំកល់ទុកនូវគ្រឿងយ័ញ្ញគ្រប់មុខ កាលបើព្រះអាទិត្យរះឡើង អញនឹងបូជា អ្នកទាំងឡាយ ចូរប្រាប់កុមារទាំងឡាយក្នុងកាលឥឡូវនេះថា រាត្រីថ្ងៃនេះឯង ជារាត្រីបំផុត។

[៣៩៣] (អភិសម្ពុទ្ធគាថា) ព្រះរាជមាតា (ព្រះបាទឯករាជ) ទ្រង់ព្រះកន្សែង ទ្រង់ស្តេចមកអំពីវិមាន ទ្រង់មានព្រះរាជសវនីយ៍ សួរនូវសេចក្តីនោះនឹងព្រះរាជានោះថា នៃកូន ឮថា កូនឯងនឹងបូជាយ័ញ្ញ ដោយព្រះរាជបុត្រទាំង ៤ នាក់មែនឬ។

[៣៩៤] (ព្រះបាទឯករាជ...) កាលបើខ្ញុំសម្លាប់ចន្ទកុមារហើយ បុត្ររបស់ខ្ញុំទាំងអស់ ក៏ខ្ញុំលះបង់ដើម្បីបូជាយ័ញ្ញដែរ លុះខ្ញុំបូជាដោយបុត្រទាំងឡាយហើយ ខ្ញុំនឹងទៅកាន់សុគតិសួគ៌។

[៣៩៥] (ព្រះរាជមាតា...) ម្នាលកូន អ្នកកុំជឿខណ្ឌហាលព្រាហ្មណ៍នោះថា សុគតិបានដោយការបូជាបុត្រឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរក មិនមែនជាផ្លូវទៅកាន់ឋានសួគ៌ទេ។ ម្នាលកូនកោណ្ឌញ្ញគោត្រ ចូរអ្នកឲ្យទានទាំងឡាយ (អ្នក) កុំបៀតបៀនសព្វសត្វដែលកើតហើយ នឹងត្រូវកើតឡើយ នេះជាផ្លូវនៃសុគតិ ផ្លូវ (នៃសុគតិ) មិនមែនបានដោយការបូជាបុត្រទេ។

[៣៩៦] (ព្រះបាទឯករាជ...) ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យខណ្ឌហាលអាចារ្យ បូជាបុត្រទាំងឡាយ ដែលគេលះបង់បានដោយកម្រហើយ នឹងទៅកាន់សុគតិសួគ៌។

[៣៩៧] (អភិសម្ពុទ្ធគាថា) ចំណែកខាងព្រះវសវត្តី ជាព្រះរាជបិតា ត្រាស់សួរហេតុនោះ ចំពោះព្រះបាទឯករាជ ជារាជបុត្រកើតអំពីព្រះឱរានោះថា ម្នាលកូន ឮថា អ្នកនឹងបូជាយ័ញ្ញដោយបុត្រទាំង ៤ មែនឬ។

[៣៩៨] (ព្រះបាទឯករាជ...) កាលបើខ្ញុំសម្លាប់ចន្ទកុមារ (បូជា) ហើយ បុត្រទាំងឡាយទាំងអស់ ក៏ខ្ញុំលះបង់ដែរ ខ្ញុំបូជាយ័ញ្ញដោយបុត្រទាំងឡាយហើយ នឹងទៅកាន់សុគតិសួគ៌។

[៣៩៩] (ព្រះរាជបិតា...) ម្នាលកូន អ្នកកុំជឿខណ្ឌហាលព្រាហ្មថា សុគតិ មានដោយការបូជាបុត្រឡើយ ផ្លូវហ្នឹង ជាផ្លូវទៅកាន់នរកទេ មិនមែនជាផ្លូវទៅកាន់ឋានសួគ៌ទេ។ ម្នាលកូនកោណ្ឌញ្ញគោត្រ ចូរអ្នកឲ្យទានទាំងឡាយ (អ្នក) កុំបៀតបៀនសព្វសត្វទាំងឡាយដែលកើតហើយ នឹងត្រូវកើត នេះជាផ្លូវនៃសុគតិ ផ្លូវ (នៃសុគតិ) មិនមែនបានដោយការបូជាបុត្រទេ។

[៤០០] (ព្រះបាទឯករាជ...) ខ្ញុំនឹងសម្លាប់ចន្ទកុមារផង សុរិយកុមារផង តាមពាក្យនៃខណ្ឌហាលអាចារ្យ ខ្ញុំបូជាបុត្រទាំងឡាយ ដែលគេលះបង់បានដោយកម្រ ហើយនឹងទៅកើតក្នុងសុគតិសួគ៌។

[៤០១] (ព្រះរាជបិតា...) ម្នាលកូន កោណ្ឌញ្ញគោត្រ អ្នកចូរឲ្យទានទាំងឡាយ (អ្នក) កុំបៀតបៀនសព្វសត្វដែលកើតហើយ និងត្រូវកើតទាំងឡាយឡើយ អ្នកចូរជាមនុស្សដែលកូនទាំងឡាយចោមរោមហើយ រក្សាដែន និងជនបទចុះ។

[៤០២] (ចន្ទកុមារ...) បពិត្រព្រះទេវៈ ព្រះអង្គកុំសម្លាប់ទូលបង្គំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំទាំងឡាយ សូមជាអ្នកជាប់ចំណង ហើយឃ្វាលដំរី នឹងសេះ។ បពិត្រព្រះទេវៈ ព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណងហើយ នឹងចោលអាចម៍ដំរី។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ចំណែកខាងទូលបង្គំជាខ្ញុំទាំងឡាយ សូមជាអ្នកជាប់ចំណងហើយ នឹងចោលអាចម៍សេះ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ព្រះអង្គមានប្រាថ្នា (ដើម្បីព្រះរាជទាន) ដល់ខណ្ឌហាលព្រាហ្មណ៍ណា សូមទ្រង់ព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះចុះ ពុំនោះសោត នឹងសូមព្រះអង្គបំបរបង់ទូលបង្គំជាខ្ញុំទាំងឡាយ ចេញចាកដែន ក៏ទូលបង្គំជាខ្ញុំទាំងឡាយ នឹងត្រាច់ទៅកាន់ភិក្ខាចារ។

[៤០៣] (ព្រះបាទឯករាជ...) អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយ យំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយ លែងកុមារទាំងឡាយទៅ ការបូជាយ័ញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ។

[៤០៤] (ខណ្ឌហាលព្រាហ្មណ៍) ទូលព្រះបង្គំជាខ្ញុំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយ័ញ្ញនុ៎ះ ជាអំពើធ្វើបានដោយកម្រផង

មិនងាយនឹងធ្វើឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញដែលទូលព្រះបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វីព្រះអង្គធ្វើឲ្យខានទៅវិញ។ ជនទាំងឡាយណា បូជាយញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងឡាយ ទាំងអស់នោះ រមែងទៅកាន់សុគតិ។

[៩០៥] (ចន្ទកុមារ...) ចុះព្រះអង្គឲ្យពួកព្រាហ្មណ៍ទាយសួស្តីរបស់ទូលព្រះបង្គំជាខ្ញុំ ពីមុនមកដើម្បីអ្វី បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គឲ្យគេសម្លាប់ពួកទូលបង្គំជាខ្ញុំ ដើម្បីប្រយោជន៍ដល់យញ្ញដោយឥតហេតុ។ ពីដើម កាលដែលទូលព្រះបង្គំជាខ្ញុំទាំងឡាយនៅក្មេងនៅឡើយ (ម្តេចក៏) ព្រះអង្គមិនសម្លាប់ មិនឲ្យគេសម្លាប់ទៅ បពិត្រព្រះបិតា ឥឡូវនេះ ទូលបង្គំជាខ្ញុំទាំងឡាយ ជាក្មេងពេញកម្លោះ ជាអ្នកឥតប្រទូស្ត ក៏ស្រាប់តែព្រះអង្គឲ្យគេសម្លាប់។ បពិត្រមហារាជ សូមព្រះអង្គទតមើល ទូលបង្គំជាខ្ញុំទាំងឡាយ ដែលពាក់គ្រឿងក្រោះជិះដំរី ជិះសេះច្បាំងហើយ និងកំពុងច្បាំង មនុស្សទាំងឡាយបែបខ្ញុំនេះ មិនមែនជាមនុស្សសម្រាប់បូជាយញ្ញទេ។ ជនទាំងឡាយ តែងបញ្ជូនពួកមនុស្សដូចទូលបង្គំជាខ្ញុំ ទៅក្នុងបច្ចន្តគ្រាម ដែលបះបោរឡើងហើយ ឬក្នុងដងព្រៃ បពិត្រព្រះបិតា កាលបើដូច្នោះ ទូលបង្គំជាខ្ញុំទាំងឡាយ មិនត្រូវព្រះអង្គឲ្យគេសម្លាប់ ក្នុងទីមិនជាឱកាស ដោយឥតហេតុទេ។ មេសត្វស្លាបទាំងឡាយណានីមួយ ធ្វើសម្បុកដោយស្មៅទាំងឡាយហើយនៅ កូនទាំងឡាយជាទីស្រឡាញ់របស់មេសត្វស្លាបទាំងនោះ បពិត្រព្រះទេវៈ កាលបើដូច្នេះ ព្រះអង្គនៅតែឲ្យគេសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយ។ ព្រះអង្គកុំជឿពាក្យខណ្ឌហាលព្រាហ្មណ៍នោះថា ខណ្ឌហាលព្រាហ្មណ៍ មិនគប្បីសម្លាប់អញខ្ញុំដូចនេះឡើយ បពិត្រព្រះទេវៈ ព្រោះខណ្ឌហាលព្រាហ្មណ៍នោះ សម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយហើយ គប្បីសម្លាប់ព្រះអង្គក្នុងកាលជាលំដាប់។ បពិត្រមហារាជ ព្រះរាជាទាំងឡាយ តែងព្រះរាជទានស្រុកដ៏ប្រសើរផង និគមដ៏ប្រសើរផង ភោគៈផង ដល់ព្រាហ្មណ៍នោះ កាលបើដូច្នោះ ពួកព្រាហ្មណ៍ទាំងនោះ ជាអ្នកបរិភោគរាល់ ៗ ដុំបាយដ៏ថ្លៃថ្លាង តែងបានបរិភោគរាល់ៗ ត្រកូល។ បពិត្រមហារាជ ព្រាហ្មណ៍នោះ ប្រាថ្នាដើម្បីប្រទូស្តចំពោះជនអ្នកឲ្យទាំងនោះ ដូចជាព្រះអង្គ បពិត្រព្រះទេវៈ ពួកព្រាហ្មណ៍ទាំងនុ៎ះ ជាមនុស្សអកតញ្ញូដោយច្រើន។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍ចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណងហើយ នឹងឃ្វាលដំរី និងសេះ។ បពិត្រព្រះសម្មតិទេព សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទាននូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយ ជាប់ចំណងហើយ នឹងចាក់អាចម៍ដំរី។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់ទូលបង្គំជាខ្ញុំទាំងឡាយឡើយ សូមព្រះអង្គព្រះរាជទានទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ទូលបង្គំជាខ្ញុំទាំងឡាយ សូមជាប់ចំណងនឹងចាក់អាចម៍សេះ។ បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់នូវទូលបង្គំជាខ្ញុំទាំងឡាយឡើយ ព្រះអង្គសព្វព្រះរាជហឫទ័យចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមព្រះរាជទាននូវទូលបង្គំជាខ្ញុំទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះវិញចុះ ពុំនោះសោត ទូលបង្គំជាខ្ញុំទាំងឡាយ បើព្រះអង្គបំបរបង់ចេញចាកដែន នឹងត្រាច់ទៅកាន់ភិក្ខាចារ។

[៩០៦] (ព្រះបាទឯករាជ...) អ្នកទាំងឡាយ បង្កើតទុក្ខដល់យើងខ្លាំងណាស់ អ្នកទាំងឡាយយំស្រែក ព្រោះតែចង់បានជីវិត ឥឡូវនេះ ចូរអ្នកទាំងឡាយលែងកុមារទាំងឡាយទៅ ការបូជាយញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ។

[៩០៧] (ខណ្ឌហាលព្រាហ្មណ៍) ទូលបង្គំជាខ្ញុំ បានក្រាបទូលតាំងពីដើមមកថា ការបូជាយញ្ញនុ៎ះ ជាអំពើធ្វើបានដោយកម្រផង មិនងាយនឹងឲ្យកើតឡើងបានផង កាលបើគ្រឿងយញ្ញដែលទូលបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វីក៏ព្រះអង្គធ្វើឲ្យអាក់ខានទៅវិញ។ ជនទាំងឡាយណា បូជាយញ្ញខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញ ដែលអ្នកផងកំពុងបូជាប្រាកដដូច្នេះក្តី ជនទាំងអស់ (នោះ) រមែងទៅកាន់សុគតិ។

[៩០៨] (ចន្ទកុមារ...) បើប្រាកដជាបុគ្គលទាំងឡាយបូជាយញ្ញដោយបុត្រទាំងឡាយហើយ ច្យុតចាកមនុស្សលោកនេះ រមែងទៅកាន់ទេវលោក បពិត្រមហារាជ ចូរព្រាហ្មណ៍បូជាមុនចុះ សឹមព្រះអង្គបូជាជាខាងក្រោយ។ ឬថា បើប្រាកដជាបុគ្គលទាំងឡាយ បូជាយញ្ញដោយបុត្រទាំងឡាយហើយ ច្យុតអំពីមនុស្សលោកនេះ រមែងទៅកាន់ទេវលោក ចូរខណ្ឌហាលព្រាហ្មណ៍ហ្នឹងឯង បូជាដោយកូនទាំងឡាយរបស់ខ្លួនចុះ។ បើខណ្ឌហាលព្រាហ្មណ៍ដឹងយ៉ាងនេះហើយ ហេតុអ្វីក៏មិនសម្លាប់កូនតូច ៗ ទាំងឡាយផង មិនសម្លាប់ជនជាញាតិទាំងអស់ផង មិនសម្លាប់ខ្លួនឯងផង។ ជនទាំងឡាយណា បូជាយញ្ញដោយខ្លួនក្តី ជនទាំងឡាយណាឲ្យគេបូជាយញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយញ្ញប្រាកដដូច្នេះក្តី ជនទាំងអស់ (នោះ) រមែងទៅកាន់នរក។

[៩០៩] ម្តេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា កុំទ្រង់សម្លាប់បុត្រដែលកើតអំពីទ្រង់ឡើយ។ ម្តេចក៏ពួកម្ចាស់ផ្ទះ និងស្រីមេផ្ទះទាំងឡាយ ដែលជាអ្នកចង់បានកូនក្នុងក្រុង មិនទូលទាស់ព្រះរាជាថា កុំទ្រង់សម្លាប់បុត្រ ដែលកើតអំពីខ្លួនឡើយ។ ខ្ញុំជាអ្នកប្រាថ្នាប្រយោជន៍ចំពោះព្រះរាជា ប្រយោជន៍ចំពោះអ្នកជនបទទាំងអស់ ឥតមាននរណាមួយថ្នាំងថ្នាក់ចិត្តនឹងខ្ញុំឡើយ (ហេតុអ្វីក៏) អ្នកជនបទមិនក្រាបទូលឲ្យទ្រង់ជ្រាប។

[៩១០] ម្នាលនាងយរណីទាំងឡាយ (ស្រីមេផ្ទះ) ចូរនាងទាំងឡាយ ទៅអង្វរព្រះរាជបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារទាំងឡាយ ដូចជាសីហៈ ជាអ្នកមិនប្រទូស្ត ម្នាលនាងយរណីទាំងឡាយ ចូរនាងទាំងឡាយទៅនិយាយអង្វរព្រះបិតាផង ខណ្ឌហាលព្រាហ្មណ៍ផងថា សូមព្រះអង្គកុំសម្លាប់កុមារទាំងឡាយ ជាទីអាល័យរបស់សត្វលោកទាំងអស់។

[៩១១] បើដូច្នោះ គួរតែអញកើតក្នុងត្រកូលអ្នកធ្វើរថ ឬអ្នកចោលសម្រាម ឬកើតក្នុងត្រកូលវេស្សៈ ទើបព្រះរាជានឹងមិនសម្លាប់អញដើម្បីយញ្ញក្នុងថ្ងៃនេះ។

[៩១២] ម្នាលពួកស្រីអ្នកមានគំនិតទាំងឡាយ ចូរនាងទាំងអស់ទៅក្រាបទៀបបាទានៃខណ្ឌហាលព្រាហ្មណ៍ជាម្ចាស់ហើយ (ប្រាប់ថា) ខ្ញុំមិនឃើញកំហុសសោះ។ ម្នាលពួកស្រីជាមេផ្ទះទាំងអស់គ្នា ចូរនាងទាំងឡាយទៅក្រាបទៀបបាទានៃខណ្ឌហាលព្រាហ្មណ៍ជាម្ចាស់ហើយ (និយាយថា) បពិត្រលោកខណ្ឌហាលដ៏ចំរើន យើងទាំងឡាយបានប្រទូស្តអ្វីដល់លោក។

[៩១៣] លំដាប់នោះ ព្រះនាងសេលា ជាព្រះរាជធីតាគួរអាណិត បានឃើញព្រះភាតាទាំងឡាយ ដែលគេនាំខ្លួនទៅហើយ ទ្រង់ព្រះកន្សែងថា ឮថាយញ្ញ ព្រះរាជបិតាអញ ទ្រង់ប្រាថ្នាឋានសួគ៌ឲ្យប្រព្រឹត្តទៅហើយ។

[៩១៤] (លំដាប់នោះ) វសុលរាជកុមារបម្រះននៀលក្នុងទីចំពោះព្រះភក្ត្រព្រះរាជា ទ្រង់ព្រះកន្សែងអង្វរថា បពិត្រព្រះទេវៈ សូមព្រះអង្គកុំសម្លាប់បិតារបស់ទូលបង្គំជាខ្ញុំឡើយ ព្រោះទូលបង្គំជាខ្ញុំនៅក្មេង ពុំទាន់ធំនៅឡើយ។

[៩១៥] (ព្រះរាជា...) ម្នាលវសុលកុមារ នុ៎ះបិតារបស់ឯង ចូរឯងស្ងប់រម្ងាប់ជាមួយនឹងបិតារបស់ឯងចុះ ឯងយំស្រែកក្នុងព្រះរាជវាំងឈ្មោះថាញ៉ាំងទុក្ខយ៉ាងខ្លាំង ឲ្យកើតឡើងដល់អញ អ្នកទាំងឡាយ ចូរលែងពួកកុមារក្នុងកាលឥឡូវនេះចុះ ការបូជាយញ្ញដោយកូនរបស់អញ ល្មមលើកលែងចុះ។

[៩១៦] (ខណ្ឌហាលព្រាហ្មណ៍) ទូលបង្គំក្រាបទូលព្រះអង្គតាំងពីដើមមកថា ការបូជាយញ្ញនេះ ជាអំពើធ្វើបានដោយកម្រផង មិនងាយ

និងឲ្យកើតឡើងបានផង កាលបើគ្រឿងយ័ញ្ញដែលទូលបង្គំជាខ្ញុំប្រុងប្រៀបស្រេចហើយ ហេតុអ្វីកំព្រះអង្គធ្វើឲ្យអាក់ខានទៅវិញ។ ជនទាំងឡាយណា បូជាយ័ញ្ញដោយខ្លួនឯងក្តី ជនទាំងឡាយណា ឲ្យគេបូជាយ័ញ្ញក្តី ឬក៏ជនទាំងឡាយណា គ្រាន់តែអនុមោទនាមហាយ័ញ្ញដែលអ្នកផងកំពុងបូជា ប្រាកដដូច្នេះក្តី ជនទាំងអស់នោះ រមែងទៅកើតក្នុងសុគតិ។

[៩១៧] បពិត្រព្រះឯករាជ យ័ញ្ញ ទូលបង្គំជាខ្ញុំចាត់ចែងរៀបចំដើម្បីព្រះអង្គ ដោយរតនៈទាំងពួងហើយ បពិត្រព្រះទេវៈ សូមព្រះអង្គយាងចេញទៅ ព្រះអង្គនឹងទៅរីករាយក្នុងឋានសួគ៌។

[៩១៨] (អភិសម្ពុទ្ធគាថា) ពួកស្រ្តីទាំង ៧០០ នុ៎ះ នៅក្មេង ៗ ដែលជាភរិយាចន្ទកុមារ រំសាយកេសា ទួញយំដើរតាមផ្លូវទៅ។ ចំណែកពួកស្រ្តីឯទៀត ក៏ចេញទៅដោយសេចក្តីសោកស្តាយ រំសាយកេសា ទួញយំដើរតាមផ្លូវទៅ ដូចជាទេវតា (ចោមរោមទេវបុត្រដែលរៀបច្យុត) ក្នុងនន្ទនវនឧទ្យាន។

[៩១៩] ចន្ទកុមារ និងសុរិយកុមារ ទ្រទ្រង់សំពត់ដ៏ស្អាតដែលកើតក្នុងដែនកាសី ជាអ្នកទ្រទ្រង់កុណ្ឌល លាបស្រឡាយដោយកំញាន និងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅដើម្បីប្រយោជន៍ដល់យ័ញ្ញនៃព្រះបាទឯករាជ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកទ្រទ្រង់សំពត់ដ៏ស្អាតដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកទ្រទ្រង់សំពត់ដ៏ស្អាត ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ។ ចន្ទកុមារ និងសុរិយកុមារ ដែលជាអ្នកបរិភោគសាច់ដ៏មានរស ជាអ្នកដែលខ្ពាន់ព្រះកេសផ្ចិតៗស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ត្រូវគេនាំយកទៅដើម្បីប្រយោជន៍ដល់យ័ញ្ញនៃព្រះបាទឯករាជ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកបរិភោគនូវសាច់ដ៏មានរស ជាអ្នកដែលខ្ពាន់ព្រះកេសផ្ចិតៗស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ត្រូវគេនាំយកទៅ។ ចន្ទកុមារ និងសុរិយកុមារ ជាអ្នកបរិភោគសាច់ដ៏មានរស ជាអ្នកដែលខ្ពាន់ព្រះកេសផ្ចិតៗស្អាតហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ត្រូវគេនាំយកទៅ។ កាលពីមុន ពួកពលដំរី តែងតាមហែហមនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់លើខ្នងដំរីដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ។ កាលពីមុន ពួកពលសេះ តែងតាមហែនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់លើខ្នងសេះដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ។ កាលពីមុន ពួករថ តែងតាមហែនូវចន្ទកុមារ និងសុរិយកុមារណា ដែលគង់ក្នុងកណ្តាលរថដ៏ប្រសើរ ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ។ កាលពីមុន ចន្ទកុមារ និងសុរិយកុមារណា ស្តេចទៅដោយព្រះទីនាំងអស្សតរ ដែលគាត់តែងដោយគ្រឿងមាស ថ្ងៃនេះ ចន្ទកុមារ និងសុរិយកុមារទាំងពីរព្រះអង្គនោះ យាងទៅដោយព្រះបាទាទទេ។

[៩២០] (មហាជន...) ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកព្រះរាជបុត្រ ៤ ព្រះអង្គ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកព្រះរាជកញ្ញាទាំង ៤ ព្រះអង្គ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅតាមទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកព្រះមហេសីទាំង ៤ ព្រះអង្គ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកគហបតីទាំង ៤ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកដំរីទាំង ៤ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកសេះទាំង ៤ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកគោឧសភ ៤ បូជាយ័ញ្ញក្នុងទីនុ៎ះ។ ម្នាលបក្សី បើអ្នកចង់ស៊ីសាច់ ចូរអ្នកហើរទៅទិសខាងកើតនៃក្រុងបុប្ផវតីចុះ ព្រោះព្រះបាទឯករាជ ភាន់ស្មារតី ទ្រង់យកសត្វបួនៗ គ្រប់មុខ បូជាយ័ញ្ញក្នុងទីនុ៎ះ។

[៩២១] ប្រាសាទនេះ ជាវិការៈនៃមាស ដេរដាសដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ផ្ទះកំពូលនេះ ជាវិការៈនៃមាស ដេរដាសដោយផ្កាកម្រង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ឧទ្យាននេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ព្រៃអសោកនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ព្រៃកណ្ណិការនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ព្រៃច្រនៀងនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ព្រៃស្វាយនេះ មានផ្ការីកសព្វកាល ជាទីរីករាយ ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ស្រះបោក្ខរណីនេះ ដេរដាស ពាសពេញដោយផ្កាឈូកស ឈូកក្រហម ទាំងទូកដែលរចនាដោយមាស វិចិត្រដោយភ្ញីវល្លិ៍ ជាទីរីករាយចិត្តដោយក្រៃលែង ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។

[៩២២] ដំរីរ័តន៍នេះ ជាដំរីឈ្មោះឯរាវ័ណ មានកំឡាំង មានភ្លុក ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ សេះរ័តន៍នេះ ជាសេះមានក្រចកមួយ មានសន្ទុះរហ័ស ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ រថសេះនេះ មានសូរសព្ទដូចសំឡេងនៃស្រវសាលី ជារថដ៏ស្អាត វិចិត្រដោយរតនវត្ថុ ជាលំអរបស់ពួកព្រះអយ្យបុត្រ ដូចជាពួកទេវតាក្នុងនន្ទនវ័ន ឥឡូវនេះ ព្រះអយ្យបុត្រទាំង ៤ ព្រះអង្គនោះ ត្រូវគេនាំចេញទៅសម្លាប់។ ម្តេចក៏ព្រះរាជាភាន់ច្រឡំ នឹងបូជាយ័ញ្ញដោយព្រះរាជបុត្រទាំង ៤ ព្រះអង្គ ដែលមានសម្បុរល្មៀង មានជាតិស្មើ ជាបុគ្គលស្អាត (ឥតទោស) ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍។ ម្តេចក៏ព្រះរាជាភាន់ច្រឡំ នឹងបូជាយ័ញ្ញដោយព្រះរាជកញ្ញាទាំង ៤ ព្រះអង្គ ដែលមានសម្បុរល្មៀង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍។ ម្តេចក៏ព្រះរាជាភាន់ច្រឡំ នឹងបូជាយ័ញ្ញដោយព្រះមហេសីទាំង ៤ ព្រះអង្គ ដែលមានសម្បុរល្មៀង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបហើយដោយខ្លឹមចន្ទន៍។ ម្តេចក៏ព្រះរាជាភាន់ច្រឡំ នឹងបូជាយ័ញ្ញដោយគហបតីទាំង ៤ នាក់ ដែលមានសម្បុរល្មៀង មានជាតិស្មើ ជាបុគ្គលស្អាត ដែលមានខ្លួនលាបដោយខ្លឹមចន្ទន៍។ ស្រុក និងនិគមទាំងឡាយ សូន្យឥតមនុស្ស ក្លាយទៅជាព្រៃធំ យ៉ាងណាមិញ កាលបើចន្ទកុមារ និងសុរិយកុមារ ត្រូវព្រះរាជាយកទៅបូជាយ័ញ្ញហើយ ក្រុងបុប្ផវតី ក៏នឹង (ស្ងាត់សូន្យឈឹង) យ៉ាងនោះដែរ។

[២២៣] (ព្រះនាងគោតមីទេវី...) ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាកសេចក្តីចំរើន ប្រឡាក់ប្រឡូសដោយអាចម៍ដីពុំខាន បើជនសម្លាប់ចន្ទកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងបែកធ្លាយ។ ខ្ញុំម្ចាស់នឹងឆ្កួត សាបសូន្យចាកសេចក្តីចំរើន ប្រឡាក់ប្រឡូសដោយអាចម៍ដីពុំខាន បើជនសម្លាប់សុរិយកុមារ បពិត្រព្រះសម្មតិទេព ជីវិតរបស់ខ្ញុំម្ចាស់នឹងបែកធ្លាយ។

[៩២៤] ស្រ្តីទាំងឡាយនេះ គឺនាងយដ្ឋិកា នាងឧបរិក្ខី នាងបោក្ខរណី និងនាងគាយិកា ជាអ្នកពោលពាក្យជាទីស្រឡាញ់ទៅរកគ្នានឹងគ្នា ម្តេចក៏មិនរាំឲ្យចន្ទកុមារ និងសុរិយកុមារសប្បាយរីករាយ (ព្រោះស្រ្តីដទៃ) ស្មើដោយស្រ្តីទាំងនោះ មិនមានទេ។

[២២៥] សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែចន្ទកុមារដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯងចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែសុរិយកុមារដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯងចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែចន្ទកុមារ ដែលគេនាំទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯង ចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ។ សេចក្តីសោកក្នុងហឫទ័យនៃអញណា ព្រោះតែសុរិយកុមារ ដែលគេនាំយកទៅដើម្បីសម្លាប់ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធរបស់អ្នក ចូរទទួលយកសេចក្តីសោកក្នុងហឫទ័យនៃអញនេះទៅចុះ។ អ្នកឯងសម្លាប់ពួកកុមារ ដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត នៃខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ។ អ្នកឯងសម្លាប់ពួកកុមារ ដែលសត្វលោកទាំងអស់ អាឡោះអាល័យ នៃខណ្ឌហាលព្រាហ្មណ៍ ម្តាយអ្នកឯង កុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ។ អ្នកឯងសម្លាប់ពួកកុមារ ដែលអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯងកុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ។ អ្នកឯងសម្លាប់ពួកកុមារ ដែលសត្វលោកទាំងអស់អាឡោះអាល័យ នៃខណ្ឌហាលព្រាហ្មណ៍ ប្រពន្ធអ្នកឯងកុំបានឃើញកូនទាំងឡាយផង ប្តីផងឡើយ។

[៩២៦] (ចន្ទកុមារ...) បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយឃ្វាលដំរី និងសេះ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយចោលអាចម៍ដំរី។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍វិញចុះ ខ្ញុំព្រះអង្គទាំងឡាយ សូមឲ្យជាអ្នកជាប់ចំណង ហើយចោលអាចម៍សេះ។ បពិត្រព្រះសម្មតិទេព ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំឡើយ បើព្រះអង្គសព្វព្រះទ័យចំពោះខណ្ឌហាលព្រាហ្មណ៍ណា សូមទ្រង់ព្រះរាជទានខ្ញុំព្រះអង្គទាំងឡាយ ឲ្យជាទាសៈនៃខណ្ឌហាលព្រាហ្មណ៍នោះចុះ ពុំនោះសោត សូមព្រះអង្គបំបរបង់ឲ្យចេញចាកដែន ខ្ញុំព្រះអង្គនឹងត្រាច់ទៅកាន់ភិក្ខាចារ។ បពិត្រព្រះសម្មតិទេព នារីពួកខ្លះ សូម្បីជាស្ត្រីកំសត់ នៅតែចង់បានកូន ហើយបន់ស្រន់ទេព្តា ស៊ូលះបង់ចំណង់ប្លែក នៅតែមិនបានកូនទាំងឡាយ ក៏មាន។ នារីពួកខ្លះ ធ្វើពាក្យប្រកបដោយសេចក្តីប៉ុនប៉ងថា កូនទាំងឡាយរបស់យើង ចូរកើតបន្ទាប់ពីនោះ ចៅទាំងឡាយចូរកើតទៀត បពិត្រព្រះសម្មតិទេព កាលបើដូច្នេះ (ហេតុអ្វីក៏) ព្រះអង្គសម្លាប់ទូលព្រះបង្គំទាំងឡាយ ដើម្បីបូជាយ័ញ្ញ ដោយមិនសមហេតុ។ ពួកស្ត្រីតែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ ព្រះអង្គកុំបូជាយ័ញ្ញនេះ ដោយបុត្រទាំងឡាយ ដែលបានដោយលំបាកឡើយ។ ពួកស្ត្រីតែងបានកូនដោយការបន់ស្រន់ បពិត្រព្រះរាជបិតា ព្រះអង្គកុំសម្លាប់ទូលព្រះបង្គំទាំងឡាយឡើយ សូមព្រះអង្គកុំញ៉ាំងទូលព្រះបង្គំទាំងឡាយ ឲ្យព្រាត់ប្រាសចាកមាតា និងបុត្រទាំងឡាយ ដែលបានដោយលំបាក។

[៩២៧] បពិត្រព្រះមាតា ព្រះអង្គបានបង្កើតបុត្រ គឺចន្ទកុមារមក មានទុក្ខព្រួយច្រើនណាស់ ព្រោះតែការចិញ្ចឹម ខ្ញុំជាកូនសូមក្រាបថ្វាយបង្គំព្រះបាទានៃព្រះមាតា សូមឲ្យព្រះរាជបិតា បានទៅបរលោក (ដែលបរិបូណ៌ដោយសម្បត្តិ) ចុះ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងទៅកាន់ទីព្រាត់ប្រាសដើម្បីប្រយោជន៍ដល់យ័ញ្ញរបស់ព្រះបាទឯករាជ។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងធ្វើសេចក្តីសោកក្នុងហឫទ័យនៃព្រះមាតា ហើយទៅកាន់ទីព្រាត់ប្រាស។ បពិត្រព្រះមាតា ណ្ហើយចុះ សូមព្រះមាតាឱបកៀកខ្ញុំ ហើយអនុញ្ញាតឲ្យថ្វាយបង្គំព្រះបាទាព្រះមាតា ឥឡូវនេះ ខ្ញុំនឹងធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ហើយទៅកាន់ទីព្រាត់ប្រាស។

[៩២៨] (ព្រះមាតា...) ម្នាលគោតមីបុត្រ ណ្ហើយចុះ បាឯងចូរបួងមោលីដោយស្លឹកឈូក បាឯងចូរប្រដាប់ផ្កាកម្រង ដែលលាយដោយត្របកផ្កាចម្បានេះជាប្រក្រតី ពីដើមរបស់បា។ ហាក បាឯងធ្លាប់លាបស្រឡាបដោយខ្លឹមចន្ទន៍ទាំងឡាយណា ហើយល្អរុងរឿងក្នុងរាជបរិស័ទ (នេះ) ជាគ្រឿងលាបរបស់បា បាចូរលាបខ្លឹមចន្ទន៍ ជាទីបំផុតចុះ។ ហាក បាឯងស្លៀកដណ្តប់សំពត់ទាំងឡាយណា មានសាច់ទន់ ៗ រមែងល្អរុងរឿង ក្នុងរាជបរិស័ទ (នេះ) ជាសំពត់មានសាច់ទន់ បាចូរស្លៀកសំពត់ដែលកើតក្នុងដែនកាសី មានក្នុងទីបំផុតចុះ។ បាឯងល្អរុងរឿងដោយហត្ថាភរណៈណា ក្នុងរាជបរិស័ទ បាចូរពាក់នូវហត្ថាភរណៈដ៏ហើយដោយកែវមុក្តា កែវមណី និងមាស (នោះចុះ)។

[៩២៩] (នាងចន្ទាទេវី...) ព្រះបាទឯករាជនេះ ជាអ្នករក្សាដែន ជាម្ចាស់ផែនដី ជាអ្នកទទួលមតិករបស់អ្នកជនបទ ជាឥស្សរៈលើលោកទ្រង់ជាធំ តែមិនញ៉ាំងសេចក្តីស្នេហាឲ្យកើតក្នុងព្រះរាជបុត្រដោយពិត។

[៩៣០] (ព្រះបាទឯករាជ...) បុត្រប្រុសទាំងឡាយ ជាទីស្រឡាញ់របស់អញ ម្យ៉ាងទៀត នាងឯងក្តី ភរិយាទាំងឡាយ (ឯទៀត) ក្តី ក៏ជាទីស្រឡាញ់របស់អញ ប៉ុន្តែអញចង់បានឋានសួគ៌ទេតើ បានជាអញឲ្យគេសម្លាប់ដោយហេតុនោះ។

[៩៣១] (នាងចន្ទាទេវី...) បពិត្រព្រះសម្មតិទេព សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់មុន កុំឲ្យសេចក្តីទុក្ខបំបែកហឫទ័យខ្ញុំម្ចាស់ឡើយ បពិត្រព្រះសម្មតិទេព បុត្ររបស់ព្រះអង្គ ជាអ្នកមានគ្រឿងអលង្ការប្រដាប់ហើយ ជាបុត្រល្អល្អះ ជាសុខុមាលជាតិ។ បពិត្រព្រះអង្គជាម្ចាស់គេ ណ្ហើយចុះ សូមព្រះអង្គសម្លាប់ខ្ញុំម្ចាស់ចុះ ខ្ញុំម្ចាស់ជាស្ត្រីមានសេចក្តីសោកជាមួយគ្នានឹងចន្ទកុមារ សូមព្រះអង្គធ្វើបុណ្យឲ្យបរិបូណ៌ចុះ យើងខ្ញុំទាំងពីរនាក់ នឹងត្រាច់ទៅក្នុងបរលោក។

[៩៣២] (ព្រះបាទឯករាជ...) ម្នាលនាងចន្ទាមានភ្នែកវិសេសវិសាល នាងកុំយំឡើយ ជនទាំងឡាយជាបងប្អូនខាងប្តីរបស់នាងជាច្រើន ជនទាំងនោះ នឹងញ៉ាំងនាងឲ្យត្រេកអរ ព្រោះគោតមីបុត្រ ត្រូវគេបូជាយ័ញ្ញហើយ។

[៩៣៣] (អភិសម្ពុទ្ធគាថា) កាលបើព្រះបាទឯករាជ ទ្រង់ត្រាស់យ៉ាងនេះហើយ នាងចន្ទាទេវីប្រហារខ្លួនឯងដោយបាតដៃទាំងឡាយ (ទ្រង់ពិលាបថា) ការរស់នៅក្នុងលោកនេះ ល្មមប៉ុណ្ណឹងហើយ អញនឹងផឹកថ្នាំពិសឲ្យស្លាប់។ ព្រោះថា ជនទាំងឡាយ ជាញាតិមិត្រ ជាសំឡាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រទាំងឡាយ ដែលកើតអំពីព្រះឱរាដូច្នេះឡើយ។ ជនទាំងឡាយ ជាញាតិមិត្រ ជាសំឡាញ់របស់ព្រះរាជានេះ មិនមានអ្នកណាមួយហ៊ានក្រាបទូលព្រះរាជាថា សូមព្រះអង្គកុំសម្លាប់ព្រះរាជបុត្រ ដែលកើតអំពីព្រះអង្គដូច្នេះឡើយ។ បុត្ររបស់ខ្ញុំម្ចាស់ទាំងឡាយនេះ ពាក់កម្រងផ្កា ទ្រទ្រង់គ្រឿងប្រដាប់ជាវិការៈនៃមាស សូមព្រះរាជាបូជាយ័ញ្ញដោយរាជបុត្រទាំងឡាយចុះ ប៉ុន្តែសូមព្រះអង្គលែងគោតមីបុត្រ។ បពិត្រមហារាជ សូមព្រះអង្គកាប់ខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយ័ញ្ញគ្រប់ទាំង ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បងដែលជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត។ បពិត្រមហារាជ សូមព្រះអង្គចិញ្ច្រាំខ្ញុំម្ចាស់ ១០០ កំណាត់ ហើយបូជាយ័ញ្ញគ្រប់ទាំង ៧ កន្លែងចុះ ព្រះអង្គកុំសម្លាប់បុត្រច្បងដែលសត្វលោកទាំងអស់អាឡោះអាល័យឡើយ។

[៩៣៤] (ចន្ទកុមារ...) គ្រឿងអាភរណៈច្រើនយ៉ាង គឺកែវមុក្តា កែវមណី កែវពៃទូរ្យដែលប្រសើរ និងមិនប្រសើរ យើងឲ្យហើយដល់នាងក្នុងរឿងដែលនាងនិយាយល្អហើយ នេះជាអំណោយ ទីបំផុត ចូរមានដល់នាងចុះ។

[៩៣៥] (នាងចន្ទាទេវី...) កាលពីដើម ព្រះរាជបុត្រទាំងឡាយណា ដែលមានកម្រងផ្ការីកសំពោង ពាក់ហើយលើ ក ទាំងឡាយ ថ្ងៃនេះ ព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវ ដែលគេសំលៀងមុត នឹងធ្លាក់លើ ក ទាំងឡាយវិញ។ ពីដើម ព្រះរាជបុត្រទាំងឡាយណា ដែលមានកម្រងផ្កាដ៏វិចិត្រហើយ ពាក់លើ ក ទាំងឡាយ ថ្ងៃនេះ ព្រះរាជបុត្រទាំងនោះ ត្រឡប់ទៅជាមានដាវ ដែលគេសំលៀងមុត នឹងធ្លាក់លើ ក ទាំងឡាយវិញ។ មិនយូរប៉ុន្មានទេ មុខតែដាវនឹងធ្លាក់លើ ក នៃរាជបុត្រទាំងឡាយពុំខាន ហឫទ័យរបស់ខ្ញុំម្ចាស់ ខានបែកធ្លាយឯណាបាន ព្រោះចំណងយ៉ាងមាំ មានដល់ខ្ញុំម្ចាស់ហើយ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់សាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ចូរចេញទៅ ដើម្បីយ័ញ្ញនៃព្រះបាទឯករាជចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ចូរចេញទៅចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកទ្រទ្រង់សំពត់មានសាច់ល្អ ដែលកើតក្នុងដែនកាសី ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជនដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្ចង់ៗល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ចូរចេញទៅដើម្បីយ័ញ្ញរបស់ព្រះបាទឯករាជចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជនដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្ចង់ ៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃមាតា ចូរស្តេចចេញទៅចុះ។ ម្នាលចន្ទកុមារ និងសុរិយកុមារ អ្នកទាំងឡាយ ជាអ្នកបរិភោគភោជនដែលលាយដោយសាច់មានរស ជាអ្នកដែលពួកអ្នកផ្ចង់ ៗ ល្អហើយ ទ្រទ្រង់កុណ្ឌល លាបស្រឡាបដោយកំញាន និងខ្លឹមចន្ទន៍ ធ្វើសេចក្តីសោកក្នុងហឫទ័យនៃជន ចូរចេញទៅចុះ។

[៩៣៦] (អភិសម្ពុទ្ធគាថា) កាលបើគ្រឿងប្រដាប់បូជាយ័ញ្ញគ្រប់យ៉ាង ដែលគេចាត់ចែងហើយ កាលបើចន្ទកុមារ និងសុរិយកុមារអង្គុយ ដើម្បីប្រយោជន៍ដល់យ័ញ្ញ ហើយនាងបញ្ចាលរាជធីតា លើកកំបង់អញ្ជលី ដើរចូលទៅត្រង់ចន្លោះពួកបរិស័ទទាំងពួង (ប្រកាសថា) ខណ្ឌហាលព្រាហ្មណ៍ ជាមនុស្សយល់ខុស ធ្វើបាបកម្ម ដោយពាក្យសច្ចៈណា ខ្ញុំម្ចាស់ព្រមព្រៀងជាមួយនឹងព្រះស្វាមី តាមពាក្យសច្ចៈនុ៎ះ។ ពួកអមនុស្ស ពួកទេវតា និងពួកសត្វកើតហើយ និងសត្វដែលត្រូវកើត មានក្នុងទីនេះ ចូរធ្វើនូវសេចក្តីខ្វល់ខ្វាយចំពោះខ្ញុំ ខ្ញុំសូមព្រមព្រៀង (ជាមួយ) នឹងព្រះស្វាមីហើយ។ ពួកទេវតា ពួកសត្វកើតហើយ នឹងសត្វដែលត្រូវកើតទាំងអស់ ដែលមកក្នុងទីនេះ សូមអ្នកទាំងឡាយ រក្សាខ្ញុំជាមនុស្សអនាថា ដែលស្វែងរកទីពឹង ខ្ញុំសូមអង្វរព្រះស្វាមី ដែលពួកបច្ចាមិត្រផ្ចាញ់មិនបាន ចំពោះលោកទាំងឡាយ។

[៩៣៧] អមនុស្ស (សក្កទេវរាជ) ឮពាក្យនោះហើយ ក៏គ្រវីដម្បងដែក បំភ័យព្រះរាជានោះ ហើយនិយាយនឹងព្រះរាជាដូច្នេះថា ម្នាលស្តេចកាឡកណ្ណី ព្រះអង្គចូរដឹងចុះ កុំឲ្យខ្ញុំសំពងក្បាលព្រះអង្គឡើយ ព្រះអង្គកុំសម្លាប់បុត្រច្បង ជាអ្នកអង់អាចដូចសីហៈ ជាអ្នកមិនប្រទូស្ត។ ម្នាលស្តេចកាឡកណ្ណី ព្រះអង្គធ្លាប់ឃើញអ្នកណា ដែលសម្លាប់បុត្រភរិយា និងសេដ្ឋី គហបតី ជាអ្នកមិនប្រទូស្ត ព្រោះប្រាថ្នាឋានសួគ៌។

[៩៣៨] ខណ្ឌហាលព្រាហ្មណ៍ បានឮពាក្យនោះ ទាំងព្រះរាជាក៏ឃើញសក្កទេវរាជដែលព្រះអង្គមិនធ្លាប់ឃើញនេះ ទើបឲ្យស្រាយចំណងពីជនទាំងពួង ឲ្យដូចជាមិនមានសេចក្តីបៀតបៀន។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកជនដែលមកប្រជុំក្នុងកន្លែងនោះ ក៏នាំគ្នាគប់មួយដុំដី ៗ ម្នាក់ នេះជាការសម្លាប់ខណ្ឌហាលព្រាហ្មណ៍។

[៩៣៩] ពួកជនទាំងពួង ធ្វើបាបកម្មហើយ ទៅកាន់នរកយ៉ាងណា ពួកជនមិនធ្វើបាបកម្ម ហើយទៅអំពីលោកនេះទៅ គប្បីបាននូវសុគតិ យ៉ាងនោះឯង។

[៩៤០] កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជបុរសមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកចួបជុំគ្នា ក្នុងទីនោះ ក៏ប្រជុំគ្នា អភិសេកចន្ទកុមារ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកចន្ទកុមារ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកចួបជុំគ្នា ក្នុងទីនោះ ក៏ប្រជុំគ្នាអភិសេកនូវចន្ទកុមារ។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជបរិស័ទដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួករាជកញ្ញាដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវបុរសដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ក្នុងកាលនោះ ពួកទេវកញ្ញាដែលមកចួបជុំគ្នាក្នុងទីនោះ ក៏ប្រជុំគ្នាលើកទង់សំពត់។ កាលបើពួកជនទាំងអស់ រួចពីចំណងហើយ ពួកជនជាច្រើនត្រេកអររីករាយ ប៉ាវគង ទូងអានន្ទភេរី ក្នុងកាលដែលចន្ទកុមារចូលទៅក្នុងនគរ ពួកជនបានប្រកាសការរួចចាកចំណង (របស់ពួកសត្វ)។

ចប់ ចន្ទកុមារជាតក ទី៧។

ចប់ ភាគ៦២ ។

## លេខយោង

1)
យុគក្កិលេសនេះ បានដល់កិលេសទាំងឡាយ គឺ កោធៈ ឧបនាហៈ មក្ខៈ បឡាសៈ ជាដើម។
2)
យោគក្កិលេសនេះ បានដល់យោគៈ ៤យ៉ាង គឺកាមយោគៈ ១ ភវយោគៈ ១ ទិដ្ឋិយោគៈ ១ អវិជ្ជាយោគៈ ១។ អដ្ឋកថា។
3)
ត្រី ៣ មួយគិតច្រើន មួយគិតតិច មួយគិតល្មម។
4)
ហេតុ ៤យ៉ាង គឺ សរីរៈ ១ ជាតិ ១ សម្លេង ១ គុណ ១ (អដ្ឋកថា)។
5)
បុរសមានជើង ៤ នេះ សំដៅយកអណ្តើកនេះឯង។ អដ្ឋកថា។
6)

សំដៅយកមនុស្សស្រី។ អដ្ឋកថា។
7)
បុគ្គលអ្នកចិញ្ចឹម មាន៣ គឺ មាតា បិតា ស្វាមី។ អដ្ឋកថា។
8)
ឮទុភ ៗ។
9)
អគ្គិ បាវកោ គណ្ហវត្តនី ទាំង៣សព្ទនេះ ជាឈ្មោះនៃភ្លើងតែម្យ៉ាង។ អដ្ឋកថា។
10)
តិមិរព្រឹក្សនេះ ជាឈ្មោះឈើមួយបែប ក្នុងអដ្ឋកថាពន្យល់ថា ឈើនេះច្រើនដុះចោមរោមដើមជ្រៃ ឈើនេះ ប្រហែលជាស្អំ ឬខ្យូស ឬក៏សំបួរមាសទេដឹង។ អ្នកពិនិត្យ។
11)
ធុរៈរបស់បុរស មាន៤យ៉ាង គឺ ទាន ១ សីល ១ ភាវនា ១ មិត្តភាព ១។ អដ្ឋកថា។
12)
ពាក្យថា មយ្ហកៈនេះ ជាឈ្មោះនៃសត្វបក្សី ១ ពួក ដែលហួងហែងផ្លែល្មៀបថា របស់អញ ៗ មិនឲ្យពួកសត្វបក្សីឯទៀត មកស៊ីផង មយ្ហកៈបក្សីនេះ ប្រហែលជាសត្វពពូល ឬកំផ្លុក ព្រោះជាសត្វស៊ីផ្លែល្មៀប។ មតិអ្នកពិនិត្យ។
13)
ការប្រព្រឹត្តិព្រហ្មចរិយៈ ឈ្មោះថា កាលិកៈ ព្រោះអាចឲ្យផលក្នុងអត្តភាពទី២ ឬទី៣។ អដ្ឋកថា។
14)
ឈ្មោះម្រឹគមានក្រចក ៨ ចួនកាលអាចសម្លាប់សីហៈក៏បាន។ អភិធានប្បទីបិកាសូចិ។
15)
ចក្រធម៌ មាន៤យ៉ាងគឺ បដិរូបទេសវាសៈ ១ សប្បុរិសូបសំសេវៈ ១ អត្តសម្មាបណិធិ ១ បុព្វេកតបុញ្ញតា ១។
16)
រាជធម៌ទាំង១០ប្រការ មានទានជាដើម។ អដ្ឋកថា។
17)
ក្នុងទីនេះ សំដៅយកជេដ្ឋាបចាយនធម៌។ អដ្ឋកថា។
18)
អសុរៈ សាមញ្ញ។
19)
ពួកអ្នកលេងតែងខ្លួនមិនរកស៊ីអ្វី យកស្ត្រីមេម៉ាយអ្នកមានទ្រព្យ ចាយទ្រព្យអស់ហើយ រករឿងបំបែកលែងស្ត្រីនោះចោល ទៅរកស្ត្រីមេម៉ាយស្តុកដទៃទៀត។ តាមន័យក្នុងអដ្ឋកថា។
20)
ពពែ និងឆ្កែ សត្វទាំងពីរនេះ មានជើងបួន ៗ តែឆ្កែខូចជើងមួយ។
21)
ធម្មតា ក្ងោកទាំងឡាយ តែពង់កន្ទុយឡើងកាលណា ក៏បញ្ចេញកេរ្តិ៍ខ្មាសរបស់វាឲ្យឃើញប្រាកដ យ៉ាងណាមិញ ពួកមនុស្ស កាលបើកើតវិវាទឈ្លោះទាស់ទែងគ្នាហើយ ក៏ប្រកាសទោសដល់គ្នានឹងគ្នា គឺជេរប្រទេច រំលើក បើកកកាយកេរ្តិ៍ខ្មាសទៅវិញទៅមក ឥតមានកោតញញើត ក៏យ៉ាងនោះដែរ។ អដ្ឋកថា។
22)
ផស្សៈ ប្រែថា ការប៉ះពាល់ មាន៤ គឺការប៉ះពាល់នឹងទុក្ខ សុខ មរណៈ និងជីវិត។ ការប៉ះពាល់ទុក្ខ និងមរណៈ មិនជាប្រយោជន៍របស់សត្វ។ ការប៉ះពាល់សុខ និងជីវិត ជាប្រយោជន៍។ អដ្ឋកថាន័យ។
23)
វត្ថុ ៤យ៉ាងគឺ មនុស្ស ១ ស្រូវ ១ ឧស ១ ទឹក ១។ អដ្ឋកថា។
24)
ទទឹកមានកំពែងសម្រាប់បុកទំលាយទឹកឲ្យហូរស្រួល។ អដ្ឋកថា។
25)
ការបូជាដោយទឹកសោម គឺសុរាមួយបែបដែលគេបានមកពីដើមឈើ និយមថា ជាសុរាវិសេស សម្រាប់យកទៅសែនព្រេន។
26)
អាចារ្យខ្លះថា សត្វអង្កត់ខ្មៅ។
27)
ចោរធម៌ និងឥសិធម៌។
28)
អ្នកលេងសុរា ឃើញសុរាហើយ អាចយកសម្គត់ទៅដូរផឹក។
29)
ប្រព្រឹត្តមេថុនមិនកើត។
30)
មនុស្សដែលយក្សិណីចាប់យកទៅចិញ្ចឹម ប្រព្រឹត្តស៊ីសាច់មនុស្សដូចយក្ស។
31)
ប្រហែល”ជៀតម្រឹគ”។
32)
គឺ មាតា១ នាងនន្ទាទេវី១ តិខិណមន្ត្រីកុមារ១ សំឡាញ់ឈ្មោះធនុសេក្ខៈ១ បុរោហិត១ មហោសធ១ ស្តេចចូឡនី១។ អដ្ឋកថា។
33)
ពាក្យថា មន្ត ក្នុងទីនេះ សំដៅយកការប្រឹក្សាគ្នាអំពីកិច្ចការស្ងាត់កំបាំង ឬសំដៅយកមន្តអាគម ដែលគេចេះដឹងហើយគួរលាក់ទុក។

អដ្ឋកថា។
34)
អសុរសាមូញ្ញ។
35)
មៀមវេស្សន្តរៈ ស្តេចតាំងក្នុងឋានៈជាមហាសេនគុត្ត។
36)
បានជាហៅថា ឥសីសិង្គៈ ព្រោះតាបសនោះ មានពកដុះមួយគូលើក្បាល ដូចជាស្នែងម្រឹគ។ អដ្ឋកថា។
37)
ពួកកូនព្រានព្រៃទេ តែហៅថា “ភោជបុត្រ” ប្រែថា កូនមេស្រុក គឺហៅដោយសេចក្តីស្រឡាញ់រាប់អាន។ អដ្ឋកថា។
38)
នេះជាសេចក្តីយល់របស់ជនជាអហេតុកវាទី។ ក្នុងអដ្ឋកថាសាមញ្ញផលសូត្រ មានសេចក្តីពន្យល់ថា អភិជាតិទាំង៦នោះគឺ កណ្ហាភិជាតិ (ជាតិខ្មៅ) បានដល់ព្រានម្រឹគ ព្រានបក្សី ជាដើម១ នីលាភិជាតិ (ជាតិខៀវ) បានដល់ភិក្ខុក្នុងព្រះពុទ្ធសាសនា១ លោហិតាភិជាតិ (ជាតិក្រហម) បានដល់ពួកនិគ្រន្ថ១ ហលិទ្ទាភិជាតិ (ជាតិលឿងដូចរមៀត) បានដល់ពួកអចេលកសាវ័ក១ សុក្កាភិជាតិ (ជាតិស) បានដល់ពួកអាជីវក១ បរមសុក្កាភិជាតិ (ជាតិសណាស់) បានដល់ពួកជនជានន្ទគោត្រ និងវច្ឆគោត្រជាដើម១។ ការត្រាច់ទៅក្នុងអភិជាតិទាំង៦ ឈ្មោះថា សង្គតិ។ ធម្មតាដែលកើតឡើងដូចៗគ្នា ឈ្មោះថា សភាវៈប្រៀបដូចបន្លាដែលស្រួចឯង ផ្លែខ្វិតមានសណ្ឋានមូលដោយខ្លួនឯង សត្វម្រឹគបក្សី មានសណ្ឋានរូបរាងវិចិត្រផ្សេង ដោយធម្មតាឯងយ៉ាងណាមិញ លោកទាំងអស់ មានសេចក្តីប្រែប្រួលទៅជាយ៉ាងដូច្នោះ មិនបាច់អាស្រ័យហេតុបច្ច័យឡើយ ប្រៀបដូចបន្លាជាដើម យ៉ាងនោះឯង ឈ្មោះថា សភាវៈ។
39) , 40)
យកម្រឹគ ឬបក្សីផងគ្នាធ្វើផ្ទាក់។
41) , 52)
ពាក្យនេះ ពោធិសត្វពោលសំដៅយកការដែលមិនបានផ្គងស្មារតីទុកដោយមេត្តាភាវនាក្នុងខណៈនោះ។
42) , 53)
ធ្នូដ៏មាំ សំដៅយកធ្នូដែលកំឡាំងនៃបុរស ១ពាន់នាក់ ទើបលើករួច។
43) , 54)
នាងទេពធីតានេះ ធ្លាប់ជាមាតាពោធិសត្វក្នុងបុព្វជាតិទី ៧ លុះច្យុតមកឧប្បត្តិក្នុងទីនេះ នាងតែងព្យាបាលពោធិសត្វសព្វៗថ្ងៃរៀងមក។
44) , 55)
១.២.៣. តាមសេចក្តីយល់របស់សក្កទេវរាជពោលតាមពាហិរសាសនាថា សីលដែលគ្រាន់តែវៀរចាកមេថុន ហៅថា ព្រហ្មចរិយៈថោកទាប អាចញុំាងបុគ្គលឲ្យទៅកើតក្នុងត្រកូលក្សត្រ។ ឧបចារជ្ឈាន ហៅថា ព្រហ្មចរិយៈជាកណ្តាល អាចញុំាងបុគ្គលឲ្យទៅកើតជាទេវតា។ សមាបត្តិប្រាំបី ហៅថា ព្រហ្មចរិយៈខ្ពង់ខ្ពស់ អាចញុំាងបុគ្គលឲ្យទៅកើតក្នុងព្រហ្មលោក។ ពួកពាហិរសាសនាសំដៅយកព្រហ្មលោកនោះ ថាជានិព្វាន។ ពុទ្ធសាសនាថា ព្រហ្មចរិយៈរបស់ភិក្ខុ ដែលមានសីលបរិសុទ្ធ តែប្រាថ្នាយកទេពនិកាយណាមួយ ចាត់ជា ព្រហ្មចរិយៈថោកទាប សមាបត្តិប្រាំបី ចាត់ជាព្រហ្មចរិយៈកណ្តាល អរហត្តមគ្គ ចាត់ជាព្រហ្មចរិយៈខ្ពង់ខ្ពស់។
45) , 56)
២
46) , 57)
៣
47) , 58)
សំដៅយក ពួកក្សត្រិយ៍ ព្រាហ្មណ៍ វេស្សៈ និងសូទ្រៈ។
48) , 59)
សក្កទេវរាជ សំដៅយកសីលថាជាគុណខ្ពស់ ទានជាគុណទាប។ អដ្ឋកថា។
49) , 60)
ព័ទ្ធដោយកំពែង គឺដំរីជាជាន់ដំបូង លំដាប់ពីនោះ ព័ទ្ធដោយកំពែង គឺរថ តពីនោះ ព័ទ្ធដោយកំពែងគឺសេះ តពីនោះ ព័ទ្ធដោយកំពែងគឺ ពលថ្មើរជើង រវាងពលដំរី និងរថចាត់ជាជាន់ទី១ រវាងពលរថ និងពលសេះ ចាត់ជាជាន់ទី២ រវាងពលសេះនិងពលថ្មើរជើង ចាត់ជា ជាន់ទី៣។ អដ្ឋកថា។
50) , 61)
ពួកនាគដែលមានឈ្មោះយ៉ាងនេះ គឺជាពួកនាគនៅក្បែរជើងភ្នំសិនេរុ ត្រូវជាញាតិខាងមាតារបស់ព្រះបាទធតរដ្ឋ។ អដ្ឋកថា។
51) , 62)
មិនមែនមានដៃមួយពាន់ទេ គឺអាចយិតធ្នូដែលខ្នាន់ធ្នូប្រាំរយនាក់យិតរួច។ អដ្ឋកថា។

---